# កំណែទម្រង់វិស័យអប់រំ នៅកម្ពុជា

## មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព



ហង់ជួន ណារ៉ុន

Edition PREAH VIHEAR

២០១៦

បោះពុម្ពផ្សាយលើកទី១

ភ្នំពេញ ឆ្នាំ២០១៦

ISBN-13: 978-99249-114-1-8

រក្សាសិទ្ធិគ្រប់យ៉ាង

# កំណែទម្រង់វិស័យអប់រំ
# នៅកម្ពុជា

## មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ
## និងវិបុលភាព

ដោយ **ហង់ជួន ណារ៉ុន**

**២០១៦**

**ភ្នំពេញ**

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី(Asian Development Bank) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(Association of Southeast Asian Nations) |
| BETP | គម្រោងអភិវឌ្ឍន៍សៀវភៅសម្រាប់ការអប់រំមូលដ្ឋាន(Basic Education TextBook Project) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(Cambodia Development Resource Institute) |
| CG | ក្រុមពិគ្រោះយោបល់(Consultative Group) |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ(Education Management Information System) |
| EU/ EC | សហភាពអឺរ៉ុប/គណៈកម្មការអឺរ៉ុប(European Union/ European Commission) |
| EQIP | គម្រោងកែលម្អគុណភាពអប់រំ(Education Quality Improvement Project) |
| FAO | អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ(Food and Agriculture Organization of the United Nations) |
| GDP | ផលិតផលក្នុងស្រុកសរុប(Gross Domestic Product) |
| HRMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស(Human Resources Management Information System) |
| ILO | អង្គការពលកម្មពិភពលោកអង្គការសហប្រជាជាតិ(International Labor Organization-United Nations) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ(International Monetary Fund) |
| MDG | ទិសដៅអភិវឌ្ឍសហស្សវត្សរ៍(Millennium Development Goals) |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(Ministry of Economy and Finance) |
| MoEYS | ក្រសួងអប់រំយុវជន និងកីឡា(Ministry of Education, Youth and Sports) |
| MoE | ក្រសួងបរិស្ថាន(Ministry of Environment) |
| MoH | ក្រសួងសុខាភិបាល(Ministry of Health) |
| MoP | ក្រសួងផែនការ(Ministry of Planning) |
| MTEF | ក្របខណ្ឌចំណាយរយៈពេលមធ្យម(Midium-term Expenditure Frame Look) |
| MoWVA | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន(Ministry of Women's and Veterans' Affairs) |
| NGOs | អង្គការក្រៅរដ្ឋាភិបាល(Non-government Organization) |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ(Official Development Assistance) |
| OECD | អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (Organization for Economic Cooperation and Development) |
| PAP | កម្មវិធីសកម្មភាពអាទិភាព(Priority Action Program) |
| PEP | កម្មវិធីចំណាយសាធារណៈ(Public Expenditures Program) |
| PIP | កម្មវិធីវិនិយោគសាធារណៈ(Public Investments Program) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា(Royal Government of Cambodia) |
| SEDP | ផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចឆ្នាំ១៩៩៦-ឆ្នាំ២០០៦ Socio-economic Development Plan 1996-2000 |
| UN | អង្គការសហប្រជាជាតិ(United Nations) |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(United Nations Development Program) |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ សហប្រជាជាតិ<br>(United Nations Educational, Scientific and Cultural Organization) |
| UNFPA | មូលនិធិអង្គការសហប្រជាជាតិសម្រាប់សកម្មភាពប្រជាជន<br>(United Nations Fund for Population Activities) |
| UNICEF | មូលនិធិកុមារអង្គការសហប្រជាជាតិ(United Nations Children's Fund) |
| WB | ធនាគារពិភពលោក(World Bank) |
| WFP | កម្មវិធីម្ហូបអាហារពិភពលោក(World Food Program) |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# មាតិកា


**អារម្ភកថា** ........ A

**ការថ្លែងអំណរគុណ** ........ E

**សេចក្តីផ្តើម** ........ G

***ផ្នែកទី១ ៖ ការស្តារប្រព័ន្ធអប់រំកម្ពុជា*** ........ 1

***ជំពូកទី១ ៖ តួនាទីវិស័យអប់រំក្នុងការកសាងជាតិ*** ........ 3

*១.១. មូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំ វប្បធម៌ និងអរិយធម៌ខ្មែរ* ........ 3

*១.២. ការស្តារប្រព័ន្ធអប់រំឡើងវិញក្នុងរជ្ជកាលព្រះបាទ អង្គឌួង* ........ 42

*១.៣. ទំនើបកម្មប្រព័ន្ធអប់រំខ្មែរសម័យអាណាព្យាបាលបារាំង* ........ 46

*១.៤. សង្គមរាស្ត្រនិយម និងវិស័យអប់រំ* ........ 72

*១.៥. ការកសាងវិស័យអប់រំឡើងវិញក្រោយរបបកម្ពុជាប្រជាធិបតេយ្យ* ........ 83

***ជំពូកទី ២ ៖ របៀបវារៈថ្មីស្តីពីគោលនយោបាយសង្គមកិច្ចសម្រាប់វិស័យអប់រំ*** ........ 97

*២.១. កម្មវិធីសកម្មភាពជាអាទិភាពក្នុងវិស័យអប់រំ ដើម្បីលើកកម្ពស់សកលកម្មការអប់រំ បឋមសិក្សា* ........ 97

*២.២. ក្របខណ្ឌចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំ* ........ 107

***ជំពូកទី ៣ ៖ គោលនយោបាយជាតិស្តីពីការអប់រំ*** ........ 147

*៣.១. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ជាក្របខណ្ឌផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* ........ 147

*៣.២. គោលនយោបាយក្នុងការលើកកម្ពស់គុណភាព និងសមធម៌អប់រំ* ........ 158

*៣.៣. ផែនការសកម្មភាពដើម្បីសម្រេចបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ* ........ 193

*៣.៤. សេចក្តីសន្និដ្ឋាន* ........ 204

***ជំពូកទី ៤ ៖ សមិទ្ធផលកំណែទម្រង់វិស័យអប់រំក្នុងរយៈពេល ១៥ ឆ្នាំ*** ........ 207

*៤.១. ការអប់រំកុមារតូច* ........ 212

*៤.២. ការអប់រំនៅបឋមសិក្សា* ........ 219

*៤.៣. ការអប់រំនៅមធ្យមសិក្សា* ........ 223

*៤.៤. ការអប់រំប្រកបដោយបរិយាប័ន្ន* ........ 229

*៤.៥. ការអប់រំក្រៅប្រព័ន្ធ* ........ 233

*៤.៦. ការអប់រំភាសាបរទេស* ........ 239





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្នែកទី២ ៖ កំណែទម្រង់វិស័យអប់រំដើម្បីកសាងសង្គមកម្ពុជាដែលមានកោសិកាផ្សារភ្ជាប់គ្នា មានការអប់រំឈានមុខ និងមានវប្បធម៌រស់រវើក....243
***ជំពូកទី ៥ ៖ កំណែទម្រង់វិស័យអប់រំដើម្បីលើកកម្ពស់សង្គមពុទ្ធិនៅកម្ពុជា***.... 245
*៥.១. បំណែងចែកប្រជាសាស្ត្រ និងជំនាញ*.... 245
*៥.២. តួនាទីអប់រំនៅក្នុងសមាហរណកម្មអាស៊ាន*.... 248
*៥.៣. បញ្ហាប្រឈមក្នុងវិស័យអប់រំ*....251
*៥.៤. កំណែទម្រង់វិស័យអប់រំដើម្បីពង្រឹងភាពប្រកួតប្រជែង*.... 254
***ជំពូកទី ៦ ៖ ការបណ្តុះបណ្តាលគ្រូបង្រៀន និងកំណែទម្រង់គ្រូបង្រៀន***.... 265
*៦.១. កំណែទម្រង់គោលនយោបាយគ្រូបង្រៀនដើម្បីផ្តល់គុណភាពសេវាកម្មអប់រំ និងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា*.... 265
*៦.២. យុទ្ធសាស្ត្រកំណែទម្រង់គោលនយោបាយគ្រូបង្រៀន*....271
*៦.៣. ការសន្និដ្ឋាន*.... 284
***ជំពូកទី ៧ ៖ អធិការកិច្ចអប់រំ***.... 287
*៧.១. សារៈសំខាន់នៃអធិការកិច្ចអប់រំក្នុងការពង្រឹងគុណភាពអប់រំ*.... 287
*៧.២. ប្រវត្តិនៃអធិការដ្ឋានអប់រំក្នុងប្រទេសកម្ពុជា*.... 294
*៧.៣. ក្របខណ្ឌធានាគុណភាពថ្មី*.... 296
*៧.៤. អធិការកិច្ចផ្ទៃក្នុង*.... 298
*៧.៥. អធិការកិច្ចផ្ទៃក្រៅ*....300
***ជំពូកទី ៨ ៖ វង្វាយតម្លៃអប់រំថ្នាក់ជាតិ***....305
*៨.១. សេចក្តីផ្តើម*....305
*៨.២. ក្របខណ្ឌទស្សនទាន*.... 306
*៨.៣. ការវាស់វែងលទ្ធផលសិក្សា*.... 308



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជំពូកទី ៩ ៖ កំណែទម្រង់កម្មវិធីសិក្សា** ........ 323
៩.១. សេចក្តីផ្តើម ........ 323
៩.២. ការកែទម្រង់កម្មវិធីសិក្សាក្នុងឆ្នាំ១៩៩៦ ........ 324
៩.៣. គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំ២០០៥-២០០៩ ........ 325
៩.៤. ការត្រួតពិនិត្យកម្មវិធីសិក្សាឡើងវិញឆ្នាំ២០១៦-២០២៥ ........ 330
៩.៥. គោលបំណងតាមមុខវិជ្ជា ........ 334
៩.៦. ការវាយតម្លៃ ........ 338
៩.៧. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ........ 338
៩.៨. សេចក្តីសន្និដ្ឋាន ........ 339
**ជំពូកទី ១០ ៖ កំណែទម្រង់ការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីលើកកម្ពស់ឧស្សាហូបនីយកម្ម** ........ 341
១០.១. ការរៀបចំស្ថាប័ន សម្រាប់ការអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជា ........ 342
១០.២. ការផ្គត់ផ្គង់ជំនាញ ........ 347
១០.៣. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ........ 358
១០.៤. តម្រូវការជំនាញ ........ 360
១០.៥. វិធានការកំណែទម្រង់ ........ 363
១០.៦. សន្និដ្ឋាន ........ 370
**ជំពូកទី ១១ ៖ តួនាទីនៃឧត្តមសិក្សាក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច** ........ 371
១១.១. ស្ថានភាពបច្ចុប្បន្ននៃឧត្តមសិក្សានៅកម្ពុជា ........ 372
១១.២. កំណែទម្រង់ឧត្តមសិក្សាដើម្បីលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច ........ 378
១១.៣. សេចក្តីសន្និដ្ឋាន ........ 395
**ជំពូកទី ១២ ៖ កំណែទម្រង់ការអប់រំ និងការកែលម្អវិធីសាស្ត្របង្រៀនក្នុងគោលដៅលើកកម្ពស់ជំនាញទន់** ........ 397
១២.១. វិធីសាស្ត្រគរុកោសល្យ ........ 397
១២.២. វិធីសាស្ត្រអំណានដំបូង ........ 398
១២.៣. វិធីសាស្ត្របង្រៀនវិទ្យាសាស្ត្រតាមបែបរិះរក ........ 403
១២.៤. វិធីសាស្ត្របង្រៀនគណិតវិទ្យាតាមបែបសិស្សមជ្ឈមណ្ឌល ........ 405


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូកទី ១៣ ៖ ការផ្តល់ប្រឹក្សាអាជីព ដើម្បីដោះស្រាយគម្លាតជំនាញ និងលើកកម្ពស់ជំនាញទន់.................... 409
១៣.១. ការស្គាល់ខ្លួនឯង.....................................................................................410
១៣.២. ជីវិត និងក្តីសុបិន្តនាំអាជីព.........................................................................410
១៣.៣. ការសិក្សា ..............................................................................................411
១៣.៤. ជំនាញ និងភាពខ្លាំង ...............................................................................411
១៣.៥. ការអប់រំ និងជម្រើសនៃអាជីព...................................................................412
ជំពូកទី ១៤ ៖ ហិរញ្ញប្បទានក្នុងវិស័យអប់រំ.......................................................................417
១៤.១. សាវតា .....................................................................................................417
១៤.២. និន្នាការនៃថវិកាក្នុងវិស័យអប់រំ...................................................................417
១៤.៣. ការវិភាជថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងតាមអនុវិស័យអប់រំ.................................... 422
១៤.៤. ការវិភាជថវិកាតាមកម្មវិធី ......................................................................... 426
១៤.៥. ថវិកាដំណើរការសាលារៀន........................................................................ 429
១៤.៦. ការផ្តល់ហិរញ្ញប្បទានក្នុងវិស័យអប់រំ ដោយដៃគូអភិវឌ្ឍន៍ ............................................... 439
ជំពូកទី ១៥ ៖ ការកែលម្អគុណភាពរបស់សាលារៀន ៖ ការបង្កើតសាលារៀនជំនាន់ថ្មី និងការគ្រប់គ្រងសាលារៀននៅកម្ពុជា.....................................................................461
១៥.១. សាលារៀនជំនាន់ថ្មី .....................................................................................461
១៥.២ ការលើកកម្ពស់ការគ្រប់គ្រងសាលារៀននៅកម្ពុជា ...................................................... 469
បញ្ជីឈ្មោះតារាង និងរូបភាព.....................................................................................473
ឯកសារយោង .......................................................................................................477
I . ឈ្មោះសៀវភៅយោងជាភាសាខ្មែរ...................................................................... 477
I I . ឈ្មោះសៀវភៅយោងជាភាសាបរទេស .................................................................... 479
បណ្ឌិត ហង់ជួន ណារ៉ុន.........................................................................................491
ស្នាដៃរបស់អ្នកនិពន្ធ............................................................................................493

# អារម្ភកថា

«ការអប់រំប្រកបដោយគុណភាព គឺជាការបំពេញសេចក្តីត្រូវការរបស់មនុស្ស ការត្រៀមខ្លួនសម្រាប់ចូលប្រឡូកក្នុងពិភពការងារ និងការចូលរួមវិភាគទានក្នុងវឌ្ឍនភាពសង្គម»

*«Chitty, C. (2002). Understanding Schools and Schooling . London: Routledge Falmer»*

«ប្រសិនបើយើងចង់ឱ្យកម្ពុជាប្រែក្លាយទៅជាប្រទេសអភិវឌ្ឍ យើងត្រូវអប់រំប្រជាជនកម្ពុជាយើងឱ្យទៅជាមនុស្សអភិវឌ្ឍជាមុនសិន»។ ប្រការនេះបញ្ជាក់ពីតួនាទីរបស់វិស័យអប់រំ ជាពិសេសធនធានមនុស្សក្នុងដំណើរការអភិវឌ្ឍ។ ម្យ៉ាងវិញទៀត ប្រវត្តិសាស្ត្រកម្ពុជាក៏បានបង្ហាញយ៉ាងប្រចក្សផងដែរថា នៅដំណាក់កាលដែល **អាណាចក្រខ្មែរ** ឈានទៅដល់អារ្យធម៌កំពូល រចនាសម្ពន្ធនៃការបណ្តុះបណ្តាលធនធានមនុស្ស គឺជាកម្លាំងចលករក្នុងការដឹកនាំអភិបាលកិច្ចនេះ។ ផ្ទុយទៅវិញ នៅពេលដែលស្រុកខ្មែរជួបប្រទះនឹងចម្បាំងរាំងជល គឺប្រព័ន្ធអប់រំ និងធនធានមនុស្សនេះឯង ដែលរងនូវការបំផ្លិចបំផ្លាញមុនគេ។ ជាក់ស្តែង ក្នុងសម័យសង្គ្រាម និងក្នុងសម័យរបបប្រល័យពូជសាសន៍ ប៉ុល ពត ធនធានមនុស្សនៅកម្ពុជាត្រូវបានបំផ្លិចបំផ្លាញយ៉ាងដំណំ។ ខ្មែរបាត់ស្មារតី និងបាត់បង់អស់នូវចំណុចយោងសម្រាប់តម្រង់ទិសដៅរបស់ខ្លួន។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ថ្ងៃរំដោះជាតិបានចូលមកដល់។ ថ្ងៃនេះជាថ្ងៃដែលរណសិរ្សរួបរួមជាតិដើម្បីស្រោចស្រង់កម្ពុជា ដោយមានកងកម្លាំងវៀតណាមជួយ បានផ្តួលរំលំរបបត្រួតត្រារបស់ខ្មែរក្រហមទាំងស្រុង។ ប្រជាជនកម្ពុជាជាច្រើននាំគ្នាប្រារព្ធទិវានេះថាជាថ្ងៃកំណើតទីពីររបស់កម្ពុជា។

មិនយូរប៉ុន្មាន រណសិរ្សនេះបានប្រកាសអំពីការចាប់បដិសន្ធិនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងទ្វេដង ដើម្បីស្តារប្រទេសជាតិឡើងវិញ រៀបចំសេដ្ឋកិច្ច បង្កើតប្រព័ន្ធសិក្សាធិការ បើកមន្ទីរពេទ្យ និងបណ្តុះបណ្តាលបុគ្គលិកកម្រិតគ្រប់គ្រង។ សាលារៀនដែលបើកទ្វារវិញដំបូងគេគឺសាលាចតុមុខ បន្ទាប់មកសាលាអនុវិទ្យាល័យភ្នំដូនពេញ(បច្ចុប្បន្នសាលាព្រះស៊ីសុវត្ថិ)។ ជំនាន់ឪពុកម្តាយបង្កើត និងឪពុកម្តាយក្មេករបស់ខ្ញុំ ពួកគាត់ខំធ្វើការគ្មានឈប់ ដើម្បីរៀបចំប្រព័ន្ធអប់រំឡើងវិញ និងស្រោចស្រង់វប្បធម៌ខ្មែរ។ លើសពីនេះ ជាភ័ព្វល្អ និស្សិតសកលវិទ្យាល័យជាច្រើនបានចេញទៅរៀនថ្នាក់ឧត្តមសិក្សានៅប្រទេសក្រៅ ជាពិសេសនៅអឺរ៉ុបខាងកើត។ ភាគច្រើននៃអ្នកទាំងនោះ បានវិលត្រឡប់មកប្រទេសកំណើតវិញដើម្បីជួយកសាងជាតិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រទេសកម្ពុជាទទួលរងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចក្រោយពីការរលំរលាយរបបខ្មែរក្រហម។ ប្រទេសនេះពុំអាចប្រើប្រាស់គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិបានទេ។ ចំណែករូបិយវត្ថុរបស់ខ្លួនក៏មិនអាចដូរបានដែរ។ ដោយសារមានជំនួយពីសហភាពសូវៀត វៀតណាម និងប្រទេសដទៃទៀតនៃប្លុកសូវៀត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលបស្ចិមប្រទេសប្រហែល ១៥ ទើបអាចបង្កលទ្ធភាពឱ្យសាធារណរដ្ឋប្រជាមានិតកម្ពុជាចាប់ផ្ដើមស្ដាបនាសេដ្ឋកិច្ច និងសង្គមឡើងវិញបាន។ ទោះជាមានកិច្ចខំប្រឹងប្រែងយ៉ាងនេះក្ដី ក៏គេពុំមានលទ្ធភាពបំពេញចន្លោះប្រហោងដ៏មហិមានៃកង្វះធនធានមនុស្ស ដែលបានបាត់បង់ក្នុងរបបខ្មែរក្រហមនោះបានដែរ។ អាទិភាពដំបូងបំផុតក្នុងការអភិវឌ្ឍគឺការផ្ដល់ការបណ្ដុះបណ្ដាល។ ការបង្កើតសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឆ្នាំ១៩៧៩ ស្ដែងឱ្យឃើញដំណាក់កាលថ្មីមួយ ក្នុងការស្ដារនីតិសម្បទា និងការស្ដាបនាប្រទេសឡើងវិញលើគ្រប់វិស័យ។

លក្ខខណ្ឌតម្រូវដំបូងៗសម្រាប់ការអភិវឌ្ឍពិតប្រាកដ នៅមិនទាន់បានបង្កើតឱ្យមាននៅឡើយ។ បរិយាកាសអសន្តិសុខនៅមានពាសពេញផ្ទៃប្រទេស។ ដោយសារគោលនយោបាយ «**ឈ្នះ-ឈ្នះ**» ដើម្បីការផ្សះផ្សាជាតិនៅឆ្នាំ១៩៩៧ ដែលផ្ដួចផ្ដើមឡើងដោយលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ទើបញ្ចប់របបខ្មែរក្រហមត្រូវបានបញ្ចប់ ដោយអង្គការយោធា និងនយោបាយនៃរបបនេះក៏ត្រូវបានរំលាយចោល។

ប៉ុន្តែ ប្រទេសកម្ពុជាទទួលរងគ្រោះយ៉ាងធ្ងន់ដោយសារសង្គ្រាម និងការនៅឯកោពីសហគមន៍អន្តរជាតិ។ ពិសេសជាងគេ ការខូចខាតផ្នែកសង្គមមានទំហំធំធេងណាស់។ នៅដើមទសវត្សរ៍ទី៩០ ប្រទេសកម្ពុជាមានអត្រាមរណភាពទារកកម្រិតខ្ពស់ជាងគេនៅលើពិភពលោក។ បើប្រៀបធៀបគ្នាទៅនឹងប្រទេសអាហ្វ្រិក និងឥណ្ឌា អត្រាមរណភាពចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលសម្រាលទារកនៅកម្ពុជាមានចំនួនលើសគេទ្វេដង។ មិនតែប៉ុណ្ណោះ ប្រទេសកម្ពុជាមានអត្រាជនពិការខ្ពស់ជាងគេ និងករណីជំងឺរបេងច្រើនជាងគេនៅលើពិភពលោកផងដែរ។ ប្រជាជនជនបទតែ១២%ប៉ុណ្ណោះមានទឹកស្អាតប្រើប្រាស់។ នៅកន្លែងខ្លះនៅជនបទ ចំនួនអ្នកចុះឈ្មោះចូលរៀនមានស្ទើរមិនដល់៣០%ផង។

ដើម្បីលើកកម្ពស់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អាទិភាពផ្នែកវិនិយោគខាងកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយផ្ដោតជាពិសេសលើការដឹកជញ្ជូន និងទូរគមនាគមន៍ ថាមពលអគ្គិសនី ការអភិវឌ្ឍធនធានមនុស្ស សកម្មភាពអតិពលកម្ម ព្រមទាំងផលិតផលរោងចក្រសម្រាប់នាំចេញ និងទេសចរណ៍។ គោលនយោបាយនេះមានគោលបំណងបង្កើតមូលដ្ឋានគ្រឹះដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចាប់តាំងពីឆ្នាំ១៩៩៣ សេដ្ឋកិច្ចកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំង និងឆាប់រហ័ស។ សេដ្ឋកិច្ចតាមបែបប្រពៃណីផ្អែកលើកសិកម្ម ឥឡូវកំពុងងាកទៅរកផ្នែកឧស្សាហកម្ម និងវិស័យបន្ទាប់បន្សំវិញ។ បន្ទាប់ពីបានសន្តិភាពឡើងវិញ បរិយាកាសនៃការមានទំនុកចិត្ត និងមោទនភាព កើតមានពាសពេញក្នុងប្រទេស ពោលគឺអារម្មណ៍ដែលជាប្រផ្នូលល្អមួយសម្រាប់ក្ដីសង្ឃឹមភ្លឺស្វាងចំពោះកំណើនសេដ្ឋកិច្ច និងការបង្កើតការងារ និងទស្សនវិស័យប្រត្យក្សនៃអនាគតគួរឱ្យជឿជាក់។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺដើម្បីជួយសម្រេចទស្សនវិស័យនេះ តាមរយៈការពង្រឹងឧត្ដមភាពប្រៀបធៀបរបស់កម្ពុជាទាំងក្នុងតំបន់ និងអន្តរជាតិ។

រាជរដ្ឋាភិបាលកម្ពុជាយកការវិនិយោគឯកជនជាកត្តាសំខាន់ ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ការចាប់ផ្ដើមសេដ្ឋកិច្ច។ យុទ្ធសាស្ត្ររបស់កម្ពុជាមានបំណងធ្វើឱ្យប្រទេសកម្ពុជាអាចទាក់ទាញការវិនិយោគពីក្រៅប្រទេស និងជំរុញការនាំចេញទំនិញ និងសេវា។ ប្រការនេះនឹងផ្ដល់លទ្ធភាពឱ្យកម្ពុជា ក្នុងឋានៈជារដ្ឋមួយ តម្រង់វាសនាសេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការឆ្លើយតបទៅនឹងកម្លាំងទីផ្សារ។ ប្រជាជនកម្ពុជាមានសមត្ថភាពសម្រេចគោលបំណងនេះបាន ដរាបណាគេមិនបិទទីផ្សារ និងប្រសិនបើមានការជួយគាំទ្រពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍដទៃទៀត។

មោទនភាពចំពោះអតីតកាលដ៏រុងរឿង និងសមិទ្ធិថ្មីៗរបស់ខ្លួន ប្រទេសកម្ពុជាអាចរកបានកម្លាំង និងឆន្ទៈក្នុងការធ្វើការសម្រេចចិត្ត និងធ្វើសកម្មភាពចាំបាច់នានា ដើម្បីបង្កើនល្បឿនអភិវឌ្ឍ។ ប្រជាជនកម្ពុជាមានការប្ដេជ្ញាចិត្តក្នុងការបំពេញសក្ដានុពលរបស់ខ្លួនដែលមានពីធម្មជាតិ និងធ្វើឱ្យសុបិនរបស់ខ្លួនក្លាយជាការពិត។ ការអភិវឌ្ឍពុំអាចធ្វើទៅបានដោយបុគ្គលណាតែម្នាក់ឯង ឬក្រុមណាមួយបាននោះទេ។ ការអភិវឌ្ឍត្រូវតែធ្វើឡើងដោយកម្លាំងរួម តាមរយៈការលះបង់ពិតៗពីសមាជិកទាំងអស់របស់សង្គម។ ប្រសិនបើទាំងអស់គ្នារួមសហការគ្នា នោះប្រទេសកម្ពុជាអាចយកជោគជ័យលើសមរភូមិប្រយុទ្ធប្រឆាំងភាពក្រីក្រ និងសម្រេចបាននូវវឌ្ឍនភាព។

ជាការសំខាន់ អ្នកដែលពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវឯកភាពគ្នាលើទិសដៅរួមមួយ ដើម្បីការអភិវឌ្ឍ និងកិច្ចការកំណែទម្រង់របស់ខ្លួន។ ដំបូង ត្រូវពង្រឹងស្ថិរភាពនយោបាយ អភិបាលកិច្ច និងការគោរពសណ្ដាប់ធ្នាប់សាធារណៈ និងត្រូវធានាការពង្រឹងការអនុវត្តច្បាប់។ ចំពោះផ្នែកប្រជាធិបតេយ្យ និងការលើកកម្ពស់ការគោរពសិទ្ធិមនុស្សវិញ ប្រទេសកម្ពុជាបានអនុវត្តប្រព័ន្ធអភិបាលកិច្ចមួយសមស្របសម្រាប់មរតកប្រវត្តិសាស្ត្រ និងវប្បធម៌របស់ខ្លួនរួចហើយ។ ការបោះឆ្នោតត្រូវបានរៀបចំជាប្រក្រតី និងប្រកបដោយតម្លាភាពនិងយុត្តិធម៌។ សេរីភាពបុគ្គល និងសមូហភាពត្រូវបានធានា។ គណបក្សនយោបាយ សហជីពកម្មករ និងសារព័ត៌មានបំពេញមុខងារដោយសេរីនៅក្នុងប្រទេសប្រជាធិបតេយ្យដ៏ក្មេងខ្ចីនេះ។ កម្ពុជាបានចុះហត្ថលេខា និងផ្ដល់សច្ចាប័នស្ទើរតែគ្រប់កិច្ចព្រមព្រៀងអន្តរជាតិស្ដីពីការការពារសិទ្ធិមនុស្ស។ ការអប់រំប្រជាពលរដ្ឋអំពីសិទ្ធិពលរដ្ឋ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងការទទួលខុសត្រូវរបស់ពួកគាត់គឺជាផ្នែកមួយសំខាន់នៃសកម្មភាពរបស់រដ្ឋាភិបាល។ ប៉ុន្តែ ការចង់បានសេរីភាពខាងនយោបាយ មិនគប្បីធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនយោបាយ និងសង្គម ដែលទទួលបានក្រោយពីភាពកោលាហល និង ការបង្ហូរឈាមគ្នាអស់ជាច្រើនទសវត្សរ៍មកហើយនោះទេ។

សៀវភៅនេះមានបំណងពិនិត្យមើលជាទូទៅលើការតស៊ូរបស់កម្ពុជា ក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងការចែករំលែកវិបុលភាព យុទ្ធសាស្ត្រ និងគោលនយោបាយសម្រាប់កំណែទម្រង់ក្នុងវិស័យសំខាន់ៗ និងលទ្ធផលដែលទទួលបាន ដោយផ្តោតលើសមិទ្ធិរបស់កម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍មុននេះ និងបញ្ហាទាំងឡាយដែលត្រូវដោះស្រាយទៅអនាគត។

ខ្ញុំមានការពេញចិត្តផ្ទាល់ខ្លួន ចំពោះការដែលខ្ញុំបានប្រឡូកយ៉ាងជិតស្និទ្ធក្នុងដំណើរការអភិវឌ្ឍកម្ពុជា ស្ទើរតែពីដើមដំបូងមកម្ល៉េះ។ បទពិសោធនេះផ្តល់ឱ្យខ្ញុំនូវការយល់ដឹងស៊ីជម្រៅ ដែលខ្ញុំបានខិតខំយកមកឆ្លុះបញ្ចាំងជូនក្នុងសៀវភៅនេះ។ ខ្ញុំនៅតែជឿជាក់ថា ការជំរុញទឹកចិត្តដើម្បីឱ្យមានការអភិវឌ្ឍប្រទេសកម្ពុជានៅកម្រិតមូលដ្ឋានគឺត្រូវតែកើតចេញមកពីប្រជាជននៃប្រទេសកម្ពុជា។ ដូច្នេះជាសំខាន់ ពួកគាត់ត្រូវតែបានដឹងអំពីសមិទ្ធិរបស់ប្រទេសខ្លួន និងបញ្ហាប្រឈមទាំងឡាយដែលនៅមាន។ សៀវភៅនេះជាវិភាគទានមួយក្នុងការកែលម្អព័ត៌មានអំពីប្រទេសកម្ពុជា ដើម្បីធ្វើឱ្យសាធារណជនកម្ពុជាអាចត្រៀមខ្លួនជាមុនឱ្យបានល្អដើម្បីតទល់នឹងបញ្ហាប្រឈមនានាក្នុងការអភិវឌ្ឍ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ការថ្លែងអំណរគុណ

ខ្ញុំសូមសម្តែងសេចក្តីដឹងគុណអស់ពីដួងចិត្ត ជូនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយដែលផ្តោតលើការបង្កើតឱ្យមានសន្តិភាពឡើងវិញ និងការលើកស្ទួយការអភិវឌ្ឍនៅកម្ពុជា។ ខ្ញុំសូមអរគុណផងដែរចំពោះឯកឧត្តម និងលោកជំទាវថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ លោកគ្រូ-អ្នកគ្រូ និងស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដែលបានចូលរួមអនុវត្តកំណែទម្រង់វិស័យអប់រំ។ ខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅចំពោះវិភាគទានរបស់ពួកគាត់។

ខ្ញុំសូមអរគុណដល់សហការីខ្ញុំជាច្រើននៅក្រសួងអប់រំ យុវជន និងកីឡា ដែលបានជួយផ្តល់ជាយោបល់ កែលម្អសៀវភៅនេះ និងសូមអរគុណដល់ **បណ្ឌិត យូន វិច្ឆិកា** ដែលជួយអានចុងក្រោយ។

ខ្ញុំសូមអរគុណចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានជួយបោះពុម្ពផ្សាយសៀវភៅនេះ។

**ហង់ជួន ណារ៉ុន**

ភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៦


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្ដីផ្ដើម

*«The only purpose of education is to teach a student how to live his life – by developing his mind and equipping him to deal with reality. The training he needs is theoretical, i.e. conceptual. He has to be taught the essentials of the knowledge discovered in the past – and he has to be equipped to acquire further knowledge by his own efforts. Ayn Rand (1905-1982)»*

«គោលដៅតែមួយនៃការអប់រំ គឺបង្រៀននិស្សិតឱ្យចេះរស់នៅក្នុងជីវិតដោយបណ្ដុះគំនិតរបស់ពួកគេ និងបង្រៀនពួកគេឱ្យចេះដោះស្រាយបញ្ហាជាក់ស្ដែង។ ការបណ្ដុះបណ្ដាលដែលគេត្រូវការគឺទ្រឹស្ដី ពោលគឺទស្សនទាន។ យើងត្រូវបង្រៀនពួកគេនូវចំណេះដឹងជាមូលដ្ឋាននៃអតីតកាល។ ហើយពួកគេត្រូវចេះចាប់យកចំណេះដឹងថ្មីថែមទៀតដោយការខិតខំប្រឹងប្រែងរបស់ខ្លួនឯងផ្ទាល់ » ។ Ayn Rand (1950-1982)

សៀវភៅនេះមានគោលបំណងបង្ហាញពីអាទិភាពនៃកំណែទម្រង់ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា ដោយផ្ដោតសំខាន់ទៅលើបញ្ហាប្រឈម និងវិធានការកំណែទម្រង់ក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។ សៀវភៅនេះក៏ជួយផ្ដល់ជាគំនិត ក្នុងកិច្ចពិភាក្សាលើបញ្ហាប្រឈមទាំងនោះ ព្រមទាំងជួយក្នុងការកសាងគោលនយោបាយអប់រំឱ្យកាន់តែប្រសើរឡើង។ គោលបំណងរបស់សៀវភៅនេះ ក៏ផ្ដោតទៅលើផែនការសកម្មភាពកំណែទម្រង់វិស័យអប់រំ ដែលនឹងត្រូវអនុវត្តទាំងនៅថ្នាក់កណ្ដាល ទាំងនៅកម្រិតសាលារៀន។

ខ្ញុំបានចូលរួមចំនួនពីរដងនៅក្នុងការធ្វើកំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា។ កំណែទម្រង់លើកដំបូង គឺការចាប់ផ្ដើមអនុវត្ត **កម្មវិធីសកម្មភាពជាអាទិភាព** (PAP) ក្នុងឆ្នាំ២០០០ ដែលនៅពេលនោះ ខ្ញុំទើបត្រូវបានតែងតាំងជាអនុប្រធាននាយកដ្ឋានថវិកា និងហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយទទួលខុសត្រូវក្នុងការចាប់ផ្ដើមកំណែទម្រង់ថវិកា។ ដើម្បីឆ្លើយតបចំពោះ **កម្មវិធីសកម្មភាពជាអាទិភាព** ក្រសួងអប់រំ យុវជន និងកីឡា(អយក) បានដាក់ចេញនូវវិធានការ ដើម្បីអនុវត្តគោលដៅចំនួន៦ ដែលមានចែងនៅក្នុង **ការអប់រំសម្រាប់ទាំងអស់គ្នា**(EFA) តាមរយៈការអនុម័ត **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ**(ESP) ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំទី១ ឆ្នាំ២០០០-២០០៥ ផ្ដោតលើការបង្កើនការចូលរៀននៅកម្រិតបឋមសិក្សាដោយ៖ (i) ចាប់ផ្ដើមពីការលុបចោលការបង់ប្រាក់ចុះឈ្មោះចូលរៀន (ii) ការផ្ដល់ថវិកាដំណើរការសាលារៀន(SOB) ទៅដល់សាលារៀន ដោយប្រើរូបមន្តដែលគាំទ្រសាលានៅតំបន់ក្រីក្រ ដាច់ស្រយាល និង(iii) ការសាងសង់សាលារៀនបឋមសិក្សានៅទូទាំងប្រទេស។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំទីពីរ២០០៦-២០១០ បានផ្លាស់ប្ដូរអាទិភាពរបស់ខ្លួន ក្នុងគោលដៅលើកកម្ពស់ការអប់រំមធ្យមសិក្សាវិញម្ដង ដោយផ្ដោតលើ៖ (i) ការកសាងអនុវិទ្យាល័យក្នុងឃុំទាំងអស់ និងវិទ្យាល័យនៅក្នុងស្រុកទាំងអស់ និង (ii) ការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ ដើម្បីឱ្យពួកគេអាចរៀនចប់ដល់ថ្នាក់ទី៩។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំទី៣ ឆ្នាំ២០០៩-២០១៣ ផ្ដោតសំខាន់លើការកែលម្អប្រសិទ្ធភាព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្ទៃក្នុងដោយ ៖ (i) ការកាត់បន្ថយអត្រារៀនត្រួតថ្នាក់ និងបោះបង់ការសិក្សា និង(ii) ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ធ្វើវិមជ្ឈការ។

ក្នុងការឆ្លើយតបទៅនឹងគម្លាតជំនាញដែលមិនស្របទៅនឹងទីផ្សារការងារ និងទៅនឹងសម័យអន្តរកាលរបស់កម្ពុជាដែលឈានពីប្រទេសមានប្រាក់ចំណូលទាបទៅជាប្រទេសមានចំណូលមធ្យម កំណែទម្រង់លើកទីពីរនេះផ្តោតលើកំណែទម្រង់វិស័យអប់រំ ដែលត្រូវបានធ្វើឡើងតាំងពីឆ្នាំ២០១៣ ពោលគឺចាប់តាំងពីខ្ញុំត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរគោលនយោបាយ **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ** ២០១៤-២០១៨ ផ្តោតទៅលើ៖ (i) សមភាព និងគុណភាពក្នុងការទទួលបានការអប់រំ (ii) ភាពឆ្លើយតបបាននៃការអប់រំទៅនឹងតម្រូវការនៃសេដ្ឋកិច្ច និង (iii) ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់មន្ត្រីអប់រំ។ តាមរយៈការបញ្ចូលគោលដៅអភិវឌ្ឍប្រកបដោយចីរភាព(SDG) សម្រាប់វិស័យអប់រំ ទៅក្នុងកម្មវិធីកំណែទម្រង់ ដែលមានគោលដៅ *«ធានាបាននូវការអប់រំប្រកបដោយបរិយាប័ន្ន សមធម៌ និងគុណភាព ព្រមទាំងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»* **ចក្ខុវិស័យសម្រាប់កំណែទម្រង់វិស័យអប់រំ** នេះមានសមាសធាតុចំនួនប្រាំ៖ (i) ការធ្វើកំណែទម្រង់ **គោលនយោបាយគ្រូបង្រៀន** (ii) ការធ្វើ**អធិការកិច្ច**តាមសាលារៀន (iii) ការធ្វើ**វាយតម្លៃលទ្ធផលសិក្សា**របស់សិស្ស (iv) ការកែលម្អ**កម្មវិធីសិក្សា** (v) និងការធ្វើ**កំណែទម្រង់ឧត្តមសិក្សា**។

ក្នុងហេតុផលខាងលើ សៀវភៅនេះត្រូវបានរៀបចំឡើងជាពីរផ្នែក។

**ផ្នែកទីមួយ** បរិយាយអំពីការកសាងប្រព័ន្ធអប់រំកម្ពុជាឡើងវិញ។

**ជំពូកទី ១** និយាយពីតួនាទីនៃការអប់រំក្នុងអំឡុងសម័យអង្គរ តួនាទីនៃព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ព្រមទាំងការប្រើប្រាស់ភាសាសំស្ក្រឹត និងបាលីក្នុងវិស័យអប់រំ។ ទំនើបកម្មនៃវិស័យអប់រំនៅកម្ពុជាក្នុងអំឡុងប្រទេសនេះនៅក្រោមអាណាព្យាបាលបារាំង ការកសាងប្រទេសជាតិក្នុងអំឡុងពេលជាង១០ឆ្នាំបន្ទាប់ពីបានឯករាជភាព និងការស្តារប្រព័ន្ធអប់រំឡើងវិញបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ក៏នឹងត្រូវរំលេចចេញតាមរយៈកញ្ចក់ឆ្លុះបញ្ចាំងពីកំណែទម្រង់នៃវិស័យអប់រំនេះដែរ។

**ជំពូកទី ២** ផ្តោតលើរបៀបវារៈគោលនយោបាយសង្គមថ្មីនៃកំណែទម្រង់វិស័យអប់រំដើម្បី **បង្កើតសង្គមកម្ពុជាមួយដែលមានវប្បធម៌រស់រវើក សង្គមពុទ្ធិ និងភាពចម្រើនលឿនខាងវិទ្យាសាស្ត្រ** ដើម្បីសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍ (MDGs) និងការអប់រំសម្រាប់ទាំងអស់គ្នា(EFA)។ អ្វីដែលគួរឱ្យកត់សម្គាល់នៅក្នុងជំពូកនេះ គឺកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើនចំណាយថវិកា លើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ដោយការកាត់បន្ថយការចំណាយលើវិស័យការពារ និងសន្តិសុខ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាតិ។ ដំណាក់កាលដំបូងនៃការធ្វើកំណែទម្រង់វិស័យអប់រំក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០០០ ផ្តោតសំខាន់ទៅលើការចាប់ផ្តើមអនុវត្ត **កម្មវិធីសកម្មភាពជាអាទិភាព**(PAP) និង **ក្របខណ្ឌចំណាយរយៈពេលមធ្យម**(MTEF) ព្រមទាំង **ផែនការយុទ្ធ-សាស្ត្រវិស័យអប់រំ**(ESP) ក្នុងគោលបំណងដើម្បីធានាឱ្យបាននូវការទទួលបានសេវាអប់រំបឋមសិក្សាជាសកល។

**ជំពូកទី ៣** ពិនិត្យឡើងវិញលើលទ្ធផលអប់រំរបស់កម្ពុជា បន្ទាប់ពីការធ្វើកំណែទម្រង់ក្នុងរយៈពេល ១៥ ឆ្នាំ ។ ការអភិវឌ្ឍវិស័យអប់រំរបស់ប្រទេសនេះត្រូវបានពិភាក្សាទៅតាមអនុវិស័យដែលរួមមាន៖ កុមារតូច បឋមសិក្សា មធ្យមសិក្សា ការអប់រំពិសេស ការអប់រំក្រៅប្រព័ន្ធ ការអប់រំបច្ចេកទេស និងឧត្តមសិក្សា។ ក្នុងជំពូកនេះក៏នឹងកំណត់ពីបញ្ហាប្រឈមនានាដែលមាននៅក្នុងវិស័យអប់រំផងដែរ។

**ជំពូកទី ៤** នឹងពិភាក្សាអំពីក្របខណ្ឌច្បាប់ និងគោលនយោបាយសម្រាប់ប្រព័ន្ធអប់រំដូចជាគោលនយោបាយស្តីពីសាលាកុមារមេត្រី(CFS) ការអប់រំបំណិនជីវិត ការអប់រំសម្រាប់កុមារពិការ កម្មវិធីអប់រំក្រៅប្រព័ន្ធ កម្មវិធីសមមូល សាលាធនធាន សុខភាពសិក្សា បច្ចេកវិទ្យាព័ត៌មាននៅក្នុងការអប់រំ ការអភិវឌ្ឍកម្រងសាលារៀន ការគាំពារនិងអភិវឌ្ឍកុមារតូច(ECCD), ការអភិវឌ្ឍការស្រាវជ្រាវ ការអភិវឌ្ឍយុវជន ការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាព សៀវភៅសិក្សា ការអប់រំបច្ចេកទេស ។ល។ ក្នុងផ្នែកនេះក៏នឹងពិភាក្សាពីគោលនយោបាយអន្តរាគមន៍ ក្នុងដំណាក់កាលនៃកំណែទម្រង់វិស័យអប់រំ ដោយផ្តោតសំខាន់លើការគាំទ្រសិស្ស និស្សិត ដើម្បីឱ្យពួកគេមានសមត្ថភាពពិតប្រាកដ។

**ផ្នែកទីពីរ** នៃសៀវភៅនេះនឹងបរិយាយពីដំណើរឆ្ពោះទៅរកគុណភាព ដោយផ្តោតលើការធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីបង្កើតបាន **សង្គមកម្ពុជាមួយដែលមានវប្បធម៌រស់រវើក សង្គមពុទ្ធិ និងភាពចម្រើនឿនលឿនខាងវិទ្យាសាស្ត្រ**។

**ជំពូកទី ៥** ពិភាក្សាអំពីការវិវត្តផ្នែកប្រជាសាស្ត្រជាពិសេស កំណើតនៃសមាមាត្រប្រជាជនវ័យក្មេងនៅកម្ពុជា ការលេចចេញឡើងនូវគម្លាតជំនាញនៅកម្ពុជា ការចាំបាច់របស់កម្ពុជាក្នុងការប្រណាំងប្រជែងក្នុងក្របខណ្ឌអាស៊ាន បញ្ហាប្រឈមក្នុងវិស័យអប់រំ និងការចាំបាច់ក្នុងការធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីអភិវឌ្ឍប្រទេសកម្ពុជា។

**ជំពូកទី ៦** ដែលនឹងបរិយាយពីកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន និងគ្រូបង្រៀន នឹងមានរៀបរាប់ពីបញ្ហានានាពាក់ព័ន្ធនឹងគុណភាពអប់រំ កំណែទម្រង់ស្ថាប័នអប់រំគ្រូបង្រៀន ការបង្កើនគុណតម្លៃគ្រូបង្រៀនទាំងផ្នែកជីវភាពនិងការគោរពក្នុងសង្គម ការផ្លាស់ប្តូរទម្លាប់ក្នុងការបង្រៀននិងរៀនដើម្បីឱ្យសិស្សទទួលបានជោគជ័យក្នុងកម្រិតខ្ពស់មួយ ធានាឱ្យមានការចូលរួម ការប្តេជ្ញាចិត្ត និងចក្ខុវិស័យតែមួយពីគ្រប់ភាគីពាក់ព័ន្ធ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងដៃគូអភិវឌ្ឍ ព្រមទាំងកំណែទម្រង់ជាមូលដ្ឋានបន្ថែមទៀតនៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនក្រោយឆ្នាំ២០២០។

**ជំពូកទី ៧** ស្តីពីអធិការកិច្ចសាលារៀន នឹងលើកឡើងពីសកម្មភាពធានាគុណភាព ដែលនឹងផ្តោតលើការពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវដំណើរការដែលត្រូវបានប្រើប្រាស់ ដើម្បីបង្កើតលទ្ធផលចុងក្រោយ។ នេះមានន័យថា កុមារ និងសិស្សានុសិស្សនឹងទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព, សេចក្តីថ្លៃថ្នូរ សីលធម៌ ចរិយាធម៌ និងឥរិយាបថល្អ ក្នុងគោលបំណងដើម្បីជំរុញឱ្យអ្នកសិក្សារៀនសូត្រយល់ដឹង ស្រឡាញ់ និងការពារវប្បធម៌ជាតិ។ អធិការកិច្ចសាលារៀនផ្តោតលើសមាសភាគចំនួន ៤ គឺ៖ (i) ការដឹកនាំ និងការគ្រប់គ្រងរបស់នាយកសាលា (ii) ការបង្រៀន និងរៀន (iii) លទ្ធផលសិក្សា និង (iv) ការគាំទ្រសាលាពីសំណាក់ឪពុកម្តាយ អាណាព្យាបាល និងសហគមន៍។

**ជំពូកទី ៨** ស្តីពីការវាយតម្លៃថ្នាក់ជាតិ នឹងបង្ហាញអំពីប្រភេទខុសៗគ្នានៃការវាយតម្លៃការអប់រំ ដែលមានដូចជា៖ (i) គ្រូបង្រៀនអនុវត្តការវាយតម្លៃនៅក្នុងថ្នាក់រៀនរបស់ពួកគេដើម្បីតាមដានវឌ្ឍនភាពរបស់សិស្ស (ii) ប្រព័ន្ធអប់រំរៀបចំការប្រឡង ដើម្បីជ្រើសរើស ឬផ្តល់វិញ្ញាបនបត្រផ្សេងៗដល់សិស្ស ដូចជាការប្រឡងឆ្លងភូមិសិក្សា ឬការប្រឡងចូលទៅក្នុងសាកលវិទ្យាល័យ និង (iii) ការវាយតម្លៃជាទ្រង់ទ្រាយធំត្រូវបានធ្វើជាធម្មតានៅតាមសាលារៀនមួយចំនួន ដែលត្រូវបានចាត់ទុកជាសំណាក ក្នុងការវាយតម្លៃរកចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធអប់រំទាំងមូល ដើម្បីគាំទ្រដល់ការសិក្សាស្រាវជ្រាវ និងការកសាងគោលនយោបាយ។ ការវាយតម្លៃថ្នាក់ជាតិរបស់កម្ពុជាត្រូវបានប្រើប្រាស់ដើម្បីទទួលបាននូវព័ត៌មានស្តីពីសមិទ្ធផលនៃប្រព័ន្ធអប់រំទាំងមូល ប្រយោជន៍ប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើផែនការ និងកំណែទម្រង់។

**ជំពូកទី ៩** ស្តីពីការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា នឹងបង្ហាញពីតម្រូវការក្នុងការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សាបច្ចុប្បន្ន គឺដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រព័ន្ធទាំងមូល ក្នុងគោលដៅធានាការអភិវឌ្ឍចំណេះដឹង ជំនាញ គុណតម្លៃស្មារតី និងភាពជាពលរដ្ឋសកល។ ជំពូកនេះមានគោលបំណងដើម្បីលើកកម្ពស់ជំនាញទន់ ជំនាញមិនប្រើការត្រិះរិះ ឬជំនាញសតវត្សរ៍ទី ២១ ឧទាហរណ៍ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា, ការធ្វើការងារជាក្រុម។ល។

**ជំពូកទី ១០** គឺស្តីពីកំណែទម្រង់វិស័យអប់រំបច្ចេកទេស និងវិជ្ជាជីវៈដើម្បីដោះស្រាយគម្លាតជំនាញ និងឆ្លើយតបបានទៅនឹងតម្រូវការនាពេលបច្ចុប្បន្ននិងទៅអនាគត ពោលគឺក្នុងគោលបំណងលើកកម្ពស់ការបង្កើតការងារ បង្កើនផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីកំណើនសេដ្ឋកិច្ចខ្ពស់ ដែលជាយុទ្ធសាស្ត្រក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍឧស្សាហកម្ម (IDP)។

**ជំពូកទី ១១** បង្ហាញនូវទិដ្ឋភាពទូទៅនៃស្ថានភាពបច្ចុប្បន្ននៃការអប់រំនៅឧត្តមសិក្សានៅកម្ពុជា។ អ្វីដែលគួរកត់សម្គាល់នៅក្នុងជំពូកនេះ គឺការអនុម័តនៃស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងវិធានការធ្វើកំណែទម្រង់ដើម្បីធានាថា ការអប់រំនៅឧត្តមសិក្សាឆ្លើយតបទៅនឹងតម្រូវការនៃសេដ្ឋកិច្ចដែលកំពុងរីកលូតលាស់ ជាពិសេសការធ្វើពិពិធកម្មសេដ្ឋកិច្ច ឆ្ពោះទៅរកគុណតម្លៃបន្ថែមខ្ពស់នៃឧស្សាហកម្ម និងសេវាកម្ម។

**ជំពូកទី ១២** លើកឡើងពីសារសំខាន់នៃការអនុវត្តវិធីសាស្ត្របង្រៀន និងគរុកោសល្យក្នុងការលើកកម្ពស់គុណភាពអប់រំ ជាពិសេសតាមរយៈការអនុវត្តវិធីសាស្ត្រអំណានដំបូង វិធីសាស្ត្របង្រៀនគណិតវិទ្យាតាមបែបសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្របង្រៀនតាមបែបរិះរក។

**ជំពូកទី ១៣** ផ្តោតលើការផ្តល់ការប្រឹក្សាអាជីព ដើម្បីដោះស្រាយគម្លាតជំនាញ និងលើកកម្ពស់ជំនាញទន់។ ជំពូកនេះពិភាក្សាអំពីដំណាក់កាលសំខាន់ៗទាំង៥ នៃការប្រឹក្សាអាជីព និងការជ្រើសរើសអាជីពទៅតាមបុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗ។

**ជំពូកទី ១៤** គឺជាជំពូកស្តីពីហិរញ្ញប្បទានវិស័យអប់រំ បំពេញបន្ថែមទៅលើជំពូកទាំងដប់បីខាងដើម តាមរយៈការវិភាគការអនុវត្តថវិកាក្នុងវិស័យអប់រំ ការបែងចែកថវិកាតាមប្រភេទនៃចំណាយ និងតាមអនុវិស័យកម្មវិធីអប់រំ និងកម្មវិធីរង ព្រមទាំងថវិកាដំណើរការសាលារៀន។ ជំពូកនេះក៏បង្ហាញពីហិរញ្ញប្បទានវិស័យអប់រំដោយដៃគូអភិវឌ្ឍន៍ផងដែរ។

**ជំពូកទី ១៥** ដាក់ចេញនូវវិធានការកែលម្អគុណភាពរបស់សាលារៀន តាមរយៈការបង្កើតសាលារៀនជំនាន់ថ្មី និងការគ្រប់គ្រងសាលារៀន។

**ហង់ជួន ណារ៉ុន**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

L

# ផ្នែកទី ១

# ការស្តារប្រព័ន្ធអប់រំកម្ពុជា

ជំពូកទី១ ៖ តួនាទីវិស័យអប់រំក្នុងការកសាងជាតិ

ជំពូកទី២ ៖ របៀបវារៈថ្មីស្តីពីគោលនយោបាយសង្គមកិច្ចសម្រាប់វិស័យអប់រំ

ជំពូកទី៣ ៖ គោលនយោបាយជាតិស្តីពីការអប់រំ

ជំពូកទី៤ ៖ សមិទ្ធផលកំណែទម្រង់វិស័យអប់រំក្នុងរយៈពេល១៥ឆ្នាំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១

# តួនាទីវិស័យអប់រំក្នុងការកសាងជាតិ

ប្រទេសកម្ពុជាបានឆ្លងកាត់វិញ្ញាសាយ៉ាងច្រើន នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ នៅពេលដែលប្រទេសជាតិមានសង្គ្រាម ជួបនឹងកលិយុគ ឬវិបត្តិម្តងៗ វិស័យអប់រំតែងតែទទួលរងនូវគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះហើយទើបប្រទេសកម្ពុជាបានឆ្លងកាត់នូវដំណាក់កាលកសាងឡើងវិញនៃប្រព័ន្ធអប់រំជាច្រើនលើកច្រើនសា ជាពិសេស គឺការខិតខំប្រឹងប្រែងកសាងឡើងវិញនូវប្រព័ន្ធអប់រំក្នុងរជ្ជកាលព្រះបាទ **អង្គឌួង** ចាប់ពីពាក់កណ្តាលទីពីរនៃស.វ.ទី១៩ ការធ្វើទំនើបកម្មវិស័យអប់រំក្នុងសម័យអាណានិគមនិយមបារាំង ការពង្រឹង និងពង្រីកប្រព័ន្ធអប់រំចាប់ពីពេលដែលកម្ពុជាទទួលបានឯករាជ្យពីបារាំងក្នុងឆ្នាំ១៩៥៣ ដល់រដ្ឋប្រហារទម្លាក់សម្តេច **នរោត្តម សីហនុ** ក្នុងឆ្នាំ១៩៧០ និងការកសាងឡើងវិញទាំងស្រុងនៃប្រព័ន្ធអប់រំក្នុងទសវត្សរ៍ទី៨០ ក្រោយការដួលរលំនៃរបបខ្មែរក្រហម។

ទន្ទឹមនឹងនេះ យើងសង្កេតឃើញផងដែរថា ប្រព័ន្ធអប់រំដែលរីកលូតលាស់យ៉ាងលឿន ក្នុងអំឡុងទសវត្សរ៍ទី៦០ និងអតុល្យភាពនៃការបណ្តុះបណ្តាលជំនាញ បានបង្កើតឱ្យមានសម្ពាធទៅលើប្រព័ន្ធនយោបាយ និងឈានទៅដល់ការផ្ទុះឡើងនៃសង្គ្រាមក្នុងស្រុកក្រោមឥទ្ធិពលនៃស្ថានភាពភូមិសាស្ត្រនយោបាយនៃសង្គ្រាមត្រជាក់។ សង្គ្រាមរវាងខ្មែរនិងខ្មែរ ដែលផ្ទុះឡើងបន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច **នរោត្តម សីហនុ** និងរបបប្រល័យពូជសាសន៍ បានធ្វើឱ្យប្រព័ន្ធអប់រំនៅកម្ពុជាធ្លាក់ដល់កម្រិតសូន្យ។ ដូច្នេះរដ្ឋប្រហារទម្លាក់សម្តេច **នរោត្តម សីហនុ** និងរបបប្រល័យពូជសាសន៍ប៉ុលពតបានកម្ទេចប្រព័ន្ធ និងស្ថាប័នអប់រំ ព្រមទាំងធនធានមនុស្ស ដែលបុព្វបុរសខ្មែរបានខិតខំប្រឹងប្រែងកសាងក្នុងរយៈពេលជាង ១២០ ឆ្នាំ។ ក្នុងន័យនេះ ការតស៊ូរបស់ប្រជាជនកម្ពុជាក្នុងរយៈពេលជិត ៤០ ឆ្នាំចុងក្រោយនេះ គឺជាការតស៊ូដើម្បីកសាងវិស័យអប់រំឡើងវិញ។

## ១.១. មូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំ វប្បធម៌ និងអរិយធម៌ខ្មែរ

**ការអប់រំ** មានរូបរាងក្រោមទម្រង់ទីទៃពីគ្នាដូចជា៖ *«ឪពុកម្តាយពន្យល់ពីគំនិតគិតឃើញទៅកូនចៅរបស់ពួកគេ មិត្តភក្តិនិយាយនិងចែករំលែកគំនិត ការបង្ហាញចេញនូវជំនាញនានា*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*ដល់គ្នាទៅវិញទៅមក ជំនាញជាលក្ខណៈប្រពៃណីដែលបង្ហាត់បង្រៀនដល់មនុស្សជំនាន់ថ្មីក្នុងការធ្វើពាណិជ្ជកម្ម គ្រូបង្រៀនបង្ហាត់បង្ហាញសិស្ស និងអ្នករួមការងារនៅក្នុងសាលាជាដើម»*[1]។

កម្ពុជា គឺជាប្រទេសបរមបុរាណ ដែលមានវប្បធម៌ និងអរិយធម៌របស់ខ្លួន។ មុនការទទួលយកការគោរពប្រតិបត្តិពីសាសនាមកពីប្រទេសឥណ្ឌា ពលរដ្ឋខ្មែរគោរពប្រតិបត្តិអ្នកតា ដែលមានរូបរាងជាដុំថ្មផ្សេងៗ[2]។ បន្ទាប់មក វប្បធម៌ និងអរិយធម៌នេះទទួលរងនូវឥទ្ធិពលពីលទ្ធិនៃព្រហ្មញ្ញសាសនា និងពុទ្ធសាសនា។ ដូច្នេះ **អរិយធម៌ខ្មែរ** គឺជាលទ្ធផលនៃការស្ល និងច្របាច់បញ្ចូលគ្នាក្នុងរយៈពេលជាច្រើនសតវត្សរ៍រវាងអរិយធម៌ខ្មែរបុរាណ និងអរិយធម៌បរទេស ដែលមានដើមប្រភពពីឥណ្ឌា បស្ចិមប្រទេស និងចិន។ យើងឃើញថាក្នុងការវិភាគពីអរិយធម៌ខ្មែរគេឃើញមានទស្សនៈពីរខុសគ្នា ៖ ទស្សនៈទីមួយ គឺអរិយធម៌ខ្មែរមានឥទ្ធិពលពីឥណ្ឌា ហើយទស្សនៈទីពីរ គឺខ្មែរបានយកវប្បធម៌ពីឥណ្ឌា ដើម្បីយកមកស្លឱ្យទៅជារបស់ខ្មែរ។

អ្នកស្រាវជ្រាវដែលប្រកាន់យកទស្សនៈទី១ យល់ឃើញថា ៖ មូលដ្ឋាននៃអរិយធម៌ខ្មែរស្ថិតនៅក្នុងទស្សនវិជ្ជានៃសាសនា ដែលជនជាតិខ្មែរទទួលយកជាបន្តបន្ទាប់ ឬក្នុងពេលតែមួយ ដូចជាវេទនិយម ព្រាហ្មណ៍និយម ហិណ្ឌូនិយម និងពុទ្ធនិយម[3]។ មូលដ្ឋាននេះតែងតែវិវត្តជាលំដាប់ទៅតាមដំណាក់កាលនៃប្រវត្តិសាស្ត្រកម្ពុជា។ ដូច្នេះការសិក្សាវប្បធម៌ និងអរិយធម៌ខ្មែរទាមទារឱ្យយល់ពីព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ដែលខ្មែរទទួលពីឥណ្ឌាផងដែរ[4]។

លោកសាស្ត្រាចារ្យ **កេង វ៉ាន់សាក់** ជាអ្នកប្រកាន់យកទស្សនៈទី២។ នៅក្នុងនិក្ខេបបទដែលមានចំណងជើងថា « ការស្រាវជ្រាវនៃឫសគល់វប្បធម៌ខ្មែរ »[5] លោកសាស្ត្រាចារ្យ **កេង វ៉ាន់សាក់** បានលើកឡើងពីសម្មតិកម្មថា ៖ «វប្បធម៌ខ្មែរ គឺជាវប្បធម៌ចម្រុះ ដែលច្របាច់បញ្ចូលនូវមូលដ្ឋានក្នុងស្រុក(វប្បធម៌ខ្មែរ-មន ដែលមានសមាសធាតុនៃវប្បធម៌អូស្ត្រូអាស៊ី) និងវិភាគទានពីបរទេស ជាពិសេសពីឥណ្ឌា បស្ចិមប្រទេស និងចិន»។ លោកបន្តទៀតថា ៖ «[អក្សរសិល្ប៍ខ្មែរ-ឥណ្ឌា] បានអនុញ្ញាតឱ្យខ្ញុំយល់យ៉ាងច្បាស់ពី

---

[1] Gary Thomas ( 2013 ) Education: A Very Short Introduction. Oxford University Press. p. 2.

[2] ជំនឿទាំងនេះមានទំនាក់ទំនងទៅនឹងអ្នកតាម្ចាស់ទឹកម្ចាស់ដី និងជីដូនជីតាដែលបានចែកឋានទៅ (John Marston and Elizabeth Guthrie (Eds.) (2004). History, Buddhism, New Religious Movements in Cambodia, Silkworm Books, p. 7.

[3] KHY Phanra (2010), Études sur la culture et la civilisation khmères : Bilan et perspectives. in KHING Hoc Dy et THONG Thel, Mélanges culturels en hommage au Vénérable PANG KHAT, p. 57.

[4] ភិក្ខុប៉ាងខាត់ (១៩៦០) «វប្បធម៌ អរិយធម៌ខ្មែរ-ឥណ្ឌា» ។

[5] Keng Vannsak ( 1970 ) *Recherch d’un fond culturel khmer*, thèse pour le doctorat de 3è cycle, Paris : Université de Sorbonne, cité par KHY Phanra, Études sur la culture et la civilisation khmères : Bilan et perspectives. p. 58.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទំនាក់ទំនងពិតៗ ដែលមានលក្ខណៈមិនត្រឹមតែខុសគ្នាទេ តែផ្ទុយគ្នារវាងអក្សរសិល្ប៍ឥណ្ឌា និងខ្មែរ។ អ្វីដែលអង្រួនខ្ញុំឱ្យភ្ញាក់ពីដំណេក គឺខ្ញុំតែងតែជឿថា ឥណ្ឌា និងខ្មែរអាចប្រៀបប្រដូចទៅនឹងការរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ ខ្ញុំចាប់ផ្ដើមភ្ញាក់ខ្លួនបន្តិចម្ដងៗ រហូតដល់ពេលមួយ ដែលខ្ញុំរកឃើញរចនាសម្ពន្ធនៃភាសាខ្មែរ ដែលធ្វើឱ្យខ្ញុំលែងស្រមើស្រមៃទៀត ហើយចាប់ផ្ដើមមើលឃើញនូវការផ្ទុយគ្នា និងការខុសគ្នាជាមូលដ្ឋានរវាងវប្បធម៌ទាំងពីរ ៖ គឺឥណ្ឌា និងខ្មែរ»។ ពោល សាស្ត្រាចារ្យ **កេង វ៉ាន់សាក់** បានទាត់ចោលសម្មតិកម្មរបស់លោក George Coedès ដែលថា៖ «ខ្មែរគឺជាជនជាតិក្ងួយ ដែលទទួលយកវប្បធម៌ឥណ្ឌា»។

ក៏ប៉ុន្តែ សាស្ត្រាចារ្យ **កេង វ៉ាន់សាក់** មិនបានទាត់ចោលនូវការចូលរួមនៃវប្បធម៌ឥណ្ឌាក្នុងការបង្កើតវប្បធម៌ខ្មែរឡើយ។ លោកចែកវប្បធម៌ជាពីរផ្នែក ៖ វប្បធម៌ខាងផ្នែកសម្ភារ និងវប្បធម៌ខាងផ្នែកគំនិតស្មារតី។ លោកលើកឡើងថា លោក Jean Delvert (Le paysan cambodgien) និង លោកស្រី Éveline Porée-Maspero (Étude sur les Rites agraires des Cambodgiens) បានសិក្សាវប្បធម៌ខ្មែរខាងផ្នែកសម្ភារយ៉ាងល្អិតល្អន់ហើយ។ ដោយឡែក ចំពោះវប្បធម៌ខាងផ្នែកគំនិតស្មារតី លោកបានចែកចេញជាពីរផ្នែកគឺ ៖ ទី១-វិភាគទានឥណ្ឌាក្នុងវប្បធម៌ និងអរិយធម៌ខ្មែរ តាមរយៈសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាមហាយាន និងភាសាសំស្រ្កឹត និងពុទ្ធសាសនាថេរវាទ និងភាសាបាលី និង ទី២-វប្បធម៌ខ្មែរសុទ្ធសាធ ដែលមានតាំងតែពីជំនាន់ហ្វូណន ហើយដែលស្លជាមួយវប្បធម៌ឥណ្ឌា ដែលជំរុញឱ្យខ្មែរអាចឈានដល់ភាពរីកចម្រើនដូចជំនាន់អង្គរ[6]។

បណ្ឌិត **មីសែល ត្រាណេ** បានយកសម្មតិកម្មរបស់សាស្ត្រាចារ្យ **កេង វ៉ាន់សាក់** ទៅធ្វើការស្រាវជ្រាវបន្ថែម និងបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ «វប្បធម៌ខ្មែរដែលបានប្រសូតឡើងនាដើមសម័យប្រវត្តិសាស្ត្រក្រោមឥទ្ធិពលឥណ្ឌានោះ គឺជាវប្បធម៌មួយដែលប្រកបដោយលក្ខណៈសំយោគរវាងសមាសធាតុមន-ខ្មែរ និងឥណ្ឌា។ មុនមានលំហូរវប្បធម៌បរទេស អ្នកស្រុកនៃជ្រោយសុវណ្ណភូមិមានវប្បធម៌ដើមរបស់ខ្លួនរួចហើយ ដូចយើងឃើញតាមរយៈកំណាយនៃស្ថានីយល្អាងស្ពាននៅខេត្តបាត់ដំបង សំរោងសែននៅខេត្តកំពង់ឆ្នាំង ស្ថាននីយយុគថ្ម ក្រូសបំបែក នៅខេត្តក្រចេះ និងស្ទឹងត្រែងជាដើម។ នៅលើមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់ដូនតាទាំងនោះ ដែលមានអាយុកាលរាប់ពាន់សែនឆ្នាំមុនគ.ស. ទើបធាតុឥណ្ឌាបានចាប់ពន្លកពីលើ ចាប់តាំងពីស.វ.ទី១ ដល់ស.វ.ទី១៤ ដោយបាននាំមកនូវ

[6] Keng Vannsak (1970), *Recherche d'un fond culturel khmer,* p. 21-22.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអភិវឌ្ឍដ៏ឧត្តុង្គឧត្តមគ្រប់វិស័យ[7]។ ក៏ប៉ុន្តែ នៅពេលដែលឥទ្ធិពលឥណ្ឌាមកដល់ប្រជាជនខ្មែរពុំទាន់មានអក្សរនៅឡើយទេ។ សំណោរប្រវត្តិសាស្ត្រខ្មែរចាប់បដិសន្ធិឡើងនៅដើម ស.វ.ទី១ ដោយទទួលនូវឥទ្ធិពលរបស់ឥណ្ឌា ហើយបង្កើតបានអក្សរជាតិតាមលំនាំឥណ្ឌា។ ឥទ្ធិពលឥណ្ឌាក៏បាននាំមកនូវរបបនយោបាយរាជាធិបតេយ្យដូចឥណ្ឌា។

ខាងផ្នែកអក្សរសាស្ត្រ ទន្ទឹមនឹងការសិក្សាភាសាសំស្ក្រឹត និងភាសាបាលី បុព្វបុរសខ្មែរក៏បានបង្កើតភាសាខ្មែរបុរាណទុកឱ្យកូនចៅជំនាន់ក្រោយផងដែរ។ អក្សរសាស្ត្រគឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំខ្មែរ។ ប្រព័ន្ធអប់រំខ្មែរមុនស.វ.ទី២០ គឺជាប្រព័ន្ធអប់រំខាងផ្នែកសាសនា។ លោក **លី ធាមតេង** បានបែងចែកអក្សរសាស្ត្រខ្មែរតាមប្រភេទផ្សេងៗដូចតទៅ ៖ (១) អក្សរសាស្ត្រលទ្ធិសាសនា (២) អក្សរសាស្ត្ររឿងព្រេង (៣) អក្សរសាស្ត្ររឿងប្រលោមលោក (៤) អក្សរសាស្ត្រសិលាចារឹក (៥) អក្សរសាស្ត្រខាងបច្ចេកទេស និង (៦) អក្សរសាស្ត្រខាងចម្រៀង។ អត្ថបទអក្សរសិល្ប៍ទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការអប់រំនៅកម្ពុជា។ យើងនឹងពិភាក្សាអំពីប្រភេទអក្សរសាស្ត្រទាំងនេះតាមសម័យកាលនៃការវិវត្តប្រព័ន្ធអប់រំខ្មែរ[8]។

### ១.១.១. ប្រព័ន្ធអប់រំខ្មែរសម័យមុនអង្គរ

នៅលើទឹកដីភាគខាងកើតនៃប្រទេសកម្ពុជា មានការតាំងទីលំនៅតាំងពីសម័យយុគថ្មមកម្ល៉េះ ។ កំណាយដោយលោកស្រី Mourer នៅស្ថានីយល្អាងស្ពាន ខេត្តបាត់ដំបង ក្នុងអំឡុងទសវត្សរ៍ទី៦០ បានបញ្ជាក់ពីវត្តមានរបស់មនុស្សនៅលើទឹកដីដ៏បុរាណនេះតាំងតែពីឆ្នាំ៤២៩០ មុនគ.ស.។ តាមឯកសាររបស់លោក David Chandler នៅសំរោងសែន គេបានជីកដីឃើញលលាដ៍ក្បាល ដែលបញ្ជាក់ថាមានមនុស្សមករស់នៅតាំងពីជិត១៥០០ ឆ្នាំមុនគ.ស.។ តាមឯកសាររបស់បណ្ឌិត **មីសែល ត្រាណេ** រដ្ឋខ្មែរដំបូងត្រូវបានបង្កើតឡើងនៅដើមស.វ.ទី១ នៃគ.ស ដោយព្រឹត្តិការណ៍ឥណ្ឌាវូបនីយកម្មបានគ្រប់គ្រងលើរដ្ឋ និងរាជធានីតូចធំមួយចំនួន ដូចជា **ស្រេស្ឋបុរៈ** ស្ថិតនៅម្តុំចម្ប៉ាសាក់នៅប្រទេសលាវ ដែលជារាជធានីដំបូងនៃសន្តតិវង្សចេនឡា មុនការបង្កើតរដ្ឋ **ឦសានបុរៈ** ឬ **សម្បូណ៌ព្រៃគុក** ដែលបានសាងសង់ឡើងដោយព្រះបាទ **ឦសានវរ្ម័នទី១** ។

នៅបុរេសម័យ មានតែជនជាតិធំៗចំនួនបីប៉ុណ្ណោះដែលតាំងទីលំនៅនៅអាស៊ីអាគ្នេយ៍ គឺជនជាតិខ្មែរ ជនជាតិមន និងជនជាតិចាម។ ជនជាតិចាមរស់នៅក្នុងភូមិភាគ

[7] មីសែល ត្រាណេ (២០១៣) «មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ» គ្រឹះស្ថានបោះពុម្ពខ្មែរ ភ្នំពេញ ទំព័រ ៩១២-៩១៣។

[8] លី ធាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ»។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខាងកើត តាមបណ្តោយមាត់សមុទ្រនៃឧបទ្វីបឥណ្ឌូចិន។ ជនជាតិថៃ និងជនជាតិវៀតណាម គឺជាជនជាតិចំណូលថ្មី ដែលមានដើមកំណើតពីប្រទេសចិន។ នៅក្នុងដំណើរឆ្ពោះទៅទិសខាងត្បូង ជនជាតិថៃបានលេបយកទឹកដីរបស់មន និងខ្មែរ។ ទីបំផុត មនត្រូវបានភូមា និងសៀមលេបយកទឹកដីអស់។

ជនជាតិខ្មែរ គឺជាជនជាតិដើមនៃអាស៊ីអាគ្នេយ៍ ដែលតាំងទីលំនៅនៅក្នុងជ្រលងនៃទន្លេមេគង្គភាគកណ្តាល និងភាគខាងក្រោម។ ប្រទេសមនមានឈ្មោះថា **អាណាចក្រទ្វារវតី** និងមានព្រំប្រទល់ជាប់នឹង **អាណាចក្រខ្មែរ** ហើយលាតសន្ធឹងតាមដងទន្លេមេណាម ឬចៅប្រាយ៉ា។ ជនជាតិមនរស់នៅផ្នែកខាងជើង និងខាងលិចទន្លេមេគង្គ គឺនៅចំភូមិភាគកណ្តាលនៃប្រទេសថៃបច្ចុប្បន្ន និងនៅតាមខ្ពង់រាបកូរ៉ាតផ្នែកខាងជើងជួរភ្នំដងរែក។ អាណាចក្រទ្វារវតីទទួលឥទ្ធិពលពីសិល្បៈឥណ្ឌាដំបូងគេដូចអាណាចក្រខ្មែរ និងចម្ប៉ាដែរ។ បើវិនិច្ឆ័យទៅតាមសិល្បៈទ្វារវតី ដែលជាសិល្បៈរីកចម្រើន ជាពិសេសព្រះពុទ្ធរូបនៅវត្តប្រាមេន ខេត្តអយុធ្យាដែលមានកាលបរិច្ឆេទនៅស.វ.ទី៨នៃគ.ស. បញ្ជាក់ថាជនជាតិមនទំនងជាគោរពព្រះពុទ្ធសាសនា និកាយថេរវាទ។

យើងឃើញថា អាណាចក្រទាំងពីរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុត ជាពិសេសខាងវិស័យវប្បធម៌ ដោយសារភាសាខ្មែរ និងភាសាមនស្ថិតនៅក្នុងគ្រួសារខ្មែរ-មនតែមួយ ហើយភាសាទាំងពីរនេះបានចារនៅក្នុងសិលាចារឹករបស់ខ្មែរ។ បើតាមមតិរបស់លោក Thierry Zephir សាស្ត្រាចារ្យនៃសាលា **លូវ៍រ** បានឱ្យដឹងថា ព្រះពុទ្ធបដិមា <**ទ្វារវតី**> ក្នុងកាយវិការបង្រៀន(វិតក៌មុទ្រ) និងរូបពោធិសត្វដែលគេបានរកឃើញនៅក្នុងតំបន់បានហៀ ឬតំបន់ព្រះនគរជ័យ(បច្ចុប្បន្ននៅក្នុងទឹកដីថៃ) មានលក្ខណៈជាខ្មែរសុទ្ធសាធ និងស្ថិតនៅក្នុងរចនាបថព្រៃក្មេង ឬកំពង់ព្រះ ពោលព្រះពុទ្ធបដិមានេះមានសិល្បៈនៃដួងព្រលឹងខ្មែរ និងបង្ហាញពីសិល្បៈទ្វារវតីផងដែរ(**កេរដំណែលខ្មែរ** លេខ ០១)។

ដោយសារតែវប្បធម៌ខ្មែរ និងវប្បធម៌មនមានលក្ខណៈស្រដៀងគ្នា និងមានប្រភពតែមួយពីឥណ្ឌាសម័យដំបូង ជាពិសេសភាសាដែលស្ថិតនៅក្នុងគ្រួសារខ្មែរ-មនតែមួយ ដែលមានប្រភពពីភាសាសំស្ក្រឹតនេះហើយ ទើបមានប្រវត្តិវិទូមួយចំនួនបានលើកឡើងពីអំណះអំណាងនៃអារ្យធម៌ខ្មែរ-មនថា ហាក់បីដូចជាអារ្យធម៌តែមួយ ដោយសារសិល្បៈទ្វារវតីនៅមុនសម័យអង្គរបានទទួលឥទ្ធិពលពីគ្នាទៅវិញទៅមក។ ឧទាហរណ៍ ស្ថានីយបុរាណវិទ្យាស៊ីទេព ដែលជាស្ថានីយខ្មែរនៅក្នុងទឹកដីថៃ ដែលជាបេះដូងនៃអាណាចក្រទ្វារវតីគឺជាតឹកតាងស្រាប់។

តាមរយៈការសិក្សាពីទិដ្ឋភាពរួមនៃអាណាចក្របុរាណនៅអាស៊ីអាគ្នេយ៍ ការគ្រប់គ្រងមានលក្ខណៈជា « Center of power » ហើយការបែងចែកព្រំដែនរវាងអាណាចក្រពីរគឺជារឿងស្មុគស្មាញនិងអាស្រ័យតាមពេលវេលា។ ឧទាហរណ៍ តាមប្រភពរបស់លោក David Snellgrove នៅស្ថានីយ **មឿងសីមា** ដែលស្ថិតនៅខាងលិចនៃ **នគររាជសីមា** នៅលើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្ពង់រាបកូរ៉ាត គេឃើញមានផ្នូរខ្មោចអាយុជាង ២០០០ ឆ្នាំ និងឃើញមាននូវសំណល់ប្រាសាទមន និងប្រាសាទខ្មែរផងដែរ[9]។

ជនជាតិខ្មែរ និងជនជាតិមន គឺជាជនជាតិដែលភាគច្រើនរស់នៅតាមតំបន់ព្រៃភ្នំ ហើយភាគតិចរស់នៅតាមមាត់សមុទ្រ។ នៅតាមមាត់សមុទ្រនៃឧបទ្វីបឥណ្ឌូចិន ភាគច្រើនជនជាតិដែលរស់នៅទីនោះគឺជនជាតិចាម ដែលមានដើមកំណើតមកពីឧបទ្វីបម៉ាឡេ និងឥណ្ឌូណេស៊ី។ ជនជាតិខ្មែរទទួលនូវឥទ្ធិពលខាងផ្នែកភាសា វប្បធម៌ និងសាសនាផ្ទាល់ពីឥណ្ឌា ជាពិសេសតាមរយៈមជ្ឈមណ្ឌលពាណិជ្ជកម្ម **អូរកែវ** នៃ **អាណាចក្រភ្នំ** ឬ **ហ្វូណន** ។

### ១.១.១.១. *អាណាចក្រភ្នំ ឬ ហ្វូណន*

នៅខាងដើមគ្រិស្តសករាជ **អាណាចក្រភ្នំ** ឬ **នគរភ្នំ** ដែលជាភាសាចិនហៅថា **ហ្វូណន** គឺជារដ្ឋសំខាន់ជាងគេនៅអាស៊ីអាគ្នេយ៍។ ប្រវត្តិវិទូ Coedès យល់ឃើញថា រាជធានីរបស់អាណាចក្រភ្នំ គឺ **វ្យាធបុរៈ** (បុរីនៃស្តេចទាក់ដំរី) ដែលស្ថិតនៅម្តុំបាភ្នំ និងបាណាមក្នុងខេត្តព្រៃវែងសព្វថ្ងៃនេះ។ តាមរយៈការស្រាវជ្រាវបុរាណវិទ្យា(១៩៩៦) នៅបាភ្នំ និងអង្គរបុរី គេសន្និដ្ឋានថា រាជធានីរបស់ហ្វូណនគួរតែស្ថិតនៅអង្គរបុរី(តាកែវ) មិនមែនបាភ្នំទេ។ អាណាចក្រភ្នំបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាយ៉ាងខ្លាំងក្លាចំនួនពីរលើក គឺលើកទីមួយនៅដើមគ.ស.ទី១ និងមួយលើកទៀតនៅដើមគ.ស.ទី៥ ។

***ឥណ្ឌាភាវូបនីយកម្ម*** ឬការទទួលធាតុផ្សេងៗនៃវប្បធម៌ឥណ្ឌាបានកើតមានឡើងចាប់តាំងពីស.វ.ទី១ មុនគ.ស.មកម្ល៉េះ ពោលគឺក្នុងពេលជាមួយគ្នានឹងពាណិជ្ជកម្មជាមួយចិនដែរ ដោយឈរលើមូលដ្ឋាននៃការវិភាគវត្ថុសិល្បៈបុរាណ ដូចជាអង្កាំ កុលាលភាជន៍ និងកំណាត់ហេតុផ្សេងៗ។ នរវិទូបានបែងចែកឥណ្ឌាភាវូបនីយកម្មជាពីរប្រភេទ ៖ ប្រភេទទី១ គឺតាមរយៈការប្រើប្រាស់ភាសាសំស្ក្រឹត ច្បាប់ និង ព្រហ្មញ្ញសាសនា និងប្រភេទទី២ គឺតាមរយៈស្រុកភូមិ ទំនៀមទម្លាប់ និងជំនឿអ្នកស្រុក។

បើតាមការស្រាវជ្រាវរបស់បណ្ឌិត **មីសែល ត្រាណេ** វប្បធម៌ និងអារ្យធម៌ខ្មែរមានតាំងពីសម័យបុរេប្រវត្តិ ហើយបានជួបនឹងវប្បធម៌ចិន មុននឹងមានការហូរចូលនៃវប្បធម៌ឥណ្ឌានាដើមស.វ.ទី១ នៃគ.ស.។ ទំនាក់ទំនងខ្មែរ និងចិនឆ្លុះបញ្ចាំងតាមរយៈស្គរមហោធិក ឬស្គរអារក្សហៅទឹកភ្លៀង ដែលគេបានរកឃើញនៅក្នុងចក្រភពបុរេអង្គរ ក៏ដូចជាក្បាច់ក្បូរលម្អលើវត្ថុសិល្បៈមួយចំនួន ដូចជាជួង កាំបិត កងដៃ កងជើងជាដើម[10]។

**អាណាចក្រភ្នំ** គឺជាអាណាចក្រតូចមួយ តែជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយដ៏សំខាន់នៅអាស៊ីអាគ្នេយ៍ ហើយកំពង់ផែ **អូរកែវ** ដើរតួនាទីយ៉ាងសំខាន់នៅក្នុងពាណិជ្ជកម្ម

[9] Snellgrove, D. (2004), Angkor Before and After : A Cultural History of the Khmers, Orchid Press, Bangkok.
[10] មីសែល ត្រាណេ (២០០៨) «វប្បធម៌ អារ្យធម៌ខ្មែរ ៖ អំពីសាសនាខ្មែរតាំងពីសម័យបុរេប្រវត្តិសាស្ត្រ(សង្ខេប)» ភ្នំពេញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះ។ ការផ្សព្វផ្សាយវប្បធម៌ឥណ្ឌាប្រព្រឹត្តទៅជាពីរដំណាក់កាល ៖ ដំណាក់កាលទី១ គឺតាមរយៈពួកឈ្មួញដែលខិតខំរៀនសូត្រភាសាអ្នកស្រុកដើម ហើយខ្លះក៏បានរៀបមង្គលការជាមួយជនជាតិដើម និងដំណាក់កាលទី២ គឺតាមរយៈពួកបញ្ញវន្តខ្មែរក្នុងវណ្ណៈខ្ពស់។

អាណាចក្រភ្នំមានការរៀបចំផ្នែកនយោបាយតាមបែបឥណ្ឌា។ ព្រះរាជាមានឋានន្តរនាមជា **ក្រុងខ្ញុំ** ព្រោះយកតាមភ្នំ ដែលព្រះអង្គគង់យាងឡើងទៅធ្វើសក្ការៈចំពោះព្រះ **មហេស្វរៈ** និងមានតម្កល់លិង្គព្រះ **គិរិស** គឺឈ្មោះព្រះឥសូរដែលសណ្ឋិតនៅលើភ្នំនោះ។ នៅក្នុងវិស័យនយោបាយក្រៅប្រទេស អាណាចក្រភ្នំបានចងស្ពានមេត្រីជាមួយប្រទេសធំៗ ដូចជាប្រទេសឥណ្ឌា និងប្រទេសចិន។ កំពង់ផែ **អូរកែវ** ជាកំពង់ផែដ៏ធំមួយរបស់អាណាចក្រភ្នំ។ អ្នកប្រាជ្ញបារាំង លោក Louis Malleret បានធ្វើកំណាយ នៅស្ថានីយ **អូរកែវ** ហើយរកឃើញខឿនសំណង់ផ្សេងៗ ព្រមទាំងវត្ថុផ្សេងច្រើនទៀត មកពីចក្រភពរ៉ូម និងឥណ្ឌា។

អាណាចក្រភ្នំប្រើប្រាស់ភាសាសំស្ក្រឹតជាភាសាផ្លូវការ ក៏ប៉ុន្តែ ភាសាខ្មែរក៏ត្រូវបានគេប្រើប្រាស់ទន្ទឹមនឹងភាសាសំស្ក្រឹតដែរ។ ក្នុងវិស័យជំនឿសាសនា ប្រជាជននៅអាណាចក្រភ្នំបានកាន់សាសនាធំៗទាំងពីររបស់ឥណ្ឌា គឺសាសនាព្រាហ្មណ៍ និងពុទ្ធសាសនា។ ព្រះពុទ្ធសាសនាដែលនាំចូលមកកាន់អាណាចក្រភ្នំដំបូង គឺព្រះពុទ្ធសាសនាថេរវាទ ដែលប្រើប្រាស់ភាសាសំស្ក្រឹត។ ចំណែកខាងសាសនាព្រាហ្មណ៍ គេឃើញមានការគោរពចំពោះ **ព្រះឥសូរ ព្រះវិស្ណុ ព្រះហរិហរៈ** (**វិស្ណុ និងឥសូររួមគ្នា**) **និងព្រះព្រហ្ម**។

នៅសម័យអាណាចក្រភ្នំ ប្រជាជនខ្មែរខ្លះគោរពបូជាព្រហ្មញ្ញសាសនា និងខ្លះទៀតព្រះពុទ្ធសាសនា។ នៅក្នុងព្រហ្មញ្ញសាសនា អ្នកខ្លះគោរពព្រះឥសូរ អ្នកខ្លះគោរពព្រះវិស្ណុ។ ដល់ក្រោយស.វ.ទី៨ ប្រជាជនខ្មែរគោរព **ព្រះហរិហរៈ** ដែលម្ខាងជាឥសូរ និងម្ខាងទៀតជាវិស្ណុ ដែលរូបចម្លាក់ច្រើនធ្វើពីសំរឹទ្ធិ និងថ្ម។

នៅសម័យអាណាចក្រភ្នំ ព្រះពុទ្ធសាសនាមានការរុងរឿងក្រៃលែង ហើយអ្នកស្រុកច្រើនគោរពនិកាយហីនយាន។ គេបានរកឃើញពុទ្ធរូបជាច្រើនអង្គធ្វើពីសំរឹទ្ធិ ពីថ្ម ឬពីឈើ ជារចនាបថភ្នំដានៅអង្គរបុរី ដែលជាមជ្ឈមណ្ឌលផលិតបដិមាទាំងនោះ។ ព្រះពុទ្ធរូបសម័យនោះដែលរកឃើញ គឺព្រះពុទ្ធរូបថ្មនៅវត្តរំលកស្រុកព្រៃកប្បាស ខេត្តតាកែវ ព្រះពុទ្ធរូបសំរឹទ្ធិនៅបាណន់ ខេត្តបាត់ដំបង និងព្រះពុទ្ធរូបនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ។

នៅក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទបុរាណត្រូវបានសាងសង់ពីដីឥដ្ឋ។ ខឿនសំណង់ផ្សេងៗ ដែលគេបានរកឃើញនៅកំពង់ផែអូរកែវ និងនៅអង្គរបុរីក៏ជាសំណង់ពីឥដ្ឋ។ នៅផ្នែកសិល្បៈបដិមា គេបានរកឃើញព្រះពុទ្ធរូប និងទេវរូបជាច្រើននៅតំបន់ភ្នំដា ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចជាពុទ្ធរូបវត្តរំលក រូបព្រះវិស្ណុ ព្រះពលរាម ព្រះកល្កិន និងព្រះគ្រឹស្នគោវធ៌នជាដើម។ ស្នាដៃទាំងនេះមានលក្ខណៈជាឥណ្ឌានៅឡើយ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមប្រភពឯកសាររបស់លោក Bernard Philippe Groslier អាណាចក្រភ្នំមិនគ្រាន់តែមានអំណាចសមុទ្រ និងជំនួញប៉ុណ្ណោះទេ ប្រទេសនេះបានធានាឱ្យមានធនធានកសិកម្មរបស់គេយ៉ាងច្រើនបំផុត ដោយរៀបចំទឹកដីរបស់គេបានប្រសើរ ដោយឈរលើការប្រឹងប្រែងដ៏មហិមា តាមរយៈការបង្កើតនូវប្រព័ន្ធព្រែកជីកសម្រាប់បង្ហូរទឹក និងធ្វើការស្រោចស្រពយ៉ាងប្រទាក់គ្នាចម្រុះ ប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ដំណាំស្រូវ។ ប្រព័ន្ធព្រែកជីកទាំងនេះប្រទាក់ក្រឡាគ្នាពីមួយទៅមួយ រួចហើយក៏បត់បែនទៅនឹងបុរី ហើយក៏បម្រើដល់ការដឹកជញ្ជូននានា ជាពិសេសសម្រាប់នាវាធំៗ ដែលអាចចូលដល់ទៅខាងក្នុងទីក្រុង។ ជាការពិតណាស់ នៅតាមដងផ្លូវទាំងនេះហើយ ដែលឥទ្ធិពលឥណ្ឌាបានជ្រាបចូលទៅតំបន់ខាងក្នុងបានយ៉ាងងាយ[11]។

សិលាចារឹកវូកាញ់(ខេត្តញ៉ាត្រាង វៀតណាម) ដែលជាស្នាព្រះហស្តរបស់ព្រះបាទ **ស្រីមារៈ** ក្នុងស.វ.ទី៣បានកត់ត្រាទុកនូវប្រវត្តិសាស្ត្រខ្មែរជំនាន់អាណាចក្រគោកធ្លក ឬ **ហ្វូណន**។ ព្រះអង្គមានព្រះរាជហឫទ័យជ្រះថ្លា និងតែងសន្តោសដល់ប្រជាពលរដ្ឋទូទៅ។ ទ្រង់បានបរិច្ចាគព្រះរាជទ្រព្យធ្វើជាទានដល់សាធារណជន។ ទ្រង់បានគ្រាស់ផ្តាំផ្ញើដល់ព្រះរាជាក្រោយៗ សូមឱ្យទ្រង់មានព្រះមេត្តាធម៌ដូចព្រះអង្គដែរ[12]។

ចាប់តាំងពីស.វ.ទី៦ នេះផងដែរ អាណាចក្រ **ស្រីវិជ័យ** (Srivijay) ដែលស្ថិតនៅមាត់សមុទ្រប៉ែកអាគ្នេយ៍នៃកោះ **ស៊ូម៉ាត្រា** បានក្លាយទៅជាមហាអំណាចជើងទឹកមួយនៃអាស៊ីភាគអាគ្នេយ៍។ ប្រការនេះក៏ជាមូលហេតុមួយផងដែរនៃការធ្លាក់ចុះនៃ **អាណាចក្រភ្នំ**។ ស្រីវិជ័យគ្រប់ដណ្តប់លើពាណិជ្ជកម្មឆ្លងកាត់ឈូងសមុទ្រ **ម៉ាឡាកា** ហើយមានរាជវង្សសៃលេន្ទ្រ(Sailendras) ដែលគោរពព្រះពុទ្ធសាសនាសោយរាជ្យ។ ព្រះរាជវង្ស **សៃលេន្ទ្រ** គឺជាស្ថាបនិកប្រាសាទ **បូរូបូឌួ** (Borobudur) ប្រាសាទ **ចន្ទ សេវុ** (Candi Sewu) និងប្រាសាទជាច្រើនទៀត។ **ស្រីវិជ័យ** ដណ្តើមបានអាណាចក្រតូចៗមួយចំនួននៅតាមមាត់សមុទ្រនៃឧបទ្វីបម៉ាឡេដែលពីមុនត្រូវនាំសួយសារអាករទៅឱ្យ **អាណាចក្រភ្នំ**។

### *១.១.១.២. អាណាចក្រចេនឡា*

ឯកសារចិនបានបញ្ជាក់ថា ចេនឡាពីដើមឡើយ គឺជាសាមន្តរដ្ឋរបស់អាណាចក្រភ្នំ។ អាណាចក្រអំណាចអង្គរលើកដំបូងចាប់ផ្តើមឡើងនៅទិសឦសាននៃប្រទេសសៀមសព្វថ្ងៃ តាមដងទន្លេសេម៉ូន។ អាណាចក្រចេនឡាដំបូង ខាងកើតមានព្រំប្រទល់ជាប់នឹងទន្លេមេគង្គកណ្តាលក្នុងតំបន់ចំប៉ាសាក់ក្នុងប្រទេសឡាវសព្វថ្ងៃ និងក្រចេះ និងទល់នឹងប្រទេសចាម ដែលបានទទួលឥទ្ធិពលឥណ្ឌា។ បន្ទាប់មកមានចលនាស្ទុះចុះរបស់ខ្មែរ ទៅ

[11] ប៊ែណារ ហ្វីលីប ហ្គ្រោសលីយេ (២០០៣) «ទីក្រុងអង្គរ ជំហរអារ្យធម៌ខ្មែរ» មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ភ្នំពេញ។

[12] ព្រះភិក្ខុ ប៉ាង ខាត់ (១៩៦០) «ពុទ្ធសាសនា ២៥០០» លើកឡើងនៅក្នុង លី ធាមតេង «អក្សរសាស្ត្រខ្មែរ» ទំព័រ៥៩។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កាន់វាលទំនាបខាងក្រោមនៃទន្លេមេគង្គ។ នៅពាក់កណ្ដាលទី២ នៃស.វ.ទី៦ ចេនឡាមានអានុភាពកាន់តែខ្លាំងឡើងៗ ហើយចាប់ផ្ដើមវាយលុកប្រឆាំងនឹងអាណាចក្រភ្នំ។ អាណាចក្រចេនឡាក៏លាតសន្ធឹងតាមដងទន្លេមេគង្គ ពីសម្បូណ៌ទៅដល់កំពង់ចាម រួចហើយក៏ឆ្ពោះទៅដល់យកអាណាចក្រភ្នំជាចំណុះនៅឆ្នាំ៥៥០។

អាណាចក្រ **ហ្វូណន** ត្រូវបានឈ្លានពានដោយរដ្ឋចំណុះជិតខាង គឺ **ចេនឡា**។ រូបព្រះពុទ្ធនៃរជ្ជកាលចេនឡាត្រូវបានប្រទះឃើញនៅខេត្តតាកែវ ហើយតំបន់ចម្លាក់ថ្មភក់តាមបែបសាសនាព្រាហ្មណ៍នៃអាស្រមមហាឫស្សីត្រូវបានគេរកឃើញនៅភ្នំដា នៅក្បែរតំបន់អង្គរបុរី។ រដ្ឋធានីដើមនៃ **ចេនឡា** ស្ថិតនៅតំបន់មេគង្គកណ្ដាល គឺនៅវត្តភូ[13]។ បន្ទាប់មក **ឦសានបុរៈ** បានក្លាយទៅជារាជធានីនៃចេនឡានៅក្រោមរជ្ជកាលនៃព្រះបាទ **ឦសានវរ្ម័នទី១** (៦១៦-៦៣៥)។ ក្រុមប្រាសាទនៅសម្បូណ៌ព្រៃគុក(ខេត្តកំពង់ធំ) ត្រូវបានកសាងឡើងនាសម័យកាលនោះ។

អ្នកប្រាជ្ញបារាំងលោក Bernard Philippe Groslier បានសរសេរថា ៖ «មហន្តរាយដែលបណ្ដាលមកពីទឹកជំនន់បានបំផ្លាញទីក្រុង និងប្រព័ន្ធបញ្ចូលទឹកក្នុងស្រែ ហើយបង្ខំឱ្យប្រជារាស្ត្រភៀសខ្លួនទៅរស់នៅត្រង់ដីខ្ពស់នៅភាគខាងជើង ពេលនោះកូសាំងស៊ីនក៏ក្លាយទៅជាវាលល្បប់មួយស្ងាត់ជ្រងំ។ ប្រហែលជាឆ្លៀតឱកាសនេះហើយដែលព្រះបាទ **ភវវរ្ម័ន** បានវាយយកប្រទេស **ហ្វូណន** នៅប្រមាណឆ្នាំ៥៥០ ដើម្បីបង្កើត **រាជាណាចក្រខ្មែរ**» ។

យ៉ាងណាមិញយើងឃើញថា ទំនាស់រាជបល្ល័ង្ក ទំនាស់ខាងសាសនា និងមហន្តរាយធម្មជាតិ គឺជាបុព្វហេតុបង្គ្រប់ទៅវិញទៅមកក្នុងចម្បាំងរវាងចេនឡា និងអាណាចក្រភ្នំ។ នៅពាក់កណ្ដាលទី២នៃស.វ.ទី៦ ព្រះបាទ **ភវវរ្ម័ន** និងប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាម **ចិត្រសេន** បានវាយលុកយកអាណាចក្រភ្នំ ចាប់តាំងពីខេត្តក្រចេះ ដល់បុរីរម្យនៅចន្លោះទន្លេមូល និងជួរភ្នំដងរែក និងដល់មង្គលបុរី។ អាណាចក្រភ្នំក៏លើករាជធានីចេញពីវ្យាធបុរៈទៅតាំងនៅទិសខាងត្បូង គឺនៅត្រង់ **នរវរនគរ** គឺនៅត្រង់ **អង្គរបុរី** ក្នុងខេត្តតាកែវ។

បន្ទាប់ពីព្រះបាទ **ភវវរ្ម័ន** សោយទិវង្គត ព្រះបាទ **ចិត្រសេន** បានឡើងសោយរាជ្យនៅឆ្នាំ៦០០ ដោយយកព្រះនាមថា **មហេន្ទ្រវរ្ម័ន** ។ បុត្ររបស់ព្រះអង្គគឺព្រះបាទ **ឦសានវរ្ម័ន** បានឡើងសោយរាជ្យនៅឆ្នាំ៦១៦។ ព្រះអង្គបានបញ្ចប់សង្គ្រាមជាមួយអាណាចក្រភ្នំដោយវាយយករាជធានី **នរវរនគរ** (**អង្គរបុរី**) ប្រមាណនៅឆ្នាំ៦៣០។ ព្រះបាទ **ឦសាន**

[13] Coedès (1968) The Indianized States of South-East Asia, East-West Center Press, p.66.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ភវវរ្ម័ន** បានតាំងរាជធានីនៅ **ល្វៀសានបុរៈ** ដែលជារមណីយដ្ឋាន **សម្បូណ៌ព្រៃគុក** នៅក្នុងខេត្តកំពង់ធំ ដែលជារាជធានីដំបូងបង្អស់របស់នគរភ្នំ និងចេនឡារួមគ្នា ហើយដែលលេចធ្លោឡើងនៅស.វ.ទី៧ តាមដងស្ទឹងសែន។ ស្ដេចដែលសោយរាជ្យក្រោយព្រះអង្គគឺព្រះបាទ **ភវវរ្ម័នទី២** ។ ព្រះបាទ **ជ័យវរ្ម័នទី១** (៦៥៧-៦៨១) ដែលជាបុត្រព្រះបាទ **ភវវរ្ម័នទី២** បានឡើងសោយរាជ្យនៅមុនឆ្នាំ៦៥៧ ហើយបានសាងសង់ប្រាសាទនៅតំបន់ **វ្យាធបុរៈ** និងនៅ **វត្តភូ** ។

តាមប្រភពឯកសាររបស់លោក Adhémar Leclère នៅចុងស.វ.ទី៧នៃគ.ស. ប្រទេសឥណ្ឌាមានឥទ្ធិពលយ៉ាងខ្លាំងមកលើ **អាណាចក្រខ្មែរ** ដោយសារបណ្ដាក្រុមឧបនិវេសន៍ដែលនាំយកអារ្យធម៌មកផ្សព្វផ្សាយនៅទីនេះបន្តិចម្ដងៗគឺក្រុមឧបនិវេសន៍ហិណ្ឌូ ហើយរាជវង្សស្ដេចដែលសោយរាជ្យនៅអាណាចក្រខ្មែរសុទ្ធតែជាប់អម្បូរក្សត្រិយ៍ឬព្រាហ្មណ៍ និងម្យ៉ាងទៀតសាសនាដែលគេគោរពគឺព្រហ្មញ្ញសាសនាឬព្រះពុទ្ធសាសនា[14]។ ច្បាប់ទម្លាប់ប្រពៃណី ដែលគេអនុវត្តសុទ្ធតែមានប្រភពចេញមកពីឥណ្ឌា។ គេគោរពបូជាអាទិទេពរបស់ឥណ្ឌា គេអានសៀវភៅឥណ្ឌា។ ពួកព្រាហ្មណ៍មកតាំងទីលំនៅក្នុងឥណ្ឌូចិនដោយស្ម័គ្រចិត្ត ព្រោះអ្នកស្រុកអនុវត្តតាមទ្រឹស្ដីរបស់គេ ហើយលើកកូនក្រមុំឱ្យគេទៀតផង។

នៅសម័យចេនឡា លទ្ធិព្រហ្មញ្ញសាសនាមានការវិវត្ត ដោយសារប្រជាជនគោរពនូវទេវរូបទាំងបី គឺ ព្រះឥសូរ ព្រះវិស្ណុ និងព្រះហរិហរៈ។

ព្រះពុទ្ធសាសនាមហាយាននៅសម័យចេនឡារុងរឿងណាស់ តែគេពុំសូវឃើញមានបដិមាពោធិសត្វអវលោកេស្វរៈទេ មានមួយនៅខេត្តក្រមួនស និងមួយទៀតនៅប្រាសាទសាកៀម ខេត្តសៀមរាប។ ចំណែកលទ្ធិហីនយានក៏មិនសាបសូន្យដែរ។

នៅដើមស.វ.ទី៨ (៧០៦) អាណាចក្រចេនឡាត្រូវបែងចែកជាពីរ ដោយសារតែអំណាចកណ្ដាលចុះខ្សោយ ៖ ភាគខាងជើងហៅថា **ចេនឡាដីគោក** ជាតំបន់ភ្នំ និងជ្រលងភ្នំ(ប្រទេសឡាវភាគកណ្ដាល) និងភាគខាងត្បូងហៅថា **ចេនឡាទឹកលិច** ដែលមានតំបន់សម្បូរដោយបឹង និងមានសមុទ្រព័ទ្ធជុំវិញ(ពីអាងទន្លេមេគង្គត្រង់ល្បាក់ខោនដល់សមុទ្រ)។ របបចេនឡាបានបែកបាក់ខ្ចាយទៅជារដ្ឋតូចៗគ្មានលំនឹង។

### *១.១.១.៣. សាសនានៅក្នុងប្រព័ន្ធអប់រំខ្មែរបុរាណ*

កម្ពុជាបានទទួលអរិយធម៌ឥណ្ឌាតាំងពីបុរាណកាល។ អ្នកប្រាជ្ញជឿថា ឥណ្ឌានីយកម្មនៃអាណាចក្រហ្វូណន ដែលជាមជ្ឈមណ្ឌលនៃទំនាក់ទំនងពាណិជ្ជកម្មនៅតំបន់អាស៊ីអាគ្នេយ៍ ចាប់ផ្ដើមនៅស.វ.ទី១ នៃយុគសម័យគ្រិស្តសាសនា ដោយសារគេបានរកឃើញវត្ថុបុរាណខាងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ ប្រការនេះមានន័យថា ជនជាតិខ្មែរខ្លះ

[14] Leclère, A. (1914), Histoire du Cambodge, Paris.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោរពព្រហ្មញ្ញសាសនា តែខ្លះទៀតគោរពពុទ្ធសាសនាមហាយាន។ អក្សរខ្មែរក៏ចាប់ផ្ដើមមានរូបរាងតាំងពីសម័យនោះមក ដោយមានសណ្ឋានរូបរាងស្រដៀងគ្នានឹងអក្សរឥណ្ឌាភាគខាងត្បូង។ ព្រហ្មញ្ញសាសនាគឺជាសាសនាលេចធ្លោចាប់ពីស.វ.ទី១ ដល់ទីស.វ.១៤។ តាមរយៈការហូរចូលនូវព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ប្រព័ន្ធអប់រំតាមបែបព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាត្រូវបានបង្កើតឡើង។ ដូចនៅតាមប្រទេសឯទៀតក្នុងសកលលោកដែរ បរិស័ទនៃសាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនាមិនត្រឹមតែផ្សព្វផ្សាយលទ្ធិសាសនាប៉ុណ្ណោះទេ ពួកគេក៏ផ្សព្វផ្សាយផងដែរនូវសមិទ្ធផលក្នុងវិស័យស្ថាបត្យកម្ម តារាសាស្ត្រ គណិតវិទ្យា និងវិទ្យាសាស្ត្រដទៃទៀត។

*ក. ព្រហ្មញ្ញសាសនា*

ព្រហ្មញ្ញសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌា នៅស.វ.ទី១០ មុនគ.ស.។ ជនជាតិខ្មែរចាប់ផ្ដើមគោរពព្រហ្មញ្ញសាសនាចាប់តាំងពី គ.ស.ទី១ តាមរយៈការផ្សព្វផ្សាយរបស់ឈ្មួញសំពៅជាតិឥណ្ឌា ដែលបានមកធ្វើជំនួញនៅអាណាចក្រខ្មែរ និងបានប្រាស្រ័យទាក់ទង លក់ដូរទំនិញជាមួយអ្នកស្រុក[15]។ ដូច្នេះពាណិជ្ជកម្មមិនគ្រាន់តែមានតួនាទីផ្លាស់ប្ដូរទំនិញរវាងជនជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយមួយដ៏សំខាន់ក្នុងការផ្សព្វផ្សាយភាសា អារ្យធម៌ និងទំនៀមទម្លាប់រវាងជនជាតិផ្សេងៗផងដែរ។ ម្ល៉ោះហើយ ឥទ្ធិពលសាសនាព្រាហ្មណ៍ ក៏បានជ្រួតជ្រាបចូលក្នុងសង្គមខ្មែរ ជាពិសេសក្នុងស្រទាប់បញ្ញវន្ត និងមន្ត្រីរាជការក្នុងប្រទេស។

រឿងនិទានខ្មែរបានរៀបរាប់ពីការចងស្ពានមានមេត្រី រវាងព្រះមហាក្សត្រីយ៍ខ្មែរជំនាន់ដើម នៅពាក់កណ្ដាលទី១ នៃ គ.ស. គឺព្រះនាងលីវយី ដែលលើកទ័ពទៅទប់ទល់នឹងទ័ពសំពៅឥណ្ឌា ក្រោមបញ្ជាការរបស់ព្រះបាទហ៊ុនទៀនដែលជាព្រាហ្មណ៍ ដែលបានចូលមកក្នុងទឹកដីខ្មែរដំបូង។ បន្ទាប់ពីទទួលបានជ័យជម្នះរួចមក ព្រះបាទហ៊ុនទៀនបានប្រកាសខ្លួនជាស្ដេចផែនដី និងបានរៀបព្រះរាជាពាហ៍ពិពាហ៍ជាមួយព្រះនាងលីវយី។ ចាប់ពីពេលនោះមក ព្រះបាទហ៊ុនទៀនបានរៀបចំប្រព័ន្ធគ្រប់គ្រងទឹកដី ទៅតាមទស្សនៈរាជាធិបតេយ្យបែបព្រាហ្មណ៍។

ព្រះបាទហ៊ុនទៀនបានលើកតម្កើងព្រាហ្មណ៍ច្រើនរូបឱ្យកាន់កិច្ចការរាជការ និងទទួលបាននូវឋានៈខ្ពង់ខ្ពស់។ ប្រការនេះបានពង្រីកឥទ្ធិពលនៃលទ្ធិព្រហ្មញ្ញសាសនាឱ្យរីកដុះដាលកាន់តែខ្លាំងឡើងថែមទៀត ជាពិសេសក្នុងចំណោមសិល្បករ បញ្ញវន្ត និងមន្ត្រីរាជការជាន់ខ្ពស់។ ម្យ៉ាងវិញទៀត ដោយសារព្រះរាជាច្រើនអង្គនៅអាណាចក្រខ្មែរបុរាណ

[15] ប្រភព ៖ ព្រះភិក្ខុប៉ាំងខាត់ (១៩៦០) «ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ, ទំព័រ១១-១៦។ Coedès (1964), Les Etats hindouisés d’ Indochine et d’Indonésie, paris, p.45.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោរពបូជាយ៉ាងខ្ជាប់ខ្ជួននូវព្រហ្មញ្ញសាសនា ធ្វើឱ្យសាសនានេះមានការរីកចម្រើនយ៉ាងខ្លាំងក្លា។

ប្រាសាទព្រហ្មញ្ញសាសនាត្រូវបានសាងសង់ឡើងដើម្បីរក្សាទុកសិវលិង្គ សម្រាប់ជាទីសក្ការបូជាតាមលទ្ធិព្រហ្មញ្ញសាសនា និងលទ្ធិទេវរាជនេះ។ ក៏ប៉ុន្តែប្រជាជននៅតាមតំបន់នោះក៏គោរពនូវព្រះពុទ្ធសាសនា និងលទ្ធិជីវចលផងដែរ។ **លទ្ធិជីវចល** គឺជំនឿលើព្រលឹង វត្ថុស័ក្តិសិទ្ធិ អ្នកតាព្រៃភ្នំ ឬដើមឈើដែលតែងតែការពារដល់មនុស្សលោក។ នៅសម័យនោះ ព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងលទ្ធិជីវចលឥតមានបៀតបៀនគ្នាទេ។ ក៏ប៉ុន្តែចាប់តាំងពីស.វ.ទី១០ មក គេឃើញព្រះរាជា និងមន្ត្រីធំៗកាន់សាសនាមិនសូវស្រប គ្នាទេ។ ប្រសិនបើព្រះរាជាកាន់ព្រហ្មញ្ញសាសនា មន្ត្រីធំៗច្រើនកាន់ព្រះពុទ្ធសាសនា ហើយប្រសិនបើព្រះរាជាកាន់ព្រះពុទ្ធសាសនា មន្ត្រីធំៗកាន់ព្រហ្មញ្ញសាសនាវិញ។

នៅពេលដែលអាណាចក្រខ្មែរស្គាល់នូវភាពរុងរឿង សាសនាទាំងពីរគឺព្រហ្មញ្ញសាសនា និងពុទ្ធសាសនាចេះរួមរស់ជាមួយគ្នា ប្រកបដោយសុខដុមរមនាអស់រយៈកាលដ៏យូរលង់។ លុះដល់ស.វ.ទី១៣ ពុទ្ធសាសនាមហាយានបានបាត់បង់។ ដល់ស.វទី១៤ ព្រហ្មញ្ញសាសនាក៏បាត់បង់ទៀត ដោយពុទ្ធសាសនាហីនយានបានចូលមកដល់។ នៅពេលនោះ គេចាប់ឃើញថា ប្រជាជនខ្មែរភាគច្រើនគោរពនូវព្រះពុទ្ធសាសនាហីនយាន តែមន្ត្រីធំៗនៅគោរពសាសនាព្រាហ្មណ៍។ សង្គ្រាមសាសនានៅសម័យក្រោយអង្គរគឺជាមូលហេតុមួយ ដែលធ្វើឱ្យខ្មែរចុះខ្សោយ និងបាត់បង់នូវឯកភាពជាតិ។

*ខ. ព្រះពុទ្ធសាសនា*

ព្រះពុទ្ធសាសនាមានដើមកំណើតនៅឥណ្ឌាក្រោយព្រហ្មញ្ញសាសនា ដែលកើតឡើងនៅក្នុងស.វទី៦ មុនគ.ស.។ នៅក្នុងរជ្ជកាលព្រះបាទអសោក (ឆ្នាំ២៧៣-២៣២ មុនគ.ស.) ព្រះពុទ្ធសាសនាត្រូវបានរីកផ្សព្វផ្សាយទាំងនៅប្រទេសឥណ្ឌា ទាំងខាងក្រៅប្រទេសតាមរយៈឈ្មួញឥណ្ឌា ដែលធ្វើពាណិជ្ជកម្ម និងផ្សព្វផ្សាយវប្បធម៌ និងអារ្យធម៌ឥណ្ឌានៅកន្លែងផ្សេងៗក្នុងពិភពលោក ជាពិសេសនៅអាណាចក្រភ្នំ។ នៅឆ្នាំ ២៥៣ មុនគ.ស. ព្រះថេរមហិន្ទ្រៈដែលជាបុត្រ ឬជាអានុជរបស់ព្រះបាទអសោក បាននាំយកព្រះពុទ្ធសាសនា **ថេរវាទ** ទៅផ្សព្វផ្សាយនៅកោះលង្កា។ ឯកសារប្រវត្តិសាស្ត្រមិនបានកំណត់ច្បាស់ថាព្រះពុទ្ធសាសនាថេរវាទនេះបានចូលមកប្រតិស្ឋានក្នុងអាណាចក្រខ្មែរឱ្យច្បាស់តាមណាទេ។ ប្រភពខ្លះបាននិយាយថា ព្រះពុទ្ធសាសនា **ថេរវាទ** ត្រូវបានផ្សព្វផ្សាយជាលើកដំបូងនៅកោះលង្កា បន្ទាប់មកទើបគេយកមកផ្សព្វផ្សាយនៅអាណាចក្រភ្នំ។ ប្រភពខ្លះបានអះអាងថា ព្រះពុទ្ធសាសនាត្រូវបានព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរជាបឋមសមណទូតនៃព្រះមហាថេរមោគ្គល្លីបុត្តបានផ្សព្វផ្សាយ នៅដែនសុវណ្ណភូមិនេះក្នុងឆ្នាំ៣០៦ មុនគ.ស. ក្រោមសាសនូបត្ថម្ភរបស់ព្រះបាទអសោក។ មានប្រភពខ្លះបានលើកឡើងថា ព្រះពុទ្ធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាសនាចូលមកដែនដីខ្មែរ ក្នុងរជ្ជកាលព្រះបាទស្រីមារៈ ឬ ព្រះបាទហ្វាន់ចេម៉ន ក្នុងគ្រិស្តសតវត្សរ៍ទី២ [16]។

| លទ្ធិ | ហីនយាន | មហាយាន |
|---|---|---|
| បំណងប្រាថ្នាមនុស្ស | យកព្រះអរហត្ត និងព្រះនិព្វាន | ទៅជាព្រះពោធិសត្វ ដែលមានពោធិញាណជាទីបំផុត |
| ព្រះនិព្វាន | បានដោយបុញ្ញកិរិយាវត្ថុ គឺសីលទាន និងការភាវនា | ដោយសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា |
| ការសម្រេចគោលដៅ | មានតែភិក្ខុទេ ដែលអាចទៅដល់ព្រះអរហត្ត | ទៅជាយរាវាស ក៏បានដល់ទីពោធិសត្វដែរ |
| កុសល | ខ្លួនទីពឹងខ្លួន ៖ កុសលដែលអ្នកណាបានធ្វើនឹងនាំអ្នកនោះឱ្យរួចចាកទុក្ខ | កុសលរបស់ខ្លួនអាចនឹងផ្សព្វផ្សាយដល់អ្នកដទៃ |

នៅក្នុងរជ្ជកាលព្រះបាទកនិស្កៈ (ឆ្នាំ ៧៨ ដល់ ១០៥ នៃគ.ស.) ពុទ្ធសាសនាបានបែកជាពីរនិកាយគឺ **ហីនយាន** និង **មហាយាន**។ បុព្វហេតុចម្បងនៃការបែកជានិកាយពីរនេះ គឺបណ្ដាលមកពីការប៉ះទង្គិចគ្នារវាងព្រហ្មញ្ញសាសនា និងពុទ្ធសាសនា។ ពុទ្ធសាសនាដើម គឺ**ហីនយាន** មានវិន័យតឹងរ៉ឹង ធ្វើឱ្យអ្នកបួសកម្រសម្រេចបានដូចបំណង បើប្រៀបធៀបនឹងព្រហ្មញ្ញសាសនា ដែលឆាប់សម្រេចជាង ។ ដូច្នេះ គណៈសង្ឃខ្លះបានបែកចេញពីពុទ្ធសាសនាដើម ក្នុងគោលដៅកែប្រែលទ្ធិខ្លះ ដើម្បីសម្រេចបានគោលដៅឱ្យលឿនកុំឱ្យចាញ់ព្រហ្មញ្ញសាសនា ដែលគេហៅថា **មហាយាន** (កង់ធំ)។ លទ្ធិពុទ្ធសាសនាមហាយានមានអាទិភាព គឺព្រះពោធិសត្វទៅជួយគ្រប់គ្រង។

## ១.១.២. ស្ថាបត្យកម្មខ្មែរបុរាណ

អារ្យធម៌ខ្មែរបានឈានដល់កម្រិតកំពូលចាប់ពីស.វ.ទី១១ ដល់ស.វ.ទី១៣។ នៅពេលនោះ ព្រះមហាក្សត្រខ្មែរបានកសាងប្រាង្គប្រាសាទជាច្រើន ដើម្បីឧទ្ទិសដល់ព្រះអាទិទេព ឬបុព្វការីជនរបស់ព្រះអង្គ និងដើម្បីធានាឱ្យបាននូវវិបុលភាព និងឯកភាពជាតិខ្មែរ។

ការសាងសង់ប្រាសាទបុរាណខ្មែរមានការវិវត្ត និងកែលម្អជាប្រចាំ ដែលឆ្លុះបញ្ចាំងពីដំណាក់កាល *យុវវ័យ ភាពចាស់ទុំ* និង *ជរាភាព*។ អ្នកដែលសិក្សាសិល្បៈខ្មែរបានបែងចែកប្រាសាទបុរាណខ្មែរ ជាស្ថាបត្យកម្ម **មុនសម័យបុរាណ** (ពីស.វ.ទី១ ដល់ស.វ.ទី៨) ស្ថាបត្យកម្ម **សម័យអង្គរ** (ពីស.វ.ទី៩ ដល់ស.វ.ទី១៣) និងស្ថាបត្យកម្ម **ក្រោយ**

[16] ប៉ាងខាត់ (១៩៦០)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**សម័យអង្គរ** (ពីស.វ.ទី១៤ ដល់សព្វថ្ងៃនេះ)។ លោក Claude Jacques បានគូសបញ្ជាក់ថា សិល្បៈខ្មែរបានវិវត្តទៅតាមវិធីសាស្ត្របួនយ៉ាង គឺ៖

ទីមួយ-តក្កកម្ម មានន័យថា ការបង្កើតអ្វីៗថ្មីទាំងស្រុង។

ទីពីរ-ការចូលរួមវិភាគទានពីសិល្បៈបរទេស (គឺពីសិល្បៈឥណ្ឌា តែក៏មានសារធាតុខ្លះនៃសិល្បៈជ្វា និងសិល្បៈចាមដែរ)។

ទីបី-ការខ្ចីនូវរចនាបថពីអតីតកាល តែមិនបានចម្លងទាំងស្រុងនូវរចនាបថទេ ដោយគ្រាន់តែស្វែងរកប្រធានបទចាស់ៗ ដើម្បីបញ្ចូលសាជាថ្មី ដោយមានធ្វើវិសោធនកម្មនៅលើអ្វីដែលមានចាស់។

ទីបួន-ការចម្លងតាមនូវបច្ចេកទេសផ្សេងៗ ហើយអ្វីដែលគេច្រើនជួបប្រទះ គឺការចម្លងតាមនូវក្បូរក្បាច់រចនានៃសំណង់ឈើតូចតាច។

ដោយឈរលើមូលដ្ឋាននៃការសិក្សានូវលក្ខណៈពិសេសខាងផ្នែកស្ថាបត្យកម្ម ឬក្បាច់រចនាផ្សេងៗ លោក Philippe Stern[17] **និង** Gilbert de Coral-Rémusat[18] បានបង្កើតបានជាបញ្ជីរចនាបថចំនួន១៣ ដោយដាក់ឈ្មោះតាមប្រាសាទសំខាន់ៗនិងមានលក្ខណៈពិសេស ហើយដែលតំណាងឱ្យរចនាបថសម័យនោះ។ តាមរយៈការសិក្សារូបចម្លាក់ លោក Jean Boisselier[19] និង Pierre Dupont បានបន្ថែមនូវរចនាបថពីរទៀត គឺរចនាបថភ្នំដា និងរចនាបថប្រាសាទអណ្តែត។ ដូច្នេះ សិល្បៈខ្មែរបានវិវត្តទៅតាមរចនាបថចំនួន១៥។ យើងឃើញថា សិល្បៈខ្មែរក្នុងដំណាក់កាលដំបូងស្ថិតនៅក្នុងសភាពក្មេងខ្ចីនៅឡើយ ហើយខ្ចីពីសិល្បៈឥណ្ឌាយ៉ាងច្រើន ដោយពុំទាន់ស្លូឱ្យចេញជាអត្តសញ្ញាណជាតិខ្មែរ ឱ្យបានទាំងស្រុងនៅឡើយ។

## ទី១-ស្ថាបត្យកម្មមុនសម័យអង្គរ

រចនាបថមុនសម័យអង្គរមាន រចនាបថភ្នំដា រចនាបថសម្បូណ៌ព្រៃគុក រចនាបថព្រៃក្មេង រចនាបថប្រាសាទអណ្តែត រចនាបថកំពង់ព្រះ និងរចនាបថគូលែន។

### ១. រចនាបថ ភ្នំដា

សិល្បៈខ្មែរនៃរចនាបថភ្នំដានៅក្នុងចន្លោះស.វ.ទី៦ និងដើមស.វ.ទី៧ គឺជាសិល្បៈដែលនៅក្មេងខ្ចីនៅឡើយ។ ប្រាសាទភ្នំដាជាប្រាសាទឥដ្ឋ ដែលសង់លើកំពូលភ្នំនៃខេត្តតាកែវ លើខឿនថ្មបាយក្រៀមដែលបន្ទុបលើខឿនប្រាសាទ ហើយមានប្រអប់ទ្វារធ្វើពីថ្ម។ គេបានរកឃើញនូវសសរពេជ្រផងដែរ។ ក៏ប៉ុន្តែ បើតាមមតិរបស់បណ្ឌិត **មីសែល ត្រាណេ**

[17] Stern, Philippe. (1923), Le Bayon d’Angkor et l’évolution de l’art khmer, in Étude et discussion de la chronologie des monuments khmers. Annales du Musée Guimet, Biblio. de Vulgarisation, 47. Paris, Paul Geuthner.
[18] Coral-Rémusat, G. de (1951), L’Art Khmer. Les grandes étapes de son évolution. Études d’art et d’éthnologie asiatique I. Paris. (2 ème édition).
[19] Boisselier, Jean. (1956), Tendances de l’art khmer : Commentaires sur 24 chefs d’œuvre du Musée de Phnom Penh, Presse Universitaires de France, Paris.


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាសាទភ្នំដានេះមិនមែនសាងសង់ឡើងនាស.វ.ទី៥ ឬទី៦ ទេ តែគឺនៅស.វ.ទី១១ ទៅវិញ ដោយសង់លើខឿនប្រាសាទចាស់មួយនាសម័យនគរភ្នំ។ ចំណែករូបចម្លាក់បីនៃរចនាបថមុនអង្គរ ពោលគឺក្នុងសម័យនគរភ្នំ ដែលរកឃើញនៅក្នុងប្រាសាទ ដែលមានលក្ខណៈធម្មជាតិនិយម និងពិសិដ្ឋនិយមគឺ ៖ ព្រះវិស្ណុដៃ៨ មួយអង្គ និងពុទ្ធបដិមា ២អង្គដែលមានស្លាកស្នាមវប្បធម៌ឥណ្ឌា-ក្រិក។

ដូច្នេះ លោក Jean Boisselier បានចាត់ថ្នាក់រចនាបថភ្នំដា ដោយឈរលើមូលដ្ឋាននៃរូបបដិមាតែប៉ុណ្ណោះ។

## ២. រចនាបថ សម្បូណ៌ព្រៃគុក

ប្រាសាទ **សម្បូណ៌ព្រៃគុក** ស្ថិតនៅក្នុងខេត្តកំពង់ធំ។ ប្រាសាទនេះសាងសង់ឡើងនៅស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទ **ឦសានវរ្ម័ន** ដែលបានតាំងរាជធានីនៅ **ឦសានបុរៈ** ដែលជារាជធានីដំបូងបង្អស់របស់នគរភ្នំ និងចេនឡារួមគ្នា ហើយដែលប្រវត្តិវិទូបានចាត់ទុកថា ជាដើមកំណើតនៃអាណាចក្រខ្មែរ។ ប្រាសាទ **សម្បូណ៌ព្រៃគុក** ចែកជាពីរក្រុម ៖ ក្រុមទី១ សាងសង់នៅក្នុងស.វ.ទី៧ ហើយក្រុមទី២ សាងសង់នៅពេលក្រោយ។ ចំណុចសំខាន់នៃប្រាសាទ **សម្បូណ៌ព្រៃគុក** គឺវត្តមាននៃស្លាកស្នាមដ៏ច្រើនលើសលប់នៃវប្បធម៌ឥណ្ឌា។ រូបបដិមាព្រះនាងទុគ៌ា ដែលរកឃើញនៅក្នុងប្រាសាទបង្ហាញឱ្យឃើញពីសម្រស់ និងរូបរាងស្ត្រីឥណ្ឌាតែម្តង។

## ៣. រចនាបថ ព្រៃក្មេង

បន្តិចម្តងៗ ស្ថាបត្យករបុរាណខ្មែរបានច្នៃប្រឌិតផ្តែរទ្វារ ដែលវិវត្តទៅតាមរចនាបថដូចជាផ្តែរទ្វារនៃរចនាបថ **ព្រៃក្មេង** ក្នុងពាក់កណ្តាលទី២ នៃស.វ.ទី៧ (ពីឆ្នាំ៦៣៥ ដល់៧០០)។ រចនាបថ **ព្រៃក្មេង** ចាប់ផ្តើមពីពេលដែលព្រះបាទ **ភវវរ្ម័នទី២** បានឡើងសោយរាជ្យ បន្ទាប់ពីព្រះបាទ **ឦសានវរ្ម័ន** បានចូលទិវង្គតនៅក្នុងឆ្នាំ៦៣៥។ ពេលនោះគឺជាសតវត្សរ៍ដែលអាណាចក្រចេនឡាកំពុងរីកចម្រើន ដោយឆ្លុះបញ្ចាំងតាមរយៈការខិតខំប្រឹងប្រែងរបស់សិល្បករ ក្នុងការស្វែងរកសុក្រឹតភាពនៃសមាមាត្រ និងសមតា។ ប្រាសាទនៃរចនាបថព្រៃក្មេងមាន ប្រាសាទព្រៃក្មេង ប្រាសាទស្វាយព្រាម ប្រាសាទបាសិត ប្រាសាទព្រៃប្រាសាទ និងប្រាសាទភ្នំបាយង់។

## ៤. រចនាបថ ប្រាសាទអណ្តែត

រចនាបថ **ប្រាសាទអណ្តែត** មានរយៈកាលជំនាន់រចនាបថ **ព្រៃក្មេង** ដែរ។ ក្រោយពីព្រះបាទ**ភវវរ្ម័នទី២** សោយទិវង្គតទៅ ព្រះបាទ **ជ័យវរ្ម័នទី១** (៦៥៧-៦៨១) ដែលជាបុត្រ បានឡើងសោយរាជ្យនៅមុនឆ្នាំ៦៥៧។ ស្នាដៃវិចិត្រជាងគេដែលឆ្លុះបញ្ចាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីរចនាបថ **ប្រាសាទអណ្ដែត** គឺរូបចម្លាក់ **ហរិហរៈ** នៃប្រាសាទអណ្ដែត ដែលស្ថិតនៅក្នុងសារមន្ទីរជាតិនៃទីក្រុងភ្នំពេញ។

## ៥. រចនាបថ កំពង់ព្រះ

ប្រាសាទ **ភូមិប្រាសាទ** និងប្រាសាទ **កំពង់ព្រះ** ដែលសាងសង់នៅក្នុងស.វ. ទី៨ នៅពេលដែលចេនឡាត្រូវបានបែងចែកជាពីរ (ចេនឡាដីគោក និងចេនឡាទឹកលិច) គឺជាតំណាងនៃរចនាបថ **កំពង់ព្រះ**។ សិល្បៈខ្មែរឆ្លុះបញ្ចាំងពីភាពបែកបាក់នេះដោយការរលត់បាត់អស់នូវវិញ្ញាណ នៅសល់តែភាពសាមញ្ញដែលខ្វះភាពច្នៃប្រឌិត។ ប្រាសាទនៃរចនាបថកំពង់ព្រះមាន ៖ ប្រាសាទកំពង់ព្រះ (កំពង់ឆ្នាំង) ប្រាសាទអកយំ ប្រាសាទត្រពាំងផុង និងប្រាសាទភូមិប្រាសាទ (កំពង់ធំ)។

## ៦. រចនាបថ គូលែន

រចនាបថ **គូលែន** គឺជាដំណាក់កាលនៃការរស់ឡើងវិញនៃសិល្បៈជាតិ ដែលបង្ហាញពីការបង្កើតឡើងថ្មី និងតក្កកម្មយ៉ាងផុសផុល។ រចនាបថនេះឆ្លុះបញ្ចាំងឱ្យឃើញនូវកម្ចីពីរចនាបថមុនៗ ហើយកែច្នៃបន្ត និងបង្ហាញពីភាពច្នៃប្រឌិតរស់រវើក តាមរយៈការបំផ្លែងលំនាំក្បាច់រចនា និងជវភាព ដែលរក្សាបាននូវតុល្យភាពយ៉ាងសុក្រឹតនៃរចនាបថគូលែន។ ព្រះបាទ **ជ័យវរ្ម័នទី២** បានសាងសង់ប្រាសាទជាច្រើននៃរចនាបថគូលែន ដូចជាប្រាង្គ (សេ១) នៅសម្បូណ៌ព្រៃគុក ប្រាសាទនៅបន្ទាយព្រៃនគរ ប្រាង្គខាងជើងនៃប្រាសាទព្រៃប្រាសាទ ប្រាសាទដំរីក្រាប ប្រាសាទអូរផ្អុង ប្រាសាទខ្ទឹងស្លាប់ ប្រាសាទរូបអារក្ស ប្រាសាទថ្មដាប់ ប្រាសាទគគីរ ប្រាសាទក្រហម និងប្រាសាទអ្នកតា។

ព្រះបាទ **ជ័យវរ្ម័នទី២** ទ្រង់គង់នៅលើភ្នំគូលែនបានមួយរយៈ ទើបយាងមកតាំងរាជធានីនៅ **ហរិហរាល័យ** វិញ ដោយនាំយកលិង្គទេវរាជមកជាមួយផង។ ព្រះអង្គសោយទិវង្គតនៅ **ហរិហរាល័យ** នៅគ.ស.៨៥០ ដោយទទួលមរណនាមថា **បរមេស្វរៈ**។

## ទី២-ស្ថាបត្យកម្មសម័យអង្គរ

រចនាបថសម័យអង្គរចែកចេញជា **មុន-បុរាណនិយម** មានរចនាបថព្រះគោ រចនាបថភ្នំបាក់ខែង រចនាបថកោះកេរ និងរចនាបថប្រែរូប។ ចំណែករចនាបថ **បុរាណនិយម** មានរចនាបថបន្ទាយស្រី រចនាបថឃ្លាំង រចនាបថបាពួន និងរចនាបថអង្គរវត្ត។

## ៧. រចនាបថ ព្រះគោ

ប្រាសាទនៃរចនាបថ **ព្រះគោ** កសាងឡើងនៅក្នុងរជ្ជកាលនៃព្រះបាទ **ឥន្ទ្រវរ្ម័នទី១** ដែលឡើងគ្រងរាជសម្បត្តិនៅក្នុងគ.ស.៨៧៧។ ព្រះអង្គបានរៀបចំឱ្យជីកបារាយណ៍ឥន្ទ្រតដាក នៅខាងជើងរាជធានី ដើម្បីបម្រើឱ្យសាសនាផង និងប្រព័ន្ធស្រោចស្រពផង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះអង្គបានកសាងប្រាសាទព្រះគោលើដីរាបនៅក្នុងឆ្នាំ៨៧៩ និងបានកសាងប្រាសាទភ្នំលើកទី១ ដោយប្រើថ្មភក់ គឺប្រាសាទបាគងនៅឆ្នាំ៨៨១។ ក្បាច់រចនាផ្តែរនៃប្រាសាទទាំងពីរនេះបានឈានដល់កម្រិតគុណភាពមួយ ដែលមិនទាន់មានប្រាសាទណាល្អលើសទេ។

## ៨. រចនាបថ បាខែង

រចនាបថ **បាខែង** គឺជាប្រាសាទដែលបានសាងសង់នៅចុងស.វ.ទី៩ និង ដើមស.វ.ទី១០។ ព្រះបាទ **យសោវរ្ម័ន** បានចាកចេញពី **ហរិហរាល័យ** (រលួស) ហើយមកសង់រាជធានីនៅ **យសោធបុរៈ** (អង្គរទី១) ដោយជ្រើសរើសយកភ្នំមួយ ដើម្បីសង់ប្រាសាទ **ភ្នំបាខែង** ដែលស្ថិតនៅចំកណ្តាលរាជធានី សម្រាប់តម្កល់សិវលិង្គ **យសោធរេស្វរៈ** (គ.ស. ៨៩៣)។ ប្រាសាទនៃរចនាបថបាខែងមានប្រាសាទភ្នំបាខែង ប្រាសាទភ្នំក្រោម និងប្រាសាទភ្នំបូក។ រចនាបថ **បាខែង** បានបន្តនូវប្រពៃណីនៃរចនាបថ **ព្រះគោ** ប៉ុន្តែបានបោះបង់ចោលឥដ្ឋ ដោយយកថ្មភក់ និងថ្មបាយក្រៀមទៅសាងប្រាសាទវិញ។

## ៩. រចនាបថ កោះកេរ

ព្រះបាទ **ជ័យវរ្ម័នទី៤** បានឡើងសោយរាជ្យនៅឆ្នាំ៩២៨ ហើយបានលើករាជធានីពី **យសោធបុរៈ** ទៅកាន់ **កោះកេរ** វិញ។ ប្រាសាទនៃរចនាបថ **កោះកេរ** ត្រូវបានសាងសង់ចាប់ពីឆ្នាំ៩២១ ដល់៩៤៤។ រូបចម្លាក់ធំៗនៃរចនាបថកោះកេរចាប់ផ្តើមបង្ហាញពីរូបមានចលនា ដូចជារូបព្រះសិវៈរាំ រូបគ្រុឌដើរ រូបចំបាប់រវាងសុគ្រីព និងពាលី រូបចំបាប់ រវាងយក្ខនិងទេវតាជាដើម។ ប្រាសាទនៃរចនាបថ **កោះកេរ** មាន ៖ ប្រាសាទធំ ប្រាង្គប្រាសាទនាងខ្មៅ ប្រាសាទដំរី ប្រាសាទក្រហម ប្រាសាទចិន ប្រាសាទបូក និងប្រាសាទប្រាំ។

## ១០. រចនាបថ ប្រែរូប

ក្រោយពីព្រះបាទ **ជ័យវរ្ម័នទី៤** បានចូលទិវង្គត វិបត្តិស្នងរាជ្យបានកើតឡើង ហើយព្រះបាទ **រាជេន្ទ្រវរ្ម័ន** ដែលជាបុត្ររបស់ប្អូនស្រីព្រះបាទ **យសោវរ្ម័នទី១** ព្រះនាម **មហេន្ទ្រទេវី** និងព្រះបាទ **មហេន្ទ្រវរ្ម័ន** បានឡើងសោយរាជ្យ។ ព្រះអង្គបានលើករាជធានីពី **កោះកេរ** មក **យសោធបុរៈ** វិញ ដោយបង្កើតជា «អង្គរទី២»។ ព្រះអង្គបានសាងប្រាសាទ **មេបុណ្យខាងកើត** និង **ប្រាសាទប្រែរូប**។ ប្រាសាទប្រែរូប គឺជាស្ថាដែដ៏ធំធេង និងមានសមាមាត្រល្អបំផុត សាងសង់ពីថ្មបាយក្រៀម និងឥដ្ឋ។

## ១១. រចនាបថ បន្ទាយស្រី

ប្រាសាទបន្ទាយស្រីត្រូវបានចាប់ផ្តើមសាងសង់នៅគ.ស.៩៦៧ ដោយព្រះរាជគ្រូរបស់ព្រះបាទ **រាជេន្ទ្រវរ្ម័ន** ឈ្មោះ **យជ្ញវរាហៈ** នៅទិសខាងជើងនៃ **យសោធបុរៈ** ។ ប្រាសាទនេះបានសាងសង់ក្នុងរជ្ជកាលនៃស្តេចពីរអង្គ ដោយសារនៅក្នុងគ.ស.៩៦៧


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះបាទ **រាជេន្ទ្រវរ្ម័ន** សោយទិវង្គត ហើយបុត្ររបស់ព្រះអង្គព្រះនាម **ជ័យវរ្ម័នទី៥** បានឡើងសោយរាជ្យ ។

## ១២. រចនាបថ ឃ្លាំង

ស្ថាបត្យកម្មនៃរចនាបថ **ឃ្លាំង** ត្រូវបានចាប់ផ្តើមសាងសង់នៅចុងស.វ.ទី១០ និងដើមស.វ.ទី ១១ តាមរយៈការសាងសង់ប្រាសាទតាកែវ ប្រាសាទភិមានអាកាស ប្រាសាទឃ្លាំង និងប្រាសាទព្រះវិហារ។ ស្ថាបត្យកម្មនៃរចនាបថឃ្លាំងមានការរីកចម្រើន ក្នុងការសាងសង់ប្រាសាទភ្នំ ដែលមានលក្ខណៈពេញលេញ ដោយដកស្រង់នូវពិសោធន៍ក្នុងការសាងសង់សាលវែង ដើម្បីច្នៃឱ្យក្លាយទៅជាកំពែងថែវមានដំបូលជារូត ប្រក់ឥដ្ឋ ឬថ្មភក់ដែលរត់ពីលើព្រលាននៃខឿនព័ទ្ធជុំវិញប្រាង្គកណ្តាល។ ប្រាសាទតាកែវ និងប្រាសាទព្រះវិហារគឺជាស្នាដៃកំពូលក្នុងចំណោមប្រាសាទបុរាណខ្មែរ។

## ១៣. រចនាបថ បាពួន

ស្ថាបត្យកម្មខ្មែរនៅពាក់កណ្តាល និងចុងស.វ.ទី១១ ដែលជារចនាបថ **បាពួន** បានឈានដល់កម្រិតកំពូលនៃការសាងសង់ប្រាសាទភ្នំ ដែលខ្ពស់ចោត។ ប្រាសាទបាពួន មានថែវធ្វើពីថ្មភក់ព័ទ្ធជុំវិញប្រាង្គកណ្តាល មានកំផែង និងគោបុរៈជាច្រើន និងមានវិមាន ដែលសង់នៅតាមជ្រុង។ ប្រាសាទនៃរចនាបថបាពួនមាន ៖ ប្រាសាទបាពួន ប្រាសាទមេបុណ្យខាងលិច និងប្រាសាទខ្លាសែនកែវ។

## ១៤. រចនាបថ អង្គរវត្ត

នៅចុងស.វ.ទី១១ និងពាក់កណ្តាលទីមួយនៃស.វ.ទី១២ ស្ថាបត្យកម្មខ្មែរបានឈានដល់កម្រិតកំពូលហើយ។ យើងឃើញថា បន្ទាប់ពីមានការវិវត្តក្នុងរយៈពេល៥០០ឆ្នាំមក ទើបសិល្បៈ និងស្ថាបត្យកម្មខ្មែរ ជាពិសេស ក្បូរក្បាច់រចនានៅលើប្រាសាទ បានឈានដល់កម្រិតកំពូលយ៉ាងសុក្រឹតមួយដ៏ល្អស្ញប់ស្ញែង។ ប្រាសាទទាំងអស់នៃរចនាបថអង្គរវត្តសុទ្ធសឹងតែសាងសង់ឡើង ដោយប្រើថ្មភក់ទាំងអស់ ពីឆ្នាំ១១០០ ដល់១១៧៥។

សសរពេជ្រនៃរចនាបថអង្គរវត្តបានវិវត្តទៅមុខ ដោយមានឆ្លាក់ក្បាច់ចិញ្ចៀនរហូតដល់១០ ឬ១២ ។ ហោជាងនៃរចនាបថអង្គរវត្តរក្សានូវរោងធ្នូកំប៉ោង ដូចរចនាបថមុនដែរ តែលើផ្ទៃហោជាង ក្បាច់ក្បូរស្លឹកឈើត្រូវបានជំនួសដោយរឿងទេវកថា **មហាភារតៈ** និង **រាមកេរ្តិ៍** វិញ។ ម្យ៉ាងវិញទៀត នៅលើជញ្ជាំងប្រាសាទអង្គរវត្តបានឆ្លាក់ចម្លាក់លឹប (Bas-relief) លើផ្ទាំងថ្មយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេសនៅលើជញ្ជាំងនៃថែវប្រាសាទ ដែលដកស្រង់ពីឈុតល្បីៗនៃទេវកថា **មហាភារតៈ** និង **រាមកេរ្តិ៍** ដូចជា **កូរសមុទ្រទឹកដោះ** ជាដើម ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ទី៣-ស្ថាបត្យកម្មក្រោយសម័យអង្គរ

រចនាបថក្រោយសម័យអង្គរគឺរចនាបថ **បាយ័ន** ពីចុងស.វ.ទី១២ ដល់ដើមស.វ.ទី១៣( ពីគ.ស.១១៧៧ ដល់គ.ស.១២៣០)។

## ១៤. រចនាបថ បាយ័ន

នៅគ.ស.១១៦៥ ចាមបានលើកទ័ពជើងទឹកវាយចូលអាណាចក្រខ្មែរ ចូលតាមដងទន្លេមេគង្គ ឡើងរហូតដល់បឹងទន្លេសាប និងវាយយករាជធានីអង្គរបាន។ ព្រះបាទ **ជ័យវរ្ម័នទី៧** គឺជាព្រះរាជាដែលបានរំដោះអាណាចក្រខ្មែរទុកឱ្យមានឥស្សរភាពឡើងវិញ។ ព្រះអង្គទទួលរាជាភិសេក និង ឡើងសោយរាជ្យនៅ **យសោធរបុរៈ** នៅគ.ស.១១៨១ នៅពេលដែលព្រះអង្គមានព្រះជន្មាយុ ៥៦ ព្រះវស្សា ។ បន្ទាប់ពីឡើងសោយរាជ្យ ព្រះអង្គបានចាត់ចែងឱ្យសាងសង់ **អង្គរធំ** ដែលមានកំពែងថ្មបាយក្រៀម និងគូទឹកព័ទ្ធជុំវិញ មានគោបុរៈចំនួន៥ និងមាន **ប្រាសាទបាយ័ន** នៅចំកណ្តាល ។ ព្រះអង្គមានព្រះមហេសីពីរអង្គ ដោយព្រះបាទ **ជ័យវរ្ម័នទី៧** បានរៀបអភិសេកជាមួយព្រះនាង **ឥន្ទ្រទេវី** ដែលជាបងបង្កើតរបស់ព្រះនាង **ជ័យរាជទេវី** ដែលបានសោយព្រះពិរាល័យទៅនោះ។ ព្រះអង្គជាព្រះមហាក្សត្រជំនាន់អង្គរទី១ ដែលគោរពព្រះពុទ្ធសាសនាមហាយាន។

ព្រះបាទ **ជ័យវរ្ម័នទី៧** បានសាងសង់ប្រាសាទជាច្រើនសន្ធឹកសន្ធាប់ ដែលមានរចនាបថ **បាយ័ន** ។ ប្រាសាទទាំងនោះមាន ប្រាសាទបាយ័ន តាព្រហ្ម តាសោម បន្ទាយក្តី ព្រះខ័ន នាគព័ន្ធ បន្ទាយឆ្មា ប្រាសាទជ្រុង ប្រាសាទប្រជល់ដំរី តាព្រហ្មបាទី ប្រាសាទបាណន់ វត្តនគរ តាណើ ក្រោលគោ បន្ទាយព្រៃ ប្រាសាទព្រៃ និងព្រះថ្កុល។ល។ ដែលជាប្រាសាទនៃរចនាបថ **បាយ័ន** សាងសង់ឡើងពីគ.ស.១១៧៧ ដល់គ.ស.១២៣០។ ក្រៅពីនេះ ព្រះអង្គបានសាងសង់ធម្មសាលាចំនួន១២១ និងមន្ទីរពេទ្យចំនួន១០២។ អ្នកស្រាវជ្រាវខ្លះសឹងតែមិនជឿថា ក្នុងរយៈពេលនេះ មានប្រាសាទដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានសាងសង់ឡើងនៅក្នុងអាណាចក្រខ្មែរ។ ដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ច្រើនលើសលប់នេះ ស្ថាបត្យករបុរាណខ្មែរបានកៀរគរប្រជាពលរដ្ឋប្រុស-ស្រី ទោះមាន ឬគ្មានជំនាញក្តី ដើម្បីចូលរួមសាងសង់ប្រាសាទ ។ ដោយសារតែបញ្ហានេះ និងគួបផ្សំជាមួយនឹងការប្រើប្រាស់ថ្មចម្រុះគុណភាព និងការសាងសង់ដោយប្រញាប់ប្រញាល់នេះហើយ ទើបប្រាសាទមួយចំនួនឆាប់បាក់បែកទ្រុឌទ្រោមជាងប្រាសាទនៃរចនាបថមុនៗ។

លោក Pilippe Stern [20] បានបែងចែកប្រាសាទនៃរចនាបថ **បាយ័ន** នេះជាបីដំណាក់កាល ដែលឆ្លុះបញ្ចាំងពីការវិវត្តផ្ទៃក្នុងនៃរចនាបថបាយ័ន កាលបរិច្ឆេទនៃការសាងសង់ប្រាសាទ និងតួនាទីនៃប្រាសាទទាំងនេះនៅក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី៧** ៖

[20] Stern, Philippe, (1923) Le Bayon d’Angkor et l’évolution de l’art khmer, in Étude et discussion de la chronologie des monuments khmers. Annales du Musée Guimet, Biblio. De vulgarisation, 47. Paris ; Paul Geuthner.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ដំណាក់កាលទី១ ៖** ប្រាសាទលម្អដោយទេវតាមានសក់រាងសាជី ដៃច្រត់ចង្កេះ ស្លៀកសំពត់ផែកតូច ដោយគ្មានគ្រឿងអលង្ការមួយចំនួន គ្មានមុខញញឹម បង្អួចបញ្ឈោត មានចម្រឹងខ្ពស់ ខ្លោងទ្វារតូចចង្អៀត និងអវត្តមាននៃកំពូលប្រាសាទដែលមានមុខបួន។ នៅជំណាក់កាលទី១ ពីគ.ស.១១៧៧ ដល់គ.ស.១១៩១ ព្រះបាទជ័យវរ្ម័នទី៧បានកសាងប្រាសាទតាព្រហ្ម ដើម្បីឧទ្ទិសដល់ព្រះមាតារបស់ព្រះអង្គ(ដែលប្រៀបបានទៅនឹងប្រាជ្ញាបារមិតា) និងសង់ប្រាសាទព្រះខ័ន ដើម្បីឧទ្ទិសដល់ព្រះបិតារបស់ព្រះអង្គ(ដែលប្រៀបបានទៅនឹងលោកេស្វរៈ) ។ បន្ទាប់មក ព្រះអង្គសាងប្រាសាទបន្ទាយក្តី ដើម្បីឧទ្ទិសដល់ព្រះពុទ្ធទាំងបីនៃពុទ្ធសាសនាមហាយាន(ប្រាជ្ញាបារមិតា-លោកេស្វរៈ-ព្រះពុទ្ធ)។

**ដំណាក់កាលអន្តរកាល** ៖ មានលេចឡើងនូវបង្អួចបញ្ឈោតមានសន្លឹកបិទ រូបពុទ្ធរូបលម្អ ព្រំជំបូល ទ្រឹស្តីស្តីពីទេវរូប អសុរៈកាន់ពស់ និងលោកេស្វរៈ។ នៅជំណាក់កាលនេះ ព្រះបាទ **ជ័យវរ្ម័នទី៧** បានដាក់ចេញនូវកំណែទម្រង់សាសនាយ៉ាងធំធេង១០ឆ្នាំក្រោយពេលព្រះអង្គឡើងគ្រងរាជ្យ ដោយលើកតម្កើងលោកេស្វរៈ។

**ដំណាក់កាលទី២ ៖** ប្រាសាទមានលក្ខណៈពិសេសដូចក្នុងសម័យអន្តរកាល និងមានការលេចឡើងនូវកំពូលប្រាសាទដែលមានមុខបួន សត្វឆ្លាក់នៅតាមមុំ (ដំរី ហង្ស គ្រុឌ) ទេវតាវែកសក់ក្លិបី ដែលមានរាងជាប៉ោយរាងត្រីកោណ តាក់តែងលម្អដោយខ្សែក ខ្សែក្រវាត់ និងមានទឹកមុខញញឹម។

**ដំណាក់កាលទី៣ ៖** ប្រាសាទដែលមានទេវតាមានកំប៉ោយសក់រាងត្រីកោណ សំពត់ផែករាងត្រីកោណ សក់លម្អដោយស្លឹកឈើ គ្រឿងអលង្ការជាខ្សែក និងខ្សែក្រវាត់ និងពាក់កម្រងផ្ការាងដូចពស់ ។

លក្ខណៈពិសេសនៃរចនាបថ **បាយ័ន** នៅស.វ.ទី១៣ គឺការសាងសង់ប្រាសាទដែលកំពូលមានមុខបួន ដែលជាតំណាង **លោកេស្វរៈ** ដែលជាតក្កកម្មខាងផ្នែកស្ថាបត្យកម្មផង និងផ្នែកសំណង់ផង ដែលយើងអាចចាត់ទុកថាជារូបចម្លាក់ដ៏ធំធេងនៅក្នុងសិល្បៈខ្មែរ ដែលផ្សារភ្ជាប់ទៅនឹងជំនឿសាសនា។ សមិទ្ធផលដ៏ធំធេងមួយទៀតនៃរចនាបថ **បាយ័ន** គឺការសង់កំពែងថ្មបាយក្រៀម និងគូទឹកព័ទ្ធជុំវិញរាជធានីអង្គរធំ ដោយមានគោបុរៈចំនួន ៥ ដែលមានទទឹង៣ គីឡូម៉ែត្រ និងបណ្តោយ១២ គីឡូម៉ែត្រ ។

តក្កកម្មទី៣ នៃរចនាបថ **បាយ័ន** គឺការសង់ប្រាង្គ **ប្រាសាទបាយ័ន** ដែលជាស្នាដៃដ៏វិសេសវិសាលនៃបុព្វបុរសខ្មែរ។ ប្រាង្គកណ្តាលនៃប្រាសាទបាយ័នមានរាងមូល សម្រាប់តម្កល់បដិមាពុទ្ធរាជ្យមួយអង្គ ដែលមានកម្ពស់ជិត៤ ម៉ែត្រ ហើយឆ្លុះបញ្ចាំងពីការរីកចម្រើនលូតលាស់ និងភាពល្បីល្បាញខ្ទរខ្ទារសុសសាយនៃ **លោកេស្វរៈ** ដែលបែរមុខទៅទិសទាំង៨ ដើម្បីសំដែងនូវមេត្តាធម៌ដល់រាជធានី អាណាចក្រ ពិភពលោក និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចក្រវាឡទាំងមូល។ ប្រាសាទនៃរចនាបថបាយ័ន ឆ្លុះបញ្ចាំងពីតម្លៃបែបអរូបកម្មរបស់សិល្បៈខ្មែរ ដោយឈរលើមូលដ្ឋាននៃគំរូតែមួយ ដោយរក្សានូវសមតាបានល្អឥតខ្ចោះ។

## ១.១.៣. ការអប់រំនៅក្នុងយុគសម័យអង្គរ

ចក្រភពអង្គរត្រូវបានចាប់ផ្តើមកសាងឡើងដោយព្រះបាទ **ជ័យវរ្ម័នទី២** (៨០២-៨៥០)។ **ព្រះបាទជ័យវរ្ម័នទី២** បានរំដោះប្រទេសជាតិឱ្យមានឥស្សរភាពឡើងវិញ និងបង្រួបបង្រួមប្រទេសឱ្យមានឯកភាពជាតិឡើងវិញ។ ព្រះអង្គបានផ្លាស់ប្តូររាជធានីញឹកញាប់ដើម្បីបង្រួបបង្រួមទឹកដី ដូចជានៅ **ឥន្ទ្របុរៈ កុតិ ហរិហរាល័យ** និងនៅ **អមរេន្ទ្របុរៈ** ជាដើម។ បន្ទាប់មក ព្រះអង្គបានយាងទៅគង់លើភ្នំគូលែន(**មហេន្ទ្របវ័ត**)។ ទ្រង់បានបង្កើតរាជធានីមួយនៅ **ឥន្ទ្របុរៈ** (នៅជិតបន្ទាយព្រៃនគរ ស្រុកត្បូងឃ្មុំ) នៅអំឡុងឆ្នាំ ៨០០ នៃគ.ស. បន្ទាប់មកទ្រង់យាងទៅគង់នៅ **កុត** (ប្រាសាទបន្ទាយក្តី) រួចបានផ្លាស់រាជធានីទៅ **ហរិហរាល័យ** (រលួស) បន្ទាប់មកទៅនៅ **អមរេន្ទ្របុរៈ** (ទំនប់ខាងលិចនៃបារាយណ៍) និងចុងក្រោយទៅ **មហេន្ទ្របវ័ត** (ភ្នំគូលែន)។ នៅលើកំពូលភ្នំគូលែន **ព្រះបាទជ័យវរ្ម័នទី២** បញ្ជាឱ្យព្រាហ្មណ៍ឈ្មោះ **ហិរណ្យទាម** ប្រារព្ធ«ពិធីទេវរាជ» ដើម្បីឱ្យប្រទេសខ្មែររួចពីចំណុះប្រទេសជ្វា ហើយអភិសេកព្រះអង្គឱ្យមានឋានៈជា **ចក្រវាទិន** (ស្តេចចក្រវាល) នៅគ.ស.៨០២ ។

### *១.១.៣.១. លទ្ធិទេវរាជនៅសម័យអង្គរ*

យើងបានដឹងយ៉ាងច្បាស់ពីលទ្ធិទេវរាជពីសិលាចារឹក **ស្តុកកក់ធំ** ដែលអ្នកប្រាជ្ញជាតិបារាំងឈ្មោះ George Coedès និង Dupont បានសិក្សាយ៉ាងលម្អិតនៅក្នុងអត្ថបទមួយក្រោមចំណងជើងថា «**សិលាចារឹកស្តុកកក់ធំ ភ្នំសណ្តក និងព្រះវិហារ**»[21]។ លទ្ធិទេវរាជនេះ ត្រូវបានបង្កើតឡើងដោយព្រាហ្មណ៍ **ហរិណ្យទាម** ដែលបានចងក្រងនូវគម្ពីរបួនគឺ **វិនាសិខ-នយោត្តរ-សម្មោហ** និង **សិរច្ឆេទ** ដែលរៀបរាប់ពីរបៀបប្រារព្ធធ្វើវិធីទេវរាជ ។

នៅឆ្នាំ៨០២ ព្រះបាទ **ជ័យវរ្ម័នទី ២** បានរៀបចំពិធី **ទេវរាជ** ដើម្បីប្រកាសឯករាជ្យដល់អាណាចក្រខ្មែរ ហើយធ្វើឱ្យព្រះរាជាទៅជា **ចក្រវាទិន** (អាទិទេពនៃស្តេច) លើភ្នំគូលែន (**មហេន្ទ្របវ័ត**)។ ក៏ប៉ុន្តែមិនមែនមានន័យថា លទ្ធិទេវរាជនេះត្រូវតែរៀបចំឡើងនៅទីកន្លែងខ្ពស់ ឬនៅលើប្រាសាទភ្នំឡើយ ។

---

[21] Coedès, G, Les stèles de Sdok Kak Thom, Phnom Sandak et Preah Vihear, BEFEO 43, p. 56ff. (APKh II, pp. 167-265).



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពិធីទេវរាជនេះត្រូវមានព្រាហ្មណ៍ជាអ្នករៀបចំ ។ ព្រាហ្មណ៍ដែលរៀបចំពិធីទេវរាជសម្រាប់ព្រះបាទ **ជ័យវរ្ម័នទី២** គឺ **សិវកៃវល្យ** ដែលជា **រាជបុរោហិត** និងរាជគ្រូរបស់ព្រះអង្គ។ បន្ទាប់ពីពិធីអភិសេកនេះ ព្រះបាទ **ជ័យវរ្ម័នទី ២** មានឋានៈជា **ទេវរាជ** ដែលពាក្យខ្មែរបុរាណហៅថា **កម្រតេងជគតរាជ** (Kamraten jagat ta raja) ដែលមានន័យថា **ស្តេចដែលជាម្ចាស់នៃចក្រវាល**។ បន្ទាប់ពីប្រសិទ្ធីហើយ ព្រះសិវលិង្គនេះក៏ក្លាយទៅជា **ទេវរូប** ដែលមានឋានៈជា **កម្រតេងជគតរាជ** ដែរ ។ ព្រះបាទ **ជ័យវរ្ម័នទី២** និងព្រាហ្មណ៍ **ហរិណ្យទាម** បានសច្ចាថា មានតែសមាជិកគ្រួសារព្រាហ្មណ៍ **សិវកៃវល្យ** ទេ ដែលអាចប្រារព្ធធ្វើពិធីទេវរាជបាន។ បន្ទាប់ពីរៀបចំពិធីទេវរាជ ព្រះសិវលិង្គទទួលប្រសិទ្ធី ហើយក្លាយទៅជាទេវរូបដែលគេរាល់គ្នាត្រូវគោរពបូជា។ ព្រះសិវលិង្គនេះមានតែមួយទេ ហើយអាចយកទៅតម្កល់ទុកនៅកន្លែងជាទីសក្ការៈ និងអាចយកពីមួយកន្លែង ទៅតម្កល់នៅមួយកន្លែងទៀត។

ទ្រង់បាននិមន្តព្រាហ្មណ៍ **ហរិណ្យទាម** ឱ្យមកបង្រៀនគម្ពីរទេវរាជទាំង៤ ដល់រាជបុរោហិត **សិវកៃវល្យ**។ វង្ស **សិវកៃវល្យ** ក៏ជាប់ជារាជបុរោហិតតាំងពីពេលនោះមក។ ព្រះរាជពិធីនេះបានរៀបចំធ្វើឡើងនៅ «**មហេន្ទ្របវ័ត**» (ភ្នំគូលែន) ជាដំបូងនៅឆ្នាំ ៨០២ ដើម្បីប្រារព្ធធ្វើពិធីសាសនាហៅថា **ពិធីទេវរាជ** ក្នុងគោលដៅអភិសេកព្រះបាទ **ជ័យវរ្ម័នទី២** ឱ្យក្លាយទៅជា **ចក្រវាទិន** ដែលមានឋានៈជា **ទេវរាជ** ឬ **កម្រតេជ៍ជគតរាជ** ។ ពិធីទេវរាជនេះត្រូវតែរៀបចំដោយសម្តេចព្រះគ្រូដែលជាបុរោហិត។ តាំងពី ស.វ.ទី៩មក ពិធីនេះត្រូវបានរៀបចំឡើងនៅលើភ្នំ ឬប្រាសាទភ្នំ ដើម្បីគោរពដល់បុព្វបុរសមហាក្សត្រខ្មែរ ដែលទើបឡើងសោយរាជ្យថ្មី និងដើម្បីអភិសេកមហាក្សត្រថ្មីនេះឱ្យមានឫទ្ធានុភាពស្មើនឹងអាទិទេពផង។

**លទ្ធិទេវរាជ** គឺជាការរៀបអភិសេក **សិវលិង្គ** ដែលគេសន្មតថា បានមកពីព្រះឥសូរ តាមរយៈព្រាហ្មណ៍ ដោយមានគោលដៅដូចតទៅ ៖

-ដើម្បីឱ្យ **អាត្ម័នពិសិដ្ឋ** របស់ព្រះរាជាបានទៅសណ្ឋិតនៅក្នុងសិវលិង្គនោះ និងបានក្លាយជានិមិត្តរូបនៃទេវរាជ។ សិវលិង្គដែលក្លាយជានិមិត្តរូបរបស់ជាតិជួយការពារអាណាចក្រខ្មែរឱ្យរួចផុតពីគ្រោះចង្រៃផ្សេងៗ ក៏ដូចជាពីសត្រូវដែលមកឈ្លានពាន។

-ធ្វើឱ្យព្រះរាជាក្លាយទៅជាព្រះឥសូរ។ ក្រោយពីការធ្វើពិធីអភិសេក«ពិធីទេវរាជ» នេះហើយ ព្រះរាជាក៏មានឋានៈជា **ចក្រវាទិន** (ស្តេចចក្រវាល) ដែលជាព្រះឥសូរបែងភាគ ដែលមានអំណាចអាចគ្រប់គ្រងទៅលើសព្វសត្វ ហើយបញ្ញារបស់ព្រះរាជាគឺជាបញ្ញា



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

របស់អាទិទេព។ ប្រការនេះមានន័យថា ព្រះរាជាទទួលបញ្ជាដោយផ្ទាល់ពីអាទិទេព ដើម្បីគ្រប់គ្រងផែនដី។

-ដោយព្រះឥសូរមានលំនៅនៅលើ **ភ្នំកៃលាស** សិវលិង្គដែលជាតំណាងព្រះឥសូរផង និងជាតំណាងព្រះរាជាផងក៏ត្រូវយកទៅតម្កល់នៅលើភ្នំដែរ។ ប្រសិនបើគ្មានភ្នំធម្មជាតិទេ គេត្រូវសាងប្រាសាទដែលមានខឿនច្រើនជាន់ ឱ្យមានកម្ពស់ដូចភ្នំ ហើយដែលគេហៅថា **ប្រាសាទភ្នំ**។ ប្រាសាទភ្នំនេះត្រូវស្ថិតនៅចំកណ្តាលរាជធានី ដែលគេចាត់ទុកថា នៅចំស្នូលនៃចក្រវាល។

ព្រះរាជបុត្ររបស់ព្រះបាទ **ជ័យវរ្ម័នទី២** ព្រះនាម**ជ័យវរ្ម័នទី៣** បានឡើងសោយរាជ្យស្នងព្រះបាទ **ជ័យវរ្ម័នទី២** ដោយគង់នៅ **ហរិហរាល័យ** រហូតដល់គ.ស. ៨៧៧។ នៅពេលដែលព្រះអង្គចូលទិវង្គត ប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាម **ឥន្ទ្រវរ្ម័នទី១** បានឡើងគ្រងរាជសម្បត្តិ។ ព្រះអង្គបានជីកបារាយណ៍ **ឥន្ទ្រតដាក** នៅខាងជើងរាជធានី ដែលមានប្រវែង៣០០០ម៉ែត្រ និងទទឹង៨០០ម៉ែត្រ។ នៅឆ្នាំ៨៧៩ ព្រះបាទ **ឥន្ទ្រវរ្ម័ន** បានកសាងប្រាសាទ **ព្រះគោ** ដើម្បីឧទ្ទិសថ្វាយចំពោះព្រះមាតា ព្រះបិតា និងជីដូនជីតា។ នៅឆ្នាំ៨៨១ ទ្រង់បានកសាងប្រាសាទ **បាគង** ដែលជាប្រាសាទភ្នំទីមួយសាងពីថ្មភក់សម្រាប់តម្កល់ទេវលិង្គ **ឥន្ទ្រេស្វរៈ**។

### *១.១.៣.២. ព្រះរាជគ្រូនិងប្រព័ន្ធអប់រំសម័យអង្គរ*

អាណាចក្រខ្មែររៀបចំប្រព័ន្ធគ្រប់គ្រងប្រទេសតាមបែបឥណ្ឌា។ ក្នុងន័យនេះ ប្រព័ន្ធអប់រំនៅយុគសម័យអង្គរក៏មានលំនាំដូចប្រព័ន្ធគ្រប់គ្រងកាលពីសម័យនោះដែរ។ ប្រព័ន្ធនេះបន្តរហូតដល់សម័យអាណាព្យាបាលបារាំង ដែលជំនួសប្រព័ន្ធនេះតាមបែបប្រព័ន្ធអប់រំតាមសម័យទំនើប។

**ព្រះបាទជ័យវរ្ម័នទី២** (គ.ស.៨០២ - គ.ស.៨៥០) គឺជាព្រះមហាក្សត្រទី១នៃសម័យអង្គរ។ សិលាចារឹក **បាពួន** (K583) ដែលបកប្រែដោយលោក Claude Jacques នៅក្នុងអត្ថបទរបស់លោក «**ការសិក្សាស្តីពីសិលាចារឹកកម្ពុជា-សិលាចារឹកបាពួន**-K583»[22] រៀបរាប់ជាភាសាសំស្ក្រឹតពីព្រះបាទ **ជ័យវរ្ម័នទី ២** ដែលជាអាទិទេពនៃក្សត្រលើគ្រប់ទ្វីបបានគ្រប់គ្រងប្រទេសប្រកបដោយទសពិធរាជធម៌ និងការពារប្រជាជនរបស់ព្រះអង្គ។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាម **ស្រីឥន្ទ្រាយុទ្ធ** មានឋាមពលខ្លាំងក្លាតាំងពីវ័យក្មេង ដោយច្បាំងឈ្នះស្តេចចម្ប៉ា។ ព្រះអង្គបានយាងទៅធ្វើធមិនៅ **លិង្គបុរី** (វត្តភូ) តាមបញ្ជារបស់ព្រះសិវៈ។ ព្រះអង្គបានកសាងលិង្គមួយពីបំណែកលិង្គធំមួយទៀតឈ្មោះ **លិង្គនិសកល**

[22] Jacques, Claude, (1976) Études d'épigraphie cambodgienne. La stèle du Baphuon, K583, BEFEO 63, pp. 351-368.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយព្រះអង្គបានតម្កល់លិង្គនេះនៅវត្តសន្ធុ ដោយប្រគេនថ្វាយព្រះចៅ **លិទ្ធបុរី** នូវទេវរូប **ស្រីសិខរិស្វរៈ** ហើយបន្ទាប់មកព្រះអង្គបានយកលិង្គនេះមកទុកនៅប្រាសាទ **ព្រះវិហារ**។ សិលាចារឹកបាពួនបានបញ្ជាក់យ៉ាងច្បាស់ពីដើមកំណើតនៃទីសក្ការបូជា ចំពោះសិខរិស្វរៈ តាំងពីជំនាន់ព្រះបាទ **ជ័យវរ្ម័នទី២** មកម្ល៉េះ។ ដូច្នេះ យើងអាចសន្និដ្ឋានបានពីវត្តមាននៃប្រាសាទ **ព្រះវិហារ** ដែលអាចមិនទាន់ជាសំណង់ថ្មនៅឡើយ នៅក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី២**។

រាជបុរោហិត ឬរាជគ្រូរបស់ព្រះមហាក្សត្រដែលជាព្រាហ្មណ៍ ឬបណ្ឌិតដើរតួនាទីយ៉ាងសំខាន់នៅក្នុងសាសនា និងនយោបាយរបស់អាណាចក្រខ្មែរ។ ព្រាហ្មណ៍ខ្លះមានដើមកំណើតពីប្រទេសឥណ្ឌា តែខ្លះទៀតគឺជាខ្មែរដែលបានសិក្សានៅប្រទេសឥណ្ឌា ហើយបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការពារប្រពៃណីហិណ្ឌូ និងវប្បធម៌សំស្ក្រឹតនៅក្នុងអាណាចក្រខ្មែរ។ ពួកព្រាហ្មណ៍ទាំងនោះក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងប្រទេស និងចូលរួមវិភាគទានក្នុងការអភិវឌ្ឍសិល្បៈខ្មែរ។

ការតែងតាំងរាជបុរោហិតមានលក្ខណៈតពូជពង្សវង្សត្រកូលតែម្តង។ ឧទាហរណ៍ សមាជិកគ្រួសារព្រាហ្មណ៍ **សិវកៃវល្យ** ត្រូវបានព្រះបាទ **ជ័យវរ្ម័នទី២** និងព្រាហ្មណ៍ **ហិរិណ្យទាម** តែងតាំងជា **រាជបុរោហិត** សម្រាប់ការប្រោរព្ធធ្វើពិធីទេវរាជ។ តាមប្រភពឯកសាររបស់លោក **ឡរ៉ែនស៍ ប៉ាលម័រ ប្រិគ្គស៍** គ្រួសារ **ប្រាណវតម្ម័ន** មានសិទ្ធិតពូជក្នុងការតែងតាំង **អាចារ្យព្រាហ្មណ៍** (Hotar)។ គ្រួសារ **ហរិបុរ** មានសិទ្ធិតពូជជាព្រះសង្ឃសម្រាប់ពិធីបូជាសពជាដើម។

អ្នកប្រាជ្ញល្បីៗនៅជំណាក់កាលដំបូងនៃសម័យអង្គរមាន ដូចជា៖

(១)បណ្ឌិត **សិវសោម**[23] ដែលរស់នៅក្នុងរជ្ជកាលព្រះបាទ **ឥន្ទ្រវរ្ម័នទី១** (គ.ស. ៨៧៧–៨៨៩) ដែលបាននិពន្ធរឿងមហាភារតៈ ក្បួនវេយ្យាករណ៍ និងសិលាចារឹកប្រាសាទកណ្តោលដើម ដែលជាអត្ថបទថ្លែងសរសើរព្រះរាជបារមីនៃព្រះបាទ **ឥន្ទ្រវរ្ម័នទី១** ដែលមានឫទ្ធានុភាពនាំឱ្យរាជសត្រូវនៅគ្រប់ទិសទីខ្លបខ្លាចព្រះចេស្តាព្រះអង្គ។ ព្រះអង្គបានសាងប្រាសាទព្រះគោ និងបាគង ដែលជាបុរាណដ្ឋានដ៏ល្អវិសេស។

(២) បណ្ឌិត **យតអមរភាវៈ**[24] ជាអ្នកប្រាជ្ញដ៏សំខាន់ក្នុងរជ្ជកាល **ព្រះបាទយសោវរ្ម័ន** (គ.ស.៨៩៩-៩០៨)។ លោកជាអធិបតីនៃបណ្ឌិតទាំងឡាយ និងមានឋានន្តរសក្តិជាសង្ឃរាជលើវត្តឥន្ទ្រាស្រមផ្នែកសាសនាព្រាហ្មណ៍ និងជាអ្នកតែងសិលា

[23] លី ធាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ៦៣ និង ម៉ុញ សារី (២០១១) វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ (Encyclopedia of Khmer Literature) មជ្ឈមណ្ឌលស្រាវជ្រាវអាសីនៃរាជបណ្ឌិតសភាកម្ពុជា ទំព័រ៥៣៨។

[24] លី ធាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ ៦៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចារឹកភ្នំបាយ៉ង់[25] ក្នុងស្រុកទ្រាំង ខេត្តតាកែវ។ តាមរយៈសិលាចារឹកដែលកើតឡើងដោយព្រះរាជូបត្ថម្ភនៃព្រះបាទយសោវរ្ម័នដែលជាព្រះមហាក្សត្រភ្លៀវក្លាមួយអង្គក្នុងស.វ.ទី៩ បណ្ឌិត យតិអមរភាវៈ បានអួតសរសើរព្រះឥស្វរ និងបានសុំបួងសួងសុំឱ្យព្រះឥស្វរថែរក្សាប្រជានុរាស្ត្រឱ្យប្រកបដោយសេចក្តីសុខ ។

នៅក្នុងរជ្ជកាល **ព្រះបាទសូរ្យវរ្ម័នទី ១** (គ.ស. ១០១០ - គ.ស. ១០៥០) ប្រវត្តិវិទូមានទស្សនៈខុសៗគ្នាពីជំនឿសាសនារបស់ព្រះបាទ **សូរ្យវរ្ម័នទី១**។ លោកស្រី Giteau និងលោក Coedès ជឿជាក់ថា ព្រះអង្គជាព្រះរាជាទី១ ដែលកាន់ព្រះពុទ្ធសាសនាមហាយាន ហើយមរណនាមរបស់ព្រះអង្គ **និវ៌ានបទ** គឺជាសក្ខីភាពនៃជំនឿលើព្រះពុទ្ធសាសនារបស់ព្រះអង្គ។ ក៏ប៉ុន្តែនៅក្នុងសៀវភៅចុងក្រោយ ដែលមានចំណងជើងថា«**ប្រវត្តិសាស្ត្រអង្គរ**» លោកស្រី Giteau បានលើកឡើងនូវទស្សនៈមួយដែលថា ព្រះបាទ **សូរ្យវរ្ម័នទី១** អាចជាស្តេចដែលគោរពព្រហ្មញ្ញសាសនា ដោយសារតែប្រាសាទដែលត្រូវបានសាងសង់នៅក្នុងរាជ្យរបស់ព្រះអង្គ គឺសុទ្ធសឹងតែជាប្រាសាទសិវនិយមទាំងអស់។ ម្យ៉ាងវិញទៀត ប្រវត្តិវិទូបារាំង លោក Filliozat បានអះអាងថា **និវ៌ានបទ** ក៏ជាមរណនាមនៃស្តេច ដែលគោរពបូជាព្រះសិវៈផងដែរ។

សិលាចារឹក K380 ដែលឆ្លាក់លើសសរក្លោងទ្វារខាងត្បូងនៃគោបុរៈទី២ បានបញ្ជាក់ថា នៅក្នុងរជ្ជកាលរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** មានការគោរពយ៉ាងខ្លាំងក្លាចំពោះ **លទ្ធិសិវនិយម** នៅលើកំពូលភ្នំព្រះវិហារ។ ព្រះអង្គបានបញ្ជាឱ្យតម្កល់ព្រះសិវលិង្គ ឈ្មោះ **សូរ្យវរមេស្វរៈ** ដំបូងនៅ **ជ័យក្សេត្រ** (បាសិត) ហើយបន្ទាប់មកនៅក្នុងគ.ស. ១០១៨ ព្រះអង្គបានបញ្ជាឱ្យយកព្រះសិវលិង្គ **សូរ្យវរមេស្វរៈ** នេះទៅតម្កល់នៅទីសក្ការៈបីទៀត គឺ **សិខរិស្វរៈ** (ព្រះវិហារ) **ឥសានត្តីធ៌ត** (Icantirtha) និង **សូរ្យទ្រ** (ភ្នំជីសូរ)។ លិង្គ **សូរ្យវរមេស្វរៈ** នេះត្រូវបានគេតម្កល់នៅក្នុងគោបុរៈទី២ នៃប្រាសាទ **ព្រះវិហារ**។

ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យសាសនានៅក្នុង ស.វ.ទី១១ និងផ្នែកទី១ នៃស.វ.ទី១២ ។ **ទិវាករបណ្ឌិត** គឺរាជគ្រូនៃព្រះមហាក្សត្រខ្មែរចំនួនប្រាំអង្គគឺព្រះបាទ **រាជេន្ទ្រវរ្ម័ន** (គ.ស.៩៤៤-គ.ស.៩៦៨) ព្រះបាទ **ឧទយាទិត្យវរ្ម័នទី១** ព្រះបាទ **ហស៌វរ្ម័នទី៣** ព្រះបាទ **ជ័យវរ្ម័នទី៦** និងព្រះបាទ **សូរ្យវរ្ម័នទី២** (គ.ស.១១១២ -គ.ស.១១៥២)។ សិលាចារឹកលេខ K383 បញ្ជាក់ថា នៅឆ្នាំ១១២១ ព្រះរាជគ្រូ **ទិវករបណ្ឌិត** បានចាររៀបរាប់ពីប្រវត្តិសាស្ត្រនៃប្រាសាទព្រះវិហារ ដែលពាក់ព័ន្ធនឹងមហាក្សត្រ ៥ អង្គខាងលើដែលបានសោយរាជ្យជាបន្តបន្ទាប់។

[25] Coedès, G, Inscription du Cambodge, T. 1, p. 256-260.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បណ្ឌិត **ទិវាករ**[26] គឺជាអ្នកប្រាជ្ញឯក ក្នុងរជ្ជកាលព្រះបាទ **រាជេន្ទ្រវរ្ម័ន** ដែលចេះចាំគម្ពីរត្រៃវេទយ៉ាងស្ទាត់ជំនាញ។ លោកបាននិពន្ធសិលាចារឹកជាភាសាខ្មែរ និងជាភាសាសំស្ក្រឹតនៅប្រាសាទកំភឹស ដែលស្ថិតនៅឃុំយាង ខេត្តម្លូព្រៃ ចម្ងាយ ១៦ គ.ម. ខាងត្បូងភ្នំសណ្តុក និង ២៥ គ.ម.ពីប្រាសាទកោះកេរ។ សិលាចារឹកនេះថ្លែងសរសើរព្រះបារមីនៃព្រះបាទជ័យវរ្ម័នទី៥ (គ.ស.៩៦៨-គ.ស.១០០២) ដែលត្រូវជាព្រះរាជបុត្រនៃព្រះបាទរាជេន្ទ្រវរ្ម័ន។

ព្រាហ្មណ៍ **ទិវាករបណ្ឌិត** មានដើមកំណើតនៅប្រទេស Vnur Dnan ក្នុងស្រុក Sady ដែលអាចជារដ្ឋតូចមួយនៃអាណាចក្រខ្មែរ។ ព្រះបាទ **ឧទយាទិត្យវរ្ម័នទី២** បានបញ្ជាឱ្យព្រាហ្មណ៍ **ទិវាករបណ្ឌិត** កសាងប្រាសាទបាពួន ដើម្បីតម្កល់ព្រះសិវលិង្គមាសនៅចំកណ្ដាលរាជធានីរបស់ព្រះអង្គ។ ព្រះបាទ **ឧទយាទិត្យវរ្ម័នទី២** បានសោយរាជ្យពីឆ្នាំ១០៥០ ដល់ឆ្នាំ១០៦០ តែពិធីតម្កល់ព្រះសិវលិង្គមាសត្រូវបានប្រារព្ធនៅចុងរាជ្យរបស់ព្រះអង្គ ប្រហែលជានៅក្នុងឆ្នាំ១០៦០ ឬក្រោយនេះបន្តិច។

សិលាចារឹក **ភ្នំសណ្ដក** (K194) ដែលបកស្រាយដោយលោក Coedès បានរៀបរាប់ថា ៖ នៅក្នុងគ.ស.១១១៩ ព្រះបាទ **សូរ្យវរ្ម័នទី ២** បានបញ្ជាក់ឱ្យគេកត់ត្រានៅលើសិលាចារឹកនេះ នូវប្រវត្តិរូបរបស់ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ដែលមានគោរមងារជា **ភគវតបាទកម្រតេងអញគុរុ** ដែលព្រះបាទ **ជ័យវរ្ម័នទី៦** បានផ្ដល់ជូននៅពេលព្រះអង្គឡើងសោយរាជ្យ តែត្រូវបានប្ដូរនឹងគោរមងារមួយទៀតដែលខ្ពស់ជាងគឺ **ធូលីជេងកម្រតេងអញ**។

នៅក្នុងរាជ្យរបស់ព្រះបាទ **ហស៌វរ្ម័នទី៣** ដែលជាព្រះរៀមរបស់ព្រះបាទ **ឧទយាទិត្យវរ្ម័នទី២** ព្រាហ្មណ៍ **ទិវាករបណ្ឌិត** បានបំពេញតួនាទីជា ***អាចារ្យប្រធាន*** (Acaryaprad- hana) នៅប្រាសាទព្រះវិហារ។

ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ត្រូវបានព្រះបាទ **ជ័យវរ្ម័នទី៦** ជ្រើសរើសជាព្រះគ្រូដើម្បីអភិសេកព្រះអង្គ។ ព្រាហ្មណ៍ **ទិវាករបណ្ឌិត** បានផ្សារភ្ជាប់ជាមួយសន្តតិវង្សថ្មីនេះ ហើយបានក្លាយជាទីប្រឹក្សាក្នុងរយៈពេល៤០ឆ្នាំ។ ក្រៅពីតួនាទីជាព្រះគ្រូ ព្រះបាទ **ជ័យវរ្ម័នទី៦** បានផ្ដល់គោរមងារដល់ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ជា **ភគវតបាទកម្រតេងអញគុរុ ស្រី ទិវាករបណ្ឌិត**។ ព្រាហ្មណ៍នេះមានតួនាទីជាអ្នកចែកអំណោយដល់ប្រាសាទជាទីសក្ការៈនានា ដើម្បីទ្រទ្រង់ និងជួសជុលប្រាសាទទាំងនេះ និងបំពេញការងារសាងសង់នានាខាងផ្នែកសាសនា។ បន្ទាប់ពីព្រះបាទ **ជ័យវរ្ម័នទី៦** បានសោយទិវង្គត ព្រះរៀមច្បងរបស់ព្រះអង្គ គឺព្រះបាទ **ធរណីន្ទ្រវរ្ម័នទី១** បានឡើងសោយរាជ្យ។

[26] លី ធាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ៦៤-៦៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ព្រះបាទ **ធរណីន្ទ្រវរ្ម័នទី១** បានបញ្ជាឱ្យព្រាហ្មណ៍ **ទិវាករបណ្ឌិត** ចែកអំណោយនៅតាមបណ្តាប្រាសាទនានា។

ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ត្រូវបានគេជ្រើសរើស ដើម្បីអភិសេកព្រះមហាក្សត្រថ្មីដោយយកព្រះបរមនាមថាព្រះបាទ **សូរ្យវរ្ម័នទី២**។ សិលាចារឹកលេខ K383 ដែលចម្លងទាំងស្រុងពីសិលាចារឹក **ភ្នំសណ្តក** បញ្ជាក់ថា **ទិវាករបណ្ឌិត** បានដឹកនាំការធ្វើគម្រោងដ៏ច្រើននៅប្រាសាទ **ព្រះវិហារ**។ នៅគ.ស.១១១៩ **ព្រះបាទសូរ្យវរ្ម័នទី២** បានត្រាស់បង្គាប់ឱ្យយកសិលាចារឹកនេះមកតម្កល់ទុកនៅប្រាសាទព្រះវិហារ។ ព្រាហ្មណ៍ **ទិវាករបណ្ឌិត** បានជីកស្រះ និងជីកប្រឡាយទឹក ដោយចំណាយទ្រព្យធនរបស់លោកផ្ទាល់ និងបានធ្វើអំណោយជាវត្ថុមានតម្លៃទៅប្រាសាទ **ព្រះវិហារ** តាមព្រះរាជបញ្ជារបស់ព្រះបាទ **សូរ្យវរ្ម័នទី២**។

នៅសម័យអង្គរ អាណាចក្រខ្មែរសម្បូរអ្នកប្រាជ្ញនិងអ្នកនិពន្ធមានទេពកោសល្យខ្ពស់ជាច្រើន។ ភាសាសំស្ក្រឹតជាមូលដ្ឋាននៃព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន និងជាភាសាផ្លូវការសម្រាប់កិច្ចការរដ្ឋសម័យអង្គរ។ ដូច្នេះហើយ អក្សរសាស្ត្រខ្មែរសម័យអង្គរមានលាយឡំអក្សរខ្មែរបុរាណ និងភាសាសំស្ក្រឹត។ អក្សរសិល្ប៍ខ្មែរជំនាន់អង្គរក៏បានឡើងដល់កម្រិតកំពូលដែរ តែយើងឃើញនៅសល់តែអក្សរសិល្ប៍ដែលបានសរសេរលើសិលាចារឹកតាមប្រាង្គប្រាសាទនានាជាភាសាខ្មែរបុរាណ និងជាភាសាសំស្ក្រឹតប៉ុណ្ណោះ។ អ្នកប្រាជ្ញជំនាន់នោះនិយមសរសេរជាភាសាសំស្ក្រឹត ដែលជាភាសាជាន់ខ្ពស់របស់អ្នកប្រាជ្ញ។ អត្ថបទអក្សរសិល្ប៍ជាភាសាសំស្ក្រឹតភាគច្រើនជាពាក្យកាព្យ ដែលនិយាយអំពីកំណាត់ហេតុនៃប្រវត្តិរជ្ជកាល និងដើម្បីថ្លែងសរសើរស្តេច ឬមន្ត្រី។ ចំណែកឯអត្ថបទជាភាសាខ្មែរបុរាណវិញ ច្រើនជាពាក្យឧទ្ទិស ឬជាបញ្ជីរាប់ពលរេហ៍ រាប់វត្ថុដែលគេបូជាសម្រាប់បូជនីយដ្ឋានទាំងនោះ។ ស្នាដៃអក្សរសិល្ប៍ដ៏ល្បីល្បាញ គឺរឿងរាមកេរ្តិ៍ និងរឿងមហាភារតៈ ដែលគេសរសេរជាភាសាខ្មែរបុរាណ លាយចម្រុះភាសាសំស្ក្រឹត។ រឿងរាមកេរ្តិ៍ គឺជារឿងទីមួយរបស់ខ្មែរ។ រឿងរាមកេរ្តិ៍ខ្មែរមិនមែនប្រែត្រង់ៗពីរឿងរាមាយណៈឥណ្ឌាសុទ្ធសាធទេ។ ខ្មែរគ្រាន់តែប្រឌិតតាមប៉ុណ្ណោះ មានវគ្គខ្លះក៏ឃ្លាតចាកពីរឿងដើម មានវគ្គខ្លះក៏ប្រហាក់ប្រហែលគ្នា[27]។

ទន្ទឹមនឹងនោះ គេឃើញមានសាស្ត្រាត្រៃភូមិ ដែលនិយាយអំពីគំនិតរបស់មនុស្សជំនាន់ដើមក្នុងការកកើតទឹកដី កំណើតសត្វលោកក្នុងភពទាំង៣ គឺឋានសួគ៌ ឋានមនុស្ស និងឋាននរក។ អ្នកប្រាជ្ញល្បីៗដទៃទៀតមាន ៖

[27] លី ធាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ ៥៨។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(១) បណ្ឌិត **សិវាចារ្យ** ជាអធិការត្រួតត្រាខាងសីលធម៌ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស.១០០២-១០៤៩) ដែលបានតែងសិលាចារឹកជាភាសាសំស្ក្រឹតនៅប្រាសាទតាកែវ។

(២) បណ្ឌិត **កវិន្ទ្រ:**[28] ជាអ្នកប្រាជ្ញយ៉ាងធំ និងជាអ្នកនិពន្ធយ៉ាងឆើតក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០) និងមានតួនាទីជាព្រះរាជគ្រូ។ លោកបានតែងនិពន្ធសិលាចារឹកប្រាសាទខ្នា[29] ជាភាសាសំស្ក្រឹត ដើម្បីសរសើរតេជ:បារមីរបស់ព្រះបាទសូរ្យវរ្ម័នទី១ ដែលមានសេចក្តីក្លាហានមោះមុតក្នុងការធ្វើសឹក។

(៣) បណ្ឌិត **សទាសិវ** ត្រូវជាក្មួយរបស់បណ្ឌិត **សិវាចារ្យ**។ លោកជាកវីនិពន្ធដែលតែងសិលាចារឹកប្រវត្តិសាស្រ្ត **ស្តុកកក់ធំ** (K-235D)។ នៅក្នុងរាជ្យរបស់ព្រះបាទ **សូរ្យវរ្ម័នទី១** ព្រាហ្មណ៍ **សទាសិវ** ត្រូវបានតែងតាំងជា **ជយេន្ទ្របណ្ឌិត** និងបានរៀបអភិសេកជាមួយប្អូនស្រីរបស់ព្រះមហាក្សត្រីយ៍ **វិរលក្ស្មី** ដែលជាប្អូនថ្លៃរបស់ព្រះអង្គ។ បន្ទាប់មក **សទាសិវ** ត្រូវបានព្រះបាទ **ឧទយាទិត្យវរ្ម័នទី២** ដែលឡើងសោយរាជ្យនៅឆ្នាំ១០៥០ តែងតាំងជារាជ្យគ្រូ និងមានឋាន:ជា **ធូលីជេងវ្រះកម្រតេង**។ សិលាចារឹក **ស្តុកកក់ធំ** (K-235D) អាចចាត់ទុកថា ជាស្នាដៃអក្សរសិល្ប៍បែបប្រវត្តិសាស្រ្តដ៏សំខាន់ជាងគេ[30]។

(៤) បណ្ឌិត **ភូបេន្ទ្រ:**[31] គឺជាអ្នកប្រាជ្ញល្បីល្បាញ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.ស.១១៨០-១២២០) ជាអធិបតីលើគណ:អ្នកប្រាជ្ញ និងមានតួនាទីជាចៅក្រមល្បីខាងចំណេះនីតិសាស្រ្ត។ លោកបាននិពន្ធសិលាចារឹកប្រាសាទទរ[32] ដែលស្ថិតនៅក្នុងតំបន់វត្តភូ ប្រទេសឡាវ ដើម្បីថ្លែងសរសើរព្រះកិត្តិគុណរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលមានព្រះមេត្តាធម៌ក្រៃលែង ព្រមទាំងសមិទ្ធិធំៗ ដែលជាស្នាព្រះហស្តនៃព្រះមហាវិរក្សត្រអង្គនេះ។

ព្រះវិហារសាសនាព្រាហ្មណ៍ ត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលសិក្សារៀនសូត្រនៅក្នុងអាណាចក្រខ្មែរ។ ព្រាហ្មណ៍ដែលជាឧត្តមមន្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងអាណាចក្រខ្មែរ។ នៅស.វ.ទី១០ក្នុងរាជព្រះបាទ **រាជេន្ទ្រវរ្ម័ន** ព្រាហ្មណ៍ **សិវាចារ្យ** ជាហោតរ **កវិន្ទ្រារីមថន** ជាស្ថាបត្យកររកសាងរាជវាំង និងប្រាសាទមេបុណ្យខាងកើត និង

[28] លី ធាមតេង (១៩៦០) «អក្សរសាស្រ្តខ្មែរ» ទំព័រ ៦៥។

[29] Coedès, G, Inscription du Cambodge, T. 1, p. 195-219.

[30] Burgess, J, (2010), Stories in Stone : The Sdok Kok Thom Inscription & the Enigma of Khmer History, River Books, Bangkok.

[31] លី ធាមតេង (១៩៦០) «អក្សរសាស្រ្តខ្មែរ» ទំព័រ ៦៦។

[32] Coedès, G, Inscription du Cambodge, T. 1, p. 227-249.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រាហ្មណ៍ **យជ្ញវរាហៈ** ជាព្រះរាជគ្រូ[33]។ ប្រាសាទ **បន្ទាយស្រី** (ត្រិភូវនមហេស្វរ) ដ៏ល្បីល្បាញត្រូវបានកសាងឡើងនៅក្នុងឆ្នាំ៩៦៧ ដោយព្រាហ្មណ៍ **យជ្ញវរាហៈ**។ ទន្ទឹមនឹងនេះ គេក៏ឃើញវត្តមាននៃព្រះពុទ្ធសាសនាមហាយាន នៅដើមសម័យអង្គរផងដែរ[34]។

ដូច្នេះ ប្រព័ន្ធអប់រំនៃអាណាចក្រខ្មែរសម័យមហានគរ គឺជាប្រព័ន្ធអប់រំតាមបែបសាសនា ដែលផ្សារភ្ជាប់ជាមួយនឹងព្រហ្មញ្ញសាសនា ហើយសម្រាប់តែកូនស្តេច និងកូនចៅនៃមន្ត្រីធំៗតែប៉ុណ្ណោះ[35] ពោល គឺជាប្រព័ន្ធអប់រំសម្រាប់វិញ្ញូជន[36]។ ការសិក្សាត្រូវធ្វើឡើងជាភាសាសំស្ក្រឹត ដែលជាភាសានៃព្រហ្មញ្ញសាសនានិងជាភាសាខ្ពង់ខ្ពស់។ អាស្រមសាសនាព្រាហ្មណ៍ ឬ **ធម្មសាលា** មានតួនាទីបីយ៉ាងគឺ ៖ លំនៅស្ថានរបស់ក្រុមព្រាហ្មណ៍បុរោហិត មជ្ឈមណ្ឌលអប់រំ និងជាកន្លែងស្នាក់អាស្រ័យសម្រាប់អ្នកពនេចរ[37]។ មុខងារចម្បងរបស់ក្រុមព្រាហ្មណ៍បុរោហិតគឺរៀន និងបង្រៀនគម្ពីរវេទ(ចំណេះដឹង)។ ព្រាហ្មណ៍បុរោហិត មានងារជារាជគ្រូ ឬព្រះគ្រូ ទទួលបន្ទុកក្នុងការអប់រំដល់ក្រុមរាជបុត្រ។ រាជគ្រូមានតួនាទីជាទីប្រឹក្សាពិសេស និងជាមហាឧបរាជ។ បណ្ណាល័យ(pustakasram[38]) សម្រាប់រក្សាទុកអត្ថបទពិសិដ្ឋត្រូវបានសាងសង់ជាទូទៅនៅសងខាងនៃទីសក្ការៈសំខាន់។ Dagens បានបង្ហាញថាមនុស្សបួននាក់ធ្វើការនៅក្នុងបណ្ណាល័យនេះ ៖ «បណ្ណារក្សម្នាក់ និងកម្មករបីនាក់ ដើម្បីរៀបសាស្ត្រាស្លឹករឹត សម្រាប់រយៈពេលពីរសប្តាហ៍»[39]។

ទន្ទឹមនឹងការបណ្តុះបណ្តាលវណ្ណៈជាន់ខ្ពស់ឱ្យយល់ដឹងខាងផ្នែកសាសនា អាទិភាពដ៏សំខាន់មួយទៀត គឺការបណ្តុះបណ្តាលអ្នកឯកទេសជំនាញខាងផ្នែកសាងសង់ប្រាសាទ។ ថ្វីត្បិតតែយើងគ្មានសក្ខីកម្ម ដែលបញ្ជាក់ពីរចនាសម្ពន្ធនៃប្រព័ន្ធអប់រំសម័យអង្គរ យើងអាចសន្និដ្ឋានបានថា ព្រះរាជគ្រូក៏មានចំណេះដឹង និងការទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលស្ថាបត្យករ និងវិស្វករ ដែលត្រូវទៅបំពេញការងារនៅតាមការដ្ឋានតាមប្រាសាទបូរាណទាំងនោះ។ ជាក់ស្តែង ក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី៧** ប្រាសាទព្រះខ័ន គឺជាសាកលវិទ្យាល័យសម្រាប់បណ្តុះបណ្តាលថ្នាក់អាណាចក្រ ហើយព្រះនាង **ឥន្ទ្រទេវ** ដែលជាអគ្គមហេសីទី២នៃព្រះបាទ **ជ័យវរ្ម័នទី៧** ជាសកលវិទ្យាធិការតែម្តង ដោយព្រះ

[33] ត្រឹង ងា (១៩៧៨) «ប្រវត្តិសាស្ត្រខ្មែរ» ភាគ១ Editions Angkor ទំព័រ ៩៥។

[34] Harris (2005) Cambodian Buddhism : History and Practice, Silkwom Books, p. 15.

[35] Chou Ta-kuan, *Customs of Cambodia*. p. 9; see also Edwards, P. (2007), Cambodge: The Cultivation of a Nation, 1860-1945, University of Hawaii Press, Honolulu, p. 71.

[36] Elitist education system

[37] Thach Toan (2012), Les Khmers à l’ère de l’hindouisme (50-1336 apr. J.-C.). Les secrets d’Angkor. L’Harmattan. Paris. p. 95.

[38] Pustaka មានន័យថាសៀវភៅ។

[39] Bruno Dagens (2005), Les Khmers. Les belles lettres. Paris. p. 284.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាងមានព្រះបញ្ញាញាណ និងចំណេះដឹងយ៉ាងខ្ពង់ខ្ពស់។ ព្រះនាង **ឥន្ទ្រទេវី** ទ្រង់បានណែនាំព្រះរាជាឱ្យមានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា និងការកសាងវប្បធម៌ជាតិ ដូចជាការបង្កើតឱ្យមានសាលាជាន់ខ្ពស់សម្រាប់បង្រៀនកូនចៅខ្មែរ និងបង្កើតវង់ភ្លេងសម្រាប់សំដែងសិល្បៈខ្មែរជាដើម [40] ។ កម្មវិធីសិក្សាត្រូវផ្តោតទៅលើការអប់រំខាងផ្នែកព្រហ្មញ្ញសាសនា ភាសាសំស្ក្រឹត តារាសាស្រ្ត វិទ្យាសាស្រ្តសំណង់ ស្ថាបត្យកម្ម បច្ចេកទេសក្នុងការធ្វើសង្គ្រាម។ល។ ទន្ទឹមនឹងនេះ ប្រាសាទព្រហ្មញ្ញសាសនាគឺជាកន្លែងសម្រាប់បណ្តុះជំនាញ ជាងចម្លាក់ និងជាងធ្វើការតាមការដ្ឋានសំណង់ ហើយជំនាញទាំងនេះ អាចត្រូវបានផ្ទេរពីឪពុកទៅកូន ពីមនុស្សជំនាន់មួយទៅជំនាន់មួយទៀត។

ពុទ្ធសាសនាបែបមហាយាន ត្រូវបាននាំចូលមកក្នុងអាណាចក្រខ្មែរដោយព្រះបាទ **ជ័យវរ្ម័នទី៧** (១១៨១-១២១៨)។ បន្ទាប់ពីការចូលទិវង្គតរបស់ព្រះអង្គ ប្រទេសកម្ពុជាវិលទៅរកព្រហ្មញ្ញសាសនាវិញក្នុងរយៈពេល៥០ឆ្នាំ។ ចាប់ពីពាក់កណ្តាលស.វ.ទី១៣ រហូតដល់ដើមស.វ.ទី១៥ ប្រជាជនខ្មែរជឿព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន។ ទោះជាបែបនោះក្តី ព្រះពុទ្ធសាសនាហីនយានត្រូវបានលើកតម្កើងជាលើកដំបូង ជាសាសនាផ្លូវការរបស់អាណាចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦។ គេសន្និដ្ឋានថា ព្រះពុទ្ធសាសនាតាមបែបហីនយាននៅប្រទេសកម្ពុជារងឥទ្ធិពលជាលើកដំបូងតាមរយៈវប្បធម៌ **ទ្វារវតី** របស់ជនជាតិមន(Boisselier 1967)។ ការអប់រំក៏ត្រូវបានធ្វើតាមរយៈការគោរពប្រតិបត្តិពិធីសាសនាផ្សេងៗ ចម្លាក់ប្រាសាទ និងសិលាចារឹកជាភាសាសំស្ក្រឹតផងដែរ[41]។

នៅក្នុងឆ្នាំ១៨៩១ លោក Adhémard Leclère បានរកឃើញសិលាចារឹកមួយផ្ទាំងនៅប្រាសាទត្រពាំងព្រៃ ស្រុកសម្បូណ៌ ខេត្តក្រចេះ ដែលសាងសង់ឡើងក្នុងស.វ.ទី៧។ ការស្រាវជ្រាវរបស់លោក Coedès តាមរយៈការសិក្សាសិលាចារឹកស.វ.ទី៧ K-127 ដែលនាពេលបច្ចុប្បន្នស្ថិតនៅក្នុងអភិរក្សអង្គរ និងបញ្ជាក់ដោយលោក Amir Aczel បានរកឃើញថា ដូនតាខ្មែរគឺជាអ្នកបង្កើតលេខសូន្យមុនគេលើពិភពលោក [42] ។ ក្នុងឆ្នាំ១៩៣១ លោក Coedès បានបកប្រែអត្ថបទលើសិលាចារឹក K-127 នេះ មកជាភាសាបារាំង និងបាន

[40] លី ធាមតេង (១៩៦០) «អក្សរសាស្រ្តខ្មែរ» ទំព័រ ៦៧។

[41] សិលាចារឹកជាភាសាសំស្ក្រឹតចំនួន ៣ គឺជាសិលាចារឹកសម័យហ្វូណន (Ian Harris (2005), Cambodian Buddhism: History and Practice, Silkworm Books, p. 241).

[42] Aczel, Amir, (2015) Finding Zero : A Mathematician's Odyssey to Uncover the Origins of Numbers. New York, St. Martin's Press, p. 174-178.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កត់សម្គាល់ថា លេខជាភាសាខ្មែរ ៦០៥ នេះ គឺជាលេខសូន្យចាស់ជាងគេលើសិលាចារឹក ដែលគាត់បានរកឃើញ[43]។ លោក Coedès បានសរសេរអត្ថបទមួយក្នុងឆ្នាំ១៩៣១ [44]។

ក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី៧** (១១៨១-១២១៨) ព្រះពុទ្ធសាសនាមហាយាន ត្រូវបានចាត់ជាសាសនារដ្ឋ។ ព្រះបាទ **ជ័យវរ្ម័នទី៧** បានកសាងធម្មសាលាចំនួន១២១ (អាស្រម) នៅតាមបណ្ដោយផ្លូវសំខាន់ៗនានានៃចក្រភពរបស់ទ្រង់។ អ្នកសិក្សាចំនួន ២ ៨៩៨ បានសិក្សានៅ«វិទ្យាល័យ»ទាំងនេះ ក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីសម្ដេចព្រះគ្រូ និងក្រុមសាស្ត្រាចារ្យ។ សាលារៀនទាំងនេះត្រូវបានសម្របសម្រួលដោយព្រាហ្មណ៍នៅប្រាសាទ **ព្រះខ័ន**[45]។ យោងតាមសិលាចារឹក មុនពេលក្លាយជាព្រះមហាក្សត្រិយានី ព្រះអង្គម្ចាស់ក្សត្រី **ឥន្ទ្រទេវី** ដែលត្រូវបានគេចាត់ទុកជាព្រះអាទិទេពនៃចំណេះដឹងមកចាប់កំណើតនោះ[46] ត្រូវបានតែងតាំងដោយព្រះរាជា ជាសកលវិទ្យាធិការនៃសាកលវិទ្យាល័យជំនាន់អង្គរ គឺប្រាសាទ **ព្រះខ័ន**។

នៅចុងសម័យអង្គរ ក្នុងឆ្នាំ១៣៣៦ មានការរីកលូតលាស់ព្រះពុទ្ធសាសនាថេរវាទ ជំនួសឱ្យព្រះពុទ្ធសាសនាមហាយាន និងព្រហ្មញ្ញសាសនា។ ព្រះពុទ្ធសាសនាមហាយាន គឺជាសាសនា ដែលប្រើប្រាស់ភាសាសំស្ក្រឹតជាភាសាយាន។ ដូច្នេះហើយ ទើបនៅក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី៧** នៅចុងស.វ.ទី១២ និងដើមស.វ.ទី១៣ យើងឃើញថា សិលាចារឹក និងប្រាង្គប្រាសាទដែលសាងសង់ដោយព្រះអង្គសុទ្ធសឹងតែចារឹកជាភាសាសំស្ក្រឹត។

ខុសពីព្រហ្មញ្ញសាសនាដែលជាសាសនារបស់នាហ្មឺនមន្ត្រី ព្រះពុទ្ធសាសនាថេរវាទ គឺជាសាសនា ដែលប្រជាជនសាមញ្ញគោរពបូជានៅតាមតំបន់ជនបទ[47]។ ពុទ្ធសាសនា និងភាសាបាលី ដែលបាននាំចូលមកនៅស.វ.ទី១២[48] ក៏បានរីកដុះដាលបន្តិចម្តងៗ។ ចាប់ពីពេលដែលព្រះពុទ្ធសាសនាថេរវាទត្រូវបានប្រកាសជាសាសនារបស់រដ្ឋ ក្រុមបូជាចារ្យព្រាហ្មណ៍ជាច្រើន ដែលមានការអប់រំខ្ពង់ខ្ពស់បានភៀសខ្លួនចេញពីអាណាចក្រខ្មែរ ហើយមួយចំនួនបានរត់ភៀសខ្លួនទៅកាន់ប្រទេសសៀម និងត្រូវបានទទួលការយកចិត្តទុកដាក់ជាខ្លាំងដោយស្ដេចសៀម។ ចាប់ពីពេលនោះមកអាស្រមនានា(មជ្ឈមណ្ឌលសាសនា) ត្រូវ

[43] Aczel, Amir, (2015) Finding Zero, Opt. cit., p. 166.
[44] Coedès, G. (1931) “A propos de l’origine des chiffres arabes», Bulletin of the School of Oriential Studies (University of London) 6, no. 2, cited in Aczel, Amir, (2015) Finding Zero. Opt. cit., p. 95.
[45] Thach Toan (2009), Histoire des Khmers, p. 123.
[46] Thach Toan (2009), Histoire des Khmers, p. 124.
[47] Harris, p. 27.
[48] អ្នកស្រី ត្រឹង ងា (១៩៧៥) អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់ (កម្មវិធីថ្មី) ទំព័រ ៣៩។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានកាន់កាប់ដោយព្រះសង្ឃពុទ្ធសាសនា។ «*គម្ពីរព្រហ្មញ្ញសាសនា ព្រមទាំងសាលារៀនត្រូវបានបំផ្លាញ ក៏ព្រោះតែគ្រូទាំងនោះ គឺជាអ្នកគោរពបូជាព្រហ្មញ្ញសាសនាទាំងអស់*»[49]។ ការទទួលយកនូវពុទ្ធសាសនាថេរវាទ ធ្វើឱ្យជនជាតិខ្មែរឈប់សាងសង់ប្រាង្គប្រាសាទជាថ្ម ដែលបន្សល់ទុកនូវភស្តុតាងជាច្រើន ហើយចាប់ផ្តើមសាងសង់វត្តអារាម និងសំណង់ជាឈើវិញ។ ការចាកចេញនៃអ្នកប្រាជ្ញខាងសាសនាព្រាហ្មណ៍ និងខាងផ្នែកភាសាសំស្ក្រឹតពីអាណាចក្រខ្មែរ អាចឱ្យយើងធ្វើសេចក្តីសន្និដ្ឋានបានថា ការទទួលយកព្រះពុទ្ធសាសនាថេរវាទ បានធ្វើឱ្យភាសាសំស្ក្រឹតត្រូវបានជំនួសដោយភាសាបាលី ដែលជាភាសានៃពុទ្ធសាសនាថេរវាទ។ បើតាមលោក Coedès ដែលបានស្រាវជ្រាវអត្ថបទសិលាចារឹក ភាសាបាលីដែលជាភាសាសក្ការៈនៃព្រះពុទ្ធសាសនាថេរវាទ ត្រូវបានចាប់ប្រើប្រាស់នៅកម្ពុជានៅដើមស.វ.ទី១៤[50]។

យើងឃើញថា ចាប់ពីពេលដែលព្រះពុទ្ធសាសនាហីនយាន ត្រូវបានលើកតម្កើងជាសាសនារដ្ឋនៃអាណាចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦ រហូតដល់ពេលចាកចោលអង្គរនៅឆ្នាំ១៤៣២ គឺមានរយៈពេលជិត១០០ឆ្នាំ។ ដូច្នេះ ការធ្លាក់ចុះជាបណ្តើរៗនៅក្នុងស.វ.ទី១៤នេះ គឺបណ្តាលមកពីការបាត់បង់បញ្ញវន្ត និងធនធានមនុស្សខ្មែរ ដែលធ្លាប់រៀនសូត្រជាភាសាសំស្ក្រឹត។ ទន្ទឹមនឹងនេះប្រវត្តិវិទូក៏បានលើកពីសម្មតិកម្មដទៃទៀត ដូចជា ផលវិបាកនៃការចាញ់សង្គ្រាមជាមួយសៀម និងបញ្ហាផ្លាស់ប្តូរបរិស្ថានជាដើម។ ជាពិសេស របកគំហើញរបស់ក្រុមស្រាវជ្រាវនៃសាលាបារាំងចុងបូព៌ា តាមរយៈការគូរដោយបច្ចេកវិទ្យាស្កេនឡាស៊ែរពីលើអាកាស(LIDAR) នៅឆ្នាំ២០១៥ បានរកឃើញនូវទីក្រុងបុរាណខ្មែរ **មហេន្ទ្របវ៌ត**[51] ទាំងមូល ដែលមានទំហំ៥០គីឡូម៉ែត្របួនជ្រុងជុំវិញភ្នំគូលែន ដែលលាតសន្ធឹងដល់ប្រាសាទព្រះខ័នកំពង់ស្វាយ។ ក្នុងបរិវេណទីក្រុងដ៏ធំនេះ មានប្រាសាទថ្ម ការដ្ឋានស្លដែក ព្រមទាំងប្រព័ន្ធផ្លូវទឹកសម្រាប់ស្រោចស្រព និងចរាចរណ៍។ របកគំហើញនេះបញ្ជាក់ពីមូលហេតុនៃការធ្លាក់ចុះសម័យអង្គរ ដែលបណ្តាលមកពីការបាត់បង់ប្រជាជន[52]។ ប្រវត្តិវិទូក៏បានលើកឡើងពីការកើនឡើងនៃពាណិជ្ជកម្មនៅតំបន់ទន្លេចតុមុខនៃរាជធានីភ្នំពេញ

---

[49] Thach Toan (2012), Les Khmers à l’ère de l’hindouisme (50-1336 apr. J.-C.), p. 206.

[50] G. Coedès (1936), “Etudes cambodgiennes” (XXXII.- La plus ancienne inscription en pali du Cambodge), BEFEO, XXXVI, 1,, p. 14-21 : «Avec cette inscription nous avons désormais un témoignage tangible de l’existence du bouddhisme de langue pali au début du XIVe siècle.. », cited in យើង ហុកឌី (២០០៦) «រឿងល្បែងនិងបញ្ញាសជាតក-នានាជាតក» ក្នុង «សម្ភូហកម្មអក្សរសាស្ត្រខ្មែរ» បណ្ណាគារអង្គរ ភ្នំពេញ ទំព័រ ៧៩។

[51] ដែលជាពាក្យបាលី ដែលមានន័យថា ៖ ភ្នំនៃព្រះឥន្ទដ៏មហិមា ដែលជាទីតាំងនៃភ្នំគូលែនបច្ចុប្បន្ន។

[52] Further secrets of Kingdom revealed. The Phnom Penh Post, Monday, June 13, 2016; Research May Alter Accepted History of Angkor’s End. The Cambodia Daily, Monday, June 13, 2016; ក្រុមស្រាវជ្រាវរកឃើញថា ក្រុងអង្គរពីអតីតកាល លាតសន្ធឹងធំដូចរាជធានីភ្នំពេញបច្ចុប្បន្ន។ ភ្នំពេញប៉ុស្ត៍។ ថ្ងៃចន្ទទី១៣ ខែមិថុនា ឆ្នាំ ២០១៦។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលអាចជាមូលហេតុនៃការផ្លាស់ប្តូររាជធានីផងដែរ។ របកគំហើញមួយទៀតរបស់បុរាណវិទូអំពីមូលហេតុនៃការធ្លាក់ចុះនៃអារ្យធម៌អង្គរ គឺការរីងស្ងួតហួតហែងនៃបារាយណ៍ និងប្រព័ន្ធធារាសាស្ត្រនៃតំបន់អង្គរ។

ថ្វីត្បិតតែព្រះពុទ្ធសាសនាថេរវាទត្រូវលើកតម្កើងជាសាសនារដ្ឋនៃអាណាចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦ ក៏ប៉ុន្តែការទទួលយកព្រះពុទ្ធសាសនាថេរវាទនេះ អាចជាដំណើរការសន្សឹមៗ ដោយត្រូវឆ្លងកាត់ដំណាក់កាលអន្តរកាល ដែលមានដំណាក់កាលមួយនោះប្រជាជនកម្ពុជាគោរពបូជាក្នុងពេលតែមួយនូវព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនាមហាយាន និងព្រះពុទ្ធសាសនាថេរវាទ។ លោកបណ្ឌិតសភាចារ្យ **ឃីង ហុកឌី** បានលើកឡើងថា ៖ «ចាប់ពីស.វ.ទី១៣មក យុវជនបានទទួលការអប់រំពីវត្តអារាម ដែលមានព្រះសង្ឃជាគ្រូអាចារ្យ ឬឧបជ្ឈាយ៍»[53]។ សម្មតិកម្មនេះធ្វើឡើងដោយឈរលើមូលដ្ឋានកំណត់ត្រារបស់បេសកជនចិន **ជីវ តាក្វាន់** នៅពេលមកទស្សនាអង្គរនៅឆ្នាំ១២៩៥-១២៩៦ ដោយបញ្ជាក់ថា «បុត្រគ្រហស្ថនានាទៅសាលាដោយមានព្រះសង្ឃជាអ្នកបង្រៀនអប់រំ។ ដល់ធំចាកសិក្ខាបទមកកាន់ជីវិតគ្រហស្ថវិញ»[54]។

## ១.១.៤. ប្រព័ន្ធអប់រំខ្មែរនៅយុគសម័យលង្វែកនិងឧដុង្គ

នៅឆ្នាំ១៤៣២ ព្រះបាទ **ពញាយ៉ាត** ផ្លាស់ប្តូររាជធានីពីអង្គរមកទួលបាសាន ហើយក្រោយមកក៏រើរាជធានីមកភ្នំពេញនៅឆ្នាំ១៤៣៤ រហូតដល់ចុងស.វ.ទី១៥។ សម័យក្រោយអង្គរគឺជាសម័យកាល ដែលខ្មែរចុះដុនដាបខាងផ្នែកសេដ្ឋកិច្ច ដោយសារអស្ថិរភាពនយោបាយ ដែលបង្កើតឡើងដោយសារទំនាស់ផ្ទៃក្នុងរាជវង្សខ្មែរ ជាពិសេសបញ្ហាស្នងរាជ្យសម្បត្តិ ការឃុបឃិតនិងទំនាស់រវាងមន្ត្រីជាន់ខ្ពស់ និងសង្គ្រាមជាមួយប្រទេសជិតខាង។ ប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរ អាចចែកចេញជាពីរដំណាក់កាលធំៗ[55] ៖

*ដំណាក់កាលទី១* ពីឆ្នាំ១៤៣១ ដល់១៥៩៥ គឺជាដំណាក់កាលភ្នំពេញ-លង្វែក។ ភ្នំពេញស្ថិតនៅជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាធិបតីអស់រយៈពេល៣០ ឆ្នាំ។ ក្រោយមក រាជធានីបានលើកទៅស្រីសន្ធរ និងទៅលង្វែក។ នៅក្នុងដំណាក់កាលនេះ ស្តេចបីអង្គ

[53] ឃីង ហុកឌី (២០០៧) «អក្សរសិល្ប៍ខ្មែរ សតវត្សរ៍ទី២០៖ កវីនិពន្ធ និងកម្រងអត្ថបទ» (Littérature cambodgienne du XXème siècle: Écrivains et textes) សក្ខាសាលាស្តីអំពី«អក្សរសិល្ប៍ខ្មែរទំនើប» ឆ្នាំ២០០៥ រៀបចំដោយសមូហកម្ម អក្សរសិល្ប៍ នូ ហាច បណ្ណាគារអង្គរ ទំព័រ ១៦។

[54] Pelliot, P (1902). "Mémoires sur les coutumes du Cambodge de Tcheou Ta-Kouan », BEFEO, t. II, p. 151, cité dans ឃីង ហុកឌី (២០០៧) «អក្សរសិល្ប៍ខ្មែរ សតវត្សរ៍ទី២០» ទំព័រ ១៦។

[55] Khin Sok (1991). Le Cambodge entre le Siam et le Vietnam (de 1775 à 1869), EFEO, Paris, p. 27.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គឺ **ស្រីរាជា បរមរាជា** និង **អង្គចន្ទ** បានខិតខំពង្រឹងសន្តិភាព និងស្ថិរភាព ដោយធ្វើការទប់ទល់ជាមួយប្រទេសសៀម។ ស.វ.ទី១៦ ខ្មែរបានខិតខំប្រឹងប្រែងងើបឡើងវិញពីអន្ធការ។ ព្រះបាទ **អង្គចន្ទ** បានចាត់ចែងឱ្យមន្ត្រីធ្វើការជួសជុលអង្គរ និងឱ្យបណ្ឌិត **ជ័យនន្ទ**និពន្ធសិលាចារឹកអង្គរវត្ត[56]។ ក៏ប៉ុន្តែ នៅឆ្នាំ១៥៨៦ ស្តេច **សត្ថា** បានលើកបុត្រ **ជ័យជេដ្ឋា** និង **ពញាតន់** ដែលមានអាយុទើបតែ១១ ឆ្នាំ និង៦ ឆ្នាំឱ្យឡើងគ្រងរាជ្យ។ មន្ត្រីសព្វមុខអ្នកការមានការមិនសប្បាយចិត្ត ធ្វើឱ្យប្រទេសធ្លាក់ចុះទៅក្នុងវិបត្តិ។ បន្ទាប់ពីការវាយលុកពីប្រទេសសៀម ទីក្រុងលង្វែកត្រូវសៀមវាយបែកក្នុងឆ្នាំ១៥៩៤។ អ្នកចេះដឹងជាច្រើនត្រូវភៀសខ្លួនទៅស្រុកសៀម។ ស្នាដៃអក្សរសិល្ប៍ក៏ធ្លាក់ចុះដែរ ដោយមិនមានអ្វីបន្សល់ទុកជាដុំកំភួន។ ម្យ៉ាងវិញទៀត ក្រាំង និងសាស្ត្រាស្លឹករឹតក៏វិនាសខ្ទេចខ្ទីដោយសារសង្គ្រាមផងដែរ មិនបានបន្សល់ទុកដល់ជនជំនាន់ក្រោយ។ សាស្ត្រាជំនាន់អង្គរជាច្រើនត្រូវបានបាត់បង់ផងដែរនៅក្នុងសង្គ្រាម ខ្លះទៀតត្រូវគេប្រមូលយកទៅទីក្រុងអយុធ្យា[57] ហើយត្រូវភ្លើងឆេះអស់នៅពេលដែលភូមាដុតក្រុងអយុធ្យាក្នុងឆ្នាំ១៧៦៧។ នៅស.វ.ទី១៧ ខ្មែរបានខិតខំប្រឹងប្រែងកសាងប្រទេស ហើយស្នាដៃអក្សរសិល្ប៍ក៏ចាប់ផ្តើមងើបឡើងវិញដែរ។ ដូច្នេះហើយទើបយើងមិនមានអក្សរសិល្ប៍អ្វីដែលនៅសេសសល់ពីដំណាក់កាលលង្វែកឡើយ។

*ដំណាក់កាលទី២* គឺដំណាក់កាលឧដុង្គ នៅស.វ.ទី១៧ និង១៨ នៅពេលដែលស្ថានភាពនយោបាយនៅកម្ពុជាកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ។ ក្នុងរយៈពេល៣៥០ឆ្នាំ ពោលគឺពីឆ្នាំ១៧៧៦ ដល់១៨៦០ កម្ពុជាបានបាត់បង់ទាំងស្រុងនូវតួនាទីនៅជ្រោយកូសាំងស៊ីន។ កម្ពុជាធ្លាក់ចុះបន្តិចម្តងៗទៅក្នុងកលិយុគ។

ស្នាដៃអក្សរសិល្ប៍ត្រូវបានកត់ត្រាទុកលើក្រាំង ដែលជាសន្លឹកក្រដាសស្នាច់បត់ជាផ្នត់ និងលើស្លឹករឹត ដែលហៅថាសាស្ត្រា ដែលសរសេរជាពាក្យកាព្យ។ អក្សរសិល្ប៍សម័យកណ្តាលមានដូចជាសិលាចារឹក(សិលាចារឹក **ជ័យនន្ទ**) របាក្សត្រ ឬព្រះរាជពង្សាវតារ ក្រម-ក្បួន-តម្រា (Les codes cambodgiens) ច្បាប់-សុភាសិត រឿងព្រេង រឿងល្បែង និងវីរកថា[58]។

«**កម្រងច្បាប់ខ្មែរពីបូរាណ**» (Les codes cambodgiens) គឺជាព្រះរាជកេរមរតកវប្បធម៌នីតិសាស្ត្រ ធម្មសាស្ត្រ និងយុត្តិធម៌របស់អតីតព្រះមហាក្សត្រខ្មែរ ដែលផ្តួចផ្តើម

---

[56] Saveros Lewitz (1972), "Les inscriptions modernes d'Angkor Wat, » *Journal Asiatique* no. 260 (1972) : 1-2, 107-129 ; Edwards, P. (2007), Cambodge, p. 23.

[57] Khin Sok (1991). Le Cambodge entre le Siam et le Vietnam (de 1775 à 1869). EFEO. Paris. p. 31.

[58] សូមមើល ឃីង ហុកឌី (២០០៣) «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដោយព្រះបាទ **ជ័យជេដ្ឋាទី១** ពិនិត្យឡើងវិញដោយព្រះបាទ **ជ័យជេដ្ឋាទី២** (១៦១៨-១៦២៥) និងដោយព្រះបាទ **អង្គសួរ ជ័យជេស្ឋា** (១៦៧៥-១៧០៦) នៅស.វ.ទី១៧ និងបន្ទាប់មកត្រូវបានកែលម្អឡើងវិញដោយព្រះបាទ **អង្គឌួង** (១៨៤៧-១៨៦០) ចាប់ពីឆ្នាំ ១៨៥៣ តាមគំរូឯកសារដើម និងត្រូវបានព្រះបាទ **នរោត្តម** ត្រាស់បង្គាប់ឱ្យបង្កើយការងារត្រួតពិនិត្យដើម្បីបោះពុម្ពផ្សាយ មុនពេលដែលប្រព័ន្ធច្បាប់និងយុត្តិធម៌ខ្មែរបានទទួលរងឥទ្ធិពលពីប្រព័ន្ធច្បាប់និងយុត្តិធម៌បារាំង។ ថ្មីៗនេះក្រុមការងារស្រាវជ្រាវ និងចងក្រងបោះពុម្ពច្បាប់ខ្មែរពីបុរាណនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយលោកសាស្ត្រាចារ្យ Olivier de BERNON និងបណ្ឌិត **ហ៊ែល ចំរើន** បានបោះពុម្ពជាពីរភាគ ដែលមានច្បាប់និងក្រមទាំងអស់ចំនួន៣០[59]។

**ច្បាប់** [60] មានន័យម្យ៉ាងទៀតថាជាអត្ថបទអក្សរសិល្ប៍ទូន្មាន ដែលសរសេរជាកំណាព្យ ដែលអ្នកប្រាជ្ញបុរាណចងក្រងទុកសម្រាប់ប្រៀនប្រដៅ ពត់ហាត់កាយ វាចា ចិត្តរបស់កុលបុត្ត កុលធីតា អ្នកច្បាប់ មន្ត្រី បុរស ស្ត្រី ព្រមទាំងសម្រាប់កុមារ និងមាតាបិតាដោយខ្លឹមសារផ្តោតលើពលរដ្ឋវិជ្ជា របៀបរបបរស់នៅ (Hansen 2004, 43) និងត្រូវបានរៀនសូត្រដោយចាំមាត់ (Moura 1988, 1: 303)។ ច្បាប់ទូន្មាននេះត្រូវបានតែងនិពន្ធដោយកវីនិពន្ធខ្មែរចាប់តាំងពីស.វ.ទី១៥ មកម្ល៉េះសម្រាប់អប់រំប្រៀបប្រដៅមនុស្សនៅក្នុងសង្គមជាតិ និងនៅក្នុងគ្រួសារ។ ឧទាហរណ៍ «ច្បាប់រាជសម្ភារ» ច្បាប់ក្រម ច្បាប់ ហៃសាធុជន ឬច្បាប់ត្រីនេត្រ។ល។ អត្ថបទច្បាប់នេះគ្មានចុះកាលបរិច្ឆេទឡើយ។ ក៏ប៉ុន្តែ តាមគោលគំនិតពាក្យសម្តី និងទំនៀមទម្លាប់ ដែលមានចែងក្នុងអត្ថបទ គេអាចកំណត់ថា អត្ថបទភាគច្រើនកើតនៅក្នុងសម័យឧដុង្គរវាងស.វ.ទី១៧-១៨ និង១៩ ប៉ុណ្ណោះ[61]។ នៅក្នុងច្បាប់ផ្សេងៗ អ្នកនិពន្ធដកស្រង់គំនិតពីពុទ្ធឱវាទ(ដំបូន្មានរបស់ព្រះពុទ្ធ) គំនិតនិងពាក្យសម្តីពីបុរាណព្រមទាំងការពិសោធផ្ទាល់យកមកប្រៀនប្រដៅ។ អត្ថបទច្បាប់ពត់ហាត់មនុស្សឱ្យមានចរិយាល្អ ដើម្បីរស់នៅសុខសាន្តក្នុងសង្គម អប់រំឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវ តាមគន្លងប្រពៃណីជាតិ ដែលជាកេរអរិយធម៌យូរអង្វែងហើយ អប់រំឱ្យមានប្រាជ្ញាវាងវៃ បង្កើន

[59] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៦) «កម្រងច្បាប់ខ្មែរពីបុរាណ» (Codes anciens du Cambodge. Corpus de 1891) ក្រុមប្រឹក្សានីតិកម្ម។

[60] ច្បាប់ក្រម ច្បាប់កេរកាល ច្បាប់អរិយសត្ថា ច្បាប់ស្រី ច្បាប់ប្រុស ច្បាប់ទូន្មានខ្លួន ច្បាប់កូនចៅ ច្បាប់ពាក្យចាស់ ច្បាប់ បណ្តាំបិតា ច្បាប់កូនចៅល្បើក ច្បាប់វិធូរបណ្ឌិត ច្បាប់ត្រីនេតិ ច្បាប់ព្រះរាជសម្ភារ។ល។ សូមអាន «ច្បាប់ផ្សេងៗ» ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៩៥។

[61] សេចក្តីសង្កេតចំពោះច្បាប់ផ្សេងៗ។ «ច្បាប់ផ្សេងៗ» (១៩៩៥) ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ។

សណ្តាប់ធ្នាប់ល្អ រស់នៅតាមគន្លងច្បាប់គ្រប់គ្រងប្រទេស ពោលគឺជាមធ្យោបាយជួយដោះស្រាយបញ្ហាក្នុងសង្គម និងរៀបចំគ្រួសារ ឬសង្គមជាតិឱ្យសុខក្សេមក្សាន្ត។

«**សាស្ត្រាល្បែង**» គឺជាអត្ថបទអក្សរសិល្ប៍ដែលពេញនិយមនៅសម័យឧដុង្គ។ រឿងល្បែងគឺជាស្នាដៃអក្សរសិល្ប៍ ដែលច្នៃប្រឌិតសម្រាប់ប្រលោមលួងលោមអារម្មណ៍អ្នកអានក្នុងកម្រងភាសាកំណាព្យដ៏ប្រណីត ពោលគឺជាកម្រងអត្ថបទរឿងរ៉ាវបែបប្រពៃណីដែលតាក់តែងជាកាព្យឃ្លោងឡើង នៅរវាងស.វ.ទី១៨-១៩[62]។ អ្នកនិពន្ធបំបែរគោលដៅទៅរកការអប់រំ ការសម្រាលទុក្ខសោក រោគភ័យមួយចំណែកធំរបស់មនុស្សជាតិ។ «**សាស្ត្រាល្បែង**»[63] គឺសាស្ត្រាដែលអានសម្រាប់បន្ធូរចិត្តទុក្ខព្រួយ ចិត្តលំបាកតឹងតែង ឱ្យធូរស្រាល[64]។

«**រឿងព្រេង**»[65] គឺជាការនិទាន សេចក្តីតំណាលតាមលំដាប់លំដោយ ដែលដូនតាយើងនិទានពីមាត់មួយទៅមាត់មួយជាយូរលង់ណាស់មកហើយ និងដែលឆ្លុះបញ្ចាំងឱ្យឃើញពីទំនៀមទម្លាប់ និងប្រពៃណីរបស់ជនជាតិខ្មែរយើង។ រឿងព្រេងទាំងអស់នេះត្រូវបានកត់ត្រាទុកដោយកវីបណ្ឌិតខ្មែរ ជាសំណេរលើស្លឹករឹត ឬលើក្រដាស ដើម្បីទុកជាកេរឱ្យខ្មែរជំនាន់ក្រោយ។ រឿងព្រេងភាគច្រើនត្រូវបានសរសេរជាពាក្យរាយ ហើយគ្មានកាលបរិច្ឆេទទេ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិតបានចងក្រងរឿងព្រេងខ្មែរ និងបានបោះពុម្ពផ្សាយរហូតដល់ឆ្នាំ១៩៧២ ជា«ប្រជុំរឿងព្រេងខ្មែរ» ដែលមាន ៨ ភាគ និងមានរឿងទាំងអស់ចំនួន២១៦។ លោកស្រី ពៅ សាវរស បានចែករឿងព្រេងទាំងនេះជា ៖ រឿងល្បើករឿងព្រេងទាក់ទងនឹងដំណើរហេតុផ្សេងៗ រឿងព្រេងប្រជាប្រិយ និងរឿងព្រេងសម្រាប់ស្ថាបនា[66]។

អ្នកនិពន្ធខ្មែរសម័យក្រោយអង្គរ ដែលយើងនិយមហៅថាអក្សរសិល្ប៍សម័យកណ្តាលបានបង្កើតស្នាដៃជាអក្សរសិល្ប៍ពុទ្ធនិយម ដោយសារអ្នកនិពន្ធជ្រើសរើសយករឿងក្នុងជាតកបែបបាលី(មានបញ្ញាសជាតក ឬជាតកក្នុងអដ្ឋកថានៃព្រះត្រៃបិដក) មកច្នៃតែងតាមចិត្តរបស់ខ្លួន ដើម្បីសម្រេចទៅតាមទស្សនសម័យនោះ គឺបញ្ហាល្អ អាក្រក់ បុណ្យបាប ក្នុងកម្មផល និងអត្ថន័យនៃរឿងរ៉ាវជាច្រើននៅសម័យឧដុង្គ[67]។

[62] យឹង ហុកឌី (២០០៣) «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» ទំព័រ៩៦។

[63] ដូចជារឿង ក្រុងសុភមិត្រ(១៧៩៨) ភោគកុលកុមារ(១៩៤០) កាកី(១៨១៥) ដាវរឿង(១៨៣៧)។ល។

[64] លាង ហាប់អាន (១៩៦៧) «សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ៖ សម័យនគរភ្នំដល់សម័យឧដុង្គ(សតវត្សរ៍ទី១ ដល់១៨៥៩)» ទំព័រ ២១៥។

[65] យឹង ហុកឌី (២០០៣) «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» ទំព័រ ៩២-៩៤។

[66] Pou, S. (1977), Etude sur le Ramakerti (XVIe-XVIIe siècles), Paris, Pub. EFEO, p. 33-35.

[67] លាង ហាប់អាន (១៩៦៧) «សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ ៖ សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សរ៍ទី១ ដល់ ១៨៥៩)»ទំព័រ ២១២-២១៣។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អក្សរសិល្ប៍ពុទ្ធនិយមចែកចេញជាពីរប្រភេទ គឺអក្សរសិល្ប៍ពុទ្ធនិយមពិត ដែលអ្នកនិពន្ធបានដកស្រង់ចេញពីគម្ពីរទសជាតក និងអក្សរសិល្ប៍ពុទ្ធនិយមក្លាយ ដែលអ្នកនិពន្ធបានដកស្រង់ចេញពីគម្ពីរបញ្ញាសជាតក ដូចជារឿងក្រុងសុភមិត្រ រឿងព្រះសុធន រឿងភោគកុលកុមារ រឿងសព្វសិទ្ធិ រឿងមរណមាតា រឿងចៅស្រទបចេកជាដើម [68] ។ ការនិពន្ធអត្ថបទអក្សរសិល្ប៍ខ្មែរ និងច្បាប់ជាពាក្យកាព្យបានឈានដល់ចំណុចកំពូលក្នុង ស.វ.ទី១៨-១៩។ ទំព័រប្រវត្តិសាស្ត្រខ្មែរដ៏ឈឺចាប់បានបណ្តុះកវីនិពន្ធជាច្រើនជំនាន់ ដើម្បីធ្វើការតស៊ូតាមរយៈកំណាព្យ ដើម្បីឱ្យវប្បធម៌ជាតិបានរស់។ ម្យ៉ាងវិញទៀត កវីនិពន្ធជំនាន់នោះមានការជួយទំនុកបម្រុង និងឧបត្ថម្ភដោយមជ្ឈដ្ឋានផ្លូវការ ហើយព្រះមហាក្សត្រក៏ព្រះអង្គតែងតែយកព្រះទ័យទុកដាក់លើកវីនិពន្ធណាស់ ដោយផ្តល់គោរមងារ និងតែងតាំងកវីនិពន្ធឱ្យកាន់ការធំក្នុងរាជការទៀតផង។ ខ្ញុំសូមសម្រាំងជ្រើសរើសតែអ្នកនិពន្ធខ្មែរល្បីៗសម័យកណ្តាលតែមួយចំនួនប៉ុណ្ណោះ ៖

(១) អ្នក **ម៉ាំង គាត**[69] គឺជាអ្នកនិពន្ធ ដែលសរសេរកំណាព្យ«ល្បើកអង្គរ» ជាបទព្រហ្មគីត បទកាកគតិ និងបទពំនោល ដែលអ្នកគ្រូ ពៅ សាវរស បានបកស្រាយតាមវិទ្យាសាស្ត្រនៃភាសាវិទ្យាថា សរសេរនៅឆ្នាំ១៦២០[70]។ កំណាព្យនេះ ដែលសរសេរឡើងនៅពេលដែលប្រជាជនកម្ពុជាមានជំនឿលើព្រះពុទ្ធសាសនាថេរវាទ បានឆ្លុះបញ្ចាំងពីលទ្ធិសុខដុមនីយកម្មរវាងសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធ[71]។

(២) **ព្រះរាជសម្ភារ** ដែលជាកវីរាជក្នុងស.វ.ទី១៧ (គ.ស.១៦២៩-១៦៣០)។ ព្រះអង្គជាព្រះរាជបុត្រច្បងរបស់ព្រះបាទជ័យជេដ្ឋា និងអ្នកម្នាងសុន ដែលមានព្រះនាមថា ព្រះអង្គតូ ក្រោយមកជាព្រះស្រីធម្មរាជា។ ដោយមានវិបត្តិស្នេហាជាមួយព្រះនាងអង្គវតី ដែលជាមហេសីរបស់ស្តេចមា ព្រះបាទឧទ័យ ព្រះអង្គបានភៀសព្រះកាយទៅខេត្តក្រចេះ ហើយត្រូវបានទ័ពព័រទុយហ្គាល់បាញ់សុគត។ ស្នាព្រះហស្តរបស់ព្រះអង្គមាន ច្បាប់រាជនីតិ កំណាព្យ«ច្បាប់រាជសម្ភារ» (ឆ្នាំ១៦២២) លិខិតផ្ញើទៅថ្វាយព្រះម៉ែយូរវត្តី ពាក្យកាព្យសរសេរលើចុងត្នោត មុនពេលសុគតដោយទាហានព័រទុយហ្គាល់បាញ់ កំណាព្យសរសើរ

---

68 ម៉ុញ សាវី (២០១១) ទំព័រ ២៦៨។

69 ម៉ុញ សាវី (២០១១) ទំព័រ ១៦៦។

70 ល្បើកអង្គរវត្ត អារម្ភកថាដោយ ឃីង ហុកឌី (២០០៦) Editions Angkor ទំព័រ XI។

71 Edwards, P. (2007), Cambodge: The Cultivation of a Nation, 1860-1945, University of Hawaii Press, Honolulu, p. 23.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហោមន្តមាស កំណាព្យ«កន្លង់មាសមង្គលថ្លៃ» កំណាព្យ«ព្រលឹងមាសអើយ» ច្បាប់ក្រម និងច្បាប់ហៃសាធុជន ឬច្បាប់ត្រីនេត្រ[72]។

(៣) បណ្ឌិត **ជ័យនន្ទ** ជាកវី និងមន្ត្រីមួយរូប ដែលនិពន្ធកំណាព្យជាភាសាខ្មែរ នៅឆ្នាំ១៧០១ នៅក្នុងរាជ្យព្រះបាទជ័យចេស្តា ឬចុងរាជ្យព្រះរាជសម្ភារ។ លោកបានតែងសិលាចារឹកមួយ ដែលប្រកបដោយសម្ផស្សជើងកាព្យ ដែលអាចយកជាគំរូមេកាព្យបាន។

(៤) ឧកញ៉ាកោសាធិបតី **កៅ** ជាកវីឯកក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី២។ លោកត្រូវបានតែងតាំងជាចៅហ្វាយឃ្លាំងមណីរតន៍ក្នុងព្រះបរមរាជវាំង និងជាទីប្រឹក្សាច្បាប់របស់ព្រះមហាក្សត្រ។ លោកបានសរសេររឿង «**ក្រុងសុភមិត្រ**» នៅឆ្នាំ១៧៩៨។

(៥) ឧកញ៉ាព្រះឃ្លាំង **នង** ជាប្អូនបង្កើតរបស់ព្រះមាតានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម។ លោកបានបួសរៀន និងបានធ្វើជាចៅអធិការនៅវត្តចតុទិសនៃក្រុងឧដុង្គ ដោយបានទទួលសមណសក្តិជាមហាព្រហ្មមុនី។ ឧកញ៉ាព្រះឃ្លាំង **នង** ជាកវីឯកនៅក្នុងរាជ្យព្រះបាទអង្គអេង និងព្រះបាទអង្គចន្ទ។ លោកបានសរសេរស្នាដៃខាងអក្សរសាស្ត្រជាច្រើន រហូតដល់បានឡើងងារជាឧកញ៉ាព្រះឃ្លាំង ជាងារចាងហ្វាងក្រុមព្រះរាជបណ្ឌិត និងជាព្រះរាជនិពន្ធរបស់ព្រះរាជាទៀតផង។ ស្នាដៃរបស់លោកមាន ៖ ច្បាប់សុភាសិត (១៧៩០) លោកនេយ្យជាតក(១៧៩៤) បុញ្ញសាសិរសា(១៧៩៧) រឿង «**ភោគកុលកុមារ**» (១៨០៤)វរនុជវរនេត្រ(១៨០៦) ព្រះសមុទ្រ(១៨០៨) និង ពង្សាវតារ(១៨១៨)។

(៦) ព្រះបទុមបរមី **ពេជ្រ** ជាអ្នកនិពន្ធរបារក្សត្រស្រុកខ្មែរ (Histoire des rois du pays khmer) នៅឆ្នាំ១៨៣៥ ហើយបោះពុម្ពផ្សាយនៅឆ្នាំ១៩៥៨។ ព្រះអង្គជាមេគណខេត្តបាភ្នំ និងជាអ្នកចេះដឹងជ្រៅជ្រះនៅសម័យនោះ។ របារក្សត្រនេះចែកចេញជា ៣ ក្បាល។ ក្បាលទី១ លើកឡើងពីអន្តរាគមន៍សៀមក្នុងឆ្នាំ១៨១២ ដែលជំរុញឱ្យវៀតណាមធ្វើអន្តរាគមន៍យោធាតាមការអញ្ជើញរបស់ស្តេចអង្គចន្ទ ការកេណ្ឌប្រជាពលរដ្ឋទៅជីកព្រែកវិញតេនិងវិញអាន និងការបះបោរប្រឆាំងនឹងវៀតណាម។ ក្បាលទី២ លើកឡើងពីការបង្ក្រាបរបស់វៀតណាមទៅលើមេបះបោរខ្មែរ ចលនាកម្ទេចវត្តមានជនជាតិវៀតណាមក្នុងចំណោមមន្ត្រីរាជការនិងកងទ័ពខ្មែរ អន្តរាគមន៍របស់សៀម ការចាកចេញរបស់វៀតណាម និងការត្រឡប់របស់វៀតណាមនៅឆ្នាំ១៨២៧។ ក្បាលទី៣ លើកឡើងពី

[72] លាង ហាប់អាន (១៩៦៧) «ប្រវត្តិអក្សរសាស្ត្រខ្មែរ៖ សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សរ៍ទី១ដល់១៨៥៩)» ទំព័រ ២១៩-២៣០។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការកម្ទេចមន្ត្រីរាជការ និងមេទ័ពខ្មែរដោយវៀតណាម ការចាប់ស្តេចអង្គអឹម និងសង្គ្រាមរវាងសៀម និងវៀតណាមនៅឧដុង្គនៅឆ្នាំ១៨៣៥[73]។

នៅមានកវីបណ្ឌិតជាច្រើនទៀត ដែលបាននិពន្ធស្នាដៃនៅក្នុងស.វ.ទី១៨-១៩ តែមិនបានដាក់ឈ្មោះនៅលើស្នាដៃអក្សរសិល្ប៍របស់ខ្លួន ដូចជារឿងពុទ្ធិសែន ព្រះសុធនទិព្វសង្វារ ហង្សយន្ត រាជកុល រតនាវង្សសង្ខសិល្ប៍ជ័យ ជាដើម។

អស់ជាច្រើនស.វ.បន្ទាប់ពីការដួលរលំនៃសម័យអង្គរ ទីអារាមព្រះពុទ្ធសាសនាបានក្លាយជាមជ្ឈមណ្ឌលសិក្សារៀនសូត្រ និងក្លាយទៅជាទីកន្លែងសម្រាប់ថែរក្សា និងអភិរក្សវប្បធម៌ ហើយបព្វជិតព្រះពុទ្ធសាសនា គឺតំណាងឱ្យបញ្ញាជនកម្ពុជា។ *ប្រព័ន្ធអប់រំខ្មែរសម័យក្រោយអង្គរ គឺជាប្រព័ន្ធអប់រំបែបព្រះពុទ្ធសាសនា*។ វត្តអារាមមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ឱ្យមកបម្រើនៅក្នុងរាជការ។ ភាសាយាន គឺភាសាបាលី ដែលជាភាសាកម្រិតខ្ពស់ និងភាសាខ្មែរ ដែលជាភាសាសម្រាប់ប្រជាជនសាមញ្ញ។ ប្រព័ន្ធអប់រំនេះមានចំណុចខ្លាំង និងចំណុចខ្សោយរបស់វា។ ចំណុចខ្លាំងស្ថិតត្រង់ថា ការអប់រំបែបព្រះពុទ្ធសាសនាត្រូវផ្តោតលើការរៀនសូត្រព្រះត្រៃបិដក ច្បាប់ស្នាដៃអក្សរសិល្ប៍ និងគម្ពីរសាស្ត្រានានា ដែលជាមូលដ្ឋាននៃសាសនាព្រះពុទ្ធ។ ក៏ប៉ុន្តែដោយសារសំណង់វត្តអារាមគឺជាសំណង់ឈើ គេគ្មានតម្រូវការក្នុងការបណ្តុះបណ្តាលស្ថាបត្យករ ឬវិស្វករឡើយ។ ដូច្នេះហើយ កម្មវិធីសិក្សាគ្មានមុខវិជ្ជាដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ ដូចនៅអារ្យប្រទេសឡើយ។ ជាក់ស្តែង យើងគ្មានភស្តុតាងពីវត្តមានអ្នកប្រាជ្ញខាងផ្នែកគណិតវិទ្យា ឬវិទ្យាសាស្ត្រនៅប្រទេសកម្ពុជាឡើយ។ ក៏ប៉ុន្តែ ប្រព័ន្ធអប់រំពុទ្ធសាសនានេះក៏បានផលិតនូវអ្នកប្រាជ្ញ កវីនិពន្ធល្បីៗដែលបង្កើតនូវចលនាអក្សរសិល្ប៍ពុទ្ធនិយមដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការស្ល ឱ្យអរិយធម៌ខ្មែរមានភាពសម្បូណ៌បែប។

ជាសរុបមក អរិយធម៌ខ្មែរមានប្រភពចេញពីលទ្ធិព្រាហ្មណ៍និយមផង ជាពិសេស គឺអរិយធម៌ជំនាន់អង្គរ និងលទ្ធិពុទ្ធនិយមផង ដូចជាគម្ពីរ **ទសជាតក៍**[74] ដែលជាអរិយធម៌ខ្មែរជំនាន់ក្រោយអង្គរ។

[73] Khin Sok (1991), Le Cambodge entre le Siam et le Vietnam (de 1775 à 1860), EFEO, Paris, pp. 5-8.

[74] ទសជាតក គឺជាប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមសម្ពុទ្ធក្នុង ១០ ជាតិ ដែលចែងក្នុងរឿងទាំង១០ ៖ (១) តេមិយជាតក (២)មហាជនកជាតក (៣) សុវណ្ណសាមជាតក (៤) នេមិរាជតក (៥) មហោសថជាតក (៦) ភូរិទត្តជាតក (៧) ចន្ទកុមារជាតក (៨) នារទជាតក (៩) វិធុរជាតក និង (១០) វេស្សន្តរជាតក។ រឿងទាំងនេះផ្តល់នូវដំបូន្មាន និងភាសិតសំខាន់ៗ ប្រកបដោយឧត្តមគតិ។ នៅក្នុងឆ្នាំ ១៩៥៨ គណៈកម្មការរៀបចំកម្មវិធីសិក្សានៃក្រសួងអប់រំជាតិ បានបញ្ចូលរឿងសង្ខេបទសជាតក ក្នុង កម្មវិធីសិក្សា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងអំឡុងស.វ.ទី១៩ នៅពេលដែលមានជម្លោះរវាងពួកសៀម និងពួកវៀតណាម ក្នុងការកាន់កាប់ត្រួតត្រាកម្ពុជា វប្បធម៌ខ្មែរគឺសឹងផុតរលត់ ក៏ព្រោះថាវត្តអារាមត្រូវបានកម្ទេច និងបំផ្លាញចោល[75]។ ប្រព័ន្ធអប់រំនៃប្រទេសខ្មែរនៅដើមស.វ.ទី១៩ ត្រូវបានបំផ្លាញដល់ឫសគល់។ កម្ពុជានៅពេលនោះខ្វះអ្នកប្រាជ្ញ និងឧត្តមមន្ត្រីដែលមានប្រាជ្ញា ថាមពល និងសមត្ថភាពដែលអាចជួយសង្គ្រោះប្រទេសជាតិឱ្យរួចចាកផុតពីគ្រោះមហន្តរាយបាន[76]។ តាមការពិត ប្រព័ន្ធអប់រំនៅកម្ពុជាមុនស.វ.ទី២០ ជាប្រព័ន្ធមួយ ដែលឈរលើមូលដ្ឋាននៃរចនាសម្ពន្ធសង្គម ដែលមិនមែនស្ថាប័នទេ តែគឺបុគ្គលជាអ្នកដើរតួនាទីឈានមុខនៅក្នុងរដ្ឋបាល។ ក្នុងប្រព័ន្ធអប់រំបែបប្រពៃណីនេះ ព្រះសង្ឃរាជ បព្វជិតព្រាហ្មណ៍ អ្នកប្រាជ្ញកវីនិពន្ធ គឺជាសសរស្តម្ភនៃប្រព័ន្ធអប់រំតាមបែបប្រពៃណី[77]។ នៅពេលខ្លះ ចតុស្តម្ភនៃរដ្ឋបាលសាធារណៈ គឺឧកញ៉ាយមរាជ ឧកញ៉ាវាំង ឧកញ៉ាក្រឡាហោម និងឧកញ៉ាចក្រី ក៏អាចជាអ្នកប្រាជ្ញបានដែរ។ ជានិច្ចជាកាល ព្រះមហាក្សត្រតែងតែជ្រើសរើសមន្ត្រី និងឧត្តមមន្ត្រី ក្នុងចំណោមអ្នកចេះដឹង និងកវីនិពន្ធ។ ឧត្តមមន្ត្រីគឺជាប្រភព និងជាសសរស្តម្ភនៃអំណាច និងភាពស្មោះត្រង់ ហើយកិច្ចដំណើរការរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមរយៈទំនាក់ទំនងជាបុគ្គល[78]។ នៅពេលដែលធនធានមនុស្សទាំងនោះបាត់បង់ទៅ ប្រព័ន្ធអប់រំក៏ដួលរលំដែរ។ ព្រះបាទ **អង្គឌួង** បានខិតខំប្រឹងប្រែងក្នុងការស្តារ និងកសាងប្រព័ន្ធអប់រំខ្មែរឡើងវិញ នៅក្នុងរជ្ជកាលរបស់ទ្រង់ ដោយស្តារឡើងវិញនូវព្រះពុទ្ធសាសនា និងសាលាវត្ត។

## ១.២. ការស្តារប្រព័ន្ធអប់រំឡើងវិញក្នុងរជ្ជកាលព្រះបាទ អង្គឌួង

សង្គមនីមួយៗតែងតែកសាងប្រព័ន្ធអប់រំ បញ្ញត្តិនៃការបង្រៀន និងរៀន កម្មវិធីសិក្សា ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សា តាមរយៈការអនុវត្តវិធីសាស្ត្របង្រៀន និងគរុកោសល្យ ដែលសមស្របទៅនឹងប្រព័ន្ធសាលារៀនរបស់ខ្លួនរៀងៗខ្លួន។ នៅដើមស.វ.ទី១៩ វិស័យអប់រំនៅកម្ពុជាស្ទើរតែធ្លាក់ដល់ចំណុចសូន្យ ដោយសារតែសង្គ្រាមជាមួយសៀម និងវៀតណាម ព្រមទាំងការបះបោរនៅក្នុងស្រុកជាច្រើនទសវត្សរ៍។ នាម៉ឺនខ្មែរធំៗព្រមព្រៀងគ្នាទៅយាងព្រះបាទ **អង្គឌួង** ពីប្រទេសសៀម ឱ្យស្តេចយាងមកគ្រងរាជ្យ

[75] រឿង បណ្តាំតាមាស (១៩០៨) ទំព័រ ៩០ បោះពុម្ពឡើងវិញដោយបណ្ណាគារអង្គរ។

[76] ឃីង ហុក ឌី (២០០៣) «មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី១៩» ទំព័រ៧។

[77] Mak Phoeun (1980), « L’Introduction de la Chronique Royale du Cambodge du lettré Nong », BEFEO, 67 (1980) : 144 ; Edwards, P. (2007), Cambodge: The Cultivation of a Nation, 1860-1945, University of Hawaii Press, Honolulu, p. 70.

[78]Mabbet and Chandler, The Khmer, p. 161; Edwards, P. (2007), Cambodge: The Cultivation of a Nation, 1860-1945, University of Hawaii Press, Honolulu, p. 71.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រោចស្រង់ប្រទេសជាតិ។ ព្រះចៅសៀមទ្រង់យល់ព្រម និងបានចាត់ពញាបឌិន ដែលជាមេទ័ពឱ្យដង្ហែទ្រង់ត្រឡប់មកវិញនៅឆ្នាំ១៨៤១។ ប្រទេសសៀម និងវៀតណាមបានចុះសន្ធិសញ្ញានៅខែធ្នូ ឆ្នាំ១៨៤៥ ដើម្បីប្រគល់រាជបល្ល័ង្កខ្មែរមកព្រះអង្គឌួងវិញ។ ព្រះបាទសម្តេចព្រះហរិរក្សរាមា **អង្គឌួង** [79] បានឡើងគ្រងរាជសម្បត្តិនៅឆ្នាំ១៨៤៨ ដោយមានវត្តមានរបស់តំណាងមហាក្សត្រមកពីប្រទេសសៀម និងវៀតណាម។ ចាប់តាំងពីពេលនោះមក ប្រទេសខ្មែរបានស្គាល់នូវសុខសន្តិភាពបរិបូណ៌ ជាហេតុឱ្យព្រះអង្គអាចដាក់ចេញនូវកំណែទម្រង់រដ្ឋ និងបានកសាងឡើងវិញនូវប្រព័ន្ធអប់រំ។

ការកសាងប្រទេសនៅក្នុងស.វ.ទី១៩ បានចាប់ផ្តើមដំបូង ដោយលើកតម្កើងជាថ្មីនូវព្រះពុទ្ធសាសនា។ នេះក៏ព្រោះថាព្រះបាទ **អង្គឌួង** បានចាត់ទុកវិស័យព្រះពុទ្ធសាសនាជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យមានសន្តិភាព និងការរស់ឡើងវិញនៃកម្ពុជា[80]។ ព្រះអង្គមានព្រះរាជបញ្ញាឱ្យប្រមូលនូវពុទ្ធវចនៈទាំងឡាយ មានគម្ពីរព្រះត្រៃបិដកជាដើម។ ការលើកតម្កើងជាថ្មីនៃវិស័យព្រះពុទ្ធសាសនានៅកម្ពុជា ក៏បានជួយក្នុងការបង្កើតលក្ខខណ្ឌចាំបាច់ក្នុងការកសាងឡើងវិញនូវវិស័យអប់រំ។ ព្រះសង្ឃខ្មែរពីរអង្គ គឺសម្តេចព្រះមហាព្រហ្មមុនី **និល ទៀង**[81] (១៨២៣-១៩១៣) ដែលជាសម្តេចព្រះសង្ឃរាជ សង្ឃនាយកខាងគណៈមហានិកាយ និងសម្តេចព្រះវិមលធម្ម **ប៉ាន**[82] បញ្ញាសីលោ(១៨២៤-១៨៩៤) ដែលជាសម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកខាងគណៈធម្មយុត្តិ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវមហិច្ឆតារបស់ព្រះបាទ **អង្គឌួង** ក្នុងការកសាងព្រះពុទ្ធសាសនាឡើងវិញ។ សម្តេចសង្ឃទាំងពីរព្រះអង្គបានទទួលនូវការគោរពជាខ្លាំង ហើយទ្រង់ក៏មានការអប់រំបែបពុទ្ធចក្របានយ៉ាងជ្រៅជ្រះ។ ព្រះបាទ **អង្គឌួង** ទ្រង់និមន្តសម្តេចទាំងពីរព្រះអង្គឱ្យបង្រៀនព្រះត្រៃបិដកដល់សិស្សានុសិស្ស។ ព្រះតេជគុណ **និល ទៀង** បាន

---

[79] ព្រះបាទ **អង្គឌួង** បានរៀនសូត្រចេះដឹងនៅទីក្រុងបាងកក និងទំនុកបម្រុងដោយរាជវង្សថៃ (See Hansen A. R. (2008) How to Behave: Buddhism and Modernity in Colonial Cambodia, 1860-1930. Silkworm Books. Chiang Mai. p. 49).

[80] Hansen. Ibid. p. 50; See also Leclère (1914), Adhémard. Histoire du Cambodge. Paris: Librairie Paul Geuthner. pp. 434-440; Chandler, David (1996). Facing the Cambodian Past. Chiang Mai: Silkworm Books. pp. 104-105, 108).

[81] ព្រះភិក្ខុ **និល ទៀង** បួសជាសាមណេរនៅក្នុងឆ្នាំ១៨៣៤ ក្នុងវ័យ ១១ វស្សា បន្ទាប់មកត្រូវបានព្រះចៅណាំក្លារនៃក្រុងសៀម រាជានុញ្ញាតឱ្យបំពេញឧបសម្បទាជាភិក្ខុក្នុងវ័យ២២វស្សា នៅវត្តព្រះកែវមរកត នៅទីក្រុងបាងកក។ ព្រះអង្គជាអ្នកប្រាជ្ញមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ចេះភាសាបាលី សំស្ក្រឹត និងសៀមយ៉ាងច្បាស់លាស់។ នៅឆ្នាំ១៨៤៩ ព្រះអង្គបានត្រឡប់ពីប្រទេសសៀមមករស់នៅក្រុងឧដុង្គវិញ តាមការនិមន្តរបស់ព្រះបាទ **អង្គឌួង**។ ព្រះអង្គត្រូវបានតែងតាំងជាសម្តេចព្រះមហាសង្ឃរាជគណៈមហានិកាយក្នុងវ័យ ៣៥ ព្រះវស្សា (លី សុវីរ ដំណើរប្រវត្តិ (២០០៨) «ស្តីពីសាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និង ក្រុមជំនុំ៣» ទំព័រ ៨ និង លាង ហាប់អាន (១៩៦៥) «អ្នកនិពន្ធខ្មែរ» ទំព័រ ៣៧)។

[82] ព្រះភិក្ខុ **ប៉ាន** ត្រឡប់ពីប្រទេសសៀម ទៅកាន់ក្រុងឧដុង្គវិញនៅឆ្នាំ១៨៥៤។ ព្រះអង្គត្រូវបានតែងតាំងជាសម្តេចព្រះសុគន្ធាធិបតី គណៈធម្មយុត្តិកនិកាយ ក្រោយការចូលទិវង្គតរបស់សម្តេចព្រះសុគន្ធាធិបតី (លី សុវីរ (២០០៨) «ដំណើរប្រវត្តិស្តីពីសាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និង ក្រុមជំនុំ៣» ទំព័រ៨ និងលាង ហាប់អាន (១៩៦៥) «អ្នកនិពន្ធខ្មែរ» ទំព័រ៣៧។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រៀបចំឡើងវិញផ្នែករដ្ឋបាលសង្ឃ[83]។ ព្រះបាទ **អង្គឌួង** កាលនោះ ក៏បានជួសជុល និងកសាងព្រះវិហារនានា។ ព្រះបាទ **អង្គឌួង** បាននាំគណៈធម្មយុត្តិកនិកាយពីសៀមមកដែរ ដោយបានសាងសង់វត្តធម្មយុត្តិកនិកាយនៅឧដុង្គ គឺវត្តសាលាគូ ឬវត្តអំពិលបី ហើយនៅពេលដែលព្រះបាទ **នរោត្តម** ចាកចោល ក្រុងឧដុង្គមានជ័យមកភ្នំពេញ សម្តេចព្រះមហាសុគន្ធាធិបតី **ប៉ាន** ដែលជាសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ក៏បាននិមន្តពីវត្តអំពិលបី មកគង់នៅវត្តវត្តបុទុមវតីរាជវរារាម[84]។ ធម្មយុត្តិកនិកាយនេះ គឺជាកំណែទម្រង់ផ្នែកព្រះពុទ្ធសាសនា ដែលធ្វើឡើងដោយស្តេច **មង្គុត** (រាមាទី ៤) នៃប្រទេសសៀម ដែលជាព្រះរាជបិតារបស់ព្រះបាទ **ជូឡាឡុងករន** (រាមាទី ៥)។ និកាយធម្មយុត្តិផ្តោតខ្លាំងទៅលើការធ្វើឱ្យមានភាពស្អាតស្អំទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងសនិទាននិយម ដើម្បីសម្រេចបាននូវការយល់ដឹងពិតប្រាកដនៃព្រះត្រៃបិដក។ ទំនើបកម្មនៃព្រះពុទ្ធសាសនានេះផ្តល់អាទិភាពទៅលើការគោរពវិន័យ ឧទាហរណ៍ការអានគម្ពីរព្រះត្រៃបិដក និងការសិក្សាភាសាបាលី ដែលចាត់ថា ជាការគោរពគោលការណ៍ព្រះពុទ្ធសាសនា។

កំណែទម្រង់វិស័យអប់រំរបស់ព្រះបាទ **អង្គឌួង** មានរួមបញ្ចូលទាំងការកសាងឡើងវិញនូវបណ្ណាល័យ និងការប្រមូលគម្ពីរព្រះពុទ្ធសាសនា ដែលបានបាត់បង់ ឬក៏ត្រូវបានបំផ្លាញក្នុងអំឡុងពេលសង្គ្រាម ការប្រមូលកុមារឱ្យចូលរៀននៅតាមសាលាវត្ត ការផ្តល់អាហារូបករណ៍សិក្សាដល់យុវជនកម្ពុជា ដើម្បីសិក្សាភាសាបរទេសនៅប្រទេសសិង្ហបុរី និងការរៀនសូត្រភាសាបាលី និងគម្ពីរព្រះត្រៃបិដក[85]។ នៅឆ្នាំ១៨៥៤ ព្រះបាទ **អង្គឌួង** ទ្រង់ព្រះតម្រិះថា នៅកម្ពុជាគ្មានព្រះត្រៃបិដកភាសាបាលី ដែលជាគោលនៃការប្រតិបត្តិព្រះពុទ្ធសាសនា និងជាមូលដ្ឋាននៃខេមរភាសា ទើបទ្រង់ឡាយចុតហ្មាយមួយច្បាប់ទៅកាន់ព្រះបាទរាមាទី ៤ **ព្រះចមក្លាវ** ដោយបានស្នើសុំគម្ពីរព្រះត្រៃបិដកជាភាសាបាលី[86]។ ព្រះរាជាសៀម **ព្រះចមក្លាវ** សព្វព្រះទ័យយល់ព្រមថ្វាយ រួចទ្រង់ប្រគេនព្រះត្រៃបិដក[87] ចំនួន ៨០ គម្ពីរ និងមានព្រះរាជឱង្ការឱ្យព្រះអមរាភិរក្ខិត **កេត** ជូនដំណើរព្រះមហា **ប៉ាន** ដើម្បីនាំមកថ្វាយដល់ព្រះបាទ **អង្គឌួង**។ សម្តេចព្រះមហាសង្ឃរាជ **នូរ** ត្រូវបានតែងតាំង

---

[83] Hansen. (2008) Ibid. p. 86.

[84] ស៊ិន សុវណ្ណនិ (២០១២) «ឯកសារស្រាវជ្រាវក្រុមជំនុំប្រែគម្ពីរ ព្រះត្រៃបិដកនៃប្រទេសកម្ពុជា» គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ ទំព័រ ៦៥។

[85] លាង ហាប់អាន (១៩៦៥) «អ្នកនិពន្ធខ្មែរ» ទំព័រ ១០-១១។

[86] King Ang Duong’s view was that there was no Tripitaka in Pali, which is the source of Khmer language as well (លាង ហាប់អាន. «អ្នកនិពន្ធខ្មែរ ព្រះបាទអង្គឌួង៖ ព្រះជីវប្រវត្តិ-ស្នាព្រះហស្ថ» បណ្ណាគារ អ៊ឹង ហ៊ុន គ.ស. ១៩៦៥. Reproduced by Editions Angkor. p. 34). Hansen. How to Behave. Ibid. p. 79.

[87] Leang Hap An (in Khmer), p. 35.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាសង្ឃនាយកទទួលបន្ទុកការបណ្តុះបណ្តាលខាងផ្នែកស្មារតី, ចំណែកឯព្រះតេជគុណ **អ៊ុក** វិញ ត្រូវបានតែងតាំងជាមហាសង្ឃរាជាធិបតី ទទួលបន្ទុកការអប់រំគ្រហស្ថ[88]។ ព្រះអង្គបានកសាងព្រះវិហារនៅឧដុង្គ កសាងសាលាទាន ទ្រង់ឱ្យអ្នកប្រាជ្ញរាជបណ្ឌិតតែងច្បាប់តាមសម័យនិយម ទ្រង់ជ្រើសរើសនាម៉ឺនក្នុងចំណោមអ្នកមានចំណេះជ្រៅជ្រះ និងទ្រង់ព្រះបញ្ញាឱ្យកុមារទៅរៀននៅវត្ត។

អក្ខរកម្មភាសាខ្មែរមានវិបុលភាពជាខ្លាំងក្នុងរជ្ជកាលព្រះបាទ **អង្គឌួង** ហើយទ្រង់ព្រះអង្គឯងក៏ជាអ្នកនិពន្ធដ៏ល្បីល្បាញផងដែរ។ ស្នាព្រះហស្ថរបស់ព្រះអង្គមាន ៖ រឿងចម្ប៉ាថោង(១៨១០) រឿងកាកី(១៨១៥-នៅពេលទ្រង់មានព្រះជន្ម ១៩ វស្សានៅឡើយ) និងច្បាប់ស្រី(១៨៣៧)។

ក្នុងរជ្ជកាលព្រះបាទ **អង្គឌួង** ព្រះពុទ្ធសាសនាថេរវាទ ឬហីនយាន សិល្បៈខ្មែរ អក្សរសាស្ត្រ និងវប្បធម៌បានរស់រានមានជីវិតឡើងវិញ។ ក្នុងសម័យរជ្ជកាលព្រះអង្គ មានអ្នកប្រាជ្ញខាងអក្សរសាស្ត្រសំខាន់ៗដូចជា ៖ អរិយគាមមុនី **ឥន** បាននិពន្ធរឿងព្រះជិនវង្ស (១៨៥៦) ព្រះធម្មបញ្ញា **ម៉ែន** បាននិពន្ធរឿងពេជ្ជតា(១៨៥៧) អម្រឹតក្សត្រី **ម៉ុក** (ឬលោកឧកញ៉ាសន្ធរវោហាម៉ុក) បាននិពន្ធរឿងទេវន្ទ(១៨៥៩) ឧកញ៉ា **យ៉ែម** បាន និពន្ធរឿងវិមានចន្ទ(១៨៥៩) ហើយអ្នកនិពន្ធដែលលេចធ្លោបំផុតនៅសម័យនោះគឺ ឧកញ៉ាព្រះឃ្លាំង **នង** ដែលបាននិពន្ធរឿងលោកន័យជាតក(១៧៩៤) បុញ្ញសាសិរសា(១៧៩៧) ភោកុលកុមារ (១៨០៤) និង ច្បាប់សុភាសិត(១៨០៩)។

មុនការមកដល់របស់បារាំង កម្ពុជាមានប្រព័ន្ធនយោបាយ ដែលទទួលរងឥទ្ធិពលពីប្រទេសឥណ្ឌា។ ការគ្រប់គ្រងប្រទេសត្រូវបានបែងចែកជាតំបន់ ឬរង្វង់ រៀបចំឡើងជុំវិញអ័ក្សកណ្តាល ដែលជាភ្នំព្រះសុមេរុ ឬព្រះមហាក្សត្រ។ នៅព័ទ្ធជុំវិញ មានអាណាចក្រតូចៗ ឬជាខេត្តដែលដឹកនាំដោយស្តេចត្រាញ់ ឬដែលទទួលស្គាល់អានុភាពរបស់ព្រះមហាក្សត្រ និងដែលនៅចាំការពារមជ្ឈិម[89]។ ប្រព័ន្ធអប់រំនៅពេលនោះ ក៏ត្រូវបានរៀបចំដូចប្រព័ន្ធរដ្ឋបាលនយោបាយដែរ។

---

[88] Ian Harris, p. 46.

[89] Guérin, Mathieu (2011), 'Domination coloniale et modernization au Cambodge', in Journal de recherche sur le Cambodge, Nos 12-13 (2010-2011), p. 30.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៣. ទំនើបកម្មប្រព័ន្ធអប់រំខ្មែរសម័យអាណាព្យាបាលបារាំង

### ១.៣.១. ការកសាងជាតិតាមរយៈការអប់រំ

នៅស.វ.ទី១៩ បារាំងបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសម្បត្តិវប្បធម៌ ជាពិសេសសម្បត្តិវប្បធម៌នៅប្រទេសអាណានិគម។ នៅក្នុងសម័យអាណាព្យាបាល អ្នកស្រាវជ្រាវបារាំងជាច្រើនបានចូលរួមចំណែកក្នុងការស្រាវជ្រាវ និងអភិរក្សវប្បធម៌និងអរិយធម៌ខ្មែរ។ ដូច្នេះហើយទើបមានអ្នកស្រាវជ្រាវបារាំងជាច្រើនបានមកដល់កម្ពុជា។ ជនជាតិបារាំងទី១ ដែលទៅទស្សនាអង្គរគឺលោក Henri Mouhot ដែលបានទៅដល់ទីនោះនៅឆ្នាំ១៨៦០ និងបានបោះពុម្ពផ្សាយពីដំណើររបស់លោកពីព្រៃនគរទៅអង្គរ នៅក្នុង Revue Maritime et Coloniale ក្នុងឆ្នាំ១៩៦៣។ ក្នុងរយៈពេលបម្រើការងារនៅកម្ពុជា តំណាងជាន់ខ្ពស់បារាំងប្រចាំកម្ពុជា[90] ក្នុងឆ្នាំ ១៨៦៤-១៨៦៥ លោក Doudart de Lagrée បានធ្វើដំណើរទៅអង្គរ ដើម្បីទៅសិក្សាពីប្រភពវប្បធម៌ និងអរិយធម៌ខ្មែរផងដែរ។ បន្ទាប់ពីបានសិក្សាស្រាវជ្រាវពីអង្គរអស់ជាច្រើនឆ្នាំ បុរាណវិទូបារាំងលោក Louis Delaporte បានប្រមូលនូវពុម្ពចម្លាក់អង្គរ ដើម្បីចូលរួមក្នុងពិព័រណ៍សកលលោក (Exposition universelle) ក្នុងឆ្នាំ១៨៧៨ ដែលធ្វើឱ្យប្រាសាទអង្គរកាន់តែមានកិត្តិនាមល្បីរន្ទឺសុសសាយខ្លាំងឡើង។

លោកស្រី Penny Edwards បានសរសេរនិក្ខេបបទថ្នាក់បណ្ឌិតមួយ ដែលមានចំណងជើងថា៖ CAMBODGE: The Cultivation of a Nation, 1860-1945[91], «**ការកសាងជាតិកម្ពុជាឡើងវិញ**»។ នៅក្នុងនិក្ខេបបទនេះ លោកស្រីបានធ្វើការសិក្សាពីតួនាទីរបស់អាជ្ញាធរអាណាព្យាបាលបារាំង ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបម្រើការងារនៅក្នុងរដ្ឋបាលអាណានិគម និងការអភិរក្សវប្បធម៌ខ្មែរ។ នៅក្នុងឆ្នាំ១៨៨៥

អគ្គទេសាភិបាលកូសាំងស៊ីន[92] Charles Thomson បានធ្វើការប្តេជ្ញាចិត្ត លើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំជាភាសាបារាំងនៅកម្ពុជា ក្នុងគោលដៅលើកកម្ពស់ធនធានមនុស្សកម្ពុជាឱ្យបានឆាប់រហ័ស ដើម្បីការងារក្នុងរដ្ឋបាលអាណានិគមនិយម[93]។ គោលនយោបាយនេះមានគោលដៅកាត់បន្ថយការប្រើប្រាស់មន្ត្រីរាជការជាជនជាតិវៀតណាម និងធ្វើឱ្យខ្មែរកាន់តែទុកចិត្តបារាំងកាន់តែខ្លាំងឡើង[94]។

---

[90] Résident supérieur au Cambodge (RSC).
[91] Edwards, P. (2007), Cambodge: The Cultivation of a Nation, 1860-1945, University of Hawaii Press, Honolulu, p. 349.
[92] Gouverneur général de l'Indochine (GGI).
[93] Edwards, P. (2007), Op.cit., p. 74.
[94] CAOM, INDO GGI 12232, Governor of Cochinchina to Representative du Protectorat du Cambodge, 29 April 1885, 1-2, cited in Edwards, P. (2007), Cambodge, p. 74.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការអភិវឌ្ឍធនធានមនុស្សក្នុងសម័យអាណាព្យាបាលបារាំង ត្រូវបានលើកកម្ពស់តាមរយៈការអនុវត្តវិធានការពីរសំខាន់ៗ ៖ ទីមួយ-ការបញ្ជូននិស្សិតកម្ពុជាឱ្យទៅរៀននៅតាមគ្រឹះស្ថានសិក្សានៅបារាំង និងនៅវៀតណាម និងទីពីរ-ការបង្កើតប្រព័ន្ធអប់រំផ្លូវការតាមរយៈការបង្កើតសាលារដ្ឋខ្មែរ-បារាំងនៅកម្ពុជា។

ដើម្បីពង្រឹងរដ្ឋបាលអាណានិគម លោក August Pavie បានផ្តួចផ្តើមគំនិតបង្កើតសាលាកម្ពុជា (École Cambodgienne) នៅទីក្រុងប៉ារីស ហើយបានជ្រើសរើសកូនមន្ត្រីជាន់ខ្ពស់ខ្មែរចំនួន ១៣ នាក់ ដើម្បីយកទៅបណ្តុះបណ្តាល ដើម្បីប្រើប្រាស់ក្នុងរដ្ឋបាលអាណានិគម។ ក្នុងឆ្នាំ១៨៨៦ ***សាលាកម្ពុជា*** ត្រូវបានបង្កើតឡើងនៅទីក្រុងប៉ារីស ហើយពីឆ្នាំ១៨៨៥ ដល់១៨៨៩ សាលានេះបណ្តុះបណ្តាលតែនិស្សិតកម្ពុជាប៉ុណ្ណោះ។ ក្នុងចំណោមនិស្សិតដែលទទួលការបណ្តុះបណ្តាលដំបូង មានអនាគតសេនាបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការ **ពេជ្រ ម៉ុណ្ណ** ដែលជាកូនឧកញ៉ាមេត្រីភូតុន និងអនាគតនាយករដ្ឋមន្ត្រី **ជួន សម្បត្ត** (១៨៦៤-១៩៥០) ផងដែរ។ ក្នុងឆ្នាំ១៨៨៩ ***សាលាកម្ពុជា*** ត្រូវបានប្រែក្លាយទៅជា ***សាលាអាណានិគម*** (École Coloniale) សម្រាប់បណ្តុះបណ្តាលនិស្សិតមកពីបណ្តាប្រទេសអាណានិគមនិយមរបស់បារាំង និងជនជាតិបារាំងដែលមានបំណងធ្វើការជាមន្ត្រីនៅតាមប្រទេសអាណានិគមទាំងនោះ។ ក្រោយសង្គ្រាមលោកលើកទី២ លោកប្រធានាធិបតី Charles De Gaule បានប្រែក្លាយ ***សាលាអាណានិគម*** នេះឱ្យទៅជា ***សាលារដ្ឋបាលជាតិ*** (École Nationale d'Administration) ក្នុងឆ្នាំ ១៩៤៩ សម្រាប់បណ្តុះបណ្តាលនិស្សិត ដែលមានបំណងចង់បម្រើការងារនៅក្នុងរដ្ឋការបារាំង។

ដោយសារមានតម្រូវការជ្រើសរើសមន្ត្រី ឱ្យចូលបម្រើការងារនៅក្នុងរដ្ឋបាលអាណានិគម អាជ្ញាធរបារាំងបានផ្តួចផ្តើមគំនិតបង្កើតសាលាបារាំង-ខ្មែរ។ លោក Paul Beau ដែលឡើងធ្វើជាអគ្គទេសាភិបាលឥណ្ឌូចិន ជំនួសលោក Paul Doumer ពីឆ្នាំ១៩០២ ដល់១៩០៨ បានផ្តល់អាទិភាពដល់ការអភិវឌ្ឍវិស័យអប់រំនៅឥណ្ឌូចិន[95]។ ទន្ទឹមនឹងការចាំបាច់ក្នុងការបំពេញតម្រូវការនៃរដ្ឋការបារាំង វិស័យឯកជនក៏ត្រូវការពលករ ដែលមានចំណេះដឹងផងដែរ។ ទន្ទឹមនឹងនេះ ***សាលារដ្ឋបាលកម្ពុជា*** (École Cambodgienne d'Administration) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩១៧ ដើម្បីបណ្តុះបណ្តាលមន្ត្រីរាជការដោយផ្តោតលើមុខវិជ្ជានីតិសាស្ត្រ រដ្ឋបាល និងវប្បធម៌ទូទៅ[96]។

---

[95] Edwards, P. (2007), Cambodge, p. 75.
[96] Edwards, P. (2007), Cambodge, p. 76.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.៣.២. ការអភិរក្សអង្គរនិងការបង្កើតអត្តសញ្ញាណជាតិខ្មែរ

អត្តសញ្ញាណខ្មែរប្រាស្រ័យភ្ជាប់គ្នា តាមរយៈមនោសញ្ចេតនា ជំនឿ សាសនា ភាសា ទំនៀមទម្លាប់ ប្រពៃណី សិល្បៈ សំណង់ សង្គម ការរស់នៅរបស់ជនជាតិខ្មែរ[97] ។ល។ ដូច្នេះហើយ ការស្រាវជ្រាវអំពីវប្បធម៌ និងអរិយធម៌ខ្មែរ គឺជាការបង្កើតនូវអត្តសញ្ញាណជាតិខ្មែរ ដើម្បីឱ្យឃើញថា ខ្មែរខុសពីជាតិសាសន៍ដទៃដូចម្តេចខ្លះ។ សាស្ត្រាចារ្យ ត្រឹងងា បានឱ្យនិយមន័យ **អរិយធម៌** ថាជា ៖ (១) វប្បធម៌ដែលមានជំនឿ សាសនា ភាសា អក្សរ-សាស្ត្រ សិល្បៈ តូរ្យតន្ត្រី ទំនៀមទម្លាប់ ប្រពៃណី ប្រាង្គប្រាសាទ ការអប់រំ កីឡា ល្បែងកំសាន្ត ច្បាប់ និង (២) សង្គមធម៌ ដែលមានលំនៅ ចំណីអាហារ សម្លៀកបំពាក់ សេដ្ឋកិច្ច សង្គមកិច្ច របៀបគ្រប់គ្រងរដ្ឋ វណ្ណៈសង្គម ស្ថាប័ន និងអង្គការសង្គមជាដើម[98]។ នៅក្នុងផ្នែកនេះ យើងនឹងពិចារណាថា តើបារាំងបានធ្វើអ្វីខ្លះក្នុងការបង្កើតអត្តសញ្ញាណជាតិខ្មែរ ? លោក Paul Doumer ដែលត្រូវបានតែងតាំងជាអគ្គទេសាភិបាលឥណ្ឌូចិនពីឆ្នាំ១៨៨៧ ដល់១៩០២ គឺជាអ្នកយកចិត្តទុកដាក់ដល់ការអភិរក្ស និងការស្រាវជ្រាវពីបេតិកភណ្ឌ។ បន្ទាប់ពីឧបទ្វីបឥណ្ឌូចិនមានភាពស្ងប់ស្ងាត់បន្តិច បន្ទាប់ពីការបះបោរប្រឆាំងបារាំងកាលពីជាង ១០ មុន លោកបានដាក់ចេញនូវកម្មវិធីកំណែទម្រង់រដ្ឋបាល។ ក្នុងឆ្នាំ១៩០០ លោកបានចេញប្រកាសស្តីពីការអភិរក្សបេតិកភណ្ឌប្រវត្តិសាស្ត្រ នៅឥណ្ឌូចិន ហើយលោក Étienne Lunet de la Jonquière[99] ត្រូវបានតែងតាំងឱ្យធ្វើការសិក្សា និងរៀបចំបញ្ជីប្រាសាទបុរាណខ្មែរ[100] ។ បេសកកម្មអចិន្ត្រៃយ៍បុរាណវិទ្យានៅឥណ្ឌូចិន ត្រូវបានបង្កើតឡើង ដោយក្រឹត្យចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៨៩៨ ដែលស្ថិតនៅក្រោមឱវាទអគ្គទេសាភិបាលឥណ្ឌូចិន(មាត្រា១) ក្នុងគោលដៅធ្វើការស្រាវជ្រាវបេតិកភណ្ឌបុរាណវិទ្យា និងអក្សរសាស្ត្រប្រវត្តិសាស្ត្រ និងចូលរួមចំណែកក្នុងការសិក្សាអរិយធម៌ឥណ្ឌា ចិន ម៉ាឡេ ។ល។ (មាត្រា២)។ នៅក្នុងឆ្នាំ១៩០០ បេសកកម្មនេះត្រូវបានដូរឈ្មោះទៅជា **សាលាបារាំងចុងបូព៌ា** (EFEO) ហើយប្រធានាធិបតីបារាំង Émile Loubert បានចេញក្រឹត្យចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩០១ ដើម្បីទទួលស្គាល់ស្ថាប័នស្រាវជ្រាវនេះ។ ដំបូងស្ថាប័ននេះមានទីតាំងនៅក្រុងហាណូយ[101] ហើយក្រោយឆ្នាំ១៩៥៤ បានលើកទីតាំងមកទីក្រុងព្រៃនគរវិញ។ **សាលា**

---

97 ហាម ឆាយលី(២០១០) «ប្រជុំអត្ថបទសម្រាំង(អត្ថបទប្រវត្តិសាស្ត្រ)» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ទំព័រ ៩។

98 អ្នកស្រី ត្រឹងងារ(១៩៧៥) អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់ ទំព័រ ៤។

99 Étienne Lunet de la Jonquière, Inventaire archéologique des monuments du Cambodge.

100 Edwards, P. (2007), Cambodge. P. 36.

101 Clémentin-Ojha, Catherine et Manguin, Pierre-Yves (2001), Un siècle pour l’Asie : L’École francaise d’Extrême-Orient, 1898-2000, Les Éditions du Pacifique, École francaise d’Extrême-Orient, Paris, p. 16.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**បារាំងចុងបូព៌ា** បានចូលរួមចំណែកក្នុងការសិក្សាស្រាវជ្រាវអំពីវប្បធម៌ និងអរិយធម៌ខ្មែរ ជាពិសេសប្រាសាទអង្គរ [102] ដែលជាដួងព្រលឹងរបស់ជាតិខ្មែរ និងដែលបង្កើតឡើងនូវស្មារតីស្នេហាជាតិ និងជាតិនិយម និងអត្តសញ្ញាណខ្មែរក្នុងចំណោមប្រជាជន និងបញ្ញវន្តខ្មែរ។ លោក Louis Finot (1864-1935) អ្នកឯកទេសបារាំងខាងផ្នែកវប្បធម៌ឥណ្ឌា ត្រូវបានតែងតាំងជាប្រធានទី១នៃស្ថាប័នស្រាវជ្រាវនេះ។ លោក Louis Finot ក៏បានចូលរួមក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សនៅកម្ពុជា ដូចជាការអញ្ជើញសម្ដេច **ជួន ណាត** និងសម្ដេច **ហួត តាត** ឱ្យទៅរៀនភាសាសំស្ក្រឹតនៅហាណូយជាដើម។ នៅក្នុងឆ្នាំ១៩៥១ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីស្នើសុំឱ្យ**សាលាបារាំងចុងបូព៌ា** បន្តបេសកកម្មបច្ចេកទេស លើការងារអភិរក្សប្រាង្គប្រាសាទចំនួន១៥០០ ដែលសាលានេះបានប្រគល់ឱ្យកម្ពុជា។ **សាលាបារាំងចុងបូព៌ា** បន្តបំពេញបេសកកម្មបច្ចេកទេស រហូតដល់ឆ្នាំ១៩៧៣ នៅខេត្តសៀមរាប និងដល់ឆ្នាំ១៩៧៥ នៅភ្នំពេញ។ ដើម្បីលើកកម្ពស់ការសិក្សាសិល្បៈ និងស្ថាបត្យកម្មខ្មែរ លោក George Groslier បានបង្កើត **សាលារចនា** ឡើងនៅឆ្នាំ១៩១៧ ដែលក្រោយមកបានក្លាយទៅជាសាកលវិទ្យាល័យវិចិត្រសិល្បៈ។

បន្ទាប់ពីការចុះសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧ និងការផ្ទេរក្រុមប្រាសាទបុរាណអង្គរឱ្យមកកម្ពុជាវិញ អាជ្ញាធរបារាំងបានតែងតាំងលោក Jean Commaille (1916) ជាអភិរក្សអង្គរដំបូងបង្អស់។ ហើយចាប់ពីឆ្នាំ១៩២០ មក **សាលាបារាំងចុងបូព៌ា** បានបង្កើតនាយកដ្ឋានបុរាណវិទ្យានៅក្នុងប្រទេសកម្ពុជា ដែលមានលោក Henri Parmentier (1871-1949) ជាប្រធានរហូតដល់ឆ្នាំ១៩៣៣, បន្ទាប់មកជំនួសដោយលោក Henri Marchal (1876-1970) រួចលោក J.-Y. Claeys ពីឆ្នាំ១៩៣៧ ដល់ឆ្នាំ១៩៤៧ និងលោក Bernard Philippe Groslier (1926-1986) ពីឆ្នាំ១៩៥៩ ដល់១៩៧៣។ បន្ទាប់ពីការបង្កើត **សាលាបារាំងចុងបូព៌ា** និងអភិរក្សអង្គរ លោក Jean Commaille បានចាប់ផ្ដើមកាប់ឆ្ការព្រៃ និងរៀបចំនៅតំបន់អង្គរឡើងវិញនៅឆ្នាំ១៩១០។ នៅក្នុងឆ្នាំ១៩២៥ **សាលាបារាំងចុងបូព៌ា** បានរៀបចំបញ្ជីបេតិកភណ្ឌដែលត្រូវការពារ ដែលក្នុងនោះមានប្រាសាទចំនួន ៦៧០ នៅកម្ពុជា ហើយនៅក្នុងឆ្នាំ១៩៣៥ ចំនួនប្រាសាទកើនឡើងដល់៧៦១[103]។ លោក Henri

---

[102] Edwards, P. (2007), Cambodge: The Cultivation of a Nation, 1860-1945, University of Hawaii Press, Honolulu, p. 21.

[103] Clémentin-Ojha, Catherine et Manguin, Pierre-Yves (2001), Un siècle pour l'Asie : L'École francaise d'Extrême-Orient, 1898-2000, p. 81.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Marchal ដែលជាអភិរក្សអង្គរចំនួនបីអាណត្តិ ពីឆ្នាំ១៩១៦ដល់ឆ្នាំ១៩៥៣ បានជួសជុលប្រាសាទ ហើយរៀបចំឱ្យមានប្រាសាទវង់តូច និងប្រាសាទវង់ធំ និងជាអ្នករៀបចំជួសជុលប្រាសាទអង្គរវត្ត ដោយប្រើប្រាស់បច្ចេកទេសរុះរើ ហើយកសាងឡើងវិញ (Anastylose)។ បន្ទាប់មកគឺលោក Georges Trouvé (1902-1935) និងលោក Maurice Glaize (1886-1964) ដែលត្រូវបានតែងតាំងជាអភិរក្សអង្គរដើម្បីបន្តការងារនេះ។ លោក Bernard Philippe Groslier ដែលជាអភិរក្សអង្គរពីឆ្នាំ១៩៥៩ ដល់ឆ្នាំ១៩៧៣ បានកែលម្អបច្ចេកទេសរុះរើហើយកសាងឡើងវិញ (Anastylose) នេះឱ្យកាន់តែសុក្រឹតឡើងថែមទៀត។

ទន្ទឹមនឹងការសិក្សា និងការអភិរក្សប្រាង្គប្រាសាទបុរាណ **សាលាចារាំង៉ចុង៉ប្ញ៉ា** បានធ្វើការសិក្សាលើសិលាចារឹកខ្មែរ ដែលជាកេរដំណែលប្រវត្តិសាស្ត្រ និងជាប្រភពនៃចំណេះដឹងខាងផ្នែកប្រវត្តិសាស្ត្រកម្ពុជា។ អ្នកដែលចាប់ផ្ដើមផ្ដិតយកសិលាចារឹកខ្មែរដំបូងគឺលោក Doudart de Lagrée នៅពេលលោកធ្វើបេសកកម្មនៅប្រាសាទអង្គរនៅឆ្នាំ១៨៦៦ ហើយអ្នកដែលបានបកប្រែសិលាចារឹកសំស្ក្រឹតខ្មែរលើកទី១ គឺអ្នកប្រាជ្ញហូឡង់ លោក Hendrik Kern[104]។ បន្ទាប់មក លោកបានផ្ដិតសិលាចារឹកមួយចំនួន ហើយផ្ញើទៅទីក្រុងប៉ារីស ហើយលោក Abel Bergaigne និង លោក Auguste Barth បានធ្វើការសិក្សា ហើយបោះផ្សាយនូវស្នាដៃមួយនៅឆ្នាំ១៨៨៣ ដែលមានចំណងជើងថា ៖ «សិលាចារឹកសំស្ក្រឹតនៅ ចម្ប៉ា និងនៅកម្ពុជា»។ ក៏ប៉ុន្តែ គឺលោក George Coedès ដែលជានាយក **សាលាចារាំង៉ចុង៉ប្ញ៉ា**ចាប់ពីឆ្នាំ១៩២៩ ដែលជាអ្នកបានចំណាយពេលស្ទើរតែពេញមួយជីវិតដើម្បីសិក្សាសិលាចារឹកខ្មែរ និងបានបោះពុម្ពសៀវភៅចំនួន ៨ ក្បាលដែលមានចំណងជើងថា «សិលាចារឹកនៃប្រទេសកម្ពុជា(១៩៣៧-១៩៦៦)» ដែលក្លាយជាប្រភពដ៏សំខាន់សម្រាប់ការសិក្សាប្រវត្តិសាស្ត្រកម្ពុជា។ លោកបានសរសេរសៀវភៅ និងអត្ថបទជាច្រើនស្ដីពីប្រវត្តិសាស្ត្រខ្មែរ។ កូនសិស្សរបស់លោក Coedès គឺលោក Claude Jacques និងលោក Kamalesvar Bhattacharya ដែលជាអ្នកឯកទេសភាសាសំស្ក្រឹតបានបន្តការសិក្សាសិលាចារឹក។ ទន្ទឹមនឹងនេះ លោកស្រីសាស្ត្រាចារ្យ ពៅ សាវរស ក៏បានចូលរួមធ្វើការសិក្សាសិលាចារឹកជាភាសាខ្មែរផងដែរ និងបានបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថា ៖ «Les inscriptions modernes d'Angkor»។

អ្នកប្រាជ្ញបារាំងផ្នែកភាសាបាលីក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការស្រាវជ្រាវពីកម្ពុជាដែរ។ ក្នុងនោះ តួឯកដ៏សំខាន់គឺលោកស្រី Suzanne Karpelès ដែលជាភាសាវិទូ

[104] Clémentin-Ojha, Catherine et Manguin, Pierre-Yves (2001), Un siècle pour l'Asie, p. 124.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពុទ្ធសាសនវិទូ និងជាអ្នកឯកទេសខាងផ្នែកគម្ពីរស្លឹករឹតជាភាសាបាលី និងជាភាសាខ្មែរ។ លោកស្រីបានចូលបម្រើការងារនៅក្នុងឆ្នាំ១៩២២ និងបានបង្កើតព្រះរាជបណ្ណាល័យភ្នំពេញនៅឆ្នាំ១៩២៥ ដើម្បីប្រមូល រៀបចំ និងអភិរក្សអក្សរសិល្ប៍ជាភាសាខ្មែរ និងបាលី។ លោកស្រីក៏បានផ្តួចផ្តើមគំនិតឱ្យខ្មែរយើងបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតឡើង ដើម្បីធ្វើការស្រាវជ្រាវខាងផ្នែកពុទ្ធសាសនា និងបោះពុម្ពផ្សាយ ព្រះត្រៃបិដក ដោយយកឯកសារពី Pali Text Society នៅទីក្រុងឡុងដ៍ជាគោល[105]។

ការសិក្សាប្រវត្តិសាស្ត្រខ្មែរ ក៏ជាអាទិភាពមួយរបស់**សាលាចារាំដ៍ចុដ៍ប្វ៉ាំ** ផងដែរ។ លោកសាស្ត្រាចារ្យ **ឃិន សុខ** និងលោកសាស្ត្រាចារ្យ **ម៉ក់ ភឿន** បានធ្វើការសិក្សាអត្ថបទផ្សេងៗនៃ **ព្រះរាជពង្សាវតារនៃប្រទេសកម្ពុជា** ដែលជាប្រភពមួយដ៏សំខាន់នៃប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរ។

បន្ទាប់ពីការបង្កើតអាណាព្យាបាលបារាំងនៅកម្ពុជា អ្នកឯកទេសបារាំងបានចាប់ផ្តើមដើរប្រមូលអត្ថបទអក្សរសិល្ប៍ ចរិយាធម៌ និងសាស្ត្រាស្តីពីប្រវត្តិសាស្ត្រកម្ពុជា ដើម្បីធ្វើការសិក្សាពីកម្ពុជា[106]។ ក៏ប៉ុន្តែ សាស្ត្រាទាំងនេះ គឺជាអត្ថបទចម្លងដោយដៃ លើស្លឹករឹតហើយមិនសូវមានច្រើនទេ។ មន្ត្រីជាន់ខ្ពស់ បញ្ញវន្ត ព្រះសង្ឃរាជ និងព្រះញាតិវង្សានុវង្ស រក្សាទុកសាស្ត្រាទាំងនេះដោយប្រុងប្រយ័ត្ន ដោយចាត់ទុកសាស្ត្រាទាំងនេះជាវត្ថុមានតម្លៃ ហើយពេលខ្លះជាវត្ថុសក្តិសិទ្ធិទៀតផង។

ទន្ទឹមនឹងនេះ នៅក្នុងសម័យអាណាព្យាបាលបារាំង អ្នកប្រាជ្ញបារាំងជាច្រើន ដែលស្រឡាញ់ខ្មែរ (Les Khmèrophiles) បានធ្វើការសិក្សាពីកម្ពុជា ដូចជា ៖

ទី១-លោក Adhémar Leclère, (1853-1917) ដែលបម្រើការជាតំណាងបារាំងនៅកម្ពុជា ជាចៅហ្វាយខេត្តកំពត (Résident du Kampot) ពីឆ្នាំ១៨៨៦ ដល់១៨៩០ ចៅហ្វាយខេត្តក្រចេះ-សម្បូណ៌ ពីឆ្នាំ១៨៩០ ដល់១៨៩៤ ចៅហ្វាយខេត្តក្រចេះ ពីឆ្នាំ១៨៩៤ ដល់១៨៩៨ និង ចៅហ្វាយក្រុងភ្នំពេញ ពីឆ្នាំ១៨៩៩ ដល់១៩០៣។ ពីឆ្នាំ១៩០៨ ដល់១៩១១ លោកត្រូវបានតែងតាំងជាអធិការ និងទីប្រឹក្សាអមតំណាងជាន់ខ្ពស់បារាំង (Résident supérieur) ប្រចាំកម្ពុជា។ ស្នាដៃធំៗរបស់លោកមាន ៖ Histoire du Cambodge, Recherches sur la législation cambodgiennes (1890), Les Fêtes religieuses bouddhiques chez les Cambodgiens (1895), Cambodge, contes et légendes (1895), Recherches sur les origines

[105] Clémentin-Ojha, Catherine et Manguin, Pierre-Yves (2001), Un siècle pour l'Asie, pp. 165-166.
[106] Edwards, P. (2007), Cambodge. P. 107; Migot, A., Les Khmers, p. 303.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

brahmaniques des lois cambodgiennes (1898), Le bouddhisme au Cambodge (1899), Livres sacrés (1906)។

ទី២-លោក Étienne Aymonier (1844-1929), ត្រូវបានតែងតាំងជាអធិការនៅឆ្នាំ ១៨៧២ ហើយនៅឆ្នាំ១៨៧៣ ត្រូវបានតែងតាំងជាអនុប្រធានរបស់លោក Jean Moura ដែលជាតំណាងបារាំងនៅកម្ពុជា។ នៅឆ្នាំ១៨៧៩ លោកត្រូវបានតែងតាំងជាតំណាងបារាំងនៅកម្ពុជា ជំនួសលោក Jean Moura។ លោកគឺជានាយកទី១នៃសាលាអាណានិគមនៅទីក្រុងប៉ារីស។ ស្នាដៃធំៗរបស់លោកមាន ៖ Le Cambodge: Tomme I (1901), Le Cambodge. Les provinces siamoises. Le Cambodge: Tomme III. Le groupe d'Angkor et leur histoire (1904). Cours de Cambodgien (1875). Géographie du Cambodge (1876)។

ទី៣-George Maspero (1872-1942) ធ្លាប់បម្រើការងារជាចៅហ្វាយក្រុងហាយហ្វុង បន្ទាប់មកជាតំណាងបារាំងនៅកម្ពុជាក្នុងឆ្នាំ ១៩២០ និងជាអគ្គទេសាភិបាលឥណ្ឌូចិន។ លោកគឺជាស្ថាបនិកម្នាក់នៃសាលាបារាំងចុងបូព៌ា។

ក្រៅពីនេះ គេឃើញមានលោក George Groslier, Henri Marshal (1876-1970), Louis Malleret ជាដើម ដែលជាអ្នកប្រាជ្ញខាងវប្បធម៌ខ្មែរដ៏ល្បីល្បាញ។

## ១.៣.៣. កំណែទម្រង់វិស័យអប់រំដើមស.វ.ទី២០

**សន្ធិសញ្ញាបារាំង-ខ្មែរឆ្នាំ១៨៨៤**[107] បានប្រគល់អំណាចឱ្យបារាំងក្នុងការគ្រប់គ្រងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា រួមទាំងវិធានការកំណែទម្រង់រដ្ឋផងដែរ ដែលក្នុងនោះការរៀបចំប្រព័ន្ធរដ្ឋបាលគ្រប់គ្រង និងប្រព័ន្ធអប់រំបាននាំឱ្យមានការផ្លាស់ប្តូរជាច្រើន។ ក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រឹត្តិការណ៍សំខាន់គឺការបង្កើត **សហព័ន្ធឥណ្ឌូចិននៅឆ្នាំ ១៨៩៨** ដែលបង្រួបបង្រួមដែនដីអាណានិគម និងអាណាព្យាបាលបារាំងនៅឥណ្ឌូចិន ដូចជាកម្ពុជា តុងកឹង អាណ្ណាម កូសាំងស៊ីន និងឡាវ ឱ្យស្ថិតនៅក្នុងសហភាពរូបិយវត្ថុ និងរដ្ឋបាលតយតែមួយ។ ក៏ប៉ុន្តែ មុននឹងបង្កើតសហព័ន្ធឥណ្ឌូចិន បារាំងក៏បានខិតខំកំណត់ព្រំប្រទល់ទឹកដីអាណានិគមរបស់ខ្លួនឱ្យបានច្បាស់លាស់ តាមរយៈការចុះកិច្ចព្រមព្រៀងឆ្នាំ១៨៧៣ ស្តីពីព្រំប្រទល់រវាងកម្ពុជា និងកូសាំងស៊ីន។

នៅឆ្នាំ១៩០២ លោក Paul Beau បានឡើងធ្វើជាអគ្គទេសាភិបាលឥណ្ឌូចិនជំនួសលោក Paul Doumer ហើយបានផ្តល់អាទិភាពដល់ការអភិវឌ្ឍវិស័យអប់រំនៅឥណ្ឌូចិន។ នៅកម្ពុជា ជំណាងជាន់ខ្ពស់បារាំងបានបង្កើត **ក្រុមប្រឹក្សាកែលម្អការអប់រំ** ក្នុងឆ្នាំ

[107] អគ្គទេសាភិបាលឥណ្ឌូចិន Charles Thomson បានឱ្យព្រះបាទ **នរោត្តម** ចុះហត្ថលេខាក្នុងឆ្នាំ១៨៨៤។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៩០៥ ដែលមានព្រះអង្គម្ចាស់ សុថារតន៍ សម្តេចចៅហ្វ៊ាវាំងជូន ព្រះសង្ឃរាជទាំងពីរគណៈ និងទីប្រឹក្សាបារាំងជាសមាជិក ក្នុងគោលដៅពិនិត្យឡើងវិញនូវកម្មវិធីសិក្សា។ ក្នុងឆ្នាំ១៩០៥ ក្រុមប្រឹក្សានេះបានផ្តល់អនុសាសន៍ក្នុងការលើកកម្ពស់ការបង្រៀនភាសាបារាំង និងបញ្ចូលមុខវិជ្ជាភូមិសាស្ត្រ និងមុខវិជ្ជាវិទ្យាសាស្ត្រទៅក្នុងកម្មវិធីសាលាវត្ត ដោយរក្សាទុកសាលាវត្តសម្រាប់ការបង្រៀនអាន និងសរសេរភាសាខ្មែរ សីលធម៌ និងព្រះពុទ្ធសាសនា ព្រមទាំងស្នើសុំឱ្យបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូសម្រាប់លោកសង្ឃដែលបង្រៀននៅសាលាវត្ត។

ក៏ប៉ុន្តែ លោក Jules Morel ដែលជាតំណាងជាន់ខ្ពស់បារាំងនៅកម្ពុជាមានមតិផ្ទុយពីនេះ ដោយលើកឡើងពីការចាំបាច់ក្នុងការបង្កើតប្រព័ន្ធអប់រំផ្លូវការ តាមរយៈការបង្កើតសាលារៀនបារាំង-ខ្មែរ និងជំរុញឱ្យមាតាបិតាបញ្ជូនកូនឱ្យទៅរៀនសាលាផ្លូវការនេះ ដើម្បីទទួលបាននូវចំណេះដឹងជាក់ស្តែង និងចេះវិទ្យាសាស្ត្រ។ សាលារៀនបារាំង-ខ្មែរបង្រៀនជាភាសាបារាំង ហើយជំនួសសាលាវត្ត ដែលបង្រៀនជាភាសាខ្មែរ ដែលមានកម្មវិធីបង្រៀនព្រះពុទ្ធសាសនា និងច្បាប់សីលធម៌ ដែលបារាំងយល់ថាជាកម្មវិធីចាស់គំរឹល។ ទន្ទឹមនឹងនេះ បារាំងបានផ្តួចផ្តើមគំនិតធ្វើឡាតាំងភាវូបនីយកម្មអក្សរខ្មែរ ដូចនៅវៀតណាមផងដែរ។ លោក François Fontaine ដែលជានាយកស្តីទីនៃសាលាបារាំង-ខ្មែរនៅភ្នំពេញបានផ្តល់អនុសាសន៍ក្នុងរបាយការណ៍របស់លោកស្តីពីការអប់រំថា ការជំនួសអក្សរខ្មែរដោយអក្សរឡាតាំងនឹងធ្វើឱ្យសិស្សងាយស្រួលរៀន និងអានភាសាខ្មែរ។ ថ្វីត្បិតតែសំណើនេះមានការគាំទ្រពីមន្ត្រីជាន់ខ្ពស់បារាំង លោក Guillaume Monod ក៏ប៉ុន្តែបញ្ញវន្តខ្មែរជាច្រើននាក់បានធ្វើការជំទាស់នឹងសំណើធ្វើឡាតាំងភាវូបនីយកម្មភាសាខ្មែរ។

សរុបមក អាជ្ញាធរអាណាព្យាបាលបានសម្រេចយកដំណោះស្រាយសម្បទានមួយក្នុងការធ្វើកំណែទម្រង់វិស័យអប់រំនៅដើមស.វ.ទី២០ ៖

**ទី១-ពង្រឹងការអប់រំតាមសាលាវត្ត** ដើម្បីលើកកម្ពស់ការអប់រំជាខេមរភាសា។ ចៅហ្វាយខេត្តបារាំងនៅកំពង់ចាម លោក Baudoin បានផ្តួចផ្តើមគំនិតតែងតាំងគ្រូគ្រហស្ថឱ្យទៅបង្រៀនភាសាបារាំង និងភាសាខ្មែរនៅតាមសាលាវត្ត ក្រៅម៉ោងបង្រៀនពុទ្ធសាសនា។

**ទី២-បង្កើតសាលារដ្ឋបារាំង-ខ្មែរ** និងរៀបចំប្រព័ន្ធអប់រំនៅកម្ពុជាឱ្យមានលក្ខណៈរៀបរយ និងមានស្តង់ដាដូចនៅប្រទេសបារាំង។ ការបង្កើត**សាលារដ្ឋបារាំង-**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្មែរនេះឡើង គឺជាផ្នែកមួយនៃគោលនយោបាយផ្សព្វផ្សាយអរិយធម៌បារាំង ហើយមានគោលដៅបណ្ដុះបណ្ដាលធនធានមនុស្ស ដែលយល់ពីបារាំង និងកាត់បន្ថយការបះបោរប្រឆាំងនឹងបារាំង។

### ១.៣.៣.១. *ការធ្វើទំនើបកម្មសាលាវត្ត*

មុនសម័យកាលអាណាព្យាបាលបារាំង(១៨៦៣-១៩៥៣) ប្រព័ន្ធអប់រំនៅកម្ពុជាមានតែនៅក្នុងវត្តអារាម ដែលធ្លាប់ជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាផ្លូវចិត្ត និងសង្គមតែប៉ុណ្ណោះ[108]។ ក្មេងប្រុសៗសម័យនោះត្រូវបួសដើម្បីបានរៀន។ ពេលបញ្ចប់ការសិក្សានៅក្នុងពុទ្ធចក្រ ពួកគេភាគច្រើនបានលាចាកសិក្ខាបទ ដើម្បីមករស់នៅ និងប្រកបរបរចិញ្ចឹមជីវិតតាមបែបគ្រហស្ថវិញ។ វត្តអារាមព្រះពុទ្ធសាសនាត្រូវបានប្រើប្រាស់ជាទីសម្រាប់អប់រំបព្វជិត និងគ្រហស្ថក្នុងការសិក្សារៀនសូត្រទៅលើគម្ពីរព្រះពុទ្ធសាសនា។ គម្ពីរទាំងនេះរួមមានគម្ពីរត្រៃភូមិ ដែលជាគម្ពីររៀបរាប់អំពីលោកធាតុវិទ្យា ព្រះវេស្សន្តរជាតក និងរឿងផ្សេងៗទៀតដែលទាក់ទងជាមួយនឹងពុទ្ធប្រវត្តិ [109] ។ បច្ចេកទេសក្នុងការអប់រំនាសម័យនោះ គឺផ្អែកលើមូលដ្ឋានច្បាប់ ដំបូន្មាន ដែលដកស្រង់យកចេញមកពីច្បាប់ផ្សេងៗ [110] ដោយផ្ដោតសំខាន់ទៅលើការអាន និងសរសេរភាសាខ្មែរ គម្ពីរព្រះពុទ្ធសាសនា ច្បាប់កម្មសិទ្ធិ និងលេខនព្វន្តមួយចំនួន[111]។

បើទោះបែបនេះក្ដី ក៏នៅមានកង្វះខាតយ៉ាងធ្ងន់ធ្ងរក្នុងការអប់រំនៅតាមវត្តអារាមនេះ។ ការអប់រំតាមបែបប្រពៃណីត្រូវបានបង្រៀនដោយរៀនសូត្រផ្ទាល់មាត់ ដោយសូត្រទន្ទេញខ្លាំងៗ តាមរយៈ *«គ្រូបង្រៀនជាដើមនោះ ដោយពួកគាត់ព្យាយាមធ្វើយ៉ាងណាដើម្បីផ្ទេរចំណេះដឹងមិនច្បាស់លាស់របស់ពួកគាត់ទៅឱ្យសិស្ស ដោយមិនមានគោលវិធី ឬគោលការណ៍គរុកោសល្យអ្វីនោះឡើយ »*[112]។

សាលាវត្តគឺជាកន្លែង ដែលក្មេងប្រុសទៅរស់នៅបម្រើលោកសង្ឃ ដើរបិណ្ឌបាត្រជាមួយលោកពេលព្រឹក និងជួយសម្អាតវត្តអារាម។ នៅពេលទំនេរ ក្មេងវត្តអាចរៀនសូត្រទន្ទេញធម៌ អានគម្ពីរព្រះត្រៃបិដក រៀនអានសាស្ត្រា និងរៀនសរសេរអក្សរនៅពេលរសៀល។ ដូច្នេះ សាលាវត្តប្រពៃណីគ្មានកម្មវិធីសិក្សា គ្មានពេលម៉ោងរៀនសូត្រច្បាស់លាស់

---

108 Jean-Michel Filippi (2011), Cambodia’s turbulent educational history, the Phnom Penh Post, 17 June 2011.

109 Anne Hansen (2004), Khmer Identity and Theravada Buddhism, in John Marston and Elizabeth Guthrie (2004), “History, Buddhism, and New Religious Movements in Cambodia”, University of Hawai’s Press and Silkworm Books, p. 43.

110 Cbaps are educational works put into verse containing prescriptive moral precepts which had to be listened to and memorised until they were known by heart (Filippi, Jean-Michel, ibid.).

111 Gyallay-Pap, 1989, p. 258.

112 Hansen, Anne Ruth (2008). How to Behave: Buddhism and Modernity in Colonial Cambodia, 1860-1930. Chiang Mai: Silkworms Books, p. 123.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងគ្មានការប្រឡងអ្វីទាំងអស់។ ម្យ៉ាងវិញទៀត សម័យនោះគ្រូគ្មានការបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវឡើយ។

ក្នុងគោលដៅលើកកម្ពស់វិស័យអប់រំនៅកម្ពុជា ព្រះបាទ **ស៊ីសុវត្ថិ** បានចុះហត្ថលេខាលើព្រះរាជក្រឹត្យនៅឆ្នាំ១៩១១ ដោយតម្រូវឱ្យក្មេងប្រុសដែលមានអាយុចាប់ពី៨ឆ្នាំឡើងទៅ ត្រូវទៅចូលរៀននៅ ***សាលាវត្តបែបថ្មី***[113]។ វិធានការនេះ គឺជាកំណែទម្រង់ដ៏ធំមួយ ដើម្បីបង្កើតឱ្យមាន ***ការអប់រំជាកាតព្វកិច្ច*** នៅកម្ពុជា។ មាតាបិតាដែលមិនបញ្ជូនកូនឱ្យទៅរៀនសាលាវត្ត នឹងត្រូវពិន័យជាប្រាក់ចំនួន ១ សេន (piastre) ចំពោះកំហុសលើកទី១ និង២សេនចំពោះកំហុសលើកក្រោយៗ។ ទោះបីជាមានវិធានការយ៉ាងនេះក៏ដោយ ក៏មាតាបិតាមួយចំនួនទុកកូនចៅឱ្យនៅជួយធ្វើស្រែចំការ[114] ទោះបីជាក្នុងឆ្នាំ១៩១៦ អាជ្ញាធរបារាំងបានបង្កើនកម្រិតទោសទណ្ឌ រហូតដល់ចាប់មាតាបិតាដាក់ពន្ធនាគារចំនួន ៥ ថ្ងៃ។ ម្យ៉ាងវិញទៀត ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំនៅសាលាវត្ត បារាំងបានបង្កើតឱ្យមានអធិការដ្ឋានចំនួនពីរសម្រាប់សាលាវត្តនៃគណៈធម្មយុត្តិ និងសាលាវត្តនៃគណៈមហានិកាយ ក្នុងគោលដៅធានាការអនុវត្ត ***ការអប់រំកាតព្វកិច្ច*** ផងដែរ។ ចាប់ពីពេលនោះមក ព្រះសង្ឃត្រូវបានតែងតាំងជាអធិការសាលាវត្ត ដើម្បីចុះទៅត្រួតពិនិត្យសាលាវត្ត។

កំណែទម្រង់ដ៏សំខាន់មួយទៀត គឺការផ្តល់ប្រាក់បៀវត្សដល់គ្រូបង្រៀននៅសាលាវត្ត។ នៅឆ្នាំ១៩១៤ សម្តេចចក្រីកុញ្ជរាធិបតី **ពេជ្រ ម៉ុណ្ណ** សេនាបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការ បានស្នើឱ្យបារាំងផ្តល់ប្រាក់បៀវត្សដល់គ្រូសាលាវត្ត។ *បទពិសោធនៃកំណែទម្រង់នៅដំណាក់កាលដំបូងនេះ ត្រូវបានយកទៅប្រើប្រាស់ក្នុងការធ្វើកំណែទម្រង់សាលាវត្តឱ្យក្លាយទៅជាសាលាវត្តបែបទំនើប។*

ដំណើរការកំណែទម្រង់សាលាវត្តឱ្យក្លាយទៅជា ***សាលាវត្តបែបថ្មី*** នៅបន្តនៅក្នុងទសវត្សរ៍ឆ្នាំ១៩២០ និង១៩៣០ នៃស.វ.ទី២០។ វិធានការកំណែទម្រង់រួមមានការបណ្តុះបណ្តាលអធិការសាលាវត្ត ការតែងតាំងគ្រូគ្រហស្ថឱ្យទៅបង្រៀននៅតាមសាលាវត្តសំខាន់ៗ និងការចែកចាយសៀវភៅនៅតាមសាលាវត្ត។ សាលាអនុវត្តត្រូវបានបង្កើតឡើង ដើម្បីធ្វើការបណ្តុះបណ្តាលលោកសង្ឃឱ្យចេះវិធីសាស្ត្របង្រៀន ហើយ

---

[113] Bilodeau, Ch. (1955) “Compulsory Education in Cambodia”, in Bilodeau, Somlith Pathammavong and Le Quang Hong, (1955), Compulsory Education in Cambodia, Laos and Vietnam, UNESCO, Paris, pp. 16-17.

[114] Tully, J. (2002), France on the Mekong: A History of the Protectorate in Cambodia, 1863-1953, University Press of America, Lanham, p. 220.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សៀវភៅគោលសិក្សាជាខេមរភាសាក៏ត្រូវបានរៀបចំសម្រាប់ការបង្រៀននៅតាមសាលាវត្តបែបថ្មី [115] ។ កំណែទម្រង់នេះបានអនុវត្តសាកល្បងលើកទី១ នៅកំពត ហើយលោកសង្ឃសុខចិត្តបញ្ជូនលោកទៅរៀននៅសាលាអនុវត្ត ដែលត្រូវបានបង្កើតឡើង ដើម្បីបណ្តុះបណ្តាលគ្រូសម្រាប់ខេត្តកំពត។

ប្រការនាំឱ្យមានកំណែទម្រង់វិស័យអប់រំក្នុងឆ្នាំ១៩២០ ដែលមានគោលបំណងធំៗចំនួនពីរ ៖ ធ្វើទំនើបកម្មប្រព័ន្ធអប់រំបែបប្រពៃណីនៅក្នុងសាលាវត្ត និងបង្កើតសាលារដ្ឋបារាំង-ខ្មែរ ក្នុងគោលបំណងបណ្តុះបណ្តាលក្រុមមន្ត្រីក្នុងស្រុក ដែលអាណាព្យាបាលបារាំងត្រូវការ[116]។ ទំនើបកម្មនៃសាលាវត្តនេះ គឺផ្តោតលើការបង្រៀនលើប្រធានបទថ្មី រួមទាំងលេខនព្វន្ត ភាសាបារាំង និងភូមិសាស្ត្រ បន្ថែមលើមុខវិជ្ជាប្រពៃណី ដែលមានស្រាប់[117]។ កំណែទម្រង់សាលាវត្តឱ្យទំនើបមានគោលដៅធ្វើការកែលម្អសាលាវត្តឱ្យស្របតាមការវិវត្ត និងតម្រូវការរបស់កម្ពុជាសម័យអាណាព្យាបាលបារាំង [118] ។ មកទល់ឆ្នាំ ១៩៣០ គ្រូជាសង្ឃចំនួន ៥៨ អង្គត្រូវបានបណ្តុះបណ្តាល រួចហើយត្រូវបានបញ្ជូនទៅកាន់វត្តដើម ដើម្បីបង្រៀនតាមសាលាវត្តទាំងនេះ។

នៅឆ្នាំ១៩៣១ អធិការដ្ឋាននៃសាលាវត្តបែបថ្មីត្រូវបានបង្កើត ដោយតែងតាំងលោក Louis Manipaud ជាទីប្រឹក្សាបច្ចេកទេស ក្នុងការបង្កើតឱ្យមានគ្រូលោកសង្ឃដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ[119]។ ដូច្នេះហើយទើបលោក Louis Manipaud បានស្នើសុំឱ្យព្រះសង្ឃសហការ និងចូលរួមធ្វើកំណែទម្រង់សាលាវត្ត។ សាលាវត្តដែលមានគ្រូជាសង្ឃមានការបណ្តុះបណ្តាល និងមានកម្មវិធីថ្មីដូចសាលារដ្ឋដែរ លើកលែងតែភាសាបារាំង ត្រូវបានប្រសិទ្ធនាមឱ្យថា«**សាលាវត្តជំនើប**» [120] ។ នាយករដ្ឋបាលអប់រំអាណានិគម លោក Henri Russier បានជំរុញដើម្បីឱ្យបន្តការ «ប្រើប្រាស់ព្រះសង្ឃ» ជាគ្រូ

---

[115] Porée, Guy et Maspéro, Éveline (1938), Moeurs et coutumes des Khmers, Payot, Paris, p. 183, cited by Edwards, P. (2007), Cambodge. p. 178.

[116] Jean-Michel Filippi, Cambodia's turbulent education history, ibid.

[117] កំណែទម្រង់នេះត្រូវបានប្រឆាំងដោយព្រះសង្ឃព្រះពុទ្ធសាសនា ដែលមានការព្រួយបារម្ភពីការបាត់បង់បុព្វសិទ្ធិដ៏សំខាន់របស់ខ្លួន។ នៅពេលជាមួយគ្នានេះដែរ ឥស្សរជនកម្ពុជាដែលបានទទួលប្រយោជន៍ពីការអប់រំជាភាសាបារាំងដូចជាព្រះអង្គម្ចាស់ **យុគន្ធរ** បានចាត់ទុកថាការអប់រំតាមបែបប្រពៃណី គឺគោលបំណង «រក្សាយើងឱ្យស្ថិតក្នុងភាពល្ងង់ខ្លៅ» (Jean-Michel Filippi, ibid.)។

[118] E. Blanguernon, "Rapport de Mission sur les Ecoles de Pagodes au Cambodge », *Bulletin Général de l'Instruction Publique,* décembre 1924, p. 43-44 ; F. Brachet, « L'ensseignement populaire et les Ecoles de Pagode au Cambodge », BGIP, décembre 1927, p. 53 ; Chau Seng, *Education et développement au Cambodge , thèse de 3ème cycle, Paris, 1970 ; J. Népote, « Education et développement dans le Cambodge moderne », Monde et développement, no 28, 1979, p. 767-792 ; cité dans*ឃើង ហុកឌី (២០០៧) «អក្សរសិល្ប៍ខ្មែរ សតវត្សរ៍ទី២០» ទំព័រ ១៧។

[119] CAOM, INDO RSC 269, Louis Manipaud, le Délégué de SM à l'Enseignement Traditionnel, Rapport annuel 1933-34 : Enseignement Traditionnel Rénové, 9, cited by Edwards, P. (2007), Cambodge. P. 179.

[120] Bilodeau, Ch. (1955) "Compulsory Education in Cambodia", in Bilodeau, Somlith Pathammavong and Le Quang Hong, (1955), Compulsory Education in Cambodia, Laos and Vietnam, UNESCO, Paris, p. 21.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀននៅតាមសាលាវត្ត ក៏ព្រោះថាការធ្វើបែបនេះ គឺវាមានសារៈសំខាន់ណាស់ «*ក្នុងការប៉ះប៉ូវការអប់រំតាមបែបប្រពៃណីខាងពុទ្ធចក្រ ដោយបន្ថែមទម្រង់សម័យផ្នែកចំណេះដឹង* »[121]។

ដូច្នេះ ទំនើបកម្មនៃសាលាវត្ត គឺជាការចាំបាច់ដើម្បីបង្កើនលទ្ធភាព ឱ្យយុវជនខ្មែរទទួលបានការអប់រំ។ ដើម្បីពង្រឹងគុណភាពអប់រំនៅតាមសាលាវត្ត ព្រះសង្ឃត្រូវបានបញ្ជូនឱ្យទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូ ដើម្បីក្លាយជាគ្រូបង្រៀនអាជីពនៅក្នុងសាលាវត្តបែប«ទំនើប»[122] (Bilodeau 1955) ។ បន្ទាប់ពីរៀនចប់ពីសាលាវត្តទំនើប សិស្សអាចបន្តការសិក្សានៅសាលាបឋមសិក្សាបំពេញវិជ្ជាបាន។ ក៏ប៉ុន្តែ បញ្ហាប្រឈមនៃសាលាវត្ត គឺគ្រូសាលាវត្តមិនមានការបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវ។ ដូច្នេះ គ្រូភាគច្រើនមានកម្រិតវប្បធម៌ទាប មិនចេះវិធីសាស្រ្តបង្រៀន ដែលតម្រូវឱ្យលោក Manipaud តែងតាំងអធិការបារាំង ដែលចេះខ្មែរឱ្យទៅធ្វើអធិការកិច្ចសាលាវត្ត។

ដូច្នេះ ការអន់ថយរបស់កម្ពុជាក្នុងវិស័យអប់រំ នៅដើមស.វ.ទី២០ គឺបណ្តាលមកពីកម្ពុជាគ្មានប្រព័ន្ធអប់រំផ្លូវការរៀបរយ ដែលមានកម្មវិធីសិក្សាច្បាស់លាស់ និងមានប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនមានវិជ្ជាជីវៈ។ អាជ្ញាធរបារាំងយល់ឃើញថា ការបន្តផ្តល់ការអប់រំដល់យុវជនកម្ពុជានៅតាមសាលាវត្តគឺជាមូលហេតុ ដែលធ្វើឱ្យវិស័យអប់រំនៅកម្ពុជាអន់ថយជាងបណ្តាប្រទេសឯទៀតនៅឥណ្ឌូចិន[123]។ ក៏ប៉ុន្តែ បញ្ហាពិតប្រាកដមានលក្ខណៈស្មុគ្រស្មាញជាងនេះ។ ទំនាស់នេះមានចរិតជាទំនាស់រវាងចរន្តពីរ ៖ ចរន្តនិយមការអប់រំជាភាសាបារាំង និងចរន្តនិយមការអប់រំជាភាសាខ្មែរ ដែលចង់អភិរក្សវប្បធម៌ជាតិឱ្យបានគង់វង្ស ហើយដែលមើលឃើញថា ការអប់រំជាភាសាបារាំងអាចនឹងធ្វើឱ្យកម្ពុជាបាត់បង់វប្បធម៌ជាតិទៅអនាគត។ ទំនាស់នេះនៅបន្តទៅទៀតក្រោយពេលដែលកម្ពុជាទទួលបានឯករាជ្យពីបារាំង គឺចលនាខេមរយានកម្ម។

ចលនាបង្កើនចំនួនសាលាវត្តទំនើបបានរីកលូតលាស់យ៉ាងឆាប់រហ័ស។ ក្នុងឆ្នាំ ១៩៣១ មានសាលាវត្តទំនើបចំនួន១០១ ទូទាំងប្រទេស ដែលមានសិស្សរៀនចំនួន ៣ ៣៣២ នាក់ ដែលពេលនោះប្រជាជនកម្ពុជាមានចំនួន ២,៩លាននាក់។ ហើយចំនួនសាលារៀនបែបនេះបានកើនឡើងដល់ ៩០៨ នៅឆ្នាំ១៩៣៩ ហើយមានសិស្សរៀនចំនួន ៣៨ ៥១៩ នាក់ លើប្រជាជនចំនួន ៣,៥លាននាក់។ ក៏ប៉ុន្តែ សាធារណជនឱ្យតម្លៃលើ

---

121 « Notes sur les écoles de pagodes (1905-1913) », quoted by Hasen, Ibid. p. 124.

122 សាលារៀនចំនួន 908 ដំណើរការនៅក្នុងទីក្រុង ទីប្រជុំជន ភូមិ និងជនបទនៅទូទាំងប្រទេស (Bilodeau, 1955)។

123 CAOM, INDO RSC 269, Chef Local du Service de l’Enseignement à RSC, 20 septembre 1933, cited by Edwards, P. (2007), Cambodge. p. 181.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សាលារដ្ឋជាង ដោយសារនៅសាលារដ្ឋ សិស្សអាចចូលរួមប្រឡងយកសញ្ញាបត្របញ្ចប់ការសិក្សាបឋមសិក្សាជាន់ដំបូង។

ដូច្នេះ នៅស.វ.ទី១៩ និងពាក់កណ្ដាលទី១នៃស.វ.ទី២០ សាលាវត្តគឺជាប្រភពដ៏សំខាន់នៃប្រព័ន្ធអប់រំនៅកម្ពុជា។ ក៏ប៉ុន្តែសាលាវត្តទាំងនេះនៅមិនទាន់អាចផ្តល់នូវការអប់រំតាមបែបទំនើបបានទេ។ ប្រព័ន្ធអប់រំកម្ពុជានៅមានភាពអន់ថយនៅឡើយ។ កវីនិពន្ធ និងបញ្ញវន្តភាគច្រើន គឺជាអ្នករៀនដោយខ្លួនឯង ហើយអ្នកខ្លះទៀតក៏មានឱកាសបានទៅរៀននៅបរទេស។ ក្នុងន័យនេះ ទំនើបភាវូបនីយកម្មវិស័យអប់រំ គឺជាការបង្កើតប្រព័ន្ធអប់រំផ្លូវការ តាមរយៈការបង្កើតសាលារដ្ឋបារាំង-ខ្មែរ។

### *១.៣.៣.២. ការបង្កើតប្រព័ន្ធអប់រំផ្លូវការនៅកម្ពុជា*

យុទ្ធសាស្ត្ររយៈពេលវែងរបស់បារាំងក្នុងការបណ្តុះបណ្តាលធនធានមនុស្ស នៅកម្ពុជានាដើមស.វ.ទី២០ គឺការបង្កើតសាលារដ្ឋបារាំង–ខ្មែរ ដោយចាប់ផ្តើមពីវិទ្យាល័យ។ នៅពេលដែលព្រះបាទ **ស៊ីសុវត្ថិ** ទ្រង់ឡើងសោយរាជ្យនៅក្នុងឆ្នាំ១៩០៤ ទ្រង់បានចាប់ផ្តើមយកចិត្តទុកដាក់ដល់ការបង្កើតសាលារដ្ឋ។ ក្នុងឆ្នាំ១៩០៥ អនុវិទ្យាល័យអាណាព្យាបាល បានប្តូរទីតាំងមក **វិទ្យាល័យព្រះស៊ីសុវត្ថិ** បច្ចុប្បន្ន ដែលជាព្រះរាជអំណោយរបស់ហ្លួង **ស៊ីសុវត្ថិ** ដែលបានប្រទានដំណាក់របស់ទ្រង់ដើម្បីធ្វើជាសាលារៀន។

ចាប់តាំងពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩១១ មក អនុវិទ្យាល័យនេះបានប្តូរឈ្មោះថា អនុវិទ្យាល័យ **ព្រះស៊ីសុវត្ថិ** ដែលជាសាលាមធ្យមសិក្សាបឋមភូមិ ដោយយកតាមគំរូរបស់អនុវិទ្យាល័យ Chasselouplaubat នៅទីក្រុង Saigon។ ដើម្បីចូលរៀន សិស្សត្រូវមានវិញ្ញាបនបត្របញ្ចប់ការសិក្សាបឋមសិក្សាសិន ទើបអាចចុះឈ្មោះចូលរៀនបាន។ ចាប់ពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៣៥ អនុវិទ្យាល័យនេះត្រូវបានដំឡើងជាសាលាមធ្យមសិក្សាទុតិយភូមិ ដែលត្រូវបានប្រសិទ្ធនាមថា **វិទ្យាល័យព្រះស៊ីសុវត្ថិ**។

មានតែសាលារដ្ឋបារាំង–ខ្មែរតែប៉ុណ្ណោះ ដែលអាចអនុវត្តកម្មវិធីសិក្សាបឋមសិក្សាយ៉ាងពេញលេញបាន។ កម្មវិធីសិក្សាអនុវិទ្យាល័យលើកដំបូង និងតែមួយគត់ត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៣៥ នៅពេលដែលអនុវិទ្យាល័យ **ព្រះស៊ីសុវត្ថិ** ត្រូវបានដំឡើងឋានៈជាសាលាមធ្យមសិក្សាទុតិយភូមិ ដែលត្រូវបានសម្ពោធយ៉ាងអធិកអធម និងប្រសិទ្ធនាមថាជា វិទ្យាល័យ **ព្រះស៊ីសុវត្ថិ**។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សាលាបារាំង-ខ្មែរចំនួនបីត្រូវបានបង្កើតឡើងនៅកំពត តាកែវ និងកំពង់ចាម ហើយអគ្គទេសាភិបាលឥណ្ឌូចិន លោក Paul Beau បានចេញក្រឹត្យកំណត់គុណវុឌ្ឍិអប្បបរមាសម្រាប់គ្រូបង្រៀន។

ក្នុងឆ្នាំ១៩១៨ អគ្គទេសាភិបាល Albert Sarraut បានដាក់ចេញនូវកំណែទម្រង់ដ៏សំខាន់មួយ ដើម្បីដាក់ឱ្យអនុវត្តប្រព័ន្ធអប់រំចំនួន ១៣ ឆ្នាំ (បឋមសិក្សា ៦ឆ្នាំ មធ្យមសិក្សាបឋមភូមិ ៤ ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ ៣ ឆ្នាំ) នៅទូទាំងឥណ្ឌូចិនតែម្តង ដើម្បីឱ្យសមមូលជាមួយប្រព័ន្ធអប់រំបារាំង ដោយមានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (Baccalauréat) ផងដែរ។ ក៏ប៉ុន្តែ កុមារភាគច្រើនបានចូលរៀនត្រឹមតែបីឆ្នាំប៉ុណ្ណោះ ហើយបន្ទាប់មកក៏បោះបង់ចោលសាលា។ ដើម្បីដោះស្រាយបញ្ហានេះ គេបានចែកការអប់រំបឋមសិក្សាជាពីរដំណាក់កាល ៖ ៣ ឆ្នាំសម្រាប់សាលាបឋមសិក្សាជាន់ដំបូង (cours élémentaire) និង ៣ ឆ្នាំទៀតសម្រាប់សាលាបឋមសិក្សាបំពេញវិជ្ជា (cours complémentaire) សម្រាប់សិស្សពូកែ។ ជារួម សិស្សដែលរៀនចប់ ហើយទទួលសញ្ញាបត្របញ្ចប់ការសិក្សាបឋមសិក្សាមានអាយុ ២០ ឆ្នាំ។ សិស្សដែលរៀនពូកែអាចរៀនចប់បឋមសិក្សានៅអាយុ ១៦ ឆ្នាំ បើប្រៀបធៀបនឹងកូនបារាំងដែលត្រូវរៀនដើម្បីប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទៅហើយ [124] ។ ដូច្នេះ បញ្ហាសិស្សមានអាយុច្រើន គឺជាបញ្ហាដែលមានមកដល់សព្វថ្ងៃនេះ។

ប្រព័ន្ធបណ្តុះបណ្តាលគ្រូត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩២៥ ដោយបង្កើតវគ្គគរុ-កោសល្យដែលបណ្តុះបណ្តាលគ្រូ និងនាយកសាលា ចំនួន ៤ ឆ្នាំនៅអនុវិទ្យាល័យ **ព្រះស៊ីសុវត្ថិ**។ រហូតដល់ឆ្នាំ១៩៤២ ទើបមហាវិទ្យាល័យគរុកោសល្យត្រូវបានបង្កើតឡើង។

នៅដើមស.វ.ទី២០ ប្រព័ន្ធអប់រំខ្មែរនៅមិនទាន់មានការអភិវឌ្ឍនៅឡើយ។ ក្នុងឆ្នាំ១៩២១ កម្ពុជាដែលមានប្រជាជនប្រមាណ ២,៥ លាននាក់ មានតែសាលាចំនួន ១៤ ប៉ុណ្ណោះដែលជាសាលាបឋមសិក្សាបំពេញវិជ្ជា ដែលសិស្សរៀនចំនួន ៦ ឆ្នាំ ហើយមានសិស្សចំនួន ៣ ៣៩៥ នាក់ និងមានសាលាបឋមសិក្សាជាន់ដំបូងចំនួន ៤៣ ដែលមានសិស្សចូលរៀនចំនួន ១ ៦៣៨។ មួយទសវត្សរ៍ក្រោយមក គឺក្នុងឆ្នាំ១៩៣១ ចំនួនសាលារដ្ឋបារាំង-ខ្មែរពេញលេញ(សាលាបឋមសិក្សាបំពេញវិជ្ជា) បានកើនឡើងត្រឹមចំនួន ១៨ និងមានសិស្សចំនួន ៥ ៨៣៨ នាក់ និងមានសាលាបឋមសិក្សាជាន់ដំបូងចំនួន ៩៣ ដែលមានសិស្សចំនួន ៤ ៨៥៣ បើទោះបីជាមានផែនការដំបូងក្នុងការប្រែក្លាយសាលាវត្តទំនើប ឱ្យ

[124] Tully, J. (2002), France on the Mekong, Op.cit., p. 221.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទៅជាសាលារដ្ឋបារាំង-ខ្មែរក៏ដោយ។ *យើងអាចនិយាយបានថា ការអភិវឌ្ឍវិស័យអប់រំរដ្ឋនៅកម្ពុជាចាប់ផ្ដើមក្នុងរាជ្យព្រះបាទ* ***ស៊ីសុវត្ថិ***។

ដូច្នេះ ប្រព័ន្ធអប់រំនៅសម័យនោះចែកចេញជា ៖ សាលារដ្ឋបារាំង-ខ្មែរ និងសាលាវត្ត។ មូលហេតុដែលធ្វើឱ្យសិស្ស ដែលរៀននៅសាលារដ្ឋមានចំនួនតិច គឺដោយសារកត្តាដូចតទៅ ៖ (១) កុមារាភាគច្រើនទៅរៀនសាលាវត្ត ដោយសារប្រជាជនកម្ពុជាភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា។ ដូច្នេះ ក្មេងស្រីមិនអាចទៅរៀនសាលាវត្តបានឡើយ (២) កង្វះខាតគ្រូបង្រៀនដែលមានការបណ្ដុះបណ្ដាលត្រឹមត្រូវ ធ្វើឱ្យសិស្សមិនចង់ទៅរៀនជាមួយ (៣) កង្វះខាតសៀវភៅគោលសិក្សាជាខេមរភាសា (៤) ប្រជាជនភាគច្រើនមិនចេះអក្សរ និងមិនយល់ពីតម្លៃនៃការសិក្សា (៥) កម្មវិធីសិក្សាមិនបានផ្ដោតទៅលើបរិស្ថានជុំវិញសាលាជាហេតុធ្វើឱ្យការសិក្សាមិនសូវមានប្រយោជន៍ក្នុងជីវភាពរស់នៅរបស់កសិករ (៦) ការចូលរៀនក្នុងសាលាបឋមសិក្សាបំពេញវិជ្ជាត្រូវមានអាហារូបករណ៍ (៧) ប្រជាជនគ្មានធនធានដើម្បីបញ្ជូនកូនទៅរៀនក្នុងសាលារដ្ឋ។ ដូច្នេះហើយទើបអាជ្ញាធរបានដាក់ចេញនូវគោល-នយោបាយធ្វើទំនើបកម្មសាលាវត្ត។

### ១.៣.៣.៣. ប្រព័ន្ធអប់រំខ្មែរនៅដើមស.វ.ទី២០

ការវិវត្តប្រព័ន្ធអប់រំខ្មែរនៅដើមស.វ.ទី២០ អាចចែកចេញជាពីរដំណាក់កាល ៖ ដំណាក់កាលទី១ ពីឆ្នាំ១៩១៥ ចាប់ពីការបង្កើតសាលាបាលី ដល់ឆ្នាំ១៩៥៣ នៅពេលដែលកម្ពុជាទទួលបាននូវឯករាជ្យពីបារាំង ដែលជាដំណាក់កាលអន្តរកាលនៃ «សន្តិសហវិជ្ជមាន» រវាងសាលាវត្តទំនើប និងសាលាបារាំង-ខ្មែរ និងដំណាក់កាលទី២ ពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៧០ ក្នុងសម័យសង្គមរាស្ត្រនិយម ដែលប្រព័ន្ធអប់រំកម្ពុជាស្គាល់នូវការរីកចម្រើននៅលើកោះសន្តិភាពចំនួន ១៥ ឆ្នាំ មុននឹងធ្លាក់ចុះទៅក្នុងអណ្ដាតភ្លើងនៃសង្គ្រាម ដែលបង្កឡើងដោយរដ្ឋប្រហារទម្លាក់សម្ដេច **នរោត្តម សីហនុ** នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ និងរបបប្រល័យពូជសាសន៍ប៉ុលពត។

នៅក្នុងអត្ថបទ «ទិដ្ឋភាពទូទៅនៃការបណ្ដុះបណ្ដាលធនធានមនុស្ស នៅប្រទេសកម្ពុជាពីដើមស.វ.ទី២០ ដល់ឆ្នាំ១៩៧៥» បណ្ឌិត ស៊ន សំណាង[125] បានបែងចែកប្រព័ន្ធ

[125] ស៊ន សំណាង « ទិដ្ឋភាពទូទៅនៃការបណ្ដុះបណ្ដាលធនធានមនុស្សនៅប្រទេសកម្ពុជា ពីដើមសតវត្សរ៍ទី២០ដល់ឆ្នាំ១៩៧៥» នៅក្នុងកម្រងឯកសារនៃសន្និសីទជាតិស្ដីពីការបណ្ដុះបណ្ដាលធនធានមនុស្សនៅកម្ពុជា ៖ តុល្យការ និងចក្ខុវិស័យ» រៀបចំដោយរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី ២៣-២៤ ធ្នូ ១៩៩៩ ទំព័រ ១-២៤។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អប់រំខ្មែរនៅពាក់កណ្ដាលទី១ នៃស.វ.ទី២០ ជាបីផ្នែកគឺ ៖ ការអប់រំបែបសាសនា ការអប់រំតាមប្រពៃណី និងការអប់រំចំណេះទូទៅ។

**ការអប់រំបែបសាសនា** មានពីរភូមិសិក្សា គឺសាលាពុទ្ធិកបឋមសិក្សា និងសាលាពុទ្ធិកមធ្យមសិក្សា។ សាលាបាលីរង (École élémentaire de Pâli) ត្រូវបានបង្កើតឡើងទូទាំងប្រទេសនៅឆ្នាំ១៩៣៣ ហើយត្រូវបានផ្លាស់ឈ្មោះជាសាលាពុទ្ធិកបឋមសិក្សានៅឆ្នាំ១៩៥៧។ នៅឆ្នាំ១៩៦៣ សាលាពុទ្ធិកបឋមសិក្សាមានចំនួន៥៩០ និងមានសមណសិស្សចំនួន ១០ ១៥០ អង្គ។ សាលាបាលីត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៤ និង បានក្លាយទៅជាសាលាបាលីជាន់ខ្ពស់នៅឆ្នាំ១៩២២ និងត្រូវបានប្ដូរឈ្មោះទៅជាគ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធសាសនា ឬពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅឆ្នាំ១៩៥៥។ ចំនួនសមណសិស្សក៏បានកើនឡើងពី ២៥ អង្គក្នុងមួយឆ្នាំ ក្នុងឆ្នាំ១៩២២ ដល់ ១០០ អង្គ ក្នុងឆ្នាំ១៩៤៧ ហើយកើនដល់៦៨០អង្គ ក្នុងឆ្នាំ១៩៦២[126]។ កម្មវិធីសិក្សាក៏ត្រូវបានកែលម្អឱ្យបានដូចសាលារដ្ឋផងដែរ។

**ការអប់រំតាមប្រពៃណី** គឺជាការអប់រំតាមសាលាវត្ត។ មុនការធ្វើកំណែទម្រង់ក្នុងទសវត្សរ៍ទី៣០នៃស.វ.ទី២០ ការអប់រំតាមសាលាវត្តផ្ដោតសំខាន់ទៅលើការអាន និងសរសេរភាសាខ្មែរ គម្ពីរព្រះពុទ្ធសាសនា និងលេខនព្វន្ត។ បន្ទាប់ពីការធ្វើទំនើបកម្មសាលាវត្ត ដោយបញ្ចូលកម្មវិធីថ្មី រួមទាំងលេខនព្វន្ត ប្រវត្តិសាស្ត្រ ជីវវិទ្យា និងភូមិសាស្ត្រ និងការអនុវត្តសាលាវត្តបែបថ្មីដោយជោគជ័យនៅខេត្តកំពតចាប់ពីឆ្នាំ១៩២៤ **សាលាវត្តបែបថ្មី** (École de pagode rénovée) ត្រូវបានពង្រីកទូទាំងប្រទេសចាប់ពីឆ្នាំ១៩៣០។ ចំនួនសាលាបានកើនឡើងពី ៨១៣ និងមានសិស្សចំនួន ៣៤ ៥៨៣ នាក់ ក្នុងឆ្នាំ១៩៣៥-១៩៣៦ ដល់ ១ ៦១៥ និងមានសិស្សចំនួន ៧៩ ០០៥ នាក់ ក្នុងឆ្នាំ១៩៦០-១៩៦១[127]។

**ការអប់រំបែបឋមសិក្សា** ត្រូវបានរៀបចំឡើងនៅតាម ៖ (១) សាលាឃុំ ឬ École communale (ចំនួនធ្លាក់ចុះពី ២០៣ និងមានសិស្ស ៧.២៥៩នាក់ ក្នុងឆ្នាំ១៩៣០ ដល់ ៨២ និងមានសិស្ស ៣ ៦២៣ នាក់ ក្នុងឆ្នាំ១៩៣៦), (២) សាលាបឋមសិក្សាជាន់ដំបូង ឬ École élémentaire (ចំនួនសាលាកើនឡើងពី ៦១ និងមានសិស្ស ៣ ១២៥ នាក់ ក្នុងឆ្នាំ១៩២១ ដល់១០០ និងមានសិស្ស ២២ ៧១៣ នាក់ ក្នុងឆ្នាំ១៩៤៤), (៣) សាលាបឋមសិក្សាបំពេញវិជ្ជា ឬ École primaire complémentaire (ចំនួនសាលាកើនឡើងពី ១០៥ និងមានសិស្ស

---

[126] ស៊ន សំណាង ទំព័រ ១-២។

[127] ស៊ន សំណាង ទំព័រ ២-៣។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៨ ៦០០នាក់ ក្នុងឆ្នាំ១៩៣០ ដល់ ២០០១ សាលា និងមានសិស្ស ៥៥៤ ៨៨៧ នាក់ក្នុងឆ្នាំ ១៩៦០)។

**ការអប់រំចំណេះទូទៅ** មានពីរភូមិសិក្សា គឺការអប់រំបឋមសិក្សា និងការអប់រំមធ្យមសិក្សា។ សាលារៀបរយទីមួយត្រូវបានបង្កើតឡើងនៅកម្ពុជា ដោយព្រះបាទ **នរោត្តម** នៅឆ្នាំ១៨៦៧ សម្រាប់តែព្រះរាជវង្សានុវង្ស និងកូននាហ៊ឺនធំៗ ហើយមានសិស្សចំនួន៨០ បានចូលរៀន។ សាលាបារាំងទី១ត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៧៣ ដោយលោក Ferreyrolles ដែលជានាយទាហានថ្មើរជើងបារាំង[128]។ សិស្សខ្លះមានឱកាសបានទៅរៀនបន្តនៅបារាំង ហើយពួកគេក៏បានចូលបម្រើក្នុងរាជការអាណានិគម។ ការកសាងប្រទេស ទាមទារឱ្យមានការអភិវឌ្ឍធនធានមនុស្ស ដើម្បីបម្រើការងារក្នុងរដ្ឋបាលអាណានិគម។ ក្នុងឆ្នាំ១៨៩៣ អាជ្ញាធរបារាំងបានបង្កើតអនុវិទ្យាល័យអាណាព្យាបាល (Collège du Protectorat) តាមសំណើរបស់លោក Ferdinand Fontaine អធិការដែលមកបំពេញបេសកកម្មពិសេសនៅកម្ពុជា។ ពេលដំបូង អនុវិទ្យាល័យអាណាព្យាបាលនេះគ្រាន់តែជាសាលាបឋមសិក្សាតែប៉ុណ្ណោះ ដែលមានទីតាំងនៅខាងជើងវត្តភ្នំ តាម Quai Piquet បច្ចុប្បន្នគឺ តិរៈវិថី ស៊ីសុវត្ថិ។ ក្នុងក្របខណ្ឌកំណែទម្រង់នេះ ការអប់រំតាមបែបបារាំងត្រូវបានបញ្ចូលមកក្នុងប្រទេសកម្ពុជា ជាមួយនឹងការបង្កើត **សាលាជរោត្តម** នៅរាជធានីភ្នំពេញនាឆ្នាំ១៩០៣។

ក្នុងឆ្នាំ១៩០៥ អនុវិទ្យាល័យអាណាព្យាបាលបានប្តូរទីតាំងមក **វិទ្យាល័យព្រះស៊ីសុវត្ថិ**សព្វថ្ងៃ និងដូរឈ្មោះទៅជាសាលា **ស៊ីសុវត្ថ** ហើយប្រែក្លាយទៅជាអនុវិទ្យាល័យ **ស៊ីសុវត្ថ** នៅឆ្នាំ១៩១១ និង វិទ្យាល័យ **ស៊ីសុវត្ថ** នៅឆ្នាំ១៩៣៥។ ដូច្នេះ ក្នុងមួយឆ្នាំៗ មានសិស្សប្រមាណជា ១០០នាក់ប៉ុណ្ណោះ ដែលបានទទួលការសិក្សាកម្រិតមធ្យមសិក្សា។ ជារួម នៅសម័យអាណាព្យាបាល សិស្សានុសិស្សភាគច្រើនទទួលបានត្រឹមតែការអប់រំកម្រិតបឋមសិក្សាប៉ុណ្ណោះ។ ចំណែកឯការបង្កើតគ្រឹះស្ថានឧត្តមសិក្សាវិញ គឺទាល់តែក្រោយសង្គ្រាមលោកលើកទីពីរ ជាពិសេសក្រោយការទទួលបានឯករាជ្យពីបារាំងក្នុងឆ្នាំ ១៩៥៣។

មកទល់ពេលដែលកម្ពុជាទទួលបានឯករាជ្យពីបារាំង ចំនួនសាលាវត្តទំនើបបានកើនឡើងពី ១០១ សាលានៅឆ្នាំ១៩៣១ (មានគ្រូជាសង្ឃចំនួន ១១១ នាក់ និងមានសិស្ស

[128] Bilodeau, Ch. (1955) “Compulsory Education in Cambodia”, in Bilodeau, Somlith Pathammavong and Le Quang Hong, (1955), Compulsory Education in Cambodia, Laos and Vietnam, UNESCO, Paris, p. 16.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួន ៣ ៣២២ នាក់) ដល់ ១ ៩៤៧ សាលានៅឆ្នាំ១៩៥២ (មានគ្រូជាសង្ឃចំនួន ១ ៨១០ នាក់ និងមានសិស្សចំនួន ៧៦ ៩៤៣ នាក់)។ ដោយឡែក នៅសាលាបឋមសិក្សាខ្មែរ-បារាំងមានបង្រៀនគណិតវិទ្យា ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រជាភាសាបារាំង។ ចំនួនសាលាបឋមសិក្សាជាន់ដំបូង(cours élémentaire) បានកើនឡើងពី ៨៩ សាលា ដែលមានសិស្ស ៧ ៨៣៤ នាក់ ក្នុងឆ្នាំ១៩៣០-៣១ ដល់ ៦៥៩ សាលា ដែលមានសិស្សរៀន ១០៣ ៧៩៥ នាក់ ក្នុងឆ្នាំ១៩៥១-៥២។ ចំនួនសាលាបឋមសិក្សាបំពេញវិជ្ជា(courscomplémentaire) បានកើនឡើងពី ១៨ សាលា ដែលមានសិស្ស ១ ៦០៣ នាក់ ក្នុងឆ្នាំ ១៩៣០-៣១ ដល់ ១២៨ សាលា ដែលមានសិស្សរៀន ១៧ ៩១៩ នាក់ ក្នុងឆ្នាំ១៩៥១-៥២[129]។ ដោយឡែក ចំនួនបេក្ខជនដែលប្រឡងជាប់វិញ្ញាបនបត្របញ្ចប់ការសិក្សាបឋមសិក្សាបំពេញវិជ្ជាបាន កើនឡើងពី ១២១ នាក់នៅឆ្នាំ១៩៣៣ ដល់ត្រឹម ១ ៣៧១ នៅឆ្នាំ១៩៥២។ សិស្សដែលបញ្ចប់ការសិក្សាបច្ចេកទេសមានចំនួនតិចតួច ហើយចំនួននេះធ្លាក់ចុះពី ៤២៣ នាក់នៅឆ្នាំ ១៩៣១ ដល់ ២៤២ នាក់ នៅឆ្នាំ១៩៥២។ សិស្សដែលបញ្ចប់ការសិក្សាមធ្យមសិក្សាបាន កើនឡើងពី ២៦៥ នាក់នៅឆ្នាំ១៩៣០-៣១ ដល់ ១ ៩៥៤ នាក់ នៅឆ្នាំ១៩៥១-៥២។ ក្រៅពីនេះ នៅមានសាលាសហគមន៍ចំនួន៧៩ នៅឆ្នាំ១៩៣៧ ដែលមានសិស្សចំនួន ៣ ៨៨៨ នាក់។ សាលាទាំងនេះត្រូវបានប្រែក្លាយទៅជាសាលារដ្ឋ។ ក្រៅពីនេះនៅមានសាលា បារាំង សាលាចិន និងសាលាវៀតណាម ដែលមានចំនួនសរុប១៨៥ នៅឆ្នាំ១៩៥១ ដែល មានសិស្សរៀនចំនួន ១៨ ០០០ នាក់។

ជារួម មូលហេតុសំខាន់ ដែលធ្វើឱ្យអាជ្ញាធរអាណាព្យាបាលមិនបានផ្តល់អាទិភាព ដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យដូចជានៅប្រទេសវៀតណាម គឺទំនាស់រវាងចរន្ត និយមការអប់រំជាភាសាបារាំងតាមរយៈការបង្កើតសាលារដ្ឋបារាំង-ខ្មែរ និងចរន្តនិយម ការអប់រំជាភាសាខ្មែរនៅតាមសាលាវត្ត ដែលចង់អភិរក្សអក្សរជាតិឱ្យបានគង់វង្ស។ នៅ ពេលដែលកម្ពុជាទទួលបានឯករាជ្យពីបារាំង សិស្សដែលបានរៀនចប់ថ្នាក់ទី៣នៃបឋម សិក្សា ដែលរៀននៅសាលាវត្តទំនើប និងសាលាបឋមសិក្សាជាន់ដំបូងមានចំនួន ១,៨ សែននាក់។ កុមារា កុមារី ដល់វ័យសិក្សាចំនួនប្រមាណពី១៥% ទៅ២០% ប៉ុណ្ណោះ ដែល បានចូលសិក្សានៅកម្រិតបឋមសិក្សា។ សិស្សដែលរៀននៅសាលាបឋមសិក្សាបំពេញវិជ្ជា មានចំនួន ១៧ ៩១៩ នាក់ ក្នុងនោះបេក្ខជន ដែលប្រឡងជាប់វិញ្ញាបនបត្របញ្ចប់ការសិក្សា បឋមសិក្សាបំពេញវិជ្ជាមានចំនួនត្រឹម ១ ៣៧១ នាក់។ សិស្សដែលរៀនចប់មធ្យមសិក្សា មានចំនួនតែ ២ ពាន់នាក់ប៉ុណ្ណោះក្នុងមួយឆ្នាំ លើប្រជាជនចំនួន ៤,៥ លាននាក់។ ដើម្បី

[129] Bilodeau, Ch. (1955) “Compulsory Education in Cambodia”, Op.cit., pp. 65-66.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទទួលការអប់រំនៅកម្រិតឧត្តមសិក្សា និស្សិតកម្ពុជាត្រូវបានបញ្ជូនទៅរៀននៅវៀតណាម ឬបារាំង។

## ១.៣.៦. ចតុស្តម្ភនៃស្ថាប័នអប់រំកម្ពុជាក្នុងស.វ.ទី២០

ទោះជាយ៉ាងណា ក្នុងអំឡុងពេលបីទសវត្សរ៍ដំបូងនៃស.វ.ទី២០ ស្ថាប័នអប់រំព្រះពុទ្ធសាសនាចំនួន៤ ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ៖ សាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យកម្ពុជា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដក។

ក្នុងគោលបំណងដើម្បីកាត់បន្ថយឥទ្ធិពលរបស់សៀមមកលើព្រះសង្ឃកម្ពុជា[130] ព្រះបាទសម្តេច **ព្រះស៊ីសុវត្ថិ** ទ្រង់ព្រះរាជានុញ្ញាតឱ្យបង្កើត ***សាលាបាលី*** ទី១ (សាលាបាលីជាន់ខ្ពស់អង្គរវត្ត) ក្នុងឆ្នាំ១៩០៩ នៅក្រុងសៀមរាប។ សាលានេះផ្តល់ការអប់រំខាងសាសនាប្រកបដោយគុណភាព ដល់សិស្សចំនួន ៤៧ នាក់នៅក្នុងឆ្នាំ១៩០៩[131]។ ទោះជាយ៉ាងនេះក្តី សាលានេះបានបិទទ្វារនៅឆ្នាំ១៩១១ ដោយសារមានការលំបាកក្នុងការជ្រើសរើសសិស្សចូលរៀន។ តាមការទទូចស្នើសុំរបស់លោក George Coedès ដែលព្រួយបារម្ភអំពីការកើនឡើងនៃឥទ្ធិពលនិកាយធម្មយុត្តិ ***សាលាបាលីជាន់ខ្ពស់*** ថ្មីមួយទៀតត្រូវបានបង្កើតឡើងនៅរាជធានីភ្នំពេញក្នុងឆ្នាំ១៩១៥។ ព្រះតេជគុណព្រះមហាវិមលធម្ម **ថោង** (១៨៦២-១៩២៧) ដែលបានសិក្សារៀនសូត្រនៅវត្តឧណ្ណាលោម ជាមួយសម្តេចព្រះសង្ឃរាជ **និល ទៀង** ត្រូវបានតែងតាំងជាចាងហ្វាងសាលាបាលីជាន់ខ្ពស់នេះ។ មេដឹកនាំអ្នកប្រាជ្ញខាងផ្នែកពុទ្ធសាសនា ចំនួនពីរអង្គទៀត គឺសម្តេចព្រះសង្ឃរាជ **ជួន ណាត**[132] និងសម្តេចព្រះសង្ឃរាជ **ហួត តាត**[133] ក៏ធ្លាប់ជាសិស្សភាសាបាលីរបស់ព្រះតេជគុណព្រះមហាវិមលធម្ម **ថោង** ផងដែរ។ ដូច្នេះ ការបង្កើត ***សាលាបាលីជាន់ខ្ពស់*** បានបណ្តុះបណ្តាលនូវបញ្ញវន្តខ្មែរឆ្នើមៗជាច្រើននាក់។ ដូចជំនាន់ព្រះបាទ **អង្គឌួង** ដែរ ខ្មែរបាន

---

[130] ក្នុងសតវត្សរ៍ទី១៩ ក្រុងបាងកកជាមជ្ឈមណ្ឌលពុទ្ធសាសនាយ៉ាងសំខាន់សម្រាប់បណ្តុះបណ្តាលភិក្ខុ និងសាមណេរកម្ពុជា ដែលចង់បន្តការសិក្សា ដើម្បីទទួលបានការសិក្សាឧត្តមសិក្សាផ្នែកភាសាបាលី (Hansen. Op. cit., p. 85)។

[131] Hansen. Op. cit., p. 133.

[132] សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** បានទទួលនាមបញ្ញត្តិថា ជោតញ្ញាណោ និងត្រូវបានតែងតាំងជាព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ ក្នុងឆ្នាំ១៩៤៨ ។

[133] សម្តេចព្រះមហាសុមេធាធិបតី **ហួត តាត** ត្រូវបានតែងតាំងជាសម្តេចព្រះសង្ឃរាជគណៈមហានិកាយ ក្នុងឆ្នាំ១៩៦៩ ក្រោយពីសម្តេច **ជួន ណាត** សុគតទៅ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លើកតម្កើងព្រះពុទ្ធសាសនា ជាពិសេសការអប់រំជាភាសាបាលី ដែលជាមធ្យោបាយដ៏ស័ក្តិសិទ្ធិក្នុងការថែរក្សាវប្បធម៌ជាតិ។ ក្នុងបរិការណ៍នេះ អ្នកចេះដឹងភាគច្រើនគឺជាសង្ឃ ហើយចលនារៀនភាសាបាលីត្រូវបានគាំទ្រប្រកបដោយប្រសិទ្ធភាព ដោយអ្នកប្រាជ្ញបារាំងមួយទៀត គឺ Suzanne Karpelès។

ការបង្កើត **ព្រះរាជបណ្ណាល័យកម្ពុជា** ក្នុងឆ្នាំ១៩២៥ គឺជាព្រឹត្តិការណ៍ប្រវត្តិ-សាស្ត្រដ៏សំខាន់មួយទៀត ក្នុងការលើកកម្ពស់ការរៀន និងការអាននៅកម្ពុជា។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩២០ លោកស្រី Suzanne Karpelès ត្រូវបានចាត់តាំងឱ្យគ្រប់គ្រង និងចាត់ចែងបណ្ណាល័យ ព្រមទាំងក្នុងការលើកកម្ពស់ការបោះពុម្ពផ្សាយអត្ថបទព្រះពុទ្ធសាសនា។ ចំនួនអ្នកអានបានកើនឡើងពី ៣ ៧៨២ ក្នុងឆ្នាំ ១៩២៦ ទៅ៥ ៩៣៧ ក្នុងឆ្នាំ ១៩៣០[134]។

ស្ថាប័នធំមួយទៀតនៅឧត្តមសិក្សានាដើមស.វ.ទី ២០ គឺ **វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ** ដែលត្រូវបានសម្ពោធនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៣០ ដោយមានភារកិច្ចឆ្លើយតបទៅនឹងតម្រូវការនៃសាលាបាលី បណ្ណាល័យ សារមន្ទីរជាដើម ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវព្រះពុទ្ធសាសនាថេរវាទ។ ភារកិច្ចសំខាន់របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យគឺត្រួតពិនិត្យ និងរៀបចំការងារកែសម្រួល ការបកប្រែ និងសរសេរគម្ពីរព្រះត្រៃបិដកជាភាសាបាលី-ខ្មែរ និងបោះពុម្ព ផ្សព្វផ្សាយអត្ថបទស្រាវជ្រាវស្តីពីវប្បធម៌ និងអារ្យធម៌ខ្មែរ។

ចាប់តាំងពីឆ្នាំ១៩៣០ មក ស្ថាប័នទាំងបីដែលរួមមាន ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សាលាបាលី និងព្រះរាជបណ្ណាល័យ បានក្លាយទៅជាមជ្ឈមណ្ឌលដ៏សំខាន់ក្នុងការលើកកម្ពស់ «**ធម៌ថ្មី**» ឬចលនា «ធម៌សម័យទំនើប» ។ នៅដើមស.វ.ទី២០ នៅវត្តឧណ្ណាលោមមានកើតជម្លោះរវាងក្រុមសង្ឃដែលប្រកាន់ «**ធម៌ចាស់**» និងក្រុមដែលប្រកាន់ «**ធម៌ថ្មី**»។ «ពួកធម៌ចាស់» [135] គឺជាក្រុមដែលប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ពីដើមរៀងមករបៀបប្រតិបត្តិព្រះពុទ្ធសាសនាតាមទម្លាប់តៗគ្នាពីបុរាណ ទោះបីជាទម្លាប់នោះខុសក្តីត្រូវក្តី។ ពួកនេះឥតរវល់នឹងពិនិត្យមើលគម្ពីរដីកាក្បួនច្បាប់ឡើយ[136]។

---

[134] Ibid, p. 145.

[135] ក្រុមនេះដឹកនាំដោយសម្តេចព្រះសង្ឃនាយក **កែ អ៊ុក** ដែលស្នងតំណែងពីសម្តេចព្រះសង្ឃរាជ **និល ទៀង** ។ គាត់គឺជាមេក្រុមធម៌ចាស់ដែលជាក្រុមបុរាណនិយមក្នុងព្រះពុទ្ធសាសនា។

[136] សម្តេចព្រះមហាសុមេធាធិបតី **ហួត តាត** ព្រះសង្ឃនាយកគណៈមហានិកាយ (១៩៧០)«កល្យាណមិត្តរបស់ខ្ញុំ គឺ សម្តេចព្រះសង្ឃរាជ **ជួន ណាត**(ជោតញ្ញាណោ)» ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ព ឡើងវិញឆ្នាំ ១៩៩៣ ទំព័រ១១។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពួកធម៌ថ្មីកើតឡើង ដោយសារភិក្ខុ ៣ រូប គឺព្រះគ្រូវិមលបញ្ញា **អ៊ុំ ស៊ូរ** ព្រះគ្រូសង្ឃសត្ថា **ជួន ណាត** និងព្រះគ្រូសង្ឃវិជ្ជា **ហួត តាត** ដែលត្រូវបានជ្រើសរើសឱ្យសម្ដែងព្រះវិន័យនៅវត្តឧណ្ណាលោមរាល់រាត្រី ដើម្បីឱ្យភិក្ខុសាមណេរស្ដាប់រហូតដល់ចេញវស្សា។ ការសិក្សាស្រាវជ្រាវរកឫសគល់នៃព្រះវិន័យ ធ្វើឱ្យភិក្ខុសាមណេរក្នុងវត្តមើលឃើញកំហុសដែលធ្លាប់ប្រតិបត្តិកន្លងមក។ ម្យ៉ាងវិញទៀត ពួកធម៌ចាស់ត្រូវសូត្រធម៌ជាភាសាបាលីដោយមិនត្រូវពន្យល់ជាភាសាខ្មែរឡើយ។ បើយោងតាមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** *«ប្រការដែលគ្រាន់តែសូត្រធម៌ជាភាសាបាលីគឺគ្មានន័យអ្វីទាំងអស់ ប្រសិនបើគេមិនយល់ពីអត្ថន័យរបស់វា។ គឺដោយសារតែការសូត្រធម៌នេះ...ទាមទារឱ្យមានជំនឿច្បាស់លាស់ និងការយល់ដឹងត្រឹមត្រូវពីជំនឿនោះ។ ពោលគឺត្រូវតែដឹងឱ្យពិតប្រាកដ និងមានការយល់ជាក់លាក់ និងត្រឹមត្រូវផង»*[137] ។ ក្រុម **«ធម៌ថ្មី»** គឺជាក្រុមដែលសិក្សា ពិនិត្យ និងប្រតិបត្តិតាមអ្វីដែលមានចែងក្នុងគម្ពីរដីកា ហើយហ៊ានកែប្រែទម្លាប់ ប្រសិនបើឃើញថាទម្លាប់ណាខុស។ សម្ដេចព្រះមហាសុមេធាធិបតី **ហួត តាត** ស្នើឱ្យមានការយល់ដឹងពីធម៌វិន័យ ដែលជាស្នូលនៃធម៌សម័យទំនើប[138]។ អ្នកដែលប្រកាន់ខ្ជាប់តាមទម្លាប់ចាស់ ពីដើមធ្លាប់សូត្រធម៌ជាបាលី លុះដល់ឮគេសូត្រធម៌ជាបាលី ព្រមទាំងសេចក្ដីប្រែជាភាសាខ្មែរផង ក៏ឱ្យឈ្មោះអ្នកសូត្រធម៌នោះថាជាពួកធម៌ថ្មីទាំងអស់ [139] ។ ទោះជាយ៉ាងនេះក្ដី ប្រការនេះធ្វើឱ្យកើតមានការប្រឈមមុខដាក់គ្នារវាង «ក្រុមធម៌ចាស់» និង«ក្រុមធម៌ថ្មី»។

ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់មួយទៀត គឺការបង្កើត **ក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដក** ក្នុងឆ្នាំ១៩២៩ ដើម្បីបកប្រែព្រះត្រៃបិដក ពីភាសាបាលីមកខេមរភាសា ដោយយកព្រះត្រៃបិដកស្លឹករឹតខ្មែរជាគោល។ **ក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដក** មាន ៦ ក្រុម។ ក្រុមជំនុំអ្នកចម្លងបានចម្លងព្រះត្រៃបិដកពីគម្ពីរស្លឹករឹតខ្មែរ ហើយបញ្ជូនទៅក្រុមជំនុំផ្ទៀងបាលី។ ក្រុមនេះបានផ្ទៀងអត្ថបទស្លឹករឹត ជាមួយព្រះត្រៃបិដកសៀម ភូមា លង្កា និងអឺរ៉ុប។ មូលហេតុដែលត្រូវផ្ទៀងផ្ទាត់ គឺដោយសារការប្រើប្រាស់ពាក្យខ្មែរ ដែលខ្ចីពីបាលី និងសំស្ក្រឹតត្រូវបានប្រើប្រាស់ខុសពីពាក្យដើម[140]។ ប្រសិនបើមានការខុសប្លែកគ្នា ក្រុមនេះធ្វើគំនូសចំណាំ រួចបញ្ជូនទៅឱ្យក្រុមបកប្រែពីភាសាបាលីមកភាសាខ្មែរ និងក្រុមជំនុំពិនិត្យសេចក្ដីប្រែ។ ក្រុមនេះត្រូវពិនិត្យសេចក្ដីប្រែ រួចបញ្ជូនទៅឱ្យក្រុមជំនុំសរសេរចម្លងឱ្យសរសេរសម្អាត រួចត្រូវបញ្ជូនទៅឱ្យក្រុមជំនុំពិនិត្យសេចក្ដីប្រែមើលម្ដងទៀត។ លុះឃើញ

[137] Chuon Nath, Gihivinaya Sankhep, quoted by Hansen, Op. cit, p. 1.
[138] Hansen, Op. cit., p. 77.
[139] សម្ដេចព្រះមហាសុមេធាធិបតី **ហួត តាត** (១៩៧០)«កល្យាណមិត្តរបស់ខ្ញុំ គឺសម្ដេចព្រះសង្ឃរាជ **ជួន ណាត**(ជោតញ្ញា-ណោ)»ទំព័រ ១២។
[140] Edwards, P. (2007), Cambodge. p. 106-107; Aymonier, “Forward”, Dictionnarie khmer-français, Saigon, 1878.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថាត្រឹមត្រូវហើយ ទើបបញ្ជូនទៅឱ្យក្រុមមួយទៀត គឺក្រុមជំនុំពិនិត្យសេចក្តីប្រែសម្រេច។ បន្ទាប់ពីបានពិនិត្យយ៉ាងហ្មត់ចត់ហើយ ទើបអត្ថបទបកប្រែត្រូវបានបញ្ជូនទៅសុំសេចក្តីយល់ព្រម ពីព្រះសង្ឃនាយកទាំងពីរគណៈ មុននឹងបញ្ជូនសំណៅគម្ពីរព្រះត្រៃបិដក ដើម្បីសុំការសម្រេចជាចុងក្រោយពីការជំនុំរដ្ឋមន្ត្រី[141]។ ការបកប្រែព្រះត្រៃបិដកពីភាសាបាលីមកខេមរភាសា បានធ្វើឱ្យភាគីនៃធម៌ទាំងពីរ គឺ«ធម៌ចាស់» និង«ធម៌ថ្មី» មានការស្រុះស្រួលគ្នា តាមរយៈការពិនិត្យមើលធម៌វិន័យ និងការកំណត់និយមន័យនៃច្បាប់នានា ដែលស្រង់ពីធម៌វិន័យ[142]។ នៅក្នុងឆ្នាំ១៩៥៧ គម្ពីរព្រះត្រៃបិដកចំនួន ៥០ ក្បាលត្រូវបានប្រែ និងបោះពុម្ពចប់សព្វគ្រប់ទាំងអស់។

អ្នកនិពន្ធខ្មែរនៅសម័យអាណាព្យាបាលមាន ៖

(១) ហ្មឺនភក្តីអក្សរ **តន់** គឺជាមន្ត្រី និងជាអ្នកនិពន្ធ ដែលបានសរសេររឿង «សព្វសិទ្ធិ» នៅឆ្នាំ១៨៩៩ នៅក្នុងការិយាល័យរបស់លោកនៅក្នុងព្រះបរមរាជវាំង។ លោកបានជំនុំប្រឹក្សាអំពីវិជ្ជាផ្សេងៗ ដូចជាសាស្ត្រាវិមានចន្ទ ទិព្វសង្វារជាដើម[143]។

(២) ព្រះបទុមត្ថេរ **សោម** (១៨៥២-១៩៣២) គឺជាកវីដ៏ល្បី ដែលមានស្រុកកំណើតនៅខេត្តព្រៃវែង។ នៅពេលមានអាយុ ២១ ឆ្នាំ ព្រះអង្គបានបួសជាភិក្ខុ និងបានបន្តការសិក្សានៅភ្នំពេញអស់ជាច្រើនឆ្នាំ ហើយបានវិលទៅធ្វើជាចៅអធិការនៅវត្តកំព្រៅខេត្តព្រៃវែងវិញ។ ព្រះអង្គបាននិពន្ធស្នាដៃដ៏ល្បីល្បាញគឺ ៖ រឿងទុំទាវ(១៩១៦)។

(៣) ឧកញ៉ាសន្ធរវោហារ **ម៉ុក**[144] (១៨៨០-១៩៣០) មាននាមដើម ម៉ុក សំឱក ជាភ្នាក់ងារនៅក្នុងព្រះបរមរាជវាំង និងជាអ្នកនិពន្ធដ៏ល្បីម្នាក់។ លោកបានប្រឡងជាប់សញ្ញាបត្របឋមសិក្សាបំពេញវិជ្ជាផុតថ្នាក់ ហើយបានចូលបម្រើជាគ្រូបង្រៀនចាប់តាំងពីអាយុ ២៣ ឆ្នាំ។ លោកត្រូវបានព្រះបាទសម្តេចព្រះនរោត្តម តែងតាំងឱ្យធ្វើជាចាងហ្វាងក្រុមព្រះអាលក្ខណ៍ ហើយជាគ្រូលើនាម៉ឺនទាំងឡាយខាងការបង្ហាត់បង្រៀនពីច្បាប់រាជការ។ លោកបានសរសេរកំណាព្យជាច្រើន និងបានសរសេររឿង «ទេវន្ទ» រឿង «ទុំទាវ» មុនរឿងទុំទាវរបស់ភិក្ខុសោម។

(៤) ឧកញ៉ាវិបុលរាជសេនា **នូកន** (១៨៧៤-១៩៤៧) មានដើមកំណើតនៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។ លោកបានបួសរៀននៅវត្ត រួចសឹកមកវិញដើម្បីចូល

[141] ស៊ិន សុវណ្ណនិ (២០១២) «ឯកសារស្រាវជ្រាវក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដកនៃប្រទេសកម្ពុជា» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។

[142] Hansen, Op. cit, p. 108. លី សុវីរ (២០០៨) «ដំណើរប្រវត្តិស្តីពីសាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និងក្រុមជំនុំ» ៣។

[143] អត្ថបទលោករឹម គិន ក្នុងទស្សនាវដ្តីមិត្តសាលាបាលី ទំព័រ ១២០ (ម៉ុញ សារី (២០១១) ទំព័រ ៣៦៧)។

[144] លី ធាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ ៩២។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ធ្វើការជាស្មៀនក្នុងរាជការ។ ក្នុងឆ្នាំ១៩០២ លោកបានប្រឡងជាប់លេខ១ ខាងអក្សរសាស្ត្រខ្មែរ និងបានសញ្ញាបត្ររាជការ ហើយក៏ត្រូវបានតែងតាំងជាចៅហ្វាយខេត្តកំពង់សៀម។ បន្ទាប់មកលោកបានក្លាយជាជំនាញការខាងច្បាប់ និងត្រូវបានតែងតាំងជាចាងហ្វាងសាលាឧទ្ធរណ៍។ បន្ទាប់ពីបានទៅរៀនបំពេញវិជ្ជាខាងរបៀបរាជការនៅប្រទេសបារាំងអស់រយៈពេល៩ខែ លោកត្រូវបានតែងតាំងជាភូឈួយ សេនាបតីក្រសួងក្សេត្រាធិការមានគោរមងារជា ឧកញ៉ាវិបុលរាជសេនា។ លោកបាននិពន្ធរឿងជាច្រើន ដូចជារឿងពិម្ពានិព្វាន(១៩២០) និង រឿង «ទាវឯក» (១៩៤២ ជាប់រង្វាន់លេខ១ ក្នុងការ ប្រឡងអក្សរសាស្ត្រក្នុងឆ្នាំ១៩៤៥) និងរឿងដទៃទៀត។

## ១.៣.៧. បញ្ញវន្តខ្មែរក្នុងស.វ.ទី២០ និងការបង្កើតវចនានុក្រមភាសាខ្មែរ

*វចនានុក្រមខ្មែរ* ដើរតួនាទីយ៉ាងសំខានក្នុងការវិវត្តភាសាខ្មែរ អក្សរសិល្ប៍ខ្មែរ ការកសាងវប្បធម៌ និងជាតិខ្មែរឡើងវិញ។ ក្រុមជំនុំជាតិខ្មែរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩១៥ ដែលមានសម្តេចចក្រីកុញ្ញរាធិបតី **ពេជ្រ ប៉ុណ្ណ** សេនាបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការជាអធិបតី និងមានសមាជិកសុទ្ធសឹងតែជាបញ្ញវន្ត ដូចជាព្រះមហាវិមលធម្ម **ថោង** ព្រះពុទ្ធឃោសាចារ្យ **ជួន ណាត** ឧកញ៉ាសុត្តន្តប្រីជា **ឥន្ទ** ព្រះឧត្តមមុនី **អ៊ុម ស៊ូ** ព្រះសក្យវង្ស **ហួត តាត** និងឧកញ៉ាទេពពិទូ **ឈឹម ក្រសេម** ជាដើម ដោយមានការទំនុកបម្រុងពីលោក Goerge Cordès ចាងហ្វាងសាលាបារាំងចុងបូព៌ា។ ក៏ប៉ុន្តែ ក្នុងចំណោមក្រុមជំនុំទាំង១៩ មានអ្នកខ្លះធ្វើការយ៉ាងពេញដៃពេញជើង អ្នកខ្លះជួយមួយដងមួយកាល ហើយអ្នកខ្លះទៀតមានតែឈ្មោះប៉ុណ្ណោះ។ មានតែព្រះពុទ្ធឃោសាចារ្យ **ជួន ណាត** មួយរូបគត់ដែលបានខិតខំប្រឹងប្រែងបំពេញការងារ រៀបចំឱ្យកើតជាវចនានុក្រមនេះឡើងនៅឆ្នាំ១៩៣៨ និងចំណាយពេលពេញមួយជីវិត ដើម្បីពិនិត្យឡើងវិញរហូតដល់ការបោះពុម្ពលើកទី៥ ក្នុងឆ្នាំ១៩៦៧ បន្ទាប់ពីបានផ្ទៀងផ្ទាត់ឡើងវិញដោយអ្នកស្ទាត់ជំនាញខាងអក្សរ-សាស្ត្រខ្មែរផងដែរ។

នៅទសវត្សរ៍ឆ្នាំ១៩៦០ មានចរន្តពីរ ដែលមិនសូវចុះសម្រុងគ្នាក្នុងការកែលម្អភាសា និងអក្សរខ្មែរ គឺចរន្តសម្តេចព្រះសង្ឃរាជ **ជួន ណាត** តំណាងអភិរក្សនិយម និងចរន្តលោក **កេង វ៉ាន់សាក់** តំណាងទំនើបកម្ម ដែលបណ្តាលឱ្យមានបក្សសាវ័ក ឬសិស្សគណៈផ្សេងៗគ្នា។ ក្នុងការបង្កើតពាក្យថ្មី ចរន្តសម្តេចព្រះសង្ឃរាជ **ជួន ណាត** ច្រើនខ្ចីពីពាក្យបាលី និងសំស្ក្រឹត។ ចំណែកលោក **កេង វ៉ាន់សាក់** បានស្នើឡើងនូវមូលភាពធំៗ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួន៥ នៅក្នុងស្នាដៃរបស់លោកស្ដីពី «មូលភាពនៃការបង្កើតពាក្យថ្មី» ៖ (១) មូលភាពនៃការចាំបាច់ (២) មូលភាពនៃវឌ្ឍននីយកម្ម (៣) មូលភាពនៃវិចារណនីយកម្ម (៤) មូលភាពនៃខេមរនីយកម្ម និង (៥) មូលភាពនៃការភ្ជាប់ទ្រឹស្ដី-អនុវត្ត។

នៅក្នុងសង្គមណាក៏ដោយ **បញ្ញវន្ត**ដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គម ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ តាមមតិលោក **វ៉ាន់ឌី កាអុន** សង្គមកម្ពុជាចាត់ទុកកវី បណ្ឌិត និងអ្នកនិពន្ធ ថាជា**បញ្ញវន្ត**[145]។ តាមមតិលោក Gramsci «**បញ្ញវន្ត** បំពេញតួនាទីរបស់ខ្លួនក្នុងនាមនៃវណ្ណៈត្រួតត្រា ជាអ្នកបង្កើត និងផ្សព្វផ្សាយចំណេះដឹងនិងមនោគមន៍វិជ្ជា- រៀបចំផលិតកម្ម និងពាណិជ្ជកម្ម- និងជាពិសេសបំពេញតួនាទីក្នុងការគ្រប់គ្រងអំណាច។ ទន្ទឹមនឹងនេះ **បញ្ញវន្ត**ដើរតួនាទីមួយទៀត គឺប្រឆាំង និងទិតៀន»[146]។ ជារួម ទស្សនវិទូ កវី និងអ្នកនិពន្ធត្រូវបានគេចាត់ទុកថា គឺជាបញ្ញវន្ត។ ដូច្នេះ បញ្ញវន្តដ៏ធំ និងល្បីល្បាញជាងគេនៅកម្ពុជានៅក្នុងស.វ.ទី២០ គឺសម្ដេចសង្ឃរាជ **ជួន ណាត** ។ ក្រៅពីសម្ដេច យើងមានតំណាងបញ្ញវន្តដ៏ឆ្នើមដទៃទៀត ដូចខាងក្រោម ៖

(១) ឧកញ៉ាសុត្តន្តប្រីជា **ឥន្ទ** (១៨៥៩-១៩២៤) បានបួសរៀននៅតាមវត្ត ដល់មានអាយុបាន ២០ ឆ្នាំ បានបួសជាភិក្ខុនៅវត្តកែវ ហើយបានទៅរៀននៅទីក្រុងបាងកក អស់រយៈពេល ៧ ឆ្នាំ។ លោកបានលាចាកសិក្ខាបទនៅពេលមានជន្មាយុ ៣៧ ឆ្នាំ។ ដល់មានជន្មាយុ ៥៥ ឆ្នាំ លោកបានមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ខាងតែងវចនានុក្រម និងផ្ទៀងផ្ទាត់គម្ពីរដីកា។ លោកគឺជាអ្នកនិពន្ធខ្មែរដ៏ល្បីម្នាក់ ដែលបាននិពន្ធរឿង «គតិលោក» (១៩២០) ចំនួន ១០ ភាគ ដែលត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាជាតិ «និរាសនគរវត្ត» (១៩២៦) ជាពាក្យកាព្យ រឿងអំបែងបែក បឋមសម្ពោធិ លោកនីតិបករណ៍ (ជាពាក្យកាព្យ) សុភាសិតច្បាប់ស្រី ក្បួនមេកាព្យ និងស្នាដៃឯទៀតចំនួន ៤៤ មុខ[147]។

(២) សម្ដេចព្រះមហាសុមេធាធិបតី **ហួត តាត** (១៨៩២-១៩៧៥) គឺជាសម្ដេចព្រះសង្ឃរាជអង្គទី៥ នៃគណៈមហានិកាយ។ សម្ដេចទ្រង់ប្រសូតនៅភូមិផ្សារឧដុង្គ ខេត្តកំពង់ស្ពឺ។ នៅពេលព្រះជន្មាយុបាន ១៣ ឆ្នាំ សម្ដេចបានបួសជាសាមណេរ និងបានសិក្សាព្រះបរិយត្តិធម៌ ក្នុងសំណាក់ព្រះធម្មលិខិតស៊្ធ។ ព្រះជន្មាយុ ២១ វស្សា សម្ដេចបាន

---

[145] Vandy Kaon et Ly Kimsok (1982). Les intellectuels khmers. Phnom Penh, p. 27.
[146] Cité dans Vandy Kaon et Ly Kimsok (1982). Les intellectuels khmers, Phnom Penh, p. 17-18.
[147] ម៉ុញ សារី (២០១១) ទំព័រ៦៤៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឧបសម្បទាក្នុងពុទ្ធសីមា វត្តឧណ្ណាលោម ក្នុងសំណាក់សម្តេចព្រះសង្ឃរាជ **និល ទៀង** ជាព្រះឧបជ្ឈាយ៍។

(៣) ព្រះភិក្ខុ **ប៉ាង ខាត់** (វីរិយបណ្ឌិតោ) គឺជាអតីតសិស្សសាលាបារាំងចុងបូព៌ា និងជាសាស្រ្តាចារ្យខាងប្រវត្តិសាសនាសកលលោក នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងជាសាស្រ្តាចារ្យភាសាខ្មែរបុរាណ(សិលាចារឹក) នៅមហាវិទ្យាល័យអក្សរសាស្រ្ត-មនុស្សសាស្រ្ត។ ព្រះអង្គមានស្នាព្រះហស្ដជាច្រើន ដូចជា ពុទ្ធជីវប្រវត្តិ វចនានុក្រមសំស្រ្កឹត-ខ្មែរ ស្រីហិតោបទេស[148] (អត្ថបទបកប្រែ) ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ មគ្គុទ្ទេសក៍នគរ។ល។

(៤) ភិរម្យភាសា **អ៊ូ ហៅ ច៊ុយ** (១៨៦៥-១៩៣៦) បានបួសរៀននៅវត្តអង្គបឹងចក ភូមិបែកស្គរ ឃុំបែកចាន។ លោកបានទៅស្វែងរៀននៅវត្តដទៃទៀតជាច្រើន ដើម្បីបំពេញចំណេះដឹងរបស់លោក។ ចេះដឹងល្មមហើយ លោកបានលាចាកសិក្ខាបទមកនិពន្ធស្នាដៃពាក្យកាព្យចំនួន៥គឺ ៖ ច្បាប់ល្បើកថ្មី(ឆ្នាំ១៩២២) ច្បាប់កេរកាលថ្មី(១៩២២) សេចក្តីរំលឹកដាស់តឿន (ឆ្នាំ១៩៣១) ច្បាប់ប្រដៅទូន្មានជនប្រុសស្រី និងបណ្តាំ ក្រមង៉ុយ (ឆ្នាំ១៩៣៥)។

(៥) លោក **កេង វ៉ាន់សាក់** (១៩២៥-២០០៨) បានប្រឡងជាប់បរិញ្ញាបត្រផ្នែកទស្សនវិជ្ជា នៅសាកលវិទ្យាល័យស័របោន ក្រុងប៉ារីស នៅឆ្នាំ១៩៥១។ នៅឆ្នាំ១៩៥២-១៩៥៤ លោកជាសាស្រ្តាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិ។ លោកជាមេដឹកនាំគណៈបក្សប្រជាធិបតេយ្យនៅពេលបោះឆ្នោតឆ្នាំ១៩៥៥។ បន្ទាប់ពីបរាជ័យនៃគណៈបក្សប្រជាធិបតេយ្យ រដ្ឋាភិបាលសង្គមរាស្រ្តនិយមបានបញ្ជាឱ្យចាប់លោកដាក់គុកធំពីខែកញ្ញា ដល់តុលា ឆ្នាំ១៩៥៥។ ដល់ពេលចេញពីពន្ធនាគារ លោកបានបោះពុម្ពផ្សាយកម្រងកំណាព្យ ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លា ទៅលើកវីនិពន្ធខ្មែរជំនាន់នោះ។ ពីឆ្នាំ១៩៥៨ ដល់១៩៦២ លោកមានតំណែងជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្រ្ត និងមនុស្សសាស្រ្ត និងជាចាងហ្វាងវិទ្យាស្ថានជាតិគរុកោសល្យ(១៩៥៨-១៩៦០)។ លោកបានការពារនិក្ខេបបទថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យស័របោន ដែលមានចំណងជើងថា «ការស្រាវជ្រាវឫសគល់នៃវប្បធម៌ខ្មែរ»។ លោកបានបង្កើតពុម្ពអក្សរខ្មែរ សម្រាប់ប្រើក្នុងម៉ាស៊ីនអង្គុលីលេខ។ ដើម្បីជាគារវកិច្ច និងជាអភិវន្ទនាការចំពោះលោក **កេង វ៉ាន់សាក់** បណ្ឌិតសភាចារ្យ **ឃីង ហុកឌី** បានសរសេរថា ៖ «សាស្រ្តាចារ្យ **កេង វ៉ាន់សាក់** ជាគ្រូអក្សរសាស្រ្តទី១ នៅឧត្តមសិក្សា លោកបានបង្ហាត់បង្រៀនសាស្រ្តាចារ្យអក្សរសាស្រ្តខ្មែរជាច្រើនជំនាន់ ហើយសាស្រ្តាចារ្យ

---

[148] **ស្រីហិតោបទេស** គឺជាស្នាដៃនិពន្ធភាសាសំស្រ្កឹតរបស់នារាយណបណ្ឌិត អ្នកប្រាជ្ញឥណ្ឌា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទាំងនេះបានចេញអប់រំយុវជនខ្មែរផ្នែកអក្សរសាស្ត្រ នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនានាទូទាំងប្រទេសរហូតដល់ឆ្នាំ១៩៧៥។ សាស្ត្រាចារ្យ **កេង វ៉ាន់សាក់** ជាកវីមួយរូបបានផ្ដើមកំណាព្យកាព្យឃ្លោងបែបទំនើប ជាអ្នកស្រាវជ្រាវ និងជាគ្រូដ៏ចំណានប្រកបដោយគុណកោសល្យខ្ពស់ បានផ្ដល់ចំណេះដឹងអ្វីជាខ្មែរជាប់ក្នុងអារម្មណ៍ និងជាអនុស្សាវរីយ៍ជានិរន្តរ៍ ដែលយើងជាសិស្សចាស់ មិនអាចបំភ្លេចបាននូវឧបការគុណនេះឡើយ»[149] ។ លោកបាននិពន្ធស្នាដៃមួយចំនួន ដូចជាម៉ាស៊ីនអង្គុលីលេខខ្មែរ(១៩៥២) កំណាព្យចិត្តក្រមុំ (១៩៥៤) និងបាននិពន្ធសិក្សាស្តីពី «មូលភាពនៃការបង្កើតពាក្យថ្មី»(១៩៦៤) និង«សូរសព្ទខ្មែរ» (១៩៦៦)[150]។

(៦) លោក **ឃួន សុខម្ភូ** (១៩៣១-១៩៧៥) កើតនៅសង្កាត់ទូកមាស ខេត្តកំពត។ លោកមានសញ្ញាបត្របណ្ឌិតអក្សរសាស្ត្រផ្នែកភាសាវិទ្យាពីសាកលវិទ្យាល័យ ហ៊ុម ប៊ុល អាល្លឺម៉ង់។ លោកបានពន្យល់ពីមូលដ្ឋាននៃអក្សរសាស្ត្រខ្មែរក្នុងស្នាដៃរបស់លោក ដែលជានិក្ខេបបទថ្នាក់បណ្ឌិតមានចំណងជើងថា «ទម្រង់សូរវិទ្យាខ្មែរ» (ឆ្នាំ ១៩៧១)។

នៅជំនាន់អាណាព្យាបាលបារាំង និងនៅជំនាន់ឯករាជ្យ យើងឃើញមានលេចឡើងនូវចលនាអក្សរសិល្ប៍ខេមរនិយម និងពុទ្ធនិយមក្រោយសម័យអាណាព្យាបាលបារាំងឆ្នាំ១៩៥៣។ ចលនាអក្សរសិល្ប៍នេះបានលើកឡើងពីការរស់នៅរបស់ខ្មែរពិតៗ ហើយដែលក្រសួងអប់រំ និងសិក្សាធិការបានដាក់បញ្ចូលស្នាដៃអក្សរសិល្ប៍នេះទៅក្នុងកម្មវិធីសិក្សាជាតិ ដែលក្នុងនោះមានស្នាដៃរបស់លោក **រីម គិន** លោក **ញ៉ុក ថែម** និងលោក **នូ ហាច**។

លោក **រីម គិន** (១៩១១–១៩៥៩) ជាសាស្ត្រាចារ្យនៅសាលាគរុវិជ្ជា និងជាអ្នកនិពន្ធខ្មែរសម័យទំនើបដ៏ល្បីល្បាញ ដែលបាននិពន្ធស្នាដៃនិពន្ធជាច្រើន ដែលក្នុងនោះរឿងសូផាត(ឆ្នាំ១៩៣៨) ដែលត្រូវបានដាក់ចូលបង្រៀនក្នុងកម្មវិធីសិក្សា។

លោក **ញ៉ុក ថែម** បាននិពន្ធរឿង កុលាបប៉ៃលិន ក្នុងឆ្នាំ១៩៣៦។ លោកជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរ និងពុទ្ធសាសនាមួយរូប និងជាសាស្ត្រាចារ្យភាសាបាលី នៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងជាអ្នកនិពន្ធនាយកយ៉ាងឆ្នើមនៃទស្សនាវដ្ដី

---

[149] បណ្ឌិតសភាចារ្យ ឃីង ហុកឌី (២០១៦) «លោកគ្រូធំ កេង វ៉ាន់សាក់» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ភ្នំពេញ ទំព័រ ១០១។

[150] ឃីង ហុកឌី (ប្រមូលផ្ដុំអត្ថបទដោយ) (២០០៦) «សម្ភារកម្មអក្សរសាស្ត្រខ្មែរ (Mélanges littéraires offerts au Professeur KENG Vannsak)» បណ្ណាគារអង្គរ ភ្នំពេញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«កម្ពុជសុរិយា» របស់ពុទ្ធសាសនបណ្ឌិត្យ។ ស្នាដៃដ៏សំខាន់មួយទៀតរបស់លោក គឺរឿងបញ្ញាសជាតក ដែលបោះពុម្ពបញ្ចូលគ្នារឿងទាំង៥០ ជាសៀវភៅមួយភាគចប់។

លោក **នូ ហាច** (១៩១៦–១៩៧៥) បាននិពន្ធរឿងប្រលោមលោកចំនួន ៤ ដែលក្នុងនោះរឿងចំនួនពីរត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សា គឺរឿងផ្កាស្រពោន(១៩៤៩) និងរឿងមាលាដួងចិត្ត(១៩៧២)។ រឿងពីរទៀតគឺរឿង នារីជាទីស្នេហា(១៩៥៣) និងរឿង លាវណ្យ និងវរិន្ទ(១៩៥៤)។

## ១.៤. សង្គមរាស្ត្រនិយម និងវិស័យអប់រំ

ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាចាប់ផ្តើមរីកចម្រើនជាបណ្តើរៗ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង១៩៦០ តាមរយៈការពង្រីកការអប់រំកម្រិតបឋមសិក្សា និងការបង្កើតគ្រឹះស្ថានឧត្តមសិក្សា។ ដោយឡែក ការអប់រំកម្រិតមធ្យមសិក្សា ទាំងមធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ) និងមធ្យមសិក្សាទុតិយភូមិ(វិទ្យាល័យ) នៅមានកម្រិតនៅឡើយ ដោយសារប្រព័ន្ធអប់រំមានលក្ខណៈជាសាជីកំពូលស្រួច ដែលផ្តោតលើតែគុណភាព ដោយមិនគិតពីសមធម៌ ក្នុងគោលដៅបណ្តុះបណ្តាលឥស្សរជនឆ្នើម មានសមត្ថភាពខ្ពស់សម្រាប់បម្រើការងាររាជការ។ បន្ទាប់ពីបានឯករាជ្យពីបារាំងនៅឆ្នាំ ១៩៥៣ វិស័យអប់រំបានក្លាយទៅជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ព្រះបាទ**សម្តេចព្រះនរោត្តម សីហនុ** ក្នុងការកសាងប្រទេសជាតិ។

### ១.៤.១. ការរីកលូតលាស់នៃសាលាបឋមសិក្សា

សាលាបឋមសិក្សា និងអនុវិទ្យាល័យនៅកម្ពុជាមានចំនួនប្រមាណជាជាង៨០០ នៅពេលដែលកម្ពុជាទទួលបានឯករាជ្យក្នុងឆ្នាំ១៩៥៣។ ជាក់ស្តែង បន្ទាប់ពីទទួលបានឯករាជ្យពីបារាំងនៅក្នុងឆ្នាំ១៩៥៣ សាលាវត្តទំនើបបានប្រែក្លាយទៅជាសាលារៀនរដ្ឋ (តាមការពិត គឺជាឈ្មោះថ្មីនៃសាលាបារាំង-ខ្មែរ ដោយមិនមានការប្តូរផ្លាស់កម្មវិធីសិក្សានោះទេ)។ ការប្រែក្លាយសាលាវត្តឱ្យទៅជាសាលារដ្ឋ បានធ្វើឱ្យចំនួនសាលារដ្ឋកើនឡើងយ៉ាងឆាប់រហ័ស ដល់១ ៦៥៣ ក្នុងឆ្នាំ១៩៥៨ ហើយបានកើនឡើងដល់៥ ០២៦ ក្នុងឆ្នាំ ១៩៦៨/៦៩ ដែលក្នុងនោះ សាលាបឋមសិក្សាមានចំនួន ៤ ៨៥៧ ហើយអនុវិទ្យាល័យ និងវិទ្យាល័យមានចំនួនត្រឹមតែ១៧៩ ប៉ុណ្ណោះ។ ចំនួនសិស្សដែលរៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបានកើនឡើងពី ៤៣២ ៦៤៩ នាក់ នៅឆ្នាំ១៩៥៦ ដល់ ១ ០១៨ ២៦៤ នាក់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងឆ្នាំ១៩៦៨-៦៩[151]។ ក្នុងនោះ សិស្សសាលាបឋមសិក្សាមានចំនួន ៩១៩ ៩៥៦ នាក់ ស្មើនឹង ៩០,៣% សិស្សអនុវិទ្យាល័យមានចំនួន ៦៣ ៦១៩ នាក់ ស្មើនឹង ៦,២% ហើយសិស្សវិទ្យាល័យមានចំនួនតែ ៣៥ ១៩៤ នាក់ប៉ុណ្ណោះ ស្មើនឹង ៣,៥%។ សិស្សទាំងនោះត្រូវបានបង្រៀនដោយគ្រូប្រមាណជា ២១ ៣១៣ នាក់ នៅកម្រិតបឋមសិក្សា និងគ្រូប្រមាណជា ៤ ៩៩១ នាក់នៅកម្រិតមធ្យមសិក្សា[152]។

*តារាងទី១ ៖ ចំនួនសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ*

| ឆ្នាំសិក្សា | សិស្សមកប្រឡង | សិស្សប្រឡងជាប់ | ភាគរយ | សង្កេត |
|---|---|---|---|---|
| 1960/61 | 6 276 | 1 474 | 23,48% | ការសិក្សាជាភាសាបារាំងពីឆ្នាំ ១៩៦០ ដល់ឆ្នាំ ១៩៦៩ |
| 1961/62 | 9 333 | 2 160 | 23,14% | |
| 1962/63 | 12 348 | 3 458 | 28,00% | |
| 1963/64 | 15 325 | 3 727 | 24,31% | |
| 1964/65 | 16 320 | 5 643 | 34,57% | |
| 1965/66 | 18 251 | 7 716 | 42,27% | |
| 1966/67 | 18 810 | 5 893 | 31,32% | |
| 1967/68 | 22 150 | 6 561 | 29,63% | |
| 1968/69 | 23 004 | 8 794 | 38,22% | |
| 1969/70 | 21 468 | 18 700 | 87,10% | |
| 1970/71 | 13 438 | 7 407 | **55,11%** | |
| | 4 636 (អ្នករៀនជាភាសាបារាំង) | 1 165 | 25,12% | ការសិក្សាជាខេមរភាសាពីឆ្នាំ ១៩៧០ |

*ប្រភព ៖ ក្រសួងអប់រំជាតិ «ស្ថានភាពខេមរយានកម្មនៅមធ្យមសិក្សា ឆ្នាំ១៩៧២» វិទ្យាស្ថានជាតិខេមរយានកម្ម ឆ្នាំ១៩៧២*

ថវិកាជាតិប្រមាណជា ២០% ចំណាយលើវិស័យអប់រំ។ សាលារៀនជាច្រើនត្រូវបានចាត់ទុកថាជាថ្នាលបណ្តុះបញ្ញា ស្មារតី គំនិតស្នេហាជាតិ និងជាទីកន្លែងសម្រាប់អនុវត្តកម្មវិធីសិក្សាជាតិ ហើយការប្រឡងថ្នាក់ជាតិវិញនោះ គឺត្រូវបានចាត់ទុកជារបាំងមួយដើម្បីជ្រើសសិស្សឆ្នើមបំផុត ដើម្បីឱ្យពួកគេបន្តការសិក្សាទៅមុខទៀត។ ការវាយតម្លៃជាបន្តបន្ទាប់របស់គ្រូទៅលើសិស្សក្នុងថ្នាក់រៀន ត្រូវបានចាត់ទុកការងារបន្ទាប់បន្សំប៉ុណ្ណោះ បើធៀបទៅនឹងការប្រឡងថ្នាក់ជាតិទាំងបីកម្រិត គឺរៀបចប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ដូចបានបង្ហាញក្នុងតារាងខាងលើ។ សិស្សដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅក្នុងទសវត្សរ៍ទី៦០ មានចំនួនពី ១ ៥០០ នាក់ (២៣% នៃសិស្សដែលចូលរួមប្រឡង) នៅក្នុងឆ្នាំ១៩៦០-៦១ ដល់ ៨ ៨០០ នាក់ (៣៨%) នៅឆ្នាំ ១៩៦៨-៦៩។ ប្រព័ន្ធសាលារៀនត្រូវបានប្រើប្រាស់ជាយន្តការមួយ ដើម្បីសម្រិតសម្រាំងឱ្យសិស្សទទួលបាននូវការអប់រំកម្រិតខ្ពស់ នៅពេលពួកគេបញ្ចប់ការសិក្សា។ សិស្សដែលពូកែបំផុតនឹងទទួលបានអាហារូបករណ៍ ដើម្បីបន្តការសិក្សារបស់ពួកគេនៅក្នុងគ្រឹះស្ថាន

[151] UNDP (1989). Kampuchea Needs Assessment Study. p. 146.
[152] UNDP (1989). Kampuchea Needs Assessment Study. p. 146.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឧត្តមសិក្សាដែលមានកិត្យានុភាព ទាំងនៅក្នុងស្រុក ទាំងនៅបរទេស។ ដូច្នេះហើយ សិស្សប្រកួតប្រជែងគ្នាយ៉ាងខ្លាំង ដើម្បីទទួលបានពិន្ទុល្អ និងចំណាត់ថ្នាក់លេខ១ នៅក្នុងថ្នាក់រៀន។ ចំនួនសិស្សនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សានៅកម្ពុជាបានកើនឡើង ពីប្រមាណជា ៩០ ០០០ នាក់ទៅជាង ១ លាននាក់ក្នុងអំឡុងពេលប្រមាណជា១៥ ឆ្នាំប៉ុណ្ណោះ[153]។ ទោះជាយ៉ាងនេះក្តី ប្រព័ន្ធអប់រំនៅកម្ពុជាត្រូវបានបង្កើតឡើងដើម្បីបណ្តុះ-បណ្តាលវិញ្ញូជន និងមន្ត្រី[154] ដើម្បីឱ្យធ្វើការជាមន្ត្រីរាជការ នៅក្នុងសេវាសាធារណៈ និងវិស័យឯកជន។

*តារាងទី២ ៖ លទ្ធផលនៃការប្រឡងផ្សេងៗក្នុងឆ្នាំ ១៩៦២-៦៣*

| ការប្រឡងផ្សេងៗ | គ្រឹះស្ថាន | បេក្ខជនចូលរួមប្រឡង | បេក្ខជនជាប់ |
|---|---|---|---|
| ១. ប្រឡងចប់បឋមសិក្សា | សាលាបឋមសិក្សា | 44 084 | 11 520 |
| ២. ប្រឡង D.E.S.P.C. | សាលាមធ្យមសិក្សា | 16 888 | 3 458 |
| ៣. ប្រឡង BAC I | សាលាមធ្យមសិក្សា | 2 999 | 550 |
| ៤. ប្រឡង BAC II | សាលាមធ្យមសិក្សា | 694 | 177 |

*ប្រភព ៖ បណ្ណសារដ្ឋានជាតិ (ថតចម្លងថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥) Résultats aux divers examens et concours (situation de l'année 1962-63)*

ប្រព័ន្ធអប់រំនាសម័យនោះ គឺមានរាងជា «**សាជីអប់រំ**» ដែលមានបាតរីកធំយ៉ាងខ្លាំងនៅកម្រិតបឋមសិក្សា រួចរួមតូចទៅៗនៅកម្រិតមធ្យមសិក្សា និងនៅសាកលវិទ្យាល័យ[155]។ យើងអាចវាយតម្លៃបានថា «**ការអប់រំនៅកម្ពុជានៅក្នុងទសវត្សរ៍ទី៦០ មានគុណ-ភាពខ្ពស់ ក៏ប៉ុន្តែគ្មានសមធម៌**»។ នៅក្នុងឆ្នាំ១៩៥៥ មានតែប្រជាជនចំនួន ៧,៥% តែប៉ុណ្ណោះបានចូលរៀន។ ១០ឆ្នាំក្រោយមក អត្រានេះកើនឡើងដល់ ១០,៦% នៅក្នុងឆ្នាំ១៩៦៣-៦៤។ សមិទ្ធិសង្គមក្នុងរយៈពេល ១០ ឆ្នាំបន្ទាប់ពីបានទទួលឯករាជ្យពីបារាំងមានដូចតទៅ ៖

*តារាងទី៣ ៖ ការអភិវឌ្ឍវិស័យអប់រំនៅសម័យសង្គមរាស្ត្រនិយម*

| ឆ្នាំ | បឋមសិក្សា | | មធ្យមសិក្សា | | ការអប់រំបច្ចេកទេស | |
|---|---|---|---|---|---|---|
| | សាលា | សិស្ស | សាលា | សិស្ស | សាលា | សិស្ស |
| 1930 | 3 014 | 65 000 | 2 | 310 | 2 | 400 |

[153] Nepote (1979), p.777-78.

[154] ប្រព័ន្ធអប់រំដែលត្រូវបានបង្កើតឡើងដោយពួកបារាំង ត្រូវបានប្រើប្រាស់ប្រៀបបីដូចជាម៉ាស៊ីនដើម្បីសម្រិតសម្រាំង ក៏ព្រោះថាប្រព័ន្ធនេះជ្រោះយកតែសិស្សពូកែពីការអប់រំមូលដ្ឋានប៉ុណ្ណោះ ដើម្បីឱ្យពួកគេបន្តការសិក្សានៅកម្រិតខ្ពស់ ក្នុងគោលបំណងដើម្បីឱ្យប្រទេសនេះមានមន្ត្រីរាជការស៊ីវិលទំនើប ប្រកបដោយ សមត្ថភាពមួយចំនួន (Nepote, 1979, p.775)។

[155] មានសិស្សនៅមធ្យមសិក្សាត្រឹមតែចំនួន ៣ ភាគរយប៉ុណ្ណោះ ដែលបានប្រឡងជាប់កម្រិតមធ្យមសិក្សាទុតិយភូមិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | | | |
|---|---|---|---|---|---|---|
| 1935 | 1 072 | 56 200 | 3 | 370 | 2 | 260 |
| 1940 | 1 300 | 72 000 | 3 | 390 | 2 | 320 |
| 1945 | 1 369 | 89 000 | 3 | 680 | 3 | 280 |
| 1950 | 1 928 | 183 000 | 4 | 1 570 | 5 | 280 |
| 1955 | 2 498 | 286 000 | 7 | 3 810 | 5 | 330 |
| 1956 | 2 805 | 344 000 | 10 | 5 410 | 5 | 390 |
| 1957 | 2 946 | 400 000 | 12 | 7 960 | 5 | 440 |
| 1958 | 3 153 | 449 000 | 18 | 11 340 | 7 | 550 |
| 1959 | 3 316 | 526 000 | 28 | 14 080 | 7 | 670 |
| 1960 | 3 470 | 542 000 | 32 | 16 840 | 7 | 980 |
| 1961 | 3 533 | 583 000 | 35 | 20 320 | 7 | 1 090 |
| 1962 | 3 515 | 563 000 | 47 | 30 630 | 7 | 1 650 |
| 1963 | 3 646 | 596 000 | 63 | 33 020 | 10 | 2 020 |
| 1964 | 3 634 | 626 000 | 71 | 44 810 | 10 | 3 230 |
| 1965 | 3 718 | 660 000 | 85 | 59 930 | 10 | 3 810 |
| 1966 | 3 521 | 757 000 | 95 | 66 520 | 10 | 4 020 |

*ប្រភព ៖ Prud'homme R. (1969), L'économie du Cambodge. Presse universitaire de France, Paris. p. 277.*

«**កម្រិតបឋមសិក្សា** ៖ សាលាបឋមសិក្សាថ្មីៗចំនួន ១ ២៣១ ខ្នងត្រូវបានសាងសង់បន្ថែមលើសាលាចាស់ចំនួន ២ ៩៨១ ខ្នង ដែលមានរួចមកហើយ នៅក្នុងឆ្នាំ ១៩៥៩។ ក្រៅពីនេះ នៅមានសាលាវត្តចំនួន ១ ៩០០ និងសាលាឯកជនចំនួន ២៨៩។

**កម្រិតមធ្យមសិក្សា** ៖ អនុវិទ្យាល័យ និងវិទ្យាល័យថ្មីៗចំនួន៦៦ ត្រូវបានបង្កើតបន្ថែមលើអនុវិទ្យាល័យ និងវិទ្យាល័យចាស់ចំនួន៨ ដែលមានរួចមកហើយ នៅក្នុងឆ្នាំ ១៩៥៩។ ក្រៅពីនេះ នៅមានគ្រឹះស្ថានមធ្យមសិក្សាឯកជនចំនួន ១០៨ ទៀត។ ចំនួនសិស្សសរុប ដែលរៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបានកើនឡើងពី ២៩៩ ០០០ នាក់ ក្នុងឆ្នាំ១៩៥៤ ដល់ ៧៩២ ០០០ នាក់នៅឆ្នាំ១៩៦៩។

«**កម្រិតឧត្តមសិក្សា** ៖ មុនឆ្នាំ១៩៥០ កម្ពុជាគ្មានគ្រឹះស្ថានឧត្តមសិក្សាទេ។ នៅឆ្នាំ១៩៥៥ កម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាចំនួនពីរ ៖ រាជសាកលវិទ្យាល័យភ្នំពេញ និងឧត្តមសិក្សាបច្ចេកទេសខាងវិជ្ជាជីវៈ និងខាងសិល្បៈ ដែលមាននិស្សិតសរុបចំនួន ៣៥០



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាក់។ ជាងដប់ឆ្នាំក្រោយមក ក្នុងឆ្នាំ១៩៦៦ កម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាចំនួន៣៧ ដែលមាននិស្សិតចំនួន ៧ ៣៦០ នាក់[156]។

គ្រូបង្រៀនត្រូវបានគេចាត់ទុកថាជាវិជ្ជាជីវៈដែលមានកិត្យានុភាពខ្ពស់ជាងគេបំផុតនៅក្នុងសង្គមកម្ពុជានៃទសវត្សរ៍ទី៦០។ គ្រូបង្រៀនទទួលបានការគោរព និងទទួលបានប្រាក់បៀវត្សខ្ពស់។ គ្រូបង្រៀនក៏ទទួលបាននូវការគាំទ្រទាំងខាងផ្នែកស្មារតីពីអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នជាតិផងដែរ។ គ្រូបង្រៀនដើរតួនាទីជាអ្នកផ្ទេរចំណេះដឹង។ គ្រូបង្រៀននាសម័យនោះបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើការបណ្តុះបណ្តាលផ្នែកមុខវិជ្ជាឯកទេស ដែលធ្វើឱ្យពួកគាត់មានគន្លងអាជីពខ្ពង់ខ្ពស់ ហើយអាចក្លាយទៅជាឧត្តមមន្ត្រី ឬជាអ្នកនយោបាយទៀតផង។ នាសម័យនោះ គេបានបែងចែកច្បាស់លាស់រវាងការបង្រៀន និងការអប់រំ។ សិស្ស និងនិស្សិតត្រូវផ្តោតជាសំខាន់ លើការក្រេបជញ្ជក់យកចំណេះដឹង។ ប្រព័ន្ធបែបនេះបានអនុគ្រោះដល់ការរៀន និងបង្រៀនតាមវិធីសាស្ត្រគ្រូមជ្ឈមណ្ឌល។ ក្រៅពីកម្មវិធីសិក្សា សកម្មភាពសង្គមនានាមិនត្រូវបានរាប់បញ្ចូលនៅក្នុងប្រព័ន្ធនេះនោះទេ។ ប្រព័ន្ធសាលារៀនបណ្តុះបណ្តាលវិញ្ញូជននេះ បានធ្វើឱ្យមានអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ ព្រោះគឺជាប្រព័ន្ធដែលរចនាឡើងដើម្បីឧត្តមភាពតែប៉ុណ្ណោះ។ សិស្សដែលពូកែអាចទទួលបានអាហារូបករណ៍ ដើម្បីទៅបន្តការសិក្សាក្នុងសាលាផ្នែកវិស្វកម្ម (Grandes Écoles) ឬសាកលវិទ្យាល័យនៅបរទេស។ ចំណែកអ្នកផ្សេងទៀតដែលប្រឡងធ្លាក់ ត្រូវទៅបន្តរៀនជំនាញវិជ្ជាជីវៈ ដែលគេចាត់ទុកថាជាការបណ្តុះបណ្តាលលំដាប់ទីពីរ។ ថ្វីត្បិតតែប្រព័ន្ធអប់រំកម្ពុជាមានការលូតលាស់គួរឱ្យកត់សម្គាល់ តែអត្រាអនក្ខរកម្មនៅតែខ្ពស់ដដែល ដោយសារចាស់ៗពីមុនមិនបានចូលរៀននៅសាលា។ តាមទិន្នន័យជំរឿនប្រជាជនក្នុងឆ្នាំ១៩៦២ ប្រជាជនកម្ពុជាប្រមាណជា ៥៧% ដែលមានអាយុលើសពី ១០ ឆ្នាំ មិនចេះអាន និងសរសេរ[157]។

## ១.៤.២. ចលនាខេមរយានកម្ម

នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ភាសាខ្មែរត្រូវបានបញ្ចូលជាបណ្តើរៗ ក្រោម **ចលនាខេមរយានកម្ម**។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦៧ អង្គប្រជុំជាន់ខ្ពស់នៃសាកលវិទ្យាល័យ

---

[156] ព្រះសុន្ទរកថានៃសម្តេចព្រះប្រមុខរដ្ឋ **នរោត្តម សីហនុ** ទ្រង់ថ្លែងក្នុងឱកាសសម្ពោធពិព័រណ៍អចិន្ត្រៃយ៍នៃសមិទ្ធិសង្គម។ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦៤។ បណ្ណសារដ្ឋានជាតិ។ B.333. Prud'homme R. (1969), L'économie du Cambodge, Presse universitaire de France, Paris. p. 277.

[157] Margaret Slocomb (2003) The People's Republic of Kampuchea, 1979-1989: The Revolution after Pol Pot. Silkworm Books, Bangkok, p. 168.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃក្រសួងអប់រំជាតិ សម្រេចបង្កើតគណៈកម្មការរៀបចំធ្វើខេមរយានកម្មក្នុងការសិក្សា។ គោលដៅនៃចលនា**ខេមរយានកម្ម**នេះ គឺដើម្បីលើកតម្កើងភាសាខ្មែរក្នុងប្រព័ន្ធអប់រំ ដើម្បីឱ្យ *«ភាសា និងអក្សរជាតិក្លាយជាកណ្ដៀវសម្រាប់ច្រូតកាត់ប្រមូលចំណេះវិជ្ជាពីបរទេសមកទុកក្នុងជង្រុកជាតិ សម្រាប់ផ្សព្វផ្សាយបន្តទៅប្រជាជាតិខ្មែរទាំងមូល»* [158] ។ ក្នុងខែកក្កដា ឆ្នាំ ១៩៦៧ អង្គប្រជុំនៃក្រសួងអប់រំជាតិបានសម្រេចឱ្យអនុវត្តខេមរយានកម្មគ្រប់មុខវិជ្ជានៅមធ្យមសិក្សានៅថ្នាក់ទី៦ ចាប់ពីឆ្នាំ ១៩៦៧-៦៨ តទៅ។ មូលហេតុដែលមានការសម្រេចឱ្យអនុវត្តខេមរយានកម្មនៅមធ្យមសិក្សា គឺដោយសារតែក្រោយពីបានទទួលឯករាជ្យពីបារាំងមក នៅកម្រិតបឋមសិក្សា ការរៀន និងការបង្រៀនមិនអាចយកភាសាបារាំងជាភាសាយានទៀតបាន ដោយសារខ្វះគ្រូជំនាញខាងភាសាបារាំង។ ម្យ៉ាងវិញទៀត ចលនា **ខេមរយានកម្ម** នេះមានគោលដៅផ្ដល់ការអប់រំប្រកបដោយសមធម៌ ដើម្បីឱ្យ *«ប្រជាជាតិខ្មែរដែលកំពុងស្រេកឃ្លានសេចក្ដីចម្រើន លូតលាស់ខាងផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ព្រមទាំងផ្នែកវប្បធម៌ទូទៅ...ទទួលបានចំណេះដឹងទាំងនេះបាន លុះត្រាតែប្រើមធ្យោបាយភាសា និងអក្សរខ្មែរជាយាន»*[159]។

ដើម្បីអនុវត្តគោលនយោបាយខេមរយានកម្មឱ្យបានជោគជ័យ ក្រសួងអប់រំជាតិបានបង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម [160] ដែលមានគណៈកម្មការពិសេស និងអគ្គលេខាធិការដ្ឋាននៅក្រោមឱវាទ និងមានមុខងារ និងភារកិច្ចដូចតទៅ ៖ (១) អនុវត្តខេមរយានកម្មក្នុងការសិក្សា (២) ផ្សព្វផ្សាយចំណេះវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ទូទៅដោយប្រើអក្សរ និងភាសាខ្មែរ (៣) រៀបរៀងបោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រ ទស្សនាវដ្ដី សៀវភៅសិក្សា សៀវភៅវប្បធម៌ទូទៅបែបខេមរយានកម្ម (៤) ប្រមូលផ្ដុំឯកសារស្រាវជ្រាវគ្រប់មុខវិជ្ជា (៥) សិក្សាស្រាវជ្រាវអំពីអក្សរខ្មែរ ភាសាខ្មែរ ព្រមទាំងវិជ្ជាឯកទេសនានា ដើម្បីជាមូលដ្ឋាននៃអនុវត្តន៍ខេមរយានកម្ម និង (៦) ទាក់ទង និងផ្លាស់ប្ដូរលទ្ធផលសិក្សាស្រាវជ្រាវនៃវិជ្ជាឯកទេសនានា ជាមួយនឹងអង្គការជាតិ និងអន្តរជាតិដែលមានសមត្ថកិច្ចដូចគ្នា។

ម្យ៉ាងវិញទៀត ក្រសួងអប់រំជាតិបានបង្កើតគណៈកម្មការបច្ចេកទេសខាងផ្នែកពាក្យវេយ្យាករណ៍ អក្សរសាស្ត្រ ប្រវត្តិវិទ្យា ភូមិវិទ្យា ទស្សនវិជ្ជា សិល្បៈ គណិតវិទ្យា រូបវិទ្យា–គីមី ធម្មជាតិវិទ្យា រោងជាង កសិកម្ម កីឡា វិជ្ជាមេផ្ទះ ដើម្បីរៀបចំសៀវភៅគោលសិក្សាតាមមុខ

---

[158] ក្រសួងអប់រំជាតិ (១៩៧២) «ស្ថានភាពខេមរយានកម្មនៅមធ្យមសិក្សា ឆ្នាំ១៩៧២» វិទ្យាស្ថានជាតិខេមរយានកម្ម។

[160] តាមរយៈលិខិតបង្គាប់ការលេខ ៥០៦ កន ចុះថ្ងៃទី ៥ សីហា ឆ្នាំ ១៩៦៧។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិជ្ជាទាំងនេះ។ ខេមរយានកម្មនៅមធ្យមសិក្សាត្រូវបានអនុវត្តជាដំណាក់កាល ៖ ឆ្នាំ ១៩៦៧-៦៨ នៅថ្នាក់ទី៦, ឆ្នាំ១៩៦៨-៦៩ នៅថ្នាក់ទី៥, ឆ្នាំ១៩៦៩-៧០ នៅថ្នាក់ទី៤, ឆ្នាំ ១៩៧០-៧១ នៅថ្នាក់ទី៣, ឆ្នាំ១៩៧១-៧២ នៅថ្នាក់ទី២, ឆ្នាំ១៩៧២-៧៣ នៅថ្នាក់ទី១, និង ឆ្នាំ១៩៧៣-៧៤ នៅថ្នាក់ទីបញ្ចប់។ ក្នុងដំណាក់កាលនោះ មានការប្រជុំអនុម័តពាក្យបច្ចេកទេសគ្រប់មុខជំនាញទាំងភាសាជាតិ ទាំងពាក្យបរទេស ដែលពាក្យទាំងនោះត្រូវបានផ្សព្វផ្សាយតាមទស្សនាវដ្ដីខេមរយានកម្ម និងបោះពុម្ពផ្សាយសទ្ទានុក្រមបារាំង-ខ្មែរ ខ្នាតតូចមួយ។ គោលការណ៍ និងពាក្យបច្ចេកទេសទាំងអស់ ដែលគណៈកម្មការជាតិខេមរ-យានកម្មបានសម្រេចហើយ ត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងអនុម័តចុងក្រោយដោយសម្ដេចព្រះសង្ឃរាជ **ជួន ណាត**។ បន្ទាប់ពីសម្ដេចព្រះសង្ឃរាជ **ជួន ណាត** សុគតទៅ ត្រូវបានជំនួសដោយសម្ដេចព្រះសង្ឃរាជ **ហួត តាត**។

តាមផែនការដែលបានដាក់ចេញនេះ ការអនុវត្តខេមរយានកម្មនៅមធ្យមសិក្សានឹងត្រូវអនុវត្តចប់សព្វគ្រប់នៅក្នុងឆ្នាំសិក្សា ១៩៧៣-៧៤ ដែលនឹងមានសិស្សជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ តាមកម្មវិធីខេមរយានកម្មជាលើកដំបូង។ នៅដំណាក់កាលបន្ទាប់ទៀត ក្រសួងអប់រំមានគម្រោងចាប់ផ្ដើមអនុវត្តកម្មវិធីខេមរយានកម្មនៅឧត្តមសិក្សា ចាប់ពីឆ្នាំ១៩៧៤-៧៥។ ក៏ប៉ុន្តែ របបកម្ពុជាប្រជាធិបតេយ្យប្រល័យពូជសាសន៍បានបញ្ឈប់ចលនាខេមរយានកម្មត្រឹមនេះតែម្ដង។

ការអប់រំត្រូវបានសាធារណជនចាត់ទុកថា ជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់យុវជនក្រីក្រជាច្រើន ដែលមកពីតំបន់ជនបទដាច់ស្រយាលនានា ដើម្បីរំដោះពួកគេឱ្យងើបចេញផុតពីភាពក្រីក្រ ក្លាយខ្លួនជាវណ្ណៈកណ្ដាល និងអាចធ្វើឱ្យពួកគេចូលប្រឡូកជីវិតនយោបាយថែមទៀតផង។ ទោះជាយ៉ាងណា ដោយមានអតីតភាពជាអ្នកក្រីក្រ ក្រុមបញ្ញវន្តទាំងនោះតែងតែមានទំនោរទៅរកនិន្នាការនយោបាយឆ្វេងនិយម។ គ្រូបង្រៀនជាច្រើនបានចូលរួមក្នុងការស្វែងរកយុត្តិធម៌សង្គម ដោយទៅចូលរួមជាមួយពួកខ្មែរក្រហម។ ប្រការនេះបាននាំទៅដល់ការធ្លាក់ចុះនៃរបបសីហានុនិយម។

## ១.៤.៣. ការអភិវឌ្ឍវិស័យឧត្តមសិក្សា

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងពិសេស ទៅលើការអប់រំឧត្តមសិក្សា តាមរយៈការបង្កើតគ្រឹះស្ថានឧត្តមសិក្សាចំនួន៦ នៅទសវត្សរ៍ឆ្នាំ១៩៥០[161]។ ដោយហេតុ

[161] The National Institute of Juridical, political, and Economic Sciences (NIJPES) was established in 1949 and had started a bachelor of law course in 1953 by Kret # 201-NS 15/05/1953; l’École Royale de Médécine was established by Kret # 513_NS of 12/10/53; l’École Royale d’Administration by Kram #35 NS of 29/03/56); l’Institut National Pédagogique (Kret #438NS of 10/07/59); l’École National de Commerce by Kret #518-NS du 27/08/58);



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះហើយ ទើបការអប់រំឧត្តមសិក្សាត្រូវបានពង្រីកវិសាលភាពយ៉ាងឆាប់រហ័ស ចាប់ពីពាក់កណ្ដាលនៃទសវត្សរ៍ឆ្នាំ១៩៥០ រហូតដល់ឆ្នាំ១៩៧០ នៅពេលដែលសង្គ្រាមក្នុងស្រុកបានផ្ទុះឡើង បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់ **សម្ដេចព្រះឧបាធ្យាយព្រះនរោត្តម សីហនុ**។ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានកើនឡើងពី១១ នៅឆ្នាំ១៩៥៦ ដល់ចំនួន១៨ ក្នុងឆ្នាំ១៩៥៨ និងដល់ចំនួន២៩ មកទល់នឹងឆ្នាំ១៩៧០។

ដូច្នេះ ទសវត្សរ៍ឆ្នាំ១៩៦០ គឺជាសម័យកាលដែលត្រូវបានចាត់ជាសុវណ្ណសម័យនៃការអប់រំឧត្តមសិក្សានៅកម្ពុជា។ ក្នុងឆ្នាំ១៩៦០ សាកលវិទ្យាល័យភូមិន្ទខ្មែរ [162] ត្រូវបានបង្កើតឡើង ដោយច្របាច់បញ្ចូលគ្នានូវគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន។ ក្រោយមកសាកលវិទ្យាល័យភូមិន្ទខ្មែរត្រូវបានប្ដូរឈ្មោះ ជាសាកលវិទ្យាល័យភូមិន្ទវិញ ដែលប្រមូលផ្ដុំមហាវិទ្យាល័យ និងវិទ្យាស្ថានចំនួន៧ [163] ។ ភាសាបារាំងត្រូវបានប្រើប្រាស់សម្រាប់ការបង្រៀន និងប្រើប្រាស់កម្មវិធីសិក្សានិងគរុកោសល្យបែបបារាំង។ សាកលវិទ្យាល័យភូមិន្ទជាផ្គុំមួយដែលមានមហាវិទ្យាល័យចំនួន៧រួមមាន ៖ នីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច មនុស្សសាស្ត្រ វិទ្យាសាស្ត្រសុខាភិបាល និងប៉ាវ៉ាមេឌីកាល់ ឱសថសាស្ត្រ ពាណិជ្ជសាស្ត្រ និងគរុវិជ្ជា។ នៅរវាងឆ្នាំ១៩៦៨ និង១៩៦៩ មាននិស្សិតសរុបចំនួន៦ ៩៧១ នាក់ បានចុះឈ្មោះចូលរៀន និងមាននិស្សិត ១៦% ជានារី [164]។

l'Université Bouddhique was established in 1954 (Phung Ton, Rapport final du Colloque National, Phnom Penh, 27/31/71).

[162] សាកលវិទ្យាល័យភូមិន្ទខ្មែរ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦០ ដោយ ក្រម #367_NS du13/01/60 ដែលមាន ៥ មហាវិទ្យាល័យ (មហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងវិទ្យាសាស្ត្រប៉ារ៉ាមេឌីកាល់ មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ វិទ្យាស្ថានជាតិគរុកោសល្យ)។ មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ត្រូវបានបង្កើតឡើង(ក្រឹត្យចេញឆ្នាំ១៩៦១) ហើយមហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៩ (ក្រឹត្យចេញឆ្នាំ១៩៦១) សូមមើល សាកលវិទ្យាល័យភូមិន្ទភ្នំពេញ «ប្រវត្តិសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៦០-២០១៥» ទំព័រ ១០។

[163] សាកលវិទ្យាល័យភូមិន្ទខ្មែរត្រូវបានប្ដូរឈ្មោះទៅជា សាកលវិទ្យាល័យភូមិន្ទ ដោយក្រម # 224_CE, 18/01/1965 និងរួមមាន វិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់មិត្តភាពខ្មែរ–សូវៀត និងសាលាជាតិពាណិជ្ជកម្ម សូមមើល សាកលវិទ្យាល័យភូមិន្ទភ្នំពេញ «ប្រវត្តិសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៦០-២០១៥» ទំព័រ ១២។

[164] អង្គការ UNDP (១៩៨៩) «របាយការណ៍ស្ដីពីកម្ពុជាត្រូវការការសិក្សាវាយតម្លៃ» ទំព័រ ១៥២។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅឆ្នាំ១៩៦៥ សាកលវិទ្យាល័យចំនួន៦ផ្សេងទៀតត្រូវបានបង្កើតឡើងរួមមាន ៖ សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស[165] សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ[166] សាកលវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម[167] សាកលវិទ្យាល័យភូមិន្ទកំពង់ចាម[168] សាកលវិទ្យាល័យបាត់ដំបង[169] សាកលវិទ្យាល័យភូមិន្ទតាកែវកំពត[170] និងសាកលវិទ្យាល័យប្រជាជន[171] ហើយនៅចុងឆ្នាំ១៩៦៩ សាកលវិទ្យាល័យមានចំនួន៩ និងមាន ៣៤ មហាវិទ្យាល័យ និងមានសាលាជាន់ខ្ពស់ចំនួន៨។ នៅឆ្នាំ១៩៦៥ ក៏មានការបង្កើតពុទ្ធកសាកលវិទ្យាល័យ ហើយមាននិស្សិតចំនួន ១២៧ នាក់។

សាកលវិទ្យាល័យភូមិន្ទបច្ចេកទេសបានបង្កើតនៅឆ្នាំ១៩៦៤។ សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យចំនួន៥ និងវិទ្យាស្ថានចំនួន១។ មហាវិទ្យាល័យទាំងនោះមានបង្រៀនមុខវិជ្ជាដូចជា ៖ វិស្វករស៊ីវិល អគ្គិសនី សិល្បៈ និងតម្បាញ គីមីវិទ្យាអនុវត្ត និងអាកាសស៊ីវិល។ វិទ្យាស្ថានមានឈ្មោះថា វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពកម្ពុជាសូវៀត[172] ដែលក្នុងវិទ្យាស្ថាននោះមានមហាវិទ្យាល័យសំណង់ ភូគព្ភសាស្ត្រ ប្រព័ន្ធធារា-

---

165 សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស (Kram# 225-CE du 18/01/65) រួមមាន ១២ មហាវិទ្យាល័យ (មហា វិទ្យាល័យវិស្វកម្មសំណង់ស៊ីវិល មហាវិទ្យាល័យជលសាស្ត្រ និងនាវាចរណ៍ មហាវិទ្យាល័យសិល្បៈ និងសិប្បកម្ម មហាវិទ្យាល័យអេឡិចត្រូនិក សាលាជាន់ខ្ពស់គីមីវិទ្យាអនុវត្ត សាលាជាន់ខ្ពស់អាកាសចរណ៍ស៊ីវិល សាលាជាន់ខ្ពស់ជំនួញសាគរ និងមហាវិទ្យាល័យបច្ចេកទេសបញ្ចូលគ្នាក្នុងវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀត មហាវិទ្យាល័យសំណង់ មហាវិទ្យាល័យភូគព្ភ-សាស្ត្រ មហាវិទ្យាល័យធារាសាស្ត្រកសិកម្ម មហាវិទ្យាល័យអេឡិចត្រូនិក មហាវិទ្យាល័យវាយនភ័ណ្ឌ)។ (Youk Ngoy, (2016) Higher Education in Cambodia, Unpublished )។

166 សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (ក្រម # 226_CE du18 / 01/65) ត្រូវបានបង្កើតឡើងដោយមាន ៥ មហាវិទ្យាល័យ (មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ មហាវិទ្យាល័យតូរតន្ត្រី មហាវិទ្យាល័យសិល្បៈសូនរូប មហាវិទ្យាល័យបុរាណវិទ្យា មហាវិទ្យាល័យស្ថាបត្យកម្ម និងផែនការក្រុង) ។

167 សាកលវិទ្យាល័យភូមិន្ទវិទ្យាសាស្ត្រកសិកម្ម (ក្រម # 244_CE នៃ 05/26/65) ដោយមាន ៦ មហាវិទ្យាល័យ (មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម មហាវិទ្យាល័យវិទ្យាសាស្ត្រវព្វា មហាវិទ្យាល័យវិទ្យាសាស្ត្របសុពេទ្យ មហាវិទ្យាល័យវិទ្យាសាស្ត្រវារី-វប្បកម្ម មហាវិទ្យាល័យវិទ្យាសាស្ត្រវិស្វកម្មជនបទ មហាវិទ្យាល័យសង្គមវិទ្យា និងសេដ្ឋកិច្ចជនបទ) (Youk Ngoy, 2016)

168 សាកលវិទ្យាល័យភូមិន្ទកំពង់ចាម (ក្រម # 227_CE នៃ 01/18/65) ដោយមាន ៣ មហាវិទ្យាល័យ (មហាវិទ្យាល័យមេកានិក មហាវិទ្យាល័យវប្បកម្មត្រូពិច មហាវិទ្យាល័យវិទ្យាសាស្ត្រគណិតវិទ្យា រូបវិទ្យា)។

169 សាកលវិទ្យាល័យភូមិន្ទបាត់ដំបង (ក្រម # 316_CE នៃ 09/09/67, ជាមួយ ៣ មហាវិទ្យាល័យ (មហាវិទ្យាល័យសំណង់មេកានិក មហាវិទ្យាល័យឧស្សាហកម្មស្បៀងអាហារ និងកសិកម្ម មហាវិទ្យាល័យភូគព្ភសាស្ត្រអនុវត្ត និងរុករករ៉ែ) (Youk Ngoy, 2016)

170 សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត (ក្រម # 228_CE នៃ 1/18/65) ជាមួយ ៣មហាវិទ្យាល័យ [ (មហាវិទ្យាល័យមេកានិក និងអេឡិចត្រូនិក មហាវិទ្យាល័យវេជ្ជសាស្ត្រ មហាវិទ្យាល័យសាគរសាស្ត្រ នៅជាគម្រោង) ] (Youk Ngoy, 2016)

171 សាកលវិទ្យាល័យប្រជាជន (ក្រម # 258_CE នៅ 19/08/65) ដោយមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចំនួន២ (មជ្ឈមណ្ឌលសិក្សាវិជ្ជាជីវៈ មជ្ឈមណ្ឌលបណ្តុះបណ្តាលអ្នកបច្ចេកទេសជាន់ខ្ពស់ និងបង្កើនផលិតភាព) (Youk Ngoy, 2016)

172 វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាស្ត្រកសិកម្ម វាយនភ័ណ្ឌ និងអគ្គិសនី។ នៅឆ្នាំ១៩៦៨ និង១៩៦៩ សាកលវិទ្យាល័យបច្ចេកទេសមាននិស្សិតចំនួន ១ ៥៦៨ នាក់ ចូលរៀន ដែលមាន៧% ជានារី។

សាកលវិទ្យាល័យវិចិត្រសិល្បៈត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៤ ដែលរួមមានមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ តូរ្យតន្ត្រី សូនរូប បុរាណវត្ថុវិទ្យា ស្ថាបត្យកម្ម និងរៀបចំដែនដី។ និស្សិតចំនួន ៧៨៧ នាក់បានចូលរៀននៅឆ្នាំ១៩៦៨ និង១៩៦៩ ហើយមាន ២៥ % ជានារី។

សាកលវិទ្យាល័យភូមិន្ទវិទ្យាសាស្ត្រកសិកម្ម (ចំការដូង) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ហើយនៅឆ្នាំ១៩៦៨ និង១៩៦៩ មាននិស្សិតចំនួន ១៣១ នាក់។ សាកលវិទ្យាល័យនេះ រួមមានមហាវិទ្យាល័យ ៖ រុក្ខសាស្ត្រ វិទ្យាសាស្ត្រកសិកម្ម នេសាទ វិទ្យាសាស្ត្របសុពេទ្យ និងវិស្វកម្មស៊ីវិល។ លើសពីនេះ វិទ្យាល័យកសិកម្មព្រែកលាបត្រូវបានបង្កើតសម្រាប់បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដែលផ្តល់ការបណ្តុះបណ្តាលរយៈពេលបីឆ្នាំ។

សាកលវិទ្យាល័យភូមិន្ទកំពង់ចាមត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៥ ដែលរួមមានមហាវិទ្យាល័យ ៖ កសិកម្មត្រូពិក វិស្វកម្មមេកានិក ព្រមទាំង វិទ្យាសាស្ត្ររូបវិទ្យា និងគណិត-វិទ្យា ដែលមាននិស្សិតសរុបចំនួន ៦៩០ នាក់ ស្រីចំនួន១២% នៅឆ្នាំ១៩៦៨ និង១៩៦៩។

សាកលវិទ្យាល័យភូមិភាគចំនួនពីរក៏ត្រូវបានបង្កើតផងដែរ។ សាកលវិទ្យាល័យបាត់ដំបងត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៦ ដោយមានមហាវិទ្យាល័យភូគព្ភសាស្ត្រ និងរ៉ែអនុវត្ត ឧស្សាហកម្មចំណីអាហារ ព្រមទាំងសំណង់មេកានិក និងមាននិស្សិតចំនួន៣៨៣នាក់ នៅឆ្នាំ១៩៦៨ និង១៩៦៩ (៩%ជានារី)។ សាកលវិទ្យាល័យតាកែវនិងកំពតត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៧ រួមមានមហាវិទ្យាល័យអគ្គិសនី វិស្វកម្មមេកានិក ការសិក្សាពីសមុទ្រ និងវេជ្ជសាស្ត្រ ដែលមាននិស្សិតចំនួន ១៩៤ នាក់ (នារីចំនួន៣%)។

សាកលវិទ្យាល័យប្រជាជនត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៦ រួមមានមជ្ឈមណ្ឌលសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងការបង្កើនផលិតកម្ម និងសាលាវិជ្ជាជីវៈ (ដែលបង្កើតនាទសវត្សរ៍ឆ្នាំ១៩៤០)។ សាកលវិទ្យាល័យប្រជាជនមានភារកិច្ចត្រួតពិនិត្យរួមលើការអប់រំបច្ចេកទេសឯកជន ផ្នែកវិទ្យុ អគ្គិសនី គណនេយ្យ លេខា វាយនភ័ណ្ឌជាដើម ដែលមាននិស្សិតចំនួន ៣៣៤ នាក់ នៅឆ្នាំ១៩៦៨ និង១៩៦៩ និង៣៨%ជានារី។

ប្រព័ន្ធអប់រំនាសម័យសង្គមរាស្ត្រនិយមត្រូវបានគេមើលឃើញថា ជាប្រព័ន្ធអប់រំមួយដែលច្របាច់បញ្ចូលគ្នា រវាងទំនើបកម្ម និងប្រពៃណី។ ក៏ប៉ុន្តែ ទោះបីជាមានឆន្ទៈក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការធ្វើទំនើបកម្មក៏ដោយ ការរីកលូតលាស់យ៉ាងឆាប់រហ័សនៃគ្រឹះស្ថានឧត្តមសិក្សា បានធ្វើឱ្យការបណ្តុះបណ្តាលតាមមុខវិជ្ជាមិនបានឆ្លើយតប ទៅនឹងតម្រូវការរបស់ប្រទេសជាតិដែលមានប្រជាជន៨០% ប្រកបរបរកសិកម្ម។ លោក Ayres បានសន្និដ្ឋានថា៖ «ការយល់ឃើញរបស់និស្សិតពីអនាគតរបស់ពួកគេ ដែលទទួលបានមកពីប្រព័ន្ធអប់រំគឺមានលក្ខណៈមិនស៊ីសង្វាក់គ្នាជាមួយនឹងសមត្ថភាពសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសក្នុងការធ្វើឱ្យសេចក្តីប្រាថ្នារបស់ពួកគេក្លាយជាការពិត»។

នៅសម័យនោះ នៅកម្ពុជាក៏ដូចជានៅក្នុងប្រទេសមិនចូលបក្សសម្ពន្ធជាច្រើនទៀតដែរ ការអប់រំត្រូវបានគេមើលឃើញភ្លាមៗថា ជាវិធីសាស្ត្រដើម្បីគេចចេញពីស្ថាន-ភាពជាកសិករ ដើម្បីទៅជាអ្នកធ្វើការងារនៅក្នុងការិយាល័យវិញ។ ប៉ុន្តែចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៦០ មក រដ្ឋលែងមានលទ្ធភាពទទួលយកមន្ត្រីរាជការថ្មីទៀតបានឡើយ។ លោក Jean-Claude Pomonti និង Serge Thion បានវិភាគយ៉ាងច្បាស់ពីស្ថានភាពនេះ នៅក្នុងសៀវភៅ «Des courtisans aux partisans» (ពីនាម៉ឺនទៅជាសមាជិកបក្ស)។

ក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៦០ មិនថានៅកម្ពុជា ឬនៅទីណា ក្តីសង្ឃឹមដ៏ធំនានាក្នុងការអភិវឌ្ឍប្រទេសជាតិ គឺផ្អែកទៅលើវិស័យអប់រំ។ ទីបំផុត ក្តីសង្ឃឹមមួយក្នុងចំណោមនោះត្រូវបានទទួលជាការខកចិត្ត និងចេញជាការស្រមើស្រមៃទៅវិញ ក៏ព្រោះថាប្រព័ន្ធអប់រំបានបង្កើតឱ្យមានវិសមភាពសង្គម។ ទោះជាបែបណាក្តី ប្រព័ន្ធអប់រំនាសម័យសង្គម-រាស្ត្រនិយមទទួលបានការកោតសរសើរជាជាងការស្តីបន្ទោស ៖ អ្វីដែលគេមើលឃើញច្បាស់នោះ គឺការបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាពនាសម័យនោះ ហើយគ្រូបង្រៀនក៏ទទួលនូវការលើកទឹកចិត្ត។ សៀវភៅសិក្សាថ្នាក់សាកលវិទ្យាល័យនាសម័យនោះក៏មានគុណភាពល្អប្រសើរ។

ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាបានចូលដល់ទីបញ្ចប់ នៅពេលដែលរដ្ឋប្រហាររបស់លោកសេនាប្រមុខ **លន់ នល់** ដើម្បីផ្តួលរំលំសម្តេច **សីហនុ** បានធ្វើឱ្យសង្គ្រាមស៊ីវិលផ្ទុះឡើងនៅឆ្នាំ១៩៧០។ គ្រូបង្រៀនជាច្រើននាក់បានឆ្លើយតបទៅនឹងការអំពាវនាវរបស់សម្តេច **សីហនុ** និងបានរត់ទៅចូលរួមក្នុងចលនាទ័ពព្រៃ ដឹកនាំដោយខ្មែរក្រហម[173]។ សាកលវិទ្យាល័យ និងសាលារៀននៅកម្ពុជាស្ទើរតែទាំងអស់ត្រូវបានបិទទ្វារជាស្ថាពរ និងមានតែគ្រឹះស្ថានសិក្សានៅភ្នំពេញប៉ុណ្ណោះ ដែលបន្តដំណើរការ។

---

[173] អ៊ិត សារិន «ស្រណោះព្រលឹងខ្មែរ» ១៩៧៣ ទំព័រ ៤។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សាធារណៈរដ្ឋខ្មែរ ដែលប្រសូតចេញមកពីការធ្វើរដ្ឋប្រហារឆ្នាំ១៩៧០ ត្រូវបានញាំញីដោយភ្លើងសង្គ្រាម ដែលរីករាលដាលទាំងនៅក្រៅទីក្រុងភ្នំពេញ និងនៅទីរួមខេត្តមួយចំនួន ហើយរដ្ឋលែងមានឱកាសក្នុងការអភិវឌ្ឍវិស័យអប់រំទៀតហើយ។

## ១.៥. ការកសាងវិស័យអប់រំឡើងវិញក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

វិស័យអប់រំនៅកម្ពុជាត្រូវបានកម្ទេចទាំងស្រុង ដោយសារសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ជាងបីទសវត្សរ៍។ គ្រឹះស្ថានសិក្សាទាំងអស់ត្រូវបិទទ្វារទាំងស្រុងក្នុង *របបកម្ពុជាប្រជាធិបតេយ្យ* (១៩៧៥-១៩៧៩) ហើយការរៀន និងការបង្រៀនត្រូវបានហាមឃាត់។ ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ពួកខ្មែរក្រហមបានបំផ្លិចបំផ្លាញអគារសិក្សា បណ្ណាល័យ និងសម្ភារដែលបម្រើដល់ការសិក្សារៀនសូត្រអស់ប្រមាណជាជាង៩០%។ គ្រឹះស្ថានឧត្តមសិក្សាចំនួនក្នុងចំណោម៩ នៅក្នុងប្រទេសត្រូវបានបំផ្លាញខ្ទេចខ្ទី ហើយគ្រឹះស្ថានពីរទៀតក៏ត្រូវខូចខាតយ៉ាងធ្ងន់ធ្ងរ។ បញ្ញវន្តបានក្លាយជាគោលដៅនៃបដិវត្តន៍វប្បធម៌របស់ពួកខ្មែរក្រហម។ គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាចំនួន៧៥%, សាស្ត្រាចារ្យនៅសាកលវិទ្យាល័យចំនួន៩១%, សិស្សរៀននៅបឋមសិក្សា និងមធ្យមសិក្សាចំនួន៦៧%, និងនិស្សិតសាកលវិទ្យាល័យចំនួន៩៦% ត្រូវបានសម្លាប់ ឬស្លាប់ដោយអត់អាហារ (ក្រសួងអប់រំ ១៩៩០; UNESCO, 1991)។ ពួកគេបានប្រែក្លាយសាលារៀន និងសាកលវិទ្យាល័យឱ្យទៅជាមន្ទីរឃុំឃាំង ឬក៏ប្រើសម្រាប់ជាជង្រុកស្រូវទៅវិញ។ សៀវភៅសិក្សា និងឯកសារផ្សេងៗត្រូវបានដុតបំផ្លាញ និងកម្ទេចចោល។ របបកម្ពុជាប្រជាធិបតេយ្យបានធ្វើឱ្យប្រព័ន្ធអប់រំនៅកម្ពុជាធ្លាក់ដល់កម្រិតសូន្យ។ មានតែបញ្ញវន្តប្រមាណជា១៥% តែប៉ុណ្ណោះដែលនៅរស់។ អ្នកចេះដឹងមួយចំនួនធំទៀតក៏សម្រេចចិត្តភៀសខ្លួនទៅនៅឯបរទេស។ យើងអាចនិយាយបានថា មូលដ្ឋានគ្រឹះនៃស្ថាប័ន និងធនធានមនុស្សរបស់កម្ពុជា ដែលបង្កើតឡើងតាមរយៈកំណែទម្រង់របស់ព្រះបាទ **អង្គ ឌួង** ចាប់តាំងពីឆ្នាំ១៨៤៨ នៅពេលដែលកម្ពុជាបានស្គាល់សុខសន្តិភាពបរិបូណ៌ បានត្រូវបំផ្លិចបំផ្លាញអស់ដល់ឫសគល់ ចាប់តាំងពីឆ្នាំ១៩៧០ នៅពេលដែលសង្គ្រាមបានផ្ទុះឡើងបន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្ដេច **នរោត្តម សីហនុ** និងរបបប្រល័យពូជសាសន៍ប៉ុលពត ឆ្នាំ១៩៧៥-១៩៧៨។ កម្ពុជាបានស្គាល់សុខសន្តិភាពចំនួន ១២២ ឆ្នាំគត់។

*របបសាធារណរដ្ឋប្រជាមានិតកម្ពុជា* (១៩៧៩-១៩៩២) ដែលដឹកនាំបន្តក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រឈមនឹងការខ្វះខាតទាំងស្រុងក្នុងវិស័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អប់រំដូចជា ៖ គ្រូបង្រៀន សម្ភារសិក្សា និងអគារសិក្សាជាដើម។ ការកសាងប្រព័ន្ធអប់រំនៅកម្ពុជានៅពេលនោះត្រូវបានបែងចែកជាបីដំណាក់កាល ៖

ទីមួយ-នៅចន្លោះឆ្នាំ១៩៧៩-១៩៨៥ ប្រព័ន្ធអប់រំចំណេះទូទៅមានរយៈពេល ១០ ឆ្នាំ ត្រូវបានអនុវត្តទៅតាមប្រព័ន្ធ ៤-៣-៣។ គឺរយៈពេល ៤ ឆ្នាំ នៅបឋមសិក្សា (ថ្នាក់ទី១ -៤) ៣ ឆ្នាំនៅមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៥-៧) និង ៣ឆ្នាំនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី៨-១០)[174]។

ទីពីរ-នៅចន្លោះឆ្នាំ១៩៨៦-១៩៩៥ ប្រព័ន្ធអប់រំចំណេះទូទៅត្រូវបានបង្កើនរហូតដល់ ១១ឆ្នាំ ដោយអនុលោមតាមប្រព័ន្ធ ៥-៣-៣។

ទីបី-ចាប់តាំងពីឆ្នាំ១៩៩៦ មក ប្រព័ន្ធអប់រំរយៈពេល ១២ ឆ្នាំ[175] ត្រូវបានដាក់ឱ្យអនុវត្តដើម្បីសម្រេចទិសដៅនៃការបង្កើនម៉ោងបង្រៀន និងពង្រឹងការសិក្សារបស់សិស្ស។

កិច្ចខិតខំប្រឹងប្រែងក្នុងការស្តារ និងកសាងប្រព័ន្ធអប់រំឡើងវិញបានចាប់ផ្តើមនៅខែមីនា-មេសា ឆ្នាំ១៩៧៩ ដោយមានការជ្រើសរើសបុគ្គលិកអប់រំដោយលោក ចាន់ វ៉េន[176] អតីតរដ្ឋមន្ត្រីនៃក្រសួងអប់រំនាពេលនោះ ដោយក្រសួងអប់រំជាតិ[177] ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ៤ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៨០[178]។ ដូច្នេះ ការកសាងប្រព័ន្ធអប់រំឡើងវិញដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងអំឡុងពេលឆ្នាំ១៩៧៩-១៩៩២ ត្រូវចាប់ផ្តើមពីចំណុចសូន្យ[179]។

ការបង្រៀនបានចាប់ផ្តើមឡើងវិញនៅឆ្នាំ១៩៧៩ ក្នុងស្ថានភាពខ្វះខាតសព្វគ្រប់បែបយ៉ាង នៅក្នុងសាលារៀនដែលនៅសេសសល់ពីការបំផ្លិចបំផ្លាញ និងក្នុងថ្នាក់រៀនបណ្តោះអាសន្នប្រក់ស្លឹកត្នោត ស្បូវ ឬរៀនក្រោមដើមឈើ។ មន្ត្រីរាជការស៊ីវិល និងគ្រូ

---

174 ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ សាលាបឋមសិក្សាមានពីថ្នាក់ទី១-៦ ហើយបន្ថែម ៦ឆ្នាំទៀតសម្រាប់ការអប់រំនៅមធ្យមសិក្សា និងបូកបន្ថែម១ឆ្នាំថែមទៀត សម្រាប់ថ្នាក់ទីបញ្ចប់ ( Classe terminale)។

175 During the first phase (1979-1986), school structure consists of 10 years (4 years of primary, 3 years of lower secondary and 3 years of upper secondary or 4+3+3); during the second phase (1986-1996) school structure increased to 11 years (5+3+3); and during the third phase (1996-2014) it increased to 12 years (6+3+3).

176 ឆាយ ច័ន្ទនីដា «នរណាជានរណា ក្នុងបុព្វហេតុកំណែទម្រង់ប្រព័ន្ធអប់រំ លោក ហង់ជួន ណារ៉ុន ទទួលទានដំណេក ៣ ម៉ោងក្នុងមួយយប់» Khmer Post. Sat, 17 January 2015.

177 ក្រសួងអប់រំ និងសិក្សាធិការជាតិ

178 MOEYS (2011), Teacher Professional Standards, p. 1.

179 នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ពួកខ្មែរក្រហមបានកម្ទេចអគារសាលា បណ្ណាល័យ និងឧបករណ៍នានាសម្រាប់បម្រើដល់ការអប់រំអស់៩០%។ បញ្ញវន្តគឺជាគោលដៅដែលត្រូវកំចាត់ដោយពួកខ្មែរក្រហម (Ministry of Education, 1990; UNESCO,1991)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀន ដែលរួចផុតពីសេចក្ដីស្លាប់បានបង្ហាញពីទឹកចិត្តលះបង់សព្វគ្រប់បែបយ៉ាង រហូតដល់ត្រូវបង្រៀនសូម្បីតែនៅពេលយប់។ គ្រូបង្រៀនដែលនៅសេសសល់ខ្លះបានចាកចេញពីកម្ពុជា ដើម្បីភៀសខ្លួនទៅនៅបរទេស ខ្លះទៀតក៏មកធ្វើជាគ្រូបង្រៀនវិញ ឬក៏ធ្វើការងារក្នុងក្រសួង-ស្ថាប័នផ្សេងទៀត។ ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងឆ្នាំសិក្សា១៩៧៩-១៩៨០ គេឃើញមានគ្រូបង្រៀនចំនួន ១៣ ៦០០ នាក់ ដែលបានបង្រៀនសិស្សចំនួន ៨២៩ ០០០ នាក់ (៨៧%នៃចំនួនសិស្សសរុបបានចូលរៀនថ្នាក់ទី១)[180]។

ប្រព័ន្ធបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានបង្កើតឡើងវិញ។ បញ្ហាជាអាទិភាពធំបំផុត គឺការបណ្ដុះបណ្ដាលគ្រូបង្រៀន និងអ្នកគ្រប់គ្រងអប់រំនៅគ្រប់កម្រិតទាំងអស់។ បន្ទាប់ពីឆ្នាំ១៩៧៩ ភ្លាម ក្រសួងអប់រំទទួលយកអ្នកណាក៏ដោយ ឱ្យតែស្ម័គ្រចិត្តមកបង្រៀន ទោះបីជាពួកគេគ្មានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីក្លាយជាគ្រូបង្រៀនក៏ដោយ។ «វគ្គបណ្ដុះបណ្ដាលខ្លីៗ» ត្រូវបានរៀបចំឡើងក្នុងគោលដៅបណ្ដុះបណ្ដាលនិស្សិត និងអ្នកចេះដឹងដែលនៅសេសសល់មួយចំនួន ដែលមានបំណងចង់ក្លាយជាគ្រូបង្រៀន។ បេក្ខជនទាំងនោះភាគច្រើនមានការសិក្សាមិនលើសពីថ្នាក់បឋមសិក្សាឡើយ។ វគ្គសិក្សាមានរយៈពេលពីមួយសប្ដាហ៍ទៅបួនខែ។ បេក្ខជនដែលមានការសិក្សាត្រឹមតែរយៈពេលបីឆ្នាំនៅបឋមសិក្សា បានទទួលការបណ្ដុះបណ្ដាលរយៈពេលមួយឆ្នាំដើម្បីក្លាយជាគ្រូបង្រៀនបឋមសិក្សា។ ពាក្យស្លោករបស់ក្រសួងអប់រំនៅទសវត្សរ៍ឆ្នាំ៨០ គឺ ៖ «**អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ**» ហើយ«**ទៅរៀន និងទៅបង្រៀន គឺស្នេហាជាតិ**»។ សាលាគរុកោសល្យបានបើកទ្វារក្នុងឆ្នាំ១៩៧៩ ដើម្បីបំប៉ន និងបណ្ដុះបណ្ដាលគ្រូ។ ជាលទ្ធផល នៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៣ គ្រូបង្រៀនចំនួន ៣៦ ០០០ នាក់បានទទួលការបណ្ដុះបណ្ដាល ឬធ្វើវិក្រឹតការដើម្បីការអប់រំនៅបឋមសិក្សា ដោយរួមបញ្ចូលទាំងគ្រូចំនួន ៦ ៣៧៨ នាក់ ដែលទទួលបានការបណ្ដុះបណ្ដាលដើម្បីបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងគ្រូចំនួន ៩៦៣ នាក់ សម្រាប់ការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ[181]។

ចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៨៦ ប្រព័ន្ធអប់រំ ១០ ឆ្នាំ ត្រូវបានដាក់ឱ្យអនុវត្ត ហើយរចនាសម្ពន្ធសាលារដ្ឋត្រូវអនុវត្តតាមលំនាំ ៤-៣-៣ ៖ គឺបួនឆ្នាំនៅបឋមសិក្សា បីឆ្នាំនៅអនុវិទ្យាល័យ និងបីឆ្នាំទៀតនៅមធ្យមសិក្សាទុតិយភូមិ។ ក្រោយមកទៀត រយៈពេលនៃ

---

[180] អង្គការ UNDP (១៩៨៩) «របាយការណ៍ស្ដីពីកម្ពុជាត្រូវការការសិក្សាវាយតម្លៃ» ទំព័រ១៥៦។

[181] អង្គការ UNDP (១៩៨៩) «របាយការណ៍ស្ដីពីកម្ពុជាត្រូវការការសិក្សាវាយតម្លៃ» ទំព័រ១៥៦។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រព័ន្ធអប់រំចំណេះទូទៅត្រូវបានផ្លាស់ប្តូរចំនួនបីដង ដោយបង្កើនរយៈពេលសិក្សាពី១០ ទៅ១២ ឆ្នាំ ដើម្បីឱ្យត្រូវទៅតាមគោលដៅនៃកំណើនម៉ោងពេលក្នុងការរៀន និងបង្រៀន ក៏ដូចជាការពង្រឹងនូវចំណេះដឹងឱ្យកាន់តែស៊ីជម្រៅសម្រាប់សិស្ស។

### ១.៤.១. បឋមសិក្សា

ការបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សាចាប់ផ្តើម ជាមួយនឹងការប្រមែប្រមូលគ្រូបង្រៀន និស្សិត និងបុគ្គលអប់រំ ដែលនៅសេសសល់ពីស្លាប់ ដើម្បីចូលរួមក្នុងវគ្គបណ្តុះ-បណ្តាលរយៈពេលខ្លីស្តីពីការអប់រំវិធីសាស្ត្របង្រៀន និងចិត្តវិទ្យា នៅតាមមជ្ឈមណ្ឌលគរុកោសល្យ[182] ទាំង១៨ នៅក្នុងខេត្ត-ក្រុងនានា។ ការបណ្តុះបណ្តារយៈពេលខ្លី ក៏ត្រូវបានរៀបចំសម្រាប់ថ្នាក់ដឹកនាំក្រសួងអប់រំនៅគ្រប់កម្រិត នៅសាលាគ្រប់គ្រងកម្មាភិបាលជាន់ខ្ពស់[183]។ នៅចន្លោះឆ្នាំ១៩៨០ និង១៩៨៤ ការបណ្តុះបណ្តាលគ្រូផ្តោតលើវគ្គសិក្សាខ្លីៗ[184] ប៉ុន្តែ ក៏មានវគ្គបណ្តុះបណ្តាលពី១ ទៅ ៣ខែ សម្រាប់គ្រូផងដែរ[185]។ ស្តង់ដារគ្រូបង្រៀនត្រូវបានបង្កើតឡើងសម្រាប់ការបណ្តុះបណ្តាលដំបូងដល់គ្រូមត្តេយ្យ និងគ្រូបឋមសិក្សា ចាប់តាំងពីឆ្នាំ១៩៨៣ មក ដោយការអនុវត្តរូបមន្ត ៧+១ ពោលគឺគ្រូបឋមសិក្សាត្រូវតម្រូវឱ្យមានការបណ្តុះបណ្តាលមួយឆ្នាំ បន្ទាប់ពីបញ្ចប់ការសិក្សានៅថ្នាក់ទី៧ [186] ។ សម្រាប់គ្រូបង្រៀននៅបឋមសិក្សា ប្រព័ន្ធពីរត្រូវបានអនុវត្តសម្រាប់គ្រប់ខេត្ត-ក្រុង គឺខេត្តក្រុងនៅតំបន់វាលរាប និងខេត្តដែលជួបការលំបាក។ សម្រាប់ខេត្តជួបការលំបាក គ្រូបង្រៀនថ្នាក់បឋមសិក្សា ត្រូវបានជ្រើសរើសពីក្នុងចំណោមសិស្សបញ្ចប់ការសិក្សានៅថ្នាក់ទី៥ សម្រាប់កម្មវិធីបណ្តុះបណ្តាលរយៈពេល ៣ ឆ្នាំ ក្នុងខណៈដែលខេត្តតំបន់វាលរាប គ្រូទាំងនោះត្រូវបានជ្រើសចេញពីសិស្ស ដែលប្រឡងធ្លាក់នៅថ្នាក់បញ្ចប់នៃកម្រិតមធ្យមសិក្សាបឋមភូមិ ហើយត្រូវទទួលការបណ្តុះបណ្តាលរយៈពេលមួយឆ្នាំ (ដូច្នេះ គេហៅថារូបមន្ត ៧+១)។ ចំពោះខេត្តជួបការលំបាក និងខេត្តដាច់ស្រយាល[187] បទដ្ឋានប្រើប្រាស់សម្រាប់ការជ្រើស-

[182] សាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្ត (MOEYS. Ibid. p.1.)។

[183] សាលាជាន់ខ្ពស់កម្មាភិបាលអប់រំ (Faculté de Pédagogie) បច្ចុប្បន្នជាវិទ្យាស្ថានជាតិអបរំ។

[184] ប្រវត្តិ និងស្ថិតិនៃការងារបណ្តុះបណ្តាល។ សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប។

[185] មុនរបបខ្មែរក្រហម គុណវុឌ្ឍិគ្រូបង្រៀនសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ គឺដំបូងឡើយត្រូវបានកំណត់ត្រឹមវិញ្ញាបនបត្រមធ្យមសិក្សាទុតិយភូមិ+១ (បណ្តុះបណ្តាល ១ ឆ្នាំ ដើម្បីក្លាយជាគ្រូបង្រៀន) បន្ទាប់មកក៏បានបង្កើនទៅដល់វិញ្ញាបនបត្រមធ្យមសិក្សាទុតិយភូមិ+២ វិញ។ ចំណែកឯគ្រូកម្រិតមធ្យមសិក្សាទុតិយភូមិវិញ គឺទាមទារឱ្យមានបរិញ្ញាបត្រ។

[186] រូបមន្ត៧+១ មានន័យថារៀនចប់ថ្នាក់ទី៧ បូកថែមការបណ្តុះបណ្តាលរយៈពេល ១ ឆ្នាំ។

[187] ខេត្តជួបការលំបាកមានចំនួន ៦ ៖ ខេត្តកោះកុង មណ្ឌលគិរី រតនៈគិរី ក្រចេះ ស្ទឹងត្រែង និងប៉ៃលិន។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រើសគ្រូបឋមគឺ ៣+១។ វិធីសាស្រ្តទាំងពីរនេះ បានបន្តអនុវត្តរហូតដល់ឆ្នាំ២០១៤ ដោយប្រើប្រាស់ស្តង់ដារូបមន្ត ១២+២ និង ៩+២។ វិធីសាស្រ្តចំនួនពីរដែលបានផ្លាស់ប្តូរនាប៉ុន្មានឆ្នាំកន្លងមក ដោយប្រើប្រាស់រូបមន្ត ១២+២ និង ៩+១ បានបន្តអនុវត្តរហូតដល់ឆ្នាំ ២០១៤។

*តារាងទី៤ ៖ ការចូលរៀននៅបឋមសិក្សាឆ្នាំ ១៩៦៨/៦៩–១៩៨៨/៨៩*

| ឆ្នាំសិក្សា | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ | សរុប |
|---|---|---|---|---|---|---|---|
| 1968/69 | 339 528 | 209,851 | 150 375 | 105 352 | 72 501 | 56 781 | 919 456 |
| 1979/80 | 824 009 | 90 708 | 20 150 | 12 450 | - | | 947 317 |
| 1980/81 | 886 873 | 336 842 | 84 774 | 19 564 | - | | 1 328 053 |
| 1981/82 | 832 476 | 424 147 | 208 147 | 74 068 | - | | 1 538 838 |
| 1982/83 | 782 840 | 408 886 | 256 347 | 149 008 | - | | 1 597 081 |
| 1983/84 | 384 153 | 367 580 | 281 581 | 214 458 | - | | 1 494 839 |
| 1984/85 | 309 384 | 287 728 | 274 346 | 250 578 | - | | 1 367 089 |
| 1985/86 | 272 710 | 238 508 | 224 262 | 246 986 | 118 400 | | 1 433 931 |
| 1986/87 | 399 983 | 262 342 | 218 241 | 199 138 | 214 523 | | 1 294 227 |
| 1987/88 | 451 133 | 269 139 | 204 062 | 174 553 | 180 166 | | 1 279 053 |
| 1988/89 | 506 608 | 293 016 | 204 966 | 158 577 | 150 522 | | 1 313 689 |

*ប្រភព ៖ UNDP, «Kampuchea Needs Assessment Study» , p. 148. នាយកដ្ឋានផែនការនៃក្រសួងអប់រំឆ្នាំ ១៩៨៩។* ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ សាលាបឋមសិក្សារួមមានថ្នាក់ទី១-៦ រួមបញ្ចូលជាមួយនឹងការបន្ថែម ៦ ឆ្នាំទៀតសម្រាប់ការនៅកម្រិតមធ្យមសិក្សា បូកមួយឆ្នាំបន្ថែមនៅកម្រិតបញ្ចប់ (ថ្នាក់បញ្ចប់) ។ ពីឆ្នាំ១៩៧៩/៨០ ដល់ឆ្នាំ ១៩៨៥/៨៦ កម្រិតបឋមសិក្សារួមមាន ថ្នាក់ទី១ ដល់ថ្នាក់ទី៤ ជាមួយនឹងថ្នាក់ទី៥-៧ នៅកម្រិតអនុវិទ្យាល័យ ថ្នាក់ទី៨-១០ នៅកម្រិតវិទ្យាល័យ។ នៅឆ្នាំ១៩៨៦/៨៧ មានការថែមឆ្នាំសិក្សាមួយឆ្នាំបន្ថែមទៀត សរុបចំនួន ១១ ឆ្នាំ នៅក្នុងការអប់រំចំណេះទូទៅ ៖ បឋមសិក្សា(ថ្នាក់ទី ១-៥) អនុវិទ្យាល័យ(ថ្នាក់ទី ៦-៨) និងវិទ្យាល័យថ្នាក់ទី៩-១១ ។

នៅចន្លោះឆ្នាំ១៩៨៦ និងឆ្នាំ១៩៩៦ ឆ្នាំសិក្សាត្រូវបានកើនឡើងដល់ ១១ ឆ្នាំ ហើយរចនាសម្ព័ន្ធសាលាសាធារណៈគឺយកតាមលំនាំ ៥-៣-៣ ដោយការអប់រំបឋមសិក្សាត្រូវបានកើនឡើងដល់ទៅ ៥ ឆ្នាំ។ រូបមន្តគុណវុឌ្ឍិ ៩+២ ត្រូវបានប្រើប្រាស់សម្រាប់ការបណ្តុះ-បណ្តាលគ្រូបង្រៀនបឋមសិក្សា នៅតាមខេត្តជួបការលំបាក ឬខេត្តដាច់ស្រយាល ចំណែកឯគ្រូបង្រៀននៅក្នុងខេត្តនៃតំបន់វាលរាបត្រូវបានជ្រើសរើសពីក្នុងចំណោមពួកអ្នកដែលប្រឡងធ្លាក់ថ្នាក់ទី១១ ហើយត្រូវទៅសិក្សារយៈពេល ២ ឆ្នាំ នៅមជ្ឈមណ្ឌលគរុកោសល្យខេត្ត។ តម្រូវការគុណវុឌ្ឍិសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិគឺថ្នាក់ទី ១១+២ ចំណែកឯគ្រូមធ្យមសិក្សាទុតិយភូមិវិញ គឺ ១១+៣ ។

ចាប់ពីឆ្នាំ១៩៩៦ មក ប្រព័ន្ធអប់រំ ១២ ឆ្នាំត្រូវបានអនុវត្ត ដើម្បីគោរពតាមស្តង់ដាអន្តរជាតិ។ រចនាសម្ព័ន្ធសាលារៀនស្របទៅតាមលំនាំ ៦-៣-៣ ។ សិស្សថ្នាក់ទី ១២ ត្រូវប្រឡងមធ្យមសិក្សាទុតិយភូមិ ដើម្បីទៅបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។ គុណវុឌ្ឍិដើម្បីក្លាយជាគ្រូបង្រៀននៅសាលាបឋមសិក្សា គឺថ្នាក់ទី ១២+២ (៩+២ សម្រាប់ខេត្តជួប



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការលំបាក និងខេត្តដាច់ស្រយាល) ចំណែកឯគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ត្រូវបានជ្រើសរើសពីក្នុងចំណោមសិស្សបញ្ចប់ការសិក្សាថ្នាក់ទី១២ បន្ទាប់មកត្រូវទទួលការបណ្តុះ-បណ្តាលរយៈពេល ២ ឆ្នាំ។

ក្រសួងអប់រំ យុវជន និងកីឡាក៏បានចូលរួមនៅក្នុងការកែលម្អគុណភាពអប់រំតាមរយៈកំណែទម្រង់នៃកម្មវិធីសិក្សា សៀវភៅសិក្សា និងវិធីសាស្ត្របង្រៀនផ្សេងៗជាច្រើន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្រៀន និងការរៀន។

## ១.៤.២. ការអប់រំនៅមធ្យមសិក្សាបឋមភូមិ

*តារាងទី៥ ៖ ការចូលរៀននៅមធ្យមសិក្សាបឋមភូមិឆ្នាំ១៩៦៨/៦៩–១៩៨៨/៨៩*

| ឆ្នាំសិក្សា | ថ្នាក់ទី៥ | ថ្នាក់ទី៦ | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ | | សរុប |
|---|---|---|---|---|---|---|---|
| 1968/69 | | | 23 285 | 22 003 | 18 323 | | 63 614 |
| 1979/80 | 3 200 | 1 137 | 466 | | | | 4 803 |
| 1980/81 | 11 847 | 3 882 | 1 622 | | | | 11 351 |
| 1981/82 | 24 727 | 11 092 | 3 696 | | | | 39 515 |
| 1982/83 | 51 900 | 23 923 | 11 180 | | | | 87 603 |
| 1983/84 | 74 005 | 48 808 | 22 913 | | | | 145 726 |
| 1984/85 | 110 565 | 78 870 | 45 492 | | | | 234 927 |
| 1985/86 | - | 101 657 | 77 717 | 5 616 | | | 184 990 |
| 1986/87 | - | 120 746 | 106 442 | 99 861 | | | 327 049 |
| 1987/88 | - | 113 022 | 105 792 | 107 589 | | | 326 403 |
| 1988/89 | - | 96 433 | 93 280 | 99 351 | | | 289 064 |

*ប្រភព ៖ UNDP, « Kampuchea Needs Assessment Study» , p. 148. នាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា ១៩៨៩។*

នៅឆ្នាំ ១៩៨៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៦ (រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តកំពង់ចាម និងខេត្តបាត់ដំបង) ត្រូវបានបង្កើតឡើងសម្រាប់ការបណ្តុះបណ្តាលគ្រូកម្រិតមធ្យមសិក្សាបឋមភូមិ ដោយប្រើរូបមន្ត ៧+៣ (បច្ចុប្បន្ននេះគឺជារូបមន្ត ១២+២)។ ដើម្បីក្លាយជាគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ បេក្ខជនដែលមានវិញ្ញាបនបត្របញ្ចប់ថ្នាក់ទី៧ (កម្រិតនៃការអប់រំមូលដ្ឋាន) ត្រូវបានជ្រើសរើស ដើម្បីទទួលបាននូវកម្មវិធីបណ្តុះបណ្តាល ៣ ឆ្នាំ (៧+៣) ។ ការបណ្តុះបណ្តាលបន្តសម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ ដើម្បីក្លាយជាគ្រូបង្រៀននៅវិទ្យាល័យត្រូវបានរៀបចំឡើងរយៈពេល ១ ខែកន្លះ រយៈពេលពីរឆ្នាំជាប់ៗគ្នា។

## ១.៤.៣. ការអប់រំនៅមធ្យមសិក្សាទុតិយភូមិ

ការបណ្តុះបណ្តាលគ្រូបង្រៀននៅវិទ្យាល័យ បានចាប់ផ្តើមក្នុងឆ្នាំ១៩៨០ នៅសាលាគរុវិជ្ជាជាន់ខ្ពស់ (ENS) បច្ចុប្បន្នជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)។ អតីត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រូបង្រៀនអនុវិទ្យាល័យទទួលការបណ្តុះបណ្តាលរយៈពេលខ្លី ដែលមានរយៈពេល ៤ ខែ ដើម្បីក្លាយទៅជាគ្រូបង្រៀននៅវិទ្យាល័យ។

*តារាងទី៦ ៖ ការចូលរៀននៅមធ្យមសិក្សាទុតិយភូមិឆ្នាំ១៩៦៨/៦៩–១៩៨៨/៨៩*

| ឆ្នាំសិក្សា | ថ្នាក់ទី៨ | ថ្នាក់ទី៩ | ថ្នាក់ទី១០ | ថ្នាក់ទី១១ | ថ្នាក់ទី១២ | ថ្នាក់បញ្ចប់ | សរុប |
|---|---|---|---|---|---|---|---|
| 1968/69 | | | 19 501 | 6 486 | 5 404 | 3 303 | 35 194 |
| 1979/80 | 120 | 92 | 69 | 12 450 | - | - | 281 |
| 1980/81 | 296 | 121 | 138 | | - | - | 555 |
| 1981/82 | 1 204 | 154 | 159 | | - | - | 1 514 |
| 1982/83 | 2 377 | 970 | 146 | | - | - | 3 493 |
| 1983/84 | 4 818 | 1 939 | 882 | | - | - | 7 639 |
| 1984/85 | 5 272 | 4 058 | 1 558 | | - | - | 10 888 |
| 1985/86 | | 4 698 | 3 706 | | - | - | 8 404 |
| 1986/87 | | 8 454 | 5 565 | 4 780 | - | - | 18 799 |
| 1987/88 | | 12 378 | 8 113 | 5 685 | - | - | 26 176 |
| 1988/89 | | 15 200 | 11 828 | 8 097 | - | - | 35 125 |

*ប្រភព ៖ UNDP, «Kampuchea Needs Assessment Study» , p.148. នាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា ១៩៨៩។*

ក្រោយមកទៀត ស្តង់ដាគ្រូមធ្យមសិក្សាទុតិយភូមិត្រូវបានបង្កើតឡើងដោយប្រើរូបមន្ត ១០+៣។ រូបមន្តនេះត្រូវបានកែលម្អបន្ថែមទៀត ដោយអនុវត្តរូបមន្ត ១០+៤ ។ នៅក្នុងឆ្នាំ១៩៩៥ សម្រាប់គ្រូមធ្យមសិក្សាទុតិយភូមិ តម្រូវការនៃគុណវុឌ្ឍិបានកើនឡើងដល់ទៅ ១២+៤។ តារាងទី៦ បង្ហាញពីការចុះឈ្មោះចូលរៀននៅវិទ្យាល័យពីឆ្នាំ ១៩៦៨/៦៩-១៩៨៨/៨៩ ។

ចាប់ពីឆ្នាំ១៩៨៦ មក ប្រព័ន្ធពីរត្រូវបានអនុវត្ត។ ប្រព័ន្ធទាំងពីរនោះ គឺរូបមន្ត ១២+៤ ឬបរិញ្ញាបត្រ+១។ នាពេលបច្ចុប្បន្ននេះ ការបណ្តុះបណ្តាលគ្រូវិទ្យាល័យត្រូវបានធ្វើឡើងនៅវិទ្យាស្ថានជាតិអប់រំ (NIE) ដោយប្រើរូបមន្តសញ្ញាបត្របរិញ្ញាបត្របូក ១ ។

*តារាងទី៧ ៖ ចំនួនសាលារៀនឆ្នាំ១៩៦៩ –១៩៨៩*

| ឆ្នាំសិក្សា | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | មធ្យមសិក្សាទុតិយភូមិ | សរុប |
|---|---|---|---|---|
| 1968/69 | 4 857 | | 179 | 5 026 |
| 1979/80 | 4 000 | 14 | 1 | 4 015 |
| 1980/81 | 4 000 | 62 | 2 | 4 064 |
| 1981/82 | 3 521 | 96 | 5 | 3 622 |
| 1982/83 | 3 114 | 173 | 7 | 3 294 |
| 1983/84 | 3 005 | 200 | 13 | 3 218 |
| 1984/85 | 3 113 | 222 | 19 | 3 374 |
| 1985/86 | 4 294 | 278 | 28 | 4 600 |
| 1986/97 | 4 282 | 304 | 33 | 4 619 |
| 1987/88 | 4 780 | 337 | 40 | 5 157 |
| 1988/89 | 4 730 | 373 | 49 | 5 152 |

*ប្រភព ៖ UNDP (1989), «Kampuchea Needs Assessment Study» , p.148. នាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា ១៩៨៩។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចការអប់រំនៅកម្រិតមុនៗដែរ ក្រសួងអប់រំ យុវជន និងកីឡាក៏បានចូលរួមនៅក្នុងការកែលម្អគុណភាពអប់រំតាមរយៈកំណែទម្រង់ប្រព័ន្ធអប់រំក្នុងប្រព័ន្ធ កម្មវិធីសិក្សា សៀវភៅសិក្សា និងវិធីសាស្ត្របង្រៀន និងរៀន។

នៅចន្លោះឆ្នាំ ១៩៨៦ និងឆ្នាំ ១៩៩៦ ឆ្នាំសិក្សាត្រូវបានកើនឡើងដល់ ១១ ឆ្នាំ ហើយរចនាសម្ព័ន្ធសាលាសាធារណៈ គឺយកតាមលំនាំ ៥-៣-៣ ដោយការអប់រំបឋមសិក្សាត្រូវបានកើនឡើងដល់ទៅ ៥ ឆ្នាំ។ រូបមន្តគុណវុឌ្ឍិ ៩ + ២ ត្រូវបានប្រើប្រាស់សម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀនបឋមសិក្សានៅតាមខេត្តជួបការលំបាក ឬខេត្តដាច់ស្រយាល ចំណែកឯគ្រូបង្រៀននៅក្នុងខេត្តនៃតំបន់វាលរាប ត្រូវបានជ្រើសរើសពីក្នុងចំណោមពួកអ្នកដែលប្រឡងធ្លាក់ថ្នាក់ទី១១ ហើយត្រូវទៅសិក្សារយៈពេល ២ ឆ្នាំ នៅមជ្ឈមណ្ឌលគរុកោសល្យខេត្ត។ គុណវុឌ្ឍិគ្រូមធ្យមសិក្សាបឋមភូមិត្រូវបានកំណត់ត្រឹមថ្នាក់ទី ១១ + ២ ចំណែកឯគ្រូមធ្យមសិក្សាទុតិយភូមិវិញ គឺ ១១ + ៣ ។

*តារាងទី៨ ៖ បុគ្គលិកអប់រំឆ្នាំ១៩៦៩ –១៩៨៩*

| ឆ្នាំសិក្សា | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | មធ្យមសិក្សាទុតិយភូមិ | សរុប |
|---|---|---|---|---|
| 1968/69 | 21 313 | | 4491 | 26 804 |
| 1979/80 | 13 619 | 205 | 20 | 13 844 |
| 1980/81 | 30 316 | 671 | 28 | 31 015 |
| 1981/82 | 31 884 | 1 568 | 65 | 33 535 |
| 1982/83 | 32 859 | 3 300 | 158 | 36 317 |
| 1983/84 | 33 479 | 4 494 | 271 | 38 244 |
| 1984/85 | 35 878 | 6 116 | 468 | 42 462 |
| 1985/86 | 35 080 | 7 416 | 617 | 43 113 |
| 1986/97 | 36 754 | 8 967 | 858 | 95 801 |
| 1987/88 | 37 292 | 10 866 | 1 064 | 49 222 |
| 1988/89 | 36 930 | 11 702 | 1 403 | 50 035 |

*ប្រភព ៖ UNDP (1989), «Kampuchea Needs Assessment Study» , p.148. នាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា ១៩៨៩។*

ខាងលើនេះជាតារាងចំនួនពីរបង្ហាញអំពីបុគ្គលិកអប់រំនៅឆ្នាំ១៩៧៩/៨៩ និងចំនួននៃសាលារៀនពីឆ្នាំ១៩៧៩/៨៩ ។

គ្រូឧទ្ទេស និងគ្រូបង្គោលទទួលការបណ្ដុះបណ្ដាលរយៈពេល ៤ ឆ្នាំ នៅសាលាកម្មាភិបាលជាន់ខ្ពស់គ្រប់គ្រងអប់រំនៅទីក្រុងភ្នំពេញ។ ចាប់តាំងពីឆ្នាំ១៩៩៦ មក ប្រព័ន្ធអប់រំរយៈពេល ១២ ឆ្នាំត្រូវបានអនុវត្ត ដើម្បីបន្សុីទៅតាមបទដ្ឋានអន្តរជាតិ ហើយរចនាសម្ពន្ធសាលាធ្វើទៅតាមលំនាំ ៦-៣-៣។ សិស្សថ្នាក់ទី១២ ត្រូវប្រឡងយកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីឈានទៅបន្តការសិក្សានៅឧត្តមសិក្សា។ នាសម័យនោះ គុណវុឌ្ឍិចាំបាច់ដើម្បីក្លាយជាគ្រូបង្រៀននៅកម្រិតបឋមសិក្សា គឺជាសិស្សដែលធ្លាក់ថ្នាក់ទី១២



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយប្រើប្រាស់រូបមន្ត ១២+២ (៩+២ សម្រាប់ខេត្តជួបការលំបាក ចំណែកឯគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ គឺត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយត្រូវទទួលការបណ្តុះបណ្តាលរយៈពេល ២ ឆ្នាំ។ សម្រាប់គ្រូវិទ្យាល័យវិញនោះ តម្រូវគុណវុឌ្ឍិត្រូវបានបង្កើនដល់ទៅ ១២+៤ នាឆ្នាំ១៩៩៥ ខណៈចាប់ពីឆ្នាំ១៩៩៦ មក ប្រព័ន្ធទាំងពីរត្រូវបានអនុវត្ត ៖ ទាំងរូបមន្ត ១២+៤ ឬ បរិញ្ញាបត្រ+ ១។ គ្រូឧទ្ទេស និងគ្រូបង្គោលទទួលការបណ្តុះ-បណ្តាលរយៈពេល ៤ ឆ្នាំ នៅសាលាកម្មាភិបាលជាន់ខ្ពស់គ្រប់គ្រងអប់រំ នៅទីក្រុងភ្នំពេញ។

## ១.៤.៤. យុទ្ធនាការរំដោះឱ្យផុតពីគ្រោះមិនចេះអក្សរ

ចលនាប្រយុទ្ធនឹងគ្រោះមិនចេះអក្សរបានចាប់ផ្តើមឡើង នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៨០។ នៅឆ្នាំ១៩៨០ ក្រសួងអប់រំបានរៀបចំថ្នាក់អប់រំអក្ខរកម្មចំនួន ១ ៣៦៥ ថ្នាក់ ដោយប្រើប្រាស់គ្រូស្ម័គ្រចិត្តចំនួន ១ ៥១៦ នាក់ និងមានសិស្សចំនួន ៦១ ២៤២ នាក់[188]។ នាយកដ្ឋានអប់រំមនុស្សចាស់ត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ការអប់រំបំពេញវិជ្ជា និងការអប់រំក្រៅផ្លូវការ។ មជ្ឈមណ្ឌលកម្មវិធីសិក្សា និងសៀវភៅសិក្សាត្រូវបានបង្កើតឡើង ក្នុងគោលបំណងរៀបចំ និងបោះពុម្ពផ្សាយសៀវភៅសម្រាប់បង្រៀនមនុស្សចាស់ និងសៀវភៅគោលសិក្សាដទៃទៀត។

នៅក្នុងឆ្នាំ១៩៨២ ក្រសួងអប់រំបានបង្កើតគណៈកម្មការអចិន្ត្រៃយ៍ទទួលបន្ទុកយុទ្ធនាការអក្ខរកម្មជាតិ ដើម្បីវាយតម្លៃការងារក្នុងរយៈពេលបីឆ្នាំកន្លងទៅ។ តាមរបាយ-ការណ៍របស់គណៈកម្មការនេះ ប្រជាជនកម្ពុជាប្រមាណ ១ លាននាក់មិនចេះអក្សរ ហើយអនក្ខរជនចំនួន ៧២,៥%បានចូលរួមក្នុងយុទ្ធនាការនេះ។ នៅក្នុងរយៈពេលនៃយុទ្ធនាការនេះ ប្រជាជនប្រមាណជិត ២ សែននាក់បានរំដោះខ្លួនឱ្យចេញផុតពីគ្រោះមិនចេះអក្សរ។ យុទ្ធនាការលើកទី២ សម្រាប់រយៈពេល ៣ ឆ្នាំ បានចាប់ផ្តើមឡើងនៅក្នុងខែមករា ឆ្នាំ

188 Margaret Slocomb (2003) The People's Republic of Kampuchea, 1979-1989: The Revolution after Pol Pot. Silkworm Books, Bangkok, p. 168.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៩៨៤ ហើយមានគោលដៅរំដោះមនុស្សប្រមាណជា ៤ សែននាក់ ឱ្យរួចផុតពីគ្រោះមិនចេះអក្សរ។

ក្នុងគោលដៅលើកទឹកចិត្តឱ្យយុវជន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ដែលគ្មានឱកាសចូលសិក្សាវិញអាចបន្តការសិក្សាឱ្យបានចប់មធ្យមសិក្សា ក្រសួងអប់រំបានបង្កើតសាលាបំពេញវិជ្ជាឡើង នៅក្នុងខែមីនា ឆ្នាំ១៩៨០ ដើម្បីលើកទឹកចិត្តឱ្យអ្នកដែលមានអាយុលើស អាចរៀនចប់មធ្យមសិក្សា និងប្រឡងយកសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិបាន។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ សាលាបំពេញវិជ្ជាចំនួន១៤ ត្រូវបានបង្កើតឡើងនៅក្នុងខេត្ត-ក្រុងចំនួន១១ ដើម្បីឱ្យសិស្សចំនួនជិត ៣ សែននាក់បានចូលរៀន។

## ១.៩.៤. ការអប់រំនៅឧត្តមសិក្សា

សាធារណរដ្ឋប្រជាមានិតកម្ពុជាបានបំពេញភារកិច្ចយ៉ាងធ្ងន់ធ្ងរក្នុងការស្តារ និងកសាងប្រព័ន្ធអប់រំឧត្តមសិក្សានៅកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ សាលាគរុកោសល្យមជ្ឈិមត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៩ ដើម្បីបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រីអប់រំជាន់ខ្ពស់ ចំណែកឯសាលាគរុវិជ្ជាជាន់ខ្ពស់[189] (វិទ្យាស្ថានជាតិគរុកោសល្យ) ត្រូវបានបង្កើតឡើងវិញនៅឆ្នាំ១៩៨១ ដែលមានតួនាទីបណ្តុះបណ្តាលគ្រូបង្រៀន[190]។

ដោយសារតែសាស្ត្រាចារ្យមហាវិទ្យាល័យកម្ពុជាស្ទើរតែទាំងអស់ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម កម្ពុជានាសម័យនោះបានអញ្ជើញសាស្ត្រាចារ្យពីប្រទេសវៀតណាម និងអតីតសហភាពសូវៀត ដើម្បីបង្រៀននៅកម្រិតឧត្តមសិក្សា។ ចាប់ពីឆ្នាំ១៩៨១ មកសាស្ត្រាចារ្យសូវៀតត្រូវបានអញ្ជើញឱ្យទៅបង្រៀននៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(ITC) ចំណែកឯសាស្ត្រាចារ្យវៀតណាមវិញបានបំពេញកិច្ចការរបស់ខ្លួន នៅវិទ្យាស្ថានជាតិសេដ្ឋកិច្ច(បច្ចុប្បន្នជាសាកលវិទ្យាល័យជាតិគ្រប់គ្រង)។ ការស្តារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនឡើងវិញ គឺជាតម្រូវការចាំបាច់ដំបូង ក្នុងការពង្រីកវិសាលភាពនៃប្រព័ន្ធអប់រំកម្ពុជា ក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ។

---

189 សាលាគរុវិជ្ជាជាន់ខ្ពស់ (ENS) ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៨០ តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ លោក ចាន់ វ៉ែន សូមមើល សាកលវិទ្យាល័យភូមិន្ទភ្នំពេញ-ប្រវត្តិសាកលវិទ្យាល័យភូមិន្ទភ្នំពេញ,១៩៦០-២០១៥, ទំព័រ ៥៨។

190 ការបណ្តុះបណ្តាលធ្វើឡើងជាដំបូងជាភាសាបារាំង សូមមើល សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ទំព័រ១៤។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៤.៦. សង្គ្រាមអក្សរសាស្ត្រ

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ក្រសួងអប់រំបានសម្រេចប្រើទម្រង់សំណេរពាក្យ តាមគោលការណ៍ខេមរយានកម្ម។ នៅឆ្នាំ១៩៨៥ ក្រសួងអប់រំបានបោះផ្សាយសៀវភៅមួយក្រោមចំណងជើងថា ៖ «បញ្ហាទំនាញសូរក្នុងសំណេរ ៖ ពាក្យមួយចំនួនដែលអាចសរសេរបានពីរយ៉ាង»។ ការអនុវត្តគោលការណ៍ទំនាញសូរនេះ គឺជាការបោះជំហានទៅមុខមួយជំហានទៅមុខទៀត ពីគោលការណ៍បង្កើតពាក្យថ្មីនៃខេមរយានកម្ម។ នៅដំណាក់កាលខេមរយានកម្ម គណៈកម្មការបានអនុម័តគោលការណ៍បញ្ចូលពាក្យវែង ឬឃ្លា ឱ្យមកក្លាយជាពាក្យដុំ តាមកម្លាយរបស់ក្បួនកម្លាយភាសាខ្មែរ ដូចជា ការកើត ទៅជាកំណើតការ ថែទាំ ទៅជាតំហែទាំ ការទទួលខុសត្រូវ ទៅជាទំនួលខុសត្រូវ។ ការអនុម័តលើគោល-ការណ៍ទំនាញសូរ ជាពិសេសការអនុម័តលើពាក្យដែលអាចសរសេរបានពីរយ៉ាង បានធ្វើឱ្យសង្គ្រាមអក្សរសាស្ត្រផ្ទុះឡើងរវាងលោក **វ៉ាន់ឌី កាអុន** ដែលជាសមាជិកក្រុមប្រឹក្សារដ្ឋនិងជានាយកវិទ្យាស្ថានសង្គមវិទ្យា ដែលប្រកាន់យកការសរសេរភាសាខ្មែរតាមវចនានុ-ក្រមខ្មែររបស់សម្ដេចសង្ឃ **ជួន ណាត** ជាមួយនឹងក្រុមអ្នកអក្សរសាស្ត្រនៃក្រសួងអប់រំយុវជន និងកីឡា ដែលប្រកាន់យកការសរសេរភាសាខ្មែរតាមខេមរយានកម្ម និងតាមបែបទំនាញសូរ។ ឧទាហរណ៍ កំណក អាចសរសេរជា កំនក អំណាច អាចសរសេរជា អំនាច។ ម្យ៉ាងវិញទៀត ពាក្យព្យាង្គតម្រួតខ្លះត្រូវបានសរសេរជាព្យាង្គរាយវិញ ដូចជា ៖ កម្លា អាចសរសេរជា កំលា ចម្លង អាចសរសេរជា ចំលង ។ល។ និងការដូរពីអក្សរ «ឡ» ទៅសរសេរជាអក្សរ «ល» វិញដូចជា ក្រឡោត អាចសរសេរជា ក្រលោត។

នៅក្នុងឆ្នាំ១៩៨៥ សង្គ្រាមអក្សរសាស្ត្រនេះត្រូវបានយកមកពិភាក្សា ក្នុងរបៀបវារៈនៃការប្រជុំការិយាល័យនយោបាយនៃគណបក្សប្រជាជនកម្ពុជា និងការពិភាក្សាក្នុងរដ្ឋសភាជាតិនៅពេលនោះ។ ក្រុមប្រឹក្សារដ្ឋបានសម្រេចក្នុងសម័យប្រជុំថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨៥ លើបីចំណុច ដើម្បីដោះស្រាយចំពោះមុខ ៖

ទី១-អនុវត្តតាមក្បួនរបៀបចាស់ និងរក្សាការសរសេរក្នុង ៦ ឆ្នាំកន្លងមក។

ទី២-ធ្វើតារាងស្ដីពីពាក្យដែលបានប្រើក្នុង ៦ ឆ្នាំកន្លងមក និងពាក្យគូ ដែលធ្លាប់ប្រើតាមរបៀបទម្លាប់ចាស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទី៣-ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវព្រាងសមាសភាពគណៈកម្មាធិការជាតិមួយស្តីពីការ-ប្រើប្រាស់អក្សរខ្មែរ[191]។

ក្រសួងអប់រំក៏បានរៀបចំប្រជុំអន្តរក្រសួងមួយ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៨៥ ដើម្បីត្រៀមរៀបចំការរៀន និងបង្រៀនជាភាសាខ្មែរ នៅឧត្តមសិក្សា និងសិក្សាបច្ចេកទេស ហើយអង្គប្រជុំបានដាក់ចេញជាគោលការណ៍រួមដូចតទៅ ៖

ទី១-បន្តស្នាដៃខេមរយានកម្មតទៅទៀត

ទី២-យកភាសាបារាំងជាគោល ក្នុងការពិគ្រោះ និងបកប្រែពាក្យ (សួរបារាំង)

ទី៣-ខិតខំស្រាវជ្រាវ ប្រើពាក្យខ្មែរសុទ្ធ ទាំងសំណោរ និងសំណួរ

ទី៤-បើរកពាក្យខ្មែរសុទ្ធមិនបាន ទើបរកពាក្យខ្មែរបុរាណ ពាក្យបាលី សំស្ក្រឹត ឬបរទេសផ្សេងៗ

ទី៥-ពាក្យដែលស៊ីជម្រៅទៅក្នុងស្រទាប់មហាជនរួចហើយ មិនត្រូវបង្កើតទៀតទេ

ទី៦-ក្នុងការបង្កើតពាក្យ ត្រូវអនុវត្តតាមវិធីផ្នួលពាក្យតាមឫសរបស់ពាក្យ

ទី៧-ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដោយក្រសួងអប់រំ

ទី៨-បង្កើតគណៈកម្មការទូលំទូលាយមួយ ដើម្បីឱ្យមានការឯកភាពក្នុងការបង្កើត និងប្រើប្រាស់ទូទាំងប្រទេស

ទី៩-ចំពោះវិទ្យាសាស្ត្រសង្គម ត្រូវអនុវត្តតាមគោលការណ៍ខាងលើ តែត្រូវឱ្យអាទិភាពទៅលើពាក្យខ្មែរសុទ្ធ

ទី១០-ចំពោះវិទ្យាសាស្ត្រពិត ត្រូវអនុវត្តតាមគោលការណ៍រួមដែរ តែត្រូវឱ្យអាទិភាពទៅលើពាក្យអន្តរជាតិ ដែលធ្លាប់ប្រើប្រាស់កន្លងមកហើយ ឬក៏សម្របសម្រួលតាមលក្ខណៈខ្មែរ ដោយរក្សាពាក្យដើម ងាយស្រួលទាក់ទងអន្តរជាតិផង។

បញ្ហាជម្លោះអក្សរសាស្ត្រនេះនៅតែបន្តរហូតដល់ឆ្នាំ២០០០។ នៅក្នុងឱកាសបិទសន្និសីទជាតិស្តីពីការស្រាវជ្រាវឯកភាព និងអភិវឌ្ឍភាសាខ្មែរ នៅរាជបណ្ឌិត្យសភាកម្ពុជា នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០០០ ឯកឧត្តម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទីបានមានប្រសាសន៍ថា ៖ «ដើម្បីសម្រេចបាននូវការឯកភាពភាសាជាតិខ្មែរយើង ពីលើវេទិកានៃអង្គសន្និសីទ

[191] ក្រសួងអប់រំ (១៩៨៥) កំណត់ហេតុស្តីពីសម័យប្រជុំអន្តរក្រសួងនៅវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ ថ្ងៃទី១៩ ខែមេសា ១៩៨៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវឱ្យជនរួមជាតិខ្មែរទាំងអស់ ទាំងក្នុងប្រទេស ទាំងបងប្អូនជនរួមជាតិខ្មែរដែលកំពុងតែរស់នៅឯបរទេស នៅពេលសរសេរអក្សរខ្មែរ ត្រូវគោរពប្រតិបត្តិតាមក្បួនច្បាប់នៃការសរសេរ និងអក្ខរាវិរុទ្ធទាំងឡាយនៅក្នុងវចនានុក្រមខ្មែរ និពន្ធ និងចងក្រងឡើងដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត** ដែលជនរួមជាតិខ្មែរគ្រប់គ្រប់គ្នាទទួលស្គាល់ថា ព្រះអង្គជាអ្នកប្រាជ្ញភាសាអក្សរសាស្ត្រខ្មែរនាស.វ.ទី២០។ ខ្ញុំគិតថា វចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ជាច្បាប់ ដែលយើងត្រូវប្រតិបត្តិតាមក្នុងការសរសេរអក្សរខ្មែរ។ ការដែលត្រូវសរសេរតាមវចនានុក្រមនេះ យើងទាំងអស់គ្នាត្រូវតែធ្វើឡើង ដោយគោរពដល់វិន័យនៃការសរសេរអក្សរសាស្ត្រជាតិ។ វិន័យនេះមានសារៈសំខាន់យ៉ាងក្រៃលែង ដល់ការស្រាវជ្រាវឯកសារ និងអភិវឌ្ឍន៍ភាសាខ្មែរ»។ ជម្លោះអក្សរសាស្ត្រនេះត្រូវបានបញ្ចប់ត្រឹមនេះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី ២
# របៀបវារៈថ្មីស្តីពីគោលនយោបាយសង្គមកិច្ច សម្រាប់វិស័យអប់រំ

## ២.១. កម្មវិធីសកម្មភាពជាអាទិភាពក្នុងវិស័យអប់រំ ដើម្បីលើកកម្ពស់សកលកម្មការអប់រំបឋមសិក្សា

វិស័យអប់រំនៅកម្ពុជាមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ដែលឆ្លុះបញ្ចាំងអំពីការខិតខំប្រឹងប្រែងកសាងប្រព័ន្ធអប់រំមួយឡើងវិញ បន្ទាប់ពីត្រូវបានបំផ្លាញខ្ទេចខ្ទីក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីការចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ ការបង្កើតឡើងវិញនៃព្រះរាជាណាចក្រកម្ពុជាទី២ នៅឆ្នាំ១៩៩៣ ត្រូវបានរំខានដោយភាគីខ្មែរក្រហមដែលបានធ្វើពហិការ ដោយមិនបានចូលរួមក្នុងដំណើរការរៀបចំការបោះឆ្នោតក្នុងឆ្នាំ១៩៩៣ និងក្នុងដំណើរការកសាងសន្តិភាពនៅក្នុងប្រទេសកម្ពុជា។

ក្នុងអំឡុងឆ្នាំ១៩៩៣-១៩៩៤ វិស័យអប់រំបានក្លាយជាវិស័យអាទិភាពមួយ។ ចាប់ពីពេលនោះមក ក្រសួងអប់រំបានទទួលការជួយជ្រោមជ្រែងពីសំណាក់ភ្នាក់ងារអន្តរជាតិជាច្រើនដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក អង្គការអន្តរជាតិ កម្មវិធីសហប្រតិបត្តិការទ្វេភាគីជាច្រើន រួមទាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផងដែរ។

### ២.១.១. កំណែទម្រង់ថវិកាអប់រំតាមរយៈ កម្មវិធីសកម្មភាពជាអាទិភាព

បន្ទាប់ពីកម្ពុជាសម្រេចបានឡើងវិញនូវសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨ បន្ទាប់ពីកម្លាំងសេសសល់របស់ខ្មែរក្រហមបានធ្វើសមាហរណកម្ម ទៅក្នុងរាជរដ្ឋាភិបាល បន្ទាប់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រ «ឈ្នះ-ឈ្នះ» សកម្មភាពជាបន្តបន្ទាប់ជាច្រើនត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ១៩៩៩ ដូចជាការបង្កើនចំណាយសាធារណៈ ដើម្បីកាត់បន្ថយភាពក្រីក្រ ការកាត់បន្ថយចំណាយលើកិច្ចការការពារជាតិនិងសន្តិសុខ និងការដាក់ឱ្យអនុវត្ត «**កម្មវិធីសកម្មភាពជាអាទិភាព**» ដើម្បីបង្កើនការផ្តល់ថវិកាដល់វិស័យអាទិភាព រួមបញ្ចូលទាំងការធ្វើសនិទានកម្មរវាងចំណាយលើវិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ចផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមក្នុងសេចក្តីថ្លែងការណ៍ទីក្រុងដាក្កា ដោយគាំទ្រដល់ការអនុវត្តគោលដៅនៃ**ការអប់រំសម្រាប់ទាំងអស់គ្នា**។ ការអប់រំសម្រាប់ទាំងអស់គ្នា គឺជាត្រីវិស័យមួយសម្រាប់តម្រង់គោលនយោបាយអប់រំនាពេលបច្ចុប្បន្ន និងជាវេទិកាមួយសម្រាប់ប្រមូលផ្តុំរាល់សកម្មភាពអប់រំទាំងអស់ ឱ្យស្ថិតនៅក្រោមដំបូលតែមួយ។ ក្នុងឆ្នាំ២០០០ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តបង្កើនការវិនិយោគលើវិស័យអប់រំ ឱ្យស្របនឹងចរន្តពិភពលោកស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា។

វិធានការជាច្រើនបានអនុវត្តឡើង ដើម្បីបង្កើនចំណាយលើការកាត់បន្ថយភាពក្រីក្រ រួមបញ្ចូលទាំងការធ្វើសនិទានកម្មចំណាយលើវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច និងកាត់បន្ថយចំណាយការពារជាតិនិងសន្តិសុខ តាមរយៈការអនុវត្ត«**កម្មវិធីសកម្មភាពជាអាទិភាព**» (PAP) ដើម្បីបង្កើនការបើកផ្តល់ថវិកាដល់វិស័យអាទិភាព។ ថ្វីបើយើងអាចមើលឃើញពីវឌ្ឍនភាពក្នុងការតម្រែតម្រង់ចំណាយរបស់រាជរដ្ឋាភិបាលពីវិស័យការពារជាតិ និងសន្តិសុខក៏ដោយ ក៏វិស័យសង្គមកិច្ចមិនទាន់ទទួលបាននូវអាទិភាពពេញលេញនៅឡើយ ដូចជាការគ្រប់គ្រងសាច់ប្រាក់ និងប្រតិបត្តិការរបស់រតនាគារនៅថ្នាក់ជាតិ និងរាជធានី ខេត្តមិនទាន់មានប្រសិទ្ធភាព។ បន្ថែមពីនេះទៀត ចំណាយក្នុងឆ្នាំ២០០០ និង២០០១ ដែលត្រូវបានប្រើប្រាស់ដោះស្រាយបញ្ហាទឹកជំនន់ និងការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ បានបន្តជាឧបសគ្គ ក្នុងការអនុវត្តថវិកាក្នុងឆ្នាំ២០០១។

កម្ពុជាបានចាប់ផ្តើមធ្វើសនិទានកម្មចំណាយយ៉ាងហ្មត់ចត់។ ចំណុចសំខាន់នៃគោលនយោបាយនេះ គឺត្រូវអនុវត្ត **របៀបវារៈថ្មីស្តីពីគោលនយោបាយសង្គមកិច្ច** នៅកម្ពុជា។ គោលគំនិតនៃរបៀបវារៈនេះគឺ កំណើនត្រូវតែដើរលើមាគ៌ាជួយជនក្រីក្រ។ អនុវត្តតាមរបៀបវារៈនេះ រាជរដ្ឋាភិបាលបានបង្កើនការបែងចែកថវិកាដល់វិស័យអាទិភាព ដូចជាវិស័យអប់រំ សុខាភិបាល កសិកម្ម និងការអភិវឌ្ឍជនបទ ដែលជាមូលដ្ឋានគ្រឹះសម្រាប់កំណើននាពេលអនាគត សមធម៌ និងការរីកចម្រើន។ រាជរដ្ឋាភិបាលបន្តធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ និងកៀរគរធនធាន ក្នុងការកសាងធនធានមនុស្សកម្ពុជា ឱ្យកាន់តែមានផលិតភាព និងពោរពេញដោយភាពប្រកួតប្រជែងក្នុងសេដ្ឋកិច្ចសកល។ របៀបវារៈនៃគោលនយោបាយថ្មីនេះមានចក្ខុវិស័យបង្កើតនូវ **សង្គមកម្ពុជាមួយដែលមានសាមគ្គីភាព មានចំណេះដឹងជ្រៅជ្រះ និងមានវប្បធម៌រស់រវើក**។ កត្តានេះទាមទារឱ្យមានការដោះស្រាយបញ្ហាភាពក្រីក្រ អនក្ខរភាព និងភាពអសកម្មទាំងឡាយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វត្ថុបំណងសំខាន់នៃការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព គឺរក្សាបាននូវការផ្ទេរធនធាន ពីវិស័យការពារជាតិនិងសន្តិសុខ មកឱ្យវិស័យអាទិភាព ជាពិសេសវិស័យអប់រំ និងសុខាភិបាល។ ជាផ្នែកមួយនៃការអនុវត្តគោលនយោបាយនេះ ថវិកាសម្រាប់វិស័យការពារជាតិ និងសន្តិសុខបានថយចុះពី ៣,០៣% នៃផលិតផលសរុបក្នុងស្រុក(ផសស) ក្នុងឆ្នាំ២០០១ មកនៅត្រឹម ២,៦៤% ក្នុងឆ្នាំ២០០៣។ ថវិកាសម្រាប់វិស័យការពារជាតិនិងសន្តិសុខបានកើនឡើងពី ២,៣៤%នៃផសស ក្នុងឆ្នាំ២០១១ ដល់ ២,៥៩%ក្នុងឆ្នាំ២០១២។ ក្នុងឆ្នាំ២០១៣ ថវិកានេះក៏រំពឹងថាកើនដល់ ២,៦%ផងដែរ។ ទោះជាយ៉ាងណា ការព្យាករណ៍បានបង្ហាញថា ថវិកាសម្រាប់វិស័យការពារជាតិនិងសន្តិសុខនឹងថយចុះពី ២៤,១%នៃថវិកាចរន្តក្នុងឆ្នាំ២០១០ មកនៅត្រឹម ២០,៨%ក្នុងឆ្នាំ២០១៨។ ចំណាយលើ វិស័យសង្គមកិច្ចនឹងបន្តកើនឡើង។ មួយផ្នែកធំនៃការកើនឡើងនេះនឹងត្រូវយកទៅបង្កើនថវិកាសម្រាប់វិស័យសុខាភិបាល និងអប់រំ។ ជាក់ស្តែង ថវិកាសម្រាប់វិស័យអប់រំបានកើនឡើងពី ១៤,៥%នៃថវិកាចរន្ត ក្នុងឆ្នាំ២០១០ ដល់១៦,២% ក្នុងឆ្នាំ២០១៤។

ដើម្បីកែលម្អការបើកផ្តល់ថវិកា និងការអនុវត្តថវិកា រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការមួយចំនួន ដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការរៀបចំកម្មវិធីនានា នៅមុនឆ្នាំនៃការអនុវត្តថវិកា និងអនុញ្ញាតឱ្យមានការបើកផ្តល់ប្រាក់ដោយស្វ័យប្រវត្តិក្នុងអំឡុងឆ្នាំអនុវត្ត។ ការបញ្ចេញសាច់ប្រាក់របស់កម្មវិធីសកម្មភាពអាទិ-ភាពជុំទី៣ គឺអាស្រ័យនឹងការទូទាត់ចំណាយរបស់ជុំទី១ ដែលកត្តានេះធ្វើឱ្យក្រសួងពាក់ព័ន្ធមានពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើរបាយការណ៍។ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវវិធានការបន្ទាន់មួយចំនួន ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ។ យន្តការនានារបស់កម្មវិធីសកម្មភាពជាអាទិភាពត្រូវបានរៀបចំឡើង ដើម្បីបង្ហូរសាច់ប្រាក់ឱ្យដល់សាលារៀន ដែលនឹងដោះស្រាយបាននូវភាពរឹងកំព្រឹស ភាពយឺតយ៉ាវ និងការបាត់បង់ក្នុងអំឡុងពេលនៃការអនុវត្តថវិកានៅកម្រិតរដ្ឋបាលថ្នាក់រាជធានី ខេត្ត។

កម្មវិធីសកម្មភាពជាអាទិភាពមានគោលបំណងធានាថា សកម្មភាពជាក់លាក់ទាំងឡាយនឹងទទួលបាននូវការវិភាគថវិកាពេញលេញ តាមរយៈការលុបបំបាត់ការប្រើ-ប្រាស់ប្រព័ន្ធបែងចែកសាច់ប្រាក់តាមឆន្ទានុសិទ្ធិ (ថវិកានឹងត្រូវទទួលបានដោយស្វ័យប្រវត្តិរៀងរាល់ត្រីមាស) និងការបង្កើតគណៈកម្មការគ្រប់គ្រងថវិកានៅតាមអង្គភាពចំណាយ។ អង្គភាពត្រូវគ្រប់គ្រងថវិកាដោយផ្ទាល់ ស្របនឹងផែនការដែលបានអនុម័តរួច។ ការជំនួស

ការត្រួតពិនិត្យមុនចំណាយ ដោយសវនកម្មក្រោយចំណាយ បានជួយពន្លឿនការបើកផ្តល់ថវិកាឱ្យបានដល់សាលារៀន និងចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំ។

ការដាក់ឱ្យអនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនេះ ជាកម្លាំងជំរុញមួយដល់ប្រព័ន្ធអនុវត្តថវិកានៅកម្ពុជា។ កិច្ចការនេះអនុវត្តចំពោះសកម្មភាពមួយចំនួន ដោយប្រើប្រាស់សវនកម្មក្រោយចំណាយ ប្រសើរជាងការត្រួតពិនិត្យមុនចំណាយ សម្រាប់ការសម្រេចចិត្តនៅតាមអង្គភាពចំណាយ និងជៀសវាងការប្រែប្រួលថវិកា តាមរយៈការសម្រេចចិត្តបែងចែកសាច់ប្រាក់ នៅក្នុងអំឡុងពេលនៃឆ្នាំសារពើពន្ធ ។

ដើម្បីធ្វើឱ្យការបើកផ្តល់សាច់ប្រាក់នៅតាមរតនាគារកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលកម្ពុជាបានកែលម្អភាពត្រឹមត្រូវ និងគុណភាពនៃការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធកុំព្យូទ័រ អនុវត្តទម្រង់គណនីសាមញ្ញដោយមិនចងជាមួយនឹងលេខកូដគណនី និងលេខកូដគណនីរតនាគារ ដើម្បីជួយសម្រួលដល់ការរាយការណ៍ថវិកានិងរបាយការណ៍ហិរញ្ញវត្ថុ ចេញពីប្រព័ន្ធទិន្នន័យតែមួយ និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរតនាគារស្តីពីការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុបែបថ្មី។

ជាចំណែកមួយក្នុងការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតលើកិច្ចការកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំនិងការអនុវត្តថវិកា និងប្រព័ន្ធលទ្ធកម្ម ដើម្បីធានាតម្លាភាពនិងគណនេយ្យភាពរបស់អង្គភាពចំណាយ។ កំណែទម្រង់នេះរួមមានសកម្មភាពជាច្រើន។

ដើម្បីកែលម្អការអនុវត្តថវិកា និងការបើកផ្តល់សាច់ប្រាក់ រាជរដ្ឋាភិបាលបានពង្រឹងយន្តការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព តាមរយៈការពង្រឹងសមត្ថភាពក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំកម្មវិធីឱ្យបានមុនឆ្នាំអនុវត្ត និងអនុញ្ញាតឱ្យមានការបើកផ្តល់សាច់ប្រាក់ជាស្វ័យប្រវត្តិ។ ការបញ្ចេញសាច់ប្រាក់ក្នុងជុំទី៣ នៃកម្មវិធីសកម្មភាពជាអាទិភាពត្រូវអាស្រ័យលើការទូទាត់ចំណាយក្នុងជុំទី១ ប្រការនេះនឹងធ្វើឱ្យក្រសួង ស្ថាប័នមានពេលវេលាច្រើនក្នុងការធ្វើរបាយការណ៍។

រាជរដ្ឋាភិបាលបានដាក់ចេញនូវដំណោះស្រាយបន្ទាន់មួយចំនួន ដើម្បីដោះស្រាយបញ្ហាខាងលើ តាមរយៈការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព។ យន្តការនានារបស់កម្មវិធីសកម្មភាពជាអាទិភាពត្រូវបានតាក់តែងឡើង ដើម្បីបង្ហូរថវិកាឱ្យដល់វិស័យអប់រំដោយមានភាពទន់ភ្លន់ គ្មានភាពយឺតយ៉ាវ និងការបាត់បង់នៅក្នុងដំណើរការអនុវត្តថវិកា។

កម្មវិធីសកម្មភាពជាអាទិភាពមានផលប៉ះពាល់ជាវិជ្ជមានដល់វិស័យអប់រំ ពិសេសសាលារៀន។ អត្រាដកសាច់ប្រាក់សម្រាប់សកម្មភាពនានា ដែលគាំទ្រដោយកម្មវិធីសកម្មភាពអាទិភាព មានកម្រិតខ្ពស់ជាងសកម្មភាពនានា ដែលគាំទ្រដោយប្រព័ន្ធថវិកាកន្លងមក។ ការសិក្សាអំពីការរៀនសូត្ររបស់សិស្សបានបង្ហាញថា ក្នុងឆ្នាំ២០០០ សិស្សក្នុងខេត្តដែលគាំទ្រដោយកម្មវិធីសកម្មភាពជាអាទិភាព មានអត្រាត្រួតថ្នាក់ទាបជាងសិស្សក្នុងខេត្តដែលមិនមានការគាំទ្រ ដោយសារថវិកាគាំទ្រសម្រាប់ការបើកថ្នាក់បំប៉ន។

ថ្វីបើមានភាពវិជ្ជមានច្រើនក៏ដោយ ក៏នៅទាមទារឱ្យមានការពិនិត្យឡើងវិញអំពីឥរិយាបថ នៃការចំណាយដែលមានភាពខុសគ្នានៅតាមអង្គភាពចំណាយ និងតម្រូវការកសាងសមត្ថភាពសម្រាប់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាបាននូវការតាម-ដានពិនិត្យនិងគណនេយ្យភាព។

ឆ្លើយតបនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការបង្កើនការបើកផ្តល់ថវិកាស្ថិតក្រោមកម្មវិធីសកម្មភាពជាអាទិភាព រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីផ្តោតលើជនក្រីក្រ ដើម្បីដោះស្រាយតម្រូវការរបស់ប្រជាជនក្រីក្រដោយផ្ទាល់។ កិច្ចការនេះបានប្រើប្រាស់យន្តការហិរញ្ញវត្ថុដូចគ្នានឹងកម្មវិធីសកម្មភាពជាអាទិភាព ក្នុងការដោះស្រាយបញ្ហាកង្វះជីវជាតិ កង្វះអាហារូបត្ថម្ភរបស់ប្រជាជន និងកែលម្អការផ្តល់សេវាអប់រំ តាមរយៈការផ្តល់កញ្ចប់ថវិកាដល់ខេត្តដែលមានស្ថានភាពក្រីក្រខ្លាំង ដូចជា ខេត្តព្រះវិហារ ឧត្តរមានជ័យ រតនគិរី និងមណ្ឌលគិរី។ ក្រៅពីកម្មវិធីផ្តល់អាហារូបករណ៍ ដល់កុមារមកពីគ្រួសារក្រីក្រ កម្មវិធីផ្តោតលើជនក្រីក្រ ក៏បានផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់គ្រូបង្រៀននៅតំបន់ដាច់ស្រយាល បង្កើនថវិកាសម្រាប់កម្មវិធីអភិវឌ្ឍសម្ភាររូបវន្ត និងផ្តល់ថវិកាដំណើរការកាន់តែច្រើនដល់សាលារៀននៅតំបន់ដាច់ស្រយាល។ ការអនុវត្តកម្មវិធីផ្តោតលើជនក្រីក្របានបង្កើនការចូលរៀនរបស់កុមារមកពីគ្រួសារក្រីក្រ កុមារី និងជនជាតិដើមភាគតិច។ តាមស្ថិតិនិងសូចនាករអប់រំបានបង្ហាញថា អត្រានៃការសិក្សារបស់កុមារនៅខេត្តរតនគិរីបានកើនឡើង៣០% រវាងឆ្នាំសិក្សា២០០០-២០០១ និងឆ្នាំសិក្សា២០០១-២០០២ ដោយសារតែមានការបង្កើនថវិកាដល់សាលារៀន ដើម្បីលុបបំបាត់ការបង់ថ្លៃសិក្សា។

ឆ្លើយតបនឹងការប្តេជ្ញាចិត្តបង្កើនថវិកាសម្រាប់វិស័យអប់រំ **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ** ត្រូវបានកសាងឡើង ដើម្បីធានាចំណងទាក់ទងរវាងគោលនយោបាយនិងយុទ្ធសាស្ត្រអប់រំ ជាមួយនឹងការអភិវឌ្ឍកម្មវិធី ព្រមទាំងផែនការសកម្មភាពនានា ក៏ដូចជារវាងការកសាងផែនការនិងការរៀបចំថវិកា។ ក្នុងជំហាននេះ ក្រសួងអប់រំ យុវជន និងកីឡា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានបំណងបន្តផ្តល់អាទិភាពខ្ពស់ ដល់ការធានាសមធម៌ក្នុងការទទួលបានសេវាអប់រំប្រកបដោយគុណភាពខ្ពស់ ជាពិសេសនៅកម្រិតអប់រំមូលដ្ឋាន ស្របទៅនឹងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ២០១៥។

កំណែទម្រង់វិស័យអប់រំមានគោលដៅដោះស្រាយបញ្ហាក្នុងវិស័យ និងឆ្លងវិស័យមួយចំនួនដូចជា ៖

(i) **ការចូលរៀន និងសមធម៌** ៖ ការចូលរៀននៅកម្រិតអប់រំមូលដ្ឋាន ៩ ឆ្នាំ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងណា កុមារមកពីគ្រួសារក្រីក្របំផុតនៅតែមិនទាន់ទទួលបានសេវាអប់រំគ្រប់កម្រិត ឬទទួលបានតិចតួចនៅឡើយ។ នៅកម្រិតបឋមសិក្សា កុមារមកពីគ្រួសារក្រីក្របំផុតមាននិន្នាការចូលរៀនយឺត និងងាយបោះបង់ការសិក្សាដោយសារកត្តាសង្គម និងហិរញ្ញវត្ថុ។ កុមារមកពីគ្រួសារក្រីក្របំផុតបានចូលរៀនប្រមាណ ៥% នៅកម្រិតមធ្យមសិក្សាបឋមភូមិ និង ២% នៅមធ្យមសិក្សាទុតិយភូមិ។ នៅកម្រិតក្រោមមធ្យមសិក្សា កុមារមកពីគ្រួសារធូរធារខ្លាំងបានចូលរៀនប្រមាណ ៦០%។ ឧបសគ្គក្នុងការចូលរៀនបង្កឡើងដោយកត្តាជាច្រើនដូចជា របាយមិនស្មើគ្នានៃសម្ភាររូបវន្តអប់រំ ចម្ងាយ និងមធ្យោបាយធ្វើដំណើរ ព្រមទាំងកត្តាសង្គមមួយចំនួនទាក់ទងនឹងចំណាយឱកាសក្នុងការសិក្សា។

(ii) **គុណភាពអប់រំ** ៖ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក៏ដូចជាការផ្តល់សៀវភៅសិក្សាគោលនៅទូទាំងប្រទេស ចាប់ពីថ្នាក់ទី១ ដល់ទី៩។ ទោះយ៉ាងណា គុណភាព និងភាពឆ្លើយតបរបស់ប្រព័ន្ធអប់រំទាមទារឱ្យមានការពិនិត្យឡើងវិញជាបន្ទាន់ ជាពិសេសនៅពេលដែលការអប់រំកម្រិតមធ្យមសិក្សាកំពុងកើនឡើងយ៉ាងឆាប់រហ័ស។ ការបំពេញការងាររបស់គ្រូបង្រៀន និងការសិក្សារបស់សិស្សានុសិស្សនៅតែជាកង្វល់ ដោយសារតែការមកបំពេញការងារនិងការមកសិក្សាមិនទៀងទាត់ និងការលើកទឹកចិត្តផ្អែកលើការបំពេញការងារនិងលទ្ធផលសិក្សាមិនទាន់បានគ្រប់គ្រាន់។ វិសមភាពបានកើតឡើងរវាងតំបន់ប្រជុំជន និងតំបន់ជនបទ រវាងកុមារមកពីគ្រួសារក្រីក្រ និងគ្រួសារធូរធារ ជាពិសេសឆន្ទៈរបស់បុគ្គលិកអប់រំមានសមត្ថភាព ដែលកំពុងបម្រើការនៅតំបន់ជនបទ និងដាច់ស្រយាលនៅមានកម្រិត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(iii) **ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រសិទ្ធភាព** ៖ គោលនយោបាយចំណាយរបស់រដ្ឋាភិបាលបានផ្តោតលើការផ្តល់ថវិកា ដែលមានចំណែកខ្ពស់សម្រាប់បឋមសិក្សា និងផ្តោតលើក្រុមជនក្រីក្រ។ ទោះជាយ៉ាងណា អនុវិស័យបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាទទួលបានធនធានមិនទាន់គ្រប់គ្រាន់នៅឡើយ បើប្រៀបធៀបនឹងប្រទេសជិតខាងក្នុងតំបន់។ កត្តាគុណភាពនិងសមធម៌ក្នុងការចំណាយ ទាមទារឱ្យមានការកែលម្អជាបន្ទាន់ ដោយសារថវិកាដំណើរការមានកម្រិតទាប និងយន្តការក្នុងការបែងចែកធនធានផ្តោតលើជនក្រីក្រមិនទាន់បានអភិវឌ្ឍនៅឡើយ។ យន្តការសម្រាប់កម្រិត និងគ្រប់គ្រងវិភាគទានរបស់មាតាបិតាសិស្សមិនទាន់បានអភិវឌ្ឍនៅឡើយ។

(iv) **ដំណើរការស្ថាប័ន អភិបាលកិច្ច និងអ្នកពាក់ព័ន្ធ** ៖ ប្រព័ន្ធអប់រំនៅមានលក្ខណៈមជ្ឈការកម្រិតខ្ពស់នៅឡើយ ដែលធ្វើឱ្យការផ្ទេរអំណាច និងការលើកទឹកចិត្តឱ្យមានការអភិវឌ្ឍនិងកំណែទម្រង់នៅមានកម្រិត។ ថ្វីបើភាពជាដៃគូរដ្ឋ និងឯកជនក្នុងវិស័យអប់រំមានភាពទូលំទូលាយក៏ដោយ ក៏លិខិតបទដ្ឋាន និងក្របខណ្ឌច្បាប់ស្តីពីអភិបាលកិច្ចសាលារៀននិងសហគមន៍ និងការបង្កើនស្វ័យភាពប្រតិបត្តិការរបស់គ្រឹះស្ថានសិក្សាមិនមានគ្រប់គ្រាន់នៅឡើយ។ វិសាលភាពនៃការផ្ទេរអំណាចនៅមានកម្រិតចង្អៀត ដោយសារកង្វះយន្តការធានាគុណភាព និងព័ត៌មានជាសាធារណៈ (ឧទា. អធិការកិច្ច) និងកង្វះក្របខណ្ឌគតិយុត្តិពាក់ព័ន្ធ។ ដំណើរការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមានភាពប្រសើរជាងមុន (ឧទា. រាជរដ្ឋាភិបាល សហគមន៍ និងដៃគូអភិវឌ្ឍ) ប៉ុន្តែទាមទារឱ្យមានការកែលម្អបន្ថែមទៀត ជាពិសេសការពិនិត្យតាមដានការបំពេញការងាររបស់វិស័យអប់រំនៅមានកម្រិត។

(v) **ការអភិវឌ្ឍសមត្ថភាព** ៖ ការបំប៉នសមត្ថភាពបុគ្គលិកអប់រំគ្រប់កម្រិតត្រូវបានធ្វើឡើងយ៉ាងខ្លាំងក្លា រួមបញ្ចូលទាំងគ្រូបង្រៀន អ្នករដ្ឋបាល និងអ្នកផែនការ។ ផលប៉ះពាល់នៃការបំប៉ននេះនៅមានកម្រិតនៅឡើយ ដោយសារកត្តាមួយចំនួនដូចជាកង្វះប្រព័ន្ធលើកទឹកចិត្តផ្អែកលើលទ្ធផលការងារ ប្រព័ន្ធទំនាក់ទំនងនិងគ្រប់គ្រងមិនទាន់មានប្រសិទ្ធភាព និងយន្តការពង្រាយនិងវាយតម្លៃបុគ្គលិកមិនទាន់មានប្រសិទ្ធភាព។

ឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តវិធានការមួយចំនួន ដើម្បីតម្រែតម្រង់ការផ្តល់សេវាអប់រំឱ្យដល់ជនក្រីក្រ។ នៅតាមគ្រឹះស្ថានឧត្តមសិក្សា រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយបង់ថ្លៃសិក្សាសម្រាប់អ្នកមានលទ្ធភាព ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋ និងបង្កើនចំណូលនៅតាម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រឹះស្ថានទាំងនោះសម្រាប់កែលម្អគុណភាពនៃការសិក្សា។ ដូចគ្នានេះដែរ ទាក់ទងនឹងការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិសម្រាប់ការបណ្តុះបណ្តាល ដោយមានសមាសភាពពីគ្រប់ភាគីពាក់ព័ន្ធ។ ប្រព័ន្ធបង្កើនការចែករំលែកចំណាយត្រូវបានរៀបចំឡើង ដើម្បីផ្តល់ថវិកាគាំទ្រការអប់រំកម្រិតមូលដ្ឋានដែលជាភូមិសិក្សាមួយមានជនក្រីក្របំផុតកំពុងសិក្សាយ៉ាងច្រើន។

របៀបវារៈកំណែទម្រង់សំខាន់ៗ មានសង្ខេបដូចខាងក្រោម ៖

- តើកំណែទម្រង់កម្រិតគោលនយោបាយអ្វីខ្លះ ដែលចាំបាច់ និងធានាថាការអភិវឌ្ឍវិស័យអប់រំកំពុងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើជនក្រីក្រ ទាក់ទងនឹងការចូលរៀន និងការកែលម្អគុណភាពអប់រំ?
- តើគោលនយោបាយផ្នែកហិរញ្ញវត្ថុអ្វីខ្លះ ដែលចាំបាច់ត្រូវតម្រង់ទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា រួមបញ្ចូលទាំងការធានាសមធម៌រវាងតំបន់ប្រជុំជន និងជនបទ និងកត្តាយេនឌ័រ?
- តើវិធានការអ្វីខ្លះ ដែលចាំបាច់និងធានាគុណភាពនៃសេវាអប់រំ ជាពិសេសប្រសិទ្ធផលនៃតុល្យភាពរវាងថវិកាសម្រាប់បៀវត្ស និងមិនមែនបៀវត្ស?
- តើសកម្មភាពអាទិភាពអ្វីខ្លះ ដែលចាំបាច់ដើម្បីផ្តល់ការធានាគុណភាព និងគតិយុត្តិដែលមានភាពស័ក្តិសិទ្ធិ គាំទ្រដល់ភាពជាដៃគូអប់រំរវាងរដ្ឋនិងឯកជន?

ការកាត់បន្ថយចំណាយលើវិស័យការពារជាតិ និងសន្តិសុខចំនួន ៤,៤% នៃផសស នៅឆ្នាំ១៩៩៤ មកនៅត្រឹម ២,៦% នៃផសស នៅឆ្នាំ២០១២ ជាភាពជាក់ស្តែងមួយនៃបម្រែបម្រួលអាទិភាពចំណាយ។ ទោះជាយ៉ាងណា ចំណាយប្រភេទនេះត្រូវបានប៉ាន់ស្មានថាមានកម្រិតថេរស្មើនឹង ២,៦% នៃផសស នៅឆ្នាំ២០១៣។ និន្នាការនេះស្របគ្នាជាមួយនឹងការបង្កើនចំណាយសម្រាប់វិស័យសង្គមកិច្ច។ វិស័យអប់រំ សុខាភិបាល កសិកម្ម និងការអភិវឌ្ឍជនបទត្រូវបានរាជរដ្ឋាភិបាលកំណត់ថា ជាវិស័យអាទិភាព។ ចំណាយផ្នែកសង្គមកិច្ចបានបន្តកើនឡើងជាលំដាប់។ ចំណែកនៃការកើនឡើងនេះបានបង្កើនការចំណាយលើវិស័យអប់រំ។

កត្តាគន្លឹះដែលត្រូវដោះស្រាយគឺការធានាថា គោលនយោបាយចំណាយបានផ្តោតលើការជួយជនក្រីក្រ ស្របពេលជាមួយគ្នានោះត្រូវធានាគុណភាពខ្ពស់ផងដែរ។ វិធានការចំណាយមួយចំនួនត្រូវបានដាក់ចេញ ដើម្បីសម្រេចវត្ថុបំណងគោលនយោបាយខាងលើ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិធានការទី១ គឺកាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតានៃគ្រួសារក្រីក្រ តាមរយៈការលុបបំបាត់ការបង់ថ្លៃសិក្សាក្រៅម៉ោង និងកាត់បន្ថយវិភាគទានរបស់មាតាបិតានៅក្នុងដំណើរការសាលារៀន នៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ។ ក្នុងន័យនេះ វិភាគទានផ្នែកឯកជនសម្រាប់ការអប់រំមូលដ្ឋាននឹងត្រូវកាត់បន្ថយពី ៤០ ០០០ រៀលក្នុងសិស្សម្នាក់មកនៅត្រឹម ២៦ ០០០ រៀល។ គោលដៅនៃការរក្សាបន្ទុកចំណាយមួយចំនួន គឺដើម្បីបំផុសគណនេយ្យភាពទៅវិញទៅមក រវាងអ្នកគ្រប់គ្រងសាលារៀន និងមាតាបិតាសិស្ស។ ជារួម សេណារីយ៉ូនេះនឹងកាត់បន្ថយការចូលរួមពីផ្នែកឯកជនពី ៥០% មកនៅត្រឹម ១៨% ក្នុងរយៈពេលមួយ ដែលជាផ្នែកមួយនៃគោលនយោបាយហិរញ្ញវត្ថុដ៏រឹងមាំ និងជួយដល់ជនក្រីក្រ។ របៀបវារៈកំណែទម្រង់នេះនឹងទាមទារឱ្យមានការពិនិត្យឡើងវិញ នូវភាពជាដៃគូអប់រំរដ្ឋ និងឯកជន នៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងភូមិសិក្សាក្រោយៗទៀត។ កំណែទម្រង់នេះទាមទារឱ្យមានការថ្លឹងថ្លែងដោយប្រុងប្រយ័ត្ន ជៀសវាងបង្កើតចំណាយក្រៅផ្លូវការចំពោះឪពុកម្តាយដែលក្រីក្រ ស្របពេលជាមួយនឹងការផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់កែលម្អគុណភាព។ យុទ្ធសាស្ត្រមួយដែលអាចធ្វើបាន គឺផ្តល់ការលើកលែងការបង់ថ្លៃសិក្សា ចំពោះសិស្សមកពីគ្រួសារក្រីក្រ តាមរយៈការគាំទ្ររបស់រដ្ឋាភិបាល ក្នុងខណៈដែលបន្តទទួលយកការបង់ថ្លៃសម្រាប់សិស្សដែលមកពីគ្រួសារធូរធារ។

## ២.១.២. ពីកម្មវិធីសកម្មភាពអាទិភាព ឆ្ពោះទៅកាន់កំណែទម្រង់ថវិកាទូលំទូលាយ

**កម្មវិធីសកម្មភាពអាទិភាព** ឬអាចហៅថាជាយុទ្ធសាស្ត្រនៅក្នុងកំណែទម្រង់ថវិកានៅកម្ពុជា។ យុទ្ធសាស្ត្រនេះជាជំហានដ៏សំខាន់ក្នុងការផ្ទេរការទទួលខុសត្រូវដល់អង្គភាពចំណាយ។ ទោះជាយ៉ាងណា យុទ្ធសាស្ត្រនេះត្រូវបានអនុវត្តនៅតាមអង្គភាពចំណាយ ដែលមានការគ្រប់គ្រងល្អប្រសើរតែប៉ុណ្ណោះ។ ការអនុវត្តយុទ្ធសាស្ត្រនេះមិនត្រឹមតែផ្តោតលើវិស័យមួយចំនួនដែលបានជ្រើសរើសនោះទេ ប៉ុន្តែក៏ផ្តោតលើការសម្រាំងយកតែអង្គភាពចំណាយមួយចំនួននៅក្នុងវិស័យនោះផងដែរ ដើម្បីប្រែក្លាយពីប្រព័ន្ធត្រួតពិនិត្យបែបមជ្ឈការទៅជា ដំណើរការអនុវត្តថវិកាបែបម្ចាស់ការ។ ដូច្នេះហើយ កម្មវិធីសកម្មភាពជាអាទិភាពគឺជាជំហានអន្តរការមួយ។ ការផ្ទេរការទទួលខុសត្រូវនេះទាមទារឱ្យដើរទន្ទឹមគ្នានឹងការកែលម្អសមត្ថភាព និងគណនេយ្យភាព។

នៅពេលខាងមុខ ទាមទារឱ្យមានភាពប្រសើរឡើងនូវតុល្យភាពរវាងប្រសិទ្ធភាពកម្រិតម៉ាក្រូនៃថវិកា ជាមួយនឹងប្រសិទ្ធភាពបច្ចេកទេស និងការបែងចែក។ ជាការប្រសើរការគ្រប់គ្រងថវិកាអាស្រ័យលើក្បួនច្បាប់ គួរតែត្រូវបានជំនួសដោយការគ្រប់គ្រងថវិកា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្ពោះទៅសម្រេចគោលដៅ ឬចំណុចដៅ។ កិច្ចការនេះនឹងបញ្ចូលនូវការតាមដានសូចនាករលទ្ធផលការងារក្នុងអំឡុងពេលមួយ ឬការប្រៀបធៀបលទ្ធផលការងារក្នុងចំណោមអង្គភាពចំណាយ ដែលផ្តល់សេវានៅកន្លែងផ្សេងៗគ្នានៃប្រទេស។ ជាចុងក្រោយ កិច្ចការនេះនឹងនាំឆ្ពោះទៅរកការគ្រោងថវិកាផ្អែកលើធាតុចេញ និងលទ្ធផលការងារ (សមិទ្ធកម្ម)។ ធាតុសំខាន់មួយ បន្ទាប់ពីការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព គឺការដាក់ឱ្យអនុវត្តជាបណ្តើរៗនូវគណនេយ្យភាពលទ្ធផល ដែលជាទិសដៅនាពេលអនាគត នៅពេលមានសមត្ថភាពពេញលេញ។

ដើម្បីកាត់បន្ថយនីតិវិធី និងជួយសម្រួលដល់ការចំណាយ ការពិភាក្សាជាច្រើនបានតម្រង់ឆ្ពោះទៅរកការធ្វើប្រតិភូកម្មការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅដល់ក្រសួង ស្ថាប័ន តាមរយៈការពង្រាយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន និងផ្តល់សិទ្ធិអំណាចក្នុងការត្រួតពិនិត្យហិរញ្ញកិច្ចមួយចំនួនដល់ក្រសួង ស្ថាប័ន ជាមួយគ្នានឹងការកែលម្អការគ្រប់គ្រងសាច់ប្រាក់ និងការកាត់បន្ថយភាពលំបាកមួយចំនួនដែលកើតមាននៅក្នុងប្រព័ន្ធរតនាគារ។

ការងារលទ្ធកម្មក៏ជាកិច្ចការសំខាន់នៅក្នុងការអនុវត្តថវិកាផងដែរ។ ចំណាយសាធារណៈមួយផ្នែកនៅគ្រប់កម្រិតរដ្ឋបាលគ្រប់គ្រង គឺជាការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងការសាងសង់។ លក្ខណៈវិនិច្ឆ័យបំពេញការងារសម្រាប់វាយតម្លៃការងារលទ្ធកម្មគឺការសន្សំសំចៃ ឧទា. ការទទួលបានទំនិញក្នុងតម្លៃទាបបំផុតដោយគ្មានប៉ះពាល់ដល់គុណភាពនិងរយៈពេលនៃការផ្គត់ផ្គង់។ ដើម្បីកែលម្អការងារលទ្ធកម្ម ក្នុងដើមឆ្នាំ២០០២ រាជរដ្ឋាភិបាលបានសម្រេចឱ្យចាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈពេញលេញ សម្រាប់ក្រសួងអាទិភាពចំនួន ៤ ដូចជាអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍជនបទ ដើម្បីទទួលបានទំនិញ សេវាកម្ម និងការសាងសង់។ ការដេញថ្លៃតាមបែបប្រកួតប្រជែង បានធ្វើឱ្យមានការសន្សំសំចៃដល់ថវិកាជាតិ ដែលអាចទៅប្រើប្រាស់ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រដទៃទៀត។

### ២.១.៣. ការផ្សារភ្ជាប់យុទ្ធសាស្ត្ររបស់វិស័យទៅនឹងថវិកា និងក្របខណ្ឌចំណាយរយៈពេលមធ្យម

កម្មវិធីសកម្មភាពជាអាទិភាពត្រូវបានដាក់ឱ្យអនុវត្តជាជំហានៗ នៅក្នុងវិស័យអប់រំ។ ផ្អែកលើការសន្មតកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំយ៉ាងតិច ៦% ថវិការយៈពេលមធ្យមបានរួមបញ្ចូលរាល់ធនធានសាធារណៈទាំងអស់ ដូចជា ពន្ធដារ ចំណូលមិនមែនពន្ធដារ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងកម្មវិធី ដែលនឹងត្រូវបែងចែក ក្នុងចំណោមកម្មវិធីអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងរយៈពេលមធ្យម ស្របជាមួយនឹងកម្រិតកំណត់នៃតុល្យភាពសារពើពន្ធ (អតិរេក ឬឱនភាព)។ ក្នុងករណីនេះ ចំណងទាក់ទងត្រូវបានគាំទ្រ ដោយកិច្ចការកន្លងមកនិងកិច្ចការកំពុងបន្ត ដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

អភិក្រមហិរញ្ញប្បទានសម្រាប់វិស័យអប់រំ មានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ក្របខណ្ឌហិរញ្ញប្បទានផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវបានរៀបចំឡើងដើម្បីផ្សារភ្ជាប់ចំណាយទៅនឹងលទ្ធផល តាមរយៈការពិនិត្យឡើងវិញប្រចាំឆ្នាំ នៃកម្មវិធីអាទិភាពផ្តោតលើលទ្ធផល ដោយចុះកិច្ចព្រមព្រៀងរួមគ្នារវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសូចនាករ និងចំណុចដៅសំខាន់ៗ ដោយភ្ជាប់ជាមួយនឹងការគាំទ្រហិរញ្ញប្បទានថវិកាពីរដ្ឋាភិបាល។ ចំណាយរបស់កម្មវិធីនានា ត្រូវបានគណនា តាមវិធីសាស្ត្រពីក្រោមឡើងលើ ឬ ហៅថាផែនការផ្អែកលើតម្រូវការ និងវិធីសាស្ត្រពីលើចុះក្រោម អាស្រ័យនឹងធនធានមានកម្រិត។ ឧទា. វិធានការលុបបំបាត់ចំណាយរបស់មាតាបិតា ដោយផ្តល់ថវិកាដំណើរការសាលារៀន ត្រូវបានគណនាដោយគិតចំណាយឯកតាក្នុងសិស្សម្នាក់ និងផលធៀបចំណាយផ្នែកសាធារណៈនិងផ្នែកឯកជន ក្នុងរយៈពេលពេល ៥ ឆ្នាំ។

ក្របខណ្ឌហិរញ្ញប្បទានផែនការយុទ្ធសាស្ត្រវិស័យអប់រំពឹងអាស្រ័យខ្លាំង ជាមួយនឹងថវិការបស់រដ្ឋាភិបាល។ កម្មវិធីសកម្មភាពជាអាទិភាពភាគច្រើនត្រូវបានអនុវត្ត ក្រោមរូបភាពជាកម្មវិធីសកម្មភាពអាទិភាព ដែលជាថវិកាចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា។ គេរំពឹងទុកថា គំណនេះនឹងកាន់តែប្រសើរឡើងជាបន្តបន្ទាប់ ស្របជាមួយនឹងការអភិវឌ្ឍយុទ្ធសាស្ត្រថវិកា និងការធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មហិរញ្ញប្បទានពីខាងក្រៅទៅក្នុងថវិការដ្ឋាភិបាល អាស្រ័យទៅតាមនីតិវិធីដែលភ្នាក់ងារផ្តល់ជំនួយជ្រើសរើស។ ក្នុងពេលបច្ចុប្បន្ន ហិរញ្ញប្បទានពីខាងក្រៅសម្រាប់វិស័យអប់រំ មានរូបភាពជាថវិកាគាំទ្រគម្រោងគាំទ្រសម្រាប់ការវិនិយោគមូលធន គម្រោងគាំទ្រសម្រាប់ការអភិវឌ្ឍសមត្ថភាព និងគម្រោងគាំទ្រកម្មវិធីអាទិភាពចរន្តមួយចំនួន។

## ២.២. ក្របខណ្ឌចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំ[192]

ការផ្តល់ឱកាសអប់រំដល់ប្រជាជនកម្ពុជាគ្រប់រូប គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច

[192] MEF (2003), Medium-Term Expenditure Framework, Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជា។ រាជរដ្ឋាភិបាលបានប្ដេជ្ញាបង្កើនល្បឿនកំណែទម្រង់វិស័យអប់រំ ដោយមានការ-ជួយជ្រោមជ្រែងពីដៃគូអភិវឌ្ឍកន្លងមក និងដៃគូថ្មីៗ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល។ បន្ថែមពីនេះទៀត រដ្ឋាភិបាលទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមពីសំណាក់អាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ្រូបង្រៀន មាតាបិតា និងក្រុមសហគមន៍ ក៏ដូចជាផ្នែកឯកជននៅក្នុងដំណើរការកែទម្រង់នេះ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានខិតខំធ្វើសុខុដុមនីយកម្មផែនការ និងកម្មវិធីរយៈពេលមធ្យម ស្របជាមួយនឹងគោលដៅរយៈពេលវែងអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍។ ក្នុងដំណើរនេះ គណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ ដើម្បីរៀបចំផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ដែលត្រូវបានអនុម័តក្នុងខែមិថុនា ឆ្នាំ២០០៣[193]។ អភិក្រមនេះធានានូវសង្គតិភាព និងការពង្រីកគោលនយោបាយអប់រំដែលមានស្រាប់ និងកម្មវិធីអាទិភាព ក៏ដូចជាការអភិវឌ្ឍអាទិភាពយូរអង្វែងផងដែរ ជាពិសេសសក្នុងអនុវិស័យអប់រំកុមារតូច និងអប់រំក្រៅប្រព័ន្ធ។

សសរស្ដម្ភទី៣នៃគោលនយោបាយអប់រំ គឺជំរុញវិសហមជ្ឈការនៃការគ្រប់គ្រងសេវាអប់រំ ដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន។ ជាក់ស្ដែង ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតបណ្ដាញអង្គភាពគ្រប់គ្រងថវិកាប្រមាណ២០០ ដោយធ្វើការផ្ទេរសិទ្ធិអំណាច ក្នុងការសម្រេចចិត្តលើចំណាយស្របតាមគោលការណ៍ណែនាំដែលបានឯកភាព។ ជាលទ្ធផលក្នុងការកែលម្អអភិបាលកិច្ចអប់រំ និងគណនេយ្យភាព ក្នុងឆ្នាំ២០០២ ប្រព័ន្ធគណនេយ្យហិរញ្ញកិច្ច និងសវនកម្មផ្ទៃក្នុងត្រូវបានកែលម្អ។

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០១-២០០៥ ដោយបានឆ្លុះបញ្ចាំងអំពីអាទិភាពគោលនយោបាយ និងយុទ្ធសាស្ត្រអប់រំសម្រាប់កំណែទម្រង់ និងស្របជាមួយនឹងគោលនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ដូចជាកម្មវិធីជាតិ កម្មវិធីកំណែទម្រង់រដ្ឋបាល កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងផែនការវិមជ្ឈការ និងវិសហមជ្ឈការនៃការគ្រប់គ្រងសេវាសាធារណៈ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០១-២០០៥ គឺជាជំហានដំបូង និងជាបង្គោលចាប់ផ្ដើមសម្រាប់មាគ៌ាដ៏វែងឆ្ងាយ ក្នុងការនាំទៅរកសេវាអប់រំដ៏ល្អប្រសើរសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ គោលដៅរបស់ក្រសួង គឺអភិវឌ្ឍសេវាអប់រំប្រកបដោយបរិយាប័ន្ន ងាយស្រួលទទួលបានសេវា និងមានគុណភាពខ្ពស់ សម្រាប់ប្រជាជនគ្រប់រូប ដោយមិនគិតអំពី

[193] RGC (2003), Education for All National Plan 2003-2015, Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ថានភាពគ្រួសារ យេនឌ័រ ជនជាតិដើមភាគតិច រូបកាយ និងស្មារតី។ ចក្ខុវិស័យរបស់ក្រសួងក៏បានរួមបញ្ចូលទាំងការយល់ដឹង អំពីតម្រូវការចាំបាច់នៃប្រព័ន្ធអប់រំនិងបណ្ដុះ-បណ្ដាលសម្រាប់កំណើនសេដ្ឋកិច្ច ការងារកាន់តែច្រើន និងឱកាសក្នុងការបង្កើនប្រាក់ចំណូល។ ចក្ខុវិស័យក៏បានផ្ដោតលើចំណេះដឹងមូលដ្ឋាន ដែលនិយាយថា ការអប់រំល្អនឹងចូលរួមក្នុងការកសាងគ្រួសារដែលរឹងមាំ និងអាហារូបត្ថម្ភគ្រប់គ្រាន់ លើកកម្ពស់ផែនការគ្រួសារ និងលើកកម្ពស់ស្ត្រី។

ចក្ខុវិស័យរាជរដ្ឋាភិបាលដែលផ្ដោតលើប្រព័ន្ធអប់រំប្រកបដោយបរិយាប័ន្ន បានផ្ដោតលើការចូលរួមយ៉ាងទូលំទូលាយពីគ្រប់កម្រិតរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល ក្នុងការទទួលខុសត្រូវទាំងការកសាងផែនការ និងការផ្ដល់សេវាអប់រំ។ ចក្ខុវិស័យមានគោលដៅអនុវត្តជាបណ្ដើរៗនូវគណនេយ្យភាពទ្វេទិសរវាងរដ្ឋាភិបាល និងសហគមន៍ដែលធានាថា សាលារៀន និងគ្រឹះស្ថានសិក្សាមានលក្ខណៈមេត្រី និងបំពេញការងារល្អប្រសើរ។ គោលដៅបន្ទាប់បន្សំ គឺការផ្ទេរសិទ្ធិអំណាចបន្តិចម្ដងៗ ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងចំណាយទៅដល់ក្រុង ស្រុក ខណ្ឌ ឬក៏ឃុំ សង្កាត់ និងសាលារៀន។

រាជរដ្ឋាភិបាលមានជំនឿថា វត្ថុបំណងរយៈពេលមធ្យមរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលបានផ្ដោតលើការបង្កើនលទ្ធភាពទទួលបានសេវាអប់រំមូលដ្ឋាន ៩ ឆ្នាំ និងការបង្កើនគុណភាពនិងភាពឆ្លើយតបក្នុងការចូលរៀន ការបន្តការសិក្សានិងការបណ្ដុះបណ្ដាល គឺជាជំហានដ៏ធំមួយឆ្ពោះទៅសម្រេចគោលដៅទាំងនេះ។ បន្ថែមពីនេះទៀតរាជរដ្ឋាភិបាលក៏មានជំនឿថា វិធានការដែលបានស្នើឡើងសម្រាប់តម្រែតម្រង់ការចំណាយរបស់រដ្ឋាភិបាល នឹងធ្វើឱ្យមាតាបិតា និងដៃគូអភិវឌ្ឍកាត់បន្ថយឧបសគ្គចំណាយក្នុងការទទួលបានសេវាអប់រំ និងនាំឱ្យហិរញ្ញប្បទានអប់រំឆ្ពោះទៅមាគ៌ាដ៏យូរអង្វែងមួយប្រកបដោយនិរន្តរភាព។ ជាចុងបញ្ចប់ អាទិភាពដែលបានកំណត់សម្រាប់ការចំណាយមូលធននៅតាមសាលារៀនក្នុងតំបន់ខ្វះសេវាអប់រំ និងការអភិវឌ្ឍស្ថាប័ន នឹងផ្ដល់ជាមូលដ្ឋានសម្រាប់សម្រេចបានការកែប្រែប្រព័ន្ធអប់រំក្នុងរយៈពេលវែង។

### ២.២.១. អាទិភាពគោលនយោបាយ និងចំណុចដៅ ២០០១-២០០៥ ៖ ការអប់រំមូលដ្ឋាន

ទិសដៅគោលនយោបាយទូទៅរបស់រាជរដ្ឋាភិបាល គឺសម្រេចបានការអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ២០១៥ ដោយធ្វើឱ្យប្រសើរឡើងនូវអត្រានៃការសិក្សា ការចូលរៀន


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វត្តមាន និងសូចនាករគុណភាពដទៃទៀត។ ប្រការនេះនឹងអាស្រ័យលើលទ្ធភាពធនធាន និងភាពជោគជ័យនៃកម្មវិធីរំកិល។ អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺធានាលទ្ធភាពក្នុងការទទួលបានសេវាអប់រំ និងកែលម្អប្រសិទ្ធភាព និងគុណភាពអប់រំ នៅកម្រិតមូលដ្ឋានរយៈពេល ៩ឆ្នាំទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ត្រឹមឆ្នាំ២០១០។ ចំណុចដៅសំខាន់ៗសម្រាប់ឆ្នាំ ២០០១-២០០៥ មានដូចខាងក្រោម ៖

- បង្កើនចំនួនសិស្សចូលរៀនពីថ្នាក់ទី១ ដល់ទី៦ និងថ្នាក់ទី៧ ដល់ទី៩។ ចំណុចដៅ ៖ សិស្សបឋមសិក្សា ២,៤ លាននាក់ និងសិស្សមធ្យមសិក្សាបឋមភូមិ ០,៨៥ លាននាក់ អត្រាពិតនៃការសិក្សានៅបឋមសិក្សា ៩៥% និងមធ្យមសិក្សាបឋមភូមិ ៥០%
- បង្កើនអត្រាគង់វង្សពីថ្នាក់ទី១ ដល់ទី៦ និងថ្នាក់ទី៧ ដល់ទី៩ សម្រាប់ក្រុមសិស្សថ្មី និងសិស្សបច្ចុប្បន្ន។ ចំណុចដៅ ៖ ៩០%
- កែលម្អគុណភាពនៃការបំពេញការងារ និងស្តង់ដារបស់សិស្សបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ
- ពង្រីកភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីអក្ខរកម្មនៅតំបន់ជួបការលំបាក។ ចំណុចដៅ ៖ អ្នកសិក្សា ២០០ ០០០ នាក់ក្នុង ១ ឆ្នាំ ចាប់ពីឆ្នាំ២០០៣។

### ២.២.២. អាទិភាពគោលនយោបាយ និងចំណុចដៅ ២០០១-២០០៥ ៖ កម្រិតក្រោយអប់រំមូលដ្ឋាន

ទិសដៅគោលនយោបាយរយៈពេលវែងរបស់រាជរដ្ឋាភិបាល សម្រាប់ការអប់រំមធ្យមសិក្សាទុតិយភូមិ ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧត្តមសិក្សាគឺអាស្រ័យនឹងការអនុវត្តភាពជាដៃគូបំពេញគ្នាទៅវិញទៅមករវាងសាធារណៈ និងឯកជន។ តួនាទីរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺការរៀបចំគោលនយោបាយនានាគាំទ្រដល់គ្រឹះស្ថានសាធារណៈ និងឯកជន ដើម្បីឆ្លើយតបនឹងតម្រូវការអប់រំ និងទីផ្សារការងារ ដោយគិតអំពីគុណសម្បត្តិប្រកួតប្រជែងរបស់គ្រឹះស្ថានទាំងនោះ។

អាទិភាពរបស់ក្រសួងសម្រាប់ឆ្នាំ២០០១-២០០៥ គឺបង្កើនលទ្ធភាពចូលរៀននៅថ្នាក់ទី១០ ដល់ថ្នាក់ទី១២ នៅកម្រិតឧត្តមសិក្សា និងនៅកម្រិតការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៅត្រឹមឆ្នាំ២០០៥។ អាទិភាពបន្ទាប់បន្សំគឺកែលម្អគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំក្រោយកម្រិតអប់រំមូលដ្ឋាន រួមបញ្ចូលទាំងការធានាអនុវត្តក្របខណ្ឌបុគ្គលិក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀនដែលមានគុណភាព និងមន្ត្រីគ្រប់គ្រងដែលមានប្រសិទ្ធផល។ ចំណុចដៅសំខាន់ៗសម្រាប់ឆ្នាំ២០០១-២០០៥ មានដូចជា ៖

- បង្កើនចំនួនសិស្សចូលរៀនថ្នាក់ទី១០ ដល់ទី១២ ស្របជាមួយនឹងការកែលម្អតុល្យភាពយេនឌ័រ កត្តាសង្គម សេដ្ឋកិច្ច និងតំបន់ប្រជុំជននិងជនបទ។ ចំណុចដៅគឺសិស្សចូលរៀន ០,៣ លាននាក់ អត្រាពិតនៃការសិក្សា ២០% ក្នុងនោះ ១០%ជាសិស្សមកពីគ្រួសារក្រីក្របំផុត និង ៦០% មកពីតំបន់ជនបទ ព្រមទាំង ៥០%ជាសិស្សស្រី
- បង្កើនចំនួននិស្សិតចូលរៀននៅឧត្តមសិក្សាសាធារណៈ និងឯកជន ដោយបង្កើនចំណែកសម្រាប់ផ្នែកឯកជន
- បង្កើនការចូលរៀននៅគ្រឹះស្ថានសាធារណៈនិងឯកជន កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធដែលមានគុណភាព ដោយបង្កើនចំណែកមិនមែនរដ្ឋាភិបាល (ដូចជា ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល)
- បង្កើនចំនួននិស្សិតចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសនិស្សិតមកពីគ្រួសារក្រីក្រ និងក្រៅតំបន់ប្រជុំជន កែលម្អភាពឆ្លើយតប និងស្តង់ដានៃការសិក្សារបស់សិស្សថ្នាក់ទី១០ ដល់ទី១២ និងក្រោយមធ្យមសិក្សា។

## ២.២.៣. អាទិភាពគោលនយោបាយ និងចំណុចដៅ២០០១-២០០៥ ៖ ការអភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ

ទិសដៅគោលនយោបាយរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺអនុវត្តប្រព័ន្ធកសាងផែនការ និងគ្រប់គ្រង ដែលនឹងធ្វើឱ្យមានការទទួលខុសត្រូវកាន់តែច្រើនឡើងក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅកម្រិតក្រុង ស្រុក ខណ្ឌ សហគមន៍ និងសាលារៀន។ អាទិភាពរយៈពេលមធ្យមគឺ ពង្រឹងស្ថាប័ន ដំណើរការ និងសមត្ថភាពរបស់ក្រសួង និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីបង្កើនការធ្វើវិមជ្ឈការការងារ និងការផ្ទេរអំណាចកាន់តែច្រើនដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ កម្រងសាលារៀន សាលារៀន និងសហគមន៍ក្នុងការកសាងផែនការ គ្រប់គ្រង ផ្តល់សេវា រាយការណ៍ និងពិនិត្យតាមដាន។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណុចដៅសំខាន់ៗសម្រាប់ថ្នាក់កណ្ដាល រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌមាន ដូចជា ៖

កែលម្អប្រព័ន្ធសម្របសម្រួលសម្រាប់ការកសាងផែនការ និងគ្រប់គ្រងថវិកា ដែលអាចព្យាករណ៍បាន រវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ។ ចំណុចដៅ ៖ ក្របខណ្ឌចំណាយរយៈពេលមធ្យមដែលឯកភាពក្នុងអនុស្សរណៈយោគយល់គ្នា និងក្រុមការងាររួមគ្នាដែលបានដំណើរការ

- កែលម្អប្រសិទ្ធផលរបស់ផ្នែកគោលនយោបាយ ផ្នែកផែនការ ផ្នែករាយការណ៍ និងផ្នែកតាមដានដំណើរការរបស់ក្រសួងនៅថ្នាក់កណ្ដាល រួមបញ្ចូលទាំងអង្គភាពគ្រប់គ្រងថវិកា។ ចំណុចដៅ ៖ អង្គភាព៨០%មានប្រសិទ្ធផល នៅចុងឆ្នាំ២០០៣
- ជំរុញដំណើរការឱ្យបានពេញលេញនូវការងារកសាងផែនការកម្មវិធី ការរាយការណ៍ និងការពិនិត្យតាមដាននៅតាមរាជធានី ខេត្ត។ ចំណុចដៅ ៖ អង្គភាព៨០%មានប្រសិទ្ធផល នៅត្រឹមឆ្នាំ២០០៣
- ជំរុញដំណើរការការិយាល័យអប់រំស្រុកឱ្យបានពេញលេញនូវការងារគ្រប់គ្រង និងការអនុវត្ត រួមបញ្ចូលទាំងអង្គភាពគ្រប់គ្រងថវិកាទាំង១៨៣។ ចំណុចដៅ ៖ អង្គភាព៨០ %មានប្រសិទ្ធផល នៅត្រឹមឆ្នាំ២០០៣។

ចំណុចដៅសំខាន់ៗសម្រាប់កម្រិតគ្រឹះស្ថាន និងសាលារៀន មានដូចជា ៖

- ជំរុញដំណើរការប្រព័ន្ធគ្រប់គ្រងសាលារៀនបានពេញលេញ លើការងារកសាងផែនការ និងអនុវត្តកម្មវិធី រួមបញ្ចូលទាំងកម្មវិធីចរន្ត និងកម្មវិធីមូលធន
- បង្កើនប្រសិទ្ធផលនៃការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ រួមបញ្ចូលទាំងតម្លាភាពនៃរបាយការណ៍ហិរញ្ញវត្ថុ កិច្ចការគណនេយ្យ និងសវនកម្ម
- កែលម្អយន្តការច្បាប់ និងបទបញ្ញត្តិ សម្រាប់អនុវត្តកម្មវិធីអាទិភាពមួយចំនួនរាប់ចាប់តាំងពីសាលារៀន គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ
- កែលម្អយន្តការរួមគ្នារវាងរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល សម្រាប់ការពិនិត្យឡើងវិញការបំពេញការងារ និងការពិនិត្យតាមដាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.២.៤. អាទិភាពគោលនយោបាយ និងចំណុចដៅ២០០១-២០០៥ ៖ ហិរញ្ញ- ប្បទានវិស័យអប់រំ

ទិសដៅគោលនយោបាយរយៈពេលវែងសម្រាប់ហិរញ្ញប្បទានវិស័យអប់រំ គឺធានាថា លទ្ធភាពក្នុងការចំណាយលើការសិក្សា ឬការបណ្តុះបណ្តាល មិនមែនជាឧបសគ្គសម្រាប់សិស្សមួយក្រុមណានោះទេ។

អាទិភាពគោលនយោបាយរយៈពេលមធ្យម គឺបង្កើនបរិមាណចំណាយលើវិស័យអប់រំ និងកាត់បន្ថយបន្ទុកចំណាយរបស់គ្រួសារក្រីក្របំផុត(ជាពិសេស នៅកម្រិតអប់រំមូលដ្ឋាន)។ វត្ថុបំណងគោលនយោបាយបន្ទាប់បន្សំ គឺផ្តល់អាហារូបករណ៍ដល់ក្រុមសិស្សគោលដៅដោយផ្អែកលើលទ្ធផលសិក្សា និងជាសិស្សមកពីគ្រួសារក្រីក្របំផុតសិក្សានៅថ្នាក់ក្រោយអប់រំមូលដ្ឋាន ខណៈដែលលើកទឹកចិត្តដល់ការចូលរួមកាន់តែខ្លាំងពីផ្នែកឯកជន ក្នុងការអប់រំមធ្យមសិក្សាទុតិយភូមិ ឧត្តមសិក្សា និងការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

គោលនយោបាយប្រតិបត្តិរយៈពេលមធ្យមបន្ទាប់បន្សំ គឺតម្រែតម្រង់ចំណែកចំណាយសាធារណៈ ឆ្ពោះទៅគាំទ្រការអប់រំមូលដ្ឋាន ស្របគ្នាជាមួយនឹងការកាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតានៅកម្រិតសិក្សានេះ។

គោលនយោបាយហិរញ្ញប្បទានសំខាន់ៗសម្រាប់ឆ្នាំ២០០១-២០០៥ មានដូចជា ៖

- បង្កើនចំណាយរបស់រាជរដ្ឋាភិបាលមកលើវិស័យអប់រំ រួមទាំងបង្កើនចំណែក និងបរិមាណចំណាយលើការអប់រំមូលដ្ឋាន
- កាត់បន្ថយការចូលរួម ដែលជាបន្ទុករបស់មាតាបិតាសិស្សនៅកម្រិតអប់រំមូលដ្ឋាន ស្របគ្នាជាមួយនឹងការបង្កើនចំណាយសាធារណៈ
- បង្កើនចំណាយសាធារណៈជាថវិកាចរន្តលើវិធានការនានា លើកកម្ពស់គុណភាព តាមរយៈបង្កើនចំណែកលើចំណាយប្រតិបត្តិ ដែលមិនមែនជាបៀវត្សឱ្យបានខ្ពស់ និងការបញ្ចេញសាច់ប្រាក់
- បន្តបង្កើនថវិកាគាំទ្រសាលារៀន និងគ្រឹះស្ថានសិក្សាសាធារណៈ ឱ្យស្របនឹងគោលការណ៍ណែនាំដែលបានឯកភាព សម្រាប់ការអភិវឌ្ឍសាលារៀន និងការថែទាំដែលជាអាទិភាព


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- បន្តផ្តល់ថវិកាសម្រាប់ចំណាយមូលធនអភិវឌ្ឍវិស័យអប់រំ ជាពិសេសផ្តល់សម្ភារៈរូបវន្តបន្ថែមដល់សាលាបឋមសិក្សានិងមធ្យមសិក្សា និងការអភិវឌ្ឍសមត្ថភាព
- ប្រើប្រាស់ថវិកាគាំទ្រ ដែលទទួលបានពីសហគមន៍អន្តរជាតិ ដើម្បីបំពេញកង្វះខាតដែលហួសពីលទ្ធភាពរបស់រដ្ឋាភិបាល និងចំណាយរបស់ផ្នែកឯកជន
- បង្កើនតម្លាភាពនៃចំណាយចរន្តនិងចំណាយមូលធន ដែលបានទទួលការគាំទ្រពីខាងក្រៅ តាមរយៈការប្រើប្រាស់ប្រព័ន្ធកសាងផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

## ២.២.៤. អាទិភាពជាយុទ្ធសាស្ត្រ ឆ្នាំ ២០០១-២០០៥

យុទ្ធសាស្ត្រទូលំទូលាយ គឺបង្កើនការប្រើប្រាស់ថវិកាអប់រំជាមធ្យោបាយក្នុងការអនុវត្តកំណែទម្រង់ប្រព័ន្ធអប់រំ ជាពិសេសលើគោលនយោបាយនិងយុទ្ធសាស្ត្រផ្តោតលើជនក្រីក្រ។

អាទិភាពជាយុទ្ធសាស្ត្រសំខាន់ៗ ក្នុងការធានាសមធម៌ទទួលបានការអប់រំកម្រិតមូលដ្ឋាន គឺកាត់បន្ថយចំណាយផ្ទាល់ និងចំណាយប្រយោលរបស់មាតាបិតាសិស្ស (ដែលជាឧបសគ្គចំណាយដ៏ចម្បងរបស់គ្រួសារក្រីក្រ) តាមរយៈការបង្កើនប្រាក់លើកទឹកចិត្តដល់គ្រូបង្រៀនផ្អែកលើការបំពេញការងារ។ យុទ្ធសាស្ត្រនេះត្រូវបានតាក់តែងឡើង ដើម្បីលុបបំបាត់ចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្សលើគ្រូបង្រៀន។ យុទ្ធសាស្ត្របន្ទាប់បន្សំគឺបង្កើនថវិកាដំណើរការសាលារៀន ជំនួសឱ្យវិភាគទានរបស់មាតាបិតាសិស្ស កែលម្អការគ្រប់គ្រងនៅកម្រិតរាជធានី ខេត្ត និងសាលារៀន។ យុទ្ធសាស្ត្រទាំងនេះនឹងជួយធានាឱ្យសិស្ស និងគ្រូបង្រៀនមានវត្តមានជាប់លាប់ អត្រាឡើងថ្នាក់ល្អប្រសើរ និងមានសម្ភារសិក្សាគ្រប់គ្រាន់សម្រាប់អប់រំកម្រិតមូលដ្ឋាន ដែលជាផ្នែកមួយនៃវិធានការលើកកម្ពស់គុណភាពអប់រំ។ យុទ្ធសាស្ត្របន្ទាប់បន្សំគឺចាត់វិធានការកែលម្អប្រសិទ្ធភាពក្នុងការពង្រាយបុគ្គលិក និងការប្រើប្រាស់សម្ភាររូបវន្តអប់រំឱ្យអស់លទ្ធភាព។

អាទិភាពជាយុទ្ធសាស្ត្រសំខាន់ៗ ក្នុងការកែលម្អប្រសិទ្ធភាពនិងគុណភាពអប់រំនៅកម្រិតអប់រំមូលដ្ឋានគឺ ធានាតុល្យភាពប្រកបដោយប្រសិទ្ធផល រវាងចំណាយចរន្តផ្តោតលើបៀវត្ស និងមិនមែនបៀវត្ស។

យុទ្ធសាស្ត្រឆ្លងវិស័យក្នុងការលើកកម្ពស់ការចូលរៀន និងលើកកម្ពស់គុណភាពអប់រំមានការកើនឡើង ប៉ុន្តែការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅមានកម្រិត។ យុទ្ធសាស្ត្រ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ទាប់បន្សំគឺបង្កើនឱកាសទទួលបានការអប់រំពីចម្ងាយ ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ឧទា. សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីចម្ងាយ) អនុវត្តកម្មវិធីសិក្សាកុំព្យូទ័រនៅតាមវិទ្យាល័យ និងគ្រឹះស្ថានសិក្សាថ្នាក់ក្រោយមធ្យមសិក្សា និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឱ្យបានញឹកញាប់ សម្រាប់ការចែករំលែកព័ត៌មានគ្រប់គ្រង និងការពិនិត្យតាមដាន។

អាទិភាពជាយុទ្ធសាស្ត្រមួយទៀត គឺចាត់វិធានការធានាឱ្យមានការកើនឡើងនូវភាពជាដៃគូសាធារណៈ និងឯកជននៅកម្រិតក្រោយអប់រំមូលដ្ឋាន ជាពិសេសនៅឧត្តមសិក្សា និងការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ អាទិភាពជាយុទ្ធសាស្ត្រ គឺផ្តល់ថវិកាដំណើរការដល់គ្រឹះស្ថានទាំងនោះ ផ្តល់ស្វ័យភាពប្រតិបត្តិកាន់តែច្រើន និងចាត់វិធានការពង្រឹងប្រសិទ្ធភាព អភិបាលកិច្ច និងការគ្រប់គ្រង។

អាទិភាពជាយុទ្ធសាស្ត្របន្ទាប់ទៀត គឺចាត់វិធានការអភិវឌ្ឍសមត្ថភាពដើម្បីធ្វើវិមជ្ឈការ ការគ្រប់គ្រងសេវាអប់រំ។ យុទ្ធសាស្ត្រជាមូលដ្ឋាន គឺអភិវឌ្ឍសមត្ថភាពប្រព័ន្ធកសាងផែនការ និងគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ជាជាងបង្កើតប្រព័ន្ធផ្សេងទៀតជាន់គ្នា។

អាទិភាពជាយុទ្ធសាស្ត្រចុងក្រោយ គឺផ្តោតចំណាយថវិកាមូលធនទៅលើការអនុវត្តកំណែទម្រង់កម្រិតគោលនយោបាយ។ អាទិភាពយុទ្ធសាស្ត្រចម្បង គឺជួសជុលសម្ភាររូបវន្តអប់រំដែលមានស្រាប់ និងពង្រីកសម្ភាររូបវន្តសម្រាប់សាលាបឋមសិក្សា និងមធ្យមសិក្សានៅតាមគោលដៅមួយចំនួន។ អាទិភាពបន្ទាប់បន្សំ គឺធ្វើវិនិយោគផ្នែកមូលធនក្នុងឧត្តមសិក្សា ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការលើកកម្ពស់គុណភាពការបណ្តុះបណ្តាលគ្រូបង្រៀន។

យុទ្ធសាស្ត្រហិរញ្ញប្បទានដ៏សំខាន់ គឺអនុវត្តនីតិវិធីហិរញ្ញវត្ថុចម្រុះរវាងរដ្ឋាភិបាល និងហិរញ្ញប្បទានពីខាងក្រៅប្រកបដោយប្រសិទ្ធផល ដែលនឹងធានាដល់ការអនុវត្តគ្រប់ចំណុចដៅគោលនយោបាយ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំបានកំណត់ថា ការគាំទ្រពីសំណាក់រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ នឹងរួមបញ្ចូលទាំងរូបភាពជាថវិកាគាំទ្រ ការវិនិយោគមូលធន និងកម្មវិធីអភិវឌ្ឍសមត្ថភាព ឆ្ពោះទៅអនុវត្តអាទិភាពគោលនយោបាយ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។

### *២.២.៥.១ ការធានាសមធម៌នៃការទទួលសេវាអប់រំ*

ផែនការយុទ្ធសាស្ត្រវិស័យអប់រំរួមមានយុទ្ធសាស្ត្រសំខាន់ៗបួន សម្រាប់ធានាសមធមិនៃការទទួលបានសេវាអប់រំ ដូចមានសង្ខេបជូនដូចតទៅ ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- យុទ្ធសាស្ត្រកាត់បន្ថយការចំណាយរបស់មាតាបិតាសិស្ស និងការរៀបចំលិខិតបទដ្ឋាននានាសម្រាប់ការអប់រំមូលដ្ឋាន ស្របគ្នានឹងការចូលរួមចំណែកចំណាយដែលបានកំណត់សម្រាប់សេវាក្រោយអប់រំមូលដ្ឋាន
- យុទ្ធសាស្ត្រលើកកម្ពស់ប្រសិទ្ធភាពផ្ទៃក្នុងនៅគ្រប់កម្រិត ដោយផ្តល់អាទិភាពសម្រាប់កែលម្អប្រសិទ្ធភាពពី ថ្នាក់ទី១ ដល់ទី៦
- ការអភិវឌ្ឍសម្ភារូបវន្តអប់រំដែលបានកំណត់ ដោយផ្តោតលើការធ្វើឱ្យសាលានានាមានគ្រប់ថ្នាក់ពីទី១ ដល់ទី៦ និងការពង្រីកការបើកថ្នាក់ទី៧ ដល់ទី១២ នៅតាមតំបន់ដែលបច្ចុប្បន្ននេះពុំទាន់មាន។

យុទ្ធសាស្ត្រ និងទិសដៅសំខាន់ៗក្នុងការកាត់បន្ថយការចំណាយរបស់មាតាបិតាសិស្ស និងការរៀបចំលិខិតបទដ្ឋានមានដូចតទៅ ៖

- ការកាត់បន្ថយការរួមចំណែកជាមធ្យមរបស់ឪពុកម្តាយសិស្ស សម្រាប់ការអប់រំមូលដ្ឋាន តាមរយៈការលុបបំបាត់វិភាគទាននៅដើមឆ្នាំសិក្សា និងការផ្តល់ថវិកាដំណើរការសាលារៀនពីរដ្ឋាភិបាល
- ការផ្តល់ប្រាក់ឧបត្ថម្ភ និងអាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្របំផុត ដែលបានកំណត់ សម្រាប់ការសិក្សានៅថ្នាក់ទី៤ ដល់ទី១២ ដោយផ្សារភ្ជាប់ទៅនឹងកម្មវិធីចូលរៀនឡើងវិញពីថ្នាក់ទី៤ ដល់ទី៦
- ការផ្តល់ប្រាក់ឧបត្ថម្ភ និងអាហារូបករណ៍ដល់សិស្សពូកែមកពីគ្រួសារក្រីក្របំផុតដែលរៀននៅគ្រឹះស្ថានឧត្តមសិក្សា និងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយប្រើប្រាស់លទ្ធផលប្រឡងនៅថ្នាក់ទី៩ និងទី១២
- ការផ្តល់ប្រាក់ឧបត្ថម្ភ និងអាហារូបករណ៍ដល់គរុនិស្សិត គរុសិស្សដែលរៀននៅសាលាបណ្តុះបណ្តាលគ្រូ ដោយផ្អែកលើការបង្កើនការប្រើប្រាស់លទ្ធផលប្រឡងនៅថ្នាក់ទី៩ និងទី១២។

យុទ្ធសាស្ត្រ និងចំណុចដៅសំខាន់ ៗ ក្នុងការបង្កើនប្រសិទ្ធភាពផ្ទៃក្នុង មានដូចតទៅ ៖

- បង្កើនអត្រាឡើងថ្នាក់ពីថ្នាក់ទី១ ដល់ទី៦ និងអត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី៦ ទៅទី៧ តាមរយៈការបំប៉នសិស្សខ្សោយពីថ្នាក់ទី១-៦ ការពង្រឹងវិធានការនានា ដើម្បីធ្វើឱ្យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វត្តមានគ្រូ និងសិស្សកាន់តែប្រសើរឡើង ព្រមទាំងអនុវត្តប្រតិទិនសិក្សាប្រចាំឆ្នាំឱ្យមានភាពទន់ភ្លន់

- កាត់បន្ថយអត្រាបោះបង់ការសិក្សាពីថ្នាក់ទី១ ដល់ទី១២ តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភនិងអាហារូបករណ៍ ចំពោះសិស្សក្រីក្របំផុត និងយុទ្ធសាស្ត្រលើកទឹកចិត្តមួយចំនួនដូចជា កម្មវិធីផ្តល់អាហារ និងការថែទាំសុខភាពនៅតាមសាលាក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត
- កែលម្អបទបញ្ញត្តិនៃការចូលរៀនថ្នាក់ទី១ និងបង្កើនឱកាសសម្រាប់ការចូលរៀនឡើងវិញដល់សិស្សបោះបង់ការសិក្សានៅថ្នាក់ទី៤ ដល់ទី៦ តាមរយៈការអនុវត្តការចូលរៀនត្រៀមបម្រុងមុនចូលថ្នាក់ទី១ នៅទូទាំងប្រទេស និងការពង្រីកកម្មវិធីទទួលសិស្សបោះបង់ឱ្យចូលរៀនជាថ្មីឡើងវិញ ។

យុទ្ធសាស្ត្រ និងចំណុចដៅសំខាន់ៗ ក្នុងការពង្រីកភាពជាដៃគូរវាងសាធារណៈ និងឯកជនមានដូចតទៅ ៖

- ការរៀបចំផែនការយុទ្ធសាស្ត្រ និង គោលនយោបាយឆ្លងវិស័យ សម្រាប់ភាពជាដៃគូ រវាងសាធារណៈ និងឯកជននៅក្នុងកម្មវិធីនិងអនុវិស័យនានា ដែលរួមមានមធ្យមសិក្សាទុតិយភូមិ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឧត្តមសិក្សា ការអភិវឌ្ឍនិងគាំពារកុមារតូច និងការអប់រំក្រៅប្រព័ន្ធ
- ការអនុវត្តកម្មវិធីលើកទឹកចិត្តដែលបានកំណត់ សម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលឯកជន ជាពិសេសការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការពង្រីកមូលនិធិបណ្តុះបណ្តាលថ្នាក់ជាតិ និងការប្រើប្រាស់មូលនិធិអភិវឌ្ឍដទៃទៀត
- ការលើកទឹកចិត្តក្នុងការពង្រីកផ្នែកឯកជននៅគ្រប់កម្រិត តាមរយៈការរៀបចំច្បាប់បទបញ្ញត្តិ និងការរៀបចំការធានាគុណភាពយ៉ាងច្បាស់លាស់
- ការអនុញ្ញាតឱ្យមានការផ្ទេរសិស្សរវាងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនតាមរយៈការទទួលស្គាល់សញ្ញាបត្រ និងការផ្ទេរក្រេឌីតរវាងគ្រឹះស្ថានសាធារណៈ និងឯកជន

- ការចាប់ផ្តើមឱ្យមានតំណាងក្នុងគណៈគ្រប់គ្រងនៅឧត្តមសិក្សា ទន្ទឹមនឹងការពង្រឹងបន្ថែមទៀតនូវក្រុមប្រឹក្សាផ្តល់យោបល់ផ្នែកឧស្សាហកម្ម សម្រាប់ការកសាងផែនការ និងរៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ។

យុទ្ធសាស្ត្រនិងចំណុចដៅសំខាន់ៗក្នុងការអភិវឌ្ឍសម្ភារបរិក្ខារអប់រំ ដែលបានកំណត់ទុកមានដូចតទៅ ៖

- ការផ្តល់បន្ទប់រៀនបន្ថែម ទន្ទឹមនឹងការអនុវត្តការបង្រៀនថ្នាក់គួបនៅតាមភូមិ ឃុំ ដែលពុំមានគ្រប់កម្រិតថ្នាក់នៅបឋមសិក្សា
- ការផ្តល់បន្ទប់រៀនបន្ថែម និងបន្ទប់ដែលអាចប្រើប្រាស់បានច្រើនយ៉ាង នៅតាមឃុំកម្រងសាលារៀន ដែលគ្មានសម្ភាររូបវន្តគ្រប់គ្រាន់សម្រាប់ថ្នាក់ទី៧-៩
- ការផ្តល់បន្ទប់រៀនបន្ថែមសម្រាប់ថ្នាក់ទី១-៦ ថ្នាក់ទី៧-៩ និង ថ្នាក់ទី១០-១២ ដល់សាលារៀននានា ដែលបច្ចុប្បន្ននេះ ឬតាមការគ្រោងទុកថា មានសិស្សច្រើនកុះករ
- ការបង្កើតមូលនិធិអភិវឌ្ឍសាលាមធ្យមសិក្សា ឧត្តមសិក្សា និងការអប់រំបណ្តុះ-បណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដែលនឹងឆ្លើយតបទៅនឹងតម្រូវការចូលរៀននៅមធ្យមសិក្សា ។

### ២.២.៥.២ *ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ*

ផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលរួមមានយុទ្ធសាស្ត្រសំខាន់ៗ ៥ សម្រាប់លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ មានសង្ខេបជូនដូចតទៅ ៖

- ការកែលម្អផលិតភាព និងប្រសិទ្ធភាពនៃសេវាអប់រំ
- ការធ្វើវិមជ្ឈការការគ្រប់គ្រង និងការកសាងផែនការប្រតិបត្តិរបស់សាលារៀននិងគ្រឹះស្ថានសិក្សា
- ការផ្គត់ផ្គង់សៀវភៅ និងសម្ភារសិក្សាប្រកបដោយចីរភាព
- ការធ្វើវិមជ្ឈការនៃការគ្រប់គ្រង និងការកសាងផែនការអភិវឌ្ឍគ្រូបង្រៀន
- ការកែលម្អការពិនិត្យតាមដានការសិក្សារបស់សិស្ស ការបំពេញការងាររបស់គ្រឹះស្ថាន និងសាលារៀន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យុទ្ធសាស្ត្រនិងចំណុចដៅចម្បងៗក្នុងការកែលម្អប្រសិទ្ធភាព និងផលិតភាពសេវាអប់រំមានដូចជា ៖

- ការកែលម្អប្រសិទ្ធភាពក្នុងការកសាងផែនការ និងការពង្រាយបុគ្គលិកបង្រៀននិងមិនបង្រៀន នៅសាលាបឋមសិក្សានិងមធ្យមសិក្សា តាមរយៈ (ក). ការពិនិត្យឡើងវិញនូវនិយាមប្រើប្រាស់បុគ្គលិកផ្អែកលើផលធៀបសិស្ស-គ្រូ ដែលមានការយល់-ព្រមពីរាជរដ្ឋាភិបាល (ខ). សេចក្តីណែនាំអំពីការប្រើប្រាស់បុគ្គលិកនៅតាមសាលារៀន (គ). ការពង្រឹងយន្តការក្នុងការអនុវត្តតាមនិយាម
- ការដាក់ពង្រាយបុគ្គលិកមិនបង្រៀនឱ្យទៅបង្រៀនវិញ ដោយកំណត់ប្រាក់គរុកោសល្យ ឱ្យគ្រូបង្រៀននៅតាមថ្នាក់ និងការលើកទឹកចិត្តផ្សេងៗទៀត
- ការដាក់ពង្រាយបុគ្គលិកមិនបង្រៀន និងបុគ្គលិកបង្រៀនពីសាលារៀនដែលលើសទៅកាន់សាលារៀនដែលខ្វះគ្រូ ដោយអនុវត្តតាមសេចក្តីណែនាំនៃការប្រើប្រាស់បុគ្គលិកដែលបានកែលម្អរួច
- ការបង្កើនការផ្តល់រង្វាន់ដល់អ្នកគ្រប់គ្រងអប់រំ គ្រូឧទ្ទេស និងបុគ្គលិកបង្រៀនទាំងអស់ ដោយគិតទាំងការដំឡើងប្រាក់បៀវត្សមូលដ្ឋានដល់មន្ត្រីរាជការស៊ីវិលព្រមទាំងការបង្កើនប្រាក់គរុកោសល្យ
- ការផ្តល់ប្រាក់លើកទឹកចិត្តផ្អែកលើការបំពេញការងារចំពោះក្រុមសំខាន់ៗ ដែលជាអ្នកគ្រប់គ្រងអប់រំ និងបុគ្គលិកបង្រៀន ជាពិសេសបុគ្គលិកដែលផ្តល់នូវប្រសិទ្ធភាពនិងផលិតភាពខ្ពស់
- ការពង្រឹងការវាយតម្លៃ និងបទបញ្ញត្តិស្តីពីស្តង់ដាអប្បបរមានៃការបំពេញការងារនិងបន្ទុកការងាររបស់បុគ្គលិក ទន្ទឹមនឹងការអភិវឌ្ឍយន្តការផ្តល់រង្វាន់លើកទឹកចិត្តនិងការដាក់ទណ្ឌកម្មសម្រាប់ពង្រឹងការអនុវត្ត ដោយមានការឯកភាពពីក្រុមប្រឹក្សាកែទម្រង់រដ្ឋបាល
- ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ ដើម្បីកំណត់ឱ្យបានច្បាស់អំពីគន្លងអាជីពសម្រាប់អ្នកគ្រប់គ្រងអប់រំ និងបុគ្គលិកបង្រៀន (ឧទា. ឋានៈក្នុងអប់រំ) ដែលជាមូលដ្ឋានសម្រាប់កសាងផែនការផ្គត់ផ្គង់និងតម្រូវការបុគ្គលិក ការបណ្តុះបណ្តាល និងកំណែទម្រង់បៀវត្ស។

យុទ្ធសាស្ត្រ និងចំណុចដៅចម្បងៗ ក្នុងការធ្វើវិមជ្ឈការការគ្រប់គ្រង និងការកសាងផែនការប្រតិបត្តិរបស់សាលារៀន និងគ្រឹះស្ថានសិក្សាមានដូចជា ៖

- ការកែលម្អដំណើរការសាលារៀន និងការចូលរួមរបស់គណៈកម្មការសាលារៀន និងមាតាបិតាសិស្ស នៅក្នុងថវិកាដំណើរការសាលាបឋមសិក្សានិងមធ្យមសិក្សា តាមរយៈការបែងចែកថវិកា PAP ដែលចាត់ចែងដោយការិយាល័យអប់រំស្រុក
- ការកែលម្អដំណើរការរបស់គ្រឹះស្ថានសិក្សា និងអង្គភាពគ្រប់គ្រងថវិការបស់គ្រឹះស្ថានឧត្តមសិក្សា ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍប្រចាំឆ្នាំ តាមរយៈយន្តការ PAP
- ការកែលម្អការគ្រប់គ្រង និងការកសាងផែនការប្រតិបត្តិផ្នែកបច្ចេកទេសនិងហិរញ្ញ-វត្ថុ នៅថ្នាក់ស្រុក តាមរយៈអង្គភាពគ្រប់គ្រងថវិកាស្រុក ដែលនឹងទទួលខុសត្រូវកាន់តែច្រើនចំពោះ PAP និងកម្មវិធីផ្សេងៗទៀត
- ការកែលម្អការពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន គ្រឹះស្ថានសិក្សានៅថ្នាក់ខេត្ត និងថ្នាក់កណ្តាល តាមរយៈស្តង់ដាដែលបានកំណត់ និងការបង្កើនថវិកាសម្រាប់ការពិនិត្យតាមដាន។

យុទ្ធសាស្ត្រនិងចំណុចដៅសំខាន់ៗ ក្នុងការផ្គត់ផ្គង់សៀវភៅ និងសម្ភារសិក្សាប្រកបដោយចីរភាព មានដូចជា ៖

- រាជរដ្ឋាភិបាលធានាចីរភាព ក្នុងការផ្តល់ថវិកាសម្រាប់សៀវភៅ និងសម្ភារសិក្សាតាមរយៈការពិនិត្យឡើងវិញ នូវកម្មវិធីសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាដែលឆ្លើយតបទៅនឹងការអភិវឌ្ឍសង្គម ពលរដ្ឋ និងសេដ្ឋកិច្ច និងដែលមានប្រសិទ្ធភាព។ ចំណុចដៅ ៖ ការកែលម្អគោលនយោបាយកម្មវិធីសិក្សា ដោយបញ្ចូលនូវមុខវិជ្ជាបំណិនជីវិត និងត្រូវបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០០៣
- ការផ្តល់សៀវភៅសិក្សាគោលប្រកបដោយសមធម៌ និងសៀវភៅអានបន្ថែមសម្រាប់ថ្នាក់ទី១-១២ ដោយប្រើប្រាស់ថវិកាជាតិ។ ចំណុចដៅ ៖ សៀវភៅមួយក្បាលសម្រាប់សិស្សម្នាក់ក្នុងមួយមុខវិជ្ជាចំពោះថ្នាក់ទី ១-៩ និងមួយក្បាលសម្រាប់សិស្ស ២ នាក់ ចំពោះថ្នាក់ទី១០-១២



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ការផ្តល់សម្ភារសិក្សាឱ្យបានគ្រប់គ្រាន់ដល់គ្រឹះស្ថានឧត្តមសិក្សា ការអប់រំបណ្តុះ-បណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ តាមរយៈយន្តការ និងចំណុចដៅរបស់ PAP ដែលបានឯកភាព

- ការធ្វើវិមជ្ឈការនៃការកសាងផែនការនិងការគ្រប់គ្រង ក្នុងការផ្តល់សៀវភៅសិក្សា និងសម្ភារសិក្សា តាមរយៈការផ្តល់ថវិកាប្រចាំឆ្នាំ ដល់សាលារៀនតាមរយៈយន្តការ PAP

- ការកែលម្អប្រសិទ្ធភាពក្នុងការបោះពុម្ព និងចែកផ្សាយសៀវភៅសិក្សានិងសម្ភារសិក្សាគោល តាមរយៈការបង្កើតគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ដែលជាសហ-គ្រាសសាធារណៈមានច្បាប់ បទបញ្ញត្តិ និងការគ្រប់គ្រងដ៏មានប្រសិទ្ធភាព

- ការធានាឱ្យមានការកែលម្អផលប៉ះពាល់ទៅលើគុណភាពបង្រៀននិងរៀន របស់សៀវភៅ និងសម្ភារសិក្សា តាមរយៈកម្មវិធីតម្រង់ទិសសៀវភៅសិក្សាប្រចាំឆ្នាំ និងពង្រឹងប្រព័ន្ធពិនិត្យតាមដាន ។

យុទ្ធសាស្ត្រនិងចំណុចដៅ ក្នុងការធ្វើវិមជ្ឈការការងារគ្រប់គ្រងនិងការកសាងផែនការអភិវឌ្ឍគ្រូបង្រៀនមានដូចជា ៖

- ការសម្របសម្រួលប្រព័ន្ធកសាងផែនការផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀន ដោយគិតគូរអំពីការកើនឡើងនូវចំនួនសិស្ស និងការកែលម្អគោលការណ៍ណែនាំក្នុងការបែងចែកគ្រូបង្រៀន តាមរយៈគណៈកម្មការបច្ចេកទេសថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលរួមមានសមាសភាពមកពី នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានផែនការ និងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ

- ការផ្ទេរសិទ្ធិអំណាចកាន់តែច្រើនដល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងអាជ្ញាធរខេត្ត ស្រុកក្នុងការគ្រោងបណ្តុះបណ្តាលគ្រូថ្មី ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា

- ការបង្កើនការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត រួមបញ្ចូលទាំងភាពទន់ភ្លន់ក្នុងការបណ្តុះ-បណ្តាលគ្រូបឋមសិក្សា គ្រូមធ្យមសិក្សាបឋមភូមិ និងគ្រូមធ្យមសិក្សាទុតិយភូមិ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការបង្កើនស្វ័យភាពប្រតិបត្តិការ ដល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនតាមរយៈការផ្តល់ថវិកាដំណើរការប្រចាំឆ្នាំ ផ្អែកលើចំនួនគរុសិស្ស និងនិយាមប្រើប្រាស់បុគ្គលិក

- ការកែលម្អគុណភាព និងការឆ្លើយតបនៃកម្មវិធីបណ្តុះបណ្តាលគ្រូគ្រប់កម្រិត និងគ្រប់ប្រភេទ តាមរយៈការកែទម្រង់ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងកម្មវិធីសិក្សា(ដូចជា ការបង្រៀនពហុមុខវិជ្ជា បង្រៀនថ្នាក់គួប បង្រៀនជនជាតិដើមភាគតិច និងបំណិនជីវិត) និង ទទួលស្គាល់ការអភិវឌ្ឍបុគ្គលិក

- ការធានាការផ្តល់គ្រូបង្រៀនគ្រប់គ្រាន់ដល់តំបន់ដាច់ស្រយាល និងតំបន់ជនជាតិភាគតិច តាមរយៈការជ្រើសរើសបេក្ខជនពីតំបន់ទាំងនោះ ដោយមានការលើកទឹកចិត្តពិសេស និងមានភាពទន់ភ្លន់ក្នុងការជ្រើសរើស និងរយៈពេលនៃការបណ្តុះ-បណ្តាល

- ការកែលម្អភាពឆ្លើយតបរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ លើតម្រូវការវិក្រឹតការគ្រូបង្រៀន តាមរយៈការបង្កើនស្វ័យភាពដំណើរការកម្មវិធី ឱ្យស្របទៅនឹងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា

- ការពង្រីកកម្មវិធីអភិវឌ្ឍ និងបណ្តុះបណ្តាលគ្រូបង្រៀននិងគ្រូជំនួយ សម្រាប់ឧត្តមសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅក្នុងប្រទេស។

យុទ្ធសាស្ត្រនិងចំណុចដៅ ក្នុងការកែលម្អការពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន គ្រឹះស្ថានសិក្សា និងការសិក្សារបស់សិស្សមានដូចជា ៖

- ការកំណត់ស្តង់ដាអប្បបរមាចំពោះលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី១-១២ ឱ្យបានរួចរាល់នៅដើមឆ្នាំ២០០២

- ការផ្សព្វផ្សាយឱ្យគ្រូបង្រៀន មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធដទៃទៀតឱ្យយល់ដឹងទាំងអស់គ្នាអំពីស្តង់ដាអប្បបរមា តាមរយៈកម្មវិធីផ្សព្វផ្សាយទូទាំងប្រទេស

- ការអនុវត្តតេស្តស្តង់ដាអប្បបរមា និង កែលម្អការប្រឡងនៅថ្នាក់ទី៤ ទី៦ ទី៩ និងទី១២

- ការបង្កើនប្រសិទ្ធភាពនៃគោលនយោបាយជ្រើសរើសបេក្ខជនចូលរៀននៅឧត្តមសិក្សា ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលគ្រូ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀន តាមរយៈបង្កើនការប្រើប្រាស់លទ្ធផលប្រឡងថ្នាក់ទី១២ សម្រាប់ពិនិត្យមើលលទ្ធភាពចូលរៀនរបស់បេក្ខជន

- ការបង្កើនប្រសិទ្ធភាពកសាងផែនការ ការគ្រប់គ្រងសាលារៀន និងការពិនិត្យតាមដានការសិក្សារបស់សិស្ស តាមរយៈការកំណត់ឱ្យច្បាស់លាស់អំពីតួនាទីរបស់អធិការនៅថ្នាក់ក្រសួង នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ និងការិយាល័យប្រឡង
- ការបង្កើនប្រសិទ្ធភាពក្នុងការកសាងផែនការ ការគ្រប់គ្រង និងការបំពេញការងាររបស់សាលារៀនជាប្រចាំ តាមរយៈការកំណត់ឡើងវិញនូវតួនាទីរបស់ប្រធានក្រុមបច្ចេកទេស និងអធិការថ្នាក់ខេត្ត អធិការថ្នាក់ស្រុក និងការបែងចែកថវិកាប្រចាំឆ្នាំសម្រាប់ការពិនិត្យតាមដាន
- ការបង្កើនតម្លាភាព និងគណនេយ្យភាពនៃការបំពេញការងាររបស់សាលារៀន និងការសិក្សារបស់សិស្ស តាមរយៈការផ្សព្វផ្សាយប្រចាំឆ្នាំនូវលទ្ធផលតេស្តស្តង់ដា និងការប្រឡង
- ការកែលម្អការរៀបចំអង្គភាព និងហិរញ្ញវត្ថុសម្រាប់ចាត់ចែងក្នុងសាលារៀន ការពិនិត្យតាមដានការសិក្សារបស់សិស្ស តាមរយៈកំណែទម្រង់ស្ថាប័នអង្គភាពថ្នាក់កណ្តាល
- ការរៀបចំស្តង់ដាថ្នាក់ជាតិ និងកែលម្អយន្តការវាយតម្លៃ និងការទទួលស្គាល់គុណភាព ដោយប្រើនូវគោលវិធីបណ្តុះបណ្តាលផ្អែកលើសមត្ថភាព(CBT) សម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- ការផ្តើមអនុវត្តយ៉ាងម៉ត់ចត់នូវយន្តការធានាគុណភាព និងអភិបាលកិច្ចនៅឧត្តមសិក្សា ។

### *២.២.៥.៣ ការអភិវឌ្ឍស្ថាប័ននិងកសាងសមត្ថភាពប្រកបដោយចីរភាពសម្រាប់ធ្វើវិមជ្ឈការ*

គោលដៅរយៈពេលវែងរបស់ក្រសួង គឺត្រូវផ្តល់លទ្ធភាពដល់សាលារៀនគ្រឹះស្ថានសិក្សា និងសហគមន៍ ឱ្យបញ្ចេញមតិនិងទទួលខុសត្រូវកាន់តែច្រើន ក្នុងការគ្រប់គ្រងនិងផ្តល់សេវាអប់រំ។ ពេលអនាគតខាងមុខ យន្តការគ្រប់គ្រងនិងចាត់ចែងសេវាអប់រំនឹងមាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សណ្ឋានជារចនាសម្ពន្ធរួមគ្នា ទាំងជារចនាសម្ពន្ធរដ្ឋបាលសាធារណៈ និងនយោបាយ កាន់តែច្បាស់ឡើង (ឧទា. តួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់)។

ដោយឡែក សមាសភាគនៃការកសាងសមត្ថភាពនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ស្របទៅនឹងអាទិភាពខ្ពស់នៃការពង្រឹងទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ ដោយផ្តោតលើការរៀបចំយន្តការបង្កើនគណនេយ្យទ្វេទិស និងអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន។ កិច្ចការនេះរួមបញ្ចូលទាំងសនិទានកម្មតួនាទីរបស់គណៈកម្មការទ្រទ្រង់សាលារៀន សមាគមមាតាបិតា គណៈកម្មការកម្រងសាលារៀន ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មការអភិវឌ្ឍភូមិ។ ការលើកកម្ពស់ទំនាក់ទំនងទាំងនេះ អាចនឹងដាក់ឱ្យអនុវត្តនៅក្នុងបរិបទដែលអាជ្ញាធររាជធានី ខេត្ត និងស្រុក ត្រូវបានកំណត់ឡើងវិញ។

នៅក្នុងបរិបទនេះ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ បញ្ចូលនូវយុទ្ធសាស្ត្ររយៈពេលមធ្យមសំខាន់ៗចំនួន៣ សម្រាប់អភិវឌ្ឍស្ថាប័ន និងលើកកម្ពស់ការកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ ដោយមានសង្ខេបដូចខាងក្រោម ៖

- ពង្រឹងប្រព័ន្ធកសាងផែនការ និងពិនិត្យតាមដានរបស់ថ្នាក់ក្រសួង និងថ្នាក់ខេត្ត
- លើកកម្ពស់ប្រព័ន្ធគ្រប់គ្រងការិយាល័យអប់រំស្រុក សាលារៀន និងគ្រឹះស្ថានសិក្សា
- កែលម្អក្របខណ្ឌគតិយុត្តិ និងអភិបាលកិច្ច។

យុទ្ធសាស្ត្រនិងចំណុចដៅសំខាន់ៗក្នុងការពង្រឹងប្រព័ន្ធកសាងផែនការ និងពិនិត្យតាមដានរបស់ថ្នាក់ក្រសួង និងថ្នាក់ខេត្ត មានដូចជា ៖

- ការកែលម្អការកសាងផែនការថវិការយៈពេលមធ្យម និងការធ្វើវិមជ្ឈការគ្រប់គ្រងថវិកា តាមរយៈការធានាពីរដ្ឋាភិបាល ចំពោះក្របខណ្ឌចំណាយរយៈពេលមធ្យម រួមបញ្ចូលទាំងការបង្កើតកម្មវិធីសកម្មភាពអាទិភាព និងកម្មវិធីថវិកាដទៃទៀត ព្រមទាំងចំណោលថវិកា
- ការកែលម្អកិច្ចសម្របសម្រួលនៅថ្នាក់កណ្តាល លើយុទ្ធសាស្ត្រនិងកម្មវិធីកសាងសមត្ថភាពប្រព័ន្ធអប់រំ តាមរយៈការពង្រឹងគណៈកម្មការជាតិសម្រាប់អភិវឌ្ឍការអប់រំចំណោះទូទៅ និងការបង្កើតគណៈកម្មការស្រដៀងគ្នានេះមួយសម្រាប់ការអប់រំក្រោយមធ្យមសិក្សា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការពង្រឹងការកសាងផែនការថវិកានិងផែនការយុទ្ធសាស្ត្រ និងការពិនិត្យតាមដាន នៅថ្នាក់កណ្តាលនិងថ្នាក់ខេត្ត តាមរយៈកម្មវិធីកសាងសមត្ថភាព ការផ្ទេរការទទួល-ខុសត្រូវអំពីការបែងចែកថវិកា PAP និងកម្មវិធីនានាទៅឱ្យថ្នាក់ខេត្ត និងគោល-ការណ៍ណែនាំ សម្រាប់ពិនិត្យតាមដានធាតុចេញ និងផលសម្រេចរបស់កម្មវិធី
- ការពង្រឹងការពិនិត្យតាមដានការបំពេញការងារ និងផលប៉ះពាល់របស់ប្រព័ន្ធ តាមរយៈការពិនិត្យឡើងវិញរួមគ្នារវាងរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ និងអ្នកពាក់ពន្ធ័ដទៃទៀត លើការបំពេញការងារប្រចាំឆ្នាំ ការឯកភាពលើសូចនាករបំពេញការងារសំខាន់ៗ និងផែនការការងារប្រចាំឆ្នាំសម្រាប់ការប្រមូល និងវិភាគទិន្នន័យ។

យុទ្ធសាស្ត្រនិងចំណុចដៅសំខាន់ៗ ក្នុងការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងការិយា-ល័យអប់រំស្រុក សាលារៀន និងគ្រឹះស្ថានសិក្សាមានដូចជា ៖

- ការពង្រឹងប្រព័ន្ធគ្រប់គ្រងកម្មវិធីរបស់ការិយាល័យអប់រំស្រុក និងសាលារៀន តាមរយៈការកសាងសមត្ថភាពដល់អង្គភាពគ្រប់គ្រងថវិកាស្រុក នាយកសាលារៀន និងសមាគមមាតាបិតាសិស្ស និងការកែលម្អគោលការណ៍ណែនាំគ្រប់គ្រងកម្មវិធីសកម្មភាពជាអាទិភាព
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ការអប់រំបណ្តុះបណ្តាលបច្ចេក-ទេសនិងវិជ្ជាជីវៈ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ តាមរយៈការកសាងសមត្ថភាពគ្រប់គ្រង ដោយផ្សារភ្ជាប់ជាមួយនឹងគោលការណ៍ណែនាំថ្មីរបស់កម្មវិធីសកម្មភាពអាទិភាព
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងបុគ្គលិកថ្នាក់ស្រុក និងថ្នាក់ខេត្ត តាមរយៈការដាក់ចេញនូវគោលការណ៍ណែនាំ និងនិយាមប្រើប្រាស់បុគ្គលិកថ្មី ការផ្តល់សិទ្ធិឱ្យថ្នាក់ស្រុកក្នុងការពង្រាយបុគ្គលិកឱ្យស្របទៅនឹងនិយាមទាំងនេះ និងការកសាងសមត្ថភាពដល់មន្ត្រីផែនការថ្នាក់ខេត្ត និងថ្នាក់ស្រុក។

យុទ្ធសាស្ត្រ និងចំណុចដៅសំខាន់ៗក្នុងការកែលម្អក្របខណ្ឌគតិយុត្តិ និងអភិបាលកិច្ចមានដូចជា ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការលើកកម្ពស់គណនេយ្យភាព តាមរយៈការកសាងច្បាប់ និងលិខិតបទដ្ឋានសម្រាប់បង្កើនស្វ័យភាពដំណើរការដល់សាលារៀន និងគ្រឹះស្ថានក្រោយមធ្យមសិក្សា
- ការបង្កើនតម្លាភាពក្នុងការប្រើប្រាស់វិភាគទានរបស់មាតាបិតាសិស្ស និងផ្នែកឯកជនរបស់សាលារៀន និងគ្រឹះស្ថានសិក្សាដទៃទៀតតាមរយៈការរៀបចំគោលការណ៍ណែនាំថ្មីស្តីពីការងារគណនេយ្យ និងការគ្រប់គ្រងប្រាក់វិភាគទានទាំងនេះ
- ការលើកកម្ពស់អភិបាលកិច្ចសាលារៀន និងគ្រឹះស្ថានក្រោយមធ្យមសិក្សាតាមរយៈការដាក់ចេញនូវគោលការណ៍ណែនាំ ដែលបានកំណត់អំពីអំណាច និងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងអប់រំ សហគមន៍ និងសមាគមមាតាបិតាសិស្ស។
- ការលើកកម្ពស់តម្លាភាពសេវាអប់រំ តាមរយៈកម្មវិធីព័ត៌មាន ការអប់រំ ការប្រាស្រ័យទាក់ទង ដែលផ្សព្វផ្សាយនៅទូទាំងប្រទេសស្តីពីព័ត៌មានសំខាន់ៗ ស្តីពីសមិទ្ធផលការងាររបស់ប្រព័ន្ធអប់រំនិងសាលារៀន។

## ២.២.៦. ក្របខណ្ឌចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំនិងចំណុចដៅបំពេញការងារ

### ២.២.៦.១ ចំណាយក្នុងវិស័យអប់រំ

*តារាងទី៩ ៖ ចំណាយរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំឆ្នាំ២០០១-២០០៥*

| | ២០០១ ជាក់ស្តែង (ឆ្នាំទី -១) | ២០០២ ជាក់ស្តែង (ឆ្នាំទី ០) | ២០០៣ ពិដានថវិកា (ឆ្នាំទី ១) | ២០០៤ ពិដានថវិកា (ឆ្នាំទី ២) | ២០០៥ ពិដានថវិកា (ឆ្នាំទី ៣) |
|---|---|---|---|---|---|
| ចំណាយរដ្ឋាភិបាល គិតជាលានរៀល | 229 653 | 286 200 | 333 366 | 399 651 | 461 131 |
| អត្រាកំណើន គិតជាភាគរយ | 35,2 | 24,6 | 16,5 | 19,9 | 15,4 |
| ធៀបនឹង ផ.ស.ស | 1,71 | 1,99 | 2,13 | 2,34 | 2,48 |
| គិតជាភាគរយនៃចំណាយចរន្ត | 16,2 | 18,2 | 18,5 | 19,5 | 20,0 |

*ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ, សីហា ២០០៨*

ចំណាយសាធារណៈសរុបសម្រាប់វិស័យអប់រំ គឺជាផលបូកថវិការបស់រដ្ឋាភិបាលជាមួយនិងការគាំទ្រជាគម្រោងនិងកម្មវិធីរបស់ដៃគូអភិវឌ្ឍ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងទី១០ ៖ គម្រោងចំណាយក្នុងវិស័យអប់រំ ២០០៣-២០០៥ (គិតជា ពាន់លានរៀល)*

| | ថវិកា ២០០១ | ថវិកា ២០០២ | MTEF ២០០៣ | MTEF ២០០៤ | MTEF ២០០៥ |
|---|---|---|---|---|---|
| **ចំណាយចរន្តសរុប** | **223 510** | **286 200** | **333 000** | **399 181** | **461 131** |
| **ចំណាយបុគ្គលិក (ជំពូក ១០)** | **136 100** | **150 040** | **180 925** | **220 781** | **261 231** |
| **មិនមែន កសអ (មិនមែនបុគ្គលិក)** | **59 030** | **61 105** | **58 875** | **65 000** | **66 000** |
| ជំពូក ១១ ចំណាយប្រតិបត្តិការ | 52 730 | 55 090 | 52 945 | | |
| ជំពូក ៣១ ទូទាត់សង្គមកិច្ច | 6 070 | 5 830 | 5 855 | | |
| ជំពូក ៣២ ទូទាត់អង្គការអន្តរជាតិ | 230 | 0,185 | 0 075 | | |
| **កម្មវិធីសកម្មភាពអាទិភាព (ជំពូក ១៣)** | **28 380** | **75 055** | **93 200** | **113 400** | **133 900** |
| ០១ ប្រសិទ្ធភាពសេវាអប់រំ | 0 | 11 200 | 13 200 | 14 500 | 15 500 |
| ០២ ប្រសិទ្ធភាពនិងគុណភាពបឋមសិក្សា | 23 814 | 24 000 | 26 000 | 30 000 | 35 400 |
| ០៣ ប្រសិទ្ធភាពនិងគុណភាពមធ្យមសិក្សា | 1 486 | 7 500 | 10 000 | 14 000 | 20 000 |
| ០៤ ប្រសិទ្ធភាពនិងគុណភាព TVET | 0 | 1 820 | 4 000 | 5 000 | 6 000 |
| ០៥ ប្រសិទ្ធភាពនិងគុណភាពឧត្តមសិក្សា | 2 100 | 2 100 | 3 000 | 4 000 | 5 000 |
| ០៦ ការបន្តអភិវឌ្ឍគ្រូបង្រៀន | 0 | 9 000 | 9 000 | 10 000 | 11 000 |
| ០៧ សម្ភារសិក្សាគោល | 0 | 14 000 | 15 000 | 18 400 | 21 000 |
| ០៨ ការពង្រីកអប់រំក្រៅប្រព័ន្ធ | 0 | 2 000 | 4 000 | 6 000 | 6 000 |
| ០៩ ការយល់ដឹងអំពីអេដស៍ក្នុងសាលារៀន | 0 | 600 | 1 350 | 1 500 | 1 500 |
| ១០ ការយល់ដឹងអំពីអេដស៍ក្រៅសាលារៀន | 980 | 400 | 1 150 | 1 500 | 2 000 |
| ១១ ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន | 0 | 2 435 | 3 500 | 3 500 | 3 500 |
| ១២ សមធម៌នៃការចូលរៀននិងអាហារូបករណ៍ | 0 | 0 | 3 000 | 5 000 | 7 000 |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ផ្អែកលើកញ្ចប់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលស្ថិតក្នុងក្របខណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០០៣-២០០៥ ក្រសួងបានបែងចែកធនធានថវិកាដ៏មានកម្រិតរបស់ខ្លួន ទៅតាមកម្មវិធីអាទិភាពមួយចំនួន ក្នុងគោលបំណងសម្រេចបានចំណុចដៅរយៈពេលមធ្យម ដូចខាងក្រោម ៖

*តារាងទី១១ ៖ សូចនាករបំពេញការងារនិងចំណុចដៅ ២០០៣-២០០៥*

| សូចនាករ | ឆ្នាំ ២០០៣ | ឆ្នាំ ២០០៤ | ឆ្នាំ ២០០៥ |
|---|---|---|---|
| *១. សមធម៌នៃការចូលរៀន* | | | |
| a. អត្រាពិតនៃការសិក្សា បឋមសិក្សា ទូទាំងប្រទេស (ភាគរយ) | 90 | 92 | 95 |
| b. អត្រាពិតនៃការសិក្សា បឋមសិក្សា ដាច់ស្រយាល (ភាគរយ) | 72 | 76 | 80 |
| c. អត្រាឡើងថ្នាក់ ទី១ ទី២ ទី៣ (ភាគរយ) | 84, 87, 86 | 86, 88, 87 | 88, 89, 88 |
| d. អត្រាពិតនៃការសិក្សា ម.បឋមភូមិ ដាច់ស្រយាល (ភាគរយ) | 6 | 10 | 15 |
| e. អត្រាពិតនៃការសិក្សា ម.ទុតិយភូមិ (ភាគរយ) | 10 | 11 | 15 |
| f. ការចូលរៀននៅ TVET សាធារណៈ | 9 410 | 9 710 | 10 110 |
| g. ការចូលរៀននៅ TVET ឯកជន | 15 000 | 17 000 | 19 000 |



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| | | | |
|---|---|---|---|
| *២. ប្រសិទ្ធភាពនិងគុណភាពអប់រំ* | | | |
| a. អត្រាត្រួតថ្នាក់ ទី១ ទី២ ទី៣ (ភាគរយ) | 8, 5, 5 | 7, 5, 5 | 6, 5, 5 |
| b. អត្រាឆ្លងភូមិសិក្សា បឋមសិក្សាទៅមធ្យសិក្សា (ភាគរយ) | 83 | 85 | 87 |
| c. ផលធៀបសិស្សគ្រូ បឋមសិក្សា | 53 | 52 | 51 |
| d. ផលធៀបសិស្សគ្រូ ម.បឋមភូមិ | 20 | 23 | 26 |
| e. ផលធៀបសិស្សគ្រូ ម.ទុតិយភូមិ | 26 | 27 | 28 |
| f. ភាគរយបុគ្គលិកបង្រៀនធៀបបុគ្គលិកសរុប | 18 | 17 | 16 |
| g. ចំណាយលើសៀវភៅសិក្សាគោលក្នុងសិស្សម្នាក់ (រៀល) | 5 200 | 5 700 | 5 800 |
| *៣. កែលម្អការគ្រប់គ្រងនិងវិមជ្ឈការសេវាអប់រំ* | | | |
| a. ចំណែកថវិកាអប់រំធៀបថវិកាចរន្តរបស់រដ្ឋាភិបាល (ភាគរយ) | 18,5 | 19,5 | 20 |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

## ២.២.៦.២ *សូចនាករសមិទ្ធកម្មនៃវិស័យនិងនិន្នាការ*

ក្នុងឆ្នាំ២០០១-២០០២ ចំនួនកុមារចូលរៀនថ្មីថ្នាក់ទី១ បានកើនឡើង ដែលក្នុងនោះក៏មានកុមារលើសអាយុ ៦ ឆ្នាំច្រើននាក់ផងដែរ។ ឆ្នាំ២០០២-២០០៣ និន្នាការនេះមានការថយចុះ។ អត្រាពិតចូលរៀនថ្មីបានកើនឡើងពី ៨១% ក្នុងឆ្នាំ២០០១-២០០២ ដល់ ៩២% ក្នុងឆ្នាំ២០០២-២០០៣ ក្នុងនោះសិស្សស្រីកើនពី ៨០% ដល់ ៨៩%។ បរិមាណសិស្សចូលរៀនថ្មីថ្នាក់ទី១ បានថយចុះ ២០%ពីចំនួន ៦៤៦ ០០០ នាក់ ក្នុងឆ្នាំ ២០០១-២០០២ មកនៅត្រឹម ៥១៦ ០០០ នាក់ ក្នុងឆ្នាំ២០០២-២០០៣។

*រូបភាពទី១ ៖ ចំនួនសិស្សចូលរៀននៅបឋមសិក្សា*




*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ការពង្រីកការអប់រំកុមារតូចគឺជាយុទ្ធសាស្ត្រសំខាន់មួយ ដើម្បីដោះស្រាយបញ្ហាកុមារចូលរៀនលើសអាយុនៅបឋមសិក្សា និងកាត់បន្ថយការរៀនត្រួតថ្នាក់នៅថ្នាក់ទី១ និងទី២ និងការបោះបង់ការសិក្សានៅថ្នាក់ទី៤ ដល់ទី៦។ ជាងនេះទៀត ក្រសួងបន្តផ្តល់ និងសម្របសម្រួលការពង្រីកកម្មវិធីថ្នាក់អក្ខរកម្មនិងថ្នាក់ក្រោយអក្ខរកម្ម ដោយមានសិស្សចូលរៀនថ្នាក់អក្ខរកម្មប្រមាណ ៧១ ០០០ នាក់ និងក្រោយអក្ខរកម្ម ៨២ ០០០ នាក់។ ចំពោះសិស្សអក្ខរកម្មដែលមានវ័យចំណាស់ អាចមានលទ្ធភាពទទួលបានការបណ្តុះ-បណ្តាលជំនាញខ្លីៗ។

ការដោះស្រាយបញ្ហាសាលារៀនមិនគ្រប់កម្រិត គឺជាអាទិភាពខ្ពស់មួយរបស់ក្រសួង ក្នុងការសម្រេចបានសកលកម្មបឋមសិក្សា។ ការវិភាគបានបង្ហាញថា សេវាអប់រំបឋមសិក្សាដែលមានមិនគ្រប់កម្រិតថ្នាក់ ធ្វើឱ្យការបោះបង់សិក្សាមានកម្រិតខ្ពស់ ដោយសារកុមារជួបការលំបាកក្នុងការធ្វើដំណើរទៅសាលារៀន។

*២.២.៦.២.១ និន្នាការនៃការចុះឈ្មោះចូលរៀនក្នុងគ្រឹះស្ថានមធ្យមសិក្សា*

អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ សម្រេចបានទាបជាងចំណុចដៅទាំងនៅកម្រិតទូទាំងប្រទេស តំបន់ប្រជុំជន ជនបទ និងដាច់ស្រយាល។ ក្នុងឆ្នាំ២០០២-២០០៣ អត្រានេះស្មើនឹង ២០% ធៀបនឹងចំណុចដៅ ២៥%។ ជារួម អត្រាពិតនៃការសិក្សាបានកើនឡើង តែ ១%ប៉ុណ្ណោះធៀបនឹងឆ្នាំ២០០១-២០០២។ ទោះជាយ៉ាងណា ចំនួនសិស្សចូលរៀននៅថ្នាក់ទី៧ ដល់ទី៩ បានកើនឡើង ១៨%គឺកើនពីប្រមាណ ៣៥២ ០០០ នាក់ក្នុងឆ្នាំ២០០១-២០០២ ដល់ ៤១៦ ០០០ នាក់ក្នុងឆ្នាំ២០០២-២០០៣។ ចំនួនសិស្សស្រីបានកើនឡើងប្រមាណ ៣១ ០០០ នាក់ និងសិស្សប្រុសកើន ៣៤ ០០០ នាក់ ក្នុងរយៈពេលដូចគ្នា។

គេអាចសន្និដ្ឋានបានពីរចំណុចចេញពីនិន្នាការកំណើនខាងលើ។ *ទី១ ការលុបចំបាត់ការយកកម្រៃនៅដើមឆ្នាំសិក្សា មានផលប៉ះពាល់ជាវិជ្ជមានចំពោះផ្នែកតម្រូវការ ដែលកំពុងមានការកើនឡើង។ ទី២ តួលេខឆ្នាំមូលដ្ឋាននៃចំនួនសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងឆ្នាំសិក្សា១៩៩៩–២០០០ មានកម្រិតទាប ទើបធ្វើឱ្យមើលឃើញអត្រាកំណើនខ្លាំង។*

អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ មិនបានសម្រេចតាមចំណុចដៅដែលបានកំណត់ ជាក់ស្តែងអត្រាពិតនៃការសិក្សាសរុបស្មើនឹង ៧% ធៀបនឹងចំណុចដៅ ១០%។ ទោះយ៉ាងណា ចំនួនសិស្សចូលរៀននៅថ្នាក់ទី១០-១២ សរុបបានកើនឡើងពី ១០៥ ០០០ នាក់ នៅឆ្នាំ២០០០-២០០១ ដល់ ១២៨ ០០០ នាក់នៅឆ្នាំ២០០២-២០០៣ (កើនឡើងប្រហែល ២២%)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*២.២.៦.២.២ និន្នាការនៃការចូលរៀនភូមិសិក្សាក្រោយមធ្យមសិក្សា*

នៅឧត្តមសិក្សា ចំនួននិស្សិតមានបរិមាណខ្ពស់ជាងចំណុចដៅ។ និស្សិតប្រមាណ ៥១ ០០០ នាក់បានចូលសិក្សា ធៀបនឹងចំណុចដៅ២៨ ០០០ នាក់។ ចំនួននិស្សិតសិក្សាបង់ថ្លៃទាំងនៅក្នុងគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជន បានកើនឡើងពី ៣២ ០០០ នាក់ក្នុងឆ្នាំ២០០១-២០០២ ដល់៤៣ ០០០ នាក់ក្នុងឆ្នាំ២០០២-២០០៣(ខ្ពស់ជាងចំណុចដៅ១០០%)។ ចំនួននិស្សិតអាហារូបករណ៍មានបរិមាណស្មើនឹងចំណុចដៅក្នុងចន្លោះពី ៧ ០០០ នាក់ទៅ ៨ ០០០ នាក់។ ប្រការនេះបង្ហាញថា តម្រូវការសេវាអប់រំនៅកម្រិតឧត្តមសិក្សាកើនឡើងក្នុងនោះកំណើនខ្លាំងនៅតាមគ្រឹះស្ថានបង់ថ្លៃ។ ទោះជាយ៉ាងណា កត្តាវិសមភាពបានកើតមានឡើង ក្នុងការទទួលបានសេវាអប់រំនៅកម្រិតនេះ។ និស្សិតភាគច្រើនមានប្រភពមកពីរាជធានីភ្នំពេញ ឬតំបន់ប្រជុំជននៃបណ្តាខេត្តនានា។ និស្សិតស្រីមានសមាមាត្រទាបនៅឡើយ ដោយសារអ្នកដែលបានចូលរៀន និងមានលទ្ធភាពប្រឡងជាប់ថ្នាក់ទី១២ មានកម្រិតទាប ព្រមទាំងកង្វះអន្តេវាសិកដ្ឋាននៅឧត្តមសិក្សាផងដែរ។

ដោយសារអ្នកផ្តល់សេវាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាលមានច្រើនសណ្ឋាន ធ្វើឱ្យមានការពិបាកក្នុងការប៉ាន់ស្មានចំនួនអ្នកសិក្សាពិតប្រាកដ។ ចំនួនអ្នកសិក្សានៅតាមគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈសាធារណៈមានលក្ខណៈថេរក្នុងរង្វង់ ៥ ៥០០ នាក់ទៅ ៦ ០០០ នាក់ និងប្រមាណ ៨០ ០០០ នាក់នៅក្នុងផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល (សមមូលពេញម៉ោង ៥០ ០០០ នាក់)។

### *២.២.៦.៣ សូចនាករកែលម្អគុណភាពនិងនិន្នាការ*

វិធានការនានាដើម្បីធានាឱ្យមានការចូលរួមពីសហគមន៍ក្នុងកិច្ចការរបស់សាលារៀន រួមបញ្ចូលទាំងព័ត៌មានស្តីពីការសិក្សារបស់សិស្ស។

## ***<u>កត្តាសំខាន់ៗក្នុងការកែលម្អគុណភាពអប់រំ</u>***

*ការស្រាវជ្រាវបឋមរបស់ BETP និង EQIP ក្នុងរយៈពេល៣ឆ្នាំ បានស្នើឡើងនូវកត្តាសំខាន់ៗមួយចំនួន ដែលមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងការកែលម្អគុណភាព និងស្តង់ដាបឋមសិក្សា ដូចខាងក្រោម ៖*

- *លទ្ធភាពទទួលបានសម្ភារសិក្សា រួមទាំងសៀវភៅសម្រាប់សិស្ស និងសៀវភៅគ្រូ*
- *វិធានការធានាការប្រើប្រាស់សម្ភារសិក្សាឱ្យអស់លទ្ធភាព រួមទាំងកម្មវិធីតម្រង់ទិស គ្រូបង្រៀន និងកិច្ចការផ្ទះ*
- *កម្រិតចំណេះដឹង និងវិជ្ជាជីវៈរបស់គ្រូបង្រៀន ក្រៅពីចំនួនឆ្នាំនៃបទពិសោធការងារ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- *ការគ្រប់គ្រងសាលារៀនជាប្រព័ន្ធ ជាពិសេសការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងអធិការកិច្ចគ្រូបង្រៀន*
- *វិធានការធានាឱ្យមានការចូលរួមពីសហគមន៍ក្នុងកិច្ចការរបស់សាលារៀន រួមទាំងព័ត៌មានស្តីពីការសិក្សារបស់សិស្ស*

សូចនាករតំណាងមួយចំនួនបានបង្ហាញថា ក្រសួងបានខិតខំបង្កើនគុណភាពអប់រំ។ ជាក់ស្តែង ក្នុងឆ្នាំ២០០២ ថវិកា ១៥ ពាន់លានរៀលបានចំណាយសម្រាប់ការទិញសម្ភារសិក្សា ពោលគឺកើន ៧% ធៀបនឹងឆ្នាំមុន។ សៀវភៅសិក្សាគោលប្រមាណ ៥,៥ លានក្បាល ត្រូវបានចែកចាយនៅក្នុងឆ្នាំ២០០២-២០០៣ ដើម្បីរក្សាបានផលធៀបសិស្សម្នាក់ទទួលបានសៀវភៅ១សម្រាប់ នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

ប្រសិទ្ធភាព និងគុណភាពនៃការបង្រៀនក៏បានកែលម្អ។ ចំនួនគ្រូបឋមសិក្សាដែលឆ្លងកាត់ការបណ្តុះបណ្តាលបានកើនឡើងពី ៤២ ០០០ នាក់ក្នុងឆ្នាំ១៩៩៩-២០០០ ដល់ ៤៧ ០០០ នាក់ក្នុងឆ្នាំ២០០២-២០០៣។ ចំនួនគ្រូមធ្យមសិក្សាដែលឆ្លងកាត់ការបណ្តុះបណ្តាលបានកើនឡើងពី ១៧ ៨០០ នាក់ ដល់ ២២ ៧០០ នាក់ក្នុងរយៈពេលដូចគ្នាស្របជាមួយគ្នានឹងការកើនឡើងចំនួនគ្រូបង្រៀន ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងបរិញ្ញាបត្រផងដែរ។

*តារាងទី១២ ៖ ចំនួនគ្រូបឋមសិក្សាមានកម្រិតនៃការអប់រំ និងទីកន្លែងបម្រើការងារ ២០០២–២០០៣*

| ទីកន្លែង | បឋមសិក្សា | បឋមសិក្សា % | មធ្យមសិក្សា | មធ្យមសិក្សា % | បរិញ្ញាបត្រ | បរិញ្ញាបត្រ % |
|---|---|---|---|---|---|---|
| តំបន់ប្រជុំជន | 412 | 4% | 9 793 | 95% | 94 | 1% |
| តំបន់ជនបទ | 2 571 | 7% | 34 333 | 93% | 13 | 0% |
| តំបន់ដាច់ស្រយាល | 574 | 48% | 616 | 52% | 1 | 0% |

ក្រសួងកំពុងចាត់វិធានការដោះស្រាយវិសមភាពក្នុងការពង្រាយគ្រូបង្រៀន ដែលមានសមត្ថភាព ជាពិសេសក្នុងតំបន់ដាច់ស្រយាល។ តារាងទី១២ បានបង្ហាញថា គ្រូបង្រៀននៅតំបន់ដាច់ស្រយាលភាគច្រើនបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា។ ក្រសួងបន្តផ្តល់ប្រាក់លើកទឹកចិត្តដល់គ្រូបង្រៀន ដែលស្ម័គ្រចិត្តទៅបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក (ឆ្នាំ២០១៣ បានគ្រោងផ្តល់ការឧបត្ថម្ភដល់គ្រូបង្រៀន ១៦ ៥០០ នាក់)។ បន្ថែមពីនេះទៀត ក្នុងឆ្នាំ២០០២-២០០៣ គរុសិស្សប្រមាណ ១ ៥០០ នាក់ (ត្រូវជា ២៥%) ត្រូវបានជ្រើសរើសចេញពីតំបន់ដាច់ស្រយាល បន្ទាប់មកត្រូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចាត់តាំងឱ្យទៅបម្រើការនៅតំបន់ទាំងនោះវិញបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល។ គេរំពឹងទុកថា ការគាំទ្រដែលមាននិរន្តរភាព ស្របជាមួយនឹងការពង្រឹងការពិនិត្យតាមដានការបំពេញការងារនៅឆ្នាំ២០០៣ នឹងរួមចំណែកកែលម្អគុណភាពអប់រំ ក្នុងពេលយូរអង្វែង។

ការវិភាគនិន្នាការលទ្ធផលប្រឡងថ្នាក់ទី១២ មានបញ្ហាដោយសារតែការកំណត់ឡើងវិញនូវស្តង់ដាចំណាត់ថ្នាក់ក្នុងឆ្នាំ២០០១-២០០២។

*តារាងទី១៣ ៖ លទ្ធផលប្រឡងថ្នាក់ទី១២ ឆ្នាំសិក្សា ២០០០–២០០១ និង ២០០១–២០០២*[194]

| លទ្ធផលប្រឡងថ្នាក់ទី១២ ឆ្នាំ ២០០២ | | | លទ្ធផលឆ្នាំ ២០០១ | |
|---|---|---|---|---|
| ចំនួនបេក្ខជនសរុប | 47 122 | - | 29 645 | - |
| ចំនួនបេក្ខជននារី | 15 722 | 33.36% | 9 677 | 32,64% |
| ចំនួនបេក្ខជនប្រឡងជាប់ | 18 767 | 39.83% | 19 749 | 66,66% |
| ចំនួនបេក្ខជនប្រឡងជាប់ ជានារី | 7 233 | 46.01% | 7 231 | 74,72% |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

រាជរដ្ឋាភិបាលបានអនុម័តព្រះរាជក្រឹត្យ ដែលកំណត់គោលការណ៍លើកកម្ពស់ការធានាគុណភាពអប់រំ និងការពិនិត្យតាមដានទាំងនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន។ គេរំពឹងទុកថា ការរៀបចំស្ថាប័ននឹងត្រូវធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០០៣ ដើម្បីអនុវត្តរាជក្រឹត្យនេះ។

## ២.២.៧. ចំណាយវិស័យអប់រំ

### *២.២.៧.១ ការពង្រឹងភាពជាដៃគូក្នុងកំណែទម្រង់វិស័យអប់រំ*

ក្រសួងអប់រំ យុវជន និងកីឡាជោគជ័យក្នុងការបន្តពង្រឹងដំណើរការក្នុងរូបភាពជាដៃគូ ទាក់ទងនឹងការងារហិរញ្ញប្បទានវិស័យអប់រំ។ ក្រសួងមានឱកាសជាច្រើនក្នុងការពង្រឹងទំនាក់ទំនងរវាងកំណែទម្រង់ហិរញ្ញប្បទានអប់រំ ជាមួយនឹងកំណែទម្រង់ថវិកាដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

វឌ្ឍនភាពសម្រេចបានរួមបញ្ចូលទាំងវិធានការកែលម្អទំនាក់ទំនង រវាងការកសាងផែនការបុគ្គលិក ការកសាងផែនការហិរញ្ញវត្ថុនិងការធ្វើថវិកា ការរៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យម និងការរៀបចំថវិកាប្រចាំឆ្នាំ។ វឌ្ឍនភាពតិចតួចមានដូចជាការឯកភាពលើកាលវិភាគការងារ ការកែលម្អផែនការហិរញ្ញវត្ថុរបស់វិស័យ ការបែងចែកថវិកាសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន។ល។

[194] ប្រភព ៖ ការិយាល័យប្រឡងនៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.២.៧.២ បម្រែបម្រួលការបែងចែកថវិកានិងចំណែកថវិកា ១៩៩៩-២០០៣

### ២.២.៧.២.១ ហិរញ្ញប្បទានវិស័យអប់រំ និងនិន្នាការថវិកា ១៩៩៩-២០០៣

រយៈពេល៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានបន្តអនុវត្តគោលនយោបាយបែងចែកឡើងវិញនូវហិរញ្ញវត្ថុសាធារណៈដោយបន្ថយចំណាយលើវិស័យការពារជាតិនិងសន្តិសុខ និងផ្តោតលើវិស័យអាទិភាព។ វឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការធានាបង្កើនធនធាន និងអាចព្យាករណ៍បានសម្រាប់វិស័យអប់រំ។

វិស័យអាទិភាពទាំង៤ បន្តទទួលបានកំណើនពីការបែងចែកថវិកា។ ចំណែកថវិកាអប់រំមានភាពសមស្របទៅនឹងចំណុចដៅដែលបានឯកភាពគ្នារវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍ លើកលែងតែក្នុងឆ្នាំ២០០៣ ដែលបានធ្លាក់ចុះទាប (១៨,៣%ធៀបនឹងចំណុចដៅ ១៨,៥%)។

ទោះបីជាយ៉ាងណា ក្រសួងទទួលបានការធានាថា បរិមាណធ្លាក់ចុះនៅឆ្នាំ២០០៣ នឹងត្រូវរ៉ាប់រងដោយថវិកាបម្រុង។ ជាភស្តុតាងបញ្ជាក់ថា ហិរញ្ញប្បទានវិស័យអប់រំគឺជាអាទិភាពខ្ពស់មួយ ក្នុងថវិការបស់រាជរដ្ឋាភិបាល។ យើងឃើញថា ការចំណាយលើវិស័យអប់រំរបស់រដ្ឋាភិបាលមានការកើនឡើងប្រហែល៣ដងក្នុងអំឡុងឆ្នាំ១៩៩៧ ដល់២០០២ (កើនពី ៧ ៨៥៦ រៀលដល់ ២១ ៦២០ រៀល)។

*រូបភាពទី ២ ៖ ចំណែកហិរញ្ញប្បទានរាជរដ្ឋាភិបាលសម្រាប់វិស័យអាទិភាព (២០០០-២០០៥)*[195]




*ប្រភព ៖* MEF (2003) Medium-term Expenditure Frame Look

---

[195] ប្រភព ៖ MEF TOFE for outturn 2000-1; RGC Budget laws for budgets 2002-03; MTEF presented at CG meeting Jan 2003 for projections 2004-05.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*២.២.៧.២.២ និន្នាការនៃការវិភាជថវិកាចរន្តសម្រាប់វិស័យអប់រំ*

ក្រសួងបានបន្តទទួលភាពអំណោយផល ក្នុងការបង្កើនការវិភាជថវិកា ដើម្បីបន្តផ្តោតលើអាទិភាពគោលនយោបាយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ តាមរយៈការបង្កើនថវិកាកម្មវិធីសកម្មភាពអាទិភាព(តារាងទី១៤)។

*តារាងទី១៤ ៖ ការបែងចែកថវិកាចរន្តសម្រាប់វិស័យអប់រំ(២០០០-២០០៦) គិតជាពាន់លានរៀល*[196]

| | ថវិកា ២០០០ | ថវិកា ២០០១ | ថវិកា ២០០២ | ថវិកា ២០០៣ | (MTEF ពាក់កណ្តាលឆ្នាំ ២០០២) | | |
|---|---|---|---|---|---|---|---|
| | | | | | គម្រោង ២០០៤ | គម្រោង ២០០៥ | គម្រោង ២០០៦ |
| ចំណាយចរន្តសរុប | 183,2 | 223,5 | 286,2 | 323,0 | 390,9 | 445,9 | 503,3 |
| បៀវត្សនិងប្រាក់កម្រៃ (ជំពូក ១០) | 126,2 | 136,1 | 150,0 | 180,9 | 212,5 | 246,4 | 275,5 |
| មិនមែន PAP មិនមែនបៀវត្ស | 47,0 | 59,0 | 61,1 | 51,6 | 65,0 | 66,0 | 67,0 |
| កម្មវិធីសកម្មភាពអាទិភាព (ជំពូក ១៣) | 10,0 | 28,4 | 75,1 | 90,5 | 113,4 | 133,5 | 160,8 |
| ពិដាន MTEF (មករា ២០០៣) | | | | | 399,7 | 461,1 | |
| កង្វះខាតធនធាន | | | | | 8,8 | 15,3 | |

*ប្រភព ៖* MEF (2003), Medium-term Expenditure Frame Look

ក្នុងឆ្នាំ២០០៣ កម្មវិធីអាទិភាពទទួលបានថវិកា២៨% នៃថវិកាចរន្តរបស់អប់រំ ស្របនឹងចំណុចដៅ។ ថវិកាបន្ថែមក្នុងឆ្នាំ២០០៣ បានផ្តោតលើ ៖

- ការបង្កើនថវិកាសម្រាប់កម្មវិធីប្រសិទ្ធភាព និងគុណភាពសាលាបឋមសិក្សានិងមធ្យមសិក្សា
- ការអនុវត្តកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ
- ការបន្តកំណែទម្រង់បុគ្គលិក ដោយគិតគូរអំពីតម្រូវការផ្ទេរហិរញ្ញវត្ថុសម្រាប់ពង្រាយគ្រូបង្រៀនបន្ថែមទៀតទៅកាន់តំបន់ជនបទ និងដាច់ស្រយាល
- ការរក្សាទុកហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ សម្រាប់គាំទ្រដល់វិធានការលើកកម្ពស់គុណភាព
- ការពង្រីកកម្មវិធីអក្ខរកម្ម និងកម្មវិធីចូលរៀនឡើងវិញ ផ្តោតលើជនក្រីក្រ
- ការផ្តល់ហិរញ្ញវត្ថុសម្រាប់ការពិនិត្យតាមដាន និងសវនកម្មផ្ទៃក្នុង។

[196] ប្រភព ៖ Budget 2003 and projections for 2004-06 as in MoEYS submission of PAP 2003-06 framework to MoEF (March 2003). Plan ceilings 2004-05 based on MoEF indicators June 2002 (lower than MTEF ceilings in MoEF presentation to CG mid-year meeting Jan 2003).



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២.២.៧.៣ ថវិកា និងអត្រាដកសាច់ប្រាក់កម្មវិធីសកម្មភាពអាទិភាពឆ្នាំ២០០២

ការដកសាច់ប្រាក់កម្មវិធីសកម្មភាពអាទិភាពជុំដំបូងត្រូវបានអនុម័ត នៅខែមិថុនា ឆ្នាំ២០០២។ ទោះជាយ៉ាងណា ការអនុវត្តថវិកានេះមិនបានចាប់ផ្តើមនោះទេ រហូតទាល់តែក្របខណ្ឌគតិយុត្តិ សម្រាប់គាំទ្រដល់ការចំណាយត្រូវបានបញ្ចប់។ សាច់ប្រាក់សរុបដែលបានដកចេញពីរតនាគារជាតិ និងរតនាគារនៅតាមរាជធានី ខេត្ត (ត្រឹមថ្ងៃទី៥ ខែឧសភា) ដែលអង្គភាពគ្រប់គ្រងថវិកាបានរាយការណ៍មកនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាមានចំនួន ៣៧,៥ ពាន់លានរៀល ស្មើនឹង ៥០% (រាជធានី ខេត្តដកបាន ៥៩% និងរដ្ឋបាលកណ្តាល ៣៥%)។

ខណៈដែលក្រសួងទទួលស្គាល់ថា អត្រានៃការដកសាច់ប្រាក់មិនបានកម្រិតខ្ពស់នោះ បរិមាណចំណាយថវិកាកម្មវិធីសកម្មភាពអាទិភាពបានកើនឡើង ធៀបនឹងឆ្នាំ ២០០១។ ជារួម កម្មវិធីសកម្មភាពអាទិភាពឆ្នាំ ២០០២ ដកសាច់ប្រាក់បាន ៣៧,៥ ពាន់លានរៀល ពោលគឺមានកម្រិតខ្ពស់ជាង ធៀបនឹងថវិកាកម្មវិធីសកម្មភាពអាទិភាពឆ្នាំ ២០០១ ដែលមានចំនួន ២៧ ពាន់លានរៀល (គិតត្រឹមចុងខែឧសភា ឆ្នាំ២០០២)។ បើប្រៀបធៀបកម្រិតនៃការដកសាច់ប្រាក់ថវិកាឆ្នាំ២០០១ និង២០០២ គិតត្រឹមដើមខែមេសា គឺមានប្រហែលតែ ១៨ ពាន់លានរៀលក្នុងឆ្នាំ ២០០១ និង ៣៥ ពាន់លានរៀន ក្នុងឆ្នាំ ២០០២។

បញ្ហានៃការបញ្ចេញសាច់ប្រាក់មួយចំនួន ដោយសារមូលហេតុដូចខាងក្រោម ៖

- **កម្មវិធី** PAP **ទី** ១ ៖ ការដកសាច់ប្រាក់បានទាប ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃសេវាអប់រំ ដោយសារការខកខានក្នុងការពង្រាយគ្រូឡើងវិញ នៅតាមសាលារៀនចំនួន ៧ ០០០ និងភាពស្មុគស្មាញនៃដំណើរការជ្រើសរើសគ្រូ
- **កម្មវិធី** PAP **ទី៧** ៖ (ការផ្គត់ផ្គង់សម្ភារសិក្សា) និងកម្មវិធី PAP ទី១១ (ហិរញ្ញវត្ថុ និងការពិនិត្យតាមដាន) ដកសាច់ប្រាក់បានតិចតួច ដោយសារការលំបាកក្នុងការរៀបចំកិច្ចលទ្ធកម្ម ជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **កម្មវិធី** PAP **ទី៨** ៖ (ការអប់រំក្រៅប្រព័ន្ធ) និងកម្មវិធី PAP ទី៩ (ការយល់ដឹងអំពីអេដស៍ក្នុងសាលារៀន) ដកសាច់ប្រាក់បានតិចតួច ដោយសារការលំបាកក្នុងការរៀបចំគ្រប់គ្រង តាមបែបវិមជ្ឈការនៅតាមរាជធានី ខេត្តនិងក្រុង ស្រុក ខណ្ឌ។

ការលំបាកផ្សេងទៀតនោះ គឺភាពមិនអាចព្យាករណ៍បាននូវពេលវេលា និងបរិមាណនៃការបញ្ចេញថវិកាកម្មវិធីសកម្មភាពជាអាទិភាពនៅកម្រិតខេត្ត ដែលបានធ្វើឱ្យក្លាយជាបញ្ហាសម្រាប់អាជ្ញាធររាជធានី-ខេត្តក្នុងការធ្វើអាទិភាពបែងចែកនៅតាមកម្មវិធីនីមួយៗ។

ក្រសួងបានចាត់វិធានការមួយចំនួនដើម្បីដោះស្រាយបញ្ហាទាំងនេះ ដូចខាងក្រោម ៖

- បន្តអនុវត្តផែនការអភិវឌ្ឍសមត្ថភាពនៅថ្នាក់កណ្តាល និងរាជធានី ខេត្តស្តីពីការកសាងផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុ ជាពិសេសនៅតាមការិយាល័យជំនាញថ្នាក់ខេត្ត ដែលមិនធ្លាប់អនុវត្តកម្មវិធីមួយចំនួន (ឧទា. ការអប់រំក្រៅប្រព័ន្ធ សុខភាពសិក្សា)
- រៀបចំផែនការគ្រប់គ្រងសាច់ប្រាក់ប្រចាំឆ្នាំ ដែលកំណត់អំពីអាទិភាពក្នុងការ-បញ្ចេញសាច់ប្រាក់តាមខែរបស់កម្មវិធីណាមួយ
- រៀបចំ និងឯកភាពលើគោលការណ៍ណែនាំស្តីពីកិច្ចលទ្ធកម្ម សម្រាប់អនុវត្តនៅតាមកម្មវិធីនីមួយៗ និងនៅតាមកម្រិតគ្រប់គ្រងវិមជ្ឈការថ្នាក់ខេត្ត (ឧទា. សម្ភារបង្រៀនតាមរយៈអង្គភាពគ្រប់គ្រងថវិកាថ្នាក់ខេត្ត និងថ្នាក់ស្រុកក្នុងឆ្នាំ២០០៣)។

### ២.២.៧.៤ និន្នាការនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល១៩៩៩-២០០៣

រាជរដ្ឋាភិបាលទទួលស្គាល់ពីសារៈសំខាន់នៃការកសាងផែនការ ការគ្រប់គ្រង និងការពិនិត្យតាមដានជំនួយពីខាងក្រៅ ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់របស់កម្មវិធីគាំទ្រវិស័យអប់រំប្រកបដោយប្រសិទ្ធផល។ ដើម្បីគ្រោងធនធានដែលជាជំនួយពីខាងក្រៅប្រកបដោយប្រសិទ្ធផល ក្រសួងបានចាត់វិធានការលើកកម្ពស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយក្នុងឆ្នាំ២០០២-២០០៣។ និន្នាការទូទៅនៃជំនួយពីខាងក្រៅអាចសង្ខេបបានដូចខាងក្រោម ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ជំនួយពីខាងក្រៅត្រូវបានព្យាករណ៍ថាមានកម្រិតខ្ពស់ក្នុង ៣ ទៅ ៤ ឆ្នាំខាងមុខ ក្នុងរង្វង់ពី ១៥០ ពាន់លានរៀល (៤០លានដុល្លារ) ដល់ ២១០ ពាន់លានរៀល (៥៥ លានដុល្លារ) ក្នុង១ឆ្នាំ
- បរិមាណថវិកាគាំទ្រដែលផ្តល់ដោយដៃគូអភិវឌ្ឍនៅថេរក្នុងរង្វង់ ៣២ ទៅ ៤០ ពាន់លានរៀលក្នុង១ឆ្នាំ ផ្អែកតាមកម្មវិធីកំពុងអនុវត្តពេលបច្ចុប្បន្ន។

ធៀបនឹងថវិកាចំណាយចរន្តរបស់រាជរដ្ឋាភិបាល ថវិកាគាំទ្រផ្តល់ដោយដៃគូត្រូវបានព្យាករណ៍ថាធ្លាក់ចុះពី១៤% នៅឆ្នាំ២០០២ មកត្រឹម ៦% នៅឆ្នាំ២០០៦ ខណៈដែលការគាំទ្រជាគម្រោងនឹងកើនឡើងក្នុងឆ្នាំ២០០៥។

នៅដំណាក់កាលដំបូងនៃកម្មវិធីកំណែទម្រង់ ថវិកាគាំទ្រផ្តល់ដោយដៃគូបានផ្តោតលើចំណាយដែលមានលក្ខណៈជាអន្តរកាល និងបំពេញបន្ថែម។ ដំណាក់កាលទី២ ការបង្កើនថវិកាចរន្តរបស់រាជរដ្ឋាភិបាល នឹងជួយដល់ការធានានិរន្តរភាពនៃគម្រោងដែលដំណើរការដោយដៃគូ (ឧទា. ថវិកាដំណើរការសាលារៀនដែលទើបសាងសង់ថ្មី)។ ដំណាក់កាលទី៣ គម្រោងជួយខាងបច្ចេកទេស ដែលគាំទ្រដោយដៃគូនឹងជួយគាំទ្រដល់ការកសាងសមត្ថភាពរយៈពេលវែងរបស់ក្រសួង។

ថ្វីបើមានការគាំទ្រច្រើនក៏ដោយ ក៏ការអភិវឌ្ឍសម្ភារបរិក្ខារនៅមានកង្វះថវិកា។ ដើម្បីឆ្លើយតបនឹងតម្រូវការពង្រីកសេវាអប់រំមធ្យមសិក្សា និងក្រោយមធ្យមសិក្សាក្នុងពេល ២ ទៅ ៣ ឆ្នាំខាងមុខ ទាមទារឱ្យមានការថ្លឹងថ្លែងឡើងវិញនូវជំនួយនៅតាមអនុវិស័យនីមួយៗ។

*រូបភាពទី៣ ៖ ការគាំទ្រថវិកាអប់រំដោយដៃគូ*




*ប្រភព ៖* MEF (2003), Medium-term Expenditure Frame Look



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ២.២.៧.៥ ការប៉ាន់ស្មានសង្គតិភាពគោលនយោបាយនៅក្នុងការគ្រោងថវិកា

ក្រសួងបានធ្វើការប៉ាន់ស្មានថា ការកសាងថវិកាក្នុងពេលបច្ចុប្បន្ន និងពេលអនាគត គឺត្រូវមានសង្គតិភាព ជាមួយនឹងអាទិភាពគោលនយោបាយ និងយុទ្ធសាស្ត្រ។ ជាឧទាហរណ៍ ផែនការហិរញ្ញប្បទានវិស័យអប់រំរយៈពេលមធ្យមបាន និងកំពុងជួយដល់ជនក្រីក្រ តាមរយៈបន្សំនៃយន្តការបែងចែកថវិកាផ្តោតលើភាពក្រីក្រ។ ឧទាហរណ៍ផ្សេងទៀតទាក់ទងនឹងផែនការថវិកាផ្តោតលើជនក្រីក្រមានដូចខាងក្រោម ៖

- រូបមន្តសម្រាប់ផ្តល់ថវិកាដំណើរការសាលារៀនស្ថិតក្នុង កម្មវិធី PAP ទី២ និង PAP ទី៣
- ការបង្កើនថវិកាផ្តោតលើជនក្រីក្រ (ឧទា. ក្រុមប្រឹក្សាបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្តល់ហិរញ្ញប្បទានដល់ PAP ទី៤)
- ការផ្តោតធនធានដល់តំបន់មួយចំនួន (ឧទា. កម្មវិធីគាំទ្រដល់បុគ្គលិកបម្រើការនៅតំបន់ដាច់ស្រយាល និងជួបការលំបាកស្ថិតក្នុង PAP ទី១)
- ការផ្តោតធនធានដល់ក្រុមគោលដៅមួយចំនួន (ឧទា. ការអនុវត្តកម្មវិធីអាហារូបករណ៍របស់រាជរដ្ឋាភិបាល ស្ថិតក្នុង PAP ទី១២)។

បរិមាណថវិកាកម្មវិធីសកម្មភាពជាអាទិភាព ដែលបានបែងចែកផ្តោតលើទម្រង់ខាងលើមានប្រមាណ ១២% ក្នុងឆ្នាំ២០០២។ បរិមាណនេះបានកើនឡើងដល់ ១៨%ក្នុងឆ្នាំ២០០៦ (សូមមើលតារាងទី១៥)។

*តារាងទី១៥ ៖ ថវិកាផ្តោតលើជនក្រីក្រក្នុងថវិកាចរន្តរបស់ក្រសួង (២០០២–២០០៦)*

| (គិតជា ពាន់លានរៀល) | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
|---|---|---|---|---|---|
| PAP ១ ៖ គាំទ្រដល់គ្រូនៅតំបន់ដាច់ស្រយាល និងជួបការលំបាក | 5,7 | 5,6 | 10.8 | 11,9 | 13,6 |
| PAP ២ ៖ ថវិកាដំណើរការសាលារៀន | 19,0 | 20,5 | 24.0 | 28,9 | 32,0 |
| PAP ៣ ៖ ថវិកាដំណើរការសាលារៀន | 6,9 | 9,4 | 13.3 | 19,2 | 24,1 |
| PAP ៤ ៖ ហិរញ្ញប្បទានការបណ្តុះបណ្តាលវិជ្ជា-ជីវៈ | 0.0 | 2,0 | 2.5 | 3,0 | 4,0 |
| PAP ៨ ៖ ការចូលរៀនឡើងវិញនិងអក្ខរកម្ម | 2,0 | 3,3 | 5.2 | 5,2 | 6,3 |
| PAP ១២ ៖ អាហារូបករណ៍សិស្សក្រីក្រ | 0,0 | 2,3 | 4.7 | 6,6 | 11,5 |
| **សរុបរួម** | **33,6** | **43,1** | **60.5** | **74,8** | **91,5** |
| **ថវិកាចរន្តរបស់ក្រសួង** | **286,2** | **323,0** | **390.9** | **445,9** | **503,3** |
| **ភាគរយថវិកាផ្តោតលើជនក្រីក្រ** | **12%** | **13%** | **15%** | **17%** | **18%** |

*ប្រភព ៖* MoEYS PAP framework 2003–2006 (March 2003)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ថែមពីនេះទៀត ក្រសួងបានទាញយកគុណសម្បត្តិ ពីការលើកកម្ពស់លក្ខខណ្ឌនៃការរស់នៅនិងការបំពេញការងាររបស់គ្រូបង្រៀន តាមរយៈយុទ្ធសាស្ត្របង្កើនបៀវត្សរបស់រាជរដ្ឋាភិបាល និងអនុវត្តវិធានការមួយចំនួនទៀតដែលស្ថិតក្រោម PAP ១។

ក្រសួងបានរៀបចំយុទ្ធសាស្ត្រឆ្លើយតបនឹងវត្ថុបំណងគោលនយោបាយទូទៅ ក្នុងការបង្កើនការចូលរៀនដោយសមធម៌របស់សិស្សស្រី និងសិស្សជនជាតិដើមភាគតិចនៅគ្រប់កម្រិតសិក្សា។

*តារាងទី១៦ ៖ ថវិកាសម្រាប់បង្កើនការចូលរៀនរបស់សិស្សស្រី និងសិស្សជនជាតិដើមភាគតិច*

| (គិតជា លានរៀល) | ថវិកា ២០០២ | គ្រោង២០០៣ (MTEF) | គ្រោង ២០០៤ (MTEF) | គ្រោង ២០០៥ (MTEF) | គ្រោង ២០០៦ ចំណោល |
|---|---|---|---|---|---|
| កម្មវិធីសកម្មភាពអាទិភាព | | | | | |
| ថវិកាសម្រាប់សិស្សស្រីនិងជនជាតិភាគតិច | 30 999 | 40 730 | 52 150 | 64 517 | 81 102 |
| ថវិកាសរុប | 75 055 | 90 500 | 113 400 | 133 522 | 160 753 |
| កម្មវិធីវិនិយោគមូលធន | | | | | |
| ថវិកាសម្រាប់សិស្សស្រីនិងជនជាតិភាគតិច | 87 480 | 86 160 | 81 000 | 61 560 | 73 732 |
| ថវិកាសរុប | 116 800 | 119 600 | 114 000 | 87 600 | 107 887 |
| *ភាគរយថវិកាចរន្តសម្រាប់សិស្សស្រី* | *41%* | *45%* | *46%* | *48%* | *50%* |
| *ភាគរយថវិកាមូលធនសម្រាប់សិស្សស្រី* | *75%* | *72%* | *71%* | *70%* | *68%* |
| *ភាគរយថវិកាសរុបសម្រាប់សិស្សស្រី* | *62%* | *60%* | *59%* | *57%* | *58%* |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

### *២.២.៧.៥.១ វឌ្ឍនភាព និងផលប៉ះពាល់លើជនជាតិដើមភាគតិច*

ការបង្កើនលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយគុណភាពខ្ពស់នៅតំបន់ជនជាតិដើមភាគតិចនៅតែជាសមាសធាតុដ៏សំខាន់នៃយុទ្ធសាស្ត្រ និងកម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ។ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនោះបង្ហាញអំពីផលប៉ះពាល់ជាវិជ្ជមាន លើការចូលរៀននៅបឋមសិក្សាក្នុងតំបន់ជនជាតិដើមភាគតិច ដោយមានកំណើនចន្លោះពី ៦% (ស្ទឹងត្រែង) ទៅ ១៦% (រតនគិរី) ក្នុងឆ្នាំ ២០០២-២០០៣។ នៅកម្រិតមធ្យមសិក្សាបឋមភូមិ ការចូលរៀនកើនឡើងចន្លោះពី ២៧% (ស្ទឹងត្រែង) និង ៥១% (មណ្ឌលគិរី) ធៀបទៅនឹងស្ថានភាពនៅឆ្នាំមូលដ្ឋានកន្លងមកដែលមានកម្រិតទាប។ កំណើននៃការចូលរៀនរបស់សិស្សស្រីខ្ពស់ជាងសិស្សប្រុសនៅក្នុងគ្រប់រូបភាពទាំងអស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទោះជាយ៉ាងណា ការចូលរៀនសរុប និងអត្រាចូលរៀនថ្មីនៅតាមខេត្តទាំងនេះនៅទាបជាងចំណុចដៅជាមធ្យមនៅថ្នាក់ជាតិ (សូមមើលតារាងទី១៧)។ ឧទាហរណ៍ អត្រាពិតនៃការសិក្សានៅបឋមសិក្សាក្នុងខេត្តរតនគិរីមាន ៥៣,៦% និងមណ្ឌលគិរីមាន៦៤,១% ដែលជាខេត្តសម្រេចបានទាបជាងគេបង្អស់។ អត្រាពិតចូលរៀនថ្មីក្នុងឆ្នាំ២០០២-២០០៣ ក៏មានកម្រិតទាបផងដែរ ដោយសារតែសិស្សលើសអាយុចូលរៀន និងតម្រូវការសេវាអប់រំក្នុងប្រព័ន្ធមិនមានភាពច្បាស់លាស់។ កត្តានេះទាមទារឱ្យមានការអភិវឌ្ឍយុទ្ធសាស្ត្រជាក់លាក់ ដើម្បីដោះស្រាយបញ្ហាប្រឈម ក្នុងការចូលរៀននៅតំបន់ជនជាតិដើមភាគតិច (ឧទា. កម្មវិធីសិក្សាពហុភាសា អាហារូបករណ៍ ការបណ្តុះបណ្តាលគ្រូបង្រៀនជនជាតិដើមភាគតិច)។

*តារាងទី១៧ ៖ សូចនាករសំខាន់ៗស្តីពីជនជាតិដើមភាគតិច*

| ទីតាំង | អត្រាពិតចូលរៀនថ្មី | | | អត្រាពិតនៃការសិក្សា | | | អត្រា បញ្ចប់ការសិក្សា | ផលធៀប សិស្ស បន្ទប់រៀន | ផលធៀប សិស្ស គ្រូ |
|---|---|---|---|---|---|---|---|---|---|
| | ស្រី | សរុប | គម្លាត | ស្រី | សរុប | គម្លាត | | | |
| មណ្ឌលគិរី | 54,8% | 59,1% | 8,6 | 56,4% | 64,1% | 15,3 | 36 | 45 | 44 |
| ព្រះវិហារ | 62,6% | 64,3% | 3,3 | 70,4% | 72,9% | 4,9 | 38 | 64 | 43 |
| រតនគិរី | 37,4% | 43,1% | 11,3 | 43,4% | 53,6% | 20,3 | 38 | 45 | 67 |
| ស្ទឹងត្រែង | 80,8% | 87,8% | 13,6 | 75,6% | 81,4% | 11,3 | 34 | 51 | 40 |
| ទូទាំងប្រទេស | 88,8% | 92,2% | 6,7 | 88,9% | 93,1% | 8,1 | 46 | 69 | 57 |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

សេវាអប់រំមធ្យមសិក្សាមិនមានគ្រប់គ្រាន់នៅតំបន់ជនជាតិដើមភាគតិច។ អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តទាំង៤ មានកម្រិតទាបជាង ៧% ធៀបនឹងមធ្យមភាគថ្នាក់ជាតិ ២០%។ នៅមធ្យមសិក្សាទុតិយភូមិក៏មានស្ថានភាពស្រដៀងគ្នានេះដែរ ដោយធៀបជាមួយនឹងមធ្យមភាគថ្នាក់ជាតិ ៧%។

ទោះជាយ៉ាងណា ចំនួនសិស្សចូលរៀននៅមធ្យមសិក្សាក្នុងតំបន់ជនជាតិដើមភាគតិចកំពុងកើនឡើងយ៉ាងខ្លាំង ធៀបជាមួយនឹងឆ្នាំមូលដ្ឋានដែលមានកម្រិតទាប។ ក្រសួងបានអនុវត្តវិធានការជាក់ស្តែងចំនួន ២ ដើម្បីដោះស្រាយបញ្ហានេះក្នុងឆ្នាំ២០០២-២០០៣ តាមរយៈការអភិវឌ្ឍសម្ភារបរិក្ខារសាលាមធ្យមសិក្សា និងផ្តល់អាហារូបករណ៍និងប្រាក់លើកទឹកចិត្តដល់សិស្សជនជាតិដើមភាគតិច។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.២.៧.៦ ការអប់រំនៅតំបន់ដាច់ស្រយាល ៖ វឌ្ឍនភាពនិងផលប៉ះពាល់

ក្រសួងបានធ្វើការវិភាគបឋមលក្ខណៈជាយុទ្ធសាស្ត្រ អំពីបញ្ហាស្ថាប័នសំខាន់ៗ ទាក់ទងនឹងការកែលម្អប្រសិទ្ធភាពសេវាអប់រំ នៅតំបន់ដាច់ស្រយាល ស្របជាមួយនឹងការដោះស្រាយបញ្ហាសាលាមានទំហំតូច និងមិនគ្រប់កម្រិត។ ក្រសួងកំពុងអនុវត្តវិធានការមួយចំនួនដើម្បីកែលម្អសេវាអប់រំនៅតំបន់ និងសាលារៀនជួបការលំបាក តាមរយៈការអនុវត្តការបង្រៀន២វេន ការបង្រៀនថ្នាក់គួប និងការផ្ដល់ប្រាក់ឧបត្ថម្ភគ្រូបម្រើការនៅតំបន់ដាច់ស្រយាល។ ក្នុងឆ្នាំ២០០២-២០០៣ កម្មវិធីស្ដីពីប្រសិទ្ធភាពសេវាអប់រំ ដែលផ្ដោតលើប្រាក់ឧបត្ថម្ភការពង្រាយគ្រូ ត្រូវបានអនុវត្តជាជំហានដំបូង។ ថវិកាសរុបសម្រាប់ឆ្នាំដំបូងមានប្រមាណ ១០ ពាន់លានរៀល (២,៥ លានដុល្លារ)។ គ្រូបង្រៀនចំនួន ១៦ ៨០០ នាក់បានទទួលប្រាក់ឧបត្ថម្ភ សម្រាប់ការបំពេញការងារនៅតំបន់ជួបការលំបាក និងដាច់ស្រយាល។ ជាមួយគ្នានេះដែរ នាយកសាលារៀននិងគ្រូបង្រៀនដែលបានពង្រាយឡើងវិញទៅសាលាខ្វះគ្រូចំនួន ៩ ១០០ នាក់ក៏បានទទួលប្រាក់ឧបត្ថម្ភបន្ថែមផងដែរ។

សាលាបឋមសិក្សានៅតំបន់ដាច់ស្រយាលមានចំនួនជាង ៣៩០ ស្ថិតក្នុងខេត្ត ១១ (សូមមើលតារាងទី១៨)។ ក្នុងចំណោមសាលាទាំងនេះ សាលាចំនួន ៣ ភាគ ៤ ជាសាលាមិនគ្រប់កម្រិត។ ជាជំហានដំបូង ក្រសួងនឹងចាត់វិធានការកែលម្អការគ្រប់គ្រងធនធានដែលមាន (ឧទា. ការផ្ដល់សៀវភៅសិក្សាទាន់ពេល ការអភិវឌ្ឍគ្រូបង្រៀននៅនឹងកន្លែង) និងពង្រឹងការសម្របសម្រួលរវាង ស្រុកនិងសាលាដាច់ស្រយាល។

*តារាងទី១៨ ៖ សាលារៀនដាច់ស្រយាលនិងមិនគ្រប់កម្រិត ឆ្នាំ ២០០២*

| ខេត្ត | សរុប | មិនគ្រប់កម្រិត | គ្រប់កម្រិត |
|---|---|---|---|
| កំពង់ស្ពឺ | 9 | 8 | 1 |
| កោះកុង | 18 | 10 | 8 |
| ក្រចេះ | 35 | 23 | 12 |
| មណ្ឌលគិរី | 35 | 32 | 3 |
| ឧត្តរមានជ័យ | 30 | 26 | 4 |
| ព្រះវិហារ | 49 | 40 | 9 |
| ពោធិ៍សាត់ | 12 | 11 | 1 |
| រតនគិរី | 70 | 63 | 7 |
| សៀមរាប | 30 | 25 | 5 |
| ស្ទឹងត្រែង | 103 | 85 | 18 |
| សរុប | **391** | **303** | **88** |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មូលដ្ឋានគ្រឹះដើម្បីសម្រេចបានគុណភាពអប់រំសម្រាប់ទាំងអស់គ្នា ទាមទារឱ្យដោះស្រាយបញ្ហាសាលាមិនគ្រប់កម្រិត ជាពិសេសនៅតំបន់ដាច់ស្រយាល។ ការលំបាកក្នុងការស្វែងរកសេវាអប់រំ ដែលមានគ្រប់កម្រិតពីថ្នាក់ទី១ ដល់ទី៦ នៅតាមឃុំ សង្កាត់ជាច្រើន បានធ្វើឱ្យអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ និងអត្រាឆ្លងភូមិសិក្សាទៅភូមិសិក្សាមធ្យមសិក្សាបឋមភូមិមានកម្រិតទាប។

គេទទួលស្គាល់ថាបញ្ហាចម្បងៗក្នុងការកាត់បន្ថយសាលាមិនគ្រប់កម្រិតគឺ ដោយសារកង្វះប្រាក់លើកទឹកចិត្តនាយកសាលាឱ្យបំពេញកិច្ចការនេះ និងការលំបាកក្នុងការប្រើប្រាស់ប្រាក់ឧបត្ថម្ភ ដែលមានស្រាប់ឱ្យមានប្រសិទ្ធផល រួមបញ្ចូលទាំង ៖

- ការកំណត់ក្រុមគោលដៅសម្រាប់ឧបត្ថម្ភការអនុវត្តថ្នាក់គួប និងការបង្រៀន២វេន ដោយផ្តោតនៅតាមសាលាមិនគ្រប់កម្រិត មិនទាន់មានប្រសិទ្ធផល
- ភាពយឺតយ៉ាវក្នុងការផ្តល់ប្រាក់ឧបត្ថម្ភគ្រូបង្រៀន មានន័យថាមិនបានលើកទឹកចិត្តដល់សាលារៀន ក្នុងការពង្រីកឱ្យគ្រប់កម្រិតពីទី១ ដល់ទី៦
- ការឧបត្ថម្ភសិស្សឱ្យនៅបន្តសិក្សាក្នុងសាលារៀនមិនគ្រប់គ្រាន់ ជាពិសេសគ្រួសារក្រីក្រ
- នាយកសាលាដែលជាសាលារៀនឧបសម្ពន្ធ (សាលារៀនមាន ១ ឬ ២ កម្រិតថ្នាក់) មិនបានទទួលប្រាក់ឧបត្ថម្ភ។

ជាជំហានដំបូង ឯកសារយុទ្ធសាស្ត្រស្តីពីការកាត់បន្ថយសាលាបឋមសិក្សាមិនគ្រប់កម្រិត ២០០២-២០០៦ ត្រូវបានរៀបចំនៅខែកុម្ភៈ ឆ្នាំ២០០៣។ ក្រសួងបានពិនិត្យឡើងវិញនូវជម្រើសយុទ្ធសាស្ត្រ ដូចខាងក្រោម ៖

- ការអភិវឌ្ឍជាជំហានៗនូវសាលារៀនដែលមានកម្រិតថ្នាក់ខ្ពស់បំផុតត្រឹមថ្នាក់ទី៣ ដល់ថ្នាក់ទី៥ ឱ្យក្លាយជាសាលាគ្រប់កម្រិត ស្របពេលជាមួយនឹងការពង្រីកសាលាឧបសម្ពន្ធឱ្យមានដល់កម្រិតថ្នាក់ទី៣
- ការបង្កើនប្រាក់ឧបត្ថម្ភថ្នាក់គួបនិងបង្រៀន ២ វេន ស្របពេលនឹងការផ្តល់ប្រាក់ឧបត្ថម្ភនាយកសាលាដែលជាសាលាឧបសម្ពន្ធ ដែលបានបង្កើនកម្រិតថ្នាក់ដល់ថ្នាក់ទី៣
- ការផ្តល់កម្មវិធីអាហារ នៅតាមសាលាមិនគ្រប់កម្រិតមួយចំនួន ជាពិសេសសាលារៀនដែលស្ថិតក្នុងឃុំ សង្កាត់ក្រីក្រ ៥០%។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២.២.៧.៧ វិមជ្ឈការអប់រំ៖ បញ្ហាគុណភាព

យុទ្ធសាស្ត្ររបស់ក្រសួងស្ដីពីវិមជ្ឈការ បានលើកឡើងពីសកម្មភាពអភិវឌ្ឍសមត្ថភាពមួយចំនួនដោយគ្របដណ្ដប់លើកំណែទម្រង់ស្ថាប័ន ការកសាងផែនការនិងគ្រប់គ្រងថវិកា ការពិនិត្យតាមដាន និងវិធានការលើកកម្ពស់គុណភាព។

ទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗស្ដីពីវិមជ្ឈការអប់រំ ត្រូវបានអនុវត្តទូលំទូលាយ ដូចជា ៖

- ការអភិវឌ្ឍបណ្ដាញកម្រងសាលារៀននៅទូទាំងប្រទេស ដើម្បីគ្រប់គ្រងព័ត៌មាន និងគាំទ្របច្ចេកទេសរវាងសាលារៀន កម្រងសាលារៀន និងស្រុក
- ស្ថាប័នីយកម្មការទទួលខុសត្រូវរបស់កម្រងសាលារៀន ដោយផ្ដោតលើការជួយសាលារៀនក្នុងការកសាងផែនការអភិវឌ្ឍ និងអាទិភាពសម្រាប់លើកកម្ពស់គុណភាព
- កម្មវិធីអភិវឌ្ឍសមត្ថភាពបឋម និងជាជំហានៗសម្រាប់អភិវឌ្ឍកម្រងសាលារៀន រួមបញ្ចូលទាំងកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាផ្នែកមួយនៃអភិបាលកិច្ចអប់រំនិងការធានា គុណភាពអប់រំ។

ដើម្បីប្រែក្លាយប្រការទាំងអស់នេះឱ្យទៅជាការកែលម្អគុណភាព ក្រសួងគ្រោងវិធានការកំណែទម្រង់ស្ថាប័នសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

- ការបញ្ចប់កំណែទម្រង់កម្មវិធីសិក្សានៅបឋមសិក្សា និងផែនការអភិវឌ្ឍសម្ភារសិក្សា និងចាប់ផ្ដើមអនុវត្តនៅដើមឆ្នាំ២០០៤
- ការរៀបចំនិងអនុវត្តការធ្វើតេស្ដស្ដង់ដាអប្បបរមា តាមកម្រិតថ្នាក់មួយចំនួននៅបឋមសិក្សា និងផែនការអនុវត្តតេស្ដស្ដង់ដាសាកល្បង ក្នុងឆ្នាំ២០០៤
- ការរៀបចំឯកសារយុទ្ធសាស្ត្ររយៈពេលមធ្យមនិងរយៈពេលវែង ស្ដីពីការបង្កើនម៉ោងសិក្សា (ជាពិសេស មុខវិជ្ជាគោល) ក្នុងខណៈដែលកំណើនសិស្សនៅបឋមសិក្សានិងការបង្រៀន ២ វេនថយចុះ ចាប់ពីឆ្នាំ២០០៤
- ការអនុវត្តបណ្ដាញកម្រងសាលារៀននៅទូទាំងប្រទេស ដើម្បីផ្ដល់ព័ត៌មានគ្រប់គ្រង និងគាំទ្របច្ចេកទេសដល់សាលារៀនក្នុងឆ្នាំ២០០៤។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រសួងទទួលស្គាល់ពីតម្រូវការក្នុងការបន្តពិភាក្សាជាជំហានៗ អំពីវិធានការលើកកម្ពស់គុណភាព។

រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីផ្ដោតលើជនក្រីក្រ ដើម្បីដោះស្រាយតម្រូវការរបស់ប្រជាជនក្រីក្រដោយផ្ទាល់។ កិច្ចការនេះបានប្រើប្រាស់យន្តការហិរញ្ញវត្ថុ ដូចគ្នានឹងកម្មវិធីសកម្មភាពជាអាទិភាព ដើម្បីដោះស្រាយបញ្ហាកង្វះជីវជាតិ កង្វះអាហារូបត្ថម្ភរបស់ប្រជាជន និងកែលម្អការផ្ដល់សេវាអប់រំ តាមរយៈការផ្ដល់កញ្ចប់ថវិកាដល់ខេត្តដែលមានស្ថានភាពក្រីក្រខ្លាំង ដូចជា ខេត្តព្រះវិហារ ឧត្ដរមានជ័យ រតនគិរី និងមណ្ឌលគិរី។ ក្រៅពីកម្មវិធីផ្ដល់អាហារូបករណ៍ ដល់កុមារមកពីគ្រួសារក្រីក្រ កម្មវិធីផ្ដោតលើជនក្រីក្រក៏បានផ្ដល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់គ្រូបង្រៀននៅតំបន់ដាច់ស្រយាល បង្កើនថវិកាសម្រាប់កម្មវិធីអភិវឌ្ឍសម្ភារបូបរន្ត និងផ្ដល់ថវិកាដំណើរការកាន់តែច្រើនដល់សាលារៀននៅតំបន់ដាច់ស្រយាល។ ការអនុវត្តកម្មវិធីផ្ដោតលើជនក្រីក្របានបង្កើនការចូលរៀនរបស់កុមារមកពីគ្រួសារក្រីក្រ កុមារី និងជនជាតិដើមភាគតិច។ តាមស្ថិតិនិងសូចនាករអប់រំបានបង្ហាញថា អត្រានៃការសិក្សារបស់កុមារនៅខេត្តរតនគិរី បានកើនឡើង ៣០% រវាងឆ្នាំសិក្សា ២០០០-២០០១ និងឆ្នាំសិក្សា ២០០១-២០០២ ដោយសារតែមានការបង្កើនថវិកាដល់សាលារៀន ដើម្បីលុបបំបាត់ការបង់ថ្លៃសិក្សា។

ជាលទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព វិស័យអប់រំនៅកម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ កម្ពុជាបានពង្រីកឱកាសអប់រំកាន់តែច្រើន ជាពិសេសនៅកម្រិតបឋមសិក្សា និងបង្កើនការចូលរៀនរបស់សិស្សស្រីនៅជនបទនិងជនជាតិដើមភាគតិច។ យោងតាមស្ថិតិជាតិ អត្រាពិតនៃការសិក្សានៅបឋមសិក្សាកើនឡើងខ្លាំង និងឈានដល់ ៩១,៣%នៅឆ្នាំ ២០០៥-០៦។ វិស័យអប់រំក៏បានកែលម្អដំណើរការកសាងផែនការនិងអនុវត្តថវិកា និងចាប់អនុវត្តថវិកាកម្មវិធី។ ចំណាយលើវិស័យអប់រំបានកើនឡើងពី ០,៩% (ឆ្នាំ ១៩៩៧) ទៅដល់ ១,៥% (២០០៦) នៃផលទុនក្នុងស្រុកសរុប។ ចំណែកសម្រាប់វិស័យអប់រំធៀបនឹងថវិកាចរន្តរដ្ឋាភិបាលបានកើនពី ១៥,៧% ក្នុងឆ្នាំ២០០១ ដល់១៨,៩%ក្នុងឆ្នាំ ២០០៦។

ចាប់តាំងពីទទួលបានសន្តិភាពពេញលេញនៅឆ្នាំ២០០០មក វិស័យអប់រំបានក្លាយជាវិស័យអាទិភាព។ សកម្មភាពជាបន្តបន្ទាប់បានចាប់មានឡើង ដើម្បីបង្កើនចំណាយសាធារណៈ ទៅលើការកាត់បន្ថយភាពក្រីក្រ រួមបញ្ចូលទាំងការធ្វើសនិទានកម្មចំណាយលើផែនការសង្គមកិច្ច និងសេដ្ឋកិច្ច ដោយកាត់បន្ថយចំណាយលើការពារជាតិនិងសន្តិសុខ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងការដាក់ឱ្យអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ដែលជាយន្តការមួយ បង្កើនការបើកផ្តល់សាច់ប្រាក់ដល់វិស័យអាទិភាព។ បម្រែបម្រួលអាទិភាពចំណាយនេះ បានធ្វើឱ្យចំណាយលើការការពារជាតិ និងសន្តិសុខថយចុះពី ៤,៥% ធៀបនឹងផលទុនក្នុងស្រុកសរុបនៅឆ្នាំ១៩៩៤ មកត្រឹម ២% នៅឆ្នាំ២០០៨។ ចំណាយនេះបានកើនបន្តិចដល់ ២,៦% នៅឆ្នាំ២០១២។

របៀបវារៈថ្មីស្តីពីគោលនយោបាយសង្គមកិច្ច បានគាំទ្រដល់ការអនុវត្តផែនការមួយនេះដែលមាន **ទស្សនវិស័យបង្កើតសង្គមកម្ពុជាមួយដែលតភ្ជាប់គ្នា មានចំណេះដឹងជ្រៅជ្រះ និងវប្បធម៌រស់រវើក**។ រាជរដ្ឋាភិបាលកម្ពុជាបានបន្តកែទម្រង់ប្រព័ន្ធអប់រំ និងលើកកម្ពស់រាល់ទម្រង់នៃការអភិវឌ្ឍមូលធនមនុស្ស ដើម្បីធ្វើឱ្យប្រទេសកម្ពុជាកាន់តែមានផលិតភាព និងភាពប្រកួតប្រជែងក្នុងសេដ្ឋកិច្ចសកល។

# ជំពូកទី ៣
# គោលនយោបាយជាតិស្តីពីការអប់រំ

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការអប់រំ ជាបញ្ហាគន្លឹះក្នុងរបៀបវារៈអភិវឌ្ឍរបស់ខ្លួន។ ក្នុងដំណាក់កាលដំបូងនៃកំណែទម្រង់ គោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាលបានផ្តល់អាទិភាព ដល់ការពង្រីកឱកាសសមធម៌អប់រំ ដែលជាមធ្យោបាយសំខាន់ ដើម្បីសម្រេចគោលដៅសេដ្ឋកិច្ចសង្គម។ ដោយការអប់រំនៅបឋមសិក្សាសម្រេចបានគោលដៅរបស់ខ្លួននាពេលកន្លងមក នាដំណាក់កាលនេះ រាជរដ្ឋាភិបាលបានផ្តោតសំខាន់ទៅលើលើគុណភាពអប់រំ និងសមាសភាពពាក់ពាក់ព័ន្ធនឹងវិស័យអប់រំវិញម្តង។

គោលនយោបាយអប់រំជាតិរបស់ប្រទេសកម្ពុជាមានធាតុផ្សំដូចតទៅនេះ ៖ (i) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ* (ESP) ជាក្របខណ្ឌដើម្បីផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយអប់រំ (ii) គោលនយោបាយក្នុងការលើកកម្ពស់ការទទួលបាននូវការអប់រំប្រកបដោយសមភាព និងគុណភាព និង (iii) ផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអប់រំ។

## ៣.១. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ជាក្របខណ្ឌផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

### ៣.១.១ការអប់រំ គឺជាសិទ្ធិមនុស្ស

បន្ទាប់ពីការបោះឆ្នោតសកលនៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌគោលនយោបាយនៃការផ្សះផ្សាបង្រួបបង្រួមជាតិ ហើយរដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសកម្ពុជាក៏ត្រូវបានអនុម័ត។ ទោះជាយ៉ាងនេះក្តី ខ្មែរក្រហមបានធ្វើពហិការមិនចូលរួមការបោះឆ្នោត និងបានបន្តសង្គ្រាមស៊ីវិលនៅតាមតំបន់ជាច្រើនក្នុងប្រទេស។ ក្នុងកាលៈទេសៈនោះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីជំរុញការកសាងប្រទេសជាតិ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ផ្តល់សិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់មនុស្ស និងប្រជាពលរដ្ឋ ជាពិសេសសិទ្ធិក្នុងការទទួលបានការអប់រំប្រកបដោយសមធម៌។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចមានចែងក្នុងមាត្រាទី៦៥ ដល់ទី៦៨ នៃរដ្ឋធម្មនុញ្ញ លក្ខណៈនៃការអប់រំជាសិទ្ធិមូលដ្ឋានត្រូវបានធានា។ រដ្ឋត្រូវការពារ និងលើកទឹកចិត្តក្នុងការជំរុញឱ្យពលរដ្ឋទទួលបាននូវការអប់រំនេះ។ មាត្រាទី៦៥ នៃរដ្ឋធម្មនុញ្ញបានចែងថា ៖ *«រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋត្រូវយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប»*។ មាត្រាទី៦៦ ចែងថា៖ *«រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងការសិក្សា និងគោលការណ៍សមភាពក្នុងវិស័យអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត»*។

កម្ពុជាមានបំណងធានានូវការអប់រំជាមូលដ្ឋានដោយឥតគិតថ្លៃ សម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន។ មាត្រាទី៦៨ ចែងថា៖ *«រដ្ឋផ្តល់ការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវទទួលបានការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។ រដ្ឋជួយផ្សព្វផ្សាយ និងលើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា»*។ ទីបំផុត កម្ពុជាបានអនុម័តក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដើម្បីលើកកម្ពស់សិទ្ធិទទួលបានការអប់រំ។

កម្ពុជាជាភាគីហត្ថលេខីលើលិខិតូបករណ៍អន្តរជាតិ ដែលទទួលស្គាល់សិទ្ធិស្តីពីការអប់រំ ដូចជា (a) សេចក្តីប្រកាសជាសកលឆ្នាំ១៩៤៨ ស្តីពីសិទ្ធិមនុស្ស (b) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (c) អនុសញ្ញាស្តីពីសិទ្ធិកុមារ (d) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW) រួមទាំងនៅក្នុងច្បាប់ទន់មានដូចជាអនុសាសន៍ ប្រកាស និងក្របខណ្ឌសម្រាប់សកម្មភាព ជាពិសេសនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។ ដើម្បីអនុវត្តសិទ្ធិក្នុងការអប់រំ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ** ដើម្បីសម្របសម្រួលសកម្មភាពនានាជាមួយនឹងភាគីពាក់ព័ន្ធ។

## ៣.១.២. ច្បាប់ស្តីពីការអប់រំ

ដើម្បីអនុវត្តបទប្បញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តក្នុងឆ្នាំ២០០៧ នូវ **ច្បាប់ស្តីពីការអប់រំ** ដែលជាឯកសារនាំផ្លូវ សម្រាប់អភិវឌ្ឍប្រព័ន្ធអប់រំ។ នៅក្នុងជំពូកទី១ នៃច្បាប់នេះបានចែងអំពីសិទ្ធិស្មើភាពគ្នារបស់ពលរដ្ឋទាំងអស់ ក្នុងការទទួលបានការអប់រំ «សិទ្ធិក្នុងការអប់រំ»។ សិស្ស និស្សិតទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការទទួលបានចំណេះដឹង ជំនាញ សេចក្តីថ្លៃថ្នូរ និងអត្តចរិត ព្រមទាំងលក្ខណៈសម្បត្តិល្អ។ ក្នុងមាត្រាទី៩ មានចែងអំពីប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។ យោង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមមាត្រានេះ ក្រសួងអប់រំទទួលខុសត្រូវក្នុងការរៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំងការបង្កើតយន្តការនៃការត្រួតពិនិត្យ អធិការកិច្ច និងសវនកម្មផ្ទៃក្នុងលើការបំពេញការងាររបស់ខ្លួន។ កម្រិតគុណភាព និងប្រសិទ្ធភាពនៃការអប់រំ គឺជាប្រធានបទដែលនឹងរៀបរាប់នៅក្នុងជំពូកទី៥។ តម្រូវការឧបករណ៍ ការកំណត់វត្ថុបំណង និងកិច្ចការរបស់សាលាដើម្បីសម្រេចបានគោលបំណងទាំងនោះ មានរៀបរាប់ក្នុងជំពូកនេះ។

ក្នុងជំពូកទី៦ មានចែងអំពីការផ្តល់សិទ្ធិដល់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការកំណត់គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រវិស័យអប់រំ។ ច្បាប់ និងកាតព្វកិច្ចអប់រំត្រូវបានបញ្ជាក់នៅក្នុងជំពូកទី៧ ដែលផ្តោតទៅលើសិទ្ធិរបស់អ្នកសិក្សា ឪពុកម្តាយ និងបុគ្គលិកអប់រំ។ ជំពូកនេះក៏មានបរិយាយអំពីសិទ្ធិទទួលបានការអប់រំសម្រាប់ប្រជាពលរដ្ឋគ្រប់រូប យ៉ាងតិច ៩ ឆ្នាំ។ មាត្រាទី៣៧ កំណត់សិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលិកអប់រំ។ ច្បាប់ស្តីពីការអប់រំមានការគោលការណ៍ទទួលស្គាល់ការគោរពសិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ចសង្គមរបស់ពលរដ្ឋទាំងអស់ដោយចែងថា ៖ «សិទ្ធិអប់រំ និងកាតព្វកិច្ច» ។ មាត្រាទី៣១ បានចែងថា ៖ «ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពយ៉ាងតិចបំផុត ៩ ឆ្នាំនៅតាមគ្រឹះស្ថានសាធារណៈដោយឥតគិតថ្លៃ»។ មាត្រាទី៣២ តម្រូវឱ្យឪពុកម្តាយធានា «ការចុះឈ្មោះចូលរៀនដល់បុត្រធីតារបស់ខ្លួនក្នុងថ្នាក់ទី១ នៃកម្មវិធីអប់រំចំណោះទូទៅផ្លូវការនៅអាយុ ៦ ឆ្នាំ» ។

អ្នកសិក្សាមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិពាក់ព័ន្ធនឹងទស្សនទានសិក្សា សិទ្ធិសេរីភាពក្នុងការសិក្សា សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព សិទ្ធិក្នុងការប្រមូលផ្តុំជាក្រុមអ្នកសិក្សា ឬក្លឹបសិក្សាសម្រាប់គោលបំណងអប់រំ សិទ្ធិពិនិត្យមើល និងចម្លងកំណត់ត្រាផ្ទាល់ខ្លួនស្តីពីការអប់រំ សិទ្ធិក្នុងការចូលរួមយ៉ាងសកម្ម និងពេញលេញក្នុងការអភិវឌ្ឍស្តង់ដាអប់រំ សិទ្ធិរួចផុតពីអំពើទារុណកម្ម ឬការដាក់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី(មាត្រាទី៣៥) ។

## ៣.១.៣ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP) ត្រូវបានប្រើប្រាស់ជាលើកដំបូងក្នុងឆ្នាំ ២០០១ ក្នុងក្របខណ្ឌនៃកំណែទម្រង់ ដើម្បីឆ្លើយតបនឹងការបង្កើនថវិកាដល់វិស័យអប់រំ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ផែនការយុទ្ធសាស្ត្រវិស័យអប់រំបានផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួនដែលផ្តោតទៅលើការពង្រីកវិស័យអប់រំ មកជាគុណភាពអប់រំវិញ។ ខាងក្រោមនេះគឺបញ្ជាក់អំពីទំនោរនៃការផ្លាស់ប្តូរដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០១-២០០៥ ផ្ដោតលើការបង្កើនការទទួលបានការអប់រំ ជាដំបូងនៅកម្រិតបឋមសិក្សា(២០០១) ប៉ុន្តែក្រោយមក ក៏រួមបញ្ចូលទាំងការអប់រំកុមារតូចផងដែរ(២០០៤)។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ ផ្ដោតជាសំខាន់ទៅលើការបង្កើនការទទួលបានការអប់រំ និងបង្កើនប្រសិទ្ធភាពផ្ទៃក្នុង។ ចាប់តាំងពីឆ្នាំ២០០៦ មក មានការផ្លាស់ប្ដូរពីការផ្ដោតទៅលើការអប់រំនៅបឋមសិក្សា មកការអប់រំនៅមធ្យមសិក្សាបឋមភូមិ ដោយសារតែកុមារកម្ពុជាកាន់តែច្រើនបានបញ្ចប់ការសិក្សាពីកម្រិតបឋមសិក្សា។

ក្នុងរយៈពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០០៩-២០១៣ ក្រសួងអប់រំ យុវជន និងកីឡា (អយក) បានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់ឱកាសដល់កុមារកម្ពុជាទាំងអស់ឱ្យទទួលបានការអប់រំ ក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការរៀនសូត្ររបស់កុមារ ព្រមទាំងប្រសិទ្ធភាពនៃការផ្ដល់សេវាអប់រំ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣ ផ្ដោតការយកចិត្តទុកដាក់ដល់ការលើកកម្ពស់សមភាពឱកាសទទួលបានការអប់រំ ដែលជាកត្តាក្នុងការបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងកត្តាចាំបាច់សម្រាប់បង្កើតការងារ។ សសរស្ដម្ភសំខាន់របស់ផែនការយុទ្ធសាស្ត្រនេះគឺ ៖ (i) ការទទួលបានសេវាអប់រំប្រកបដោយសមធម៌ (ii) គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ និង (iii) ការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ។ ដៃគូអភិវឌ្ឍអន្តរជាតិដែលចូលរួមក្នុងកិច្ចការនេះជាមួយក្រសួងអប់រំ យុវជន និងកីឡា ជាដៃគូវិស័យអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជាបានវាយតម្លៃសមិទ្ធិផលនេះថាគួរឱ្យទុកចិត្ត ទូលំទូលាយ មានភាពប្រទាក់ក្រឡា និងបានទៅដល់អ្នកក្រីក្រ។

គោលបំណងរបស់រាជរដ្ឋាភិបាល គឺធ្វើយ៉ាងណាដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដូច្នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួនបួនគឺ ៖ (១) ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧% (២) បង្កើតការងារបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋ ជាពិសេសយុវជន (៣) សម្រេចឱ្យបានក្នុងការកាត់បន្ថយភាពក្រីក្រជារៀងរាល់ឆ្នាំជាង ១% (៤) ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដូច្នេះ ការផ្ដោតអារម្មណ៍ទៅលើផែនការយុទ្ធសាស្ត្រ វិស័យអប់រំឆ្នាំ២០១៤-២០១៨ គឺរំពឹងទៅលើការពង្រឹងនូវសមិទ្ធផល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលទទួលបានតាម រយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងទៅ ដោយធ្វើយ៉ាងណាលុបបំបាត់ឱ្យបានច្រើនបំផុតនូវអ្វីដែលជាបញ្ហាប្រឈមធំៗ ដែលធ្លាប់បានជួបប្រទះ និងដោយផ្តល់នូវការរៀនសូត្រមួយប្រកបដោយគុណភាពខ្ពស់ និងដែលពាក់ព័ន្ធដល់ការអភិវឌ្ឍជាតិ។ សេវាអប់រំត្រូវបានផ្តល់ប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាព ក្នុងគោលបំណងដើម្បីបណ្តុះគ្រឹះចំណេះដឹង ជំនាញសេដ្ឋកិច្ចមូលដ្ឋានរឹងមាំ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ បានដាក់ចេញក្របខណ្ឌគោលនយោបាយសំខាន់ចំនួនបី។

*គោលនយោបាយទី ១ ៖ ធានាការទទួលបាននូវសេវាអប់រំប្រកបដោយសមធម៌នៅគ្រប់កម្រិត*

(១) កុមារទាំងអស់មានសិទ្ធិទទួលបានគ្រប់ទម្រង់សេវាអប់រំ ដែលមានដូចជាការអប់រំកុមារតូច ការអប់រំនៅបឋមសិក្សា ការអប់រំនៅមធ្យមសិក្សា មានន័យថាកុមារទាំងអស់ទទួលបាននូវឱកាស ដើម្បីបន្តការរៀនសូត្ររបស់ខ្លួននៅគ្រប់កម្រិត។ សម្រាប់កុមារដែលមិនអាចចូលរៀនក្នុងប្រព័ន្ធអប់រំផ្លូវការ ពួកគេនឹងទទួលបាននូវការអប់រំមួយផ្សេងទៀតដែលស្របតាមតម្រូវការរបស់ពួកគេ។

(២) បង្កើនចំនួនកុមារ និងយុវជនដែលអាចទទួលបាននូវការអប់រំគ្រប់កម្រិតសិក្សា ជាមួយនឹងការយកចិត្តទុកដាក់ ដោយផ្តោតលើសមភាព និងការទទួលបាននូវសេវាអប់រំសម្រាប់តំបន់និងក្រុមកុមារជួបការលំបាកខ្លាំង។ បង្កើនឱកាសសម្រាប់កុមារដើម្បីបញ្ចប់ការអប់រំរយៈពេល ១២ ឆ្នាំ ប្រកបដោយចំណេះដឹង និងជំនាញត្រិះរិះច្បាស់លាស់ ព្រមទាំងជំនាញតក្កដែលអាចកសាងជំនាញ និងចំណេះដឹងទាំងនេះតាមរយៈការបណ្តុះបច្ចេកទេស ការបណ្តុះបណ្តាលនៅឧត្តមសិក្សា និងតាមរយៈមធ្យោបាយផ្សេងទៀត។

*គោលនយោបាយទី២ ៖ ការបង្កើនគុណភាព និងអ្វីដែលពាក់ព័ន្ធនឹងការរៀន*

(១) ធ្វើយ៉ាងណាឱ្យកុមារ និងយុវជនទាំងអស់ដែលមានចំណេះ និងជំនាញចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយប្រសិទ្ធភាព។

(២) ធានាឱ្យបានថាការរៀនសូត្រ គឺប្រកបដោយគុណភាពខ្ពស់ និងភ្ជាប់ការរៀនសូត្រទៅនឹងគោលដៅសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ និងបរិបទមូលដ្ឋាន ដោយប្រើប្រាស់ក្របខណ្ឌគុណភាពមួយដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀន និងអ្នកគ្រប់គ្រង នូវស្តង់ដាលទ្ធផល និងការត្រួតពិនិត្យ ព្រមទាំងរបាយការណ៍ពាក់ព័ន្ធនឹងការងារនេះ។

*គោលនយោបាយទី ៣ ៖ ធានាយ៉ាងមានប្រសិទ្ធភាពនូវភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដល់គ្រប់បុគ្គលិកអប់រំនៅគ្រប់កម្រិត*

ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈផ្តល់នូវគុណតម្លៃល្អបំផុត (ដោយផ្តោតសំខាន់លើលទ្ធផល)។ ការត្រួតពិនិត្យទាន់ពេលវេលា ត្រឹមត្រូវ និងការរាយ-ការណ៍អំពីលទ្ធផលជាមួយនឹងមតិត្រឡប់ គឺជាម៉ែត្រសម្រាប់វាស់ស្ទង់ប្រកបដោយគណនេយ្យភាព និង ជាយន្តការមួយសម្រាប់កែសម្រួលគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងស្ថាប័នអប់រំសាធារណៈអាចឆ្លើយតបទៅយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការនានានៅកម្រិតសាលារៀន។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺដើម្បីកសាងសង្គមកម្ពុជាមួយ ដែលមានសេចក្តីសុខសាន្តជាមួយនឹងស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ប្រែក្លាយជាប្រទេសមួយដែលមានវិបុលភាព ជាមួយនឹងកំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកបដោយចីរភាព និងសមភាព បង្កើនជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយភាពក្រីក្រ។ នៅចុងឆ្នាំ២០១៣ ប្រទេសកម្ពុជាសម្រេចបាន ៩៨% នៃអត្រាជាក់ស្តែងក្នុងការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា។

ទោះជាបែបនោះក្តី Hanushek និង Woessmann (ឆ្នាំ 2008) សង្កេតឃើញថា ការសិក្សាពីផលប៉ះពាល់នៃការអប់រំ លើកំណើនសេដ្ឋកិច្ច ដែលមិនបានមើលអំពីចំណេះជំនាញខុសៗគ្នា ផ្តល់ដោយសាលាដែលមានគុណភាពផ្សេងៗគ្នា វានឹងមានភាពលម្អៀងខ្ពស់ក្នុងការប៉ាន់ប្រមាណនូវផលប៉ះពាល់នៃការសិក្សារបស់សិស្ស។

បើប្រមើលមើលទៅថ្ងៃអនាគត កម្លាំងពលកម្មភាគច្រើនដែលចូលទៅក្នុងទីផ្សារការងារក្នុងពេលអនាគត ប្រសិនបើពួកគេមិនទទួលបានការអប់រំរហូតដល់កម្រិតមធ្យមសិក្សាទេ នឹងបង្កឱ្យមានឱនភាពក្នុងចង្វាក់ផលិតកម្មនៃផ្នែកសេដ្ឋកិច្ចសម្រាប់រយៈពេលជាច្រើនទសវត្សរ៍ទៅមុខ។ ដូច្នេះ កត្តាចាំបាច់នាពេលបច្ចុប្បន្ន គឺការពង្រឹងទាំងផ្នែកមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ រាជរដ្ឋាភិបាលនឹងផ្តោតលើការអភិវឌ្ឍធនធានមនុស្សដើម្បីធានាឱ្យមានការប្រកួតប្រជែងនៅក្នុងទីផ្សារការងារនៅក្នុងតំបន់ដែលបើកចំហកាន់តែខ្លាំងឡើងតាមរយៈ ៖ (១) ការបណ្តុះបណ្តាលពលករជំនាញ និងប្រកបដោយផលិតភាព ដើម្បីបំពេញតាមតម្រូវការទីផ្សារ និងបង្កើនគុណតម្លៃបន្ថែម (២) ការកសាងស្ថាប័នបណ្តុះបណ្តាលអប់រំ និងវិជ្ជាជីវៈ និងការអភិវឌ្ឍក្របខណ្ឌច្បាប់


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(៣) លើកទឹកចិត្តឱ្យមានការចូលរួមរបស់វិស័យឯកជន (៤) ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងការបង្កើតថ្មី។

គុណភាពនៃការអប់រំដែលបានផ្ដល់ គឺគ្មានការរើសអើងពូជសាសន៍ និងវប្បធម៌ ជំនឿសាសនា ចំពោះសិស្សានុសិស្ស និងនិស្សិតគ្រប់រូប។ គោលនយោបាយការអប់រំបញ្ចូលគ្នាបានបើកឱកាសដល់កុមារជនជាតិដើមភាគតិច និងក្រុមបាត់បង់ឱកាស ព្រមទាំងកុមារពិការឱ្យបានទទួលការអប់រំដែរ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបានផ្ដោតលើការធ្វើកំណែទម្រង់នៃកម្មវិធីអប់រំ ក្នុងគោលបំណងដើម្បីធ្វើឱ្យកម្មវិធីនេះអាចបត់បែនបាន និងដើម្បីតម្រូវទៅតាមតម្រូវការនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយផ្ដោតបន្ថែមទៀតលើការបណ្ដុះបណ្ដាលវិស្វករ អ្នកជំនាញកសិកម្ម និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

### ៣.១.៤ ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

គោលបំណងរួមរបស់ **មូលនិធិភាពជាដៃគូអភិវឌ្ឍសមត្ថភាព** (CDPF) (២០១១-២០១៤) គឺដើម្បីរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល ២០០៩-២០១៣ និងការអនុវត្ត ព្រមទាំងការត្រួតពិនិត្យផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសមិទ្ធផលនៃការអប់រំសម្រាប់ទាំងអស់គ្នា EFA និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជាតាមរយៈការអនុវត្តផែនការអភិវឌ្ឍសមត្ថភាព ២០១១-២០១៣ និងផែនការមេសម្រាប់ការអភិវឌ្ឍសមត្ថភាព ២០១១-២០១៥។ គោលបំណងនៃ CDPF គឺដើម្បីគាំទ្រដល់ការអនុវត្តគោលដៅអភិវឌ្ឍសមត្ថភាពនៃផែនការវិស័យ ព្រមទាំងផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) ដែលបានដំណើរការ តាមរយៈផែនការអភិវឌ្ឍសមត្ថភាព ២០១១-២០១៣ និងផែនការមេសម្រាប់ការអភិវឌ្ឍសមត្ថភាព ២០១៣-២០១៥។

អនុគោលបំណងទាំងបីរបស់ CDPF មានដូចខាងក្រោម ៖

**ទីមួយ–** ពង្រឹងសមត្ថភាពក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើផែនការគ្រប់គ្រងអប់រំ និងការត្រួតពិនិត្យសម្រាប់ការផ្ដល់សេវាអប់រំ គុណផលគុណវិស័យ និងលទ្ធផលឱ្យកាន់តែមានភាពប្រសើរឡើង។

**ទីពីរ–** ពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើយ៉ាងណាដើម្បីធានានិរន្តរភាពនៃភាពប្រទាក់ក្រឡា និងទំនាក់ទំនងរវាងម៉ាក្រូ និងដំណើរការនៃកំណែទម្រង់កម្រិតគុណវិស័យ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្ដល់សេវាអប់រំ អភិបាលកិច្ច ជាពិសេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ និងសេវាស៊ីវិល/ កំណែទម្រង់រដ្ឋបាល។

**ទីបី–** ពង្រឹងសមត្ថភាពក្នុងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពក្រសួងអប់រំ យុវជន និងកីឡា ក្នុងការស្រូបប្រសិទ្ធភាពប្រព័ន្ធធ្វើឱ្យប្រសើរឡើង, ការផ្ដល់សេវាអប់រំ និងប្រព័ន្ធគណនេយ្យភាព។

កម្មវិធី CDPF ២០១១-២០១៤ គឺជាមូលនិធិទទួលពីពហុភាគីដែលបានគ្រប់គ្រងដោយអង្គការ UNICEF និងផ្ដល់ហិរញ្ញវត្ថុដោយសហភាពអឺរ៉ុប (៧ ៤៥0 000 អឺរ៉ូ), ប្រទេសស៊ុយអែត (sek ២១ 000 000) និង UNICEF ($១ ៥00 000)។ ជំនួយមូលនិធិសរុបគឺស្មើនឹង ១៤,១ លានដុល្លារអាមេរិក។

កម្មវិធី CDPF ត្រូវបានគ្រប់គ្រងដោយគណៈកម្មការដឹកនាំ (Steering Committee) ដែលដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយរួមសហការជាមួយសហភាពអឺរ៉ុប និងដោយមានសមាសភាពថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក និងនាយកដ្ឋានផែនការ ព្រមទាំងអ្នកតំណាងស្ថានទូតស៊ុយអែត។ គណៈកម្មការដឹកនាំបានធ្វើការសម្រេចចិត្តបែបយុទ្ធសាស្ត្រដោយផ្អែកលើរបាយការណ៍ វិសោធនកម្ម និងផែនការ។ លេខាធិការ CDPF រៀបចំឯកសារសំខាន់ៗសម្រាប់គណៈកម្មការដឹកនាំ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ នេះជាការផ្ដើមចេញពីនាយកដ្ឋានផែនការ បុគ្គលិក និងហិរញ្ញវត្ថុ ព្រមទាំង UNICEF។

កម្មវិធី CDPF ទទួលស្គាល់ថា ការអភិវឌ្ឍសមត្ថភាពពហុវិស័យនឹងក្លាយជាជំនួយអន្តរាគមន៍នៅថ្នាក់ស្ថាប័ន អង្គភាព និងបុគ្គល ក្នុងការសម្របសម្រួលដល់ផលប៉ះពាល់លើវិស័យនីមួយៗ។ ក្នុងឆន្ទៈដ៏ខ្លាំងក្លានៃការផ្ដល់ជំនួយដ៏មានប្រសិទ្ធភាព កម្មវិធី CDPF បានបង្កើតស្របនឹងផែនការមេរបស់ក្រសួងអប់រំ យុវជននិងកីឡា សម្រាប់ការអភិវឌ្ឍសមត្ថភាពឆ្នាំ២០១១-២០១៥ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ សម្រាប់ការអនុវត្តបន្ត។ លក្ខខណ្ឌសម្រាប់អន្តរាគមន៍ដែលគាំទ្រដោយកម្មវិធី CDPF គឺត្រូវតែស្របទៅនឹងការពង្រឹងប្រព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយមិនអនុវត្តលើគម្រោងដូចគ្នា ដែលទទួលបានការឧបត្ថម្ភពីរដ្ឋាភិបាលដូចជាការប្រើប្រាស់ថវិកាកម្មវិធី ឬថវិកាដៃគូអភិវឌ្ឍន៍ និងមិនរាប់បញ្ចូលនឹងការជួយដោយផ្ទាល់លើការផ្ដល់សេវាដូចជាសៀវភៅ និងការបណ្ដុះបណ្ដាលគ្រូនោះឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលដៅនៃកម្មវិធី CDPFសម្រាប់ឆ្នាំ២០១៣-២០១៤ គឺ ៖ (១) ពង្រឹងសមត្ថភាពលើការអភិវឌ្ឍគោលនយោបាយ ផែនការ និងការសិក្សា (២)ផ្តល់ជំនួយហិរញ្ញវត្ថុនិងប្រព័ន្ធធនធានមនុស្ស និង (៣) ផែនការនិងការគ្រប់គ្រងនៅកម្រិតសាលា។

កម្មវិធី CDPF គឺកំពុងគាំទ្រលើស្ថាប័នសំខាន់មួយចំនួនដូចជា វិទ្យាស្ថានអន្តរជាតិផែនការនីយកម្មអប់រំ (IIEP), វិទ្យាស្ថានជាតិអប់រំ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ កម្មវិធី CDPF គឺកំពុងគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបោះជំហានទៅមុខក្នុងការធ្វើស្ថាប័ននីយកម្មនៅថ្នាក់ស្រុក ខេត្ត និងជាតិសម្រាប់ការគ្រប់គ្រងនិងផែនការ។

ជាក់ស្តែង នាយកដ្ឋានផែនការត្រូវបានទទួលការគាំទ្រក្នុងការអភិវឌ្ឍសមត្ថភាពលើផ្នែកបច្ចេកទេស និងនៅថ្នាក់ក្រោមជាតិ លើផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រអប់រំ សម្រាប់ថ្នាក់ខេត្ត ការវិភាគទិន្នន័យ និងការអភិវឌ្ឍសូចនាករអប់រំ ការសរសេររបាយការណ៍នៅក្នុងសន្និបាតអប់រំ។

តួនាទីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំស្រុកត្រូវបានផ្តល់ឱ្យឃើញច្បាស់នូវការគាំទ្រដោយអាទិភាពលើតម្រូវការអភិវឌ្ឍសមត្ថភាព និងលទ្ធភាពក្នុងការដោះស្រាយតម្រូវការទាំងនោះ។ នេះក៏ជាផ្នែកមួយនៃការជួយ និងពង្រឹងដល់កំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការក្នុងការកសាងជំនាញគ្រប់គ្រង និងផែនការ ក៏ដូចជាពង្រីកវិសាលភាពនៃការទទួលខុសត្រូវលើខ្ទង់ចំណាយផ្សេងៗ។

ការគាំទ្រនេះ ត្រូវបានផ្តល់ដល់នាយកដ្ឋានបុគ្គលិកក្នុងការបន្តធ្វើស្ថាប័ននីយកម្ម និងពង្រឹងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HRMIS)។ ការគាំទ្រលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ក៏ជាអាទិភាពសំខាន់មួយនៃកម្មវិធី CDPF ដែលជាលទ្ធផល នាយក-ដ្ឋានហិរញ្ញវត្ថុបានផ្តល់ការបណ្តុះបណ្តាល លើដំណើរការទូទាត់ការចំណាយថវិកាកម្មវិធីនៅនាយកដ្ឋាន និងការិយាល័យបុគ្គលិក។

កម្មវិធី CDPF ដំណាក់កាលទី២ បានចាប់ផ្តើមក្នុងខែមករា ឆ្នាំ២០១៥ និងបញ្ចប់ក្នុងខែធ្នូ ឆ្នាំ២០១៦ និងមានទឹកប្រាក់ប្រមាណ ១១លានដុល្លាអាមេរិក។ នេះក៏ស្របទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងសេចក្តីព្រាងផែនការមេសម្រាប់ការអភិវឌ្ឍសមត្ថភាពឆ្នាំ២០១៤-២០១៨។ ផ្នែកសំខាន់ៗដែលត្រូវបានគាំទ្រមានដូចជាការបណ្តុះបណ្តាលថ្នាក់ក្រសួង ជំនួយបច្ចេកទេស ទស្សនកិច្ចសិក្សា ការបណ្តុះបណ្តាលខាងក្រៅ ព្រមទាំងភាពជាដៃគូជាមួយនឹង IIEP ដែលមានដូចជា ៖

- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ប្រព័ន្ធលើកទឹកចិត្តការងារ និងការគ្រប់គ្រងព័ត៌មានធនធានមនុស្ស
- វិមជ្ឈការ និងសហវិមជ្ឈការ
- ការគ្រប់គ្រង និងការកសាងផែនការសាលារៀន-ការបណ្ដុះបណ្ដាលគណៈកម្មការទ្រទ្រង់សាលាដោយនាយកដ្ឋានបឋម និងអង្គការ CARE
- ការស្រាវជ្រាវផ្ដោតលើគោលនយោបាយ។

ការធ្វើឱ្យប្រសើរលើការគ្រប់គ្រងទូទៅនៃបុគ្គលិកក្នុងក្រសួង បានត្រូវធ្វើឡើងតាមការរៀបចំជាប្រព័ន្ធលើកទឹកចិត្តការងារបុគ្គលិក ឱ្យស្របតាមកំណែទម្រង់រដ្ឋបាលសាធារណៈ។ សេចក្ដីណែនាំទូទៅលើការគ្រប់គ្រង និងផែនការការងារ ការរៀបចំដំណើរ-ការ និងប្រព័ន្ធថ្នាក់ជាតិត្រូវបានបង្កើតឡើង និងអភិវឌ្ឍ។

តួនាទី និងការទទួលខុសត្រូវនៃគណៈកម្មការទ្រទ្រង់សាលានៅបឋមសិក្សាត្រូវបានបង្ហាញតាមរយៈការអភិវឌ្ឍនៃសេចក្ដីណែនាំគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាដែលត្រូវបានអនុម័តនៅខែកញ្ញា ឆ្នាំ២០១២ និងបញ្ជូនដល់២៥រាជធានី ខេត្ត ជាមួយនឹងការបណ្ដុះបណ្ដាលដល់អ្នកទទួលខុសត្រូវនៃរាជធានី ខេត្តមួយចំនួន ដោយនាយកដ្ឋានបឋមសិក្សា និងអង្គការ CARE ក្នុងខេត្តរតនគិរី។

បច្ចុប្បន្នមានការយកចិត្តទុកដាក់ខ្លាំងលើសារៈសំខាន់នៃការអភិវឌ្ឍសមត្ថភាព និងផែនការស្ថាប័នដើម្បីសម្រេចបាននូវវត្ថុបំណងនៃវិស័យអប់រំ។

កម្មវិធី CDPF គាំទ្រនាយកដ្ឋានផែនការក្នុងការរចនារៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ក្រោមការដឹកនាំរបស់អ្នកផ្ដល់ប្រឹក្សាជាន់ខ្ពស់ផ្នែកផែនការ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺជាផែនការគោលសម្រាប់បង្ហាញផ្លូវដល់កំណែទម្រង់គ្រប់អនុវិស័យដោយផ្អែកលើការរៀបចំផែនការផ្អែកលើលទ្ធផល និងពង្រីកផ្នែកហិរញ្ញវត្ថុឱ្យបានទូលាយ។

កម្មវិធីជំនួយ CDPF បានផ្ដល់លទ្ធភាពដល់ការអភិវឌ្ឍផែនការមេលើប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំឆ្នាំ ២០១៤-២០១៨ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ការបង្កើនសមត្ថភាពដល់ប្រព័ន្ធបច្ចុប្បន្ន ការធ្វើប្រតិភូកម្ម ការទទួលខុសត្រូវសម្រាប់ការបញ្ចូលទិន្នន័យដល់ថ្នាក់ស្រុកតាមទម្រង់វេបសាយ។ ក្នុងចក្ខុវិស័យ ទម្រង់បែបនេះនឹងធ្វើការលើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទិន្នន័យនៃលទ្ធផលសិក្សា សាលាវិជ្ជាជីវៈ និងឯកជន ការស្ទង់មតិ សុខភាពប្រជាជន និង សង្គមសេដ្ឋកិច្ចប្រទេសកម្ពុជា ស្ថាប័នឧត្តមសិក្សា ក៏ដូចជាប្រព័ន្ធព័ត៌មានគ្រប់គ្រង ហិរញ្ញវត្ថុ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ដើម្បីក្លាយជាឧបករណ៍ដ៏មានតម្លៃ សម្រាប់ការសម្រេចចិត្តលើការគ្រប់គ្រងនិងផែនការ។

ការធ្វើឱ្យប្រសើរលើការងារគ្រប់គ្រងទូទៅនៃបុគ្គលិកក្នុងក្រសួង ត្រូវបានធ្វើឡើង តាមការរៀបចំជាប្រព័ន្ធលើកទឹកចិត្តការងារបុគ្គលិក ឱ្យស្របតាមកំណែទម្រង់រដ្ឋបាល សាធារណៈ។ សេចក្តីណែនាំទូទៅលើការគ្រប់គ្រង និងផែនការការងារ ការរៀបចំដំណើរ ការ និងប្រព័ន្ធថ្នាក់ជាតិត្រូវបានបង្កើត និងអភិវឌ្ឍ។

តួនាទីនិងការទទួលខុសត្រូវនៃគណៈកម្មការទ្រទ្រង់សាលានៅបឋមសិក្សាត្រូវ បានបង្ហាញតាមរយៈការកសាងសេចក្តីណែនាំគណៈកម្មការទ្រទ្រង់សាលានៅបឋម សិក្សា ដែលត្រូវបានអនុម័តនៅខែកញ្ញា ឆ្នាំ២០១២ និងបញ្ជូនដល់ ២៤រាជធានី ខេត្ត ជាមួយនឹងការបណ្តុះបណ្តាលនៅខេត្តមួយចំនួន ដោយនាយកដ្ឋានបឋមសិក្សា និង អង្គការ CARE ក្នុងខេត្តរតនគិរី។

នៅឆ្នាំ២០១២ និង២០១៣ នាយកសាលាវិទ្យាល័យចំនួន ៨៤៤នាក់ (ក្នុងនោះ៦៩ នាក់ជាស្ត្រី) នៅទូទាំងប្រទេសត្រូវបានទទួលការបំប៉នលើជំនាញគ្រប់គ្រងនិងការងារ រដ្ឋបាល ស្វ័យវាយតម្លៃសាលា និងការធ្វើផែនការឱ្យបានប្រសើរ ជំនាញវិជ្ជាជីវៈនិងទំនាក់ ទំនងរវាងសាលារៀន និងសហគមន៍។

ក្នុងឆ្នាំ២០១៣ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបញ្ចប់ការស្រាវជ្រាវដ៏សំខាន់ មួយដែលដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា លើកំណែទម្រង់កម្មវិធីសិក្សានៅ មធ្យមសិក្សាទុតិយភូមិក្នុងប្រទេសកម្ពុជា ដោយពិនិត្យមើលពីទំនាក់ទំនងទីផ្សារការងារ និងការអប់រំកម្រិតឧត្តមសិក្សា។ ការស្រាវជ្រាវនេះបានវាយតម្លៃលើប្រសិទ្ធភាពនៃកំណែ ទម្រង់កម្មវិធីសិក្សានៅសាលាមធ្យមសិក្សាទុតិយភូមិ។ លទ្ធផលនៃការស្រាវជ្រាវបាន បង្ហាញថា មានគម្លាតរវាងសៀវភៅសិក្សាគោល កម្មវិធីសិក្សា និងការរំពឹងទុករបស់វិនិ- យោគិន។ ការស្រាវជ្រាវនេះបានក្លាយជាពន្លឺអាទិភាពដល់កំណែទម្រង់នៃវិស័យ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.១.៤. វិមជ្ឈការ និងវិសហមជ្ឈការ

វិមជ្ឈការនៃការគ្រប់គ្រងអប់រំ ត្រូវបានក្លាយជាចំណុចអាទិភាពនៃក្រសួងអប់រំ យុវជន និងកីឡា។ តែទោះជាយ៉ាងណា សមត្ថភាពនៅមូលដ្ឋានក្នុងការទទួលខុសត្រូវ និងសកម្មភាពក្នុងការធ្វើឱ្យប្រសើរឡើងនៃសេវាអប់រំគឺនៅមានកម្រិត។ ការបែងចែកថវិកា និងការចំណាយលើប្រាក់ឧបត្ថម្ភបានធ្លាក់ចុះគួរកត់សម្គាល់ ដែលជាការចំណាយផ្ទួនៗលើការអប់រំ ដោយសារកិច្ចខិតខំប្រឹងប្រែងក្នុងគោលនយោបាយបង្កើនជំនួយមិនមែនប្រាក់ឧបត្ថម្ភ។ ជាលទ្ធផល មានការធ្លាក់ចុះចំណែកថវិកាក្នុងប្រាក់បៀវត្សពី៧៨%នៅឆ្នាំ ១៩៩៧ មក ៦០%នៅឆ្នាំ២០០៥។

វត្ថុបំណងនៃគោលនយោបាយនេះគឺផ្តល់លទ្ធភាពក្នុងការធ្វើវិមជ្ឈការគ្រប់គ្រង និងត្រួតពិនិត្យអប់រំ តាមរយៈការិយាល័យអប់រំស្រុក មន្ទីរអប់រំ និងថ្នាក់អធិការកិច្ចអប់រំ។ សន្ទុះនៃអន្តរាគមន៍ទាំងនេះ បានជំរុញដល់គោលនយោបាយថ្មីនៃអធិការកិច្ចសាលា ក្នុងបំណងពន្លឿនការពង្រឹងសេវាគាំទ្រដោយផ្ទាល់ និងការឆ្លើយតបទៅនឹងតម្រូវការសាលា។

## ៣.២. គោលនយោបាយក្នុងការលើកកម្ពស់គុណភាព និងសមធម៌អប់រំ

### ៣.២.១. គោលនយោបាយ អប់រំបំណិនជីវិត ឆ្នាំ២០១៦

បំណិនជីវិតបានក្លាយជាធនធានដ៏សំខាន់សម្រាប់គ្រូបង្រៀន សាលារៀន ស្ថាប័នអប់រំ មជ្ឈមណ្ឌលសិក្សាសហគមន៍ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា។ បំណិនជីវិតត្រូវបានកំណត់ថាជា «បំណិនបញ្ញា បុគ្គលិកលក្ខណៈអន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែក ក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព»។ មានការចែកបំណិនជីវិតជា២ប្រភេទគឺ **បំណិនមូលដ្ឋាន** និង**បំណិនអាជីព**។

**បំណិនមូលដ្ឋាន** ជាបំណិនចាំបាច់ដែលអ្នកសិក្សាគ្រប់រូបត្រូវតែទទួលបាន ដើម្បីជាគ្រឹះមូលដ្ឋាន សម្រាប់ការរស់នៅនិងមាន (១) បំណិនជីវិតទូទៅ មានដូចជាសុខភាព អនាម័យ សុវត្ថិភាព ការធ្វើផែនការសម្រាប់ជីវិតប្រចាំថ្ងៃ ការរៀបចំចាត់ចែង ការធ្វើទំនាក់ទំនង និងភាពជាពលរដ្ឋល្អប្រកបដោយសីលធម៌ខ្ពស់ (២) បំណិនបុរេវិជ្ជាជីវៈ ដែលអាចឱ្យសិស្សចូលរួមក្នុងការងារពលកម្ម ឬ សហគមន៍របស់គេ បំណិនក្នុងការធ្វើទំនាក់-ទំនង បំណិនគណិតវិទ្យា បំណិនក្នុងការដោះស្រាយបញ្ហា និងបំណិនក្នុងការចេះធ្វើការងារជាក្រុម។ បំណិនទាំងនេះ ត្រូវបានបង្រៀនដល់អ្នកសិក្សាគ្រប់រូប ដែលជាផ្នែកមួយនៃកម្មវិធីសិក្សាថ្នាក់ជាតិនៃការអប់រំមូលដ្ឋាន និងការអប់រំក្រៅប្រព័ន្ធ។

**បំណិនអាជីព** ជាបំណិនដែលសិស្សអាចជ្រើសរើសសិក្សា ដើម្បីជាសញ្ញាណវិជ្ជាជីវៈមូលដ្ឋាន សម្រាប់ឈានទៅដល់អាជីពមួយច្បាស់លាស់នាពេលអនាគត។ បំណិនអាជីពមាន ៖

(១) **បំណិនអាជីពងាយ** ជាបំណិនដែលទាក់ទងនឹងមុខជំនាញសាមញ្ញ ដោយត្រូវការបណ្តុះបណ្តាលរយៈពេលខ្លី និងបច្ចេកទេសងាយៗ សម្រាប់ឱ្យអ្នកសិក្សាមានលទ្ធភាពលើកកម្ពស់ជីវភាព ឬបង្កើនសេដ្ឋកិច្ចគ្រួសារ។ អ្នកសិក្សាម្នាក់ៗ មានវិធីសាស្ត្រផ្សេងៗគ្នាក្នុងការអភិវឌ្ឍបំណិនអាជីពងាយ អាស្រ័យលើធនធាន តម្រូវការមូលដ្ឋាន និងចំណង់ចំណូលចិត្តរបស់គេផ្ទាល់។ បំណិនទាំងនោះរួមមាន ការកាត់ដេរសម្លៀកបំពាក់ ជំនាញកាត់សក់ ដាំបន្លែ ចិញ្ចឹមសត្វ មុខរបរតិចតួច ជួសជុលម៉ូតូនិងកង់ ផលិតឧបករណ៍កសិកម្ម ផលិតឧបករណ៍តម្បាញ ចម្លាក់ ការកែសម្ផស្ស គន្ធ្រីប្រពៃណី សិល្បៈ និងរបាំ ។

(២) **បំណិនវិជ្ជាជីវៈ** ជាបំណិនដែលទាក់ទងទៅនឹងមុខជំនាញឯកទេស ដោយត្រូវការវគ្គបណ្តុះបណ្តាលរយៈពេលមធ្យម និងវែង ព្រមទាំងសមត្ថភាពបច្ចេកទេសកម្រិតខ្ពស់ សម្រាប់អ្នកសិក្សាគ្រប់រូប ធ្វើជាទុនក្នុងការប្រកបមុខរបរនានា ដើម្បីចិញ្ចឹមជីវិត។ បំណិនទាំងនេះទាក់ទងនឹងទេសចរណ៍ គណនេយ្យ បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ព្រមទាំងការគ្រប់គ្រង។

បំណិនជីវិតត្រូវបានបង្រៀនទាំងក្នុងសាលាអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ។ នៅក្នុងកម្រិតអប់រំមូលដ្ឋាន បំណិនជីវិតត្រូវបានបញ្ចូលជាកម្មវិធីសិក្សាស្នូលក្នុងមុខវិជ្ជាស្នូលមួយចំនួនដូចជា ៖ ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រពិត និងសិក្សាសង្គម។ នៅសាលាអប់រំក្រៅប្រព័ន្ធ បំណិនជីវិតត្រូវបានផ្តល់ក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីក្រោយអក្ខរកម្ម កម្មវិធីសមមូល ព្រមទាំងកម្មវិធីបង្កើនប្រាក់ចំណូល។

### ៣.២.២ គោលនយោបាយ សាលាកុមារមេត្រី ២០០៧

ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការទទួលបានការអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័ត **គោលនយោបាយសាលាកុមារមេត្រី** នៅឆ្នាំ២០០៧ បន្ទាប់ពីការដាក់ឱ្យអនុវត្តសាកល្បង ប្រកបដោយជោគជ័យជាង១៤ឆ្នាំមក (១៩៩៣-២០០៦) និងបានពង្រីកគោលដៅដល់ ១០ រាជធានី ខេត្ត នៅទូទាំងប្រទេស។ គោលនយោបាយនេះគ្របដណ្តប់គ្រប់សាលាអប់រំមូលដ្ឋាននៅទូទាំងប្រទេស។ នេះមានន័យថា ជាការធានាឱ្យសាលាកុមារមេត្រី ក្លាយជាសាលាស្វែងរកកុមារ សាលាសិស្សមជ្ឈមណ្ឌល និងសាលា

ដែលមានបរិស្ថានល្អ។ វត្ថុបំណងនៃគោលនយោបាយនេះគឺ ៖ (១) ការអនុវត្តសិទ្ធិកុមារដែលទទួលស្គាល់ជាសកល (២) ការចុះឈ្មោះចូលរៀនរបស់កុមារ និងការអប់រំបន្ត (៣) ការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពការអប់រំមូលដ្ឋាន និង (៤) ការសិក្សារបស់កុមារគ្រប់រូបត្រូវបានដោះស្រាយ។

គោលនយោបាយសាលាកុមារមេត្រីបង្ហាញពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព និងគោលការណ៍អនុវត្ត សម្រាប់ការអប់រំមូលដ្ឋានតាមរយៈការអនុវត្តសមាសភាគទាំង ៦ រួមមាន ៖ (១) សមធម៌ក្នុងការចូលរៀន (២) ប្រសិទ្ធភាពការអប់រំ (៣) ការគាំពារកុមារ (៤) សមភាពយេនឌ័រ (៥) ការចូលរួមរបស់កុមារ និង (៦) ការគាំទ្រថ្នាក់ជាតិ។ ចក្ខុវិស័យនៃនយោបាយស្តីពីសាលាកុមារមេត្រី គឺធានាថា កុមារដល់វ័យ និងក្នុងវ័យសិក្សាទាំងអស់បានចូលរៀន និងទទួលបានការអប់រំប្រកបដោយគុណភាព យ៉ាងហោចណាស់ត្រឹមកម្រិតអប់រំមូលដ្ឋាន។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម ៖

**ទីមួយ**–បង្កើតក្របខណ្ឌគតិយុត្តិ និងយន្តការ ដើម្បី (១) ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយ និង (២) ការកសាងផែនការសកម្មភាពជាក់ស្តែង ដោយមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងស្ថាប័នទទួលខុសត្រូវ។

**ទីពីរ**–ធានាថាកុមារទាំងអស់បានចូលរៀន តាមរយៈ (១) ការរៀបចំផែនទីសិក្សា និងផែនទីខ្នងផ្ទះ (២) ការប្រមូលនិងប្រើទិន្នន័យព័ត៌មានឱ្យមានប្រសិទ្ធភាព និង (៣) ការបើកយុទ្ធនាការចុះឈ្មោះចូលរៀនគ្រប់រូបភាព (៤) ការលើកទឹកចិត្តសិស្សបោះបង់ការសិក្សាឱ្យត្រឡប់មករៀនវិញ និងការបង្កើនអត្រាឆ្លងភូមិសិក្សា និងអត្រាបញ្ចប់ការសិក្សា។

**ទីបី**–ធានាការបង្រៀន និងរៀនដោយប្រសិទ្ធភាព តាមរយៈ (១) ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល (២) រៀបចំបន្ទប់រៀនតាមមុខវិជ្ជាសម្រាប់អប់រំនៅមធ្យមសិក្សាបឋមភូមិ និងភាសាបរទេសនៅបឋមសិក្សា (៣) ការជួយសិស្សរៀនយឺត ឱ្យរៀនទាន់គេ និងការធ្វើតេស្តឡើងថ្នាក់ចុងឆ្នាំ និងដើមឆ្នាំសិក្សា (៤) ការបំប៉នគ្រូឯកទេសសម្រាប់ការអប់រំពិសេស (៥) ការជម្រុញការសិក្សាភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) និង (៦) ការបង្កើនការប្រើប្រាស់ឧបករណ៍សម្ភារឧបទេស ក្នុងការបង្រៀន និងរៀននៅមធ្យមសិក្សាបឋមភូមិ ជាពិសេសសម្រាប់មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជីបួន**–ធានាសុខភាព សុវត្ថិភាព និងការពារកុមារ តាមរយៈ (១) ការលើកកម្ពស់ការអប់រំសុខភាព អនាម័យល្អ និងបំណិនជីវិត (២) ការផ្តល់ការពិនិត្យសុខភាព និងសេវាសុខភាព (៣) ការរៀបចំបរិស្ថានសាលារៀន ប្រកបដោយសុវត្ថិភាព (៤) ការលើកកម្ពស់សកម្មភាពអប់រំកាយ កីឡា និងសិល្បៈ (៥) ការផ្តល់ឧបករណ៍ជំនួយសម្រាប់កុមារពិការ (៦) ការផ្តល់អាហារូបត្ថម្ភដល់កុមារនៅក្នុងតំបន់ងាយរងគ្រោះ ជាពិសេសកុមារី និង (៧) ការបំពាក់សម្ភារបរិក្ខារអនាម័យតាមនិយាមត្រឹមត្រូវ។

**ជីប្រាំ**–ធានាសមភាពយេនឌ័រ តាមរយៈ (១) ការបញ្ជ្រាបយេនឌ័រ នៅគ្រប់សមាសភាគ (២) ការលើកកម្ពស់សមភាពយេនឌ័រក្នុងការដឹកនាំ ដោយផ្តល់អាទិភាពដល់កុមារី។

**ជីប្រាំមួយ**–ធានាការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ តាមរយៈ (១) ការបំផុសចលនាប្រឡងប្រណាំងកុមារបីល្អ (២) ការបំផុសកុមារឱ្យចូលរួមក្នុងចលនាសង្គម (៣) ការលើកកម្ពស់ភាពជាអ្នកដឹកនាំក្នុងចំណោមកុមារ (៤) ការបង្កើតមូលនិធិសម្រាប់សាលារៀន (៥) ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការទ្រទ្រង់សាលារៀន និង (៦) ការលើកទឹកចិត្តឱ្យមានការរៀបចំកម្រងស្នាដៃសិស្ស និងការតាំងពិព័រណ៍ស្នាដៃសិស្ស។

ដើម្បីសម្រេចបាននូវអ្វីដូចបានរៀបរាប់ខាងលើ ត្រូវផ្តល់អាហារូបករណ៍ និងអាហាពេលព្រឹកដោយមិនគិតថ្លៃ ដើម្បីបង្កើនការចូលរៀនសម្រាប់សិស្សក្រីក្រនៅបឋមសិក្សា។ ការអនុវត្តកម្មវិធីអំណានសម្រាប់ថ្នាក់ទី១ ដល់ទី៣ បានចូលរួមចំណែកក្នុងការលើកកម្ពស់ការអាននិងសរសេរ។ ក្រសួងបានផ្តល់មធ្យោបាយដឹកជញ្ជូនដល់ក្រុមពិនិត្យតាមដាននៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ស្រុក ខណ្ឌដើម្បីអនុវត្តនិងជួយសាលាកុមារមេត្រី។ ដោយអនុវត្តការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ គ្រូអាចបញ្ជាក់អត្តសញ្ញាណកុមារពិការដែលអាចរៀនបាន និងផ្តល់ឱ្យពួកគេនូវជំនួយចាំបាច់នានា។ ដើម្បីលើកកម្ពស់ការអាន ត្រូវរៀបចំគោលនយោបាយដោយផ្តល់ជាបរិក្ខារ និងបណ្ណាល័យ។ គុណភាពជាក់លាក់ដែលជាធាតុចូលសម្រាប់គោលនយោបាយនេះ រួមមានការអប់រំបញ្ចូល ប្រសិទ្ធភាពបង្រៀន និងរៀន ការរៀបចំការបណ្តុះបណ្តាលគ្រូ និងការសិក្សាស្តីអំពីអត្រាប្រេវ៉ាឡង់ជនពិការ។

ពាក់ព័ន្ធនឹងបញ្ហានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានគាំទ្របន្ថែមលើកម្មវិធីសាលាកុមារមេត្រី(សាលាកុមារមេត្រីមានចំនួន ៤ ៥០៥ សាលានៅឆ្នាំ២០១១/១២ ស្មើ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នឹង៦៥,៨% ក្នុងចំណោមសាលាបឋមសិក្សាទាំងអស់) ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនការចូលរៀន ការបង្ការការបោះបង់ការសិក្សា និងការលើកទឹកចិត្តឱ្យបញ្ចប់ការសិក្សា។ លើសពីនេះទៀត ក្រសួងបានជំរុញឱ្យនាយកសាលា និងក្រុមពិនិត្យតាមដានអនុវត្តឱ្យបានពេញលេញលើគោលនយោបាយសាលាកុមារមេត្រី ដោយធានាការអនុវត្តអប់រំពីរភាសា កម្មវិធីរៀនឡើងវិញ ការបង្កើនកម្មវិធីរៀន ការរៀបចំកាលវិភាគដែលមានភាពទន់ភ្លន់។ល។ ព្រមទាំងការគាំទ្រការផ្តល់សៀវភៅសិក្សាគោលដើម្បីធានាដល់ការបង្រៀន និងរៀនប្រកបដោយគុណភាពដើម្បីឱ្យកុមារទទួលនូវការយល់ដឹង និងជំនាញដោះស្រាយបញ្ហា។

### ៣.២.៣ គោលនយោបាយស្តីពី **ការអប់រំកុមារពិការ** (២០០៨)

គោលនយោបាយស្តីពី **ការអប់រំកុមារពិការ** មានគោលបំណងជួយគាំទ្រដល់ការអនុវត្តគោលនយោបាយសាលាកុមារមេត្រី និងធ្វើឱ្យស្ថាប័នអប់រំមានការយល់ដឹងកាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការផ្តល់លទ្ធភាពដល់កុមារពិការគ្រប់ប្រភេទឱ្យទទួលបានការអប់រំ និងការអភិវឌ្ឍ ក្នុងគោលដៅប្រែក្លាយពួកគេឱ្យទៅជាសមាជិកសកម្មក្នុងការចូលរួមកសាងសង្គមជាតិ។

គោលនយោបាយនេះរៀបចំឡើង ដើម្បីបង្កើនការយល់ដឹងពីពិការភាព កំណត់អត្តសញ្ញាណពិការភាព និងផ្តល់អន្តរាគមន៍ទាន់ពេល លើសេវាស្តារលទ្ធភាពពលកម្ម សេវាសុខភាព ការចាក់ថ្នាំបង្ការ ការផ្តល់ការអប់រំប្រកបដោយគុណភាព រួមទាំងផ្តល់ការអប់រំបំណិនជីវិត ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើនអត្រាប្រមូលកុមារចូលរៀន និងអត្រាគង់វង្សរបស់កុមារពិការ។ គោលនយោបាយស្តីពី **ការអប់រំកុមារពិការ** មានសមាសភាគចំនួន ៦ ដូចខាងក្រោម ៖

- **កុមារគ្រប់រូបត្រូវបានចូលរៀន (បរិយាប័ន្ន)**៖ ត្រូវបញ្ជាក់អត្តសញ្ញាណ និងចុះឈ្មោះកុមារងាយពិការទាំងអស់នៅគ្រប់សហគមន៍នៅក្នុងប្រទេសកម្ពុជា
- **ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព** ៖ ដើម្បីផ្តល់ឱ្យកុមារពិការគ្រប់រូបទទួលបានសេវាអប់រំសមស្របទៅតាមតម្រូវការរបស់គេ ដូចជា ៖ សុខភាព ការស្តារនិតិសម្បទាសហគមន៍ និងការកែលម្អសេវាអប់រំពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាបឋមភូមិ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- **សុខភាព សុវត្ថិភាព និងការការពារកុមារ ៖** ដើម្បីធានាថាកុមារគ្រប់រូប ជាពិសេសកុមារពិការ បានចូលរៀន និងបានចូលរួមនៅគ្រប់សកម្មភាពរបស់សាលា និងសង្គម
- **ការឆ្លើយតបទៅនឹងយេនឌ័រ ៖** ធានាដល់កុមារគ្រប់រូប ពិសេសកុមារពិការឱ្យបានចូលរៀន និងបានចូលរួមក្នុងសកម្មភាពសាលារៀននិងសង្គម
- **ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍នៅក្នុងដំណើរការសាលាក្នុងសហគមន៍របស់ខ្លួន ៖** ដើម្បីបង្កើនការយល់ដឹង និងការទទួលស្គាល់កុមារពិការ និងតម្រូវការរបស់កុមារពិការនៅក្នុងសហគមន៍ និងក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងការផ្តល់ការអប់រំដល់កុមារពិការទាំងនោះ
- **ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ៖** ដើម្បីធានាការគាំទ្រសម្រាប់ការអប់រំកុមារពិការ ឱ្យមានប្រសិទ្ធភាពនៅគ្រប់កម្រិតអប់រំ។

### ៣.២.៤ គោលនយោបាយស្តីពី កម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ (២០០៨)

**កម្មវិធីសមមូល** គឺជាសមាសភាគមួយ ក្នុងចំណោមសមាសភាគសំខាន់ផ្សេងៗទៀត នៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ ដែលមានគោលបំណងផ្តល់ឱកាសថ្មី ដល់អ្នកសិក្សាដែលមិនអាចចូលរៀនក្នុងប្រព័ន្ធអប់រំបាន ដើម្បីឱ្យពួកគេអាចបន្ត និងបញ្ចប់ការសិក្សារបស់ខ្លួននៅគ្រប់កម្រិត និងដើម្បីអភិវឌ្ឍធនធានមនុស្សដើម្បីសម្រេចបានគោលដៅអប់រំសម្រាប់ទាំងអស់គ្នា។ ការងារនេះឆ្លើយតប ទៅនឹងតម្រូវការសិក្សារបស់ប្រជាពលរដ្ឋគ្រប់រូបរួមមាន ៖ កុមារនៅក្រៅសាលា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ និយោជិកដែលធ្វើការនៅក្នុងរោងចក្រ។ ចំពោះបញ្ហានេះ ត្រូវអនុវត្តនូវយុទ្ធសាស្ត្រដូចខាងក្រោម ៖

- បង្កើតកាលានុវត្តភាពសម្រាប់កុមារ និងយុវជននៅក្រៅសាលា និងអ្នកបោះបង់ការសិក្សានៅគ្រប់កម្រិតដើម្បីទទួលបានការអប់រំ
- បង្កើតលក្ខខណ្ឌអនុគ្រោះសម្រាប់ប្រជាពលរដ្ឋ កម្មករនិយោជិក និងកងកម្លាំងប្រដាប់អាវុធគ្រប់រូប ដែលមានលិខិតបញ្ជាក់ការសិក្សាសមមូលនៅមធ្យមសិក្សាបឋមភូមិ ដើម្បីបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការវាយតម្លៃនៃការបញ្ចប់ការសិក្សា ៖ (១) ត្រូវធ្វើការប្រឡងបញ្ចប់រយៈពេលពីរឆ្នាំសម្រាប់ការអប់រំសមមូលនៅបឋមសិក្សា (២) ការវាយតម្លៃសម្រាប់ការអប់រំសមមូលនៅមធ្យមសិក្សាបឋមភូមិត្រូវធ្វើឡើងតាមរយៈការប្រឡង។

កម្មវិធីសិក្សានៃកម្មវិធីសមមូលរួមមាន ៖ (១) ៧០%នៃខ្លឹមសារត្រូវបានជ្រើសសម្រាំងចេញពីកម្មវិធីសិក្សានៃការអប់រំក្នុងប្រព័ន្ធ និង (២) ៣០% ខ្លឹមសារបំណិនជីវិត។ ការសិក្សាក្នុងមួយឆ្នាំមានយ៉ាងតិច ៣៨សប្តាហ៍ក្នុងមួយឆ្នាំ និង១២ម៉ោង ក្នុងមួយសប្តាហ៍។ ថ្នាក់កម្មវិធីអប់រំត្រូវបានរៀបចំឡើង ៖ ការសិក្សាចំនួនពីរឆ្នាំ សម្រាប់ការអប់រំសមមូលនៅបឋមសិក្សា(ថ្នាក់ទី៣ ដល់ថ្នាក់ទី៦) ការសិក្សាចំនួនពីរឆ្នាំសម្រាប់សមមូលមធ្យមសិក្សាបឋមភូមិ និងការសិក្សាចំនួនពីរឆ្នាំសម្រាប់កម្រិតសមមូលមធ្យមសិក្សាទុតិយភូមិ។

សាលារៀនសម្រាប់កម្មវិធីអប់រំអាចជា ៖ សាលារៀមចំណេះទូទៅ សាលាបំពេញវិជ្ជា មជ្ឈមណ្ឌលសិក្សាសហគមន៍ រោងចក្រ សហគ្រាស មជ្ឈមណ្ឌលហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ ឬកន្លែងដែលសមស្រប។

### ៣.២.៩ គោលនយោបាយស្តីពី **សាលាមធ្យមសិក្សាធនធាន** (២០០៨)

**សាលាមធ្យមសិក្សាធនធាន** គឺជាសាលាដែលឈានមុខគេនៅក្នុងបណ្តាញសាលារៀន ដែលបានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារ ដូចជាអគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹកនិងភ្លើង ។ល។ វាគឺជាសាលាគំរូផ្អែកទៅលើការគ្រប់គ្រង និងអភិបាលកិច្ចល្អ និងនាំទៅរកការអនុវត្តវិធីសាស្ត្រស្រាវជ្រាវ និងនវានុវត្តន៍ក្នុងការបង្រៀន និងរៀន ដោយប្រើប្រាស់សម្ភារបរិក្ខារបង្រៀនបន្ថែមសាមញ្ញៗ។

**សាលាមធ្យមសិក្សាធនធាន** អាចប្រើសម្រាប់ការចែករំលែកនូវបទពិសោធជាមួយសាលាដទៃៗទៀតនៅក្នុងបណ្តាញ ដោយរៀបចំជាបទបង្ហាញសាកល្បងនៅក្នុងថ្នាក់ និងការបង្រៀនយ៉ាងទៀងទាត់ និងបណ្តុះបណ្តាលគ្រូដើម្បីលើកកម្ពស់សមត្ថភាពបង្រៀននិងគ្រប់គ្រង ក្នុងការដឹកនាំសាលារៀន រួមទាំងការរៀបចំផែនការអភិវឌ្ឍសាលារៀន។ វាក៏ផ្តល់នូវកាលានុវត្តភាពផងដែរដើម្បីពន្លឿនអ្នកសិក្សា សិស្សរៀនខ្សោយ និងសិស្សជនជាតិភាគតិច ដើម្បីបង្កើនការចូលរៀនដោយសមធម៌នៅមធ្យមសិក្សា។

**សាលាមធ្យមសិក្សាឆនឆាន** អាចត្រូវបង្កើតឡើងក្នុងចំណោម ៖ (១) សាលាដែលមានស្រាប់ ដែលមានការគ្រប់គ្រងនិងសហការល្អជាមួយសហគមន៍ (២) សាលាដែលមានបរិវេណធំទូលាយ ដែលមានវិសាលភាពអាចពង្រីកបាន (៣) សាលារៀនដែលមានកំណត់ត្រាសុវត្ថិភាព និង (៤) សាលារៀនដែលបណ្តាញអគ្គីសនី និងមានទឹកផឹកសុវត្ថិភាព មានទីពិសោធន៍វិទ្យាសាស្ត្រ និងកុំព្យូទ័រ។ សាលារៀនដែលមានហេដ្ឋារចនាសម្ពន្ធស្តង់ដាត្រូវមាន ៖ (១) ការិយាល័យសម្រាប់នាយកសាលា នាយករង និងលេខាធិ-ការ (២) បន្ទប់ប្រជុំ បន្ទប់គ្រូ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់ពិសោធន៍កុំព្យូទ័រ បន្ទប់សោតទស្សន៍ ឃ្លាំង (៣) បណ្ណាល័យ (៤) អាហារដ្ឋាន និង (៥) បង្គន់អនាម័យ។

វត្ថុបំណងនៃ**សាលាមធ្យមសិក្សាឆនឆាន** គឺដើម្បី ៖ (១) លើកកម្ពស់ការចែករំលែកនូវការអនុវត្ត សហប្រតិបត្តិការ និងការទ្រទ្រង់ទៅវិញទៅមកបានល្អរវាងសាលារៀន និងបុគ្គលិកបង្រៀននៅក្នុងបណ្តាញ (២) លើកកម្ពស់ការអភិវឌ្ឍអាជីពសម្រាប់គ្រូបង្រៀន (៣) ពង្រឹងការគ្រប់គ្រង និងដឹកនាំសាលារៀន (៤) លើកកម្ពស់ផែនការអភិវឌ្ឍសាលារៀន និងធានាការអនុវត្តរបស់ខ្លួន និង(៥) លើកកម្ពស់បំណិនជីវិត។

### ៣.២.៦ គោលនយោបាយស្តីពី សុខភាពសិក្សា (២០០៩)

វត្ថុបំណងនៃ **គោលនយោបាយស្តីពីសុខភាពសិក្សា** គឺដើម្បីចែករំលែកការលើកកម្ពស់គុណភាពអប់រំដោយណែនាំសិស្សសាលាឱ្យមានទម្លាប់អនាម័យស្អាត និងសម្អាតកន្លែងរស់នៅ ជួយថែរក្សាបរិស្ថានសាលារៀនរបស់ខ្លួនឱ្យបានស្អាត និងមានសុវត្ថិភាពដោយមានសុខភាពអនាម័យក្នុងការរស់នៅ។ វាផ្តល់នូវសិទ្ធិស្មើគ្នាក្នុងការថែទាំសុខភាពចំពោះសិស្ស និងបុគ្គលិកអប់រំទាំងអស់។ ការលើកកម្ពស់សុខភាពអនាម័យអាចកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្ស។ នៅក្នុងប្រទេសកម្ពុជា កុមារជិត៥,៥% ស្លាប់មុនអាយុ៥ឆ្នាំ។ ចំពោះបញ្ហានេះ ៨% គឺបណ្តាលមកពីជំងឺរាករូស ដែលអាចគណនាប្រមាណ ២ ០០០នាក់ នៃកុមារដែលមានអាយុក្រោម៥ឆ្នាំ។ ជំងឺដូចជា រាករូសដែលនាំឱ្យមានកង្វះអាហារូបត្ថម្ភ ស្លេកស្លាំង ធ្វើឱ្យកុមារថយសមត្ថភាពរៀន។

គោលនយោបាយសុខភាពសិក្សាផ្តោតទៅលើសមាសភាគបួនគឺ ៖

**ទីមួយ**–ផ្តល់សេវាកម្មថែទាំសុខភាពចាំបាច់ដល់សិស្សានុសិស្ស និស្សិត បុគ្គលិកអប់រំ ដើម្បីធានាការចូលរៀនដោយសមធម៌ ក្នុងការអភិវឌ្ឍផ្លូវកាយ សម្បទា បញ្ញាស្មារតី និងសង្គម។ យុទ្ធសាស្ត្រអនុវត្តគឺ ៖ (១) បង្កើតបទបញ្ជាសុខភាពសិក្សាតាមសាលាសម្រាប់គ្រឹះស្ថានអប់រំ (២) ការពិនិត្យសុខភាព ការចាក់វ៉ាក់សាំងសង្គ្រោះបឋម និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការតាមដានសុខភាព (៣) ការផ្តល់ថ្នាំបង្ការ ការទប់ស្កាត់ជំងឺឆ្លង និងជំនួយសង្គ្រោះបន្ទាន់ (៤) ក្លឹបសុខភាព (៥) ការពិគ្រោះយោបល់ និង(៦) ម្ហូបអាហារ និងអាហារូបត្ថម្ភ។

**ជំពីរ**–ផ្តល់ការអប់រំសុខភាព និងផ្តោតលើការការប្រាស្រ័យទាក់ទង ដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបទ ៖ (១) ការបញ្ចូលខ្លឹមសារអប់រំសុខភាពទៅក្នុងកម្មវិធីសិក្សា (២) ការលើកកម្ពស់ការផ្សព្វផ្សាយស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ អនាម័យ និងការបង្ការគ្រោះថ្នាក់ និងជំងឺផ្សេងៗ (៣) ការពង្រឹងសមត្ថភាពមន្ត្រីអប់រំ (៤) ការបណ្តុះ-បណ្តាលគ្រូបង្គោល (៥) ការពិនិត្យតាមដានគុណភាពសេវាសុខភាព និង (៦) ការទប់ស្កាត់ការប្រើប្រាស់ផលិតផលថ្នាំជក់ គ្រឿងញៀន និងគ្រឿងស្រវឹង។

**ជំបី**–លើកកម្ពស់បរិស្ថានសិក្សា និងសម្ភារូបវន្តផ្នែកសុខភាពឱ្យសមស្របតាមស្ថានភាព កាលៈទេសៈ ទីតាំងភូមិសាស្ត្រ និងប្រជាសាស្ត្រជាក់ស្តែង ដើម្បីធានាប្រសិទ្ធ-ភាព និងគុណភាពអប់រំ ៖ (១) ស្តង់ដាសមស្របសម្រាប់សាលារៀន រួមទាំងទីធ្លាសម្រាប់ក្មេងលេង ទីលានហាត់ប្រាណ សួនច្បារ សួនបន្លែ ដើមឈើ ទឹកស្អាត បង្គន់អនាម័យ កន្លែងលាងដៃ អាហារដ្ឋាន និងអន្តេវាសិកដ្ឋាន (២) សម្ភារូបវន្តផ្នែកអនាម័យ ដូចជាធុងសំរាម អំបោស ធុងទឹក សាប៊ូ កន្សែងជូតដៃ និងឧបករណ៍ផ្សេងៗទៀត (៣) ការបែងចែកភារកិច្ចប្រចាំថ្ងៃ ដើម្បីរក្សាសណ្តាប់ធ្នាប់ និង (៤) ការរៀបចំប្រារព្ធទិវាអនាម័យ ឬការប្រឡងប្រណាំង សាលារៀនស្អាត និងថ្នាក់រៀនស្អាត។

**ជំបួន**–បើកទូលាយឱ្យមានការចូលរួមពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីធ្វើឱ្យសាលារៀន សហគមន៍ និងទីកន្លែងសាធារណៈមានអនាម័យ សោភណភាព សុវត្ថិភាព និងផាសុកភាព ៖ (១) ពង្រឹងយន្តការសម្របសម្រួលរវាងក្រសួង និងអ្នកពាក់ព័ន្ធនានា (២) បង្កើតគណៈកម្មការសុខភាពសិក្សាតាមគ្រឹះស្ថានសិក្សា (៣) បើកទូលាយឱ្យមានការចូលរួមពីផ្នែកឯកជន និងសហគមន៍ និង (៤) ការចូលរួមរបស់សិស្សានុសិស្ស និងមាតាបិតា។

សុខភាព សុវត្ថិភាព និង ការការពារកុមារ គឺជាផ្នែកមួយនៃគោលនយោបាយរបស់ក្រសួងស្តីពីសាលាកុមារមេត្រី(សមាសភាគទី៣)។ ទោះបីមនុស្សមានទំនោរលាងដៃនឹងទឹក តែមានមនុស្សតិចតួចណាស់ដែលលាងដៃនឹងសាប៊ូបន្ទាប់ពីការប្រើប្រាស់បង្គន់ ព្រមទាំងលាងដៃមុននឹងទទួលទានអាហារ។ ការលាងដៃនឹងសាប៊ូបន្ទាប់ពីចេញពីបង្គន់ និងមុនពេលញ៉ាំអាហារគឺជាមធ្យោបាយដ៏សាមញ្ញ និងមានប្រសិទ្ធភាពបំផុតដើម្បីបង្ការការរាករូស។ វាអាចកាត់បន្ថយករណីរាករូសបាន៥០% និងជំងឺរលាកទងសួតបាន២៥%។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ទាប់ពីមានសម្ភារៈរូបវន្តលាងសម្អាតដៃ (WASH) គ្រប់គ្រាន់នៅតាមសាលារៀន គឺអាចជួយកាត់បន្ថយការរាករូស កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារដែលមានផលប៉ះពាល់អវិជ្ជមានលើការអភិវឌ្ឍ និងរៀនខ្សោយ។ លើសពីនេះទៀត កុមារដែលមានជំងឺអាចនាំទៅរកអវត្តមានជាប្រចាំហើយនៅទីបំផុត ពួកគេបោះបង់ការសិក្សា។ អត្រាបោះបង់ការសិក្សានៅប្រទេសកម្ពុជាមានកម្រិតខ្ពស់រហូតជាង១០% នៅបឋមសិក្សា និង២១%នៅមធ្យមសិក្សាបឋមភូមិ។ ការលាងដៃគឺជាសមាសភាពសំខាន់ណាស់ក្នុងការអភិវឌ្ឍបរិស្ថានអំណោយផលដល់ការសិក្សារបស់កុមារ។ កុមារសិក្សាប្រកបដោយប្រសិទ្ធភាពដោយសារពួកគេមានសុខភាពល្អ ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។ នៅត្រឹមឆ្នាំ២០១៨ សាលាបឋមសិក្សាចំនួន៨៧% នឹងមានបង្គន់ ព្រមទាំងទឹកស្អាត ហើយសាលារៀន៦០% នឹងមានកន្លែងលាងដៃ។ អង្គការយូនីសេហ្វបានគាំទ្រគំនិតផ្តួចផ្តើមចំពោះគម្រោង School to Community Water សុខភាព និងអនាម័យក្នុងរាជធានី ខេត្តជាច្រើន។ ប្រការនេះធ្វើឱ្យកុមារ និងគ្រួសាររបស់ពួកគេផ្លាស់ប្តូរឥរិយាបទ និងមានទម្លាប់អនាម័យល្អ។

ហេតុដូច្នេះហើយ ការលើកកម្ពស់ការលាងដៃនៅតាមសាលារៀននឹងជួយកាត់បន្ថយអត្រាមរណៈភាពរបស់កុមារទាក់ទងទៅនឹងជំងឺផ្លូវដង្ហើម និងរាករូសដោយបង្ហាញនូវការផ្លាស់ប្តូរសាមញ្ញទៅលើឥរិយាបថរបស់ប្រជាជន និងបង្កើតវប្បធម៌លាងដៃនឹងសាប៊ូ។ បើទោះបីជាក្នុងប្រទេសកម្ពុជាមានសាលាប្រមាណ៥០% ដែលមានឧបករណ៍លាងដៃក៏ដោយចុះ តែតាមលទ្ធផលនៃការចុះសិក្សាស្រាវជ្រាវបង្ហាញថា ឧបករណ៍ជាច្រើនត្រូវបានគេចាក់សោរ គគ្រេចស្មោកគ្រោក ឬមិនដំណើរការ ហើយជានិច្ចជាកាលមិនមានទឹក និងសាប៊ូលាងដៃ ដែលនេះជារនាំងដ៏ចម្បង។ ក្រសួងអប់រំ និងក្រសួងអភិវឌ្ឍជនបទ បានធ្វើយុទ្ធនាការស្តីពីការលាងដៃនៅតាមសាលារៀន។ នេះរួមទាំងការអភិវឌ្ឍ និងការធ្វើការសាកល្បងគោលការណ៍ណែនាំស្តីពីតម្លៃអប្បរមាសម្រាប់ប្រតិបត្តិការ និងតំហែទាំទឹក និងអនាម័យឱ្យមានប្រសិទ្ធភាពនៅតាមសាលារៀន ដោយប្រើប្រាស់ថវិកាកម្មវិធីនៅពេលអនាគត។ ការលើកកម្ពស់សុខភាពសិក្សានឹងត្រូវចាត់វិធានការបន្ថែមទៀតដូចខាងក្រោម ៖

- ផ្តល់ជាអនុសាសន៍ស្តីពីទិន្នន័យបន្ថែមដែលត្រូវប្រមូលតាមរយៈ EMIS លើមុខងារ និងការប្រើប្រាស់កន្លែងលាងដៃ ការបោះចោលកាកសំណល់រឹង និងទឹកកខ្វក់ដោយសុវត្ថិភាព ព្រមទាំងថាតើបង្គន់អនាម័យដំណើការ និងប្រើប្រាស់បាន

  ឧទា. ដូចជាមិនត្រូវបានចាក់សោរ និងមានទឹក


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ភាពជាដៃគូជាមួយផ្នែកឯកជន ពាក់ព័ន្ធនឹងចំណុចខ្លាំងដែលអាចប្រៀបធៀបបាន ព្រមទាំងការងារពាក់ព័ន្ធនឹងខ្សែបណ្តាញផ្គត់ផ្គង់ ភស្តុភា និងភាពបត់បែនដើម្បីធានាបាននូវការបែងចែកឱ្យបានទូលំទូលាយ និងមាននិរន្តរភាពកម្មវិធីលាងសម្អាតដៃ
- ធានាថាថវិកាប្រតិបត្តិសាលារៀន មានរួមបញ្ចូលនូវគម្រោងថវិកាដើម្បីទិញសាប៊ូលាងដៃ និងដើម្បីថែទាំកន្លែងលាងដៃនៅតាមសាលារៀន ក្នុងន័យនេះ ក៏មានន័យថា សហការជាមួយផ្នែកឯកជន និងគណៈកម្មទ្រទ្រង់សាលាដើម្បីចូលរួមចំណែកដល់សហគមន៍
- ធានាថាកន្លែងលាងដៃដែលប្រើប្រាស់បាន មាននៅគ្រប់សាលារៀន និងអនុវត្តការអប់រំក្នុងការលាងសម្អាតដៃជាប្រចាំ គឺមិនមែនអប់រំណែនាំតែនៅពេលដែលរៀបចំជាព្រឹត្តិការណ៍អ្វីមួយនោះទេ
- អនុវត្តគោលការណ៍ថ្នាក់ជាតិស្តីពីការរៀបចំទិវាសុខភាព នៅតាមសាលារៀន (ចេញដោយក្រសួងអយក ២០១៣) «សិស្សគ្រប់រូបត្រូវអនុវត្តការលាងដៃដោយប្រើសាប៊ូ។ ការលាងដៃ គឺប្រើប្រាស់ទឹកតិចតួច និងសាប៊ូមួយចំនួន តែវាទាមទារឱ្យនាយកសាលា លោកគ្រូ អ្នកគ្រូ ឪពុកម្តាយ និងសិស្សត្រូវមានការប្តេជ្ញាចិត្តខ្ពស់»។

### ៣.២.៧ ផែនការគោលស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ (២០១០)

នៅឆ្នាំ២០០៥ ក្រសួងអយក បានចេញគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ក្នុងវិស័យអប់រំ។ គោលនយោបាយនេះមានគោលដៅសំខាន់បី គឺ ៖ (១) បង្កើនការចូលរៀនថ្នាក់អប់រំមូលដ្ឋានសម្រាប់ទាំងអស់គ្នាទាំងផ្លូវការទាំងក្រៅប្រព័ន្ធ ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទូរគមនាគមន៍ (ICT) ជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ផ្សេងទៀតសម្រាប់រៀន បង្រៀន ការស្រាវជ្រាវ និងការចែករំលែកព័ត៌មាន (២) លើកកម្ពស់គុណភាពអប់រំមូលដ្ឋាន និងជំរុញការរៀនដោយឯករាជ្យ និងពេញមួយជីវិត ជាពិសេសសម្រាប់ការអប់រំក្រោយបឋមសិក្សា និង (៣) មានកម្លាំងពលកម្មដែលមានជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ឆ្លើយតបទៅនឹងតម្រូវការការងារ និងប្រើប្រាស់នៅក្នុងសង្គមពុទ្ធិ ដើម្បីធានាថាប្រទេសកម្ពុជាអាចប្រកួតប្រជែង និងសហ-

ប្រតិបត្តិការនៅក្នុងពិភពលោក ដែលកំពុងតែរីកចម្រើនឥតឈប់ឈរខាងផ្នែកបច្ចេក-វិទ្យា។

គោលនយោបាយរបស់ក្រសួងអយក ស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ក្នុងវិស័យអប់រំ ផ្តោតទៅលើវិស័យបួនសំខាន់ៗគឺ ៖

- ធានាការចូលរៀនដោយប្រើឧបករណ៍បច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT)
- យកចិត្តទុកដាក់លើតួនាទី និងមុខងារផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ក្នុងវិស័យអប់រំ សម្រាប់ជាឧបករណ៍បង្រៀន និងរៀន
- លើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នា ដោយប្រើប្រាស់វិទ្យុ ទូរទស្សន៍ សម្ភារបោះពុម្ព និងប្រព័ន្ធឃោសនាដទៃៗទៀត
- យកចិត្តទុកដាក់លើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ដើម្បីបង្កើនផលិត-ភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការគ្រប់គ្រងអប់រំ។

គោលដៅនៃគោលនយោបាយបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) គឺរួមមាន ៖ (១) បង្កើនការចូលរៀនមូលដ្ឋាននៃការអប់រំសម្រាប់ទាំងអស់គ្នា ទាំងផ្លូវការទាំងក្រៅប្រព័ន្ធ ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ជាឧបករណ៍មួយក្នុងចំណោមឧបករណ៍បង្រៀន រៀន ស្រាវជ្រាវ និងការចែករំលែកព័ត៌មាន (២) លើកកម្ពស់គុណភាពអប់រំមូល-ដ្ឋាន និងបង្កើនការរៀនដោយឯករាជ្យ និងពេញមួយជីវិត ជាពិសេសសម្រាប់អប់រំក្រោយបឋមសិក្សា និង(៣) លទ្ធភាពរកការងារធ្វើ (កម្លាំងពលកម្ម) ដែលទាក់ទងនឹងជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ដែលត្រូវការសម្រាប់ស្វែងរកការងារធ្វើ និងប្រើប្រាស់នៅក្នុងសង្គមពុទ្ធិ ដើម្បីធានាថាប្រទេសកម្ពុជាអាចប្រកួតប្រជែងជាមួយពិភពលោកខាងក្រៅ។

យុទ្ធសាស្ត្រជាក់លាក់សម្រាប់បច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) នៅក្នុងវិស័យអប់រំរួមមាន ៖ (១) ការបញ្ចូលការអប់រំបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) និងការបណ្តុះបណ្តាលជាដំបូងនៅមធ្យមសិក្សាដែលបានជ្រើសរើស គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សាបច្ចេកទេស (២) កម្មវិធីចម្រាញ់ កម្មវិធីសិក្សាជម្រើស (៣) ការពង្រីកបច្ចេក-វិទ្យាព័ត៌មានវិទ្យា(ICT) សម្រាប់លើកកម្ពស់ការគ្រប់គ្រងសាលា ការចែករំលែកព័ត៌មាន ការគ្រប់គ្រងទំនាក់ទំនង និងចំណេះដឹង និង (៤) ការពង្រីកកាលានុវត្តភាពរៀនពីចម្ងាយ ជាពិសេសការប្រើប្រាស់កម្មវិធីគោលដៅផ្អែកលើបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) សម្រាប់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមងាយរងគ្រោះក្នុងសង្គម ដើម្បីធានាការចូលរៀនឡើងវិញ និងដើម្បីបញ្ជ្រាបការអប់រំផ្លូវការ។

កម្មវិធីនេះត្រូវបានរចនាឡើង ដើម្បីធ្វើផែនការក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) នៅពេលអនាគត នៅក្នុងក្រសួងដោយធ្វើការជាបឋមទៅលើ ៖ ការអភិវឌ្ឍកម្មវិធីសិក្សា ការអប់រំគរុនិស្សិត និងគ្រូ តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំរចនាសម្ព័ន្ធ និងយន្តការរបស់ក្រសួង ការបណ្តុះបណ្តាលមន្ត្រីក្រសួង ជម្រើសទាក់ទងការអភិវឌ្ឍមាតិកាអប់រំសម្រាប់បង្រៀននៅតាមសាលា និងអប់រំគ្រូបង្រៀន។

ក្រៅពីការអភិវឌ្ឍគោលនយោបាយស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ក្រសួងក៏បានអភិវឌ្ឍផងដែរនូវ«ផែនការគោលបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ក្នុងវិស័យអប់រំ ២០០៩-២០១៣» ដែលត្រូវបានអនុម័តនៅឆ្នាំ២០១០ ហើយវាគឺជាផ្នែកមួយនៃឧបករណ៍ប្រតិបត្តិសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣។ ផែនការគោលបានដាក់បញ្ចូលគោលនយោបាយសំខាន់ៗ ជាពិសេសការអប់រំសម្រាប់ទាំងអស់គ្នា(EFA) និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ផែនការគោលបែងចែកការងារជា៥ផ្នែកសំខាន់ៗគឺ ៖

**ទីមួយ**–ការអប់រំទូទៅ ៖ (១) វគ្គ ICT មូលដ្ឋានអាជីព និងបុរេជំនាញឧត្តមសិក្សាត្រូវបានបង្រៀនជាប្រព័ន្ធនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ ជាពិសេសកម្មវិធីតម្រង់ទិសផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យាមូលដ្ឋាន (ICT) សម្រាប់ថ្នាក់ទី១០ និងកម្មវិធីសិក្សាបច្ចេកវិទ្យាព័ត៌មានវិទ្យាជាអាជីព (ICT) សម្រាប់សិស្សថ្នាក់ទី១១ និង១២ និង (២) ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាស្តីពីជំនាញអាជីពមូលដ្ឋានលើបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ។

**ទីពីរ**–ឧត្តមសិក្សា ៖ (១) ការបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) សម្រាប់គ្រូ និងបុគ្គលិកនៅឧត្តមសិក្សា ដែលនឹងត្រូវផ្តល់ដល់គ្រប់គ្រឹះស្ថានឧត្តមសិក្សា (២) ការរៀបចំជាប្រព័ន្ធទិន្នន័យនិស្សិតបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សានៅប្រទេសកម្ពុជា ដែលមានជំនាញអាជីពផ្អែកលើបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ដើម្បីចូលក្នុងទីផ្សារការងារ ឬដើម្បីបន្តការអប់រំបន្ថែម និង (៣) ការអភិវឌ្ឍរចនាសម្ព័ន្ធ និងយន្តការដែលមានប្រសិទ្ធភាពសម្រាប់ការផ្តល់ការគាំទ្រ និងគ្រប់គ្រងការរៀនដោយបើកចំហរ និងពីចម្ងាយ (OLD) នៅក្នុងប្រទេស រួមទាំងការផ្តល់វគ្គសិក្សាបើកចំហរ និងពីចម្ងាយ (OLD) តាមរយៈការបង្កើតសាកលវិទ្យាល័យ National Open University ថ្នាក់ជាតិនៅកម្ពុជា ព្រមទាំង (៤) ក្រុមអ្នកស្រាវជ្រាវ ហើយសាស្ត្រាចារ្យនៅឧត្តមសិក្សាត្រូវចែករំលែក និងធ្វើការស្រាវជ្រាវលើសម្ភារបង្រៀន និងធនធានអប់រំដទៃៗទៀត ព្រមទាំងធ្វើសហប្រតិបត្តិការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លើការសិក្សា និងស្រាវជ្រាវ តាមរយៈការលើកកម្ពស់អន្តរទំនាក់ទំនងអន្តរសាកលវិទ្យាល័យ។

**ជីបី**–ការបណ្តុះបណ្តាលគ្រូ ៖ (១) ការបណ្តុះបណ្តាលគ្រូឧទ្ទេស គរុនិស្សិត និងនាយកសាលា តាមរយៈការលើកកម្ពស់ជំនាញគរុកោសល្យ និងប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) (២) តម្រូវឱ្យមានគ្រូដែលមានគុណវុឌ្ឍិផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) នៅមធ្យមសិក្សាទុតិយភូមិ ដើម្បីរៀបចំកម្មវិធីសិក្សាបច្ចេក-វិទ្យាព័ត៌មានវិទ្យា(ICT) និង (៣) គ្រូអាចទទួលសម្ភារបណ្តុះបណ្តាលគ្រូ និងធនធានអប់រំផ្សេងៗ ដែលបង្កើតដោយក្រសួងអយក និងគ្រូដទៃទៀត។

**ជីបួន**–អប់រំក្រៅប្រព័ន្ធ និងក្រៅផ្លូវការ ៖ (១) ការរៀបចំការប្រឡងសមមូលមធ្យមសិក្សាទុតិយភូមិ ជាពិសេសសម្រាប់គ្រូបឋមសិក្សា ត្រូវគាំទ្រដោយសម្ភារបណ្តុះបណ្តាលតាមវីដេអូ (២) គាំទ្រសមាជិកសហគមន៍ដើម្បីលើកកម្ពស់ជំនាញ សម្រាប់ពង្រីកប្រាក់ចំណូលតាមរយៈសម្ភាររៀនតាមវីដេអូ។

**ជីប្រាំ**–រដ្ឋបាលក្រសួង និងបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) សម្រាប់គាំទ្រវិស័យអប់រំ ៖ (១) ក្រសួងអយកអនុវត្តនូវយុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានច្បាស់លាស់ ដែលធ្វើឱ្យមានសុខដុមនីយកម្ម កំណត់ស្តង់ដា និងធ្វើអន្តរទំនាក់ទំនងព័ត៌មាន និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅគ្រប់នាយកដ្ឋាន (២) ការធ្វើស្តង់ដានីយកម្ម និងអន្តរប្រតិបត្តិការទិន្នន័យ និងទំនាក់ទំនងតាមសារអេឡិចត្រូនិក នៅខាងក្នុងក្រសួងអយក ត្រូវបានធ្វើរួច (៣) រាល់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ និងការគ្រប់គ្រងទិន្នន័យដទៃទៀត នៅក្នុងក្រសួងអយក ត្រូវបានធ្វើសុខដុមនីយកម្មនិងបញ្ចូលគ្នា (៤) ការិយាល័យរដ្ឋបាលទាំងអស់ នៃក្រសួងអយកអាចធ្វើការដោះដូរទិន្នន័យទៅវិញទៅមកតាមរយៈអ៊ីនត្រាណិត (៥) បច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ត្រូវបានប្រើដើម្បីសម្របសម្រួលរដ្ឋបាលសាលារៀន និងសាលាគរុកោសល្យដែលមានអគ្គិសនី និង(៦) ការិយាល័យអយកស្រុក ខណ្ឌប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ដើម្បីសម្របសម្រួលកិច្ចការរដ្ឋបាលរបស់ខ្លួន (៧) ការិយាល័យបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) សម្រាប់អប់រំនឹងត្រូវពង្រឹងដើម្បីសម្របសម្រួលសកម្មភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) របស់ក្រសួង និង(៨) តម្លៃវិនិយោគនិងការចំណាយចរន្តនៅក្នុងការអនុវត្តបច្ចេក-វិទ្យាព័ត៌មានវិទ្យា(ICT) ក្នុងវិស័យអប់រំត្រូវបានចែករំលែកជាមួយអ្នកពាក់ព័ន្ធ។

សរុបមក ការផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ក្នុងវិស័យអប់រំក៏ត្រូវបានធ្វើផងដែរទៅលើការអប់រំក្រៅប្រព័ន្ធ ការអប់រំពីចម្ងាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបណ្តុះបណ្តាលវិជ្ជាជីវៈ គុណភាពអប់រំនៅមធ្យមសិក្សាទុតិយភូមិ និងកម្រិតអប់រំក្រោយមធ្យមសិក្សាតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យា(ICT) ឱ្យក្លាយជាបំណិនជីវិតចាំបាច់ដែលត្រូវការនៅក្នុងសង្គមដែលត្រូវការចំណេះដឹងជាមូលដ្ឋាន និងឧបករណ៍សំខាន់ៗសម្រាប់បង្កើតភាពជាដៃគូរវាងគ្រឹះស្ថានរដ្ឋាភិបាល អង្គការថ្នាក់ជាតិ និងអន្តរជាតិ សង្គមស៊ីវិល និងសហគមន៍ ព្រមទាំងអង្គភាពស្របច្បាប់នៅក្នុងផ្នែកឯកជនផងដែរ។

### ៣.២.៨ គោលនយោបាយស្តីពី **ការអភិវឌ្ឍកម្រងសាលារៀន** (២០១០)

គោលនយោបាយស្តីពី **ការអភិវឌ្ឍកម្រងសាលារៀន** ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការអប់រំមូលដ្ឋាន និងពង្រឹងគុណភាពអប់រំ។ កម្រងសាលារៀន គឺជាក្រុមសាលារៀននៅតាមទីប្រជុំជន ឬស្រុក ខណ្ឌ ដែលត្រូវចងជាមួយសាលារៀនដែលស្ថិតនៅជិតៗគ្នា ដើម្បីងាយស្រួលក្នុងការទាក់ទង ការគ្រប់គ្រង និងជួយគ្នាទៅវិញទៅមក។ ប្រព័ន្ធកម្រងសាលារៀន គឺជាយន្តការមួយដែលជួយសម្របសម្រួលការងាររវាងការិយាល័យអប់រំស្រុក ខណ្ឌ និងសាលារៀន។ កម្រងសាលារៀននីមួយៗត្រូវមានសាលារៀនបង្គោលមួយ ដែលមានទីតាំងនៅចំកណ្តាល ក្នុងចំណោមសាលារណបផ្សេងៗ និងមានធនធានគ្រប់គ្រាន់(ធនធានមនុស្ស និងសម្ភារ) សម្រាប់ដំណើរការ និងមានសាលាសម្ព័ន្ធផ្សេងទៀត ដែលមានទីតាំងនៅក្បែរគ្នា។ ក្រៅពីសាលាសម្ព័ន្ធ ក៏អាចមានសាលាឧបសម្ព័ន្ធផ្សេងទៀត ដែលមានទីតាំងនៅក្បែរគ្នា។ កម្រងសាលារៀនអាចប្រមូលផ្តុំចងក្រង សាលាមត្តេយ្យ សាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដែលត្រូវបែងចែកទៅតាមប្រភេទដូចជា ៖ សាលាកម្រងទីប្រជុំ កម្រងធម្មតា កម្រងមិនធម្មតា និងកម្រងដាច់ស្រយាល។ ការបង្កើតសាលាកម្រងមានគោលបំណងបម្រើអត្ថប្រយោជន៍សំខាន់ៗ ៤គឺ ៖ អត្ថប្រយោជន៍ផ្នែករដ្ឋបាល គរុកោសល្យ សេដ្ឋកិច្ច និងសហគមន៍ ដែលសាលារៀនបង្គោល និងសាលារៀនសម្ព័ន្ធជាសមាជិកទទួលបានក្នុងពេលដំណើរការ។

គោលបំណងនៃការបង្កើតគោលនយោបាយនេះ គឺដើម្បី (១) ធានាថារាល់កុមារដែលដល់វ័យសិក្សាបានចូលរៀនគ្រប់ៗគ្នាប្រកបដោយសមធម៌ លើកកម្ពស់គុណភាពអប់រំ និងបង្កលក្ខណៈឱ្យសិស្សានុសិស្សបានបន្តការសិក្សារបស់ខ្លួនរហូតបញ្ចប់កម្រិតអប់រំមូលដ្ឋាន ៩ ឆ្នាំ និង(២) កែលម្អការងារគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេសតាមបែបវិមជ្ឈការ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលនយោបាយនេះ បានដាក់ចេញជាយុទ្ធសាស្ត្រដូចខាងក្រោម ៖

**ទីមួយ–ពង្រឹងរចនាសម្ពន្ធគ្រប់គ្រងគ្រប់ឋានានុក្រម** តាមរយៈ (១) ការចាត់តាំង និងប្រគល់ភារកិច្ចច្បាស់លាស់ដល់គណៈកម្មការអភិវឌ្ឍន៍ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀនគ្រប់លំដាប់ថ្នាក់ (២) ការផ្តល់ការទទួលខុសត្រូវជាប្រព័ន្ធ ក្នុងភាពជាម្ចាស់លើរាល់ការសម្រេចចិត្ត និងការអនុវត្តការងារ។

**ទីពីរ–ពង្រីកការងារគ្រប់គ្រងរដ្ឋបាលកម្រងសាលារៀន** តាមរយៈ៖ (១) ការបំប៉នសមត្ថភាពដល់អ្នកពាក់ព័ន្ធនៅក្នុងអនុគណៈកម្មការទទួលបន្ទុករដ្ឋបាលរបស់កម្រង (២) ការចាត់តាំង និងប្រគល់ភារកិច្ចដល់សមាជិកម្នាក់ៗ តាមជំនាញរបស់ខ្លួន ដោយមានការតាមដាន និងវាយតម្លៃលទ្ធផលការងារទៀងទាត់ និងកែលម្អចំណុចខ្វះខាតឱ្យបានទាន់ ពេលវេលា (៣) ការផ្សព្វផ្សាយបទពិសោធ និងស្នាដៃល្អៗរបស់ក្រុម និង (៤) ការបង្កើតគោលការណ៍ប្រឡងប្រណាំងពីការងាររដ្ឋបាល រវាងសាលានៅក្នុងកម្រង។

**ទីបី–ពង្រឹងការងារបច្ចេកទេស គរុកោសល្យតាមកម្រងសាលារៀន** តាមរយៈ (១) ការប្រើក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT) ដើម្បីជួយពង្រឹងសមត្ថភាព (២) ការប្រើថ្ងៃព្រហស្បតិ៍នៃសប្តាហ៍ទី៤សម្រាប់ប្រជុំការងារបច្ចេកទេស និងផ្លាស់ប្តូរបទ-ពិសោធន៍លើការគ្រប់គ្រង និងដឹកនាំថ្នាក់រៀន និងជួយសិស្សរៀនយឺត (៣) ការតាមដានយ៉ាងទៀងទាត់លើការរីកចម្រើនរបស់សាលារៀន និងពិនិត្យតាមដានលទ្ធផលនៃការសិក្សារបស់សិស្សយ៉ាងទៀងទាត់ (៤) ការចាត់តាំងអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៅក្នុងការបង្រៀន និងរៀនតាមរយៈសកម្មភាពបុគ្គល ដៃគូ ក្រុមតូច នៅក្នុងថ្នាក់ និងក្រៅថ្នាក់ និងការសិក្សាស្រាវជ្រាវបន្ថែម ព្រមទាំងការផ្តល់ឱកាសឱ្យនាយកសាលា និងគ្រូបង្រៀន បានផ្លាស់ប្តូរបទពិសោធការងារ តាមរយៈការធ្វើថ្នាក់និទស្សន៍ ថ្នាក់បង្ហាញនិងការធ្វើទស្សនកិច្ចសិក្សារវាងសាលារៀន។

**ទីបួន–ពង្រឹងប្រព័ន្ធទំនាក់ទំនង និងសហប្រតិបត្តិការជាមួយសហគមន៍ និងដៃគូអភិវឌ្ឍ** តាមរយៈ (១) បញ្ចូលសមាសភាពសហគមន៍នៅក្នុងគណៈកម្មការ និងអនុគណៈកម្មការ និង (២) ផ្តល់ឱកាសឱ្យសហគមន៍ចូលរួមគ្រប់សកម្មភាពរបស់សាលារៀន។

**ទីប្រាំ–ពង្រឹងការគ្រប់គ្រងដំណើរការមជ្ឈមណ្ឌលធនធាន** តាមរយៈ (១) ការបង្កើតមជ្ឈមណ្ឌលធនធាននៅគ្រប់កម្រងសាលារៀន (២) ការប្រមូលថវិការបស់កម្រងសាលារៀន ដែលបានមកពីគ្រប់សាលាសម្ពន្ធ ដោយចាប់ផ្តើមអភិវឌ្ឍពីសាលាបង្គោល និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពង្រីកទៅដល់សាលាសម្ពន្ធ ព្រមទាំង (៣) បែងចែកគ្រប់សម្ភារដែលបានផលិត ដល់គ្រប់សាលាសម្ពន្ធ។

**ជីទ្រាំមួយ–ពង្រឹងការអនុវត្តគោលការណ៍កម្រងសាលារៀន និងកម្មវិធីសាលាកុមារមេត្រី** តាមរយៈ (១) ការចាត់តាំងរៀបចំបង្កើតកម្រងសាលារៀន តាមប្រភេទនៅគ្រប់ទីកន្លែង និងចាត់តាំងការគ្រប់គ្រងតាមគោលការណ៍ណែនាំ និង (២) កសាងផែនការអភិវឌ្ឍកម្រងសាលារៀន និងសាលារៀន ដោយផ្សារភ្ជាប់ទៅនឹងសកម្មភាព ដែលបានកំណត់នៅក្នុងសមាសភាគទាំង៦ នៃកម្មវិធីសាលាកុមារមេត្រី។

**ជីទ្រាំពីរ–បង្កើនការលើកទឹកចិត្តការបំពេញការងារ** តាមរយៈ (១) ការរៀបចំគោលការណ៍ប្រឡងប្រណាំង ការបំពេញការងាររបស់គណៈកម្មការអភិវឌ្ឍកម្រងសាលារៀននៅគ្រប់កម្រិត និង (២) ការលើកទឹកចិត្តដល់គណៈកម្មការ និងការកែលម្អការងាររបស់គណៈកម្ម-ការ និងអនុគណៈកម្មការ។

### ៣.២.៩ គោលនយោបាយជាតិស្តីពី ការគាំពារ និងអភិវឌ្ឍន៍កុមារតូច (២០១០)

គោលនយោបាយថ្នាក់ជាតិស្តីពី **ការគាំពារ និងអភិវឌ្ឍន៍កុមារតូច** (ECCD) មានគោលដៅផ្តល់ការគាំពារ និងអភិវឌ្ឍកុមារកម្ពុជាគ្រប់រូប ចាប់ពីពេលកកំណើត ដល់អាយុ ៦ ឆ្នាំ ដោយធានាថា ស្ត្រីគ្រប់រូបទទួលបាននូវសេវាអប់រំសុខភាព កុមារតូចទាំងអស់ទទួលបានការចុះបញ្ជីកំណើត ការថែទាំ និងពិនិត្យសុខភាពជាប្រចាំ ថ្នាំបង្ការ និងអាហា-រូបត្ថម្ភគ្រប់គ្រាន់ ព្រមទាំងទទួលបានការអប់រំតាំងពីវ័យកុមារ ហើយកុមារគ្រប់រូបមានការរីកចម្រើនផ្នែករាងកាយ ចំណេះដឹង ប្រាជ្ញា និងស្មារតី។ យុទ្ធសាស្ត្រដើម្បីសម្រេចបានគោលបំណងទាំងនេះ មានដូចខាងក្រោម ៖

**ជីមួយ–**រៀបចំក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការ ដើម្បីគាំទ្រ និងអនុវត្តគោល-នយោបាយឱ្យមានប្រសិទ្ធភាព តាមរយៈការធ្វើសហប្រតិបត្តិការ និងអនុវត្តភារកិច្ចរបស់ភាគីពាក់ព័ន្ធ។

**ជីពីរ–**លើកកម្ពស់យន្តការពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់ ឬទើបបង្កើតថ្មី ដោយមានការចូលរួមពីក្រសួង/ស្ថាប័ន សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងកែលម្អគណៈកម្មការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការបែងចែកភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជីបី**–កសាងសមត្ថភាព (បណ្តុះបណ្តាលមុន និងកំពុងបម្រើការងារ) អ្នកអនុវត្តកម្មវិធី មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាកុមារលើខ្លឹមសារ និងវិធីថែទាំឱ្យស្របតាមកម្មវិធីសិក្សា និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**ជីបួន**–បង្កើតយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់វិញ្ញាបនបត្រ ឬលិខិតទទួលស្គាល់ ដល់អ្នកអនុវត្តកម្មវិធី ទៅតាមសេវាថែទាំជាក់ស្តែង។

**ជីប្រាំ**–បង្កើនសេវា និងការអប់រំស្តីពីការថែទាំសុខភាព និងអាហារូបត្ថម្ភដល់ស្ត្រីទាំងអស់ ដែលមានផ្ទៃពោះ។

**ជីប្រាំមួយ**–បង្កើនសេវាថែទាំ ព្យាបាលសុខភាព ជំងឺដល់កុមារតូច ចាប់ពីពេលកើត ដល់អាយុបីឆ្នាំ ដោយពិនិត្យសុខភាពជាប្រចាំ ផ្តល់ថ្នាំបង្ការ ហើយតាមដានការផ្តល់សេវាអាហារូបត្ថម្ភ ចំពោះកុមារដែលខ្វះអាហារូបត្ថម្ភ មានជំងឺពុំរ៉ៃ មានការលូតលាស់យឺត និងពិការ។

**ជីប្រាំពីរ**–ពង្រីកការផ្តល់សេវាគាំពារ និងអភិវឌ្ឍកុមារតូច រួមមានសេវារដ្ឋ សេវាសហគមន៍ ឯកជន និងតាមខ្នងផ្ទះ ជាពិសេសការហាត់រៀនដំបូង។

**ជីប្រាំបី**–ធានាឱ្យគ្រប់គ្រួសារទទួលបានព័ត៌មាន និងសេវា ដូចជា ៖ ទឹកស្អាត និងអនាម័យ សុខភាព អាហារូបត្ថម្ភ ការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារ បន្ថែម ការទទួលថ្នាំបង្ការ ជីវជាតិអា ជាតិដែក និងអំបិលអ៊ីយ៉ូដ ការរៀនពីដំបូង ការចុះបញ្ជីកំណើត ការទប់ស្កាត់ជំងឺគ្រប់ប្រភេទ ដូចជា ៖ មេរោគអេដស៍ និងជំងឺអេដស៍ ជំងឺគ្រុនចាញ់ ការការពារគ្រួសារពីអំពើហិង្សា និងការរងគ្រោះដោយប្រការផ្សេងៗ។

**ជីប្រាំបួន**–បង្កើតយន្តការផ្សព្វផ្សាយព័ត៌មានស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូចដើម្បីទាក់ទាញការគាំទ្រសេវាទាំងនេះ។

## ៣.២.១០ គោលនយោបាយស្តីពី ការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ (២០១០)

គោលនយោបាយស្តីពី **ការអភិវឌ្ឍការសិក្សាស្រាវជ្រាវក្នុងវិស័យអប់រំ** មានគោលដៅបង្កើតវប្បធម៌ស្រាវជ្រាវនៅគ្រប់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីពង្រឹងគុណភាពវិស័យអប់រំ បង្កើនចំណេះដឹងថ្មីៗ សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងវប្បធម៌ ដោយលើកកម្ពស់ការស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងផ្នែកស្រាវជ្រាវ។ វត្ថុបំណងនៃគោលនយោបាយនេះ គឺដើម្បី ៖ (១) លើកកម្ពស់គុណភាពអប់រំឧត្តមសិក្សានៅប្រទេសកម្ពុជា តាមរយៈការបង្កើន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រឹះស្ថានឧត្តមសិក្សាឱ្យទៅជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ សម្រាប់ការអភិវឌ្ឍ និងបង្កើតចំណេះថ្មីៗ (២) បង្កើនកាលានុវត្តភាពសម្រាប់សហប្រតិបត្តិការជាមួយនឹងស្ថាប័នស្រាវជ្រាវថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង (៣) ពង្រឹងសមត្ថភាពធនធានមនុស្ស ក្នុងការបង្កើតថ្មី និងនវានុវត្តន៍។

ដើម្បីសម្រេចបានវត្ថុបំណងខាងលើនេះ គឺត្រូវចាត់វិធានការដើម្បី ៖ (១) ធានាឱ្យមានការស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ក្នុងគ្រប់វិស័យ និងមុខជំនាញសិក្សា (២) លើកកម្ពស់ការកសាងសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា (៣) លើកកម្ពស់ការគោរពក្រមសីលធម៌ស្រាវជ្រាវ ការការពារស្នាដៃ និងការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ និង (៤) ជំរុញការប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវសម្រាប់បង្កើតចំណេះដឹងថ្មី និងការអភិវឌ្ឍ។

ដើម្បីសម្រេចបានគោលដៅនេះ គេបានរៀបចំយុទ្ធសាស្ត្រដូចខាងក្រោម ៖

**ទីមួយ**–**អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ** ៖ ដោយបណ្តុះបណ្តាលសមត្ថភាពស្រាវជ្រាវនៅក្នុងវិស័យគន្លឹះ ដែលឆ្លើយតបទៅនឹងអាទិភាពជាតិ។

**ទីពីរ**–**លើកកម្ពស់គុណភាពស្រាវជ្រាវ** ៖ ដោយលើកទឹកចិត្តអ្នកសិក្សាស្រាវជ្រាវឱ្យបង្ហាញរបកគំហើញរបស់ខ្លួន នៅសន្និបាតថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ព្រមទាំងគាំទ្រនូវការរៀបចំសន្និសីទថ្នាក់ជាតិ និងអន្តរជាតិ រៀបចំវេទិកាស្រាវជ្រាវដើម្បីឱ្យមានជំនួបរវាងអ្នកស្រាវជ្រាវ ផ្តល់ឱកាសសម្រាប់ការបោះពុម្ពផ្សាយ លើកទឹកចិត្តការស្រាវជ្រាវអំពីប្រធានបទទាក់ទងនឹងកម្ពុជា និងគាំទ្រការបង្កើតទស្សនាវដ្តីស្រាវជ្រាវអេឡិចត្រូនិក។

**ទីបី**–**ជំរុញការស្រាវជ្រាវរួមគ្នា** ៖ តាមរយៈកិច្ចសហប្រតិបត្តិការរវាងគ្រឹះស្ថានស្រាវជ្រាវទាំងក្នុង និងក្រៅប្រទេស។

**ទីបួន**–**ផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវ** ៖ តាមរយៈការបង្កើននូវវប្បធម៌រាយការណ៍ និងការបោះពុម្ពលទ្ធផលស្រាវជ្រាវជាទៀងទាត់ និងការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (database) ស្រាវជ្រាវ។

**ទីប្រាំ**–**រៀបចំក្រមសីលធម៌ស្រាវជ្រាវ និងការអនុញ្ញាតឱ្យស្រាវជ្រាវ** ៖ ដើម្បីលើកទឹកចិត្តដល់ការគោរពក្រមសីលធម៌ស្រាវជ្រាវនិងបង្កើតយន្តការសម្រាប់ពិនិត្យឡើងវិញ។

**ជំហានទីមួយ–លើកកម្ពស់សហប្រតិបត្តិការអន្តរជាតិ ៖** ដើម្បីបង្កឱកាសឱ្យអ្នកស្រាវជ្រាវកម្ពុជាសហការជាមួយអ្នកស្រាវជ្រាវអន្តរជាតិ លើកកម្ពស់ការផ្លាស់ប្តូរលទ្ធផលស្រាវជ្រាវ និងជំរុញកិច្ចសហការជាមួយគ្រឹះស្ថានស្រាវជ្រាវ និងសាកលវិទ្យាល័យ។

**ជំហានទីពីរ–ការសិក្សាទីផ្សារនិងការអភិវឌ្ឍ ៖** ក្នុងគោលដៅធានាថា អ្នកសិក្សាស្រាវជ្រាវទទួលបាននូវអត្ថប្រយោជន៍សមស្របពីការស្រាវជ្រាវ និងការអភិវឌ្ឍ។

ដើម្បីសម្របសម្រួលសកម្មភាពសិក្សាស្រាវជ្រាវ គឺចាំបាច់ត្រូវបង្កើតគណៈកម្មាធិការសម្រាប់ការអភិវឌ្ឍការសិក្សាស្រាវជ្រាវលើវិស័យអប់រំ ដើម្បីផ្តល់ការគាំទ្របច្ចេកទេស និងរដ្ឋបាលសម្រាប់គ្រឹះស្ថានឧត្តមសិក្សាពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ។

## ៣.២.១១ គោលនយោបាយជាតិស្តីពី **ការអភិវឌ្ឍយុវជនកម្ពុជា** (២០១១)

គោលនយោបាយជាតិស្តីពី **ការអភិវឌ្ឍយុវជនកម្ពុជា** ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់សមត្ថភាពយុវជន និងផ្តល់ឱ្យពួកគេនូវកាលានុវត្តភាព ដើម្បីអភិវឌ្ឍសក្តានុពលលើវិស័យអប់រំ ការងារ សុខភាព និងការសម្រេចចិត្ត ព្រមទាំងការចូលរួមអភិវឌ្ឍគ្រួសារ សហគមន៍ សង្គមជាតិ និងពិភពលោក។ ដើម្បីអភិវឌ្ឍយុវជនតាមមធ្យោបាយដែលធ្វើឱ្យពួកគេមានសុចរិតភាព ទាំងផ្លូវកាយ បញ្ញា មនសិការ ក្រមសីលធម៌ គុណតម្លៃ និងជំនាញ និងធ្វើយ៉ាងណាឱ្យពួកគេក្លាយទៅជាពលរដ្ឋល្អ គោលនយោបាយនេះ ត្រូវកំណត់គោលដៅដូចខាងក្រោម ៖ (១) ផ្តល់ឱ្យយុវជនបានចូលរៀន និងបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយគុណភាព និងសមធម៌ (២) លើកទឹកចិត្តយុវជនឱ្យចេះផ្តួចផ្តើមគំនិតបង្កើតថ្មី នវានុវត្តន៍ និងសហគ្រិនភាព (៣) លើកកម្ពស់យេនឌ័រក្នុងចំណោមយុវជន និងជាពិសេសផ្តល់កាលានុវត្តភាព និងសិទ្ធិដល់ស្ត្រី (៤) អភិវឌ្ឍយុវជនទៅតាមមធ្យោបាយដែលធ្វើឱ្យពួកគេមានសម្បទា ចំណេះដឹង ជំនាញ ក្រមសីលធម៌ ស្មារតីស្រឡាញ់សន្តិភាព ភក្តីភាពចំពោះជាតិ ទំនុកចិត្តខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និងយល់ដឹងទូលំទូលាយពីសង្គម និង (៥) ផ្តល់កាលានុវត្តភាពសម្រាប់យុវជនដើម្បីបញ្ចេញមតិ និងធ្វើការសម្រេចចិត្តទាក់ទងទៅនឹងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ។

ដើម្បីសម្រេចបានគោលបំណងដូចរៀបរាប់ខាងលើ គោលនយោបាយត្រូវធ្វើទៅតាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

**ជីមួយ–រៀបចំក្របខណ្ឌច្បាប់ និងយន្តការ ៖** ដើម្បី (១) គាំទ្រការអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព តាមរយៈកិច្ចសហប្រតិបត្តិការនៃគ្រប់ភាគីពាក់ព័ន្ធ និង (២) កសាងផែនការសកម្មភាពថ្នាក់ជាតិស្តីពីការអភិវឌ្ឍយុវជន និងកម្មវិធីនានា ដែលមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងកំណត់ក្រសួងទទួលខុសត្រូវ។

**ជីពីរ–លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព ៖** ដើម្បី (១) ជំរុញនិងលើកទឹកចិត្តយុវជន ជាពិសេសយុវជនដែលងាយរងគ្រោះ និងពិការ អាចចូលរៀន និងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ (២) លើកកម្ពស់បំណិនជីវិតដែលឆ្លើយតបទៅនឹងតម្រូវការប្រចាំថ្ងៃរបស់យុវជន និងទីផ្សារការងារ (៣) លើកកម្ពស់គុណភាពអប់រំផ្នែកបច្ចេកវិទ្យា វិទ្យាសាស្ត្រនិងភាសាបរទេស នៅគ្រប់កម្រិតអប់រំ ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម និងអនុលោមទៅតាមបទដ្ឋានក្នុងស្រុក និងអន្តរជាតិ (៤) បង្កើតមជ្ឈមណ្ឌលយុវជន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងលើកទឹកចិត្តឱ្យយុវជនចូលរួមយ៉ាងសកម្ម ក្នុងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមសហគមន៍ និង (៥) លើកទឹកចិត្តការបណ្តុះបណ្តាលសហគ្រិនភាពដល់យុវជន ដោយផ្សារភ្ជាប់នឹងឱកាសធ្វើជំនួញខ្នាតតូច មធ្យម និងធំ។

**ជីបី–បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព** តាមរយៈ (១) ការពង្រីកការអប់រំសុខភាព និងការបង្កើនលទ្ធភាពទទួលបានព័ត៌មានអំពីការអប់រំ និងបង្ការនូវបញ្ហាមួយចំនួន ដូចជា៖ បញ្ហាសុខភាព សុខភាពបន្តពូជ គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់នៅកន្លែងធ្វើការ បញ្ហាអនាម័យ និងការប្រើប្រាស់ទឹកស្អាត សុខភាពផ្លូវចិត្ត ការធ្វើអត្តឃាត និងការទប់ស្កាត់អំពើហិង្សា និង (២) ការបង្កើនការទទួលសេវាសុខភាពសម្រាប់យុវជនប្រកបដោយភាពងាយស្រួល និងមានគុណភាព និង(៣) ការពង្រឹងបណ្តាញសន្តិសុខសង្គម ដើម្បីធានាថាយុវជនដែលក្រីក្របំផុតក៏អាចទទួលបានសេវាថែទាំសុខភាព។

**ជីបួន–បណ្តុះស្មារតីសហគ្រិនភាព និងទីផ្សារការងារ** តាមរយៈ (១) ការធ្វើឱ្យ ប្រសើរឡើងនូវបរិយាកាសទីផ្សារការងារនិងសហគ្រិនភាពសម្រាប់យុវជន (២) ការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញអាជីព និងជំនាញប្រកបរបរចិញ្ចឹមជីវិត និងផ្តល់ព័ត៌មានពីការជ្រើសរើសការងារដល់អ្នកស្វែងរកការងារធ្វើ (៣) ការអភិវឌ្ឍផែនការដើម្បីពិនិត្យតាមដាន និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និង (៤) ការផ្តល់កាលានុវត្តភាពដល់យុវជន ដើម្បីចាប់ផ្តើមអាជីវកម្មខ្នាតតូច មធ្យម និងធំ ព្រមទាំងផ្តល់មូលនិធិមួយចំនួនសម្រាប់ការចាប់ផ្តើម និងការពង្រឹងអាជីវកម្មរបស់ខ្លួន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជីថ្ងៃទី៦–លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ សន្តិភាព និងយុត្តិធម៌** តាមរយៈ (១) ការយល់ដឹងអំពីច្បាប់ សិទ្ធិ ផលប្រយោជន៍ កាតព្វកិច្ច និងការទទួលខុសត្រូវ និងស្វែងរកដំណោះស្រាយនូវបញ្ហារបស់យុវជន (២) ការបង្កើត និងអនុវត្តរាល់ការផ្តួចផ្តើមគំនិតនៅថ្នាក់ឃុំ សង្កាត់ ដើម្បីទប់ស្កាត់អំពើឧក្រិដ្ឋកម្ម និងបទល្មើស។

**ជីថ្ងៃទី៧–បង្កើនការចូលរួមរបស់យុវជន** តាមរយៈ (១) ការបង្កលក្ខណៈងាយស្រួលឱ្យយុវជនចូលរួមក្នុងសហគមន៍ និងមូលដ្ឋាន (២) ជំរុញឱ្យមានតំណាង យុវជននៅក្នុងគណៈកម្មាធិការ ឬក្រុមប្រឹក្សាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងថ្នាក់តំបន់ ព្រមទាំងការធានាសមាហរណកម្មយុវជនចូលទៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ និង (៣) ការគាំទ្រការចូលរួមរបស់យុវជននៅក្នុងការបង្កើតគោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ដែលបម្រើផលប្រយោជន៍របស់យុវជន។

**ជីថ្ងៃទី៨–លើកកម្ពស់ការសម្រាក ការកំសាន្ត និងកីឡា** តាមរយៈ (១) ការបង្កើតហេដ្ឋារចនាសម្ព័ន្ធកីឡា និងពហុកីឡដ្ឋាន និងលើកកម្ពស់ការចូលរួមលេងកីឡានិងការបណ្តុះបណ្តាលកីឡា និង (២) លើកកម្ពស់ការយល់ដឹងពីតម្លៃកីឡា ការចូលរួមរបស់ខ្លួនលើវិស័យកីឡា សកម្មភាពអប់រំកីឡា និងការប្រកួតកីឡា ព្រមទាំងស្វែងរកការគាំទ្រពីឪពុកម្តាយ សហគមន៍ សាលារៀន ក្លឹប សហព័ន្ធកីឡា និងអ្នកនយោបាយ ដើម្បីអភិវឌ្ឍកីឡាគ្រប់ប្រភេទ។

**ជីថ្ងៃទី៩–លើកកម្ពស់សិល្បៈ និងវប្បធម៌** តាមរយៈ ៖ (១) ការលើកតម្កើងតម្លៃនៃការអប់រំ និងចំណេះដឹងអំពីប្រវត្តិសាស្ត្រ ប្រពៃណីជាតិ សាសនា និងការថែរក្សានូវបេតិកភណ្ឌជាតិ (២) ការលើកតម្កើង និងគាំទ្រគំនិតផ្តួចផ្តើមទាក់ទងនឹងតន្ត្រី គំនូរ ស្ថាបត្យកម្ម ភាពយន្ត អក្សរសិល្ប៍ខ្មែរ និងទម្រង់ផ្សេងៗទៀតក្នុងសិល្បៈ និង (៣) លើកតម្កើងការអប់រំ ដោយផ្អែកលើគោលការណ៍ជាមូលដ្ឋាននៃសិល្បៈ និងវប្បធម៌ ការចូលរួមរបស់យុវជនក្នុងសកម្មភាពវប្បធម៌ក្នុងសហគមន៍ និងសិប្បករផ្សេងៗទៀត។

**ជីថ្ងៃទី១០–**លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរៈកិច្ច។

**ជី១១–បង្កើនការងារស្ម័គ្រចិត្ត** តាមរយៈ ៖ (១) បង្កើនការយល់ដឹងពីសារៈសំខាន់នៃការងារស្ម័គ្រចិត្តរបស់យុវជន និងអត្ថប្រយោជន៍របស់វា និងកសាងបណ្តាញអ្នកស្ម័គ្រចិត្តក្នុងកម្រិតថ្នាក់ជាតិ និងក្រោមជាតិ (២) លើកកម្ពស់ចលនាស្ម័គ្រចិត្ត និងដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិ និងសកម្មភាពមនុស្សធម៌ (៣) គាំទ្រគំនិតផ្តួចផ្តើមអ្នកស្ម័គ្រចិត្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងស្រុក អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការទាក់ទងនឹងការងារស្ម័គ្រចិត្ត និងបណ្ដាញយុវជនស្ម័គ្រចិត្ត ព្រមទាំងសម្របសម្រួលយន្តការដែលត្រូវបានបង្កើតឡើង និងសហការប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដើម្បីជួយដល់យុវជន។

**ជីជប់មួយ**–លើកកម្ពស់សមភាពយេនឌ័រ តាមរយៈ៖ (១) លើកទឹកចិត្តដល់វិស័យឯកជន និងសាធារណៈ និងសង្គមស៊ីវិលដើម្បីយកចិត្តទុកដាក់ទៅលើបញ្ហាវិសមភាពយេនឌ័រ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងឡាយ និង (២) លើកកម្ពស់តួនាទីភាពជាអ្នកដឹកនាំ និងសិទ្ធិក្នុងតួនាទីជាអ្នកសម្រេចចិត្តរបស់យុវជន។

**ជីជប់ពីរ**–ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្តារយុវនីតិសម្បទា តាមរយៈ៖ (១) ការបង្កើតនូវយន្តការ និង ការអនុវត្តផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងការពារយុវជន ឱ្យរួចផុតពីការពាក់ព័ន្ធនឹងការដាំដុះ ការផលិត ការជួញដូរ ការចរាចរ និងការរក្សាទុក ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀន (២) ការបង្កើតនូវយន្តការមិត្តអប់រំមិត្ត ដើម្បីលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និង (៣) ការរៀបចំមជ្ឈមណ្ឌលនីតិសម្បទា ដើម្បីព្យាបាល និងស្តារនីតិសម្បទា ព្រមទាំងបណ្តុះ-បណ្តាលជំនាញដល់យុវជនរងគ្រោះ និងធ្វើសមាហរណកម្មពួកគេចូលទៅក្នុងសង្គមវិញ។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនទទួលស្គាល់នូវសុបិន្ត តម្រូវការ និង ស្ថានភាពយុវជន តាមរយៈការកំណត់យ៉ាងច្បាស់ពីចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ ដើម្បីធ្វើឱ្យមានចលនាយុវជនកម្ពុជា ក្នុងគោលបំណងអភិវឌ្ឍយុវជនឱ្យក្លាយជាប្រជាពលរដ្ឋល្អ ដោយភ្ជាប់ជាមួយ ចំណេះដឹង ជំនាញ ការច្នៃប្រឌិត គំនិតផ្តួចផ្តើម និងជំនាញសហគ្រិនភាព ដែលជាកត្តាដ៏មានសក្តានុពលសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

## ៣.២.១២ គោលនយោបាយស្តីពី ធនធានមនុស្សក្នុងវិស័យអប់រំ (២០១២)

គោលនយោបាយស្តីពី **ធនធានមនុស្សក្នុងវិស័យអប់រំ** មានគោលបំណងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ មានជំនាញវិជ្ជាជីវៈច្បាស់លាស់ មានការទទួលខុសត្រូវខ្ពស់ មានភាពឆ្លើយតប ដើម្បីប្រើប្រាស់តាមតម្រូវការប្រកបដោយភាពស័ក្តិសិទ្ធិ ក្នុងគោលដៅពង្រឹងសមត្ថភាពបុគ្គល និងស្ថាប័ន។ គោល-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នយោបាយនេះ ត្រូវបានរៀបចំឡើងដើម្បី ៖ (១) បង្កើនប្រសិទ្ធភាពការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ (២) ធ្វើសនិទានកម្មលើដំណើរការគ្រប់គ្រង ការអភិវឌ្ឍ និងការប្រើ-ប្រាស់ធនធានមនុស្សក្នុងវិស័យអប់រំ (៣) ពង្រឹងសមត្ថភាពបុគ្គល អង្គភាព និងស្ថាប័នក្នុងវិស័យអប់រំ និង (៤) ពង្រឹងក្រមសីលធម៌ និងវិន័យការងាររបស់បុគ្គលិកអប់រំ។

គោលនយោបាយរៀបចេញជាយុទ្ធសាស្ត្រដូចខាងក្រោម ៖

**ទីមួយ–កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការ** ៖ សម្រាប់ការអនុវត្ត គាំទ្រ ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ។

**ទីពីរ–ពង្រឹង និងធ្វើទំនើបកម្មការកសាងផែនការធនធានមនុស្ស** ៖ ដោយបង្កើនប្រសិទ្ធភាពប្រព័ន្ធប្រមូល គ្រប់គ្រង និងវិភាគទិន្នន័យធនធានមនុស្ស ការរៀបចំផែនការ ធ្វើការ-ស្រាវជ្រាវ វិភាគតម្រូវការ និងការផ្គត់ផ្គង់បុគ្គលិកអប់រំ និងលើកកម្ពស់ការអភិវឌ្ឍបុគ្គលិកអប់រំ ៖ ដោយរៀបចំឱ្យពួកគេបំពេញការងារចំកន្លែង ទាន់ពេល ចំជំនាញ ស្របតាមការពណ៌នាមុខតំណែង លក្ខណសម្បត្តិមុខតំណែង និងអាទិភាពតម្រូវការ។

**ទីបី–លើកកម្ពស់គុណភាពបណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈ** ៖ ដោយរៀបចំគន្លងអាជីពសម្រាប់បុគ្គលិកអប់រំ ធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលមុនពេលបម្រើការងារ កំណត់លក្ខណសម្បត្តិអប្បរមាសម្រាប់ជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូសហគមន៍ ព្រមទាំងបង្កើនសមត្ថភាពវិភាគ និងវាយតម្លៃការផ្គត់ផ្គង់ និងតម្រូវការការជ្រើសរើសបុគ្គលិកអប់រំ។

**ទីបួន–លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងដឹកនាំ**៖ ដោយបង្កើតស្តង់ដាប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលបំពេញការងាររបស់បុគ្គលិកអប់រំ ពង្រឹងនីតិវិធី នៃការជ្រើសរើស ការបំប៉ន និងការរក្សាទុកបុគ្គលិកអប់រំមានស្នាដៃល្អ លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំ បែងចែកនិងផ្លាស់ប្តូរទីកន្លែងបម្រើការងារបុគ្គលិកអប់រំ តាមនិយាម និងគោលការណ៍កំណត់ និងធ្វើសវនកម្មលើការប្រើប្រាស់ក្របខណ្ឌបុគ្គលិកតាមស្ថាប័នអប់រំ។

**ទីប្រាំ–កំណត់គោលការណ៍ដើម្បីធានាឱ្យបុគ្គលិកអប់រំបំពេញការងារអស់លទ្ធភាព**៖ ដោយធានាគោលការណ៍លើកទឹកចិត្ត ៖ ប្រាក់បៀវត្ស លាភការបន្ថែម និងអត្ថប្រយោជន៍ផ្សេងៗ ពង្រឹងការអនុវត្តច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ជំរុញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអនុវត្ត និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបុគ្គលិកអប់រំ លើកកម្ពស់ផាសុកភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ និងលើកកម្ពស់តម្លៃ សេចក្ដីថ្លៃថ្នូរ និងក្រមសីលធម៌វិជ្ជាជីវៈរបស់បុគ្គលិកអប់រំ។

### ៣.២.១៣ ផែនការមេស្ដីពី ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ២០១៤-២០១៨ (២០១៤)

ផែនការមេស្ដីពី **ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ** (MPCD) មានគោលបំណងដើម្បីដោះស្រាយបញ្ហា ដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍសមត្ថភាព ដែលបានរកឃើញនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ដោយផ្ដោតលើបញ្ហាទាំងឡាយណាដែលនឹងនាំឱ្យមានផលប៉ះពាល់លើគុណផលជារួម សម្រាប់រយៈពេលយូរអង្វែង តែក៏មានរួមបញ្ចូលវិស័យគន្លឹះមួយចំនួនទៀត ដែលនឹងផ្ដល់គុណប្រយោជន៍សម្រាប់រយៈពេលខ្លី និងមធ្យម។ ផែនការគោលនេះនឹងពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលនឹងគាំទ្រកម្មវិធីកំណែទម្រង់ចម្បង។ ផែនការគោល គឺជាការតាមដាននូវផែនការអភិវឌ្ឍសមត្ថភាព ២០១១-២០១៣ ដែលផ្អែកលើការវាយតម្លៃតម្រូវការ សម្រាប់នាយកសាលាមន្ទីរ និងការិយាល័យជំនាញក្នុងការកំណត់ឱ្យច្បាស់នូវតម្រូវការ និងអាទិភាពរបស់ពួកគេ។ សមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺមុខងារនៃ ៖ (១) ចំណេះដឹង ជំនាញ និងការលើកទឹកចិត្តបុគ្គលម្នាក់ៗ (២) មុខងារនៃប្រព័ន្ធ និងដំណើរការ យន្តការទំនាក់ទំនងផ្សេងៗ (៣) ការតភ្ជាប់គ្នារវាងប្រព័ន្ធ អង្គភាព និងកម្រិតរដ្ឋបាលផ្សេងៗគ្នា (៤) យុទ្ធសាស្ត្រ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ និង (៥) វប្បធម៌ជាតិ មានជាអាទិ៍ វប្បធម៌ស្ថាប័នរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបទដ្ឋានវិន័យអាកប្បកិរិយាក្នុងក្រសួង។

ដោយហេតុដូច្នេះហើយបានជា ផែនការមេប្រើប្រាស់នូវក្របខណ្ឌធម្មតាមួយដែលមានសមាសភាពដូចខាងក្រោម ៖

**បរិយាកាសបង្កើត** ៖ ប្រព័ន្ធអប់រំដំណើរការ ក្នុងក្របខណ្ឌកម្លាំងទំនាក់ទំនងផ្នែកវប្បធម៌ និងបទដ្ឋានសង្គម ដែលធ្វើឱ្យមានទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងអង្គការប្រព័ន្ធអភិបាល ច្បាប់ និងបទដ្ឋាន ជំនួយបរិស្ថាន កម្មវិធីកំណែទម្រង់ ទំនាក់ទំនងរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល អ្នកប្រើប្រាស់សេវាអប់រំ ដែលគេឱ្យឈ្មោះថាអ្នកសិក្សា មាតាបិតា និងសមាជិកសហគមន៍ ព្រមទាំងវិស័យឯកជន។

**ធនធានមនុស្ស** ៖ ការអភិវឌ្ឍធនធានមនុស្សគឺមិនត្រូវធ្វើឡើង ដើម្បីគ្រាន់តែធានាថា  បុគ្គលគ្រប់រូបមានជំនាញចាំបាច់ និងចំណេះដឹង ព្រមទាំងការយល់ដឹងដើម្បី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អនុវត្តការងារពួកគេនោះទេ តែត្រូវមានភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព និងបទ-ពិសោធន៍ ទាំងក្នុងក្រុមការងារ ទាំងក្នុងនាយកដ្ឋាន ជាដើម។ ការផ្លាស់ប្តូរការគ្រប់គ្រង ការបង្កើតនូវប្រសិទ្ធភាព បរិយាកាសរៀនសូត្រ ការលើកទឹកចិត្ត ដោយផ្សារភ្ជាប់ នឹងគុណតម្លៃរួម និងសុភនិច្ឆ័យនៃបេសកកម្ម និងគោលបំណង គឺមានភាពសំខាន់ណាស់។

**ប្រព័ន្ធ** ៖ វិស័យអប់រំត្រូវបានបង្ហាញចេញ ដោយប្រព័ន្ធចាក់ស្រេះគ្នាជាច្រើន។ នាយកសាលាប្រកបដោយឧបនិស្ស័យលើទំនាក់ទំនងរវាងបុគ្គល និងជំនាញក្នុងការត្រួតពិនិត្យ ត្រូវតែទទួលបានការគាំទ្រ ដោយប្រព័ន្ធគ្រប់គ្រងមួយ ក្នុងការតាក់តែងផែនការអភិវឌ្ឍសាលារៀន បង្កើតមូលនិធិត្រឹមត្រូវ និងបង្កើតប្រព័ន្ធតាមដានមានលក្ខណៈប្រសើរមួយ។

**យន្តការ** ៖ ត្រូវមានយន្តការនានា ដើម្បីគាំទ្រឱ្យប្រព័ន្ធអប់រំនោះមានប្រសិទ្ធភាព ហើយយន្តការទាំងនោះមានដូចជា ៖ (១) ភាពចាស់ទុំក្នុងសិល្បៈដឹកនាំ ដើម្បីបង្កើតបានជាយុទ្ធសាស្ត្រទូលំទូលាយពាក់ព័ន្ធនឹងវិស័យនេះ និងដើម្បីធានាជារួមនូវភាពស៊ីចង្វាក់ និងទិសដៅ (២) ការពិគ្រោះយោបល់ និងការចូលរួមជាមួយអ្នកដែលពាក់ព័ន្ធសំខាន់ៗក្នុងវិស័យអប់រំ (៣) ការបញ្ចូលបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងយេនឌ័រ សមធម៌ និងបញ្ហាដែលកាត់គ្នា (៤) តំណភ្ជាប់ទៅនឹងកម្មវិធី កំណែទម្រង់រដ្ឋាភិបាល (៥) ការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ និង (៦) ទំនាក់ទំនងជាខ្សែបណ្តោយ និងធ្វើការរួមគ្នាឆ្លងតាមនាយកដ្ឋានជំនាញ និងវិស័យផ្សេងៗ។

ដូច្នេះហើយបានជានៅក្នុងផែនការមេ មានលេចចេញជាសកម្មភាពដូចខាងក្រោម ៖

- ការបណ្តុះបណ្តាល និងបន្តការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់អ្នកគ្រប់គ្រង និងអ្នកដឹកនាំ
- ការគាំទ្រក្នុងការរៀបចំអភិវឌ្ឍមន្ទីរអយក រាជធានី ខេត្ត និងការិយាល័យអប់រំស្រុក ខណ្ឌ
- ការបណ្តុះបណ្តាលសមត្ថភាព និងយន្តការសម្រាប់ធ្វើផែនការយុទ្ធសាស្ត្រ វិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ការបណ្តុះបណ្តាល និងបន្តការអភិវឌ្ឍសមត្ថភាពសម្រាប់នាយកដ្ឋានផែនការ
- ការបណ្តុះបណ្តាល និងបង្កើតកាលានុវត្តភាពអភិវឌ្ឍសមត្ថភាពផ្សេងទៀត ដើម្បីកសាងផែនការថ្នាក់ក្រោមជាតិ និងជំនាញតាមដាន និងវាយតម្លៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការបណ្តុះបណ្តាល និងបង្កើតកាលានុវត្តភាពអភិវឌ្ឍសមត្ថភាពផ្សេងទៀត ដែលទាក់ទងនឹងការពិនិត្យឡើងវិញទៅតាមវិស័យ និង សន្និបាតអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិ
- ការអនុវត្ត និងតាមដានផែនការមេសម្រាប់ការអភិវឌ្ឍសមត្ថភាព
- ការពង្រឹងយន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ
- ការអភិវឌ្ឍបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងវិមជ្ឈការថ្នាក់ក្រោមជាតិ និងវិសហមជ្ឈការ (D&D)
- ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ និងការិយាល័យអប់រំស្រុកសម្រាប់តួនាទី និងរចនាសម្ពន្ធថ្មី
- ការបណ្តុះបណ្តាល និងបន្តការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់នាយកដ្ឋានបុគ្គលិក
- ការបណ្តុះបណ្តាលភាសាអង់គ្លេស
- ការបង្កើនភាពច្បាស់លាស់ និងមុខងារនៃការពណ៌នាមុខងារ និងការកំណត់មុខងាររបស់បុគ្គលិក
- ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស (HRMIS) និងសមត្ថភាពបុគ្គលិក ដើម្បីប្រើប្រាស់ប្រព័ន្ធនេះ
- ការពង្រឹងការអនុវត្តនិយាមប្រើប្រាស់បុគ្គលិក
- ការអភិវឌ្ឍការរក្សាទុកបុគ្គលិក និងប្រព័ន្ធវាយតម្លៃបុគ្គលិក
- ការពង្រឹងប្រព័ន្ធឯកសារ និងរដ្ឋបាល
- ការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាព័ត៌មាន (ICT)
- ការបង្កើនធនធានរូបវន្តនៃនាយកដ្ឋានបច្ចេកទេស ការិយាល័យអប់រំស្រុក និងមន្ទីរ
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ
- ការបណ្តុះបណ្តាល និងបន្តអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ សវនកម្ម និងអធិការកិច្ច
- ការបណ្តុះបណ្តាលនាយកសាលា និងអភិវឌ្ឍវិជ្ជាជីវៈ (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋាមធ្យមសិក្សាចំណេះទូទៅ)
- ការពង្រឹងសមត្ថភាពគណៈកម្មការទ្រទ្រង់សាលារៀន (SSC) ដើម្បីចូលរួមក្នុងការគ្រប់គ្រង និងអភិវឌ្ឍសាលារៀន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- អភិវឌ្ឍសមត្ថភាព និងរចនាសម្ពន្ធនៃក្រុមការងារតាមដាន និងបណ្តុះបណ្តាលថ្នាក់ស្រុក (DTMTs) និងនៃកម្រងសាលា ព្រមទាំងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងនាយកដ្ឋានបឋមសិក្សា
- ពង្រឹងយន្តការសម្រាប់ការធានាគុណភាពអប់រំ
- អភិវឌ្ឍសមត្ថភាពគ្រប់គ្រង និងក្របខណ្ឌសម្រាប់ការអប់រំកុមារតូច (ECE)
- អភិវឌ្ឍសមត្ថភាពគ្រប់គ្រង និងរចនាសម្ពន្ធសម្រាប់ការអប់រំក្រៅប្រព័ន្ធ (NFE)
- ពង្រឹងវិទ្យាស្ថានជាតិអប់រំ (NIE)
- ពង្រឹងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និងស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សាដែលមានការទទួលស្គាល់ផ្សេងៗទៀតដើម្បីគាំទ្រការស្រាវជ្រាវអប់រំ
- ពង្រឹងអង្គការមិនមែនរដ្ឋាភិបាលដើម្បីគាំទ្រការស្រាវជ្រាវដែលជាប់ពាក់ព័ន្ធក្នុងវិស័យអប់រំ។

### ៣.២.១៤ គោលនយោបាយស្តីពី សៀវភៅសិក្សា (២០១២)

សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គឺជាមធ្យោបាយដ៏ចម្បងសម្រាប់គាំទ្រដល់ការបង្រៀន និងរៀននៅកម្ពុជា។ គោលនយោបាយស្តីពី **សៀវភៅសិក្សា** មានគោលដៅផលិត និងចែកចាយឱ្យបានគ្រប់គ្រាន់ សៀវភៅគោលសិក្សា ដែលមានគុណភាពខ្ពស់ សម្រាប់ជួយគ្រូលើកកម្ពស់វិធីសាស្រ្តបង្រៀន និងវិធីរៀនថ្មី និងនាំមកនូវការផ្លាស់ប្តូរពីការរៀនដោយទន្ទេញចាំមាត់ ទៅជាការរៀនបែបសកម្ម។ វិធីសាស្រ្តថ្មីនេះអាចជួយសម្រួលគ្រូបង្រៀនតាមរយៈការផ្តល់ឧទាហរណ៍ថ្មីៗ និងអនុញ្ញាតឱ្យសិស្សអាចចាប់យកខ្លឹមសារព័ត៌មាន និងឱ្យសិស្សអាចប្រើប្រាស់វាបាន។ គោលបំណងនៃគោលនយោបាយនេះ គឺការផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សិស្សដោយឥតគិតថ្លៃ ដើម្បីសម្រេចបាននូវផលធៀបសៀវភៅ និងសិស្ស ១:១ មានន័យថាសៀវភៅមួយក្បាល សម្រាប់សិស្សម្នាក់ សម្រាប់គ្រប់មុខវិជ្ជាពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។ ទោះបីជាយ៉ាងណា ចំណុចដៅបឋម គួរតែសម្រេចបានផលធៀប ១:១ សម្រាប់ ថ្នាក់ទី១ ដល់ថ្នាក់ទី ៩ និង បន្ទាប់មកទៀតសម្រាប់ថ្នាក់ទី១០ ដល់ទី១២ ក៏ព្រោះតែថវិកាសម្រាប់អនុវត្តគោលនយោបាយនេះមានរួចស្រេចទៅហើយ។ ក្នុងរយៈវែង សម្ភារគាំទ្របន្ថែមក្នុងទម្រង់ជាសៀវភៅគោលសិក្សា សៀវភៅលំហាត់ សម្ភារបន្ថែមជាដើម គួរតែឱ្យមាននៅតាមសាលា។ នាពេលបច្ចុប្បន្ន សៀវភៅសិក្សាគោលទាំងអស់ត្រូវបានរៀបចំ និងបោះពុម្ពដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ដែលជាសហគ្រាសស្វយ័តរបស់រដ្ឋ។ ក៏ប៉ុន្តែនាពេលថ្មីៗនេះ ការបោះពុម្ពសៀវភៅគោលសិក្សា ចាប់ផ្តើមមានការប្រកួតប្រជែង ពី

បណ្ណាល័យពុម្ពនានាផងដែរ។ នាពេលអនាគត សាលារៀន គ្រូបង្រៀន និងមាតាបិតា សិស្សអាចជ្រើសរើសសៀវភៅគោល ដែលអភិវឌ្ឍដោយក្រុមហ៊ុនឯកជន។ ការចែកចាយសៀវភៅសិក្សាដល់ស្រុក និងសាលារៀនត្រូវបាន និងកំពុងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយអ្នកផ្គត់ផ្គង់ឯកជន។

សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅគ្រូត្រូវតែឆ្លុះបញ្ចាំង និងគាំទ្រចំពោះវត្ថុបំណងរបស់កម្មវិធីសិក្សា និងលើកទឹកចិត្តការរៀនសូត្របែបសកម្ម ដើម្បីគាំទ្រលទ្ធផលការសិក្សាឱ្យកាន់តែប្រសើរ។ ក្នុងន័យនេះ វត្ថុបំណងនៃការផ្គត់ផ្គង់សៀវភៅសិក្សាគោលមានដូចតទៅ៖ (១) **លទ្ធភាពទទួលបាន**- សិស្សានុសិស្សទាំងអស់ នៅគ្រប់កម្រិតសិក្សាត្រូវមានលទ្ធភាពទទួលបានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ឬមានលទ្ធភាពអាចទិញសៀវភៅសិក្សាផ្សេងទៀត (២) **គុណភាព**- សៀវភៅសិក្សាគោលដែលបានអនុម័តឱ្យប្រើប្រាស់ ត្រូវមានគុណភាពខ្ពស់ និងគាំទ្រដល់កម្មវិធីសិក្សា សម្រាប់មុខវិជ្ជានីមួយៗ និងគ្រប់កម្រិតថ្នាក់ និង (៣) **ការគាំទ្រ**- រាល់សៀវភៅសិក្សាគោលទាំងអស់ត្រូវមានការគាំទ្រពីសៀវភៅសិក្សាគោលសម្រាប់គ្រូ និងសម្ភារឧបទេសបន្ថែមសម្រាប់ការរៀន និងការបង្រៀន ដើម្បីពង្រីកការយល់ដឹងកាន់តែបានច្រើន។ ការគ្រប់គ្រងលើសៀវភៅសិក្សានៅតាមសាលារៀន គឺមានសារៈសំខាន់ខ្លាំងណាស់។ ដល់ចំណុចនេះ ការផ្តល់នូវភាពគត់មត់ ទូរដាក់សៀវភៅដែលអាចចាក់សោបាន និងការបណ្តុះបណ្តាលបន្ថែមដល់នាយកសាលា ក្នុងការគ្រប់គ្រងសៀវភៅដើម្បីកាត់បន្ថយអត្រានៃការបាត់បង់ និងខូចខាតសៀវភៅ គឺជាប្រការចាំបាច់ដែលត្រូវធ្វើ។

សៀវភៅសិក្សាគោលត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស (ក.អ.ស.ស.) ដែលមានតួនាទីជាអ្នកទទួលខុសត្រូវ លើការវិនិច្ឆ័យលើគុណភាពទាក់ទងនឹងភាពសមស្របជាមួយនឹងកម្មវិធីសិក្សា។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡាត្រូវពង្រឹងសមត្ថភាពរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីអាចធ្វើការវាយតម្លៃគុណភាពនៃសម្ភារ ដែលបានដាក់ឱ្យវាយតម្លៃទាំងនោះ។ ម្យ៉ាងវិញទៀត សៀវភៅសិក្សាគោល និងកម្មវិធីសិក្សាគួរតែត្រូវបានវាយតម្លៃឱ្យបានទៀងទាត់ ដើម្បីធានាថា សៀវភៅទាំងនោះ សមស្របនឹងគោលបំណងនៃការអប់រំ។

សម្ភារបន្ថែមរួមទាំងសៀវភៅអំណាន សម្ភារងាយសម្រាប់ជំនួយដល់ការបង្រៀនគណិតវិទ្យា និងសម្ភារផ្សេងៗទៀត (ក្រដាស ខ្មៅដៃ ស្កុតស្អិត ជាដើម) គួរតែមានប្រើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីជួយដល់គ្រូក្នុងការអភិវឌ្ឍសមត្ថភាព ជាជំនួយក្នុងការបង្រៀន និងដើម្បីលើកកម្ពស់ឱ្យមានការរៀនសូត្រកាន់តែសកម្ម។

គោលដៅក្នុងរយៈពេលវែងសម្រាប់សាលានីមួយៗក្នុងប្រទេសកម្ពុជា គឺការបង្កើតបណ្ណាល័យដែលមានសៀវភៅអប់រំគ្រប់គ្រាន់ ដើម្បីគាំទ្រវប្បធម៌អំណាន។ ជំនាញស្រាវជ្រាវក្នុងបណ្ណាល័យត្រូវបានលើកទឹកចិត្ត ព្រោះថាការស្រាវជ្រាវនេះមានសារៈសំខាន់ ចំពោះគោលការណ៍នៃការសិក្សាពេញមួយជីវិត។ ការបណ្តុះបណ្តាលដំបូង និងបន្តដោយមានបញ្ចូលនូវជំនាញពាក់ព័ន្ធនឹងសៀវភៅសិក្សា នឹងធ្វើឱ្យគ្រូដែលមានស្រាប់ព្រមទាំងគរុសិស្ស និងនិស្សិតមានចំណេះជំនាញក្នុងការប្រើប្រាស់ និងគ្រប់គ្រងសៀវភៅសិក្សានៅក្នុងសាលារៀន ។

### ៣.២.១៩ គោលនយោបាយស្តីពី **ការអប់រំបច្ចេកទេស** (២០១៣)

គោលនយោបាយស្តីពី **ការអប់រំបច្ចេកទេស** មានគោលបំណងផ្តល់ឱ្យសិស្សកម្រិតមធ្យមសិក្សា ទទួលបានចំណេះដឹង សមត្ថភាព និងតម្លៃ ដើម្បីក្លាយខ្លួនជាពលករជំនាញ និងពលរដ្ឋថ្លៃថ្នូរ មានជំនាញបច្ចេកទេស នវានុវត្តន៍ និងសហគ្រិនភាព ដើម្បីឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងលើកតម្កើងការសិក្សាពេញមួយជីវិត។ គោលបំណងនៃគោលនយោបាយនេះគឺដើម្បី ៖ (១) អភិវឌ្ឍគ្រឹះស្ថានមធ្យមសិក្សា ឱ្យមានលក្ខណសម្បត្តិពេញលេញ ជាគ្រឹះស្ថានអប់រំបច្ចេកទេស (២) ពង្រឹងសមត្ថភាពគ្រូបង្រៀន ឱ្យមានជំនាញអប់រំបច្ចេកទេសពិតប្រាកដ (៣) អភិវឌ្ឍកម្មវិធីសិក្សាអប់រំបច្ចេកទេស ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម (៤) ផ្តល់ឱ្យសិស្សមធ្យមសិក្សានូវជម្រើសនៃការបន្តការសិក្សាផ្នែកអប់រំបច្ចេកទេស ដើម្បីទទួលបានជំនាញ ស្របទៅតាមតម្រូវការចាំបាច់សម្រាប់ការងារនាពេលអនាគត (៥) កៀរគរធនធានពីអ្នកពាក់ព័ន្ធទាំងអស់។

គោលនយោបាយស្តីពី **ការអប់រំបច្ចេកទេស** មានយុទ្ធសាស្ត្រដូចខាងក្រោម៖

***ទីមួយ***–អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការសម្រាប់ការអនុវត្ត។

***ទីពីរ***–ពង្រីកបណ្តាញវិទ្យាល័យអប់រំបច្ចេកទេស ដោយបំពាក់នូវសម្ភារចាំបាច់សម្រាប់ការបណ្តុះបណ្តាល។

***ទីបី***–កសាងសមត្ថភាពបុគ្គលិកអប់រំ ផ្នែកការអប់រំបច្ចេកទេស។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជីប្អូន**–អភិវឌ្ឍកម្មវិធិសិក្សានៃការអប់រំបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម ជាពិសេស តាមរយៈការបង្កើនការអនុវត្តកម្មវិធីបំណិនជីវិតមូលដ្ឋាន និងជំនាញវិជ្ជាជីវៈ ហើយក៏រៀបចំសៀវភៅសិក្សានិងសៀវភៅគ្រូស្តីពីការអប់រំបច្ចេកទេស។

**ជីទ្រាំ**–លើកកម្ពស់ការតម្រង់ទិសវិជ្ជាជីវៈ ការអប់រំបច្ចេកទេស ការប្រឹក្សាការងារ និងបង្កើនការយល់ដឹងរបស់សិស្ស ពីតម្រូវការនៃទីផ្សារពលកម្ម ដើម្បីតភ្ជាប់ការតម្រង់ទិសបច្ចេកទេសជាមួយទីផ្សារការងារ។

**ជីទ្រាំពីរ**–លើកកម្ពស់សហប្រតិបត្តិការលើការអប់រំបច្ចេកទេស ជាមួយដៃគូអភិវឌ្ឍ និងវិស័យឯកជន ។

**ជីទ្រាំបី**–កាត់បន្ថយវិសមភាពយេនឌ័រក្នុងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។

**ជីទ្រាំប្អូន**–បណ្តុះស្មារតីសហគ្រិនភាព និងទីផ្សារការងារ។

## ៣.២.១៦ គោលនយោបាយស្តីពី ចក្ខុវិស័យឧត្តមសិក្សា ២០៣០ (២០១៤)

**ចក្ខុវិស័យឧត្តមសិក្សា ២០៣០** ត្រូវបានរៀបចំឡើងដើម្បីធានាសមធម៌ទូលំទូលាយ និងការចូលរៀនសម្រាប់និស្សិត ការសម្របសម្រួលដ៏រលូន និងមានប្រសិទ្ធភាពអភិបាលកិច្ចល្អនៅឧត្តមសិក្សា យន្តការចាំបាច់នានាដើម្បីគាំទ្រគុណភាពប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា និងការអភិវឌ្ឍធនធានមនុស្ស ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសកម្ពុជាលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងទីផ្សារពលកម្ម។ គោលបំណងរបស់គោលនយោបាយនេះ គឺ៖ (១) បង្កើតកម្មវិធីសមធម៌ និងការចូលរៀនឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាថា និស្សិតដែលមានសមត្ថភាពអាចចូលរៀននៅឧត្តមសិក្សា (២) អភិវឌ្ឍកម្មវិធីសិក្សាដែលមានភាពឆ្លើយតប ដើម្បីផ្តល់ឱ្យនិស្សិតនូវចំណេះដឹង និងជំនាញដ៏ប្រសើរបំផុត (៣) លើកកម្ពស់គុណភាពនៃការរៀន ការបង្រៀន និងការស្រាវជ្រាវ ដើម្បីផ្តល់ឱ្យនិស្សិតនូវចំណេះដឹង និងជំនាញ (៤) អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច យន្តការ និងគោលនយោបាយឧត្តមសិក្សា ដើម្បីលើកកម្ពស់គុណភាពនៃការគ្រប់គ្រង និងសមិទ្ធកម្មនៃគ្រឹះស្ថានឧត្តមសិក្សា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលនយោបាយស្តីពី **ចក្ខុវិស័យឧត្តមសិក្សា ២០៣០** មានយុទ្ធសាស្ត្រដូចខាងក្រោម ៖

**ទីមួយ**–ធានាថានិស្សិតដែលមានសមត្ថភាពមានឱកាសចូលរៀនថ្នាក់ឧត្តមសិក្សា ដោយមិនគិតទៅដល់កម្រិតសេដ្ឋកិច្ច និងឋានៈក្នុងសង្គម។

**ទីពីរ**–ធានាថា គ្រប់ស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សាទាំងអស់ផ្តល់ឱ្យសិស្សនូវកម្មវិធីសិក្សាដែលមានគុណភាព ដើម្បីបំពេញតម្រូវការ និងអាទិភាពជាតិ។

**ទីបី**–ធានាថា ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាកម្ពុជាបង្កើនឱកាសអតិបរមាសម្រាប់និស្សិត ដែលមានសមត្ថភាពឱ្យចូលរៀនពេញមួយជីវិត និងការអភិវឌ្ឍវិជ្ជាជីវៈ។

**ទីបួន**–ធានាថា គ្រប់ស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សាទាំងអស់ អភិវឌ្ឍប្រព័ន្ធធានាគុណភាព ដើម្បីបំពេញស្តង់ដាទទួលស្គាល់គុណភាពអប់រំ និងធានាបាននូវសមាហរណកម្មពេញលេញនៃគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដែលបានធានាបាននូវគុណភាព ចូលក្នុងប្រព័ន្ធឧត្តមសិក្សាតំបន់។

**ទីប្រាំ**–ធានាថា និស្សិត និងបុគ្គលិកសិក្សា ជាពិសេស និស្សិតថ្នាក់ក្រោយឧត្តមអាចចូលរួមបង្កើនការស្រាវជ្រាវ និងអភិវឌ្ឍវប្បធម៌ស្រាវជ្រាវនៅកម្ពុជា ដើម្បីឆ្លើយតបទៅតាមតម្រូវការនៃការអភិវឌ្ឍជាតិ។

**ទីប្រាំមួយ**–ធានាថា និស្សិតទាំងអស់ ដែលបានបញ្ចប់ការសិក្សាត្រូវមានចំណេះដឹង និងជំនាញ ដែលអាចឱ្យពួកគេចូលរួមយ៉ាងពេញលេញ ក្នុងការអភិវឌ្ឍប្រទេសជាតិក្នុងបរិបទនៃការប្រែប្រួលដ៏ឆាប់រហ័សនៃសង្គមជាតិ។

**ទីប្រាំពីរ**–ធានាថា គ្រប់កម្មវិធីសិក្សាត្រូវបានអភិវឌ្ឍ ដោយផ្សារភ្ជាប់គ្នានឹងការវិភាគពីតម្រូវការក្នុងការបណ្តុះបណ្តាល និងតម្រូវការជំនាញថ្នាក់ជាតិ។

**ទីប្រាំបី**–ធានាថា គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធសម្របសម្រួល និងសហការដើម្បីបង្កើនឱ្យបានជាអតិបរមា ដើម្បីជាគុណប្រយោជន៍នៃការអប់រំឧត្តមសិក្សា សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម សង្គម និងវប្បធម៌ ។

### ៣.២.១៧ គោលនយោបាយអប់រំក្រៅប្រព័ន្ធ (២០០២)

កម្មវិធី **អប់រំក្រៅប្រព័ន្ធ** (NFE) នៅកម្ពុជាត្រូវបានរៀបចំ និងអនុវត្តដោយ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការជួយឧបត្ថម្ភពីអង្គការជាតិ អង្គការអន្តរជាតិអង្គការក្រៅរដ្ឋាភិបាល និងតួអង្គផ្សេងៗទៀតជាច្រើន។ ស្ថាប័នរដ្ឋផ្សេងទៀតរួមមាន ៖ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នា ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា ក្រសួងអភិវឌ្ឍជនបទ ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម។ ដៃគូអង្គការក្រៅរដ្ឋាភិបាល និងក្រុមសហគមន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើពលរដ្ឋដែលជួបការលំបាក។

ការអប់រំក្រៅប្រព័ន្ធមានតួនាទីចម្បង ក្នុងការបង្កើតមូលដ្ឋានធនធានមនុស្សដែលចាំបាច់សម្រាប់ការសម្រេចបានគោលដៅជាតិពាក់ព័ន្ធនឹងសន្តិភាព ការកាត់បន្ថយភាព-ក្រីក្រជានិរន្តរ៍ និងសមភាពសង្គម ព្រមទាំងកំណើនសេដ្ឋកិច្ច។ គោលដៅអភិវឌ្ឍសហ-ស្សវត្សរ៍ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល រួមបញ្ចូលនូវការកាត់បន្ថយភាពក្រីក្រ ការពង្រឹងសេវាសុខភាព ការលើកកម្ពស់ការចូលរៀន និងសមភាពយេនឌ័រ។ កុមារ យុវជន និងមនុស្សពេញវ័យនឹងទទួលបានជំនាញចាំបាច់ ក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ និងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍជាតិជារួម ដើម្បីអភិវឌ្ឍគុណភាពជីវិតផ្ទាល់ខ្លួន ជាពិសេសក្នុងការអាន និងការសរសេរ ការគិតលេខ និងបំណិនជីវិតមូលដ្ឋាន។

**គោលនយោបាយអប់រំក្រៅប្រព័ន្ធ** ដាក់ចេញនូវយុទ្ធសាស្ត្រដូចតទៅ ៖

- បង្កើតកាលានុវត្តភាព ដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់អាចចូលរៀនបានពេញមួយជីវិត
- លើកកម្ពស់ការអាន និងសរសេរ និងបន្តការអប់រំដោយបង្កើតការតភ្ជាប់ ដែលផ្តល់នូវការងារធ្វើ និងជំនាញវិជ្ជាជីវៈ
- ការផ្តល់នូវព័ត៌មាន និងចំណេះដឹងទៀងទាត់ស្តីពីការបណ្តុះបណ្តាលជំនាញវិជ្ជា-ជីវៈ និងបច្ចេកទេស និងមុខវិជ្ជាវិទ្យាសាស្ត្រដល់មនុស្សគ្រប់រូប។

ក្រុមមនុស្សដែលជាគោលដៅគឺ ៖ (១) អ្នកដែលមិនអាចចូលរៀននៅសាលារដ្ឋ (ប្រព័ន្ធអប់រំផ្លូវការ) (២) ប្រជាពលរដ្ឋក្រីក្រ ងាយរងគ្រោះ (៣) កុមារ និងយុវជនធ្វើពលកម្ម និងនៅក្រៅសាលា (៤) កុមារ និងយុវជនជនជាតិដើមភាគតិច និង (៥) មនុស្ស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពេញវ័យចាប់ពីអាយុ១៥ ដល់៤៥ ឆ្នាំ។ ក្នុងចំណោមក្រុមគោលដៅនេះ រាជរដ្ឋាភិបាលផ្តោតសំខាន់ទៅលើកុមារី និងស្ត្រី។

ក្រសួង និងស្ថាប័ន ដែលជាសមាជិកនៃគណៈកម្មាធិការការអប់រំសម្រាប់ទាំងអស់គ្នា និងស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវតែចូលរួមក្នុងការគាំទ្រការអប់រំសម្រាប់ទាំងអស់គ្នា។ ប្រការនេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមក្រសួងផ្សេងៗទៀតដូចជា ៖ ក្រសួងមហាផ្ទៃ ក្រសួងធម្មការ និងសាសនា ក្រសួងព័ត៌មាន និងក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចផ្តល់កាលានុវត្តភាព ឱ្យសហគមន៍ដើម្បីចូលរួមក្នុងការបង្កើតថ្នាក់រៀនអក្ខរកម្ម ថ្នាក់រៀនក្រោយអក្ខរកម្ម ថ្នាក់រៀនបំពេញវិជ្ជា ថ្នាក់រៀនជំនាញវិជ្ជាជីវៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ បន្ទប់អាន និងបណ្ណាល័យជាដើម។ អ្នកគ្រប់គ្រងរោងចក្រ អាជីវករ និងក្រុមហ៊ុនត្រូវតែស្វែងរកមធ្យោបាយ ដើម្បីបើកថ្នាក់រៀនអក្ខរកម្ម ឬថ្នាក់រៀនជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិករបស់ពួកគេ។

គណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នា ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័ន និងក្រសួងមានសមត្ថកិច្ច ដោយផ្តោតលើទំនួលខុសត្រូវដូចខាងក្រោម ៖

- រៀបចំ និងអនុវត្តផែនការសកម្មភាព ដើម្បីសម្រេចបាននូវគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា និងពិនិត្យ និងវាយតម្លៃលទ្ធផលសម្រាប់ការអប់រំក្រៅប្រព័ន្ធព្រមទាំង ដាក់ជូនរបាយការណ៍ទាំងនោះដល់រាជរដ្ឋាភិបាលទៅតាមកាលកំណត់មួយ
- បង្កើតទំនាក់ទំនងរវាងការអប់រំក្រៅប្រព័ន្ធ និងកម្មវិធីអប់រំផ្លូវការនៅគ្រប់កម្រិតទាក់ទងនឹងការរៀបចំផែនការ ការទទួលស្គាល់គុណភាព ការបញ្ចូលឱ្យរៀនឡើងវិញ ដោយប្រើប្រាស់អគារសិក្សា បន្ទប់រៀន បុគ្គលិក និងធនធានដែលអាចប្រើរួមគ្នាបាន
- បង្កើនភាពជាដៃគូជាមួយរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ និងវិស័យឯកជន ដើម្បីលើកកម្ពស់ការសម្រេចបាននូវសមិទ្ធផលក្នុងការអាន និងសរសេរ និងការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈ ដែលជាការចូលរួមដើម្បីបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ពង្រឹងសមត្ថភាពនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ក្នុងការរៀបចំផែនការ ការគ្រប់គ្រង ការប្រមូលទិន្នន័យ និងការតាមដាន និងវាយតម្លៃ ដើម្បីធ្វើយ៉ាងណាឱ្យពួកគេ មានសមត្ថភាពក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សានៅគ្រប់កម្រិត
- បង្កើតលក្ខខណ្ឌសម្រាប់ផ្តល់នូវការសរសើរ និងរង្វាន់ដល់បុគ្គលម្នាក់ៗ អង្គភាព សហគមន៍ និងអង្គការដែលបានបង្កើតនូវសមិទ្ធផលក្នុងការស្រាវជ្រាវ និងគាំទ្រ ការអប់រំក្រៅប្រព័ន្ធ
- ពង្រឹងមជ្ឈមណ្ឌលគ្រប់គ្រងព័ត៌មាន ទិន្នន័យការអប់រំក្រៅប្រព័ន្ធ ដើម្បីឱ្យ ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព័ត៌មានទាំងនោះ និងជំរុញប្រព័ន្ធព័ត៌មាន គ្រប់គ្រងអប់រំដែលមានស្រាប់ ដើម្បីបញ្ចូលទិន្នន័យរបស់ការងារអប់រំក្រៅប្រព័ន្ធ ទៅក្នុងប្រព័ន្ធនោះ
- ផ្តល់នូវការគាំទ្រក្នុងការបញ្ចូលឡើងវិញនូវផែនការសកម្មភាពនៃការអប់រំក្រៅ ប្រព័ន្ធ ទៅក្នុងគ្រប់ផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមដល់ ការអភិវឌ្ឍធនធានមនុស្ស និងការកាត់បន្ថយភាពក្រីក្រ។

កម្មវិធីសិក្សាសម្រាប់ការអប់រំក្រៅប្រព័ន្ធ នឹងរួមបញ្ចូលនូវសមាសធាតុដូចខាង ក្រោម ៖

- អក្ខរកម្មវិជ្ជាជីវៈ
- ការអប់រំបន្ត រួមមាន ៖ (១) កម្មវិធីក្រោយអក្ខរកម្ម (២) កម្មវិធីសមមូល (៣) កម្មវិធី កែលម្អគុណភាពរស់នៅ ជាពិសេសអនាម័យទូទៅ ការទប់ស្កាត់ជំងឺអេដស៍ បញ្ហា យេនឌ័រ បញ្ហាវប្បធម៌ សន្តិភាព សីលធម៌ និងពលរដ្ឋវិជ្ជា (៤) កម្មវិធីបង្កើនប្រាក់ ចំណូល ដូចជាវិស័យកសិកម្ម សេវាកម្ម សិប្បកម្ម និងអាជីវកម្មខ្នាតតូច ការផ្តល់ ឥណទានផ្សេងៗជាដើម។
- ការអប់រំក្នុងគ្រួសារ ដើម្បីការអភិវឌ្ឍកុមារតូច
- កម្មវិធីចុះឈ្មោះចូលរៀនឡើងវិញ ដើម្បីបំប៉នសិស្សបោះបង់ការសិក្សានៅបឋម សិក្សា ហើយដែលពួកគេមានសមត្ថភាពត្រឡប់មកចូលរៀននៅសាលាចំណេះ ទូទៅវិញ
- កម្មវិធីសិក្សា សៀវភៅសិក្សា និងឯកសារសម្រាប់ការអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវ មានខ្លឹមសារសមស្រប ដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ និង

សង្គម និងមានរូបភាពត្រឹមត្រូវ ដែលនឹងផ្តល់ជាគុណប្រយោជន៍ល្អដល់អ្នកសិក្សា។ សកម្មភាពនៃការអប់រំក្រៅប្រព័ន្ធបែបនេះ នឹងត្រូវបានរៀបចំឱ្យបានសមស្របតាមលទ្ធភាពនៃអ្នករៀន ដូចជារៀបរយ ពាក់កណ្តាលរៀបរយ ក្រៅម៉ោងធ្វើការ ស្វ័យសិក្សា និងសិក្សាពីចម្ងាយជាដើម។

## ៣.៣. ផែនសកម្មភាពដើម្បីសម្រេចឱ្យបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ

### ៣.៣.១ បញ្ហាប្រឈមក្នុងវិស័យអប់រំ

បើទោះបីជាមានវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ក្តី សិស្សមានប្រហែលត្រឹមតែ៨០ % ប៉ុណ្ណោះ ដែលបានចូលរៀនបឋមសិក្សា ហើយដែលបានបញ្ចប់ការសិក្សានៅថ្នាក់ទី៦។ ការងារជាច្រើននៅតែចាំបាច់ត្រូវធ្វើតទៅទៀត ដើម្បីធានាថា រាល់សិស្សដែលគ្រប់អាយុចូលរៀននៅបឋមសិក្សានឹងបញ្ចប់ការសិក្សារបស់ពួកគេនៅកម្រិតបឋមសិក្សា បើទោះបីជាយើងមិនគិតពីចំណេះដឹង ដែលពួកគេត្រូវមាននៅកម្រិតនោះក្តី។ មានន័យថា កុមារមួយចំនួននៅកម្ពុជាមិនបានបញ្ចប់ការសិក្សានៅកម្រិតបឋមឡើយ ហើយពួកគេបានបង្ហាញវត្តមានក្នុងទីផ្សារការងារ ជាអ្នកធ្វើការដែលមិនចេះអក្សរ។

វិស័យអប់រំប្រឈមនឹងបញ្ហាធំៗមួយចំនួន ៖ (១) សិស្សចុះឈ្មោះចូលរៀនបឋមសិក្សាមានអាយុលើស (២) អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានចំនួន ៨០% អត្រាត្រួតថ្នាក់ និងបោះបង់មានកម្រិតខ្ពស់នៅបឋមសិក្សា (៣) ថ្លៃចំណាយលើការអប់រំទាំងផ្ទាល់ និងប្រយោលមានកម្រិតខ្ពស់ និង (៤) ការលំបាកក្នុងការអនុវត្តវិមជ្ឈការនៃការគ្រប់គ្រងអប់រំ។

**ទីមួយ**–កុមារមានអាយុលើស៦ ឆ្នាំចុះឈ្មោះចូលរៀនថ្នាក់ទី១ នៅបឋមសិក្សាមាននៅគ្រប់ទីកន្លែង។ និន្នាការនៃអត្រាចូលរៀនពិតប្រាកដ និងសរុបបានបង្ហាញថា ចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃការចូលរៀនរបស់សិស្សថ្មីចន្លោះឆ្នាំ១៩៩៩ និង២០០៤ កើនឡើងរវាងកុមារអាយុច្រើនជាង៦ឆ្នាំ។ ក្រុមកុមារដែលងាយប្រឈម គឺមានអាយុច្រើនជាងអាយុ ៦ ឆ្នាំ។ ភាគច្រើននៃកុមារដែលចុះឈ្មោះចូលរៀនដំបូងមានអាយុ ៧ ឆ្នាំ ហើយកុមារស្ទើរជិតពាក់កណ្តាល ដែលបានចូលរៀន មានអាយុចាស់ជាងអាយុកំណត់ យ៉ាងហោចណាស់ ២ ឆ្នាំ។ តាំងពីឆ្នាំ ២០០១ មក អាយុចូលរៀននៅថ្នាក់ទី១ ជាមធ្យមនៅថេរ គឺមានអាយុចន្លោះពី៧ ទៅ៨ ឆ្នាំ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ទីពីរ**–គម្លាតយេនឌ័រ ក្នុងឱកាសទទួលការអប់រំ គឺជាប្រភពនៃការព្រួយបារម្ភនៅគ្រប់កម្រិតនៃការអប់រំ។ កម្ពុជាសម្រេចបានវឌ្ឍនភាព គួរឱ្យកត់សម្គាល់ ក្នុងការកាត់បន្ថយគម្លាតយេនឌ័រ ជាពិសេសនៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ។ បើទោះជាយ៉ាងនេះក្តី និន្នាការនេះបានបង្ហាញថា គម្លាតយេនឌ័រក្នុងការចុះឈ្មោះចូលរៀនបានកើនឡើង ជាបន្តបន្ទាប់ពីថ្នាក់មួយ ទៅថ្នាក់មួយទៀត ជាពិសេសនៅមធ្យមសិក្សាទុតិយភូមិ។ កត្តានេះធ្វើឱ្យចំនួនសិស្សស្រី ដែលបានបញ្ចប់វិទ្យាល័យថយចុះ ដែលធ្វើឱ្យចំនួននៅកម្រិតបរិញ្ញាបត្រ ចំនួននិស្សិតស្រីដែលរៀននៅគ្រឹះស្ថានឧត្តមសិក្សាមានត្រឹម ៤០% បើប្រៀបធៀបនឹងនិស្សិតប្រុសចំនួន ៦០%។ ដូច្នេះ ស្ត្រីមានឱកាសរកការងារធ្វើក្នុងជំនាញវិជ្ជាជីវៈ និងរដ្ឋបាលតិចជាងបុរស។ វិសមភាពយេនឌ័រនេះបានចាក់ឫសតាំងពីយូរលង់ណាស់មកហើយ។ ស្ថានភាពនេះបណ្តាលមកពីកត្តាតម្លៃក្នុងការសិក្សា កង្វះហេដ្ឋារចនាសម្ព័ន្ធ ការចូលរៀនលើសអាយុ និង អត្រាបោះបង់ និងត្រួតថ្នាក់ខ្ពស់។

**ទីបី**–បញ្ហាចម្បងផ្សេងមួយទៀតគឺ អត្រានៃការបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាមានចំនួនត្រឹម ៨០%។ បញ្ហានេះ គឺមានលក្ខណៈធ្ងន់ធ្ងរ ក្នុងចំណោមកុមារក្រីក្រ ហើយកម្ពុជាប្រឈមភាពលំបាកជាច្រើន ក្នុងការរក្សាកុមារទាំងនោះនៅក្នុងសាលារៀននៅកម្រិតបឋមសិក្សាថ្នាក់ដំបូង។ ជារួម កុមារប្រហែល ៨០% ដែលបានចាប់ផ្តើមចូលរៀនក្នុងសាលា បានបញ្ចប់ថ្នាក់បឋមសិក្សា និង ត្រឹមតែ ៤០% បានបញ្ចប់ការអប់រំជាមូលដ្ឋាន។ ការកើនឡើងភាគច្រើននៃការចុះឈ្មោះចូលរៀនដុលនៅបឋមសិក្សា ដោយសារតែមានការកើនឡើងសមាមាត្រនៃកុមារដែលលើសអាយុចូលរៀន គឺមិនមែនដោយសារកុមារ ដែលមានអាយុត្រឹមត្រូវចូលរៀននៅបឋមសិក្សានោះទេ។ អត្រាត្រួតថ្នាក់ និងបោះបង់នៅបឋមសិក្សាក៏មានកម្រិតខ្ពស់ បើទោះបីកម្ពុជាធ្លាប់ជួបបទពិសោធនូវនិន្នាការធ្លាក់ចុះក្នុងបញ្ហាទាំងនោះក៏ដោយចុះ។ នៅចន្លោះឆ្នាំ១៩៩៧ និង២០០៦ អត្រាត្រួតថ្នាក់នៅបឋមសិក្សាធ្លាក់ចុះពី ២៦,៣% ទៅដល់ ១១%។ កុមារីស្ថិតក្នុងហានិភ័យខ្លាំងជាងកុមារា ចំពោះបញ្ហានេះ។ ហើយកុមារនៅតំបន់ដាច់ស្រយាល និងជនបទ ដែលអាចនឹងបោះបង់ការសិក្សាមានអត្រាលើសកុមារនៅទីប្រជុំជន ជាងពីរដង។ ការបោះបង់ការសិក្សារបស់សិស្សនៅឆ្នាំចុងក្រោយនៃបឋមសិក្សា នៅមានកម្រិតខ្ពស់នៅឡើយ ហើយគឺមានតែសិស្សដែលមានគ្រួសារធូរធារនោះទេ ដែលមិនបោះបង់ (MoEYS ២០០៧)។ កត្តាសំខាន់មួយទៀត ដែលធ្វើឱ្យអត្រាបោះបង់ការសិក្សាមាន កម្រិតខ្ពស់ គឺចំនួនសាលារៀនមិនដែលមានគ្រប់កម្រិតនៅបឋមសិក្សានៅមានចំនួនច្រើននៅឡើយ ដែលសាលាទាំងនោះមិនអាចផ្តល់នូវវគ្គសិក្សាពីកម្រិតថ្នាក់ពីទី១ ដល់ទី៦ បាន។

**ទីបួន**–ឧបសគ្គនានាក្នុងការទទួលបានការអប់រំ ក៏មានរួមបញ្ចូលកត្តាផ្សេងៗទៀត ដូចជា ចំណាយផ្ទាល់ និងចំណាយមិនផ្ទាល់ខ្ពស់ក្នុងការសិក្សា ។ ទោះបីការអនុវត្ត **កម្មវិធីសកម្មភាពជាអាទិភាព** (PAP) នៅឆ្នាំ២០០០ ហើយ **ថវិកាដំណើរការសាលារៀន** (SOB) បានជួយកាត់បន្ថយចំណាយផ្ទាល់របស់គ្រួសារបានមួយកម្រិតក៏ដោយ ក៏ចំណាយផ្សេងទៀតនៅតែខ្ពស់ដដែល។ ការដាក់ឱ្យអនុវត្តថវិកាដំណើរការសាលារៀន បានផ្តល់ប្រភពធនធានដ៏សំខាន់ដល់សាលារៀន ដើម្បីយកទៅជំនួសប្រាក់បង់ថ្លៃចុះឈ្មោះចូលរៀន សម្ភារសិក្សា និងការបង់លុយនៅពេលប្រឡង ជាពិសេសនៅបឋមសិក្សា ។ ទោះជាយ៉ាងនេះក្តី ចំណាយទាំងនេះ គឺជាកម្រិតតិចតួច បើប្រៀបធៀបទៅនឹងចំណាយផ្សេងៗរបស់គ្រួសារ រួមមានដូចជា ឯកសណ្ឋានសិស្ស ប្រាក់ហោប៉ៅ មធ្យោបាយធ្វើដំណើរ និងការរៀនគួរក្រៅម៉ោងសិក្សា។

**ទីប្រាំ**–ចន្លោះពីឆ្នាំ១៩៩៨ ដល់១៩៩៩ និងពីឆ្នាំ២០០៥ ដល់២០០៦ ផលធៀបគ្រូសិស្សបឋមសិក្សាជាមធ្យម នៅកម្រិតថ្នាក់ជាតិ មានការឡើងចុះចន្លោះពី ៩៨,១ ទៅ ៥០,៨ បើទោះជាចំនួនថ្នាក់រៀនជារួមមានចំនួនកើនឡើង ។ ម្យ៉ាងវិញទៀត ចំនួនគ្រូបង្រៀន និងនាយកសាលា មិនត្រូវបានពង្រាយប្រកបដោយសមធម៌នោះទេ នៅទូទាំងប្រទេសកម្ពុជា។ បញ្ហានេះបណ្តាលមកពីប្រាក់បៀវត្សនៅមានកម្រិត និងប្រាក់ឧបត្ថម្ភមួយលើកដើម្បីទៅបម្រើការងារនៅស្រុកដាច់ស្រយាល មានចំនួនតិចតួច ដែលមិនអាចលើកទឹកចិត្តគ្រប់គ្រាន់ ឬទាក់ទាញបុគ្គលិកអប់រំ ឱ្យទៅបម្រើការងារនៅតំបន់ជនបទ និងដាច់ស្រយាល ។

បញ្ហាប្រឈមទាំងនេះនៅក្នុងវិស័យអប់រំ គឺជាមូលហេតុធ្វើឱ្យលទ្ធផលសិក្សានៅទាប ដែលបង្ហាញចេញនៅក្នុងរង្វាយតម្លៃសិក្សា។ លទ្ធភាពទទួលបានសេវាសិក្សារៀនសូត្រនៅសាលាប្រកបដោយសមធម៌ ត្រូវបានពង្រឹងសម្រាប់កុមារកម្ពុជាដោយពុំគិតពីកត្តាយេនឌ័រ ពូជសាសន៍ ជំនឿ សាសនា កុលសម្ពន្ធ ឬក៏ស្ថានភាពសេដ្ឋកិច្ច សង្គមនោះទេ ។ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងផ្តល់អន្តេវាសិកដ្ឋានដល់និស្សិតស្រី ដើម្បីលើកកម្ពស់យេនឌ័រក្នុងវិស័យអប់រំ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.៣.២ ផែនការសកម្មភាពឆ្លើយតបនឹងវិស័យអប់រំ

ក្នុងក្របខណ្ឌយុទ្ធសាស្ត្រដើម្បីពង្រីកសម្ភារបរិក្ខារអប់រំនៅបឋមសិក្សា សកម្មភាពមួយចំនួនដូចខាងក្រោមត្រូវបានដាក់ចេញ ៖

#### *៣.៣.២.១ បង្កើនលទ្ធភាពចូលរៀន និងពង្រឹងគុណភាពអប់រំបឋមសិក្សា*

វត្ថុបំណងនៃយុទ្ធសាស្ត្រនេះ គឺសំដៅលើកកម្ពស់គោលដៅនៃលទ្ធផលអប់រំមូលដ្ឋានជាសកល ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ តាមរយៈការសាងសង់ថ្នាក់រៀនថ្មីៗបន្ថែមទៀតនៅបឋមសិក្សា និងការផ្តល់ការលើកទឹកចិត្តដល់ភាគីខាងតម្រូវការ តាមរយៈការលើកកម្ពស់គំនិតផ្តួចផ្តើមនៃសាលាកុមារមេត្រី ដើម្បីពង្រឹងនូវគុណភាពអប់រំ និងសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀន ។ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងសាងសង់អាគារសិក្សាបន្ថែម ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ និងដើម្បីធានាបាននូវសមធម៌ក្នុងការផ្តល់សេវាអប់រំនានា ។

#### *៣.៣.២.២ ការផ្តល់សម្ភារឧបទេស*

ក្រសួងអប់រំមានផែនការបង្កើតបណ្ណាល័យ ដោយបំពាក់នូវសម្ភារសិក្សាបន្ថែមគ្រប់គ្រាន់ និងផ្តល់សៀវភៅសមស្របតាមអាយុ(ដូចជាសៀវភៅរឿងនិទានរូបភាព) និងសម្ភារឧបទេស(ដូចជាល្បែងអប់រំ និងផែនទីជាដើម) ដល់សាលាបឋមសិក្សានានា។ ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបណ្ណាល័យ ត្រូវរៀបចំឡើងសម្រាប់នាយកសាលា និងបណ្ណារក្ស រួមគ្នាជាមួយនឹងមន្ត្រីមកពីការិយាល័យ និងមន្ទីរអប់រំ យុវជន និងកីឡា។

#### *៣.៣.២.៣ អាហារូបករណ៍*

ការផ្តល់អាហារូបករណ៍នឹងមានឥទ្ធិពលខ្លាំង លើសូចនាករនៃការបញ្ចប់ការសិក្សានៅបឋមសិក្សា ការបោះបង់ការសិក្សា ការត្រួតថ្នាក់ និងគម្លាតខុសប្លែកគ្នាតាមតំបន់ជាដើម ។ លើសពីនោះ កំណើននៃចំណាយមានទំនាក់ទំនង នឹងលទ្ធភាពនៃការចូលរៀននៅសាលារបស់កុមារក្រីក្រ នៅតំបន់ជនបទក្នុងកម្រិតមួយខ្ពស់ ហើយប្រការនេះក៏មិនរំពឹងថានឹងមានការធ្លាក់ចុះនោះដែរ ប្រសិនបើជីវភាពរបស់ប្រជាជននៅតាមតំបន់ជនបទនៅតែទាប។

ក្រសួងនឹងបន្តអនុវត្តកម្មវិធីអាហារូបករណ៍ដែលបានកំណត់(ក្រុមគោលដៅក្រីក្រងាយរងគ្រោះ ពិការ ក្រុមជនជាតិភាគតិច កុមារី និងតំបន់ដាច់ស្រយាលជាដើម។ល។)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទន្ទឹមនឹងនោះ ពង្រឹងការគ្រប់គ្រងកម្មវិធីអាហារូបករណ៍ (តម្លាភាព ការបើកថវិកាឧបត្ថម្ភទាន់ពេលវេលា ការពិនិត្យតាមដាន សវនកម្ម។ល។)។

អាហារូបករណ៍មានតួនាទីដ៏សំខាន់ និងជាមាត្រដ្ឋានគាំពារសង្គមដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយគម្លាតខុសប្លែកគ្នាក្នុងសង្គម និងតាមតំបន់។

សកម្មភាពគោលនយោបាយនានា គឺដើម្បីបង្កើតនូវគោលនយោបាយអាហារូបករណ៍ដាច់ដោយឡែកមួយ សម្រាប់សិស្សមកពីគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ នៅកម្រិតបឋមសិក្សា (រួមមានក្រុមកុមារពិការ និងកុមារមកពីក្រុមជនជាតិភាគតិច) រួមបញ្ចូលអាហារូបករណ៍ សម្រាប់សិស្សថ្នាក់ទី៤ ដល់ទី៦ នៅតាមតំបន់ព្រំដែនក្នុងខេត្តចំនួន១៥។

លទ្ធផលការសិក្សាស្តីពីអត្រាចំណេញពីឧបករណ៍គាំពារសង្គមនៅកម្ពុជា[197] ឆ្នាំ២០១២ បង្ហាញថា ការទទួលបានការអប់រំមួយឆ្នាំបន្ថែមទៀតសម្រាប់សិស្ស អាចឱ្យពួកគេទទួលបានប្រាក់បៀវត្សខ្ពស់ជាងចំនួន ៤,១% នៅថ្នាក់ជាតិ និងធ្វើឱ្យចំណាយរបស់គ្រួសារកើនឡើងចំនួន ១,៨% សម្រាប់ក្រុមគ្រួសារក្រីក្រនៅជនបទ។ ម្យ៉ាងវិញទៀត ការចំណាយនឹងកើនឡើងខ្លាំង ចំពោះគ្រួសារក្រីក្រនៅតំបន់ជនបទ ដែលមានកូនទៅសាលារៀន ហើយប្រការនេះក៏មិនរំពឹងថានឹងមានការធ្លាក់ចុះនោះដែរ ប្រសិនបើជីវភាពរបស់ប្រជាជននៅតាមតំបន់ជនបទនៅតែទាប។

ក្រសួងអប់រំបានអនុវត្តកម្មវិធីអាហារូបករណ៍ សម្រាប់សិស្សក្រីក្រ និងងាយរងគ្រោះនៅកម្រិតបឋមសិក្សា ដោយប្រើប្រាស់ថវិកាជាតិចាប់តាំងពីឆ្នាំ២០០៣ (អនុក្រឹត្យលេខ៦៦) ។ អាហារូបករណ៍ត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍនានានៅបឋមសិក្សា ប៉ុន្តែរាជរដ្ឋាភិបាលចាំបាច់ ត្រូវធ្វើសុខដុមនីយកម្មនៃកម្មវិធីអាហារូបករណ៍ដោយឡែកៗពីគ្នាទាំងនេះ ព្រមទាំងបង្ហាញពីការប្តេជ្ញាចិត្ត ដើម្បីបង្កើនលទ្ធភាពទទួលបានអាហារូបករណ៍ប្រកបដោយសមធមិនៅបឋមសិក្សា ដោយពង្រីកកម្មវិធីអាហារូបករណ៍ពីអនុវិទ្យាល័យទៅដល់បឋមសិក្សា។ ការផ្តល់នូវធនធានបន្ថែមសម្រាប់អាហារូបករណ៍ គឺជាអនុសាសន៍សំខាន់មួយក្នុងចំណោមអនុសាសន៍ទាំង៥ នៅក្នុងវិស័យអប់រំ ក្នុងកម្មវិធីរបស់ធនាគារពិភពលោកនៅឆ្នាំ២០១១[198]។

អាហារូបករណ៍សរុបចំនួន ២១ ៨៧០ ត្រូវបានផ្តល់ឱ្យសិស្សរៀននៅថ្នាក់ទី៤ ទី៥ និងទី៦ នៅតាមបណ្តាខេត្តគោលដៅចំនួន៣ (ខេត្តមណ្ឌលគិរី រតនគិរី និងព្រះវិហារ) ទៅ

[197] Rates of Return on Social Protection Instrument in Cambodia.
[198] World Bank Integrated Fiduciary Assessment and Public Expenditure Review.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមប្រភេទផលិតទានអាហារូបករណ៍។ ការស្ទង់មតិមួយបានរកឃើញថា កម្មវិធីអាហារូប-ករណ៍ នៅសាលាបឋមសិក្សាមានប្រសិទ្ធភាព ក្នុងការបង្កើនការចូលរៀននៅសាលារៀន និងការសម្រេចជោគជ័យក្នុងការសិក្សា។ ការវាយតម្លៃផលប៉ះពាល់ បានបញ្ជាក់ថាវិធី-សាស្ត្រដែលត្រូវបានប្រើសម្រាប់ជ្រើសរើសបេក្ខជនទទួលអាហារូបករណ៍ គឺមានភាពយុត្តិធម៌ និងបានដល់ក្រុមទទួលផលដែលចង់បាន។ លទ្ធផលរកឃើញទាំងពីរនេះ បានផ្តល់នូវមូលដ្ឋានយ៉ាងរឹងមាំដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពិចារណាបង្កើតនូវគោលនយោបាយមួយស្តីពីអាហារូបករណ៍បឋមសិក្សា ក៏ដូចជាសេចក្តីព្រាងគោលនយោបាយស្តីពីអាហារូបករណ៍មធ្យមសិក្សាបឋមភូមិ ដែលនឹងក្លាយទៅជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយស្តីពីអាហារូបករណ៍ថ្នាក់ជាតិមួយក្នុងពេលអនាគត។

ជាបន្តទៀត អង្គការភាពជាដៃគូសកលសម្រាប់ការអប់រំ(GPE) អាចបានផ្តល់នូវមូលនិធិ ដើម្បីចាប់ផ្តើមដំណើរការកម្មវិធីនៅឆ្នាំ២០១៤ ហើយក្រសួងអប់រំ យុវជន និងកីឡា ទទួលប្រតិបត្តិការបន្តចាប់ពីឆ្នាំ២០១៥ បន្ទាប់ពីមានការសម្រេចយល់ព្រមលើអនុ-ក្រឹត្យ៦៦ ដែលត្រូវបានកែសម្រួលឡើងវិញ។ ការកំណត់ផ្តល់ថវិកាឧបត្ថម្ភក្នុងកម្រិតច្រើនគួរសមមួយសម្រាប់សូចនាករនេះ ត្រូវបានឃើញថាជារង្វាន់លើកទឹកចិត្តមួយសម្រាប់រដ្ឋាភិបាល ដើម្បីផ្គត់ផ្គង់ហិរញ្ញវត្ថុដល់កម្មវិធី រួមជាមួយធនធានផ្ទាល់របស់កម្មវិធីចាប់ពីឆ្នាំ ២០១៥។

ក្រសួងបានអនុវត្តកម្មវិធីអាហារូបករណ៍មួយសម្រាប់សិស្សក្រីក្រ និងងាយរងគ្រោះនៅកម្រិតសិក្សាទាប ដោយប្រើប្រាស់ថវិការបស់រដ្ឋាភិបាលចាប់តាំងពីឆ្នាំ២០០៣ (អនុក្រឹត្យលេខ៦៦)។ សាលាសរុបចំនួន៨០៩ ទទួលបានមូលនិធិអាហារូបករណ៍សម្រាប់ថ្នាក់ទី៧ ដោយចំនួនអាហារូបករណ៍ថ្មី បានកើនឡើងចំនួន ៥ ០០០ ចន្លោះពីឆ្នាំ ២០១២ និង២០១៣ (ដែលតំណាងឱ្យសាលាចំនួន២៨៣ បន្ថែមទៀត ជាផ្នែកមួយនៃកម្មវិធី)។ សរុបរួម សិស្សចំនួន ២៧០ នាក់ នៅថ្នាក់ទី៧ និងចំនួន ១៥ ៤០១ នាក់ នៅថ្នាក់ទី៨ និង ១៣ ១៦៨ នាក់ នៅថ្នាក់ទី៩ ទទួលបានអាហារូបករណ៍។ ក្នុងចំណោមសិស្សទទួលបានអាហារូបករណ៍ទាំងអស់ មានសិស្សស្រីចំនួន ៩ ២២០ នាក់ រៀននៅថ្នាក់ទី៨ (៦០%) កំពុងទទួលបានអាហារូបករណ៍ និង ៧ ៨៣០ នាក់ រៀននៅថ្នាក់ទី១០ (៦០%) កំពុងទទួលបានអាហារូបករណ៍ ។

សិស្សត្រូវបានជ្រើសរើស ដើម្បីទទួលបានប្រាក់ឧបត្ថម្ភចំនួន៥៥ដុល្លារក្នុងមួយឆ្នាំ។ ការផ្តល់នេះបានទទួលប្រសិទ្ធភាពនៅឆ្នាំ២០០៣ ជាមួយនឹងការកើនឡើងពីចំណុច



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អតិផរណា ៥,៣% ក្នុងរយៈពេល១០ឆ្នាំមុន ដែលប្រាក់ឧបត្ថម្ភមានត្រឹមតែ២៦ដុល្លារ និង ខុសពីការចំណាយជាមធ្យម១៧១ដុល្លារ សម្រាប់កុមារមួយរូបក្នុងកម្រិតអនុវិទ្យាល័យ នេះបើយោងតាមការស្ទង់មតិផ្នែកសេដ្ឋកិច្ចសង្គមនៅឆ្នាំ២០១១។ ជាក់ស្តែង ប្រការនេះ កំណត់ប្រសិទ្ធភាពអន្តរាគមន៍ ដើម្បីកាត់បន្ថយការបោះបង់ការសិក្សាជាពិសេសនៅតាម តំបន់ (រោងចក្រកាត់ដេរ ឬនៅចម្ការកៅស៊ូ ជាដើម) ដែលចំណាយលើវិស័យអប់រំមាន កម្រិតខ្ពស់។ យ៉ាងណាមិញ ការវាយតម្លៃផលប៉ះពាល់នៃអាហារូបករណ៍ ដែលផ្តល់ទឹក-ប្រាក់ពី៤៥ ទៅ៦០ដុល្លារ សម្រាប់សិស្សានុសិស្សនៅមធ្យមសិក្សាបឋមភូមិ ក្រោមគំនិត ផ្តួចផ្តើមដំណាប់រហ័ស(FTI) បានបង្ហាញពីផលប៉ះពាល់យ៉ាងសំខាន់លើការចុះឈ្មោះចូល រៀន និងវត្តមានប្រហែល២០% នៃកុមារដែលបានចុះឈ្មោះចូលរៀន។

ក្រសួងអប់រំ យុវជន និងកីឡាបានដំឡើងទឹកប្រាក់អាហារូបករណ៍ ពី៤៥ដុល្លារ ទៅ៩០ដុល្លារក្នុងមួយឆ្នាំ ដែលស្មើនឹងទឹកប្រាក់ ដែលបានផ្តល់ដោយធនាគារពិភពលោក សម្រាប់អាហារូបករណ៍នៅមធ្យមសិក្សាទុតិយភូមិ។

### *៣.៣.២.៤ គោលនយោបាយគ្រូបង្រៀន*

ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានបំផ្លាញទាំងស្រុងក្នុងអំឡុងរបបប្រល័យ ពូជសាសន៍ខ្មែរក្រហម និងសង្គ្រាមស៊ីវិល។ អំឡុងពេលនោះ បុគ្គលិកសិក្សាចំនួន ៨០% បានបាត់បង់ជីវិត។ ដោយបញ្ហាខ្វះគ្រូបង្រៀន នាប៉ុន្មានទសវត្សរ៍កន្លងមក ក្រសួងបាន កំណត់គុណវុឌ្ឍិសម្រាប់គ្រូបង្រៀនដូចជា (១) សម្រាប់គ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សា និង បឋមសិក្សា ត្រូវរៀនចប់ថ្នាក់ទី១២ ហើយត្រូវចូលរៀននៅក្នុងសាលាគរុកោសល្យខេត្ត ចំនួន ២ ឆ្នាំថែមទៀត (ចំពោះខេត្តដាច់ស្រយាល និងខេត្តជួបការលំបាក យើងប្រើរូបមន្ត ៩+២) (២) សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ត្រូវមានគុណវុឌ្ឍិត្រឹមសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិ (ថ្នាក់ទី១២) និងត្រូវចូលរៀននៅសាលាគរុកោសល្យភូមិភាគចំនួន ២ ឆ្នាំ (១២+២) និង (៣) សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ត្រូវមានគុណវុឌ្ឍិត្រឹមបរិញ្ញាបត្រ និងការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំចំនួន១ឆ្នាំ។

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានបែងចែកជា៤ គឺ (១) មជ្ឈមណ្ឌល បណ្តុះបណ្តាលគ្រូមត្តេយ្យមជ្ឈិមនៅរាជធានីភ្នំពេញ ដែលជាកន្លែងបណ្តុះបណ្តាលគ្រូ មត្តេយ្យ (២) សាលាគរុកោសល្យខេត្ត រាជធានី ចំនួន១៨ ដែលបណ្តុះបណ្តាលគ្រូបឋម សិក្សា (៣) សាលាគរុកោសល្យភូមិភាគចំនួន៦ ដែលបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋម ភូមិ និង (៤) វិទ្យាស្ថានជាតិអប់រំ ដែលបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ។ ជាទូទៅ

គេទទួលស្គាល់ថា ការបណ្តុះបណ្តាលគរុកោសល្យផ្តោតខ្លាំងតែលើចំណេះដឹង ជាជាងជំនាញគរុកោសល្យ និងវិធីសាស្ត្របង្រៀន។

មានការបែងចែកការបណ្តុះបណ្តាលក្នុងពេលកំពុងបម្រើការងារ ចែកចេញជា ៣ ប្រភេទគឺ ការបណ្តុះបណ្តាលអាជីព (ការប្រជុំបច្ចេកទេស ថ្នាក់និទស្សន៍ដែលរៀបចំឡើងនៅសាលារៀន) សិក្ខាសាលារៀបចំឡើងដោយមន្ទីរអប់រំ និងសិក្ខាសាលាដែលរៀបចំដោយក្រសួង។ នៅឆ្នាំ២០១២ និង២០១៣ មានបុគ្គលិកបង្រៀនចំនួន ៨៧ ២០៣នាក់។ ក្នុងចំណោមនោះគ្រូមូលដ្ឋានមានចំនួន ៦៦,២% មានគុណវុឌ្ឍិ ១២+២ និង គ្រូបឋមមានចំនួន ៩៧,៨% មានត្រឹមថ្នាក់ទី៩ បូក២។ មធ្យមភាគថ្នាក់ជាតិបានបង្ហាញពីវិសមភាពយ៉ាងខ្លាំង ដែលនៅខេត្តកែប មានគ្រូ ១២ + ២ រហូតដល់៩២,២% បើប្រៀបធៀបនឹងខេត្តមណ្ឌលគិរី ដែលមានគ្រូប្រភេទនេះត្រឹមតែ ៤៤,១% ប៉ុណ្ណោះ។ បុគ្គលិកបង្រៀនមានត្រឹមតែ០,៨%ប៉ុណ្ណោះ ដែលមិនបានទទួលការបណ្តុះបណ្តាលផ្នែកគរុកោសល្យរយៈពេល ២ ឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហាកង្វះគ្រូបង្រៀន ក្រសួងបានផ្តួចផ្តើមប្រើប្រាស់គ្រូជាប់កិច្ចសន្យា (១ ៨៥២នាក់ នៅឆ្នាំ២០១២) ជាពិសេសនៅតំបន់ដាច់ស្រយាល ហើយគ្រូកិច្ចសន្យាមួយចំនួនមានគុណវុឌ្ឍិទាបខ្លាំង (ក្រោមថ្នាក់ទី៦ និងគ្មានការបណ្តុះបណ្តាលគរុកោសល្យ)។ ក្រសួងមានបំណងកាត់បន្ថយចំនួនគ្រូកិច្ចសន្យាបន្តិចម្តងៗ។

### *៣.៣.២.៥ ការលុបបំបាត់វិសមភាពយេនឌ័រ*

ប្រទេសកម្ពុជាបានលុបបំបាត់វិសមភាពយេនឌ័រស្ទើរតែទាំងស្រុងក្នុងវិស័យអប់រំ។ ក្នុងឆ្នាំ២០០១ អត្រាពិតនៃការសិក្សាសម្រាប់កុមារីនៅបឋមសិក្សាមាន ៨៤% ចំណែកនៅឆ្នាំ២០១១ និង២០១២ មានរហូតដល់ ៩៦,១% និងក្រោម ៩៦,៤% សម្រាប់ទាំងពីរភេទ។ បន្ថែមពីនេះទៀត ការវិភាគមួយដែលធ្វើឡើងនៅឆ្នាំ២០១១បានបង្ហាញថា មានវិសមភាពតិចតួចបំផុតនៅពេលបច្ចុប្បន្ន និងបានធ្វើចំណោលលើចំនួនសិស្សប្រុស និងសិស្សស្រីដែលបានបញ្ចប់ការសិក្សានៅកម្រិតមូលដ្ឋាន និងគ្រប់អនុវិស័យនៅកម្រិតមូលដ្ឋាន។ នៅមធ្យមសិក្សាទុតិយភូមិ ត្រូវបានធ្វើចំណោលថានឹងទទួលបាននូវសមភាពយេនឌ័រនៅឆ្នាំ២០១២ និង២០១៣។ លទ្ធផលថ្នាក់ជាតិទាំងនេះនឹងក្លាយជាចំណុចប្រែប្រួលដ៏សំខាន់នៅថ្នាក់ខេត្ត។

### *៣.៣.២.៦ ការជានាសមធម៌នៃការទទួលសេវាអប់រំ*

នៅថ្នាក់ជាតិ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាបានកើនឡើងយ៉ាងខ្លាំង (៨៧,៣% នៅឆ្នាំ២០១២ និង២០១៣ និង៨៧,៨% សម្រាប់កុមារី) ប៉ុន្តែវាមិនបានបង្ហាញពី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការពិតពីកុមារដែលមានអាយុលើសជាច្រើននៅថ្នាក់ទី៦ (នៅបឋមសិក្សា មានកុមារអាយុលើសចំនួន២០%) ក៏ដូចជាការបង្ហាញពីវិសមភាពនៅកម្រិតតំបន់ផងដែរ។

យុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាប្រឈមទាំងនេះរួមមាន ៖ ធានាការចូលរៀនរបស់កុមារអាយុត្រឹម៦ឆ្នាំ នៅបឋមសិក្សា ក៏ដូចជាសម្រាប់កុមារបាត់បង់ឱកាសដូចជាកុមារពិការ និងកុមារជនជាតិភាគតិចជាដើម ព្រមទាំងកាត់បន្ថយឧបសគ្គនៃការចំណាយគ្រប់រូបភាពរបស់អាណាព្យាបាល។

ដូច្នេះ សូចនាករនេះបានក្លាយជាតម្រូវការក្នុងការធ្វើអន្តរាគមន៍ដ៏ជាក់លាក់ ដើម្បីធ្វើឱ្យកើនឡើងនូវការចូលរៀន និងកាត់បន្ថយការបោះបង់ការសិក្សា សម្រាប់កុមារដែលបាត់បង់ឱកាស(កុមារក្រីក្រ កុមារជនជាតិភាគតិច កុមារពិការជាដើម)។ កត្តានេះពិតជាមានសារសំខាន់សម្រាប់ថ្នាក់ស្រុក ក្នុងការប្រើប្រាស់សូចនាករខាងលើ។

ភាពប្រាកដនៃសូចនាករនេះ បានផ្តល់ជាការគាំទ្របន្ថែមសម្រាប់កម្មវិធីសាលាកុមារមេត្រី(សាលាចំនួន ៤ ៥០៥ នៅឆ្នាំ២០១១ និង២០១២ ដែលស្មើនឹង ៦៥,៨%នៃសាលាបឋមសិក្សាទាំងអស់) ដែលបានដើរតួនាទីដ៏សំខាន់ ក្នុងកំណើនការចុះឈ្មោះចូលរៀន ការបង្ការទប់ស្កាត់ការបោះបង់ការសិក្សា និងការធានាការបញ្ចប់ការសិក្សា។ កម្មវិធីសាលាកុមារមេត្រីត្រូវបានគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ជាច្រើន។ គួរកត់សម្គាល់ផងដែរថា ជាមួយនឹងប្រសិទ្ធផលដ៏ប្រសើរនៃប្រព័ន្ធ ចំនួននៃកុមារលើសអាយុចូលរៀនត្រូវបានកាត់បន្ថយ។

ជាសរុបមក ក្រសួងអប់រំ យុវជន និងកីឡានឹងចាត់វិធានការដូចតទៅ ៖ (១) ធ្វើអន្តរាគមន៍ក្នុងការធ្វើឱ្យកើនឡើងនូវការចុះឈ្មោះចូលរៀន និងការកាត់បន្ថយការបោះបង់ជាពិសេសសម្រាប់កុមារបាត់បង់ឱកាស (២) បែងចែកគោលដៅនៃអន្តរាគមន៍នៅថ្នាក់ស្រុក ជាមួយនឹងការផ្តល់ជំនួយជាក់លាក់ក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋាន (៣) កាត់បន្ថយចំនួនសាលាមិនគ្រប់កម្រិត និងធ្វើការពង្រាយគ្រូបន្ថែមទៀត ទៅតំបន់ដាច់ស្រយាល (៤) ពង្រឹងសមត្ថភាពនាយកសាលា និងក្រុមការងារត្រួតពិនិត្យ និងបណ្តុះ-បណ្តាលនៅថ្នាក់ស្រុក ដើម្បីអនុវត្តគោលនយោបាយសាលាកុមារមេត្រីឱ្យបានពេញលេញ (៥) បង្កើនថវិកាដំណើរការសាលារៀន និងពង្រឹងគណៈកម្មការទ្រទ្រង់សាលា (៦) ផ្តល់អាហារូបករណ៍ និងកម្មវិធីផ្តល់អាហារនៅបឋមសិក្សា (៧) កាត់បន្ថយចំណាយលើការសិក្សា និងលុបបំបាត់ចំណាយក្រៅផ្លូវការផ្សេងៗ (៨) បង្កើតយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីការអប់រំ (៩) ពង្រីកការអប់រំពីរភាសា កម្មវិធីចូលរៀនឡើងវិញ កម្មវិធី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពន្លឿន និង (១០) ផ្តល់សៀវភៅសិក្សាគោល ដើម្បីធានាគុណភាពការរៀន និងបង្រៀន ដើម្បីឱ្យកុមារទទួលបាននូវជំនាញដោះស្រាយបញ្ហា និងពិចារណា។

### *៣.៣.២.៧ កំណើនអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនៅស្រុកដែលមានគុណផលទាប*

សាលាមធ្យមសិក្សាបឋមភូមិជាថ្នាលពង្រីក និងពង្រឹងការរៀនជំនាញដែលទទួលបានពីបឋមសិក្សា និងត្រូវបានកំណត់ជាកត្តាដ៏សំខាន់ក្នុងការទទួលបានប្រាក់ចំណូលពីឯកជន និងសង្គមដោយបង្កើតឱកាសវិនិយោគនានា។ ភូមិសិក្សានេះ គឺជាការផ្តល់នូវជំនាញសម្រាប់កុមារមួយចំនួន ក្នុងការទទួលបានការងារធ្វើ ខណៈកុមារភាគច្រើននឹងប្រើប្រាស់ជំនាញទាំងនោះសម្រាប់សិក្សាបន្ត និងជាលទ្ធផលនៃការបញ្ចូលគ្នាសម្រាប់កុមារ និងយុវជនដែលបាត់បង់ឱកាស ក្នុងការទទួលបានការងារតាមលទ្ធភាព។

ការចុះឈ្មោះចូលរៀនមានកម្រិតទាប(អត្រារួមនៃការចុះឈ្មោះចូលរៀនមាន ៥៣,៦% និងអត្រាពិតនៃការចុះឈ្មោះចូលរៀនមាន ៣៧,៨% ក្នុងឆ្នាំ២០១២–២០១៣) ហើយការបោះបង់ការសិក្សាមានកម្រិតខ្ពស់(២០%ក្នុងឆ្នាំ២០១២–២០១៣) ដែលជាទូទៅគឺដោយសារឱកាសទទួលបានការងារធ្វើ ការចំណាយផ្ទាល់នៃការអប់រំ(សៀវភៅឯកសណ្ឋាន ការធ្វើដំណើរ និងការចំណាយក្រៅផ្លូវការ) រដូវកាលធ្វើស្រែចម្ការកំឡុងពេលសិក្សា ក៏ដូចជាចម្ងាយពីសាលាទៅផ្ទះនៅតំបន់ជនបទ ព្រមទាំងចំនួនមនុស្សច្រើនហួសនៅតំបន់ប្រជុំជន។ ការយល់ឃើញ និងក្នុងការផ្តល់គុណតម្លៃទាបរបស់គ្រួសារ និងបញ្ហាពាក់ព័ន្ធនានាក្នុងការអប់រំនៅមធ្យមសិក្សាបឋមភូមិ ដូចជាគ្រូអវត្តមានច្រើន និងអត្រាត្រួតថ្នាក់ខ្ពស់បាននាំឱ្យការចុះឈ្មោះចូលរៀនមានកម្រិតទាប និងនាំឱ្យមានការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ។

អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិបានបង្ហាញពីនិន្នាការថយចុះ ក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅ ពី៤៩% ក្នុងឆ្នាំ២០០៨–២០០៩ មក៤០,៦% ក្នុងឆ្នាំ២០១២-២០១៣ ដែលជាការធ្លាក់ចុះនៃភាគរយកុមារដែលមានអាយុ ១៤ឆ្នាំ ដែលរៀនដល់ថ្នាក់ទី៩។ ផ្ទុយទៅវិញ សូចនាករនេះមានភាពមិនអាចជឿទុកចិត្តបានខ្លះៗ ជាពិសេសនៅកម្រិតថ្នាក់ស្រុក ដែលបានផ្តល់ព័ត៌មានស្តីពីចំណាកស្រុកខ្ពស់របស់ប្រជាពលរដ្ឋ ដោយចាកចេញពីស្រុកមួយ ទៅស្រុកមួយក្នុងប្រទេស ហើយដែលការពិតនោះ គឺមានចំនួនកុមារដែលលើសអាយុជាច្រើននៅក្នុងសាលារៀន។ ទោះជាយ៉ាងណាក៏ដោយក៏និន្នាការនេះបានធ្លាក់ចុះយ៉ាងខ្លាំង ចាប់តាំងពីអត្រាត្រួតថ្នាក់បានថយចុះយ៉ាងឆាប់រហ័សមក។

ដើម្បីដោះស្រាយបញ្ហានេះ គឺទាមទារឱ្យមានការពង្រាយគ្រូបង្រៀន ដែលមានសមត្ថភាពឱ្យបានគ្រប់គ្រាន់ នៅតំបន់ដាច់ស្រយាល ការបង្កើនថវិកាដំណើរការសាលារៀន និងការពង្រឹងគណៈកម្មការទ្រទ្រង់សាលា ការផ្តល់អាហារូបករណ៍ សៀវភៅសិក្សាគោល ព្រមទាំងការអនុវត្តកម្មវិធីការចូលរៀនឡើងវិញ កម្មវិធីពន្លឿន ការអនុវត្តកម្មវិធីសិក្សាមានភាពទន់ភ្លន់ និងភ្ជាប់ទំនាក់ទំនងរវាងការងារទាំងនេះ ជាមួយនឹងការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស។

សរុបមក ក្រសួងបានចាត់វិធានការដូចតទៅ (១) ធ្វើអន្តរាគមន៍ក្នុងការធ្វើឱ្យកើនឡើងការចុះឈ្មោះចូលរៀន និងការកាត់បន្ថយការបោះបង់ ជាពិសេសសម្រាប់កុមារបាត់បង់ឱកាស (២) បែងចែកគោលដៅនៃការធ្វើអន្តរាគមន៍នៅថ្នាក់ស្រុក ជាមួយនឹងការផ្តល់ជំនួយជាក់លាក់ ក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋាន (៣) អនុវត្តគោលនយោបាយសាលាកុមារមេត្រីនៅមធ្យមសិក្សា (៤) ធានាការពង្រាយគ្រូបង្រៀនដែលមានសមត្ថភាពឱ្យបានគ្រប់គ្រាន់ នៅតំបន់ដាច់ស្រយាល (៥) បង្កើនថវិកាប្រតិបត្តិសាលារៀន និងពង្រឹងគណៈកម្មការទ្រទ្រង់សាលា ផ្តល់អាហារូបករណ៍ និងសៀវភៅសិក្សាគោល កាត់បន្ថយចំណាយផ្សេងៗនៅសាលា និងចំណាយក្រៅផ្លូវការ កាត់បន្ថយអវត្តមានគ្រូ ធ្វើយុទ្ធនាការលើការយល់ដឹងពីការអប់រំ ភាពបត់បែននៃការសិក្សា ដោយភ្ជាប់ជាមួយនឹងការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស កម្លាំងពលកម្ម និងការសើរើទិន្នន័យនៃការស្ទង់មតិនៅថ្នាក់ជាតិឆ្នាំ២០១៣។

### *៣.៣.២.៨ ការកាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ*

ជំនាញដែលទទួលបានពីសាលារៀនគួរតែពាក់ព័ន្ធនឹងតម្រូវការ និងលើសពីចំណេះដឹងតាមមុខវិជ្ជា ជាឧទាហរណ៍ជំនាញ ដែលអាចផ្ទេរបន្តក្នុងការអនុវត្តចំណេះដឹងទៅក្នុងការងារជាក់ស្តែង ជំនាញដោះស្រាយបញ្ហា និងជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ ដូច្នេះ សាលារៀនមានតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់ការអប់រំ ដោយរៀបចំសកម្មភាពនានា និងអនុវត្តក្នុងថ្នាក់រៀន និងការបង្រៀន ដែលជំរុញទឹកចិត្តសិស្សដែលបាត់បង់ឱកាស និងផ្តល់ភាពជឿជាក់លើសមត្ថភាពរបស់ពួកគេ។ ការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិបានកើនឡើងពី១៨,៨% នៅឆ្នាំ២០០៨–២០០៩ ដល់២១,៧% នៅឆ្នាំ២០១០–២០១១ (២១,៩%សម្រាប់កុមារី) និងបង្ហាញពីវិសមភាពដ៏ធំរវាងតំបន់ប្រជុំជន និងតំបន់ជនបទ។

មូលហេតុចម្បងនៃការបោះបង់ការសិក្សាត្រូវបានពណ៌នាខាងលើរួចហើយ។ ទោះបីជាបែបណា កត្តានេះមានសារៈសំខាន់ផងដែរក្នុងការធ្វើឱ្យកត់សម្គាល់រវាង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការចល័តរបស់សិស្ស ដូចជាការផ្លាស់ប្តូរពីកម្មវិធីមួយ (ឧទា. ការប្តូរទៅចាប់ការបណ្តុះ-បណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស) ឬពីសាលាទៅកម្មវិធីផ្សេងទៀត (ការចំណាកស្រុកមានចំនួនច្រើននៅប្រទេសកម្ពុជា) និងសិស្សដែលបានបោះបង់ចោលទាំងស្រុងពីប្រព័ន្ធអប់រំ។

សរុបមក ក្រសួងអប់រំ យុវជន និងកីឡានឹងចាត់វិធានការដើម្បីកាត់បន្ថយការបោះបង់ការសិក្សា ជាពិសេសសម្រាប់តំបន់ និងកុមារដែលបាត់បង់ឱកាស។ ក្រសួងអប់រំ យុវជន និងកីឡានឹងរៀបចំយុទ្ធសាស្ត្រយ៉ាងមុតស្រួចក្នុងការដោះស្រាយបញ្ហាបោះបង់ការសិក្សា ដោយផ្អែកលើមេរៀន និងបទពិសោធដែលទទួលបានពីកម្មវិធីសាកល្បងការបង្ការការបោះបង់ការសិក្សា ដោយផ្តល់ជាអាហារូបករណ៍ និងធានាការពង្រាយគ្រូបង្រៀន ដែលមានសមត្ថភាពទៅតំបន់ដាច់ស្រយាល ការពង្រឹងការអនុវត្តគោលនយោបាយសាលាកុមារមេត្រីនៅមធ្យមសិក្សាបឋមភូមិ ដោយបញ្ចូលបញ្ហាជាក់ស្តែងរបស់កុមារីដូចជា ថ្នាក់កុមារីមេត្រី បង្គន់អនាម័យ សម្ភារសិក្សា ដើម្បីធានាការអនុវត្តម៉ោងបង្រៀន។ លើសពីនេះ ក្រសួងក៏នឹងធ្វើការកាត់បន្ថយបញ្ហាគ្រូអវត្តមានច្រើន ដោយផ្តល់ជាជំនួយបន្ថែមសម្រាប់សិស្សដែលរៀនយឺត អនុវត្តកម្មវិធីពន្លឿន និងការពង្រឹងភាពទាក់ទងរវាងកម្មវិធីសិក្សា និងការអប់រំវិជ្ជាជីវៈ និង បច្ចេកទេស ការធានាការអនុវត្តម៉ោងបង្រៀនពី៨៥០ ទៅ១ ០០០ម៉ោង ការធានាមតិត្រឡប់លើលទ្ធផលនៃការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិក្នុងប្រព័ន្ធ ការគាំទ្របន្ថែមសម្រាប់សិស្សខ្សោយ និងការកាត់បន្ថយពលកម្មកុមារ។

## ៣.៤. សេចក្តីសន្និដ្ឋាន

កំណែទម្រង់វិស័យអប់រំបានបង្ហាញចេញជាមេរៀន និងបទពិសោធដែលអាចប្រើប្រាស់លើកំណែទម្រង់ស្ថាប័ន ដើម្បីធ្វើឱ្យប្រសើរលើការផ្តល់សេវាអប់រំ។ កំណែទម្រង់បានចេញជាលទ្ធផលដល់ការចូលរៀនជាលក្ខណៈសកល និងសមធម៌នៅកម្រិតបឋមសិក្សា។ លទ្ធផលនេះ អាចត្រូវបានប្រើជាទិន្នន័យបឋមសម្រាប់កំណែទម្រង់ស្ថាប័នក្នុងវិស័យអប់រំ។

**ទីមួយ**–យុទ្ធសាស្ត្រដ៏មុតមាំ និងភាពស៊ីចង្វាក់នៃប្រតិបត្តិការក្នុងផែនការវិស័យអប់រំ ដោយពិនិត្យលើគោលបំណង យុទ្ធសាស្ត្រ និងកម្មវិធីដែលបង្កើតបានជាភាពជាម្ចាស់ការរបស់ជាតិ។ កម្មវិធីកំណែទម្រង់បានគូសចេញជាផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលផ្តោតសំខាន់លើបញ្ហានៃការចូលរៀន និងគុណភាពអប់រំ។ សកម្មភាពនានានៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ បានឆ្លុះបញ្ចាំងក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អប់រំ យុវជន និងកីឡា និងសកម្មភាពនានាដែលទទួលបានជំនួយពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល។

**ជំពីរ**–ការធានាការកសាងសមត្ថភាព ជាមួយនឹងស្ថាប័នក្នុងការអនុវត្តគម្រោងនានាប្រកបដោយនិរន្តរភាព។

**ជំបី**–កម្មវិធីអាហារូបករណ៍បានដាក់គោលដៅដល់សិស្ស ដែលមានសក្ដានុពលលើការសិក្សា ស្របនឹងការធានានូវសិស្សក្រីក្រក្នុងការទទួលបានកម្មវិធីលើកទឹកចិត្តដោយសមធម៌ និងប្រសិទ្ធភាព។ អ្នកដែលទទួលបានគឺត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃភាពក្រីក្រនិងលទ្ធផលសិក្សា (meri)។ វិធីសាស្ត្រទាំងពីរនេះបានផ្ដល់នូវពន្លឺសម្រាប់ការផ្ដល់ឱ្យប្រកបដោយប្រសិទ្ធភាព និងសមធម៌។

**ជំបួន**–ការត្រួតពិនិត្យនៃកម្មវិធីកំណែទម្រង់ បានផ្ដោតលើសូចនាករនៃលទ្ធផលដែលអាចវាស់វែងបាន។ ការដឹកនាំ និងការត្រួតពិនិត្យនៅកម្រិតវិស័យគួរតែធ្វើរចនាសម្ពន្ធឡើងវិញ លើក្របខណ្ឌលទ្ធផលក្នុងការសម្របសម្រួល លើវិធានការវិវត្ត និងធានាការអភិវឌ្ឍនៃផលប៉ះពាល់។ សកម្មភាពទាំងនេះ ត្រូវបានប្រើជាឧបករណ៍ដ៏សំខាន់សម្រាប់ការគ្រប់គ្រង និងសម្រាប់ការលើកទឹកចិត្ត។

**ជំប្រាំ**–សមត្ថភាពស្ថាប័នត្រូវបានពង្រឹង ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តលក្ខខណ្ឌព្រាងទុក សម្រាប់គំនិតផ្តួចផ្តើមសាំញ៉ាំនានា ដែលត្រូវបានសាកល្បងជាលើកដំបូង។ បញ្ហាជួបប្រទះនានានៅក្នុងការអនុវត្ត អាចនឹងត្រូវកាត់បន្ថយតាមរយៈសមត្ថភាពវាយតម្លៃយ៉ាងហ្មត់ចត់។

បញ្ហាជួបប្រទះនានានៅក្នុងការអនុវត្ត អាចនឹងត្រូវកាត់បន្ថយតាមរយៈសមត្ថភាពវាយតម្លៃយ៉ាងហ្មត់ចត់។ មួយវិញទៀត ការសាកល្បងទ្រង់ទ្រាយតូចនៃអន្តរាគមន៍ជាអាទិ៍ភាពទាំងនោះ មុននឹងអនុវត្តកម្មវិធីជាទ្រង់ទ្រាយធំអាចមានប្រយោជន៍ក្នុងការលើកកម្ពស់គុណភាព។ ក្នុងន័យនេះ ការវាយតម្លៃសមត្ថភាពនៃការកសាងនាយកដ្ឋាន អាចជួយពិតប្រាកដក្នុងការសម្រេចគោលដៅការងារមន្ត្រីរាជការ។

# ជំពូកទី ៤
# សមិទ្ធផលកំណែទម្រង់វិស័យអប់រំ
# ក្នុងរយៈពេល ១៥ ឆ្នាំ

វិស័យអប់រំនៅកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្ដូរមុខមាត់ខ្លាំងក្លា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខណៈដែលប្រទេសកម្ពុជាព្យាយាមពង្រីកប្រព័ន្ធអប់រំ ដើម្បីឆ្លើយតបនឹងតម្រូវការកើនឡើងនៃកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័ស ។ ក្រសួងអប់រំ យុវជន និងកីឡា មានការជួយគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍជាច្រើន ដោយរួមមាន៖ អង្គការអន្តរជាតិ កម្មវិធីសហប្រតិបត្តិការទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀតដែលមានបម្រើការងារក្នុងវិស័យអប់រំ។

ប្រទេសកម្ពុជាបានធ្វើការប្ដេជ្ញាចិត្តលើគំនិតផ្ដួចផ្ដើមជាសកលជាច្រើន ដែលត្រូវបានគេស្គាល់ថាជាច្បាប់ទន់ ដូចជា (១) ក្របខណ្ឌ **ការអប់រំសម្រាប់ទាំងអស់គ្នា** នៅទីក្រុងដាក្កា ឆ្នាំ២០០០[199]។ **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** ឆ្នាំ២០០០ ដែលមានគោលបំណងលើកកម្ពស់គោលនយោបាយ «**ការអប់រំសម្រាប់ទាំងអស់គ្នា**»។ រដ្ឋាភិបាលបានទទួលស្គាល់ថា ការងារនេះជាប់ទាក់ទងនឹងចំណុចបី៖ (១) រកឱ្យឃើញ និងអនុវត្តវិធីសាស្ត្រមានប្រសិទ្ធភាព ក្នុងការប្រមូលកុមារឱ្យចូលរៀន កាត់បន្ថយអត្រាបោះបង់ និងត្រួតថ្នាក់ (២) បង្កើនគុណភាពបង្រៀន និងរៀន និង (៣) ពង្រឹងសមត្ថភាពនៃការរៀបចំផែនការ និងគ្រប់គ្រងនៅគ្រប់កម្រិតទាំងអស់[200]។ ចំណុចទាំងនេះគឺជាគោលការណ៍នាំផ្លូវ ដែលក្រសួងអប់រំ យុវជន និងកីឡាចង់យកមកប្រើសម្រាប់ការអប់រំនៅ

---

[199] សេចក្ដីថ្លែងការណ៍ពិភពលោកស្ដីពីការអប់រំសម្រាប់ទាំងអស់គ្នានៅ **ជុមទៀន** ឆ្នាំ១៩៩០ បានលើកស្នើសមាសភាគ៦ ដែលប្រទេសនានាត្រូវកំណត់ចំណុចដៅរៀងខ្លួន (ការសម្រេចតម្រូវការអប់រំមូលដ្ឋាន, ទីក្រុង**ប៉ារីស** ៖ អង្គការយូណេស្កូ។ ជាលទ្ធផល គណៈកម្មការជាតិអប់រំសម្រាប់ទាំងអស់គ្នាបានដាក់ចេញផែនការសកម្មភាពអប់រំសម្រាប់ទាំងអស់គ្នា។ វេទិកាអប់រំពិភពលោកនៅដាក្កាឆ្នាំ២០០០បានដាក់ចេញគោលដៅចំនួន៦ ៖ (១) ការអប់រំនិងថែទាំកុមារតូច (២) ការអប់រំបឋមសិក្សាជាសកល (៣) ការសិក្សានិងបំណិន សម្រាប់យុវជន និងមនុស្សពេញវ័យ (៤) អក្ខរកម្មមនុស្សពេញវ័យ (៥) សមភាព និងយុគភាពយេនឌ័រ (៦) គុណភាពអប់រំ។ ទាំងនេះបាននាំរដ្ឋាភិបាលនិងអ្នកផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអប់រំ និងកាន់តែមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល។

[200] MoEYS 2000, Education For All (EFA): the Year 2000 Assessment. Country Report by the National EFA 2000 Assessment Group, Phnom Penh, pp. 103-4.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជា។ ប៉ុន្តែកត្តាទាំងនោះក៏ជាយុទ្ធសាស្ត្រ ដើម្បីសម្រេចបាននូវគោលដៅគោល-នយោបាយគ្របដណ្តប់ទូលំទូលាយនៃការអប់រំសម្រាប់ទាំងអស់គ្នា។

ការអប់រំមានសារៈសំខាន់ ដោយសារតែបានផ្តល់ឱ្យសិស្សនូវចំណេះដឹង ជំនាញ និងគុណតម្លៃ ដែលអាចធ្វើឱ្យពួកគេអាចដំណើរការបាន យ៉ាងមានប្រសិទ្ធភាពក្នុងពិភព-លោក ដែលមានការផ្លាស់ប្តូរដ៏ឆាប់រហ័ស នៅផ្ទះ ក្នុងសហគមន៍ និងទីកន្លែងការងារ ទាំងបច្ចុប្បន្ន និងអនាគត ។ សសរស្តម្ភ៤ នៃការសិក្សា ត្រូវបានកំណត់ដោយគណៈកម្មាធិការអន្តរជាតិស្តីពីការអប់រំសម្រាប់ស.វ.ទី២១ ដែលបានដាក់ជូនអង្គការយូណេស្កូ ៖ **រៀនដើម្បីចេះ រៀនដើម្បីធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីរស់នៅជាមួយគ្នា។**

ដូចនេះ ជាទូទៅ ការរៀននិងការបង្រៀនត្រូវអនុវត្តទៅតាមកម្មវិធីសិក្សា ដែលរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃគោលការណ៍ជាគន្លឹះមួយចំនួន ៖ (១) **ភាពបត់បែន**-សិស្សានុសិស្សត្រូវមានជម្រើសច្រើន ដែលអាចធ្វើឱ្យពួកគេមានសមត្ថភាពឆ្លើយតបទៅនឹងអនាគត និងតម្រូវការទីផ្សារពលកម្ម ដែលមិនប្រាកដប្រជា និង (២) **ការសិក្សាពេញមួយជីវិត** - ការរៀនបំណិន ដែលអាចឱ្យសិស្សរៀននាពេលបច្ចុប្បន្ន និងអនាគត។

**បំណិនរៀនពេញមួយជីវិត** រួមមាន៖ សមត្ថភាពនៃការរៀនទាំងបច្ចុប្បន្ន និងទៅអនាគត។ ទាំងនេះគឺជាបំណិន ដែលអាចធ្វើឱ្យយើងផ្លាស់ប្តូរ ពីសភាពការណ៍មួយទៅសភាពការណ៍មួយទៀត នៅពេលដែលជួបនឹងបញ្ហាប្រឈមនឹងបរិបទថ្មី។ បំណិនដ៏សំខាន់បំផុតមួយ ក្នុងចំណោមបំណិនទាំងនេះគឺ **ការរៀនពីរបៀបគិត** ដោយភាពច្នៃប្រឌិត និងត្រិះរិះពិចារណា។ នេះពិតជាបំណិនសំខាន់ខ្លាំងណាស់ ក្នុងពិភពលោកដែលអ្វីៗផ្លាស់ប្តូរឆាប់រហ័ស។ សិស្សានុសិស្សគួរតែអាច (១) ស្វែងយល់ និងស្គាល់បញ្ហា (ការ-ចោទជាបញ្ហា ការរកអត្តសញ្ញាណកម្មបញ្ហា) (២) វិភាគស្ថានភាព (បញ្ហា ឬការវិភាគស្ថានភាព) (៣) រៀបចំគម្រោងផែនការ ឬកំណត់ជម្រើសយុទ្ធសាស្ត្រ សម្រាប់ដោះស្រាយបញ្ហា (រៀបចំផែនការ បំណិនចាត់ចែង និងបំណិនដោះស្រាយបញ្ហា) (៤) វាយតម្លៃជម្រើសយុទ្ធសាស្ត្រ (បំណិនគិតត្រិះរិះពិចារណា បំណិនស៊ើបអង្កេត និងស្រាវជ្រាវ) (៥)ទំនាក់ទំនងជាមួយអ្នកដទៃ ទាំងស្វែងរក និងចែករំលែកគំនិត និងព័ត៌មាន (បំណិនទំនាក់ទំនង) និង (៦) សហការជាមួយអ្នកដទៃ (គ្រួសារ មិត្តរួមថ្នាក់ សហគមន៍) ដើម្បីដោះស្រាយបញ្ហាទៅវិញទៅមក ដែលកំពុងប្រឈមក្នុងគ្រួសាររបស់យើង និង/ឬ សហគមន៍ (បំណិនទំនាក់ទំនង និងចរចា)។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដូចនេះ **បំណិនរៀនពេញមួយជីវិត** ត្រូវមានសមាសភាគដូចតទៅ ៖ (១) បំណិនផ្ទាល់ខ្លួន និងទំនាក់ទំនង រួមទាំងការធ្វើការជាមួយអ្នកដទៃ (២) បំណិនភាសា និងទំនាក់ទំនង (៣) បំណិនលេខនព្វន្ត (៤) បំណិនបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (៥) បំណិនដោះស្រាយបញ្ហា និង (៦) បំណិនរៀននិងគិត។

ដើម្បីឆ្លើយតបនឹងការប្តេជ្ញាចិត្តបង្កើនថវិកាសម្រាប់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញគោលនយោបាយកំណែទម្រង់ ដោយមានគោលបំណងលើកកម្ពស់ **ការអប់រំសម្រាប់ទាំងអស់គ្នា** (EFA) ។ **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ** ត្រូវបានរៀបចំឡើង ដើម្បីធានានូវការតភ្ជាប់រវាងគោលនយោបាយអប់រំ និងយុទ្ធសាស្ត្រជាមួយកម្មវិធីអភិវឌ្ឍន៍ និងផែនការសកម្មភាព និងរវាងការរៀបចំថវិកា និងផែនការផងដែរ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺជាក្របខណ្ឌគោលនយោបាយ និងជាផែនទីចង្អុលផ្លូវសម្រាប់វិស័យអប់រំ ៖ (១) **ការអប់រំសម្រាប់ទាំងអស់គ្នា៖** គោលដៅរយៈពេលវែងនៃកំណែទម្រង់ ដើម្បីសម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នា នៅឆ្នាំ២០១៥ និងការអប់រំមូលដ្ឋានប្រកបដោយគុណភាពរយៈពេល ៩ឆ្នាំ នៅឆ្នាំ២០១០ (២) **ការអប់រំប្រកបដោយសមធម៌** ៖ គោលបំណងគោលនយោបាយរយៈពេលមធ្យម ដើម្បីធានាឱ្យមាននូវកាលានុវត្តភាព ប្រកបដោយសមធម៌នៅគ្រប់កម្រិតនៃការអប់រំ ជាពិសេសសម្រាប់សិស្សានុសិស្សមកពីគ្រួសារដែលក្រីក្របំផុត (៣) **បង្កើនស្តង់ដានៃការអប់រំ** ៖ រាល់កំណែទម្រង់ ដែលធានាឱ្យមានសាលារៀនល្អ លទ្ធផលសិក្សារបស់សិស្ស និងការបំពេញការងាររបស់គ្រូ ដែលមានភាពល្អប្រសើរ និងធនធានដ៏សំខាន់សម្រាប់ការបង្កើនគុណភាពសមិទ្ធផល (៤) **ការកសាងសមត្ថភាព** ៖ កម្មវិធីកសាងសមត្ថភាពដែលជាគោលដៅនៅគ្រប់កម្រិតនៃប្រព័ន្ធអប់រំ ដោយមានការប្តេជ្ញាចិត្តដើម្បីធ្វើវិមជ្ឈការក្នុងការគ្រប់គ្រង (៥) **ការតាមដាន និងវាយតម្លៃ** ៖ ការកសាងប្រព័ន្ធគ្រប់គ្រងវិស័យអប់រំល្អប្រសើរ ដោយផ្អែកលើសមិទ្ធផល ដោយមានកម្មវិធីត្រួតពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់នៃកម្មវិធី និង (៦) **ផ្តល់ហិរញ្ញប្បទានប្រកបដោយសមធម៌** ៖ ការប្រើប្រាស់យន្តការហិរញ្ញវត្ថុ និងការវិភាជថវិកា ដែលផ្តោតលើអាទិភាពគោលនយោបាយសម្រាប់ការអប់រំជាមូលដ្ឋាន និងនៅកម្រិតក្រោយការអប់រំមូលដ្ឋាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ** ២០០៩-២០១៣ ផ្តល់អាទិភាពទៅលើការ-ពង្រីកការអប់រំកុមារតូច ការអប់រំក្រៅប្រព័ន្ធ ការណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងបង្កើនកាលានុវត្តភាពក្នុងការចូលរៀននៅមធ្យមសិក្សា និងក្រោមមធ្យមសិក្សា។ លើសពីនេះ មានគោលនយោបាយអប់រំជាច្រើន និងឯកសារបោះពុម្ពផ្សេងៗទៀតដែលមានសារៈសំខាន់ក្នុងការអភិវឌ្ឍវិស័យអប់រំ រួមទាំងគោលនយោបាយសាលាកុមារមេត្រី[201] គោល-នយោបាយស្តីពីការអប់រំកុមារពិការ និងគោលនយោបាយស្តីពីសុខភាពសិក្សា និងសៀវភៅណែនាំបែបបទស្នើសុំអាហារូបករណ៍។ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការជាមួយដៃគូអភិវឌ្ឍជាច្រើន ដើម្បីអនុវត្តគោលនយោបាយទាំងនេះឱ្យមានប្រសិទ្ធភាព។

ជាលទ្ធផល ចេញពីអន្តរាគមន៍ និងគោលនយោបាយ ដែលបានបង្ហាញខាងលើ ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងវិស័យអប់រំ។ កម្ពុជាបានពង្រីកកាលានុវត្តភាពអប់រំជាច្រើន ជាពិសេសផ្តល់ការអប់រំនៅកម្រិតបឋមសិក្សាជាសកល ដែលធ្វើឱ្យកើនឡើងនូវការចូលរៀនរបស់កុមារីនៅជនបទ និងកុមារជនជាតិដើមភាគតិច។ ការរៀបចំផែនការថវិកា និងដំណើរការអនុវត្ត ព្រមទាំងការដាក់ឱ្យអនុវត្តថវិកាកម្មវិធីសម្រាប់វិស័យអប់រំត្រូវបានកែលម្អ។ ចំណែកនៃចំណាយវិស័យអប់រំកើនពី ០,៩% នៃផសស ក្នុងឆ្នាំ១៩៩៧ ដល់ ១,៧% ក្នុងឆ្នាំ២០០០ ហើយសម្រេចបាន ២,៣% ក្នុងឆ្នាំ ២០១៥។ ចំណាយវិស័យអប់រំធៀបនឹងថវិកាចំណាយចរន្តកើនឡើងពី ១៥% ក្នុងឆ្នាំ ២០០០ ដល់ ១៧,៣% ក្នុងឆ្នាំ២០១៥។

ប្រព័ន្ធអប់រំនៅកម្ពុជាត្រូវបានរៀបចំឡើង តាមរចនាសម្ពន្ធ ៦-៣-៣-៤, ៥, ឬ ៦ ដោយមានរយៈពេលសិក្សានៅបឋមសិក្សាចំនួន ៦ឆ្នាំ, នៅមធ្យមសិក្សាបឋមភូមិចំនួន ៣ ឆ្នាំ, និង នៅមធ្យមសិក្សាទុតិយភូមិចំនួន ៣ឆ្នាំទៀត ដោយបន្ថែមពីរ ឬ បួនឆ្នាំទៀតនៅសាកលវិទ្យាល័យ។ ការអប់រំនៅមត្តេយ្យសិក្សាមានរយៈពេល ៣ឆ្នាំ សម្រាប់ក្មេងៗអាយុពី ៣-៥ ឆ្នាំ។ ការសិក្សានៅកម្រិតមត្តេយ្យសិក្សាមិនទាន់ចែងជាកាតព្វកិច្ចនៅឡើយ។ ការអប់រំនៅបឋមសិក្សាពិតជាចាំបាច់សម្រាប់កុមារអាយុចាប់ពី ៦-១១ឆ្នាំ។ កម្មវិធីអប់រំនៅបឋមសិក្សាមានរយៈពេល ៦ឆ្នាំ ចាប់ពីថ្នាក់ទី១ ដល់ ទី៦ ដែលជំណាក់កាលទីមួយនៃការអប់រំមូលដ្ឋាន។ ការអប់រំមធ្យមសិក្សាចំណេះទូទៅ ត្រូវបានបែងចែកជាពីកម្រិតគឺ បឋមភូមិ និងទុតិយភូមិ។ បឋមភូមិសម្រាប់ថ្នាក់ទី៧-៩ និងតាមគោលការណ៍កាតព្វកិច្ច

[201] គោលនយោបាយសម្រាប់សាលាកុមារមេត្រីនេះ បង្ហាញពីយុទ្ធសាស្ត្រក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព និងគោលការណ៍ជាមូលដ្ឋាន សម្រាប់ការអប់រំតាមរយៈសមាសភាគប្រាំមួយ៖ (i) សមភាពក្នុងការចូលរៀន, (ii) ប្រសិទ្ធភាពនៃការអប់រំ, (iii) ការការពារកុមារ, (iv) សមភាពយេនឌ័រ, (v) ការចូលរួមរបស់កុមារ និង (vi) ការគាំទ្រថ្នាក់ជាតិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់សិស្សអាយុចាប់ពី ១២-១៤ឆ្នាំ។ នៅកម្រិតទុតិយភូមិមិនមែនជាកាតព្វកិច្ច ចាប់ពីថ្នាក់ទី១០-១២។ ការអប់រំក្រោយទុតិយភូមិរួមបញ្ចូលទាំងការអប់រំកម្រិតឧត្តម និងបណ្តុះ-បណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ បន្ទាប់ពីបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សិស្សមានជម្រើសពីរ ៖ គឺបន្តផ្នែកអប់រំទូទៅ ឬផ្នែកអប់រំបច្ចេកទេស។ បន្ទាប់ពីបញ្ចប់ផ្នែកទាំងពីរនេះ សិស្សអាចបន្តទៅសាកលវិទ្យាល័យ។ ការអប់រំថ្នាក់ឧត្តមចំណាយពេលពី៤ ទៅ ៧ឆ្នាំ។ តារាងខាងក្រោមបង្ហាញពីប្រព័ន្ធអប់រំបច្ចេកទេស និងទូទៅ និងវិទ្យាល័យបច្ចេកទេស និងវិទ្យាល័យចំណេះទូទៅ។

<table>
<tr><td>អាយុ</td><td colspan="6" rowspan="5">ឧត្តមសិក្សា</td><td rowspan="5"></td></tr>
<tr><td>២១</td></tr>
<tr><td>២០</td></tr>
<tr><td>១៩</td></tr>
<tr><td>១៨</td></tr>
<tr><td colspan="8">ការប្រឡងថ្នាក់ជាតិ</td></tr>
<tr><td>១៧</td><td colspan="2" rowspan="3">មធ្យមសិក្សា<br>ទុតិយភូមិ</td><td rowspan="3">ផ្នែក<br>ចំណេះ<br>ទូទៅ</td><td>ថ្នាក់ទី<br>១២</td><td>ឆ្នាំទី<br>៣</td><td rowspan="3">ផ្នែក<br>បច្ចេកទេស</td><td rowspan="13">ការអប់រំ<br>ក្រៅ<br>ប្រព័ន្ធ</td></tr>
<tr><td>១៦</td><td>ថ្នាក់ទី<br>១១</td><td>ឆ្នាំទី<br>២</td></tr>
<tr><td>១៥</td><td>ថ្នាក់ទី<br>១០</td><td>ឆ្នាំទី<br>១</td></tr>
<tr><td colspan="7">ការប្រឡងថ្នាក់ជាតិ</td></tr>
<tr><td>១៤</td><td rowspan="9">អប់រំមូលដ្ឋាន រយៈពេល ៩ឆ្នាំ</td><td rowspan="3">មធ្យមសិក្សា<br>បឋមភូមិ</td><td colspan="4">ថ្នាក់ទី៩</td></tr>
<tr><td>១៣</td><td colspan="4">ថ្នាក់ទី៨</td></tr>
<tr><td>១២</td><td colspan="4">ថ្នាក់ទី៧</td></tr>
<tr><td>១១</td><td rowspan="6">បឋមសិក្សា</td><td colspan="4">ថ្នាក់ទី៦</td></tr>
<tr><td>១០</td><td colspan="4">ថ្នាក់ទី៥</td></tr>
<tr><td>៩</td><td colspan="4">ថ្នាក់ទី៤</td></tr>
<tr><td>៨</td><td colspan="4">ថ្នាក់ទី៣</td></tr>
<tr><td>៧</td><td colspan="4">ថ្នាក់ទី២</td></tr>
<tr><td>៦</td><td colspan="4">ថ្នាក់ទី១</td></tr>
</table>

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.១. ការអប់រំកុមារតូច

**ការអប់រំកុមារតូច** (ECE) ក្នុងប្រទេសកម្ពុជា ជាដំបូងត្រូវបានរៀបចំឡើងដើម្បីគាំទ្រតម្រូវការរបស់ស្ត្រី ។ នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ មានទារកដ្ឋានប្រហែលចំនួន៨០ សម្រាប់មើលថែទាំកុមារចាប់ពីអាយុ២ដល់៣៦ខែ និងសាលាមត្តេយ្យចំនួន៦៥០ទៀត ដែលបម្រើឱ្យប្រជាជនប្រហែល៣% ក្នុងចំណោមប្រជាជនអាយុពី៣ដល់៦ ឆ្នាំ[202]។ ដូច្នេះ ការអភិវឌ្ឍនៃការអប់រំកុមារតូច គឺជារឿងថ្មីមួយសម្រាប់កម្ពុជា។

បញ្ហាប្រឈមរបស់កម្ពុជា គឺសិស្សលើសអាយុចូលរៀន ដែលជាហេតុនាំឱ្យមានអត្រានៃការបោះបង់សិក្សាខ្ពស់ នៅមធ្យមសិក្សាបឋមភូមិ។ ដើម្បីធានាថា កុមារកម្ពុជាចាប់ផ្តើមចូលសាលារៀននៅអាយុ៦ឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមយុទ្ធនាការដើម្បីលើកកម្ពស់ការអប់រំកុមារតូច (ការបង្កើនការចុះឈ្មោះចូលរៀន និងការអប់រំកុមារតូចគឺជាគន្លឹះ ដើម្បីបង្កើននូវការត្រៀមខ្លួនរួចជាស្រេច ដើម្បីកាត់បន្ថយការត្រួតថ្នាក់នៅបឋមសិក្សា(ជាពិសេស ក្នុងថ្នាក់ទី១) កាត់បន្ថយការបោះបង់(បងប្អូនធំៗមិនចាំបាច់នៅផ្ទះមើលថែទាំប្អូននោះទេ) និងបង្កើនការយល់ដឹងរបស់ឪពុកម្តាយអំពីការអប់រំ។ យោងតាមការសិក្សាស្រាវជ្រាវមួយចំនួន *«ប្រសិនបើយើងចំណាយ ១ លើការមើលថែទាំកុមារតូច...ផ្តល់ផលមកវិញដល់១០ ឬក៏ច្រើនជាងនេះ...»*[203]។

យើងត្រូវបែងចែកឱ្យបានច្បាស់រវាងទស្សនទាន **ការអប់រំកុមារតូច** (ECE) (ការអប់រំផ្លូវការនៅសាលារដ្ឋ ឯកជន ឬមត្តេយ្យសិក្សាសហគមន៍) និង **ការគាំពារ និងអភិវឌ្ឍន៍កុមារតូច** (ECCD) ។ **ការគាំពារ និងអភិវឌ្ឍន៍កុមារតូច** (ECCD) រួមបញ្ចូលទាំងការអប់រំនៅតាមខ្នងផ្ទះ កម្មវិធីអប់រំមាតាបិតា[204] ដែលខុសគ្នាពីការចុះឈ្មោះចូលរៀននៅតាមសាលាក្នុងប្រព័ន្ធ។ ដូចនេះ យើងត្រូវផ្តោតលើសូចនាករនៃទិន្នន័យដែលបានបំបែកសម្រាប់ប្រភេទនីមួយៗនៃការគាំពារ និងអភិវឌ្ឍន៍កុមារតូច។ គោលបំណងនៃកម្មវិធីការអប់រំកុមារតូច គឺដើម្បីបង្កើនគុណភាព និងពង្រីកសេវាកម្មការថែទាំកុមារតូចសម្រាប់កុមារពីអាយុ ០ ដល់តិចជាង ៦ឆ្នាំ ជាពិសេស កុមារមកពីគ្រួសារក្រីក្រ កុមារជនជាតិដើមភាគតិច និងកុមារមានភាពពិការ និងជាមួយអាទិភាព ដែលត្រូវបានផ្តល់ឱ្យសហគមន៍ និងមត្តេយ្យសាលានៅតាមខ្នងផ្ទះ។ អាទិភាពត្រូវបានពង្រីកក្នុង

---

[202] UNDP (1989). The Report of the Kampuchea Needs Assessment Study. p. 150.
[203] "America's new aristocracy" (2015) The Economist, January 24th – 30th , p. 9.
[204] ដែលធ្វើហិរញ្ញប្បទានក្នុងក្របខណ្ឌ FTI/Global Partnership for Education (GPE)។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការចូលរៀនក្នុងកម្មវិធីការអប់រំកុមារតូច សម្រាប់កុមារអាយុចាប់ពី៣ ដល់ក្រោម៦ឆ្នាំ ដែលត្រូវបានដៅកំណត់ដល់ឃុំទាំងឡាយណា ដែលមានអត្រាពិតចូលរៀនថ្មីទាប និង អត្រាត្រួតថ្នាក់ខ្ពស់នៅបឋមសិក្សា។

ការសម្របសម្រួលរវាងក្រសួងរដ្ឋាភិបាល និងភ្នាក់ងារ គឺសំខាន់ណាស់ដើម្បី សម្រេចបាននូវគោលបំណងនៃគោលនយោបាយ ដែលពាក់ព័ន្ធនឹងការគាំពារនិង អភិវឌ្ឍកុមារតូច។ ដោយមានហេតុផលបែបនេះហើយ ទើបគណៈកម្មការជាតិគាំពារ និង អភិវឌ្ឍន៍កុមារតូច ត្រូវបានបង្កើតឡើងនៅខែមីនា ឆ្នាំ២០១៤ ដើម្បីឆ្លើយតបទៅនឹងបញ្ហា ទាំងឡាយណាដែលទាក់ទងនឹងការសម្របសម្រួលខាងផ្នែកថែរក្សា និងការពារកុមារតូច។

សមាមាត្រនៃស្ត្រីដែលបានសម្រាលកូននៅមណ្ឌលសុខភាពបានកើនឡើងពី ៣៩% ក្នុងឆ្នាំ២០០៨ ដល់៨០% ក្នុងឆ្នាំ២០១៣ ។ ទារកពីអាយុ ០-៦ខែ ត្រូវបានបំបៅ ដោយទឹកដោះម្ដាយទាំងស្រុង បានកើនឡើងពី១១,៤% ដល់ ៧៣,៥%។ តួលេខនេះ បង្ហាញឱ្យឃើញពីលទ្ធផល ក្នុងការកាត់បន្ថយដ៏ខ្លាំងក្លានៃអត្រាមរណភាពកុមារ និងទារក។ បើយោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅឆ្នាំ២០១០ (HDS) អត្រាមរណភាព កុមារធ្លាក់ចុះពី៩៥ ក្នុងឆ្នាំ២០០៥ ដល់៤៥ ក្នុងចំណោមកុមារ ១ ០០០នាក់នៅឆ្នាំ២០១០។ អត្រាមរណកុមារក្រោមអាយុ៥ឆ្នាំ បានកាត់បន្ថយពី១២៤ដល់ ៥៤ក្នុងកំណើតជីវិត ១ ០០០នាក់។ បើទោះជាយ៉ាងនេះក្ដី កង្វះសារធាតុចិញ្ចឹមនៅតែជាបញ្ហា។ សមាមាត្រនៃ កុមារអាយុចាប់ពី០ ដល់ ៥៩ខែ មានសភាពក្រិនមធ្យម និងខ្លាំង (កម្រិតខ្ពស់សម្រាប់ក្រុម អាយុនេះ) មានភាពទ្រឹងត្រឹមប្រហែល៤០%[205] ។ ក្មេងៗដែលក្រិនមិនអាចរៀនពូកែ ដោយសារតែប្រព័ន្ធការគិតក្នុងរយៈពេលយូរអង្វែងត្រូវបានបំផ្លាញ។ ដើម្បីដោះស្រាយ បញ្ហានេះ ការអន្តរាគមដែលមានការសម្របសម្រួលត្រូវការជាចាំបាច់ ដូចជាការអនុវត្តនូវ អនាម័យ និងភាពស្អាតឱ្យបានល្អប្រសើរឡើង ការផ្ដល់នូវអាហារដែលធ្វើឱ្យរឹងមាំ និង សារជាតិចិញ្ចឹមមីក្រូ។ល។

គោលនយោបាយជាតិស្ដីពី **ការគាំពារ និងអភិវឌ្ឍន៍កុមារតូច** (ECCD) ត្រូវ បានអនុម័តនៅឆ្នាំ២០១០។ ដោយផ្អែកលើគោលនយោបាយជាតិនេះ ផែនការសកម្មភាព អនុវត្តគោលនយោបាយគាំពារ និងអភិវឌ្ឍន៍កុមារតូចត្រូវបានរៀបចំឡើង និងអនុម័ត ដោយគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅខែសីហា ឆ្នាំ២០១៤ ដើម្បី លើកកម្ពស់ការឆ្លើយតបទាំងមូល និងអន្តរវិស័យ រួមបញ្ចូលទាំងសារធាតុចិញ្ចឹម អនាម័យ

[205] អត្រាកុមារក្រិននៅកម្ពុជាមានចំនួនខ្ពស់ជាងគេ ក្នុងចំណោមប្រទេសក្នុងតំបន់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអប់រំពីរភាសា បរិយាប័ន្ន និងដើម្បីបង្កើតប្រព័ន្ធជាតិអប់រំកុមារតូច ដែលគ្រប់គ្រងស្តង់ដានៃការរៀន កម្មវិធីបណ្តុះបណ្តាលគ្រូ លិខិតបទដ្ឋានបណ្តុះបណ្តាលគ្រូឧទ្ទេស ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងការប្រមូលទិន្នន័យ ។

ដើម្បីសម្រេចបាននូវគោលបំណងនៃគោលនយោបាយ ក្របខណ្ឌលទ្ធផលនៃផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ២០១៤-២០១៨ ត្រូវបានរៀបចំឡើងដើម្បី ៖ (១) តភ្ជាប់ចង្វាក់លទ្ធផល (គោលបំណង និងទិសដៅ) ជាមួយក្រុមគោលដៅ (កុមារ មាតា អ្នកផ្តល់សេវាកម្ម មន្ត្រីក្រសួង និងវិស័យឯកជន) និង (២) តម្រឹមគោលបំណង និងគោលដៅជាមួយនឹងយុទ្ធសាស្ត្រតែមួយ[206]។

ក្របខណ្ឌទូលំទូលាយនៃការពិនិត្យតាមដាននិងវាយតម្លៃផ្តោតលើលទ្ធផល[207] សម្រាប់**ការអប់រំកុមារតូច**នេះ តម្រូវឱ្យនាយកដ្ឋានអប់រំកុមារតូចប្រមូលព័ត៌មានស្តីពីវឌ្ឍនភាពកុមារចូលរៀន និងការផ្តល់សេវារបស់ការិយាល័យអប់រំក្នុងស្រុកទូទាំងប្រទេស។ ក្របខណ្ឌនេះត្រូវបានធ្វើការសាកល្បង ក្នុងខេត្តជាច្រើនក្នុងអំឡុងពេលអនុវត្តគម្រោងមុនពេលពង្រីកពេញប្រទេសក្នុងឆ្នាំ២០១៥។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំស្រុក និងសាលារៀនត្រូវរៀបចំផែនការតាមដាន នៅកម្រិតមន្ទីរ ស្រុក និងសាលារៀន។ ទិន្នន័យដែលបានប្រមូលរួច នឹងត្រូវបានប្រើដោយអ្នកពាក់ព័ន្ធដើម្បីរៀបចំផែនការការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពកាន់តែខ្លាំងឡើង។

ការពង្រីកនូវការអប់រំកុមារតូច ត្រូវបានគេមើលឃើញថាជាកត្តារួមចំណែកដ៏សំខាន់មួយ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្សក្នុងសាលាបឋមសិក្សា។ ចំនួនសាលាមត្តេយ្យបានកើនឡើងពី៨៧៤ ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ដល់៥ ៨០៧ ក្នុងឆ្នាំសិក្សា ២០១៤-២០១៥ ។ ក្នុងនោះសាលា ៣ ១៨៤ ជាមត្តេយ្យសាលារដ្ឋ (ដែលក្នុងនោះមានថ្នាក់មត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សា និងសាលាមត្តេយ្យដាច់ដោយឡែកចំនួន២១១) និង ៤០៣ ជាមត្តេយ្យសាលាឯកជន។ មត្តេយ្យសិក្សាសហគមន៍មានចំនួន ២ ២២០ ដែលផ្តល់សេវាអប់រំដល់កុមារប្រមាណ ២៤៩ ៩៩៩ នាក់ ។ កម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ និងជាក្រុមតាមផ្ទះ មាននៅតែក្នុងក្រុង ស្រុក ខណ្ឌ ចំនួន១៨១។ កម្មវិធីតាមខ្នងផ្ទះ

[206] **The ECCD goals** (1. All women are provided with care, health education services and nutrition during pregnancy. 2. All children have their births registred, are provided with care, regular health checkups, adequate immunization and nutrition, and early learning. 3. All young children are ready to start grade one at age six. 6. All young children from birth to school age shall enjoy physical, cognitive, mental and emotional development at their own home and centres which provide quality and sustainable health services, nutrition and education) **should be aligned with the strategies** (6. Expand health care and healing services for all infants. 7. Expand early childhood care and development services provision. and 5. Expand services and education on health care and nutrition).

[207] វាត្រូវបានបង្កើតឡើងដោយមានការគាំទ្របច្ចេកទេសពីធនាគារពិភពលោក។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គ្របដណ្ដប់មនុស្សចំនួន ៧៨ ៨៨៨ ដោយរួមទាំងមាតាបង្គោលចំនួន ២ ៦០០នាក់ និងកុមារចំនួន ៧៩ ២២៤ នាក់ ដែលក្នុងនោះមានកុមារីចំនួន ៥១,៥២% ។

ចំនួនកុមារអាយុចាប់ពី០-៦ឆ្នាំ ដែលបានចូលរៀនកើនឡើងពី ៥០ ៥៩៧ នាក់ ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ដល់ ៣២៨ ៧២៣ នាក់ ក្នុងឆ្នាំសិក្សា២០១៤-២០១៥ ដែលត្រូវជា១៧,៥៩% នៃចំនួនកុមារសរុបក្នុងក្រុមអាយុនេះ ក្នុងនោះ ៤៩,៥០ % ជាកុមារី។ ចំនួនកុមារចាប់ពីអាយុ ០-៣ ឆ្នាំ បានចូលរៀនក្នុងឆ្នាំសិក្សា ២០១៤-២០១៥ មានចំនួន ៣៧ ៦០៦ នាក់ ស្មើនឹង ៣,៧៨% នៃចំនួនកុមារសរុបក្នុងក្រុមអាយុនេះ។ ក្នុងនោះ ៥០,៣៣% ជាកុមារី។ ក្នុងឆ្នាំសិក្សា២០១៤-២០១៥ ចំនួនកុមារអាយុ៣ និង៤ឆ្នាំ បានចូលរៀនមានចំនួន ១២០ ៥៩៦ ដែលត្រូវជា ២០,៥០% នៃចំនួនកុមារសរុបសម្រាប់ក្រុមអាយុនេះ។ ក្នុងនោះ ៥០,៦៧% គឺជាកុមារី។

ក្នុងឆ្នាំសិក្សា ២០១៤-២០១៥ ចំនួនកុមារដែលមានអាយុ៥ឆ្នាំ កំពុងសិក្សាមានចំនួន ១៧០ ៥២១ នាក់ ឬ ៥៩,៩៣% នៃចំនួនសរុបក្នុងក្រុមអាយុនេះ។

ចាប់តាំងពីឆ្នាំ២០០៩ មក យើងបានឃើញថា ការចូលរៀនមានការរីកដុះដាលនៅការអប់រំកុមារតូចកម្រិតខ្ពស់ (អាយុ៥ឆ្នាំ) ដែលចេញពីចំណុចដំបូងមានចំនួន ៣៩,៨ % ក្នុងឆ្នាំសិក្សា២០០៩-២០១០ ដល់៦០% នៅឆ្នាំសិក្សា២០១៣-២០១៤។ ផែនការយុទ្ធ-សាស្ត្រវិស័យអប់រំ ២០១៤-២០១៨ នឹងឆ្ពោះទៅកាន់ការចូលរៀនឱ្យបានកាន់តែច្រើនរហូតដល់៨០% ។

ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ មានមត្តេយ្យសាលាចំនួន ៥ ៨០៧ នៅកម្ពុជា ក្នុងនោះមាន ៣ ១៨៤ ជាសាលារដ្ឋ (២១១ ជាមត្តេយ្យសាលាដាច់ដោយឡែក) មត្តេយ្យសាលាឯកជនចំនួន៤០៣ ចំណែកឯមត្តេយ្យសាលាសហគមន៍មានចំនួន ២ ២២០ ដែលផ្ដល់សេវាកម្មអប់រំដល់កុមារប្រហែល ២៤៩ ៩៩៩។ ការអប់រំកុមារតូចក្នុងទម្រង់តាមខ្នងផ្ទះ និងក្រុមតាមផ្ទះ មានតែនៅក្នុងខណ្ឌ ស្រុក និងក្រុង ចំនួន១៨១ប៉ុណ្ណោះ។ កម្មវិធីតាមផ្ទះ គ្របដណ្ដប់លើប្រជាជានចំនួន ៧៨ ៨៨៨ ដោយរួមទាំងមាតាបង្គោលចំនួន ២ ៦០០ និងកុមារចំនួន ៧៩ ២២៤ ដែលកុមារីមានចំនួន៥១,៥២% ។ ប្រព័ន្ធអប់រំកុមារតូចមិនទាន់ត្រូវបានបង្កើតពេញលេញនៅឡើយទេ។ នៅមានតម្រូវការដើម្បីបញ្ចប់ស្តង់ដានៃការរៀនកម្មវិធីបណ្ដុះបណ្ដាលគ្រូ លិខិតបទដ្ឋានគតិយុត្តអ្នកបណ្ដុះបណ្ដាលជាមូលដ្ឋានក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃការប្រមូលទិន្នន័យ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួនកុមារ អាយុពី ០-ក្រោម៦ឆ្នាំ ដែលបានចូលរៀនមានចំនួន ៣២៨ ៧២៣ នាក់ ដែលស្មើនឹង១៧,៥៩% នៃកុមារក្នុងក្រុមអាយុនេះ ដែលក្នុងនោះមាន៤៩,៥០% ជាកុមារី។ ចំនួនកុមារអាយុពី ០-ក្រោម ៣ឆ្នាំ មានចំនួន ៣៧ ៦០៦ នាក់ ដែលស្មើនឹង ៣,៧៨% នៃកុមារសរុបក្នុងក្រុមអាយុនេះ ដែលក្នុងនោះកុមារីមាន ៥០,៣៣%។ ចំនួនកុមារអាយុ៣ និង៤ឆ្នាំ មាន ១២០ ៥៩៦ នាក់ ដែលស្មើនឹង ២០,៥០% នៃកុមារក្នុងក្រុមអាយុនេះ ដែលក្នុងនោះមានកុមារីចំនួន៥០,៦៧%។ កុមារអាយុ៥ឆ្នាំបានកើនឡើងពី ៣២,៦% ក្នុងឆ្នាំសិក្សា ២០០៨-២០០៩ ដល់ ៥៩,៩៣% នៃកុមារក្នុងក្រុមអាយុនេះ ដែលកុមារីមានចំនួន ៤៨,៥៩% ឬ ១៧០ ៥២១ នាក់ (៤៩% រដ្ឋ ៩% ឯកជន ២៩% សហគមន៍ ១៨% ខ្ទង់ផ្ទះ) ។

បុគ្គលិកអប់រំនៅមត្តេយ្យសិក្សាមានចំនួន ១០ ១៥៨ ក្នុងនោះ ៩១,២៨% ជាស្ត្រី ដោយរួមទាំងបុគ្គលិកចំនួន ៤ ៧១៧ នៅមត្តេយ្យសាលារដ្ឋ ស្ត្រីមានចំនួន៩៥,៣៣% និងបុគ្គលិកចំនួន ២ ៩១៨ នៅមត្តេយ្យសាលាឯកជន ក្នុងនោះមានស្ត្រីចំនួន៧៩,១៩ % និងបុគ្គលិកចំនួន ២ ៥២៣ ទៀតធ្វើការនៅមត្តេយ្យសាលាសហគមន៍ ដែលបុគ្គលិកជាស្ត្រីមានចំនួន ៩៧,៧០ % ។

បន្ថែមលើនេះ គ្រូនៅកម្រិតអប់រំកុមារតូចមានប្រហែលត្រឹមតែ ២០០នាក់ ដែលត្រូវបានបណ្តុះបណ្តាលជារៀងរាល់ឆ្នាំ និងបន្ទប់រៀននៃសាលាមត្តេយ្យភាគច្រើនត្រូវបានសាងសង់ដោយមូលនិធិរបស់ Education Fast Tract Initiative (FTI) ។ ថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡាមានចំនួនតិចតួច ដែលត្រូវបានបម្រុងទុកដល់ការអប់រំកុមារតូច។ ដូចនេះ វាជាការចាំបាច់ ក្នុងការជំរុញការខិតខំប្រឹងប្រែងបង្កើនការចុះឈ្មោះចូលរៀននៅកម្រិតអប់រំកុមារតូច។

***សាលាមត្តេយ្យរដ្ឋ***ទាំងអស់ត្រូវទទួលបានថវិកាដំណើរការសាលារៀន ពីឆ្នាំ ២០១៤។ ក៏ប៉ុន្តែ ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ដែលផ្អែកលើសហគមន៍ ត្រូវបានផ្តល់ទៅឱ្យក្រុមប្រឹក្សាឃុំ ដែលទទួលខុសត្រូវរ៉ាប់រងរាល់ការចំណាយសម្រាប់សាលាដោយរួមបញ្ចូលទាំងប្រាក់បៀវត្សគ្រូផងដែរ។ ក្នុងការអនុវត្តវិញ ថវិកាដែលបម្រុងដោយក្រុមប្រឹក្សាឃុំសម្រាប់មត្តេយ្យសិក្សាសហគមន៍នៅមានកម្រិត និងមិនគ្រប់គ្រាន់ ហើយគ្រូបង្រៀនផ្លាស់ចេញច្រើន។

***សាលាមត្តេយ្យសហគមន៍*** ៖ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងកែលម្អហេដ្ឋារចនាសម្ពន្ធសាលា និងបន្ទប់រៀន ផ្តល់អាហារពេលព្រឹកដោយមិនបង់ថ្លៃនៅសាលាមួយចំនួន ដើម្បីធានានូវនិរន្តរភាពនៃការសិក្សា ។ ដើម្បីលើកកម្ពស់ការអភិវឌ្ឍ

របស់កុមារ ត្រូវមានគោលនយោបាយបង្កើនថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា និងលើកកម្ពស់មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាតាមផ្ទះ។ នៅចន្លោះឆ្នាំ ២០០៨ និង២០១២ សាលាមត្តេយ្យសិក្សាសហគមន៍ថ្មីប្រហែល៩៥០ត្រូវបានដំណើរការ ក្រោមគម្រោងរបស់ធនាគារពិភពលោកក្នុងខេត្តចំនួន១២ ដែលពីមុនទីកន្លែងទាំងនោះ ពុំមានការផ្តល់នូវសេវាកម្មអប់រំកុមារតូច។ លើសពីនេះ មជ្ឈមណ្ឌលធនធាន មត្តេយ្យសិក្សាថ្មីចំនួន២៥ ក្នុងខេត្ត២៤ ត្រូវបានកសាង ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាចំនួន១ ត្រូវបានបង្កើតឡើងនៅរាជធានីភ្នំពេញផងដែរ។

ការចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីមត្តេយ្យសិក្សាសហគមន៍ ក្នុងឆ្នាំ២០១០-២០១១ មានចំនួន៧ ១១៩ (កុមារី ៣ ៩០៧)។ តួលេខនេះកើនឡើងដល់ ៩ ១៣១ (ស្រី៤ ៦៩០) ក្នុងឆ្នាំ ២០១១-២០១២។ គ្រប់កម្មវិធីមត្តេយ្យសិក្សាសហគមន៍ទាំងអស់ទទួលបានសម្ភារអនាម័យ និងសម្ភារសិក្សា ដែលផ្តល់ដោយនាយកដ្ឋានអប់រំកុមារតូចនៃក្រសួងអប់រំ យុវជន និងកីឡា។ ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ត្រូវបានផ្តល់សិទ្ធិទៅដល់ក្រុមប្រឹក្សាឃុំ ដែលទទួលខុសត្រូវរ៉ាប់រងរាល់ការចំណាយសម្រាប់សាលារៀន រួមទាំងប្រាក់បៀវត្សរ៍គ្រូ។ តម្រូវការចាំបាច់មួយ គឺការអនុម័តស្តង់ដាសិក្សា កម្មវិធីបណ្តុះបណ្តាលគ្រូ លិខិតបទដ្ឋានគតិយុត្តិសម្រាប់បណ្តុះបណ្តាលគ្រូខេត្ត ក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃ និងការប្រមូលទិន្នន័យ។ គោលបំណងគឺដើម្បីបង្កើនចំនួនប្រជាជនកម្ពុជាវ័យក្មេងក្នុងឃុំដែលជួបការលំបាក ឱ្យទទួលបានអត្ថប្រយោជន៍ពីសេវាកម្មអប់រំកុមារតូចតាមរយៈការកសាងបន្ទប់រៀនមត្តេយ្យសិក្សាថ្មីជាផ្លូវការ និងការពង្រីកកម្មវិធីអប់រំកុមារតូចនៅខ្នងផ្ទះ និងនៅតាមសហគមន៍។

ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូត្រូវបានអនុវត្ត ដោយផ្តល់ការអប់រំផ្នែកគរុកោសល្យ និងការអភិវឌ្ឍសម្ភារបង្រៀន ដែលបានរៀបចំសម្រាប់កម្មវិធីសិក្សារបស់មត្តេយ្យសិក្សាសហគមន៍ សម្រាប់គ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន ៩៥០នាក់។ ក្នុងអំឡុងពេលអនុវត្តថវិកាសម្រាប់មត្តេយ្យសិក្សាសហគមន៍បានកើនឡើងយ៉ាងខ្លាំង នៅក្នុងថវិកាឃុំ ក្នុងក្របខណ្ឌវិមជ្ឈការ ហើយបច្ចុប្បន្នគ្រូមត្តេយ្យសិក្សាសហគមន៍បើកប្រាក់ខែពីក្រុមប្រឹក្សាឃុំ។

**កម្មវិធីអប់រំតាមខ្នងផ្ទះ** ៖ ចំនួនសរុបនៃកម្មវិធីនេះ មាន៩៥០ ដែលត្រូវបានដំណើរការក្នុងខេត្តចំនួន១០ ចន្លោះឆ្នាំ២០០៨ និង២០១២។ កម្មវិធីតាមខ្នងផ្ទះដំណើរការតាមរយៈបណ្តាញមាតាស្ម័គ្រចិត្ត ដឹកនាំដោយមាតាបង្គោលស្ម័គ្រចិត្ត។ មាតាបង្គោល



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សម្របសម្រួលក្រុមមាតាក្នុងសហគមន៍ ក្នុងតំបន់ដើម្បីផ្សព្វផ្សាយការអនុវត្តល្អៗក្នុងការមើលថែកុមារកម្រិតមត្តេយ្យសិក្សា។ មាតាបង្គោលត្រូវបានបណ្តុះបណ្តាលស្តីពីការមើលថែទាំនិងអភិវឌ្ឍន៍កុមារតូច ដោយផ្តោតលើសកម្មភាពប្រចាំថ្ងៃនៅផ្ទះ។ នាយកដ្ឋានអប់រំកុមារតូចបានធ្វើការជាមួយថ្នាក់ឃុំ ស្រុក និងខេត្ត ដើម្បីបង្កើតក្រុមបណ្តាញគ្រប់គ្រង និងបច្ចេកទេស ក្នុងការពិនិត្យ និងផ្តល់ការគាំទ្រដល់កម្មវិធីអប់រំមត្តេយ្យសិក្សានៅកម្រិតភូមិ។ ក្នុងឆ្នាំសិក្សា២០១០-២០១១ កម្មវិធីនេះបានទទួលកុមារប្រហែល ១៣ ៩០៣នាក់(កុមារី ៦ ៦៨៥នាក់) ។ ក្នុងឆ្នាំសិក្សា២០១១-២០១២ តួលេខនេះបានកើនឡើងពី១៥ ៩៧២នាក់ (កុមារី ៧ ៩១៥ នាក់)។ និន្នាការនេះបាននាំមកនូវសេវាកម្មអប់រំកុមារតូចដល់តំបន់ជនបទ និងដាច់ស្រយាល ដែលពីមុនការចូលរៀនថ្នាក់អប់រំកុមារតូចនៅតំបន់នោះមិនទាន់ត្រូវបានគិតគូរ។ កម្មវិធីអប់រំតាមខ្នងផ្ទះត្រូវបានពង្រីកដោយរដ្ឋាភិបាល ៖ ក្នុងឆ្នាំសិក្សា២០១១-២០១២ មានចំនួន ១ ៧៤៣។

នាយកដ្ឋានអប់រំកុមារតូចក៏បានរៀបចំឯកសារបណ្តុះបណ្តាលអប់រំកុមារតូចជាមួយនឹងការគាំទ្រផ្នែកបច្ចេកទេស ពីទីប្រឹក្សាបច្ចេកទេសអន្តរជាតិការអប់រំ និងអភិវឌ្ឍន៍កុមារតូច។ មាតិកានៃសៀវភៅនេះគឺផ្តោតទៅលើរបៀបនៃការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាល ដែលមានប្រសិទ្ធភាពសម្រាប់កម្មវិធីមត្តេយ្យសិក្សាជាផ្លូវការ។ នាយកដ្ឋានអប់រំកុមារតូច មានផែនការបង្កើតក្រុមគ្រូឧទ្ទេសនៅក្នុងនាយកដ្ឋានដើម្បីបណ្តុះបណ្តាលគ្រូឧទ្ទេសផ្សេងៗទៀត នៅថ្នាក់ខេត្ត ធានាឱ្យបាននូវគុណភាព និងសង្គតិភាពនៃផែនការបណ្តុះបណ្តាល។

ក្រសួងអប់រំ យុវជន និងកីឡា នឹងចាត់វិធានការដូចខាងក្រោម ៖

- ការបង្កើតប្រព័ន្ធជាតិនៃការអប់រំកុមារតូច (ស្តង់ដារការសិក្សា ឯកសារបណ្តុះបណ្តាលគ្រូ លិខិតបទដ្ឋានគតិយុត្តិក្នុងការបណ្តុះបណ្តាលគ្រូឧទ្ទេស ក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃ ការប្រមូលទិន្នន័យ ជាដើម)
- បង្កើនថវិការដ្ឋសម្រាប់ការអប់រំកុមារតូច ដោយរួមទាំងសម្រាប់ការគាំទ្រ/ការតាមដានសាលារៀន
- តម្រូវការសម្រាប់ក្រុមប្រឹក្សាឃុំ ដើម្បីធ្វើផែនការចំណាយថវិកាឱ្យបានសមស្រប ដើម្បីរ៉ាប់រងទាំងស្រុងនូវថ្លៃដំណើរការនៃមត្តេយ្យសិក្សាសហគមន៍ (ថវិកាប្រតិបត្តិការសាលារៀន និងប្រាក់បៀវត្សរ៍គ្រូបង្រៀន)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- បង្កើនចំនួនគ្រូមត្តេយ្យសិក្សាជាផ្លូវការ ដែលបានជ្រើសរើសប្រចាំឆ្នាំ
- យុទ្ធនាការចុះឈ្មោះចូលរៀនការអប់រំកុមារតូច និងការបង្កើនការចូលរួមពីមាតាបិតាក្នុងការអប់រំកុមារតូច
- បង្កើនការគាំទ្រ និងពិនិត្យតាមដាន និងផ្តល់ឱ្យដោយការិយាល័យអប់រំស្រុក
- ចំនួនទឹកប្រាក់ ការចំណាយទាន់ពេល និងភាពបត់បែនក្នុងការប្រើប្រាស់ថវិកាដំណើរការសាលារៀន

បើទោះជាយ៉ាងនេះក្តី ការចាប់ផ្តើមដ៏ល្អមួយមិនទាន់គ្រប់គ្រាន់នៅឡើយ។ ដូចដែលលោក Andreas Schleicher ប្រធានក្រុមការងារការអប់រំនៃអង្គការអភិវឌ្ឍសេដ្ឋកិច្ច និងសហប្រតិបត្តិការ (OECD) បានចង្អុលបង្ហាញថា ការវិនិយោគក្នុងវិស័យគាំពារ និងអភិវឌ្ឍន៍កុមារតូច *«មិនបានទទួលផលចំណេញក្នុងការសិក្សាដោយស្វ័យប្រវត្តិទេ លុះណាតែប្រព័ន្ធអប់រំផ្ទេរការវិនិយោគនេះទៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា»*[208]។

## ៤.២. ការអប់រំនៅបឋមសិក្សា

សេដ្ឋកិច្ចវិទូដែលសិក្សាពីអត្រាទទួលបានផលត្រឡប់នៃការអប់រំ មានទស្សនៈឯកភាពគ្នាថា ប្រទេសក្រីក្រដែលចាប់ផ្តើមពីមូលដ្ឋានធនធានមនុស្សកម្រិតទាបគួរតែវិនិយោគឱ្យបានច្រើននៅបឋមសិក្សា ពីព្រោះថាភស្តុតាងនៃអត្រាទទួលបានផលត្រឡប់គឺខ្ពស់ ចំពោះការអប់រំនៅកម្រិតបឋមសិក្សានេះ[209]។

អត្រាពិតនៃការសិក្សាបឋមសិក្សាកើនឡើងពី៨៧% នៅឆ្នាំសិក្សា ១៩៩៩-២០០០ ទៅដល់ ៩៨% នៅឆ្នាំសិក្សា២០១៤-២០១៥ ដោយសារកំណើនថវិកា។ លទ្ធផលនេះសម្រេចបាន ដោយសារតែការលុបបំបាត់ការបង់ប្រាក់បង់វិភាគទានចូលរៀននៅឆ្នាំ ២០០១ ការសាងសង់សាលាបឋមសិក្សានៅស្ទើរគ្រប់ភូមិ ការកែលម្អហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ជាពិសេស ទៅលើការសិក្សានៅបឋមសិក្សា(ថ្នាក់ទី១ដល់ទី៦)។ ចាប់តាំងពីឆ្នាំ១៩៩៩ កម្ពុជាបានចាប់ផ្តើមកម្មវិធីមួយ ដើម្បីបង្កើតសាលាបឋមសិក្សាឱ្យបាននៅគ្រប់ភូមិ។ រាជរដ្ឋាភិបាលបានអនុម័តកម្មវិធីសិក្សាជា

---

[208] "An hereditary meritocracy". The Economist. January 24th – 30th 2015. p. 19.

[209] Psacharopoulos and Patrinos (2004), Return to Investment in Education: A Futher Update, Education Econometrics, Vol. 12, No 2, August 2004.

កាតព្វកិច្ចចំនួន៦ឆ្នាំ និងបន្ទាប់មកទៀត បានពង្រីកកម្មវិធីនេះទៅដល់៩ឆ្នាំ។ ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក៏ដោយ ក៏ការទទួលបានការអប់រំជាមូលដ្ឋាន ពីថ្នាក់ទី១ ដល់ទី៩ ជារួមនៅតែមានកម្រិតទាប ហើយកម្ពុជាកំពុងប្រឈមនឹងបញ្ហាចម្បងក្នុងការសម្រេចឱ្យបានគោលដៅរបស់ខ្លួនក្នុងការអប់រំមូលដ្ឋានចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៩នៅឆ្នាំ២០១៥។ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានការកែលម្អ ប៉ុន្តែអត្រាបញ្ចប់ការសិក្សាសម្រេចបានត្រឹម៨០%។ ភាគច្រើននៃការកើនឡើងអត្រាពិតនៃការសិក្សាបានមក ដោយសារកំណើនពិតនៃសមាមាត្រកុមារដែលបានចូលរៀន ដែលភាគច្រើនគឺជាសិស្សដែលលើសអាយុជាជាងសិស្សដែលរៀនបានយូរ។

*រូបភាពទី៤ ៖ អត្រារួមនិងអត្រាពិតនៃការសិក្សានៅបឋមសិក្សា*




*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ចំនួនសាលាបឋមសិក្សា បានកើនឡើងពី ៥ ២៧៤ នៅឆ្នាំសិក្សា១៩៩៩-២០០០ ដល់ ៦ ៩៩៣ នៅឆ្នាំ សិក្សា២០១៤-២០១៥ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធរឹងមាំ ដោយបំពេញបានទាំងស្តង់ដាសុវត្ថិភាព និងអនាម័យ។ សាលាបឋមសិក្សាទាំងនេះមានសិស្សចំនួន ២,០៧លាននាក់ ដែលក្នុងនោះ សិស្សស្រីចំនួន ១,០២លាននាក់។ សាលាបឋមសិក្សាឯកជនមានចំនួន ២៤៣ មានសិស្សចំនួន ៥៤ ៨២២នាក់ ក្នុងនោះសិស្សស្រីមាន ៥០,២ %។ សាលារៀនចំនួន ៥ ០៦៨ បានក្លាយជាសាលាកុមារមេត្រីកម្រិតមធ្យម និងខ្ពស់ ដែលមានការកើនឡើងចំនួន ៨៨សាលា ឬ កើន ១,៧៧% ធៀបនឹងឆ្នាំសិក្សាមុន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាលាបឋមសិក្សាមិនគ្រប់កម្រិតមានចំនួន ៨១៦ ឬ១១,៦ % នៃចំនួនសាលាបឋមសិក្សាសរុប។ ចំនួនស្រុក ខណ្ឌ ដែលមានអត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សាយ៉ាងតិច ៨០% មានចំនួន១៣០ ក្នុងចំណោម១៩៤ ធៀបនឹងចំណុចដៅចំនួន១៥០ស្រុក។ លទ្ធផលនេះអាចសម្រេចទៅបាន ដោយសារការលុបបំបាត់ការបង់ប្រាក់ចូលរៀនក្នុងឆ្នាំ២០០១ ដែលបានធ្វើឱ្យអត្រាចូលរៀននៅបឋមសិក្សាក្នុងឆ្នាំ២០០១ និង២០០២ មានការកើនឡើង។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡាបន្តខិតខំប្រឹងប្រែង ដើម្បីបង្កើនលទ្ធភាពឱ្យកុមារទទួលបានការអប់រំនៅកម្រិតបឋមសិក្សា នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ចាប់ពីឆ្នាំ២០០១ ដល់ ឆ្នាំ២០១២ ចំនួនសាលារៀនបឋមសិក្សាបានកើនឡើងរហូតទៅដល់ ២០% (១ ១០៨ សាលារៀន)។ គិតត្រឹមឆ្នាំ២០០៤-២០០៥ អត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សាសម្រេចបានទាប (៤៦,៨%) តែបានកើនឡើងដល់ ៨០% ក្នុងឆ្នាំសិក្សា ២០១៤–២០១៥ ដែលបានបង្ហាញកាន់តែច្បាស់ថា ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំផ្តោតការយកចិត្តទុកដាក់ទៅលើទាំងបរិមាណ គុណភាព និងប្រសិទ្ធភាពនៃសេវាកម្មអប់រំផងដែរ។

*តារាងទី១៩ ៖ ចំនួនសាលារៀនតាមកម្រិតសិក្សា និងប្រភេទអ្នកផ្តល់សេវា*

| ភូមិសិក្សា | ១៩៩៣ | ២០០០ | ២០១០ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| **សាលាបឋមសិក្សា** | | | | | | |
| រដ្ឋ | ៤ ៦៩៣ | ៥ ៤៦៨ | ៦ ៧៦៧ | ៦ ៩៩៣ | ៧ ០៥១ | ៧ ០៨៥ |
| ឯកជន | N/A | N/A | ១២០ | ២៤៣ | ២៩៧ | ៣៥៧ |
| សរុប | ៤ ៦៩៣ | ៥ ៤៦៨ | ៦ ៨៨៧ | ៧ ២៣៦ | ៧ ៣៤៨ | ៧ ៤៤២ |
| **សាលាមធ្យមសិក្សាបឋមភូមិ** | | | | | | |
| រដ្ឋ | ៣៥៤ | ៣៦៧ | ១ ១៨៩ | ១ ២៤៤ | ១ ២៤៩ | ១ ២៥១ |
| ឯកជន | N/A | N/A | ១៥ | ៣៥ | ៤៦ | ៤៣ |
| សរុប | ៣៥៤ | ៣៦៧ | ១ ២០៤ | ១ ២៧៩ | ១ ២៩៥ | ១ ២៩៤ |
| **សាលាមធ្យមសិក្សាទុតិយភូមិ** | | | | | | |
| រដ្ឋ | ៨៩ | ១៥១ | ៤០៧ | ៤៤៤ | ៤៥៥ | ៤៦៣ |
| ឯកជន | N/A | N/A | ៣៦ | ៨៧ | ៨៧ | ១០៨ |
| សរុប | ៨៩ | ១៥១ | ៤៤៣ | ៥៣១ | ៥៤២ | ៥៧១ |

*ប្រភព ៖ ក្រសួងអយក (ឆ្នាំ២០១៦) ៖ ស្ថិតិ និងសូចនាករអប់រំ ឆ្នាំសិក្សា ២០១៥–២០១៦*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងបានដាក់ចេញបទបញ្ញាផ្ទៃក្នុងដើម្បីកែលម្អអត្រាឡើងថ្នាក់ និងបានវិនិយោគបន្ថែមទៀត ដើម្បីកែលម្អធាតុចូលផ្សេងទៀតដូចជា ការបំប៉នសមត្ថភាពរបស់គ្រូ និងការផ្តល់កាន់តែច្រើន និងការកែលម្អគុណភាពនៃសៀវភៅសិក្សាគោល។ ក្រសួងក៏បានអនុវត្តកំណែទម្រង់កម្មវិធីសិក្សាផងដែរ។ ចាប់ពីឆ្នាំ២០០១–២០០២ មករាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ធនធានបន្ថែមទៀតដល់សាលារៀន តាមរយៈថវិកាដំណើរការសាលារៀន សម្រាប់សកម្មភាពជាក់ស្តែងនានារបស់សាលា ក្នុងគោលបំណងកែលម្អគុណភាពអប់រំ។ ឆ្លើយតបទៅនឹងអន្តរាគមន៍ទាំងនេះ គិតត្រឹមឆ្នាំ២០១១–២០១២ អត្រាបញ្ចប់ការសិក្សាជាមធ្យម នៅកម្រិតបឋមសិក្សាទូទាំងប្រទេស បានកើនឡើងដល់ ៨៩,៧%។ ទន្ទឹមនឹងនេះដែរ អត្រាត្រួតថ្នាក់បានថយចុះពី១១% នៅឆ្នាំ២០០១ មកត្រឹម ៥,៨% នៅឆ្នាំសិក្សា២០១១-២០១២ ហើយអត្រាបោះបង់ការសិក្សាបានថយចុះពី១២% មកនៅត្រឹម ៨,៣% ក្នុងរយៈពេលដូចគ្នា។

*តារាងទី២០ ៖ ចំនួនសិស្សតាមកម្រិតសិក្សា និងប្រភេទអ្នកផ្តល់សេវា*

| ភូមិសិក្សា | ១៩៩៣ | ២០០០ | ២០១០ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| **សាលាបឋមសិក្សា** | | | | | | |
| រដ្ឋ | ១ ៦២១ ៦៨៥ | ២ ៩០៨ ១០៩ | ២ ១៩១ ១៩២ | ២ ០៧៣ ៨១១ | ២ ០១២ ១៧៥ | ២ ០១០ ៦៧៣ |
| ឯកជន | N/A | N/A | ៣៣ ០៧៥ | ៥៤ ៨២២ | ៧៣ ៧៩៤ | ៩៥ ២៣០ |
| សរុប | ១ ៦២១ ៦៨៥ | ២ ៩០៨ ១០៩ | ២ ២២៤ ២៦៧ | ២ ១២៨ ៦៣៣ | ២ ០៨៥ ៩៦៩ | ២ ១០៥ ៩០៣ |
| **សាលាមធ្យមសិក្សាបឋមភូមិ** | | | | | | |
| រដ្ឋ | ២២៤ ២៧៣ | ២៨៣ ៥៧៨ | ៥៦០ ៨៦៨ | ៥៣៨ ៦២៦ | ៥៤៦ ៨៦៤ | ៥៥៨ ៦២១ |
| ឯកជន | N/A | N/A | ១ ០៧៧ | ១ ៨២៨ | ៣ ៦១៥ | ២៨ ២៣៥ |
| សរុប | ២២៤ ២៧៣ | ២៨៣ ៥៧៨ | ៥៦១ ៩៤៥ | ៥៤០ ៤៥៤ | ៥៥០ ៤៧៩ | ៥៨៦ ៨៥៦ |
| **សាលាមធ្យមសិក្សាទុតិយភូមិ** | | | | | | |
| រដ្ឋ | ៦១ ៥០៦ | ១០៥ ០៨៦ | ៣៣៤ ៧៣៤ | ២៦៦ ២៩៣ | ២៦២ ០៧២ | ២៦៦ ៤៤៩ |
| ឯកជន | N/A | N/A | ១២ ៥៥៤ | ២៧ ៦៤៤ | ២៦ ៩៤០ | ៨ ៦៩១ |
| សរុប | ៦១ ៥០៦ | ១០៥ ០៨៦ | ៣៤៧ ២៨៨ | ២៩៣ ៩៣៧ | ២៨៩ ០១២ | ២៧៥ ១៤០ |

*ប្រភព ៖ ក្រសួងអយក (ឆ្នាំ២០១៦) ៖ ស្ថិតិ និងសូចនាករអប់រំ ឆ្នាំសិក្សា ២០១៥–២០១៦*

ប្រការនេះបានបង្ហាញឱ្យឃើញ នូវការកើនឡើងយ៉ាងខ្លាំងនៃអត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សា ចាប់តាំងពីឆ្នាំ២០០០។ គិតត្រឹមឆ្នាំសិក្សា ២០១៣-២០១៤ អត្រាពិត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃការសិក្សានៅកម្ពុជា នៅបឋមសិក្សាសម្រេចបាន៩៨% ពោលគឺជាការសម្រេចបាននូវសកលកម្មនៃការអប់រំបឋមសិក្សា។ សាលាបឋមសិក្សាចំនួន ៦ ៩៩៣ មានហេដ្ឋារចនាសម្ព័ន្ធសមស្រប ទាំងស្តង់ដាសុវត្ថិភាព និងអនាម័យ ដែលមានសិស្សចូលរៀន ២,០៧ លាននាក់ ក្នុងនោះសិស្សស្រី ១,០២លាន នាក់។

អត្រាពិតចូលរៀនថ្មី ៩៨,១% (ចំណុចដៅ ESP ១០០ %), ក្នុងនោះ ស្រី ៩៨,២ % ដែលក្នុងនោះអត្រាពិតចូលរៀនថ្មីសាលាឯកជន២,៨% ក្នុងនោះស្រី ២,៩ %។ អត្រាពិតនៃការសិក្សា ៩៨,២ % (ចំណុចដៅ ESP ៩៨%), ក្នុងនោះអត្រាពិតនៃការសិក្សាសាលាឯកជន ២,៦% ក្នុងនោះស្រី២,៧ភាគរយ។

អត្រាឡើងថ្នាក់ ៨៤,៧% ក្នុងនោះស្រី ៨៧,៦%។ អត្រាត្រួតថ្នាក់ ៤,៨% ស្រី ៤,១% (ចំណុចដៅ ESP ៥%)។ អត្រាបោះបង់ការសិក្សា១០,៥% ស្រី ៨,៣% (ចំណុចដៅ ESP ៥%)។ អត្រាឆ្លងភូមិសិក្សា ៧៦,៨% ស្រី ៨១,៤%។ អត្រាបញ្ចប់ការសិក្សា ៨៨,៩៤% ស្រី ៩០,១៩% (ចំណុចដៅ ESP ៥%)។

## ៤.៣. ការអប់រំនៅមធ្យមសិក្សា

ទោះបីជាមានបញ្ហាជាមួយនឹងអត្រាគង់វង្សនៅកម្រិតបឋមសិក្សា កម្ពុជាបច្ចុប្បន្ននេះ បានបង្វែរការយកចិត្តទុកដាក់របស់ខ្លួន ទៅដំណាក់កាលទីពីរនៃការអប់រំមូលដ្ឋាន គឺមធ្យមសិក្សាបឋមភូមិ។ ទាំងនេះត្រូវបានចាត់ទុកថាមានសារៈសំខាន់ដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនផលិតភាពតាមរយៈការអភិវឌ្ឍធនធានមនុស្ស។ ការអប់រំនៅមធ្យមសិក្សាបឋមភូមិ បង្កើតឱ្យមានការតភ្ជាប់រវាងការអប់រំនៅបឋមសិក្សា មធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

ការផ្លាស់ប្តូររចនាសម្ព័ន្ធការងារ មានន័យថាឱកាសការងារនឹងមានកាន់តែច្រើននៅក្នុងវិស័យបច្ចេកទេសថ្នាក់កណ្តាល ដូចជាពាណិជ្ជកម្ម រដ្ឋបាលនិង ប្រភេទនៃការផ្តល់សេវាកម្មផ្សេងទៀត។ ការងារបែបនេះតម្រូវឱ្យមានយ៉ាងហោចណាស់កម្រិតអប់រំនៅមធ្យមសិក្សាបឋមភូមិ។ ដំណាក់កាលបន្ទាប់នៃវិស័យសេវា និងកសិកម្មកម្រិតខ្ពស់ចាំបាច់ត្រូវការឱ្យកម្មករចេះអាន និងចេះសរសេរ ដើម្បីងាយស្រួលការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងធ្វើពិពិធកម្មឧស្សាហកម្ម។

ប្រព័ន្ធអប់រំមធ្យមសិក្សានៅកម្ពុជាទើបតែបានចាប់ផ្តើមឡើងប៉ុណ្ណោះ។ នៅពេលដែលការចូលរៀននៅបឋមសិក្សាកើនឡើង តម្រូវឱ្យពង្រីកការចូលរៀននៅមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ ដល់ទី៩ )។ ការផ្តល់ឱកាសដល់សិស្សក្រីក្រ ដើម្បីបានចូលរៀននៅ

មធ្យមសិក្សាទុតិយភូមិ ការបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស និងឧត្តមសិក្សាត្រូវកំណត់ថាជាវិស័យអាទិភាព សម្រាប់ការអភិវឌ្ឍគោលនយោបាយ។

គោលនយោបាយអប់រំនៅកម្រិត **មធ្យមសិក្សាបឋមភូមិ** ស្រដៀងគ្នាទៅនឹងគោលនយោបាយនៅកម្រិតបឋមសិក្សា គឺការកសាងសាលារៀន, ការបណ្តុះបណ្តាលគ្រូបង្រៀន, ការផ្តល់សម្ភារសម្រាប់ការរៀននិងបង្រៀន ការអភិវឌ្ឍកម្មវិធីសិក្សា និងការបើកផ្តល់ថវិកាដំណើរការសាលារៀន។ ក្រសួងយកចិត្តទុកដាក់ទៅលើការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា ការបង្រៀននិងរៀន ការគ្រប់គ្រង ការធ្វើផែនការ ការប្រឡង និងលទ្ធផលសិក្សារបស់សិស្ស។ ដូចនៅបឋមសិក្សាដែរ ការចូលរួមរបស់សហគមន៍ ការធ្វើផែនការនៅតាមសាលារៀនឱ្យមានប្រសិទ្ធភាព និងការគ្រប់គ្រង គឺជាធាតុផ្សំយ៉ាងសំខាន់នៃយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើនចំនួនសាលារដ្ឋបីដង ដោយផ្តល់ការអប់រំនៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅចន្លោះឆ្នាំសិក្សា១៩៩០-២០០០ និងឆ្នាំសិក្សា២០១៤-២០១៥។ ចំនួនអនុវិទ្យាល័យកើនពី៣៦៣ ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ទៅដល់ ១ ២៤៩ នៅឆ្នាំសិក្សា២០១៤-២០១៥ ដែលក្នុងនោះមានអនុវិទ្យាល័យចំនួន ៩២៣ បានក្លាយជាសាលាកុមារមេត្រី។ អនុវិទ្យាល័យទាំងនេះមានសិស្សចូលរៀនចំនួន ៥៣៨ ៦២៦ នាក់។ អត្រារួមនៃការសិក្សា ៥៥,៣% ស្រី ៥៦,២% ដែលក្នុងនោះ អត្រារួមនៃការសិក្សាសាលាឯកជន ១,៨% ស្រី ១,៨%។ អត្រាពិតនៃការសិក្សាស្មើនឹង ៣៧,៨% ក្នុងនោះស្រី ៤៩,៧១%។ អនុវិទ្យាល័យឯកជនមានចំនួន ៣៥ មានសិស្ស ១ ៨២៨នាក់ ក្នុងនោះស្រី ៥៦,៥ %។ អនុវិទ្យាល័យ ៨៤ %មានបង្គន់អនាម័យ និង៥១% មានទឹកស្អាតប្រើប្រាស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាពទី៥ ៖ អត្រានៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ*




*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

លទ្ធផលបានបង្ហាញថាមានការកើនឡើងនូវអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី ៧ ដល់ទី៩) ពី ២២,៩% ក្នុងឆ្នាំសិក្សា១៩៩០-២០០០ ដល់ ៥៥% នៅឆ្នាំសិក្សា២០១៤-២០១៥។ អត្រារួមនៃការសិក្សាសាលាឯកជន ១,៨% ស្រី ១,៨%។ នៅមធ្យមសិក្សាបឋមភូមិ អត្រាឡើងថ្នាក់ ៧៧,៤% (ស្រី ៧៨,៥%) ធៀបនឹងចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៨៨% (ស្រី ៨៨%)។ អត្រាត្រួតថ្នាក់១,៨% ធៀបនឹងចំណុចដៅ១,៥%។ អត្រាត្រួតថ្នាក់របស់សិស្សស្រីសម្រេចបានតាមចំណុចដៅ ១,២%។

អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនឡើងដល់២១,០% (ចំណុចដៅ១៣%) នៅឆ្នាំសិក្សា២០១៣-២០១៤ ពី១៨,៨% ក្នុងឆ្នាំសិក្សា២០០៩-២០១០។ ស្ថានភាពនេះមានភាពពាក់ព័ន្ធនឹងការថយចុះអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិដែលបានថយចុះពី៦០%នៅឆ្នាំសិក្សា២០០៧-២០០៨ មកនៅត្រឹម ៥៥% ក្នុងឆ្នាំសិក្សា២០១១-២០១២។ ការដោះស្រាយបញ្ហានេះ គឺជាអាទិ-ភាពមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ទោះបីជាយ៉ាងនេះក៏ដោយ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានត្រឹមតែ ៥៥% នេះបង្ហាញយ៉ាងច្បាស់ថា ក្រសួងអប់រំ យុវជន និងកីឡា ត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មអប់រំផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងឆ្នាំសិក្សា២០១៤-២០១៥ សិស្សចំនួន ១០៤ ៧០៨ នាក់ (៩៥,៥៨%) បានប្រឡងជាប់ថ្នាក់ទី៩ ដែលជាថ្នាក់បញ្ចប់នៃការអប់រំមូលដ្ឋាន។ ដើម្បីបង្កើនការចូលរៀន និងកាត់បន្ថយអត្រាបោះបង់ការសិក្សា អាហារូបករណ៍ត្រូវបានផ្តល់ទៅឱ្យសិស្សចំនួន ៥៤ ៧៩៨ នាក់។ មជ្ឈមណ្ឌលធនធាននៅតាមសាលារៀនត្រូវបានបង្កើតឡើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសិក្សា និងផ្តល់ឱកាសក្នុងការសិក្សា។

ចំនួនវិទ្យាល័យសម្រាប់ការអប់រំកម្រិត **មធ្យមសិក្សាទុតិយភូមិ** កើនឡើងពី ១៩០ ក្នុងឆ្នាំសិក្សា១៩៩៩-២០០០ ដល់ ៤៥៥ នៅឆ្នាំសិក្សា២០១៤-២០១៥ ក្នុងនោះមានសាលាធនធាន ២៩ ដែលស្ថិតនៅគ្រប់ទីរួមខេត្ត និងរាជធានី។ វិទ្យាល័យទាំងនេះមានសិស្ស ២៦៦ ២៩៣ នាក់ ក្នុងនោះស្រី ៤៧,៧០ %។ អត្រារួមនៃការសិក្សាកើនពី ១១,៦ % នៅឆ្នាំសិក្សា១៩៩៩-២០០០ ដល់ ២៦% នៅឆ្នាំសិក្សា២០១៣-២០១៤ ប៉ុន្តែអត្រាបោះបង់ការសិក្សាកើនឡើងដល់២៥ % ក្នុងឆ្នាំសិក្សា២០១៤-២០១៥ សិស្សស្រី២៥,៧ %។ អត្រារួមនៃការសិក្សាសាលាឯកជន១,១ % ស្រី១,១ %។ ចំនួនវិទ្យាល័យឯកជនមានចំនួន ៨៧ មានសិស្ស ២៧ ៦៤៤ នាក់ ស្រី៤៦,៩%។

*រូបភាពទី៦ ៖ អត្រានៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ*




*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

នៅឆ្នាំសិក្សា២០១៣-២០១៤ អត្រាឡើងថ្នាក់នៅមធ្យមសិក្សាទុតិយភូមិ ៦៨,៥% ក្នុងនោះស្រី ៧១,៤ %។ ចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៨៨,៨% ស្រី ៨៦,៨%។ អត្រាត្រួតថ្នាក់៤,០% ធៀបនឹងចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២,២% ស្រី៣,២% ធៀបនឹងចំណុចដៅ១,២%។ អត្រាបោះបង់ការសិក្សា ២៧,៥% ធៀបនឹងចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៩,០%។ ស្រី ២៥,៤% ធៀបនឹងចំណុចដៅ៨,០%។ នៅចន្លោះឆ្នាំសិក្សា២០០៧-២០០៨ និង២០១១-២០១២ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនឡើងពី២០% ដល់២៧,៨% ។ សិស្សចំនួន ៧៨ ៩២៥ នាក់ បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំសិក្សា២០១២-២០១៣ ស្មើនឹង៨៥%។

ដូច្នេះ នៅមធ្យមសិក្សា កម្ពុជានៅមិនទាន់អាចសម្រេចបាននូវចំណុចដៅជាយុទ្ធ-សាស្ត្រដូចនៅកម្រិតបឋមសិក្សាឡើយ។ ទោះបីជាមានការកើនឡើងទ្វេដងនៃចំនួនសាលារដ្ឋ ដែលផ្តល់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ នៅចន្លោះឆ្នាំសិក្សា២០០១-២០០២ និង២០១១-២០១២ ព្រមទាំងការកើនឡើងនៃអត្រាពិតនៃការសិក្សា (ពី១៩% នៅឆ្នាំសិក្សា២០០១-២០១២ ដល់ ៣៥,១% នៅឆ្នាំសិក្សា២០១១-២០១២ នៅមធ្យមសិក្សាបឋមភូមិ) អនុវិស័យនេះមិនទាន់សម្រេចបានចំណុចដៅនៃផែនការយុទ្ធសាស្ត្រអប់រំនៅឡើយ។ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ចំណុចដៅអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៥២% មធ្យមសិក្សាទុតិយភូមិ ២២% តែអត្រានេះសម្រេចបានតែ ៣២,១% នៅមធ្យមសិក្សាបឋមភូមិ និង ១៩,៦% នៅមធ្យមសិក្សាទុតិយភូមិ។ នៅពេលដែលអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនឡើងពី ២០% នៅឆ្នាំសិក្សា២០០៧-២០០៨ ដល់២៩% នៅឆ្នាំសិក្សា២០១១-២០១២ អត្រានៅមធ្យមសិក្សាបឋមភូមិបានធ្លាក់ពី ៦០%នៅឆ្នាំសិក្សា២០០៧-២០០៨ មកនៅត្រឹម៤៤%នៅឆ្នាំសិក្សា២០១១-២០១២ ។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ អាចបណ្តាលមកពីការកើនឡើងអត្រាបោះបង់ការសិក្សាពី១៨% នៅឆ្នាំសិក្សា២០០៩-២០១០ ដល់ ២១,៧% នៅឆ្នាំសិក្សា២០១១-២០១២។

កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល រួមមានគោលការណ៍ស្តីពីសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី ការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ ការអប់រំប្រកបដោយបរិយាប័ន្ន សម្រាប់កុមារពិការ យេនឌ័រ លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការចូលរួមក្នុងសកម្មភាពសង្គម។ បំណិនជីវិតជាមូលដ្ឋានមួយចំនួនត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា រួមមាន សិប្បកម្ម កសិកម្ម ពលរដ្ឋវិទ្យា ជំនាញដេរប៉ាក់ អនាម័យទូទៅ និងចំណីអាហារ ការចិញ្ចឹមសត្វ ជាងឈើ ការការពារបរិស្ថាន ការប្រយុទ្ធប្រឆាំងនឹងមេរោគនិងជំងឺអេដស៍



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រឿងញៀន និងការជួញដូរមនុស្ស ភាសាជនជាតិដើមភាគតិច និងការយល់ដឹងពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ(UXOs)។

បច្ចុប្បន្ននេះ បញ្ហាប្រឈមគឺត្រូវផ្តល់ការអប់រំដែលមានគុណភាព។ ចំណុចនេះត្រូវពឹងផ្អែកលើធាតុផ្សំទាំងបី៖ ធនធានហិរញ្ញវត្ថុ គោលនយោបាយអប់រំស៊ីជម្រៅ និងអភិបាលកិច្ចល្អ។ សមាសភាគទាំងបីដែលកំណត់ពីលទ្ធផលមានដូចជា ការផ្តល់គ្រូបង្រៀនឱ្យបានគ្រប់គ្រាន់ គុណភាពគ្រូនិងការបំពេញការងារ និងហេដ្ឋារចនាសម្ព័ន្ធសាលារៀននិងការគ្រប់គ្រង ។

ក្រសួងអប់រំ យុវជន និងកីឡាក៏បានផ្តល់ការអប់រំបច្ចេកទេសដល់សិស្សចំនួន ៣៩៥នាក់ នៅវិទ្យាល័យបច្ចេកទេសចំនួន៥។ នៅកម្រិតមធ្យមសិក្សា គោលនយោបាយគឺដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ តាមរយៈការបង្រៀនជំនាញងាយៗ ការអនុវត្តកម្មវិធីសិក្សាមានលក្ខណៈទន់ភ្លន់ ដែលអាចឱ្យសិស្សមកពីថ្នាក់ទី១១ និង១២ ជ្រើសរើសយកមុខវិជ្ជា ទៅតាមសមត្ថភាពរបស់ខ្លួន ៖ វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។ ការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សាបានធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ខណៈពេលដែលក្របខណ្ឌពិនិត្យតាមដាន បានរួមចំណែកដល់ការកែលម្អគុណភាពនៃការបង្រៀននិងការរៀន។ ការពិនិត្យឡើងវិញនៃកម្មវិធីសិក្សានេះកំពុងបន្តធ្វើ ខណៈពេលដែលមានការខិតខំប្រឹងប្រែង ក្នុងការបោះពុម្ពសៀវភៅបន្ថែមទៀត និងបង្កើតស្តង់ដាអប្បបរមាដើម្បីលើកកម្ពស់គុណភាព។

ទោះជាយ៉ាងណា បញ្ហាសមធម៌នៃការទទួលបានការអប់រំ នៅតែជាបញ្ហាចោទធ្ងន់ធ្ងរនៅកម្ពុជាដែលចាំបាច់ត្រូវមានកាត់បន្ថយបន្ទុកចំណាយពីគ្រួសារក្រីក្រលើការអប់រំ ដើម្បីកែលម្អគុណភាពនៃការផ្តល់សេវានៅសាលារៀន និងផ្តល់ការឧបត្ថម្ភដល់សិស្សដែលចេញមកពីគ្រួសារក្រីក្រ។

បញ្ហាដែលកុមារជាច្រើនមិនអាចបន្តការសិក្សាទៅមធ្យមសិក្សាទុតិយភូមិ បន្ទាប់ពីបញ្ចប់ការសិក្សានៅបឋមសិក្សា បង្ហាញថាការពង្រីកកាតព្វកិច្ចអប់រំរយៈប្រាំបួនឆ្នាំ គឺជាបញ្ហាប្រឈមយ៉ាងពិតប្រាកដ។ ការសិក្សាបានបង្ហាញថា កុមារដែលមានអាយុពី១៣ ដល់ ១៥ឆ្នាំ ដែលមិនបានចុះឈ្មោះចូលរៀន បានបោះបង់ការសិក្សា ដោយសារហេតុផលហិរញ្ញវត្ថុ ព្រោះពួកគេមិនមានលទ្ធភាពចំណាយ ហើយសិស្សផ្សេងទៀតត្រូវធ្វើការដើម្បីរកប្រាក់ចិញ្ចឹមជីវិត។ ការសិក្សាថ្មីនេះ ហាក់ដូចជាបានបង្ហាញថា បច្ចុប្បន្ននេះ អត្រាទទួល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផលនៅបឋមសិក្សានៅទាបជាងអត្រានៅក្រោយបឋមសិក្សា (Colclough, Kingdonនិង Patrinos 2009) ។

ទោះជាយ៉ាងណា គុណភាពនៃការអប់រំ គឺនៅទាបជាងបណ្តាប្រទេសក្នុងអាស៊ានមួយចំនួន។ គុណភាពនៃការអប់រំត្រូវរងផលប៉ះពាល់ដោយសារគ្រូទទួលបានការបណ្តុះ-បណ្តាលមិនគ្រប់គ្រាន់ អវត្តមានគ្រូបង្រៀនច្រើននៅតំបន់ជនបទ ការផ្តោតលើការរៀនបែបទន្ទេញ សៀវភៅសិក្សាគោលមិនគ្រប់គ្រាន់ អគារសិក្សាដែលមានគុណភាពអន់ ការខ្វះបង្គន់អនាម័យប្រើប្រាស់ និងទឹកស្អាតសម្រាប់ប្រើប្រាស់។

លើសពីនេះទៀត ប្រាក់ខែគ្រូមានកម្រិតទាប ទាបជាងបណ្តាប្រទេសមួយចំនួន។ រដ្ឋាភិបាលបានខិតខំដំឡើងប្រាក់បៀវត្ស តាមរយៈការផ្តល់ជូនប្រាក់ឧបត្ថម្ភបន្ថែមទៅលើកម្រិតសញ្ញាបត្រ និងប្រាក់ឧបត្ថម្ភសម្រាប់តំបន់ដាច់ស្រយាល។

ជាការឆ្លើយតបទៅនឹងការរកឃើញនូវចំណុចខ្វះខាតរបស់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការធ្វើតេស្តសមត្ថភាព ដើម្បីធានាថាគ្រូបង្រៀនត្រូវបានវាយតម្លៃយ៉ាងហ្មត់ចត់ មុនពេលទទួលបានវិញ្ញាបនបត្រ។ គុណភាពនៃប្រព័ន្ធអប់រំពឹងលើកត្តាបីយ៉ាង៖ ធនធានហិរញ្ញវត្ថុ គោលនយោបាយ និងអភិបាលកិច្ច។ កត្តាទាំងបីនេះ នឹងកំណត់លទ្ធផលរយៈមធ្យមមានដូចជា មានគ្រូគ្រប់គ្រាន់ គ្រូមានគុណភាពនិងការបំពេញការងារ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការគ្រប់គ្រង។

ចំណែកឯវិធីសាស្ត្រក្នុងការបង្រៀន ទោះបីជាក្រសួងអប់រំ យុវជន និងកីឡា បានលើកទឹកចិត្តឱ្យបញ្ចូលបច្ចេកទេសបង្រៀន ដែលមានលក្ខណៈច្នៃប្រឌិតថ្មីចូលទៅក្នុងមេរៀន «គ្រូជាច្រើននៅតែប្រើប្រាស់ពេលវេលាជាច្រើនដើម្បីសូត្រមេរៀនឱ្យសិស្សស្តាប់ និងសង្ខេបខ្លឹមសារមេរៀនឱ្យសិស្ស»។

## ៤.៤. ការអប់រំប្រកបដោយបរិយាប័ន្ន

ការអប់រំប្រកបដោយបរិយាប័ន្ន មានន័យថា «...*សាលារៀនគួរតែដាក់បញ្ចូលកុមារទាំងអស់ដោយមិនគិតពីរូបរាងកាយ ប្រាជ្ញាស្មារតី សង្គម អារម្មណ៍ ភាសា ឬក៏ស្ថានភាពផ្សេងៗទៀត។ រួមមាន៖ កុមារពិការ និងកុមារដើរសុំទាន កុមាររស់នៅតាមចិញ្ចើមថ្នល់ និងកុមារធ្វើការ កុមារមកពីតំបន់ដាច់*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ស្រយាល និងកុមារពនេចរ កុមារជនជាតិដើមភាគតិច និងកុមារមកពីតំបន់ជួបការលំបាក ឬតំបន់/ក្រុមទីទ័លក្រ»*[210]។

ការអប់រំប្រកបដោយបរិយាប័ន្ន គឺជាសមាសធាតុដ៏គន្លឹះដើម្បីធានាថា«*ការចូលរៀនប្រកបដោយសមធម៌ សម្រាប់កុមារទាំងអស់នៅបឋមសិក្សា រួមទាំងក្រុមទីទ័លក្រ ដូចជាកុមារពិការ កុមារជនជាតិដើមភាគតិច កុមារពាក់ព័ន្ធពលកម្ម។ល។*» នៅពេលដែលកម្ពុជាសម្រេចបានអត្រាពិតនៃការសិក្សានៅបឋមសិក្សា៩៧% (៩៨,៥% រួមទាំងសាលាឯកជនផងដែរ) តម្រូវការសង្កត់ធ្ងន់ទៅលើការធានាការចូលរៀនសម្រាប់កុមារជួបការលំបាកដែលនៅសេសសល់ នៅមិនទាន់បានចុះឈ្មោះចូលរៀន ឬកុមារបោះបង់ការសិក្សាពីសាលាបឋមសិក្សា។

នៅក្នុងបរិបទនៃប្រទេសកម្ពុជា ការអប់រំប្រកបដោយបរិយាប័ន្នមានកម្មវិធីដូចតទៅ ៖ ការអប់រំសម្រាប់ (១)កុមារពិការ (២)ការអប់រំពីរភាសា (BE) សម្រាប់កុមារជនជាតិដើមភាគតិច និង (៣)កម្មវិធីថ្នាក់ពន្លឿន (AL) សម្រាប់កុមារលើសអាយុ។ នៅថ្នាក់ជាតិ ការិយាល័យអប់រំពិសេសត្រូវបានបង្កើតឡើងនៅនាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ប៉ុន្តែមិនទាន់មាននៅនាយកដ្ឋានមត្តេយ្យសិក្សានិងឧត្តមសិក្សាទេ។ នៅថ្នាក់ក្រោមជាតិ មានក្រុមការងារថ្នាក់ខេត្ត សម្រាប់កុមារពិការ ការអប់រំពីរភាសា និងថ្នាក់ពន្លឿន (AL) និងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT)។ នៅឆ្នាំ ២០១៣ ថវិកាប្រមាណ ៣៦លានដុល្លារអាមេរិក ត្រូវបានបែងចែកសម្រាប់ការអប់រំបរិយាប័ន្ន (AOP/PED) ក្នុងនោះថវិកាចំនួន ១១លានដុល្លារជាបដិភាគរបស់រាជរដ្ឋាភិបាល។ ថវិកាអប់រំបរិយាប័ន្នរបស់រដ្ឋមានតិចជាង ១% នៃថវិកាកម្មវិធី(PB) ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់នាយកដ្ឋានបឋមសិក្សា ដែលបានបែងចែកសម្រាប់កុមារពិការ នៅពេលដែលគ្មានថវិកាកម្មវិធី(PB) សម្រាប់ការអប់រំពីរភាសា(BE) និង ថ្នាក់ពន្លឿន(AL)។

### ៤.៤.១. ការអប់រំសម្រាប់កុមារពិការ

**ការអប់រំសម្រាប់កុមារពិការ** ត្រូវបានចែងនៅក្នុងគោលនយោបាយ និងផែនការមេស្តីពីការអប់រំសម្រាប់កុមារពិការ ដែលបានអនុម័តនៅក្នុងឆ្នាំ២០០៩។ ការអប់រំបរិយាប័ន្នបានដាក់បញ្ចូលទៅក្នុងគោលនយោបាយសាលាកុមារមេត្រី និងផែនការមេសម្រាប់ការអប់រំមូលដ្ឋាន(ថ្នាក់ទី១ ដល់ទី៩)។ វិធីសាស្ត្រក្នុងការអប់រំបរិយាប័ន្នកម្រិតអប់រំមូលដ្ឋាន ត្រូវបានបញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ(PRESET) នៅសាលាគរុកោសល្យខេត្ត–ក្រុងចំនួន ១៨ និងបានអនុវត្តនៅក្នុងវគ្គវិក្រឹតការ (INSET) នៅក្នុងស្រុក

[210] The Salamanca Statement and Framework for Action on Special Needs Education.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាង២២ ស្រុក ក្នុងខេត្តចំនួន១៧។ ដើម្បីអនុវត្តគម្រោងនេះ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការជាមួយដៃគូដូចជាមូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ, HI, CRS, Krousar Thmey, AEAI, Caritas, Czech Republic, Rabbit School, UNICEF, Fred Hollow Foundation (FHF) និង WV។

ការពិនិត្យភាពពិការដំបូងរបស់កុមារក្នុងសាលា និងកុមារក្រៅសាលា ៖ ចាប់ពីខែកញ្ញា ឆ្នាំ២០១១ ដល់ខែមេសា ឆ្នាំ២០១២ ទិន្នន័យត្រូវបានប្រមូលទៅលើកុមារ ៩៩ ២៨៣ នាក់ ដែលមានអាយុចាប់ពី២ ដល់ ១៧ឆ្នាំ មកពីគ្រួសារចំនួន ២០ ៨១៥ ។ គ្រប់កុមារដែលមានអាយុចាប់ពី ២ ដល់ ៩ឆ្នាំ បានធ្វើតេស្តវិជ្ជមាន ដោយប្រើឧបករណ៍សំណួរចំនួន ១០ របស់អង្គការសុខភាពពិភពលោក ដើម្បីការវាយតម្លៃសុខភាព។ គោលបំណងនៃការសិក្សាគឺដើម្បី៖ (១) កំណត់ចំនួនកុមារក្រៅសាលា ឬក៏កុមារដែលងាយបោះបង់ការសិក្សា និងរកមូលហេតុរបស់វា (២) ប្រើប្រាស់ព័ត៌មានដែលទទួលបាន ដើម្បីបង្កើតគំរូប្រតិបត្តិការមួយសម្រាប់ការចុះឈ្មោះកុមារទាំងអស់ចូលរៀន ដើម្បីសម្រេចឱ្យបានគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា។

ទោះបីជាយ៉ាងណាក៏ដោយ ក្រសួងអប់រំ យុវជន និងកីឡាប្រឈមនឹងបញ្ហាមួយចំនួន ៖ ខ្វះទិន្នន័យស្តីពីកុមារពិការដែលគួរឱ្យទុកចិត្តបាន, ប្រព័ន្ធទិន្នន័យ EMIS មិនអាចធ្វើចំណាត់ថ្នាក់កម្រិត និងប្រភេទផ្សេងៗគ្នានៃពិការភាព, សមត្ថភាព និងបទពិសោធមានកម្រិតនៅក្នុងផ្នែកពិការភាពនៅក្នុងក្រសួង, កង្វះសេវាពិនិត្យសុខភាពនៅតាមសាលារៀន, កង្វះម៉ូដែលនៃការអប់រំប្រកបដោយចីរភាព ដែលអាចពង្រីកវិសាលភាព និងអាចបង់ប្រាក់បាន, ថវិកានៅមានកម្រិតសម្រាប់ការពង្រីកទូទាំងប្រទេស មិនគ្រាន់តែសម្រាប់ការបណ្តុះបណ្តាលគ្រូនិងពិនិត្យតាមដាន ប៉ុន្តែថែមទាំងសម្រាប់ការផ្តល់សេវានៅតាមសាលារៀនថែមទៀត។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ថវិកាសម្រាប់ការអប់រំកុមារពិការគួរតែត្រូវបង្កើន និងទិន្នន័យនៃកុមារពិការត្រូវតែបោះពុម្ពផ្សាយតាមរយៈ EMIS ដោយមានបំបែកលម្អិតតាមអាយុ និងប្រភេទ។

### ៤.៤.២. ការអប់រំពហុភាសា (MLE) សម្រាប់ជនជាតិដើមភាគតិច

ដោយសារមានក្រុមជនជាតិដើមភាគតិចចំនួន២៤ ដូច្នេះក៏ត្រូវមានភាសាជនជាតិចំនួន២៤ ដែរនៅកម្ពុជា ដែលវាបាននាំទៅរកគម្លាតក្នុងការចុះឈ្មោះចូលរៀន និងអត្រាបោះបង់ការសិក្សានៅក្នុងស្រុក ដែលមានជនជាតិដើមភាគតិចរស់នៅ។ ដូច្នេះ ការអប់រំពីរភាសា (ជាភាសាកំណើត និងជាភាសាខ្មែរ) គឺជាយុទ្ធសាស្ត្រមួយដ៏សំខាន់ដើម្បីសម្រេច

បានចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ដើម្បីធានាបាននូវសមធម៌នៃការចូលរៀនកម្រិតបឋមសិក្សា ដោយសារការអប់រំពីរភាសាត្រូវអនុវត្តនៅក្នុងសាលាបឋមសិក្សា និងសាលាមត្តេយ្យ ដើម្បីអាចឱ្យសិស្សមកពីសហគមន៍ជនជាតិដើមភាគតិចទទួលបាននូវមូលដ្ឋានដ៏រឹងមាំមួយ សម្រាប់ការសិក្សារៀនសូត្រ។ ការសិក្សា ស្រាវជ្រាវបង្ហាញថា សិស្សរៀនចេះចាំបានល្អ ប្រសិនបើរៀនជាភាសាដែលប្រើនៅផ្ទះ។ ការយល់ដឹងរបស់កុមារីកលូតលាស់បានលឿន ប្រសិនបើផ្សារភ្ជាប់គំនិតទៅនឹងបញ្ញត្តិ ដែលប្រើប្រាស់នៅឯផ្ទះ[211]។

**កម្មវិធីអប់រំពហុភាសា**ត្រូវបានដាក់ឱ្យដំណើរការ ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ នៅកម្ពុជា និងការអប់រំពីរភាសានៅកម្រិតបឋមសិក្សាត្រូវបានផ្ដួចផ្ដើមដោយអង្គការ CARE ក្នុងឆ្នាំ២០០២។ កម្មវិធីនេះ ឈរលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ជំនាញជាច្រើនដែលបានរៀនជាភាសាដើមកំណើតអាចត្រូវបានផ្ទេរយ៉ាងងាយស្រួលទៅភាសាទីពីរ។ ដូច្នេះ ចាំបាច់ត្រូវឱ្យកុមារកាន់តែច្រើនបានចូលរៀន និងពង្រឹងគុណភាពនៃការសិក្សាជាភាសាកំណើត ដែលខុសពីភាសាជាតិផ្លូវការ។

សេចក្ដីណែនាំស្ដីពីការអនុវត្តកម្មវិធីពហុភាសា សម្រាប់កុមារជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាបបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា នៅខែសីហា ឆ្នាំ២០១០ ដែលបានកំណត់សកម្មភាព ដើម្បីពង្រីកការអប់រំពីរភាសា ដោយផ្អែកលើម៉ូដែលមួយ ដែលបានរៀបចំ និងសាកល្បងដោយអង្គការ CARE។ ដើម្បីធានានិរន្តភាព ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើសមាហរណកម្មសាលារៀនសហគមន៍ពហុភាសាទាំងនេះទៅក្នុងប្រព័ន្ធសាលារៀនរដ្ឋ ជាសាលាឧបសម្ពន្ធ ដូច្នេះហើយសិស្សអាចទទួលប្រយោជន៍ពីកម្មវិធីអាហារូបករណ៍។ សមាសភាគដ៏សំខាន់នៃម៉ូដែលនេះគឺជាការបង្កើតឡើងឱ្យមានគណៈកម្មការគ្រប់គ្រងសាលារៀនសហគមន៍(CSMCs) ការអនុម័តប្រតិទិនសិក្សាឆ្លាស់វេនជាមួយសកម្មភាពដាំដុះ និងការជ្រើសរើសការបណ្ដុះបណ្ដាល និងការងាររបស់អ្នកប្រើប្រាស់ភាសាមូលដ្ឋានក៏ដូចជាគ្រូបង្រៀន។ ការអប់រំពហុភាសាត្រូវបានអនុវត្តតាមប្រកាសដែលបានឯកភាព និងអនុម័តនៅឆ្នាំ២០១៣ និងផែនការសកម្មភាពជាតិស្ដីពីការអប់រំពីរភាសា ដែលបានអនុម័តនៅឆ្នាំ២០១៥។

[211] Comini, D. (2016). Remarks at the Official Launch of Multilingual Education National Action Plan. Kratie, 1 March 2016.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងទី២១ ៖ កម្មវិធីសិក្សាពហុភាសា*

| | |
|---|---|
| **ថ្នាក់ទី៤**<br>ភាសាជនជាតិ -0% | ភាសាខ្មែរ -100% |
| **ថ្នាក់ទី៣**<br>ភាសាជនជាតិ -30%<br>• 15% ការសិក្សាភាសា<br>• 15% ការសិក្សាសង្គម | ភាសាខ្មែរ-70%<br>• 15% គណិតវិទ្យា<br>• 45% ការសិក្សាភាសា<br>• 10% ការសិក្សាសង្គម |
| **ថ្នាក់ទី២**<br>ភាសាជនជាតិ -60%<br>• 15% គណិតវិទ្យា<br>• 35% ការសិក្សាសង្គម<br>• 30% ការសិក្សាភាសា | ភាសាខ្មែរ-40%<br>• 25% ការសិក្សាភាសា<br>• 15% គណិតវិទ្យា |
| **ថ្នាក់ទី១**<br>ភាសាជនជាតិ -80%<br>• 15%គណិតវិទ្យា<br>• 35% ការសិក្សាសង្គម<br>• 30% ការសិក្សាភាសា | ភាសាខ្មែរ -20% (ផ្ទាល់មាត់) |
| មត្តេយ្យសិក្សា, កុមារអាយុ៥ឆ្នាំ៖ ភាសានៅផ្ទះ | មេរៀនភាសាខ្មែរសម្រាប់រយៈពេល ២០ នាទី រៀងរាល់ថ្ងៃ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា (២០១៥)៖* MENAP ភ្នំពេញ

ចាប់ពីការដាក់ឱ្យអនុវត្តសាលាពីរភាសាចំនួន ៦កន្លែង និងសិស្សចំនួន ២៧៨ នាក់ នៅឆ្នាំ២០០៣ ឥឡូវនេះកម្ពុជាបានអនុវត្តការអប់រំពីរភាសា នៅតាមសាលាបឋមសិក្សារដ្ឋចំនួន៤៣ [212] កន្លែង និងសាលារៀនសហគមន៍ចំនួន១១ កន្លែង ក្នុងខេត្តចំនួន៥

[212] ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥ របាយការណ៍ការអប់រំពហុភាសា ខែមករា ឆ្នាំ២០១៥



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(មណ្ឌលគិរី[213] ក្រចេះ[214] រតនគិរី[215] ស្ទឹងត្រែង[216] និងព្រះវិហារ[217])។ គ្រូក្របខណ្ឌរដ្ឋ និងគ្រូសហគមន៍ចំនួន ២០០នាក់ [218] បានទទួលការបណ្តុះបណ្តាល និងកុមារជនជាតិដើមភាគតិចចំនួន ៥ ០០០ នាក់ បានចុះឈ្មោះចូលរៀនក្នុងកម្មវិធីនេះ។ កម្មវិធីអប់រំពហុភាសាត្រូវបានអនុវត្តក្នុងកិច្ចសហការជាមួយអង្គការ UNICEF, CARE, ICC និង SIL។ ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តកម្មវិធីសិក្សា និងសៀវភៅសិក្សាចំនួន៧៨ សម្រាប់ការអប់រំពីរភាសា។ ការបង្រៀនថ្នាក់គួបក៏ត្រូវបានអនុវត្តផងដែរ សម្រាប់សាលារៀនមួយចំនួន។ ភាសាជនជាតិទំពួង គ្រឹង ព្រៅ និងការ៉ែតត្រូវបានបង្រៀននៅខេត្តរតនគិរី ភាសាជនជាតិព្នងបង្រៀននៅខេត្តមណ្ឌលគិរី ភាសាជនជាតិការ៉ែតបង្រៀននៅខេត្តស្ទឹងត្រែង។ ភាសាជនជាតិចារ៉ាយ និងគួយនឹងត្រូវបានបន្ថែមនាពេលអនាគត។

បញ្ហាប្រឈមរួមមាន ៖ កង្វះគ្រូបង្រៀនពហុភាសាមានគុណភាព កង្វះសម្ភារបង្រៀន និងកម្មវិធីសិក្សាមិនសមស្រប កុមារជនជាតិភាគតិចមួយចំនួនប៉ុណ្ណោះបានចូលរួមកម្មវិធីអប់រំពហុភាសា និងមានការដាក់កម្រិតអាយុសម្រាប់ការប្រឡងចូលរៀននៅសាលាគរុកោសល្យភូមិភាគ សម្រាប់ខេត្តភូមិភាគឦសាន។ អត្រាបោះបង់ការសិក្សាសម្រាប់ការអប់រំពហុភាសាមានកម្រិតខ្ពស់ ដោយសារតែអត្រាភាពក្រីក្រខ្ពស់ និង ចម្ងាយផ្លូវឆ្ងាយ។

ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូបង្រៀន ក្រសួងអាចពិចារណាបង្កើនការកំណត់អាយុគ្រូពី២៥ ទៅ៣០ឆ្នាំ និងបន្ធូរបន្ថយលក្ខខណ្ឌជ្រើសរើស[219]សម្រាប់គ្រូពហុភាសាប្រឡងចូលរៀននៅសាលាគរុកោសល្យខេត្ត ការបង្កើតតម្រូវការពិសេសសម្រាប់គ្រូជាប់កិច្ចសន្យា និងផ្តល់អាហារូបករណ៍ សម្រាប់បណ្តុះបណ្តាគ្រូបង្រៀនជាជនជាតិដើមភាគតិច។ គ្រូ

[213] ក្នុងចំណោមប្រជាជនចំនួន ៧២ ៦៨០ នាក់ប្រជាជនចំនួន ៤១ ៩៦៤ នាក់ជាក្រុមជនជាតិភាគតិច។ ជនជាតិព្នងគឺតំណាងឱ្យក្រុមជនជាតិធំបំផុតដែលមានចំនួន ៣៧ ២៥៨ នាក់ ឬ ៥៨ភាគរយ។

[214] ក្រុមជនជាតិភាគតិចមានតែត្រឹម ៦ភាគរយ ឬ ២២ ០៣៥ នាក់ក្នុងចំណោមចំនួនប្រជាជន ៣៤៤ ១៩៥ នាក់នៅខេត្តក្រចេះ។ ជនជាតិភាគតិចព្នង គឺជាក្រុមជនជាតិភាគតិចធំបំផុតដែលមានចំនួន ៨ ៥៩២ នាក់ជនជាតិចាម ( ៧ ៧១៧ នាក់) និងជនជាតិក្រោល (៤ ៥៤៩ នាក់)។

[215] ក្នុងចំណោមប្រជាជន ១៨៣ ៦៩៩ នាក់ ជនជាតិភាគតិចមានចំនួន ៦៤ភាគរយ ឬ ១១៧ ១២៩ នាក់ ក្នុងខេត្តរតនគិរី។ ក្រុមធំជាងគេបំផុត គឺជាជនជាតិទំពួន ( ៥១ ០៥៣នាក់)។

[216] ក្នុងចំណោមប្រជាជនសរុបចំនួន ១២២ ៧៩០ នាក់នៅខេត្តស្ទឹងត្រែង ជនជាតិភាគតិចមានចំនួន ១៧ ៣០១ នាក់ ឬ ១៤% រួមមានជនជាតិឡាវ និងចាម។ ជនជាតិការ៉ែតមានចំនួនប្រជាជន ៤ ៩១២ នាក់ គឺជាក្រុមជនជាតិភាគតិចធំបំផុត។

[217] ក្នុងចំណោមប្រជាជនចំនួន ២៣៥ ៣៧០ នាក់នៅខេត្តព្រះវិហារ ជនជាតិភាគតិចមានចំនួន ៦ ៨៥៣ នាក់ (៣ភាគរយ) ដែលមិនមែនជាជនជាតិខ្មែរ និងក្រុមជនជាតិភាគតិចគួយ ជាតំណាងក្រុមធំជាងគេ (៦ ១៣៦ នាក់)។

[218] អង្គការCARE និង ICC ផ្តល់ការបណ្តុះបណ្តាល ៣០ថ្ងៃ សម្រាប់គ្រូសហគមន៍។

[219] ផ្អែកលើទម្រង់ការបណ្តុះបណ្តាល ៩+២ ជាមួយនឹងចំណេះដឹងទាំងភាសាជនជាតិដើមនិងភាសាខ្មែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បង្រៀនសហគមន៍ពហុភាសាក៏ខ្វះការលើកទឹកចិត្តផងដែរ។ បញ្ហានេះតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡា ធ្វើសមាហរណកម្មគ្រូបង្រៀនទាំងនេះទៅជាបុគ្គលិកអប់រំ ដូច្នេះពួកគេអាចទទួលបានប្រាក់បៀវត្សខ្ពស់។ កម្មវិធីពហុភាសាមិនអាចត្រូវបានពង្រីក ដើម្បីគ្របដណ្តប់ទៅដល់កុមារជនជាតិដើមភាគតិច ដោយសារតែបញ្ហាថវិកា។ ដើម្បីដោះស្រាយបញ្ហានេះយើងត្រូវផ្តល់អាហារូបករណ៍ អាហារូបត្ថម្ភ និងអន្តេវាសិកដ្ឋាន ដើម្បីពង្រីកដំណើរការចូលរួម។

### ៤.៤.៣. ថ្នាក់ពន្លឿនការសិក្សា (AL) សម្រាប់កុមារលើសអាយុច្រើន

**កម្មវិធីថ្នាក់ពន្លឿន**ត្រូវបានគ្រប់គ្រងដោយគោលការណ៍ណែនាំ អនុម័តនៅឆ្នាំ ២០១៣។ កម្មវិធីថ្នាក់ពន្លឿនបានអនុវត្តនៅខេត្តចំនួន៦ ដែលមានកុមារលើសអាយុ និងកុមារបោះបង់ការសិក្សាចូលរៀនជាង ៣ ០០០ នាក់ ជាង១០០ ថ្នាក់។ ក្រសួងអប់រំ យុវជន និងកីឡាធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការ UNICEF និង PSE ដើម្បីអនុវត្តកម្មវិធីនេះ។ ទោះជាយ៉ាងនេះក្តី បច្ចុប្បន្ននេះ សៀវភៅសិក្សារបស់កម្មវិធីថ្នាក់ពន្លឿនមិនទាន់មានគ្រប់គ្រាន់ឡើយ។ ម្យ៉ាងវិញទៀត កម្មវិធីថ្នាក់ពន្លឿននាពេលបច្ចុប្បន្នមិនបានគ្របដណ្តប់ទៅដល់កុមារទាំងអស់ដែលលើសអាយុ(១៩%) កុមាររៀនត្រួតថ្នាក់(៩,៧%) និងកុមារបោះបង់ការសិក្សា(៩%) នៅតាមសាលាបឋមសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡានឹងអនុម័តផែនការថ្នាក់ជាតិ ដើម្បីអនុវត្តឱ្យបានទូលំទូលាយ(អនុម័តសៀវភៅសិក្សាសាកល្បងរបស់ថ្នាក់ពន្លឿនការសិក្សា)។ ក្រសួងបានដាក់ចេញវិធានការទប់ស្កាត់ការលើសអាយុក្នុងចំណោមកុមារក្រីក្រ និងកុមារងាយរងគ្រោះ និងមានផែនការប្រើប្រាស់ឧបករណ៍ការពារសង្គមដូចជាការផ្ទេរជាសាច់ប្រាក់ ឬជាអាហារូប-ករណ៍ ដើម្បីទាក់ទាញការចូលរៀនរបស់កុមារ និងការបញ្ចប់ការសិក្សា។

## ៤.៥. ការអប់រំក្រៅប្រព័ន្ធ

ការបង្ហាញនូវសមិទ្ធផលអប់រំមួយផ្សេងទៀត គឺការពង្រីកថ្នាក់អក្ខរកម្ម។ អក្ខរកម្មមានអត្ថន័យធំធេងលើសពីការអាន និងការសរសេរកម្រិតមូលដ្ឋាន។ អក្ខរកម្ម គឺបង្ហាញពីរបៀបដែលបុគ្គលប្រើបំណិន ដែលទទួលបានដើម្បីកែលម្អមុខរបររបស់ពួកគេ និងគុណភាពនៃជីវិតរបស់ពួកគេ ដោយទទួលបាននូវមុខរបរដ៏ល្អ ការទទួលប្រាក់ចំណូលដ៏សមរម្យ និងទទួលបានឱកាសបណ្តុះបណ្តាល។ ដូចនេះអក្ខរកម្មបានធ្វើឱ្យមនុស្សបានចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងសង្គម និងបានយល់ពីសារៈសំខាន់នៃបញ្ហាសាធារណៈទៀតផង។

ការប្តេជ្ញាចិត្តក្នុងការផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលកំណត់ថា *«រដ្ឋនឹងអភិវឌ្ឍប្រព័ន្ធអប់រំមួយពេញលេញតែមួយតាមរយៈរដ្ឋ... ដើម្បីឱ្យប្រជាពលរដ្ឋមានឱកាសស្មើគ្នា ក្នុងការបង្កើននូវមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ»*[220]។ ច្បាប់ស្តីពីការអប់រំចែងថា ប្រព័ន្ធអប់រំតែមួយពេញលេញគួរតែបញ្ចូល ៖ *«ការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំក្រៅផ្លូវការ»*[221]។ ជាងនេះទៅទៀត ការអប់រំក្រៅប្រព័ន្ធ គឺជាប្រព័ន្ធអប់រំផ្លូវការមួយ ដែលនឹងរួមចំណែកដើម្បីសម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នា និងផ្តល់ឱ្យប្រជាជននូវការអប់រំពេញមួយជីវិត និងក៏បានជួយសាងនូវសង្គមសិក្សាមួយប្រកបដោយសមធម៌ យុត្តិធម៌ និងការអភិវឌ្ឍសង្គម[222]។

នៅឆ្នាំ១៩៦៩ អត្រាអក្ខរកម្មនៅក្នុងប្រទេសកម្ពុជាមានចំនួន៩១% [223] ។ នៅឆ្នាំ ១៩៧៩ ការកាត់បន្ថយអនក្ខរកម្មត្រូវបានបង្កើតឡើង តាមរយៈយុទ្ធនាការអប់រំយុវជន និងអក្ខរកម្មទ្រង់ទ្រាយធំមួយ។ មានគ្រូស្ម័គ្រចិត្តប្រហែល ៣៣ ៥៩៧នាក់ ត្រូវបានប្រមូលផ្តុំសម្រាប់យុទ្ធនាការនេះ។ អ្នកបង្រៀន (ភាគច្រើនគឺ គ្រូបង្រៀន មន្ត្រីរដ្ឋាភិបាល និងសិស្សមធ្យមសិក្សា) បានបង្កើតថ្នាក់អក្ខរកម្ម ដែលមានរយៈពេល៦ម៉ោងក្នុងមួយសប្តាហ៍ ហើយទទួលបានជាអង្ករ ឬលុយជាការលើកទឹកចិត្ត។ នៅពេលដែលបានបណ្តុះបណ្តាល ១៥០ ម៉ោងហើយ (៥ ទៅ ៦ខែ) សិស្សអក្ខរកម្មមានសមត្ថភាពអាចអាន សរសេរ និងអាចគិតលេខបាន។

ការអង្កេតអក្ខរកម្មជាតិនៅឆ្នាំ ១៩៩៩ បានបង្ហាញថា ៣៧,១ % នៃប្រជាជនដែលមានអាយុពី ១៥ ឆ្នាំឡើងទៅត្រូវបានរកឃើញថាជាអ្នកចេះ និង២៦,៦% បានសិក្សារៀនសូត្រមធ្យម ហើយពួកគេមានលទ្ធភាពអាចអាន សរសេរ និងរាប់បានបន្តិចបន្តួចចំណែក ៣៦,៣% គឺជាជនអនក្ខរកម្ម ហើយភាគច្រើនជាស្ត្រី[224]។ ការកើនឡើងនៃអនក្ខរជន គឺបណ្តាលមកពីកុមារគ្រប់អាយុចូលសាលាមិនបានចូលទៅក្នុងប្រព័ន្ធអប់រំផ្លូវការ ការបោះបង់ចោលការសិក្សានៅបឋមសិក្សា និងមួយចំនួនត្រឡប់ទៅរកភាពអនក្ខរកម្ម។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ គោលនយោបាយជាតិស្តីពីការអប់រំក្រៅប្រព័ន្ធបានផ្តោតទៅលើ ៖[225]

---

[220] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រាទី៦៦។

[221] ច្បាប់អប់រំឆ្នាំ២០០៧ មាត្រាទី១៥។

[222] រាជរដ្ឋាភិបាលកម្ពុជា (២០០២) គោលនយោបាយជាតិស្តីពីការអប់រំក្រៅប្រព័ន្ធ ទំព័រទី៩។

[223] UNDP (1989). Report of the Kampuchea Needs Assessment Study. p. 149.

[224] រាជរដ្ឋាភិបាលកម្ពុជា ទំព័រទី១១៩។

[225] រាជរដ្ឋាភិបាលកម្ពុជា ទំព័រទី១១។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ការបង្កើតឱកាសសម្រាប់ការអប់រំពេញមួយជីវិត
- លើកកម្ពស់ថ្នាក់អក្ខរកម្ម និង ការអប់រំបន្តដោយផ្តល់នូវបំណិនវិជ្ជាជីវៈ និង
- ផ្តល់ព័ត៌មាន និងចំណេះដឹងអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ការអប់រំក្រៅប្រព័ន្ធ គឺផ្តោតទៅលើប្រជាជនក្រីក្រ និងអ្នកដែលរស់នៅក្នុងស្ថានភាពលំបាក យុវជន និងកុមារដែលកំពុងធ្វើការ កុមារក្រៅសាលា កុមារនិងយុវជនជនជាតិដើមភាគតិច និងយុវជនដែលមានអាយុពី១៥ ទៅ៤៥ឆ្នាំ ជាពិសេសអ្នកដែលរស់នៅក្នុងតំបន់ដាច់ស្រយាល តំបន់ក្រីក្រ និងតំបន់តាមព្រំដែន ដែលជាអតីតតំបន់ខ្មែរក្រហម។ ជាងនេះទៅទៀត ក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារផ្សេងៗទៀតដែលផ្តល់ការគាំទ្រដល់ការអប់រំក្រៅប្រព័ន្ធ គឺត្រូវបានសម្របសម្រួលដោយគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នា និងក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាព ឱ្យស្របទៅនឹងគោលដៅការអប់រំក្រៅប្រព័ន្ធ។ កម្មវិធីសិក្សាអប់រំក្រៅប្រព័ន្ធរួមមាន ៖[226] (i) អក្ខរកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំបន្ត ដូចជាថ្នាក់ក្រោយអក្ខរកម្ម វគ្គបង្កើនគុណភាពនៃជីវិត(អនាម័យ ការការពារមេរោគ និងជំងឺអេដស៍ យេនឌ័រ វប្បធម៌ សន្តិភាព សីលធម៌ និងពលរដ្ឋវិជ្ជា) ការបង្កើនប្រាក់ចំណូល (កសិកម្ម សេវាកម្ម ជំនួញទ្រង់ទ្រាយតូច និងហត្ថកម្ម) ការអប់រំក្នុងគ្រួសារ ឬការអភិវឌ្ឍកុមារតូច និងកម្មវិធីចូលរៀនឡើងវិញ សម្រាប់ថ្នាក់បោះបង់ការសិក្សានៅបឋមសិក្សា។ ដូច្នេះ ពួកគេមានលទ្ធភាពអាចវិលត្រឡប់ទៅសាលារដ្ឋវិញ។

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំក្រៅប្រព័ន្ធ ឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តនូវគោលនយោបាយស្តីអំពីកម្មវិធីសមមូលការអប់រំក្រៅប្រព័ន្ធ[227] ក្នុងគោលបំណងដើម្បីផ្តល់ឱកាសថ្មីដល់អ្នកសិក្សា និងផ្តល់ពួកគេនូវសញ្ញាបត្រសមមូលនឹងអ្នកដែលរៀនក្នុងប្រព័ន្ធផ្លូវការដែរ។ កម្មវិធីសមមូលមានដូចជាថ្នាក់ពន្លឿនការសិក្សាដែលមានរយៈពេល៦ឆ្នាំ ៖ ២ ឆ្នាំនៅកម្រិតបឋមសិក្សា ២ ឆ្នាំទៀតនៅកម្រិតមធ្យមសិក្សាបឋមភូមិ និង២ឆ្នាំទៀតនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ កម្មវិធីសមមូលអាចត្រូវបានធ្វើឡើងនៅក្នុងសាលារៀនផ្លូវការ សាលាបំពេញវិជ្ជា មជ្ឈមណ្ឌល

---

[226] រាជរដ្ឋាភិបាលកម្ពុជា (២០០២) «គោលនយោបាយថ្នាក់ជាតិស្តីពីការអប់រំក្រៅប្រព័ន្ធ» ទំព័រទី១៥។

[227] គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡាទៅលើកម្មវិធីសមមូលការអប់រំក្រៅប្រព័ន្ធ នៅឆ្នាំ២០០៨។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិក្សាសហគមន៍ (CLC)[228] រោងចក្រ មជ្ឈមណ្ឌលបណ្តុះបណ្តាលកងកម្លាំងប្រដាប់អាវុធ ឬទីកន្លែងផ្សេងទៀតដែលសមស្រប។ កម្មវិធីសិក្សារួមមាន ៖ ៧០% មកពីការអប់រំផ្លូវការ និង ៣០% ជាបំណិនជីវិត។

បច្ចុប្បន្ននេះ អត្រាអក្ខរកម្មយុវជនដែលមានអាយុចាប់ពី១៥ ដល់២៤ឆ្នាំ កើនដល់ ៩៣% នៅក្នុងឆ្នាំ២០១៣[229] ខណៈដែលអត្រាអក្ខរកម្មមនុស្សពេញវ័យអាយុចាប់ពី១៥ឆ្នាំឡើងទៅមានត្រឹមតែ៨០%ប៉ុណ្ណោះ។ អត្រាអនក្ខរកម្មគឺនៅតែខ្ពស់នៅតំបន់ដាច់ស្រយាលជាងតំបន់ប្រជុំជន និងស្ត្រីច្រើនជាងបុរស ប៉ុន្តែនៅក្នុងករណីទាំងពីនេះគម្លាតកាន់តែតូចទៅៗ។ ភាពក្រីក្រនៅតែបន្តឱ្យមានអនក្ខរកម្មខ្ពស់ជាងអ្នកមាន។ ទោះបីជាយ៉ាងណាក៏ដោយគម្លាតកាន់តែតូចទៅៗ។ អត្រាអនក្ខរកម្មមនុស្សពេញវ័យខុសគ្នារវាងតំបន់។

ដូច្នេះ ដើម្បីសម្រេចបាននូវគោលដៅអប់រំសម្រាប់ទាំងអស់គ្នា(៨៤,៥% នៅឆ្នាំ ២០១៥) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រកម្មវិធី Cap EFA របស់អង្គការយូណេស្កូ បានអនុម័តផែនការបង្កើនល្បឿនអក្ខរកម្ម (CLAP), ២០១៣-២០១៥[230] សម្រាប់កំណត់គោលដៅថ្នាក់អក្ខរកម្ម និងណែនាំពីដំណើរការនៃយុទ្ធនាការអក្ខរកម្មជាតិ។ ក្រសួងបានរៀបចំផែនទីជាង ៥០០ សន្លឹក ដែលបង្ហាញពីអត្រាអនក្ខរកម្មនិងចំនួនបុគ្គលដែលមិនចេះអក្សរនៅគ្រប់ស្រុកទាំងអស់ និងតាមបណ្តាខេត្ត ដែលមានទិន្នន័យអក្ខរកម្មថ្នាក់ភូមិ សម្រាប់ការវិភាគផ្អែកលើភស្តុតាង និងការធ្វើផែនការ[231]។ ផែនការនេះអំពាវនាវឱ្យបង្កើនអ្នកចូលរៀនថ្នាក់អក្ខរកម្ម កែលម្អសមត្ថភាពរបស់គ្រូអក្ខរកម្ម និងផ្តល់សម្ភារបង្រៀន និងរៀនឱ្យបានគ្រប់គ្រាន់សម្រាប់ថ្នាក់អក្ខរកម្ម។ ខេត្តនីមួយៗត្រូវមានការរៀបចំផែនការពន្លឿនអក្ខរកម្ម (CLAP) របស់ខ្លួនដើម្បីកំណត់អត្តសញ្ញាណនៃគោលដៅការធ្វើអន្តរាគមន៍ នៅក្នុងកម្រិតថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ផែនការពន្លឿនអក្ខរកម្ម**បានបង្ហាញអាទិភាព និងយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីឈានទៅដល់ក្រុមទីទ័លក្រ។ កម្មវិធីនេះមានគោលដៅផ្តល់ឱ្យអនក្ខរជនក្រីក្រនៅក្រៅសាលា ស្ត្រី/កុមារី និងជនជាតិដើមភាគតិចបានទទួលនូវបំណិនអក្ខរកម្ម និងអាចចូលរួមបានល្អប្រសើរជាងមុននៅក្នុងសហគមន៍ និងការអភិវឌ្ឍសង្គម។ អាទិភាពត្រូវបាន

---

[228] មជ្ឈមណ្ឌលសិក្សាសហគមន៍ ( CLC ) គឺជាស្ថាប័នកម្រិតសហគមន៍ ដើម្បីកសាងធនធានមនុស្សដោយផ្តល់ឱកាសសម្រាប់ការសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនទាំងអស់ដើម្បីផ្លាស់ប្តូរសង្គម និងជំរុញគុណភាពនៃជីវិតជាកន្លែងដែលភាពជាម្ចាស់ គឺជាកម្លាំងចលករដ៏សំខាន់។

[229] CSES, 2013.

[230] ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) «ផែនការបង្កើនល្បឿនអក្ខរកម្ម (២០១៣-២០១៥)» ។

[231] Ibid. ទំព័រទី១០។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្ដល់ឱ្យ ៖ (i) ក្រុមអាយុសកម្មផ្នែកសេដ្ឋកិច្ច (១៥-៤៥ឆ្នាំ) (ii) ក្រុមប្រជាជនវ័យក្មេងអាយុពី ១៥ ទៅ ២៤ឆ្នាំ ដើម្បីឱ្យពួកគេអាចបន្តការសិក្សា នៅក្នុងការអប់រំក្នុងប្រព័ន្ធបាន (iii) លើកកម្ពស់ស្ត្រីដើម្បីធានាបាននូវសមភាពយេនឌ័រនិង (iv) ប្រជាជនជួបការលំបាក។[232]

សិស្សចំនួន ៣៥ ៤២៥ នាក់ បានចូលរួមថ្នាក់អក្ខរកម្មជំនាញវិជ្ជាជីវៈនៅឆ្នាំសិក្សា ២០១២-២០១៣ និងសិស្ស ២៦ ៨៩០ នាក់ បានបញ្ចប់ថ្នាក់អក្ខរកម្មជំនាញវិជ្ជាជីវៈ។ ដើម្បីលើកកម្ពស់ការអប់រំក្រៅប្រព័ន្ធបណ្ណាល័យចំនួន៣៧ និងមណ្ឌលអាន២២៩ ត្រូវបានសាងសង់ឡើង។ មជ្ឈមណ្ឌលសិក្សាសហគមន៍ (CLC) ៣២១ កន្លែង ត្រូវបានបង្កើតឡើង ដើម្បីបម្រើដល់ប្រជាជន ១០ ៥០៧ នាក់។ សិស្សចំនួន ២ ៣២២ នាក់ បានបញ្ចប់កម្មវិធីសមមូល ខណៈពេលដែលសិស្ស ២១ ៩១៣ នាក់ ចូលរួមក្នុងកម្មវិធីចូលរៀនឡើងវិញ។

ដើម្បីសម្រេចគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីអង្គការយូណេស្កូ បានចាប់ផ្ដើមយុទ្ធនាការអក្ខរកម្ម ឆ្នាំ២០១៥ ដើម្បីអនុវត្តថ្នាក់អក្ខរកម្មចំនួន ៣ ៦៨៥ ថ្នាក់ សម្រាប់សិស្សចំនួន ៩២ ១២៥ នាក់។ គ្រូបង្រៀននៅសាលាបឋមសិក្សាចំនួន ២ ៥៥៨ នាក់ ចូលរួមក្នុងវគ្គតម្រង់ទិសស្ដីពីការរៀបចំថ្នាក់អក្ខរកម្ម នៅក្នុងសាលារៀនសាធារណៈ។ បន្ថែមពីនេះទៀត គ្រូអក្ខរកម្មជាប់កិច្ចសន្យាចំនួន ១ ១២៧ នាក់ បានទទួលការបណ្ដុះបណ្ដាល។ គ្រូឧទ្ទេសថ្នាក់អក្ខរកម្ម ចំនួន៦៦០ នាក់ត្រូវបានបណ្ដុះបណ្ដាល សម្រាប់ផ្ដល់ការគាំទ្រដល់គ្រូបង្រៀនអក្ខរកម្ម៣ ៦៨៥នាក់។ យុទ្ធនាការអក្ខរកម្មនេះនឹងចំណាយប្រាក់ប្រមាណ ៣,៦ លានដុល្លារអាមេរិក[233]។

## ៤.៦. ការអប់រំភាសាបរទេស

ក្រសួងអប់រំបានអនុម័តការបង្រៀនភាសាអង់គ្លេស និងភាសាបារាំងក្នុងកម្មវិធីសិក្សា។

---

[232] Ibid. ទំព័រទី១៣។

[233] ចំណាយសរុប ៣,៦លានដុល្លារ រួមមាន៖ (i) វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលសម្រាប់ ៥ ថ្ងៃ (៨៨ ៨៦៩ដុល្លារ); (ii) វគ្គបំប៉នតម្រង់ទិសដល់គ្រូកម្រិតបឋម ២ ៥៥៨ នាក់ (បានគ្រោងទុកគ្រូជាប់កិច្ចសន្យា ១ ១២៧ នាក់) សម្រាប់ ២ ថ្ងៃ ថ្ងៃធ្វើដំណើរ ១ ថ្ងៃ (២៦០ ៩១៦ដុល្លារ); (iii) សៀវភៅសិស្ស និងសៀវភៅគ្រូ កម្មវិធីសិក្សាសម្រាប់ថ្នាក់អក្ខរកម្មសម្រាប់អ្នកចូលរួម ៣ ៦៨៥ នាក់ (២៣៦ ៥៧៧ដុល្លារ); (iv) សម្ភារប្រតិបត្តិការផ្សេងទៀតសម្រាប់ថ្នាក់អក្ខរកម្មដូចជាក្ដារខៀន ក្ដារឆ្នួន ដីស ក្រដាសវ៉ាម ខ្មៅដៃ សៀវភៅកត់ត្រា២០០ទំព័រ ថ្មពិល 70A និងចង្កៀង (៧៤៧ ៣១៨ដុល្លារ); (v) ប្រាក់ខែសម្រាប់គ្រូបង្រៀនអក្ខរកម្ម ៨ ខែ (២ ២១១ 000ដុល្លារ); និង (vi) ការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ ៥ ថ្ងៃ (៨៥ 000ដុល្លារ) (សូមមើលយុទ្ធនាការអក្ខរកម្មជាតិ ខែវិច្ឆិកា ឆ្នាំ ២០១៤ ដល់ខែវិច្ឆិកាឆ្នាំ ២០១៥ ដើម្បីសម្រេចបាននូវគោលដៅ EFA (អត្រាអក្ខរកម្មមនុស្សពេញវ័យ ៨៤,៥ភាគរយ)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.៦.១. ការបង្រៀនភាសាអង់គ្លេស

ដោយមានវត្តមាននៃកងកម្លាំងថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩២-១៩៩៣ ប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរជាបណ្តើរៗពីប្រទេសនិយាយភាសាបារាំងទៅជាប្រទេសនិយាយភាសាអង់គ្លេស។ នៅឆ្នាំ១៩៨៩ ភាសាបរទេសត្រូវបានបង្រៀននៅមធ្យមសិក្សា។ នៅឆ្នាំ១៩៩០ គណៈកម្មាធិការមួយត្រូវបានបង្កើតឡើង ដើម្បីធ្វើការអភិវឌ្ឍសៀវភៅសិក្សាភាសាអង់គ្លេស ដែលមានឈ្មោះថា «The Cambodia English Course»។ នៅឆ្នាំ ១៩៩៦ ផែនការមេមួយត្រូវបានអនុម័ត ដើម្បីដាក់ចេញនូវការអប់រំភាសាអង់គ្លេស។ ការសិក្សាភាសាអង់គ្លេសមានសន្ទុះកើនឡើង បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអាស៊ាន។ សៀវភៅរៀនភាសាអង់គ្លេសមាន ៦ កម្រិត ដែលមានឈ្មោះថា «English For Cambodia» ត្រូវបានអនុម័ត សម្រាប់បង្រៀនសិស្សថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ ដើម្បីបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀនភាសាអង់គ្លេស អង្គការ VSO បានផលិតសៀវភៅគ្រូ ៣ កម្រិត សម្រាប់សាលាបឋមសិក្សា នៅក្នុងឆ្នាំ ២០០៣ ដែលមានឈ្មោះថា «Preparatory English Language»។ នៅឆ្នាំ ២០១០ គីហ្សូណា ដោយមានការគាំទ្រពីមូលនិធិ Nippon Foundation បានរៀបចំសៀវភៅជាភាសាអង់គ្លេស English for Fun(៦កម្រិត) សម្រាប់មធ្យមសិក្សាបឋមភូមិ ដើម្បីលើកកម្ពស់បំណិនស្តាប់ និងនិយាយ។

តាំងពីឆ្នាំ២០១៣ ភាសាអង់គ្លេសត្រូវបង្រៀនចាប់ពីថ្នាក់ទី៤។ សៀវភៅសិក្សាសម្រាប់ថ្នាក់ទី៤ និងទី៥ ត្រូវបានបង្កើតឡើង និងចែកចាយទៅតាមសាលារៀន ខណៈពេលដែលសៀវភៅសិក្សាសម្រាប់ថ្នាក់ទី៦ បាននិងកំពុងរៀបចំ។ នាពេលបច្ចុប្បន្ន ភាសាអង់គ្លេសត្រូវបានបង្រៀន ៤ម៉ោង ក្នុង១សប្តាហ៍នៅកម្រិតបឋមសិក្សា និងកម្រិតមធ្យមបឋមភូមិ និង២ម៉ោងក្នុង១សប្តាហ៍នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ សៀវភៅសិក្សាសម្រាប់ថ្នាក់ទី៧-៩ ត្រូវបានរៀបចំដោយអង្គការ គីហ្សូណា ខណៈដែលសៀវភៅ «English For Cambodia» កម្រិតទី៤ ដល់ ទី៦ កំពុងត្រូវបានប្រើក្នុងការបង្រៀនភាសាអង់គ្លេសនៅថ្នាក់ទី១០ដល់ទី១២។ ចំនួនសរុបនៃគ្រូបង្រៀនភាសាអង់គ្លេសមានចំនួន ៤ ១០៥ នាក់ ត្រូវបានទទួលការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦។ តែគ្រូបឋមសិក្សាចំនួន ៣ ៣០០ នាក់ បានទទួលការបណ្តុះបណ្តាលវិក្រឹតការក្នុងខេត្តចំនួន១៣។ ប្រទេសកម្ពុជាខ្វះគ្រូបង្រៀនភាសាអង់គ្លេសដើម្បីអនុវត្តកម្មវិធីសិក្សា។

## ៤.៦.២. ការបង្រៀនភាសាបារាំង

ការអប់រំភាសាបារាំងមាន ៖ ថ្នាក់ពីរភាសា *classe bilingue*, le francais renforce និងភាសាបារាំងជាជីវភាសាទីមួយ (LV1) និងភាសាបារាំងជាជីវភាសាទីពីរ (LV2)។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ថ្នាក់ពីរភាសាត្រូវបានអនុវត្តនៅរាជធានី ខេត្តចំនួន៧ (បាត់ដំបង សៀមរាប កំពង់-ចាម តាកែវ កណ្តាល ព្រះសីហនុ និងរាជធានីភ្នំពេញ)។ មានសិស្សានុសិស្ស ប្រមាណ ៤ ០០០ នាក់បានសិក្សានៅថ្នាក់ទាំងនេះ ដែលក្នុងនោះសិស្សចំនួន ៣ ០០០ នាក់នៅតាមសាលាមធ្យមសិក្សា។ គ្រូបង្រៀនចំនួន៩០នាក់ ដែលក្នុងនោះមានគ្រូបង្រៀនភាសាបារាំងចំនួន ៤៦នាក់ បានចូលរួមក្នុងការបង្រៀនថ្នាក់ទាំងនេះ។ កម្មវិធីថ្នាក់ពីរភាសានេះត្រូវបានទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយសិស្សានុសិស្សក្នុងខេត្តកំពង់ចាម កណ្តាល បាត់ដំបង និងសៀមរាប ខណៈពេលដែលសិស្សានុសិស្សក្នុងខេត្តផ្សេងពីនេះចំនួន៣ មានការយកចិត្តទុកដាក់តិចតួច។ ទោះជាយ៉ាងណា គុណភាពនៃកម្មវិធីនេះមានការធ្លាក់ចុះ ដោយសារតែកង្វះគ្រូបង្រៀនសម្រាប់បង្រៀនមុខវិជ្ជាមិនមែនជាមុខវិជ្ជាភាសា ដូចជាគណិតវិទ្យា រូបវិទ្យា និងជីវវិទ្យា។ គ្រូបង្រៀនទាំងនេះមិនបានទទួលការបណ្តុះបណ្តាល ឬវិក្រឹតការណាមួយទេ ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះដឹងរបស់ខ្លួន លើមុខវិជ្ជាឯកទេស និងគរុកោសល្យ។ លើសពីនេះទៅទៀត គ្រូបង្រៀនភាគច្រើនគ្មានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់បង្រៀនភាសាបារាំងឡើយ។

ខេត្តចំនួន២ គឺខេត្តកំពង់ស្ពឺ និងពោធិ៍សាត់ បានផ្តល់វគ្គសិក្សា le francais renforce ដល់សិស្សានុសិស្សចំនួន ២០០ នាក់ក្នុងឆ្នាំសិក្សា២០១៥-២០១៦។ កម្មវិធីនេះទទួលបានការវាយតម្លៃខ្ពស់។ សិស្សត្រូវរួមចំណែកថវិកាផ្ទាល់ខ្លួន ចំនួន១៥ ដុល្លារក្នុងមួយខែ ដើម្បីសិក្សាភាសាបារាំង ក្នុងរយៈពេល ៦ម៉ោង។ សិស្សានុសិស្សកម្ពុជាចំនួន ១២៤ ០០០ នាក់ បានសិក្សាភាសាបារាំងជាជីវភាសាទីមួយ ឬទីពីរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ២

# កំណែទម្រង់វិស័យអប់រំដើម្បីកសាងសង្គមកម្ពុជាដែលមានកោសិកាផ្សារភ្ជាប់គ្នា មានការអប់រំឈានមុខ និងមានវប្បធម៌រស់រវើក


ជំពូកទី ៥ ៖ កំណែទម្រង់វិស័យអប់រំដើម្បីលើកកម្ពស់សង្គមពុទ្ធិនៅកម្ពុជា

ជំពូកទី ៦ ៖ ការបណ្តុះបណ្តាលគ្រូបង្រៀន និងកំណែទម្រង់គ្រូបង្រៀន

ជំពូកទី ៧ ៖ អធិការកិច្ចអប់រំ

ជំពូកទី ៨ ៖ វាយតម្លៃអប់រំថ្នាក់ជាតិ

ជំពូកទី ៩ ៖ កំណែទម្រង់កម្មវិធីសិក្សា

ជំពូកទី ១០ ៖ កំណែទម្រង់ការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីលើកកម្ពស់ឧស្សាហូបនីយកម្ម

ជំពូកទី ១១ ៖ តួនាទីនៃឧត្តមសិក្សាក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច

ជំពូកទី ១២ ៖ កំណែទម្រង់ការអប់រំ និងការកែលម្អវិធីសាស្ត្របង្រៀនក្នុងគោលដៅលើកម្ពស់ជំនាញទន់

ជំពូកទី ១៣ ៖ ការផ្តល់ប្រឹក្សាអាជីព ដើម្បីដោះស្រាយគម្លាតជំនាញ និងលើកកម្ពស់ជំនាញទន់

ជំពូកទី ១៤ ៖ ហិរញ្ញប្បទានក្នុងវិស័យអប់រំ

ជំពូកទី ១៥ ៖ ការកែលម្អគុណភាពរបស់សាលារៀន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៥
# កំណែទម្រង់វិស័យអប់រំដើម្បីលើកកម្ពស់សង្គមពុទ្ធិនៅកម្ពុជា

ក្រោយពីបង្កើនចំណាយថវិកាសម្រាប់វិស័យអប់រំ ក្នុងរយៈពេល ១ទសវត្សរ៍ រួចមក រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយ ដើម្បីលើកកម្ពស់ការទទួលបានការអប់រំជាសកល។ ជារួម កំណែទម្រង់អប់រំនៅកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០០០ ទទួលបានផ្លែផ្កាជាវិជ្ជមាន។

## ៥.១. បំណែងចែកប្រជាសាស្ត្រ និងជំនាញ

### ៥.១.១.ការវិវត្តផ្នែកប្រជាសាស្ត្រ

កម្ពុជាមានប្រជាជនប្រមាណ ១៤,៩៦ លាននាក់ (ក្នុងឆ្នាំ២០១២) ជាមួយរាងសាជីដែលផតសម្រាប់មនុស្សវ័យចន្លោះពី៣៥ ទៅ៣៩ឆ្នាំ ដោយសារតែការបាត់បង់ធនធានមនុស្ស ក្នុងសម័យខ្មែរក្រហម។ ក្រោយមកចំនួនប្រជាជនមានការកើនឡើង ដោយសារអត្រាកំណើតខ្ពស់ក្នុងទសវត្សរ៍ទី៨០។ នៅឆ្នាំ២០១០ អត្រាកំណើតសម្រេចបាន ៣.០ (អង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា ២០១០)។

*រូបភាពទី៧ ៖ សាជីនៃប្រជាជនកម្ពុជា ២០១២*




*ប្រភព ៖ ក្រសួងផែនការ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួនប្រជាជនកម្ពុជាទទួលរងឥទ្ធិពលពីកត្តាសំខាន់ពីរយ៉ាង ៖ (១) ការអភិវឌ្ឍ ដែលលើកកម្ពស់សុខភាព និងសុខុមាលភាព ដែលនាំឱ្យមានអត្រាមរណៈកុមារទាប និង (២) របបខ្មែរក្រហមដែលសម្លាប់ប្រជាជនអស់ជិត ២ លាននាក់។ ប្រការនេះនាំឱ្យប្រជាជន ដែលមានអាយុក្នុងចន្លោះពី០ ទៅ១៤ ឆ្នាំមានចំនួនតិច និងប្រជាជនដែលមានអាយុចាប់ពី ៦៥ឆ្នាំ ឡើងទៅបានកើនឡើង(តារាងទី១)។ ជាលទ្ធផល ចំនួនកូនសិស្សរៀននៅសាលា បឋមសិក្សាមានចំនួនថយចុះ។ ផ្ទុយទៅវិញ ចំនួនមនុស្សដែលមានវ័យពីអាយុ១៥ ទៅ ៦៤ ឆ្នាំ ដែលជាកម្លាំងពលកម្មពេញបានកើនឡើងពី ២,៤ លាននាក់ក្នុងឆ្នាំ១៩៥០ ដល់ ៩,១លាននាក់ក្នុងឆ្នាំ២០១០(តារាងទី២២) ដែលជាភាគលាភប្រជាសាស្ត្រ។ នេះក៏ជាកត្តា ដែលនាំឱ្យមានកំណើនកូនសិស្សនៅក្នុងថ្នាក់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិផងដែរ។

*តារាងទី២២ ៖ ចំនួនប្រជាជនកម្ពុជាសរុបតាមក្រុមអាយុ ឆ្នាំ១៩៥០–២០១០*

| | Age Category [000s] | | | | Percentage | | |
|---|---|---|---|---|---|---|---|
| Year | 0-14 | 15-64 | 65+ | Total | 0-14 | 15-64 | 65+ |
| *1950* | 1,834 | 2,395 | 117 | **4,346** | 42% | 55% | 3% |
| *1970* | 2,997 | 3,747 | 194 | **6,938** | 43% | 54% | 3% |
| *1980* | 2,537 | 3,780 | 189 | **6,506** | 39% | 58% | 3% |
| *1995* | 5,305 | 5,551 | 313 | **11,169** | 47% | 50% | 3% |
| *2010* | 4,510 | 9,091 | 537 | **14,138** | 32% | 64% | 4% |

*Source: United Nations Population Division 2011*

## ៥.១.២ .ប្រជាជនវ័យពេញការងារនៅកម្ពុជា

ពីរភាគបីនៃចំនួនប្រជាជននៅកម្ពុជា ជាប្រជាជនវ័យពេញការងារអាយុចន្លោះពី ១៥-៦៤ ឆ្នាំ។ នៅចន្លោះឆ្នាំ១៩៩៨-២០០៨ ចំនួនប្រជាជនវ័យពេញការងារកើនឡើងគួរឱ្យ កត់សម្គាល់ប្រហែល ៣៦% (២,៣៩២ លាននាក់)។ ចំនួនការងារមានការកើនឡើងជាង ២ ដង។ កម្ពុជានៅតែជាប្រទេស ដែលប្រជាជនភាគច្រើនប្រកបរបរកសិកម្ម នៅទីជនបទ ដែលមានកម្រិតទីប្រជុំជនប្រមាណ ៣០% ក្នុងឆ្នាំ ២០១៣។

## ៥.១.៣ .និយោជកនៅកម្ពុជា

យោងតាមជំរឿនសេដ្ឋកិច្ចជាតិក្នុងខែមីនា ឆ្នាំ២០១១ មានក្រុមហ៊ុន សហគ្រាស ចំនួនជាងកន្លះលានដែលមាននិយោជិត ១,៧ លាននាក់។ ភាគច្រើនគឺជាសហគ្រាសធុន តូច ដែលមានបុគ្គលិក ១០នាក់ ឬតិចជាង។ សហគ្រាសប្រភេទនេះមានចំនួន ៩៨% ប៉ុន្តែ មានកម្មករតែ ៥៨% នៃចំនួនកម្មករសរុបទាំងអស់តែប៉ុណ្ណោះ។ ផ្ទុយពីនេះ មានសហ-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រាសតែ៧៨១ (០,២% នៃសហគ្រាសសរុប) ប៉ុណ្ណោះដែលមានបុគ្គលិកលើសពី១០០ នាក់។ សហគ្រាសប្រភេទនេះមានបុគ្គលិកជាង ៩៥០ ០០០ នាក់ ដែលចំនួននេះច្រើនជាងមួយភាគបួននៃកម្លាំងពលកម្មផ្លូវការ។ ជាមធ្យម សហគ្រាសធុនតូចមានបុគ្គលិកតែ ២ នាក់ សហគ្រាសធុនមធ្យមមានបុគ្គលិកតែ ២៣ នាក់ (ពី១១ ដល់ ១០០ នាក់) ក្នុងពេលដែលសហគ្រាសធុនធំមានបុគ្គលិកតែ ៥៧៨ នាក់។

## ៤.១.៤ .ការលេចចេញជួរគម្លាតជំនាញ

គម្លាតជំនាញអាចត្រូវបានវាយតម្លៃតាមរបៀបជាច្រើន។ នៅក្នុងអត្ថបទនេះ យើងប្រើនិយមន័យពីរ ៖ ទីមួយផ្អែកលើការរំពឹងទុករបស់និយោជក(និងនិយោជិត) និងទីពីរផ្អែកលើមធ្យមភាគជាលក្ខណៈអន្តរជាតិ ឬមធ្យមភាគនៃប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ និយមន័យទីមួយផ្អែកលើយុទ្ធសាស្ត្រតម្រូវការ និងជាញឹកញាប់ប្រើសម្រាប់វាស់គម្លាតជំនាញថ្នាក់ខ្ពស់។ និយមន័យទីពីរផ្អែកលើយុទ្ធសាស្ត្រផ្គត់ផ្គង់នោះ គឺការធ្វើតេស្តជាលក្ខណៈអន្តរជាតិ។ តែតេស្តប្រភេទនេះធ្វើតែនៅក្នុងកម្រិតមធ្យមសិក្សា លើជំនាញមូលដ្ឋាន។ ដូច្នេះ ការវាយតម្លៃផ្តោតតែទៅលើជំនាញពុទ្ធិ(ចំណេះដឹង) ប៉ុណ្ណោះ។

សម្រាប់កម្មករជំនាញ និងអ្នកអាជីព/អ្នកគ្រប់គ្រង គម្លាតដ៏ធំមួយ គឺគម្លាតខាងចំណេះដឹងភាសាអង់គ្លេស និងជំនាញកុំព្យូទ័រ បន្ទាប់មកគឺបំណិនខាងការគិត និងបំណិនឥរិយាបថ។ បំណិនខាងការគិត និងឥរិយាបថ គឺជាបំណិន ដែលចាំបាច់បំផុត សម្រាប់និយោជក។

ដោយអនុលោមតាមការរំពឹងទុករបស់និយោជក គម្លាតដ៏ធំបំផុតសម្រាប់ជំនាញជាក់លាក់ក្នុងការបំពេញការងារ គឺចំណេះដឹងខាងផ្នែកទ្រឹស្តី និងការអនុវត្ត នៅក្នុងការបំពេញការងារ។ គម្លាតនេះគឺជាផលិតផលរបស់សាលារៀន ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងកង្វះបទពិសោធក្នុងវិស័យនេះ។

តើអ្វីជាមូលហេតុចម្បងដែលនាំឱ្យមានគម្លាតនេះ? ភស្តុតាងជាក់ស្តែងជាច្រើនបានបង្ហាញថា បញ្ហាគុណភាព និងភាពឆ្លើយតបនៃការអប់រំទៅនឹងការងារ គឺជាបញ្ហាដែលមានសារៈសំខាន់បំផុត។ កត្តាផ្សេងទៀត ដូចជាកង្វះពិពិធកម្មក្នុងការជ្រើសរើសបុគ្គលិក យន្តការមិនសមស្រប ក្នុងការបញ្ជាក់ការសិក្សា អត្រាប្តូរការងារខ្ពស់ និងប្រាក់បៀវត្សទាបនៅពេលចាប់ផ្តើមដំបូង ក៏អាចពន្យល់ពីភាពលំបាកក្នុងការផ្គត់ផ្គង់ជំនាញដល់វិស័យកម្មន្តសាល និងសេវាកម្មផងដែរ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តម្រូវការការបណ្ដុះបណ្ដាល និងអប់រំ ដែលមានគុណភាពខ្ពស់នៅតែកើនឡើងជាប្រចាំ ក្នុងចំណោមសហគ្រាសកម្មន្តសាល និងសេវាកម្ម។ រង្វាយតម្លៃរបស់និយោជកអំពីគុណភាពនិស្សិត ដែលបានបញ្ចប់ការសិក្សាបានបង្ហាញយ៉ាងច្បាស់ថា គម្លាតនៃការបណ្ដុះបណ្ដាល និងការអប់រំ ប្រកបដោយគុណភាពខ្ពស់ គឺជាគម្លាតដ៏សំខាន់មួយ។

ទោះបីជាយ៉ាងនេះក៏ដោយ តម្រូវការក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេស ក្នុងវិស័យសេវាកម្ម និងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ ដូចជាអេឡិចត្រូនិក កម្មន្តសាល និងសេវាកម្មកម្រិតខ្ពស់បាននាំឱ្យរដ្ឋាភិបាលរឹតតែមានកង្វល់ខ្លាំងឡើងអំពីគុណភាព និងភាពឆ្លើយតបនៃការអប់រំទៅនឹងតម្រូវការ។ ការបារម្ភនេះនាំឱ្យមានការវិភាគអំពីសូចនាករចាំបាច់មួយចំនួន ដែលទាក់ទងនឹងគុណភាពអប់រំ ដូចជាគ្រូបង្រៀន ជាពិសេសកម្រិតវប្បធម៌ សមត្ថភាពលើជំនាញមុខវិជ្ជា និងជំនាញគរុកោសល្យ។

## ៥.២. តួនាទីអប់រំនៅក្នុងសមាហរណកម្មអាស៊ាន

ការអប់រំ គឺជាចំណុចស្នូលនៃដំណើរការសមាហរណកម្មអាស៊ាន។ ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងអាស៊ាន «គម្លាតការអប់រំ» រវាងសមាជិកអាស៊ានចាស់ទាំង៦ (ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ) និងសមាជិកអាស៊ានថ្មីទាំង៤ (កម្ពុជា ឡាវ ភូមា និងវៀតណាម) ដែលទើបតែងើបចេញពីសង្គ្រាម និងភាពឯកកោនៅមានទំហំធំ។ វាក៏ឆ្លុះបញ្ចាំងផងដែរទៅលើភាពខុសគ្នា ខាងគុណភាពអប់រំក្នុងចំណោមប្រទេសសមាជិកអាស៊ាន។ ភាពខុសគ្នារវាងប្រព័ន្ធអប់រំក្នុងចំណោមប្រទេសសមាជិកអាស៊ាន គឺជាការប្រឈមដ៏ចម្បងមួយ ក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ជាពិសេសគោលដៅប្រកបដោយមហិច្ឆតាមួយ គឺលំហូរពលករជំនាញដោយសេរី។ ការអប់រំត្រូវបានចាត់ទុកជាឧបករណ៍ដ៏មានប្រសិទ្ធភាព សម្រាប់សមាហរណកម្មអាស៊ានជាទូទៅ និងសម្រាប់បង្រួមគម្លាតអភិវឌ្ឍន៍រវាងសមាជិកអាស៊ានចាស់ទាំង ៦ និងសមាជិកអាស៊ានថ្មីទាំង៤ (CLMV) ។

ដោះស្រាយគម្លាតអប់រំតម្រូវឱ្យមានកិច្ចប្រឹងប្រែងយ៉ាងខ្លាំង ពីសំណាក់ប្រទេសសមាជិកអាស៊ានថ្មីទាំង៤ (CLMV) ក្នុងការលើកកម្ពស់ការចូលរៀននៅគ្រប់កម្រិត ជាពិសេសលើកកម្ពស់គុណភាពអប់រំ។

ក្រោយពេលដែលទទួលបានសន្តិភាព កម្ពុជាបានចូលជាសមាជិកអាស៊ាននៅខែមេសា ឆ្នាំ១៩៩៩។ ប៉ុន្តែអាស៊ានជាអង្គការ ដែលរដ្ឋជាសមាជិកមានគម្លាតអភិវឌ្ឍធំរវាងសមាជិកអាស៊ានចាស់ទាំង៦ និងសមាជិកអាស៊ានថ្មីទាំង៤។ ឧទាហរណ៍ សិង្ហបុរីមាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗជាមធ្យម(៥០ ១៣០ ដុល្លារ) ពោលគឺ ៥០ ដង ច្រើនជាងកម្ពុជា(១ ២០០ដុល្លារ)។

គម្លាតអភិវឌ្ឍនេះក៏ឆ្លុះបញ្ចាំងកម្រិតនៃគុណភាពអប់រំផងដែរ។ សមាជិកអាស៊ានចាស់ទាំង៦ មានពិន្ទុក្នុងប្រព័ន្ធវាយតម្លៃចំណេះដឹងសិស្ស(PISA) ទាបជាងប្រទេសសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍(OECD)[234] លើកលែងតែសិង្ហបុរីដែលមានពិន្ទុខ្ពស់ជាងគេក្នុងឆ្នាំ២០១២។ ប្រទេសវៀតណាមក៏ទទួលបានពិន្ទុល្អដែរលើផ្នែកវិទ្យាសាស្ត្រ។ ភាពខុសគ្នារវាងប្រព័ន្ធអប់រំក្នុងចំណោមប្រទេសសមាជិកអាស៊ាន គឺជាការប្រឈមដ៏ចម្បងមួយក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ជាពិសេសគោលដៅប្រកបដោយមហិច្ឆតាមួយ គឺលំហូរពលករជំនាញដោយសេរី។

ការអប់រំត្រូវបានចាត់ទុកជាឧបករណ៍ដ៏មានប្រសិទ្ធភាព សម្រាប់សមាហរណកម្មអាស៊ាន[235]ជាទូទៅ និងសម្រាប់បង្រួមគម្លាតអភិវឌ្ឍ រវាងសមាជិកអាស៊ានចាស់ទាំង៦ និងសមាជិកអាស៊ានថ្មីទាំង៤ (CLMV) ដោយឡែក។ គំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន និងផែនការការងាររបស់វាផ្តោតលើការកសាងសមត្ថភាព ការបណ្តុះបណ្តាលភាសា និងអាហារូបករណ៍។ ទាំងផែនការគោលនៃសហគមន៍សង្គមវប្បធម៌អាស៊ាន និងទាំងផែនការការងារអប់រំ ៥ ឆ្នាំរបស់អាស៊ាន (២០១១-២០១៥) បានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រក្នុងការបង្កើតសង្គមពុទ្ធិ សម្រេចបានការអប់រំបឋមសិក្សាជាសកល ផ្តល់នូវការបណ្តុះបណ្តាល និងអប់រំបច្ចេកទេស និងវិជ្ជាជីវៈឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ច លើកកម្ពស់ឧត្តមសិក្សា និងកសាងអត្តសញ្ញាណអាស៊ានតាមរយៈការអប់រំ។

ទោះបីជា ជាទូទៅ អាស៊ានមានការអប់រំល្អ បើធៀបនឹងតំបន់ផ្សេងទៀតនៅលើពិភពលោក តែនៅតែមានភាពខុសគ្នាខ្លាំងរវាងបណ្តាប្រទេសជាសមាជិក ទាំងការទទួលបានការអប់រំ និងគុណភាពអប់រំ។ ការដោះស្រាយគម្លាតអប់រំតម្រូវឱ្យមានកិច្ចប្រឹងប្រែងយ៉ាងខ្លាំងពីសំណាក់ប្រទេសសមាជិកអាស៊ានថ្មីទាំង៤ (CLMV) ក្នុងការលើកកម្ពស់ការចូលរៀនគ្រប់កម្រិត ជាពិសេសលើកកម្ពស់គុណភាពអប់រំ[236]។

កង្វះពលករជំនាញ និងជំនាញមិនត្រូវទៅនឹងតម្រូវការ គឺជាបញ្ហាទូទៅនៅក្នុង បណ្តាប្រទេសសមាជិកអាស៊ាន[237]។ លើសពីនេះទៀត និស្សិតក៏នៅខ្វះជំនាញដោះស្រាយ

[234] ASEAN State of Education Report 2013. The ASEAN Secretariat. Jakarta. 2014. p.22.
[235] Article 1 of the ASEAN Charter states that "To develop human resources through closer cooperation in education and life-long learning, and in science and technology, for the empowerment of the peoples of ASEAN and for the strengthening of the ASEAN community".
[236] ASEAN State of Education Report 2013. p.19.
[237] Ibid. p. 22.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បញ្ហា និងគំនិតច្នៃប្រឌិតផងដែរ។ ដើម្បីដោះស្រាយបញ្ហានេះ គេមានបំណងបង្កើតក្របខណ្ឌទទួលស្គាល់ជំនាញក្នុងបណ្ដាប្រទេសសមាជិកអាស៊ាន[238]។

ភាពខុសគ្នានៅក្នុងឧត្ដមសិក្សា និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈក៏ជាបញ្ហាប្រឈមមួយសម្រាប់អាស៊ានផងដែរ។ មានសាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្ដមសិក្សា ៦ ៥០០ នៅអាស៊ាន។ គ្រឹះស្ថានឧត្ដមសិក្សាមានចាប់តាំងពីលេខខ្ពស់ជាងគេនៅអាស៊ី និងគ្រឹះស្ថានដែលគេមិនសូវស្គាល់។ ដោយសារមូលហេតុនេះហើយ ដែលសាកលវិទ្យាល័យនៅអាស៊ានមានការស្ទាក់ស្ទើរក្នុងការទទួលស្គាល់ការផ្លាស់ប្ដូរក្រេឌីត ដែលចេញដោយសាកលវិទ្យាល័យជាដៃគូរបស់ខ្លួនក្នុងតំបន់។ នេះមិនគ្រាន់តែរាំងចលនាផ្លាស់ប្ដូរនិស្សិតក្នុងតំបន់ប៉ុណ្ណោះទេ តែក៏ជាឧបសគ្គក្នុងការធ្វើចលនាដោយសេរីក្នុងចំណោមពលករជំនាញផងដែរ។ ដើម្បីលើកកម្ពស់គុណភាពអប់រំ សាកលវិទ្យាល័យក្នុងតំបន់មួយចំនួនបានចាប់យកអន្តរជាតូបនីយកម្មនៃគ្រឹះស្ថានឧត្ដមសិក្សា។ សិង្ហបុរី គឺជាប្រទេសឈានមុខគេក្នុងការធ្វើអន្តរជាតូបនីយកម្មឧត្ដមសិក្សាដើម្បីលើកកម្ពស់សេដ្ឋកិច្ចផ្អែកលើចំណេះដឹង។ នៅប្រទេសម៉ាឡេស៊ី ការរៀបចំវិស័យឧត្ដមសិក្សាឡើងវិញមានទម្រង់ជាឯកជននីយកម្ម អាជីវកម្មនីយកម្ម និងអន្តរជាតូបនីយកម្ម[239]។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ រដ្ឋមន្ត្រីអប់រំអាស៊ានបានស្នើវិធានការក្នុងការលើកកម្ពស់ក្របខណ្ឌយោងគុណវុឌ្ឍិអាស៊ាន(AQRF) និងប្រព័ន្ធផ្លាស់ប្ដូរក្រេឌីតសម្រាប់អាស៊ាន[240]។ ទោះបីជាយ៉ាងនេះក៏ដោយ វាឆាប់ពេក ឬមិនអាចទៅរួចក្នុងការស្នើឱ្យមានសុខដុមនីយកម្មនៃប្រព័ន្ធអប់រំនៅអាស៊ាន ដោយសារតែគម្លាតគុណភាពអប់រំឆ្ងាយគ្នាពេក និងប្រព័ន្ធអប់រំខុសគ្នាដែលមានគំរូតាមបារាំង និងអង់គ្លេស[241]។ ការអប់រំមិនមែនជាបញ្ហានយោបាយតែមួយនោះទេ តែក៏ជាបញ្ហាសង្គមផងដែរ ហេតុនេះការប៉ុនប៉ងឱ្យមានសុខដុមនីយកម្មក្នុងប្រព័ន្ធអប់រំបឋមសិក្សា និងមធ្យមសិក្សាក្នុងចំណោមប្រទេសជាសមាជិកនឹងមិនមានភាពប្រាកដនិយមទេ។

ជំហានដំបូង អាស៊ានគួរតែលើកកម្ពស់ការផ្លាស់ប្ដូរនិស្សិត និងបុគ្គលិកសិក្សាក្នុងចំណោមគ្រឹះស្ថានឧត្ដមសិក្សាជាតិ ដែលបានទទួលស្គាល់គុណភាព។ ការប៉ុនប៉ងក៏គួរតែធ្វើផងដែរក្នុងការបង្កើតស្តង់ដាររួមសម្រាប់កម្មវិធីថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត និងចែករំលែកបទពិសោធកម្មវិធីបណ្ដុះបណ្ដាលល្អៗ។ បណ្ដាញសាកលវិទ្យាល័យ

238 Ibid. p.26.
239 Tham Siew Yean (Eds). Higher Education in Malaysia: Understanding, Challenges and practices. 2013. Singapore, ISEAS. p. 18.
240 Statement of the ASEAN Education Ministers Meeting in Vientiane.
241 Singapore and Brunei have adopted the o-level and A-level British systems.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាស៊ាន និងអង្គការរដ្ឋមន្ត្រីអប់រំប្រទេសអាស៊ីអាគ្នេយ៍គួរតែគាំទ្ររដ្ឋជាសមាជិកក្នុងការលើកកម្ពស់ការធានាគុណភាពអប់រំ និងធ្វើការជាមួយអ្នកវាយតម្លៃជាតិដើម្បីពង្រីកបណ្ដាញសាកលវិទ្យាល័យ ដែលនឹងត្រូវបានទទួលស្គាល់ក្នុងតំបន់ ប៉ុន្តែត្រូវតែធ្វើតាមគោលការណ៍ស្ម័គ្រចិត្ត។ ភាពជាដៃគូ និងកម្មវិធីរួមគ្នាគួរតែត្រូវបានលើកទឹកចិត្តក្នុងចំណោមសាកលវិទ្យាល័យក្នុងតំបន់។ កិច្ចសហប្រតិបត្តិការក្រោមក្របខណ្ឌសាកលវិទ្យា-ល័យវិស្វកម្មនៃបណ្ដាញសាកលវិទ្យាល័យអាស៊ាន គួរតែត្រូវបានពង្រីកទៅកាន់វិស័យផ្សេងទៀត។ អង្គការរដ្ឋមន្ត្រីអប់រំប្រទេសអាស៊ីអាគ្នេយ៍ គួរតែធ្វើការឱ្យបានជិតស្និទ្ធថែមទៀតជាមួយរដ្ឋជាសមាជិក ក្នុងការចែករំលែកការអនុវត្តល្អៗទាក់ទងនឹងជំនាញសម្រាប់ ស.វ.ទី២១ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឧត្ដមសិក្សា និងការលើកកម្ពស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

## ៥.៣. បញ្ហាប្រឈមក្នុងវិស័យអប់រំ

ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ វិស័យអប់រំនៅតែបន្តប្រឈមនឹងបញ្ហាមួយចំនួន។

(១) ការចូលរៀនយឺតនៅបឋមសិក្សា នៅតែជារឿងសំខាន់។ និន្នាការនៃការចុះឈ្មោះចូលរៀន (អត្រាកំណើនដុល និងពិត) ក្នុងរវាងឆ្នាំ១៩៩៤-២០០៤ បង្ហាញឱ្យឃើញថា នៅមានកូនសិស្សអាយុច្រើនជាង ៦ ឆ្នាំច្រើននៅឡើយ។ កូនសិស្សក្នុងចំណោមក្រុមងាយរងគ្រោះ ដែលចុះឈ្មោះចូលរៀន គឺមានអាយុច្រើនជាង ៦ ឆ្នាំច្រើន។ ក្នុងចំណោមកូនសិស្សចូលរៀនថ្នាក់ទី ១ ដែលមានអាយុស្គង់ជា ៦ ឆ្នាំ ក្នុងនោះគឺមានតែ ២៨% តែប៉ុណ្ណោះដែលមានអាយុ ៦ ឆ្នាំឬតិចជាង។ ជាទូទៅ ក្មេងអាយុ ៧ ឆ្នាំគឺចុះឈ្មោះចូលរៀនថ្នាក់ទី១ និងប្រហែលពាក់កណ្ដាលចុះឈ្មោះ ២ ឆ្នាំ ក្រោយអាយុចូលរៀន។

និន្នាការនេះមិនមានការផ្លាស់ប្ដូរទេក្នុងរវាងឆ្នាំ២០០៤-២០១១ (ការវាយតម្លៃភាព-ក្រីក្រនៅកម្ពុជារបស់ធនាគារពិភពលោក)។ ពីរភាគប្រាំនៃកូនសិស្សបឋមសិក្សាចូលរៀនក្រោយអាយុត្រូវចូលរៀនពីរឆ្នាំ ហើយដល់ថ្នាក់ទី៦ កូនសិស្សមានអាយុលើសបីឆ្នាំក្រោយអាយុត្រូវចូលរៀន។ នេះមានន័យថា ចំនួនសិស្សភាគច្រើននឹងមានអាយុពេញកម្លាំងពលកម្មនៅពេលដែលពួកគេចូលដល់ថ្នាក់មធ្យមសិក្សាបឋមភូមិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាពទី៨ ៖ លំហូរកូនសិស្សក្នុងប្រព័ន្ធសាលារៀន*




(២) អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាទាប និងអត្រាត្រួតថ្នាក់ និងបោះបង់ចោលការសិក្សាខ្ពស់។ បញ្ហានេះមានសភាពធ្ងន់ធ្ងរ ក្នុងចំណោមសិស្សក្រីក្រ ហើយកម្ពុជាមានការលំបាកក្នុងការរក្សាកូនសិស្ស ដែលមកពីគ្រួសារជួបការលំបាកឱ្យនៅក្នុងសាលារៀនបានយូរ។ ជាទូទៅ មានប្រហែលជា៨៥% នៃអ្នកដែលបានចុះឈ្មោះចូលរៀនបានបញ្ចប់បឋមសិក្សា និង៦៥% ប៉ុណ្ណោះបានបញ្ចប់ការអប់រំមូលដ្ឋាន។ កំណើនអត្រាចុះឈ្មោះចូលរៀនពិតក្នុងរយៈពេលចុងក្រោយនេះ បានមកពីការចុះឈ្មោះចូលរៀន ជាជាងបានមកពីការបញ្ចប់ការសិក្សាឱ្យត្រូវតាមអាយុ។ អត្រាត្រួតថ្នាក់ និងបោះបង់ចោលការសិក្សានៅតែខ្ពស់ ទោះបីជាកម្ពុជាមានការវិវឌ្ឍវិជ្ជមានក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ។ រវាងឆ្នាំ ១៩៩៧-២០០៦ អត្រាត្រួតថ្នាក់នៅបឋមសិក្សាមានការថយចុះពី២៦,៣% មកត្រឹម១១%។ សិស្សស្រីមានអត្រាបោះបង់ចោលការសិក្សាច្រើនជាងសិស្សប្រុស និងសិស្សនៅទីជនបទ និងដាច់ស្រយាលមានអត្រាបោះបង់ខ្ពស់ជាងសិស្សនៅទីប្រជុំជន ២ ដង។ ដោយសារតែកត្តាបោះបង់ចោលការសិក្សានេះហើយដែលធ្វើឱ្យសិស្សដែលមកពីគ្រួសារអ្នកមានមានចំនួនច្រើននៅមធ្យមសិក្សាទុតិយភូមិ។ សាលាភាគច្រើន គឺជាសាលាមិនពេលលេញ មិនមានថ្នាក់រៀនពីទី ១ ដល់ទី ៦។

នៅក្នុងឆ្នាំ២០១០ ក្នុងចំណោមសិស្ស ១ ០០០ នាក់ដែលចូលរៀននៅបឋមសិក្សាមានតែពាក់កណ្តាលទេដែលរៀនដល់មធ្យមសិក្សាបឋមភូមិ(សូមមើលរូបភាពទី ៧) និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ច្រើនជាងមួយភាគបួនបន្តិចរៀនដល់មធ្យមសិក្សាទុតិយភូមិ។ ហើយតិចជាងមួយក្នុងចំណោមប្រាំនាក់ដែលបានបញ្ចប់ការសិក្សាថ្នាក់ទី១២។

ទោះបីជាមានការរីកចម្រើនក្នុងការរក្សាកូនសិស្សឱ្យនៅក្នុងថ្នាក់ និងឆ្លងភូមិសិក្សាក៏ដោយ កូនសិស្សមួយចំនួននៅតែមិនអាចបញ្ចប់ការសិក្សាមូលដ្ឋាន ៩ ឆ្នាំបាន។ ពួកគេបានបោះបង់ចោលការសិក្សានៅកម្រិតបឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ ឬមិនបន្តការសិក្សា បន្ទាប់ពីបញ្ចប់បឋមសិក្សា។

(៣) ឧបសគ្គក្នុងការទទួលបានការសិក្សារួមមាន កត្តាខាងតម្រូវការដូចជាចំណាយលើការចូលរៀនដោយផ្ទាល់ និងមិនផ្ទាល់ខ្ពស់។ ទោះបីជាការដាក់ឱ្យមានថវិកាដំណើរការសាលា ជួយកាត់បន្ថយការចំណាយផ្ទាល់របស់គ្រួសារបានមួយកម្រិតក៏ដោយ ការចំណាយនៅតែខ្ពស់។ ថវិកាដំណើរការសាលាផ្តល់ឱ្យសាលារៀនជាពិសេសសម្រាប់ចាយលើការចុះឈ្មោះចូលរៀន សម្ភារបង្រៀន និងតេស្ត។ ទោះបីជាយ៉ាងនេះក៏ដោយ ការចំណាយនេះមានទំហំតូចបើធៀបនឹងការចំណាយលើឯកសណ្ឋាន ការធ្វើដំណើរ លុយហោប៉ៅ និងការរៀនគួរ។

(៤) អត្រាសិស្ស-គ្រូខ្ពស់ ៖ ក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយ អត្រាសិស្ស-គ្រូថ្នាក់ជាតិប្រែប្រួលពី៤៨,១ ទៅ៥០,៨ ទោះបីជាមានកំណើនថ្នាក់រៀនក៏ដោយ។ គុណវុឌ្ឍិគ្រូបង្រៀនទាប គឺជាឧបសគ្គក្នុងការលើកកម្ពស់លទ្ធផលរៀន និងបង្រៀន។ លើសពីនេះទៀត គ្រូនិងនាយកសាលាពុំបានបែកចែកប្រកបដោយសមធម៌នៅទូទាំងប្រទេសទេ។ នេះគឺជាតថភាព ដែលបណ្តាលមកពី មួយផ្នែកប្រាក់ខែទាប និងមួយផ្នែកទៀតបណ្តាលមកពីកង្វះលាភការគ្រប់គ្រាន់ ក្នុងការទាក់ទាញបុគ្គលិកទៅធ្វើការនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។

(៥) កម្មវិធីសិក្សាច្រើនហួស៖ ជាញឹកញាប់ជាការដាក់បញ្ចូលមេរៀនថ្មី និងធ្វើឱ្យមានការស្មុគស្មាញជាងមុន ដោយក្រសួងរៀបចំក្របខណ្ឌកម្មវិធីសិក្សា ដោយកំណត់សមត្ថភាព[242]។ ជាទូទៅ កម្មវិធីសិក្សាត្រូវបានពន្លឿ (បង្រៀនឱ្យលឿន) និងស្តែកស្តះ (បង្រៀនច្រើន) - នេះនាំឱ្យការបង្រៀនចាកចេញពីភាពចាំបាច់នៃអំណាន សរសេរ និងលេខនព្វន្ត ទៅកាន់រឿងផ្សេងៗជាច្រើន (ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព និងបំណិនជីវិត) និងរបៀបបង្រៀនថ្មី (ដូចជាសិស្សមជ្ឈមណ្ឌល និងការរៀនតាមបែបចូលរួម/អន្តរកម្ម)។ ជួនកាល មុខវិជ្ជាថ្មីត្រូវបានបង្រៀនជាមុខវិជ្ជាឯករាជ្យ និងជួនកាលត្រូវបាន

[242] ប្រទេសមួយចំនួនក្នុងតំបន់បានប្តូរមកជាកម្មវិធីសិក្សាដោយផ្អែកលើសាលា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀនចូលគ្នាជាមួយមុខវិជ្ជាភាសាខ្មែរ។ ការប្រែប្រួលនេះនាំឱ្យមានការលំបាកដល់គ្រូបង្រៀន ជាពិសេសក្នុងចំណោមគ្រូ ដែលមានចំណេះដឹងមុខវិជ្ជាខ្សោយ ការគាំទ្រអាជីពបង្រៀនតិច និងកង្វះកាលានុវត្តភាពចូលរួមវគ្គវិក្រឹតការ។

(៦) ផលប្រយោជន៍សេដ្ឋកិច្ច ដែលបានមកពីការវិនិយោគលើការអប់រំក្រោយកម្រិតបឋមសិក្សានៅកម្ពុជាបានធ្លាក់ចុះពី៧% ក្នុងឆ្នាំ ២០០៤ ដល់៦% នៅឆ្នាំ២០១៥។ ប្រការនេះមានន័យថា ការបញ្ចប់ការសិក្សាមួយថ្នាក់នឹងជួយឱ្យមានកំណើនប្រាក់ចំណូលតែ ៦%ប៉ុណ្ណោះ។ ហេតុនេះ សម្រាប់បុគ្គល និងក្រុមគ្រួសារដែលចាប់ផ្តើមការងារនៅអាយុ ១៦ ឆ្នាំ វានឹងមានប្រយោជន៍ខាងសេដ្ឋកិច្ចនៅក្នុងរយៈពេលវែង ប្រសិនបើពួកគេឈប់រៀននៅថ្នាក់ទី៧ ឬទី៨ ជាជាងនៅរៀនដល់ចប់ថ្នាក់ទី ៩ រួចទើបធ្វើការងារ។

ការពង្រីកប្រព័ន្ធអប់រំយ៉ាងលឿន ក្នុងរយៈពេលខ្លីបានដាក់បន្ទុកបន្ថែមលើប្រព័ន្ធមួយនេះ ដែលមិនទាន់មានគ្រឹះរឹងមាំនៅឡើយ។ នៅក្នុងអំឡុងឆ្នាំ១៩៨០ គ្រូមួយចំនួនដែលមានការបណ្តុះបណ្តាល ឬបទពិសោធតិចតួច ត្រូវបានគេរៀបចំឱ្យទៅជាគ្រូបង្រៀន និងឱ្យទៅបង្រៀនភ្លាមៗ។ នៅពេលបច្ចុប្បន្ននេះ គ្រូដែលមានបទពិសោធច្រើន និងរស់រានមានជីវិតក្រោយសម័យខ្មែរក្រហមភាគច្រើនបានចាកចេញពីវិស័យអប់រំអស់ហើយ។

លទ្ធផលមួយដែលកើតចេញពីស្ថានការណ៍នៃការបណ្តុះបណ្តាលតិចតួច និងកង្វះការគាំទ្រ គឺបានបង្កើតនូវវប្បធម៌បង្រៀនដែលមិនឱ្យអាទិភាពខ្ពស់លើការណែនាំល្អ។

ជាទូទៅ គ្រូមានសេរីភាពក្នុងការចំណាយពេលវេលាបន្ថែម លើកិច្ចការបង្រៀនដែលពួកគាត់យល់ថាត្រឹមត្រូវ។ កង្វះគំរូណែនាំល្អ និងការប្រឈមនឹងថ្នាក់រៀនដែលមានសិស្សច្រើន គ្រូភាគច្រើនបានចំណាយពេលផ្តល់តែមេរៀន និងរំពឹងថាកូនសិស្សនឹងមានទំនួលខុសត្រូវក្នុងការពង្រឹងកម្មវិធីសិក្សាទាំងមូលដោយខ្លួនឯង។

### ៥.៤. កំណែទម្រង់វិស័យអប់រំដើម្បីពង្រឹងភាពប្រកួតប្រជែង

ក្រោមក្របខណ្ឌផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិក្រសួងអប់រំយុវជន និងកីឡាបានរៀបចំ *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨* ដោយមានមហិច្ឆតាអភិវឌ្ឍធនធានមនុស្ស ដើម្បីធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ កត្តាចម្បងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ គឺយើងត្រូវបង្កើនចំនួនយុវជន និងមនុស្សពេញវ័យឱ្យមានជំនាញ

ខាងគិតលេខ អក្ខរកម្ម និងបំណិនសង្គម និងមានជំនាញបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីមានការងារធ្វើពេញលេញ និងមានសហគ្រិនភាព។

ទោះបីជាយ៉ាងនេះក៏ដោយ ក្រសួងអយកបានមើលឃើញកត្តាប្រឈមមួយចំនួនដូចខាងក្រោម ៖

**ទីមួយ**–ការគ្រប់គ្រងបុគ្គលិកមិនល្អបានធ្វើឱ្យខេត្ត និងស្រុកខ្លះខ្វះគ្រូ និងខេត្ត និងស្រុកខ្លះលើសគ្រូ នេះបណ្តាលមកពី (១) បញ្ហាបែងចែកគ្រូបង្រៀន ៖ គ្រូដែលតម្រូវឱ្យទៅបង្រៀននៅទីជនបទតែងតែសុំមកបង្រៀននៅទីប្រជុំជន ដែលនាំឱ្យមានគ្រូលើសនៅទីប្រជុំជន និងកង្វះគ្រូនៅទីជនបទ (២) កង្វះប្រព័ន្ធឧបត្ថម្ភដោយផ្អែកលើសមត្ថភាពការងារ និងកង្វះប្រព័ន្ធឧបត្ថម្ភដល់គ្រូបង្រៀននៅទីជនបទ និងទីដាច់ស្រយាល។

**ទីពីរ**–ការប្រឡងនៅគ្រប់កម្រិតទាំងអស់មានភាពមិនប្រក្រតី និងកំហុសឆ្គងដូចជាការលួចចម្លង ហេតុនេះនាំឱ្យមានការបាត់បង់ការជឿជាក់លើស្ថាប័នរដ្ឋ និងការធ្លាក់ចុះនៃគុណភាពអប់រំ។

**ទីបី**–គុណភាពនៃការអប់រំគ្រប់កម្រិតមានការធ្លាក់ចុះ និងការបណ្តុះបណ្តាលជំនាញអាជីព និងបច្ចេកទេសមិនឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍប្រទេស។

**ទីបួន**–អ្នកវិនិយោគមិនអាចរកកម្មករជំនាញគ្រប់ចំនួនតាមតម្រូវការ ហើយនិស្សិតបញ្ចប់សាកលវិទ្យាល័យមិនអាចរកការងារធ្វើបាន ដោយហេតុតែការសិក្សារបស់ពួកគេមិនឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

ហេតុនេះ បញ្ហាបន្ទាន់ និងចាំបាច់សម្រាប់ក្រសួងអប់រំ យុវជននិងកីឡា គឺត្រូវអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ដែលនឹងរួមចំណែកបង្កើនចំនួនយុវជន និងមនុស្សពេញវ័យឱ្យមានជំនាញខាងគិតលេខ អក្ខរកម្ម បំណិនសង្គម និងមានជំនាញបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីមានការងារធ្វើពេញលេញ និងមានសហគ្រិនភាព។

***វិធានការទី១*** ៖ អនុវត្តកំណែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅប្រើប្រាស់ធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព ដើម្បីកៀរគរធនធានពីខាងក្រៅបន្ថែម។ អង្គភាពកណ្តាលនៅក្រសួងអប់រំ យុវជន និងកីឡាដើរតួជាគំរូសម្រាប់មន្ទីរអប់រំ យុវជន និងកីឡា និងផ្នែកផ្សេងទៀត ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ក្រសួងនឹងណែនាំឱ្យប្រើអង្គភាពថវិកា ដើម្បីធានាថាគោលនយោបាយអប់រំនឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយមានធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់។

**វិធានការទី២** ៖ ពង្រឹងការគ្រប់គ្រងបុគ្គលិក ដោយអនុវត្តកំណែទម្រង់មន្ត្រីរាជការស៊ីវិល និងណែនាំឱ្យប្រើប្រាស់ការគ្រប់គ្រង និងដំឡើងឋានៈបុគ្គលិកតាមសមត្ថភាព និងការប្រឹងប្រែង ជាពិសេសលុបបំបាត់ការចំណាយក្រោមតុ ដើម្បីឈានទៅលុបបំបាត់ការមិនពេញចិត្តក្នុងចំណោមបុគ្គលិក។

**វិធានការទី៣** ៖ ពង្រឹងការប្រឡងគ្រប់ប្រភេទតាមរយៈការអនុវត្តគោលការណ៍ ៤ ៖ គឺច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន។ ការលុបបំបាត់ភាពអនាធិបតេយ្យ និងសំណូកដើម្បីបានប្រឡងជាប់ នឹងនាំឱ្យមានការគោរពគ្រូ និងស្តារកិត្តិយសគ្រូបង្រៀនឡើងវិញ។

**វិធានការទី៤** ៖ បង្កើតធនាគារខួរក្បាលសម្រាប់វិស័យអប់រំ នៅក្នុងនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ដោយជ្រើសរើសអ្នកជំនាញមកពីសាកលវិទ្យាល័យ ក្នុងគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងដាក់ចេញវិធានការកំណែទម្រង់វិស័យអប់រំ។

**វិធានការទី៥** ៖ កំណែទម្រង់ឧត្តមសិក្សា ក្នុងគោលដៅពង្រឹងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងត្រួតពិនិត្យគ្រឹះស្ថានឧត្តមសិក្សាឯកជន ក្នុងបំណងបណ្តុះបណ្តាលធនធានមនុស្សឱ្យមានជំនាញខ្ពស់ ដើម្បីឆ្លើយតបទៅនឹងទិសដៅអភិវឌ្ឍសេដ្ឋកិច្ច ឧទាហរណ៍ក្នុងវិស័យសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម។

**វិធានការទី៦** ៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំនៅគ្រប់កម្រិត និងការបណ្តុះបណ្តាលជំនាញ និងអាជីពឱ្យស្របនឹងតម្រូវការអភិវឌ្ឍជាតិ។

**វិធានការទី៧** ៖ អភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់ក្នុងចំណោមយុវជន ជាពិសេសការផ្តល់ជំនាញដើម្បីត្រៀមចូលសហគមន៍សេដ្ឋកិច្ចអាស៊ាន២០១៥ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងឱកាសកំណើនការងារដោយរៀបចំជា «វេទិកាការងារ» សម្រាប់យុវជន និងសិស្សក្នុងគោលបំណងឱ្យពួកគេបានជួបជាមួយអ្នកតំណាងក្រុមហ៊ុន និងសហគ្រាសមុនពេលពួកគេបញ្ចប់ការសិក្សា។

**វិធានការទី៨** ៖ កំណែទម្រង់ការអប់រំកាយ និងកីឡា ដើម្បីត្រៀមការប្រកួតកីឡាស៊ីហ្គេម២០២៣។

គោលនយោបាយកំណែទម្រង់វិស័យអប់រំអាចចែកចេញជាពីរផ្នែក ៖ ទី១-គោលនយោបាយដែលមានឥទ្ធិពលទៅលើ **ការផ្គត់ផ្គង់** (Supply side of schooling) និងទី២-គោលនយោបាយដែលមានឥទ្ធិពលទៅលើ **តម្រូវការ** (Demand side of schooling)។

កត្តាដែលកំណត់ថា តើកុមារនឹងចូលរៀនបានប៉ុន្មានឆ្នាំ និងថាតើកុមារទាំងនេះរៀនបានប៉ុន្មាននៅក្នុងសាលា អាចចែកចេញបានជាពីរផ្នែកគឺ ៖

ទី១-**កត្តាសិស្ស និងគ្រួសារ** (Child and family characteristics) និង

ទី២-**កត្តាសាលា និងគ្រូបង្រៀន** (School and teacher characteristics) ៖ ទំហំថ្នាក់រៀន (អត្រាសិស្ស-គ្រូ) គុណវុឌ្ឍិគ្រូបង្រៀន សៀវភៅគោលសិក្សា តុកៅអី ការបណ្តុះ-បណ្តាលគ្រូ វិធីសាស្ត្របង្រៀន។ ក្នុងន័យនេះ បរិស្ថានសាលារៀន ដូចជា អគារសិក្សាដែលមានដំបូល និងជញ្ជាំង ឬកម្រាលឥដ្ឋល្អ តុ កៅអី ក្តារខៀន និងបណ្ណាល័យបង្កើតឱ្យមានលក្ខខណ្ឌអំណោយផលសម្រាប់ការសិក្សារបស់សិស្ស។ គោលនយោបាយដែលមានគោលដៅកែលម្អ **កត្តាសាលារៀននិងគ្រូបង្រៀន** គឺជាគោលនយោបាយដែលមានឥទ្ធិពលទៅលើ **ការផ្គត់ផ្គង់**។

ជារួម គោលនយោបាយរបស់រាជរដ្ឋាភិបាលពិបាកនឹងមានឥទ្ធិពលលើកត្តាសិស្ស និងគ្រួសារណាស់ ថ្វីត្បិតតែគោលនយោបាយខ្លះ ដូចជាការកែពង្រឹងសុខភាពសិស្សនឹងនាំឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរជាងមុន។ ក៏ប៉ុន្តែ គោលនយោបាយរបស់រដ្ឋមានបច្ច័យដោយផ្ទាល់ និងដោយប្រយោល ទៅលើកត្តាសាលារៀន និងគ្រូបង្រៀន[243]។

ការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា កត្តាសិស្សអាចត្រូវបានកែលម្អតាមរយៈការអនុវត្តគោលនយោបាយចំនួន ៣ ដូចតទៅ[244]៖

(១) គោលនយោបាយ ដែលកែលម្អកត្តាសិស្សមុនពេលចូលរៀនបឋមសិក្សា ៖ គោលនយោបាយនេះមានគោលដៅពង្រឹងកត្តាសិស្ស នៅពេលដែលពួកគេនៅតូចៗនៅឡើយ ដូចជា ៖ (ក) កម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច ជាពិសេសការផ្តល់សេវាមត្តេយ្យសិក្សា ដែលជួយឱ្យសិស្សរៀនបានលទ្ធផលល្អ និងមានប្រាក់ចំណូលខ្ពស់ និង (ខ) កម្មវិធីសុខភាពសិក្សា និងការផ្តល់អាហារូបត្ថម្ភ ដូចជាការផ្តល់អាហារពេលព្រឹក ដល់សិស្សក្រីក្រជាដើម។ គោលនយោបាយសុខភាពសិក្សា ដូចជាការផ្តល់ថ្នាំទម្លាក់ព្រូន សុខភាពអនាម័យ ការបង្រៀនសិស្សឱ្យមានទម្លាប់លាងដៃនឹងសាប៊ូ ជួយកែលម្អប្រសិទ្ធភាពសេដ្ឋកិច្ច និងកាត់បន្ថយវិសមភាព។

243 Glewwe, P. (2014), Overview of Education Issues in Developing Countries, in Glewwe, P. (2014) Edited, Education Policy in Developing Countries, University of Chicago Press, Chicago, p. 3.
244 Glewwe, P. (2014), Overview of Education Issues in Developing Countries, p. 5.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(២) គោលនយោបាយ ដែលផ្លាស់ប្តូរឥរិយាបថរបស់សិស្ស និងគ្រូ ដែលជាគោល-នយោបាយ ដែលមានឥទ្ធិពលទៅលើ **តម្រូវការ** មានគោលដៅផ្តល់ការលើកទឹកចិត្តដល់គ្រួសារឱ្យបញ្ជូនកូនមករៀន ដូចជា ៖ (ក) កម្មវិធីផ្តល់ថវិកាដល់គ្រួសារក្រីក្រ (Conditional cash-transfer programs) (ខ) ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងសិស្សដែលរៀនពូកែ (គ) កម្មវិធីផ្តល់ថវិកាឱ្យបញ្ជូនកូនមករៀន (School-voucher Programs) (ឃ) កម្មវិធីផ្តល់អាហារពេលព្រឹក ឬ ផ្តល់ម្ហូបអាហារដល់ក្រុមគ្រួសារ (Food-for-education programs)។

(៣) គោលនយោបាយ ដែលកែលម្អការគ្រប់គ្រងសាលា និងផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា - គោលនយោបាយ ដែលមានឥទ្ធិពលទៅលើ **តម្រូវការ**ដូចជា ៖ ការពង្រឹង**ការគ្រប់គ្រងសាលារៀន** (School-based management) និងការលើកទឹកចិត្តឱ្យមានការប្រណាំងប្រជែងរវាងសាលារៀន ទាំងសាលារៀនរដ្ឋ ទាំងសាលារៀនឯកជន។ គោលនយោបាយពង្រឹងការគ្រប់គ្រងសាលារៀន រួមមាន ការធ្វើវិមជ្ឈការការគ្រប់គ្រងសាលារៀន ការធ្វើវង្វាយតម្លៃសិក្សា និងការផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀន។

លើសពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់អាទិភាពដូចខាងក្រោមសម្រាប់កំណែទម្រង់ ៖

### ៩.៤.១ ការអប់រំកុមារតូច

បង្កើនការចូលរួមរបស់កុមារអាយុ ៥ ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូច គឺជាគន្លឹះត្រៀមកូនសិស្សក្នុងការរៀនពេញមួយជីវិត កាត់បន្ថយអត្រាត្រួតថ្នាក់នៅកម្រិតបឋមសិក្សា (ជាពិសេសថ្នាក់ទី១) កាត់បន្ថយការបោះបង់ចោលការសិក្សា និងបង្កើនការចាប់អារម្មណ៍របស់ឪពុកម្តាយលើការអប់រំ។ ក្នុងឆ្នាំ ២០១២/២០១៣ មានកុមារអាយុ ៥ ឆ្នាំ៦០% ចុះឈ្មោះចូលរៀនកម្មវិធីអប់រំ និងអភិវឌ្ឍកុមារតូច (ក្នុងនោះ ៤៩,៥% ជាកុមារី) និងមានតែ ១៧,៤% ប៉ុណ្ណោះក្នុងចំណោមកុមារ ៣ និង ៤ ឆ្នាំបានចុះឈ្មោះចូលរៀនកម្មវិធីអប់រំ និងអភិវឌ្ឍកុមារតូច នេះរាប់ទាំងការអប់រំតាមខ្នងផ្ទះផងដែរ។

គោលនយោបាយការអប់រំ និងអភិវឌ្ឍកុមារតូច ត្រូវបានអនុម័តជាផ្លូវការនៅឆ្នាំ ២០១០។ គោលដៅនៃកម្មវិធីការអប់រំកុមារតូចគឺលើកកម្ពស់គុណភាព និងពង្រីកសេវាការអប់រំកុមារតូចពីអាយុ ០ ឆ្នាំដល់ ៦ ឆ្នាំ ជាពិសេសក្នុងចំណោមកុមារក្រីក្រ ជនជាតិភាគតិច និងកុមារពិការ និងជាពិសេសទៀត ការប្រើប្រាស់សេវាសហគមន៍ និងតាមខ្នងផ្ទះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងន័យនេះ អាទិភាពចម្បង គឺការពង្រីកសេវាការអប់រំកុមារតូចពីអាយុ ៣ ឆ្នាំដល់តិចជាង ៦ ឆ្នាំ និងផ្តោតលើសហគមន៍ ដែលមានអត្រាចុះឈ្មោះចូលរៀនបឋមសិក្សាទាប និងត្រួតថ្នាក់នៅបឋមសិក្សាខ្ពស់។

ការគ្រប់គ្រងមត្តេយ្យសហគមន៍ត្រូវបានធ្វើវិមជ្ឈការទៅឱ្យក្រុមប្រឹក្សាឃុំ ដែលទទួលខុសត្រូវលើចំណាយទាំងអស់ រាប់ទាំងប្រាក់ខែគ្រូបង្រៀនផងដែរ។ ហេតុនេះ វាតម្រូវឱ្យមានការបញ្ចប់ស្តង់ដារៀន មេរៀនបណ្តុះបណ្តាលគ្រូ ការត្រួតពិនិត្យគ្រូបង្គោល ក្របខណ្ឌតាមដាន និងវាយតម្លៃ និងការប្រមូលទិន្នន័យ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច ដើម្បីអនុវត្តផែនការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច ដោយប្រើប្រាស់យុទ្ធវិធីអន្តរវិស័យ និងពេញលេញរួមមាន អាហារូបត្ថម្ភ អនាម័យ ការអប់រំពីរភាសា បរិយាប័ន្ន និងបង្កើតប្រព័ន្ធអប់រំកុមារតូចដើម្បីគ្រប់គ្រងស្តង់ដារៀន មេរៀនបណ្តុះបណ្តាលគ្រូ ការត្រួតពិនិត្យគ្រូបង្គោល ក្របខណ្ឌតាមដាន និងវាយតម្លៃ និងការប្រមូលទិន្នន័យ។

## ៤.៤.២ បង្កើនអត្រាបញ្ចប់ការសិក្សាបឋមសិក្សាក្នុងស្រុកដែលមានអត្រាបញ្ចប់ការសិក្សាទាប

មធ្យមភាគបញ្ចប់ការសិក្សាបឋមសិក្សាថ្នាក់ជាតិមានកម្រិតខ្ពស់គ្រាន់បើ(៨៧,៣% ក្នុងឆ្នាំ២០១២/១៣ ៨៧,៧% ជាកុមារី) ប៉ុន្តែទិន្នន័យនេះបានមើលរំលងកត្តា ដែលមានកុមារអាយុច្រើនជាង ៦ ឆ្នាំច្រើន (ជាង ២០%) ក្នុងសាលាបឋមសិក្សា ក៏ដូចជាភាពខុសគ្នាខ្លាំងនៅតាមបណ្តាស្រុកនីមួយៗ។ យុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហានេះរួមមាន៖ «ធានាថាកុមារអាយុ ៦ ឆ្នាំទាំងអស់បានចូលរៀនគ្រប់គ្នា រាប់ទាំងកុមារពិការ កុមារជនជាតិភាគតិច» និង «កាត់បន្ថយឧបសគ្គចំណាយរបស់ឪពុកម្តាយ ដូចជាការបង់លុយក្រៅផ្លូវការ»។

ក្នុងន័យនេះ ក្រសួងអប់រំនឹងបន្ថែមជំនួយដល់សាលាកុមារមេត្រី (សាលាកុមារមេត្រីមាន ៤ ៥០៥ ក្នុងឆ្នាំ២០១១/១២ ស្មើនឹង ៦៥,៨% នៃសាលាទាំងអស់) ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនការចូលរៀន ការពារមិនឱ្យមានការបោះបង់ចោលការសិក្សា និងជំរុញឱ្យមានកំណើនបញ្ចប់ការសិក្សាខ្ពស់។ បន្ថែមពីលើនេះទៀត ក្រសួងអប់រំជំរុញឱ្យនាយកសាលា និងក្រុមតាមដានត្រួតពិនិត្យឱ្យអនុវត្តឱ្យបានពេញលេញនូវគោលនយោបាយសាលាកុមារមេត្រី ផ្តល់អាហារូបករណ៍ កម្មវិធីអាហារពេលព្រឹក អនុវត្តការអប់រំពីរភាសា កម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីពន្លឿនការរៀនសូត្រ និងកាលវិភាគ

ដែលមានលក្ខណៈបត់បែន និងផ្តល់សៀវភៅសិក្សាគោលដើម្បីធានាគុណភាពរៀននិងបង្រៀន ហេតុនេះកូនសិស្សទទួលបាននូវចំណេះដឹង និងជំនាញដោះស្រាយបញ្ហា។

### ៤.៤.៣ បង្កើនអត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិក្នុងស្រុកដែលមានអត្រាបញ្ចប់ការសិក្សាទាប

ការសិក្សាមធ្យមសិក្សាបឋមភូមិពង្រីក និងធ្វើឱ្យបំណិនមូលដ្ឋានដែលបានរៀននៅមធ្យមសិក្សាបឋមភូមិកាន់តែរឹងមាំឡើង និងត្រូវបានកំណត់ថា ជាគ្រឹះនៃការសិក្សាទាំងមូល ដែលក្នុងការឱ្យផលត្រឡប់មកវិញទាំងមកលើបុគ្គល និងមកលើសង្គមខ្ពស់ជាងឱកាសដែលបានមកពីការអប់រំក្នុងកម្រិតដទៃទៀត។ គំនិតគឺថា ត្រូវផ្តល់ជំនាញសម្រាប់មានការងារធ្វើជាបឋម សម្រាប់សិស្សមួយចំនួន និងត្រៀមសិស្សមួយចំនួនទៀតសម្រាប់ការសិក្សាបន្ត។ ហេតុនេះការងារចាំបាច់ដែលត្រូវធ្វើ គឺធ្វើយ៉ាងណាឱ្យសិស្សដែលមកពីគ្រួសារ ដែលជួបការលំបាកបានទទួលការអប់រំក្នុងកម្រិតនេះសម្រាប់ការទទួលបានការងារធ្វើដែលផ្អែកលើសមត្ថភាព។

ការចុះឈ្មោះនៅមានកម្រិតទាប (កំណើនអត្រាចុះឈ្មោះមាន ៥៣,៦% និងអត្រាចុះឈ្មោះពិតមានតែ ៣៧,៨% ក្នុងឆ្នាំ ២០១២/១៣) ហើយការបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់ (២០% ក្នុងឆ្នាំ ២០១១/១២) ជាទូទៅ កត្តានេះគឺបណ្តាលមកពីការខាតបង់នៃឱកាសរកប្រាក់ចំណូលខ្ពស់ (កម្លាំងពលកម្មកុមារ) និងចំណាយផ្ទាល់លើការសិក្សា (សៀវភៅសិក្សាគោល សម្លៀកបំពាក់ ការធ្វើដំណើរ និងការបង់លុយក្រៅផ្លូវការ) រដូវធ្វើស្រែចម្ការស្របពេលកំពុងរៀន ក៏ដូចជាចម្ងាយផ្លូវទៅសាលារៀនឆ្ងាយនៅតាមទីជនបទ និងកូនសិស្សច្រើនក្នុងថ្នាក់រៀននៅទីប្រជុំជន។ ការមើលឃើញពីគុណភាព និងផលប្រយោជន៍នៃការសិក្សាទាប ក៏ដូចជាអវត្តមានគ្រូច្រើន និងអត្រាត្រួតថ្នាក់ខ្ពស់ ក៏បានរួមចំណែកក្នុងការចុះឈ្មោះទាប និងការបោះចោលការសិក្សាខ្ពស់នៅមធ្យមសិក្សាផងដែរ។

អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិបានបង្ហាញពីទិន្នាការថយចុះក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយថយពី ៤៩% ក្នុងឆ្នាំ ២០០៨/០៩ ដល់ ៤០,៦% ក្នុងឆ្នាំ ២០១២/១៣ និងការថយចុះភាគរយនៃចំនួនកុមារអាយុ១៤ ដែលរៀនដល់ថ្នាក់ទី ៩។ ទោះបីជាយ៉ាងនេះក៏ដោយ សូចនាករហាក់មិនទាន់អាចទុកចិត្តបាន ជាពិសេសនៅកម្រិតស្រុក ពីព្រោះបញ្ហាចំណាកស្រុកខ្ពស់ និងដោយហេតុថាមានកូនសិស្សលើសអាយុច្រើននៅក្នុងសាលារៀន។ តែយ៉ាងណាក៏ដោយ និន្នាការនេះថយចុះជាលំដាប់ ពីព្រោះហេតុថាអត្រាត្រួតថ្នាក់ថយចុះយ៉ាងខ្លាំង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីដោះស្រាយបញ្ហានេះ វាតម្រូវឱ្យមានការបែងចែកគ្រូ ដែលមានសមត្ថភាពទៅតំបន់ដាច់ស្រយាល បង្កើនថវិកាចរន្តរបស់សាលា និងពង្រឹងគណៈកម្មការទ្រទ្រង់សាលា ផ្តល់អាហារូបករណ៍ សៀវភៅសិក្សាគោល និងអនុវត្តកម្មវិធីចូលរៀនឡើងវិញ កម្មវិធីពន្លឿនការរៀនសូត្រ និងកាលវិភាគដែលមានលក្ខណៈបត់បែន និងភ្ជាប់កម្មវិធីទាំងនេះជាមួយការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។

## ៤.៤.៤ កាត់បន្ថយអត្រាបោះបង់ចោលការសិក្សានៅមធ្យមសិក្សាបឋមភូមិ

ការអប់រំមធ្យមសិក្សាផ្តល់នូវក្តីសង្ឃឹមសម្រាប់យុវជនក្នុងការអភិវឌ្ឍជំនាញ និងឱកាសសម្រាប់ប្រកួតប្រជែងយកការងារល្អៗ។ ការផ្តោតលើការបោះបង់ចោលការសិក្សាផ្តល់សញ្ញាអាសន្នដំបូងសម្រាប់វិធានការបន្ថយការបោះបង់ ឱ្យបានទាន់ពេលវេលា។ សញ្ញាអាសន្នដំបូងសម្រាប់វិធានការបន្ថយការបោះបង់នឹងមានលក្ខណៈទូលំទូលាយ និងចំណាយតិចក្នុងការចាត់វិធានការ។

ប៉ុន្តែនេះមានន័យថា ជំនាញដែលបានរៀនសូត្រត្រូវតែមានភាពឆ្លើយតបនឹងតម្រូវការរបស់ពួកគេ និងពង្រីកឱ្យហួសពីចំណេះដឹងតាមមុខវិជ្ជា ធ្វើឱ្យមានជំនាញក្នុងការអនុវត្តចំណេះដឹងសម្រាប់កន្លែងធ្វើការងារ ជំនាញដោះស្រាយបញ្ហា និងជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ ហេតុនេះសាលារៀនមានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ និងអភិវឌ្ឍការអនុវត្តតាមថ្នាក់រៀន និងរបៀបបង្រៀនដើម្បីឱ្យយុវជនដែលមកពីគ្រួសារងាយរងគ្រោះមានទំនុកចិត្តលើសមត្ថភាពរបស់ខ្លួន។ ការបោះបង់ចោលការសិក្សាមានការកើនឡើងពី ១៨,៨% ក្នុងឆ្នាំ២០០៨/០៩ ដល់ ២១,៧% ក្នុងឆ្នាំ ២០១០/១១ (២១,៩% ជាកុមារី) និងមានអត្រាខុសគ្នាច្រើនរវាងទីប្រជុំជន និងទីជនបទ។

ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងអប់រំនឹងអភិវឌ្ឍយុទ្ធសាស្ត្រពេញលេញទប់ស្កាត់ការបោះបង់ចោលការសិក្សា ផ្អែកលើបទពិសោធកន្លងមកដូចជា ផ្តល់អាហារូបករណ៍ ធានាបែងចែកគ្រូបង្រៀនដែលមានសមត្ថភាពទៅទីជនបទ ពង្រឹងការអនុវត្តគោលនយោបាយសាលាមេត្រីនៅក្នុងសាលាមធ្យមសិក្សាបឋមភូមិ ដោយបញ្ចូលបញ្ហាជាក់លាក់សម្រាប់កុមារីដូចជា ថ្នាក់មេត្រីសម្រាប់កុមារី បង្គន់អនាម័យ ឯកសារបង្រៀន ធានាអនុវត្តម៉ោងបង្រៀនពេញលេញ។ បន្ថែមពីលើនេះទៀត ក្រសួងអប់រំនឹងធ្វើការដើម្បីកាត់បន្ថយអវត្តមានគ្រូ ផ្តល់ថ្នាក់បំប៉នបន្ថែមសម្រាប់សិស្សខ្សោយ អនុវត្តកាលវិភាគដែលមានលក្ខណៈបត់បែន និងកម្មវិធីពន្លឿនការរៀនសូត្រ និងពង្រឹងការឆ្លើយតបរបស់កម្មវិធីសិក្សាដោយភ្ជាប់កម្មវិធីទាំងនេះជាមួយការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៥.៤.៥ អនុវត្តកម្មវិធីអាហារូបករណ៍ថ្នាក់ជាតិសម្រាប់សិស្សក្រីក្រ និងងាយរងគ្រោះនៅសាលាបឋមសិក្សា

ការផ្តល់អាហារូបករណ៍ គឺអាចមានឥទ្ធិពលខ្លាំងទៅលើសូចនាករការបញ្ចប់ការសិក្សា ការបោះបង់ចោលការសិក្សា ការត្រួតថ្នាក់ និងភាពខុសគ្នាតាមតំបន់នៅបឋមសិក្សា។ លើសពីនេះទៀត ការបរិភោគសមរម្យមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយលទ្ធភាពចូលរៀនសម្រាប់សិស្សក្រីក្រ និងបន្ថយបញ្ហាក្មេងក្រោមទម្ងន់។

ក្រសួងនឹងបន្តអនុវត្តទម្រង់អាហារូបករណ៍ជាក់លាក់ (ដោយផ្តោតលើភាពក្រីក្រ កុមារងាយរងគ្រោះ ពិការ ក្រុមជនជាតិភាគតិច កុមារី និងតំបន់ជនបទ) និងពង្រឹងការគ្រប់គ្រងអាហារូបករណ៍(តម្លាភាព ផ្តល់ឱ្យទាន់ពេល តាមដានត្រួតពិនិត្យ និងធ្វើសវនកម្ម...)។

## ៥.៤.៦ ពង្រីកកម្មវិធីអាហារូបករណ៍ថ្នាក់ជាតិសម្រាប់សិស្សក្រីក្រ និងងាយរងគ្រោះនៅសាលាមធ្យមសិក្សា

គោលដៅគឺ ៖ (១)កាត់បន្ថយឧបសគ្គក្នុងការចូលរៀន និង (២)លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាកម្មអប់រំ ដើម្បីរក្សាកូនសិស្សថ្នាក់ទី៧-៩ ឱ្យបានច្រើន និងបង្កើនអត្រាឆ្លងពីថ្នាក់ទី៩ ទៅទី១០។ ប្រការនេះនឹងធានាបាននូវការទទួលបានការអប់រំប្រកបដោយសមធម៌ ក្នុងចំណោមសិស្សនៅតំបន់ជួបការលំបាក និងក្រីក្រ។ សាលាសរុប ៨០៩ ទទួលបានអាហារូបករណ៍ថ្នាក់ទី៧ ជាមួយនឹងកំណើនសិស្សថ្មី ៥ ០០០ នាក់ក្នុងឆ្នាំ ២០១២/១៣ (នេះស្មើនឹងសាលាថ្មី ២៨៣ ដែលចូលរួមក្នុងកម្មវិធីនេះ)។ ជាសរុប សិស្សថ្នាក់ទី៧ ចំនួន ២៤ ២៧០ នាក់ សិស្សថ្នាក់ទី៨ ចំនួន ១៥ ៤០១ នាក់ និងសិស្សថ្នាក់ទី៩ ចំនួន ១៣ ១៦៨ នាក់ទទួលបានអាហារូបករណ៍នេះ។ ក្នុងចំណោមនោះ មាន ៩ ២២០ ជាសិស្សស្រី (៦០%) ទទួលអាហារូបករណ៍នៅថ្នាក់ទី ៨ និង ៧ ៨៣០ (៦០%) ទទួលបានអាហារូបករណ៍ថ្នាក់ទី១០។

## ៥.៤.៧ បង្កើនចំនួនសាលាបង្រៀនពីរភាសា

ការអប់រំប្រកបដោយបរិយាប័ន្នជាគន្លឹះសម្រាប់ធានា «ការអប់រំប្រកបដោយសមធម៌សម្រាប់កុមារទាំងអស់ រួមទាំងកុមារដែលងាយរងគ្រោះដូចជា កុមារពិការ កុមារជនជាតិភាគតិច និងកុមារដែលកំពុងធ្វើការងារ...» ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជ្រុងទីមួយនៃគោលនយោបាយកុមារមេត្រីរបស់ក្រសួង បញ្ជាក់យ៉ាងច្បាស់អំពីសាលា ដែលមានការអប់រំប្រកបដោយបរិយាប័ន្ន ក្នុងនោះគឺការស្វែងរកកុមារនៅក្រៅសាលា ៖ សាលាកុមារមេត្រីនឹងស្វែងរកយ៉ាងសកម្មនូវកុមារដែលនៅក្រៅសាលា ជាពិសេសកុមារ ដែលងាយរងគ្រោះដោយសារភាពក្រីក្រ ពិការភាព ជនជាតិភាគតិច និងយេនឌ័រ។

ដោយសារតែមានជនជាតិភាគតិចចំនួន២៤ ហេតុនេះនៅកម្ពុជាក៏មាន ២៤ ភាសាផ្សេងគ្នាដែរ នេះនាំឱ្យមានគម្លាត ក្នុងការទទួលបានការអប់រំនៅតាមស្រុកដែលមានជនជាតិភាគតិចច្រើន។ ការអប់រំពីរភាសា (ផ្អែកលើភាសាកំណើត) ត្រូវបានចាត់ទុកថាជាយុទ្ធសាស្ត្រគន្លឹះក្នុងការសម្រេចបានគោលដៅផែនការយុទ្ធសាស្ត្រអប់រំ «ធានាការទទួលបានការអប់រំប្រកបដោយសមធម៌នៅកម្រិតបឋមសិក្សា»។

នៅកម្ពុជា កម្មវិធីអក្ខរកម្មពីរភាសាបានដំណើរការចាប់តាំងពីពាក់កណ្ដាលឆ្នាំ ១៩៩០ ហើយការអប់រំពីរភាសាត្រូវបានផ្ដួចផ្ដើមដោយអង្គការ CARE ក្នុងឆ្នាំ ២០០២ ដោយផ្អែកលើការស្រាវជ្រាវដែលបង្ហាញថា ជំនាញជាច្រើនដែលរៀននៅក្នុងភាសាទីមួយ គឺងាយស្រួលផ្ទេរមកកាន់ភាសាទីពីរក្នុងពេលក្រោយ។ ហេតុនេះ វាចាំបាច់ក្នុងការពង្រឹង និងពង្រីកគុណភាពអប់រំសម្រាប់កូនសិស្ស ដែលមានភាសាកំណើតខុសពីភាសាជាតិ។

ចេញពីសាលាបង្រៀនពីរភាសាដែលមានតែ៦ និងកូនសិស្ស ២៧៨ នាក់ក្នុងឆ្នាំ ២០០៣ ឥឡូវនេះ កម្ពុជាមានសាលាបង្រៀនពីរភាសាចំនួន ៣៩ និងកូនសិស្សប្រហែល ២ ៨០០ នាក់ ដែលមានភាសាជនជាតិភាគតិចចំនួន៥។ ទោះបីជាមានការប្ដេជ្ញាចិត្ត និងការប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាយ៉ាងនេះក៏ដោយ គេនៅតែសង្កេតឃើញថាកម្មវិធីនេះភាគច្រើននៅតែគាំទ្រដោយដៃគូអភិវឌ្ឍ។

ផ្អែកលើការវិភាគលទ្ធផលប្រឡងក្នុងឆ្នាំ ២០១៤-២០១៥ ក្រសួងអប់រំបានដាក់ចេញនូវទស្សនវិស័យកំណែទម្រង់អប់រំ ដែលរួមមានសសរស្តម្ភ ៥ នៃគុណភាពអប់រំ ៖

**ទីមួយ**–ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដើម្បីបង្កើនចំនួនគ្រូបង្រៀនដែលមានសមត្ថភាព។ គ្រូបង្រៀនគឺជាស្នូលនៃប្រព័ន្ធអប់រំ។ គុណភាពប្រព័ន្ធអប់រំផ្អែកទាំងស្រុងទៅលើគុណភាពគ្រូបង្រៀន និងអ្វីដែលពួកគាត់បង្រៀនក្នុងថ្នាក់រៀន។

**ទីពីរ**–ការធ្វើអធិការកិច្ចសាលារៀន

**ទីបី**–វង្វាយតម្លៃការសិក្សា (ការវាយតម្លៃពិន្ទុ ការប្រឡង ការធ្វើតេស្តថ្នាក់ជាតិ តំបន់ និងអន្តរជាតិ)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជីប្លួន**–ការពិនិត្យ និងកែប្រែកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលក៏ដូចជាការលើកកម្ពស់ហេដ្ឋារចនាសម្ពន្ធសាលារៀន

**ជីច្រាំ**–កំណែទម្រង់ឧត្តមសិក្សា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៦
# ការបណ្តុះបណ្តាលគ្រូបង្រៀន និងកំណែទម្រង់គ្រូបង្រៀន

ការអប់រំ គឺ ៖ (១) ជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស និងការធ្វើឱ្យមានសិទ្ធិ (២) ជាសម្បត្តិសាធារណៈ និងជាអ្នកគាំទ្រសមភាពយេនឌ័រ និង (៣) ជាកត្តាដែលធានានូវសមធម៌ និងសមភាពក្នុងសង្គម។ កម្ពុជាប្តេជ្ញាចិត្ត *«ធានាឱ្យបាននូវគុណភាពអប់រំប្រកប ដោយសមធម៌ ការអប់រំបញ្ចូលគ្នា និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា»* (គោលដៅទី៤ នៃ **ការអភិវឌ្ឍប្រកបដោយនិរន្តរភាព**)។ រដ្ឋមានកាតព្វកិច្ចរៀបចំការអប់រំសម្រាប់ជាតិ ដោយធានាឱ្យបាននូវការគោរពសិទ្ធិសម្រាប់ទទួលការអប់រំមួយ ដែលមានគុណភាពដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដើម្បីអនុវត្តការអប់រំសម្រាប់ទាំងអស់គ្នា រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការហ្មត់ចត់ ដើម្បីបង្កើនការចូលរៀនរបស់សិស្ស បង្កើនគុណភាព និងលើកកម្ពស់ភាពបញ្ចូលគ្នាក្នុងការអប់រំ។ ការលើកកម្ពស់ការបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជា។

ការអភិវឌ្ឍប្រព័ន្ធអប់រំកម្ពុជាអាចចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលទី១ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៩ ជាការកសាងឡើងវិញនូវប្រព័ន្ធអប់រំ និងដំណាក់កាលទី២ ចាប់ពីឆ្នាំ២០០០ មកជាការពង្រីកប្រព័ន្ធអប់រំ។

## ៦.១. កំណែទម្រង់គោលនយោបាយគ្រូបង្រៀនដើម្បីផ្តល់គុណភាពសេវាកម្មអប់រំ និងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា

តាមលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែង និងសេចក្តីសម្រេចទីក្រុងចុមទៀង និងទីក្រុងដាក្កាស្តីពី **ការអប់រំសម្រាប់ទាំងអស់គ្នា** និង **គោលដៅអភិវឌ្ឍសហស្សវត្សរ៍** ប្រព័ន្ធអប់រំកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស តាមរយៈកំណើននៃការបណ្តុះបណ្តាលគ្រូបង្រៀន និងកំណើននៃចំនួនគ្រូបង្រៀន។ ក្នុងរយៈពេល១២ឆ្នាំដំបូងនៃទសវត្សរ៍ឆ្នាំ២០០០ គោលនយោបាយអប់រំរបស់កម្ពុជាបានផ្តោតទៅលើការបង្កើនចំនួនកុមារឱ្យបានចូលរៀនក្នុងសាលារៀនចំណោះទូទៅ ដើម្បីសម្រេចចំណុចដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅសហស្សវត្សរ៍ ហើយផ្តោតលើគោលដៅសកលកម្មការចុះឈ្មោះចូលរៀននៅបឋមសិក្សា និងសមធម៌យេនឌ័រ។ ប្រព័ន្ធអប់រំត្រូវបានពង្រីកយ៉ាងឆាប់រហ័ស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈកម្មវិធីជាតិ ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា។ តាមរយៈកម្មវិធីនេះសាលារៀនបឋមសិក្សា និងមធ្យមសិក្សាជាច្រើនត្រូវបានសាងសង់ ដែលបានផ្តល់ឱកាសដ៏ឆាប់រហ័សដល់កុមារកម្ពុជា ដែលពីមុនគ្មានឱកាសចូលរៀនឱ្យអាចចូលរៀនបាន។

ប្រព័ន្ធអប់រំទាំងមូលកាន់តែរីកធំធាត់ កាន់តែមានភាពស្មុគស្មាញ និងកាន់តែមានការប្រឈមច្រើន។ ទាំងនេះជាចំណុចដែលទាមទារឱ្យមានការកែទម្រង់។

រាជរដ្ឋាភិបាលកម្ពុជាបានចាប់យកកម្មវិធីកំណែទម្រង់អប់រំ ក្នុងបំណងធ្វើឱ្យការអប់រំកាន់តែមានភាពបត់បែន និងឆ្លើយតបទៅនឹងតម្រូវការផ្សេងៗនៃសេដ្ឋកិច្ចដោយផ្តោតទៅលើការបង្កើនការបណ្តុះបណ្តាលវិស្វករ អ្នកឯកទេសកសិកម្ម និងឯកទេសផ្សេងទៀតក្នុងវិស័យតម្រង់ទិសវិជ្ជាជីវៈ។

កំណែទម្រង់ស្ថាប័នទាមទារឱ្យមានការប្រើគោលវិធីជាប្រព័ន្ធមួយ ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំ។ ការផ្តល់ការអប់រំដែលមានគុណភាពមួយមានសារៈសំខាន់ណាស់ ក្នុងការពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា។ សរុបមក រាល់អាទិភាពនានាត្រូវតែមានការឯកភាពនៅក្នុងគោលនយោបាយ និងក្របខណ្ឌគតិយុត្តិការគ្រប់គ្រងវិស័យ កត្តាថ្នាក់រៀន និងសាលារៀន ការសម្របសម្រួល និងដៃគូក្នុងការអប់រំ។

ស្របតាម **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ** ឆ្នាំ ២០១៤-២០១៨ ក្រសួងអប់រំយុវជននិងកីឡាបានកំណត់នូវការប្រឈមមួយចំនួន និងបានដាក់ចេញនូវវិធានការគន្លឹះខ្លះ សម្រាប់កែទម្រង់គោលនយោបាយគ្រូបង្រៀន ៖

## ៦.១.១ .មូលហេតុនៃកំណែទម្រង់គោលនយោបាយស្តីពីគ្រូបង្រៀន

ការស្រាវជ្រាវបានបង្ហាញថា *«គ្រូបង្រៀនគឺជាធាតុចូលដ៏មានសារៈសំខាន់បំផុតសម្រាប់ផ្តល់គុណភាពនៃការសិក្សា»*[245]។ គេច្រើនចាត់ទុកថា «**គុណភាពអប់រំ គឺជាគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលា**»។ ក្នុងន័យនេះ ការធ្វើកំណែទម្រង់គ្រូបង្រៀនត្រូវតែមានគោលនយោបាយគ្រូបង្រៀនដ៏ច្បាស់លាស់មួយ។ ការបណ្តុះបណ្តាល និងការធ្វើវិក្រឹតការគ្រូបង្រៀនរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កើនគុណភាពគ្រូបង្រៀន។

កំណែទម្រង់គោលនយោបាយគ្រូបង្រៀនមានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍកម្ពុជានាពេលអនាគត ដោយសារតែកំណែទម្រង់នេះជះឥទ្ធិពលដល់

[245] UNESCO, Ogawa, Keiichi (2014) «សៀវភៅណែនាំស្តីពីឧបករណ៍វិភាគសម្រាប់ការងាររដ្ឋបាលនិងហិរញ្ញវត្ថុអប់រំ» សាកលវិទ្យាល័យកូបេ ទំព័រទី២។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គុណភាពនៃការអប់រំ និងដល់លទ្ធផលសិក្សារបស់អ្នកសិក្សា។ កំណែទម្រង់គោលនយោបាយស្ដីពីគ្រូបង្រៀនបញ្ចូលដំណាក់កាលសំខាន់ៗនៃការអភិវឌ្ឍគ្រូបង្រៀនដ៏ប្រសិទ្ធភាព រួមនឹងប្រព័ន្ធគ្រប់គ្រងផង។

**គោលនយោបាយស្ដីពីគ្រូបង្រៀន**[246] ត្រូវបានអនុម័តក្នុងឆ្នាំ២០១៣។ គោល–នយោបាយនេះបានកំណត់នូវកម្មវិធីកំណែទម្រង់ច្បាស់លាស់ ប្រកបដោយមហិច្ឆតាមួយសម្រាប់កែលម្អប្រព័ន្ធអប់រំជាតិ តាមរយៈការដាក់ចេញនូវតួនាទីនិងការទទួលខុសត្រូវដល់គ្រូបង្រៀន នាយកសាលារៀន មន្ត្រីគ្រប់គ្រងអប់រំ និងអាជ្ញាធរអប់រំមូលដ្ឋាន។ ជាមួយនេះដែរ គោលនយោបាយក៏បានកំណត់យុទ្ធសាស្ត្រចាំបាច់នានា សម្រាប់បង្កើនគុណភាព និងសុខុមាលភាពបុគ្គលិកអប់រំ និងគាំទ្រដល់ច្បាប់អប់រំ ដែលបានអនុម័តកាលពីឆ្នាំ ២០០៧។

គោលនយោបាយស្ដីពីគ្រូបង្រៀនបានកំណត់សមត្ថភាព ដែលគ្រូបង្រៀនត្រូវមានក្នុងផ្នែកទាំងបួនគឺ៖ គរុកោសល្យ បុគ្គលិក សង្គម និងវិជ្ជាជីវៈ និងសម្របសម្រួលសមត្ថភាពទាំងនោះទៅក្នុង **ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន**។ ចំណុចសំខាន់ដែលគួរឱ្យកត់សម្គាល់នៃគោលនយោបាយនេះ គឺការព្យាយាម «ពង្រឹងវិជ្ជាជីវៈ» គ្រូបង្រៀន តាមរយៈការកសាងគ្រូបង្រៀន ឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម ។

កំណែទម្រង់ដ៏គ្រប់ជ្រុងជ្រោយនេះ រួមមាន ការរៀបចំជាប្រព័ន្ធ ដែលគ្របដណ្ដប់លើគ្រប់ស្ថាប័ន យន្តការ យុទ្ធសាស្ត្រ និងដំណើរការនានា ទាក់ទងទៅនឹងគ្រូបង្រៀន ដោយផ្ដើមចេញពីការជ្រើសរើសគ្រូបង្រៀនឱ្យចូលមកសិក្សាក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន រហូតដល់ពេលពួកគាត់ចូលនិវត្តន៍។ ការងារនេះមានចែងក្នុង **ច្បាប់ស្ដីពីការអប់រំ** និង **គោលនយោបាយស្ដីពីគ្រូបង្រៀន** និងលិខិតបទដ្ឋានគតិយុត្តិនានារបស់ក្រសួង ដូចជា **ផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀន** (TPAP) ដែលបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ ២០១៥។ ផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀនបានផ្ដោតទៅលើ (១) ការរៀបចំចក្ខុវិស័យថ្មីមួយ សម្រាប់វិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា (២) ការពង្រឹងគុណភាពអប់រំនៅគ្រប់ភូមិសិក្សា (៣) ការធ្វើកំណែទម្រង់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនទាំងអស់ (៤) ការផ្ដល់ការលើកទឹកចិត្ត ទាំងផ្នែកសម្ភារនិងមិនមែនសម្ភារ ជាពិសេសឋានៈវិជ្ជាជីវៈគ្រូបង្រៀន (៥) ការធ្វើការផ្លាស់ប្ដូរគោលការណ៍

[246] ក្រសួងអប់រំយុវជននិងកីឡា (២០១៣) «គោលនយោបាយស្ដីពីគ្រូបង្រៀន»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សំខាន់ៗនៃរបៀបបង្រៀន និងរៀន ដែលកំពុងអនុវត្តបច្ចុប្បន្ន សំដៅឈានទៅសម្រេចបានលទ្ធផលសិក្សារបស់សិស្សខ្ពស់ (៦) ការធានាការចូលរួម ការប្តេជ្ញាចិត្ត និងការមានចក្ខុវិស័យរួមពីគ្រប់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍទាំងអស់ និង(៧) ការរៀបចំមូលដ្ឋានគ្រឹះសម្រាប់ធ្វើកំណែទម្រង់ស៊ីជម្រៅ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀននៅក្រោយឆ្នាំ២០២០។

**ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន** ត្រូវបានរៀបចំដោយផ្អែកទៅលើស្ថានភាពបច្ចុប្បន្នរបស់គ្រូបង្រៀន។ ក្នុងឆ្នាំសិក្សា២០១៣-១៤ក្រសួងអប់រំ យុវជន និងកីឡាមានបុគ្គលិកបង្រៀនសរុបស្មើនឹង៨៣% ធៀបនឹងបុគ្គលិកទាំងអស់ដែលបម្រើការងារក្នុងក្រសួង។ ក្នុងឆ្នាំសិក្សា២០១៥-១៦ ក្នុងចំណោមបុគ្គលិកបង្រៀនសរុប ៨៨ ៨១៨នាក់ គ្រូបង្រៀននៅសាលាបឋមសិក្សាមានប្រមាណ៥១% គ្រូមធ្យមសិក្សាបឋមភូមិមាន៣១% គ្រូមធ្យមសិក្សាទុតិយភូមិមាន១៣% និងគ្រូមត្តេយ្យសិក្សាមាន៥%។ បញ្ហាដែលគួរយកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់គ្រូបង្រៀន គឺលំហូរចេញពីក្របខណ្ឌគ្រូបង្រៀន (ភាគច្រើនបានចេញដាច់ពីវិជ្ជាជីវៈគ្រូបង្រៀន) ដែលមានច្រើនជាង២ ០០០នាក់ក្នុងមួយឆ្នាំៗ (ឧទា.នៅឆ្នាំ២០១២ មាន២ ០១៧នាក់ នៅឆ្នាំ២០១៣ មាន២ ១៣៧នាក់)។ ចំនួននេះមានទំហំធំបើធៀបនឹងចំនួនក្របខណ្ឌថ្មី ដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវបណ្តុះបណ្តាលរៀងរាល់ឆ្នាំ ដែលមានចំនួនប្រមាណ ៥ ០០០នាក់។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ការខ្វះគ្រូបង្រៀននៅតែបន្តកើនឡើង ដែលបង្កបញ្ហាដល់ការផ្គត់ផ្គង់គ្រូបង្រៀន និងធ្វើឱ្យប៉ះពាល់ដល់គុណភាពសិក្សារបស់សិស្ស។ ការប្រើប្រាស់គ្រូបង្រៀន ដែលរួមបញ្ចូលទាំងការពង្រាយនិងផលធៀបគ្រូ-សិស្សមិនទាន់បានអនុវត្តឱ្យបានត្រឹមត្រូវ តាមគោលការណ៍នៅឡើយទេ។

*តារាងទី២៣ ៖ តម្រូវការគ្រូបង្រៀន*

| ឆ្នាំ | ប្រព័ន្ធអប់រំ | តម្រូវការ | កង្វះខាត |
|---|---|---|---|
| ២០១៥ | -មត្តេយ្យសិក្សា | ១០ ០៣៤ | ៤៩៩ |
| | -បឋមសិក្សា | ៤៧ ៧៦០ | ១ ៩៦១ |
| | -មធ្យមសិក្សាបឋមភូមិ | ២៧ ០៦៧ | ៩០៩ |
| | -មធ្យមសិក្សាទុតិយភូមិ | ១០ ៦២៩ | ៦៨១ |
| ២០១៦ | -មត្តេយ្យសិក្សា | ១១ ៥១៣ | ៥៣៩ |
| | -បឋមសិក្សា | ៤៨ ៦៣៧ | ២ ៣៣៦ |
| | -មធ្យមសិក្សាបឋមភូមិ | ២៧ ០៦៧ | ៩០៩ |
| | -មធ្យមសិក្សាទុតិយភូមិ | ១១ ៦៨៤ | ១ ២៨៩ |
| ២០១៧ | -មត្តេយ្យសិក្សា | ១២ ៨៣០ | ៥៦៤ |
| | -បឋមសិក្សា | ៥០ ៩៩៧ | ៣ ៣៧៥ |



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

| | | | |
|---|---|---|---|
| | -មធ្យមសិក្សាបឋមភូមិ<br>-មធ្យមសិក្សាទុតិយភូមិ | ២៧ ៤៥១<br>១៣ ២៦៤ | ១ ៣០៦<br>១ ៨៤៥ |
| ២០១៨ | -មត្តេយ្យសិក្សា<br>-បឋមសិក្សា<br>-មធ្យមសិក្សាបឋមភូមិ<br>-មធ្យមសិក្សាទុតិយភូមិ | ១៤ ២២៩<br>៥២ ៩៤៨<br>២៧ ៨២៤<br>១៥ ៦៦៨ | ៥៦២<br>៤ ០៤០<br>១ ៣០៩<br>២ ៧១៧ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា /* UNICEF

កន្លងមក ដោយសារកត្តាប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងសង្គម-សេដ្ឋកិច្ច ក្រសួងអប់រំ យុវជន និងកីឡាបានប្រើរូបមន្តច្រើនសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន។ ចាប់ពីដើមទសវត្សរ៍ឆ្នាំ ១៩៨០ រយៈពេលនៃការបណ្តុះបណ្តាល គឺមានការកើនឡើងចាប់ពី៤ ខែ ៧ខែ ឈានទៅប្រើប្រាស់រូបមន្ត ៣+១[247], ៤+១, ៥+៣, ៧+១, ៨+១, ៧+៣, ១០+៣, ១០+៤, ១១+១, ១២+១, ១២+២ រហូតដល់បរិញ្ញាបត្របូក១។ មកដល់ពេលនេះការបណ្តុះ-បណ្តាលគ្រូបង្រៀនតាមរូបមន្តទាបៗ (ទាបជាងបរិញ្ញាបត្របូក១) មានចំនួន១១១ ជំនាន់ និងបានបណ្តុះបណ្តាលគ្រូបង្រៀនប្រមាណ ១០២ ០០០ នាក់[248]។

នៅឆ្នាំ ២០២០ ក្រសួងអប់រំ យុវជន និងកីឡាមានបំណងឱ្យគ្រូបង្រៀនកម្រិតមូលដ្ឋានទទួលបានស្តង់ដាគុណវុឌ្ឍិបរិញ្ញាបត្រ បូក១ ឬ១២+៤ និងគ្រូបង្រៀនកម្រិតឧត្តមទទួលបានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បូក១។ បច្ចុប្បន្នគ្រូបង្រៀន ដែលមានគុណវុឌ្ឍិទាបជាងសញ្ញាបត្របរិញ្ញាបត្រមានចំនួនជាង ៧៥ ០០០នាក់ (EMIS, ២០១៣)។

*តារាងទី២៤ ៖ ស្តង់ដាគុណវិឌ្ឍិគ្រូបង្រៀន*

| កម្រិតសិក្សា | ១៩៨០-១៩៩៥ | ១៩៩៦-២០១៤ | ២០១៥-២០២០ |
|---|---|---|---|
| មត្តេយ្យសិក្សាបឋមសិក្សា ៖ ដាច់ស្រយាល<br>ក្រុង | ៧+១<br>៨+១ | ៩+២<br>១២+២ | ១២+២ |
| បឋមសិក្សា ៖ ដាច់ស្រយាល<br>ក្រុង | ៧+១<br>៨+២ | ៩+២<br>១២+២ | ១២+២ |
| មធ្យមសិក្សាបឋមភូមិ ៖ ដាច់ស្រយាល<br>ក្រុង | ៧+៣<br>៨+៣<br>៩+១ | ១២+២ | ១២+២ |
| មធ្យមសិក្សាទុតិយភូមិ | ១១+៣<br>១១+៤ | បរិញ្ញាបត្រ+១ | បរិញ្ញាបត្រ+១ |

247 ៣+១ គឺមានន័យថាជ្រើសរើសអ្នករៀនចប់ថ្នាក់ទី ៣ រួចបណ្តុះបណ្តាលចំនួន ១ ឆ្នាំដើម្បីឱ្យក្លាយជាគ្រូបង្រៀន។

248 ប្រភពនា.បវ (២០១៤) ចំនួននេះមិនបានបញ្ចូលទិន្នន័យ បរិញ្ញាបត្រ+១ តាមឆ្នាំសិក្សាមួយចំនួនទេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| ឧត្តមសិក្សា | | បរិញ្ញាបត្រ+ | បរិញ្ញាបត្រជាន់ខ្ពស់ + |
|---|---|---|---|

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ថ្មីៗនេះ (ឆ្នាំសិក្សា២០១៥-១៦) អត្រាបុគ្គលិកអប់រំ ដែលមានសញ្ញាបត្របរិញ្ញាបត្រ មានការកើនឡើងប្រមាណ ២% ក្នុងមួយឆ្នាំ។ តួលេខនេះបង្ហាញថា បើសិនជាគ្មានគោល-នយោបាយ និងអន្តរាគមន៍បន្ថែមទេ នៅឆ្នាំ២០២០ ចំនួនគ្រូបង្រៀនដែលមានគុណវុឌ្ឍិបរិញ្ញាបត្រនឹងមានត្រឹមតែ២៨%ប៉ុណ្ណោះ(សូមមើលតារាងខាងក្រោម)។ ដូច្នេះ កិច្ចការដែលត្រូវធ្វើជាបន្ទាន់សម្រាប់ការបណ្តុះបណ្តាល និងវិក្រឹតការ គឺត្រូវធានាថាគ្រូបង្រៀនមានឱកាសអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីទទួលបានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រ ឬកម្រិតប្រហាក់ប្រហែល។

*តារាងទី២៥ ៖ កម្រិតវប្បធម៌របស់គ្រូបង្រៀន*

| ឆ្នាំសិក្សា | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | មធ្យមសិក្សាទុតិយភូមិ | បរិញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | បណ្ឌិត |
|---|---|---|---|---|---|---|
| ២០១២-១៣ | ១ ៩២៣ | ២៧ ៥៤២ | ៤៦ ២៣០ | ១០ ៩៨៨ | ៥១៨ | ១ |
| ២០១៣-១៤ | ១ ៧០៨ | ២៣ ៩៣៤ | ៥០ ០០៦ | ១២ ៦១១ | ៥៥៥ | ៤ |
| ២០១៤-១៥ | ១ ៥៥០ | ២២ ៩១០ | ៤៩ ៧១៧ | ១៤ ២១២ | ៧៥៧ | ៥ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ការលំបាកមួយក្នុងការទាក់ទាញបេក្ខជនរៀនពូកែឱ្យមកចូលធ្វើគ្រូបង្រៀន គឺមកពីស្ថានភាពសង្គមរបស់គ្រូបង្រៀននៅមានកម្រិតទាបនៅឡើយ។ បច្ចុប្បន្នគ្រូបង្រៀនទទួលបៀវត្សទាបនៅឡើយ បើប្រៀបធៀបនឹងបៀវត្សរបស់អ្នកមានវិជ្ជាជីវៈផ្សេងទៀតក្នុងវិស័យឯកជន ដែលមានគុណវុឌ្ឍិ និងបំណិនប្រហាក់ប្រហែលគ្នា។ គ្រូបង្រៀនជាច្រើនបានបង្ខំចិត្តប្រកបមុខរបរទីពីរ ដែលភាគច្រើនទទួលកម្រៃតិចតួចបន្ថែមសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ។ ទង្វើនេះបានធ្វើឱ្យសហគមន៍ជុំវិញពួកគាត់ឱ្យតម្លៃទាបដល់វិជ្ជាជីវៈ និងឋានៈគ្រូបង្រៀននៅក្នុងសង្គម។ អាស្រ័យហេតុនេះ រួមផ្សំនឹងកត្តាទាក់ទងផ្សេងទៀត ទើបកន្លងមកមានគរុសិស្ស/គរុនិស្សិតជាង៨០% ដែលប្រឡងចូលសាលាគរុកោសល្យមាននិទ្ទេសសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិត្រឹមតែ D ឬ Eប៉ុណ្ណោះ។ ដើម្បីបង្កើនគុណភាពអប់រំឱ្យបានឆាប់រហ័ស សម្រាប់រយៈពេលខ្លី និងមធ្យម គឺទាមទារឱ្យមានសកម្មភាពបន្ទាន់មួយ ដែលផ្តល់អាទិភាពដល់ការបង្កើនការទាក់ទាញបេក្ខជន ដែលពូកែឱ្យចូលក្នុងវិជ្ជាជីវៈគ្រូបង្រៀន និងផ្តល់ការបណ្តុះបណ្តាលដែលមាន រយៈពេលខ្លីចំពោះបេក្ខជន ដែលមានគុណវុឌ្ឍិខ្ពស់ ព្រមទាំងការបង្កើតច្រកចូលច្រើនសម្រាប់ចូលធ្វើ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាគ្រូបង្រៀន ដែលអនុញ្ញាតឱ្យនិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យឆាប់បានទៅជួយបង្រៀនសិស្សក្នុងថ្នាក់។

លើសពីនេះ **គោលនយោបាយស្តីពីគ្រូបង្រៀន** និង **ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន** មានសមាសភាគសំខាន់ៗ ដែលក្តោបគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍគ្រូបង្រៀន។

## ៦.២. យុទ្ធសាស្ត្រកំណែទម្រង់គោលនយោបាយគ្រូបង្រៀន

តាមការសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុន **McKinsey** និងការសិក្សាផ្សេងទៀតស្តីពីសាលារៀន ដែលមានសមិទ្ធផលខ្ពស់ជាងគេ បានបង្ហាញឱ្យឃើញថា គ្រូបង្រៀនគឺជាកត្តាយ៉ាងសំខាន់បំផុត ដែលកំណត់នូវលទ្ធផលសិក្សារបស់សិស្ស។ មានកត្តាចំនួនបី ដែលធ្វើឱ្យសាលារៀនទទួលបាននូវជោគជ័យ ៖

ទីមួយ– ជ្រើសរើសបេក្ខជនដែលមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈនេះ

ទីពីរ– រៀបចំរចនាសម្ព័ន្ធប្រាក់បៀវត្សសមស្របសម្រាប់គ្រូបង្រៀន

ទីបី– បណ្តុះបណ្តាលគ្រូបង្រៀន ឱ្យក្លាយទៅជាអ្នកអប់រំប្រកបដោយប្រសិទ្ធភាពខ្ពស់ និងសក្តានុពល[249]។

ដើម្បីពង្រឹង និងកែលម្អកត្តាគ្រូ ក្នុងការអភិវឌ្ឍវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័ត ក្នុងខែមករា ឆ្នាំ២០១៥ **នូវផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន** ដែលមានសមាសភាគសំខាន់ៗដូចតទៅ[250] ៖

### ៦.២.១ .ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន

ដើម្បីទាក់ទាញបេក្ខជន ដែលមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀនរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្របង្កើនប្រាក់បៀវត្ស និងលើកកម្ពស់ឋានៈ និងតម្លៃរបស់គ្រូបង្រៀនដូចតទៅ ៖

---

[249] McKinsey & Company (2007) How the World's Best-Performing School Systems Come on the Top; see also Hanushek, E.A. and S.G. Rivkin. (2003). How to Improve the Supply of High Quality Teachers. Paper Prepared for the Brookings Papers on Education Policy.

[250] ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) «ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន» ភ្នំពេញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### *ក.លើកកម្ពស់ជីវភាព តម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម*

កំណែទម្រង់ផ្តោតទៅលើការតម្លើងប្រាក់បៀវត្ស និងប្រាក់បំណាច់មុខងាររបស់គ្រូបង្រៀន ឱ្យសមស្របតាមកំណើនសេដ្ឋកិច្ច និងលទ្ធភាពថវិកាជាតិ។ ការស្រាវជ្រាវបង្ហាញឱ្យឃើញថា *«ការលើកទឹកចិត្តដល់គ្រូបង្រៀន ដែលរៀបចំបានល្អ នឹងបង្កើនការខិតខំប្រឹងប្រែងរបស់គ្រូ និងពង្រឹងលទ្ធផលសិក្សារបស់សិស្ស ដែលកំពុងរៀនក្នុង បរិបទមួយដែលលំបាក។ ក៏ប៉ុន្តែ គ្រូដែលមានគុណវុឌ្ឍិទាបត្រូវមានអ្នកជួយណែនាំ ដើម្បី ឱ្យពួកគេអាចបង្រៀនសិស្ស ក្នុងកម្រិតមួយដែលអាចទទួលយកបាន និងដើម្បីឱ្យការរៀនសូត្រប្រចាំថ្ងៃរបស់សិស្ស មានការប្រែប្រួល»*[251]។

យុទ្ធសាស្ត្រនេះត្រូវបានអនុវត្ត តាមរយៈការច្របាច់បញ្ចូលគ្នានូវប្រាក់បំណាច់ និងប្រព័ន្ធលាភការផ្សេងៗរបស់បុគ្គលិកអប់រំ ឱ្យទៅជា «**ចាក់បំណាច់អប់រំ**» ដែលត្រូវបំពេញបន្ថែមទៅនឹងប្រាក់បៀវត្សមូលដ្ឋាន និងជួយលើកទឹកចិត្តដល់ «វិជ្ជាជីវៈគ្រូបង្រៀន»។ កំណែទម្រង់ថ្មីៗរបស់រាជរដ្ឋាភិបាលកម្ពុជា គឺសំដៅលើកកម្ពស់ជីវភាពរបស់គ្រូបង្រៀនដូចមានបង្ហាញខាងក្រោម៖

- អនុក្រឹត្យ ៩៦៨ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ ២០១៣ ស្តីពីការបង្កើនបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខណ្ឌ គ ឋានន្តរសក្តិទី ៣ និង ក្របខណ្ឌ គ ឋានន្តរសក្តិទី ២ ក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឱ្យដល់កម្រិត ៣២០ ០០០៛ ហើយអនុវត្តពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០១៣។
- <u>ការតម្លើងបៀវត្សក្នុងឆ្នាំ ២០១៧</u> ៖ (១) ផ្តល់ ៩០ ០០០៛ ក្នុង ១ខែលើបៀវត្ស ក្របខណ្ឌ ក (២) ផ្តល់ ៨០ ០០០៛ ក្នុង ១ខែលើបៀវត្ស ក្របខណ្ឌ ខ គ និង ឃ

  និង (៣) ផ្តល់បន្ថែម ដើម្បីឱ្យបៀវត្សអប្បបរមាឡើងដល់ ៩២៩ ០០០៛។
- <u>កំណែទម្រង់ប្រាក់បៀវត្ស រយៈពេលមធ្យម ២០១៥-២០១៨</u>
- <u>ការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ</u> ៖ ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានជ្រើសរើសជាក្រសួងអាទិភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០១៤ ដោយចាប់ផ្តើមពីថ្នាក់កណ្តាល រួចទើបបន្តនៅថ្នាក់ក្រោមជាតិ។

ការបង្កើន «**ចាក់បំណាច់អប់រំ**» បានធ្វើឱ្យវិជ្ជាជីវៈបង្រៀនកាន់តែមានភាពទាក់ទាញ និងបង្កើតឱ្យមានការលើកទឹកតម្លៃវិជ្ជាជីវៈគ្រូបង្រៀន។ ម្យ៉ាងវិញទៀត

[251] Murnane and Ganimian (2014).



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបើកបៀវត្សទាន់ពេលដល់គ្រូបង្រៀន និងការផ្តល់លាភការផ្សេងទៀតបានជួយដល់គ្រូបង្រៀនឱ្យកាន់តែមានកម្លាំងចិត្តច្រើនឡើង។ ការបើកបៀវត្សតាមប្រព័ន្ធធនាគារក៏បានចូលរួមចំណែកក្នុងការកាត់បន្ថយបុគ្គលិកខ្មោចផងដែរ។

### *១.លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន និងកំណត់លក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស*

តាមបទពិសោធពីបណ្តាប្រទេសជាច្រើនបង្ហាញថា ការទាក់ទាញអ្នកដែលមានសមត្ថភាពខ្ពស់ ឱ្យចូលបម្រើការងារជាគ្រូបង្រៀនទាមទារកត្តាជាច្រើន ដូចជាការបង្កើនបៀវត្ស ការលើកកម្ពស់តម្លៃវិជ្ជាជីវៈ និងឋានៈគ្រូបង្រៀន ការរៀបចំគន្លងអាជីពគ្រូបង្រៀន និងការប្រែក្លាយគ្រូបង្រៀនឱ្យទៅជា *«អ្នកមានជំនាញវិជ្ជាជីវៈ អ្នកមានស្មារតីនវានុវត្ត និងអ្នកស្រាវជ្រាវក្នុងវិស័យអប់រំ»*[252]។

ការជ្រើសរើសគរុនិស្សិតឱ្យចូលទៅសិក្សាក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គឺជាជំហានទី១នៃអាជីពរបស់គ្រូបង្រៀនថ្មី។ យើងបានដាក់ចេញនូវយុទ្ធសាស្ត្រ ដើម្បីជ្រើសរើសបេក្ខជន ដែលមានសមត្ថភាពខ្ពស់ ឱ្យចូលបម្រើក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ចាប់ពីឆ្នាំ២០១៥មក ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចទទួលយកសិស្ស ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និទ្ទេស A, B និងC ឱ្យជាប់ជាស្វ័យប្រវត្តិ ដើម្បីចូលរៀនក្នុងសាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ក្នុងការ បណ្តុះបណ្តាលគ្រូកម្រិតបឋម និងគ្រូកម្រិតមូលដ្ឋាន។ ការបង្កើតឱ្យមានច្រកចូលច្រើន ដើម្បីធ្វើជាគ្រូបង្រៀន ក៏អាចទាក់ទាញបេក្ខជនដែលមានសមត្ថភាពខ្ពស់ ឱ្យចូលធ្វើគ្រូដែរ។ វិធីនេះអាចអនុវត្តទៅបាន ដោយអនុញ្ញាតឱ្យបេក្ខជន ដែលមានសញ្ញាបត្របរិញ្ញាបត្រ ចេញដោយគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន និងតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលពន្លឿន សម្រាប់គ្រូ១២+២ ឱ្យទទួលបានសញ្ញាបត្របរិញ្ញាបត្រ ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា ហើយបន្ទាប់មកផ្តល់ឱ្យគរុនិស្សិតទាំងនោះ នូវអាជ្ញាបណ្ណគ្រូបង្រៀន។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡាអាចផ្តល់អាហារូបករណ៍សិក្សា ដល់បេក្ខជនដែលមានសមត្ថភាពខ្ពស់ ឱ្យចូលធ្វើគ្រូបង្រៀន។

ជាការពិតណាស់ កំណែទម្រង់គ្រូត្រូវផ្តោតទៅលើការពង្រឹងគុណវុឌ្ឍិគ្រូបង្រៀន។ ក៏ប៉ុន្តែ បទពិសោធដែលមាននៅក្នុងការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា កម្រិតគុណវុឌ្ឍិដែលគ្រូទទួលបានក្នុងរយៈពេលបណ្តុះបណ្តាលមុនក្លាយជាគ្រូបង្រៀន មិនមែនជាកត្តា

---

[252] Andreas Schleicher (2011) Building a High-Quality Teaching Professions: Lessons from Aroud the World.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចាំបាច់ ដែលកំណត់នូវការបង្រៀនប្រកបដោយប្រសិទ្ធភាពទេ។ កត្តាផ្សេងទៀត ដូចជា **ប្រព័ន្ធគ្រប់គ្រងល្អ** និង **ស្វ័យភាពសាលារៀន** គឺជាកត្តាដែលមានសារៈសំខាន់ក្នុងការសម្រេចបាននូវលទ្ធផលល្អប្រសើរ។

ការសិក្សាស្រាវជ្រាវក៏បានផ្តល់នូវអនុសាសន៍ ឱ្យអនុវត្តការបណ្តុះបណ្តាលគ្រូ ឱ្យមានសង្គតិភាពជាមួយកម្មវិធីសិក្សា គរុកោសល្យ ចំណេះដឹង និងការអនុវត្ត។ ម្យ៉ាងវិញទៀត ការរៀបចំសៀវភៅគ្រូ និងការរៀបចំកិច្ចតែងការបង្រៀន គឺជាវិធីសាស្ត្រដ៏ល្អ ក្នុងការកែលម្អគុណភាពរៀន និងបង្រៀន។ ក្នុងន័យនេះ គ្រូត្រូវមានគរុកោសល្យ និងចេះវិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីទាក់ទាញសិស្សឱ្យផ្តោតលើការសិក្សា។ ប្រព័ន្ធអប់រំត្រូវរៀបចំឱ្យមានការគាំទ្រដល់គ្រូ ដែលបង្រៀនតាមថ្នាក់រៀន និងបង្កើតនូវប្រព័ន្ធគាំទ្រ ដល់គ្រូ ដែលមិនសូវមានបទពិសោធ ឱ្យចូលរួមសិក្ខាសាលា គាំទ្រការបង្រៀនក្នុងថ្នាក់រៀនស្វ័យសិក្សា និងរៀបចំកម្រងបច្ចេកទេស។

ការសិក្សាស្រាវជ្រាវបានបង្ហាញថា កត្តាខាងក្រោមនេះ គឺជា *«សមាសភាគគន្លឹះនៃការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន»*[253]៖

- ការបណ្តុះបណ្តាល ដែលផ្តោតលើ **វិធីសាស្ត្របង្រៀន** ដែលសមស្របទៅនឹងតួនាទីនិងភារកិច្ចរបស់គ្រូបង្រៀន ជាជាងការបណ្តុះបណ្តាលដែលផ្តោតទៅលើតែទ្រឹស្តី
- វិធីសាស្ត្រគរុកោសល្យ ដែលផ្សារភ្ជាប់ចំណេះដឹងជាក់ស្តែង និងបំណិនពាក់ព័ន្ធនឹងការរៀនរបស់សិស្ស
- សកម្មភាពដែលពាក់ព័ន្ធនឹងការបង្រៀននៅក្នុងថ្នាក់រៀន និងការងារសាលា
- ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា រួមទាំងវិធីសាស្ត្រអំណាន
- សង្គតិភាពរវាងគរុកោសល្យសម្រាប់ការបណ្តុះបណ្តាលគ្រូ និងគរុកោសល្យសម្រាប់បង្រៀនសិស្ស។

ម្យ៉ាងវិញទៀត កំណែទម្រង់ទាមទារឱ្យមានការផ្លាស់ប្តូរទម្លាប់ និងវប្បធម៌នៃអាជីពគ្រូបង្រៀន[254]។សារជាតិរបស់មនុស្សមិនចូលចិត្តភាពមិនប្រាកដប្រជា។ ដូច្នេះហើយទើបមានការប្រឆាំងនឹងកំណែទម្រង់។ ក្នុងន័យនេះ ដើម្បីឱ្យកំណែទម្រង់ទទួល

[253] Vegas (2005), cited in Murnane and Ganimian (2014).
[254] Argyris (1992), cited in Dooley (1995).



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជោគជ័យ ចាំបាច់ត្រូវមានចក្ខុវិស័យច្បាស់លាស់ ដើម្បីឱ្យបុគ្គលិកអប់រំមានជំនឿជឿជាក់ទៅលើកំណែទម្រង់គ្រូបង្រៀន។

## ៦.២.២ .កំណត់ស្តង់ដាប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន

ដើម្បីលើកទឹកចិត្តគ្រូបង្រៀនឱ្យគិតថា គ្រូជាមុខរបរប្រកបដោយកិត្តិយសនោះ ក្រសួងអប់រំ យុវជន និងកីឡាត្រូវផ្តល់ការបណ្តុះបណ្តាលគ្រូ ឱ្យមានចំណេះដឹងទូទៅ បំណិន និងតម្លៃ ដើម្បីក្លាយខ្លួនទៅជាគ្រូបង្រៀនល្អ។ ដើម្បីសម្រេចបាននូវគោលដៅនេះ យើងបានដាក់ចេញនូវវិធានការដូចតទៅ ៖

### *ក. ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន*

ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនជាកត្តាដ៏មានសារៈសំខាន់ក្នុងការរួមចំណែកលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀន។

សម្រាប់ប្រទេសកម្ពុជា វិធីថ្មីសម្រាប់ពង្រឹងគុណភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការបណ្តុះបណ្តាលគ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ក្នុងបរិបទនៃការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនមានសារៈសំខាន់ណាស់។ វិធានការនេះរួមមាន ៖ (១) កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មីផ្អែកលើសមត្ថភាព(Competency-based) ដើម្បីបង្កើនចំណេះដឹង និងបំណិនដល់គ្រូថ្មី (២) គរុសិស្ស/គរុនិស្សិតត្រូវចំណាយពេលវេលាច្រើន ដើម្បីអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀនចាប់ពីពេលដំបូង ដើម្បីឱ្យពួកគេនឹងក្លាយជាគ្រូបង្រៀន ដែលចេះទាំងការអនុវត្ត ទាំងការបង្កើនបំណិន និងចំណេះដឹងដែលចាំបាច់ក្នុងការបង្រៀន។

ការធ្វើកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូ អាចសម្រេចទៅបានដោយសារ ៖

(១) ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីបណ្តុះបណ្តាលបួនឆ្នាំថ្មីសម្រាប់គ្រូបឋមសិក្សា ដែលកម្មវិធីនេះជំនួសឱ្យកម្មវិធី ១២ +២ (ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងរៀន ២ឆ្នាំ) ព្រមទាំងការពិនិត្យឡើងវិញ និងការពង្រឹងគុណភាពនៃវគ្គបណ្តុះបណ្តាលគ្រូបឋមសិក្សា និងមធ្យមសិក្សា ដោយបញ្ចូលនូវមុខវិជ្ជាថ្មី និងវិធីសាស្ត្របង្រៀនថ្មី។

(២) រៀបចំការសិក្សាស្រាវជ្រាវលម្អិត អំពីប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនបច្ចុប្បន្ន ដោយសិក្សា និងវិភាគធនធាន និងហេដ្ឋារចនាសម្ពន្ធគ្រឹះស្ថានបណ្តុះបណ្តាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រូបង្រៀនដែលមានស្រាប់ និងតម្រូវឱ្យគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀននីមួយៗធ្វើការសិក្សាស្វ័យវាយតម្លៃ ធៀបនឹងស្ដង់ដាគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន (TEPS)។

(៣) កែទម្រង់កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនគ្រប់កម្រិតតាមរយៈ ៖ (ក)រៀបចំកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរូបមន្ត១២+៤ (បរិញ្ញាបត្រអប់រំ) សម្រាប់សិស្សថ្នាក់ទី១២ ដែលជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយផ្ដោតលើចិត្តគរុកោសល្យ ICT វិធីសាស្ត្របង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្ត្រ។ (ខ) រៀបចំកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតមូលដ្ឋាន តាមរូបមន្តបរិញ្ញាបត្រ+១ សម្រាប់អ្នកមានបរិញ្ញាបត្រនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដោយផ្ដោតលើចិត្ត-គរុកោសល្យ ICT វិធីសាស្ត្របង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្ត្រ។ (គ)រៀបចំកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម(បង្រៀននៅវិទ្យាល័យ)តាមរូបមន្តបរិញ្ញាបត្រជាន់ខ្ពស់+១ នៅវិទ្យាស្ថានជាតិអប់រំ សម្រាប់អ្នកមានបរិញ្ញាបត្រជាន់ខ្ពស់ ដោយផ្ដោតលើចិត្តគរុកោសល្យ ICT វិធីសាស្ត្របង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្ត្រ។ (ឃ) ពង្រឹងកម្មសិក្សាគរុកោសល្យ និងគាំទ្រសាលាអនុវត្ត ដែលនៅជិតសាលាគរុកោសល្យ និងប្រើប្រាស់សម្រាប់ធ្វើកម្មសិក្សាគរុកោសល្យ។ (ង) ធានាថាមានការបញ្ជ្រាបការអប់រំបញ្ចូលគ្នា និងយេនឌ័រ ក្នុងការកែលម្អកម្មវិធីបណ្ដុះបណ្ដាលគ្រូ។

ក្នុងគោលដៅបង្កើនគុណវុឌ្ឍិគ្រូបង្រៀនពី ១២+២ ទៅ ១២+៤ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកម្មវិធីបណ្ដុះបណ្ដាលតាមប្រព័ន្ធពន្លឿន តាមរយៈការរៀបចំកម្មវិធីប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន (១២+២) ដើម្បីធ្វើការបណ្ដុះបណ្ដាល ឱ្យទៅជាកម្រិត(១២+៤) ក្នុងរយៈពេល ១០ ខែ និងមាន៦០ ក្រេឌីត លើមុខវិជ្ជា ចំនួន៦ រួមមាន ៖ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា។ ក្រសួងនឹងកំណត់យកគ្រឹះស្ថានឧត្ដមសិក្សា ដើម្បីធ្វើការបណ្ដុះបណ្ដាល ប្រកបដោយគុណភាព។

(៤) អនុវត្តការបណ្ដុះបណ្ដាលគ្រូបង្រៀនតាមស្ដង់ដាគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន(TEPS) តាមរយៈ ៖ (ក) សាកល្បងអនុវត្តការបណ្ដុះបណ្ដាលគ្រូបង្រៀនតាមរូបមន្ត ១២+៤ (បរិញ្ញាបត្រអប់រំ) នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួនពីរ ដោយប្រើជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្ដមសិក្សា។ (ខ) សាកល្បងអនុវត្តការបណ្ដុះបណ្ដាលគ្រូបង្រៀនតាមរូបមន្ត បរិញ្ញាបត្រ+១ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួនពីរ ដោយប្រើជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្ដមសិក្សា និង អនុវត្តការបណ្ដុះបណ្ដាលគ្រូបង្រៀន

តាមរូបមន្តបរិញ្ញាបត្រជាន់ខ្ពស់+១ នៅវិទ្យាស្ថានជាតិអប់រំ និងនៅគ្រឹះស្ថានឧត្តមសិក្សាណា ដែលបំពេញបានតាមស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (TEPS)។

## ១. បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខណ្ឌ

ដោយមានចំណេះដឹងមូលដ្ឋានដ៏រឹងមាំ គ្រូចេញថ្មីប្រែក្លាយពីគរុសិស្ស/គរុនិស្សិតទៅជាគ្រូបង្រៀនពេញលក្ខណៈ ដោយងាយស្រួល។ រយៈពេលកម្មសិក្សា គឺជាពេលវេលាដកស្រង់បទពិសោធ ដែលមានរយៈពេលមួយឆ្នាំ។ រយៈពេលនេះ គឺជាពេលដែលគ្រូថ្មីត្រូវទទួលការវាយតម្លៃលើសមត្ថភាពរបស់ខ្លួនក្នុងការបង្រៀន។ ឧបករណ៍ដែលប្រើប្រាស់ក្នុងពេលសាកល្បងរួមមានការធ្វើតេស្តសរសេរ ការសង្កេតថ្នាក់រៀនលើខ្លឹមសារចំណេះដឹង និងការអនុវត្តការបង្រៀន។ ឧបករណ៍ទាំងនេះ ត្រូវបានរៀបចំសម្រាប់ជាភ័ស្តុតាងបង្ហាញថា គរុសិស្ស/គរុនិស្សិតឈានដល់កម្រិតស្តង់ដាវិជ្ជាជីវៈ ដែលកំណត់ (ទាំងចំណេះដឹងខាងផ្នែកមុខវិជ្ជា ទាំងគរុកោសល្យបង្រៀន)។

តាមការស្រាវជ្រាវរបស់អង្គការយូណេស្កូ ការបណ្តុះបណ្តាលគ្រូបង្រៀន និងការគាំទ្រគ្រូបង្រៀនក្នុងអំឡុងពេល៥ឆ្នាំដំបូងនៃការបង្រៀនក្នុងថ្នាក់ គឺជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុត ក្នុងការលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈ និងប្តេជ្ញាចិត្តបម្រើការងារក្នុងអាជីពជាគ្រូ។ ការគាំទ្រពង្រឹងវិជ្ជាជីវៈរួមមាន ឱកាសសិក្សារបស់គ្រូបង្រៀន សិក្ខាសាលាបំប៉ន ការគាំទ្រពីអ្នកណែនាំក្នុងវគ្គវិក្រឹតការ និងពីអធិការ ទស្សនកិច្ចសិក្សាតាមសាលារៀន និងការពិគ្រោះយោបល់ជាមួយសហសេវិកក្នុងកម្រងសាលារៀន[255]។

ប្រទេសមួយចំនួនដែលមានលទ្ធផលលំដាប់ខ្ពស់ផ្នែកកម្មវិធីវាយតម្លៃសិក្សាកម្រិតអន្តរជាតិ(PISA) ដូចជាប្រទេសសិង្ហបុរី សាធារណរដ្ឋកូរ៉េ និងជប៉ុនក៏បានរៀបចំការបណ្តុះ-បណ្តាលគ្រូបង្រៀន តាមរូបមន្ត១២+៤ ដែរ។

ការសម្រួល និងការជួយគាំទ្រក្នុងដំណាក់កាលធ្វើកម្មសិក្សា នឹងជួយលើកទឹកចិត្តដល់គ្រូបង្រៀន និងបង្កើនសមត្ថភាពការបង្រៀនរបស់ពួកគេ។ ចំណុចនេះសំខាន់ណាស់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ការជួយគាំទ្រក្នុងពេលកម្មសិក្សានេះ ពេលខ្លះគឺជាសកម្មភាពធម្មតា ដូចជាការស្វាគមន៍របស់នាយកសាលារៀន និងពេលខ្លះទៀត គឺជាសកម្មភាពផ្លូវការ ដូចជាជួយដឹកនាំ ការចូលរួមសិក្ខាសាលា និងការសង្កេតថ្នាក់និទស្សន៍ជាដើម។

[255] Ogawa (2014). p. 2.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រសួងអប់រំ យុវជន និងកីឡានឹងពង្រឹងការជួយគាំទ្រដល់កម្មសិក្សារបស់គ្រូចេញថ្មី នៅតាមសាលារៀនតាមរយៈវិធានការដូចតទៅ ៖

(១) រៀបចំឯកសារជំនួយសម្រាប់កម្មសិក្សាការី/កម្មសិក្សាការិនី ដូចជាស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការណែនាំអំពីស្វ័យភាពគ្រូបង្រៀន គន្លងអាជីពគ្រូបង្រៀន ព្រឹត្តិបត្រវាយតម្លៃការបណ្តុះបណ្តាលគ្រូបង្រៀន និងឯកសារនានាដែលទាក់ទងនឹងគ្រូបង្រៀន

(២) បង្កើតប្រព័ន្ធទំនុកបម្រុងគាំទ្រគ្រូបង្រៀននៅនឹងសាលារៀន

(៣) បន្ថយម៉ោងបង្រៀនរបស់គ្រូ ដែលមានបទពិសោធខ្ពស់ ដើម្បីឱ្យពួកគាត់មានពេលវេលាច្រើនក្នុងការផ្តល់សេវាជួយដល់សកម្មភាពកម្មសិក្សា និងការណែនាំផ្ទាល់។

### ៦.២.៣ .អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលនឹងផ្តោតទៅលើ ៖

(ក) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដោយកែលម្អហេដ្ឋារចនាសម្ព័ន្ធនៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ផ្តល់សម្ភារឧបទេស បរិក្ខារ ឧបករណ៍ ICT បន្ទប់ពិសោធន៍ បង្គន់អនាម័យ អន្តេវាសិកដ្ឋាន ។ល។

(ខ) ប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន។

(គ) បង្កើនគុណវុឌ្ឍិវិជ្ជាជីវៈ និងបទពិសោធបុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន ដោយជ្រើសរើសគ្រូឧទ្ទេស ដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត ឬអ្នកដែលមានបទពិសោធបង្រៀន។

(ឃ) ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀនដើម្បីបន្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន តាមរយៈការបណ្តុះបណ្តាលអធិការ ការបណ្តុះបណ្តាលនាយកគ្រឹះស្ថានសិក្សា និងបណ្តុះបណ្តាល/វិក្រឹតការអ្នកគ្រប់គ្រងអប់រំនៅថ្នាក់មន្ទីរអប់រំយុវជន និងកីឡា រាជធានី-ខេត្ត និងការិយាល័យអប់រំយុវជន និងកីឡា ក្រុង-ស្រុក-ខណ្ឌ។

ក្រសួងអប់រំ យុវជន និងកីឡានឹងដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូកម្រិតឧត្តមសិក្សា តាមកម្មវិធីសិក្សាថ្មី ដែលជាផ្នែកមួយនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តពេញមួយជីវិត។ របៀបវារៈសម្រាប់កំណែទម្រង់នេះរួមមាន ៖

(១) ការបង្កើនម៉ោងសម្រាប់អនុវត្តការបង្រៀននៅក្នុងថ្នាក់ ដោយមានការបង្វឹក និងណែនាំផ្ទាល់ពីគ្រូបង្រៀនដែលមានបទពិសោធបង្រៀនក្នុងថ្នាក់។

(២) ការផ្តោតយ៉ាងខ្លាំងលើបទពិសោធ និងការសង្កេតនៅនឹងសាលារៀន។

(៣) ការបំពាក់សម្ភាររូបវន្តសមស្របពាក់ព័ន្ធនឹងបន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់ពិសោធភាសា បណ្ណាល័យ និងសម្ភារបង្រៀនបច្ចេកវិទ្យា។

(៤) ការបន្ថែមនូវធនធានដើម្បីឱ្យគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនអាចរៀបចំការបង្រៀនតាមវិធីសិស្សមជ្ឈមណ្ឌល និងប្រើវិធីសាស្ត្របង្រៀនបែបអន្តរកម្ម ក៏ដូចជាប្រតិបត្តិបានល្អប្រសើរក្នុងពេលធ្វើកម្មសិក្សា។

## ៦.២.៤ . ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា

វិស័យអប់រំមានបុគ្គលិកសរុបស្មើនឹង៦០%នៃមន្ត្រីរាជការស៊ីវិលទាំងអស់។ ចំនួននេះមិនគិតបញ្ចូលបុគ្គលិកកិច្ចសន្យាទេ។ ការធ្វើសនិទានកម្មក្នុងការពង្រាយគ្រូបង្រៀនមានសារៈសំខាន់ណាស់ ព្រោះទង្វើនេះនឹងផ្គត់ផ្គង់គ្រូបង្រៀនទៅសាលារៀន តាមអត្រាមួយសមស្រប នឹងរក្សាបាននូវផលធៀបសិស្ស-គ្រូក្នុងកម្រិតអតិបរមាតាមសាលារៀននីមួយៗ (ឧទា.៤០-៤៥)។

ការផ្តួចផ្តើមជ្រើសរើសគ្រូបង្រៀនតាមមូលដ្ឋានប្រឈមនឹងការលំបាក ដោយសារកង្វះប្រភពធនធាន (អ្នកដែលមានសមត្ថភាព) សម្រាប់រើស។ អាទិភាពរបស់ក្រសួងអប់រំ គឺការកសាងសាលាបឋមសិក្សាមិនគ្រប់កម្រិត ឱ្យក្លាយជាសាលាគ្រប់កម្រិត រួចកសាងអនុវិទ្យាល័យ ឬវិទ្យាល័យក្នុងសហគមន៍ក្រីក្រ។ ម្យ៉ាងវិញទៀត ការផ្តល់ប្រាក់ឧបត្ថម្ភដល់សិស្សក្រីក្រក្នុងតំបន់ទាំងនេះ នឹងអាចបង្កើនលទ្ធភាពឱ្យពួកគេអាចបន្ត និងបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា។ ជាទីបញ្ចប់ ក្រសួងអប់រំត្រូវផ្តល់ឱកាសឱ្យគរុសិស្ស/គរុនិស្សិតមកពីតំបន់ជួបការលំបាក ដើម្បីចូលរួមក្នុងការបណ្តុះបណ្តាល ឱ្យទៅជាគ្រូបង្រៀន។ ក្នុងន័យនេះ ការធ្វើសនិទានកម្មក្នុងការពង្រាយគ្រូបង្រៀន នឹងផ្តោតលើចំណុចដូចតទៅ ៖

*(ក) ទំនើបកម្មផែនការតម្រូវការនិងផ្គត់ផ្គង់គ្រូបង្រៀន សម្រាប់ការបណ្តុះបណ្តាលមុនពេលបម្រើការងារ*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចំណុចនេះរួមមាន ៖ (១) ការធ្វើសមាហរណកម្មទិន្នន័យ ពីគ្រប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ សម្រាប់កសាងផែនការផ្គត់ផ្គង់គ្រូបង្រៀនដ៏មានប្រសិទ្ធភាពមួយ(EMIS, HRMIS, HEMIS, NFEMIS, FMIS)(២) ការធានាភាពសុក្រឹត ភាពជឿទុកចិត្តបានតាមរយៈការធ្វើបច្ចុប្បន្នកម្ម និងសុពលភាពនៃទិន្នន័យ (៣) ការប្រើប្រព័ន្ធទិន្នន័យដែលបានរៀបចំសម្រាប់ធ្វើផែនការផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀន ឱ្យមានប្រសិទ្ធភាព(បង្កើតឯកសារផ្ទាល់ខ្លួនរបស់គ្រូបង្រៀន (Teacher Profile) សិក្សាអត្រាគង់វង្ស ផែនការបម្រុងសម្រាប់ជំនួសអ្នកឈប់ ចំណោលតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជា)។

*(ខ) ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់និងតាមគោលការណ៍*

ក្រសួងអប់រំ យុវជន និងកីឡានឹងណែនាំការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ តាមរយៈ ៖ (១) ការកែលម្អ និងអនុវត្តសេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ឆ្នាំ២០១៤ តាមលទ្ធផលនៃការសាកល្បងនៅរាជធានី-ខេត្តចំនួន៥ (២) ការប្រើនិយាមបុគ្គលិកអប់រំថ្មី ដើម្បីកែលម្អការអនុវត្តការពង្រាយគ្រូបង្រៀន ផលធៀបសិស្ស-គ្រូ តាមរាជធានី/ខេត្ត-ក្រុង/ស្រុក/ ខណ្ឌ និងឃុំ/សង្កាត់។

*(គ) លើកកម្ពស់ការគ្រប់គ្រង និងកែលម្អការពង្រាយគ្រូបង្រៀន*

ចំណុចនេះ អាចសម្រេចបានដោយពង្រាយគ្រូបង្រៀនថ្មីគ្រប់ភូមិសិក្សាឱ្យទៅបម្រើការងារនៅតំបន់ ដែលខ្វះគ្រូបង្រៀនតាមតម្រូវការ។ តាមការស្រាវជ្រាវ ក្រសួងអប់រំ យុវជន និងកីឡាបានរកឃើញថា នៅក្នុងឆ្នាំសិក្សា២០១៤-២០១៥ មានគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ៣ ១០៩ នាក់ ដែលលើសតម្រូវការប្រើប្រាស់ (ធៀបនឹងនិយាម) នៅទូទាំងប្រទេស។ ប៉ុន្តែអនុវិទ្យាល័យមួយចំនួនក៏ប្រឈមនឹងការខ្វះគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ដោយឡែក ក្រសួង ក៏បានរកឃើញ ផងដែរនូវតម្រូវការគ្រូបង្រៀនកម្រិតឧត្តមគ្រប់ឯកទេស ចំនួន ៣ ៧៨៦ នាក់ (ធៀបនឹងនិយាម) នៅទូទាំងប្រទេស។ តាមរយៈការវាយតម្លៃ និងធ្វើស្វ័យប្រកាសស្តីពីស្ថានភាពលើស និងខ្វះគ្រូបង្រៀននៅតាមវិទ្យាល័យ និងអនុវិទ្យាល័យ ក្រសួងបានរកឃើញ វិទ្យាល័យចំនួន ៩៣៩ ដែលខ្វះគ្រូបង្រៀនគ្រប់មុខវិជ្ជា ចំនួន ៣ ៧២៦ នាក់ ក្នុងនោះខ្វះគ្រូកម្រិតឧត្តមមុខវិជ្ជា៖ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា ចំនួន ២ ២០២ នាក់[256]។

ក្នុងគោលដៅកែលម្អការពង្រាយគ្រូដោយស្ម័គ្រចិត្ត ក្រសួងបានរៀបចំកម្មវិធីប្រឡងជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្ម័គ្រចិត្តទៅបង្រៀននៅវិទ្យាល័យដែលកំពុងខ្វះគ្រូបង្រៀនកម្រិតឧត្តម ដើម្បីឱ្យពួកគាត់មាន សមត្ថ-

[256] ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) របាយការណ៍ស្តីពីការចាត់វិធានការដើម្បីពង្រាយគ្រូបង្រៀន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ។ ក្រសួងបានរៀបចំកម្មវិធីបណ្តុះបណ្តាល រយៈពេល ១០ ខែ មាន ៦០ ក្រេឌីត លើមុខវិជ្ជា ចំនួន ០៦ រួមមាន៖ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា សម្រាប់ធ្វើការបណ្តុះបណ្តាល។ ក្នុងន័យនេះ ក្រសួងបានផ្តល់អាទិភាពក្នុងការបណ្តុះបណ្តាល គ្រូកម្រិតមូលដ្ឋាន ដែលកំពុងបង្រៀនថ្នាក់ទី១០ ១១ និង១២។

*(ឃ) លើកកម្ពស់ដំណើរការនិងនីតិវិធីនៃការជ្រើសរើសនិងរក្សាទុកគ្រូបង្រៀនមានស្នាដៃល្អសម្រាប់ធានានិរន្តរភាពគ្រឹះស្ថានសិក្សា*

ចំណុចនេះនឹងបង្កើនប្រសិទ្ធភាពនៃការជ្រើសរើសគ្រូបង្រៀន និងជួយរក្សាទុកគ្រូបង្រៀន ដែលមានស្នាដៃសម្រាប់ផ្តល់បទពិសោធដល់អ្នកជំនាន់ក្រោយ។

*(ង) លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀននិងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធផលសិក្សារបស់សិស្ស*

សកម្មភាពដែលនឹងអនុវត្តក្នុងការពង្រឹងគណៈកម្មការទ្រទ្រង់សាលារៀនឱ្យកាន់តែមានសមត្ថភាព ក្នុងការជួយគាំទ្រដល់សាលារៀន រួមមាន ៖ ការបង្កើនការចូលរួមរបស់សមាជិកគណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធ ឱ្យកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងកិច្ចការគ្រូបង្រៀន និងសាលារៀន ដូចជាការជ្រើសរើស ការផ្តល់រង្វាន់ ការពិន័យ កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ការផ្ទេរ វិន័យ ការវាយតម្លៃវេទិកាសាធារណៈ ការប្រជុំ មតិសិស្ស ការវាយតម្លៃសេវាមូលដ្ឋាន។

## ៦.២.៤ .ការរៀបចំប្រព័ន្ធវិក្រឹតការ និងពង្រឹងសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន

ក្រសួងអប់រំនឹងដាក់ឱ្យអនុវត្តប្រព័ន្ធវិក្រឹតការគ្រូបង្រៀន តាមរយៈការដាក់ឱ្យដំណើរការនូវកម្មវិធីបណ្តុះបណ្តាល ដោយឈរលើក្រេឌីត ក្នុងគោលដៅធានាសមមូលរវាងបទពិសោធវិជ្ជាជីវៈ និងចំណេះដឹង ក៏ដូចជាការរៀនសូត្រពីមុន និងតម្រូវការនានាសម្រាប់ទទួលបានការលើកទឹកចិត្តជាក់លាក់ដូចជាការតម្លើងឋានៈ ការបង្កើនបៀវត្ស ឬការអនុវត្តគន្លងអាជីពគ្រូបង្រៀន។

*(ក) បណ្តុះវប្បធម៌រៀនពេញមួយជីវិត ចែករំលែកចំណេះដឹង និងបទពិសោធជាមួយមន្ត្រីអប់រំផ្សេងទៀត*

យើងត្រូវជំរុញគ្រូបង្រៀន ឱ្យមានវប្បធម៌រៀនពេញមួយជីវិត ៖ ដោយរៀបចំកម្មវិធីបណ្តុះបណ្តាល ដែលផ្តល់ការលើកទឹកចិត្ត និងប្រព័ន្ធក្រេឌីត ដែលផ្តោតលើការអប់រំ

បញ្ចូលគ្នា ICT ប្រព័ន្ធផ្សព្វផ្សាយចម្រុះ ការអប់រំពហុភាសា ការរៀបកិច្ចតែងការបង្រៀន ការបង្កើតបណ្ណាល័យ ការបង្រៀនភាសាអង់គ្លេស និងការផលិតនិងប្រើប្រាស់សម្ភារឧបទ្ទេស។

*(ខ) រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ*

ក្រសួងអប់រំ យុវជន និងកីឡានឹងរៀបចំយន្តការដ៏មានប្រសិទ្ធភាពមួយ សម្រាប់គាំទ្រគ្រូបង្រៀននៅនឹងកន្លែង តាមរយៈ៖ (១) ការពង្រឹងប្រព័ន្ធគាំទ្រគ្រូបង្រៀននៅនឹងកន្លែងដើម្បីឆ្លើយតបទៅនឹងតម្រូវការវិជ្ជាជីវៈរបស់គ្រូបង្រៀន (២) បង្កើតប្រព័ន្ធបំប៉នសមត្ថភាពគ្រូបង្រៀននៅនឹងកន្លែង នៅគ្រប់គ្រឹះស្ថានសិក្សា។

*(គ) រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការ និងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ*

ការលើកកម្ពស់គុណភាពអប់រំទាមទារការយកចិត្តទុកដាក់លើការគ្រប់គ្រង និងការអភិវឌ្ឍគ្រូបង្រៀន តាមរយៈវិធានការទាក់ទាញបេក្ខជនមានសមត្ថភាពឱ្យចូលធ្វើគ្រូបង្រៀន ការបើកច្រកចូលឱ្យបានច្រើន ដើម្បីធ្វើជាគ្រូបង្រៀន និងការផ្តល់បៀវត្សខ្ពស់ដល់គ្រូ។

ជារួម ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ត្រូវបានរៀបចំឡើងចំពេលវេលា និងមានសារៈសំខាន់ណាស់ ព្រោះផែនការនេះបានដាក់ចេញនូវចក្ខុវិស័យច្បាស់លាស់អំពីរបៀបកែលម្អប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន និងបានបើកច្រកថ្មីៗជាច្រើនសម្រាប់អ្នកមានសមត្ថភាព ឱ្យចូលធ្វើគ្រូបង្រៀន សំដៅឆ្លើយតបនឹងតម្រូវការអភិវឌ្ឍធនធានមនុស្សនៅមូលដ្ឋាន ជាពិសេសសាលារៀនជំនាន់ថ្មី។

## ៦.២.៦ .លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន

*(ក) លើកកម្ពស់លក្ខខណ្ឌធ្វើការងារនិងរស់នៅរបស់គ្រូបង្រៀន៖* តាមរយៈការផ្តល់បៀវត្សលាភការសុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ អត្ថប្រយោជន៍ពេលចូលនិវត្តន៍ ជាពិសេសដល់គ្រូបង្រៀន នៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

*(ខ) ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ*

(១) រង្វាន់ដល់គ្រូបង្រៀនដោយផ្តោតលើលទ្ធផលការងារ ទាំងការបង្រៀន ស្រាវជ្រាវ និងកិច្ចការសាលារៀនផ្សេងៗទៀត។

(២) សិក្សានិងកែសម្រួលសេចក្តីណែនាំ/លក្ខណៈវិនិច្ឆ័យនៃការផ្តល់រង្វាន់ដល់គ្រូបង្រៀនឱ្យមានតម្លាភាព និងផ្អែកលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ គ្រូបង្រៀនទាំងអស់មាន



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សិទ្ធិចូលរួមប្រកួត ដើម្បីទទួលរង្វាន់ រួមទាំងគ្រូបង្រៀនដែលចូលនិវត្តន៍មានស្នាដៃនិងបទពិសោធល្អ។

(៣) អនុវត្តនិងបើកវគ្គបំប៉នអំពីសេចក្តីណែនាំថ្មីស្តីពីការផ្តល់រង្វាន់។

(៤) បង្កើតវេទិកាប្រកួតពានរង្វាន់គ្រូបង្រៀនឆ្នើម ៖ ដើម្បីចែករំលែកបទពិសោធល្អៗ តាមមុខវិជ្ជា។

*(គ) លើកកម្ពស់ការដំឡើងឋានៈក្នុងអាជីព ស្វ័យភាព និងការសម្រេចចិត្ត សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស*

(១) ភ្ជាប់ប្រព័ន្ធក្រេឌីតនៃវគ្គវិក្រឹតការ ទៅនឹងការលើកទឹកចិត្តតាមគន្លងអាជីពសម្រាប់គ្រូបង្រៀន

(២) ពង្រីកឬបង្កើតយន្តការសម្រាប់បន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដូចជាការបង្កើតក្លឹបសិក្សា/សមាគមវិជ្ជាជីវៈតាមមុខវិជ្ជាឯកទេស ដើម្បីជួយគាំទ្រផ្នែកបច្ចេកទេសតាមមុខវិជ្ជា ចែករំលែកបទពិសោធជំនាញ ធ្វើការស្រាវជ្រាវ ដឹកនាំសន្និសីទវិជ្ជាជីវៈ បោះពុម្ពស្នាដៃ និងបទពិសោធល្អៗ។

(៣) បង្កើតក្រុមបច្ចេកទេសក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន សម្រាប់ចុះជួយតាមមុខវិជ្ជា និងប្រជុំបច្ចេកទេសតាមមុខវិជ្ជាឯកទេសឱ្យបានទៀងទាត់។

## ៦.២.៧ .ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន

ភាពជាអ្នកដឹកនាំសាលារៀន និងប្រសិទ្ធភាពនៃបុគ្គលិកសាលារៀនជាកម្លាំងចលករក្នុងការធ្វើឱ្យសាលារៀនមានប្រសិទ្ធភាព។

*(ក) ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព* តាមរយៈការអនុវត្តនូវសកម្មភាពដូចតទៅ ៖ (១) បង្កើនការយល់ដឹងពីតម្រូវការរបស់នាយកសាលារៀន ដើម្បីពង្រឹងភាពជាអ្នកដឹកនាំសាលារៀន (២) អភិវឌ្ឍស្តង់ដានាយកសាលារៀន (៣) អភិវឌ្ឍសៀវភៅណែនាំការគ្រប់គ្រងសាលារៀន (៤) បណ្តុះបណ្តាលនាយកសាលារៀន (៥) ជ្រើសរើស និងចាត់តាំងនាយកសាលារៀន អនុវត្តតាមស្តង់ដានាយកសាលារៀន និងសេចក្តីណែនាំស្តីពីការជ្រើសរើសដោយផ្តល់អាទិភាពដល់នារី (៦) បង្កើតក្រុមប្រឹក្សា/សមាគមនាយកសាលារៀន ៖ បង្កើតយន្តការដើម្បីគាំទ្រដល់នាយកសាលារៀន។

*(ខ) កែលម្អលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស ការបណ្តុះបណ្តាល ការបំពេញការងារ និងផលប្រយោជន៍របស់គ្រូឧទ្ទេសនិងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ*

*(គ) កំណត់និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ សំដៅធានាការអនុវត្តគោលការណ៍ និងបំពេញតាមលក្ខខណ្ឌគតិយុត្តិ* ក្នុងគោលដៅធានាការគ្រប់គ្រងបុគ្គលិកអប់រំ ប្រកបដោយប្រសិទ្ធភាពនិងរៀបចំបទបញ្ញត្តិស្តីពីកម្រិតនៃកំហុស និងវិធានការរដ្ឋបាលសម្រាប់បុគ្គលិកអប់រំ។

## ៦.២.៨ .ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀន

ក្រសួងអប់រំ យុវជននិងកីឡានឹងពិនិត្យឡើងវិញប្រព័ន្ធទទួលខុសត្រូវរបស់គ្រូបង្រៀន ដោយផ្តោតលើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូក្នុងគោលដៅ៖

*(ក) បង្កើនប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន ៖* តាមរយៈការកែលម្អទិន្នន័យមូលដ្ឋានក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន។

*(ខ) បង្កើតនិងប្រើប្រាស់យន្តការពិនិត្យតាមដាននិងវាយតម្លៃដើម្បីកែលម្អ លទ្ធផលបំពេញការងាររបស់គ្រូបង្រៀន*

(១) កែលម្អ ឬបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យតាមដាននិងវាយតម្លៃគ្រូបង្រៀនទាំងអស់ ដោយផ្តោតលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និយាមប្រើប្រាស់បុគ្គលិកអប់រំ ពណ៌នាមុខតំណែង(JD) លក្ខណសម្បត្តិមុខតំណែង(JS) និងគន្លងអាជីពគ្រូ។

(២) អនុវត្តលក្ខណៈវិនិច្ឆ័យវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ

*(គ) បង្កើនប្រសិទ្ធភាពការប្រើប្រាស់លទ្ធផលវាយតម្លៃការប្រតិបត្តិរបស់គ្រូបង្រៀនដើម្បីអភិវឌ្ឍសមិទ្ធិអប់រំ*

*(ឃ) កំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រងនិងអភិវឌ្ឍអង្គភាព។*

## ៦.៣. ការសន្និដ្ឋាន

ប្រព័ន្ធអប់រំកម្ពុជាត្រូវសម្របទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច ភាពរីកចម្រើននៃបច្ចេក-វិទ្យា ចលនាប្រជាសាស្ត្រ និងការផ្លាស់ប្តូរនៃទីផ្សារពលកម្ម។ អ្នកអប់រំត្រូវបណ្តុះបណ្តាលសិស្ស/និស្សិត សម្រាប់ទីផ្សារការងារនាពេលបច្ចុប្បន្ននិងអនាគត តាមទាន់ភាពរីកចម្រើននៃបច្ចេកវិទ្យា ព្រមទាំងបញ្ជ្រាបនិងបណ្តុះនូវវប្បធម៌ តម្លៃ ភាសានិងឥរិយាបថ ដែលអាចឱ្យសិស្ស/និស្សិតធ្វើការ និងរស់នៅក្នុងពិភពលោកបែបសកលភាវូបនីយកម្ម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការគ្រប់គ្រងវិស័យអប់រំមានសារៈសំខាន់ណាស់ សម្រាប់ការបង្កើនលទ្ធផលសិក្សា។ កំណែទម្រង់ការអប់រំត្រូវផ្តោតលើការគ្រប់គ្រងធនធានមនុស្ស ការធ្វើអន្តរាគមន៍/គាំទ្រប្រកបដោយប្រសិទ្ធភាព វង្វាយតម្លៃសិក្សា ការពិនិត្យតាមដាននិងវាយតម្លៃការប្រឡង ការគ្រប់គ្រងព័ត៌មាន រួមទាំងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS) សមត្ថភាពស្ថាប័ន និងការអនុវត្តកម្មវិធី/គោលនយោបាយ។

កត្តាសាលារៀន និងថ្នាក់រៀនក៏ដើរតួនាទីសំខាន់ក្នុងការផ្តល់គុណភាពអប់រំដែរ ដូចជា កម្មវិធីសិក្សា គរុកោសល្យ បរិស្ថានសិក្សា តម្លាភាពនៃវង្វាយតម្លៃតាមដំណាក់និងវង្វាយតម្លៃសរុប ការធ្វើតេស្តនិងការប្រឡង ភាពជាអ្នកដឹកនាំសាលារៀន បច្ចេកវិទ្យាក្នុងការអប់រំ សុខភាពសិក្សានិងអនាម័យ។

ត្រូវពិនិត្យតាមដានគុណភាពអប់រំឱ្យបានជាប្រក្រតី ដោយប្រើមធ្យោបាយផ្សេងៗគ្នា។ វិធីសំខាន់ៗនៃការធានាគុណភាពរួមមាន អធិការកិច្ច វង្វាយតម្លៃនិងការទទួលស្គាល់ជាផ្លូវការ។ សកម្មភាពបន្ថែមនៃការធានាគុណភាពមានការរៀបជាចំណាត់ថ្នាក់ ការប្រើសូចនាករប្រតិបត្តិ និងលទ្ធផលនៃការធ្វើតេស្ត/ប្រឡង ។

ការសម្របសម្រួល និងភាពជាដៃគូក្នុងការអប់រំបង្កើតជាសសរស្តម្ភដ៏រឹងមាំសម្រាប់ការលើកកម្ពស់គុណភាពអប់រំ។ ការផ្តល់សេវាកម្មអប់រំឱ្យបានកាន់តែល្អប្រសើរទាមទារការចូលរួមពីសំណាក់មាតាបិតា និងសហគមន៍ ការសហការរវាងវិស័យ និងអន្តរវិស័យ ការសម្របសម្រួលជាមួយម្ចាស់ជំនួយ និងការចូលរួមរបស់មាតាបិតា។

# ជំពូកទី ៧
# អធិការកិច្ចអប់រំ

## ៧.១. សារៈសំខាន់នៃអធិការកិច្ចអប់រំក្នុងការពង្រឹងគុណភាពអប់រំ

ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើការកែលម្អជាច្រើន។ បញ្ហាប្រឈមនៃប្រព័ន្ធអប់រំនៅកម្ពុជា គឺមានកុមារដែលមិនបានចូលរៀន ឬបោះបង់ការសិក្សាមុនពេលពួកគេទទួលបានការអប់រំកម្រិតមូលដ្ឋាន សិស្សនៅកម្រិតមធ្យមសិក្សាបានបោះបង់ការសិក្សាដោយសារតែការមិនចាប់អារម្មណ៍ក្នុងការសិក្សា ឬក៏ដោយសារឪពុកម្តាយរបស់ពួកគេគ្មានលទ្ធភាពចំណាយលើការសិក្សា។ ទន្ទឹមនឹងនេះ ក៏មានបញ្ហាផ្សេងៗទៀតដូចជាសិស្សបានបញ្ចប់កម្មវិធីសិក្សាអប់រំ ក៏ប៉ុន្តែមិនបានឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ឬមិនអាចបន្តការសិក្សានៅឧត្តមសិក្សាបាន និស្សិតមួយចំនួនដែលរៀនចប់ថ្នាក់ឧត្តមសិក្សា ក៏ប៉ុន្តែគ្មានសមត្ថភាពកាន់មុខតំណែងការងារ ដោយសារគម្លាតជំនាញ ឬគុណវុឌ្ឍិការសិក្សាមិនត្រូវតាមតម្រូវការលក្ខខណ្ឌនៃការងារក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម។ យើងទាំងអស់គ្នាត្រូវរួមគ្នារកដំណោះស្រាយបញ្ហាទាំងនេះ ក្នុងគោលដៅបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយបរិយាប័ន្ន។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាព ទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តអប់រំ ដូចជាការសាងសង់សាលារៀននៅតាមភូមិ ឃុំ ឱ្យខិតជិតប្រជាជន។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីកែលម្អវិស័យអប់រំ ជាពិសេសគុណភាពអប់រំ គឺត្រូវបណ្តុះ-បណ្តាលគ្រូបង្រៀនឱ្យមានសមត្ថភាព និងគុណភាពខ្ពស់។ គ្រូបង្រៀនមានគុណភាពខ្ពស់អាស្រ័យលើកត្តាមួយចំនួន ដូចជា ៖ ដំណើរការជ្រើសរើសគ្រូបងៀនប្រកបដោយការ-យកចិត្តទុកដាក់ខ្ពស់បំផុត គុណភាពនិងពេលវេលាបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យ ឬនៅតាមគ្រឹះស្ថានឧត្តមសិក្សា ចំណង់ចំណូលចិត្តចង់ធ្វើជាគ្រូបង្រៀន ប្រាក់បៀវត្សគ្រូមានកម្រិតសមរម្យ និងមានការលើកទឹកចិត្តជាដើម។

ជាការពិត ហេដ្ឋារចនាសម្ព័ន្ធដើរតួរនាទីសំខាន់នៅក្នុងវិស័យអប់រំ ក៏ប៉ុន្តែគ្រូបង្រៀនដែលប្រកបដោយគុណវុឌ្ឍិ គឺកាន់តែមានសារៈសំខាន់ខ្លាំង ដើម្បីធានាដល់គុណ-ភាពអប់រំ។ គ្រូបង្រៀនត្រូវតែយល់ដឹងអំពីតួនាទីដ៏សំខាន់របស់ខ្លួននៅក្នុងសង្គម មាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សមត្ថភាពក្នុងការប្រើប្រាស់សម្ភារផ្សេងៗដែលបម្រើឱ្យការងារអប់រំ យល់ដឹងពីកម្មវិធីសិក្សា មានទស្សនវិទ្យាអប់រំ អាចប្រើប្រាស់សម្ភារឧបទ្ទេសអប់រំផ្សេងៗ និងត្រូវបានទទួលការលើកទឹកចិត្ត និងមានមនសិការវិជ្ជាជីវៈខ្ពស់។

ក្នុងរយៈពេលកន្លងទៅនេះ ដើម្បីសម្រេចបានតាមគោលដៅខាងលើ ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតយកចិត្តទុកដាក់ លើការ-កសាងសាលាធនធាន ដើម្បីរៀបចំបរិស្ថានសាលារៀនឱ្យមានលក្ខណៈអំណោយផល។ សាលាធនធានបានបំពាក់នូវឧបករណ៍ទំនើបៗ សម្រាប់ការរៀននិងការបង្រៀន ផ្តល់មធ្យោបាយនិងធនធានដើម្បីជំរុញឱ្យគ្រូបង្រៀន និងសិស្សប្រមូលផ្តុំទៅលើការរៀនដោយ លើកទឹកចិត្តការអនុវត្តជាក់ស្តែង និងបង្កលក្ខណៈឱ្យសិស្សអាចធ្វើពិសោធន៍បាន។ ជំហានដំបូង អ្វីដែលជាការរៀនរបស់ពួកគេ គឺការអនុវត្ត។ សិស្សគួរតែអាចចូលរួមនៅក្នុងដំណើរនៃការរៀន ព្រមទាំងដំណើរការនៃការរៀនពីរបៀប ដែលពួកគេអាចយកការរៀនរបស់ពួកគេនេះទៅអនុវត្តការងារជាក់ស្តែង និងធ្វើការសម្រេចចិត្តដែលពួកគេនឹងត្រូវតែធ្វើនៅក្នុងស្ថានភាពការងារជាក់ស្តែងនាពេលអនាគត។ បច្ចុប្បន្ននេះ គ្រូបង្រៀនភាគច្រើនតែងតែបង្រៀនតាមសៀវភៅគោល និងការរៀនទ្រឹស្តី ក៏ប៉ុន្តែមិនបានបង្រៀនពីរបៀបប្រើប្រាស់នូវចំណេះដឹងពីការរៀន ដើម្បីទៅបង្កើតបានជាលទ្ធផលទេ។ ពួកគាត់បង្រៀនសិស្សឱ្យទន្ទេញចាំមាត់ តែមិនបានបង្រៀនពីរបៀបបកស្រាយ និងវិភាគដើម្បីយកទៅអនុវត្តនៅក្នុងស្ថានភាពជាក់ស្តែងទេ។ ដំណើរការនេះមិនបានពង្រឹងទៅដល់ការរៀនឡើយ។ គោលដៅរបស់ការអប់រំ គឺការរៀនមិនមែនការបង្រៀនទេ។ ប្រព័ន្ធអប់រំចាំបាច់ត្រូវផលិតនូវមនុស្ស ដែលអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូររបស់សង្គម។ ដូច្នេះគ្រូបង្រៀនត្រូវតែជាមនុស្សដែលចេះសម្របខ្លួននិងផ្លាស់ប្តូរ ព្រមទាំងគិតពីការរៀនក្រៅពីសៀវភៅសិក្សាគោល។ បច្ចុប្បន្ន ថ្នាក់ត្រូវបានគេបំពាក់នូវសម្ភារជាមួយ និងធនធានដែលអាចឱ្យសិស្សអនុវត្តការរៀនរបស់ពួកគេ ក៏ប៉ុន្តែគ្រូបង្រៀនមិនអាចប្រើប្រាស់នូវសម្ភារទាំងអស់នោះបាន។ នេះជាកត្តាមួយដែលឆ្លុះបញ្ចាំងពីគម្លាតមួយយ៉ាងធំរវាងការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងកម្រិតនៃការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ គឺនៅត្រូវពង្រឹងថែមទៀត។ បញ្ហាទាំងនេះគួរតែត្រូវរកដំណោះស្រាយ។ នៅពេលសង្គម និងបច្ចេក-វិទ្យាមានការរីកចម្រើនកាន់តែខ្លាំង យើងត្រូវការមនុស្សកាន់តែច្រើន ដែលមានកម្រិតខ្ពស់ខាងផ្នែកវិទ្យាសាស្ត្រដើម្បីបំពេញនូវតួនាទីនិងការងារជាច្រើន ដែលត្រូវបានគេបង្កើតឡើង។ មានវិធីពីរយ៉ាងដើម្បីដោះស្រាយបញ្ហាទាំងនេះ ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ទីមួយ ៖** បង្កើតសាលាបណ្តុះបណ្តាលបច្ចេកទេសឯកទេស ដែលជាកន្លែងឱ្យសិស្សអាចចូលរៀនលើជំនាញបច្ចេកវិទ្យា។ នៅក្នុងប្រទេសកម្ពុជាមានសាលាបណ្តុះបណ្តាលជំនាញបច្ចេកទេសមួយចំនួន។

**ទីពីរ ៖** ប្រទេសជាច្រើនបានតម្រង់ទិសដៅការអប់រំរបស់ខ្លួន នៅកម្រិតវិទ្យាល័យ ដើម្បីផ្តល់ឱកាសកាន់តែច្រើនដល់លំហូរតម្រង់ទិសបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមិនមែនជាការជ្រើសរើសរវាងវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រ តែផ្តោតលើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា ឬគីមីវិទ្យា តាមរយៈការបង្កើតកម្មវិធីសិក្សាដែលមានជម្រើសកាន់តែច្រើន ដែលសិស្សអាចជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ នៅពេលដែលសិស្សដទៃទៀតអាចជ្រើសរើសគណិតវិទ្យាអនុវត្តន៍ និងវិទ្យាសាស្ត្រអនុវត្តន៍ សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស។ ដូច្នេះសិស្សអាចរៀននូវកម្មវិធីសិក្សាដែលមានភាពទូលំទូលាយ និងមានជម្រើសច្រើន។ ការបណ្តុះបណ្តាលដូចនេះអាចជាការកែតម្រូវ និងរៀបចំសម្រាប់ផ្តល់នូវសេវាសង្គម ការបណ្តុះបណ្តាលកុំព្យូទ័រ ធុរកិច្ច និងសហគ្រិនភាព។ល។

កម្មវិធីសិក្សាត្រូវតែកែលម្អ ដើម្បីឱ្យសិស្សអាចធ្វើការក្នុងសហគមន៍ នៅតាមរោងចក្រ សហគ្រាស ដើម្បីពង្រីកនូវចំណេះដឹងលើវិស័យជាច្រើន ដូចជាពាណិជ្ជកម្ម ធ្វើម្ហូបអាហារ សំណង់។ល។ សិស្សអាចទទួលបាននូវបទពិសោធការងារខាងការចម្អិនអាហារសម្រាប់សណ្ឋាគារ ដើម្បីទទួលបាននូវថវិកាសម្រាប់រៀនសូត្រ។ គ្មានរដ្ឋាភិបាលណាមួយដែលអាចចេញចំណាយទាំងអស់តែឯងឱ្យសិស្សបានទេ។ ដូច្នេះ ថ្វីត្បិតតែថវិកាសម្រាប់វិស័យអប់រំជាបញ្ហាសំខាន់ តែថវិកាតែមួយមុខមិនមែនជាដំណោះស្រាយនោះទេ។ ដូច្នេះ ដើម្បីលើកកម្ពស់គុណភាពអប់រំ យើងត្រូវរួមគ្នាពង្រឹងប្រព័ន្ធអប់រំ ដើម្បីផ្តល់ឱកាសអប់រំប្រកបដោយគុណភាពឱ្យបានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស។

នៅក្នុងសាលាធនធាន គ្រូបង្រៀនត្រូវបានគេបង្រៀនពីរបៀបប្រើប្រាស់បន្ទប់ពិសោធន៍ និងរបៀបប្រើប្រាស់ឧបករណ៍ក្នុងបន្ទប់ពិសោធន៍។ ក៏ប៉ុន្តែ សិស្សានុសិស្សមានលទ្ធភាពធ្វើការពិសោធន៍បានតិចតួចណាស់។ ភាគច្រើន ការបង្រៀនសិស្សនៅតែអនុវត្តតាមវិធីសាស្ត្រចាស់ គឺបង្រៀនតែតាមទ្រឹស្តី។ ហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនក៏នៅតែជាឧបសគ្គផងដែរ ដោយក្នុងថ្នាក់រៀនមួយមានសិស្សជាមធ្យម ៥០នាក់។ ចំនួនសិស្សច្រើននេះមិនបានជួយសិស្សក្នុងការរៀនទេ។ ដូច្នេះ យើងត្រូវកាត់បន្ថយចំនួនសិស្សដើម្បីងាយស្រួលបង្រៀន និងធ្វើការអនុវត្តនៅក្នុងបន្ទប់ពិសោធន៍ ក៏ប៉ុន្តែសាលា រៀនភាគច្រើនខ្វះបន្ទប់រៀន។ ដូច្នេះហើយ ទើបការគ្រប់គ្រងសាលារៀនទាមទារឱ្យមានភាពបត់បែន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រូបង្រៀនដើរតួរនាទីគន្លឹះនៅក្នុងប្រព័ន្ធអប់រំកម្ពុជា។ ប្រសិនបើលក្ខខណ្ឌ និងគុណភាពគ្រូបង្រៀនមិនបានកែលម្អទេ នោះប្រព័ន្ធអប់រំកម្ពុជាក៏មិនអាចសម្រេចបានលទ្ធផលល្អប្រសើរជាងនេះដែរ។ ក្នុងន័យនេះ មាតាបិតាសិស្សត្រូវចូលរួមឱ្យសកម្ម នៅក្នុងសកម្មភាពនៃគ្រឹះស្ថានសិក្សា និងត្រូវបង្កើតឱ្យមានវេទិកាដើម្បីឱ្យពួកគាត់បង្ហាញពីទស្សនៈ និងការយល់ឃើញរបស់ពួកគាត់។ នាយកសាលាត្រូវពង្រឹងភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រង ព្រមទាំងផ្តល់ការណែនាំ និងបង្ហាត់បង្ហាញដល់គ្រូ។ ទាំងនេះជាចំណុចផ្លាស់ប្តូរដ៏សំខាន់។ សាលាធនធានកំពុងខិតខំប្រឹងប្រែងដើម្បីចាប់ផ្តើមណែនាំអនុវត្តកិច្ចការទាំងនេះទៅដល់សាលារៀនក្នុងកម្រង។ កម្ពុជាមានសាលាធនធានមួយ ឬពីរនៅតាមខេត្តនីមួយៗនៅក្នុងវិទ្យាល័យ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តាញសាលាធនធានមានសាលារៀនចំនួន ១៤ ក្នុងកម្រង។ សាលាធនធានមិនគ្រាន់តែត្រូវបានប្រើ-ប្រាស់ សម្រាប់គ្រូបង្រៀនវិទ្យាល័យប៉ុណ្ណោះទេ ក៏ប៉ុន្តែសម្រាប់គ្រូមកពីសាលាដ៏ទៀតនៅក្នុងកម្រង ព្រមទាំងជាកន្លែងដ៏ល្អវិសេសសម្រាប់គ្រូទាំងនេះមករៀនពីវិធីសាស្ត្រថ្មីៗ។ ការធ្វើវិក្រឹតការគ្រូបង្រៀនគឺជាការចាំបាច់។ ការបន្តបណ្តុះបណ្តាល និងធ្វើវិក្រឹតការគ្រូជាបន្តបន្ទាប់ គឺជាការចាំបាច់ ដូចជាតម្រូវការឱ្យយោធាត្រូវហ្វឹកហាត់ជាប្រចាំ ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាពអប់រំ។ គ្រូបង្រៀននៅសាលាធនធានអាចទទួលបាននូវប្រាក់ឧបត្ថម្ភផងដែរ។ នៅពេលបច្ចុប្បន្ន គ្រូបង្រៀនអាចផ្ទេរតែចំណេះដឹងផ្នែកទ្រឹស្តីតែប៉ុណ្ណោះ។ ក៏ប៉ុន្តែក្នុងជីវិតជាក់ស្តែង បំណិនខាងចំណេះដឹងអនុវត្តពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ចំណេះដឹងអនុវត្តដូចជាជាងឈើ ។ល។ គឺមានសារៈសំខាន់សម្រាប់សិស្សានុសិស្ស។ តើបញ្ហានេះ យើងត្រូវដោះស្រាយតាមរបៀបណា?

ដូចជាងឈើដែលត្រូវការឧបករណ៍សម្រាប់ឈូសឈើ គ្រូបង្រៀនត្រូវការសម្ភារឧបទេសសម្រាប់បង្រៀន។ ដើម្បីជំរុញគ្រូបង្រៀនឱ្យផ្ទេរចំណេះដឹងឱ្យសិស្ស ឱ្យមានប្រសិទ្ធភាព សាលាត្រូវផលិតសម្ភារបង្រៀន និងផ្តល់ឱ្យគ្រូបង្រៀន ដើម្បីផ្តល់ការណែនាំនូវអ្វីដែលជាការរំពឹងទុករបស់ពួកគេ និងរបៀបធ្វើការរបស់ពួកគេ។ ក្រៅពីប្រាក់បៀវត្សនិងការលើកទឹកចិត្តផ្សេងទៀត ដូចជាប្រាក់ខែខ្ពស់ និងលក្ខខណ្ឌការងារកាន់តែប្រសើរ គ្រូបង្រៀនចាំបាច់ត្រូវតែគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដើម្បីឱ្យក្លាយជាសមាជិកដែលមានតម្លៃរបស់សង្គម។ គ្រូបង្រៀនត្រូវតែទទួលស្គាល់ថាពួកគាត់ ត្រូវតែផ្លាស់ប្តូរអាកប្បកិរិយា ប្រសិនបើពួកគាត់ចង់បានឋានៈក្នុងសង្គម ដែលត្រូវបានគេគោរពកោតសរសើរ។ គ្រូបង្រៀនត្រូវធ្វើឱ្យមាតាបិតា សិស្សានុសិស្ស ប្រជាជន មានការជឿទុកចិត្ត។ ប្រការនេះមានន័យថា គ្រូបង្រៀនត្រូវឈប់ប្រព្រឹត្តអំពើអសកម្មក្នុងថ្នាក់ ដូចជាការទារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាក់ពីសិស្ស ក្នុងពេលផ្តល់សេវាអប់រំ។ ពួកគាត់ត្រូវតែគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន រួមមាន ៖

- គ្មានការទារលុយដោយខុសច្បាប់ពីសិស្ស ដើម្បីបានចូលរៀន

- ធ្វើខ្លួនរបស់ពួកគាត់ជាអ្នកមានវិជ្ជាជីវៈក្នុងការបង្រៀនប្រកបដោយភាពឧស្សាហ៍ព្យាយាម

- បន្តពង្រីកនិងពង្រឹងជំនាញ និងគុណវុឌ្ឍិគ្រប់កាលៈទេសៈទាំងអស់។

កិច្ចការនេះអាចធ្វើទៅបាន ប្រសិនបើមានការជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យអប់រំ ដែលជាវិស័យមានអាទិភាពខ្ពស់ជាងគេ តាមរយៈការផ្តល់ការឧបត្ថម្ភ និងលើកទឹកចិត្តដល់គ្រូបង្រៀនឱ្យបានសមស្រប និងផ្តល់ការទទួលស្គាល់។

ប្រទេសណា ដែលការទទួលស្គាល់ កិត្យានុភាព និងឋានៈក្នុងសង្គមរបស់គ្រូបង្រៀន ស្ថិតនៅក្នុងលំដាប់បាតក្រោមក្នុងចំណោមវិជ្ជាជីវៈក្នុងសង្គម នោះប្រទេសទាំងនោះពិតជាមានការលំបាកក្នុងការលើកតម្កើងកិត្យានុភាព និងការទទួលស្គាល់ឡើងវិញ។ ក្នុងករណីនេះ សាធារណៈជនមានទំនុកចិត្តតិចតួចណាស់ក្នុងប្រព័ន្ធអប់រំ។ មាតាបិតា និយោជក និងសិស្សានុសិស្សត្រូវតែជឿជាក់ និងមានទំនុកទុកចិត្តលើប្រព័ន្ធអប់រំ។ ក្នុងន័យនេះ អ្នកដឹកនាំ និងអ្នកគ្រប់គ្រងប្រព័ន្ធអប់រំត្រូវធ្វើយ៉ាងណា ឱ្យគ្រូបង្រៀនមានជំនាញឯកទេស ទទួលការបណ្តុះបណ្តាល និងមានឆន្ទៈខ្ពស់ ក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាពខ្ពស់ដល់សិស្ស ហើយសាលាធនធានត្រូវផ្តល់សម្ភារបរិក្ខារ និងធនធានគ្រប់គ្រាន់សម្រាប់ការធ្វើទស្សនកិច្ចផ្លាស់ប្តូរពិសោធន៍ និងការបង្ហាញ។

ការគ្រប់គ្រងដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឱ្យប្រសើរឡើងនៃសាលារៀន និងការលើកកម្ពស់ការបំពេញការងាររបស់គ្រូបង្រៀន។ ប្រការនេះទាមទារឱ្យនាយក ឬនាយិកាអនុវត្តនូវវិធានការតឹងរឹង ដូចខាងក្រោម ៖

- ការដាក់ទណ្ឌកម្មដល់គ្រូបង្រៀន ដែលទារលុយខុសច្បាប់ពីសិស្ស

- ការដាក់វិធានការដ៏តឹងរឹង ចំពោះអ្នកដែលមានកំហុស ហើយមិនកែប្រែ

- ការបណ្តុះបណ្តាលនាយកខាងផ្នែកគ្រប់គ្រង និងភាពជាអ្នកដឹកនាំ

- ការដាក់ទណ្ឌកម្មដល់នាយក ដែលមិនបានពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ

- ការរៀបចំយន្តការធ្វើសវនកម្ម និងប្រព័ន្ធរបាយការណ៍។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គុណភាពនៃប្រព័ន្ធគ្រឹះស្ថានសិក្សា គឺជាបញ្ហាមួយដែលមានការព្រួយបារម្ភពីសំណាក់សាធារណៈជន និងដៃគូអភិវឌ្ឍ។ បញ្ហាទាំងនេះបណ្តាលមកពី ទាំងហេតុផលគោលនយោបាយ សមធម៌ និងកំណើនសេដ្ឋកិច្ច។ កម្ពុជាត្រូវផ្តល់ឱកាសស្មើៗគ្នា ដើម្បីឱ្យសិស្សានុសិស្សទទួលបានការអប់រំប្រកបដោយគុណភាព។ នៅពេលដែលប្រជាពលរដ្ឋមានចំណេះដឹងខ្ពស់ កម្ពុជានឹងសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

គោលបំណងនៃច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧ គឺការអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់អ្នកទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយា ប្រកបដោយសីលធម៌សំដៅជំរុញអ្នកសិក្សាឱ្យស្គាល់ ស្រលាញ់ និងរួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ។

ការអប់រំប្រកបដោយគុណភាព គឺជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍប្រទេស។ ចាប់តាំងពីឆ្នាំ១៩៩៣ មក ប្រទេសកម្ពុជាបានទទួលនូវសន្តិភាព ហើយក្នុងរយៈពេល២០ឆ្នាំមកនេះ ការផ្លាស់ប្តូរជាច្រើនបានកើតឡើង។ ក្រសួងអប់រំ យុវជន និងកីឡាមានការចាប់អារម្មណ៍យ៉ាងខ្លាំង និងមានឆន្ទៈមោះមុត ដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំឱ្យរីកចំរើន។

ការពិនិត្យឡើងវិញនូវ **ផែនការយុទ្ធសាស្ត្រអប់រំ២០០៩-២០១៣** បានលើកឡើងពីការផ្លាស់ប្តូរ និងបានចង្អុលបង្ហាញឱ្យឃើញថា នេះជាដំណាក់កាលដ៏សំខាន់ដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវតែបន្តកែទម្រង់ផ្នែកអប់រំ យុវជន និងកីឡា ស្របតាមកំណែទម្រង់របស់រាជរដ្ឋាភិបាល។ នៅក្នុងកំឡុងពេលប្រាំឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍បានធ្វើឱ្យមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ក្នុងការធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ និងការគ្រប់គ្រងអប់រំ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យធានាឱ្យមានទំនាក់ទំនងរវាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ជាមួយកម្មវិធីអភិវឌ្ឍន៍ និងផែនការសកម្មភាព ព្រមទាំងរវាងការធ្វើផែនការ និងថវិកាកម្មវិធី។ នៅក្នុងដំណាក់កាលនេះ ក្រសួងមានបំណងបន្តផ្តល់អាទិភាពខ្ពស់បំផុតដល់ការទទួលបាននូវសេវាអប់រំប្រកបដោយគុណភាព និងសមធម៌ ជាពិសេសការអប់រំមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងផែនការអប់រំជាតិសម្រាប់ទាំងអស់គ្នានៅឆ្នាំ២០១៥។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ផ្តោតការយកចិត្តទុកខ្លាំងជាងគេ ទៅលើការពង្រីកការអប់រំកុមារតូច



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងការពង្រីកឱកាសទទួលសេវាអប់រំថ្នាក់មធ្យមសិក្សា និងក្រោយមធ្យមសិក្សា។

អាទិភាពចម្បងរបស់រាជរដ្ឋាភិបាល គឺការធានាថាការអប់រំមានគុណភាពល្អ និងឈានដល់ស្តង់ដាខ្ពស់ និងការទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋាន។ ប្រការនេះទាមទារឱ្យមានការចូលរួមពីគ្រប់កម្រិតទាំងអស់ ស្ថាប័ននីតិបញ្ញត្តិ ក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានសិក្សា នាយកសាលា គ្រូបង្រៀន មាតាបិតា អាណាព្យាបាល សិស្សានុសិស្ស ព្រមទាំងសង្គមជាតិទាំងមូល។

ច្បាប់ស្តីពីការអប់រំបានចែងថា «រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំ ដើម្បីបំពេញសេចក្តីត្រូវការសម្រាប់ការអប់រំមូលដ្ឋាន និងសេចក្តីត្រូវការជំនាញ ដើម្បីធ្វើឱ្យអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព»។

ម្យ៉ាងវិញទៀត តាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣ រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការខិតខំប្រឹងប្រែង ដើម្បីធានាឱ្យបាននូវលទ្ធផលដ៏ល្អបំផុត ពីចំណាយលើវិស័យអប់រំ ដោយការធ្វើការកែលម្អឱ្យបានច្បាស់នូវសូចនាករដែលបានកំណត់ ដើម្បីធានាឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសសង្កត់ធ្ងន់ទៅលើការផ្តល់សេវាអប់រំដល់កុមារ និងយុវជន ដែលមិនមានឱកាសទទួលបានសេវាអប់រំ។ អាទិភាពដទៃទៀតរួមមាន ការពង្រឹងការអនុវត្តច្បាប់ស្តីពីការអប់រំ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងអភិបាលកិច្ចល្អ។ កត្តាទាំងនេះគឺជាសមាសភាគនៃសកម្មភាព ដើម្បីសម្រេចឱ្យបាននូវគុណភាពល្អ។ គុណភាព គឺបញ្ហាអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ក្នុងគោលដៅពង្រឹងគុណភាពអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវរបៀបវារៈមួយដ៏សំខាន់ គឺការអនុវត្តអធិការកិច្ចនៅតាមគ្រឹះស្ថានសិក្សា។ ក្នុងនោះក៏មានសមាសភាគពីរផ្សេងទៀត ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអធិការកិច្ចគឺការធ្វើស្វ័យវាយតម្លៃសាលារៀន ការផ្តល់ជំបូន្មាន និងការណែនាំ ដែលត្រូវបានពិភាក្សានៅក្នុងជំពូកនេះ។

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការសម្រេចចិត្ត ដើម្បីផ្លាស់ប្តូរទស្សនវិស័យសម្រាប់ការធ្វើអធិការកិច្ច ពីការធ្វើអធិការកិច្ចតាមមុខវិជ្ជា និងលើគ្រូបង្រៀន ទៅជាការធ្វើអធិការកិច្ចជាប្រព័ន្ធ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៧.២. ប្រវត្តិនៃអធិការដ្ឋានអប់រំក្នុងប្រទេសកម្ពុជា

អាណាព្យាបាលបារាំងបានចាប់ផ្តើមធ្វើកំណែទម្រង់អប់រំ បន្ទាប់ពីការចុះហត្ថលេខាលើអនុសញ្ញា ឆ្នាំ១៨៨៤[257]។ អនុសញ្ញាមានគោលបំណងធ្វើទំនើបកម្ម និងមជ្ឈការប្រព័ន្ធរដ្ឋបាលរបស់កម្ពុជា ឱ្យស្ថិតនៅក្រោមការដឹកនាំរបស់តំណាងជាន់ខ្ពស់បារាំង[258] ដោយ ចាប់ផ្តើមធ្វើកំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។ នៅក្នុងឆ្នាំ១៩១១តំណាងជាន់ខ្ពស់បារាំងបានតែងតាំង មន្ត្រីអាណានិគមជាតិបារាំងទទួលបន្ទុកវិស័យអប់រំ ដែលមានភារកិច្ចដឹកនាំនាយកដ្ឋានអប់រំ និងសិក្សាធិការ។ ក្នុងន័យនេះ អាណា-ព្យាបាលបារាំងបានដាក់ឱ្យអនុវត្តអធិការដ្ឋានអប់រំនៅប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃការខិតខំប្រឹងប្រែង ដើម្បីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ធ្វើការផ្នែករដ្ឋបាល។ នៅតាមខេត្តធំ មន្ត្រីអប់រំជនជាតិបារាំងត្រូវបានជ្រើសតាំងជាមន្ត្រីអធិការបឋមសិក្សា ដែលបានធ្វើអធិការកិច្ចនៅតាមសាលាបឋមសិក្សាទំនើប។ សាលាវត្តមិនត្រូវបានដាក់បញ្ចូលក្នុងអធិការកិច្ចនេះទេ ប៉ុន្តែត្រូវបានគេដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីប្រតិភូព្រះមហាក្សត្រគឺលោក Manipoud។ ដូច្នេះ ចាប់ពីដើមស.វ.ទី២០មក មានតែជនជាតិបារាំងទេដែលត្រូវបានតែងតាំងធ្វើជាអធិការអប់រំ ដូចជា លោក Russier[259], Manipoud[260], Camfort ។ល។ អធិការអប់រំមានតួនាទីធ្វើកំណែទម្រង់សាលាវត្ត និងបណ្តុះបណ្តាលគ្រូបង្រៀន[261]។ ដូច្នេះ ប្រព័ន្ធសិក្សាអប់រំកម្ពុជាត្រូវបានគេដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរដ្ឋបាលអាណាព្យាបាលបារាំងរវាងឆ្នាំ១៩១១ និងឆ្នាំ១៩៤៥។

នៅទសវត្សរ៍ឆ្នាំ១៩៣០ បារាំងបានចាប់ផ្តើមជំនួសគ្រូបង្រៀនជនជាតិបារាំងដោយគ្រូបង្រៀនសញ្ជាតិកម្ពុជា។ នៅពេលដែលគ្រូបង្រៀនកម្ពុជាកាន់តែច្រើនបានទទួលបទពិសោធនៃការបង្រៀននៅសាលារៀនទំនើប ប្រព័ន្ធអធិការដ្ឋានអប់រំត្រូវបានចាប់ផ្តើម

---

[257] Convention pour régler les rapports respectifs des deux pays, 17 juin 1884.

[258] Résident supérieur

[259] Henri Russier ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានសិក្សាធិការ។ លោកបានសរសេររបាយការណ៍ស្តីពីការអប់រំបឋមសិក្សានៅកម្ពុជា។ (RUSSIER, H., “L’enseignement élémentaire au Cambodge”, Revue indochinoise, avril 1913, p. 409-420.), cited by Khing Hoc Dy (2014). L’enseignement primaire au Cambodge depuis le protectorat français jusqu’en 1975. p. 5.

[260] Manipoud spoke Khmer fluently and was a lover of Cambodia. He played an important role in the reform of pagoda schools. Teachers were selected from among Buddhist monks who enjoyed strong confidence from among pagoda supporters. They were trained to widen their general knowledge and subjects. After graduation, they should return to teach at their original pagoda (Yang Thy et Sorn Samnang, Histoire de l’éducation primaire et secondaire au Cambodge. Des temps anciens à nos jours, 1998-99. p. 27).

[261] Delvert, Jean, “Servitude et grandeur de l’enseignement: l’exemple du Cambodge», Philippe Héduy (1983) (Ed.), Histoire de l’Indochine. Le destin 1885-1954, Paris, Henri Vyrier, p. 326. Cited by Khing Hoc Dy, p. 17.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅក្នុងប្រព័ន្ធអប់រំកម្ពុជា។ ការប្រឡងជ្រើសរើសអធិការត្រូវបានរៀបចំឡើង ហើយបេក្ខជនដែលជាអធិការបឋមសិក្សាត្រូវបានគេជ្រើសរើស ពីក្នុងចំណោមគ្រូបង្រៀនដែលបានបង្រៀននៅអនុវិទ្យាល័យ។[262] ការប្រឡងជ្រើសរើសមានភាពតឹងរ៉ឹង និងសម្រិត-សម្រាំងបំផុត។ អធិការចំនួនតិចតួចប៉ុណ្ណោះត្រូវបានគេជ្រើសរើស។

អធិការសាលាបឋមសិក្សាត្រូវបានគេជ្រើសរើស ពីក្នុងចំណោមបញ្ញវន្តជាន់ខ្ពស់ដែលមានការទទួលស្គាល់ និងមានការគោរព ជាមួយនឹងបទពិសោធការងារជាច្រើនឆ្នាំធ្វើការនៅក្នុងក្រសួងអប់រំ ឬក៏ធ្វើការជាប្រធានមន្ទីរអប់រំខេត្ត ឬបង្រៀននៅតាមអនុវិទ្យាល័យ ឬក៏ជានាយកសាលា។ អធិការត្រូវបានទទួលការបណ្តុះបណ្តាលរយៈពេលមួយឆ្នាំបន្ទាប់ពីការប្រឡងជ្រើសរើសអធិការ។ អធិការដែលល្បីៗរួមមាន លោក ពុង ប៉េងចេង លោក ទ្រឹញ រ៉ាញ លោក ឈូក ម៉ឹងម៉ៅ លោក ហូ តុង ហូ លោក ណុប ឆោម លោក ផៃ ផេង លោក តៅ ហ៊ឹង លោក ធុយ ប៊ុនសូ លោក យឹម ឌិត លោក ចាន់ ឡូវ និងលោក ចៃត្រ ឆែម។ល។[263]

នៅក្នុងឆ្នាំ១៩៤៥ នៅពេលដែលប្រទេសសម្ពន្ធមិត្ត (សហរដ្ឋអាមេរិក បារាំង និងចក្រភពអង់គ្លេស) បានឈ្នះសង្គ្រាមលោកលើកទី២ ក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈត្រូវបានបង្កើតឡើង និងត្រូវបានដឹកនាំដោយឥស្សរជនខ្មែរ។ ក្នុងឆ្នាំ១៩៤៧ នាយកដ្ឋានអធិការកិច្ចត្រូវបានបង្កើតឡើង ហើយចែកចេញជាពីរក្រុម។ ក្រុមទី១ ដឹកនាំដោយលោក អ៊ុំ ឈាងស៊ុន ជាអធិការនាយក ដែលទទួលខុសត្រូវជាអធិការដ្ឋានសាលាវត្ត និងក្រុមទី២ ដឹកនាំដោយលោក ចៃត្រ ឆែម ជាអធិការនាយក ដែលទទួលខុសត្រូវជាអធិការដ្ឋានសាលាបារាំងខ្មែរ។ នៅចុងបញ្ចប់នៃសង្គ្រាមលើកទី២ មានគ្រឹះស្ថានធារណៈ៧៨៧ និងសាលាវត្តកំណែទម្រង់ចំនួន ១ ៩៤៧[264]។ ដូច្នេះ ចំនួនគ្រឹះស្ថានធារណៈបានកើនឡើងយ៉ាងឆាប់រហ័ស ពីសាលាចំនួន ៣ នៅក្នុងឆ្នាំ១៩០៣ ដល់៧៨៧ ក្នុងឆ្នាំ១៩៤៥[265]។ ក្នុងឆ្នាំ១៩៤៩ ក្រុមអធិការដ្ឋានអប់រំទាំងពីរត្រូវបានច្របាច់បញ្ចូលគ្នាតែមួយ។ បន្ទាប់ពីទទួលបានឯករាជ្យ ខេត្តនីមួយៗត្រូវបានបែងចែកជាតំបន់ ក្នុងគោលបំណងសម្រាប់ធ្វើអធិការកិច្ចតាមសាលា ហើយនៅក្នុងឆ្នាំ១៩៦៩/១៩៧០ មានតំបន់ធ្វើអធិការចំនួន១៩៨ ដែលដឹកនាំដោយអធិការមួយនាក់ និងមានអធិការរងម្នាក់ ឬពីរនាក់ជាជំនួយការ។ អធិការតាម

[262] Khing Hoc Dy (2014), op. cit., p. 20.
[263] Khing Hoc Dy, op. cit., p. 20.
[264] Khing Hoc Dy, op. cit., p. 12.
[265] In 1903 there were only three public French-Cambodian schools in the Kingdom, one in Phnom Penh and two others were located in Kompong Cham and Pursat provinces. The first public school in Cambodia, Norodom Primary School, was only established in 1903 by King Norodom to schooling princes and sons of high-ranking court official. In 1905, the French colonial authority transformed the college du Protectorat into école Sisowath, a lower secondary school. The number of students of école Sisowath increased from 65 in 1907 to 130 in 1920.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តំបន់នីមួយៗមានភារកិច្ចធ្វើអធិការកិច្ចគ្រូបង្រៀនជាង១០០នាក់។ មហាវិទ្យាល័យគរុកោសល្យ[266] ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៨ ដែលមានភារកិច្ចបណ្ដុះបណ្ដាលអធិការ ដែលជាផ្នែកមួយក្នុងចំណោមតួនាទីដ៏សំខាន់របស់ខ្លួន ក្នុងការបណ្ដុះបណ្ដាលគ្រូបឋមសិក្សា គ្រូអនុវិទ្យាល័យ និងការស្រាវជ្រាវ។

បន្ទាប់ពីសង្គ្រាមស៊ីវិលបានផ្ទុះឡើងនៅខែមីនាឆ្នាំ១៩៧០ អធិការអប់រំនិងប្រព័ន្ធអប់រំកម្ពុជាត្រូវបានធ្លាក់ចុះ។ អធិការអប់រំត្រូវបានរំលាយចោលទាំងស្រុង បន្ទាប់ពីរបបខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥។ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាបានខិតខំប្រឹងប្រែង ដើម្បីស្ដារឡើងវិញនូវប្រព័ន្ធអប់រំកម្ពុជា ដែលរងនូវការខ្ទេចខ្ទាំ។ប្រព័ន្ធអធិការអប់រំកម្ពុជាត្រូវបានស្ដារឡើងវិញក្នុងទសវត្សរ៍១៩៩០។ តាមអនុក្រឹត្យលេខ២១ ចុះថ្ងៃទី២៣ ខែមីនាឆ្នាំ១៩៩៨ សេចក្ដីណែនាំលេខ៣ ស្ដីពីការរៀបចំមន្ទីរអប់រំខេត្តត្រូវបានអនុម័តនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៩៨ ដែលគ្រប់មន្ទីរអប់រំទាំងអស់តម្រូវឱ្យបង្កើតការិយាល័យអធិការ។ អធិការអប់រំត្រូវបានបង្កើតឡើងវិញនៅក្នុងឆ្នាំ១៩៩៩ ជាមួយនឹងការបណ្ដុះបណ្ដាល ក្រោមការជួយជ្រោមជ្រែងពីស្ថានទូតបារាំង។ វត្ថុបំណងនៃការបណ្ដុះបណ្ដាល គឺដើម្បីបែងចែកអធិការអប់រំទៅគ្រប់ការិយាល័យអប់រំស្រុក ដើម្បីលើកកម្ពស់គុណភាពអប់រំ។ ទោះបីជាយ៉ាងណាក៏ដោយការបែងចែកអធិការអប់រំមិនបានពង្រាយឱ្យដល់ថ្នាក់ស្រុក/ខណ្ឌទេ។ បន្ទាប់ពីបានបញ្ចប់កម្មវិធីបណ្ដុះបណ្ដាល អធិការត្រូវបានគេបែងចែកឱ្យទៅបម្រើការនៅតាមនាយកដ្ឋានជំនាញ (នាយកដ្ឋានបឋម និងមធ្យម) និងតាមមន្ទីរអប់រំ។ ជាងនេះទៅទៀត ការបណ្ដុះបណ្ដាលអធិការអប់រំត្រូវបានរៀបចំឡើងដោយគ្មានក្របខណ្ឌច្បាប់ អនុក្រឹត្យ ឬប្រកាសណាមួយ ឬក៏ឧបករណ៍ណាមួយសម្រាប់អធិការអប់រំឡើយ[267]។

## ៧.៣. ក្របខណ្ឌធានាគុណភាពថ្មី

ដើម្បីចាប់ផ្ដើមបង្កើតប្រព័ន្ធអធិការអប់រំថ្មី អនុស្សរណៈយោគយល់គ្នាមួយត្រូវបានចុះហត្ថលេខានៅក្នុងឆ្នាំ២០១២ រវាងក្រសួងអប់រំ យុវជន និងកីឡា និងអគ្គាធិការដ្ឋានអប់រំប្រទេសស៊ុយអែត។ វត្ថុបំណងនៃកិច្ចសហប្រតិបត្តិការនេះ គឺដើម្បីកសាងនូវប្រព័ន្ធធានា

[266] Institut National Pédagogique. Teacher training was also conducted by the Tonle Bati Teacher Training Center (1955) and the Kampong Kantuot Teacher Training Center (1957).
[267] Yang Thy et Sorn Samnang, Histoire de l’éducation primaire et secondaire au Cambodge. Des temps anciens à nos jours, 1998-99. p. 48.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គុណភាពមួយ ដែលរួមចំណែកក្នុងការអនុវត្តសេចក្តីណែនាំ ប្រកាស អនុក្រឹត្យ ច្បាប់អប់រំ កម្មវិធីសិក្សា និងឯកសារគោលនយោបាយផ្សេងៗ។

### ៧.៣.១. ក្របខណ្ឌគតិយុត្តិ

ឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា គឺជាការសម្រេចចិត្តខាងនយោបាយដែលជាមធ្យោបាយដើម្បីធ្វើឱ្យប្រសើរឡើង និងធានាឱ្យបាននូវគុណភាពប្រព័ន្ធអប់រំនៅតាមគ្រឹះស្ថានសិក្សាកម្ពុជា។ លិខិតបទដ្ឋានជាធរមានទាំងនេះ អាចជាមូលដ្ឋានសម្រាប់កំណត់វិសាលភាពនៃការធ្វើអធិការកិច្ចអប់រំ។ កម្ពុជាបានអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានថ្លែងពីសិទ្ធិទទួលការអប់រំដោយឥតគិតថ្លៃនៅបឋមសិក្សា ការអនុវត្តនូវសេចក្តីថ្លៃថ្នូររបស់មនុស្ស និងគ្មានអំពើហិង្សាក្នុងវិស័យអប់រំ។ អនុសញ្ញាផ្តល់តម្លៃខ្ពស់ទៅលើការអប់រំ និងចែងថាមនុស្សវ័យក្មេងគួរតែត្រូវបានលើកទឹកចិត្ត ដើម្បីទទួលបាននូវការអប់រំកម្រិតខ្ពស់បំផុត ទាំងចំណេះដឹង និងសមត្ថភាពការងារ។ នៅក្នុងអនុសញ្ញានេះ មានមាត្រាជាច្រើនដែលពាក់ព័ន្ធនឹងវិស័យអប់រំ និងការទទួលខុសត្រូវរបស់រដ្ឋ នៅក្នុងការគ្រប់គ្រងប្រព័ន្ធសាលារៀន។

**ច្បាប់ស្តីពីការអប់រំ** ត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០៧។ ជំពូកទី១នៃច្បាប់ស្តីពីការអប់រំបានចែងថា មនុស្សគ្រប់រូបមានតម្លៃ និងសិទ្ធិស្មើគ្នា ដើម្បីទទួលបានសេវាអប់រំ។ ច្បាប់ស្តីពីការអប់រំក៏បានចែងពីប្រព័ន្ធវាយតម្លៃ និងគ្រប់គ្រងនៅក្នុងមាត្រាទី៩ (វិស័យអប់រំត្រូវមានប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃវិស័យអប់រំ ដែលរួមមានការត្រួតពិនិត្យតាមដាន អធិការកិច្ច និងសវនកម្មផ្ទៃក្នុងលើការបំពេញការងារ។ ក្រសួងទទួលបន្ទុកវិស័យអប់រំមានភារកិច្ចទទួលខុសត្រូវរៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃនេះ)។

កម្មវិធីអធិការកិច្ចអប់រំចែកមានសមាសភាគ ៤ គឺ ៖ ក្របខណ្ឌធានាគុណភាពអប់រំ (QAF) ឧបករណ៍ធានាគុណភាពអប់រំ (QAT) ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (QEMIS) និងការកសាងសមត្ថភាព ដើម្បីធានាគុណភាពអប់រំ (CDQA)។ ជាលទ្ធផល **ក្របខណ្ឌជាតិគុណភាពកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា**[268] ត្រូវបានអនុម័តនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥។ សកម្មភាពធានាគុណភាពនឹងផ្តោតទៅលើការពង្រឹង និងកែលម្អដំណើរការអប់រំ ដើម្បីបង្កើតលទ្ធផលចុងក្រោយល្អប្រសើរ។

[268] ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) «ក្របខណ្ឌជាតិគុណភាពកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា» ភ្នំពេញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់ប្រព័ន្ធអប់រំនៅកម្ពុជា សកម្មភាពធានាគុណភាព មានន័យថា ធ្វើឱ្យសិស្សានុសិស្ស ទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ និងអាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ។

ការធ្វើអធិការកិច្ចសាលារៀន គឺជាយន្តការត្រួតពិនិត្យ និងតាមដានថា តើសាលារៀនបានសម្រេចតាមតម្រូវការរបស់ខ្លួនបានត្រឹមកម្រិតណា។ អធិការកិច្ចក៏អាចវាយតម្លៃផងដែរថា តើសាលារៀនអាចសម្រេចបានទំនួលខុសត្រូវរបស់ខ្លួន ទាក់ទងនឹងគោល-ការណ៍ទាំងឡាយ ដែលមានចែងក្នុងច្បាប់ស្តីពីការអប់រំបានត្រឹមកម្រិតណា។ អធិការត្រូវធ្វើការវាយតម្លៃថា តើសកម្មភាពអប់រំ ដែលសាលារៀនកំពុងធ្វើទាក់ទងនឹងវត្ថុបំណង និងកម្មវិធីសិក្សារបស់ជាតិសម្រេចបានល្អត្រឹមកម្រិតណាហើយ។ គេអាចនិយាយបានថា ភារកិច្ចសំខាន់បំផុតរបស់អធិការ គឺពិនិត្យមើលថាតើសាលារៀនមានប្រព័ន្ធសម្រាប់ធ្វើស្វ័យវាយតម្លៃ និងយុទ្ធសាស្ត្រស្វ័យកែលម្អហើយឬនៅ។ បន្ថែមលើការពិនិត្យនេះ អធិការក៏ត្រូវតែចូលរួមក្នុងការអនុវត្តទាំងនោះផងដែរ។

ជាសង្ខេប **គោលបំណងរួមរបស់អធិការកិច្ច** គឺកែលម្អអ្នកសិក្សាទាំងអស់តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត និងពង្រឹងសមត្ថភាពធ្វើស្វ័យវាយតម្លៃ។ អធិការកិច្ចក៏ត្រូវវាយតម្លៃសាលារៀនផងដែរ ដើម្បីបង្ហាញអំពីចំណេះដឹង និងស្ថានភាពសិក្សាជាក់ស្តែងរបស់កម្ពុជា។

## ៧.៣.២. វិធីសាស្ត្រធ្វើអធិការកិច្ច

អធិការកិច្ចអាចអនុវត្តតាមវិធីផ្សេងៗ ៖ អធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅ។

## ៧.៤. អធិការកិច្ចផ្ទៃក្នុង

### ៧.៤.១. ស្វ័យវាយតម្លៃសាលារៀន

**អធិការកិច្ចផ្ទៃក្នុង** គឺផ្អែកលើស្វ័យវាយតម្លៃរបស់សាលារៀន ដែលអនុវត្តដោយនាយកសាលា គ្រូបង្រៀន និងសិស្សានុសិស្ស។ កិច្ចការនេះក៏ត្រូវផ្តោតផងដែរលើការងារទាក់ទងនឹងគុណភាពផ្ទៃក្នុងនៅកម្រិតសាលារៀន ដោយប្រើប្រាស់ធនធានផ្ទៃក្នុង ឬធនធានមូលដ្ឋាន។ ការធ្វើអធិការកិច្ចផ្ទៃក្នុងត្រូវរៀបចំ និងអនុវត្តជាប្រចាំប៉ុន្តែពុំសូវមានលក្ខណៈផ្លូវការដូចអធិការកិច្ចពីខាងក្រៅទេ ហើយចំពោះការធ្វើការកែលម្អអ្វីមួយវិញក៏ត្រូវធ្វើឡើងជាប្រចាំផងដែរក្នុងអំឡុងឆ្នាំសិក្សា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ប្រព័ន្ធស្វ័យវាយតម្លៃ**សាលារៀនដ៏មានប្រសិទ្ធភាព និងជាប្រចាំអាចផ្តល់ឱកាសក្នុងការសិក្សា អង្កេតទៅលើជីវភាពខាងក្នុង និងមហិច្ឆតារបស់សាលារៀន ថាតើបានកែលម្អលទ្ធផលសិក្សារបស់សិស្សត្រឹមកម្រិតណា ជាជាងរង់ចាំអធិការអប់រំ ដែលមកមើលសាលារៀនម្តងម្កាល។ **ប្រព័ន្ធស្វ័យវាយតម្លៃ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការជាការកែលម្អរយៈពេលវែង**។ នាយកសាលារៀនមានតួនាទីយ៉ាងសំខាន់ ក្នុងការដឹកនាំធ្វើស្វ័យវាយតម្លៃសាលារៀន។ ការងារប្រកបដោយគុណភាព និងជាប្រព័ន្ធមានន័យថា សាលារៀនធ្វើការពិនិត្យ តាមដានសកម្មភាពជាប្រព័ន្ធ និងជាប្រចាំ ធ្វើការវិភាគលទ្ធផល ដែលទាក់ទងនឹងគោលដៅរបស់ជាតិ និងផ្អែកលើផែនការ និងការអភិវឌ្ឍវិស័យអប់រំ។ នាយកសាលាវិភាគទៅមូលហេតុនៃភាពផ្សេងៗគ្នា ពាក់ព័ន្ធនឹងប្រសិទ្ធភាពការងាររវាងក្រុមផ្សេងៗ និងថ្នាក់រៀនផ្សេងៗ ឬក៏រវាងមុខវិជ្ជាផ្សេងៗ និងចំណុចដៅមុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សា។ លទ្ធផលគួរតែត្រូវបានគេពិភាក្សាក្នុងចំណោមគ្រូបង្រៀន និងបុគ្គលិក។ ការវាយតម្លៃផ្តោតទៅលើពេលវេលា ដែលបានប្រើប្រាស់ក្នុងការបង្រៀន ប្រវត្តិរូបរបស់គ្រូបង្រៀន ជំនាញ តម្លៃ ឥរិយាបថ និងវិធីសាស្រ្តក្នុងការអភិវឌ្ឍកុមារនិងការសិក្សា ព្រមទាំងជំនាញឯកទេសរបស់គ្រូបង្រៀននិងបុគ្គលិកដទៃទៀតក្នុងការបំពេញបេសកកម្មរបស់ខ្លួន។

នាយកដែលនឹងក្លាយជាអ្នកដឹកនាំជោគជ័យ តែងតែផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់គាត់លើវត្ថុបំណងទូទៅចំនួនបួន ៖

១-លើកកម្ពស់យ៉ាងខ្លាំងក្លាលើដំណើរការរៀន និងបង្រៀន ដើម្បីសម្របសម្រួលសមិទ្ធផលសិក្សាសម្រាប់កុមារទាំងអស់។

២-បណ្តុះគំនិតសហគមន៍ឱ្យចូលរួមយ៉ាងខ្លាំងក្លា ព្រោះថាពួកគាត់ទាំងអស់គឺជាផ្នែកមួយរបស់សាលារៀន។

៣-ផ្តល់តម្លៃ និងលើកកម្ពស់ស្ថានភាពសង្គម–សេដ្ឋកិច្ចរបស់កុមារ។

៤-លើកទឹកចិត្ត និងជំរុញការអភិវឌ្ឍវប្បធម៌អប់រំរបស់គ្រួសារ។

គ្រូបង្រៀនគឺជាចំណុចស្នូលនៃកំណែទម្រង់សាលារៀន។ ដូចនេះ ជោគជ័យនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីក្នុងបរិបទកំណែទម្រង់ គឺអាស្រ័យលើសមត្ថភាពរបស់គ្រូបង្រៀន ដែលកំពុងស្ថិតនៅក្នុងប្រព័ន្ធនោះ។ ដូចនេះបញ្ហាប្រឈមចម្បងនៃការធ្វើកំណែទម្រង់សាលារៀន គឺបណ្តាលមកពីគ្រូបង្រៀនមិនបានបំពេញគ្រប់លក្ខខណ្ឌនៃការអប់រំ និងការបណ្តុះបណ្តាល។ ការងារនេះក៏ត្រូវរួមផងដែរនូវការបណ្តុះបណ្តាល និងវិក្រឹតការដែលមានគុណភាពខ្ពស់សម្រាប់គ្រូបង្រៀន ដើម្បីពួកគាត់អាចមានលទ្ធភាពបំពេញ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការងារប្រកបដោយប្រសិទ្ធភាព ដែលផ្អែកលើគោលការណ៍សិស្សមជ្ឈមណ្ឌល និងគរុកោសល្យដ៏ទាក់ទាញ ដែលជាបេះដូងនៃកម្មវិធីសាលាកុមារមេត្រី។

### ៧.៤.២. កម្រិតស្រុក

***សាលាកុមារមេត្រី*** បានដើរតួនាទីយ៉ាងសំខាន់ ដើម្បីជួយនិងលើកកម្ពស់គុណភាពអប់រំ។ គោលនយោបាយអប់រំមិនមែនត្រឹមតែមានគោលដៅទទួលកុមារឱ្យចូលក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើការកែលម្អគុណភាពនៃការសិក្សា ព្រមទាំងបង្ហាញឱ្យឃើញអំពីបញ្ហាប្រឈមទាំងឡាយចំពោះបុគ្គលិកអប់រំ និងសិស្សានុសិស្ស។ ប្រសិនបើប្រព័ន្ធអប់រំអាចដោះស្រាយបញ្ហាគុណភាព និងការចូលរៀន នោះកុមារដែលកំពុងនៅក្នុងសាលារៀននឹងអាចបន្តការសិក្សារបស់គេតទៅទៀត រហូតដល់ចប់ភូមិសិក្សាពេញលេញ ព្រមទាំងអាចទទួលបានលទ្ធផលសិក្សាល្អ ដូចការរំពឹងទុកទៀតផង។ គោលបំណងរបស់កម្មវិធីកុមារមេត្រីគឺជំរុញសាលារៀន និងប្រព័ន្ធអប់រំឱ្យមានការរីកចម្រើនឈានឆ្ពោះទៅរកស្តង់ដាគុណភាព បង្ហាញអំពីកត្តាទាំងឡាយ ដែលជះឥទ្ធិពលលើការកែលម្អសុខុមាលភាព និងសិទ្ធិរបស់កុមារដែលជាអ្នកសិក្សា និងជាអ្នកទទួលផលជាចម្បងពីការបង្រៀន។ ស្តង់ដាគុណភាព គឺត្រូវបង្កលក្ខណៈដល់កុមារទាំងអស់អាចចូលរៀនបន្តការសិក្សាពីកម្រិតថ្នាក់មួយ ទៅកម្រិតថ្នាក់មួយទៀត និងបញ្ចប់ភូមិសិក្សាតាមកាលកំណត់។ ទន្ទឹមនឹងនោះ គឺផ្តល់បទពិសោធន៍អប់រំល្អៗដល់សិស្សដែលអាចជម្នះ អភិវឌ្ឍ និងសម្រេចទៅតាមសក្តានុពលរបស់ពួកគេ។

ដូចនេះ ជោគជ័យនៃការអនុវត្តគោលនយោបាយសាលាកុមារមេត្រីអាចវាស់វែងបាន តាមរយៈសមត្ថភាពក្នុងការជួយគាំទ្រដល់វត្ថុបំណង និងគោលដៅដែលបានកំណត់។ ដូច្នេះ បញ្ហាសំខាន់បំផុត គឺត្រូវកំណត់ចំណុចដៅជាក់លាក់ និងសូចនាករសម្រាប់វាស់វែងប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងសមធម៌របស់កម្មវិធីសាលាមេត្រី។

## ៧.៥. អធិការកិច្ចផ្ទៃក្រៅ

***អធិការកិច្ចផ្ទៃក្រៅ*** គឺជាការធ្វើអធិការកិច្ចរយៈពេលខ្លីណាមួយ ដោយអ្នកដែលមកពីខាងក្រៅសាលារៀន។ ការធ្វើអធិការកិច្ចនេះ គឺជាការសាកសួរដើម្បីរកឱ្យឃើញនូវផ្នែកទាំងឡាយណា ដែលសាលារៀនបំពេញបានល្អ ឬមិនទាន់បានល្អ រួចរិះរកវិធានការ ឬផ្តល់អនុសាសន៍ ដើម្បីស្វែងរកតម្រូវការនានាសម្រាប់កែលម្អចំណុចមិនទាន់បានល្អទាំងនោះ។ អធិការកិច្ចអប់រំផ្តោតលើការវាយតម្លៃគ្រូបង្រៀន និងការវាយតម្លៃសាលារៀន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ការវាយតម្លៃគ្រូបង្រៀន** គឺសំដៅលើការជួយគ្រូបង្រៀន តាមរយៈការសង្កេតថ្នាក់ និងសម្ភាសន៍ផ្ទាល់ជាមួយគ្រូបង្រៀន ក្នុងគោលបំណងពិនិត្យមើលលើវិធីសាស្ត្របង្រៀន ដែលគ្រូបង្រៀនប្រើ។ ចំណុចដែលត្រូវធ្វើអធិការកិច្ចមានដូចជា ការផ្តោតលើមុខវិជ្ជា មានន័យថាអធិការម្នាក់ពិនិត្យមើលគ្រូបង្រៀនមុខវិជ្ជាគីមីវិទ្យា ហើយអធិការម្នាក់ទៀតពិនិត្យមើលគ្រូបង្រៀនគណិតវិទ្យាជាដើម ការផ្តោតលើឥរិយាបថគ្រូបង្រៀនចំពោះសិស្ស ការផ្តោតលើវិធីសាស្ត្រដែលគ្រូបង្រៀនប្រើដើម្បីបង្ហាញខ្លឹមសារ ការផ្តោតលើវិធីដែលគ្រូបង្រៀនប្រើប្រាស់សៀវភៅសិក្សា និងសម្ភារឧបទេស។ ការផ្តោតលើសមត្ថភាពរបស់គ្រូបង្រៀន ក្នុងការបង្កើតការលើកទឹកចិត្ត គឺជាឧទាហរណ៍នៃសកម្មភាពដែលត្រូវប្រើក្នុងការងារអធិការកិច្ចប្រភេទនេះ។

**ការវាយតម្លៃសាលារៀន** គឺសំដៅលើការការធ្វើអធិការកិច្ចជាប្រព័ន្ធ ពីព្រោះថា អធិការត្រូវពិនិត្យមើលប្រព័ន្ធសាលារៀន ក្នុងទិដ្ឋភាពគ្រប់ជ្រុងជ្រោយតែម្តង។ ភារកិច្ចរបស់អធិការ គឺធ្វើឱ្យប្រាកដថាសាលារៀនមានប្រព័ន្ធរបស់ខ្លួនច្បាស់លាស់ និងសមត្ថភាពធ្វើឱ្យសម្រេចតម្រូវការ ដែលមានចែងក្នុងគោលការណ៍ណែនាំ។ ឧទាហរណ៍អធិការអាចពិនិត្យមើលលើវិធីសាស្ត្រ ដែលនាយកសាលារៀនដឹកនាំ ការងារគរុកោសល្យ ការពិនិត្យតាមដានសាលារៀន និងស្វ័យវាយតម្លៃសកម្មភាពរបស់គ្រូបង្រៀនទាក់ទងនឹងកម្មវិធីសិក្សា និងកម្រិតយល់ដឹងរបស់ពួកគាត់ទាក់ទងនឹងបេសកកម្មជាគ្រូបង្រៀន សម្ភារផ្សេងៗរបស់សាលារៀន និងការប្រើប្រាស់សម្ភារទាំងនោះ ឱ្យសមស្របតាមវិធានគរុកោសល្យ។ ការសម្ភាសជាមួយនាយកសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស និងការធ្វើសង្កេត គឺជាសកម្មភាពចម្បងសម្រាប់អធិការកិច្ចប្រភេទនេះ។

រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានអប់រំ និងអគ្គាធិការដ្ឋានគឺជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យតាមដានអប់រំ។ ក្នុងអគ្គាធិការដ្ឋានមានអង្គភាពពីរ ដែលមានភារកិច្ចត្រួតពិនិត្យគឺអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងនាយកដ្ឋានធានាគុណភាពអប់រំ។

១-នាយកដ្ឋានធានាគុណភាពអប់រំ ជាអ្នកអនុវត្តអធិការកិច្ចតាមប្រធានបទ។

២-អធិការអប់រំខេត្ត-ក្រុង ជាអ្នកទទួលខុសត្រូវលើការពិនិត្យតាមដានជាប្រចាំ និងត្រួតពិនិត្យ ដំណើរការអធិការកិច្ចតាមកាលកំណត់។ នេះមានន័យថា នាយកដ្ឋានធានាគុណភាពអប់រំទទួលខុសត្រូវ លើការពិនិត្យឡើងវិញជាប្រចាំលើដំណើរការ អធិការ-កិច្ច ព្រមទាំងត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តដំណើរការអធិការកិច្ចរបស់អធិការនៅតាមរាជធានីខេត្ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣-នាយកដ្ឋានធានាគុណភាពអប់រំត្រូវធ្វើការវិភាគ និងរៀបចំរបាយការណ៍ប្រចាំឆ្នាំជូនក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើ ៖ ការងារអធិការកិច្ចតាមប្រធានបទដែលបានបញ្ចប់ការងារអធិការកិច្ចតាមកាលកំណត់ដែលបានបញ្ចប់ និងការវិភាគផ្នែកស្ថិតិ។

## ៧.៤.១. អធិការកិច្ចតាមប្រធានបទ

**អធិការកិច្ចតាមប្រធានបទ** គឺជាការពិនិត្យ និងវាយតម្លៃជាលក្ខណៈប្រព័ន្ធលើគុណភាពរបស់កិច្ចការមួយ ក្នុងប្រធានបទមួយដែលបានកំណត់។ ការវាយតម្លៃត្រូវផ្អែកលើការបកស្រាយទៅតាមគោលបំណងថ្នាក់ជាតិ និងគោលការណ៍ណែនាំគាំទ្រដោយលទ្ធផលស្រាវជ្រាវ និងការអនុវត្តល្អបំផុត។ លទ្ធផលដែលបានមកនឹងបង្ហាញអំពីកិច្ចការណាខ្លះ ដែលមានដំណើរការល្អ និងកិច្ចការណាខ្លះទៀតដែលត្រូវការកែលម្អ។

នាយកដ្ឋានធានាគុណភាពអប់រំ ជាអ្នកទទួលខុសត្រូវលើការធ្វើអធិការកិច្ចតាមប្រធានបទនេះ។ ការធ្វើអធិការកិច្ចអាចផ្តោតលើការប្រើប្រាស់កម្មវិធីសិក្សា គោលដៅនិងគោលការណ៍ណែនាំ ព្រមទាំងផ្តោតលើទិដ្ឋភាពផ្សេងៗទៀតនៃគុណភាព។ វត្ថុបំណងនៃការធ្វើអធិការកិច្ច គឺដើម្បីទទួលបាននូវការអនុវត្តកាន់តែប្រសើរឡើងក្នុងសាលារៀនដែលបានពិនិត្យ រួមជាមួយនឹងការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស ហើយប្រមូលចំណេះដឹងល្អៗ ដើម្បីផ្សព្វផ្សាយទៅសាលារៀនដទៃទៀតនៃប្រទេស និងជូនក្រសួងផងដែរ។

ភាពញឹកញាប់ និងខ្លឹមសារនៃការធ្វើអធិការកិច្ចតាមប្រធានបទ គឺអាស្រ័យទៅលើប្រធានបទ និងភាពបន្ទាន់របស់ប្រធានបទដែលត្រូវធ្វើការពិនិត្យនោះ។ នាយកដ្ឋានធានាគុណភាពអប់រំ ត្រូវរៀបចំផែនការធ្វើអធិការកិច្ចតាមប្រធានបទពី២ ទៅ៥ ប្រធានបទក្នុងមួយឆ្នាំ លើសាលារៀនចំនួនពី១៥ ទៅ៤០ សម្រាប់ការចុះធ្វើអធិការកិច្ចម្តងៗ តាមរយៈការជ្រើសរើសដោយចៃដន្យ។ នាយកដ្ឋានធានាគុណភាពអប់រំ ធ្វើការវាយតម្លៃគុណភាពសកម្មភាពមួយ ថាតើសាលារៀនបានគ្រប់គ្រងសកម្មភាពនោះ ឱ្យមានដំណើរការយ៉ាងដូចម្តេច ដើម្បីឈានទៅសម្រេចបានវត្ថុបំណងថ្នាក់ជាតិ។

របាយការណ៍អធិការកិច្ចថ្នាក់ខេត្តមានពីរប្រភេទគឺ ៖ ១-របាយការណ៍សាលារៀន និង ២-របាយការណ៍ថ្នាក់ជាតិ។ សាលារៀនដែលបានធ្វើអធិការកិច្ចរួច នឹងទទួលបានរបាយការណ៍លទ្ធផលមួយច្បាប់ ដែលមានរៀបរាប់អំពីការវាយតម្លៃលើផ្នែក ដែលអធិការកិច្ចបានផ្តោត។ អនុសាសន៍ក្នុងរបាយការណ៍នឹងត្រូវប្រើប្រាស់ជាចំណុចចាប់ផ្តើមសម្រាប់កែលម្អគុណភាពប្រតិបត្តិការ។ ជាការសំខាន់ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដែលគ្រប់គ្រងសាលារៀនទាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នោះក៏ត្រូវទទួលបានរបាយការណ៍សាលារៀនផងដែរ ដើម្បីក្រុមបំប៉នតាមស្រុក(DTMT) អាចប្រើប្រាស់អនុសាសន៍ ដែលបានចុះក្នុងរបាយការណ៍សម្រាប់ជាមូលដ្ឋានណែនាំ។

### ៧.៤.២. អធិការកិច្ចតាមកាលកំណត់

**អធិការកិច្ចតាមកាលកំណត់** គឺជាការពិនិត្យ និងវាយតម្លៃសាលារៀនទាំងអស់ជាប្រព័ន្ធ ដើម្បីធានាថាពួកគេបានគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន។

អធិការកិច្ចតាមកាលកំណត់នឹងត្រូវអនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡា ទាំង ២៥ រាជធានីខេត្ត និងក្រុមអធិការរបស់ពួកគេ។ ឧបករណ៍ទាំងអស់សម្រាប់ការធ្វើអធិការកិច្ចត្រូវផ្អែកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំកម្មវិធីសិក្សាអនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលនយោបាយថ្នាក់ជាតិផ្សេងទៀតនៃវិស័យអប់រំនៅកម្ពុជា។

នាយកដ្ឋានធានាគុណភាពអប់រំ នឹងទទួលខុសត្រូវលើការត្រួតពិនិត្យលើបេសកកម្មអធិការកិច្ចទាំង ២៥ រាជធានីខេត្ត ដោយផ្តល់សៀវភៅណែនាំវាយតម្លៃ ឧបករណ៍សម្រាប់ប្រើប្រាស់ឯកសារសម្រាប់ការរាយការណ៍ និងតម្រូវការវិសាលភាពការងារអធិការកិច្ច។

ក្រុមអធិការនេះមិនមែនជាក្រុមអធិការតាមមុខវិជ្ជាទេ។ ពួកគាត់ត្រូវបានបណ្តុះបណ្តាលដើម្បីពិនិត្យលើគ្រប់ផ្នែកទាំងអស់។ ជាទូទៅ អធិការនៅតាមរាជធានីខេត្តជាអ្នកប្រមូលឯកសារ ពិនិត្យសាលារៀន សង្កេតការបង្រៀន និងធ្វើសម្ភាសន៍ជាមួយបុគ្គលិកសំខាន់ៗ និងសិស្សានុសិស្ស។

អធិការកិច្ចតាមកាលកំណត់អាចអនុវត្តទៅ លើផ្នែកសំខាន់ៗចំនួន៤ ៖ (១) ការដឹកនាំ និងគ្រប់គ្រង (២) ការបង្រៀន និងរៀន (៣) សមិទ្ធផលសិក្សារបស់សិស្ស និង (៤) ការគាំទ្រសាលារៀនដោយសហគមន៍។

អធិការធ្វើការវាយតម្លៃលើផ្នែកដែលបានរៀបរាប់ខាងលើ ចាប់ពីរបៀបគ្រប់គ្រងរបស់សាលារៀន រហូតដល់ការសម្រេចបាននូវគោលបំណងថ្នាក់ជាតិ។

ជាមួយនឹងគំរូនេះ អធិការថ្នាក់រាជធានី ខេត្តទាំងអស់(ប្រហែល ១៣០ នាក់) អាចធ្វើអធិការកិច្ចបានប្រហែល ៩០០ សាលារៀនជារៀងរាល់ឆ្នាំ។ ដូចនេះក្នុងរយៈពេល ៥ ឆ្នាំ សាលារៀន ៥០% (៤ ៩៤២សាលារៀន) នឹងត្រូវបានធ្វើអធិការកិច្ច។ ក្នុងពេលជាមួយគ្នានេះ សាលារៀនទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវអនុវត្តប្រព័ន្ធស្វ័យវាយតម្លៃសាលារៀនរបស់ខ្លួន។

ដើម្បីអាចអនុវត្តអធិការកិច្ចតាមកាលកំណត់បាន ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឧបករណ៍ជាក់លាក់មួយចំនួន ដូចជា ៖

– សៀវភៅណែនាំស្តីពីការវាយតម្លៃសម្រាប់អធិការ
– លិខិតជូនដំណឹង (ពីអធិការទៅសាលារៀននិងក្រុង ស្រុក ខណ្ឌ)
– សៀវភៅណែនាំស្តីពីការអង្កេត
– កម្រងសំណួរសម្រាប់នាយកសាលារៀន គ្រូបង្រៀនសិស្សមាតាបិតា សហគមន៍ និងក្រុង ស្រុក ខណ្ឌ
– សៀវភៅណែនាំស្តីពីការធ្វើសម្ភាសន៍
– ឧបករណ៍សម្រាប់វិភាគការវាយតម្លៃ
– សៀវភៅណែនាំស្តីពីការធ្វើរបាយការណ៍
– គោលការណ៍ណែនាំស្តីពីរបៀបធ្វើអធិការកិច្ច របៀបប្រើឧបករណ៍ថ្មី របៀបធ្វើរបាយការណ៍លទ្ធផល និងរបៀបបកស្រាយទំនាក់ទំនងលទ្ធផល។

# ជំពូកទី ៨
# វង្វាយតម្លៃអប់រំថ្នាក់ជាតិ

## ៨.១. សេចក្តីផ្តើម

វង្វាយតម្លៃ បានដើរតួយ៉ាងសំខាន់ ក្នុងការលើកកម្ពស់គុណភាពអប់រំ។ ដូច្នេះហើយទើបវង្វាយតម្លៃ ត្រូវបានចាត់ទុកជាសសរស្តម្ភមួយនៃកំណែទម្រង់អប់រំនៅកម្ពុជា។ តែទោះជាយ៉ាងនេះក្តី ដើម្បីធានាបាននូវគុណភាពអប់រំ ការពង្រឹងលើសមាសភាគផ្សេងៗទៀតនៃប្រព័ន្ធអប់រំ គឺជាការចាំបាច់។

នៅកម្រិតមីក្រូ ការយកចិត្តទុកដាក់ត្រូវផ្តោតទៅលើការពង្រឹងសមត្ថភាព និងឥរិយាបថរបស់សិស្ស ព្រមទាំងចរិតលក្ខណៈរបស់ឪពុកម្តាយ ឬគ្រួសារ (Coleman et al. 1966) សាលារៀន (Sammons, Hillman និង Mortimore 1995; Creemers 1997) និងគ្រូបង្រៀន (Bennett et. al 1976; Hanushek 1971; Wayne និង Young 2003; Rivkin, Hanushek និង Kain 2005)។

នៅកម្រិតម៉ាក្រូ គុណភាពអប់រំត្រូវបានពង្រឹង តាមរយៈការជំរុញសកម្មភាពគោលនយោបាយជាក់លាក់ កម្មវិធី និងកំណែទម្រង់នានា ក៏ដូចជាសមត្ថភាពរបស់អង្គភាព និងស្ថាប័ននៃប្រព័ន្ធអប់រំ (Bishop 1997; USAID/EQUIP2 2006; Woessmann 2003)។

ជាចុងក្រោយ បរិបទវិស័យសេដ្ឋកិច្ច នយោបាយ និងសង្គមក៏បានដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាពផងដែរ។ ឧទាហរណ៍៖ ការសិក្សាមួយចំនួនបានគូសបញ្ជាក់អំពីទំនាក់ទំនងរវាងលទ្ធផលសិក្សារបស់សិស្ស ជាមួយនឹងកត្តាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Hanushek 1986, 1996; Greenwald, Hedges និង Laine 1996; Levacic និង Vignoles 2002)។ ការសិក្សាផ្សេងទៀតបានពិនិត្យទៅលើបរិបទសង្គមទាក់ទងនឹងគុណភាពអប់រំ (Hallinger និង Murphy 1986; Alexander 2000)។

នៅក្នុងយុទ្ធសាស្ត្រអប់រំរបស់ធនាគារពិភពលោកឆ្នាំ២០២០ (World Bank 2011) ការវិភាគលើគុណភាពអប់រំត្រូវបានផ្លាស់ប្តូរ ពីវិធីសាស្ត្រផ្អែកលើកត្តាមួយៗ ទៅជាវិធីសាស្ត្រជាប្រព័ន្ធ មានដូចជាការកំណត់កត្តាជំរុញគុណភាព និងធាតុផ្សំនៃគុណភាពក្នុងការផ្តល់សេវាកម្មអប់រំ។ ក្នុងក្របខណ្ឌនេះ គុណភាពមិនត្រឹមតែបានចាត់ទុកថាជាគោល-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដៅប៉ុណ្ណោះទេ ប៉ុន្តែវាក៏រំលេចឡើងនូវគោលបំណង វិធានការ និងទិសដៅជាក់លាក់ផង ដែរ។

ម្យ៉ាងវិញទៀត គម្រោង និងកម្មវិធីវិស័យអប់រំអាចត្រូវបានរៀបចំឡើង ស្របទៅតាមកត្តាចំនួន៦ ឬA ចំនួន៦ គឺៈ (១) Assessment (វង្វាយតម្លៃ) (២) Autonomy (ស្វ័យភាព) (៣) Accountability (គណនេយ្យភាព) (៤) Attention to teachers (ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន) (៥) Attention to early childhood Development (ការយកចិត្តទុកដាក់ដល់កុមារតូច) និង (៦) Attention to culture (ការយកចិត្តទុកដាក់ដល់វប្បធម៌)។ កត្តាទាំងនេះតំណាងឱ្យអភិក្រម «ធាតុចូល-ធាតុចេញ-លទ្ធផល» ក្នុងការដោះស្រាយបញ្ហាគុណភាព ៖ ការវាយតម្លៃ ស្វ័យភាព គណនេយ្យភាព ការយកចិត្តទុកដាក់លើគ្រូបង្រៀន ការយកចិត្តទុកដាក់លើការអភិវឌ្ឍកុមារតូច និងការយកចិត្តទុកដាក់លើវប្បធម៌។

## ៨.២. ក្របខណ្ឌទស្សនទាន

វង្វាយតម្លៃ គឺសំដៅដល់ឧបករណ៍ និងនីតិវិធី ដើម្បីផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់សំខាន់ៗដូចជា គ្រូបង្រៀន មន្ត្រីគ្រប់គ្រងអប់រំ អ្នករៀបចំគោលនយោបាយ សិស្ស និងគ្រួសាររបស់ពួកគេ ស្តីពីការសិក្សារបស់សិស្ស[269]។ បំណិនក្នុងការអានរបស់សិស្ស គួរត្រូវបានពិនិត្យតាមដាន ធៀបនឹងស្តង់ដា និងវឌ្ឍនភាព ហើយខ្លឹមសារ និងវិធីសាស្ត្រនៃការបង្រៀន ត្រូវតែកែសម្រួល ឱ្យស្របទៅតាមនោះដែរ[270]។

ប្រព័ន្ធវាយតម្លៃសិស្សនឹងមានសារប្រយោជន៍ លុះត្រាតែព័ត៌មានគ្រប់ជ្រុងជ្រោយប្រកបដោយបច្ចេកទេស ដែលប្រមូលបាន ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងប្រើប្រាស់ដើម្បីធ្វើឱ្យមានការកែលម្អ និងការផ្លាស់ប្តូរ (Abdul-Hamid, Abu-Lebdeh និង Patrinos 2011; Alvarez, Garcia Moreno និង Patrinos 2007; Gertler, Patrinos និង Rubio-Codina 2012)។

វង្វាយតម្លៃអាចត្រូវបានអនុវត្តដើម្បីកំណត់កត្តាផ្សេងៗ ដែលអាចជះឥទ្ធិពលជាអវិជ្ជមានលើលទ្ធផលសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជា ការអភិវឌ្ឍយឺត ម៉ោងបង្រៀនតិច ការអនុវត្តតិចតួច គរុកោសល្យមិនសមស្រប និងឧបសគ្គផ្នែកភាសា (ភាព-ស្មុគស្មាញនៃការប្រកបពាក្យ ការបង្រៀនដោយប្រើប្រាស់ភាសាដែលមិនមែនជាភាសា

[269] Patrinos, H.A., E. Velez and C.Y. Wang. (2013). Framework for the Reform of Education Systems and Planning for Quality. Policy Research Working Paper 6701. WashingtonD.C.: World Bank. p. 7.
[270] Students should read a minimum of one word per second or 60 words per minute on average, so that by the end of the sentence they can remember the content as they read (Abadzi 2006, 2008).


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណើត)។ កត្តាទាំងនេះអាចនឹងបង្កឱ្យបំណិនអំណានមានកម្រិតទាបពីថ្នាក់ទី១ ដល់ថ្នាក់ទី៣។

ម្យ៉ាងទៀត កត្តាទាំងនេះនឹងបង្កជាផលវិបាកក្នុងការដោះស្រាយលំហាត់គណិតវិទ្យាពីថ្នាក់ទី៣ ដល់ថ្នាក់ទី៦។ ដូច្នេះ សម្រាប់រយៈពេលខ្លី កត្តានេះនឹងធ្វើឱ្យលទ្ធផលនៃរង្វាយតម្លៃថ្នាក់ជាតិ និងតំបន់ ឬរង្វាយតម្លៃថ្នាក់អន្តរជាតិ ដូចជាកម្មវិធីរង្វាយតម្លៃសិស្សកម្រិត អន្តរជាតិ(PISA) និងនិន្នាការក្នុងការសិក្សាលើគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ (TIMSS) ជាដើម នឹងទទួលបានពិន្ទុទាប ហើយសម្រាប់រយៈពេលវែង នឹងធ្វើឱ្យជំនាញមូលដ្ឋានរបស់សិស្សមានកម្រិតទាប នៅពេលបញ្ចប់ការសិក្សា ព្រមទាំងចំណូល និងគុណភាពជីវិត មានកម្រិតទាប។ ចំណុចគោល និងរង្វាយតម្លៃផ្អែកលើចំណុចគោល គឺជាចំណុចគន្លឹះនៃការធ្វើផែនការ និងកំណែទម្រង់វិស័យអប់រំ ដើម្បីពង្រឹងគុណភាព។

រង្វាយតម្លៃអប់រំជាទូទៅមានបីប្រភេទគឺ ៖ (i) គ្រូបង្រៀនអនុវត្តការវាយតម្លៃក្នុងថ្នាក់រៀនរបស់ខ្លួន ដើម្បីត្រួតពិនិត្យវឌ្ឍនភាពរបស់សិស្ស (ii) ប្រព័ន្ធអប់រំរៀបចំការប្រឡងសម្រាប់បម្រើការងារជ្រើសរើស ឬការបញ្ជាក់ការសិក្សា ដូចជាការប្រឡងបញ្ចប់កម្រិតមធ្យមសិក្សា ឬបន្តសិក្សានៅថ្នាក់ឧត្តមសិក្សាជាដើម និង (iii) រង្វាយតម្លៃលើគំរូសំណាកកម្រិតធំ ដែលអនុវត្តជាទូទៅលើក្របខណ្ឌសាលារៀនជាគំរូសំណាកមួយ ដោយធ្វើបញ្ហាវិនិច្ឆ័យលើប្រព័ន្ធសម្រាប់បម្រើដល់កិច្ចការស្រាវជ្រាវ និងគោលនយោបាយ។ ពិន្ទុគឺជាចំណុចស្នូលនៃរង្វាយតម្លៃទាំងអស់ ហើយពិន្ទុទាំងនេះគឺជាលទ្ធផលសម្រាប់បម្រើគោលបំណងនៃរង្វាយតម្លៃ។ ប៉ុន្តែ ពេលខ្លះពិន្ទុបានបង្វែរការយកចិត្តទុកដាក់របស់សិស្ស និងសាលារៀន ពីការផ្តោតលើជំនាញនៃផ្នែកសិក្សាសំខាន់ៗ ទៅលើការផ្តោតជាពិសេសលើការទទួលបានលទ្ធផលល្អពីការប្រឡងទៅវិញ។ ដូច្នេះ រង្វាយតម្លៃគប្បីត្រូវបានប្រើប្រាស់ដើម្បីទទួលបានព័ត៌មានស្តីពីសមិទ្ធផលនៃប្រព័ន្ធអប់រំទាំងមូល សម្រាប់ការងារផែនការ និងកំណែទម្រង់ ដោយផ្អែកលើភ័ស្តុតាង (Greaney និង Kellaghan 2008) ហើយប្រព័ន្ធទាំងនេះមិនគួរផ្អែកតែទៅលើរង្វាយតម្លៃតែមួយទម្រង់ ដូចជាការប្រឡងថ្នាក់ជាតិជាដើមនោះទេ។

ការប្រើប្រាស់ដ៏ប្រសើរបំផុតនូវព័ត៌មានរង្វាយតម្លៃ គឺការបំពេញចំណោះដឹងដែលមានស្រាប់ ឬជំរុញការពិភាក្សាថ្មីៗស្តីពីដំណើរការវិស័យអប់រំ។ តែទោះជាយ៉ាងនេះក្តី ក្នុងផ្នែកមួយចំនួន ដូចជាផ្នែកពណ៌នាលើកម្រិតសមិទ្ធផលសិក្សារបស់សិស្ស លទ្ធផលបានផ្តល់ជាភ័ស្តុតាងដ៏ច្បាស់លាស់អំពីអ្វីដែលកំពុងកើតឡើងនៅក្នុងប្រព័ន្ធដូចជា ព័ត៌មាន



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដែលទាក់ទងនឹងថ្នាក់ទី៣ នៅក្នុងប្រទេសកម្ពុជាជាដើម។ ដូច្នេះ យើងក៏ត្រូវពិចារណាលើដំណោះស្រាយផងដែរ ទោះបីជាគោលបំណងសំខាន់នៃការស្រាវជ្រាវរបស់វង្វាយតម្លៃបានផ្តោតលើការកំណត់បញ្ហា ជាជាងដំណោះស្រាយបញ្ហាក៏ដោយ។

ដំណើរការផ្តល់ព័ត៌មានត្រឡប់ទៅសាលារៀន គឺជាវិធីសាស្ត្រសំខាន់ដែលត្រូវតែបន្តប្រើ ដើម្បីឱ្យវង្វាយតម្លៃមានឥទ្ធិពលក្នុងរយៈពេលវែង។ ប្រសិនបើមុខងារផ្នែកវាយតម្លៃបានប្រែក្លាយទៅជាយន្តការ ដើម្បីពង្រឹងគុណភាពសាលារៀនក្នុងមូលដ្ឋាន និងដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមាតាបិតាសិស្ស នោះទម្រង់ផ្សេងៗនៃ «ព័ត៌មានត្រឡប់» គប្បីត្រូវបានសាកល្បង។ វង្វាយតម្លៃថ្នាក់ជាតិ គឺជាយន្តការដ៏ល្អសម្រាប់អនុវត្តការងារនេះ ដោយសារតែការងារនេះត្រូវអនុវត្តជាមួយនឹងសំណាកតិចតួច។ បន្ទាប់មក បទពិសោធទាំងនេះ នឹងអាចយកមកប្រើប្រាស់ ដើម្បីបង្កើតជាវិធីសាស្ត្រដែលកាន់តែប្រសើរឡើងៗ សម្រាប់សហគមន៍ និងសាលារៀន ដើម្បីចូលរួមក្នុងសកម្មភាពទាំងនេះក្នុងពេលអនាគត។

ក្របខណ្ឌគតិយុត្តិក្នុងការអនុវត្តវង្វាយតម្លៃក្នុងប្រទេសកម្ពុជា គឺច្បាប់ស្តីពីការអប់រំ ជាពិសេស មាត្រា ២១ ស្តីពីគុណភាព និងប្រសិទ្ធផលនៃការអប់រំ និងមាត្រា ២២ ស្តីពីយន្តការនៃការធានាគុណភាព។

## ៨.៣. ការវាស់វែងលទ្ធផលសិក្សា

លទ្ធផលសិក្សារបស់សិស្សអាចវាយតម្លៃបាន ដោយប្រើប្រាស់លទ្ធផលនៃការប្រឡងថ្នាក់ជាតិ ដែលមានលក្ខណៈស្តង់ដា ឬការធ្វើតេស្តអន្តរជាតិដែលមានលក្ខណៈស្តង់ដា។ នៅកម្រិតអន្តរជាតិ ដូចជា «និន្នាការក្នុងការសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ (TIMMS)» «វឌ្ឍនភាពក្នុងការសិក្សាអក្ខរកម្មអំណានអន្តរជាតិ(PIRLS)» និង «កម្មវិធីវង្វាយតម្លៃសិស្សកម្រិតអន្តរជាតិ (PISA)» ត្រូវបានប្រើប្រាស់ ដើម្បីវិភាគគុណភាពអប់រំទូទាំងសកលលោក។

PISA អនុញ្ញាតឱ្យប្រទេសដែលចូលរួម រៀនសូត្រអំពីបទពិសោធគោលនយោបាយពីប្រទេសដទៃទៀត ពិសេសពីប្រទេសដែលមានបញ្ហា និងលក្ខខណ្ឌរួម ដោយរៀនសូត្រពីគ្នា និងចែករំលែកគ្នាទៅវិញទៅមកនូវការអនុវត្ត និងចំណេះដឹងល្អៗរបស់ខ្លួន ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស។ PISA ក៏ផ្តោតផងដែរលើការសិក្សារបស់សិស្សសម្រាប់កំណែទម្រង់គោលនយោបាយ ការអភិវឌ្ឍវិជ្ជាជីវៈ និងការបណ្តុះបណ្តាលគ្រូបង្រៀន ការដឹកនាំ និងស្វ័យភាពសាលារៀន ការបញ្ចូលគ្នា និងការកែសម្រួល

ស្តង់ដា សមត្ថភាព និងជំនាញរបស់សិស្សដែលលើសពីខ្លឹមសារកម្មវិធីសិក្សា។ បន្ថែមលើនេះ PISA ក៏បានបង្កើតផងដែរនូវវប្បធម៌មិត្តភាព ការចែករំលែក និងការប្តេជ្ញាចិត្ត។

កម្ពុជាមិនទាន់ចូលរួមក្នុងកម្មវិធីវាយតម្លៃអន្តរជាតិដូចជា កម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ(PISA) ឬនិន្នាការក្នុងការសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ (TIMMS) នៅឡើយទេ។ ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡាបានចូលរួមជាមួយអង្គការ UNICEF និង SEAMEO ដើម្បីគាំទ្រដល់ការចូលរួមក្នុងតេស្តវាយតម្លៃថ្នាក់តំបន់កម្រិតបឋមសិក្សា(SEA-PLM)។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានចូលរួមក្នុងកម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍(PISA for Development, PISA-D) ដែលនឹងត្រូវបានអនុវត្តលើសិស្សអាយុ ១៥ឆ្នាំ ក្នុងឆ្នាំ ២០១៦-២០១៧ ផងដែរ។ វិធីនេះ គឺជាវឌ្ឍនភាពដ៏សមស្រប ដែលបានមកពីតេស្តវាយតម្លៃថ្នាក់ជាតិ ហើយនឹងជំរុញភាពប្រកួតប្រជែងក្នុងតំបន់របស់កម្ពុជា ក្នុងទិដ្ឋភាពសមាហរណកម្មតំបន់ (អាស៊ាន)។ កម្ពុជាបានដាក់ចេញនូវ គោលនយោបាយពង្រឹងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិជាមុនសិន មុននឹងចូលរួមក្នុងការវាយតម្លៃអន្តរជាតិទាំងនេះ។

នៅកម្ពុជា ការប្រៀបធៀបតាមសាលារៀន និងតាមខេត្តដោយប្រើប្រាស់ទិន្នន័យប្រឡង/តេស្តថ្នាក់ជាតិ គឺមានសារប្រយោជន៍ណាស់ក្នុងការកែលម្អគុណភាពអប់រំ។ ម្យ៉ាងវិញទៀត ក្នុងរវាងឆ្នាំ ២០០៥ និងឆ្នាំ២០១០ ក្រោមការសម្របសម្រួលរបស់ធនាគារពិភព-លោក គម្រោងគាំទ្រវិស័យអប់រំកម្ពុជា(CESSP) បានអនុវត្តតេស្តវាយតម្លៃថ្នាក់ជាតិលើថ្នាក់ទី៣, ៦ និង ៩។ ប៉ុន្តែមុខងារស្នូលនៃវាយតម្លៃរបស់គម្រោងគាំទ្រវិស័យអប់រំកម្ពុជា គឺដើម្បីជួយកំណត់បញ្ហា ដែលមានលក្ខណៈជាប្រព័ន្ធ ហើយដែលអាចជួយកែលម្អបានតាមរយៈសកម្មភាពផ្ទាល់របស់នាយកដ្ឋាននានារបស់ក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធផ្សេងទៀត។ ការវាយតម្លៃអំណានកម្រិតដំបូង(EGRA) និងការវាយតម្លៃគណិតវិទ្យាកម្រិតដំបូង(EGMA) ក៏ត្រូវបានអនុវត្តដើម្បីធ្វើជាឧបករណ៍ដ៏សំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាផងដែរ។

### ៨.៣.១. **ការវាយតម្លៃអំណានកម្រិតដំបូង** (EGRA)

កម្ពុជាបានសាកល្បងអនុវត្ត តេស្តវាយតម្លៃអំណានកម្រិតដំបូង ជាផ្នែកមួយនៃវាយតម្លៃថ្នាក់ជាតិ ក្រោមការគាំទ្របច្ចេកទេសពីគម្រោងគាំទ្រវិស័យអប់រំកម្ពុជា(CESSP) ដែលមានដំណើរការពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ ដែលជាផ្នែកមួយក្នុងចំណោមគំនិតផ្តួច-ផ្តើមមួយចំនួន ដើម្បីពង្រឹងគុណភាពអប់រំ។ ការធ្វើតេស្តត្រូវបានអនុវត្តក្នុងឆ្នាំ២០១០ និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្នាំ២០១២ ក្រោមគម្រោង Fast Track Initiative (FTI) ហើយបន្ទាប់មកបានឈានទៅដល់ការអនុម័ត និងអនុវត្ត **អំណានហ្វូនិកថ្មី** ឬវិធីសាស្ត្រ ចែត្រ ឆែម (Chet Chhem)។

ការវាយតម្លៃអំណានកម្រិតដំបូងថ្នាក់ទី១ ៖ ក្នុងផ្នែកមួយនៃការពង្រីកទៅទូទាំងប្រទេស គ្រូបង្រៀនថ្នាក់ទី១ សរុបចំនួន ២៤ ០៤៨ នាក់ និងមន្ត្រីរបស់មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកចំនួន ១ ៧៩០ នាក់ ត្រូវបានបំប៉នទាក់ទងនឹងកម្មវិធីអំណានថ្នាក់ទី ១ ថ្មី។ សៀវភៅសិក្សាគោលភាសាខ្មែរថ្នាក់ទី១ ចំនួន ៥៨២ ៣៣៨ ក្បាល ត្រូវបានចែកចាយនៅតាមសាលារៀននៅទូទាំងប្រទេស ដើម្បីធានាថា សិស្ស និងគ្រូបង្រៀនថ្នាក់ទី១ ទាំងអស់ទទួលបានសៀវភៅនេះគ្រប់ៗគ្នា។ សៀវភៅចំនួន ១០ ០៤០ ក្បាល ត្រូវបានផ្តល់ឱ្យមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក។

គោលបំណងទូទៅនៃការធ្វើតេស្តវង្វាយតម្លៃអំណានកម្រិតដំបូង គឺដើម្បីវាស់វែងជារៀងរាល់ឆ្នាំ លើសមត្ថភាពអំណានរបស់សិស្សកម្រិតបឋមនៅកម្ពុជា។ គោលបំណងជាក់លាក់របស់ការវាយតម្លៃអំណានកម្រិតដំបូងនៅឆ្នាំ២០១២ គឺដើម្បីកំណត់ និងពន្យល់ឱ្យបានល្អបំផុតនូវភាពខុសគ្នាលើលទ្ធផលរវាងទិន្នន័យការសិក្សាគោល ដែលអនុវត្តនៅឆ្នាំ ២០១០ និងការធ្វើតេស្តលើកទី២ ដែលបានអនុវត្តក្នុងឆ្នាំ២០១២ ដើម្បីរកមូលហេតុនៃការផ្លាស់ប្តូរទាំងនេះ និងដើម្បីផ្តល់អនុសាសន៍ដល់អ្នកពាក់ព័ន្ធទាំងអស់។ ការវាយតម្លៃត្រូវអនុវត្តលើសិស្សចំនួន ២ ៤០០នាក់ នៃថ្នាក់ទី១ ដល់ទី៦ ក្នុងសាលារៀនចំនួន៤០ ក្នុងខេត្តចំនួន១៨ ។

**ការវាយតម្លៃអំណានកម្រិតដំបូងថ្នាក់ទី២** ៖ ក្រុមការងារបច្ចេកទេសអំណានកម្រិតដំបូងបានរៀបចំសៀវភៅសិក្សាគោលភាសាខ្មែរថ្នាក់ទី២។ សៀវភៅសិក្សាគោលថ្មីនេះត្រូវបានដាក់ឱ្យសាកល្បងក្នុងដើមឆ្នាំ២០១១-២០១២ នៅសាលារៀនដដែល ដែលបានសាកល្បងកាលពីថ្នាក់ទី១។ គ្រូបង្រៀនចំនួន ៥២៩ នាក់ មន្ត្រីការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្តចំនួន ១ ៣០៧នាក់ ត្រូវបានបណ្តុះបណ្តាលលើការប្រើប្រាស់សៀវភៅសិក្សាគោលថ្នាក់ទី២ ថ្មីនេះ។ សៀវភៅសិក្សាគោលថ្នាក់ទី២ ថ្មីចំនួន ៤៩២ ៥១៩ ក្បាលត្រូវបានបោះពុម្ព និងចែកចាយទៅតាមសាលារៀនទូទាំងប្រទេសសម្រាប់ឆ្នាំសិក្សា ២០១២-២០១៣។ សៀវភៅចំនួន ៩ ៩៧១ ក្បាលបន្ថែមទៀត ត្រូវបានចែកចាយទៅតាមការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត។ ការប្រើប្រាស់សៀវភៅសិក្សាគោលថ្នាក់ទី១ និងទី២ ថ្មី រួមនឹងការកែប្រែវិធីសាស្ត្របង្រៀនអំណាន ត្រូវបានអនុវត្តក្រោមការឧបត្ថម្ភគាំទ្រដោយគម្រោង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្មតិកម្មមូលដ្ឋានដែលត្រូវធ្វើការសិក្សាគឺថា តើការប្រើប្រាស់វិធីសាស្ត្រ ចៃត្រ ឆែម ឬហ្វូនិក ក្នុងការបង្រៀនអំណានភាសាខ្មែរ ច្បាស់ជាធ្វើឱ្យសិស្សកម្ពុជាអាចសិក្សាបានប្រសើរជាងវិធីសាស្ត្រនៃការបង្រៀនមុនគឺ «វិធីសាស្ត្រសរុប (Whole word approach)» ឬយ៉ាងណា។ លក្ខណៈខុសគ្នានោះគឺថា វិធីសាស្ត្រ ចៃត្រ ឆែម ដំបូងសិស្សសិក្សាស្រៈ និងព្យញ្ជនៈ បន្ទាប់មកផ្សំគ្នា ដើម្បីបង្កើតជាសំឡេង និងពាក្យ ហើយជាចុងក្រោយ ផ្សំពាក្យទាំងនោះទៅជាល្បះ។ ផ្ទុយទៅវិញ ការបង្រៀនតាម «វិធីសាស្ត្រសរុប» ពួកគេសិក្សាពាក្យទាំងមូលជាជំហានដំបូង បន្ទាប់មកផ្សំពាក្យទាំងនោះទៅជាល្បះ។

លទ្ធផលបង្ហាញថា ការប្រើប្រាស់វិធីសាស្ត្របង្រៀន ចៃត្រ ឆែម ឬហ្វូនិក បានធ្វើឱ្យមធ្យមភាគពិន្ទុតេស្តសរុបរបស់សិស្សមានការកើនឡើងយ៉ាងល្អប្រសើរ នៅគ្រប់កម្រិតថ្នាក់ទាំងអស់។ អាចមានមូលហេតុ ឬទំនាក់ទំនងមួយចំនួនរវាងវិធីសាស្ត្រ ចៃត្រ ឆែម លើការបង្រៀនអំណាន និងការកើនឡើងលើពិន្ទុតេស្តសរុប ក្នុងរវាងឆ្នាំ២០១០ និងឆ្នាំ២០១២។ ការវិភាគបានបង្ហាញពីការកើនឡើងនូវពិន្ទុតេស្តចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២ គឺជាមធ្យម ពិន្ទុបានកើនឡើង ២៦%។ តែទោះជាយ៉ាងនេះក្តី យើងមិនគួរសន្និដ្ឋានថាកំណើននេះគឺដោយសារតែអន្តរាគមន៍របស់វិធីសាស្ត្រ ចៃត្រ ឆែម តែមួយនោះទេ។ អាចមានកត្តាមួយចំនួនដែលចូលរួមធ្វើឱ្យពិន្ទុតេស្តមានការកើនឡើងក្នុងរយៈពេលកន្លងមកដូចជា ៖ កម្មវិធីអភិវឌ្ឍកម្មវិធីសិក្សា ដែលត្រូវបានអនុវត្តក្នុងអំឡុងពេលដូចគ្នានេះ កម្មវិធីដែលបានអនុវត្តមុនឆ្នាំ២០១០ ប៉ុន្តែទើបនឹងមានសន្ទុះ និងលទ្ធផលក្នុងអំឡុងពេលដែលបានសិក្សាកម្រិតខុសគ្នានៃបញ្ហារបស់សិស្ស រួមមានសិស្សជនជាតិដើមភាគតិច ឬតាមតំបន់ជនបទ-តំបន់ក្រុង គ្រួសារនៅក្នុងសហគមន៍តែមួយ។ ប៉ុន្តែមានសៀវភៅ និងការសន្ទនាខុសៗកម្រិតនៃការបង្រៀនខុសៗគ្នារវាងសាលារៀនក្នុងសហគមន៍តែមួយ ឬរវាងថ្នាក់រៀនក្នុងសាលារៀនតែមួយ។ ដូចនេះ ទោះជាមានកត្តាផ្សេងៗដែលជំរុញឱ្យមានកំណើនលទ្ធផលតេស្តក៏ដោយ ប៉ុន្តែយើងអាចលើកជាសម្មតិកម្មបង្ហាញថា ការបញ្ចូលវិធីសាស្ត្រអំណាន ចៃត្រ ឆែម បានចូលរួមយ៉ាងខ្លាំងធ្វើឱ្យមានការកើនឡើងនេះ។

## ៨.៣.២. ការវាយតម្លៃគណិតវិទ្យាកម្រិតដំបូង (EGMA)

កម្ពុជាបានអនុវត្តការវាយតម្លៃគណិតវិទ្យាកម្រិតដំបូង (EGMA)[271] ក្នុងឆ្នាំ២០១៥ ដែលគាំទ្រដោយភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) ដើម្បីកំណត់គម្លាតក្នុង

[271] GMA were validated in over 14 countries. It was developed by RTI and funded by USAID.

ការសិក្សាគណិតវិទ្យា។ ការវាយតម្លៃការសាកល្បងគោល ត្រូវបានរៀបចំ និងអនុវត្តក្នុងរាជធានី-ខេត្តចំនួន៨ គឺខេត្តបាត់ដំបង កំពង់ចាម ក្រចេះ សៀមរាប ព្រៃវែង ស្ទឹងត្រែង ត្បូងឃ្មុំ និងរាជធានីភ្នំពេញ។ ខេត្ត និងសាលារៀនត្រូវបានជ្រើសរើសស្របទៅតាមទម្រង់ដែលប្រើប្រាស់សម្រាប់ EGRA។ ថ្នាក់រៀនត្រូវបានជ្រើសរើសដោយឥតព្រាងទុកពីសាលារៀននីមួយៗ។ សម្រាប់ថ្នាក់ទី១ ទី២ និងទី៣ កុមារា ៥ នាក់ និង កុមារី ៥ នាក់ត្រូវបានជ្រើសរើសពីថ្នាក់នីមួយៗ។ សម្រាប់ថ្នាក់ទី៦ កុមារា ១០ នាក់ និងកុមារី ១០ នាក់ត្រូវបានជ្រើសរើសពីថ្នាក់ នីមួយៗ។

ការធ្វើតេស្ត ត្រូវបានអនុវត្តដើម្បីកំណត់ការយល់អំពីបញ្ញត្តិ ធៀបនឹងការយល់អំពីទម្រង់។ សំណួរតេស្តសម្រាប់ថ្នាក់ទី១ ទី២ និងទី៣ រួមមានការស្គាល់ចំនួន ការប្រៀបធៀបចំនួន ការបំពេញចំនួន ប្រមាណវិធីបូក ដក និងចំណោទ។ ការធ្វើតេស្តថ្នាក់ទី៦ គឺផ្តោតលើការយល់អំពីបញ្ញត្តិ និងការយល់អំពីទម្រង់ ត្រូវបានអនុវត្តជាលើកដំបូងនៅកម្ពុជា។ ការវាយតម្លៃថ្នាក់ទី៦ ផ្តោតលើការយល់អំពីចំនួន ប្រមាណវិធីមូលដ្ឋាន រង្វាស់រង្វាល់ ចំណោទ ប្រភាគ ចំនួនទសភាគ ភាគរយ ធរណីមាត្រ និងស្ថិតិ។ នៅពេលដែលសិស្សមានការយល់ដឹងរឹងមាំអំពីបញ្ញត្តិនៅកម្រិតដំបូងហើយ ពួកគេនឹងសិក្សាបានកាន់តែប្រសើរនៅថ្នាក់ខ្ពស់។ គួរកត់សម្គាល់ដែរថា លទ្ធផលដែលបានមក មិនមែនមានន័យថាសិស្សមិនចេះធ្វើប្រមាណវិធី គណិតវិទ្យាមូលដ្ឋាននោះទេ។ វាមិនមែនជាលទ្ធផលសិក្សាឡើយ។

លទ្ធផលបង្ហាញថា ភាគច្រើននៃសិស្សថ្នាក់ទី១ ទី២ និងទី៣ ដែលត្រូវបានធ្វើតេស្តអាចអានចំនួនបាន ប៉ុន្តែមិនទាន់យល់អំពីបញ្ញត្តិបានរឹងមាំនៅឡើយ។ សិស្សថ្នាក់ទី៦ មានជំនាញលើទម្រង់បានល្អ ប៉ុន្តែមានកង្វះខាតផ្នែកការយល់អំពីបញ្ញត្តិ។ ដូច្នេះ គប្បីចាត់សកម្មភាពដើម្បីពង្រឹងការយល់ដឹងអំពីចំនួន ប្រភាគ ចំនួនទសភាគ ភាគរយ និងធរណីមាត្រ ព្រមទាំងកែលម្អជំនាញមូលដ្ឋាននៅកម្រិតដំបូង កាត់បន្ថយការសូត្រ/ទន្ទេញ ប៉ុន្តែគប្បីផ្តោតលើបញ្ញត្តិបន្ថែមទៀត។ បញ្ហាប្រឈមនោះគឺ ៖ គ្រូបង្រៀនមិនអនុវត្តតាមកិច្ចតែងការបង្រៀន កុមារមិនមានសម្ភារសិក្សាគ្រប់គ្រាន់ គ្រូបង្រៀនគ្មានសម្ភារបង្រៀនគ្រប់គ្រាន់ ហើយគ្រូបង្រៀនមិនប្រើប្រាស់ល្បែង ឬចម្រៀងសិក្សាផ្សេងៗ។

### ៨.៣.៣. តេស្តវាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ និងទី៩

តេស្តវាយតម្លៃថ្នាក់ជាតិ ត្រូវបានអនុវត្តសម្រាប់ថ្នាក់ទី៣ ទី៦ និងទី៩ លើភាសាខ្មែរ និងគណិតវិទ្យា ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ បានបង្ហាញអំពីលទ្ធផលមានវឌ្ឍន-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពល្អ រវាងឆ្នាំទាំងនោះ។ ការវាយតម្លៃនេះក៏នឹងត្រួតពិនិត្យលើការវាយតម្លៃគណិតវិទ្យាកម្រិតដំបូង ក្រោមគម្រោងភាពជាដៃគូសកលសម្រាប់ការអប់រំ។ កម្ពុជាគ្រោងពង្រីកវង្វាយតម្លៃអំណាន និងគណិតវិទ្យាកម្រិតដំបូងនៅទូទាំងប្រទេស។

### ៨.៣.៣.១ តេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៣ ឆ្នាំ២០០៦

លទ្ធផលនៃតេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ ត្រូវបានបែងចែកជាបីក្រុម ៖ ការសិក្សារបស់សិស្ស បរិយាកាសបង្រៀននិងរៀន និងនិរន្តរភាពរបស់ស្ថាប័ន។

១) **ការសិក្សារបស់សិស្ស** ៖ ចំណេះដឹងរបស់សិស្សផ្តោតលើជំនាញមូលដ្ឋានជារួម ចំណេះដឹងរបស់សិស្សលើកម្មវិធីសិក្សាផ្លូវការថ្នាក់ទី៣ មុខវិជ្ជា កម្រិតពុទ្ធិ និងខ្លឹមសារ។ លទ្ធផលវង្វាយតម្លៃនេះ មិនអាចបកស្រាយដោយសាមញ្ញថាជាពិន្ទុខ្ពស់ និងទាប ជាប់ ឬធ្លាក់បានទេ។

សមាសភាគសង្គមសេដ្ឋកិច្ច មានទំនាក់ទំនងយ៉ាងរឹងមាំទៅនឹងភាពខុសគ្នារវាងសមិទ្ធផលសិក្សារបស់សិស្ស និងសាលារៀន។ ទោះបីជាសិស្សភាគច្រើននៅក្នុងសំណាកគំរូមកពីគ្រួសារក្រីក្រនៃតំបន់ជនបទក៏ដោយ ក៏នៅមានយន្តការដែលផ្តោតលើភាពក្រីក្រមួយចំនួន អាចពន្យល់បានអំពីលទ្ធផលខុសគ្នានោះ ដូចជា មូលធនវប្បធម៌របស់គ្រួសារ (ដូចជា តើកុមារដឹងអំពីថ្ងៃកំណើត និងសៀវភៅក្នុងផ្ទះរបស់ខ្លួនឬទេ) របស់របរដែលមានក្នុងគ្រួសារ ពលកម្មកុមារ និងចំនួនបងប្អូនបង្កើត។ បន្ថែមពីលើនេះ ភាពខុសគ្នាលើស្ថានភាពសង្គមសេដ្ឋកិច្ចនៅតាមសាលារៀន បានពន្យល់អំពីលទ្ធភាពដែលអាចធ្វើបានរបស់សាលារៀនមួយចំនួន ដូចជាការសិក្សាក្រៅម៉ោងជាដើម។

២) **បរិយាកាសបង្រៀន និងរៀន** ៖ បញ្ហាទាក់ទងនឹងសាលារៀន និងគ្រូបង្រៀន

គោលបំណងមួយនៃការប្រមូលទិន្នន័យរបស់គម្រោងគាំទ្រវិស័យអប់រំកម្ពុជា គឺដើម្បីវាស់វែងកម្រិតដែលសាលារៀន គ្រូបង្រៀន និងថ្នាក់រៀន កំណត់សមិទ្ធផលសិក្សាប្រចាំឆ្នាំនៅតាមសាលាបឋមសិក្សានៅកម្ពុជា។ ភស្តុតាងបានសម្តែងជាសេចក្តីសន្និដ្ឋានថា ភាពខុសគ្នាលើសមិទ្ធផលសិក្សា គឺមិនមែនយោងតែទៅលើកត្តាសង្គមសេដ្ឋកិច្ចប៉ុណ្ណោះទេ ព្រោះកត្តានេះវាហួសពីកម្រិតនៃការគ្រប់គ្រងរបស់ភាគីពាក់ព័ន្ធក្នុងវិស័យអប់រំ។ សាលារៀន និងគ្រូបង្រៀនអាចធ្វើឱ្យមានការប្រែប្រួលបាន។ លើសពីនេះទៀត កត្តាសំខាន់ៗទាំងនេះពិតជាតំណាងឱ្យមធ្យោបាយគោលនយោបាយដែលរងឥទ្ធិពលពីសកម្មភាពរបស់រដ្ឋាភិបាល យ៉ាងហោចណាស់ក៏ក្នុងកម្រិតណាមួយដែរ។ លទ្ធផលដែលគួរឱ្យកត់សម្គាល់ដទៃទៀតមានដូចជា ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ក) ចំណេះដឹងផ្នែកគរុកោសល្យរបស់គ្រូបង្រៀន គឺជាកត្តាកំណត់ដ៏សំខាន់ចំពោះចំណេះដឹងផ្នែកគណិតវិទ្យារបស់សិស្ស។* គ្រូបង្រៀនដែលមានតែចំណេះដឹងផ្នែកគណិតវិទ្យាតែមួយមុខ គឺមិនទាន់គ្រប់គ្រាន់ទេ គាត់ត្រូវតែយល់ដឹងពីវិធីសាស្រ្តគរុកោសល្យដែលធ្វើឱ្យពួកគាត់អាចធ្វើការពន្យល់ប្រកបដោយប្រសិទ្ធភាព។ ការសិក្សាបានចូលរួមដល់ការអភិវឌ្ឍផ្នែកនេះ ដោយបង្កើតជាទំនាក់ទំនងដ៏សំខាន់រវាងចំណេះដឹងជ្រៅជ្រះលើគណិតវិទ្យារបស់គ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ ចំពោះទស្សនៈគោលនយោបាយ ទំនាក់ទំនងនេះមានសារៈសំខាន់ណាស់ ព្រោះវាកំណត់វិធីបណ្ដុះបណ្ដាលដ៏មានសក្ដានុពលក្នុងការពង្រឹងសមត្ថភាពគ្រូបង្រៀន ដែលធ្វើឱ្យពួកគាត់អាចបង្រៀនសមស្របទៅនឹងជីវភាពខុសៗគ្នារបស់សិស្ស។

*ខ) ជាទូទៅ សមិទ្ធផលសិក្សារបស់សិស្សមានកម្រិតខ្ពស់ ចំពោះថ្នាក់រៀនដែលសិស្សបានលើកឡើងថា មានការចូលរួមពីសិស្សគ្រប់ៗគ្នា និងមានឱកាសឡើងក្ដារខៀនញឹកញាប់។* លទ្ធផលនេះបានលើកពីសារៈសំខាន់នៃសកម្មភាពបង្រៀនជាក់លាក់ក្នុងថ្នាក់រៀន ហើយក៏បានលើកឡើងថា យុទ្ធសាស្រ្តបង្រៀនដែលសង្កត់ធ្ងន់លើការចូលរួម បានផ្ដល់ប្រសិទ្ធភាពខ្ពស់។

*គ) សមិទ្ធផលសិក្សារបស់សិស្សមានកម្រិតខ្ពស់ ប្រសិនបើគ្រូបង្រៀនមកពីសហគមន៍ ឬក្រុងជាមួយសាលារៀន។* គ្រូបង្រៀនទាំងនេះប្រហែលជាត្រូវបានការគាំទ្រពីគ្រួសារ ហើយអាចមានទំនោរតិចតួចក្នុងការធ្វើកិច្ចការបន្ថែមក្រៅពីបង្រៀន។

### *៨.៣.៣.២ តេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ ឆ្នាំ២០០៩*

លទ្ធផលដែលនឹងបង្ហាញនៅពេលនេះ គឺសមិទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ និងបរិយាកាសសិក្សា ដែលបានពីការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិលើកទី៤ អនុវត្តដោយក្រុមវាយតម្លៃរបស់ក្រសួងអប់រំ យុវជន និងកីឡា (សូមមើល CESSP, 2006, 2007)។ លទ្ធផលសង្ខេបទទួលបានពីការវាយតម្លៃថ្នាក់ទី៣ បានគាំទ្រការរកឃើញសំខាន់ៗប្រាំបីចំណុច៖

សមិទ្ធផលសិក្សារបស់សិស្សថ្នាក់ទីបី មានការរីកចម្រើនគួរឱ្យកត់សម្គាល់ បើប្រៀបធៀបនឹងការអនុវត្តដំបូងនៅឆ្នាំ២០០៦ ធៀបនឹងការវាយតម្លៃលើកចុងក្រោយដែលបានអនុវត្តក្នុងឆ្នាំ២០០៩។ ចម្លើយរបស់សិស្សលើសំណួរតេស្តដូចគ្នា(ហៅថាសំណួរតេស្តភ្ជាប់ ឬរួម) បង្ហាញពីការកើនឡើងក្នុងឆ្នាំ២០០៩ ដូចនេះ យើងអាចសន្និដ្ឋានបានថា សមិទ្ធផលសិក្សារួមលើភាសាខ្មែរ និងគណិតវិទ្យាបានកើនឡើងក្នុងរយៈពេលខ្លីប៉ុណ្ណោះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទោះបីជាមានការកើនឡើងនូវសមិទ្ធផលសិក្សាថ្នាក់ទី៣ រវាងឆ្នាំ២០០៦ ដល់ឆ្នាំ ២០០៩ ក្ដី ប៉ុន្តែនៅមានកិច្ចការផ្សេងទៀតដើម្បីធានាថា សិស្សទាំងអស់ទទួលបានការសិក្សាគ្រប់គ្រាន់នៅក្នុងកម្រិតនេះ។ បច្ចុប្បន្ន សិស្សថ្នាក់ទី៣ ជាទូទៅ ទទួលបានលទ្ធ-ផលប្រសើរជាងមុន ប៉ុន្តែសិស្សមួយចំនួននៅតែមានបញ្ហានៅឡើយ បើធៀបនឹងខ្លឹមសារនៃកម្មវិធីសិក្សាថ្នាក់ទី៣ ពិសេសលើមុខវិជ្ជាគណិតវិទ្យា និងផ្នែកសំណេរនៃភាសាខ្មែរ។

ចំណុចដែលគួរលើកមកពន្យល់ទាក់ទងនឹងសិស្សថ្នាក់ទី៣ មួយចំនួនដែលកំពុងបន្តជួបការលំបាកធៀបនឹងខ្លឹមសារកម្មវិធីសិក្សាថ្នាក់ទី៣ នោះគឺ បំណិនអំណានមូលដ្ឋានរបស់សិស្សមានកម្រិតទាប។ គ្រូបង្រៀនថ្នាក់ទី៣ បានខិតខំកំណត់សិស្សណាដែលអានយឺត ហើយបានផ្ដល់ជំនួយបន្ថែមដល់ពួកគេ។ ទោះបីជាយ៉ាងនេះក្ដី សមិទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ អាចស្ថិតក្នុងកម្រិតខ្ពស់ទៅបាន លុះត្រាតែបំណិនអំណានមូលដ្ឋានត្រូវបានផ្ដល់តាំងពីនៅកម្រិតថ្នាក់ដំបូងៗ។ នេះគូសបញ្ជាក់ពីសារៈសំខាន់នៃការផ្ដល់បំណិនមូលដ្ឋានដល់សិស្សនៅថ្នាក់ទី១ និងទី២ និងការបង្កើនការចូលរៀននៅកម្រិតមត្តេយ្យសិក្សា។ ការកែលម្អជាប្រព័ន្ធបែបនេះ នឹងអាចមានឥទ្ធិពលច្រើនទៅលើសមិទ្ធ-ផលសិក្សារបស់សិស្សថ្នាក់ទី៣ ជាងការបំប៉ន និងការគាំទ្រជាក់លាក់ដល់គ្រូបង្រៀន និងសិស្សថ្នាក់ទី៣។

ភ័ស្តុតាងបានបង្ហាញថា អត្រានៃការរីកចម្រើនចន្លោះឆ្នាំ២០០៦ និង២០០៩ បានកើនឡើងខ្ពស់នៅតាមសាលារៀនក្នុងតំបន់ទីប្រជុំជន។ នេះមានន័យថា គម្លាតនៃការសិក្សារវាងតំបន់ជនបទ និងទីប្រជុំជនកំពុងតែកើនឡើង។

ទោះបីជាមានការជះឥទ្ធិពលខ្លាំងពីស្ថានភាពគ្រួសារក៏ដោយ ការរកឃើញដ៏សំខាន់មួយពីការសិក្សានេះគឺស៊ីគ្នាទៅនឹងការសិក្សាលើកមុនរបស់ក្រសួងអប់រំ យុវជន និងកីឡាដែរ ៖ អញ្ញត្រដែលទាក់ទងនឹងគ្រូបង្រៀន សាលារៀន និងថ្នាក់រៀនគឺជាបញ្ហាសំខាន់។ តាមទស្សនៈគោលនយោបាយ គេមិនអាចបំប៉ោងលទ្ធផលនេះបានទេ ៖ អ្នកធ្វើគោលនយោបាយ អាចធ្វើឱ្យលទ្ធផលទាំងនេះប្រែប្រួលបាន។ តើកត្តាណាមួយដែលមានសារៈសំខាន់ជាងគេ សម្រាប់ពន្យល់អំពីសមិទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣? កត្តាដែលលេចធ្លោជាងគេមានដូចជា ៖

- សិស្សដែលគ្រូបង្រៀនបានហៅជាញឹកញាប់ក្នុងថ្នាក់រៀនដើម្បីឱ្យចូលរួម ហើយមិនចាំបាច់តែជាសិស្សពូកែនោះទេ(ឥទ្ធិពលវិជ្ជមាន)
- សិស្សដែលត្រូវបានផ្ដល់ឱកាសជាញឹកញាប់ឱ្យឡើងក្ដារខៀន ដើម្បីបង្ហាញកិច្ចការរបស់ខ្លួន(ឥទ្ធិពលវិជ្ជមាន)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- គ្រូបង្រៀនប្រើសិស្សកែកិច្ចការគ្នាទៅវិញទៅមកជាញឹកញាប់(ឥទ្ធិពលវិជ្ជមាន)
- សិស្សរាយការណ៍ជាញឹកញាប់អំពីការវាយតប់គ្នាទៅវិញទៅមក នៅក្នុងសាលារៀន(ឥទ្ធិពលអវិជ្ជមាន)
- ចំនួនសិស្សច្រើននៅក្នុងថ្នាក់រៀន(ឥទ្ធិពលអវិជ្ជមាន)

### *៨.៣.៣.៣ តេស្តវាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៦ ឆ្នាំ២០០៧*

លទ្ធផល និងសេចក្តីសន្និដ្ឋាននៃការវាយតម្លៃបានផ្តោតទៅលើទាំងលទ្ធផលជាក់-លាក់ និងទូទៅ។

សមិទ្ធផលសិក្សារួមនៃអំណានភាសាខ្មែរថ្នាក់ទី៦ មានលក្ខណៈខ្ពស់យ៉ាងខ្លាំងបើប្រៀបធៀបជាមួយលទ្ធផលតេស្តអំណានថ្នាក់ទី៣ កាលពីឆ្នាំ២០០៦។ សិស្សជាមធ្យមអាចឆ្លើយសំណួរអំណានភាសាខ្មែរបានត្រឹមត្រូវប្រហែល ៦៥% ដែលបង្ហាញថា ពួកគេជាទូទៅមានសមត្ថភាពមូលដ្ឋានទាក់ទងនឹងការយល់ ការតែងប្រយោគ និងសញ្ញាវណ្ណយុត្តិ។

លទ្ធផលសិក្សាលើបំណិនផ្សេងទៀតនៃភាសាខ្មែរ និងគណិតវិទ្យាបង្ហាញថា នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។ ពិន្ទុទាបទៅលើសកម្មភាពសំណេរ(ទម្រង់បើក) បង្ហាញយ៉ាងច្បាស់ថា សិស្សត្រូវបានតម្រូវឱ្យសរសេរតិចតួចបំផុតនៅក្នុងកិច្ចការប្រចាំថ្ងៃរបស់ពួកគេ។

ស្ថានភាពគ្រួសារ បន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់កម្រិតសមិទ្ធផលសិក្សារបស់សិស្ស។ ទោះបីជាក្រុមសិស្សថ្នាក់ទី៦ ត្រូវបានជ្រើសរើសក៏ដោយ ផលប៉ះពាល់ពីភាពក្រីក្រចំពោះសមិទ្ធផលសិក្សាគឺពិតជាកើតមាន។ ភ័ស្តុតាងមួយនៃបញ្ហានេះគឺភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៃសមិទ្ធផលសិក្សារវាងសហគមន៍ ជាពិសេសនៅតាមតំបន់ជនបទ និងទីប្រជុំជន។ បញ្ហាជះឥទ្ធិពលចំពោះបុគ្គលរួមមាន ៖

- *អាយុសិស្ស* ៖ សិស្សមានអាយុច្រើនដែលរៀនត្រួតថ្នាក់ និងចុះឈ្មោះចូលរៀនយឺតទទួលបានលទ្ធផលសិក្សាទាប។ ដូចនេះ គប្បីពង្រឹងបន្ថែមលើការអភិវឌ្ឍបំណិនដំបូង និងពិនិត្យកម្រិតការត្រួតថ្នាក់ដើម្បីជាមធ្យោបាយកែលម្អការសិក្សា។
- *អវត្តមាន* ៖ មិនមានអ្វីភ្ញាក់ផ្អើលឡើយ នៅពេលដែលសិស្សអវត្តមានច្រើនដង ពួកគេទទួលបានលទ្ធផលសិក្សាទាប។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- *ពលកម្មកុមារ* ៖ សិស្សដែលបានបង្ហាញថា ពួកគេខកខានមិនបានទៅសាលារៀន ដោយ សារជាប់រវល់ធ្វើការ ពិន្ទុតេស្តរបស់ពួកគេទាបយ៉ាងខ្លាំង។

- *ស្ថានភាពសេដ្ឋកិច្ច-សង្គមគ្រួសារ និងសៀវភៅនៅផ្ទះ* ៖ លទ្ធផលសម្រាប់ការសិក្សានេះ គឺស្របជាមួយនឹងការសិក្សាដទៃទៀត ហើយរកឃើញថា ប្រសិនបើធនធានតាមគ្រួសារខ្ពស់ ការព្យាករណ៍លើសមិទ្ធផលសិក្សាក៏ឃើញថាមានកម្រិតខ្ពស់ដែរ។

ក្រៅពីស្ថានភាពសង្គមដែលជះឥទ្ធិពលយ៉ាងខ្លាំង ដល់សមិទ្ធផលសិក្សារបស់សិស្ស គ្រូបង្រៀនក៏អាចធ្វើឱ្យសមិទ្ធផលសិក្សានៃសិស្សរបស់គាត់មានការប្រែប្រួលដែរ។ តាមទស្សនៈគោលនយោបាយនេះ គឺជាលទ្ធផលដ៏សំខាន់បំផុត ដែលបានមកពីការសិក្សារបស់យើង ហើយត្រូវនឹងចំណុចដែលមិនអាចបំផ្លើសបាន ៖ អ្នកកសាងគោលនយោបាយ អាចធ្វើឱ្យមានការប្រែប្រួលនៅក្នុងដំណើរការទាំងនេះ។ លទ្ធផលដែលបានរកឃើញមួយចំនួនរួមមាន ៖

- *សមិទ្ធផលសិក្សាមានកម្រិតខ្ពស់ ចំពោះថ្នាក់រៀនដែលគ្រូបង្រៀនជាស្ត្រី ហើយរស់នៅក្នុងសហគមន៍ដែលពួកគាត់ធ្វើការ* ៖ លទ្ធផលនេះរំលឹកយើងថា ស្ត្រីគឺជាប្រភពប្រកបដោយសក្តានុពលសម្រាប់ការអប់រំនៅកម្ពុជា។

- *ពេលវេលាបង្រៀនកាន់តែច្រើន សមិទ្ធផលសិក្សាកាន់តែខ្ពស់* ៖ នៅពេលគ្រូបង្រៀនរាយការណ៍ថា ពួកគាត់បានចំណាយពេលកាន់តែច្រើននៅក្នុងថ្នាក់រៀន សមិទ្ធផលសិក្សារបស់សិស្សកាន់តែខ្ពស់។ នេះមិនមែនជាលទ្ធផលដែលគួរឱ្យភ្ញាក់ផ្អើលនោះទេ ប៉ុន្តែយើងត្រូវពង្រឹងលើសារៈសំខាន់នៃការរៀបចំកាលវិភាគរបស់គ្រូបង្រៀន ដោយផ្តោតជាពិសេសលើសមាសធាតុសំខាន់ៗនៃការបង្រៀន។

- *ចំណេះដឹងផ្នែកគណិតវិទ្យារបស់គ្រូបង្រៀនជាបញ្ហាសំខាន់* ៖ សហសម្ពន្ធវិជ្ជមានរវាងគ្រូបង្រៀន និងពិន្ទុគណិតវិទ្យារបស់សិស្ស គឺជាការដាស់តឿនពីសារៈសំខាន់នៃខ្លឹមសារចំណេះដឹងដែលប្រើប្រាស់ក្នុងពេលបណ្តុះបណ្តាលគ្រូបង្រៀន។ ដើម្បីឱ្យមានប្រសិទ្ធភាពនៅក្នុងថ្នាក់រៀន គ្រូបង្រៀនត្រូវមានជំនាញជាមួយខ្លឹមសារដែលពួកគេទទួលខុសត្រូវ។

- *ការចូលរួម និងការដោះស្រាយបញ្ហារបស់សិស្ស នាំឱ្យមានសមិទ្ធផលសិក្សាខ្ពស់* ៖ គ្រូបង្រៀនដែលបានហៅសិស្សឡើងសរសេរលើក្តារខៀន និងដោះស្រាយលំហាត់នៅក្នុងថ្នាក់ជាញឹកញាប់ សមិទ្ធផលសិក្សានៃសិស្សរបស់ពួកគាត់ ក៏មានប្រសិទ្ធភាពខ្ពស់ជាងគេដែរ។ នេះគឺជាលទ្ធផលដ៏ច្បាស់លាស់ដែលបង្ហាញថា វិធីសាស្ត្របង្រៀន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កាន់តែរស់រវើក ជាពិសេសការផ្ដល់ឧទាហរណ៍អនុវត្តច្រើន និងការបង្កឱកាសឱ្យសិស្សទាំងអស់ចូលរួម ធ្វើឱ្យលទ្ធផលនៃការបង្រៀន មានប្រសិទ្ធភាពខ្ពស់បំផុត។

- *ឥរិយាបថរបស់គ្រូបង្រៀនក៏ជាបញ្ហាសំខាន់ដែរ ៖* គ្រូបង្រៀនដ៏មានប្រសិទ្ធភាពបំផុតនៃសាលារៀនក្នុងគំរូសំណាក គឺជាគ្រូបង្រៀនដែលជឿជាក់ថាគ្មានសិស្សណាម្នាក់មិនត្រូវបានទទួលការយកចិត្តទុកដាក់នោះឡើយ ហើយពួកគាត់តែងតែគិតថាការងាររបស់ពួកគាត់ នៅតែត្រូវការពង្រឹងបន្ថែម។ កត្តាឥរិយាបថទាំងនេះ មានភាពលំបាកក្នុងការបកប្រែទៅក្នុងគោលនយោបាយ ប៉ុន្តែកត្តាទាំងនេះបានរំលឹកយើងថា គ្រូបង្រៀនដែលទទួលបានការលើកទឹកចិត្ត អាចធ្វើឱ្យមានការប្រែប្រួល។

ការវាយតប់គ្នារបស់សិស្ស គឺជាកត្តាព្យាករណ៍មួយលើសមិទ្ធផលសិក្សាទាប។ ទោះបីជានេះមិនមែនជាកត្តាព្យាករណ៍ដ៏រឹងមាំលើសមិទ្ធផលសិក្សារបស់សិស្ស សម្រាប់ការសិក្សានេះក៏ដោយ ក៏វាបានគូសបញ្ជាក់អំពីការព្រួយបារម្ភពាក់ព័ន្ធនឹងបរិយាកាសនៅក្នុងសាលារៀននៅកម្ពុជាផងដែរ។

មានភ័ស្តុតាងតិចតួចបំផុតដែលបង្ហាញថា ចំណាយក្រៅផ្លូវការរបស់សិស្សទៅលើគ្រូបង្រៀន ធ្វើឱ្យលទ្ធផលសិក្សាមានភាពល្អប្រសើរឡើង ហើយភ័ស្តុតាងខ្លះទៀតបានបញ្ជាក់ថា វាអាចមានផលប៉ះពាល់អវិជ្ជមានជារួមទៅវិញ។ នេះគឺជាបញ្ហាចម្រូងចម្រាសមួយ ដែលមិនអាចបញ្ជាក់បានជាមួយនឹងទិន្នន័យក្នុងការសិក្សានេះបានទេ។ ការបង្រៀនមិនត្រូវបានអនុវត្តទៅលើសិស្សឱ្យបានដូចៗគ្នាទេ ហើយបញ្ហានេះ ហាក់មានទំនោរទៅរកការពង្រឹងវិសមភាពដែលមានស្រាប់។ បញ្ហានេះ ក៏នឹងនាំឱ្យសមិទ្ធផលសិក្សាកាន់តែថយចុះថែមទៀត ប្រសិនបើកុមារក្រីក្រមិនត្រូវបានចូលរៀនបន្ថែម ដោយសារតែពួកគេមិនមានលទ្ធភាពក្នុងការបង់ថ្លៃ។

### *៨.៣.៣.៤ តេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៩ ឆ្នាំ២០០៨*

លទ្ធផលនៃការសិក្សាសិស្សថ្នាក់ទី៩ និងបរិយាកាសសិក្សា គឺបានមកពីការធ្វើតេស្ត វង្វាយតម្លៃថ្នាក់ជាតិលើកទីបី ដែលរៀបចំដោយក្រុមវាយតម្លៃក្រសួងអប់រំ យុវជន និងកីឡា (មើល CESSP, ឆ្នាំ២០០៦ ,២០០៧)។ សេចក្ដីសន្និដ្ឋានជារួមសម្រាប់ថ្នាក់ទី៩ គឺមានភាពស្រដៀងគ្នាទៅនឹងអ្វី ដែលត្រូវបានបង្ហាញពីតេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ ក្នុងឆ្នាំ២០០៧ (CESSP, ២០០៧)។ លទ្ធផលសំខាន់ៗត្រូវបានសង្ខេបដូចខាងក្រោម ៖

ជាទូទៅ សិស្សថ្នាក់ទី៩ មានសមត្ថភាពក្នុងការអានភាសាខ្មែរ ដែលជាការកែលម្អដ៏គួរឱ្យចាប់អារម្មណ៍មួយ បើប្រៀបធៀបជាមួយនឹងលទ្ធផលតេស្តវាយតម្លៃថ្នាក់ជាតិលើការអានថ្នាក់ទី៣ ក្នុងឆ្នាំ២០០៦។ សិស្សជាមធ្យមអាចឆ្លើយសំណួរអំណានបានត្រឹមត្រូវ ៦៥% ដែលបង្ហាញថាពួកគេមានមូលដ្ឋានគ្រឹះនៃអំណានទាក់ទងនឹងការយល់ និងវេយ្យាករណ៍។

សមិទ្ធផលសិក្សាលើបំណិនផ្សេងទៀត ដូចជាការសរសេរភាសាខ្មែរ និងគណិត-វិទ្យាបានបង្ហាញថា នៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីកែលម្អគុណភាព និងការសិក្សារបស់សិស្ស។ ពិន្ទុទាបលើសំណួរតេស្តសំណេរទម្រង់បើក បានបង្ហាញយ៉ាងច្បាស់ថា សិស្សសរសេរបានតិចតួចនៅក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ ដើម្បីកែលម្អលទ្ធផលនេះ តម្រូវឱ្យមានធាតុចូលផ្សេងៗគ្នាពីនាយកដ្ឋាននានារបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាការប្រើប្រាស់ឱ្យបានកាន់តែលម្អិតថែមទៀត នូវទិន្នន័យវាយតម្លៃថ្នាក់ទី៩ ដើម្បីធ្វើបញ្ហាវិនិច្ឆ័យរកកំហុសរបស់សិស្ស និងភ្ជាប់ការណែនាំទាំងនេះសម្រាប់គ្រូបង្រៀន។

ស្ថានភាពគ្រួសារបន្តដើរតួនាទីសំខាន់ក្នុងការកំណត់សមិទ្ធផលសិក្សារបស់សិស្ស។ ទោះបីជាក្រុមសិស្សថ្នាក់ទី៩ ត្រូវបានជ្រើសរើសក៏ដោយ ផលប៉ះពាល់ពីភាពក្រីក្រចំពោះសមិទ្ធផលសិក្សាគឺពិតជាកើតមាន។ អញ្ញត្តិមួយចំនួនដូចជាសៀវភៅនៅផ្ទះ ស្ថានភាពសង្គម-សេដ្ឋកិច្ច និងអាយុរបស់សិស្សជាដើម ជួយពន្យល់ពីភាពខុសគ្នានៃលទ្ធផលសិក្សារវាងសិស្ស។ សិស្សដែលមកពីគ្រួសារដែលមានទ្រព្យធនច្រើនអាចទទួលបានការសិក្សាល្អជាង ដោយសារមានពេលវេលាសិក្សាច្រើនជាង និងមានប្រាក់សម្រាប់ការរៀនបន្ថែមជាមួយគ្រូបង្រៀន។

ទោះបីជាមានការជះឥទ្ធិពលយ៉ាងខ្លាំងពីស្ថានភាពគ្រួសារក៏ដោយ ក៏លទ្ធផលមានលក្ខណៈដូចគ្នាទៅនឹងការវាយតម្លៃការសិក្សាកាលពីលើកមុនរបស់ក្រសួងអប់រំ យុវជន និងកីឡាផងដែរ ទាក់ទងនឹងលទ្ធផលដ៏សំខាន់មួយ ៖ អញ្ញត្តិទាក់ទងនឹងគ្រូបង្រៀន សាលារៀន និងថ្នាក់រៀនក៏ជាបញ្ហាសំខាន់ផងដែរ។ តាមទស្សនៈគោល-នយោបាយ នេះជាលទ្ធផលដ៏សំខាន់បំផុតដែលបានមកពីការសិក្សារបស់យើង និងជាចំណុចដែលមិនអាចបំប៉ោងបានឡើយ ៖ អ្នកបង្កើតគោលនយោបាយអាចធ្វើឱ្យលទ្ធផលមានការប្រែប្រួលបាន។ ឧទាហរណ៍ពីរត្រូវបានលើកឡើង ៖ ទីមួយ សមិទ្ធផលសិក្សារបស់សិស្សមានលក្ខណៈទាបយ៉ាងខ្លាំងចំពោះសាលារៀនដែលសិស្សបានរាយការណ៍

មកថាមានការវាយតប់គ្នាជាញឹកញាប់។ ទីពីរ សមិទ្ធផលសិក្សារបស់សិស្សមានលក្ខណៈល្អប្រសើរនៅក្នុងថ្នាក់រៀនដែលគ្រូបង្រៀនបានហៅសិស្សឡើងលើក្តារខៀនញឹកញាប់ ជាពិសេសចំពោះមុខវិជ្ជាគណិតវិទ្យា។

## ៨.៣.៤. សេចក្តីសន្និដ្ឋាន

នៅឆ្នាំ២០១១ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតការិយាល័យវាយតម្លៃថ្នាក់ជាតិ(NAO) នៅក្នុងនាយកដ្ឋានធានាគុណភាពអប់រំ ដើម្បីអនុវត្តប្រព័ន្ធវាយតម្លៃថ្នាក់ជាតិ។ នៅឆ្នាំ២០១២ ការិយាល័យវាយតម្លៃថ្នាក់ជាតិ បានធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យានៅលើសិស្សថ្នាក់ទី៤ មួយចំនួននៅដើមឆ្នាំសិក្សា ដែលប្រហាក់ប្រហែលនឹងសិស្សថ្នាក់ទី៣ ដោយសារការពន្យារពេលនៅក្នុងការរៀបចំការគ្រប់គ្រងតេស្ត។ នោះជាការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារតែវាត្រូវបានធ្វើឡើងជាមួយធនធានមនុស្ស និងធនធានហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាលើកដំបូង។ បច្ចុប្បន្ន ការធ្វើតេស្តស្តង់ដាថ្នាក់ទី៨ ត្រូវបានស្នើឡើង ជំនួសឱ្យថ្នាក់ទី៩ ដែលជាថ្នាក់បញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ។

នាយកដ្ឋានធានាគុណភាពអប់រំ បានចាប់ផ្តើមអភិវឌ្ឍក្របខណ្ឌធានាគុណភាពអប់រំ និងឧបករណ៍សម្រាប់អនុវត្ត ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ហើយដែលគាំទ្រដោយរដ្ឋាភិបាលប្រទេសស៊ុយអែត នៅខែតុលា ឆ្នាំ២០១២។

នេះគឺជាសូចនាករមួយនៃសូចនាករស្នូលទាំង៦ (CBI) នៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ ២០០៩-១៣ និងជាសូចនាករស្នូលនៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ ២០១៤-១៨ (ESP2014-18)។ អន្តរាគមន៍នេះ ជាធាតុដ៏សំខាន់ក្នុងការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានចាត់ទុកគុណភាពជាស្នូលនៃ ESP 2014-18។ គោលបំណងសំខាន់នៃការងារវាយតម្លៃរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺដើម្បីផ្តល់ការធ្វើបញ្ហាវិនិច្ឆ័យជាលក្ខណៈប្រព័ន្ធទូលំទូលាយ លើគុណភាពសាលារៀន និងការសិក្សារបស់សិស្ស ដោយយោងទៅតាមការកំណត់ស្តង់ដាអប់រំថ្នាក់ជាតិ និងការអនុវត្តកម្មវិធីសិក្សា ដែលអាចជួយកែលម្អគុណភាពអប់រំដោយ «ផ្តល់ព័ត៌មានត្រឡប់លើលទ្ធផល» ទៅក្នុងប្រព័ន្ធ។ នេះគឺជាការបង្កលក្ខណៈងាយស្រួលដល់ការតាមដានវឌ្ឍនភាពគ្រប់ពេលវេលា រួមទាំងការកាត់បន្ថយគម្លាតសិក្សារវាងតំបន់ជនបទ និងទីប្រជុំជន និងវាស់ស្ទង់លទ្ធផលនៃយុទ្ធសាស្រ្ត និងអន្តរាគមន៍ក្នុងការកែលម្អគុណភាព។

ក្នុងគោលដៅដោះស្រាយបញ្ហាពង្រឹងគុណភាពអប់រំ ក្រសួងអប់រំ យុវជន និងកីឡានឹងដាក់ចេញនូវវិធានការដូចខាងក្រោម ៖

- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានធានាគុណភាពអប់រំ នាយកដ្ឋានបឋមសិក្សានាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- ផ្តល់ធនធានមនុស្ស និងហិរញ្ញវត្ថុសមរម្យដើម្បីធ្វើតេស្ត និងវិភាគលទ្ធផលតេស្ត
- កសាងសមត្ថភាពលើការវិភាគ និងប្រើប្រាស់លទ្ធផលតេស្តវង្វាយតម្លៃថ្នាក់ជាតិដើម្បីផ្តល់ព័ត៌មានត្រឡប់អំពីកម្មវិធីសិក្សា និងការបណ្តុះបណ្តាល និងលើកយុទ្ធសាស្ត្រឬអន្តរាគមន៍ជាក់លាក់ ដើម្បីកែលម្អគុណភាព (ការប្រើប្រាស់ថវិកាដំណើរការសាលារៀន ការគាំទ្ររបស់ក្រុម DTMT ការងារអធិការកិច្ច ម៉ោងបង្រៀន ការផ្តល់សៀវភៅសិក្សាគោល។ល។)
- អភិវឌ្ឍក្របខណ្ឌធានាគុណភាពអប់រំ
- ភ្ជាប់ទំនាក់ទំនងរវាងតេស្តវង្វាយតម្លៃថ្នាក់ជាតិ ទៅនឹង EGRA/EGMA និងការប្រឡងថ្នាក់ជាតិ
- ធ្វើទំនាក់ទំនងជាមួយការវាយតម្លៃថ្នាក់តំបន់ និងអន្តរជាតិ (ឧទាហរណ៍ (SEA-PLM, PISA, PIRLS, TIMMS)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៩
# កំណែទម្រង់កម្មវិធីសិក្សា

## ៩.១. សេចក្ដីផ្ដើម

**ការអភិវឌ្ឍកម្មវិធីសិក្សា** គឺជាការងារស្នូលនៃការខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យគុណភាព និងប្រសិទ្ធភាពនៃការអប់រំបានល្អប្រសើរ។ ជារួម កម្មវិធីសិក្សាសំដៅលើការអភិវឌ្ឍធនធានមនុស្ស ដើម្បីធានាក្នុងការអភិវឌ្ឍចំណេះដឹង ជំនាញ តម្លៃគុណធម៌ និងភាពជាពលរដ្ឋសកល (រៀនដើម្បីចេះធ្វើ រៀនដើម្បីរៀនបន្ត រៀនដើម្បីធ្វើជាមនុស្សល្អ រៀនដើម្បីរស់នៅជាមួយគ្នា)។ កម្មវិធីសិក្សាមានគោលបំណងលើកកម្ពស់ជំនាញទន់ ឬជំនាញនៃស.វ.ទី២១។ ឧទាហរណ៍គំនិតប្រកបដោយការពិចារណា ការដោះស្រាយបញ្ហា និងការធ្វើការងារជាក្រុម។ល។ ដូច្នេះប្រព័ន្ធនៃការអប់រំ ចាំបាច់ត្រូវបង្រៀនសិស្សនូវជំនាញគ្រប់កម្រិត ដើម្បីឆ្លើយតបតាមតម្រូវការសង្គម និងសេដ្ឋកិច្ច ព្រមទាំងជំនាញនៃការសិក្សាពេញមួយជីវិតផងដែរ។

កម្មវិធីសិក្សាផ្ដោតលើការបណ្ដុះបណ្ដាលធនធានមនុស្ស ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ ផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នានិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ។ល។

ចាប់ពីឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ន កម្មវិធីសិក្សាត្រូវបានកែប្រែជាបន្តបន្ទាប់ ៖

- **ដំណាក់កាលទី១** ៖ ពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៧ ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា កម្មវិធីសិក្សាត្រូវបានបែងចែកជាបីកម្រិតគឺ ៖
    - កម្មវិធីសិក្សាសម្រាប់បឋមសិក្សាចំណេះទូទៅ (កម្រិតសិក្សាទី១)
    - កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាចំណេះទូទៅកម្រិតសិក្សាទី២ និងទី៣
- **ដំណាក់កាលទី២** ៖ ពីឆ្នាំ១៩៨៧ ដល់ ឆ្នាំ១៩៩៦ កម្មវិធីសិក្សាត្រូវបានបែងចែកជាបីកម្រិតគឺ ៖
    - កម្មវិធីសិក្សាសម្រាប់បឋមសិក្សាចំណេះទូទៅ(កម្រិតសិក្សាទី១)
    - កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាបឋមភូមិចំណេះទូទៅ(កម្រិតសិក្សាទី២)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- កម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិចំណេះទូទៅ (កម្រិតសិក្សាទី៣)។

## ៩.២. ការកែទម្រង់កម្មវិធីសិក្សាក្នុងឆ្នាំ ១៩៩៦

- **ដំណាក់កាលទី៣** ៖ ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៥ ក្នុងសម័យព្រះរាជាណាចក្រកម្ពុជាកម្មវិធីសិក្សាត្រូវបែងចែកជាបីកម្រិតគឺ ៖
  - កម្មវិធីសិក្សាគោលសម្រាប់បឋមសិក្សា
  - កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាបឋមភូមិ
  - កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ។

ការកែទម្រង់នេះដកស្រង់ពីបទពិសោធនានានៃកម្មវិធីសិក្សាពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៦៧ (សម័យសង្គមរាស្ត្រនិយម) កម្មវិធីសិក្សាពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៦ (សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា) និងកម្មវិធីសិក្សារបស់បណ្តាប្រទេសកំពុងអភិវឌ្ឍ និងអភិវឌ្ឍមួយចំនួនក្នុងតំបន់ និងក្រៅតំបន់អាស៊ាន។ មានបញ្ញត្តិជាច្រើនរួមទាំងច្បាប់សិទ្ធិមនុស្សផងដែរ ដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា តាមមុខវិជ្ជាភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងមុខវិជ្ជាសិក្សាសង្គម។ ការអប់រំសិទ្ធិមនុស្សត្រូវបានពង្រឹងបន្ថែមផងដែរដោយអនុលោមតាមសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្សសិទ្ធិកុមារ និងសិទ្ធិស្ត្រី ។ល។

ការកែទម្រង់កម្មវិធីសិក្សានៅទស្សវត្សរ៍ឆ្នាំ ១៩៩០ មានគោលបំណងដូចតទៅ[272]៖

- បន្ថែម១ឆ្នាំទៅលើកម្មវិធីសិក្សាបឋមសិក្សា ដូច្នេះកម្មវិធីសិក្សាចំណេះទូទៅ បឋមសិក្សាមានរយៈពេល៦ឆ្នាំ កម្មវិធីសិក្សាមធ្យមសិក្សាបឋមភូមិមានរយៈពេល៣ឆ្នាំ និងកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិមានរយៈពេល៣ឆ្នាំ
- ម៉ោងសិក្សាត្រូវបានកើនឡើងជាបន្តបន្ទាប់ដើម្បីឆ្លើយតបតាមស្តង់ដាអន្តរជាតិ (១ ០០០ម៉) ម៉ោងសិក្សាមាន៦ម៉ោងក្នុងមួយថ្ងៃនិង៣៨សប្តាហ៍ក្នុងមួយឆ្នាំសិក្សា។
- ១ម៉ោងសិក្សាមានរយៈពេល៤៥នាទីនៅបឋមសិក្សា ហើយមានរយៈពេល៥០នាទីនៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។
- មុខវិជ្ជាសិក្សានៅបឋមសិក្សាមាន៦មុខវិជ្ជា ហើយនៅមធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិមាន៨មុខវិជ្ជា ជាមុខវិជ្ជាចាំបាច់។ សកម្មភាពពិសេសនានា

[272] Yahan Chin. Cambodian National Curriculum and Human Rights Education. Available at the website of the Asia-Pacific Human Rights Information Center, www.hurights.or.jp/.../cambodian-national-curriculum-and-human-rights-education.html. Consulted on 7th January 2016.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រូវបានដាក់បញ្ចូលក្នុងវិធីសាស្ត្រគោល «វិធីសិស្សមជ្ឈមណ្ឌល»។ សកម្មភាពទាំងអស់ជួយដល់សិស្សនូវជំនាញផ្សេងៗក្នុងសង្គម និងបុគ្គលផ្ទាល់ខ្លួន ។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិសិស្ស ត្រូវបានបែងចែកជាក្រុមតាមមុខវិជ្ជាមូលដ្ឋាន និងមុខវិជ្ជាជ្រើសរើសតម្រូវការជាក់ស្តែង។

- ភាសាអង់គ្លេស និងបារាំងត្រូវបានបង្រៀនចាប់ពីថ្នាក់ទី៥ឡើងទៅ នៅកម្រិតបឋមសិក្សា
- មុខវិជ្ជានីមួយៗមានបញ្ចូលជំនាញអប់រំសិទ្ធិមនុស្ស សន្តិភាព អនាម័យ សុខភាព ម្ហូបអាហារ បរិស្ថាន ទេសចរណ៍ សេដ្ឋកិច្ច អាជីវកម្ម កុំព្យូទ័រ អប់រំជំងឺអេដស៍ និងកិច្ចការសង្គម ។ល។
- កម្មវិធីសិក្សាផ្តោតលើបញ្ញត្តិសុខដុមនីយកម្មមនុស្សក្នុងសង្គម តំបន់ភាវូបនីយកម្ម សាសនាភាវូបនីយកម្ម និងសកលភាវូបនីយកម្ម។
- ការយកចិត្តទុកដាក់លើចំណេះដឹង ជំនាញ អាកប្បកិរិយានិងតម្លៃ ដោយផ្តោតលើជំនាញភាសា គណិតវិទ្យា កុំព្យូទ័រ បច្ចេកវិទ្យាព័ត៌មាន ការដោះស្រាយបញ្ហា ឯករាជភាព កិច្ចសហប្រតិបត្តិការ អប់រំកាយ ការរៀន ការធ្វើការងារ និងការអនុវត្តទ្រឹស្តីវិទ្យាសាស្ត្រ (ការអង្កេត ការបង្កើតសម្មតិកម្ម ការប្រមូលទិន្នន័យ) ដើម្បីបង្កើតសមត្ថភាពជាមនុស្សថ្លៃថ្នូរ ជាមនុស្សមានការច្នៃប្រឌិត ជាអ្នកស្រឡាញ់បរិស្ថាន និងជាមនុស្សមានប្រយោជន៍ក្នុងសង្គម។

## ៩.៣. គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំ២០០៥-២០០៩[273]

- **ដំណាក់កាលទី៤** ៖ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៩ សម័យព្រះរាជាណាចក្រកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ (ថ្នាក់ទី១ដល់ទី៩) និងកម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១០ដល់ទី១២)។

[273] Ministry of Education, Youth and Sport (2004). Policy for Curriculum Development, 2005-2009.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណុចគន្លឹះជាអាទិភាព ដែលបានកែសម្រួលពីកម្មវិធីសិក្សាឆ្នាំ ២០០៥–២០០៩ រួមមាន ៖

- គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ដែលគោលនយោបាយនេះបរិយាយពីម៉ោងបង្រៀន
- ការផ្តល់ម៉ោងសិក្សាសម្រាប់កម្មវិធីសិក្សាបំណិនជីវិតមូលដ្ឋាន(ថ្នាក់ទី១ ដល់ទី១០) ហើយផ្តល់មុខវិជ្ជាជម្រើស សម្រាប់សិស្សថ្នាក់ទី១១ និង១២ដោយបន្ថែមម៉ោងសិក្សាតាមមុខវិជ្ជានីមួយៗ ដោយឱ្យសិស្សរៀនមុខវិជ្ជាតិចជាងមុន។

គោលនយោបាយនេះរៀបចំឡើងសម្រាប់រយៈពេល៥ឆ្នាំ(២០០៥-២០០៩) ហើយត្រូវបានពិនិត្យឡើងវិញក្នុងឆ្នាំ២០០៩ ដោយអភិវឌ្ឍគោលនយោបាយថ្មីសម្រាប់រយៈពេល៥ឆ្នាំទៀត (២០១០-២០១៤) ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍប្រទេសជាតិ។ គោលនយោបាយនេះផ្តល់មធ្យោបាយជារូបវន្ត និងប្រភពធនធានផ្សេងៗសម្រាប់គ្រូបង្រៀន នាយកសាលា មន្ត្រីអប់រំ ឪពុកម្តាយ អាណាព្យាបាល អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធដទៃទៀត។

គោលនយោបាយនេះបានកំណត់គោលបំណង និងរចនាសម្ពន្ធកម្មវិធីសិក្សាច្បាស់លាស់ រួមទាំងម៉ោងបង្រៀនផងដែរ។ កម្មវិធីសិក្សាលម្អិតមាននៅក្នុងឯកសារកម្មវិធីសិក្សាជាតិថ្មី។

គោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សានេះមានបំណងធ្វើឱ្យសម្រេចនូវចំណុចគន្លឹះជាអាទិភាពទាំងឡាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានកំណត់ក្នុងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥ដូចជា ៖

- សមធម៌ក្នុងការទទួលការអប់រំនៅកម្រិតមូលដ្ឋាន
- ផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់នៅមធ្យមសិក្សាទុតិយភូមិ
- គោលនយោបាយហិរញ្ញវត្ថុជួយដល់សិស្សក្រីក្រ
- ការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព
- ការបង្កើនការទទួលខុសត្រូវក្នុងការអភិវឌ្ឍស្តង់ដា

គោលបំណងនៃកម្មវិធីសិក្សាគឺអភិវឌ្ឍទេពកោសល្យ និងសមត្ថភាពរបស់សិស្ស ដើម្បីឱ្យគេក្លាយជាមនុស្សពេញលេញ រីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមាន

តុល្យភាពរវាងប្រាជ្ញា ស្មារតី មនោសញ្ចេតនា និងរូបកាយ។ ជាពិសេសនៅពេលសិស្សបញ្ចប់ការសិក្សា ពួកគេអាច ៖

- មានចំណូលចិត្ត និងស្រឡាញ់ការសិក្សាដើម្បីបម្រើការងារ និងបន្តការសិក្សាពេញមួយជីវិតបាន
- មានចំណេះដឹងផ្នែកភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យាជាមូលដ្ឋាន
- មានចំណេះដឹង បំណិន និងឥរិយាបថចាំបាច់ ដើម្បីថែរក្សាសុខភាពផ្នែកផ្លូវកាយ បញ្ញា ស្មារតីរបស់ខ្លួន ហើយចូលរួមចំណែកក្នុងការលើកស្ទួយការថែរក្សាសុខភាពក្រុមគ្រួសារ និងសង្គមឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។
- មានសមត្ថភាពគ្រប់គ្រង មានទំនួលខុសត្រូវលើសកម្មភាព លើសេចក្តីសម្រេចរបស់ខ្លួន និងមានទំនុកចិត្តលើខ្លួនឯង
- មានការកោតសរសើរ និងឱ្យតម្លៃសារៈសំខាន់នៃគំនិតវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការបង្កើតថ្មី និងគំនិតច្នៃប្រឌិត
- មានបំណិនក្នុងការបម្រើការងារ យល់ដឹងនិងមានឥរិយាបថវិជ្ជមានចំពោះការងារ និង មានសមត្ថភាពធ្វើការងារជាមួយអ្នកដទៃប្រកបដោយប្រសិទ្ធភាពនិងសុខដុម
- មានសមត្ថភាពក្នុងការពិចារណា ថ្លឹងថ្លែង មានស្មារតីទទួលខុសត្រូវ មានសីលធម៌ ចេះបែងចែក ចេះវិភាគដោះស្រាយបញ្ហាក្នុងគ្រួសារ និងសង្គម
- ស្វែងយល់ និងឱ្យតម្លៃដល់អ្នកដទៃ ដល់អរិយធម៌ វប្បធម៌ផ្សេងៗ ប្រវត្តិសាស្ត្រនានា ដែលអាចឈានទៅរកការកសាងស្មារតីសាធារណៈ ក្នុងន័យចេះគោរពសិទ្ធិអ្នកដទៃ និងមានសមធម៌
- ជាពលរដ្ឋសកម្ម មានគំនិតយល់ដឹងជ្រៅជ្រះអំពីវិវត្តនៃសង្គម ប្រព័ន្ធគ្រប់គ្រងច្បាប់ទម្លាប់របស់ប្រទេសកម្ពុជា ចេះរក្សានិងលើកស្ទួយតម្លៃជាតិ មានស្មារតីស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រ
- យល់ដឹងពីសារៈសំខាន់ និងចេះការពារ ថែរក្សាបរិស្ថានធម្មជាតិ សង្គម និងវប្បធម៌។

ដើម្បីសម្រេចគោលបំណងទាំងនេះ កម្មវិធីសិក្សាត្រូវតែ ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ផ្តល់បទពិសោធសិក្សាដើម្បីឱ្យសិស្សរៀនស្គាល់ រៀនធ្វើ រៀនរៀបចំខ្លួន និងរៀនរស់នៅជាមួយគ្នា។
- បំពាក់ឱ្យសិស្សនូវបំណិនជីវិតប្រចាំថ្ងៃ ដែលពួកគេត្រូវមាន ដើម្បីឱ្យពួកគេមានសក្តានុពលពេញលេញ ក្លាយជាសមាជិកផលិត និងសមាជិកដែលមានសមត្ថភាពក្នុងសង្គម។
- ឱ្យសិស្សទទួលបានចំណេះដឹង និងបំណិនកម្រិតខ្ពស់ក្នុងបណ្តុំមុខវិជ្ជា ៖
  - ភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ
  - គណិតវិទ្យា
  - វិទ្យាសាស្ត្រ(រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីនិងបរិស្ថានវិទ្យា)
  - សិក្សាសង្គម(ប្រវត្តិវិទ្យា ភូមិវិទ្យា គេហវិទ្យា អប់រំសិល្បៈ សីលធម៌ និងពលរដ្ឋវិជ្ជា)
  - ភាសាបរទេស
  - អប់រំកាយ កីឡា និងសុខភាព
- សង្កត់ធ្ងន់ទៅលើការរៀន និងការអនុវត្តយ៉ាងសកម្មនូវចំណេះដឹងគ្រប់មុខវិជ្ជាក្នុងកម្មវិធី សិក្សាគោល ដោយរួមទាំងការសិក្សាបច្ចេកវិទ្យា ដែលជាការអនុវត្តចំណេះដឹងសំដៅបង្កើនគុណភាពជីវិតរបស់ប្រជាពលរដ្ឋទាំងអស់។
- គោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សានេះត្រូវបានរៀបចំឡើង ដើម្បីសម្រេចគោលបំណងទាំងនោះ។

ចំណុចគន្លឹះនៃការកែលម្អកម្មវិធីសិក្សាឆ្នាំ ២០០៥–២០០៩ ដែលមានរចនាសម្ពន្ធដូចតទៅ ៖

- សម្រួលកម្មវិធីសិក្សាផ្នែកដំបូងនៃបឋមសិក្សា ដើម្បីឱ្យគ្រូផ្តោតលើការបង្រៀនដែលអាចធ្វើឱ្យសិស្សទាំងអស់ចេះភាសាខ្មែរ និងចេះគណនាលេខស្ទាត់នៅដំណាច់ថ្នាក់ទី៣។
- ឱ្យនិយមន័យ និងបញ្ជាក់ពីការផ្តល់ការអប់រំបំណិនជីវិត និងផ្តល់ឱកាសអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ប្រើគោលវិធីបញ្ចូលគ្នានូវមុខវិជ្ជាវិទ្យាសាស្ត្រ និងសិក្សាសង្គមក្នុងការអប់រំមូលដ្ឋាន(ថ្នាក់ទី១-៣) ដើម្បីធ្វើឱ្យការបង្រៀនកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់។
- ការបង្រៀនភាសាបរទេសជាអាទិភាពមួយ។ ផែនការណែនាំការបង្រៀនភាសាបរទេស អាស្រ័យលើអត្ថិភាពធនធានដែលមានក្នុងប្រទេសទាំងមូល។ ក្រសួងនឹងផ្តល់ការបង្រៀនភាសាបរទេសចាប់ពីថ្នាក់ទី ៥ដល់ទី១២។ នៅបឋមសិក្សាថ្នាក់ទី ៥-៦ ក្នុងដំណាក់កាលទី១ (២០០៥-២០០៩) ក្រសួងអប់រំ យុវជន និងកីឡានឹងជំរុញសាលារៀនឱ្យ បង្រៀនភាសាបរទេសដោយប្រើធនធានឧបត្ថម្ភពីខាងក្រៅ និងប្រើម៉ោងក្នុងកម្មវិធី បំណិនជីវិតតាមមូលដ្ឋាន។
- មានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់អភិវឌ្ឍស្តង់ដា មុខវិជ្ជាភាសាខ្មែរ និងគណិត-វិទ្យា(ការគណនាលេខ) នៅដំណាច់ថ្នាក់ទី៣ និងទី៦ ព្រមទាំងមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងភាសាបរទេសក្នុងការប្រឡងថ្នាក់ជាតិ នៅដំណាច់ថ្នាក់ទី៩
- មានជម្រើសមុខវិជ្ជាសិក្សានៅថ្នាក់ទី១១ និង១២ ដោយមានបន្ថែមម៉ោងសិក្សាសម្រាប់មុខវិជ្ជានីមួយៗ ដើម្បីឱ្យសិស្សដែលបានបញ្ចប់ការសិក្សាកាន់តែមានគុណភាពល្អប្រសើរ។ មុខវិជ្ជាដែលសិស្សត្រូវរៀនមានចំនួនតិចជាងមុន។
- មានរចនាសម្ព័ន្ធច្បាស់លាស់ សម្រាប់ពង្រីកការផ្តល់ការអប់រំនៅមធ្យមសិក្សាទុតិយភូមិ តាមរយៈភាពជាដៃគូរដ្ឋ និងឯកជន។

គោលនយោបាយនេះផ្តល់គម្រោងការងារសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាក្នុងអំឡុងឆ្នាំ ២០០៥-២០០៩។ កម្មវិធីសិក្សាថ្មីនេះមានផែនការអភិវឌ្ឍតាមកម្មវិធីសាកល្បងមួយ ហើយនឹងត្រូវអនុវត្តពេញលេញនៅឆ្នាំ២០០៧ លើកលែងតែករណីការបង្រៀនភាសាបរទេស ដែលត្រូវបានប្រមើលមើលថានឹងអនុវត្តជាដំណាក់ៗ ហើយត្រូវបញ្ចប់នៅឆ្នាំ២០០៩។

ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចផ្តល់មូលនិធិ ផ្តល់គ្រូបង្រៀន ផ្តល់មធ្យោបាយរូបវន្ត និងប្រភពធនធានផ្សេងៗទៀតដែលមានចែងក្នុងកម្មវិធីសិក្សាជាតិ។ កម្មវិធីសិក្សាជាតិត្រូវកំណត់ឱ្យបង្រៀន៣៨សប្តាហ៍ក្នុងមួយឆ្នាំសិក្សា។ សាលារៀនសហគមន៍មូលដ្ឋាន អង្គការសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាកម្ម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អប់រំឯកជនត្រូវអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីជួយបង្កើនគុណភាព និងជួយពង្រឹងកម្មវិធីសិក្សាជាតិឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

សាលារៀនត្រូវបង្កើនភាពជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការ សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល ហើយត្រូវអភិវឌ្ឍកម្មវិធីបំណិនជីវិតមូលដ្ឋាន ដែលមាន ២ ទៅ ៥ម៉ោងសិក្សាក្នុងមួយសប្តាហ៍ (មួយម៉ោងសិក្សាមានរយៈពេល ៥០នាទីសម្រាប់បឋមសិក្សា និង៥០នាទីសម្រាប់មធ្យមសិក្សា) ដើម្បីជួយបំពេញកម្មវិធីសិក្សាជាតិ។

## ៩.៤. ការត្រួតពិនិត្យកម្មវិធីសិក្សាឡើងវិញ ឆ្នាំ២០១៦-២០២៥[274]

ការត្រួតពិនិត្យកម្មវិធីសិក្សាឡើងវិញ គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារអាស៊ាននៅដំណាច់ឆ្នាំ ២០១៥។

លទ្ធផលសិក្សានៃកម្មវិធីសិក្សា និងការវិភាគលើសៀវភៅសិក្សាគោលដែលកំពុងប្រើប្រាស់បានបង្ហាញថា ខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលចំណុចមួយចំនួនមានកំហុសបច្ចេកទេស មានភាពមិនពាក់ព័ន្ធគ្នា ពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយ ហើយមានភាពច្រំដែល។ លើសពីនេះ មេរៀនខ្លះនៃមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រក្នុងកម្មវិធីសិក្សាចំណេះទូទៅពុំទាក់ទងទៅនឹងការអនុវត្តជាក់ស្តែង ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងការវិវឌ្ឍរបស់ពិភពលោក។ សិស្សដែលបញ្ចប់ការសិក្សា ពីភូមិសិក្សានីមួយៗមិនមានសមត្ថភាពគ្រប់គ្រាន់ សម្រាប់ប្រកបកិច្ចការរស់នៅ សម្រាប់បន្តការសិក្សានៅតាមសាលាបច្ចេកទេស ឬនៅគ្រឹះស្ថានឧត្តមសិក្សាបាន។

ការកែទម្រង់ការអភិវឌ្ឍកម្មវិធីសិក្សាដំណាក់កាលទី៥នេះ មានគោលបំណងធ្វើឱ្យសមត្ថភាពសិស្សដែលបញ្ចប់ការសិក្សាពីភូមិសិក្សានីមួយៗ មានចំណេះដឹង បំណិន និងឥរិយាបថ សម្រាប់ការរស់នៅ និងសម្រាប់បន្តការសិក្សា។ ជាងនេះទៅទៀត ក្របខណ្ឌកម្មវិធីសិក្សានេះ ធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ ដើម្បីឆ្លើយតបការវិវឌ្ឍរបស់ពិភពលោក ហើយឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ ដែលបានបង្ហាញការប្តេជ្ញាចិត្តក្នុងការប្រែក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវគោលដៅនេះ ប្រទេសកម្ពុជាត្រូវការលើកកម្ពស់កត្តាសំខាន់ៗ ដើម្បីជួយ

[274] ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) «ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ» ភ្នំពេញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់ខ្លួន និងបង្កើនការប្រកួតប្រជែងខណៈពេលដែលប្រទេសកម្ពុជាកំពុងពង្រីកខ្លួនចូលទៅក្នុងឧស្សាហកម្មថ្មីនៃទីផ្សារការងារថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សមាហរណកម្មអាស៊ាន និងការប្រែប្រួលរបស់ពិភពលោក ការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាថ្មីមានលក្ខណៈទាន់សម័យ និងវិទ្យាសាស្ត្រ សម្រាប់បង្កើតពលរដ្ឋពេញលេញ គឺជាកត្តាអាទិភាព និងចាំបាច់បំផុត។

ក្របខណ្ឌកម្មវិធីសិក្សាថ្មីនេះ ត្រូវបានអភិវឌ្ឍឡើងដោយផ្អែកលើគោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ ២០០៥-២០០៩ និងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនៃបណ្តាប្រទេសក្នុងសហគមន៍អាស៊ានមួយចំនួន ដូចជា ៖ ប្រទេសសិង្ហបុរី ប្រទេសម៉ាឡេស៊ី និងប្រទេសថៃ។

ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ដែលបានលើកឡើង ក្នុងការសិក្សាស្រាវជ្រាវនានាស្តីពីលទ្ធផលសិក្សារបស់សិស្ស ភាពប្រទាក់ក្រឡាគ្នានៃកម្មវិធីសិក្សា និងឆ្លើយតបទៅនឹងកម្មវិធីសិក្សា ពីមធ្យមសិក្សាទៅឧត្តមសិក្សា និងទីផ្សារការងារ ចំណុចសំខាន់ៗត្រូវបានកែសម្រួល និងបន្ថែមលើគោលនយោបាយការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ ២០០៥-២០០៩ ដែលមានដូចខាងក្រោម ៖

- កែសម្រួលក្របខណ្ឌកម្មវិធីសិក្សាពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ដើម្បីសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នារវាងកម្រិតថ្នាក់ និងមុខវិជ្ជា
- លទ្ធផលរំពឹងទុកតាមភូមិសិក្សាត្រូវបានរៀបចំឡើង
- បញ្ចូលកម្មវិធីសិក្សាភាសាបរទេស អង់គ្លេស និងបារាំង ចាប់ពីថ្នាក់ទី៤-៦ ជាមុខវិជ្ជាគោលក្នុងកម្មវិធីសិក្សា
- បំបែកមុខវិជ្ជាអប់រំសុខភាព អប់រំសិល្បៈ និងអប់រំកាយនិងកីឡា
- បញ្ចូលគោលការណ៍ណែនាំស្តីពីទំនើបកម្មវិធីសាស្ត្របង្រៀននៅគ្រប់កម្រិតសិក្សា
- បញ្ចូលគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើកម្មវិធីសិក្សាថ្មី និងការវាយតម្លៃការរៀន និងការបង្រៀន

- រៀបចំទម្រង់នៃប្រព័ន្ធអប់រំថ្មី តាមរចនាសម្ពន្ធឱ្យសិស្សនៅមធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ទៅ មានជម្រើសបី រួមមានមុខវិជ្ជាវិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម និងអប់រំបច្ចេកទេស

- បញ្ចូលក្របខណ្ឌកម្មវិធីសិក្សា ស្តង់ដា និងសូចនាករ ជាឯកសារតែមួយសម្រាប់ជំនួយ ដល់ការអភិវឌ្ឍសៀវភៅសិក្សាគោល សៀវភៅគ្រូ សៀវភៅអនុវត្ត និងសម្ភារឧបទេស នានាដើម្បីបម្រើឱ្យការរៀន និងការបង្រៀនកាន់តែសម្បូរបែប និងមានបច្ចុប្បន្នភាព

ចក្ខុវិស័យនៃកម្មវិធីសិក្សាចំណេះទូទៅ ធានាអប់រំឱ្យពលរដ្ឋមានលក្ខណសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដែលមានតុល្យភាពរវាងរូបកាយ ចំណេះដឹង បំណិន សីលធម៌ អត្តចរិតល្អ និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការធ្វើសមាហរណកម្មកម្ពុជាក្នុងតំបន់ និងក្នុងពិភពលោក។

កម្មវិធីសិក្សាចំណេះទូទៅមានគោលបំណងដូចតទៅ ៖

- **អភិវឌ្ឍសមត្ថភាពភាសាខ្មែរ និងភាសាបរទេសលើបំណិនទាំង៤** (ការស្តាប់ ការនិយាយ អំណាន និងសំណេរ) ច្បាស់លាស់សម្រាប់ប្រើប្រាស់ក្នុងការសិក្សា និងការប្រាស្រ័យទាក់ទងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- **អភិវឌ្ឍសមត្ថភាពគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកទេស បច្ចេកវិទ្យាព័ត៌មាន** សម្រាប់ជាមូលដ្ឋានបន្តការសិក្សា និងការប្រាស្រ័យទាក់ទងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- **អភិវឌ្ឍបំណិនសិល្បៈ សុខភាព កីឡា សោភ័ណ ការច្នៃប្រឌិត សហគ្រិនភាព និងបំណិនពលរដ្ឋវិជ្ជា** សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃក្នុងនាមជាបុគ្គល ជាប្រជាពលរដ្ឋ ជាសមាជិកគ្រួសារ សហគមន៍ និងសង្គម
- **អភិវឌ្ឍបំណិនស្វែងយល់ ស្រាវជ្រាវ ត្រិះរិះពិចារណា ច្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហា** ក្នុងបរិបទផ្សេងៗ
- **មានសមត្ថភាពក្នុងការវាយតម្លៃ និងការធ្វើសេចក្តីសម្រេចចិត្ត** ប្រកបដោយសុភនិច្ឆយ និងការទទួលខុសត្រូវ

- **មានចំណេះដឹងក្នុងការបំពេញកាតព្វកិច្ច និងប្រើប្រាស់សិទ្ធិជាពលរដ្ឋ** ដោយមានការទទួលខុសត្រូវក្នុងនាមជាបុគ្គល ជាប្រជាពលរដ្ឋ ជាសមាជិកគ្រួសារ សហគមន៍ សង្គម តំបន់ និងពិភពលោក
- **អភិវឌ្ឍបំណិនសិក្សាពេញមួយជីវិត** ដើម្បីមានចំណេះដឹងទូលំទូលាយពីសេដ្ឋកិច្ច នយោបាយ ប្រវត្តិសាស្ត្រ វប្បធម៌ អត្តសញ្ញាណជាតិ និងបរិស្ថានរបស់ប្រទេសខ្លួន តំបន់ និងពិភពលោកក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងភាពជាដៃគូក្នុងមនោសញ្ចេតនាមនុស្សលោកដូចគ្នា
- **អភិវឌ្ឍស្មារតីស្រឡាញ់ ការពារ និងកសាងជាតិមាតុភូមិ និងពូជសាសន៍របស់ខ្លួន** ដោយឈរលើគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស ផ្អែកលើច្បាប់ជាតិ និងអន្តរជាតិ។

សមត្ថភាពសំខាន់ៗរួមមាន ៖

- **អក្ខរពុទ្ធិ (អក្សរសាស្ត្រ) និងលេខពុទ្ធិ (លេខសាស្ត្រ)៖** ជាសមត្ថភាពដែលសិស្សប្រើប្រាស់ភាសា និងគណិតសាស្ត្រសម្រាប់យល់ដឹង ពន្យល់ បកស្រាយ ជជែកវែកញែក សម្របសម្រួល លើកទឹកចិត្ត ស្វែងយល់ និងដោះស្រាយបញ្ហាទាំងក្នុងការសិក្សា ជីវភាពប្រចាំថ្ងៃ និងក្នុងការងារវិជ្ជាជីវៈ
- **បំណិនភាសាបរទេស ៖** សិស្សមានសមត្ថភាពភាសាបរទេសគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការប្រាស្រ័យទាក់ទងគ្នា ស្រាវជ្រាវ និងបន្តការសិក្សា
- **បំណិនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍៖** សិស្សមានសមត្ថភាពបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ប្រើប្រាស់ បង្កើត ចែកចាយ ទុកដាក់ និងគ្រប់គ្រងព័ត៌មាន រួមទាំងការប្រើប្រាស់កុំព្យូទ័រក្នុងការសិក្សា និងជីវភាពប្រចាំថ្ងៃ
- **បំណិនទំនាក់ទំនង ៖** សិស្សមានសមត្ថភាពទំនាក់ទំនងក្នុងការប្រើប្រាស់បំណិន អក្ខរពុទ្ធិ និងលេខពុទ្ធិដើម្បី ៖ (១) ផ្សព្វផ្សាយគំនិត ចំណេះដឹង ជំនាញ អារម្មណ៍ និងទស្សនៈ (២) ធ្វើសុភនិច្ឆ័យព័ត៌មានដែលត្រូវទទួល ឬមិនត្រូវទទួលដោយឈរលើគោលការណ៍ វិភាគហេតុផល និង (៣) ចរចាស្វែងរកយន្តការ និងវិធីសាស្ត្រដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព សម្រាប់ជាប្រយោជន៍ទាំងអស់គ្នា
- **បំណិនពិចារណា និងការបង្កើតថ្មី៖** សិស្សមានសមត្ថភាពអភិវឌ្ឍបំណិន (១) វិភាគ និងវាយតម្លៃព័ត៌មានសមហេតុផល និងគ្រប់ជ្រុងជ្រោយ ដើម្បីស្វែងរក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដំណោះស្រាយ និងការធ្វើសេចក្ដីសម្រេចចិត្ត (២) បង្កើតគំនិតឬចំណេះដឹងថ្មី និង (៣) ជំរុញការស្រឡាញ់ ឯករាជ្យ និងការសិក្សាដោយពេញមួយជីវិត

- **បំណិនអនុវត្តចំណេះដឹង៖** សិស្សមានសមត្ថភាពប្រើប្រាស់ចំណេះដឹង ដែលបានរៀនពីមុខវិជ្ជានីមួយៗនៅគ្រប់កម្រិតថ្នាក់ ដើម្បីជាប្រយោជន៍សម្រាប់ការរស់នៅប្រចាំថ្ងៃ ហើយផ្ទេរចំណេះដឹងពី ព័ត៌មានសង្គមទៅចំណេះដឹងសង្គម
- **បំណិនអភិវឌ្ឍបុគ្គល និងសង្គម៖** សិស្សមានសមត្ថភាពអភិវឌ្ឍផ្នែកបញ្ញា និងស្មារតី សម្រាប់ប្រើប្រាស់ក្នុងការរស់នៅជាពលរដ្ឋក្នុងសង្គម ដែលកំពុងមានការប្រកួតប្រជែង និងអភិវឌ្ឍន៍។ បំណិនអភិវឌ្ឍបុគ្គល និងសង្គមមានគោល-បំណងអភិវឌ្ឍពលរដ្ឋ ៖ (១) ការទទួលខុសត្រូវក្នុងការបំពេញការងារ ដើម្បីខ្លួនឯង គ្រួសារ និងសង្គម ប្រកបដោយការយល់ដឹង ការស្រឡាញ់ និងការប្ដេជ្ញាចិត្ត (២) សីលធម៌រស់នៅ ដឹងខុសត្រូវ ការពារ និងអំពើសុចរិត (៣) សាមគ្គីភាពក្នុងការបំពេញការងារជាក្រុម ឬមានទំនាក់ទំនងជាមួយគ្នាប្រកបដោយមេត្តាធម៌ និងករុណាទៅវិញទៅមក ដើម្បីលើកកម្ពស់សេចក្ដីសុខ និងសុភមង្គលផ្ទាល់ខ្លួន គ្រួសារ និងសង្គម។
- **សហគ្រិនភាព ៖** សិស្សមានសមត្ថភាពក្នុងការអនុវត្តចំណេះដឹងដែលខ្លួនមានរួមទាំងបំណិនទាំង៧ ដែលរៀបរាប់ខាងលើដើម្បីប្រកបអាជីវកម្មខ្នាតតូចដោយជោគជ័យ។

ជំនាញក្នុងស.វ.ទី២១ មានស្តង់ដារសមត្ថភាព ៥ ៖ ការគិតពិចារណានិងបង្កើតថ្មី ការទំនាក់ទំនង ការដោះស្រាយបញ្ហា បំណិនជីវិត និងការអនុវត្តបច្ចេកវិទ្យា។

## ៩.៥. គោលបំណងតាមមុខវិជ្ជា

***ភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ៖*** គោលបំណងនៃការសិក្សាមុខវិជ្ជាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ គឺធានាឱ្យសិស្សអាច ៖

- ទទួលចំណេះដឹង និងបំណិនផ្នែកភាសាខ្មែរ និងអក្សរសាស្ត្រខ្មែររឹងមាំ
- មានសមត្ថភាពក្នុងការពិពណ៌នា វិភាគ វិនិច្ឆ័យ ពន្យល់ បកស្រាយ បានត្រឹមត្រូវ និងសមហេតុផល
- អនុវត្តចំណេះដឹង និងបំណិនភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរដើម្បីសិក្សាមុខវិជ្ជាដទៃ និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- យល់ដឹង និងស្រឡាញ់នូវតម្លៃមុខវិជ្ជាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ហើយមានមោទនភាពប្រើប្រាស់ភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ។

**គណិតវិទ្យា៖** គោលបំណងនៃការសិក្សាមុខវិជ្ជាគណិតវិទ្យា គឺធានាឱ្យសិស្សអាច៖

- ទទួលបានចំណេះដឹង និងបំណិនគណិតវិទ្យាមូលដ្ឋានរឹងមាំ
- មានសមត្ថភាពគណនា វិភាគ និងពន្យល់ បកស្រាយបានត្រឹមត្រូវ និងរហ័ស
- អនុវត្តចំណេះដឹង និងបំណិនគណិតវិទ្យាក្នុងកាសិក្សាមុខវិជ្ជាដទៃនិងប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- ឱ្យតម្លៃមុខវិជ្ជាគណិតវិទ្យា និងការអនុវត្តគណិតវិទ្យា។

**សិក្សាសង្គម ៖** គោលបំណងនៃការសិក្សាមុខវិជ្ជាសិក្សាសង្គម គឺធានាឱ្យសិស្សអាច ៖

- ទទួលបានចំណេះដឹង និងបំណិនទាក់ទងទៅនឹងប្រវត្តិសាស្ត្រ វប្បធម៌ សិល្បៈ បរិស្ថាន ភូមិសាស្ត្រ និងនយោបាយរបស់កម្ពុជា និងបណ្តាប្រទេសក្នុងតំបន់
- អភិវឌ្ឍបំណិនពលរដ្ឋពាក់ព័ន្ធទៅនឹងតួនាទី និងការទទួលខុសត្រូវ ក្នុងនាមជាសិស្ស និងពលរដ្ឋទាំងនៅក្នុងសាលារៀន គ្រួសារ និងសង្គម
- ប្រើប្រាស់ចំណេះដឹង និងបំណិនដែលបានមកពីការសិក្សាមុខវិជ្ជានានាក្នុងមុខវិជ្ជាសិក្សាសង្គម សម្រាប់ការរៀនសូត្រនិងប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- ស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រក្នុងនាមជាប្រជាពលរដ្ឋដែលមានចំណេះដឹង ការទទួលខុសត្រូវ និងមានមោទនភាពចំពោះខ្លួន និងជាតិសាសន៍ខ្លួន

**វិទ្យាសាស្ត្រ ៖** គោលបំណងនៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ គឺធានាឱ្យសិស្សអាច ៖

- ទទួលបានចំណេះដឹង និងបំណិនវិទ្យាសាស្ត្រមូលដ្ឋានរឹងមាំ
- មានសមត្ថភាពគណនា វិភាគ និងពន្យល់ បកស្រាយបានត្រឹមត្រូវតាមវិធីវិទ្យា-សាស្ត្រ និងរហ័ស
- អនុវត្តចំណេះដឹង និងបំណិនវិទ្យាសាស្ត្រក្នុងការសិក្សា និងប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ឱ្យតម្លៃមុខវិជ្ជាវិទ្យាសាស្ត្រ និងការអនុវត្តវិទ្យាសាស្ត្រក្នុងការអភិវឌ្ឍប្រទេសជាតិ។

**ព័ត៌មានវិទ្យា និងគមនាគមន៍វិទ្យា៖** គោលបំណងនៃការសិក្សាមុខវិជ្ជាព័ត៌មានវិទ្យា និងគមនាគមន៍វិទ្យា គឺធានាឱ្យសិស្សអាច ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ទទួលបានចំណេះដឹង និងបំណិនមូលដ្ឋានគ្រឹះកុំព្យូទ័រ
- មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីទំនាក់ទំនង សហការ ប្រមូល និង វិភាគទិន្នន័យក្នុងការសិក្សា និងស្រាវជ្រាវដោយប្រសិទ្ធភាព។

**ភាសាបរទេស(អង់គ្លេសនិងបារាំង)**៖ គោលបំណងនៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ គឺធានាឱ្យសិស្សអាច៖

- មានសមត្ថភាពទំនាក់ទំនងក្នុងបំណិនទាំងបួន គឺការស្តាប់ ការនិយាយ ការអាន និងការសរសេរ
- ក្លាយជាអ្នកសិក្សាពេញមួយជីវិត ប្រកបដោយការច្នៃប្រឌិត និងទំនុកចិត្ត។

**អប់រំកាយ និងកីឡា**៖ គោលបំណងនៃការសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា គឺធានាឱ្យសិស្សមាន ៖

- រាងកាយមាំមួន សុខភាពល្អ ក្តីសប្បាយ និងសុភមង្គលក្នុងជីវិត
- បំណិនចាំបាច់ក្នុងការលេងកីឡាគ្រប់ប្រភេទ
- ឥរិយាបថល្អ ក្នុងការប្រកួតក៏ដូចក្នុងកិច្ចសហប្រត្តិបត្តិ
- បម្រុងប្រយ័ត្នចំពោះសុខភាព
- អំណត់ អធ្យាស្រ័យ ភាពវាងវៃ រហ័សរហួន ឆន្ទៈមោះមុត និងមានគំនិតសមូហភាព
- ការរីកចម្រើនក្នុងការសិក្សា សណ្តាប់ធ្នាប់ និងវិន័យល្អ
- ចំណូលចិត្តហាត់ប្រាណ និងលេងកីឡា។

**អប់រំសុខភាព** ៖ គោលបំណងនៃការសិក្សាមុខវិជ្ជាអប់រំសុខភាព គឺធានាឱ្យសិស្សមាន ៖

- ចំណេះដឹងសុខភាព ស្របតាមការលូតលាស់នៃរាងកាយ និងស្មារតីប្រកបដោយវិទ្យាសាស្ត្រ
- បំណិនសម្រាប់បង្ការជំងឺឆ្លង ជំងឺមិនឆ្លង គ្រោះថ្នាក់ផ្សេងៗ និងវិធីជួយសង្គ្រោះបឋម
- គុណតម្លៃ និងឥរិយាបថដែលនាំឱ្យពួកគេអភិវឌ្ឍខ្លួនប្រកបដោយសុខភាពពេញលេញ ទាំងកាយ ប្រាជ្ញា និងស្មារតី ចេះទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន។

**អប់រំសិល្បៈ** ៖ គោលបំណងនៃការសិក្សាមុខវិជ្ជាអប់រំសិល្បៈ គឺធានាឱ្យសិស្សអាច ៖

- យល់ដឹងច្បាស់ពីទ្រឹស្តីជាមូលដ្ឋាន និងការអនុវត្តសិល្បៈជាក់ស្តែង
- ស្គាល់ប្រវត្តិ តម្លៃពិត និងសារៈសំខាន់នៃសិល្បៈ វប្បធម៌របស់ជាតិខ្លួន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- មានគំនិតច្នៃប្រឌិតរស់រវើក
- ប្រុងប្រយ័ត្នក្នុងការរក្សាលំនឹង ស្មារតី រៀបចំកាយវិការ ដាក់មនោសញ្ចេតនាទៅតាមទម្រង់សិល្បៈនីមួយៗ
- មានវិញ្ញាណវាងវៃចំពោះសិល្បៈសោភ័ណ និងសិល្បៈអារម្មណ៍
- មានគំនិតស្រឡាញ់ ថែរក្សា ការពារ និងកសាងសិល្បៈវប្បធម៌របស់ប្រទេសជាតិ
- មានឥរិយាបថត្រឹមត្រូវចំពោះសិល្បៈ វប្បធម៌ជាតិ និងអន្តរជាតិ។

**បំណិនជីវិតមូលដ្ឋាន៖** គោលបំណងនៃការសិក្សាមុខវិជ្ជាបំណិនជីវិតមូលដ្ឋានគឺធានាឱ្យសិស្សអាច ៖

- មានបំណិនបញ្ញា បុគ្គលិកលក្ខណៈអន្តរបុគ្គល និងវិជ្ជាជីវៈដែលអាចជួយដល់ការសម្រេចចិត្ត ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព អាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន
- លើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព។

ដើម្បីអនុវត្តកម្មវិធីសិក្សាខាងលើ ក្រសួងបានកំណត់ម៉ោងសិក្សាដូចតទៅ ៖

- ៣០ម៉ោងក្នុងមួយសប្តាហ៍នៅមត្តេយ្យសិក្សា
- ៣០ម៉ោងនៅបឋមសិក្សា
- ៤០ម៉ោងនៅមធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិ។

ការបង្រៀនត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ ៖

- ការបង្រៀនគឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស ដើម្បីឱ្យពួកគេមានវិជ្ជា
- សម្បទា បំណិនសម្បទា និងចរិយាសម្បទាដោយប្រើប្រាស់វិធីសាស្ត្រគោលវិធីសិស្សមជ្ឈមណ្ឌល។
- ការបង្រៀនគឺជាសកម្មភាពជួយនិងលើកទឹកចិត្តសិស្សឱ្យចេះរបៀបរៀនដោយខ្លួនឯង យ៉ាងសកម្ម មានប្រសិទ្ធភាពនិងទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្ត
- ចំណេះដឹង សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃ ដោយប្រើប្រាស់វិធីសាស្ត្រទំនើប ដូចជាសហការនិងអង្កេត។
- ការបង្រៀនត្រូវបន្តពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់
- ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់ និងផ្តល់តម្លៃដល់ការសិក្សា។

- ការបង្រៀនត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីវិទ្យាសាស្ត្រ
- និងសម្ភារឧបទេសរួមទាំងបច្ចេកវិទ្យាព័ត៌មានសម្បូរបែប និងមានបច្ចុប្បន្នភាព។

## ៩.៦. ការវាយតម្លៃ

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ត្រូវធ្វើឡើងចំពោះវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការវាយតម្លៃជាដំណើរការជានិរន្តរ៍ សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភ័ស្តុតាងអំពីកម្រិតនៃសមត្ថភាពរបស់សិស្សក្រោយពីដំណើរការរៀន និងបង្រៀនទាំងក្នុងថ្នាក់ទាំងក្រៅថ្នាក់។ ការវាយតម្លៃគឺសំដៅរកព័ត៌មាន ឬភ័ស្តុតាង ដើម្បីសន្និដ្ឋានសម្រេចចិត្ត រកវិធីនិងផ្តល់ធាតុចូល ជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងស្តង់ដាលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ។ លទ្ធផលនៃការវាយតម្លៃនឹងត្រូវប្រើប្រាស់ សម្រាប់កំណែទម្រង់ និងកែលម្អប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា។

## ៩.៧. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

ដើម្បីសម្រេចបាននូវការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មីនេះ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនត្រូវផ្តោតលើចំណុចសំខាន់ៗដូចជា ៖

- ត្រូវពង្រឹងគ្រូបង្រៀនឱ្យមានចំណេះដឹងច្បាស់លាស់ និងស៊ីជម្រៅលើកម្មវិធីសិក្សាមុខវិជ្ជាបង្រៀន និងវិធីសាស្ត្របង្រៀន
- ត្រូវពង្រឹងគ្រូបង្រៀន ឱ្យមានបំណិនក្នុងការវាយតម្លៃលើលទ្ធផលសិក្សារបស់សិស្ស តាមកម្រិតថ្នាក់ និងសាលារៀន និងប្រើប្រាស់លទ្ធផលដើម្បីកែលម្អវិធីសាស្ត្របង្រៀនទៅតាមតម្រូវការពិសេសរបស់សិស្ស
- គាំទ្រគ្រូបង្រៀនទាំងផ្នែកបច្ចេកទេស សម្ភារឧបទេសនិងស្មារតី ដើម្បីលើកទឹកចិត្តពួកគាត់ ឱ្យអនុវត្តវិធីសាស្ត្របង្រៀនផ្អែកលើគោលវិធីសិស្សមជ្ឈមណ្ឌល ដើម្បីឆ្លើយតបនឹងក្របខណ្ឌកម្មវិធីសិក្សាថ្មី និងបរិបទពិភពលោក។
- បណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានសមត្ថភាពច្នៃប្រឌិត និងបង្កើតស្នាដៃក្នុងការសិក្សាស្រាវជ្រាវប្រតិបត្តិ សម្រាប់ប្រើប្រាស់ក្នុងការរៀន និងបង្រៀនពេញមួយជីវិត និងមានលក្ខណៈជាប្រព័ន្ធច្បាស់លាស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៩.៨. សេចក្តីសន្និដ្ឋាន

សិស្សទទួលបានកម្មវិធីសិក្សាតាមរយៈសៀវភៅសិក្សាគោល និងសៀវភៅគ្រូ។ វិធីសាស្ត្រ ការសិក្សាជាក្រុម និងតាមរយៈមិត្តភក្តិ ការសិក្សាក្នុងថ្នាក់ ស្វ័យសិក្សាតាមរយៈគ្រូដាក់កិច្ចការឱ្យសិស្សធ្វើ។ សកម្មភាពផ្សេងៗ រួមទាំងវិធីសាស្ត្រដទៃៗទៀតត្រូវបានយកមកអនុវត្តក្នុងការសិក្សា ដូចជាសិស្សមជ្ឈមណ្ឌល សកម្មភាពសិក្សា ការអនុវត្តការសិក្សាតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល។ សកម្មភាពជាក់លាក់នៅមូលដ្ឋាន គឺជាយុទ្ធសាស្ត្រ ដែលមានប្រសិទ្ធភាព ដើម្បីបង្កើតមុខទាក់ទងទៅការសិក្សារបស់សិស្ស។ គុណភាពកម្មវិធីសិក្សាត្រូវផ្តោតលើកត្តាដូចតទៅ៖ ខ្លឹមសារ គ្រូបង្រៀន លទ្ធផលសិក្សារបស់សិស្ស ការគ្រប់គ្រង ការរៀននិងបង្រៀន បរិស្ថានសាលារៀន និងអ្នកសិក្សា។

កត្តាមួយចំនួនផ្តល់លទ្ធផលវិជ្ជមានពីក្នុងកម្មវិធីសិក្សា ៖

- វិធីសាស្ត្រមជ្ឈមណ្ឌល
- កែលម្អខ្លឹមសារកម្មវិធីសិក្សា
- ប្រព័ន្ធអប់រំថ្មី
- ការចូលរួមពីគ្រូបង្រៀន
- ផ្តល់និងផ្គត់ផ្គង់សៀវភៅសិក្សានិងសម្ភារសិក្សា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១០

# កំណែទម្រង់ការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីលើកកម្ពស់ឧស្សាហូបនីយកម្ម

ប្រាក់ចំណូលរបស់ប្រជាជនកម្ពុជាម្នាក់ក្នុងមួយឆ្នាំ បានកើនឡើងស្មើរបួនដងពោលគឺចាប់ពី ៣២៨ ដុល្លារអាមេរិក ក្នុងឆ្នាំ២០០២ រហូតដល់ប្រមាណជា ១ ២២៨ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៥។ ទោះបីជាការបង្កើតការងារបានកើនឡើង ក្នុងរយៈពេលដូចគ្នានេះ ដោយក្នុងនោះ គេសង្កេតឃើញការងារថ្មីៗជាច្រើន ត្រូវបានបង្កើតឡើងក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មក៏ដោយ ប៉ុន្តែសេដ្ឋកិច្ចកម្ពុជា នៅតែប្រឈមនឹងបញ្ហាចម្បងក្នុងការស្រូបទាញអ្នកស្វែងរកការងារធ្វើប្រហែល ៣០០ ០០០នាក់  ឱ្យចូលមកក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ។ ការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីវិបត្តិសេដ្ឋ-កិច្ចក្នុងឆ្នាំ២០០៨ មិនទាន់ធ្វើឱ្យប្រទេសនេះ មានកំណើនការងារច្រើនដូចពេលមុននៅឡើយទេ។ បច្ចុប្បន្ន ការងារត្រូវបានបង្កើតឡើង តែវាមិនសមស្របទៅនឹងកំណើនសេដ្ឋកិច្ចកម្ពុជាឡើយ។ កម្ពុជា ចាំបាច់ត្រូវផ្លាស់ប្តូរមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីរក្សានិរន្តរភាពកំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះ។

ពិពិធកម្មសេដ្ឋកិច្ច មានទំនាក់ទំនងយ៉ាងសំខាន់ ទៅនឹងប្រព័ន្ធអប់រំ និងទីផ្សារការងារនៅកម្ពុជា។ ទោះបីយ៉ាងណាក៏ដោយ នៅប្រទេសកម្ពុជា កម្មករភាគច្រើន មិនមានជំនាញ ឬមានជំនាញពាក់កណ្តាល។ កម្មករទាំងនោះ ខ្វះទាំងបទពិសោធ ទាំងគុណវុឌ្ឍិជំនាញ។ ជាលទ្ធផល សេដ្ឋកិច្ចកម្ពុជា ត្រូវប្រឈមនឹងការធ្វើការខុសជំនាញ។ *ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលដែលឆ្លើយតប និងសមស្របនឹងប្រព័ន្ធសេដ្ឋកិច្ច ទាមទារឱ្យសិស្សត្រូវមានចំណេះដឹង និងជំនាញចាំបាច់ ដើម្បីក្លាយទៅជាកម្លាំងពលកម្មប្រកប ដោយផលិតភាព* [275]។

ការដោះស្រាយវិបត្តិធ្វើការខុសជំនាញដ៏ធ្ងន់ធ្ងរនេះ មានសារៈសំខាន់ណាស់ ដោយវាមិនត្រឹមតែជំរុញការបង្កើតការងារប៉ុណ្ណោះទេ ថែមទាំងទ្រទ្រង់ឱ្យមានផលិតភាពការប្រកួតប្រជែង និងកំណើនកាន់តែខ្ពស់ ដែលនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (IDP) ដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

[275] S. Damico (2010). Higher Education and Skills for the Labor Market in Cambodia. Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កាលពីឆ្នាំ២០១៥។ ពលករជំនាញ ដើរតួនាទីដ៏សំខាន់ក្នុងការជំរុញឱ្យមានកំណើនការងារ ការប្រកួតប្រជែង និងលើកកម្ពស់ភាពច្នៃប្រឌិត។ ដូច្នេះ កំណែទម្រង់ការអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាត់ទុកជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា។ លើសពីនេះទៀត ប្រព័ន្ធអប់រំចំណេះទូទៅមានគោលដៅលើកកម្ពស់មុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេក-វិទ្យា វិស្វកម្ម គណិតវិទ្យា (STEM) នៅគ្រប់កម្រិតសិក្សា ដោយរួមបញ្ចូលទាំងការបង្កើតសាលាជំនាន់ថ្មី ផងដែរ។

## ១០.១. ការរៀបចំស្ថាប័ន សម្រាប់ការអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជា-ជីវៈនៅកម្ពុជា

### ១០.១.១. ពិពិធកម្មសេដ្ឋកិច្ច និងការលេចឡើងនូវគម្លាតជំនាញ

ប្រព័ន្ធអប់រំនៅកម្ពុជាត្រូវផ្តល់កម្លាំងពលកម្ម ដែលមានសមត្ថភាពត្រៀមខ្លួនជាស្រេច ក្នុងការធ្វើការនៅក្នុងទីផ្សារការងារ ដើម្បីឱ្យសេដ្ឋកិច្ចកម្ពុជា អាចរីកចម្រើន និងផ្តល់នូវផលិតភាពខ្ពស់។ មាតាបិតា និងសិស្សានុសិស្សត្រូវមានជំនឿជឿជាក់ ក្នុងការបន្តការសិក្សាក្នុងប្រព័ន្ធអប់រំ ពីព្រោះការសិក្សានេះនឹងផ្តល់អត្ថប្រយោជន៍ដល់ពួកគេ នាពេលអនាគត។ ទោះបីជាយ៉ាងណាក៏ដោយ ជាមធ្យម សិស្សានុសិស្សកម្ពុជាចំនួន ២០% រៀនបានត្រឹមថ្នាក់ទី៦ ក៏បោះបង់ចោលការសិក្សាទៅ។

បញ្ហាសំខាន់ដែលសាលារៀននៅកម្ពុជា កំពុងប្រឈម គឺអត្រាបោះបង់ចោលការសិក្សាខ្ពស់ នៅកម្រិតមធ្យមសិក្សាបឋមភូមិ។ សិស្សមានបំណងបន្តការសិក្សារបស់ខ្លួន នៅពេលពួកគេរៀនដល់កម្រិតមធ្យមសិក្សាទុតិយភូមិ។ ដូច្នេះ ប្រព័ន្ធអប់រំចាំបាច់ត្រូវផ្តល់ឱ្យសិស្សនូវទស្សនវិស័យដ៏វែងឆ្ងាយ ដែលពួកគេអាចសម្លឹងមើលឃើញពីអនាគតដល់ពួកគេ។ ប្រសិនបើអនាគតរបស់សិស្ស មើលទៅភ្លឺត្រចះត្រចង់ មាតាបិតាសិស្សនឹងចង់ឱ្យកូនៗរបស់ខ្លួន បន្តការសិក្សាទៅមុខទៀត ជាពិសេសប្រសិនបើមានផ្លូវសិក្សាច្បាស់លាស់ទៅកាន់សាកលវិទ្យាល័យ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើការងារ និងការប្រកបមុខរបរខ្លួនឯង។ និយោជកអាចនឹងទទួលបានការលើកទឹកចិត្តឱ្យចេញថ្លៃសិក្សាដល់និយោជិតរបស់ខ្លួន ប្រសិនបើពួកគេមើលឃើញពីអត្ថប្រយោជន៍ក្នុងការទទួលបានពលករដែលអាចសម្របខ្លួនធ្វើការបានកាន់តែលឿន និងក្លាយទៅជានិយោជិតប្រកបដោយផលិតភាព។

បច្ចុប្បន្ន ប្រព័ន្ធអប់រំវិជ្ជាជីវៈនៅកម្ពុជា មិនទាន់មានការរីកចម្រើននៅឡើយទេ ហើយសិស្ស បោះបង់ចោលការសិក្សានៅមធ្យមសិក្សាបឋមភូមិ ទៅស្វែករកការងារដោយទទួលបានប្រាក់កម្រៃទាប ឬប្រកបមុខរបរដោយខ្លួនឯង នៅពេលពួកគេមិនអាច



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មើលឃើញថា ការសិក្សាបន្តទៀតនឹងអាចបំពេញតម្រូវការរបស់ខ្លួនបាន។ ក្នុងស្ថានភាពជាក់ស្តែង សិស្សភាគច្រើននឹងមិនបន្តការសិក្សានៅសាកលវិទ្យាល័យ ឬឧត្តមសិក្សាឡើយ ខណៈដែលការបណ្តុះបណ្តាលវិជ្ជាជីវៈមួយចំនួន អាចបំពេញតម្រូវការរបស់សិស្សដែលខ្វះឱកាសទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈនោះ។ ដូច្នេះ វិធីសាស្ត្រផ្តោតលើលទ្ធផល ត្រូវធ្វើយ៉ាងណារៀបចំសិស្សឱ្យទទួលបានការបណ្តុះបណ្តាលជំនាញត្រូវនឹងតម្រូវការសេដ្ឋកិច្ច ពោលគឺជំនាញដែលមានតម្រូវការខ្ពស់ ដូចជា កម្មករសំណង់ ជំនាញកែច្នៃម្ហូបអាហារ ការគ្រប់គ្រងសណ្ឋាគារ ។ល។ និងអភិវឌ្ឍការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបំពេញតម្រូវការទាំងនេះ ក៏ដូចជាផ្តល់ឱកាសកាន់តែច្រើន ដល់សិស្ស ដើម្បីឱ្យពួកគេអាចស្វែងរកការងារជំនាញកាន់តែច្រើន។

ការរៀនសូត្រ គួរមានទាំងការប្រតិបត្តិជាក់ស្តែង ទាំងការពិសោធ។ សិស្សមិនត្រឹមតែទាមទារឱ្យដឹងព័ត៌មានប៉ុណ្ណោះទេ ថែមទាំងអាចធ្វើពិសោធន៍អ្វី ដែលពួកគេបានរៀនផងដែរ។ ឧទាហរណ៍ សិស្សអាចរៀនកុំព្យូទ័រ ប៉ុន្តែការរៀនពិតប្រាកដ រាប់បញ្ចូលទាំងការចេះប្រើប្រាស់កុំព្យូទ័រផងដែរ។ ដូចគ្នាផងដែរ សិស្សអាចដឹងពីរុក្ខជាតិ ជីវវិទ្យា រូបវិទ្យា ប៉ុន្តែដើម្បីយល់ច្បាស់អំពីគោលការណ៍ទាំងនេះ ទាមទារឱ្យសិស្សត្រូវធ្វើពិសោធន៍ជាក់ស្តែង តាមរយៈការពិនិត្យទៅលើរុក្ខជាតិ ឬវត្ថុមួយ ហើយយកវាមកធ្វើពិសោធន៍ដើម្បីយល់ច្បាស់អំពីគោលការណ៍ទាំងនោះ។ បច្ចុប្បន្ន សិស្សកម្ពុជាជាច្រើន មិនបានយកចំណេះដឹងរបស់ខ្លួន ទៅអនុវត្តជាក់ស្តែងឡើយ ផ្ទុយទៅវិញ ពួកគេបែរជាទន្ទេញព័ត៌មានសម្រាប់ធ្វើតេស្តទៅវិញ។ ការអប់រំចាំបាច់ត្រូវផ្តល់នូវមធ្យោបាយមួយ ដើម្បីប្រែក្លាយសាលារៀនឱ្យទៅជាកន្លែងការងារ។ បញ្ហាមួយផ្នែក កើតចេញពីការអប់រំនៅឧត្តមសិក្សា។ គ្រូបង្រៀន ត្រូវបានបណ្តុះបណ្តាលដោយគ្រឹះស្ថានឧត្តមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សាកំពុងបង្កើតបញ្ហាធ្វើការខុសជំនាញរវាងការរៀនសូត្រ និងការយកជំនាញទាំងនោះ ទៅប្រើប្រាស់នៅកន្លែងធ្វើការ ៖ បញ្ហាដែលអាចកើតឡើង រាប់បញ្ចូលទាំងការគ្មានការងារធ្វើ ឬគុណភាពរៀនសូត្រខ្សោយខ្លាំង មិនអាចឆ្លើយតបទៅនឹងទីផ្សារការងារ។ ដូច្នេះ គ្រូបង្រៀន មិនអាចត្រៀមខ្លួនបានល្អ ដើម្បីបំពេញការងាររបស់ខ្លួន។ រោងចក្រដែលកំពុងបិទទ្វារឈប់ដំណើរការ បានរាយការណ៍អំពីកង្វះអ្នកគ្រប់គ្រង និងអ្នកត្រួតពិនិត្យដែលមានសមត្ថភាព។ យើងសង្ឃឹមថានឹងឃើញសិស្សកម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារគ្រប់គ្រងទាំងនោះបាន។

ក្នុងគោលដៅបង្កលក្ខណៈឱ្យសិស្ស និងនិស្សិតចាប់ផ្តើមគិតគូរអនាគតរបស់ខ្លួន ក៏ដូចជាចាប់យកអាជីព ដែលពួកគេមានសម្បទា ទៅតាមចំណង់ចំណូលចិត្តចំពោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការងារ ដែលពួកគេចាប់អារម្មណ៍ និងសមស្របទៅតាមទីផ្សារការងារ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំឱ្យមានការប្រឹក្សាការងារសម្រាប់សិស្ស និងនិស្សិត។ សិស្សមួយចំនួនបានគិតគូរអំពីចំណុចទាំងនេះ រួចជាស្រេច ខណៈដែលសិស្សមួយចំនួនទៀត មិនទាន់ច្បាស់អំពីបញ្ហាទាំងនេះ។ បញ្ហាទាំងនេះ អាចដោះស្រាយបានតាមរយៈការណែនាំសិស្សឱ្យស្គាល់ និងឃើញការងារមួយចំនួន ដើម្បីឱ្យពួកគេចាប់ផ្ដើមផ្សារភ្ជាប់សមត្ថភាពរបស់ខ្លួន ទៅនឹងការងារដែលអាចរកបាន។ ការធ្វើបែបនេះ អាចឱ្យពួកគេពិចារណាថាតើខ្លួនគួរស្វែងរកការងារធ្វើក្នុងឧស្សាហកម្មម្ហូបអាហារ មេកានិក ។ល។ ឬយ៉ាងណា។ សាលារៀនត្រូវទទួលខុសត្រូវអនុវត្តកម្មវិធី«**តម្រង់ទិសទៅអាជីព**»។

ដោយគ្មានការប្រឹក្សាការងារ ទើបយើងសង្កេតឃើញមានបញ្ហាធ្វើការខុសជំនាញ ដោយសមត្ថភាពរបស់សិស្ស មិនស៊ីគ្នាទៅនឹងការងារដែលពួកគេធ្វើឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រព័ន្ធអប់រំត្រូវតែរៀបចំឱ្យមានសមត្ថភាព និងចាប់អារម្មណ៍បន្ថែមទៀត ដូច្នោះ ប្រព័ន្ធអប់រំ ត្រូវមានគុណភាព និងភាពទាក់ទាញ ដើម្បីឱ្យប្រជាជនជឿទុកចិត្តថា នឹងទទួលបានអត្ថប្រយោជន៍ពីការសិក្សាបន្ត។ ក្នុងស្ថានភាពនេះ ការផ្ដល់អាហារូបករណ៍ និងការលើកទឹកចិត្តផ្សេងៗទៀត ចាំបាច់ត្រូវតែមាន ដើម្បីលើកទឹកចិត្តមាតាបិតាឱ្យយល់ថា អ្វីដែលពួកគាត់លះបង់សម្រាប់អនាគតកូនៗគាត់ ពិតជាផ្ដល់តម្លៃដល់គាត់វិញ នាពេលអនាគត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាពទី៩ ៖ ប្រព័ន្ធអប់រំនៅកម្ពុជា*




*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ការធ្វើការខុសជំនាញ អាចវាយតម្លៃបានដោយផ្អែកលើភាពមិនស៊ីគ្នាទាក់ទងនឹងការរំពឹងទុករបស់និយោជក(វិធីសាស្ត្រផ្អែកលើតម្រូវការ) ឬផ្អែកលើគម្លាតចំណេះដឹង បើប្រៀបធៀបនឹងមធ្យមភាគអន្តរជាតិ(វិធីសាស្ត្រផ្អែកលើការផ្គត់ផ្គង់)។ និយោជកផ្តោតជាសំខាន់លើជំនាញគិត និងអាកប្បកិរិយា។ ដូច្នេះ ប្រព័ន្ធអប់រំមិនគួរផ្តោតជាសំខាន់តែលើជំនាញមូលដ្ឋាននោះទេ គួរផ្តោតលើបទពិសោធជាក់ស្តែង ការអភិវឌ្ឍពុទ្ធិ ជំនាញត្រិះរិះពិចារណា និងជំនាញដែលអាចផ្លាស់ប្តូរផ្សេងៗទៀត។

រាជរដ្ឋាភិបាលកម្ពុជាកាន់តែព្រួយបារម្ភខ្លាំងឡើងទាក់ទងនឹងស្ថានភាព និងភាពពាក់ព័ន្ធនៃការអប់រំដែលខ្លួនបាន និងកំពុងផ្តល់ដល់ប្រជាជនរបស់ខ្លួន នៅពេលមានតម្រូវការធ្វើឱ្យសេដ្ឋកិច្ចកាន់តែរីកចម្រើន ជាពិសេសការលេចឡើងនូវវិស័យសេវាកម្ម និងឧស្សាហកម្មបន្ថែមតម្លៃ ដូចជាគ្រឿងអេឡិចត្រូនិក រោងចក្រ និងសេវាកម្មកាន់តែទំនើប។ តម្រូវការការអប់រំ និងការបណ្តុះបណ្តាលដែលមានគុណភាពកាន់តែខ្ពស់ នឹងកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត។ ក្នុងស្ថានភាពបែបនេះ គុណភាពអប់រំ និងការបណ្តុះបណ្តាល គួរមានគោលដៅផ្តល់ទាំងចំណេះដឹងផ្នែកទ្រឹស្តី ទាំងការប្រតិបត្តិ រួមទាំងជំនាញដែលអាចផ្លាស់ប្តូរបាន(ជួនកាល ហៅថាជំនាញប្រចាំស.វ.ទី២១)។ ការផ្លាស់ប្តូរជាអាទិភាពនេះ នាំឱ្យមានការវិភាគដោយប្រុងប្រយ័ត្នលើសូចនាករជាច្រើន ដែលអាចចាត់ទុកថាជាសូចនាករប្រហាក់ប្រហែលសម្រាប់វាស់វែងគុណភាពអប់រំ។ ចំណុចដែលត្រូវផ្តោតជាសំខាន់ គឺកម្រិតអប់រំ ចំណេះដឹងលើមុខវិជ្ជាណាមួយ និងជំនាញគរុកោសល្យរបស់គ្រូបង្រៀន។

ដើម្បីដោះស្រាយបញ្ហាធ្វើការខុសជំនាញ ក្រសួងអប់រំ យុវជន និងកីឡាបានពិនិត្យឡើងវិញនូវកម្មវិធីសិក្សា ក្នុងគោលដៅកែលម្អជំនាញមូលដ្ឋានសំខាន់ៗ ដូចជា ៖ (i) ជំនាញមូលដ្ឋានដែលទទួលបានពីគ្រឹះស្ថានអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដូចជាគណិតវិទ្យា អក្ខរកម្ម និងភាសាអង់គ្លេស (ii) ជំនាញទន់ដែលអាចផ្លាស់ប្តូរបាន(ជួនកាលហៅថា ជំនាញប្រចាំស.វ.ទី២១) ដែលទទួលបានតាមរយៈកម្មវិធីសិក្សា និងវិធីសាស្ត្រគរុកោសល្យ ក្នុងគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលនានា។ ជំនាញទន់ រួមមានជំនាញត្រិះរិះពិចារណា (ការគិតល្អិតល្អន់ និងប្រកបដោយគំនិតច្នៃប្រឌិត ការដោះស្រាយបញ្ហា) និងជំនាញអាកប្បកិរិយា (ការទំនាក់ទំនង ការគ្រប់គ្រងខ្លួនឯង ការអត់ធ្មត់ ជំនាញរៀបចំចាត់ចែង ការធ្វើការជាក្រុម និងភាពជាអ្នកដឹកនាំ)[276] និង (iii) ជំនាញអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការងារ។ ជំនាញទាំងនេះ ហៅម្យ៉ាងទៀតថា «ជំនាញបំណិនការងារ»។

ដូច្នេះ សាលារៀនដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ជំនាញដល់យុវជន។ ការសិក្សាជាមូលដ្ឋាន និងជំនាញទន់ទូទៅ អាចត្រូវបានផ្តល់នៅកម្រិតបឋមសិក្សា នៅពេលដែលការសិក្សាជំនាញខ្ពស់ និងជំនាញទន់ អាចត្រូវបានផ្តល់ឱ្យចាប់ពីកម្រិតមធ្យមសិក្សាបឋមភូមិឡើងទៅ។

[276] World Bank. (2006). p. 15.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំនាញបច្ចេកទេសមួយចំនួន ត្រូវបានផ្តល់នៅកម្រិតមធ្យមសិក្សា។ សាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំឧត្តមសិក្សា ផ្តល់ការបណ្តុះបណ្តាលជំនាញកាន់តែខ្ពស់ ជំនាញទូទៅ និងជំនាញបច្ចេកទេស។ ការអប់រំក្រៅប្រព័ន្ធ គួរផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ជំនាញទូទៅ និងជំនាញបច្ចេកទេស ដល់សិស្សបោះបង់ការសិក្សា។ នៅកម្ពុជា ក្រុមហ៊ុនមួយចំនួន ផ្តល់ការបណ្តុះបណ្តាល ដើម្បីបង្កើនជំនាញបច្ចេកទេស និងជំនាញទូទៅ ដល់បុគ្គលិករបស់ខ្លួន។

ក្នុងន័យនេះ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងបំណិនការងារ ធ្វើឡើងនៅពេលកុមារបញ្ចប់ការអប់រំមូលដ្ឋាន ពោលគឺនៅមធ្យមសិក្សាបឋមភូមិ។ នៅពេលសិស្សរៀនចប់មធ្យមសិក្សាបឋមភូមិ ពួកគេនឹងទទួលបានការអប់រំពីរផ្នែក (i) ផ្នែកវិជ្ជាជីវៈសម្រាប់សិស្សដែលមានបំណងចង់ចូលបម្រើការតែម្តង និង (ii) ផ្នែកចំណេះទូទៅសម្រាប់សិស្សដែលមានបំណងចង់បន្តការសិក្សាទៅឧត្តមសិក្សា[277]។

បណ្តាប្រទេសមួយចំនួនរៀបចំប្រព័ន្ធសិក្សាតាមបែបប្រពៃណី ដោយបង្កើតឡើងនូវជម្រើសពីរសម្រាប់សិស្ស។ ក៏ប៉ុន្តែ ប្រព័ន្ធនេះមិនអាចផ្តល់ភាពបត់បែនតាមតម្រូវការរបស់សិស្សបានឡើយ។ នៅពេលពួកគេផ្លាស់ប្តូរបំណងប្រាថ្នារបស់ខ្លួន នៅមុនពេល ឬក្រោយពេលបញ្ចប់មធ្យមសិក្សា។ ប្រព័ន្ធបែបនេះ មាននិន្នាការដាក់សិស្ស ឱ្យនៅដាច់ដោយឡែកពីគ្នា ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច[278]។ ដូច្នេះ ប្រទេសកម្ពុជា កំពុងស្ថិតក្នុងដំណើរការផ្តល់ការបណ្តុះបណ្តាលមុខជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ បន្ថែមពីលើការអប់រំ ដែលមានច្រកពីរ។

## ១០.២. ការផ្គត់ផ្គង់ជំនាញ

### ១០.២.១. ការរៀបចំស្ថាប័ន

នៅប្រទេសកម្ពុជា មានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) សរុបចំនួន ៣២៥ ដែលបានចុះឈ្មោះ និងស្ថិតនៅក្រោមឱវាទក្រសួងចំនួន ១២។ គ្រឹះស្ថានទាំងនោះ រួមមាន៖ អង្គការមិនមែនរដ្ឋាភិបាល ៥៧ ស្ថាប័ន ឯកជន ២១១ និងគ្រឹះស្ថានសាធារណៈ ៥៦។ ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងប្រព័ន្ធអប់រំផ្លូវការ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងវែង។

---

277 These countries are Germany, the Netherlands, Korea and Turkey.

278 Un Leang, Upper Secondary School Curriculum Reform in Cambodia: Relevance for Employment and Tertiary Education, p. 33. See also Levin, B. and Segedin, L. (2011). International Approaches to Secondary Education. Ontario: The Higher Education Quality Council of Ontario. p. 14.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**គណៈកម្មាធិការជាតិបណ្តុះបណ្តាល** (NTB) ត្រូវបានបង្កើតឡើងដើម្បីបង្កើតគោលនយោបាយស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈ អនុម័តវិធានទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការសម្របសម្រួលមូលនិធិបណ្តុះបណ្តាលជាតិ និងការត្រួតពិនិត្យមើល**ទីភ្នាក់ងារជាតិមុខរបរ និងការងារ**(NEA)។ ស្តង់ដាជំនាញត្រូវបានបង្កើតឡើងសម្រាប់វិស័យអាទិភាព បន្ទាប់ពី **ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា** ទទួលបានការអនុម័តក្នុងឆ្នាំ២០១២។

ទោះបីជាចំនួនសិស្ស ដែលចុះឈ្មោះចូលរៀនក្នុងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជា-ជីវៈ នៅមានកម្រិតតិចតួច បើធៀបទៅនឹងសិស្សដែលចូលរៀនក្នុងការអប់រំចំណេះទូទៅក៏ដោយ ប៉ុន្តែតម្រូវការជំនាញវិជ្ជាជីវៈសម្រាប់យុវជនកម្ពុជា នៅតែមានកម្រិតខ្ពស់ដដែល។ ការសិក្សាជាច្រើនបានកំណត់បញ្ហាបច្ចុប្បន្ន ដូចជា ៖ ការសម្របសម្រួលអន្តរក្រសួងមានតិចតួច កិច្ចសហប្រតិបត្តិជាមួយឧស្សាហកម្មនៅមានកម្រិត ក្របខណ្ឌគតិមិនឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែង កម្មវិធី និងមុខវិជ្ជាដែលបណ្តុះបណ្តាលមិនសម ស្របទៅនឹងតម្រូវការទីផ្សារ និងសមត្ថភាពរបស់ស្ថាប័ននៅមានកម្រិត។

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត **ក្របខណ្ឌគុណវុឌ្ឍិជាតិ** ក្នុងគោលដៅសម្របសម្រួលស្ថាប័ន សមមូលសញ្ញាបត្រ និងជំនាញ ព្រមទាំងកំណត់នីតិវិធី ដើម្បីធានាឱ្យបាននូវការទទួលស្គាល់សមមូលជំនាញប្រកបដោយប្រសិទ្ធភាព និងអាចប្រៀបធៀបបាន។

### *១០.១.២.១. ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈសាធារណៈស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផ្ទេរពីក្រសួងអប់រំ យុវជន និងកីឡា ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅឆ្នាំ២០០៥ បន្ទាប់ពីក្រសួងថ្មីនេះត្រូវបានបង្កើតឡើង[279]។ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានបង្កើតឡើង នៅតាមខេត្តចំនួន២២ ដើម្បីផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្ម សិប្បកម្ម និងជំនាញវិជ្ជាជីវៈមូលដ្ឋាន។ ការចុះឈ្មោះចូលរៀនរបស់សិស្សនៅឆ្នាំ២០១០ មានចំនួន ៦ ០៣៥នាក់។ សិស្សចំនួន ១ ៩៨១នាក់ បានកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រជាន់ខ្ពស់ ចំណែកសិស្ស ៣ ៣០៨នាក់ផ្សេងទៀត បានកំពុងសិក្សាកម្រិតវិញ្ញាបនបត្រ។ សិស្សចំនួន ៧៤៦

---

[279] Royal Kram No. NS/RKM/0105/003 of January 17, 2005, promulgating the law on establishment of Ministry of Labor and Vocational Training.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាក់ កំពុងសិក្សាវគ្គខ្លីៗ កម្រិត១ ដល់៣។ ការបណ្តុះបណ្តាលកម្រិត២, ៣ និង៤ មានតម្លៃសមមូលទៅនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រែក្លាយ **មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ** ខេត្តចំនួន ៥ ទៅជា **មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈភូមិភាគ** ដែលផ្តល់ការបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ និងសញ្ញាបត្រ។

ការទាក់ទាញសិស្សប្រឡងជាប់ថ្នាក់ទី៩ ឱ្យចូលរៀនមុខវិជ្ជាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានសាធារណៈ គឺជាបញ្ហាប្រឈមដ៏ធំដោយសារ (i) កង្វះព័ត៌មានស្តីពីកម្មវិធីការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទំនាក់ទំនងរវាងកម្មវិធីនេះទៅនឹងទីផ្សារការងារ (ii) ការមន្ទិលសង្ស័យពាក់ព័ន្ធនឹងគុណភាពនៃការផ្តល់សេវា និង (iii) ការមិនមានមធ្យោបាយចុះឈ្មោះសិស្សចូលរៀននៅសាលាចំណោះទូទៅឡើងវិញ នៅពេលដែលសិស្សចង់វិលត្រឡប់ទៅសិក្សាផ្នែកចំណេះទូទៅវិញ។

ក្រៅពីមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តចំនួន ២២ នៅមាន **វិទ្យាស្ថានពហុបច្ចេកទេស** ចំនួន ៧ ទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយវិទ្យាស្ថានពហុបច្ចេកទេស និងមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសចំនួន ៩ ស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងផ្សេងៗទៀត។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតស្តង់ដា និងកម្មវិធីសិក្សាផ្អែកលើសមត្ថភាព ក៏ដូចជាមុខវិជ្ជាសិក្សាទាក់ទងនឹងការងារចំនួន ១១ ប្រភេទ (សំណង់ ៤ ប្រភេទ មេកានិក ៣ ប្រភេទ និង បច្ចេកវិទ្យាព័ត៌មាន/ពាណិជ្ជកម្ម ៤ ប្រភេទ) សម្រាប់ ៣ កម្រិតផ្សេងគ្នា។ ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តតាមប្រព័ន្ធវិមជ្ឈការ ទោះបីជាវិស័យនេះ ទាមទារនូវការពង្រឹងសមត្ថភាពដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈក៏ដោយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ខេត្ត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ជាតិ ដើម្បីសម្របសម្រួលការបណ្តុះបណ្តាល ការបង្កើតបញ្ជីសារពើភណ្ឌសម្រាប់ការបណ្តុះបណ្តាល និងការរៀបចំផែនការបណ្តុះបណ្តាលថ្នាក់ខេត្ត។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏មានរៀបចំផែនការសម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត (PTCs) ដើម្បីអភិវឌ្ឍតួនាទីរបស់ខ្លួន ឱ្យកាន់តែទូលំទូលាយ លើសពីការបណ្តុះបណ្តាលផ្ទាល់ និងដើម្បីអភិវឌ្ឍខ្លួនឱ្យក្លាយទៅជាអ្នកបង្កើត និងអ្នកសម្របសម្រួលការរៀបចំផែនការ និងការផ្តល់សេវាកម្ម


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈសម្រាប់ខេត្តនានា។ រដ្ឋាភិបាលមិនទាន់បានបង្កើតហិរញ្ញប្បទានសម្រាប់ប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលបានធ្វើវិមជ្ឈការក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាល វិជ្ជាជីវៈនៅឡើយទេ។

### *១០.១.២.២. ស្ថាប័នបណ្ដុះបណ្ដាលសាធារណៈស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា* (MoEYS)

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០១៩-២០១៨ ត្រូវបានអនុម័ត ដើម្បីជា«ប្រទីបបំភ្លឺផ្លូវ» សម្រាប់អនុវិស័យមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សានិងអប់រំបច្ចេកទេស អប់រំក្រៅប្រព័ន្ធ និង ឧត្តមសិក្សា។ ជារួម ផែនការនេះ ផ្ដោតលើបញ្ហាគន្លឹះពីរ គឺ ៖ (១) ការសម្រេចបានការអប់រំមូលដ្ឋាន និងបច្ចេកទេស ជាសកល ប្រកបដោយគុណភាពខ្ពស់ និង (២) ការលើកកម្ពស់សមធម៌ក្នុងឱកាសអប់រំ ដើម្បីបង្កើនប្រាក់ចំណូល និងឱកាសការងារ។

វត្ថុបំណងជាក់លាក់នៃគោលនយោបាយស្ដីពីអនុវិស័យអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស គឺដើម្បីធានា ៖ (i) ការទទួលបានការអប់រំមធ្យមសិក្សា ទាំងផ្នែកចំណេះទូទៅ ទាំងផ្នែកបច្ចេកទេស ប្រកបដោយសមធម៌ (ii) សិស្សដែលបានបញ្ចប់មធ្យមសិក្សា មានជំនាញត្រឹមត្រូវ ដើម្បីទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេសកាន់តែខ្ពស់ និងបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ហើយ (iii) ប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល អាចបំពេញមុខងារបានពេញលេញ។

ក្នុងន័យនេះ ដើម្បីបែងចែកឱ្យច្បាស់ នូវការទទួលខុសត្រូវរបស់ក្រសួងទាំងពីរ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការបែងចែក ការអប់រំបច្ចេកទេស និងបណ្ដុះបណ្ដាលវិជ្ជាជីវៈជាពីរផ្នែក ៖ (១) ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលជាសមត្ថកិច្ចរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង (២) ការអប់រំបច្ចេកទេស ដែលជាសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធី «អប់រំបច្ចេកទេស» នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស នៅបណ្ដាខេត្តមួយចំនួន ចាប់តាំងពីឆ្នាំ២០០២ មក ក្នុងនោះ រាប់បញ្ចូលទាំងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស៣ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ១៥៧ ដែលផ្ដល់ការបណ្ដុះបណ្ដាលអក្ខរកម្ម និងមូលដ្ឋានសម្រាប់ឱ្យសិក្ខាកាមចូលរួមអាចស្វែងរកប្រាក់ចំណូលបាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ១. វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ត្រូវបានកសាងឡើងនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដោយព្រះមហាក្សត្រកម្ពុជា។ ការបណ្តុះបណ្តាលនៅវិទ្យាល័យនេះ ផ្តោតលើជំនាញ ២ គឺ អគ្គិសនី និង គ្រឿងត្រជាក់។

*តារាងទី២៦ ៖ គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស*

| ឆ្នាំសិក្សា | ក្បេរត្រជាក់ | | អគ្គិសនី | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៣-២០១៤ | ១ | ០ | ១ | ០ | ២ | ០ |

ថវិកាដំណើរការមានចំនួនសរុបប្រហែល ១១៥លានរៀល ដើម្បីឆ្លើយតបនឹងតម្រូវការបង្រៀន និងរៀន និងដើម្បីទ្រទ្រង់ការអភិវឌ្ឍសម្ភាររូបវន្តវិទ្យាល័យ។

*តារាងទី២៧ ៖ ការចុះឈ្មោះចូលរៀនរបស់សិស្ស*

| ឆ្នាំសិក្សា | អេឡិចត្រូនិក | | អគ្គិសនី | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១៣-២០១៤ | ៣០ | ១០ | ២១ | ១៨ | ៥៣ | ២៨ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

### ២. វិទ្យាល័យកំពង់ឈើទាល

វិទ្យាល័យកំពង់ឈើទាល គាំទ្រដោយគម្រោងឧបត្ថម្ភរបស់ព្រះអង្គម្ចាស់ក្សត្រិយ៍ មហាចក្រី សិរិនថន របស់ប្រទេសថៃ។ វិទ្យាល័យកំពង់ឈើទាល ជាវិទ្យាល័យដំបូងគេ ដែលបានផ្តល់ការបណ្តុះបណ្តាលពីរផ្នែក គឺការអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេស។ មូលនិធិរបស់គម្រោងនេះ ត្រូវបានយកទៅប្រើប្រាស់សម្រាប់កសាងហេដ្ឋារចនាសម្ពន្ធ អគារ និងសម្ភារផ្សេងៗ។ វិទ្យាល័យកំពង់ឈើទាល បានបើកដំណើរការចាប់ពីឆ្នាំ២០០១ មក។ នៅឆ្នាំ២០១៣/២០១៤ វិទ្យាល័យនេះ មានសិស្សសរុប ៥២៦នាក់ ដែលបានសិក្សា ជំនាញអេឡិចត្រូនិក អគ្គិសនី បសុវប្បកម្ម និងគ្រឿងត្រជាក់។

*តារាងទី២៨ ៖ គ្រូបច្ចេកទេសដែលទទួលបានការបណ្ដុះបណ្ដាលដោយមូលនិធិគម្រោង*

| ឆ្នាំសិក្សា | កៅស៊ូគ្រសាស្ត្រ | | អគ្គិសនី | | អេឡិចត្រូនិក | | បសុវប្បកម្ម | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១១-២០១២ | ១២ | ៤ | ១២ | ១ | ៧ | ០ | ១០ | ៥ | ៤១ | ១០ |
| ២០១២-២០១៣ | ១១ | ៣ | ១១ | ១ | ៥ | ០ | ៩ | ៥ | ៣៦ | ៩ |
| ២០១៣-២០១៤ | | | | | | | | | | |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

កម្មវិធីសិក្សា រាប់បញ្ចូលទាំងឆ្នាំមូលដ្ឋាន ដែលតម្រូវឱ្យសិស្សត្រូវចំណាយពេលសិក្សាលើមុខវិជ្ជាគោល ៦០% និង ៤០%លើមុខវិជ្ជាបច្ចេកទេសមិនសំខាន់។ នៅឆ្នាំទី២ សិស្សត្រូវចំណាយពេល ៤០% ដើម្បីសិក្សាមុខវិជ្ជាគោល និង៦០% លើមុខវិជ្ជាបច្ចេក-ទេស។ នៅឆ្នាំទី៣ សិស្សត្រូវសិក្សាមុខវិជ្ជាគោល ២០% និង ៨០% លើមុខវិជ្ជាបច្ចេក-ទេស។ ដើម្បីបន្តការសិក្សារបស់ខ្លួនទៅមុខទៀត សិស្សតម្រូវឱ្យប្រឡងបញ្ចប់ឆ្នាំជាប់ជាចាំបាច់។

ក្នុងចំណោមសិស្សដែលបានបញ្ចប់ការសិក្សានៅឆ្នាំ២០១១-២០១២ ចំនួន៤៣% បានបន្តការសិក្សាបន្ថែម ៣៧%ស្វែងរកការងារធ្វើនៅក្នុងក្រុមហ៊ុន ៥ %ចូលបម្រើការងារក្នុងស្ថាប័នរដ្ឋ និង ៩%បង្កើតអាជីវកម្មដោយខ្លួនឯង។ ចំណែក ៥% មិនមានព័ត៌មាន។

*តារាងទី២៩ ៖ ការចុះឈ្មោះចូលរៀនរបស់សិស្ស*

| ឆ្នាំសិក្សា | ចំនួនសិស្សផ្នែកអប់រំបច្ចេកទេស | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | អេឡិចត្រូនិក | | អគ្គិសនី | | កៅស៊ូគ្រសាស្ត្រ | | បសុវប្បកម្ម | | សរុប | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១១-២០១២ | ៧៩ | ៥ | ១១៨ | ៦ | ១៩០ | ៨៩ | ១០៨ | ៥០ | ៤៩៥ | ១៥០ |
| ២០១២-២០១៣ | ៨៩ | ១២ | ១៣៨ | ១២ | ១៥១ | ១០១ | ៩៨ | ៤៩ | ៤៧៦ | ១៧៤ |
| ២០១៣-២០១៤ | | | | | | | | | | |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ផែនការប្រតិបត្តិសម្រាប់ការបង្រៀន និងរៀន នៅវិទ្យាល័យកំពង់ឈើទាល មានចំនួនសរុបប្រហែល ៣៣៤ ២លានរៀល។ មូលនិធិគម្រោងដែលគាំទ្រដោយគម្រោងរបស់ព្រះអង្គម្ចាស់ក្សត្រិយ៍ មហាចក្រី សិរិនថន ប្រើសម្រាប់បំពេញតម្រូវការផ្សេងៗទៀត ដូចជា ជួសជុលហេដ្ឋារចនាសម្ពន្ធ ការចំណាយលើថ្លៃភ្លើង។ល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣. វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ROTA ខ្សាច់កណ្ដាល

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ROTA ខ្សាច់កណ្ដាល ត្រូវបានបង្កើតឡើងដោយមូលនិធិដែលផ្ដល់ដោយមូលនិធិព្រះអង្គម្ចាស់ក្សត្រិយ Qatar និងមូលនិធិមុនីឋាបនា។ សាលានេះ ចាប់ផ្ដើមផ្ដល់ការសិក្សាពីរជំនាញផ្សេងគ្នា នៅឆ្នាំ២០១២-២០១៣។ មូលនិធិនេះ ប្រើសម្រាប់កសាងអគារ និងបំពាក់សម្ភារផ្សេងៗនៅសាលានេះ។ ការបណ្ដុះបណ្ដាលនៅសាលានេះ ផ្ដោតសំខាន់លើពីរជំនាញផ្សេងគ្នា គឺអគ្គិសនី និងអេឡិចត្រូនិក។

*តារាងទី៣០ ៖ គ្រូអប់រំបច្ចេកទេស*

| ឆ្នាំសិក្សា | អេឡិចត្រូនិក | | អគ្គិសនី | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១២-២០១៣ | ២ | ០ | ២ | ០ | ៤ | ០ |
| ២០១៣-២០១៤ | ២ | ០ | ២ | ០ | ៤ | ០ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ថវិកាដំណើរការរបស់សាលានេះ មានចំនួនសរុបប្រហែល ១៤៧,៥លានរៀល។ មូលនិធិគម្រោង ប្រើសម្រាប់បំពេញតម្រូវការមួយចំនួន ដូចជាការជួសជុលហេដ្ឋារចនា-សម្ព័ន្ធ ចំណាយលើថ្លៃភ្លើង។ល។

*តារាងទី៣១ ៖ ការចុះឈ្មោះចូលរៀនរបស់សិស្ស*

| ឆ្នាំសិក្សា | អេឡិចត្រូនិក | | អគ្គិសនី | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១២-២០១៣ | ៦៤ | ៤ | ៧១ | ០២ | ១៣៥ | ០៦ |
| ២០១៣-២០១៤ | ៣៦ | ០២ | ៤០ | ០៣ | ៧៦ | ០៥ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### *១០.១.២.៣. ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី*

ដៃគូអភិវឌ្ឍដែលរួមចំណែកយ៉ាងសំខាន់ដល់ការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា រួមមានធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍស្វីស។

ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ បានលើកកម្ពស់គុណភាពកម្លាំងពលកម្ម ក្រោមកម្មវិធីគាំពារសង្គម ដូចជា កម្មវិធីបណ្ដុះបណ្ដាលជំនាញដែលមានលិខិតបញ្ជាក់ (Voucher Skills Training Program-VSTP)។ កម្មវិធីបណ្ដុះបណ្ដាលជំនាញដែលមានលិខិតបញ្ជាក់ ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីផ្ដល់ការបណ្ដុះបណ្ដាលជំនាញមូលដ្ឋានរយៈពេលខ្លី នៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលខេត្ត។ ការបណ្ដុះបណ្ដាលក្រោម VSTP បានទទួលអ្នកបណ្ដុះបណ្ដាលជាមធ្យមជាង ២០ ០០០នាក់ (៦០%ជាស្ត្រី) ក្នុងមួយឆ្នាំ ក្នុងអំឡុងឆ្នាំ២០០៦-២០១៣។ ការបណ្ដុះបណ្ដាលនេះ ជួយបង្កើនប្រាក់ចំណូល តាមរយៈការលើកកម្ពស់ជំនាញកសិកម្ម សិប្បកម្ម និងមេកានិកមូលដ្ឋាន។ កម្មវិធីបណ្ដុះបណ្ដាលជំនាញ ដែលមានលិខិតបញ្ជាក់ ធ្វើឱ្យប្រជាជននៅតំបន់ជនបទទទួលបានការបណ្ដុះបណ្ដាលជំនាញចិញ្ចឹមជីវិតកាន់តែប្រសើរ និងជួយបង្កើនប្រាក់ចំណូលសម្រាប់សិស្សទើបបញ្ចប់ការសិក្សា។ កម្មវិធីនេះ ក៏បានរួមចំណែកដល់ការអភិវឌ្ឍដំណើរការផ្ដល់ជំនាញមូលដ្ឋាន តាមបែបវិមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព។

### *១០.១.២.៤. ដៃគូអភិវឌ្ឍ អ្នកផ្ដល់សេវាបណ្ដុះបណ្ដាលឯកជន*

អាជីវកម្មឯកជនប្រហែល ៧៥០ ក្រុមហ៊ុន ផ្ដល់សេវាបណ្ដុះបណ្ដាលបង់ថ្លៃ រាប់បញ្ចូលទាំងការបណ្ដុះបណ្ដាលជំនាញកុំព្យូទ័រ និងភាសាអង់គ្លេស សាលាបង្រៀនបើកបរ សាលារបាំ ហាងជួសជុលរថយន្ត និងឧបករណ៍អគ្គិសនី និងការបង្រៀនវិជ្ជាជីវៈក្រៅផ្លូវការជាដើម។

នាពេលបច្ចុប្បន្ននេះ ពលករភាគច្រើន បានទទួលការអប់រំក្រោមកម្រិតមធ្យមសិក្សា ហើយងាកមករៀនជំនាញដើម្បីស្វែងរកការងារធ្វើ។ និយោជកជាច្រើនបានផ្ដល់ការបណ្ដុះបណ្ដាល ដើម្បីលើកកម្ពស់ផលិតភាព ភាពបត់បែន ការចេះជំនាញសព្វគ្រប់ និងការចេះសម្របទៅនឹងកន្លែងការងារ និងដើម្បីធានាបាននូវការផ្លាស់ប្ដូរដ៏រលូននៅកន្លែងការងារ។ ការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈទាក់ទងនឹងជំនាញកាត់ដេរ សម្រាប់ឧស្សាហកម្ម ជាឧទាហរណ៍នៃការបណ្ដុះបណ្ដាលអំពីការងារ។ បច្ចុប្បន្ន វិស័យកាត់ដេរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្លៀកបំពាក់ឯកជនបានខ្ចីប្រាក់ពីទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍ ដើម្បីបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលអ្នកជំនាញគ្រប់គ្រងវិស័យកាត់ដេរ។ ក្នុងវិស័យបដិសណ្ឋារកិច្ច ភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានបង្កើតឡើង ដើម្បីបង្កើតសាលាបង្រៀនធ្វើម្ហូបថ្នាក់ជាតិ។

### ១០.២.២. កម្រិតនៃការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ

ប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ មានការបណ្តុះបណ្តាល ៦ កម្រិត ក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ៖

១. **ការបណ្តុះបណ្តាល** ត្រឹមកម្រិតវិញ្ញាបនបត្រ ៖ មានរយៈពេល ៤ ទៅ ៦ខែ ដែលផ្តល់ការបណ្តុះបណ្តាលដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. **ការបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ (កម្រិត ១ដល់ ៣)**៖ សម្រាប់ការបណ្តុះបណ្តាលជំនាញអាជីវកម្ម ក្រោយថ្នាក់ទី ៩ ដែលផ្តល់ការបណ្តុះបណ្តាលដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (សម្រាប់ឆ្នាំទី១ ទី២ និងទី៣)។

៣. **ការបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ** ៖ ថ្នាក់បរិញ្ញាបត្ររង ១២ + ២[280] ដែលផ្តល់ការបណ្តុះបណ្តាលដោយវិទ្យាស្ថានពហុបច្ចេកទេស។ បច្ចុប្បន្ន វិទ្យាស្ថានពហុបច្ចេកទេស មានចំនួន ៧ ដែលស្ថិតក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងនោះ រួមមានវិទ្យាស្ថានពហុបច្ចេកទេសជាតិកម្ពុជា វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ (PPI) វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI) វិទ្យាស្ថានពហុបច្ចេកទេសបាត់ដំបង (PPI) វិទ្យាស្ថានពហុបច្ចេកទេសនៅខេត្តបាត់ដំបង និងវិទ្យាស្ថានជាតិពាណិជ្ជកម្ម (NIB)។ វិទ្យាស្ថានទាំងនេះបង្កើតឡើងជាមជ្ឈមណ្ឌលជាតិ ដើម្បីពង្រឹងសមត្ថភាពជំនាញសាងសង់ មេកានិក និង បច្ចេកវិទ្យាព័ត៌មាន/ពាណិជ្ជកម្ម។ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស(NTTI) ផ្តល់ការបណ្តុះបណ្តាលគរុនិស្សិត និងដើរតួនាទីជាមជ្ឈមណ្ឌលប្រមូលផ្តុំ និងសម្របសម្រួលការរៀនសូត្រជាដៃគូ ចែករំលែកចំណេះដឹង និងការសម្រេចចិត្តមិនផ្លូវការ។

៤. **កម្រិតបរិញ្ញាបត្រ** ៖ ក្រោយបញ្ចប់មធ្យមសិក្សាទុតិយភូមិ ១២ + ៤ (៤ ឬ៥ ឆ្នាំ សម្រាប់វិស្វករ)

[280] BTS Level in France

### ១០.២.៣. ការចុះឈ្មោះចូលរៀនវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ

ចំនួនសិស្សចុះឈ្មោះចូលរៀនកម្មវិធីអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានកើនឡើងពី ២៧ ៨៩៤នាក់ នៅឆ្នាំ ២០០៥ រហូតដល់ ១៦៨ ៦៣០នាក់ នៅឆ្នាំ២០០៩។ កំណើននៃការចុះឈ្មោះចូលរៀននេះ មួយផ្នែកធំបណ្ដាលមកពីការចុះឈ្មោះចូលរៀនកម្មវិធីបណ្ដុះបណ្ដាលរយៈពេលខ្លី ដែលទទួលបានជំនួយឧបត្ថម្ភពីរដ្ឋ បានកើនឡើងពី ២៤,៥% នៅឆ្នាំ ២០០៤ រហូតដល់ ៦៩,៥% នៅឆ្នាំ២០០៩។ កំណើននេះឆ្លុះបញ្ចាំងឱ្យឃើញថា សិស្សដែលបានបញ្ចប់ការសិក្សាមួយចំនួនធំ (៦៩,៥%) បានចូលរៀនវគ្គបណ្ដុះបណ្ដាលបឋមរយៈពេលខ្លី (៤-៦សប្ដាហ៍) នៅមជ្ឈមណ្ឌលអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈសាធារណៈ។

ថ្វីបើយ៉ាងនេះក្ដី ចាប់តាំងពីឆ្នាំ២០០៩ មក ចំនួនសិស្សចុះឈ្មោះចូលរៀនការបណ្ដុះបណ្ដាលវិជ្ជាជីវៈ បាន និងកំពុងថយចុះ។ ចំនួនសិស្សផ្នែកបច្ចេកទេស សិស្សទើបបញ្ចប់មធ្យមសិក្សាទុតិយភូមិ និងសិស្សក្រោយបញ្ចប់មធ្យមសិក្សាទុតិយភូមិ ដែលបានចុះឈ្មោះចូលរៀនការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានថយចុះពី ៣,៧% នៅឆ្នាំ ២០០៥ មកនៅត្រឹម ០,៧៩% នៅឆ្នាំ២០០៩។ សិស្សដែលបានបញ្ចប់មធ្យមសិក្សាទុតិយ-ភូមិចំនួន ៣៥,៥%បានចូលរៀននៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលរបស់ឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល។ សិស្សចុះឈ្មោះចូលរៀននៅគ្រឹះស្ថានរដ្ឋ ក្នុងរាជធានីភ្នំពេញ ឬនៅថ្នាក់ជាតិ ហាក់មានចំនួនថយចុះ លើកលែងតែនៅកម្រិត ៥ ដែលបានកើនឡើងតិចតួច។

*តារាងទី៣២ ៖ TVET និងការចុះឈ្មោះចូលរៀននៅកម្ពុជា*

| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|
| ការចុះឈ្មោះចូលរៀន TVET | ២៤ ៥៨៧ | ២៧ ៨៩៤ | ៤៧ ៩៨៦ | ៨៨ ៣៦៧ | ១១៣ ៦៤៨ | ១៦៨ ៦៣០ |
| ការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាទុតិយភូមិ | | | ២០៤ ៩២៥ | ២២២ ២៧១ | ២៦០ ៩៦៥ | ២៩២ ៤២៣ |

*ប្រភព ៖ NIS និង ILO ,លោក អ៊ុន លាង ,កំណែទម្រង់កម្មវិធីមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ៖ ទំនាក់ទំនងរវាងការងារ និងការអប់រំកម្រិតឧត្ដមសិក្សា ទំព័រ ២៣។*

គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈបានលើកឡើងពីផលវិបាករបស់ខ្លួន ក្នុងការស្វែងរកសិស្សមានសមត្ថភាព ដើម្បីទទួលបានអាហារូបករណ៍។ ជួនកាល គ្រឹះស្ថានទាំងនោះ ផ្ដល់អាហារូបករណ៍ជាច្រើនកន្លែង ប៉ុន្តែសិស្សគ្មានសមត្ថភាពទទួលបានអាហារូបករណ៍ទាំងនោះឡើយ។ ការជ្រើសរើសសិស្សទទួលអាហារូបករណ៍ ចាំបាច់ត្រូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធ្វើឱ្យបានតឹងរ៉ឹង ដើម្បីធានាបាននូវគុណភាពអប់រំ។ ស្ថានការណ៍នេះ ធ្វើឱ្យវិស័យសាធារណៈ ប្រឈមនឹងភាពចម្រូងចម្រាស ពីព្រោះរដ្ឋមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ផ្តល់អាហារូបករណ៍ដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែមិនអាចស្វែងរកសិស្សដែលមានលទ្ធផលសិក្សាល្អ ឱ្យទទួលបានអាហារូបករណ៍ ដោយសារការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា នៅមានភាពខ្សោយនៅឡើយ។

នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលភូមិភាគ ការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិត ១ មានការកើនឡើង លើកលែងតែនៅខេត្តស្វាយរៀង ដែលការចុះឈ្មោះរបស់សិស្សបានថយចុះ។ ជាទូទៅ លទ្ធផលបង្ហាញថា មជ្ឈមណ្ឌលទាំងនោះ គួរផ្តោតជាសំខាន់លើការបង្កើនចំនួនសិស្សចុះឈ្មោះចូលរៀន ដែលកំពុងតែមានកម្រិតទាប ហើយដែលមិនទាន់បានផ្តោតជាសំខាន់លើការបណ្តុះបណ្តាលផ្នែកឧស្សាហកម្មនៅឡើយ។ នៅឆ្នាំ២០១០-២០១១ ការចុះឈ្មោះចូលរៀនសរុបនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមានចំនួន ៣៧ ៤១៤នាក់ (ក្នុងនោះ សិស្សស្រី មាន ៥៩%) រីឯការចុះឈ្មោះចូលរៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលឯកជន មានចំនួន ៤៩ ៥១១នាក់ (៤១%ជាសិស្សស្រី)។ ជាង៧០%នៃសិក្ខាកាមសរុប បានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍជំនាញកសិកម្ម ដែលតួលេខនេះ ស្មើនឹងចំនួនកម្លាំងពលកម្មដែលបានបម្រើការងារក្នុងវិស័យកសិកម្ម។ វគ្គបណ្តុះបណ្តាលមេកានិកមូលដ្ឋាន និងកាត់ដេរ ក៏កំពុងមានតម្រូវការខ្ពស់ផងដែរ។

អ្នកស្វែងរកការងារធ្វើ ដែលមានវិញ្ញាបនបត្របញ្ចប់ការសិក្សាផ្នែកអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងប្រព័ន្ធ មានចំនួនត្រឹមតែ ៣០% ប៉ុណ្ណោះ។ កម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្រ និងវិញ្ញាបនបត្រក្នុងប្រព័ន្ធ នៅមានកម្រិតនៅឡើយ ហើយគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស ផ្តល់តែវគ្គបណ្តុះបណ្តាលផ្នែកជួសជុលម៉ាស៊ីនត្រជាក់ ជួសជុលរថយន្ត មេកានិក និងអគ្គិសនី ត្រឹមកម្រិតវិញ្ញាបនបត្រប៉ុណ្ណោះ ។

លទ្ធភាពចុះឈ្មោះចូលរៀនរបស់សិស្ស ក្នុងវិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈចាប់ពីកម្រិត ២ ដល់ កម្រិត ៥ នៅមានបរិមាណតិចតួចនៅឡើយ។ ក្នុងនោះ គេសង្កេតឃើញថា ការចុះឈ្មោះចូលរៀននៅកម្រិត ៥ មានប្រហែល ៣០% នៃការចុះឈ្មោះចូលរៀនសរុប ក្នុងគ្រឹះស្ថានរដ្ឋដែលផ្តល់ការបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ និងបរិញ្ញាបត្ររង។ សម្រាប់កម្រិត ២, ៣ និង ៤ គ្រឹះស្ថានរដ្ឋ អាចស្រូបទាញសិស្សឱ្យចុះឈ្មោះចូលរៀន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានត្រឹមតែ ១០% នៃការចុះឈ្មោះសរុបប៉ុណ្ណោះ ដោយសារកង្វះអគារសិក្សា និងសម្ភារបរិក្ខារ។

របាយការណ៍ថ្នាក់ជាតិប្រចាំឆ្នាំ ២០១០ បានបង្ហាញថា សិស្សដែលបានបញ្ចប់កម្មវិធីបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្ររយៈពេលវែង មានចំនួនត្រឹមតែ ២,៨% ប៉ុណ្ណោះ។ ការធ្លាក់ចុះនូវចំនួនសិស្សចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសរយៈពេលវែង ធ្វើឱ្យសិស្សជ្រើសរើសជំនាញខុស ដោយសារតម្រូវការកម្លាំងពលកម្មជាង ៥០%ទាមទារឱ្យពលករ និងអ្នកបច្ចេកទេស មានជំនាញបច្ចេកទេស។

ការចុះឈ្មោះចូលរៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាល មានចំនួនទាបជាងការចុះឈ្មោះចូលរៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាបណ្តុះបណ្តាលឯកជន ដែលផ្តល់ការបណ្តុះបណ្តាលដូចគ្នា។ មជ្ឈមណ្ឌលបណ្តុះបណ្តាលជាច្រើន ប្រឈមនឹងបញ្ហាមួយចំនួន ដូចជាគ្មានឧបករណ៍ទំនើបៗ វគ្គបណ្តុះបណ្តាលចាស់ៗ ការបង្រៀនខ្សោយ និងសិស្សមានការសិក្សាខ្សោយ។ ស្ថានភាពយ៉ាប់យ៉ឺន និងកេរ្តិ៍ឈ្មោះមិនសូវល្អ ពាក់ព័ន្ធនឹងការអប់រំ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ ធ្វើឱ្យមាតាបិតាសិស្ស មិនត្រឹមតែអល់អែក ក្នុងការបញ្ជូនកូនរបស់ខ្លួនមករៀននៅសាលាបច្ចេកទេសប៉ុណ្ណោះទេ ថែមទាំងឃាត់ឃាំងពួកគេ មិនឱ្យមករៀនជំនាញបច្ចេកទេសទៀតផង។

## ១០.៣. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

មូលនិធិសម្ធលសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានបង្ហាញខាងក្រោម បានផ្តល់អត្ថប្រយោជន៍ដល់សិស្សសរុប ១១៤ ១៤២នាក់ (ក្នុងនោះ សិស្សស្រីមានចំនួន ៥៦ ៨៨២ នាក់)។ មូលនិធិទាំងនោះរួមមាន ៖

១. មូលនិធិបណ្តុះបណ្តាលថ្នាក់ជាតិ (NTF) ដែលគ្រប់គ្រងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. កម្មវិធីបណ្តុះបណ្តាលជំនាញដែលមានលិខិតបញ្ជាក់ (Voucher Skill Training Programme) ក្រោមជំនួយឧបត្ថម្ភរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់ក្រុមងាយរងគ្រោះនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល PTCs។

៣. មូលនិធិពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលផ្តោតជាសំខាន់លើការអភិវឌ្ឍជំនាញ និងសហគ្រិនភាព។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៤. កម្មវិធីស្ពានចម្លងស្ដីពីបច្ចេកវិទ្យាក្រោយប្រមូលផល និងជំនាញវិជ្ជាជីវៈសម្រាប់យុវជនគ្មានការងារធ្វើ និងមិនបានចូលសាលារៀន។

ការផ្ដល់ហិរញ្ញប្បទានដល់គ្រឹះស្ថានបណ្ដុះបណ្ដាលរបស់រដ្ឋភាគច្រើន អាស្រ័យលើម្ចាស់ជំនួយ ឬរដ្ឋាភិបាល។ ការចំណាយរបស់រដ្ឋាភិបាលទៅលើការអប់រំ និងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១១ មានទឹកប្រាក់ប្រមាណជា ៣,៣លានដុល្លារអាមេរិក ដោយក្នុងនោះ ទឹកប្រាក់ចំនួន ១,៦លានដុល្លារ យកទៅចំណាយលើការបណ្ដុះបណ្ដាលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ តួលេខនេះបានកើនឡើង ៥៥% ក្នុងមួយឆ្នាំ ចាប់តាំងពីមានការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅឆ្នាំ២០០៥ មក។ ចំណាយលើប្រាក់បៀវត្សគោល និងថ្លៃសម្ភារបរិក្ខារមានទឹកប្រាក់សរុប ១,២លានដុល្លារអាមេរិក។ នៅឆ្នាំ២០១២ ខ្ទង់ចំណាយបានកើនឡើងគួរឱ្យកត់សម្គាល់រហូតដល់ ៨,៨លានដុល្លារអាមេរិក (កំណើនជិត ១៧០%)។ កំណើនដ៏ខ្លាំងក្លានេះបណ្ដាលមកពីការវិនិយោគដ៏ច្រើនសន្ធឹក-សន្ធាប់លើសម្ភារ និងការបង្កើនជំនួយដល់កម្មវិធីបណ្ដុះបណ្ដាលក្រៅប្រព័ន្ធ។

រដ្ឋាភិបាលនៅតែបន្តស្វែងរកមធ្យោបាយសម្រាប់ផ្ដល់ហិរញ្ញប្បទានគ្រប់គ្រាន់ និងមានស្ថិរភាពដល់គ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈសាធារណៈ ដើម្បីផ្ដល់កម្មវិធីបណ្ដុះ-បណ្ដាលប្រកបដោយគុណភាព។ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានចេញប្រកាសជាបន្តបន្ទាប់នៅឆ្នាំ២០១១ និង២០១២ ដើម្បីឱ្យវិទ្យាស្ថានបណ្ដុះបណ្ដាលការអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈសាធារណៈមួយចំនួន បើកវគ្គបណ្ដុះបណ្ដាលបង់ថ្លៃ ដើម្បីទទួលបានប្រាក់ចំណូលខ្លះៗពីសិស្សបង់ថ្លៃ និងនិយោជកមួយចំនួន។ គោល-នយោបាយនេះ គាំទ្រដល់ការអនុវត្តផែនការអាជីវកម្មដែលបង្កើតឡើងដោយគ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈសាធារណៈ ក្រោមកម្មវិធីគម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំបណ្ដុះ-បណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។ ម្យ៉ាងវិញទៀត ការបណ្ដុះបណ្ដាលរបស់គ្រឹះស្ថានរដ្ឋភាគច្រើនទទួលបានហិរញ្ញប្បទានតាមរយៈការផ្ដល់អាហារូបករណ៍ពីរដ្ឋាភិបាល និងដៃគូម្ចាស់ជំនួយ។

ចំពោះមជ្ឈមណ្ឌលបណ្ដុះបណ្ដាល ដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល ឬអ្នកផ្ដល់សេវាគិតប្រាក់កម្រៃ គេសង្កេតឃើញថា គ្រឹះស្ថានធំៗកំពុងស្រូបទាញសិស្សចូលរៀនបានកាន់តែច្រើនឡើងៗ ផ្ទុយពីគ្រឹះស្ថានតូចៗ ដែលកំពុងប្រឈមនឹងការថយសិស្ស ឬចំនួនសិស្សនៅថេរដដែល។ បញ្ហានេះរាំងស្ទះដល់ការធានានូវនិរន្តរភាពរបស់គ្រឹះស្ថានទាំងនោះ ដោយសារគ្រឹះស្ថានដែលកំពុងជួបបញ្ហា ត្រូវទម្លាក់ថ្លៃសេវាចូលរៀនរបស់ខ្លួន។

### ១០.៤. តម្រូវការជំនាញ

ជាមធ្យម កម្លាំងពលកម្មថ្មីៗប្រមាណជា ១លាននាក់ ក្នុងមួយឆ្នាំៗ បានហក់ចូលមកក្នុងទីផ្សារការងារនៅកម្ពុជា នៅចន្លោះឆ្នាំ២០១២ និង២០១៥។ ថ្វីបើយ៉ាងនេះក្តី កំណើនការងារភាគច្រើននឹងផ្តល់ឱកាសការងារដល់ពលករគ្មានជំនាញ ក្នុងវិស័យកសិកម្មមិនមែនការដាំដុះ និងវិស័យសេវាកម្ម។ ទាក់ទងនឹងការបង្កើនជំនាញ ក្រុមពលករដែលមានជំនាញមធ្យម ដូចជា បុគ្គលិកបម្រើសេវាកម្មក្នុងវិស័យទេសចរណ៍ អចលទ្រព្យ និងសិប្បករក្នុងវិស័យកាត់ដេរ និងរោងចក្រឈើ/ក្រដាស ទទួលបានប្រយោជន៍ពីកំណើនការងារនេះ ច្រើនជាងក្រុមពលករដែលមានជំនាញខ្ពស់។ ក្រុមពលករដែលមានជំនាញខ្ពស់ ហើយដែលត្រូវបានគេរំពឹងថានឹងទទួលបានការងារកាន់តែច្រើន មានតែអ្នកជំនាញខាងអចលទ្រព្យ និងវិស័យអាជីវកម្ម និងអ្នកបច្ចេកទេសខាងអគ្គិសនី ឧស្ម័ន និងទឹកប៉ុណ្ណោះ។

គំរូព្យាករណ៍របស់កូរ៉េ ដែលប្រើប្រាស់ដោយលោក Jeong បង្ហាញថា ក្រុមពលករជំនាញ ៤ ក្រុម ដែលមានកំណើនខ្លាំងជាងគេនោះ រួមមាន ពលករគ្មានជំនាញ បុគ្គលិកបម្រើសេវាកម្ម សិប្បករ និងស្មៀន។ កំណើនការងារជាមធ្យមសម្រាប់ក្រុមពលករជំនាញទាំងនេះ ក្នុងអំឡុងឆ្នាំ២០១២-២០១៥ មានចំនួន ៥៦៤ ៥៦៨នាក់ សម្រាប់ពលករគ្មានជំនាញ ២៤៤ ៨៨៥នាក់ សម្រាប់បុគ្គលិកបម្រើសេវាកម្ម ១៧៤ ១៦៣នាក់ សម្រាប់សិប្បករ និង ៩៨ ១៦៣នាក់សម្រាប់ស្មៀន។ ផ្ទុយទៅវិញ កសិករ (ពលករមានជំនាញកសិកម្ម) ត្រូវបានគេរំពឹងថានឹងថយចុះមកនៅត្រឹម ៣៦ ៦៩២នាក់ ជាមធ្យមក្នុងមួយឆ្នាំៗ ក្នុងអំឡុងឆ្នាំ ២០១២-២០១៥។

ក្រុមពលករជំនាញ អាចចែកចេញជា ៖ (i) «ក្រុមពលករមានជំនាញខ្ពស់ រាប់បញ្ចូលទាំងអ្នកគ្រប់គ្រង អ្នកជំនាញ អ្នកបច្ចេកទេស និងជាងមេកានិក» (ii) «ក្រុមពលករជំនាញមធ្យម រួមមានបុគ្គលិកបម្រើសេវាកម្ម ស្មៀន និងសិប្បករ» (iii) «ក្រុមពលករមានជំនាញទាប រួមមានពលករគ្មានជំនាញ និងកសិករ»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងទី៣៣ ៖ តម្រូវការជំនាញជាក់ស្ដែង និងតាមការរំពឹងទុក*

| ឆ្នាំ | អ្នកគ្រប់គ្រង | អ្នកជំនាញ | អ្នកបច្ចេកទេស | ស្មៀន | អ្នកផ្តល់សេវា | កសិករ | សិប្បករ | ជាងមេកានិច | អ្នកគ្មានជំនាញ | កងទ័ព |
|---|---|---|---|---|---|---|---|---|---|---|
| ២០០៧ | ៦២ ២៩១ | ២២០ ២៨៩ | **១៩៧ ០៦៥** | ១៣៨ ៩៣៧ | **៨៩១ ៦៥៨** | ៣ ៨២២ ៥៩៥ | **៦៨៧ ០៣៤** | **៦០៩ ៩០១** | ៧៧១ ៧៥៧ | ៣២ ៥២៧ |
| ២០០៨ | ៦០ ៩៩៨ | ២៤៤ ៨១០ | **១៦៣ ២៦៨** | ១៨១ ៩៦៨ | **៧២៤ ៧៦៤** | ៣ ៦១៨ ៩១១ | **៦៩២ ៨០២** | **៦៥៩ ២២៣** | ១ ០៩៦ ២៨៧ | ៣៦ ៧៧៣ |
| ២០០៩ | ៤៣ ៦៣១ | ១៩៤ ៦៦៤ | **៧០ ៧២៤** | ១៩៩ ៩៧០ | **១ ១៩៣ ៩២៤** | ៣ ៧៧៩ ១០៧ | **៩២០ ៨០២** | **២២៥ ១១៥** | ១ ២១៦ ២៩១ | ៥០ ៣៨៣ |
| ២០១០ | ៤៣ ៩២៣ | ២១៣ ៣៨៥ | **៦៨ ០២៦** | ១៨៣ ២៩៧ | **១ ៣២១ ១៦៨** | ៣ ៥៦៦ ២៧៦ | **១ ០០៣ ៩៥១** | **២៥៥ ៣១៦** | ១ ២៥៧ ០៧៥ | ៦០ ៩៩២ |
| ២០១១ | ៥១ ៧៩១ | ១៩៥ ៩៣១ | **៧៥ ៨០៣** | ២៩៨ ២៨១ | **១ ៩៧៤ ៨៣១** | ៣ ៣៩៤ ០៥២ | **១ ២២៤ ៩៧៩** | **៣២៨ ៨៩៦** | ១ ៦៨៦ ២៩៩ | ៦០ ៣៩២ |
| ២០១២ | ៥១ ៧៩១ | ១៩៥ ៩៣១ | **៧៥ ៨០៣** | ២៩៨ ២៨១ | **១ ៩៧៤ ៨៣១** | ៣ ៣៩៤ ០៥២ | **១ ២២៤ ៩៧៩** | **៣២៨ ៨៩៦** | ១ ៦៨៦ ២៩៩ | ៦០ ៣៩២ |
| ២០១៣ | ៥៤ ៥២៤ | ១៩៦ ២៩៨ | **៨២ ៩៦២** | ៣០៧ ៦៧៦ | **១ ៦៨៧ ៩៧៦** | ៣ ៣៦០ ៩៨២ | **១ ៣៧២ ៩៤០** | **៣៣១ ០៧៧** | ២ ១៩៩ ៧១៣ | ៥៩ ០៩១ |
| ២០១៤ | ៥៩ ៩២៧ | ២៣១ ៧៣៣ | **១០៣ ៩០៦** | ៩០១ ១៨២ | **១ ៨៦៧ ៣៩២** | ៣ ២៨១ ៧០៦ | **១ ៥៣៨ ៧១៤** | **៣៧៩ ៩១៤** | ២ ៦៨០ ៣៩២ | ៥៩ ៨៨៦ |
| ២០១៥ | ៦៩ ៥៩៥ | ២៩៦ ៧៦១ | **១៣៣ ១៩៥** | ៥៩២ ៧៧១ | **២ ២០៩ ៨៨៦** | ២ ២៨៣ ៩៧៥ | **១ ៧៩៧ ៧៧២** | **៣៩១ ៩៩៩** | ៣ ៣៨០ ០០៤ | ៦៣ ១៩៩ |

*ប្រភព ៖ របៀបវារៈស្ដីពីគោលនយោបាយកម្ពុជាសម្រាប់ការអភិវឌ្ឍជំនាញឧស្សាហកម្ម ប្រព័ន្ធឧស្សាហកម្ម និងឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម ឆ្នាំ២០១៣*

ថ្វីបើយ៉ាងនេះក្ដី ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ មិនបានបំពេញតម្រូវការរបស់និយោជកឡើយ។ ការងារមានចំនួន ២៥ ០០០កន្លែង ប៉ុន្តែយុវជនតែ ៧ ៨១៦នាក់ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀនវគ្គបណ្ដុះបណ្ដាល ការអប់រំ និងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលរបស់រដ្ឋ។ ក្នុងចំណោមយុវជនទាំងនេះ ជាង ៥០% កំពុងសិក្សាវគ្គបណ្ដុះបណ្ដាលកម្រិត១ ដែលអាចមានរយៈពេលពី២ ឬ ៣ សប្ដាហ៍ទៅ ៦ខែ។ ក្នុងវគ្គបណ្ដុះបណ្ដាលនេះ មុខវិជ្ជាកសិកម្មមានប្រជាប្រិយភាពខ្លាំងជាងគេ។ ការធ្វើផែនទីតម្រូវការឧស្សាហកម្ម និងការព្យាករជំនាញដែលកំពុងមានតម្រូវការក្នុងទីផ្សារហាក់នៅមានតិចតួច។ អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្ដល់សេវាអប់រំ បណ្ដុះ-បណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនភាគច្រើន ផ្ដល់ការបណ្ដុះបណ្ដាលកម្រិត១ រីឯការបណ្ដុះបណ្ដាលកម្រិត ២, ៣, ៤ និង ៥ មានតិចតួចប៉ុណ្ណោះ។

មុខតំណែងទំនេរភាគច្រើន ដែលនិយោជកកំពុងត្រូវការ គឺអ្នកកាន់ និងដំឡើងម៉ាស៊ីនរោងចក្រ។ បុគ្គលិកទាំងនេះដែលបានបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិ មានសមត្ថភាពអាន និងសរសេរ យល់ច្បាស់ពីការណែនាំស្ដីពីគោលនយោបាយពាក់ព័ន្ធនឹងសុវត្ថិភាព ការសង្គ្រោះបន្ទាន់ និងសុខភាព។ និយោជកក្នុងវិស័យកាត់ដេរសង្កត់ធ្ងន់ថា វាជាការប្រសើរណាស់ ប្រសិនបើពួកគេអាចមានអ្នកកាន់ម៉ាស៊ីនដែលយល់ច្បាស់អំពីគោលគំនិតក្នុងការផ្ទេរជំនាញ ហើយអាចបំប៉នឱ្យចេះប្រើម៉ាស៊ីនខុសៗគ្នាមួយចំនួន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រៅពីប្រឈមនឹងការផ្លាស់ប្ដូរការងារញឹកញាប់របស់បុគ្គលិកជំនាញមធ្យម និងខ្ពស់ និយោជកធំៗ ក៏កំពុងប្រឈមនឹងកង្វះនិយោជិកជំនាញផងដែរ។ កង្វះជំនាញសំខាន់ៗរួមមាន ៖ (i) ជំនាញមូលដ្ឋាន និងបំណិនជីវិត (ii) ជំនាញទំនាក់ទំនង (iii) ការធ្វើការជាក្រុម (iv) ការដោះស្រាយបញ្ហា (v) ជំនាញគ្រប់គ្រង និងត្រួតពិនិត្យ (vi) ជំនាញថ្មីកដៃ (vii) បទពិសោធ និងភាពចាស់ទុំ។ និយោជកក៏ប្រឈមនឹងបញ្ហាផ្សេងទៀតដូចជា ៖ (i) ពលករ មិនបានបំពេញការងាររបស់ខ្លួន ឱ្យអស់ពីលទ្ធភាព (ii) ខ្វះការលើកទឹកចិត្ត និងភាពម្ចាស់ការលើកខ្លួនឯង (iii) សហជីពកម្មករបង្កើនប្រាក់ចំណូលរបស់ខ្លួន (iv) ការយកនយោបាយជាខែល។

កង្វះជំនាញសំខាន់ៗនៅកម្ពុជារួមមាន សមត្ថភាពទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ការធ្វើការជាក្រុម និងការដោះស្រាយបញ្ហា ការគ្រប់គ្រង និងការត្រួតពិនិត្យ និងជំនាញថ្មីកដៃ។

ចំណែកនិយោជកធំៗត្រូវការ ៖ (i) អ្នកកាន់ និងដំឡើងម៉ាស៊ីនពេងចក្រ (ii) បុគ្គលិកបម្រើសេវាកម្ម និងផ្នែកលក់ (iii) អ្នកបច្ចេកទេស អ្នកជំនាញពាក់ព័ន្ធ និងបុគ្គលិកស្មៀន (iv) ការងារមូលដ្ឋាន (v) បុគ្គលិកសិប្បកម្ម និងអាជីវកម្ម និង (vi) អ្នកជំនាញវិជ្ជាជីវៈ និងអ្នកគ្រប់គ្រង។

ដូច្នេះ គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ គួរមានយុទ្ធសាស្ត្រជាក់លាក់ ដើម្បីបំពេញតម្រូវការជំនាញក្នុងតំបន់របស់ខ្លួន ហើយគួរចងចាំថា និយោជកធំៗ មិនមែនសុទ្ធតែតំណាងឱ្យកន្លែង ដែលមានតម្រូវការជំនាញផ្នែកណាមួយជាក់លាក់ឡើយ។

បញ្ហាប្រឈមដែលវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ កំពុងជួបប្រទះរួមមាន ៖ ការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈបច្ចុប្បន្នមិនអាចបំពេញតម្រូវការរបស់និយោជកក្នុងវិស័យនេះបានឡើយ ពីព្រោះ (i) ការបណ្ដុះបណ្ដាលសម្រាប់ឧស្សាហកម្មនៅមានកម្រិត (ii) កង្វះគ្រូបច្ចេកទេសដែលមានសមត្ថភាព ហើយជំនាញវិជ្ជាជីវៈ និងចំណេះដឹងរបស់គ្រូ ការអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅមានកម្រិត (iii) ជំនាញសហគ្រិនភាព មិនត្រូវបានគេផ្ដោតជាសំខាន់ ហើយនៅពេលដែលវគ្គបណ្ដុះ-បណ្ដាលជំនាញពាណិជ្ជកម្ម ការគ្រប់គ្រងកុំព្យូទ័រ និងភាសាអង់គ្លេសមានសន្ទុះខ្លាំង វគ្គបណ្ដុះបណ្ដាលបច្ចេកទេសទាក់ទងនឹងការធ្វើអាជីវកម្មបែបប្រពៃណី បែរជាធ្លាក់ចុះខ្លាំងទៅវិញ (iv) កង្វះព័ត៌មានទីផ្សារការងារ (v) ទំនាក់ទំនងជាមួយសហគ្រាស និងក្រុមហ៊ុន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នានានៅខេត្តឆ្ងាយ ពីព្រោះនិយោជក មិនសូវដឹង ឬយល់អំពីការផ្ដល់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅតំបន់របស់ខ្លួន (vi) កង្វះការទទួលបានឱកាសបណ្ដុះបណ្ដាលជាផ្លូវការនៅតំបន់ជនបទ (vii) កង្វះភាពសហការ និងភាពបត់បែនក្នុងការផ្ដល់ការបណ្ដុះ-បណ្ដាល (viii) ប្រភពធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់ កង្វះសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការទីកន្លែងបណ្ដុះបណ្ដាល កង្វះឧបករណ៍ សម្ភារ និងកម្មវិធីបណ្ដុះបណ្ដាល អគារបណ្ដុះបណ្ដាលគ្មានការថែទាំត្រឹមត្រូវ ហើយការបណ្ដុះបណ្ដាលមានគុណភាពទាប និងការអនុវត្តជំនាញផ្ទាល់បានតិចតួច។

ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈស្ទើរតែទាំងអស់ ផ្ដោតជាសំខាន់លើការបណ្ដុះបណ្ដាលកម្រិត១ ដែលក្នុងនោះ វិស័យសាធារណៈផ្ដោតជាសំខាន់លើការ-បណ្ដុះបណ្ដាលជំនាញកសិកម្ម រីឯវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ផ្ដោតលើការបណ្ដុះបណ្ដាលជំនាញផ្សេងៗគ្នាជាច្រើន។ ទោះបីជាការបណ្ដុះបណ្ដាលកម្រិត១បង្ហាញថា រយៈពេលបណ្ដុះបណ្ដាលមានពី៤ ទៅ៦ខែ ក៏ដោយ ប៉ុន្តែការបណ្ដុះបណ្ដាលជាក់ស្ដែងផ្ទុយពីអ្វីដែលបានលើកឡើង។ គ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈរដ្ឋផ្ដល់ការបណ្ដុះបណ្ដាលរយៈពេលខ្លី ត្រឹមពីរ ឬបីថ្ងៃ ក៏ប៉ុន្តែវិស័យឯកជន ឬអង្គការមិនមែនរដ្ឋាភិបាលផ្ដល់ការបណ្ដុះបណ្ដាលរហូតដល់១ឆ្នាំ។

ទោះបីសិស្សទើបបញ្ចប់ការសិក្សាពីគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅកម្រិតមូលដ្ឋាន បង្ហាញនិន្នាការត្រៀមខ្លួនជាស្រេចសម្រាប់បំពេញការងារក៏ដោយ ពួកគេនៅតែខ្វះជំនាញមូលដ្ឋានសំខាន់ៗដដែល។ ក្រុមហ៊ុនស្ទើរតែទាំងអស់នៅតែត្រូវផ្ដល់ការបណ្ដុះបណ្ដាលជំនាញមូលដ្ឋានដល់ពួកគេ នៅកន្លែងធ្វើការរបស់ខ្លួន។

## ១០.៥. ឧបសគ្គ និងបញ្ហាប្រឈម

ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់កម្ពុជា។ ជំនាញបច្ចេកទេសជាជំនាញដែលកំពុងមានតម្រូវការខ្លាំងនៅក្នុងទីផ្សារក្នុងស.វ.ទី២១ ហើយកង្វះបុគ្គលិកដែលមានសមត្ថភាពខ្ពស់ខាងផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ ធ្វើឱ្យប្រទេសជាច្រើន ប្រឈមនឹងការខាតបង់ផ្នែកសេដ្ឋកិច្ចជាច្រើន។ ដូច្នេះ ការធ្វើឱ្យការបណ្ដុះបណ្ដាលវិជ្ជាជីវៈកាន់តែទាក់ទាញជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរបំផុត។

នៅប្រទេសកម្ពុជា ចំណេះដឹងផ្នែកទ្រឹស្ដី និងការអនុវត្ត ដែលទទួលបានពីសាលារៀន និងតាមរយៈបទពិសោធការងារពិតជាមានសារៈសំខាន់ណាស់សម្រាប់អភិវឌ្ឍ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំនាញបច្ចេកទេសរបស់បុគ្គលិកគ្រប់គ្រង/បុគ្គលិកវិជ្ជាជីវៈ និងបុគ្គលិកជំនាញផ្នែកផលិត-កម្ម។ ម្យ៉ាងវិញទៀត និយោជកចាត់ទុកថា ចំណេះដឹងផ្នែកគណិតវិទ្យា និងអក្ខរកម្ម ដែលទទួលបានតាមរយៈការអប់រំនៅកម្រិតបឋមសិក្សា ជាមូលដ្ឋានគ្រឹះសម្រាប់កសាងសមត្ថ-ភាពបុគ្គលិក។ ជំនាញត្រិះរិះពិចារណា និងអាកប្បកិរិយា ក៏ត្រូវបានចាត់ទុកថាមានសារៈសំខាន់ចំពោះអ្នកគ្រប់គ្រង និងអ្នកជំនាញវិជ្ជាជីវៈផងដែរ។ រីឯជំនាញសិក្សាមូលដ្ឋានត្រូវបានគេចាត់ទុកថាជាបុរេលក្ខខណ្ឌដ៏សំខាន់សម្រាប់បុគ្គលិកជំនាញផលិតកម្ម។ ក្នុងចំណោមជំនាញពាក់ព័ន្ធនឹងអាកប្បកិរិយា ក្រុមហ៊ុនជាច្រើនបានផ្តល់តម្លៃខ្ពស់លើជំនាញទំនាក់ទំនង និងសមត្ថភាពធ្វើការដោយឯករាជ្យ។

បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាកំពុងផ្តោតជាសំខាន់ លើការធ្វើពិពិធភាវូបនីយកម្មឧស្សាហកម្ម និងការងារលើតម្លៃបន្ថែមកាន់តែច្រើន។ ដើម្បីឱ្យឧស្សាហកម្មទទួលបានអត្ថប្រយោជន៍កាន់តែច្រើន ពីយុវជនជំនាញដែលទើបបញ្ចប់ការសិក្សា ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជរដ្ឋាភិបាលចាំបាច់ត្រូវធានាថា ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានការសម្របសម្រួលត្រឹមត្រូវ អាចជឿទុកចិត្តបាន និងជាប់ទាក់ទងគ្នា។ ម្យ៉ាងវិញទៀត វិស័យការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈចាំបាច់ត្រូវមានភាពបត់បែន ហើយផ្តោតជាសំខាន់លើការផ្លាស់ប្តូរសេដ្ឋកិច្ច ដែលអាចកើតមានឡើង។ ការធ្វើបែបនេះអាចធានាបានថា ការបណ្តុះបណ្តាល ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានទំនាក់ទំនងគ្នា និងមានកម្មវិធីសិក្សាថ្មីៗ ដើម្បីបំពេញតម្រូវការឧស្សាហកម្មដែលកំពុងមានការផ្លាស់ប្តូរ។

### ១០.៨.១. ការលើកកម្ពស់ប្រព័ន្ធអប់រំដែលផ្សារភ្ជាប់ចំណេះខ្ទៅទៅនឹងជំនាញវិជ្ជាជីវៈ

គុណភាពអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ចាំបាច់ត្រូវទទួលបានការយកចិត្តទុកដាក់ជាសំខាន់ ដើម្បីធានាថា ការអប់រំបន្ត និងការបណ្តុះបណ្តាលបន្ថែមទាំងការ-អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងកម្រិតមហាវិទ្យាល័យ អាចផ្តល់កម្លាំងពលកម្មនៅកម្ពុជានាពេលអនាគត ប្រកបដោយជំនាញ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការទីផ្សារការងារ ហើយទទួលបានភាពជឿជាក់ពីឧស្សាហកម្ម។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការនានា ដើម្បីបង្កើនការចុះឈ្មោះចូលរៀនផ្នែកបច្ចេកទេសវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការអាជីវកម្ម។ ផ្ទុយទៅវិញ ការចុះឈ្មោះចូលរៀនមានអត្រាខ្ពស់ជាងតម្រូវការទីផ្សារ ហើយបញ្ហានេះចាំបាច់ត្រូវធ្វើឱ្យវាមានតុល្យភាពគ្នា។ ដើម្បីដោះស្រាយបញ្ហានេះ ប្រព័ន្ធអប់រំពីរផ្នែក «**ចំណេះខ្ទៅ និងជំនាញវិជ្ជាជីវៈ**» គួរត្រូវបានលើកកម្ពស់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈការជំរុញឱ្យមានការសហការគ្នារវាងក្រុមហ៊ុនឯកជនធំៗ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យសិស្សអាចទទួលបានបទពិសោធការងារដំបូងពីក្រុមហ៊ុនទាំងនោះ។

ដើម្បីលើកទឹកចិត្តសិស្សក្មេងៗឱ្យចាប់អារម្មណ៍នឹងការអប់រំវិជ្ជាជីវៈ រាជរដ្ឋាភិបាលកម្ពុជានឹងលើកកម្ពស់ «ប្រព័ន្ធអប់រំពីរផ្នែក» គឺការអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេសនៅវិទ្យាល័យបច្ចេកទេស។ វិទ្យាល័យបច្ចេកទេសនឹងផ្តល់ឱ្យសិស្សនូវវគ្គបណ្តុះបណ្តាលពីរ ដែលអាចឱ្យពួកគេសិក្សាទាំងមុខវិជ្ជាចំណេះទូទៅ ទាំងមុខវិជ្ជាវិជ្ជាជីវៈក្នុងពេលតែមួយ។ កម្មវិធីនេះ នឹងអាចជួយធ្វើឱ្យមុខវិជ្ជាបច្ចេកទេស ទទួលបានការពេញនិយមកាន់តែខ្លាំង ក្នុងចំណោមសិស្សជាច្រើន ពីព្រោះពួកគេមិនចាំបាច់បោះបង់ការអប់រំចំណេះទូទៅ ដើម្បីមកបន្តការអប់រំបច្ចេកទេសឡើយ ពោលគឺពួកគេអាចរៀនទាំងពីរមុខក្នុងពេលតែមួយបាន។

ម្យ៉ាងវិញទៀត វិទ្យាល័យបច្ចេកទេស គួរមានកម្មវិធីបណ្តុះបណ្តាលភាសាបរទេសក្រៅម៉ោង និងកម្មវិធីបណ្តុះបណ្តាលភាសាបរទេសពេញម៉ោង ក្នុងកម្មវិធីសិក្សារបស់ខ្លួន ដើម្បីលើកកម្ពស់សមត្ថភាពភាសាបរទេសរបស់សិស្ស ឱ្យដូចគ្នានឹងសិស្សដែលកំពុងនៅសាលាធម្មតា។ ដូច្នេះ វិទ្យាល័យបច្ចេកទេសត្រូវការថវិកាជាច្រើន ដោយសារចំនួនសិស្សកាន់តែច្រើន នឹងទាមទារនូវសម្ភារ គ្រូ និងបុគ្គលិកបន្ថែម ហើយជំនួយឧបត្ថម្ភលើសិស្សម្នាក់ៗក៏កើនឡើងផងដែរ។

### ១០.៥.២. ការកែលម្អសម្ភាររូបវន្តសម្រាប់អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

សំខាន់ជាងនេះទៀត រដ្ឋាភិបាលនឹងវិនិយោគកាន់តែច្រើនលើការអប់រំបណ្តុះ-បណ្តាលវិជ្ជាជីវៈ(TVET) និងការអប់រំបច្ចេកទេស(TE) ដើម្បីធ្វើឱ្យវិស័យនេះកាន់តែមានភាពទាក់ទាញ។ ការវិនិយោគដ៏ច្រើននេះនឹងផ្តោតជាសំខាន់លើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសគ្រឿងម៉ាស៊ីនទាក់ទងនឹងកន្លែងការងារ ដើម្បីឱ្យសិក្ខាកាមអាចទទួលបានបទពិសោធដូចខ្លួនកំពុងស្ថិតនៅកន្លែងធ្វើការពិតៗ ក្នុងពេលបណ្តុះបណ្តាល ហើយពួកគេអាចត្រៀមខ្លួនជាស្រេច ដើម្បីបំពេញការងារនៅកន្លែងធ្វើការ។ ដើម្បីសម្រេចគោល-បំណងនេះ កម្ពុជាត្រូវផ្លាស់ប្តូរសម្ភាររូបវន្ត និងអគារចាស់ៗនៅសាលាបណ្តុះបណ្តាលវិជ្ជា-ជីវៈ ហើយប្រែក្លាយសាលាទាំងនោះឱ្យទៅជាបរិវេណដ៏ធំទូលាយ ដែលបំពាក់ដោយបច្ចេកវិទ្យាទាន់សម័យ និងផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងឧស្សាហកម្ម។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ១០.៤.៣. ការកែលម្អកម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ទោះបីជាការបំពាក់គ្រឿងម៉ាស៊ីន និងសម្ភារបង្រៀនឱ្យកាន់តែប្រសើរ និងឱ្យជាប់ទាក់ទងទៅនឹងជំនាញឧស្សាហកម្មក៏ដោយ ប៉ុន្តែកង្វះកម្មវិធីសិក្សាសមស្រប និងកង្វះគ្រូបង្រៀនកម្រិត២, ៣ និង ៤ នោះ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្តោតជាចម្បងលើការអភិវឌ្ឍកម្មវិធីសិក្សា និងការងារអាទិភាពដើម្បីយល់ច្បាស់អំពីតម្រូវការរោងជាង និងគ្រឿងចក្រចាំបាច់។

ម្យ៉ាងវិញទៀត សាលាទាំងនោះត្រូវផ្តល់ការបណ្តុះបណ្តាលជំនាញឱ្យបានកាន់តែច្រើន រាប់បញ្ចូលទាំងជំនាញវិស្វកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជីវសាស្ត្រ ការទំនាក់-ទំនង និងព័ត៌មានវិទ្យា វិទ្យាសាស្ត្រសុខាភិបាល ពាណិជ្ជកម្ម គណនេយ្យ វិទ្យាសាស្ត្រសង្គម ប្រព័ន្ធផ្សព្វផ្សាយ និងការផ្សព្វផ្សាយឌីជីថល ដើម្បីបំពេញកង្វះខាតក្នុងការអប់រំ និងការផ្តល់ការបណ្តុះបណ្តាលទាំងមូល។ ក្នុងគ្រឹះស្ថានបណ្តុះបណ្តាលរបស់រដ្ឋ មានតែជំនាញជួសជុលម៉ាស៊ីនត្រជាក់ និងជួសជុលរថយន្ត វិស្វកម្មប៉ុណ្ណោះ ដែលមានការបណ្តុះ-បណ្តាលចាប់ពីកម្រិត២ ដល់៥ នៅថ្នាក់ជាតិ ចំណែកវគ្គបណ្តុះបណ្តាលលើការថែទាំយានយន្ត មានចាប់ពីកម្រិត២ ដល់៥ នៅថ្នាក់ខេត្ត។ ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្តមានផ្តល់វគ្គបណ្តុះបណ្តាលវិស្វកម្មអគ្គិសនីកម្រិត ១, ២, ៣ និង ៥ លើកលែងតែថ្នាក់ខេត្ត ដែលមានការបណ្តុះបណ្តាលជំនាញនេះ នៅកម្រិត៤ដែរ។

ការបណ្តុះបណ្តាល ចាំបាច់ត្រូវធ្វើឱ្យមានស្តង់ដារួមតែមួយ (ឈ្មោះវគ្គបណ្តុះ-បណ្តាល ខ្លឹមសារ ការវាយតម្លៃ និងការប្រឡង) នៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលទាំងអស់ ហើយគ្រឹះស្ថានបណ្តុះបណ្តាលដែលមានកម្មវិធីសិក្សាស្រាប់ ត្រូវចែករំលែកកម្មវិធីសិក្សាគ្នាទៅវិញទៅមក ដើម្បីជៀសវាងការប្រើធនធានជាន់គ្នារវាងគ្រឹះស្ថានរដ្ឋ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។

ការរៀបចំកម្មវិធីសិក្សាសម្រាប់កុមារី និងស្ត្រី ទាក់ទងនឹងការងារបែបប្រពៃណីសម្រាប់ស្ត្រី ដូចជា សូត្រ តម្បាញ។ល។ ក៏ជាកត្តាចាំបាច់ផងដែរ។ ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ជំនាញបែបប្រពៃណីដែលផ្តោតជាសំខាន់លើស្ត្រីភេទ អាចលើកទឹកចិត្តយុវតី និងមាតាបិតាពួកគេ ឱ្យងាកមកជ្រើសរើសការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គួរផ្តោតជាសំខាន់លើការរៀនសូត្រដែលនឹងជះឥទ្ធិពលនាពេលអនាគត មិនមែនជាការបណ្តុះបណ្តាលវគ្គខ្លីដែលមានត្រឹមតែកម្រិតវិញ្ញាបនបត្រ និងការបណ្តុះបណ្តាលដែលធ្វើឱ្យសិស្សមិនអាចចាប់បានជំនាញ ឬការរៀនសូត្រឡើយ។ ដូច្នេះ ការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព និងក្របខណ្ឌគុណវុឌ្ឍិ ពិតជាសំខាន់ណាស់ក្នុងកាលៈទេសៈនេះ ដើម្បីធានាបានថាយុវជនចំណាយពេលវេលាគ្រប់គ្រាន់ដើម្បីរៀនសូត្រ។ រយៈពេលបណ្តុះបណ្តាលត្រូវឆ្លើយតបទៅនឹងជំនាញដែលយកមកបង្រៀនសិស្ស។ ម្យ៉ាងវិញទៀត កម្មវិធីសិក្សាចាំបាច់ត្រូវធ្វើការកែលម្អថ្មីជាប្រចាំ ដើម្បីឱ្យការបណ្តុះបណ្តាលតាមទាន់សន្ទុះនៃការរីក-ចម្រើនផ្នែកបច្ចេកវិទ្យាដ៏លឿនរហ័ស។

## ១០.៤.៤. ការផ្តោតជាសំខាន់លើគ្រូដែលមានសមត្ថភាព

ជំហានទីបីគឺត្រូវលើកកម្ពស់ជំនាញ និងចំណេះដឹងរបស់បុគ្គលិកបង្រៀន ដោយសារអ្នកទាំងនេះជាឆ្អឹងខ្នងនៃការអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលទាំងអស់។ គ្រូដែលមានសមត្ថភាពខ្ពស់ ចាំបាច់ត្រូវបង្រៀនសិស្សឱ្យទទួលបានលទ្ធផលល្អ។ «កង្វះគ្រូ» គឺជាបញ្ហាចោទ។ ប៉ុន្តែការកែលម្អវិធីសាស្ត្របង្រៀនឱ្យកាន់តែប្រសើរ ក៏ជាកត្តាចាំបាច់។ ការលើកទឹកចិត្តគ្រូបង្រៀនឱ្យចូលរួមដោយផ្ទាល់ក្នុងការបណ្តុះបណ្តាលកម្រិតសហគ្រាសជាកត្តាចាំបាច់ ដើម្បីធ្វើឱ្យពួកគាត់ទទួលបានបទពិសោធជីវិតការងារជាក់ស្តែង។ ការបំពាក់សម្ភារ និងបច្ចេកវិទ្យាទំនើបៗសម្រាប់គ្រូបង្រៀន និងការលើកកម្ពស់សមត្ថភាពគ្រូឱ្យចេះប្រើសម្ភារ និងបច្ចេកវិទ្យាទាំងនោះ ក៏ជាកត្តាចាំបាច់ផងដែរ ដើម្បីបង្កើនការអនុវត្តជាក់ស្តែងក្នុងការបណ្តុះបណ្តាលនៅកម្រិត២, ៣ និង៤។

## ១០.៤.៥. ការលើកកម្ពស់ការចូលរួមក្នុងឧស្សាហកម្ម

ការលើកកម្ពស់គុណភាពបណ្តុះបណ្តាល ការបង្កើនចំនួនសិស្សបញ្ចប់ការសិក្សា និងការពង្រឹងទំនាក់ទំនងរវាងឧស្សាហកម្ម និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាកត្តាចាំបាច់។ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចាំបាច់ត្រូវលើកកម្ពស់ការចូលរួមរបស់ខ្លួន ក្នុងឧស្សាហកម្មនៅកម្រិតសហគ្រាស ពីព្រោះការចូលរួមនេះអាចជះឥទ្ធិពលដល់ការផ្គត់ផ្គង់បុគ្គលិក គុណភាពបណ្តុះបណ្តាល និងការចែករំលែកព័ត៌មាន។ ការចូលរួមនេះអាចធ្វើឡើងតាមរយៈ (i) ការបង្កើតទំនាក់ទំនងជាមួយក្រុមប្រឹក្សាភិបាលសហគ្រាស (ii) ការបង្កើតផែនការយុទ្ធសាស្ត្រ ដែលអាចឱ្យឧស្សាហកម្មយល់ច្បាស់អំពីយុទ្ធសាស្ត្រ និងអាទិភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាល និងផែនការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សកម្មភាពដែលបង្ហាញអំពីដំណើរការអភិវឌ្ឍជំនាញរបស់សិស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្មក្នុងស្រុក និងឧស្សាហកម្មផ្សេងៗទៀត ឱ្យបានកាន់តែទូលំទូលាយ (iii) ផ្តោតសារឡើងវិញលើវគ្គបណ្តុះបណ្តាល ឬកម្មវិធីសិក្សាដែលអាចបង្ហាញយ៉ាងច្បាស់អំពីការរីកចម្រើននៃការអភិវឌ្ឍជំនាញ សម្រាប់ឧស្សាហកម្ម និងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

## ១០.៨.៦. ការកសាងសមត្ថភាពគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈសាធារណៈ

ទោះបីជារចនាសម្ពន្ធ និងស្ថាប័នគ្រប់គ្រង ហាក់ដូចជាបង្ហាញថាមានទំនាក់ទំនងជាមួយឧស្សាហកម្មក្តី ប៉ុន្តែការចូលរួមជាក់ស្តែងហាក់មានតិចតួច ហើយចំណេះដឹងពាក់ព័ន្ធនឹងការចាប់ផ្តើមការចូលរួមជាមួយឧស្សាហកម្មក៏នៅមានតិចតួចដែរ។ បើតាមការអង្កេតលើតម្រូវការ សហគ្រាសភាគច្រើនស្ថិតក្រោមការគ្រប់គ្រងរបស់បរទេស (៧៩%)។ សហគ្រាសធំៗដែលគ្រប់គ្រងដោយកម្ពុជាមានប្រហែល ២០%។ ការកសាងសមត្ថភាព និងទំនុកចិត្តរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរដ្ឋដើម្បីទាក់ទាញឧស្សាហកម្មដែលគាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកនិងវិជ្ជាជីវៈជាកត្តាដ៏សំខាន់។

ការកសាងសមត្ថភាព ដើម្បីអភិវឌ្ឍទំនាក់ទំនងជាមួយឧស្សាហកម្ម នឹងអាចឱ្យបុគ្គលិកចូលរួមកាន់តែច្រើនក្នុងឧស្សាហកម្ម។ ការកសាងសមត្ថភាព រាប់បញ្ចូលទាំងការបង្កើតបណ្តាញទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាល ដើម្បីយល់ច្បាស់ថាតើអាជីវកម្មថ្មីៗប្រភេទណាដែលកំពុងបង្កើតថ្មី ការបង្កើតបណ្តាញទំនាក់ទំនង និងការខិតទៅជិតក្រុមហ៊ុនដែលមានស្រាប់។ ម្យ៉ាងវិញទៀត គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ក៏គួរទទួលបានការកសាងសមត្ថភាពមូលដ្ឋាន ទាក់ទងនឹងការកសាងទំនាក់ទំនង ជំនាញសម្ភាស ការទាក់ទង និងការចូលរួមជាមួយសហគមន៍អាជីវកម្មផងដែរ។

## ១០.៨.៧. ការបង្កើតប្រព័ន្ធរឹងមាំសម្រាប់វិទ្យាល័យបច្ចេកទេស

ក្រសួងអប់រំ យុវជន និងកីឡាផ្តល់អាទិភាពខ្ពស់ ដល់ការពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឱ្យបានយ៉ាងហោចណាស់មួយសាលាក្នុងមួយខេត្ត ពង្រឹងការអនុវត្តកម្មវិធីអប់រំបច្ចេកទេសនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសដែលកំពុងដំណើរការ បំប៉នគ្រូបច្ចេកទេសលើមុខវិជ្ជាដែលកំពុងមានតម្រូវការទីផ្សារ អភិវឌ្ឍកម្មវិធីសិក្សាលើមុខវិជ្ជាទាក់ទងនឹងសង្គមការងារ និងបង្កើតផែនការគោលសម្រាប់ការអប់រំបច្ចេកទេស។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១០.៩.៨. ការបង្កើតប្រព័ន្ធធានាគុណភាពអប់រំ

ការត្រួតពិនិត្យថ្នាក់ជាតិ ចាំបាច់ត្រូវតែមាន ដើម្បី៖ ធានាគុណភាពអប់រំ គុណវុឌ្ឍិ វិញ្ញាបនបត្រ និងការផ្តល់ជំនួយ។ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈត្រូវការ ការសម្របសម្រួល ការកំណត់តម្រូវការជំនាញ ការផ្តល់និងត្រួតពិនិត្យការអប់រំបណ្តុះ-បណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈក្រៅប្រព័ន្ធ ទំនាក់ទំនងរវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងការផ្តល់ការទម្រង់ទិសវិជ្ជាជីវៈ។

### ១០.៩.៩. ការផ្លាស់ប្តូរការយល់ឃើញរបស់យុវជនចំពោះការអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការយល់ឃើញរបស់យុវជនពិតជាសំខាន់ណាស់។ សិស្ស និស្សិតជាច្រើន យល់ឃើញថា ការងារមានប្រាក់កម្រៃទាប ជាការងារកខ្វក់ ពិបាក និងគ្រោះថ្នាក់ ហើយការងារបែបនេះទទួលរងនូវការមាក់ងាយជាញឹកញាប់ពីសំណាក់គ្រួសាររបស់ពួកគេ។ ការងារប្រភេទនេះត្រូវបានគេចាត់ទុកថាជាការងារចុងក្រោយសម្រាប់ដោះទាល់មួយគ្រាៗតែប៉ុណ្ណោះ។ នៅកម្ពុជា សិស្សជាច្រើនបន្តការសិក្សាក្នុងប្រព័ន្ធ ដោយសារពួកគេជឿជាក់ថា ការអប់រំនេះនឹងផ្តល់ឱ្យពួកគេនូវការងារដែលមានអនាគតកាន់តែភ្លឺស្វាង។ រូបភាពមិនល្អៗពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបានចាក់ឫសគល់យ៉ាងជ្រៅក្នុងផ្នត់គំនិតរបស់សិស្ស និងមាតាបិតារបស់ពួកគេ។ ជាបឋម កិច្ចការដែលត្រូវធ្វើជាចាំបាច់ គឺការរៀបចំវេទិកាដើម្បីបង្កើនការយល់ដឹងរបស់យុវជន អំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ដើម្បីផ្លាស់ប្តូរទស្សនៈសាធារណជន គ្រឹះស្ថានអប់រំរបស់រដ្ឋ គួរបង្កើតឱ្យមានការស្រាវជ្រាវទីផ្សារ និងការបង្កើតយុទ្ធនាការផ្សព្វផ្សាយពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ។

### ១០.៩.១០. ការប្រឹក្សាអាជីព

សិស្សគួរទទួលបានឱកាសមួយ ដើម្បីយល់ឱ្យបានច្បាស់អំពីឱកាសការងារជាច្រើន ដែលពួកគេអាចទទួលបាន នៅគ្រប់កម្រិត មុនពេលពួកគេសម្រេចចិត្តជ្រើសរើសផ្លូវសិក្សាជំនាញ។ ពួកគេក៏គួរទទួលបានការលើកទឹកចិត្តឱ្យជ្រើសរើសវគ្គបណ្តុះបណ្តាល ដែលដឹកនាំពួកគេឱ្យឆ្ពោះទៅរកអាជីពមួយ ស្របតាមចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ជាជាងការងារផ្អែកលើប្រាក់បៀវត្ស និងឋានៈការងារដែលសង្គមយល់ឃើញ។

## ១០.៦. សន្និដ្ឋាន

ប្រព័ន្ធអប់រំនៅកម្ពុជាចាំបាច់ត្រូវដើរទន្ទឹមគ្នា និងសម្របទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច ការរីកចម្រើនខាងបច្ចេកវិទ្យា ស្ថានភាពសន្ទុះប្រជាសាស្ត្រ និងទីផ្សារការងារដែលកំពុងផ្លាស់ប្តូរ។ អ្នកអប់រំត្រូវតែបណ្តុះបណ្តាលសិស្សឱ្យទទួលបានការងារនាពេលបច្ចុប្បន្ន និងនាពេលអនាគត ដើរតាមទាន់បច្ចេកវិទ្យា បណ្តុះគុណតម្លៃថ្មីៗ ក៏ដូចជាអភិវឌ្ឍផ្នែកភាសា និងឥរិយាបថសិស្ស ដើម្បីឱ្យពួកគេត្រៀមខ្លួនជាស្រេច ក្នុងការបម្រើការងារ និងរស់នៅក្នុងពិភពភាវូបនីយកម្ម។

ការសម្របសម្រួល និងភាពជាដៃគូក្នុងការអប់រំ ជួយបង្កើតគ្រឹះដ៏រឹងមាំសម្រាប់លើកកម្ពស់គុណភាពអប់រំ។ ការផ្តល់សេវាអប់រំកាន់តែប្រសើរ ទាមទារនូវការចូលរួមពីសំណាក់មាតាបិតាសិស្ស និងសហគមន៍ ការសម្របសម្រួលតាមវិស័យ និងអន្តរវិស័យ ការសម្របសម្រួលម្ចាស់ជំនួយ និងការចូលរួមពីវិស័យឯកជន រាប់បញ្ចូលទាំងឆន្ទៈរបស់និយោជកក្នុងការវិនិយោគលើការបណ្តុះបណ្តាល និងការអភិវឌ្ឍកម្លាំងពលកម្មនាពេលអនាគត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១១

# តួនាទីនៃឧត្តមសិក្សាក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច

លក្ខណៈពិសេសនៃវិស័យឧត្តមសិក្សានៅកម្ពុជាមានដូចខាងក្រោម ៖

**ទីមួយ**–ការកើនឡើងយ៉ាងគំហុកនៃចំនួននិស្សិត ដែលចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា។ ចំនួនគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា មានការកើនឡើងយ៉ាងខ្លាំងក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ ចំនួនគ្រឹះស្ថានឧត្តមសិក្សា និងចំនួននិស្សិតបានកើនឡើងយ៉ាងយឺត ដោយសារកង្វះថវិការដ្ឋក្នុងការវិនិយោគ។ ដូច្នេះ និន្នាការកើនឡើងដ៏ខ្លាំងក្លា នាពេលថ្មីៗនេះ គឺអាស្រ័យដោយកត្តា ៣ រួមមាន ៖ (១) សិស្សជាច្រើនបានបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា បន្ទាប់ពីអនុវត្តគោលនយោបាយការអប់រំដើម្បីទាំងអស់គ្នា (២) កំណែទម្រង់មន្ត្រីរាជការនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ២០០០ ដែលតម្រូវឱ្យមន្ត្រីរាជរដ្ឋាភិបាលត្រូវមានកម្រិតសញ្ញាបត្រសមស្របតាមតួនាទី និង (៣) ការរីកចម្រើននៃវិស័យឯកជន ដែលទាមទារឱ្យមានគុណវុឌ្ឍិវិជ្ជាជីវៈផ្លូវការ និងតម្រូវឱ្យមានកម្លាំងពលកម្មដែលមានជំនាញខ្ពស់។

**ទីពីរ**–ឯកជនភាវូបនីយកម្មនៃគ្រឹះស្ថានឧត្តមសិក្សានៅប្រទេសកម្ពុជា។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការឱ្យមានគុណវុឌ្ឍិកាន់តែខ្ពស់ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញកំណែទម្រង់គោលនយោបាយថ្មី ដោយអនុញ្ញាតឱ្យមានការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជន។ គ្រឹះស្ថានឧត្តមសិក្សាឯកជនដំបូងគេ គឺសាកលវិទ្យាល័យ **ន័រតុន** ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩៧។ ក្នុងឆ្នាំ២០១៥ មានគ្រឹះស្ថានឧត្តមសិក្សាឯកជនចំនួន៦៧ ដែលផ្តល់ការអប់រំកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ គោលនយោបាយសេរីភាវូបនីយកម្មនេះ បានលើកទឹកចិត្តសាកលវិទ្យាល័យក្រៅប្រទេសឱ្យចាប់ដៃគូជាមួយសាកលវិទ្យាល័យកម្ពុជា ក្នុងការបណ្តុះបណ្តាល ដែលផ្តល់សញ្ញាបត្ររួមគ្នា។

ដើម្បីពិនិត្យមើលតួនាទីនៃឧត្តមសិក្សា ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច យើងនឹងវិភាគស្ថានភាពបច្ចុប្បន្ននៃវិស័យឧត្តមសិក្សានៅកម្ពុជា និងដាក់ចេញនូវវិធានការកំណែទម្រង់មួយចំនួន ដើម្បីឱ្យវិស័យឧត្តមសិក្សាអាចចូលរួមចំណែកក្នុងការលើកកម្ពស់ពិពិធ-កម្មសេដ្ឋកិច្ចកម្ពុជា។

## ១១.១. ស្ថានភាពបច្ចុប្បន្ននៃឧត្តមសិក្សានៅកម្ពុជា

### ១១.១.១. ការកើនឡើងនៃចំនួននិស្សិតចូលរៀនទៅឧត្តមសិក្សាតាមរយៈឯកជនភាវូបនីយកម្ម

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ ចំនួនសិស្សចុះឈ្មោះចូលរៀនមានការកើនឡើងជាលំដាប់ ចាប់ពីកម្រិតបឋមសិក្សា និងបន្តដល់កម្រិតមធ្យមសិក្សា។ ការកើនឡើងនៃការអប់រំមធ្យមសិក្សាបាននាំឱ្យមានការកើនឡើងនូវចំនួននិស្សិតនៅកម្រិតឧត្តមសិក្សា។ ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ សមត្ថភាពស្រូបយកនៃគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាមានការកើនឡើងយ៉ាងខ្លាំង។ ចំនួននិស្សិតបានកើនឡើងពី ៨ ៩០២ នាក់ក្នុងឆ្នាំ១៩៩៨ ដល់១២៤ ៩៤៧នាក់ ក្នុងឆ្នាំ២០០៨ និងកើនដល់ជាង ២២៧ ៣៨៥ នាក់ក្នុងឆ្នាំ២០១៦។ អត្រាចុះឈ្មោះចូលរៀនសរុបបង្ហាញថា និស្សិតចុះឈ្មោះចូលរៀនគិតជាភាគរយនៃក្រុមមនុស្សអាយុពី១៩ ដល់២៣ឆ្នាំ នៅកម្រិតឧត្តមសិក្សា មានការកើនឡើងពី១,៤% ក្នុងឆ្នាំ១៩៩៨ ដល់១១,១% ក្នុងឆ្នាំ២០០៨ និងបន្តកើនដល់១៥% ក្នុងឆ្នាំ២០១៦។ ស្របពេលដែលសេដ្ឋកិច្ចកម្ពុជា បានផ្លាស់ប្តូរពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកសិកម្ម និងសេវាកម្ម ទៅជាសេដ្ឋកិច្ច ដែលពឹងផ្អែកលើវិស័យកម្មន្តសាល និងសេវាកម្មដែលមានតម្លៃបន្ថែមខ្ពស់ ប្រទេសកម្ពុជាចាំបាច់ត្រូវការអ្នកធ្វើការដែលមានការអប់រំកម្រិតឧត្តមសិក្សាកាន់តែច្រើនឡើងៗ។

*រូបភាពទី១០ ៖ ចំនួននិស្សិតឧត្តមសិក្សា*




*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងឆ្នាំ២០១៦ គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាមានចំនួន១១៨ ដែលក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈមានចំនួន៤៦ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនមានចំនួន ៧២។ ហេតុដូច្នេះហើយ វិស័យឧត្តមសិក្សានេះមានលក្ខណៈឯកជនភាវូបនីយកម្មយ៉ាងខ្លាំងក្លា។ ចំនួនគ្រឹះស្ថានឧត្តមសិក្សាសរុបខាងលើ គឺជាចំនួនសរុបទាំងសាខាគ្រឹះស្ថានឧត្តមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាបានបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ២៤ ៩៧០ នាក់ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ១៨២ ៩៨៧ នាក់ និស្សិតថ្នាក់អនុ-បណ្ឌិតចំនួន ១៩ ៤២៨ នាក់ និងនិស្សិតថ្នាក់បណ្ឌិតចំនួន ១ ១៧៥ នាក់។ និស្សិតប្រមាណ ៣៥ ០០០ នាក់ បានបញ្ចប់ការសិក្សាគ្រប់កម្រិតនៅតាមគ្រឹះស្ថានឧត្តមសិក្សាជារៀងរាល់ឆ្នាំ និងនិស្សិតប្រហែល ១ ០០០ នាក់បានសិក្សានៅកម្រិតឧត្តមសិក្សានៅបរទេស។ ក្នុងចំណោមនិស្សិត ១ ០០០នាក់ដែលទៅសិក្សានៅបរទេស មាននិស្សិតចំនួន ៥០០នាក់ទទួលអាហារូបករណ៍។ ស្របពេលគ្នានេះដែរ និស្សិតបរទេសចំនួន ១៥២ នាក់ក៏បានមកសិក្សានៅប្រទេសកម្ពុជា។

*រូបភាពទី១១ ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សា ១៩៧៩–២០១០*




*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

និស្សិតភាគច្រើនចុះឈ្មោះចូលរៀននៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ដែលស្ថិតក្រោមឱវាទក្រសួង និងស្ថាប័នចំនួន១៤។ ក្រសួង និងស្ថាប័នទាំងនោះ រួមមានក្រសួងអប់រំ យុវជន និងកីឡា (គ្រឹះស្ថានឧត្តមសិក្សាចំនួន៦៥) ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ (គ្រឹះស្ថានឧត្តមសិក្សាចំនួន១៩) ក្រសួងសុខាភិបាល (គ្រឹះស្ថានឧត្តមសិក្សាចំនួន២) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (គ្រឹះស្ថានឧត្តមសិក្សាចំនួន២) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គ្រឹះស្ថានឧត្តមសិក្សាចំនួន៣) ក្រសួងការពារជាតិ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(គ្រឹះស្ថានឧត្តមសិក្សាចំនួន៥) ក្រសួងធម្មការ និងសាសនា (គ្រឹះស្ថានឧត្តមសិក្សាចំនួន២) និងគ្រឹះស្ថានឧត្តមសិក្សាចំនួន១១បន្ថែម ក្រោមក្រសួង និងស្ថាប័ននីមួយៗទាំងនេះ ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា ទីស្តីការគណៈរដ្ឋមន្ត្រី និងធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានឧត្តមសិក្សារដ្ឋអាចចែកចេញជា ៣ប្រភេទ (១) សាកលវិទ្យាល័យរដ្ឋធំៗ ដែលក្នុងនោះរួមមាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យជាតិគ្រប់គ្រង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិអប់រំ (២) វិទ្យាស្ថានពហុបច្ចេកវិទ្យា ដែលក្នុងនោះរួមមាន៖ វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ (PPI) វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ITI) វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI) និងវិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង (វ.ព.ប) (៣) សាកលវិទ្យាល័យរដ្ឋចំនួន ២០ផ្សេងទៀតដែលស្ថិតក្រោមឱវាទក្រសួងផ្សេងៗទៀត។

គ្រឹះស្ថានឧត្តមសិក្សារដ្ឋជារឿយៗផ្តល់ការបណ្តុះបណ្តាលតាមមុខវិជ្ជាសិក្សាជាច្រើន រួមមាន វិស្វកម្ម កសិកម្ម សុខភាពសាធារណៈ នីតិសាស្ត្រ សេដ្ឋកិច្ច ធុរកិច្ច និងគ្រប់គ្រង ក៏ដូចជាមុខវិជ្ជាសិក្សាចម្រុះ តួយ៉ាង អប់រំ ទស្សនវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ទទួលនិស្សិតចុះឈ្មោះចូលរៀនស្មើនឹង៩០%នៃចំនួននិស្សិតសរុប ហើយគ្រឹះស្ថានឧត្តមសិក្សាទាំងនោះបានកំណត់ស្តង់ដាគុណភាពសិក្សា និងការបំពេញការងារ។

*រូបភាពទី១២ ៖ បញ្ហាដែលពាក់ព័ន្ធនឹងគុណភាពអប់រំ*




*ប្រភព ៖* Survey by HRINC Cambodia, March 2011



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចបានបញ្ជាក់នៅខាងដើម ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀនកើនឡើងយ៉ាងឆាប់រហ័ស នៅកម្រិតឧត្តមសិក្សា គឺអាចកកើតឡើងដោយសារការបើកចំហរឱ្យមានគ្រឹះស្ថានឧត្តមសិក្សាឯកជនថ្មីៗជាច្រើន។ ចំនួនគ្រឹះស្ថានឧត្តមសិក្សាឯកជនមានការកើតឡើងខ្លាំងចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ គឺនៅពេលដែលការណែនាំ និងបទបញ្ជាផ្សេងៗ នៅធូររលុងនៅឡើយ ប្រាក់ចំណូលរបស់ប្រជាជនមានការកើនឡើងប្រជាពលរដ្ឋថ្នាក់កណ្តាលផ្តើមយល់ពីតម្លៃនៃការអប់រំ និងកំណើនសេដ្ឋកិច្ច ដែលទាំងអស់នេះហើយធ្វើឱ្យមានការឡើងនូវតម្រូវការនិស្សិតបញ្ចប់ការសិក្សា។ គ្រឹះស្ថានឧត្តមសិក្សាធំៗមួយចំនួន តួយ៉ាង សាកលវិទ្យាល័យន័រតុន សា.បញ្ញាសាស្ត្រកម្ពុជា សា.ពុទ្ធិ-សាស្ត្រ និងសា.បៀលប្រាយ ចាប់ផ្តើមពង្រីកខ្លួនអំឡុងទសវត្សរ៍ឆ្នាំ២០០០ ហើយឋានៈនៃគ្រឹះស្ថានឧត្តមសិក្សាទាំងនេះ ត្រូវបាននិយ័តកម្មតាមរយៈច្បាប់ស្តីពីអប់រំឆ្នាំ២០០៧។

ក្នុងចំណោមនិស្សិតដែលចុះឈ្មោះចូលរៀនតាមមហាវិទ្យាល័យនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន និស្សិតភាគច្រើនចុះឈ្មោះចូលរៀនផ្នែកវិទ្យាសាស្ត្រសង្គម និងធុរកិច្ច។ មុខវិជ្ជាសិក្សាក្នុងផ្នែកទាំងពីរនេះទាមទារនូវធនធានតិចតួច និងមិនមានអ្នកឯកទេសសម្រាប់បង្រៀន។ ធនធានសម្រាប់បណ្តុះបណ្តាលមុខវិជ្ជាសិក្សាក្នុងផ្នែកទាំងពីរមានតម្លៃថោក និងងាយស្រួលសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ដែលទាំងនេះធ្វើឱ្យគ្រឹះស្ថានឧត្តមសិក្សាចំណាយតិចតួចតែប៉ុណ្ណោះលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារផ្សេងៗ។ បន្ថែមលើនេះ ក្រុមគ្រួសារ និងយុវជនជាច្រើនក៏មានចំណង់ចំណូលចិត្តសិក្សាមុខវិជ្ជាសិក្សាក្នុងផ្នែកទាំងពីរ និងចង់បានសញ្ញាបត្រផ្នែកហ្នឹងដែរ។ ទោះជាយ៉ាងនេះក្តី បើទោះជាមានកំណើននៃនិស្សិតដែលសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម និងធុរកិច្ចក៏ដោយ ក៏មិនទាន់មានកំណើនតម្រូវការការងារនៃផ្នែកទាំងពីរនេះដែរ។

គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ ទាំងឯកជន បានធ្វើឱ្យមានភាពមិនស៊ីគ្នាជាខ្លាំងនៃជំនាញនិស្សិត និងតម្រូវការទីផ្សារការងារ។ ភាពមិនស៊ីគ្នានេះគឺរវាងអ្នកដែលទទួលយកនិស្សិតដែលបានបញ្ចប់ការសិក្សាភាគច្រើន និងអ្នកដែលចង់ឱ្យមានកំណើនសេដ្ឋកិច្ច។ គ្រឹះស្ថានឧត្តមសិក្សានឹងទទួលបានការចំណេញថវិកាកាន់តែច្រើន តាមរយៈការបើកថ្នាក់បង់ថ្លៃ មុខវិជ្ជាសិក្សាចំណាយប្រាក់តិច តួយ៉ាង បច្ចេកវិទ្យាព័ត៌មានវិទ្យាហិរញ្ញវត្ថុ គណនេយ្យ នីតិសាស្ត្រ ធុរកិច្ច និងគ្រប់គ្រងជាជាងការបើកកម្មវិធីអប់រំដែលតម្រូវឱ្យមានធនធានបង្រៀនច្រើននិងថ្លៃ។ និស្សិតកម្ពុជាជាងពាក់កណ្តាលបានចុះឈ្មោះចូលរៀនផ្នែកវិទ្យាសាស្ត្រសង្គម និងធុរកិច្ច ស្របពេលដែលប្រទេសមួយនេះជាប់ចំណាត់



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ថ្នាក់ជាប្រទេស ដែលមានចំនួននិស្សិតចូលទាបបំផុតលើផ្នែកវិស្វកម្ម(២,៥%) កសិកម្ម (៣%) និងវិទ្យាសាស្ត្រ។ បញ្ហាប្រឈមគឺកត្តាសេដ្ឋកិច្ចជារួម ដែលសាកលវិទ្យាល័យទាំងរដ្ឋ ទាំងឯកជន មិនបានពិចារណាគិតគូពីទីផ្សារការងារ។ កត្តានេះហើយធ្វើឱ្យនិស្សិតកម្ពុជាដែលបានបញ្ចប់ការសិក្សាមិនអាចចូលរួមប្រកួតប្រជែងពេញដៃ ពេញជើង លើទីផ្សារការងារ ដែលតម្រូវឱ្យនិស្សិតមានជំនាញបច្ចេកទេស និងការគ្រប់គ្រងកម្រិតខ្ពស់ ឬជំនាញទន់កម្រិតខ្ពស់។ ការងារល្អៗជាច្រើនបានធ្លាក់ក្នុងដៃជនបរទេស ខណៈពេលដែលប្រជាជនកម្ពុជានៅតែបន្តធ្វើការដោយប្រើកម្លាំង និងការងារកម្រិតទាប។ ទិដ្ឋភាពនេះកើតមានជាពិសេស ក្នុងការងារវិស័យស្ថាបត្យកម្ម បច្ចេកវិទ្យា សណ្ឋាគារ ចំណីអាហារ និងទេសចរណ៍។

មូលហេតុនៃភាពខុសគ្នារវាងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ទីមួយគឺទិដ្ឋភាពច្បាប់។ គ្រឹះស្ថានឧត្តមសិក្សារដ្ឋត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ខណៈដែលគ្រឹះស្ថានឧត្តមសិក្សាឯកជនបង្កើតឡើងដោយបុគ្គល ប៉ុន្តែត្រូវមានការទទួលស្គាល់ និងឯកភាពលើឋានៈគ្រឹះស្ថានឧត្តមសិក្សាដោយរាជរដ្ឋាភិបាលតាមរយៈអនុក្រឹត្យ។ បុគ្គលិកនៃគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ជាមន្ត្រីរាជការដែលទទួលប្រាក់បៀវត្សពីរដ្ឋ។ រដ្ឋក៏ជាម្ចាស់កម្មសិទ្ធិលើដីធ្លី និងអគារនៃគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ចំណែកគ្រឹះស្ថានឧត្តមសិក្សាឯកជន មានសិទ្ធិក្នុងការជួល និងបញ្ឈប់បុគ្គលិក និងជាម្ចាស់កម្មសិទ្ធិលើដីធ្លី និងអគារខ្លួនផ្ទាល់។ គ្រឹះស្ថានឧត្តមសិក្សាឯកជននៅប្រទេសកម្ពុជាភាគច្រើនទទួលថវិកាតាមរយៈការបង់ថ្លៃសិក្សារបស់និស្សិត និងជំនួយហិរញ្ញវត្ថុខ្លះៗពីបរទេស។

ស្ថានភាពកម្ពុជានៅមិនទាន់មានភាពប្រសើរនៅឡើយទេ បើប្រៀបធៀបជាមួយបណ្តាប្រទេសក្នុងសមាគមអាស៊ាន លើចំនួននៃបុគ្គលិកបង្រៀនដែលមានគុណវុឌ្ឍិខ្ពស់។ បច្ចុប្បន្ននេះ សាស្ត្រាចារ្យបង្រៀននៅឧត្តមសិក្សាមានចំនួន ១២ ២៥៦នាក់។ ក្នុងនោះមានតែសាស្ត្រាចារ្យ៨% ឬ៩៧១នាក់ប៉ុណ្ណោះដែលមានសញ្ញាបត្របណ្ឌិត ចំណែកឯសាស្ត្រាចារ្យជាង៦៨% ឬ៣២១នាក់ទៀត មានសញ្ញាបត្រថ្នាក់អនុបណ្ឌិត។ សាស្ត្រាចារ្យស្ត្រីនៅកម្រិតឧត្តមសិក្សាមានចំនួនតិចជាង១០%។ ប្រាក់បៀវត្សរបស់សាស្ត្រាចារ្យនៃគ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅទាបនៅឡើយ។ សាស្ត្រាចារ្យរដ្ឋមួយចំនួនរកប្រាក់ចំណូលបន្ថែម តាមរយៈការបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សាឯកជន។ សាស្ត្រាចារ្យទាំងនោះមានពេលវេលាតិចតួចណាស់សម្រាប់ការសិក្សាស្រាវជ្រាវ និងពិគ្រោះប្រឹក្សាយោបល់។

លើសពីនេះទៀត សាស្ត្រាចារ្យភាគច្រើននៅតាមគ្រឹះស្ថានឧត្តមសិក្សា មានឱកាស ឬស្ទើរគ្មានឱកាសបង្កើតគុណវុឌ្ឍិខ្លួនបន្ថែម ដែលជាផ្នែកមួយនៃការអប់រំពេញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មួយជីវិត។ ឱកាសក្នុងការផ្លាស់ប្តូរសាស្ត្រាចារ្យកម្រិតអន្តរជាតិនៅមានតិចតួច។ ការចូលរួមសន្និសីទអន្តរជាតិ ការបន្តការសិក្សារយៈពេលខ្លី ឬការផ្លាស់ប្តូរការសិក្សាជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាបរទេសនៅមានកម្រិត។ ប្រភពសំខាន់ៗសម្រាប់ការសិក្សា តួយ៉ាងទស្សនាវដ្តីបរទេស ក៏នៅមានការខ្វះខាតដែរ ហើយបញ្ហាមួយទៀតគឺ ការគ្មានគន្លងអាជីពច្បាស់លាស់។ ព្រះរាជក្រឹត្យស្តីពីការកំណត់ឋានៈសាស្ត្រាចារ្យ ត្រូវបានឡាយព្រះហត្ថលេខារួច ប៉ុន្តែមិនទាន់មានការអនុវត្តបានពេញលេញ។

ដូចបានបញ្ជាក់ខាងដើម ដើម្បីដោះស្រាយបញ្ហាខ្វះខាតសាស្ត្រាចារ្យនៅគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ ទាំងឯកជន គ្រឹះស្ថានឧត្តមសិក្សាត្រូវមានដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សាបរទេស ឬត្រូវមានសាស្ត្រាចារ្យបរទេស ដើម្បីអាចជួយចែករំលែកជំនាញ និងវិជ្ជាជីវៈរបស់ពួកគេ តាមរយៈការបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ឬតាមរយៈការបង្កើតកម្មវិធីសិក្សាដែលមានមុខវិជ្ជារួមគ្នា។ នាពេលបច្ចុប្បន្នមានសាស្ត្រចារ្យបរទេសចំនួន ៥៨៨ នាក់ កំពុងបង្រៀននៅកម្រិតឧត្តមសិក្សា។

### ១១.១.៦. ហិរញ្ញប្បទានឧត្តមសិក្សា

ថវិការដ្ឋចំណាយសម្រាប់វិស័យឧត្តមសិក្សានៅកម្ពុជា គឺនៅទាប ធៀបទៅនឹងស្តង់ដាក្នុងតំបន់ និងអន្តរជាតិ។ ហិរញ្ញប្បទានឧត្តមសិក្សាមួយចំណែកធំបានមកពីប្រភពឯកជន ជាពិសេសការបង់ថ្លៃសិក្សារបស់និស្សិត និងប្រាក់ចំណូលផ្សេងៗទៀត។ ប្រភពចំណូលបែបនេះ ក៏ឃើញកើតមានទាំងនៅគ្រឹះស្ថានឧត្តមសិក្សាឯកជន និងបន្តកើនឡើងដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ។ ថវិកាចំណាយសរុបសម្រាប់វិស័យអប់រំ ត្រូវបានគេប៉ាន់ស្មានថាស្មើនឹង ៣%នៃផសស ក្នុងឆ្នាំ២០១៥។ ថវិកាចំណាយសរុបសម្រាប់អនុវិស័យឧត្តមសិក្សា គឺស្មើនឹង០,៥៨%នៃផសស ដែលក្នុងនោះថវិការដ្ឋចំណាយសរុប ត្រូវបានប៉ាន់ស្មានថាស្មើនឹង ០,០៩%នៃផសស ឬស្មើនឹង១៨%នៃថវិកាចរន្ត ខណៈពេលដែលថវិកាចំណាយរបស់ផ្នែកឯកជនស្មើនឹង ០,៤៩% នៃផសស ។

ដើម្បីធានាគុណភាពអប់រំ រក្សាសាស្ត្រាចារ្យ និងទទួលបានសម្ភារទំនើប គ្រឹះស្ថានឧត្តមសិក្សារដ្ឋត្រូវបង្កើតថ្នាក់សិក្សាបង់ថ្លៃ។ ការធ្វើបែបនេះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋបានបង្ហាញសមត្ថភាពខ្លួន ដើម្បីឆ្លើយតប និងប្រកួតប្រជែងជាមួយវិស័យឯកជន។ ហេតុដូច្នេះហើយ ឧត្តមសិក្សាដែលមានពីរប្រព័ន្ធនេះ នៅតែបានផ្តល់លទ្ធផលល្អនៅឡើយ។

ដើម្បីបង្កើនចំនួននិស្សិត ដែលជួបការលំបាកអាចចូលសិក្សានៅកម្រិតឧត្តមសិក្សា គ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ ទាំងឯកជន ត្រូវផ្តល់អាហារូបករណ៍ដល់សិស្ស


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រីក្រ។ ការផ្តល់អាហារូបករណ៍ ត្រូវផ្អែកលើទាំងលទ្ធផលនៃការសិក្សា និងសន្ទស្សន៍នៃភាពក្រីក្ររបស់ក្រុមគ្រួសារ។ សិស្សក្រីក្រតិចជាង១០% ប៉ុណ្ណោះ អាចបំពេញគ្រប់លក្ខខណ្ឌក្នុងការទទួលបានអាហារូបករណ៍ ហើយអាហារូបករណ៍នោះ មិនបានរាប់បញ្ចូលតម្លៃសិក្សាទេ គឺស្មើនឹងតម្លៃ៣០%នៃការចំណាយសរុបនៃការអប់រំនៅឧត្តមសិក្សាសម្រាប់ពួកគេតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ បើទោះជានិស្សិតមិនចំណាយលើការបង់ថ្លៃសិក្សាក៏ដោយ ក៏និស្សិតនៅតែត្រូវចំណាយលើការស្នាក់នៅ ចំណីអាហារ និងសៀវភៅសិក្សានានា។ ការចំណាយសម្រាប់ការអប់រំនៅឧត្តមសិក្សា ធ្វើឱ្យកំណើនចំនួននិស្សិតក្រីក្រនៅឧត្តមសិក្សាតិចតួច ជាពិសេសនិស្សិតមកពីបណ្តាខេត្តនិងសិក្សានៅរាជធានី ដែលពួកគេត្រូវបែកពីគ្រួសារ ឬសាច់ញាតិ។

ហេតុដូចនេះ ដើម្បីលើកកម្ពស់សមធម៌នៃការចូលរៀននៅឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់បន្ថែមលើការបង្កើតគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ ទាំងឯកជននៅតាមបណ្តាខេត្តនានា។ ទោះជាយ៉ាងក្តី សាស្ត្រាចារ្យល្អៗ អាចនឹងស្ទាក់ស្ទើរទៅបម្រើការនៅតាមគ្រឹះស្ថានឧត្តមសិក្សាតាមខេត្ត ពីព្រោះនៅតាមខេត្តមិនទាន់មានសេវាគ្រប់គ្រាន់។

ការណែនាំឱ្យមានប្រព័ន្ធប្រាក់កម្ចីសិក្សាដល់និស្សិតអាចនឹងត្រូវយកទៅពិចារណាថា ជាវិធីមួយក្នុងការបង្កើនសមធម៌នៃការចូលរៀននៅឧត្តមសិក្សា។ ការធ្វើបែបនេះនឹងជួយផ្តល់អាហារូបករណ៍ដល់និស្សិតក្រីក្រ និងអនុញ្ញាតឱ្យនិស្សិតអាចខ្ចីប្រាក់សម្រាប់បង់ថ្លៃការសិក្សា។ ការសិក្សាពីប្រព័ន្ធប្រាក់កម្ចីសិក្សានៅតាមប្រទេសផ្សេងៗ បានបង្ហាញថា ប្រព័ន្ធកម្ចីប្រាក់សិក្សាមានពីរប្រភេទ (១) កម្ចីប្រាក់សិក្សាដែលមានការគាំទ្រពីរាជរដ្ឋាភិបាល ផ្តល់ដោយធនាគារ (២) ប្រាក់កម្ចីផ្អែកលើប្រាក់ចំណូល(ICL) ដែលជាទម្រង់មួយ ដែលនិស្សិតប្តេជ្ញាសងឥណទាន ដោយផ្អែកលើប្រាក់ចំណូលរបស់ពួកគេ នៅពេលអនាគត។ ជម្រើសមួយផ្សេងទៀត គឺអាចយកតាមគំរូប្រទេសអូស្ត្រាលី ដែលរដ្ឋាភិបាលផ្តល់ប្រាក់កម្ចីដល់និស្សិតណា ដែលអាចសងវិញបានបន្ទាប់ពីការកាត់ប្រាក់ពន្ធលើប្រាក់ចំណូល។ យើងត្រូវពិភាក្សាច្រើនទៀត ដើម្បីជ្រើសរើសយកវិធីសាស្ត្រមួយដ៏ល្អបំផុតសម្រាប់ប្រទេសកម្ពុជា។

### ១១.២. កំណែទម្រង់ឧត្តមសិក្សាដើម្បីលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច

ផ្នែកនេះនឹងសិក្សាពីបញ្ហាប្រឈមចម្បងៗ នៅក្នុងវិស័យឧត្តមសិក្សាកម្ពុជា។ ផ្នែកនេះក៏នឹងបង្ហាញពីទិដ្ឋភាពរួមនៃបញ្ហា និងទិសដៅបន្ត ដែលត្រូវយកទៅពិចារណានា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពេលអនាគតខ្លីខាងមុខ និងសម្រាប់រយៈពេលមធ្យម ដើម្បីឱ្យកម្ពុជាអាចដើរតួឈានមុខ ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

## ១១.២.១. បង្កើនគុណភាពអប់រំតាមរយៈការទទួលស្គាល់គុណភាពអប់រំ និងអន្តរជាតូបនីយកម្មឧត្តមសិក្សាកម្ពុជា

ផ្នែកនេះនឹងផ្តោតលើភាពចាំបាច់ ក្នុងការបង្កើនគុណភាពអប់រំនៅឧត្តមសិក្សាតាមរយៈការទទួលស្គាល់គុណភាពអប់រំ និងការបង្កើនអន្តរជាតូបនីយកម្មនៃប្រព័ន្ធអប់រំឧត្តមសិក្សា ដោយរៀបចំឱ្យមានកម្មវិធីអប់រំរួមគ្នា និងកម្មវិធីអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សាបរទេស ក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាបរទេស ក៏ដូចជាគោលនយោបាយអនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សាបរទេសបង្កើតសាខារបស់ខ្លួននៅប្រទេសកម្ពុជា។ បញ្ហាគុណភាពអប់រំនៅកម្ពុជា ជានិច្ចកាលនៅតែជាកង្វល់ជាពិសេសនៅពេលដែលគ្រឹះស្ថានអប់រំដំណើរការ ដើម្បីស្វែងរកប្រាក់ចំណេញ។ បញ្ហាគុណភាពនៃការសិក្សាមិនមែនជាការប្រកួតប្រជែង រវាងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ជាមួយឯកជនទេ។ គុណភាពនេះមានច្រើនផ្នែក ហើយវាបានក្លាយជាបញ្ហាដ៏សំខាន់ នៅពេលដែលចំនួននិស្សិត និងតម្រូវការរបស់ឧស្សាហកម្មកាន់តែកើនឡើង។

តាមមតិរបស់ក្រុមហ៊ុនជ្រើសរើសបុគ្គលិក គ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ ទាំងឯកជននៅកម្ពុជាបណ្តុះបណ្តាលនិស្សិត ដែលមានគុណភាពខុសៗគ្នា។ យើងមានគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ ទាំងឯកជនឈានមុខចំនួនប្រហែល២០ គឺជាស្ថាប័នអប់រំដែលមានកេរ្តិ៍ឈ្មោះល្អ។ គ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ ទាំងឯកជនលំដាប់ថ្នាក់កណ្តាលក៏បានផ្តល់ការអប់រំ ប្រកបដោយគុណភាពអាចទទួលយកបានដែរ។ ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាចំនួនពាក់កណ្តាល នៅមានការងារច្រើនទៀត ដែលត្រូវធ្វើ ដើម្បីពង្រឹងគុណភាពនិស្សិតរបស់ខ្លួន។ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់នោះភាគច្រើន ទទួលបានសិស្សក្រីក្រចូលសិក្សា ពីព្រោះការសិក្សាមានតម្លៃទាប ដែលអាចចូលរួមចំណែកក្នុងការ ផ្តល់ការអប់រំប្រកបដោយសមធម៌។

គុណភាពនៃប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា ក៏ទាក់ទងផងដែរទៅនឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ការរីកដុះដាលនៃចំនួនគ្រឹះស្ថានឧត្តមសិក្សាឯកជន ធ្វើឱ្យគ្រឹះស្ថានឧត្តមសិក្សាបើកថ្នាក់សិក្សាបង់ថ្លៃ ដែលជាលទ្ធផលធ្វើឱ្យសូម្បីតែសិស្សដែលមិនបានបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សា ដោយបានពិន្ទុទាបក៏អាចចុះឈ្មោះចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សាបានដែរ។ ដូច្នេះ កំណែទម្រង់ការប្រឡង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នឹងអាចជួយដោះស្រាយបញ្ហានេះបាន តាមរយៈការបណ្តុះគ្រាប់ពូជល្អៗ សម្រាប់ទៅសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ទោះជាយ៉ាងនេះក្តី ប្រពៃណីនៃការលើកទឹកចិត្តស្ងួចស្តើង ដល់បុគ្គលិកនៅតាមគ្រឹះស្ថានឧត្តមសិក្សា នៅតែជាបញ្ហាចម្បងក្នុងការទាក់ទាញ និងរក្សាទុកបុគ្គលិកអប់រំ ដែលមានគុណវុឌ្ឍិខ្ពស់។

ដើម្បីបង្កើនគុណភាពនៃការបង្រៀន និងរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា សកម្មភាពចម្បង២គួរត្រូវបានអនុវត្តៈ (ក) អនុវត្តប្រព័ន្ធទទួលស្គាល់គុណភាពអប់រំ ដោយភាពជាក់លាក់ ប្រកបដោយវិជ្ជាជីវៈ និងតម្លាភាព និង (ខ) ធ្វើអន្តរជាតូបនីយកម្មគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាជាបណ្តើរៗ។

យុទ្ធសាស្ត្រទូលំទូលាយ គឺបង្កើនការប្រើប្រាស់ថវិកាអប់រំជាមធ្យោបាយក្នុងការអនុវត្តកំណែទម្រង់ប្រព័ន្ធអប់រំ ជាពិសេសលើគោលនយោបាយនិងយុទ្ធសាស្ត្រផ្តោតលើជនក្រីក្រ។

### ១១.២.១.១ *ការទទួលស្គាល់គុណភាពអប់រំ*

ការទទួលស្គាល់គុណភាពអប់រំ មានពីរប្រភេទ ៖ ការទទួលស្គាល់គុណភាពអប់រំកម្រិតកម្មវិធី និងកម្រិតគ្រឹះស្ថាន។ ទោះបីជាប្រទេសកម្ពុជាទទួលយកការទទួលស្គាល់គុណភាពអប់រំកម្រិតគ្រឹះស្ថានក៏ដោយ ក្នុងស្ថានភាពជាក់ស្តែង កម្មវិធីអប់រំនៅតាមឧត្តមសិក្សាទាំងសាធារណៈ ទាំងឯកជន ភាគច្រើនមិនទាន់បានទទួលស្គាល់គុណភាពនៅឡើយ ដោយសារតែកង្វះខាតមន្ត្រីវាយតម្លៃដែលមានគុណវុឌ្ឍិ។

**គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា** (គ.ទ.ក) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣។ គណៈកម្មាធិការនេះ មានភារកិច្ចទទួលស្គាល់ការធានាគុណភាពអប់រំកម្រិតកម្មវិធី និងកម្រិតគ្រឹះស្ថាន។ គ.ទ.ក មានសិទ្ធិអំណាចធានាថា គ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ត្រូវអនុវត្តតាមស្តង់ដាដែលមានចែងក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ ទោះជាយ៉ាងនេះក្តី គ.ទ.ក នៅមានភាពខ្វះខាតធនធានមនុស្សក្នុងការបំពេញភារកិច្ចខាងលើនេះ។ ដោយហេតុផលនេះហើយ បានជាក្នុងរយៈពេលកន្លងមក គ.ទ.ក អាចមានលទ្ធភាពត្រឹមតែធ្វើការលើការទទួលស្គាល់គុណភាពអប់រំនៃកម្មវិធីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សាតែប៉ុណ្ណោះ។

ក្នុងឆ្នាំ២០១៣ អគ្គលេខាធិការនៃគ.ទ.កបានផ្ទេរពីទីស្តីការគណៈរដ្ឋមន្ត្រី មកក្រសួងអប់រំ យុវជន និងកីឡា។ តាមរយៈរបៀបវារៈនៃកំណែទម្រង់ឧត្តមសិក្សារបស់ថ្នាក់



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដឹកនាំក្រសួង គ.ទ.ក ត្រូវបានស្នើសុំឱ្យមានការពិនិត្យកែសម្រួលស្តង់ដាសម្រាប់ការទទួលស្គាល់គុណភាពអប់រំ ដែលជាការទទួលស្គាល់គុណភាពអប់រំតាមកម្មវិធី។ ស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ត្រូវបានអនុម័តនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ដែលក្នុងនោះមានស្តង់ដាចំនួន៩ និងសូចនាករចំនួន៧៣។ ខាងក្រោមនេះជាការពិពណ៌នាសង្ខេបនៃស្តង់ដានីមួយៗ។

### ១១.២.១.១.១ ស្តង់ដា១ ៖ ចក្ខុវិស័យ បេសកកម្ម និងគោលដៅ

គ្រឹះស្ថានឧត្តមសិក្សាត្រូវកំណត់ឱ្យបានច្បាស់លាស់ អំពីចក្ខុវិស័យ បេសកកម្ម និងគោលដៅអប់រំ ដើម្បីបំពេញតម្រូវការរបស់និស្សិត និងសហគមន៍។ ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់គ្រឹះស្ថានត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ តំបន់ ឬអន្តរជាតិ ព្រមទាំងគោរព និងការពារវប្បធម៌ និងអត្តសញ្ញាណជាតិ។ គ្រឹះស្ថានឧត្តមសិក្សាត្រូវមានភស្តុតាងបញ្ជាក់ថា គ្រប់ភាគីពាក់ព័ន្ធបានចូលរួមក្នុងដំណើរការកំណត់ចក្ខុវិស័យ បេសកកម្ម និងគោលដៅនេះ ហើយសមាជិកសហគមន៍បញ្ញវន្តថ្មីបានទទួលការណែនាំ និងតម្រង់ទិសអំពីចក្ខុវិស័យ បេសកកម្ម និងគោលដៅនេះ។ រាល់ការពិនិត្យឡើងវិញ និងការកែលម្អចក្ខុវិស័យ បេសកកម្ម និងគោលដៅ ត្រូវមានភាពច្បាស់លាស់ មានបច្ចុប្បន្នភាព ហើយមានប្រយោជន៍សម្រាប់យកទៅអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា។

### ១១.២.១.១.២ ស្តង់ដា២ ៖ អភិបាលកិច្ច និងការគ្រប់គ្រង

ប្រព័ន្ធអភិបាលកិច្ចល្អរបស់គ្រឹះស្ថានឧត្តមសិក្សា ជួយឱ្យគ្រឹះស្ថានទទួលបានជោគជ័យក្នុងការសម្រេចចក្ខុវិស័យ បេសកកម្ម និងគោលដៅ។ ប្រព័ន្ធអភិបាលកិច្ចរបស់គ្រឹះស្ថាន រួមបញ្ចូលទាំងក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងលំដាប់ថ្នាក់នៃគ្រឹះស្ថាន។ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងដើរតួនាទីសំខាន់ក្នុងការបង្កើតចក្ខុវិស័យ បេសកកម្ម គោលដៅ ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍគ្រឹះស្ថានស្របតាមបទបញ្ញត្តិពាក់ព័ន្ធ និងកំណត់ការដឹកនាំគ្រប់គ្រង និងបញ្ហាអាទិភាពដែលត្រូវដោះស្រាយ។

### ១១.២.១.១.៣ ស្តង់ដា៣ ៖ បុគ្គលិកអប់រំ

ការជ្រើសរើស ការជួល ការរក្សាទុកបុគ្គលិកអប់រំ និងការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំជាកិច្ចការចាំបាច់របស់គ្រឹះស្ថានឧត្តមសិក្សា។ ការទទួលខុសត្រូវចម្បងរបស់បុគ្គលិកអប់រំ គឺសំដៅធ្វើឱ្យសម្រេចគោលដៅកម្មវិធីអប់រំ និងធានាគុណភាពនៃការអប់រំ។ ដើម្បី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រេចភារកិច្ចរបស់ខ្លួន បុគ្គលិកអប់រំមានសិទ្ធិអំណាចលើសេរីភាពក្នុងការអប់រំ និងមានតួនាទីសំខាន់ក្នុងដំណើរការសម្រេចចិត្តដែលមានឥទ្ធិពលលើកម្មវិធីអប់រំរបស់គ្រឹះស្ថាន។

### ១១.២.១.១.៤ ស្តង់ដា៤៖ កម្មវិធីអប់រំ

ការសម្រេចបាន និងការរក្សាបាននូវកម្មវិធីសិក្សាប្រកបដោយគុណភាពខ្ពស់ គឺជាការទទួលខុសត្រូវបឋមរបស់គ្រឹះស្ថានឧត្តមសិក្សា។ ដោយលក្ខខណ្ឌ និងតម្រូវការតែងតែមានការផ្លាស់ប្តូរ គ្រឹះស្ថានឧត្តមសិក្សា ត្រូវពិនិត្យ និងវាយតម្លៃកម្មវិធីសិក្សារបស់ខ្លួនក្នុងអំឡុងពេលទៀងទាត់ឱ្យឆ្លើយតបទៅនឹងបរិបទជាតិ និងការប្រែប្រួលទីផ្សារការងារ។ ការរៀបចំកម្មវិធីអប់រំថ្មី ត្រូវផ្អែកលើការវាយតម្លៃជាទៀងទាត់លើបេសកកម្ម គោលដៅតម្រូវការនិស្សិត និងផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិ។

កម្មវិធីសិក្សា ត្រូវបង្ហាញឱ្យបានច្បាស់លាក់អំពីលទ្ធផលសិក្សាដែលរំពឹងទុក និងសមត្ថភាពរបស់និស្សិត។ លទ្ធផលសិក្សារំពឹងទុកនៃកម្មវិធីអប់រំ ត្រូវសមស្របទៅនឹងកម្រិតគុណវុឌ្ឍិដែលផ្តល់ឱ្យ និងក្របខណ្ឌគុណវុឌ្ឍិជាតិ។ គ្រឹះស្ថានឧត្តមសិក្សាមានវិធីសាស្ត្រសមស្របក្នុងការបណ្តុះបណ្តាល ការវាយតម្លៃនិស្សិត និងការរក្សាទុកព័ត៌មានរបស់និស្សិត។ វិធីសាស្ត្រទាំងនេះ ជាមូលដ្ឋានគ្រឹះក្នុងការរក្សាគុណភាពនៃកម្មវិធីអប់រំ។

### ១១.២.១.១.៥ ស្តង់ដា៥ ៖ សេវានិស្សិត

គ្រឹះស្ថានឧត្តមសិក្សា កំណត់លក្ខខណ្ឌជ្រើសរើសនិស្សិតឱ្យចូលរៀន និងផ្តល់បរិយាកាសឱ្យនិស្សិតក្នុងការអភិវឌ្ឍផ្នែកវប្បធម៌ សង្គម សីលធម៌ ប្រាជ្ញា និងកាយសម្បទា។ ការផ្តល់សេវានិស្សិតត្រូវផ្អែកលើការវាយតម្លៃលើតម្រូវការរបស់និស្សិត ដើម្បីគាំទ្រឱ្យសម្រេចបានគោលដៅសិក្សា និងសមស្របទៅតាមបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា។

### ១១.២.១.១.៦ ស្តង់ដា៦ ៖ ធនធានសិក្សា

ធនធានសិក្សា សំដៅលើបណ្ណាល័យ បន្ទប់ពិសោធ បន្ទប់កុំព្យូទ័រ សៀវភៅសិក្សា អត្ថបទស្រាវជ្រាវ អ៊ីនធឺណិត។ល។ ដែលគាំទ្រដល់ការបង្រៀន ការរៀន និងការស្រាវជ្រាវស្របទៅនឹង ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់គ្រឹះស្ថានឧត្តមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សាផ្តល់ធនធាន និងសេវាសិក្សាគ្រប់គ្រាន់ និងសមស្របទៅនឹងកម្មវិធីអប់រំ។ គ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់លើការផ្តល់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឱ្យបានគ្រប់គ្រាន់ និងមានបច្ចុប្បន្នភាពទាំងផ្នែកទន់ ទាំងផ្នែករឹង។ លើសពីនេះ ធនធានសិក្សាត្រូវមានលក្ខណៈគ្រប់គ្រាន់ទាំងគុណភាព បរិមាណ ទាំងពិពិធភាព ដើម្បីគាំទ្រដល់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការសិក្សា ការបង្រៀន និងការតម្រូវការផ្នែកស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់គ្រូបង្រៀន និងនិស្សិត។

### ១១.២.១.១.៧ ស្តង់ដា៧ ៖ ធនធានរូបវន្ត

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានទីតាំងប្រកបដោយបរិស្ថានល្អ ដែលអំណោយផលដល់ការបង្រៀន និងការសិក្សា និងមានទីធ្លាធំទូលាយសម្រាប់សកម្មភាពកីឡា សិល្បៈ និងសកម្មភាពផ្សេងៗទៀត។ គ្រឹះស្ថានឧត្តមសិក្សា មានអគារសិក្សា បន្ទប់សិក្សា ការិយាល័យ បន្ទប់ប្រជុំ សាលប្រជុំ សាលសហសិក្សា និងការផ្គត់ផ្គង់អគ្គិសនី និងទឹកគ្រប់គ្រាន់ ហើយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់។ គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានផែនការគ្រប់គ្រងសម្ភាររូបវន្តច្បាស់លាស់ ដើម្បីធានាគុណភាព និងការប្រើប្រាស់សម្ភាររូបវន្តទាំងនោះ ប្រកបដោយប្រសិទ្ធភាព។

### ១១.២.១.១.៨ ស្តង់ដា៨ ៖ ធនធានហិរញ្ញវត្ថុ

គ្រឹះស្ថានឧត្តមសិក្សា បង្ហាញពីស្ថិរភាពហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និងអនាគត ដើម្បីបំពេញបេសកកម្មប្រកបដោយប្រសិទ្ធភាព និងធានានិរន្តរភាពនៃកម្មវិធីអប់រំ និងសេវាកម្មរបស់ខ្លួន។ គ្រឹះស្ថានឧត្តមសិក្សា មានគោលនយោបាយ ឬគោលការណ៍ និងនីតិវិធីរៀបចំផែនការថវិកា ត្រួតពិនិត្យ ការចំណាយ ធ្វើបញ្ជីគណនេយ្យ និងសវនកម្ម។

### ១១.២.១.១.៩ ស្តង់ដា៩ ៖ ការធានាគុណភាពផ្ទៃក្នុង

គ្រឹះស្ថានឧត្តមសិក្សា បង្ហាញពីការប្តេជ្ញាក្នុងការធានា និងបន្តលើកកម្ពស់គុណភាពអប់រំ តាមរយៈការវាយតម្លៃជាប្រព័ន្ធលើប្រសិទ្ធភាពនៃប្រតិបត្តិការ និងកម្មវិធីអប់រំទាំងអស់របស់ខ្លួន។ គ្រឹះស្ថានឧត្តមសិក្សាប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ សម្រាប់រៀបចំផែនការថវិកា កំណត់អាទិភាព និងកែលម្អកម្មវិធីអប់រំ និងសេវាកម្មនៃគ្រឹះស្ថាន។

ហេតុដូចនេះ ស្តង់ដារបស់ គ.ទ.ក គ្របដណ្តប់ទាំងទិដ្ឋភាពនៃការសិក្សា ទាំងទិដ្ឋភាពមិនមែនការសិក្សា នៃកម្មវិធីអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងមហាវិទ្យាល័យ។ ទិដ្ឋភាពអប់រំ រាប់បញ្ចូលរួមមាន ៖ រយៈពេលនៃកម្មវិធីអប់រំ តម្រូវចំនួនក្រេឌីត លក្ខណៈនៃមុខវិជ្ជាសិក្សា ខ្លឹមសារមុខវិជ្ជាសិក្សា ចំនួនម៉ោងបង្រៀនសម្រាប់មុខវិជ្ជានីមួយៗ លក្ខណៈនៃការវាយតម្លៃ លទ្ធផលរំពឹងទុកនៃការសិក្សា និងគុណវុឌ្ឍិនៃបុគ្គលិកបង្រៀន។ គ.ទ.ក ក៏នឹងធ្វើសវនកម្មលើវិធាន និងបទបញ្ញារដ្ឋបាលសម្រាប់កម្មវិធីអប់រំ កំណត់គ្រាការជួស-

ជុលថែទាំ មុខវិជ្ជាសិក្សា សម្ភារបរិក្ខារ បន្ទប់សិក្សា បន្ទប់ពិសោធ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន បណ្ណាល័យ និងសៀវភៅ។

បើទោះជាមានការអភិវឌ្ឍនៃប្រព័ន្ធទទួលស្គាល់គុណភាពអប់រំទូលំទូលាយថ្មី និងមានការកែលម្អ គ.ទ.ក ខ្លួនឯងក៏ដោយ ស្ថាប័នថ្មីមួយនេះនៅតែមិនទាន់បានធ្វើការវាយតម្លៃទៅលើគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ទាំងគ្រឹះស្ថានរដ្ឋ ទាំងគ្រឹះស្ថានឯកជន ដោយសារខ្វះមន្ត្រីវាយតម្លៃដែលមានបទពិសោធ។ ម្យ៉ាងទៀត ការជ្រើសរើសមន្ត្រីវាយតម្លៃពីចំណោមបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សានានា ធ្វើឱ្យមានកង្វះទំនុកចិត្តលើលទ្ធផលនៃការវាយតម្លៃ។

ដើម្បីធ្វើឱ្យប្រព័ន្ធទទួលស្គាល់គុណភាពអប់រំមានប្រសិទ្ធភាព វាទាមទារឱ្យមានក្រុមវាយតម្លៃមួយដែលមានគុណភាពខ្ពស់ ទទួលបានប្រាក់បៀវត្សខ្ពស់ និងឯករាជ្យ ដែលក្នុងនោះរួមមានដូចជា អ្នកសិក្សាអន្តរជាតិ ដែលអាចផ្តល់ការបង្ហាត់បង្រៀនដល់មន្ត្រីវាយតម្លៃកម្ពុជា។

ក្នុងឆ្នាំ២០១៥ គ.ទ.ក បានធ្វើការវាយតម្លៃទាំងស្រុងលើគ្រឹះស្ថានឧត្តមសិក្សាចំនួន ៦ (សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សាកលវិទ្យាល័យបៀលប្រាយ សាកលវិទ្យាល័យកម្ពុជា សាកលវិទ្យាល័យអាស៊ីអឺរ៉ុប សាកលវិទ្យាល័យអន្តរជាតិ និងសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ) និងគ្រោងវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សាចំនួន៥បន្ថែមទៀត។ នៅរយៈពេលខាងមុខ ដំណើរការទទួលស្គាល់គុណភាពអប់រំ នឹងអាចដំណើរការប្រកប ដោយប្រសិទ្ធភាពនៅប្រទេសកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសផ្សេងៗដែរ។ ទោះជាយ៉ាងនេះក្តី ភាពជាក់ស្តែងដែលមិនអាចគេចបាននោះគឺថា រហូតមកដល់ពេលនេះ ទីផ្សារការងារនឹងដើរតួជាអ្នកកាត់ក្តីនៃគុណភាព។ មាតាបិតា និងនិស្សិតនឹងពិចារណាជ្រើសរើស ឬមិនជ្រើសរើសគ្រឹះស្ថានឧត្តមសិក្សា និងមុខវិជ្ជាសិក្សាណាមួយ។ ពេលនោះមានន័យថា និស្សិតដែលបានបញ្ចប់ការសិក្សាចំណាត់ថ្នាក់ល្អនៅមធ្យមសិក្សា និង/ឬ មាតាបិតាដែលមានជីវភាពធូរធារនឹងជ្រើសរើសយកគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនដែលល្អ។

### *១១.២.១.២ អន្តរជាតូបនីយកម្មឧត្តមសិក្សាកម្ពុជាជាបណ្តើរៗ*

អន្តរជាតូបនីយកម្ម រាប់បញ្ចូល វិធានការក្នុងការលើកកម្ពស់ភាពជាដៃគូនៃកម្មវិធីអប់រំភ្លោះ(twinning) ការទទួលស្គាល់សញ្ញាបត្រគ្នាទៅវិញទៅមក និងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈស្វយ័ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១១.២.១.២.១ *ភាពជាដៃគូនៃកម្មវិធីអប់រំភ្លោះ*

ស្របពេលដែលចំនួនគ្រឹះស្ថានឧត្តមសិក្សាមានការកើនឡើង ប្រជាជនកម្ពុជាជាច្រើនមើលឃើញថា ការអប់រំនៅកម្រិតឧត្តមសិក្សា គឺជាចំណុចគន្លឹះដើម្បីទទួលបានឱកាសការងារ។ ការរៀបចំកម្មវិធីអប់រំភ្លោះ ជាមួយគ្រឹះស្ថានឧត្តមសិក្សានៅបរទេស នឹងអនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុក ផ្តល់សេវាអប់រំនៅឆ្នាំសិក្សាទី១ និងបន្តរហូតដល់ឆ្នាំសិក្សាទី២ តាមកម្មវិធីអប់រំភ្លោះនៃគ្រឹះស្ថានឧត្តមសិក្សាដៃគូក្នុងប្រទេសកម្ពុជា។ និស្សិតនឹងបន្តបញ្ចប់ការសិក្សានៅឆ្នាំបន្តបន្ទាប់នៅបរទេស។ ការរៀបចំបែបនេះ គឺមានលក្ខណៈជា ១+២ (សិក្សារយៈពេល១ឆ្នាំនៅកម្ពុជា និងសិក្សារយៈពេល២ឆ្នាំបន្ទាប់នៅបរទេស) និង លក្ខណៈជា ២+១ (សិក្សារយៈពេល២ឆ្នាំនៅកម្ពុជា និងសិក្សារយៈពេល១ឆ្នាំនៅបរទេស)។ សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ កំពុងតែផ្តល់កម្មវិធីអប់រំបែបនេះ។ សញ្ញាបត្រ ដែលត្រូវបានផ្តល់ឱ្យក្រោមការរៀបចំកម្មវិធីអប់រំភ្លោះ គឺមានលក្ខណៈដូចគ្នាបេះបិទតាមរចនាសម្ពន្ធកម្មវិធីអប់រំ តម្រូវការនៃមុខវិជ្ជាសិក្សាមុខវិជ្ជា និងខ្លឹមសារមេរៀននៃគ្រឹះស្ថានឧត្តមសិក្សាបរទេសដៃគូ។

ភាពជាដៃគូនៃកម្មវិធីភ្លោះ រវាងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ស.ភ.ន.វ.ស) ជាមួយនឹងសាកលវិទ្យាល័យ Lyon 2 ជាការបោះជំហានមួយដ៏រឹងមាំនៃការផ្តល់សញ្ញាបត្រអន្តរជាតិនៅប្រទេសកម្ពុជា។ កម្មវិធីនេះ ត្រូវបានគេស្គាល់ថាគោលការណ៍ ៣+0 គឺមានន័យថា សិក្សារយៈពេល៣ឆ្នាំនៅប្រទេសកម្ពុជា និងមិនបាច់ទៅសិក្សានៅបរទេស។

ទោះជាយ៉ាងក៏ដោយ ដើម្បីលើកកម្ពស់ការរៀបចំកម្មវិធីភ្លោះនេះ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា និងគ្រឹះស្ថានឧត្តមសិក្សាបរទេស ត្រូវមានសកម្មភាពលើកកម្ពស់សមត្ថភាពបុគ្គលិកអប់រំកម្ពុជា ទាំងផ្នែកបង្រៀន ទាំងផ្នែកមិនបង្រៀន និងកម្រិតនៃការគ្រប់គ្រងតាមរយៈការលើកទឹកចិត្តពួកគាត់ឱ្យបន្តការសិក្សាកម្រិតខ្ពស់បន្ថែមទៀត និងចូលរួមផ្នែកសិក្សាស្រាវជ្រាវ។ បន្ថែមពីលើនេះ សម្ភារបរិក្ខារ ដូចជាបណ្ណាល័យ បន្ទប់សិក្សា និងទីកន្លែងលំហែសម្រាកនានា ក៏គួរត្រូវបានធ្វើទំនើបកម្មដែរ។ សម្រាប់រយៈពេលនេះ ជាជំហានដំបូង គ្រឹះស្ថានឧត្តមសិក្សា នឹងត្រូវបានលើកទឹកចិត្តឱ្យចងសម្ពន្ធលើកម្មវិធីអប់រំជាមួយគ្រឹះស្ថានឧត្តមសិក្សាបរទេស។

### ១១.២.១.២.២ សាខាសាកលវិទ្យាល័យ និងទ្វេសញ្ញាបត្រ

ចំណុចមួយទៀតនៅក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងគុណភាពថ្នាក់ឧត្តមសិក្សា គឺគោលនយោបាយក្នុងការអនុញ្ញាតឱ្យសាកលវិទ្យាល័យបរទេសដែលល្បីៗមកបង្កើតសាខានៅក្នុងប្រទេសកម្ពុជា។ ទោះបីជាសាខាសាកលវិទ្យាល័យបរទេស ជាធម្មតា យកថ្លៃឈ្នួលខ្ពស់ជាងសាកលវិទ្យាល័យក្នុងស្រុក ដោយការផ្តល់នូវសញ្ញាបត្របរទេស ពួកគេនឹងជួយដល់ការពង្រឹងគុណភាព។

ការអភិវឌ្ឍដ៏គួរឱ្យចាប់អារម្មណ៍មួយទៀត ក្នុងផ្នែកឧត្តមសិក្សាគឺការបង្កើតឱ្យមានទ្វេសញ្ញាបត្រ (dual/double degrees) និងសញ្ញាបត្ររួមគ្នា (joint degrees)។ និស្សិតដែលបានបំពេញគ្រប់លក្ខខណ្ឌ សម្រាប់ទទួលបានសញ្ញាបត្រ ដែលគុណភាពសិក្សារបស់ពួកគេត្រូវបានវាយតម្លៃដោយសាកលវិទ្យាល័យបរទេសណាមួយ ប្រហែលជាអាចទទួលបាននូវសញ្ញាបត្រពីរ មួយបានមកពីសាកលវិទ្យាល័យក្នុងស្រុក និងមួយទៀតបានមកពីសាកលវិទ្យាល័យបរទេស។ កម្មវិធីទ្វេសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច និងច្បាប់ ត្រូវបានអនុវត្តដោយជោគជ័យរវាងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យ Lyon 2។

### ១១.២.១.២.៣ ស្វ័យភាពនៃសាកលវិទ្យាល័យរដ្ឋ

ផ្នែកមួយនៃកម្មវិធីកំណែទម្រង់របស់ក្រសួងអប់រំយុវជននិងកីឡាកំពុងធ្វើដំណើរឆ្ពោះទៅកាន់ប្រព័ន្ធវិមជ្ឈការបន្ថែមទៀត លើការគ្រប់គ្រងនិងបទបញ្ញត្តិសាកលវិទ្យាល័យរដ្ឋ ដោយចាប់ផ្តើមជាមួយស្ថាប័នសំខាន់ៗ។ ភ័ស្តុតាងជាលក្ខណៈអន្តរជាតិបង្ហាញឱ្យឃើញថា ស្ថាប័នឧត្តមសិក្សាត្រូវការស្វ័យភាព និងសេរីភាពក្នុងការស្រាវជ្រាវ ដើម្បីទទួលបានជោគជ័យ។ ដូច្នេះការគ្រប់គ្រងស្ថាប័នឧត្តមសិក្សា នឹងត្រូវបានផ្លាស់ប្តូរទៅជាស្ថាប័នសិក្សា ហើយក្រុមប្រឹក្សាភិបាលនឹងដំណើរការដោយឯករាជ្យដោយស្របទៅតាមបទបញ្ញាដែលបានបង្កើតឡើងយ៉ាងច្បាស់លាស់ដោយរដ្ឋាភិបាល។

ទោះជាយ៉ាងណាក៏ដោយ ដោយមិនគិតពីស្វ័យភាពទូទៅ ទាំងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនត្រូវតែចាប់ផ្តើមដោះស្រាយជាបន្ទាន់ នូវភាពខ្វែងគំនិតគ្នារវាងកម្មវិធីអប់រំ ដែលត្រូវបានផ្តល់ឱ្យជាមួយនឹងតម្រូវការរបស់និយោជកចំពោះនិស្សិតបញ្ចប់ការសិក្សា ដែលជំនាញនិងចំណេះដឹងគួរមានការពាក់ព័ន្ធច្រើនទៅនឹងការងារ។ វាធ្វើឱ្យមានការចាប់អារម្មណ៍ ក្នុងការគិតដល់លទ្ធភាពនៃការគាំទ្រពីរដ្ឋាភិបាល ចំពោះសាកលវិទ្យាល័យឯកជន ដែលមានបំណងចង់បង្កើត និងអភិវឌ្ឍវគ្គសិក្សាដែលផ្តល់នូវសញ្ញាបត្រវិជ្ជាជីវៈ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១១.២.២. វិធានការកំណែទម្រង់ឧត្តមសិក្សា

នៅក្នុងអាណត្តិថ្មីរបស់រាជរដ្ឋាភិបាល ការអភិវឌ្ឍវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា នឹងប្រើប្រាស់នូវយុទ្ធសាស្ត្រថ្មីមួយ ដែលចាប់ផ្តើមជាមួយនឹងការអនុវត្តនូវដំណាក់កាលទី៣ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្តេចនាយករដ្ឋមន្ត្រីបានប្រកាសក្នុងកំឡុងពេលនៃកិច្ចប្រជុំទីមួយនៃគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៥ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣។ ចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ ក៏ត្រូវបានរៀបចំឡើងដោយនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគោលដៅដ៏យូរអង្វែង និងយុទ្ធសាស្ត្រអនុវត្តន៍សម្រាប់វិស័យនេះ។

ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ និងចក្ខុវិស័យឧត្តមសិក្សាឆ្នាំ ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ និងដាក់ចេញនូវយុទ្ធសាស្ត្រគោលនយោបាយសំខាន់ៗ ក្នុងគោលបំណងបង្កើនកំណែទម្រង់ឧត្តមសិក្សា ដោយពង្រឹងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងពង្រឹងបទបញ្ជារបស់គ្រឹះស្ថានឧត្តមសិក្សាឯកជន។ ទាំងនេះរួមមានការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សឱ្យមានគុណភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច។ វិធីមួយដែលអាចធ្វើទៅបាន គឺភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងសហគ្រាសឯកជន។ កំណែទម្រង់ឧត្តមសិក្សា ក៏នឹងផ្តោតទៅលើការពង្រឹងគុណភាពអប់រំ និងការឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមផងដែរ។

ឯកសារនេះ គឺមានគោលបំណងបង្កើតកិច្ចពិភាក្សា និងការជជែកដេញដោលគ្នា ដើម្បីបង្កើតគោលដៅច្បាស់លាស់ទៅលើកំណែទម្រង់សំខាន់ៗចាំបាច់មួយចំនួន ដែលយើងគួរសិក្សាស្វែងយល់។ វានឹងពិភាក្សាយុទ្ធសាស្ត្ររយៈពេលខ្លី (ក) តួនាទីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍឧត្តមសិក្សា និង (ខ) យុទ្ធសាស្ត្ររយៈពេលមធ្យម និងរយៈពេលវែងផងដែរ ដើម្បីធានាថាឧត្តមសិក្សាឆ្លើយតបទៅនឹងតម្រូវការនៃ សេដ្ឋកិច្ចដែលកំពុងកើនឡើង និងរីកចម្រើន។

សំណើជាច្រើនត្រូវបានដាក់ជា ១០ ចំណុចធំៗ។ សំណើមួយចំនួនគឺជាយុទ្ធ-សាស្ត្រសាមញ្ញៗ ដែលត្រូវបានគេធ្វើឡើងយ៉ាងឆាប់រហ័ស ដោយពុំមានតម្រូវការចំណាយធំដុំទេ។ ទោះជាយ៉ាងណាក៏ដោយ សំណើផ្សេងទៀតទាមទារពេលវេលាបន្ថែម និងថវិកាដ៏សន្ធឹកសន្ធាប់។ សំណើជាច្រើនគឺផ្អែកទៅលើការអនុវត្តដ៏ល្អបំផុតដែលមាននៅក្នុងប្រទេសដទៃផ្សេងទៀតដែលជាសមាជិកអាស៊ាន។

### ១១.២.២.១ វិធានការរយៈពេលខ្លី

### ១១.២.២.១.១ ពង្រឹងតួនាទីដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍឧត្តមសិក្សា

តួនាទីទាំងនេះរួមមាន ៖

–ការអនុវត្តចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ ដែលជាឯកសារគោលនយោបាយ ដែលភ្ជាប់ទំនាក់ទំនងឧត្តមសិក្សាទៅនឹងការអភិវឌ្ឍជាតិនៃប្រទេសកម្ពុជាក្នុងឆ្នាំ២០៣០ និងការអនុវត្តគម្រោងសកម្មភាពឆ្នាំ២០១៤-២០១៨ ដោយផ្តោតតែទៅលើចំណុចអាទិភាពធំៗជាចម្បងមួយចំនួន ដែលអាចធ្វើបាន និងអត្ថប្រយោជន៍របស់វាមានភាពប្រាកដនិយម សម្រាប់កំណែទម្រង់ថវិកា ដើម្បីគាំទ្រការអនុវត្តនូវចំណុចអាទិភាពទាំងនេះ និងយន្តការទាំងអស់នេះ។

–រឹតបន្តឹងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ទៅលើសាកលវិទ្យាល័យថ្មីៗ ជាពិសេស ករណីសាកលវិទ្យាល័យដែលខ្វះធនធានមនុស្ស និងហេដ្ឋារចនាសម្ពន្ធគ្រប់គ្រាន់។

–ពង្រឹងការសម្របសម្រួលស្ថាប័នរវាងក្រសួងពាក់ព័ន្ធ ក្នុងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតនៅក្រោមឱវាទ។

–ការលើកកម្ពស់ការបណ្តុះបណ្តាលគ្រូឧទ្ទេសរយៈពេលវែង ចំពោះគ្រូឧទ្ទេស និងសាស្ត្រាចារ្យឧត្តមសិក្សា ដើម្បីបំពេញនូវតម្រូវការដែលបានរំពឹងទុក សម្រាប់ធនធានមនុស្ស និងឧបករណ៍។ល។

– អនុម័តផែនទីប្រតិបត្តិសម្រាប់ការអភិវឌ្ឍវិស័យឧត្តមសិក្សា ក្នុងអំឡុងពេល ១០ ទៅ ១៥ ឆ្នាំខាងមុខ ក្នុងគោលដៅធ្វើផែនការនីយកម្មតម្រូវការ និង ការផ្គត់ផ្គង់អ្នកជំនាញស្របទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច។

### ១១.២.២.១.២ កែលម្អការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡានៅក្នុងវិស័យឧត្តមសិក្សា

វិធានការនេះត្រូវពិនិត្យឡើងវិញនូវតួនាទី ដែលទាក់ទងនឹងរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ដែលទទួលបន្ទុកអនុវិស័យឧត្តមសិក្សា និងដំណើរការរៀបចំផែនការនៃអគ្គ-នាយកនៃនាយកដ្ឋានឧត្តមសិក្សា និងនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ កុំឱ្យពួកគេធ្វើការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាន់គ្នា។ នាយកដ្ឋានឧត្តមសិក្សា ស្រាវជ្រាវ និងផែនការ ត្រូវតែធ្វើការជាមួយគ្នា ហើយត្រូវមានសូចនាករ ដើម្បីវាស់ស្ទង់ផលប៉ះពាល់នៃគោលនយោបាយ។

នៅក្នុងបរិបទនេះ សកម្មភាពខាងក្រោមត្រូវបានស្នើឡើង ៖

-បង្កើតកម្មវិធីការងារប្រចាំឆ្នាំមួយដែលមានការប្រជុំទៀងទាត់ និងក្រុមការងារមួយក្រុមដែលទទួលខុសត្រូវក្នុងការរៀបចំ និងធ្វើសេចក្តីព្រាងបទបញ្ជា និងសេចក្តីសម្រេច។

-បង្កើតគេហទំព័រ ដើម្បីផ្សព្វផ្សាយជូនដល់បុគ្គលិកសិក្សាទាំងអស់ នូវវឌ្ឍនភាពការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ។ គេហទំព័រអាចអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទំនាក់ទំនងជាមួយព្រឹត្តិការណ៍អន្តរជាតិ ដែលត្រូវបានចូលរួមដោយមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

-បង្កើតប្រព័ន្ធទិន្នន័យស្ថិតិ ដែលអាចជឿទុកចិត្តបាន និងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់នូវចំនួននិស្សិត និងសាស្ត្រាចារ្យ ដោយត្រូវជៀសវាងការរាប់បញ្ចូលច្រើនដង។ ការងារដែលត្រូវបានអនុវត្ត ក្នុងកំឡុងពេលនៃការរៀបចំផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ ដែលត្រូវបានបញ្ជាក់សាជាថ្មីម្តងទៀត នូវការលំបាកនៃការយល់ដឹងពីកន្លែងដែលកំណែទម្រង់ គួរតែចាប់ផ្តើម។

## ១១.២.២.២ *វិធានការរយៈពេលមធ្យម និងរយៈពេលវែង*

### ១១.២.២.២.១ *វិធានការដែលទាក់ទងនឹងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ*

*១). ធានាស្វ័យភាពរបស់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងកំណត់តួនាទីរបស់សកលវិទ្យាធិការ*

ស្វ័យភាព មិនមែនមានន័យថាគ្រប់គ្នាសុទ្ធតែអាចធ្វើអ្វីបានតាមតែចិត្តនោះទេ។ ស្វ័យភាពនៅតាមសាកលវិទ្យាល័យ គឺសំខាន់ត្រូវតែជ្រើសរើសរកវិធី និងមធ្យោបាយដើម្បីបំពេញនូវទិសដៅដែលបានកំណត់ដោយក្រសួងអប់រំ។ វាជាការលំបាកក្នុងការជ្រើសរើសយកប្រព័ន្ធមួយ ដែលសាកលវិទ្យាល័យនីមួយៗត្រូវរៀបចំផែនការយុទ្ធ-សាស្ត្ររយៈពេល៥ឆ្នាំរបស់ខ្លួន ដោយផ្អែកទៅលើសកម្មភាពដែលបានគ្រោងទុករបស់នាយក-ដ្ឋាននីមួយៗ។ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានការដែលមានក្នុងពេលបច្ចុប្បន្ននេះ សកម្មភាពខាងក្រោមត្រូវបានស្នើឡើង ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

–សាកលវិទ្យាល័យនីមួយៗត្រូវមានផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ដែលកើតចេញពីការណែនាំតម្រង់ទិសរបស់នាយកដ្ឋានសំខាន់ៗ ។

–បង្កើតក្រុមប្រឹក្សាសាកលវិទ្យាធិការជាតិមួយ ដែលជាវេទិកាសំខាន់មួយសម្រាប់ការសន្ទនា និងការពិគ្រោះយោបល់រវាងក្រសួងអប់រំ យុវជន និងកីឡា និងសាកលវិទ្យាល័យនានា។

–អនុម័តលក្ខន្តិកៈស្តីពីការគ្រប់គ្រងសាកលវិទ្យាល័យ និងការអនុវត្តល្អប្រសើរដែលស្របគ្នាទៅនឹងសាកលវិទ្យាល័យអាស៊ាន ។

–កែទម្រង់បែបបទជ្រើសរើសគ្រូបង្រៀននៅឧត្តមសិក្សា និងដោយអនុញ្ញាតឱ្យសាកលវិទ្យាល័យធ្វើការជ្រើសរើសដោយខ្លួនឯង ។

–បង្កើតធម្មនុញ្ញនៃការគ្រប់គ្រងរបស់សាកលវិទ្យាល័យ និងការអនុវត្តដ៏ល្អ ដែលស្របទៅនឹងធម្មនុញ្ញរបស់ប្រទេសដែលជាសមាជិកអាស៊ាន។

### *១១.២.២.២.២ កំណត់សិទ្ធិនិងការទទួលខុសត្រូវរបស់សាស្ត្រាចារ្យឧត្តមសិក្សា*

លក្ខន្តិកៈត្រូវកំណត់នូវលក្ខខណ្ឌតម្រូវអប្បបរមា សម្រាប់ការបង្រៀនការសិក្សាស្រាវជ្រាវ និងការចូលរួមក្នុងការអភិវឌ្ឍ ។ ការអនុវត្តលក្ខន្តិកៈថ្មីនេះ ត្រូវតែធ្វើឡើងរួមជាមួយនឹងការដំឡើងប្រាក់បៀវត្សក្នុងគោលដៅរក្សាគ្រូបង្រៀនល្អៗ និងការពន្លឿនយន្តការទទួលស្គាល់គុណវុឌ្ឍិរបស់គ្រូបង្រៀន មកពីប្រទេសផ្សេងដែលមានប្រព័ន្ធគុណភាពខ្ពស់។

### *១១.២.២.២.៣ លើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ និង គំនិតច្នៃប្រឌិតរបស់សកលវិទ្យាល័យ*

មិនដូចជាប្រវត្តិសាស្ត្រនៃបណ្តាប្រទេសដែលកំពុងអភិវឌ្ឍដទៃទៀតទេ ថ្មីៗនេះកម្ពុជាបានឆ្លងកាត់នូវការបំផ្លាញទាំងស្រុងនូវវិស័យសិក្សាធិការរបស់ខ្លួន និងគ្មានទម្លាប់ក្នុងការស្រាវជ្រាវនោះទេ ដែលនាពេលបច្ចុប្បន្ននេះ ត្រូវតែកសាងឡើងចាប់ពីចំណុចសូន្យ។ បទពិសោធនៃការស្រាវជ្រាវ ដែលទទួលបានដោយបុគ្គលិកដែលបានទៅរៀនថ្នាក់បណ្ឌិតនៅក្រៅប្រទេសតាមរយៈអាហារូបករណ៍នោះ គឺមិនគ្រប់គ្រាន់ទេ ហើយបទពិសោធបង្ហាញឱ្យឃើញថា មាននិស្សិតដែលបន្តការស្រាវជ្រាវមាននៅតិចនៅឡើយ។ ដូច្នេះហើយបានជាសកម្មភាពខាងក្រោមទាំងនេះ ត្រូវបានស្នើឡើង ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

–ការបង្កើតក្រុមប្រឹក្សាជាតិសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងបណ្តុះបណ្តាលធនធានមនុស្សដើម្បីធ្វើការស្រាវជ្រាវ។

–ការបង្កើតមូលនិធិសម្រាប់ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា មូលនិធិនេះនឹងជួយជំរុញសកម្មភាពស្រាវជ្រាវ ដោយផ្អែកលើការអំពាវនាវឱ្យមានការដេញថ្លៃនៅក្នុងវិស័យជាអាទិភាពមួយចំនួន ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាស្រាវជ្រាវជាតិ។ ការ ផ្តល់មូលនិធិពីវិស័យឯកជននឹងត្រូវបានពិចារណា។

–ការចាប់ផ្តើមគម្រោងមួយ ដែលមានរយៈពេល៥ឆ្នាំ ដោយបង្កើតបាននូវកម្មវិធីថ្នាក់បណ្ឌិតកម្រិតអន្តរជាតិនៅក្នុងប្រទេសកម្ពុជា ដែលបានបង្កើតឡើងក្នុងសាកលវិទ្យាល័យមួយចំនួន សម្រាប់ជាការធ្វើពិសោធន៍ជាមួយនឹងបទពិសោធក្នុងការស្រាវជ្រាវ។ គម្រោងនេះនឹងត្រូវបានគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ប៉ុន្តែត្រូវពាក់ព័ន្ធគ្រប់អនុវិស័យឧត្តមសិក្សាទាំងអស់។

–ការលើកកម្ពស់វប្បធម៌ស្រាវជ្រាវ ដោយការផ្តល់ជូនប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់បុគ្គលិកបង្រៀនអចិន្ត្រៃយ៍ ដោយឆ្លុះបញ្ចាំងនូវលទ្ធផលនៃការស្រាវជ្រាវ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងការបង្រៀន និងការស្រាវជ្រាវបានស្មើគ្នា។

### ១១.២.២.២.៤ *ផ្សារភ្ជាប់ទំនាក់ទំនងរវាងមធ្យមសិក្សា និងឧត្តមសិក្សា*

អនុវិស័យមធ្យមសិក្សា និងឧត្តមសិក្សា គួរតែធ្វើការរួមគ្នា ដោយហេតុថា និស្សិតនៅឧត្តមសិក្សាបានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ។ ទោះជាយ៉ាងនេះក៏ដោយ នៅមិនទាន់មានយន្តការសម្របសម្រួលជាផ្លូវការណាមួយ រវាងភូមិសិក្សាទាំងពីរនេះនៅឡើយ។ អន្តរភាពរវាងអនុវិស័យទាំងពីរនេះ គឺត្រូវបានអនុវត្តឡើងក្នុងក្របខណ្ឌឆ្នាំសិក្សាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ដោយគណៈកម្មការទទួលស្គាល់គុណភាពអប់រំកម្ពុជា (គ.ទ.ក) ប៉ុន្តែទិសដៅ និងខ្លឹមសារនៃកម្មវិធីនេះត្រូវតែពិនិត្យមើលឡើងវិញទាំងស្រុង។

គិតពីកំណើនយ៉ាងឆាប់រហ័សនូវចំនួននិស្សិត និងផលប៉ះពាល់ជាអវិជ្ជមានរបស់វាទៅលើគុណភាពនៃការអប់រំ និងលំហូរចូលរបស់និស្សិតដែលត្រូវបណ្តុះបណ្តាលគួរតែមានភាពបត់បែនគ្រប់គ្រាន់សម្រាប់និស្សិត ដើម្បីជ្រើសរើសយកផ្លូវដ៏សម្បូរបែបនិងឱកាស ដើម្បីឆ្ពោះទៅកាន់វិថីសម្រាប់វិជ្ជាជីវៈ បច្ចេកទេស និងការសិក្សានៅកម្រិតអនុវិទ្យាល័យ។ ខ្លឹមសារនៃការអប់រំជាទូទៅ ដែលត្រូវបានផ្តល់ឱ្យនិស្សិតនៅវិទ្យាល័យក៏គួរតែត្រូវបានកែប្រែ ដើម្បីផ្តល់នូវគ្រឹះដ៏រឹងមាំមួយបន្ថែមទៀតក្នុងជំនាញវិទ្យាសាស្ត្រ និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បច្ចេកវិទ្យា ដោយហេតុថាទាំងនេះគឺជាជំនាញជាមូលដ្ឋានសម្រាប់ថ្ងៃអនាគត។ និស្សិតក៏គួរត្រូវបានគេជំរុញចិត្ត ឱ្យមើលឃើញនូវអត្ថប្រយោជន៍សម្រាប់ការអនុវត្តការហាត់ការងារសម្រាប់អ្នកដែលមានជំនាញបច្ចេកទេស។ ការអប់រំជំនាញបច្ចេកទេសនៅអនុវិទ្យាល័យគឺជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលដំបូង ប៉ុន្តែកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងវិស័យនេះ គឺនៅមានកម្រិត នាពេលបច្ចុប្បន្ននេះ។ នៅឧត្តមសិក្សា ការគ្រប់គ្រងលំហូររបស់និស្សិតគួរតែត្រូវធ្វើឡើងដោយផ្អែកលើចំណុចគោលចំនួនបី ១) ការជ្រើសរើសនិស្សិតដ៏តឹង ២) ការបង្រៀន និងប្រព័ន្ធអប់រំដ៏មានប្រសិទ្ធភាព ដែលអាចបញ្ចៀសនូវការត្រួតថ្នាក់របស់និស្សិត និងការបង្រៀនឡើងវិញដែលមិនចាំបាច់ និង ៣) កម្រិតផ្សេងៗគ្នានៃគុណវុឌ្ឍិអាជីពដែលទាក់ទងគ្នា សមស្របនឹងពេលវេលាហើយស្របទៅនឹងសមត្ថភាពរបស់និស្សិត។

ការត្រួតពិនិត្យឡើងវិញនៃកម្មវិធីសិក្សា ដើម្បីកំណត់នូវជំនាញដែលទទួលបានក្នុងកំឡុងពេលនៃការអប់រំនៅថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ និងនីតិវិធីសម្រាប់ការត្រួតពិនិត្យមើលនូវការទទួលបានទាំងនេះគឺមានន័យថា កម្មវិធីវាយតម្លៃនិស្សិតអន្តជាតិ (PISA)គឺមានសារៈសំខាន់ចាំបាច់បំផុតក្នុងការកំណត់ កម្រិតជាក់លាក់របស់និស្សិតកម្ពុជាធៀបជាមួយនឹងចំណុចយោងអន្តរជាតិ។ ព័ត៌មាននេះគឺជាមូលដ្ឋានក្នុងការធ្វើកំណែទម្រង់ឧត្តមសិក្សាឱ្យបានជោគជ័យ។ ការប្រៀបធៀបជំនាញបែបនេះ នឹងអនុញ្ញាតឱ្យប្រព័ន្ធអប់រំកម្ពុជាមានជំហរលើខ្លួនឯងឡើងវិញចំពោះមុខប្រទេសជិតខាង។

### *១១.២.២.២.៩ ពង្រឹងការបង្រៀន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅកម្រិតឧត្តមសិក្សា*

ដូចក្នុងប្រទេសអាស៊ានដទៃផ្សេងទៀតដែរ ប្រព័ន្ធសាកលវិទ្យាល័យកម្ពុជាគួរតែនាំមុខគេក្នុងការផ្តោតទៅលើការបង្រៀនមុខវិជ្ជាខាងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា គណិតវិទ្យា និងវិស្វកម្ម(STEM) ក្នុងគោលដៅបណ្តុះបណ្តាលកម្លាំងពលកម្ម ដែលមានសមត្ថភាពសម្រាប់ការវិនិយោគ ប្រកបដោយផលិតភាពនៅក្នុងប្រទេសកម្ពុជា ជាពិសេសដើម្បីទាក់ទាញវិនិយោគក្នុងវិស័យអេឡិចត្រូនិក បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ឧស្សាហកម្មកែច្នៃផលិតផលម្ហូបអាហារ និងភូគព្ភសាស្ត្រ។

ប្រសិនបើយើងពិនិត្យមើលការវិភាគសេដ្ឋកិច្ចថ្មីៗចុងក្រោយនេះ ការអភិវឌ្ឍប្រទេសកម្ពុជាក្នុងរយៈពេល១៥ឆ្នាំទៀត គឺផ្អែកទៅលើការបង្កើតឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ ដែលជាប់ពាក់ព័ន្ធនឹងដំណើរការបង្កើតផលិតផលកសិកម្ម សម្រាប់ផលិតផលចំណីអាហារសម្រាប់ការប្រើប្រាស់របស់មនុស្ស និងការចិញ្ចឹមសត្វ គ្រឿងសម្អាង ការផលិតថ្នាំពីរុក្ខជាតិក្នុងស្រុក ការផលិតថាមពល។ល។ កម្ពុជាក៏ដូចជាប្រទេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅតាមតំបន់ជនបទដទៃទៀតផ្សេងទៀតដែរ គឺកំពុងតែបង្កើតជាបណ្តើរៗនូវបណ្តាញតម្លៃបន្ថែមដែលមានចាប់ពីវត្ថុធាតុដើម រហូតដល់ផលិតផលសម្រេច។ សព្វថ្ងៃនេះវត្ថុធាតុដើមជាច្រើន ត្រូវបាននាំចេញទាំងនៅដោយមិនបានកែច្នៃ ហើយបន្ទាប់មកបាននាំចូលមកវិញពីប្រទេសដទៃទៀត នូវផលិតផលសម្រេចទាំងនោះ។ ការបន្ថែមតម្លៃ សេដ្ឋកិច្ចក៏រាប់បញ្ចូលនូវផលិតផលដែលមាននៅក្រោមដី ដែលគិតចាប់ពីការទាញយករ៉ែផ្សេងៗ រហូតដល់ការផលិតចេញជាផលិតផលសម្រេច។ សរុបសេចក្តីមក ឧត្តមសិក្សាត្រូវតែបំពេញតម្រូវការនៃការអភិវឌ្ឍឧស្សាហកម្ម ដោយរួមបញ្ចូលវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយផ្តល់នូវជំនាញការគ្រប់ប្រភេទ និងជំនាញដែលចាំបាច់តាមរយៈការផ្តល់ឱ្យនូវការអប់រំនៅសាកលវិទ្យាល័យដែលពាក់ព័ន្ធ ជាពិសេសតាមរយៈការបង្កើតវគ្គខ្លីៗសម្រាប់អាជីពការងារ (Bac + 2 or Bac +3)។

### ១១.២.២.២.៦ *ពង្រឹងការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សាឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម*

ភាពមិនស៊ីគ្នារវាងការផ្គត់ផ្គង់ នៃការអប់រំកម្រិតឧត្តមសិក្សា និងតម្រូវការទីផ្សារពលកម្មបានក្លាយទៅជាបញ្ហាប្រឈមដ៏ធំមួយ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពមានការងារធ្វើមិនគ្រប់គ្រាន់ ឬភាពគ្មានការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ឧត្តមសិក្សា ក្រសួងនឹងអនុវត្តនូវវិធានការដូចតទៅ ៖

–ធ្វើការស្រាវជ្រាវពីតម្រូវការនៃទីផ្សារ ហើយផ្សព្វផ្សាយនៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

–ផ្អាកជាបណ្តោះអាសន្នការបង្កើតគ្រឹះស្ថានឧត្តមសិក្សាថ្មី លើកលែងតែគ្រឹះស្ថានសិក្សា ដែលបណ្តុះបណ្តាលក្នុងវិស័យកសិកម្ម វិស្វកម្ម ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងមុខជំនាញដែលទីផ្សារត្រូវការ។

–ផ្សព្វផ្សាយអំពីទស្សនទាន នៃអភិក្រមផ្អែកលើសមត្ថភាព (CPA) ដើម្បីតម្រូវឱ្យគ្រឹះស្ថានសិក្សាអនុវត្តនូវស្តង់ដា និងកម្មវិធីសិក្សាប្រកបដោយវិជ្ជាជីវៈខ្ពស់។

–រៀបចំវេទិកាការងារ ដើម្បីបង្កលក្ខណៈឱ្យនិស្សិតជួបជាមួយនិយោជក និងទទួលបាននូវព័ត៌មានស្តីពីទីផ្សារការងារ ។

–ជំរុញឱ្យគ្រឹះស្ថានឧត្តមសិក្សា តាមដាននិស្សិតរៀនចប់ ដែលកំពុងធ្វើការនៅតាមកន្លែងផ្សេងៗ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១១.២.២.២.៧ សមាហរណកម្មគ្រឹះស្ថានឧត្តមសិក្សាចូលក្នុងសហគមន៍សេដ្ឋកិច្ច អាស៊ាន

ប្រទេសកម្ពុជាមានទីតាំងនៅក្នុងតំបន់ភូមិសាស្ត្រ ដែលមានសាកលវិទ្យាល័យជាច្រើននៅក្នុងប្រទេសជិតខាងបានទទួលស្គាល់ពីគុណភាពល្អជាអន្តរជាតិ ដែលមានជាអាទិ៍ ដូចជាប្រទេសសិង្ហបុរី ថៃ និងម៉ាឡេស៊ី។

នៅក្នុងបរិបទនេះ កម្ពុជាមានអ្វីៗទាំងអស់ ដើម្បីទទួលបានពីការធ្វើសមាហរណកម្មអាស៊ាន ក្នុងវិស័យឧត្តមសិក្សា ការស្រាវជ្រាវ និងនវានុវត្តន៍។ ដូច្នេះ យើងត្រូវលើកកម្ពស់គុណភាពឧត្តមសិក្សា ជាពិសេសគ្រឹះស្ថានឧត្តមសិក្សាធំៗឱ្យឈានដល់ការទទួលស្គាល់ក្នុងតំបន់ តាមរយៈការចូលរួមស្រាវជ្រាវក្នុងតំបន់អាស៊ាន ការបង្កើតភាពជាដៃគូនៃសាកលវិទ្យាល័យថ្នាក់តំបន់ ការរៀបចំទស្សនកិច្ចសិក្សា ការផ្លាស់ប្តូរគ្រូបង្រៀន និង/ឬនិស្សិត ការដឹកនាំការសរសេររួមគ្នា និង ការពង្រឹងកម្មវិធីឧត្តមសិក្សា តាមគំនិតផ្តួចផ្តើម Krabi។

### ១១.២.២.២.៨ ទាក់ទាញនិងរក្សាអ្នកមានទេពកោសល្យដែលមានជំនាញផ្នែកឧត្តមសិក្សានៅក្រសួងអប់រំយុវជននិងកីឡា

វិធានការនេះនឹងជួយពង្រឹងសមត្ថភាពស្ថាប័ននៃនាយកដ្ឋានឧត្តមសិក្សា និងនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ដោយការជ្រើសរើសអ្នកបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតមកពីបរទេស ដែលមានមុខជំនាញខុសៗគ្នា ដើម្បីចូលរួមចំណែកក្នុងការអនុវត្តកំណែទម្រង់វិស័យឧត្តមសិក្សា។

### ១១.២.២.២.៩ វិធានការដែលទាក់ទងនឹងស្ថាប័នឧត្តមសិក្សាឯកជន

វិធានការមួយចំនួនត្រូវបានពិចារណា ដើម្បីពង្រឹងគុណភាពនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន។

–ក្រសួងអប់រំ យុវជន និងកីឡា បន្តមិនចុះហត្ថលេខាលើសញ្ញាបត្រ ដែលចេញដោយសាកលវិទ្យាល័យឯកជននានា ប៉ុន្តែពង្រឹងការគ្រប់គ្រង ដើម្បីជៀសវាងសញ្ញាបត្រក្លែងក្លាយ។

–គណៈកម្មការទទួលស្គាល់គុណភាពអប់រំកម្ពុជា នឹងដើរតួយ៉ាងសំខាន់ក្នុងការវាយតម្លៃគុណភាពនៃគ្រឹះស្ថានឧត្តមសិក្សាឯកជននៅកម្ពុជា។

–ការអនុញ្ញាតឱ្យបើកគ្រឹះស្ថានឧត្តមសិក្សាឯកជន ត្រូវតែផ្អែកទៅលើគោលដៅច្បាស់លាស់។

## ១១.៣. សេចក្តីសន្និដ្ឋាន

វិស័យឧត្តមសិក្សារបស់ប្រទេសកម្ពុជា កំពុងតែរីកចម្រើនយ៉ាងខ្លាំង។ ការរីក-ចម្រើននេះឆ្លុះបញ្ចាំងពីកំណើនសេដ្ឋកិច្ចប្រកបដោយជវភាព និងសេចក្តីប្រាថ្នាយ៉ាងខ្លាំង ដើម្បីពង្រឹងគុណភាពអប់រំនៅឧត្តមសិក្សា និងការឆ្លើយតបទៅនឹងតម្រូវការវិស័យឯកជន។

កម្ពុជាត្រូវបន្តកំណែទម្រង់វិស័យឧត្តមសិក្សា តាមរយៈការបង្កើនថវិកា ការពង្រឹងក្របខណ្ឌគតិយុត្តិ និងគុណភាពនៅតាមគ្រឹះស្ថានសិក្សា ដើម្បីឱ្យសាកលវិទ្យាល័យទទួលបាននូវការទទួលស្គាល់នៅក្នុងតំបន់។

វប្បធម៌នៃការសិក្សានឹងត្រូវផ្លាស់ប្តូរ ដើម្បីផ្តល់ការលើកទឹកចិត្តដល់ឧត្តមភាពក្នុងការបង្រៀន និងការស្រាវជ្រាវ កែលម្អការជ្រើសរើសសាស្ត្រាចារ្យ និងលើកកម្ពស់ការផ្លាស់ប្តូរសាស្ត្រាចារ្យ និងនិស្សិតឱ្យបានកាន់តែច្រើន ដើម្បីបង្កើតនូវគំនិតប្រកួតប្រជែងផ្លាស់ប្តូរបទពិសោធ ទាំងនៅលើឆាកអន្តរជាតិ និងក្នុងតំបន់។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១២
# គំណែទម្រង់ការអប់រំ និងការកែលម្អវិធីសាស្ត្របង្រៀនក្នុងគោលដៅលើកកម្ពស់ជំនាញទន់

## ១២.១. វិធីសាស្ត្រគរុកោសល្យ

ការសិក្សារបស់ **នាយកដ្ឋានអភិវឌ្ឍអន្តរជាតិ** នៃចក្រភពអង់គ្លេស (DfID) បានបង្ហាញឱ្យឃើញថា ដើម្បីលើកកម្ពស់គុណភាពអប់រំ និងលទ្ធផលសិក្សារបស់សិស្ស ការអនុវត្តវិធីសាស្ត្របង្រៀន និងគរុកោសល្យ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាអប់រំ ប្រកបដោយប្រសិទ្ធភាព នៅប្រទេសកំពុងអភិវឌ្ឍ។ វិធីសាស្ត្រគរុកោសល្យ ត្រូវបានរៀបចំឡើង តាមរយៈអន្តរសកម្មរវាងការគិតរបស់គ្រូបង្រៀន និងអាកប្បកិរិយារបស់គ្រូ រវាងសកម្មភាពរបស់គ្រូនៅក្នុងថ្នាក់រៀន និងលទ្ធផលដែលគ្រូទទួលបានពីការអនុវត្តតាមថ្នាក់រៀន[281]។ ការសិក្សានេះបានរកឃើញនូវ **អាកប្បកិរិយាពីរបែបរបស់គ្រូ**[282] ដែលលើកទឹកចិត្តឱ្យប្រើ **យុទ្ធសាស្ត្រអន្តរសកម្ម និងគមនាគមន៍** (Interactive and communicative strategies) ចំនួនបីប្រភេទគឺ ៖

- ទី១-ការផ្តល់ព័ត៌មានត្រឡប់ ការយកចិត្តទុកដាក់ជាប្រចាំ និងការចូលរួមពីសិស្សទាំងអស់គ្នា
- ទី២- ការបង្កើតបរិស្ថានប្រកបដោយសុវត្ថិភាព ដែលជួយគាំទ្រសិស្សក្នុងការរៀន
- ទី៣-ការគិតគូរពីស្ថានភាពគ្រួសារ និងបទពិសោធរបស់សិស្ស។

---

[281] Westbrook J., Durrana N., Brown R., Orr D., Pryor J., Boddy J., Salvi F. (2013) Pedagogy, Curriculum, Teaching Practices and Teacher Education in Developing Countries. Final Report. Education Rigorous Literature Review. Department for Internaitonal Development. p. 2.

[282] អាកប្បកិរិយាវិជ្ជមានរបស់គ្រូ ចំពោះការបណ្តុះបណ្តាលរបស់គេ និងចំពោះសិស្ស ដើម្បីធ្វើឱ្យគេរៀបចំដំណើរការបង្រៀន និងរៀន ឱ្យមានលក្ខណៈអន្តរសកម្ម និងគមនាគមន៍ ពោលគឺមានការឆ្លើយឆ្លងរវាងគ្រូ និងសិស្ស ដើម្បីឱ្យសិស្សឆ្លើយនឹងសំណួរ ដែលបង្ហាញឱ្យយើងឃើញថា សិស្សកំពុងរៀន។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

យុទ្ធសាស្ត្រទាំង៣នេះសម្រួលដល់ការអនុវត្ត**វិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាពចំនួន ៦ បែប** ដើម្បីលើកកម្ពស់គុណភាពបង្រៀន និងធ្វើឱ្យសិស្ស ជក់ចិត្តពោលគឺៈ

ទី១- ការប្រើប្រាស់វិធីសាស្ត្របង្រៀន ប្រកបដោយភាពទន់ភ្លន់ ជាក្រុមសិស្សក្នុងថ្នាក់ទាំងមូលការងារជាក្រុម និងការងារជាគូ ដើម្បីលើកទឹកចិត្តសិស្ស។

ទី២- ការប្រើប្រាស់ឱ្យបានញឹកញាប់  និងឱ្យបានសមស្របនូវសម្ភារជំនួយបង្រៀន ដោយមិនត្រូវប្រើតែសៀវភៅសិក្សាគោលតែឯងឡើយ។

ទី៣- ការប្រើប្រាស់សំណួរបើក និងបិទ ការពង្រីកចម្លើយ និងការលើកទឹកចិត្តឱ្យសិស្សសួរសំណួរ។

ទី៤- ការបកស្រាយបង្ហាញ និងការពន្យល់ ដោយប្រើប្រាស់ចំណេះដឹងខាងផ្នែកគរុកោសល្យច្បាស់លាស់។

ទី៥-ការប្រើប្រាស់ភាសារបស់សិស្ស។

ទី៦- ការរៀបចំផែនការបង្រៀនបានច្បាស់លាស់។

## ១២.២. ១ធីសាស្ត្រអំណានដំបូខ

### ១២.២.១ .វិធីសាស្ត្រអំណានរបស់អង្គការរូមធូរីដ[283]

អង្គការរូមធូរីដចាប់ផ្តើមចូលរួមចំណែកជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការចងក្រងសៀវភៅរៀនអាន-សរសេរថ្នាក់ទី១ ទី២ និងទី៣ ចាប់ពីឆ្នាំ ២០១០ មក និងបានប្រើសៀវភៅគោលនេះ នៅតាមសាលាគោលដៅរបស់ខ្លួន។ ក៏ប៉ុន្តែ ដោយយោងតាមបទពិសោធ ការប្រើប្រាស់សៀវភៅសិក្សាគោលតែឯង មិនអាចសម្រេចលទ្ធផលសិក្សាតាមការគ្រោងទុកនោះទេ។ ដូច្នេះ ចាប់ពីឆ្នាំ ២០១២-២០១៤ រូមធូរីដបានធ្វើការ នៅតាមសាលាចំនួន២០០ នៅខេត្តសៀមរាប ដោយប្រើប្រាស់សម្ភារជំនួយដូចជា ៖ អក្សរចល័ត ប័ណ្ណពង្រឹងការអាន សៀវភៅលំហាត់ សៀវភៅរឿងខ្លីៗងាយអាន និងវិធីសាស្ត្របង្រៀនចម្រុះ ព្រមទាំងតាមដានការសិក្សារបស់សិស្សផងដែរ។ ក្រោយបញ្ចប់គម្រោង លទ្ធផលសិក្សារបស់សិស្សលើផ្នែកអំណានមានការកើនឡើង។

[283] រូមធូរីដ (២០១៦) «សេចក្តីសង្ខេបអំពីយុទ្ធសាស្ត្រ កម្មវិធីពង្រឹងបំណិនអាន-សរសេរថ្នាក់ទី១-២ ដែលរូមធូរីដកំពុងអនុវត្ត»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១២.២.១.១. *ការពង្រឹងបំណិនអានតាមរយៈវិធីសាស្ត្របង្រៀន*

បំណិនអាន សំដៅទៅលើសមត្ថភាពជាក់លាក់ ដែលសិស្សម្នាក់ៗអានបានដោយឯករាជ្យ។ បំណិនអានផ្ដោតទៅលើការអានដោយស្គាល់ច្បាស់តួអក្សរ ពាក្យពេចន៍ ឃ្លា ប្រយោគ មានភាពស្ទាត់ជំនាញ និងត្រូវតាមក្បួនខ្នាតវេយ្យាករណ៍។

ក្នុងន័យនេះ ដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស ចាំបាច់ត្រូវកែលម្អវិធីសាស្ត្របង្រៀន និងប្រើប្រាស់សៀវភៅអំណានជំនួយ ដើម្បីឱ្យគ្រូងាយស្រួលអនុវត្ត និងឱ្យសិស្សសកម្មនៅក្នុងថ្នាក់ និងមានពេលហ្វឹកអាន-សរសេរច្រើន។ ក្នុងគោលដៅឱ្យកុមារមានបំណិនអាន និងទម្លាប់អាន កុមារត្រូវការហ្វឹកអានសៀវភៅ ដែលមានខ្លឹមសារ និងឈានពីជំហានងាយៗ ទៅលំបាក(Scaffolding) ទៅតាមអក្សរនីមួយៗ ដែលគេបានរៀន។ ឯកសារជំនួយត្រូវបានរៀបចំឡើង ដោយផ្អែកលើសមាសភាគទាំង៥ នៃការរៀនអាន និងការរៀនសរសេរគឺ៖ (១) ការរៀនស្គាល់សូរអក្សរ (Phonological awareness-PA) ការភ្ជាប់សូរអក្សរទៅតួអក្សរដើម្បីប្រកបសូរ(Phonics) ការអានបង្កើនភាពស្ទាត់ជំនាញ(Fluency) វាក្យស័ព្ទ(Vocabulary) ការយល់ន័យ(Comprehension) និង ការសរសេរ(Writing)។

វិធីសាស្ត្រអំណានត្រូវផ្ដោតលើសមាសភាគដូចតទៅ៖ (១) គ្រូធ្វើ (២) គ្រូនិងសិស្សធ្វើ និង (៣) សិស្សធ្វើ[284]។

**ជី១-គ្រូធ្វើ** ៖ ជាសកម្មភាព ដែលគ្រូពន្យល់ពីអ្វី ដែលសិស្សត្រូវធ្វើ រួចធ្វើបង្ហាញជា គំរូដល់សិស្ស។

**ជី២-គ្រូនិងសិស្សធ្វើ** ៖ ជាសកម្មភាព ដែលគ្រូ និងសិស្សធ្វើជាមួយគ្នា។

**ជី៣-សិស្សធ្វើ** ៖ ជាសកម្មភាព ដែលសិស្សហ្វឹកហាត់ធ្វើជាដៃគូ ឬ បុគ្គល។ ពេលសិស្សអនុវត្ត (សិស្សធ្វើ) សិស្សត្រូវអនុវត្តតាមវិធីសាស្ត្រដូចតទៅ៖

- សិស្សអានជាដៃគូ
- បន្ទាប់មក សិស្សម្នាក់អាន ហើយសិស្សម្នាក់ទៀតចង្អុល រួចដូរវេនគ្នា
- ជាចុងក្រោយ សិស្សអានដោយខ្លួនឯង។

[284] រូមធូរីដ (២០១៦) «សេចក្ដីសង្ខេបអំពីយុទ្ធសាស្ត្រ កម្មវិធីពង្រឹងបំណិនអាន-សរសេរថ្នាក់ទី១-២ ដែលរូមធូរីដកំពុងអនុវត្ត»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***វិធីសាស្ត្រអំណាន*** នេះក៏ទុកពេលឱ្យសិស្សចេះត្រិះរិះពិចារណា ចេះប្រើពាក្យដើម្បីធ្វើជាល្បះដោយខ្លួនឯង និងចេះធ្វើការងារជាក្រុម ដែលជាចំណែកមួយដ៏សំខាន់នៃជំនាញទន់។

### ១២.២.១.២. *ការបណ្តុះទម្លាប់អានតាមបណ្ណាល័យ*

ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវវិធានការបីយ៉ាង ដើម្បីបង្កើតទម្លាប់អាននៅតាមបណ្ណាល័យ ៖

ទីមួយ-បង្កើតបណ្ណាល័យកុមារមេត្រីក្នុងសាលា ដែលមានលក្ខណៈដូចតទៅ ៖ (ក) សៀវភៅអានមានគ្រប់ប្រភេទតាមកម្រិតអាន (៦ កម្រិត ដោយផ្អែកលើចំនួនពាក្យក្នុងមួយឃ្លា និងចំនួនឃ្លាក្នុងមួយទំព័រ ពីស្រួលទៅពិបាក) ដោយមានបិទលេខកូដ (ខ) មានកន្លែងឱ្យសិស្សស្រួលរកសៀវភៅ និងអង្គុយអាន (គ) មានបណ្ណារក្ស ឬគ្រូដឹកនាំសកម្មភាពអាន។

ទីពីរ- មានម៉ោងបណ្ណាល័យ និងម៉ោងសម្រាប់អាន ដើម្បីឱ្យកុមារចូលរួមសកម្មភាពអំណាននៅក្នុង ឬនៅក្រៅបណ្ណាល័យ។

ទីបី- មាន ***សកម្មភាពអំណាន*** ដែលលើកទឹកចិត្តសិស្ស ឱ្យចាប់អារម្មណ៍ និងស្រឡាញ់សៀវភៅ។

ដើម្បីការបណ្តុះទម្លាប់អាន បណ្ណារក្ស ឬគ្រូត្រូវរៀបចំ ***សកម្មភាពអំណាន*** ដែលមានសមាសភាគចំនួន៤ គឺ[285] ៖

***១-អំណានឮ*** ៖ មានគោលដៅឱ្យសិស្សស្តាប់ឮ និងយល់ពីខ្លឹមសារក្នុងសៀវភៅ។ គ្រូត្រូវរើសយកសៀវភៅដែលលើសពីសមត្ថភាពសិស្សអាន តែដែលសិស្សអាចយល់បាន ដោយបង្ហាញរូបភាព ចំណងជើង ប្រាប់ឈ្មោះអ្នកនិពន្ធ និងសួរសំណួរទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ។ បន្ទាប់មក គ្រូអានរឿងនោះឮៗចំនួន១០ ទៅ១៥ នាទី ដោយលើកដាក់សំឡេង និងធ្វើកាយវិការ។ ក្រោយពេលអាន គ្រូត្រូវសួរសំណួរ ដែលទាក់ទងនឹងសាច់រឿង និងជំរុញសិស្សឱ្យបញ្ចេញយោបល់។

***២-អំណានចូលរួម*** ៖ មានគោលដៅឱ្យសិស្សចូលរួមសកម្មភាពក្នុងការអាន។ នៅក្នុងអំណានចូលរួម គ្រូត្រូវអានចំនួនពីរលើក ៖ (ក) ក្នុងអំណានលើកទី១ គ្រូត្រូវជ្រើស-

[285] រូមធូរីដ (២០១៦) «ឯកសារជំនួយស្តីពីបណ្ណាល័យ និងការអាន»។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រើសសៀវភៅតាមកម្រិតអានរបស់សិស្ស បង្ហាញរូបភាព ចំណងជើង សួរ ឬប្រាប់ឈ្មោះអ្នកនិពន្ធ។ នៅពេលអាន គ្រូត្រូវអានរឿងនោះឮៗចំនួន ១០ ទៅ ១៥ នាទី ដោយលើកដាក់សំឡេង និងធ្វើកាយវិការ ដោយមានសួរសំណួរងាយៗផង។ ក្រោយពេលអានលើកទីមួយ គ្រូត្រូវសួរសំណួរមួយចំនួន ដើម្បីលើកទឹកចិត្តឱ្យសិស្សចូលរួមក្នុងការអានរឿងនោះ ជាលើកទីពីរ (ខ) ក្នុងអំណានលើកទី២ គ្រូត្រូវលើកទឹកចិត្តសិស្ស ឱ្យអានជាមួយបន្ទាប់មក គ្រូត្រូវអានឮៗ និងចង្អុលតាមឃ្លានីមួយៗដោយយឺតៗ។

**៣-*អំណានដៃគូ*** ៖ មានគោលដៅឱ្យសិស្សជួយគ្នាទៅវិញទៅមកក្នុងការអានពាក្យថ្មី ឬពាក្យពិបាក។ សិស្សដៃគូត្រូវមានកម្រិតអានប្រហាក់ប្រហែលគ្នា។ គ្រូត្រូវជ្រើសរើសដៃគូសិស្ស និងសៀវភៅតាមកម្រិតអានរបស់សិស្ស និងណែនាំឱ្យសិស្សជួយគ្នាក្នុងការអាន។ នៅពេលសិស្សកំពុងអាន គ្រូត្រូវដើរពិនិត្យមើល និងជួយសិស្សក្នុងការអាន។ ពេលខ្លះគ្រូអាចអានជាមួយសិស្ស។ ក្រោយពេលអានចប់ គ្រូឱ្យដៃគូបង្ហាញពីផ្នែកដែលពួកគេចូលចិត្ត ឱ្យសង្ខេបរឿងដោយប្រើពាក្យខ្លួនឯង និងអាចគូររូបផងដែរ។

**៤-*អំណានបុគ្គល*** ៖ មានគោលដៅឱ្យសិស្សអាចអានសៀវភៅ តាមកម្រិតអាន និងជ្រើសរើសសៀវភៅដែលគេចង់អាន។ មុនពេលអាន គ្រូត្រូវឱ្យសិស្សរើសយកសៀវភៅតាមកម្រិតអានរបស់ពួកគេ។ ក្នុងពេលអាន គ្រូត្រូវជួយសម្របសម្រួលដល់សិស្ស ដោយពន្យល់ពាក្យ ឬឃ្លាពិបាក។ ក្រោយពេលអាន គ្រូត្រូវឱ្យសិស្សនិយាយរឿងឡើងវិញជាក្រុម ឬជាបុគ្គល ដោយជ្រើសរើសផ្នែក ដែលពួកគេចូលចិត្ត និងអាចគូររូបផងដែរ។

## ១២.២.២ វិធីសាស្ត្រអំណានរបស់ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅដែលបោះពុម្ពផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំវិធីសាស្ត្របង្រៀនអានដូចខាងក្រោម ៖

- គ្រូបង្ហាញសម្ភារជាក់ស្តែង រូបភាព ធ្វើកាយវិការ លើកឧទាហរណ៍ ធ្វើការប្រៀប-ធៀប ឬសួរសំណួរ តម្រូវទៅតាមប្រភេទពាក្យ (នាម គុណនាម កិរិយា) ដើម្បីបង្កើតពាក្យដែលត្រូវរៀន។ ឱ្យសិស្សថា ពាក្យនោះ ៣-៤ នាក់
- គ្រូអានពាក្យឱ្យសិស្សស្តាប់ និងថាតាមទាំងអស់គ្នា ៖
    - គ្រូបង្ហាញបណ្ណពាក្យ រួចសរសេរពាក្យលើក្តារខៀនឱ្យសិស្សអានជាបុគ្គល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ឱ្យសិស្សអានពាក្យនីមួយៗឡើងវិញដោយប្រកប

- គ្រូចង្អុលព្យាង្គ ពាក្យឆ្លាស់គ្នាឱ្យសិស្សអានជាបុគ្គល ឬគ្រូអានហៅសិស្សចង្អុល
- ឱ្យសិស្សរៀបអក្សរចល័តជាពាក្យតាមការកំណត់របស់គ្រូ តាមក្រុមតូចៗ
- ឱ្យសិស្សអានព្យាង្គ ពាក្យ ល្បះនៅក្នុងសៀវភៅជាបុគ្គល ជាដៃគូ ឬក្រុម ដោយប្តូរវេនគ្នាចង្អុល។

*ការបង្រៀនអំណានអត្ថបទ*

- គ្រូចម្លងអត្ថបទដាក់លើក្តារខៀនបិទវាំងនន ឬសរសេរលើក្រដាសផ្ទាំងធំ ឬប្រើអត្ថបទក្នុងសៀវភៅ
- គ្រូឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់
- លំនាំបង្រៀនអានមានបំណងបណ្តុះបណ្តាលសិស្សលើបំណិនអាន ពាក្យ ឃ្លា ល្បះ រហូតការអានអត្ថបទបានត្រឹមត្រូវ មិនទាក់ ឬរដាក់រដុប និងដើម្បីជួយដល់ការសរសេរបានច្បាស់ត្រឹមត្រូវ។

*ការចាប់ផ្តើមមេរៀន*

- ការប្រើសំណួរបំផុស ៖ គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីស្ទាបស្ទង់ចំណេះដឹង ឬបទពិសោធរបស់សិស្សទាក់ទងនឹងមេរៀនថ្មី
- គ្រូឱ្យសិស្សមើលរូបភាព រួចគ្រូសួរសំណួរលើរូបភាព។

***<u>ការអានលើកទី១</u>***

- គ្រូឱ្យសិស្សអានអត្ថបទរៀងៗខ្លួនដោយស្ងៀមស្ងាត់

- គ្រូឱ្យសិស្សម្នាក់ៗរកពាក្យដែលគេមិនទាន់ចេះអាន និងពិបាកយល់ន័យ ហើយប្រាប់គ្រូឱ្យសរសេរ ពាក្យទាំងនោះនៅលើក្តារខៀន

- ក្នុងករណីមានពាក្យពិបាកផ្សេងទៀតនៅក្នុងអត្ថបទ ហើយមិនមានប្រាប់ក្នុងការរៀនពាក្យ គ្រូគប្បីបង្រៀនដោយអានពាក្យទាំងនោះឱ្យសិស្សស្តាប់ និងអានតាម ៖

- គ្រូហៅពាក្យម្តងមួយៗឱ្យសិស្សសរសេរលើក្តារឆ្នួន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- គ្រូពន្យល់ន័យរបស់ពាក្យ ដោយប្រើប្រាស់រូបភាព វត្ថុជាក់ស្ដែងជាជំនួយ លើកឧទាហរណ៍ ធ្វើការប្រៀបធៀប ឬធ្វើកាយវិការ ដើម្បីបញ្ជាក់ន័យរបស់ពាក្យទៅតាមប្រភេទពាក្យនីមួយៗ។

***ការអានលើកទី២***

- គ្រូអានអត្ថបទមួយចប់ដោយមានការលើកដាក់សំឡេងជាគំរូ។ សិស្សម្នាក់ៗផ្ទៀងតាមដោយប្រើអត្ថបទនៅក្នុងសៀវភៅរបស់គេ

- គ្រូ និងសិស្សអានអត្ថបទជាមួយគ្នា

- ចែកសិស្សជាក្រុមតូចៗ ដើម្បីឱ្យសិស្សតាមក្រុមអានរួមគ្នាដោយប្រើសៀវភៅតែមួយ

- ឱ្យសិស្សអានសៀវភៅជាដៃគូរួមគ្នា

- ឱ្យសិស្សអានសៀវភៅជាបុគ្គល

- ឱ្យសិស្សអានសំណួរមួយក្នុងសៀវភៅជាមុនសិន មុននឹងអានអត្ថបទ

- ឱ្យសិស្សអានអត្ថបទ ដោយស្ងៀមស្ងាត់ម្ដងទៀត ដើម្បីយល់ខ្លឹមសារមេរៀន

- ឱ្យសិស្សឆ្លើយសំណួរនៅក្នុងសៀវភៅ។ បើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបាន គ្រូត្រូវឱ្យសិស្សអានត្រង់វគ្គ ដែលទាក់ទងនឹងសំណួរទាំងនោះឡើងវិញដោយស្ងៀមស្ងាត់ ឬដោយឮៗ ដើម្បីយល់ន័យអាចឆ្លើយបាន

- សួរសំណួរទាក់ទងបទពិសោធដែលសិស្សយល់បានពីខ្លឹមសារ និងន័យនៃអត្ថបទផ្សារភ្ជាប់នឹងការរស់នៅរបស់គេជាក់ស្ដែង។

## ១២.៣. វិធីសាស្ត្របង្រៀនវិទ្យាសាស្ត្រតាមបែបរិះរក

នៅក្នុងឆ្នាំ ២០១១ ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA STEPSAM2) ក្នុងការចងក្រងសៀវភៅណែនាំស្ដីពីការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរក[286] (Inquiry-Based Learning) ក្នុងគោលដៅ

[286] ក្រសួងអប់រំ យុវជន និងកីឡា (២០១១) «សៀវភៅណែនាំស្ដីពីការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរក (Inquiry-Based Learning)» នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អនុវត្តការរៀន និងការបង្រៀនវិទ្យាសាស្ត្រ(គីមីវិទ្យា ជីវវិទ្យា រូបវិទ្យា និងផែនដីវិទ្យា) ឱ្យមានភាពរលូន និងមានប្រសិទ្ធភាព។

### ១២.៣.១ .និយមន័យ

«**ការរិះរក**» ជាវិធីមួយនៅក្នុងវិធីសាស្ត្រ **សិស្សមជ្ឈមណ្ឌល** ដែលផ្តោតទៅលើការអប់រំវិទ្យាសាស្ត្រ។ ការរិះរក គឺជាការរកចំណេះដឹងតាមរយៈសំណួរ ហើយការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរក គឺជាការបង្រៀនដែលលើកទឹកចិត្តឱ្យសិស្សធ្វើការជាមួយគ្នា ដើម្បីផ្តល់ចម្លើយទៅនឹងសំណួររបស់ពួកគាត់ ជាជាងការបង្រៀនដោយផ្ទាល់ពីគ្រូ ធ្វើអ្វីៗតាមគ្រូ។ ការងាររបស់គ្រូនៅក្នុងការបង្រៀន និងរៀនតាមបែបរិះរក គឺមិនមែនផ្តល់ចំណេះដឹងទៅឱ្យសិស្សនោះទេ ប៉ុន្តែត្រូវជួយសិស្សឱ្យរកបាននូវចំណេះដឹងដោយខ្លួនឯង។ ការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរកតម្រូវឱ្យសិស្សសង្កេត និង វិភាគអំពីបាតុភូតវិទ្យាសាស្ត្រ ដើម្បីបង្កើតសំណួរ ធ្វើពិសោធន៍ដើម្បីឆ្លើយទៅនឹងសំណួរ របស់ពួកគេ និងទាញសេចក្តីសន្និដ្ឋានសមស្រប តាមរយៈលទ្ធផលពិសោធ។ នៅក្នុងដំណើរការរិះរកនេះ សិស្សនឹងយល់ពីខ្លឹមសារបានស៊ីជម្រៅ ទទួលបានជំនាញ និងចំណេះដឹងបែបវិទ្យាសាស្ត្រពិតប្រាកដ[287]។ ចំណែកគ្រូវិញក៏អាចទទួលបាននូវបទពិសោធផងដែរ តែគ្រូត្រូវមានចំណេះដឹងខ្ពស់ខាងផ្នែកវិទ្យាសាស្ត្រ។

### ១២.៣.២ .សំណួរគន្លឹះ ការស្រាវជ្រាវ និងការសន្និដ្ឋាន

លក្ខណៈសំខាន់បំផុតនៃវិធីសាស្ត្រនេះ គឺ «សំណួរគន្លឹះ» ដែលត្រូវបានបង្កើតឡើងផ្អែកតាមការសង្កេត និងការពិភាក្សារបស់សិស្សទៅលើបាតុភូតិវិទ្យាសាស្ត្រ ដែលគ្រូបានផ្តល់ឱ្យ ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងមេរៀន។ គ្រូត្រូវជួយតម្រង់ការយកចិត្តទុកដាក់របស់សិស្សទៅលើខ្លឹមសារមេរៀន ដើម្បីជួយឱ្យពួកគេបង្កើតនូវ «សំណួរគន្លឹះ»។ ប្រការនេះ គឺជា «ការបង្ហាញពីបាតុភូត» ដែលផ្តើមចេញពីការសង្កេតបាតុភូតធម្មជាតិដោយគ្រូបង្ហាញសិស្សយ៉ាងជាក់ស្តែង ហើយជំរុញការគិតរបស់សិស្ស ដោយសួរសំណួរថា «ហេតុអ្វី» បានជាមានបាតុភូតនេះ។ ម៉្យាងវិញទៀត គ្រូក៏អាចបង្ហាញរូបភាពបាតុភូតធម្មជាតិអ្វីមួយ ដើម្បីឱ្យសិស្សចោតជាសំណួរឡើង។

[287] ក្រសួងអប់រំ យុវជន និងកីឡា (២០១១) «សៀវភៅណែនាំស្តីពីការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរក (Inquiry-Based Learning)» ទំព័រ ២។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិស្សត្រូវពិភាក្សា និងបង្កើតសម្មតិកម្ម ដើម្បីរៀបចំសកម្មភាព និងប្រមូលទិន្នន័យ ហើយ«សំណួរគន្លឹះ» នេះត្រូវជំរុញឱ្យមាន «សកម្មភាពស្រាវជ្រាវ»។

«ការស្រាវជ្រាវ» គឺជាការពិសោធ ការសង្កេត និងការវិភាគ ដើម្បីឆ្លើយតបទៅនឹង «សំណួរគន្លឹះ» និងដើម្បីទាញនូវ «សេចក្ដីសន្និដ្ឋាន» តាមការរំពឹងទុក។

សិស្សត្រូវទាញយក «សេចក្ដីសន្និដ្ឋាន» ដោយផ្អែកលើសកម្មភាពស្រាវជ្រាវ និងលទ្ធផលពិសោធ។ គ្រូត្រូវពិនិត្យរាល់ដំណើរការទាំងអស់នៅក្នុងពិសោធន៍ ហើយជួយសិស្សឱ្យធ្វើបានត្រឹមត្រូវ។ សិស្សត្រូវពិភាក្សាគ្នា ដើម្បីទាញយក «សេចក្ដីសន្និដ្ឋាន» ដោយផ្អែកលើលទ្ធផលពិសោធ។ ដោយផ្អែកលើ «សេចក្ដីសន្និដ្ឋាន» នេះ យើងអាចវាយតម្លៃបានថា តើ «ការរិះរក» នេះសម្រេចបានតាម «វត្ថុបំណង» ឬយ៉ាងណានោះ។

## ១២.៤. វិធីសាស្ត្របង្រៀនគណិតវិទ្យា តាមបែបសិស្សមជ្ឈមណ្ឌល[288]

សៀវភៅ «ការវាយតម្លៃក្នុងដំណើរការសិក្សាមុខវិជ្ជាគណិតវិទ្យា នៅបឋមសិក្សា» ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយអង្គការ VVOB លើកទឹកចិត្តឱ្យគ្រូប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលជាគោល។

### ១២.៤.១. លក្ខខណ្ឌសម្រាប់ការអនុវត្ត

វិធីសាស្ត្រនេះមានលក្ខណៈស្មុគស្មាញដែលទាមទារឱ្យគ្រូមានភាពវៃឆ្លាត ទន់ភ្លន់ ចេះបត់បែនតាមស្ថានភាពជាក់ស្ដែងរបស់សិស្ស។ ការប្រើប្រាស់សម្ភារឧបទេសបានច្រើនក៏មិនអាចធានាថា ការបង្រៀននោះគោរពតាមគោលវិធីសិស្សមជ្ឈមណ្ឌល។ គ្រូត្រូវរៀបចំសម្ភារ និងវិធីសាស្ត្របង្រៀនឱ្យមានប្រសិទ្ធភាព ដោយដើរតួជាអ្នកសម្របសម្រួល ជាជាងការផ្ទេរចំណេះដឹងដោយផ្ទាល់។ ហេតុនេះ គ្រូត្រូវមានចំណេះដឹងទូលំទូលាយ និងចេះវាយតម្លៃការយល់ដឹងរបស់សិស្សក្នុងដំណើរការសិក្សា។ តាមរយៈការវាយតម្លៃការយល់ដឹងរបស់សិស្ស គ្រូអាចរកឃើញនូវគំនិតភាន់ច្រឡំរបស់សិស្ស និងលទ្ធភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហា។

---

288 ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) «ការវាយតម្លៃក្នុងដំណើរការសិក្សាមុខវិជ្ជាគណិតវិទ្យា នៅបឋមសិក្សា» នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១២.៤.២. ការបង្រៀនជាក្រុម

ការបង្រៀនគណិតវិទ្យាតាម «**គោលវិធីសិស្សមជ្ឈមណ្ឌល**» តម្រូវឱ្យគ្រូបែងចែកសិស្សឱ្យធ្វើការងារជាក្រុម ដោយក្រុមនីមួយៗត្រូវពិភាក្សាគ្នាលើទ្រឹស្តី និងដោះស្រាយលំហាត់ ហើយត្រូវផ្ទៀងផ្ទាត់ចម្លើយ។

សិស្សត្រូវចូលរួមយ៉ាងសកម្ម ហើយគ្រូជាអ្នកសម្របសម្រួល និងត្រួតពិនិត្យតាមដានគ្រប់សកម្មភាពរបស់ពួកគេ។ គ្រូត្រូវឱ្យសិស្សពន្យល់ពីការគិត និងវាយតម្លៃការយល់ដឹងរបស់ពួកគេ។ គ្រូត្រូវ ៖

- ត្រួតពិនិត្យតាមដាន វាយតម្លៃតម្រូវការក្នុងការរៀនសូត្ររបស់សិស្ស ដោយស្វែងរកគំនិតភាន់ច្រឡំរបស់សិស្សពាក់ព័ន្ធនឹងចំណេះដឹងមានស្រាប់របស់គេ

- បង្កើតផែនការជួយសិស្ស ដោយរៀបចំយុទ្ធវិធីបង្រៀន ដើម្បីរំលេចឱ្យឃើញនូវគំនិតភាន់ច្រឡំ និងផ្លាស់ប្តូរគំនិតឱ្យទាន់ពេលវេលា

- ឆ្លុះបញ្ចាំងលើប្រសិទ្ធភាពនៃការបង្រៀន ដើម្បីជួយគ្រូ ក្នុងការវាយតម្លៃការងារផ្ទាល់ខ្លួន ដូចជាការប្រើប្រាស់វិធីសាស្ត្របង្រៀន ការរៀបចំសកម្មភាព សម្ភារបង្រៀន និងអភិវឌ្ឍមេរៀនឱ្យកាន់តែមានប្រសិទ្ធភាពក្នុងពេលអនាគត។

ការអនុវត្តវិធីសាស្ត្រនេះនឹងជួយឱ្យសិស្សទទួលបាននូវជំនាញទន់ គឺការចេះធ្វើការងារជាក្រុម និងចេះជួយគ្នាផងដែរ។

### ១២.៤.២. ការធ្វើឱ្យសិស្សចេះត្រិះរិះពិចារណា និងការវាយតម្លៃសិក្សា

គោលដៅនៃការបង្រៀនមុខវិជ្ជាគណិតវិទ្យា ដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈ-មណ្ឌល គឺចង់ឱ្យសិស្សចេះត្រិះរិះពិចារណា ចេះគិតដោយខ្លួនឯងថា តើត្រូវដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច ដោយមិនត្រឹមតែទន្ទេញរូបមន្តឱ្យចាំមាត់ទេ តែត្រូវដឹងថា តើត្រូវរករូបមន្តនេះតាមវិធីណា។ សិស្សត្រូវដឹងថា តើចម្លើយណាត្រឹមត្រូវ ហើយចម្លើយណាដែលខុស។ ដូច្នេះ សិស្សត្រូវដឹងថាមូលហេតុអ្វី ដែលចម្លើយនេះត្រឹមត្រូវ ឬខុស។

គ្រូត្រូវវាយតម្លៃក្នុងដំណើរការសិក្សា ដោយធ្វើការពិនិត្យតាមដានការងារ និងការរីកចម្រើនរបស់សិស្ស រួចហើយកត់ត្រាទុក ព្រមទាំងផ្តល់អនុសាសន៍ និងព័ត៌មានត្រឡប់ពីសកម្មភាពផ្សេងៗ ជាជាងការដាក់ពិន្ទុដោយការធ្វើតេស្ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សិស្សក៏ត្រូវវាយតម្លៃសិក្សាដោយខ្លួនឯងផងដែរ។ នៅពេលសិស្សធ្វើការចប់ គេអាចប្រើប្រាស់អត្រាកំណែ ដើម្បីផ្ទៀងផ្ទាត់កិច្ចការរបស់គេ តាមរយៈចម្លើយដែលគេបានរកឃើញ។ តែប្រសិនបើគេមិនអាចរកចម្លើយដោយខ្លួនឯងបាន គេអាចរកជំនួយពីមិត្តរួមថ្នាក់ ឬគ្រូរបស់ពួកគេ។

គ្រូក៏អាចប្រើវិធីវាយតម្លៃ ដោយឱ្យសិស្សធ្វើការវាយតម្លៃកិច្ចការគ្នាទៅវិញទៅមក។ គ្រូត្រូវពន្យល់សិស្សពីរបៀបនៃការវាយតម្លៃគ្នាទៅវិញទៅមក។ គ្រូឱ្យសិស្សបង្កើតការងារធ្វើដោយខ្លួនឯង ហើយពេលធ្វើចប់ត្រូវប្តូរការងារគ្នាទៅវិញទៅមកជាមួយដៃគូ។ បន្ទាប់ពីការកែទៅវិញទៅមករួច គេត្រូវពិភាក្សារកចម្លើយត្រឹមត្រូវ។ សិស្សទាំងអស់ត្រូវបកស្រាយនូវចម្លើយរបស់ខ្លួននៅចុងបញ្ចប់នៃសកម្មភាព។ គ្រូត្រូវផ្តល់ព័ត៌មានកែលម្អជាចុងក្រោយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៣
# ការផ្តល់ប្រឹក្សាអាជីព ដើម្បីដោះស្រាយគម្លាតជំនាញ និងលើកកម្ពស់ជំនាញទន់

**ការផ្តល់ប្រឹក្សាអាជីព** គឺជា «ដំណើរការ ដែលអ្នកផ្តល់ប្រឹក្សា និងអ្នកទទួលប្រឹក្សាត្រូវសហការគ្នាប្រកបដោយជវភាព ដោយផ្តោតទៅលើការកំណត់ និងការធ្វើតាមគោលដៅរបស់អ្នកទទួលប្រឹក្សា។ នៅក្នុងដំណើរការនេះ អ្នកផ្តល់ប្រឹក្សាត្រូវប្រើប្រាស់នូវបច្ចេកទេស និងដំណើរការ ដើម្បីឱ្យអ្នកទទួលប្រឹក្សាចេះស្គាល់ខ្លួនឯង យល់ដឹងពីជំរើសផ្សេងៗក្នុងការចាប់យកអាជីព និងធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ និងដោយ ឈរលើមូលដ្ឋាននៃព័ត៌មាន ដែលអ្នកផ្តល់ព័ត៌មានត្រូវផ្តល់ឱ្យ»[289]។ ជារួម ការផ្តល់ប្រឹក្សាអាជីពអាចចែកចេញជាសមាសភាគចំនួន ៤ សំខាន់ៗ[290] ៖

ទីមួយ-ជួយដល់បុគ្គលម្នាក់ៗឱ្យស្គាល់ខ្លួងឯងឱ្យច្បាស់ ពីចំណង់ចំណូលចិត្ត ចំណាប់អារម្មណ៍ តម្លៃ សមត្ថភាព និងលក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈរបស់ខ្លួន។

ទីពីរ-បណ្តុះបណ្តាលឱ្យសិស្ស និងនិស្សិតចេះរកព័ត៌មាន ដើម្បីឱ្យពួកគេមានការយល់ដឹងពីទីផ្សារការងារ អាជីព និងមុខជំនាញដែលពួកគេត្រូវជ្រើសរើស។

ទីបី-បង្ហាត់បង្រៀនឱ្យសិស្ស និងនិស្សិតចេះធ្វើការសម្រេចចិត្ត ដើម្បីឱ្យពួកគេជ្រើសរើសយកគន្លងអាជីព ដែលត្រូវទៅនឹងចំណង់ចំណូលចិត្ត ចំណាប់អារម្មណ៍ តម្លៃ សមត្ថភាព និងលក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈរបស់ពួកគេ។

ទីបួន-ជួយឱ្យបុគ្គលម្នាក់ៗសកម្មម្ចាស់ការ ក្នុងការជ្រើសរើសគន្លងអាជីព និងត្រៀមខ្លួនក្នុងការរៀនសូត្រពេញមួយជីវិត ដោយរៀបចំនូវផែនការឱ្យបានច្បាស់លាស់ក្នុងការអភិវឌ្ឍជំនាញរបស់ខ្លួនជាប់ជាប្រចាំ។

---

[289] UNESCO (2002). Handbook on Career Counselling. A practical manual for developing, implementing and assessing career counseling services in higher education settings. Paris, p. 5.
[290] UNESCO (2002). *Op. cit.*, p. 4.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងគោលដៅដោះស្រាយប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវបញ្ហា **គម្លាតជំនាញ** និងកាត់បន្ថយការបោះបង់ចោលការសិក្សានៅកម្រិតមធ្យមសិក្សា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំនិងអនុម័តនូវមគ្គុទ្ទេសក៍ស្តីពី «**ការផ្តល់ការប្រឹក្សាអាជីព និងព័ត៌មានស្តីពីការសិក្សាជំនាញ**»[291]។ ក្រសួងមានគោលបំណងបញ្ចូលការផ្តល់ប្រឹក្សាអាជីព ក្នុងកម្មវិធីសិក្សា ដោយបណ្តុះបណ្តាលគ្រូប្រឹក្សាអាជីព និងអនុវត្តកម្មវិធីប្រឹក្សាអាជីព ចាប់ពីកម្រិតមធ្យមសិក្សាបឋមភូមិ នៅក្នុងម៉ោងមុខវិជ្ជាបំណិនជីវិត។ សម្រាប់មធ្យមសិក្សាបឋមភូមិ មគ្គុទ្ទេសក៍នៃការអប់រំនិងវិជ្ជាជីវៈបានរួមបញ្ចូលនូវចំណុចសំខាន់ៗមួយចំនួនដូចជាការសិក្សាជំនាញ ការធ្វើការងារនៅសហគមន៍របស់សាលារៀន ចំណេះដឹងផ្ទាល់ខ្លួន ជម្រើសសម្រាប់ការសិក្សា ការបន្តមុខរបរ និងវិស័យមុខរបរ ព្រមទាំងជីវិតការងារ។ ការប្រឹក្សាអាជីពចែកចេញជា ៥ ដំណាក់កាលសំខាន់ៗ ៖

## ១៣.១. ការស្គាល់ខ្លួនឯង

នៅក្នុងដំណាក់កាលដំបូងនៃវដ្តប្រឹក្សាអាជីពនេះ គឺជួយឱ្យសិស្សបង្កើនចំណេះដឹងអំពីខ្លួនឯង បុគ្គលិកលក្ខណៈ អារម្មណ៍ ចំណង់ចំណូលចិត្ត និងចំណាប់អារម្មណ៍។ ម្យ៉ាងវិញទៀត ការប្រឹក្សាអាជីពមានគោលបំណងជួយសិស្ស ឱ្យស្គាល់អ្នកដែលអាចជួយគាំទ្រពួកគេ ក្នុងជីវិតរស់នៅប្រចាំថ្ងៃទាំងក្នុងសាលារៀន និងក្នុងផ្ទះ ឬជួយគាំទ្រក្នុងការកសាងអនាគតរបស់ពួកគេ។ ការស្គាល់ខ្លួនឯងអាចឱ្យសិស្សសង្កេតមើល នូវឱកាស និង បរិស្ថានរស់នៅរបស់ពួកគេ។ នេះគឺជាជំហានដំបូងនិងសំខាន់បំផុតក្នុងការប្រឹក្សាអាជីព។

## ១៣.២. ជីវិត និងក្តីសុបិន្តនៃអាជីព

នៅក្នុងដំណាក់កាល ការប្រឹក្សាអាជីពមានទិសដៅជំរុញឱ្យសិស្សបញ្ជាក់ពីក្តីប្រាថ្នា និងក្តីសុបិន្តសម្រាប់អនាគត ទាំងជីវិត និងការងារ។ គ្រូប្រឹក្សាអាជីពត្រូវជំរុញឱ្យសិស្សគិតអំពីការងារក្នុងក្តីសុបិន្ត ឱ្យស៊ីជម្រៅថែមទៀត ជាពិសេសដោយផ្តោតលើប្រភេទ ទីកន្លែង លក្ខខណ្ឌការងារ និងជំនាញដែលត្រូវការ ហើយសិស្សត្រូវរៀនសូត្រអ្វីខ្លះ ដើម្បីសម្រេចគោលដៅនេះ។

ជាដំបូង សិស្សត្រូវកំណត់ថាតើពួកគេធំឡើងចង់ធ្វើអ្វី។ បន្ទាប់មកគ្រូបង្គោលត្រូវសួរសំណួរបន្ថែម ដើម្បីសិក្សាស្វែងយល់ពីការគិត និងការត្រៀមខ្លួនរបស់សិស្ស ដើម្បី

[291] ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ការផ្តល់ប្រឹក្សាអាជីព និងព័ត៌មានស្តីពីការសិក្សាជំនាញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រេចក្តីសុបិន្តរបស់ពួកគេ។ សិស្សត្រូវរៀបរាប់ពីចំណាង់ចំណូលចិត្ត ចំណាប់អារម្មណ៍របស់ពួកគេ ព្រមទាំងឆ្លុះបញ្ចាំងការងារណាមួយដែលជាក្តីសុបិន្តរបស់គេ ដូចជាលក្ខខណ្ឌការងារ ចំណាប់អារម្មណ៍លើមុខវិជ្ជា និងកម្រិតនៃប្រាក់បៀវត្សជាដើម។

## ១៣.៣. ការសិក្សា

ការសិក្សាគឺជាដំណើរការពេញមួយជីវិត ហើយការសិក្សាកើតមានគ្រប់ទីកន្លែងតាមរយៈការអប់រំនិងការងារ និងការធ្វើស្វ័យសិក្សានៅពេលទំនេរ។ គ្រូត្រូវជំរុញឱ្យសិស្សយកចិត្តទុកដាក់ចំពោះកត្តាគាំទ្រការសិក្សា និងធ្វើឱ្យការសិក្សាអាចសម្រេចបាន ដោយស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយ បទពិសោធ និងការយល់ពីរបៀបផ្សេងៗនៃការសិក្សា។ គ្រូប្រឹក្សាអាជីពអាចឱ្យសិស្សពិភាក្សាជាបុគ្គល ជាក្រុមតូច ឬជាក្រុមធំ ទៅលើសំណួរសំខាន់ៗ ដើម្បីគាំទ្រការសិក្សា ឱ្យសិស្សហាត់ពត់ខ្លួនឱ្យក្លាយជាសិស្សពូកែជាពិសេសកំណត់បញ្ហាក្នុងការរៀនសូត្រ។

## ១៣.៤. ជំនាញ និងភាពខ្លាំង

ជំនាញ គឺលទ្ធភាព និងសមត្ថភាពរបស់បុគ្គល។ សិស្សត្រូវស្គាល់ពីភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន។ ភាពខ្លាំងរបស់សិស្សត្រូវមានសម្បទាសំខាន់ៗបីគឺ ៖ ជំនាញក្នុងការគិត (ចំណេះដឹង) ជំនាញបច្ចេកទេស (ចំណេះធ្វើ) និង ទំនាក់ទំនងអន្តរបុគ្គល (ឥរិយាបថ)។ ការប្រឹក្សាអាជីពត្រូវជួយឱ្យសិស្សកំណត់នូវភាពខ្លាំង ជំនាញ គុណតម្លៃ និងបុគ្គលិកលក្ខណៈល្អៗរបស់គេ។ បន្ទាប់មក សិស្សត្រូវគិតអំពីទំនាក់ទំនងរវាងភាពខ្លាំងរបស់ខ្លួន និងជម្រើសអាជីព ដោយផ្សារភ្ជាប់រវាងអ្វីដែលខ្លួនគេមានទៅនឹងសុបិន្ត។

ឧទាហរណ៍ សិស្សដែលពូកែភាសា អាចជ្រើសរើសអាជីព ជាអ្នកសារព័ត៌មានបណ្ណារក្ស អ្នកអត្ថាធិប្បាយ បុគ្គលិករដ្ឋបាល អ្នកប្រឹក្សាយោបល់ មេធាវី កវី អ្នកបកប្រែភាសា អ្នកធ្វើបទបង្ហាញតាមវិទ្យុ/ទូរទស្សន៍ អ្នកសរសេរអត្ថបទផ្សាយពាណិជ្ជកម្ម អ្នកលក់ អ្នកប្រឹក្សាព័ត៌មាន និងគ្រូបង្រៀន។

សិស្សដែលពូកែតក្កវិទ្យា និងគណិតវិទ្យា អាចក្លាយទៅជាគណនេយ្យករ អ្នកស្ថិតិ ប៉ូលិស អាកាសចរ អវកាសយានិក អ្នកស្រាវជ្រាវ អ្នកបង្កើតកម្មវិធីកុំព្យូទ័រ វិស្វករ អ្នកស៊ើបអង្កេត ធនាគារិក និងអ្នកវិទ្យាសាស្ត្រ ជាដើម។

សិស្សដែលចូលចិត្តតូរ្យតន្ត្រី អាចក្លាយទៅជាតន្ត្រីករ អ្នកចម្រៀង អ្នកនិពន្ធបទភ្លេងនិងបទចម្រៀង អ្នកសម្តែង គ្រូតន្ត្រី អ្នកបង្កើតឧបករណ៍ភ្លេង អ្នកដឹកនាំវង់ភ្លេង DJ អ្នករៀបចំវីឌីអូនិងភាពយន្ត និងអ្នករៀបចំពិធីជប់លៀងផ្សេងៗ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សិស្សដែលមានកាយសម្បទាល្អ អាចក្លាយទៅជាយន្តការី សិប្បករ គ្រូបង្វឹក អត្តពលិក អ្នកវិភាគកីឡា កីឡាករ អ្នករាំ នាដករ ជាងសំណង់ អ្នកធ្វើសក់ អ្នកសង្គ្រោះ ទន្តពេទ្យ គ្រូពេទ្យវះកាត់ អ្នកសម្តែងភាពយន្ត ទាហាន អ្នកពន្លត់អគ្គិភ័យ អ្នកបើកបរ អ្នកថៃសួន ចុងភៅ និងជាងជួសជុលផ្សេងៗ។

សិស្សដែលពូកែផ្នែកទំនាក់ទំនងអាចជ្រើសរើសអាជីព ជាគ្រូបង្រៀន តួសម្តែង អ្នកលក់ អ្នកគ្រប់គ្រង អ្នកសម្ភាសន៍ អ្នកនយោបាយ អ្នកធ្វើការងារសង្គម អ្នកផ្តល់ប្រឹក្សា អ្នកជំនួញ ភ្នាក់ងារទេសចរណ៍ អ្នកគ្រប់គ្រងសណ្ឋាគារ និងអ្នកផ្សព្វផ្សាយជាដើម។

សិស្សដែលពូកែផ្នែកចិត្តសាស្ត្រ និងអារម្មណ៍អាចក្លាយទៅជាសិល្បករ ម្ចាស់ជំនួញខ្នាតតូច អ្នកស៊ើបអង្កេត ចាងហ្វាងខ្សែភាពយន្ត អ្នកប្រឹក្សា អ្នកធ្វើការផ្នែកសង្គម អ្នកធ្វើផែនការ អ្នកស្រាវជ្រាវ ចិត្តវិទូ ទស្សនវិទូ អ្នកបណ្តុះបណ្តាល ឬអ្នកនិពន្ធ ជាដើម។

### ១៣.៥. ការអប់រំ និងជម្រើសនៃអាជីព

ការប្រឹក្សាអាជីពនេះនៅដំណាក់កាលនេះ គឺជួយឱ្យសិស្សឱ្យយល់ដឹងនូវទិដ្ឋភាពពាក់ព័ន្ធទាំងអស់ដែលមានឥទ្ធិពលដល់ជម្រើសនៃអាជីព ស្វែងយល់ពីចំណាប់អារម្មណ៍បច្ចុប្បន្ន ក្តីរំពឹងទុកនាពេលអនាគត កំណត់ការងារ ដែលសិស្សចាត់ទុកថាជាជម្រើសអាជីពនៅថ្ងៃអនាគត ការប្រមូលព័ត៌មានអំពីការអប់រំ និងការបណ្តុះបណ្តាលសម្រាប់អាជីពដែលបានគ្រោងទុក រៀបចំជំហានបន្ទាប់ដែលគេត្រូវដើរទៅមុខ ការសិក្សា និងគន្លងអាជីពបន្ទាប់ពីបញ្ចប់ការសិក្សា និងការរៀបចំផែនការដើម្បីសម្រេចគោលដៅ។

### ១៣.៦. តេស្តហូឡែនខូដ (RIASEC test)

យើងអាចបែងចែកការងារជា ៦ ប្រភេទ ទៅតាមចំណាប់អារម្មណ៍ ៖

R =វិស័យដែលមានការអនុវត្តជាក់ស្តែង ការងារក្រៅការិយាល័យ

I =វិស័យខាងវិទ្យាសាស្ត្រ ការស្រាវជ្រាវវិទ្យាសាស្ត្រសង្គម និងធម្មជាតិ

A =វិស័យសិល្បៈ

S =វិស័យទំនាក់ទំនង ការថែទាំសុខភាព និងសង្គម ការអប់រំ

E = ការគ្រប់គ្រង ការប្រើឥទ្ធិពលលើអ្នកដទៃតាមរយៈការដឹកនាំ សហគ្រិនភាព

C = ការងារការិយាល័យ ការបញ្ចូលទិន្នន័យ (ផ្នែកលេខ)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចន ហូឡែន និយាយថា ជម្រើសនៃអាជីព គឺជាការបញ្ជាក់ពីចរិយាសម្បត្តិ។ លើសពីនេះការជ្រើសយកអាជីព មុខជំនាញ ឬកម្មវិធីបណ្តុះបណ្តាល ឱ្យត្រូវនឹងចរិយាសម្បត្តិ គឺនាំមកនូវការពេញចិត្ត និងភាពជោគជ័យក្នុងការងារ។

យោងតាមលោកហូឡែន មនុស្សត្រូវបានបែងចែកដោយផ្អែកលើមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ជីវិតរបស់គេ ទៅជាប្រាំមួយក្រុមដោយមានទម្រង់នៃបុគ្គលិកលក្ខណៈ ឬចំណាប់អារម្មណ៍ផ្សេងៗគ្នាដូចជា ៖ អ្នកប្រាកដនិយម អ្នកពូកែអង្កេត អ្នកសិល្បៈនិយម អ្នកខាងសង្គម អ្នកខាងសណ្តាប់ធ្នាប់ និងអ្នកខាងត្រិះរិះពិចារណា។ ប្រភេទទាំងប្រាំមួយនាំឱ្យមានអក្សរកាត់ថា RIASEC។ យោងតាមលោក **ហូឡែន** យើងទាំងអស់គ្នាមានចំណាប់អារម្មណ៍មួយចំនួន ប្រហាក់ប្រហែលគ្នានឹងប្រភេទពីរឬបីក្នុងចំណោមប្រភេទទាំងប្រាំមួយ (R, I, A, S, E or C) ប៉ុន្តែយើងចាប់អារម្មណ៍ជាចម្បងតែលើបីប្រភេទនៃវិស័យទាំងនោះដែលកើតចេញពីបន្សំនៃចម្លាស់អក្សរទាំង៦តួខាងលើ។

តេស្តលេខកូដ ហូឡែន ជាម៉ូដែលកំពុងពេញនិយមសម្រាប់ប្រើធ្វើតេស្តស្តីពីអាជីពនាពេលបច្ចុប្បន្ន។ ទោះជាតេស្តមិនតម្រូវឱ្យមានចម្លើយពិតប្រាកដក៏ដោយ វាមិនមានន័យថាតេស្តសមត្ថភាពនេះ មិនគួរឱ្យទុកចិត្តបាននោះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួររក្សាទុកក្នុងចិត្តថា លទ្ធផលនៃតេស្តនេះគ្រាន់តែនាំអ្នកឱ្យស្គាល់ពីរបៀបជ្រើសផ្លូវអាជីពប៉ុណ្ណោះទេ។

*តារាងទី៣៤ ៖ ការពិពណ៌នាប្រភេទនៃបុគ្គលិកលក្ខណៈរបស់ ហូ ឡែន*

| ប្រភេទនៃបុគ្គលិកលក្ខណៈ | ការពិពណ៌នាទូទៅ | វិស័យនៃអាជីព |
|---|---|---|
| អ្នកប្រាកដនិយម R | មនុស្សប្រាកដនិយម ប្រសប់នឹងការងារ នឹងធឹង ធម្មតា មានការតស៊ូ ដាក់ខ្លួន ស្ងៀមស្ងាត់ ចិត្តទូលាយ និងអៀនខ្មាស។ ពួកគេមានសមត្ថភាពខាងអត្តពលកម្ម និងខាងយានយន្ត។ គេចូលចិត្តធ្វើការជាមួយ ម៉ាស៊ីន ឧបករណ៍ រោងចក្រ សត្វ ឬក្រៅការិយាល័យ។ ពួកគេមិនចូលចិត្តការងារក្រដាសស្នាម និងអាចមានអារម្មណ៍មិនស្រួលក្នុងមជ្ឈដ្ឋានសង្គម។ | កសិកម្ម សេវាសុខភាព បច្ចេកវិទ្យាព័ត៌មាន ការសាងសង់គ្រឿងយន្ត វិស្វកម្ម អាហារ និងបដិសណ្ឋារកិច្ច |
| អ្នកពូកែអង្កេត I | អ្នកអង្កេត ជាប្រភេទមនុស្សចេះវិភាគ ឆ្លាតខាងវិទ្យាសាស្ត្រ ខាងរុករក ទិតៀន ចង់ចេះចង់ដឹង ឯករាជ្យ ឆ្ងើង និងគោរពពេលវេលា។ គេចូលចិត្តសង្កេត វិភាគវាយតម្លៃ ឬដោះស្រាយបញ្ហា។ ពួកគេផ្តោតលើ លទ្ធផលការងារ និងចូលចិត្តកិច្ចការ | ជីវវិទ្យា វិស្វកម្ម គីមី ឱសថ/សល្យសាស្ត្រ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | ផ្សេងៗគ្នា។ ពួកគេចូលចិត្តធ្វើការឯករាជ្យ ហើយមិនចូលចិត្ត សកម្មភាពដដែលៗទេ។ ពួកគេអាចខ្វះជំនាញដឹកនាំ។ | សេដ្ឋកិច្ច<br>អតិថិជន<br>ចិត្តវិទ្យា |
| **អ្នកសិល្បៈនិយម**<br>A | មនុស្សសិល្បៈមានគំនិតច្នៃប្រឌិត ចិត្តទូលាយ បង្កើតថ្មី រក្សាភាពដើម ឆាប់ដឹង ឆាប់យល់អារម្មណ៍ ឯករាជ្យ ហើយឆាប់ រំជួលចិត្ត។ គេមិនចូលចិត្តរចនាសម្ពន្ធ ក្បួនច្បាប់ទេ ពោលគឺ អ្នកសិល្បៈធ្វើការក្នុងបរិស្ថានប្រកបដោយសេរីភាព ដោយ ប្រើក្តីស្រមៃរបស់គេ។ ពួកគេសុខចិត្តប្រថុយប្រថាន ដើម្បី សាកល្បងអ្វីដែលថ្មី ប៉ុន្តែមិនសូវចូលចិត្តយកចិត្តទុកដាក់លើ ភាពល្អិតល្អន់ទេ។ | ការទំនាក់ទំនង<br>លោហធាតុវិទ្យា<br>វិចិត្រសិល្បៈ និង<br>ការសំដែង ការថតរូប<br>វិទ្យុ និងទូរទស្សន៍<br>ការតុបតែងផ្ទះ<br>ស្ថាបត្យកម្ម<br>សិល្បៈ និង<br>ការទាក់ទង |
| **អ្នកខាងសង្គម**<br>S | មនុស្សខាងសង្គម មានភាពរួសរាយ ចិត្តល្អ ពូកែយល់ ចេះ ជួយសហការ គាំទ្រ រាក់ទាក់ និងមានទំនួលខុសត្រូវ។ ពួកគេ ចូលចិត្តធ្វើការជាមួយមនុស្ស ហើយមានការបារម្ភពីសុខុមាល ភាពអ្នកដទៃ។ ពួកគេមានជំនាញថ្វីមាត់ និងទំនាក់ទំនងល្អ។ មនុស្សខាងសង្គមមិនចូលចិត្តធ្វើការងារជាមួយម៉ាស៊ីន ឬ ស្ថានភាពដែលមានរចនាសម្ពន្ធទំនើបពេកទេ។ | ការប្រឹក្សាយោបល់<br>ការព្យាបាល<br>ការព្យាបាលផ្លូវចិត្ត<br>ការធ្វើដំណើរ<br>ការផ្សព្វផ្សាយ<br>ទំនាក់ទំនងអន្តរជាតិ<br>ការអប់រំ សេវាសុខភាព<br>សេវាកម្មធនធានមនុស្ស<br>និងសេវា<br>សាធារណៈ |
| **អ្នកខាង សណ្តាប់ធ្នាប់**<br>E | មនុស្សខាងសហគ្រាស គឺមានមហិច្ឆតាខ្ពស់ ប្រកួតប្រជែង មាន កម្លាំងចិត្ត ប្រកបដោយសុទិដ្ឋិនិយម រួសរាយ មានទំនុកចិត្ត លើខ្លួនឯង និងក្លាហាន។ ពួកគេក៏ឱ្យតម្លៃលើកិត្តយស អំណាច លុយ និងឋានៈ។ គេចូលចិត្តធ្វើការជាមួយអ្នកដទៃ ហើយចូលចិត្តធ្វើអ្វីធ្វើឱ្យកើត។ ពួកគេជាអ្នកដឹកនាំដ៏ខ្លាំង ប្រកបដោយជំនាញថ្វីមាត់ និងមានឆន្ទៈមោះមុតដើម្បីសម្រេច គោលដៅរបស់អង្គភាព ឬភាពចំណេញផ្នែកសេដ្ឋកិច្ច។ ពួកគេ មិនចូលចិត្តវិទ្យាសាស្ត្រ និងការគិតជាប្រព័ន្ធឡើយ។ | សុរិយោដី<br>ទីផ្សារ/ផ្នែកលក់<br>ច្បាប់ វិទ្យាសាស្ត្រ<br>នយោបាយ<br>ពាណិជ្ជកម្មអន្តរជាតិ<br>ជំនួញផ្នែកហិរញ្ញវត្ថុ/<br>ធនាគារ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| **អ្នកខាងត្រិវិះ C** | អ្នកខាងត្រិវិះ ជាមនុស្សផ្ដោតលើភាពល្អិតល្អន់ មានសណ្ដាប់ធ្នាប់ មានមនសិការ មានប្រសិទ្ធផល ប្រសប់នឹងការងារ ស្ងប់ស្ងាត់ មានទំនួលខុសត្រូវ អភិរក្ស និងឆ្អើង។ ពួកគេចូលចិត្តបរិស្ថានរៀបរយ ហើយធ្វើតាមនីតិវិធី និងទម្លាប់ដែលបានរៀបចំទុក។ គេជាមនុស្សមានប្រសិទ្ធភាពចំពោះកិច្ចការដែលមានភាពច្បាស់លាស់។ ពួកគេចូលចិត្តការងារខាងទិន្នន័យ និងការងារលម្អិតជាជាងការប្រើគំនិត។ ពួកគេជៀសវាងស្ថានភាព ឬបញ្ហាមិនច្បាស់លាស់។ | គណនេយ្យ<br>របាយការណ៍ តុលាការ<br>ការធានារ៉ាប់រង<br>រដ្ឋបាល<br>កំណត់ត្រាឱសថ<br>ធនាគារ<br>ការគ្រប់គ្រងទិន្នន័យ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ការផ្ដល់ប្រឹក្សាអាជីព និងព័ត៌មានស្ដីពីការសិក្សាជំនាញ*

លំហាត់នេះ អាចយកមកប្រើប្រាស់សម្រាប់ការប្រឹក្សាយោបល់មុខទល់មុខ (Face to Face) និងក្នុងថ្នាក់រៀន (Classroom Guidance) ហើយក៏អាចយកមកប្រើប្រាស់ជាកិច្ចការផ្ទះបានដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៤
# ហិរញ្ញប្បទានក្នុងវិស័យអប់រំ

## ១៤.១. សាវតារ

បន្ទាប់ពីជម្លោះជិតពីរទសវត្សរ៍ បរិយាកាសនយោបាយក្នុងប្រទេសកម្ពុជាមានភាពអំណោយផលសម្រាប់ការចាប់ផ្តើមកាត់បន្ថយចំណាយលើសន្តិសុខ និងការពារជាតិ ហើយបង្កើនចំណាយផ្នែកសង្គម។ ចាប់តាំងពីឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានធ្វើវិចារណ-កម្មមុខចំណាយកាន់តែរន្តើនឡើងៗ។ កម្លាំងរុញច្រាននៃគោលនយោបាយនេះ គឺការឈានទៅអនុវត្ត «របៀបវារៈគោលនយោបាយថ្មីផ្នែកសង្គម» នៃប្រទេសកម្ពុជា។ អាទិភាពគឺការតម្រង់ទិសនៃកំណើនសេដ្ឋកិច្ចឱ្យបម្រើប្រជាជនក្រីក្រ។ ក្នុងការអនុវត្ត «របៀបវារៈគោលនយោបាយថ្មីផ្នែកសង្គម» ជាក់ស្តែង រាជរដ្ឋាភិបាលបានបង្កើនការបែងចែកថវិកាដល់វិស័យអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ ដែលជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ច សមធម៌ និងវឌ្ឍនភាព ក្នុងពេលអនាគត។ រាជរដ្ឋាភិបាលកំពុងបន្តធ្វើការកែទម្រង់ប្រព័ន្ធអប់រំ និងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សតាមមធ្យោបាយផ្សេងៗទៀត ដើម្បីពង្រឹងសមត្ថភាពប្រជាជនកម្ពុជា ឱ្យកាន់តែមានផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ក្នុងបរិការណ៍នៃសេដ្ឋកិច្ចសកល។ «របៀបវារៈគោលនយោបាយថ្មីផ្នែកសង្គម» មានទស្សនវិស័យ «**កសាងសង្គមកម្ពុជា ដែលមានកោសិកាផ្សារភ្ជាប់គ្នា មានការអប់រំឈានមុខ និងមានវប្បធម៌រស់រវើក**» ដែលទាមទារការដោះ-ស្រាយបញ្ហានៃភាពក្រីក្រ អនក្ខរភាព និង ជំងឺតម្កាត់។ គោលបំណងចម្បង គឺរក្សាចីរភាពនៃការបែងចែកធនធានទៅដល់ក្រសួងអាទិភាព ជាពិសេស ផ្នែកអប់រំ និងសុខាភិបាល។ ការផ្លាស់ប្តូរនេះបានបង្ហាញឱ្យឃើញក្នុងទិដ្ឋភាពច្រើនយ៉ាង តាមរយៈការកើនឡើងនូវចំណែកនៃថវិការបស់ក្រសួងអាទិភាព ជាទឹកប្រាក់ថវិកា ជាចំណែកនៃថវិកាសរុប និងចំណែកនៃផលិតផលក្នុងស្រុកសរុប ។

## ១៤.២. និន្នាការនៃថវិកាក្នុងវិស័យអប់រំ

សកម្មភាពគន្លឹះៗនៃផ្នែកចំណាយសាធារណៈរួមមាន ការចាប់ផ្តើម **កម្មវិធីសកម្មភាពអាទិភាព** (Priority Action Program) ដើម្បីជំរុញការបើកផ្តល់ថវិកាក្នុងវិស័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាទិភាពទាំងនោះ ក៏ដូចជា ការលុបចេញបុគ្គលិកខ្មោច និងទាហានខ្មោច ចេញពីការចំណាយបៀវត្សរបស់មន្ត្រីរាជការ។

ចំណាយផ្នែកសន្តិសុខ និងការពារជាតិបានកាត់បន្ថយពី ៦,១ % នៃផសស ក្នុងឆ្នាំ ១៩៩៨ មកត្រឹម ៣,៨% នៃផសស ក្នុងឆ្នាំ ២០០២, មកត្រឹម ២,៨% នៃផសស ក្នុងឆ្នាំ ២០១០ និង ២,៨% នៃផសស ក្នុងឆ្នាំ ២០១៦។ ក្នុងពេលជំណាលគ្នានេះ ចំណាយផ្នែកសង្គមកើនឡើងជាបន្តបន្ទាប់ពី ២,៥% នៃផសស ក្នុងឆ្នាំ១៩៩៨, ទៅដល់ ៣,៥% នៃផសស ក្នុងឆ្នាំ២០១០ និងបន្តកើនឡើងដល់ ៥,២៥% នៃផសស ក្នុងឆ្នាំ ២០១៥។ ភាគច្រើនលើសលប់នៃកំណើននេះត្រូវបានប្រើប្រាស់សម្រាប់បង្កើនចំណាយក្នុងវិស័យអប់រំ និងសុខាភិ-បាល។

ការកែលម្អការគ្រប់គ្រងចំណាយសាធារណៈ គឺជាចំណុចស្លាប់រស់នៃការអនុវត្តគោលនយោបាយសាធារណៈ។ ការអនុវត្តការងារនេះ មានគោលបំណងសម្រេចឱ្យបានលទ្ធផល ដូចខាងក្រោម ៖

– **ប្រសិទ្ធភាពនៃការវិភាជ** (Allocative Efficiency) មានន័យថារដ្ឋាភិបាលគួរចំណាយតែលើមុខសញ្ញាដែលត្រឹមត្រូវ។ ផ្នែកមួយនៃគោលនយោបាយដែលបានស្នើ គឺការបែងចែកធនធានឡើងវិញជាយុទ្ធសាស្ត្រ ឆ្ពោះទៅវិស័យអាទិភាព ជាពិសេស អប់រំ និងសុខាភិបាល ដោយកាត់បន្ថយចំណាយក្នុងវិស័យការពារជាតិ និងសន្តិសុខ។

–**ប្រសិទ្ធភាពនៃប្រតិបត្តិការ** (Operational Efficiency) មានន័យថាអ្នកបង់ពន្ធទទួលបានប្រយោជន៍ច្រើនបំផុតពីប្រាក់ពន្ធ។ នៅពេលដែលរដ្ឋាភិបាលសម្រេចផ្តល់សេវាសាធារណៈក្នុងចំនួន និងគុណភាពជាក់លាក់មួយ សេវាទាំងនោះគួរត្រូវបានផ្តល់ដោយយកការវិភាគចំណេញខាតធ្វើជាមូលដ្ឋាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាពទី១៣ ៖ ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាគិតជាពាន់លានពីឆ្នាំ១៩៩៤-២០១៤*




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ក្របខណ្ឌហិរញ្ញប្បទានវិស័យអប់រំ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងថវិការបស់រដ្ឋាភិបាល។ ភាគច្រើននៃកម្មវិធីអាទិភាពត្រូវបានអនុវត្តដោយប្រើប្រាស់ថវិកាចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាពេលបច្ចុប្បន្ន ហិរញ្ញប្បទានខាងក្រៅក្នុងវិស័យអប់រំត្រូវបានផ្តល់ តាមរយៈថវិកាគាំទ្រ (Budget Support) គម្រោងវិនិយោគមូលធន គម្រោងកសាងសមត្ថភាព និងកម្មវិធីអាទិភាពចរន្តខ្លះ។ ចំណាយសាធារណៈសរុបសម្រាប់វិស័យអប់រំ គឺជាផលបូកចំណាយនៃថវិការដ្ឋ កម្មវិធីជំនួយ និងកម្មវិធីគាំទ្រ។ គោលដៅនៃក្រសួងអប់រំ យុវជន និងកីឡា គឺបង្កើតនូវសេវាអប់រំប្រកបដោយសមភាព ក្នុងទទួលបាន និងមានគុណភាពខ្ពស់។ ចក្ខុវិស័យរបស់ ក្រសួងអប់រំ យុវជន និងកីឡា រួមមានការស្វែងយល់ពីតម្រូវការចាំបាច់នៃប្រព័ន្ធបណ្តុះបណ្តាល និងអប់រំ ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ច បង្កើនលទ្ធភាពទទួលបានការងារ និងបង្កើនឱកាសរកប្រាក់ចំណូល។ ក្នុងច្បាប់ថវិកាឆ្នាំ២០១៦ ចំណាយសរុបមានចំនួនដល់ ១៨ ២៨៤ ពាន់លានរៀល ឬ ២២,៣២% នៃផសស ដែលក្នុងនោះចំណាយចរន្តមានទឹកប្រាក់ចំនួន ១១ ៨២៥ ពាន់លានរៀល ដែលស្មើនឹង ១៤,៨៣% នៃផសស។ លើសពីនេះទៅទៀតចំណាយលើប្រាក់បៀវត្សមានចំនួន ១ ៦២៧ ពាន់លានរៀល ដែលស្មើនឹង ១៣,៦៧% នៃចំណាយចរន្ត ឬ ១,៩៨% នៃផសស។ ចំណាយក្នុងវិស័យការពារជាតិ និងសន្តិសុខ មានចំនួន ៣,៣៨% នៃផសស។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងទី៣៥ ៖ ការបែងចែកតាមវិស័យ និងក្រសួងអាទិភាព*

| | 1994 | 2000 | 2010 | 2014 | 2015 est. | 2016 (BL)[292] |
|---|---|---|---|---|---|---|
| | ភាគរយនៃផ.ស.ស | | | | | |
| ចំណាយសរុប | 15.3 | 14.8 | 21.63 | 21.55 | 20.98 | 22.32 |
| ចំណាយចរន្ត | 8.7 | 9.0 | 10.99 | 12.72 | 13.12 | 14.43 |
| វិស័យរដ្ឋបាលទូទៅ | 1.3 | 2.9 | 1.59 | 1.94 | 2.00 | 1.95 |
| វិស័យការពារជាតិ និងសន្តិសុខ | 6.1 | 3.4 | 2.78 | 3.06 | 3.11 | 3.38 |
| វិស័យសង្គម | 2.4 | 3.8 | 3.78 | 4.30 | 4.84 | 5.24 |
| ដែលក្នុង វិស័យអប់រំ | 1.2 | 1.8 | 1.56 | 1.91 | 2.12 | 2.48 |
| *-ការអប់រំ (គិតជា ពាន់រៀល)* | 61.6 | 183.2 | 824.9 | 1,342 | | |
| *-ជាភាគរយនៃចំណាយចរន្ត* | 6.76 | 11.54 | 14.16 | 15.05 | 16.15 | 17.17 |
| វិស័យសេដ្ឋកិច្ច | 4.7 | 4.0 | 0.95 | 1.19 | 1.33 | 1.41 |
| ចំណាយមូលធនហិរញ្ញប្បទានក្រៅប្រទេស | 0.6 | 5.20 | 7.27 | 6.26 | 4.92 | 4.72 |
| ចំណាយមូលធនហិរញ្ញប្បទានក្នុងប្រទេស | 0.0 | 2.10 | 3.07 | 2.11 | 2.36 | 2.54 |
| ចំណាំ៖ | | | | | | |
| ផសស (គិតជាពាន់រៀល) | 7,105,000 | 14,083,000 | 47,048,000 | 67,740,450 | 74,932,237 | 81,934,333 |
| ចំណាយមូលធនហិរញ្ញប្បទានក្រៅប្រទេស (គិតជាលានដុល្លារអាមេរិក) | | | 855.11 | 1,060.12 | 921.75 | 967.84 |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ចំណាយមូលធនមានចំនួន ៦ ៤៥៤ ពាន់លានរៀល ឬ៧,៨៨%នៃផសស។ អតិរេកថវិកាចរន្តកើនឡើងពី ១,៩៥% នៃផសស ក្នុងឆ្នាំ២០១៣ រហូតដល់ ២,២៨% នៃផសស ក្នុងឆ្នាំ ២០១៤ និង ២,៩៣% នៃផសស ក្នុងឆ្នាំ ២០១៦។ ឱនភាពថវិកាធ្លាក់ចុះពី ៦% នៃផសស ក្នុងឆ្នាំ ២០១៣ មកដល់ -៥,៣២% នៃផសស ក្នុងឆ្នាំ២០១៤ និងដល់ -៤,៧៩%នៃផសស ក្នុងឆ្នាំ ២០១៦។

ស្របគ្នានឹងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ថវិកាឆ្នាំ២០១៦នឹងកែលម្អបន្ថែមទៀតចំពោះចំណាយផ្នែកសង្គម ក៏ដូចជាការកៀរគរធនធានក្នុងផ្នែកនេះ។ ថវិកាឆ្នាំ ២០១៦ គ្រោងឡើងផ្អែកលើកំណើនចំណូលក្នុងប្រទេសរហូតដល់ ១៧,៣៧% នៃផសស ដោយរក្សាចំណាយចរន្តឱ្យនៅត្រឹម ១៤,៤៣% នៃផសស និងការរក្សាអតិរេកថវិកាចរន្ត ២,៩៣% នៃផសស។ ចំណូលសារពើពន្ធមានទំហំ ១៥,០៥% នៃផសស នៅពេលដែលចំណូលមិន

[292] ច្បាប់ថវិកា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មែនសារពើរពន្ធមានទំហំ ២,៣១% នៃផសស។ ចំណូលមកពីនាយកដ្ឋានគយនិងរដ្ឋាករត្រូវបានព្យាករណ៍ថាមានប្រហែលជា ៨,១១%នៃផសស ចំណែកឯចំណូលពីនាយកដ្ឋានពន្ធដារគឺមាន ៥,៩៩% នៃផសស។

ចំណាយសង្គមបានកើនឡើង គួរឱ្យកត់សម្គាល់ក្នុងកំឡុងពេលសិក្សានេះ។ កំណើននេះ មួយចំណែកធំត្រូវបានប្រើប្រាស់សម្រាប់បង្កើនថវិកាក្នុងវិស័យអប់រំ និងសុខាភិបាល។ ដើម្បីគាំទ្រដល់គោលនយោបាយសង្គមដែលរៀបរាប់ខាងលើថវិកាឆ្នាំ ២០១៦ បានបង្កើនដល់វិស័យអប់រំពី ១៧,០៨% នៃថវិកាចរន្តក្នុងឆ្នាំ២០១៥ រហូតដល់ ១៨,២% ក្នុងឆ្នាំ២០១៦។

*រូបភាពទី១៤ ៖ ភាគរយនៃថវិកាចរន្តជាតិដែលបែងចែកទៅក្រសួងអប់រំ យុវជន និងកីឡា*




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ចំណាយរបស់ក្រសួងអប់រំ យុវជន និងកីឡា មានទឹកប្រាក់ ២ ០២៩ ៨៩៦,៩ ពាន់លានរៀល (៥០០ លានដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ។ ជាភាគរយនៃផសស ចំណាយសាធារណៈក្នុងវិស័យអប់រំបានកើនឡើងពី ១,២% នៃផសស នៅឆ្នាំ១៩៩៤ ដល់ ១.៨% នៃផសស នៅឆ្នាំ២០០០ ដល់ ១,៩% នៃផសស នៅឆ្នាំ២០១០ និងរហូតដល់ ២,៤៨% នៃផសស នៅឆ្នាំ២០១៦។ ជាចំណែកនៃចំណាយចរន្តសរុប ដែលបានបែងចែកទៅក្រសួងអប់រំ យុវជន និងកីឡា បានកើនឡើងពី ១១% ក្នុងឆ្នាំ១៩៩៤ ទៅដល់ ១៩,២% ក្នុងឆ្នាំ២០០៧។ ចំណែកនេះបានធ្លាក់ចុះជាបន្តបន្ទាប់ពី ១៩,២% ក្នុងឆ្នាំ២០០៧ មកត្រឹមតែ ១៥,៥% ក្នុងឆ្នាំ២០១៣ ។ ទោះបីជាយ៉ាងណា ក្នុងឆ្នាំ២០១៤ និន្នាការនៃការធ្លាក់ចុះនេះបានផ្លាស់ប្តូរ ហើយបានត្រឡប់កើនឡើងដល់ ១៦,២%វិញ។ ចំណែកនេះបានកើនឡើងបន្ថែមទៀតដល់ ១៧,០៨% ក្នុងឆ្នាំ២០១៥ និង បន្តកើនដល់ ១៨,២% នៃចំណាយចរន្តក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្នាំ២០១៦។ ដូចនេះ ការកើនឡើងយ៉ាងខ្លាំងនេះកើតឡើងរវាងឆ្នាំ ២០០០ និង ២០០៧ និង បន្តកើនក្នុងឆ្នាំ២០១៣ និង២០១៦ នៅពេលដែលថវិកាក្នុងវិស័យអប់រំកើនឡើងគួរឱ្យកត់សម្គាល់។

ទោះបីមានការកើនឡើងបែបនេះក៏ដោយ ក៏នៅមានគម្លាតហិរញ្ញប្បទានគួរឱ្យកត់សម្គាល់សម្រាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធអាទិភាព។ ក្នុងពេលបច្ចុប្បន្ន ក្រសួងកំពុងកែលម្អទាំងការវាយតម្លៃតម្រូវការអាទិភាព ទាំងការកំណត់ប្រភពនៃធនធានដែលអាចប្រើប្រាស់បាននិងធនធានដែលមានសក្តានុពលនឹងប្រើប្រាស់បាន។ គម្លាតហិរញ្ញប្បទានត្រូវបាន់ស្មានថាមានទំហំប្រមាណជា ៥០ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ឱនភាពសរុបនឹងកម្រិតទៅតាមទំហំជំនួយសម្បទានដែលមាន។

ការរក្សាឱ្យបាននូវអតិរេកថវិកាចរន្តមានសារៈសំខាន់ ដើម្បីបន្តធានាបានថាសេដ្ឋកិច្ចប្រព្រឹត្តទៅបានដោយល្អ។ ការកែទម្រង់រចនាសម្ព័ន្ធ និងសារពើពន្ធដែលបានរៀបរាប់ខាងលើ នឹងបង្កើនសក្តានុពលនៃកំណើនចំណូល។ ផលលាភផ្នែកសារពើពន្ធដែលទទួលបានពីការកែទម្រង់នេះ អាចប្រើប្រាស់ដើម្បីបែងចែកទៅលើការបង្កើនចំណាយផ្នែកសេដ្ឋកិច្ច និងសង្គម ក៏ដូចជាផ្តោតលើមុខសញ្ញាចំណាយថ្មីៗ ប៉ុន្តែនៅរក្សាជំហរថវិកាឱ្យបានល្អ។

## ១៤.៣. ការចែកចាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងតាមអនុវិស័យអប់រំ

ថវិកាឆ្នាំ ២០១៦ អាចពិនិត្យលម្អិតទៅតាមប្រភេទចំណាយ ៖ ជំពូក៦០-ការទិញ ជំពូក៦១-សេវា ជំពូក៦២-ផលប្រយោជន៍សង្គម ជំពូក៦៣-ពន្ធដារ ជំពូក៦៤-ចំណាយបុគ្គលិក និង ជំពូក៦៥-ការចូលរួមវិភាគទានសមាជិកភាព។

*តារាងទី៣៦ ៖ ថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (គិតជា លានរៀល)*

| ជំពូក | ច្បាប់ថវិកា ២០១៥ | | ច្បាប់ថវិកា ២០១៦ | | បម្រែបម្រួល |
|---|---|---|---|---|---|
| ៦០-ការទិញ | 138 812,3 | 8,8% | 143 215,7 | 7,1% | 103,2% |
| ៦១-សេវា | 135 721,2 | 8,6% | 156 061,5 | 7,7% | 115,0% |
| ៦៤-បុគ្គលិក | 1 231 016,8 | 77,7% | 1 626 838,1 | 80,1% | 132,5% |
| ៦២-ជំនួយសង្គម | 77 018,4 | 4,9% | 102 877,9 | 5,1% | 133,7% |
| ៦៥-ការឧបត្ថម្ភធន | 423,3 | 0,0% | 440,9 | 0,0% | 104,2% |
| ៦៣-ពន្ធដារ | 316,4 | 0,9% | 462,8 | 0,0% | 146,3% |
| សរុប | 1 583 308,4 | 100% | 2 029 896,9 | 100% | 128,2% |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៥*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការញែកថវិកាឆ្នាំ២០១៦ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ឆ្លុះបញ្ចាំងឱ្យឃើញពីការផ្តោតការយកចិត្តទុកដាក់លើការបង្កើនប្រាក់បៀវត្សសម្រាប់មន្ត្រីស៊ីវិល។ កំណើននេះត្រូវបានផ្តល់ក្នុងគោលបំណងកែលម្អការផ្តល់សេវាអប់រំ។ ចំណាយលើប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភបានកើនឡើងពី ៧២,៩% នៃចំណាយចរន្តបច្ចុប្បន្នក្នុងឆ្នាំ២០០០ ដល់ ៧៧,៧% ក្នុងឆ្នាំ ២០១៥ និងកើនឡើងដល់ ៨០% ក្នុងឆ្នាំ២០១៦ ដែលកើនឡើង ៣២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៥។ ការកើនឡើងនៃចំណាយប្រាក់បៀវត្សគ្រូបង្រៀន គឺបណ្តាលមកពីការកើនឡើងចំនួនគ្រូបង្រៀនសរុប និងការកើនឡើងប្រាក់បៀវត្ស ក៏ដូចជាការកើនឡើងនៃប្រាក់ឧបត្ថម្ភគ្រូជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប និង គ្រូបង្រៀនពីរវេនផងដែរ។ ក្នុងឆ្នាំ ២០១៦ គ្រូបង្រៀនម៉ូស្លឹមចំនួន ១ ៥០០នាក់ នឹងត្រូវបញ្ចូលជាមន្ត្រីស៊ីវិលបន្ថែមទៀត។

*តារាងទី៣៧ ៖ ចំណាយតាមរដ្ឋបាលថ្នាក់កណ្តាល និងខេត្ត (គិតជាពាន់លានរៀល)*

| | 1994 | 2000 | 2010 | 2014 | 2015 (BL) | 2016 (BL) |
|---|---|---|---|---|---|---|
| សរុប | 66,4 | 249,5 | 736,1 | 1 307,67 | 1 813,59 | 2 206,53 |
| ចរន្តនៃប្រាក់បៀវត្ស | 61,6 | 165,8 | 732,0 | 1 296,62 | 1 583,31 | 2 029,90 |
| មូលធន | (86,3) | (72,9) | (72,4) | (78,6%) | (77,7%) | (80,1%) |
| | 4,8 | 83,7 | 4,1 | 11 | 35 | 35 |
| ថ្នាក់កណ្តាល | 11,7 | 38,4 | 122,5 | 197,44 | 632,32 | 467,58 |
| (%) | (19,0) | (23,2) | (16,7) | (15,23) | (34,87) | (21,19) |
| ថ្នាក់ខេត្ត | 54,6 | 127,3 | 609,5 | 1 099,19 | 1 181,28 | 1 738,95 |
| (%) | (81) | (76,8) | (83,3) | (84,77) | (65,13) | (78,81) |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៥*

ចំណាយនៅថ្នាក់កណ្តាលមានតែ ២១% នៃថវិកាអប់រំឆ្នាំ២០១៦ (៤៦៧ ពាន់លានរៀល) នៅពេលដែល ៧៩% នៃថវិកាសរុបត្រូវបានបែងចែកទៅថ្នាក់រាជធានី ខេត្ត។

*តារាងទី៣៨ ៖ និន្នាការថវិកាថ្នាក់កណ្តាល និងខេត្ត ២០០៩–២០១៥*

| | **2009** | **2010** | **2011** | **2012** | **2013** | **2014** | **2015* គិតត្រឹមខែសីហា** |
|---|---|---|---|---|---|---|---|
| **គម្រោងថវិកា** | **795,5** | **853,1** | **915,8** | **1 010** | **1 106** | **1 383** | **1 623,1** |
| *ថ្នាក់កណ្តាល* | *138,4* | *136,2* | *159,8* | *178,9* | *204 7* | *245,3* | *324,4* |
| *ថ្នាក់ខេត្ត* | *657,0* | *716,9* | *766,0* | *831,0* | *901 2* | *1 138,1* | *1 298,6* |
| **ការអនុវត្ត** | **710,6** | **734,1** | **800,2** | **908,8** | **1 017,4** | **1 250,7** | **791,7** |
| *ថ្នាក់កណ្តាល* | *124,0* | *122,5* | *138,0* | *165,6* | *187,2* | *198,0* | *46,8/ 14,4%* |
| *ថ្នាក់ខេត្ត* | *586,6* | *611,6* | *662,2* | *743,2* | *830,2* | *1 052,7* | *744,9/ 57,4%* |
| **អត្រាអនុវត្ត** | **89,3%** | **86,1%** | **87,4%** | **90,0%** | **91,9%** | **90,4%** | **48,7%** |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងទី៣៩ ៖ ការបែងចែកថវិកាតាមអនុវិស័យ (គិតជា ពាន់លានរៀល)*

| | 1994 | 2000 | 2010 | 2014 | 2015 (BL) | 2016 (BL) |
|---|---|---|---|---|---|---|
| រដ្ឋបាលកណ្ដាល(ចរន្ត) | **6,9** | **38,4** | **122,52** | **197,44** | **402,03** | **290,95** |
| អប់រំ | 4,8 | 22,7 | 65,85 | 102,25 | 305,37 | 206,77 |
| *-បឋម* | - | - | - | - | ***4,67*** | ***4,01*** |
| *-មធ្យមសិក្សា* | - | - | - | - | ***25,10*** | ***23,19*** |
| ឧត្តមសិក្សា | 1,47 | 9,0 | 42,19 | 60,28 | 53,08 | 36,88 |
| យុវជននិងកីឡា | 0,6 | 6,7 | 14,48 | 34,91 | 43,58 | 47,30 |
| ខេត្ត | **54,67** | **127,33** | **609,52** | **1 099,19** | **1 181,28** | **1 738,95** |
| សរុប (ថ្នាក់កណ្ដាល+ខេត្ត) | 61,57 | 165,73 | 732,04 | 1 296,62 | 1 583,31 | 2 029,90 |

*ចំណាំ ៖ BL: ច្បាប់ថវិកា*

ថវិការដ្ឋបាលកណ្ដាលបានវិភាជ ទៅកាន់អនុវិស័យអប់រំទូទៅមានទឹកប្រាក់ ២០៦,៧ ពាន់លានរៀល ឬ ១១% នៃថវិកាវិស័យអប់រំ, ក្នុងទឹកប្រាក់ ៣៦ ពាន់រៀល ឬ ៩% ទៅឧត្តមសិក្សា និងក្នុងទឹកប្រាក់ ៤៧ ពាន់លានរៀល ឬ ២,៥% ទៅអនុវិស័យយុវជន និងកីឡា។ ការវិភាជតាមអនុវិស័យនេះឆ្លុះបញ្ចាំងឱ្យឃើញពីកិច្ចប្រឹងប្រែង ជំរុញដំណើរការវិមជ្ឈការ តាមរយៈការផ្ទេរថវិកាទៅដល់ថ្នាក់ក្រោមជាតិ។

*តារាងទី៤០ ៖ និន្នាការនៃការវិភាជថវិការដ្ឋតាមអនុកម្មវិធី និងអនុវិស័យ (គិតជា ពាន់លានរៀល)*

| អនុកម្មវិធីនៃកម្មវិធីទី ១ | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|
| ១. ការពង្រីកការអប់រំកុមារតូច | 792,3 | 1 130,4 | 2 096,4 | 2 260,5 | 3 509,9 |
| ២. ការពង្រឹងការអប់រំបឋម | 45 040,6 | 43 743,3 | 45 390,2 | 54 580,4 | 4 691,0 |
| ៣. ការពង្រឹងការអប់រំមធ្យម | 20 562,5 | 21 055,0 | 21 484,1 | 21 412,0 | 25 147,9 |
| ៤. ការពង្រីកការអប់រំក្រៅប្រព័ន្ធ | 6 241,5 | 6 479,6 | 6 535,7 | 6 773,2 | 6 595,6 |
| ៥. ការពង្រីកសុខភាពសាលា | 1 256,8 | 1 400,0 | 1 060,4 | 1 221,4 | 712,7 |
| ៦. ការពង្រីកការបណ្ដុះបណ្ដាលវិជ្ជាជីវៈ | 773,8 | 584,3 | 514,8 | 826,8 | 5 793,0 |
| ៧. ការអភិវឌ្ឍនិងការបណ្ដុះបណ្ដាលគ្រូបង្រៀន | | | | | 8 277,2 |
| ៨. ការអភិវឌ្ឍកម្មវិធីសិក្សា | | | | | 28 766,7 |
| ៩. សេវាគាំទ្រមន្ទីរខេត្ត | | | | | 139 001 |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

*តារាងទី៨១ ៖ ផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ ឱកាសវិនិយោគតាមអាទិភាពនៃការអប់រំ*

| ភាគរយ | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | 7,2% | 7,1% | 7,0% | 6,8% | 6,4% |
| ការអប់រំបឋម | 47,1% | 46,1% | 46,4% | 46,3% | 45,7% |
| ការអប់រំមធ្យម | 29,4% | 31,8% | 32,5% | 33,3% | 33,6% |
| -មធ្យមសិក្សាបឋមភូមិ | *212%* | *22,8%* | *22,1%* | *21,5%* | *19,9%* |
| -មធ្យមសិក្សាទុតិយភូមិ | *8,3%* | *9,0%* | *10,4%* | *11,8%* | *13,7%* |
| ឧត្តមសិក្សា | 11,8% | 12,0% | 11,6% | 11,3% | 11,8% |
| ការអប់រំក្រៅប្រព័ន្ធ | 1,2% | 1,1% | 1% | 0,9% | 0,8% |
| ការអភិវឌ្ឍយុវជន | 0,6% | 0,6% | 0,5% | 0,5% | 0,4% |
| អប់រំកាយ និងកីឡា | 2,7% | 1,3% | 1,1% | 1% | 1,3% |
| សរុប | **100%** | **100%** | **100%** | **100%** | **100%** |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ប្រកាសអន្តរក្រសួងលេខ ១៩១ (រវាងក្រសួងសេដ្ឋកិច្ច និងក្រសួងអប់រំ) ស្ដីពីនិតីចំណាយថវិកាកម្មវិធីសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់មុខចំណាយអន្តរាគមន៍ ដែលអាចអនុវត្តបាននៅក្រោមថវិកាកម្មវិធីរបស់ក្រសួង។ ការកំណត់មុខចំណាយនេះ បានអនុវត្តចំពោះថវិកាដំណើរការសាលារៀន (SOB) រួមមាន ការបំប៉នសិស្សខ្សោយ ការប្រជុំបច្ចេកទេស និងការបំប៉នបច្ចេកទេសគ្រូ។ ប្រកាសនេះមិនបានធ្វើបច្ចុប្បន្នភាព ចាប់តាំងពីអនុម័តក្នុងឆ្នាំ ២០០៧ មក។ បន្ទាប់ពីមានការពិភាក្សាបន្ថែមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានអនុម័តសេចក្ដីប្រកាសថ្មីមួយ (៥០៨) ដែលបានបង្កើនថវិកាដំណើរការសាលារៀន និងពង្រីកវិសាលភាពដល់សាលាមត្តេយ្យក្នុងប្រព័ន្ធទាំងអស់។ ប្រទេសស៊ុយអែតក៏បានផ្ដល់ថវិកាចំនួន ៥ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៣-២០១៥ ដើម្បីបំពេញបន្ថែមថវិកាដំណើរការសាលារៀន សម្រាប់គាំទ្រការអនុវត្តផែនការកែលម្អសាលារៀន។

ការកើនឡើងនៃថវិកាកម្មវិធីនៃក្រសួងអប់រំ យុវជន និងកីឡា តាមរយៈប្រកាសថ្មីលេខ ៥០៨ និងកើនឡើងនូវប្រាក់បៀវត្សគ្រូបង្រៀន គួរឱ្យកត់សម្គាល់ ត្រូវបានមើលឃើញថា គឺជាបុរេលក្ខខណ្ឌចាំបាច់ ដើម្បីជាធនធាន សម្រាប់ការកែទម្រង់ទូលំទូលាយដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ ឱ្យឈានទៅសម្រេចបានធាតុចេញ និងលទ្ធផលដែលបានកំណត់។ ប្រការនេះនឹងជះឥទ្ធិពលខ្លាំងទៅលើសមភាព និងគុណភាពនៃការទទួលបានសេវាអប់រំ ព្រមទាំងគាំទ្រដល់ដំណើរការវិមជ្ឈការផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណែកភាគច្រើននៃលំហូថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ប្រើប្រាស់សាច់ប្រាក់ជាមូលដ្ឋាន នៅថ្នាក់ខេត្ត (ឧទា.ប្រាក់បៀវត្សគ្រូ និងប្រាក់ឧបត្ថម្ភផ្សេងៗ ថវិកាដំណើរការសាលារៀន និងអាហារូបករណ៍)។ ស្ថានភាពមិនទៀងទាត់នៃសាច់ប្រាក់បានបង្កលទ្ធភាពនាំទៅភាពមិនប្រក្រតីនៃចំណាយ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានយល់ព្រមបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលទាំងអស់តាមប្រព័ន្ធធនាគារ ក្នុងកំឡុងឆ្នាំ ២០១៤-២០១៨។

## ១៤.៤. ការធ្វើថវិកាតាមកម្មវិធី

ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងសាកល្បងមួយ ក្នុងការអនុវត្តកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល។ គោលដៅដ៏ធំមួយនៃការកែទម្រង់នេះ គឺផ្លាស់ប្តូរទៅការអនុវត្តថវិកាតាមកម្មវិធីពេញលេញចាប់ពីឆ្នាំ២០១៥។

ចាប់ពីឆ្នាំ ២០០៧ ដល់ ២០១៤ ភាគរយនៃថវិកាកម្មវិធីធៀបនឹងថវិកាចរន្តប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺមានប្រហែលជា ១៥%។ កម្មវិធីចំនួន ៥ ត្រូវបានរៀបចំឡើងដើម្បីគ្របដណ្តប់លើមុខងារទាំងមូលរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបញ្ចូលទាំងនាយកដ្ឋានបច្ចេកទេសនៅថ្នាក់កណ្តាល មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំស្រុក និងសាលារៀន។ ចាប់តាំងពីឆ្នាំ២០១៥មក ថវិកាទាំងអស់ក្នុងកម្មវិធីទាំង៥ គឺត្រូវប្រើប្រាស់ជាថវិកាកម្មវិធីទាំងស្រុង។

*តារាងទី៤២ ៖ និន្នាការនៃថវិកាកម្មវិធីឆ្នាំ ២០១១-២០១៥ (គិតជា ពាន់លានរៀល)*

| | 2011 | 2012 | 2013 | 2014 | 2015 *<br>គិតត្រឹមសីហា |
|---|---|---|---|---|---|
| គម្រោងថវិកា | 671 645,6 | 745 361,2 | 812 538 | 1 050 548 | 1 086 882 |
| ការអនុវត្ត | 583 844,1 | 663 882,9 | 749 995,1 | 974 760 | 378 170 |
| អត្រាអនុវត្ត | 86,93% | 89,1% | 92,3% | 92,8% | 34,8% |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ចំណាំ ៖

១. ថវិកាកម្មវិធីសម្រាប់ឆ្នាំ ២០១៥ មិនបានបញ្ចូល ថវិកាមូលធនដែលមានទឹកប្រាក់ ៣៥ ពាន់លានរៀល ។

២. ការអនុវត្តចំណាយជាក់ស្តែងសម្រាប់ឆ្នាំ ២០១៥ គិតត្រឹមថ្ងៃទី ៣១ ខែសីហា ដែលអាណត្តិបានបញ្ជូនទៅរតនាគារជាតិប៉ុណ្ណោះ។

៣. សាច់ប្រាក់ជាក់ស្តែងបញ្ចេញពីរតនាគារ គិតត្រឹមខែសីហា គឺមានចំនួន ៨៩៧ ពាន់លានរៀល។

៤. អាណត្តិដែលបានបញ្ជូនទៅអ្នកប្រមូលហិរញ្ញវត្ថុមិនទាន់បានបញ្ចូលជាចំណាយគឺ R16.8B។

៥. អត្រាអនុវត្តរួមបញ្ចូលទាំងធានាចំណាយដែលបានបញ្ជូនទៅក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុគឺ ៥១%។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បន្ថែមលើថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា (ដែលប្រើប្រាស់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ថវិកាដំណើរការសាលារៀន អាហារូបករណ៍ សៀវភៅសិក្សា ការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា សវនកម្ម កិច្ចប្រជុំ និងការចំណាយមិនមែនរដ្ឋបាល និងមិនមែនប្រាក់បៀវត្ស) មានកំណើនមធ្យមតែ ២,៥% ប្រចាំឆ្នាំ ពីឆ្នាំ ២០០៨-២០១២ ប៉ុណ្ណោះ នៅពេលដែលថវិកាមិនមែនកម្មវិធីមានកំណើនជាមធ្យម ១៥,៧% ដែលកំណើននេះបណ្តាលមកពីកំណើនប្រាក់ខែគោលនៃមន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំចំនួន ២០%។ ជាលទ្ធផល ថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡាបានធ្លាក់ចុះពី ២៦,៥% នៃថវិកាចរន្តប្រចាំឆ្នាំរបស់ក្រសួងក្នុងឆ្នាំ ២០០៦ មកត្រឹម ១៣,៧% ក្នុងឆ្នាំ ២០១៣ ហើយអំណាចទិញ (purchasing power) បានថយចុះគួរឱ្យកត់សម្គាល់។

*តារាងទី៤៣ ៖ ការវិភាជថវិកាតាមកម្មវិធី*

| *ពាន់លានរៀល* | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 |
|---|---|---|---|---|---|---|---|
| កម្មវិធីទី ១ | 80,9 | 83,5 | 83,3 | 87,6 | 99,9 | 222,4 | 244,4 |
| កម្មវិធីទី ២ | 3,4 | 4,2 | 4,4 | 4,9 | 5,4 | 53,1 | 36,9 |
| កម្មវិធីទី ៣ | 1,3 | 1,4 | 1,6 | 1,9 | 2,6 | 53,2 | 57 |
| កម្មវិធីទី ៤ | 0,6 | 0,7 | 1,0 | 1,8 | 2,3 | 9,5 | 12,4 |
| កម្មវិធីទី ៥ | 40,7 | 47,9 | 51,1 | 57,1 | 62,3 | 1 245,2 | 1 679,2 |
| សរុប | 127 | 137,6 | 141,5 | 153,2 | 172,5 | 1 583,3 | 2 029,9 |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

**កម្មវិធីទី១** ស្រូបយកចំណែកធំមួយនៃថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីនេះគ្របដណ្តប់លើមុខងារសំខាន់ៗ ដូចជា ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំមធ្យមសិក្សា ការអប់រំបច្ចេកទេស ការអប់រំក្រៅផ្លូវការ សុខភាពនៅសាលារៀន ការបណ្តុះបណ្តាលគ្រូបង្រៀន និង ការអភិវឌ្ឍកម្មវិធីសិក្សា។

**កម្មវិធីទី២** គ្របដណ្តប់មុខងារមួយចំនួននៅកម្រិតឧត្តម ការស្រាវជ្រាវ ការយកចិត្តទុកដាក់លើគុណភាពអប់រំ និងការធានា និងការទទួលស្គាល់គុណភាពអប់រំ ដែលអនុវត្តចំពោះស្ថាប័នឧត្តមសិក្សា។ កញ្ចប់នៃកម្មវិធីទី ២ មិនបានផ្លាស់ប្តូរច្រើនទេក្នុងកំឡុងពេលនេះទេ។

**កម្មវិធីទី៣** គ្របដណ្តប់មុខងារមួយចំនួននៃការអប់រំកាយ និងកីឡា ជាពិសេសកីឡាមហាជន កីឡាគ្រឹះស្ថានអប់រំ និងកីឡាកម្រិតខ្ពស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**កម្មវិធីទី៤** គ្រប់ដណ្ដប់មុខងារខ្លះនៃការអភិវឌ្ឍយុវជន ដែលអនុវត្តដោយនាយកដ្ឋានបច្ចេកទេសចំនួនពីរ និងមជ្ឈមណ្ឌលយុវជនខេត្ត។ កម្មវិធីទាក់ទងនឹងយុវជនផ្សេងទៀត រួមមានកម្មវិធីពង្រឹងក្រុមប្រឹក្សានិស្សិត និងកម្មវិធីសហាគ្រិនភាព។

**កម្មវិធីទី៥** មានចំណែកដ៏ធំបំផុត ដែលគ្របដណ្ដប់លើមុខងារគាំទ្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចជា វិធានការដើម្បីពង្រឹងផែនការវិស័យអប់រំ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងផ្ទៃក្នុង ការវាយតម្លៃការសិក្សា សវនកម្មផ្ទៃក្នុង អធិការកិច្ច ព័ត៌មាន-វិទ្យា បទបញ្ញត្តិ សំណង់ ព្រមទាំង ការត្រួតពិនិត្យនិងការវាយតម្លៃ។

ក្នុងឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តចំណាយនៅក្រោមថវិកាកម្មវិធី១០០% ដែលរួមមានប្រាក់បៀវត្ស។ ទឹកប្រាក់ជាច្រើននៃថវិកាបានផ្ដោតលើការផ្ដល់សេវា ដែលរួមទាំង ការិយាល័យអប់រំខេត្ត ការិយាល័យអប់រំស្រុក និងសាលារៀន។

ការញែកថវិកាឆ្នាំ២០១៦ បានបង្ហាញថាការវិភាជលម្អៀងទៅរកការអប់រំបឋមសិក្សាមានចំនួន០,២០ % នៃថវិកា ចំណែកការអប់រំមធ្យមសិក្សាមានចំនួន១,១៤ %នៃថវិកា។ ការអប់រំឧត្តមសិក្សាទទួលបាននូវចំណែកអសមាមាត្រដ៏ធំ។ ការអប់រំកុមារតូចដែលទទួលបានចំណែកតិចតួចនៅក្នុងឆ្នាំ២០១០ ប៉ុន្តែទទួលបាន០,១៥% ក្នុងឆ្នាំ២០១៦។ ចំពោះឧត្តមសិក្សា ភាគរយប្រាក់បៀវត្សបានធ្លាក់ចុះ ប៉ុន្តែភាគរយចំណាយមូលធន ការទិញទំនិញ និងសេវាបានកើនឡើងយ៉ាងខ្លាំង។ មូលហេតុសំខាន់ គឺចំណាយលើប្រាក់បៀវត្សមានចំណែកប្រមាណជា ៨០ភាគរយ នៃចំណាយអប់រំសរុប។

*តារាងទី៤៤ ៖ ថវិកាអាហារូបករណ៍ និងទំហំឆ្នាំ ២០១៥ (គិតជា លានរៀល)*

| ទំហំ | ថវិកាសរុប | % ចំណែក |
|---|---|---|
| សរុប | 44 109,5 | 100% |
| ថ្នាក់កណ្ដាល | 3 981,7 | 9% |
| ថ្នាក់ខេត្ត | 40 127,8 | 91% |
| បំបែកថវិការបស់ខេត្ត | | % នៃថវិកាថ្នាក់ខេត្ត |
| ការអប់រំមធ្យមសិក្សា | 430 | 10,7% |
| ការអប់រំបច្ចេកទេស | 60 | 0,15% |
| ការអភិវឌ្ឍ និង ការបណ្ដុះបណ្ដាលគ្រូបង្រៀន | 180 | 0,45% |
| គាំទ្រដល់ការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ | 37 276,6 | 92,9% |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៤.៥. ថវិកាដំណើរការសាលារៀន

ការដាក់ឱ្យអនុវត្តថវិកាដំណើរការសាលារៀន(SOB) មានឥទ្ធិពលយ៉ាងជ្រាលជ្រៅលើវិស័យអប់រំ។ មុនពេលមានប្រព័ន្ធថវិកាដំណើរការសាលារៀន សាលារៀនពឹងផ្អែកលើប្រាក់ចំណូលរបស់ខ្លួន សម្រាប់ដំណើរការជាប្រចាំ ចំណែកធនធានដែលទទួលបានពីក្រសួងមិនអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងបាន។ ថវិកាដំណើរការសាលារៀនមានគោលបំណងលុបបំបាត់ចោលនូវការប្រមូលកម្រៃពីសិស្ស ដែលជារបាំងមួយចំពោះការទទួលបានសេវាអប់រំរបស់កុមារនៃគ្រួសារក្រីក្រ តាមរយៈការផ្តល់នូវថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការសាលារៀន។ លក្ខណៈពិសេសដ៏សំខាន់មួយនៃថវិកាដំណើរការសាលារៀន គឺផ្តល់នូវភាពទន់ភ្លន់កាន់តែច្រើនថែមទៀត ក្នុងការប្រើប្រាស់ថវិកា ដែលអនុញ្ញាតឱ្យសាលារៀនអាចដោះស្រាយបានតាមតម្រូវការជាក់ស្តែង ដោយមានប្រសិទ្ធភាពខ្ពស់។

គោលបំណងនៃថវិកាដំណើរការសាលារៀន គឺដើម្បីជំរុញសមភាពនៃការទទួលបានសេវាអប់រំ មានគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រង និងគណនេយ្យភាព។ ការដាក់ឱ្យអនុវត្តថវិកាដំណើរការសាលារៀននឹងទទួលបានលទ្ធផលដូចតទៅ៖ ការកាត់បន្ថយការប្រមូលវិភាគទានពីឪពុកម្តាយសិស្ស (ឧទា. ថ្លៃដាក់ពាក្យសុំចូលរៀន ថ្លៃប្រឡងប្រចាំខែ ថ្លៃប្រឡងឆមាស ជាដើម) ការបង្កើនអត្រាចុះឈ្មោះចូលរៀន និងកែលម្អគុណភាពនៃការបង្រៀន និងរៀន ដែលនឹងបង្ហាញឱ្យឃើញ តាមរយៈការកើនឡើងនៃអត្រាបញ្ចប់ការសិក្សា ការថយចុះអត្រាត្រួតថ្នាក់ និងការបោះបង់ចោលការសិក្សា។

ថវិកាដំណើរការសាលារៀនអាចចំណាយលើ៖ (១) រដ្ឋបាលសាលារៀន ដូចជាសម្ភារចាំបាច់(សម្ភារការិយាល័យ សម្ភារបង្រៀន) ការជួលជុលតូចតាច ទឹកស្អាត និងអនាម័យ អគ្គិសនី និងរដ្ឋបាលសាលារៀន (២) បង្កើនការចុះឈ្មោះ ដូចជាការផ្សព្វផ្សាយអំពីការចុះឈ្មោះចូលរៀន និងការរៀបចំផែនទីគ្រួសារសិស្ស (ការអង្កេតសិស្ស) (៣) កែលម្អគុណភាពបង្រៀន និងការរៀន ដូចជាសម្ភារបង្រៀន បន្ទប់ពិសោធ បណ្ណាល័យ និងសៀវភៅ បរិស្ថានសាលារៀន និងការកែលម្អបន្ទប់រៀន បំប៉នសិស្សខ្សោយ ទប់ស្កាត់ការបោះបង់ការសិក្សា(ការប្រឹក្សាយោបល់ជាមួយឪពុកម្តាយ សម្ភារផ្សេងៗ និង ការដឹកជញ្ជូន ..) កិច្ចប្រជុំ សិក្ខាសាលាបណ្តុះបណ្តាល ការគាំទ្រសិស្សពិការ ឬខ្សោយសរីរាង្គ (ខ្សោយត្រចៀក ខ្សោយភ្នែក) បំណិនជីវិត (កីឡា សិល្បៈ រោងជាង កិច្ចការផ្ទះ កសិកម្ម)។

ថវិកាដំណើរការសាលារៀន ត្រូវបានចែកជាចំណាត់ថ្នាក់ថវិកាដូចតទៅ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(១) ការទិញ (ជំពូក ៦០)៖ ៦០ ០១១ ៖ ការសម្អាត និងអនាម័យ, ៦០ ០២១ ៖ សម្ភារផ្គត់ផ្គង់ការិយាល័យ, ៦០ ០៥១ ៖ សម្ភារបង្រៀន, ៦០ ០៥៣ ៖ ឧបករណ៍ និងសម្ភារ ៦០ ០៦១ ៖ អគ្គិសនី, ៦០ ០៦២ ៖ ការផ្គត់ផ្គង់ទឹក។

(២) សេវា (ជំពូក ៦១)៖ ៦១ ០៥១ ៖ ការថែរក្សាសួនច្បារ, ៦១ ០៥២ ៖ ការជួសជុលអគារ, ៦១ ០៥៧ ៖ ជួលជុលសម្ភារបង្រៀន, ៦១ ០៨១ ៖ សោហ៊ុយធ្វើដំណើរ, ថវិកាសម្រាប់ដំណើរការសាលារៀនត្រូវបានរៀបចំដោយរូបមន្តថេរ ដោយផ្អែកលើអញ្ញាតចំនួន ៣ [ ប្រកាស ៥០៨ ] ៖

*តារាងទី៤៥ ៖ ទឹកប្រាក់ថេរ ផ្អែកលើចំនួនថ្នាក់រៀន*

| ក្នុងសាលារៀនមួយ | ដាច់ស្រយាល | ធម្មតា |
|---|---|---|
| ថ្នាក់រៀនច្រើនជាង ៦ | 1 200 000 | 1 000 000 |
| ថ្នាក់រៀនតិចជាង ៦ | 1 000 000 | 800 000 |

ចំណាំ ៖ រាល់ការចំណាយគិតជាលុយរៀល

*តារាងទី៤៦ ៖ ចំនួនសិស្ស*

| ក្នុងសិស្សម្នាក់ | ដាច់ស្រយាល | ធម្មតា |
|---|---|---|
| ថ្នាក់រៀនច្រើនជាង ៦ | 10 000 | 90 000 |
| ថ្នាក់រៀនតិចជាង ៦ | 12 000 | 10 000 |

*តារាងទី៤៧ ៖ ការវិភាជសម្រាប់សាលាបឋមសិក្សា*

| ក្នុងសាលារៀនមួយ | ដាច់ស្រយាល | ធម្មតា |
|---|---|---|
| ថ្នាក់រៀនច្រើនជាង ១០ | 2 500 000 | 2 000 000 |
| ថ្នាក់រៀនតិចជាង ១០ | 2 000 000 | 1 500 000 |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ខេត្តកំពង់ធំ គឺជាឧទាហរណ៍នៃការអនុវត្តថវិកាប្រតិបត្តិការសាលាបឋមសិក្សាមួយ ទទួលបានថវិកាក្នុងចន្លោះពី ២ ៣៥០ ០០០ រៀល ទៅ ១ ០៦០ ០០០ រៀល។ ថវិកាសម្រាប់សាលារៀនបឋមសិក្សាមួយគឺស្ថិតក្នុងចន្លោះពី ៥ ៩៩០ ០០០ ទៅ ២ ៦៥០ ៨០០ រៀល ។

លទ្ធផលសំខាន់មួយនៃការអនុវត្តថវិកាដំណើរការសាលារៀន និង ការលុបបំបាត់ការយកប្រាក់កម្រៃចូលរៀន គឺជាកំណើនយ៉ាងខ្លាំងនៃសិស្សបញ្ចប់ការសិក្សានៅគ្រប់កម្រិត (ថ្នាក់ទី៦ ទី៩ និងទី១២ ក្នុងអត្រារៀងគ្នា៩៨%, ៣៣១% និង៣៥៩%)។ មានភស្តុតាងបង្ហាញថា ការកើនឡើងចំនួនសិស្ស មិនធ្វើឱ្យប៉ះពាល់ដល់គុណភាពអប់រំជាទូទៅនោះទេ ។ ជាក់ស្តែង ការទិញសម្ភារបង្រៀន និងសម្ភារដទៃផ្សេងៗទៀត ដោយប្រើ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាស់ថវិកាដំណើរការសាលារៀន បានចូលរួមចំណែកធ្វើឱ្យសាលាសម្រេចបានលទ្ធផលកាន់តែប្រសើរ នៅតំបន់មួយចំនួន ។

ក្នុងប្រព័ន្ធថវិកាដំណើរការសាលារៀន ផែនការថវិកាសាលារៀនប្រចាំឆ្នាំត្រូវបានរៀបចំឡើងដោយនាយកសាលា ដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងតំណាងសហគមន៍នៅក្នុង **គណៈកម្មការទ្រទ្រង់សាលារៀន** (LSSC) ដែលបង្កើតជាផ្លូវការ និងមានការពិនិត្យពីមន្ត្រីការិយាល័យអប់រំស្រុក។ នាយកសាលា គណៈកម្មការទ្រទ្រង់សាលា និងមន្ត្រីការិយាល័យអប់រំស្រុក តម្រូវឱ្យចុះហត្ថលេខាលើផែនការថវិកាសាលារៀនប្រចាំឆ្នាំ និងផ្ទៀងផ្ទាត់វិក្កយបត្រទៅក្នុងកម្រិតសមស្របនៃចំណាយ។ ប្រព័ន្ធនេះជួយសម្រួលឱ្យមានតម្លាភាពនៃការគ្រប់គ្រងសាលារៀន និងពង្រឹងគណនេយ្យភាព ក្នុងការកែលម្អសេវានៅក្នុងសាលារៀន។ ប្រព័ន្ធថវិកាដំណើរការសាលារៀនត្រូវបានត្រួត ពិនិត្យដោយក្រុមត្រួតពិនិត្យ និងបណ្តុះបណ្តាលថ្នាក់ស្រុក (DTMT) ដែលរួមមានមន្ត្រីអប់រំស្រុក នាយកសាលា និងតំណាងគណកម្មការគាំទ្រសាលារៀន។ ការទទួលខុសត្រូវរបស់ក្រុមនេះគឺ ដើម្បីបណ្តុះបណ្តាល គាំទ្រ និងត្រួតពិនិត្យ ការប្រព្រឹត្តទៅរបស់សាលារៀន។

*តារាងទី៤៨ ៖ ថវិកាដំណើរការសាលា និងថវិកាដែលបានបញ្ចេញក្នុងឆ្នាំ២០១៥ (គិតជា លានរៀល)*

| កម្រិតសិក្សា | ថវិកា | ថវិកាដែលបញ្ចេញ<br>គិតត្រឹម ១៥ កញ្ញា | % ការបញ្ចេញថវិកាគិតជា<br>ភាគរយ |
|---|---|---|---|
| សរុប | **46 966,7** | **33 472,7** | **71,2%** |
| សាលាមត្តេយ្យ | 429,8 | | |
| សាលាបឋមសិក្សា | 27 586,8 | | |
| សាលាមធ្យមសិក្សា | 18 472,8 | | |
| សាលាបច្ចេកទេស | 477,2 | | |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ចំណាំ ៖ ការវិភាជសម្រាប់ឆមាសទី៣ គឺ ៩០% ត្រូវបានបញ្ចេញដោយផ្ទាល់ទៅគណនីធនាគាររបស់សាលារៀន ។ ត្រូវវិភាជបន្ថែមនៅទឹកប្រាក់នៅសល់ ។

នៅពេលថវិកាដំណើរការសាលារៀន គឺជាអន្តរាគមន៍ជាវិជ្ជមានមួយក្នុងប្រព័ន្ធអប់រំ មានកត្តាបួនដែលធ្វើឱ្យប្រសិទ្ធភាពធ្លាក់ចុះ។

**ទីមួយ–** ទឹកប្រាក់វិភាជន៍នៃថវិកាដំណើរការសាលារៀនបានធ្លាក់ចុះ ជាបន្តបន្ទាប់ ។ ប្រកាសលេខ១៩១ បានកំណត់ពីចំនួនទឹកប្រាក់ថេរ ដែលគិតជារៀលសម្រាប់សាលារៀននីមួយៗ និងសម្រាប់សិស្សម្នាក់ៗ ហើយខុសគ្នាតាមកម្រិតសិក្សា ដោយមិន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានការកែតម្រូវទៅតាមអតិផរណា។ នាពេលបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចបានធ្វើការកែតម្រូវសេចក្តីប្រកាស ហើយបានអនុវត្តក្នុងឆ្នាំ ២០១៤។

**ទីពីរ–** វិធាននៃថវិកាកម្មវិធីនៃថវិកាប្រតិបត្តិការសាលារៀន បានបំបែកថវិកាទៅតាមចំណាត់ថ្នាក់ ដូចមានចែងក្នុងសេចក្តីប្រកាសលេខ ១៩១ ហើយទោះជាសាលារៀនមានឆន្ទានុសិទ្ធិពេញលេញក្នុងការវិភាជថវិកា ទៅតាមចំណាត់ថ្នាក់នោះក៏ដោយ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យផ្ទេរថវិកាចេញពីចំណាត់ថ្នាក់ មួយទៅចំណាត់ថ្នាក់មួយទៀតទេនៅក្នុងឆ្នាំ។ មានន័យថា សាលាមធ្យមសិក្សាដែលអាចនឹងត្រូវការសម្ភារបន្ទប់ពិសោធន៍ បែរមិនត្រូវការសៀវភៅសិក្សាវិញនោះ ការអនុវត្តថវិកាដំណើរការសាលារៀនមិនអនុញ្ញាតឱ្យយកថវិកាដែលគ្រោងសម្រាប់ទិញសៀវភៅសិក្សាខ្លះ ទៅទិញសម្ភារ បន្ទប់ពិសោធបានទេ។

**ទីបី–** ថវិកាកម្មវិធីត្រូវបានបើកផ្តល់ ៤លើកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅកាន់រតនាគារជាតិខេត្ត និងពីរតនាគារជាតិខេត្ត ទៅកាន់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ការបើកផ្តល់យឺត ដែលក្រសួងអប់រំ យុវជន និងកីឡាមិនអាចគ្រប់គ្រងបានបណ្តាលឱ្យការបើកផ្តល់ថវិកាយឺតយ៉ាវដល់សាលារៀន ហើយសាលារៀនមិនអាចចាយថវិកាទាន់ពេលវេលា ដែលធ្វើមានប្រសិទ្ធភាពតិចតួចដល់ឆ្នាំសិក្សា។ លើសពីនេះទៀត ដោយសារថវិកាត្រូវបានបញ្ចេញក្រោយឆ្នាំសិក្សា សាលាមិនអាចធ្វើសកម្មភាព ឬត្រូវពន្យារពេលអន្តរាគមន៍ ដែលតម្រូវការចំណាយកាន់តែមានកើនឡើងច្រើន។

**ទីបួន–** សមត្ថភាពនៃប្រព័ន្ធគ្រប់គ្រងថវិកាសាលារៀននៅមានកម្រិត។ ក្នុងការសិក្សាមួយ ដែលធ្វើដោយក្រសួងអប់រំ យុវជន និងកីឡា លើសាលារៀនចំនួន ១៥០ រកឃើញថាសាលារៀន៧១% យល់ថាកង្វះការបណ្តុះបណ្តាលផ្នែករដ្ឋបាល និងការគ្រប់គ្រងគឺជាឧបសគ្គចម្បងមួយនៃការប្រើប្រាស់ថវិកាសាលារៀន។ ដូចនេះ គួរមានថវិកាសម្រាប់បណ្តុះបណ្តាល គាំទ្រ និង ត្រួតពិនិត្យសកម្មភាព។

ការអង្កេតក៏បានរកឃើញផងដែរថា ក្រសួងអប់រំ យុវជន និងកីឡា ជួបប្រទះនឹងបញ្ហាប្រឈមបន្ថែមទៀត ក្នុងការអនុវត្តថវិកាដំណើរការសាលារៀនឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ដំណោះស្រាយ ដែលមានចំពោះបញ្ហាប្រឈមសំខាន់មានដូចខាងក្រោម ៖

- ពិនិត្យរូបមន្តនៃការផ្តល់ថវិកានៅក្នុងប្រកាសលេខ ៥០៨ ដើម្បីធានាថាសាលារៀនអាចទទួលបានថវិកាប្រកបដោយសមធម៌



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ពិនិត្យស្តង់ដានៃផលធៀបរវាងសិស្ស និងគ្រូ
- ពិចារណាការប្រើប្រាស់ប្រព័ន្ធផ្អែកលើសមិទ្ធកម្ម សម្រាប់វិភាជថវិកា
- ពិចារណាក្នុងការកាត់បន្ថយម៉ោងបង្រៀនអតិបរមា ប៉ុន្តែបង្កើនប្រាក់ម៉ោង
- ការអនុវត្តប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ ដើម្បីតាមដានការផ្ទេរថវិកា និងការចំណាយ
- ការកសាងសមត្ថភាពនាយកសាលា ដូចជាការកត់ត្រាគណនេយ្យ ការគ្រប់គ្រង ជាដើម ដោយភ្ជាប់ជាមួយនឹងឧបករណ៍សម្រាប់តាមដាន និងវាយតម្លៃ
- ដោះស្រាយបញ្ហាថវិកា ដែលមិនបានប្រើប្រាស់ចំនួន១០% ទៅ១៥%
- បង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាមញ្ញមួយសម្រាប់ការបើកផ្តល់ថវិកា និងទូទាត់ថវិកាដំណើរការសាលារៀន
- ថវិកាជាច្រើនមិនបានចំណាយដោយសារការគ្រោងខ្ពស់នៃថវិកាក្នុងជំពូក៦៤ ដែលគ្រោងសម្រាប់ប្រាក់បៀវត្សគ្រូបង្រៀន និងមន្ត្រីចូលនិវត្ត និងការបើកផ្តល់ទាបចំពោះប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់គ្រូបង្រៀន
- នាពេលបច្ចុប្បន្ន ថវិកាត្រូវបានបើកផ្តល់បួនលើកក្នុងមួយឆ្នាំ។ ការកាត់បន្ថយការបើកផ្តល់មកត្រឹម២លើកក្នុងមួយឆ្នាំ ដើម្បីឱ្យសមស្របនឹងឆ្នាំសិក្សារបស់សាលា អាចនឹងលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផល
- នីតិវិធីសម្រាប់ទូទាត់ចំណាយលើថ្លៃអគ្គិសនី ទឹក ជាដើម សម្រាប់សាលាដាច់ស្រយាលត្រូវធ្វើឱ្យងាយស្រាយជាងនេះ
- នីតិវិធីដែលអាចផ្ទេរថវិកាពីចំណាត់ថ្នាក់មួយទៅចំណាច់ថ្នាក់មួយទៀត គួរតែត្រូវដោះស្រាយ
- ប្រព័ន្ធលើកទឹកចិត្តគ្រូបង្រៀននៅតំបន់លំបាក និងគម្លាតប្រាក់បៀវត្សរវាងគ្រូបង្រៀន នាយកសាលា និងបុគ្គលិករដ្ឋបាលត្រូវពិនិត្យឡើងវិញ
- នីតិវិធីនៃការទូទាត់ថវិកាដែលបានបើកផ្តល់គួរធ្វើឱ្យមានភាពងាយស្រួលជាងនេះ
- គោលការណ៍ណែនាំសាមញ្ញ និងច្បាស់លាស់ស្តីពីការទូទាត់ការចំណាយគួររៀបចំឡើង ដើម្បីជៀសវាងការពន្យារពេលដោយសារកំហុស និងការយល់ខុសផ្នែកគណនេយ្យ។

ការអង្កេតនេះក៏រួមបញ្ចូលលទ្ធផលដូចខាងក្រោមនៅថ្នាក់មូលដ្ឋាន ៖

***ការរៀបផែនការអភិវឌ្ឍសាលារៀន***

- សាលារៀនមានព័ត៌មានគ្រប់គ្រាន់សម្រាប់ធ្វើផែនការ និងមានតែ ២០% មិនមានផែនទីគ្រូសារសិស្ស
- ៩៤% នៃសាលារៀនបានធ្វើផែនការទាន់ពេលវេលា ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ
- ៦៧% នៃសាលារៀនមានភាពជឿជាក់ថាផែនការរបស់ពួកគេល្អ។ អ្នកផ្សេងទៀតគិតថា ផែនការរបស់ពួកគេមធ្យម។

***ការអនុវត្តថវិកា***

- មានតែសាលារៀនមួយប៉ុណ្ណោះដែលរាយការណ៍ថាពួកគេមិនបានអនុវត្តផែនការដែលបានគ្រោង
- សាលារៀនជាង ៧០% រាយការណ៍ថាពួកគេបានបញ្ចប់ផែនការសកម្មភាពជាង ៧០%នៃគម្រោង
- ៨៥% នៃសាលារៀនរាយការណ៍ថាពួកគេបានចាយលើសពី ៥០% នៃថវិការបស់ពួកគេ
- សាលាប្រហែលជា ៧០% បានកែលម្អដំណើការសាលា និងគុណភាពអប់រំ
- មានតែ ១៥% នៃសាលារៀន រាយការណ៍ថា ពួកគេត្រូវធ្វើការកែតម្រូវផែនការនៅក្នុងឆ្នាំ
- សាលារៀនទាំងអស់អះអាងពីតម្លាភាពនៃចំណាយរបស់ខ្លួន។

***បញ្ហាប្រឈមនៃថវិកាដំណើរការសាលារៀន***

- ថវិកាមានចំនួនតិចណាស់ ធៀបនឹងតម្រូវការសម្រាប់អភិវឌ្ឍន៍សាលារៀន
- ការពន្យារពេលនៃការផ្តល់សាច់ប្រាក់គឺជាលទ្ធផលនៃអសមត្ថភាពក្នុងការអនុវត្តផែនការប្រចាំឆ្នាំបានទាន់ពេលវេលា។ បុគ្គលិកសាលារៀនកង្វះខាតជំនាញផ្នែកគណនី និងការគ្រប់គ្រងហិរញ្ញវត្ថុ
- ចំណាត់ថ្នាក់ថវិកាគ្មានភាពបត់បែនគ្រប់គ្រាន់ ដើម្បីឆ្លើយតាមតម្រូវការរបស់សាលារៀននៅមូលដ្ឋាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការគាំទ្រថវិកាមិនបានរួមបញ្ចូលប្រាក់ឧបត្ថម្ភធ្វើដំណើរ។ នេះបង្ករការលំបាកសម្រាប់បុគ្គលិកនៅតំបន់ដាច់ស្រយាល និងតំបន់ជនបទខ្លះទទួលបានថវិកា តាមរយៈធានាគារ
- នីតិវិធីហិរញ្ញវត្ថុមានភាពស្មុគស្មាញ
- ឧបករណ៍ និងសម្ភារមួយចំនួនមិនមាន និងមិនអាចទិញនៅតំបន់ទីតាំងសាលារៀន និងមិនមានថវិកាសម្រាប់ធ្វើដំណើរ
- ការផ្លាស់ប្តូរជាបន្តបន្ទាប់នៃនីតិវិធីហិរញ្ញវត្ថុបណ្តាលឱ្យមានការភាន់ច្រឡំ។

## ១៤.៩.១ អនុសាសន៍

- បង្កើតរូបមន្តដែលសាមញ្ញនិងគួរឱ្យទុកចិត្តសម្រាប់ការបើកផ្តល់ និងរៀបចំប្រព័ន្ធគណនេយ្យ សម្រាប់ថវិកាដំណើរការសាលារៀន ដោយមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសក្នុងក្របខណ្ឌថវិការយៈពេលមធ្យម។ រូបមន្តគួរតែបញ្ចូលអញ្ញត្តិសមិទ្ធកម្ម
- កែលម្អគុណភាពនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំកាន់តែត្រឹមត្រូវ និងជឿទុកចិត្តបាន
- ពិនិត្យប្រភេទចំណាយដែលមានសិទ្ធិចំណាយបាន នាពេលបច្ចុប្បន្ន ដើម្បីបញ្ចូលប្រភេទចំណាយគន្លឹះផ្សេងៗទៀត ដូចជាប្រាក់សោហ៊ុយធ្វើដំណើរ
- តស៊ូមតិក្នុងថវិកាដំណើរការសាលារៀនជាកញ្ចប់ ដោយភ្ជាប់នូវបញ្ជីទូលាយនៃប្រភេទចំណាយដែលមានសិទ្ធចាយ និងមានភាពបត់បែនទៅតាមតម្រូវការចំណាយជាក់ស្តែងរបស់សាលារៀន។ ផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដល់បុគ្គលិកសាលារៀនអំពីនីតិវិធីហិរញ្ញវត្ថុ
- ជំរុញការិយាល័យអប់រំខេត្តឱ្យសកម្មចូលរួមក្នុងការគាំទ្រសាលារៀន និងបង្កើនល្បឿនបើកផ្តល់ថវិកាឱ្យបានទាន់ពេលវេលា។ បន្តតស៊ូមតិឱ្យមាននីតិវិធីទូទាត់ថវិកាដំណើរការសាលារៀនឱ្យកាន់តែសាមញ្ញ ។

## ១៤.៩.២ និន្នាការរួមនៃថវិកាកែលម្អសាលារៀន

ចាប់តាំងពីឆ្នាំ២០១៣ អង្គការ SIDA បានផ្តល់ថវិកាចំនួន ២៣ លានដុល្លារ ជាជំនួយឥតសំណងសម្រាប់កែលម្អសាលារៀន ក្នុងទម្រង់នៃការវិភាជថវិកាបន្ថែមដល់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាលារៀន ក្នុងគោលបំណងពង្រីកការទទួលបាននូវសេវាអប់រំដល់ក្មេងដែលងាយរងគ្រោះ ព្រមទាំងជំរុញការបន្តការសិក្សា និងបញ្ចប់ការសិក្សាក្នុងប្រព័ន្ធអប់រំឱ្យពេញលេញចាប់ពីបឋម ដល់ថ្នាក់ទី១២។ ថវិកាកែលម្អសាលារៀនត្រូវបានសាកល្បងក្នុងឆ្នាំ ១៩៩៨-២០០៣ ដោយគម្រោងកែលម្អគុណភាពអប់រំ(EQIP) និងក្នុងឆ្នាំ ២០០៩-២០១២ ដោយគម្រោងពង្រីកសកម្មភាពគាំទ្រវិស័យអប់រំ(ESSSUAP) ដោយប្រើប្រាស់មូលនិធិ The Fast Track Initiative Catalytic Funds (FTI-CF)) ដែលបច្ចុប្បន្នហៅថា ភាពជាដៃគូសកលសម្រាប់ការអប់រំ។

ទឹកប្រាក់ ៦,៦ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ បានផ្តល់ជាជំនួយឥតសំណងសម្រាប់កែលម្អសាលា ដើម្បីគាំទ្រប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជា ដូចជា មជ្ឈមណ្ឌលការអប់រំកុមារតូច សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ គោលបំណងនៃជំនួយឥតសំណងនេះ គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្រៀន និងការរៀន និងការបង្កើនការចុះឈ្មោះ ការកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា។ សាលានីមួយៗអាចរៀបចំកម្មវិធីសកម្មភាពផ្ទាល់ខ្លួន ដោយផ្អែកលើកម្មវិធីសិក្សា និងតម្រូវការក្នុងតំបន់របស់ខ្លួន ទៅបញ្ជីសកម្មភាពរបស់ថ្នាក់កណ្តាលទៅតាមកម្រិតសិក្សា។ ធនធានទាំងនេះនឹងត្រូវប្រើប្រាស់សម្រាប់ ៖

- កែលម្អបរិយាកាសសិក្សាឱ្យកាន់តែប្រសើរ តាមរយៈការកែលម្អសម្ភាររូបវន្ត និងសម្ភារគាំទ្រដល់ការបង្រៀន និងការរៀន។
- កសាងសមត្ថភាពរបស់គ្រូបង្រៀន និង
- ការបំប៉នសិស្សខ្សោយ និងសិស្សដែលប្រឈមនឹងការបោះបង់ការសិក្សា ឬមានហានិភ័យខ្ពស់នឹងការបោះបង់ការសិក្សា។

មួយផ្នែកនៃថវិកា ត្រូវបានប្រើប្រាស់សម្រាប់ការកសាងសមត្ថភាព ដើម្បីគាំទ្រការប្រើប្រាស់ថវិកានេះឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ។ ផ្នែកទីបីនៃថវិកា ត្រូវប្រើប្រាស់សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើភស្តុតាង។

គោលនយោបាយនេះរួមបញ្ចូល វិធីសាស្ត្រអប់រំ ដែលផ្តោតលើការសិក្សារកុមារមណ្ឌល និង កំណត់លក្ខណសម្បត្តិនៃការបង្រៀន និងការរៀនដែលមានការច្នៃប្រឌិតការរៀនដោយចូលរួម ការសិក្សាស្រាវជ្រាវ ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា និងជំរុញការគិតបែបច្នៃប្រឌិត។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**គណៈកម្មការទ្រទ្រង់សាលា** (LSSC) ទទួលខុសត្រូវជាចម្បងចំពោះថវិកាកែលម្អសាលារៀន ដែលជាផ្នែកមួយនៃដំណើរការរៀបចំផែនការអភិវឌ្ឍសាលារៀន។ សាលារៀនគួរតែធ្វើផែនការសកម្មភាពនៃថវិកាកែលម្អសាសារៀន ត្រឹមខែមិថុនារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនផែនការអភិឌ្ឍសាលារៀនដែលរួមមាន ថវិកាកែលម្អសាសារៀន និងថវិកាដំណើរការសាលារៀន ដែលដាច់ដោយឡែកពីគ្នា ទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្ទៀងផ្ទាត់ផែនការសកម្មភាព ដែលមានក្នុងថវិកាកែលម្អសាលារៀន និងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកានេះ ។

ដំណើរការនៃការធ្វើផែនការ និងការរៀបចំថវិកាចាប់ផ្តើមក្នុងខែឧសភានៅថ្នាក់កណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ដោយត្រួតពិនិត្យទៅតាមរូបមន្តនៃការវិភាជថវិកា។ ក្រសួងអប់រំ យុវជន និងកីឡា ចេញសារាចរណែនាំប្រចាំឆ្នាំ ដោយកំណត់ពីវិធាន និងតម្រូវការឯកសារបន្ថែមទៅនឹងសៀវភៅគោលការណ៍ណែនាំហិរញ្ញវត្ថុ និងបច្ចេកទេស។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បោះផ្សាយថវិកាវិភាជតាមសាលារៀននីមួយៗ និងតម្រូវឱ្យខេត្ត ស្រុក និងសាលាផ្សព្វផ្សាយព័ត៌មាននៅក្នុងតំបន់។ បន្ថែមពីលើនេះទៅទៀត ក្រសួងត្រូវផ្តល់គោលការណ៍ណែនាំស្តីពីថ្លៃទៅតាមចំណាត់ថ្នាក់ស្តង់ដាការងារ ទំនិញ និងសេវា ដើម្បីជាមគ្គុទ្ទេសក៏ក្នុងការរៀបចំផែនការ និងរៀបចំថវិកា។

បន្ទាប់ពីការចេញផ្សាយសារាចររួច ការិយាល័យអប់រំ យុវជន និងកីឡាខេត្តនឹងរៀបចំកិច្ចប្រជុំបិទបញ្ចប់ឆ្នាំសិក្សា ដើម្បីជូនដំណឹងដល់សាលាស្តីពីថវិកាវិភាជនៅឆ្នាំបន្ទាប់ និងពិភាក្សាលើសារាចរណែនាំជាមួយនាយកសាលា។ សាលារៀននឹងចាប់ផ្តើមធ្វើការ ឬបញ្ចប់ដំណើររៀបចំផែនការរបស់ខ្លួន។ ក្នុងដំណាក់កាលនេះ ការិយាល័យអប់រំស្រុក គណៈកម្មការគ្រប់គ្រងថវិកាស្រុក (DGMC) ក្រុមត្រួតពិនិត្យ និងបណ្តុះបណ្តាលស្រុក (DTMT) និងសាលារៀនកម្រង ឬសាលារៀនធនធាននឹងផ្តល់ការគាំទ្រដល់សាលាដើម្បីធានាថាផែនការឆ្លើយតបនឹងតម្រូវការ និងបានដាក់បញ្ចូលប្រភេទខ្ទង់ចំណាយដែលអាចអនុញ្ញាតបាននៅក្នុងក្របខណ្ឌចំណាយរបស់ SIG។

ត្រឹមចុងខែឧសភា សាលារៀនត្រូវបានតម្រូវឱ្យផ្ញើសំណើថវិកា រួមគ្នាជាមួយនឹងផែនការអភិវឌ្ឍសាលារៀន មកការិយាល័យអប់រំស្រុក។ នាយកសាលារៀនដែលជាប្រធានគណៈកម្មការទ្រទ្រង់សាលារៀន ត្រូវចុះហត្ថលេខាលើគម្រោងថវិកានិងផែនការ។ គណៈកម្មការគ្រប់គ្រងជំនួយថ្នាក់ស្រុក ត្រូវពិនិត្យ និងបញ្ជាក់លើផែនការ រួចបញ្ជូនបន្តទៅគណៈកម្មការគ្រប់គ្រងជំនួយថ្នាក់ខេត្ត ដើម្បីអនុម័ត ឬបញ្ជូនត្រឡប់ទៅសាលារៀន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិញដើម្បីកែតម្រូវ បញ្ហាដែលបានរកឃើញ នៅពេលត្រួតពិនិត្យ។ នៅថ្នាក់ខេត្ត អាចនឹងពិនិត្យមើផែនការសាលារៀនចោះៗ ដែលថ្នាក់ស្រុកបានត្រួតពិនិត្យហើយ ។ ថ្នាក់ខេត្តនឹងវាយតម្លៃសុពលភាពដោយផ្អែកលើការត្រួតពិនិត្យរបស់ថ្នាក់ស្រុក ។ នៅពេលដែលថ្នាក់ខេត្តអនុម័តផែនការ និងគម្រោងថវិការួម ពួកគេរៀបចំសំណើសរុបមួយសម្រាប់ស្នើសុំបញ្ចេញថវិកា និងបញ្ជូនបន្តទៅនាយកដ្ឋានបច្ចេកទេសរបស់ ក្រសួងអប់រំ យុវជន និងកីឡា នៅមុនខែសីហា ជារៀងរាល់ឆ្នាំ។

ផែនការ និងគម្រោងថវិកាត្រូវតែបិទផ្សាយជាសាធារណៈនៅសាលារៀន មុននឹងចាប់ផ្តើមបញ្ជូនទៅគណៈកម្មការស្រុក។ ផែនការ និងគម្រោងថវិកាដែលអនុម័តចុងក្រោយក៏ត្រូវបិទផ្សាយផងដែរ ដោយកត់ត្រាថវិកាដែលរំពឹងទុក សកម្មភាព និងថវិកាដែលបានវិភាជ។

### ១៤.៥.៣. សេចក្តីសង្ខេបនៃហិរញ្ញប្បទានសំខាន់ៗក្នុងពេលបច្ចុប្បន្នជាក់ជង់នឹងវិស័យអប់រំ

- ធានាការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលនៃកំណើនថវិកាចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ពង្រឹងផែនការយុទ្ធសាស្រ្តថវិការបស់ក្រសួងអប់រំ(ការរៀបចំថវិកាផ្អែកលើលទ្ធផល) និងកែលម្អផែនការសម្រាប់ថវិកាបុគ្គលិក
- បន្តការបង្កើនការវិភាជថវិកាប្រចាំឆ្នាំលើចំណាយប្រតិបត្តិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្តសកម្មភាព ដែលមាននៅក្នុងផែនការយុទ្ធសាស្រ្តអប់រំ និងកាត់បន្ថយការពឹងផ្អែកលើដៃគូអភិវឌ្ឍន៍ ក៏ដូចជាធ្វើសមាហរណកម្មចំណាយមូលធន
- អនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលរួមមានការផ្លាស់ប្តូរទៅជាមូលនិធិកែលម្អសាសារៀន(SIF)ក្នុងឆ្នាំ២០០៧
- កែលម្អការគ្រប់គ្រងថវិកាដំណើរការសាលារៀន (ដោយផ្សារភ្ជាប់នឹង ការកែលម្អផែនការការផ្តល់ថវិកាទាន់ពេលវេលា បង្កើនភាពបត់បែន តម្លាភាព ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលា ការប្រើប្រាស់គណនីធនាគារ សវនកម្ម ជាដើម)
- គាំទ្រដល់គណៈកម្មការទ្រទ្រង់សាលារៀន និងនាយកសាសា ដើម្បីពង្រឹងដំណើរការគ្រប់គ្រងសាលារៀន និងផែនការអភិវឌ្ឍន៍សាលារៀន ស្តីពីការប្រើប្រាស់ថវិកាឱ្យស៊ីចង្វាក់គ្នានឹងផែនការកែលម្អសាលារៀន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១៤.៥.៤ ការងារត្រូវធ្វើបន្ត

យន្តការគណនេយ្យភាពនៅថ្នាក់ស្រុក និងនៅថ្នាក់សាលារៀន គួរតែពង្រឹងបន្ថែម ដើម្បីកែលម្អការគ្រប់គ្រងការអប់រំ និងធានាអំពីតម្លៃលុយ។ ការគ្រប់គ្រងសាលារៀន គឺជាស្នូលនៃភាពជោគជ័យនៃកិច្ចប្រឹងប្រែងកែទម្រង់ និងចុងបញ្ចប់កែលម្អលទ្ធផលអប់រំ។ សំខាន់ជាងគេបំផុតនោះគឺ សមត្ថភាពនៃអ្នកពាក់ព័ន្ធនៅកម្រិតសាលារៀន ដើម្បីកែលម្អការអនុវត្តការគ្រប់គ្រងសាលារៀន។ ការកែលម្អនេះ រួមមានផ្នែកជាច្រើន ប៉ុន្តែត្រូវជំរុញការចូលរួមរបស់សហគមន៍ ព្រមទាំងបញ្ជាក់ឱ្យច្បាស់ និងបង្កើនអំណាចរបស់គណៈកម្មការសាលារៀន ដែលជាស្នូលនៃការកែលម្អការអនុវត្តជាក់ស្តែង។ ទន្ទឹមនឹងគ្នានេះដែរ ការកែលម្អការគ្រប់គ្រងសាលាត្រូវប្រែក្លាយទៅជាការកែលម្អលទ្ធផលនៃការអប់រំ។ ការប្រែក្លាយនេះផ្អែកលើសមត្ថភាពរបស់គ្រូបង្រៀន និងរចនាសម្ពន្ធគាំទ្រជុំវិញសាលារៀន។ ទាំងអស់នេះ គូសរំលេចឱ្យឃើញពីតម្រូវការ ដើម្បីពង្រឹង និងផ្តល់ឱកាសការទទួលបានកាន់តែច្រើននៃការអភិវឌ្ឍជំនាញអាជីពគ្រូបង្រៀន ដើម្បីបំពាក់បំប៉នគ្រូបង្រៀននូវយុទ្ធសាស្រ្តចាំបាច់ដើម្បីកែលម្អ និងត្រួតពិនិត្យលទ្ធផលនៃការអប់រំ។

ជារួម ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចនូវវឌ្ឍនភាពល្អ ក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្នុងប៉ុន្មានឆ្នាំនេះ។ បច្ចុប្បន្នមានការអនុវត្តថវិកាទទួលបានការទុកចិត្ត និងត្រឹមត្រូវតាមប្រព័ន្ធ និងនីតិវិធីដែលអនុវត្តបានជោគជ័យទាំងបួនកម្រិតពីថ្នាក់កណ្តាល រហូតដល់កន្លែងផ្តល់សេវា។ ប្រការនេះបានផ្តល់តម្លៃកាន់តែល្អក្នុងការប្រើប្រាស់ថវិកាកែលម្អសាលារៀន។ ប្រាកដណាស់បញ្ហាប្រឈមនៅតែមាន។ ទាំងនោះរួមមានការកែលម្អនីតិវិធីលទ្ធកម្មសាធារណៈ ការបង្កើតប្រព័ន្ធគណនីតាមកុំព្យូទ័រ និងការពង្រឹងសវនកម្មផ្ទៃក្នុង។

### ១៤.៦. ការផ្តល់ហិរញ្ញប្បទានក្នុងវិស័យអប់រំ ដោយដៃគូអភិវឌ្ឍន៍

ហិរញ្ញប្បទានក្នុងវិស័យអប់រំ ត្រូវបានតម្រែតម្រង់ទៅតាមផែនការយុទ្ធសាស្រ្តអប់រំ ដែលត្រូវបានរៀបចំទៅតាមសកម្មភាពអាទិភាព ក្នុងក្របខណ្ឌនៃការប្រឹក្សាយោបល់ដែលគ្របដណ្តប់លើគ្រប់វិស័យ ជាមួយភាគីពាក់ព័ន្ធ ជាពិសេសដៃគូអភិវឌ្ឍ។ អាទិភាពទាំងនោះ ត្រូវបានកំណត់នៅក្នុងក្រុមការងារបច្ចេកទេសស្តីពីការអប់រំ។ គោលនយោបាយអប់រំក៏ត្រូវបានពិភាក្សាក្នុងសិក្ខាសាលាវិបស្សនាស្តីពីការអប់រំប្រចាំឆ្នាំ នៅពេលដែលកិច្ចប្រជុំបូកសរុបការងារអប់រំប្រចាំឆ្នាំ បានផ្តល់ជាយន្តការមួយ ក្នុងការកែលម្អការត្រួតពិនិត្យរួមគ្នា និងការផ្តល់ហិរញ្ញប្បទាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងទី៤៩ ៖ ហិរញ្ញប្បទានក្នុងវិស័យអប់រំដោយដៃគូអភិវឌ្ឍន៍(គិតជា ពាន់ដុល្លាអារមេរិក)*

| No | Donors | Own Fund 2012 | Own Fund 2013 | Own Fund 2014 | Plan 2015 | Plan 2016 | Plan 2017 |
|---|---|---|---|---|---|---|---|
| 1 | WFP | 9 401 | 10 861 | 26 646 | 25 924 | 15 715 | 0 |
| 2 | World Bank | 2 898 | 4 729 | 13 250 | 27 500 | 26 250 | 0 |
| 3 | EU | 9 060 | 4 521 | 12 525 | 15 109 | 30 127 | 0 |
| 4 | Sweden | 3 860 | 11 576 | 11 303 | 12 657 | 4 543 | 0 |
| 5 | ADB | 3 592 | 8 884 | 8 600 | 5 000 | 6 000 | |
| 6 | UNICEF | 1 656 | 7 218 | 5 939 | 681 | 0 | 0 |
| 7 | ROK | 3 263 | 1 459 | 1 455 | 1 000 | 4 500 | 0 |
| 8 | Japan | 0 | 1 641 | 1 351 | 722 | 0 | 0 |
| 9 | France | 443 | 478 | 309 | 0 | 0 | 0 |
| 10 | UNESCO | 302 | 268 | 30 | 20 | 0 | 0 |
| Sub-Total 10 DPs | | 34 474 | 51 634 | 81 407 | 88 612 | 87 135 | 0 |
| All DPs | | 38 165 | 53 892 | 81 407 | 99 313 | 97 835 | 10 700 |

*ប្រភព ៖ (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៖ យកចេញពីរបាយការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការថ្ងៃទី២៦ វិច្ឆិកា ២០១៤)*

យោងតាមក្រុមប្រឹក្សាសម្រាប់អភិវឌ្ឍន៍កម្ពុជា វិស័យអប់រំបានទទួលមូលនិធិពីដៃគូអភិវឌ្ឍន៍ចំនួន ៧០-៨០ លានដុល្លារអាមេរិក។ ក្នុងឆ្នាំ២០១៤ ថវិកាក្នុងវិស័យអប់រំដែលផ្តល់ដោយដៃគូបរទេសមានរហូតដល់ ៨០ លានដុល្លារអាមេរិក ដោយសារការកើនឡើងហិរញ្ញប្បទានរបស់កម្មវិធីស្បៀងអាហារពិភពលោក និងសហភាពអឺរ៉ុប។ ភាគច្រើននៃហិរញ្ញប្បទានបរទេសទទួលបានពីដៃគូអភិវឌ្ឍន៍ដូចខាងក្រោម ។

## ១៤.៦.១ ធនាគារអភិវឌ្ឍន៍អាស៊ី

### ១. គម្រោងជំនាញមូលដ្ឋាន (ប្រាក់កម្ចី ១៣៦៨ CAM) ២៥,០០០,០០០ដុល្លារអាមេរិក

គោលបំណងទូទៅ គឺដើម្បីជួយរាជរដ្ឋាភិបាលក្នុង (១) ការបង្កើតប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈមូលដ្ឋាន ដែលត្រូវការសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជំនាញក្នុងវិស័យសេវាដែលកំពុងមានកំណើនខ្ពស់ និងជំនាញសេវាសុខភាពមូលដ្ឋាន (២) បំពាក់បំប៉នក្រុមដែលងាយរងគ្រោះ និងប្រជាជនដែលប្រឈមនឹងការផ្លាស់លំនៅដ្ឋាននូវជំនាញមូលដ្ឋានសម្រាប់រកប្រាក់ចំណូល និង (៣) បង្កើតផែនការ និងពង្រឹងសមត្ថភាពគ្រប់គ្រង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់រដ្ឋាភិបាល ក្នុងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល និងបច្ចេកទេស។ គម្រោងនេះរួមមានសមាសធាតុពីរ ៖ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអភិវឌ្ឍវិស័យសុខភាព។

ក្នុងសមាសធាតុនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ លទ្ធផល និងធាតុចេញដែលរំពឹងទុក គឺ (១) បង្កើតក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ជាតិ និងមូលនិធិបណ្តុះបណ្តាលថ្នាក់ជាតិ (២) កែលម្អគុណភាព និងភាពសមស្របនៃកម្មវិធីបណ្តុះបណ្តាលជំនាញ តាមរយៈការស្តារឡើងវិញនូវវិទ្យាស្ថានបណ្តុះបណ្តាលជំនាញសំខាន់ៗ និងរៀបចំកម្មវិធីសិក្សាវិជ្ជាជីវៈថ្នាក់ជាតិ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍បុគ្គលិក និង (៣) ពង្រីកកម្មវិធីបណ្តុះបណ្តាលវិជ្ជា-ជីវៈ ទៅតំបន់ឆ្ងាយៗ ដោយបង្កើត ឬកែលម្អមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈថ្នាក់ខេត្ត មជ្ឈមណ្ឌលស្ត្រី និងការគាំទ្រការបណ្តុះបណ្តាលវិជ្ជាជីវៈសហគមន៍ចល័ត។ សកម្មភាពទាំងនោះរួមមាន (១) ការងារសំណង់ស៊ីវិល និងការប្រើប្រាស់ឧបករណ៍/សម្ភារ (២) កម្មវិធីបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស និង (៣) ការអភិវឌ្ឍ និងការផលិតកម្មវិធីសិក្សា និងសម្ភារបណ្តុះបណ្តាល ។

**២. គម្រោងអភិវឌ្ឍន៍វិស័យអប់រំ ( ESDP ) ២០០២-២០០៧ មានទឹកប្រាក់ ៤៤ ៤៣០ ០០០ ដុល្លារអាមេរិក**

កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ(ESDP) ត្រូវបានអនុម័តក្នុងឆ្នាំ២០០១ ដើម្បីកែលម្អការទទួលបានការអប់រំសម្រាប់សិស្សកម្ពុជាក្រីក្រ។ ក្នុងប្រទេសកម្ពុជា ការទទួលបានសេវាអប់រំនៅមានបញ្ហាផ្នែកសមភាពយេនឌ័រ ជាពិសេសសម្រាប់គ្រួសារក្រីក្រ និងនៅតំបន់ជនបទ ដែលមានស្ត្រីទទួលបានការអប់រំតិចជាងបុរស។ គម្លាតយេនឌ័របានកើនឡើងទៅតាមកម្រិតសិក្សានីមួយៗ ហើយជាពិសេស ចាប់ពីកម្រិតអនុវិទ្យាល័យឡើងទៅ។ ស្ត្រីក៏មានអត្រាការបន្តការសិក្សាតិចជាងបុរសផងដែរ។ ហេតុផលសេដ្ឋកិច្ច និងសង្គម ដែលធ្វើឱ្យមានក្មេងស្រីតិចតួចបន្តការសិក្សា ក្នុងនោះរួមមាន ការចំណាយលើការអប់រំខ្ពស់ ចម្ងាយសាលារៀនឆ្ងាយ និងបំណងតិចតួចរបស់ឪពុកម្តាយចំពោះការអប់រំកូនស្រី។

កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ(ESDP) ត្រូវបានរៀបចំឡើង ដើម្បីជួយកាត់បន្ថយរបាំងដ៏ច្រើននៃការទទួលបានការអប់រំមូលដ្ឋានសម្រាប់ទាំងអស់គ្នា ជាពិសេសសម្រាប់ស្ត្រី និងកុមារជនជាតិភាពតិច។ ការអនុវត្តចាប់ពីឆ្នាំ២០០២ និង២០០៧ កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំបានសម្រេចបាននូវសមភាពយេនឌ័រជាក់ស្តែងមួយចំនួន។ រាជរដ្ឋាភិបាលបានអនុវត្តផែនការសកម្មភាពដោយវិជ្ជមាន ជាពិសេសចំពោះផែនការអប់រំ និងគោលនយោបាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើនការចូលរួមរបស់ស្ត្រី និងកុមារជនជាតិភាគតិចក្នុងគ្រប់កម្រិតសិក្សា។ កម្មវិធីលើកទឹកចិត្តក្នុងទម្រង់នៃការផ្តល់អាហារូបករណ៍ផ្អែកលើសមត្ថភាព ដែលផ្តោតសំខាន់លើសិស្សស្រីនៅមធ្យមសិក្សាត្រូវបានបង្កើត។ ជាបន្តបន្ទាប់ ភាគរយនៃស្ត្រីក្នុងការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យបានកើនឡើងពី ៣០% ទៅ ៤៥,៦% លើសពីគោលដៅដែលគ្រោងទុក ៤០%។ ទន្ទឹមនឹងគ្នានេះដែរ អត្រាចេះអក្សររបស់យុវនារីកើនដល់ ៦៤,១% ក្នុងឆ្នាំ២០០៥ ដែលកើនឡើង ១១% ពីឆ្នាំ២០០០ បើធៀបនឹងគោលដៅមាន ៥០% ត្រឹមឆ្នាំ ២០១៥។

**៣. កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ (ESDP) II មានទឹកប្រាក់ ២៥ ១៦០ ០០០ ដុល្លារអាមេរិក**

គោលបំណងរួមនៃកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំលើកទី២ គឺដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ដោយលើកកម្ពស់ការទទួលបានការអប់រំ និងគុណភាពកម្រិតមធ្យមសិក្សា ព្រមទាំងផ្តល់ឱកាសសម្រាប់អភិវឌ្ឍន៍ជំនាញដល់យុវជនដែលមិនបានចូលរៀន។ ESDP II កសាងបន្ថែមលើ ESDP I ដែលបានជួយសិស្សប្រហែល ៤,២ លាននាក់ឱ្យអាចទទួលបានការអប់រំកម្រិតបឋម រហូតដល់កម្រិតវិទ្យាល័យក្នុងប្រទេសកម្ពុជា និងបានជួយបង្កើតប្រព័ន្ធអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលដែលឆ្លើយតបទៅនឹងទីផ្សារ ដែលនឹងជួយបង្កើនកម្រិតអប់រំក្នុងទីផ្សារការងារ និងជាលទ្ធផលបង្កើនប្រាក់ចំណូលរបស់គ្រួសារ។ លើសពីនេះទៀត កម្មវិធីដែលហិរញ្ញប្បទានដោយប្រាក់កម្ចីនេះ ជួយគាំទ្រដល់វិធានការគោលនយោបាយក្នុងការដោះស្រាយបញ្ហាប្រឈមទាំង៤ នៅក្នុងវិស័យអប់រំ (១) បង្កើនសមភាពនៃការទទួលបានសេវាអប់រំ និងការបណ្តុះបណ្តាល (២) លើកកម្ពស់ស្តង់ដាគុណភាព និងប្រសិទ្ធភាពផ្ទៃក្នុងវិស័យអប់រំ ដោយកែលម្អសមត្ថភាពវិស័យអប់រំ ដើម្បីធ្វើវិមជ្ឈការកាន់តែខ្លាំងថែមទៀត (៣) ការបង្កើនការកៀរគរធនធាន និង (៤)ការធ្វើវិភាជថវិកា។

គម្រោងវិនិយោគ ត្រូវបានបំពេញបន្ថែមដោយគំនិតផ្តួចផ្តើមគោលនយោបាយនៅក្នុងកម្មវិធី ដើម្បីពង្រឹងសមភាពនៃការទទួលបានការកែលម្អគុណភាពអប់រំកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ និងផ្តល់ឱកាសបណ្តុះបណ្តាលផ្អែកលើតម្រូវការ ផ្អែកលើសហគមន៍សម្រាប់សិស្ស ជាពិសេសសម្រាប់យុវជន/នារី ដែលមិននៅក្នុងសាលារៀន តាមរយៈ៖ (១) ពង្រីកឱកាសអប់រំកម្រិតអនុវិទ្យាល័យ (២) ពង្រីកឱកាសអប់រំកម្រិតវិទ្យាល័យ (៣) ពង្រីកការបណ្តុះបណ្តាលជំនាញផ្អែកលើតម្រូវការសហគមន៍ ចំពោះយុវជនមិននៅក្នុងសាលារៀននៃសហគមន៍ក្រីក្រ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

### ៤. គម្រោងពង្រឹងគុណភាពអប់រំ(EEQP) មានទឹកប្រាក់ ២៧ ១០០ ០០០ដុល្លារអាមេរិក

គម្រោងពង្រឹងគុណភាពអប់រំ (EEQP) របស់ធនាគារអភិវឌ្ឍន៍អាស៊ីគឺដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងផ្នែកនេះ។ លទ្ធផលដ៏សំខាន់ៗដែលនឹងដោះស្រាយនៅក្នុងគម្រោងនេះ រួមមាន ៖

- ការផ្សព្វផ្សាយច្បាប់អប់រំ។ ការផ្សព្វផ្សាយនេះនឹងធានាថា នាយកសាលា គ្រូបង្រៀន និងសហគមន៍យល់អំពីសិទ្ធិស្របច្បាប់របស់ពួកគេ
- ការបង្កើតក្របខណ្ឌគោលនយោបាយរឹងមាំមួយដើម្បីធានាថា ការអប់រំដើរតួនាទីក្នុងការអភិវឌ្ឍគ្រូបង្រៀនដែលមានគុណភាពខ្ពស់ ការជ្រើសរើសដោយយកចិត្តទុកដាក់ លើកកម្ពស់ការបណ្តុះបណ្តាល ការបង្កើនសមត្ថភាព និងបង្កើនប្រាក់បៀវត្ស ដើម្បីឱ្យក្លាយជាអាជីពល្អប្រសើរ
- ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធធានាគុណភាពនៅគ្រប់សាលា និងគ្រប់ស្ថាប័នអប់រំដើម្បីជំរុញចលនការនៃការអប់រំឱ្យកាន់តែមានកម្រិតខ្ពស់
- បំពាក់សមត្ថភាពវិជ្ជាជីវៈសម្រាប់អ្នកគ្រប់គ្រងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ឱ្យមានភាពជាអ្នកដឹកនាំ ដើម្បីធ្វើឱ្យគ្រូបង្រៀនមានជំនាញកាន់តែខ្ពស់ និងការធ្វើវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ ដែលអាចអប់រំកូន និងយុវជនរបស់យើងឱ្យបានល្អ
- ស្តារឡើងវិញ និងបង្កើតមណ្ឌលពហុព័ត៌មាន ដែលមានសម្ភារគ្រប់គ្រាន់ អាចឱ្យគ្រូបង្រៀនក្នុងកម្រិតវិទ្យាល័យមានជំនាញពហុព័ត៌មាន និងប្រើប្រាស់សម្រាប់ការសិក្សា
- ការបណ្តុះបណ្តាលគ្រូដែលមិនទាន់មានគុណសម្បត្តិគ្រប់គ្រាន់ ដែលដាក់ឱ្យកាន់តំណែងនៅកម្រិតអនុវិទ្យាល័យ នៅពេលដែលតម្រូវការការអប់រំកើនខ្ពស់ខ្លាំងពេក ប៉ុន្តែមិនទាន់បានបណ្តុះបណ្តាល និងរៀបចំគ្រប់គ្រាន់
- ការសាងសង់មជ្ឈមណ្ឌលសិក្សា នៅក្នុងសាលាបណ្តុះបណ្តាលគ្រូបង្រៀនដែលមានសម្ភារសារគមនាគមន៍ទាន់សម័យសម្រាប់គ្រូបង្រៀន និងគ្រូឧទ្ទេស
- ការសាងសង់មជ្ឈមណ្ឌលធនធានទាន់សម័យនៅវិទ្យាល័យ ដោយបំពាក់នូវបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ប្រជុំ

- ផ្តល់អាហារូបករណ៍សម្រាប់សិស្សដាច់ស្រយាល និងជួបការលំបាក ដើម្បីលើកទឹកចិត្តឱ្យពួកគេបន្តការសិក្សានៅសាលាក្នុងការពង្រឹងសមត្ថភាព
- រៀបចំកម្មវិធីសិក្សាអាទិភាពដូចជា ព័ត៌មានវិទ្យា Multi-media ទេសចរណ៍ ដែលមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចរបស់យើង។

**៥. កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ(ESDP)III មានទឹកប្រាក់ ៣១ ២០០ ០០០ដុល្លារអាមេរិក**

កម្ចីនេះនឹងគាំទ្ររដ្ឋាភិបាល ក្នុងការកែលម្អគុណភាព ភាពប្រើប្រាស់បាន និងការគ្រប់គ្រងការអប់រំនៅកម្រិតអនុវិទ្យាល័យ តាមរយៈការផ្តល់ថវិកាកែលម្អសាលារៀន ដោយផ្តោតលើការដោះស្រាយបញ្ហាត្រួតថ្នាក់ និងបោះបង់ការសិក្សា ការកសាងសមត្ថភាពគ្រប់គ្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលា ការពង្រឹងសមត្ថភាពគ្រូលើមុខវិជ្ជាសំខាន់ៗដូចជា ការអប់រំវិទ្យាសាស្ត្រនិងគណិតវិទ្យា និងការចាប់ផ្តើមកម្មវិធីជំនាញដែលស្របទៅនឹងទីផ្សារការងារ។

កម្ចីនេះនឹងជួយរដ្ឋាភិបាលសាងសង់សាលាកម្រិតអនុវិទ្យាល័យថ្មីចំនួន ៦០ និងពង្រីកបន្ថែមចំនួន ២៨។ សាលាបឋមសិក្សាចំនួន ២២ នឹងត្រូវពង្រីក ដោយរួមបញ្ចូលថ្នាក់រៀននៅកម្រិតអនុវិទ្យាល័យ។ ផ្ទះសម្រាប់គ្រូបង្រៀននឹងត្រូវសាងសង់ក្នុងខេត្តចំនួន ១៥ សម្រាប់គ្រូឧទ្ទេស មកពីតំបន់ដាច់ស្រយាល និងជនបទ។ ទឹកស្អាត និងបង្គន់ សម្រាប់សាលាអនុវិទ្យាល័យក៏នឹងត្រូវសាងសង់ផងដែរ។

**៦. កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ (ESDP) IV**

បច្ច័យនៃកម្មវិធីនេះ គឺការលើកកម្ពស់ការទទួលបានការងារក្រោយបញ្ចប់ការសិក្សាថ្នាក់ទី ១២។ លទ្ធផល គឺបង្កើនការចូលរួមប្រកបដោយគុណភាពនៅកម្រិតវិទ្យាល័យ។ កម្មវិធីនេះមានសូចនាករធាតុចេញ ចំនួន៣ ដូចខាងក្រោម ៖

**<u>ធាតុចេញទី ១ ៖ ការបង្កើនការទទួលបានការអប់រំកម្រិតមធ្យមសិក្សា</u>**

កម្មវិធីនេះនឹងគាំទ្រដល់ការកែទម្រង់គោលនយោបាយអាហារូបករណ៍ជាតិ សំដៅពង្រឹងសមធម៌ ការជ្រើសជ្រើសគ្រូបង្រៀនមធ្យមសិក្សានៅជនបទ និងកែសម្រួលប្រព័ន្ធបណ្តាញនៃមជ្ឈមណ្ឌលធនធាននៅវិទ្យាល័យ។ អន្តរាគមន៍របស់កម្មវិធីគឺផ្តោតនៅតំបន់ជនបទ ដោយសាងសង់សាលាថ្មី និងកែលម្អសាលាដែលមានស្រាប់ ព្រមទាំងនិវេសនដ្ឋានរបស់គ្រូ និងរបស់សិស្សស្រីផងដែរ។ កម្មវិធីសំណាញ់សុវត្ថិភាពសង្គម រៀបចំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាកល្បងគាំទ្រកុមារក្រីក្រ និងគ្រួសារងាយរងគ្រោះឱ្យបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី ៩ ដោយនឹងធ្វើការវាយតម្លៃបច្ច័យនៃការសាកល្បងនេះ។

<u>**ធាតុចេញទី ២ ៖ ការពង្រឹងគុណភាព និងភាពប្រើការបាននៃការអប់រំកម្រិតមធ្យមសិក្សា**</u>

កម្មវិធីនេះនឹងគាំទ្រដល់ការកែទម្រង់គោលនយោបាយ ដើម្បីកែលម្អអត្រាបន្តការសិក្សានៅវិទ្យាល័យ ដោយផ្តោតលើសិស្សស្រី និងសិស្សក្រីក្រ។ ក្នុងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ការអន្តរាគមរបស់កម្មវិធីធ្វើឡើងដើម្បី ៖ (១) គាំទ្រការដល់ការអភិវឌ្ឍន៍កម្មវិធីស្ពានចម្លង ពីសាលារៀនទៅកន្លែងធ្វើការ (២) កម្មវិធីជំនាញដែលអាចរកការងារបាន និង (៣) កម្មវិធីភាពជាសហគ្រិន។ អន្តរាគមន៍ទាំងនេះនឹងសង្កត់ធ្ងន់លើការចូលរួមរបស់ស្ត្រី។ កម្មវិធីនឹងបំពាក់សម្ភារ និងឧបករណ៍បង្រៀន និងរៀន ដើម្បីលើកកម្ពស់វិទ្យាសាស្រ្ត គណិតវិទ្យា និងការអប់រំបច្ចេកវិទ្យា។ មជ្ឈមណ្ឌលធនធាននៅវិទ្យាល័យនឹងត្រូវបង្កើតដើម្បីផ្តល់ការអប់រំបច្ចេកទេសក្នុងភាពជាដៃគូជាមួយនឹងនិយោជក និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស។ កម្មវិធីសិក្សានៅវិទ្យាល័យនឹងត្រូវកែសម្រួល។ ការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ដែលបានរៀបចំក្នុងគម្រោងពង្រឹងគុណភាពអប់រំ (EEQP)នឹងត្រូវគាំទ្របន្ត។

<u>**ធាតុចេញទី៣ ៖ អភិបាលកិច្ច និងការគ្រប់គ្រងការអប់រំមធ្យមសិក្សាត្រូវបានពង្រឹង**</u>

កម្មវិធីនេះនឹងគាំទ្រការកែទម្រង់គោលនយោបាយ ទៅរកស្វ័យភាពនៃសាលាមធ្យមសិក្សា ភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីគ្រប់គ្រងការផ្តល់សេវាអប់រំមធ្យមសិក្សា និងការផ្តល់ហិរញ្ញវត្ថុសាធារណៈគ្រប់គ្រាន់ដល់សាលាមធ្យមសិក្សា។ អន្តរាគមន៍របស់គម្រោងនឹងផ្តល់ការកសាងសមត្ថភាព ក្នុងការគ្រប់គ្រងផ្អែកលើលទ្ធផលនៅវិទ្យាល័យ និងការគ្រប់គ្រងសាលា និងអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា។

## ១៤.៦.២ ធនាគារពិភពលោក

ធនាគារពិភពលោកបានធ្វើការក្នុងនាមជាដៃគូជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ថវិកា គោលការណ៍ណែនាំ ការគ្រប់គ្រង និងគាំទ្រដល់គម្រោងសាងសង់ និងការអប់រំធំចំនួន៥ ក្នុងប្រទេសកម្ពុជារវាងឆ្នាំ១៩៩៨ និង២០១៦ ដូចខាងក្រោម ៖

ទីមួយ–គម្រោងកែលម្អគុណភាពអប់រំ(EQIP) ១៩៩៨-២០០៣ ផ្តល់ហិរញ្ញប្បទាន និងគ្រប់គ្រង ដោយធនាគារពិភពលោក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទីពីរ–គម្រោងគាំទ្រវិស័យអប់រំ(CESSP) ២០០៥-២០១១ ផ្តល់ហិរញ្ញប្បទាន និង គ្រប់គ្រងដោយធនាគារពិភពលោក។

ទីបី–កម្មវិធីពង្រីកវិសាលភាពនៃសកម្មភាពគាំទ្រវិស័យអប់រំ (ESSSUAP) ២០០៨-២០១២ ផ្តល់ហិរញ្ញប្បទាន ដោយអង្គការភាពជាដៃគូសកលសម្រាប់ការអប់រំ និង គ្រប់គ្រង ដោយធនាគារពិភពលោក។

ទីបួន–គម្រោងកែលម្អសមត្ថភាព និងគុណភាពឧត្តមសិក្សា (HEQCIP) ២០១០-២០១៥ បានពន្យារពេលអនុវត្តដល់ឆ្នាំ២០១៧ ដែលផ្តល់ហិរញ្ញប្បទាន និងគ្រប់គ្រងដោយ ធនាគារពិភពលោក ។

ទីប្រាំ–គម្រោងគាំទ្រវិស័យអប់រំទី២ (SESSP) ២០១៤-២០១៧ បានផ្តល់មូនិធិដោយ អង្គការភាពជាដៃគូសកលសម្រាប់ការអប់រំ និងគ្រប់គ្រងដោយធនាគារពិភពលោក ។

គម្រោងទាំង ៥ មានខ្លឹមសារលម្អិតដូចខាងក្រោម ៖

**១. គម្រោងកែលម្អគុណភាពអប់រំ (EQI P) ១៩៩៨-២០០៣**

គោលបំណង ៖ ដើម្បីបង្កើតគំរូដ៏មានប្រសិទ្ធភាពមួយនៃអភិក្រមដោយមាន ការចូលរួម ដើម្បីលើកកម្ពស់គុណភាពសាលារៀន ដែលអាចពង្រីកដល់ខេត្តផ្សេងៗទៀត។ គម្រោងនេះផ្តោតលើការអប់រំនៅបឋមសិក្សា។

*មូលនិធិ៖ ៤ លានដុល្លារអាមេរិក។ ជំនួយឥតសំណងរបស់ជំនួយ អភិវឌ្ឍន៍អន្តរជាតិ* (IDA)

លទ្ធផលគន្លឹះ ៖ កម្មវិធីនេះបានផ្តល់ថវិកាដំណើរការសាលារៀននៅខេត្តចំនួនបី ហើយជោគជ័យនៃកម្មវិធីនេះ បានឈានទៅដល់ការដាក់ចេញកម្មវិធីផែនការសកម្មភាព អាទិភាព។ មេរៀនដែលទទួលបាន យកទៅប្រើប្រាស់ក្នុងកម្មវិធីពង្រីកវិសាលភាពនៃ សកម្មភាពគាំទ្រវិស័យអប់រំ ដោយផ្តល់ថវិកាដល់សាលារៀន។ ការបង្កើតបណ្ណាល័យនៅ សាលាបឋមសិក្សា ដែលឈានទៅដាក់ចេញនូវគោលនយោបាយវិមជ្ឈការកាលវិភាគ ការដាក់ចេញនូវកម្មវិធីភាពជាអ្នកដឹកនាំនៃវិជ្ជាជីវៈនាយកសាលា ដែលទៅដាក់ចេញនូវ កម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិក្នុងពេលបច្ចុប្បន្ន ។

**២. គម្រោងគាំទ្រវិស័យអប់រំកម្ពុជា (CESSP) ២០០៥-២០១១**

គោលបំណង ៖ ដើម្បីអនុវត្តន៍គោលដៅកែលម្អវិស័យអប់រំ លើសមភាពនៃ ការទទួលសេវាអប់រំ ការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការកសាងសមត្ថភាពស្ថាប័ន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយផ្តោតចម្បងលើប្រជាជនក្រីក្រ និងឃុំដែលទទួលបានសេវាអប់រំមិនគ្រប់គ្រាន់ ។ គម្រោងនេះផ្តោតជាចម្បងលើការអប់រំកម្រិតអនុវិទ្យាល័យ។ មូលនិធិ ៖

- ៨ លានដុល្លារអាមេរិក IDA កម្ចីលេខ ៥៥៥-KH
- ២០ លានដុល្លារអាមេរិក IDA ជំនួយឥតសំណងលេខ H161-KH
- ២ លានដុល្លារអាមេរិក បដិភាគនៃរាជរដ្ឋាភិបាលកម្ពុជា

លទ្ធផលគន្លឹះ ៖

ទី១–ការសាងសង់ ៖ អនុវិទ្យាល័យចំនួន ២៣៦ និងសាលាបឋមសិក្សាចំនួន ១៨ ត្រូវបានបញ្ចប់ការសាងសង់ ដោយរួមមាន អណ្តូង បង្គន់ គ្រឿងសង្ហារិម និងការពង្រីកបណ្ណាល័យនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ទី២–អាហារូបករណ៍ត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា។

ទី៣–ស្តង់ដាគុណភាពគ្រូត្រូវបានបង្កើតនិងអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា។

ទី៤–កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនអប់រំមូលដ្ឋាន ៖ គ្រូបង្រៀនចំនួន ៧ ៨០៤ ត្រូវបានបណ្តុះបណ្តាល។

ទី៥–ម៉ូឌុលភាពជាអ្នកដឹកនាំសម្រាប់បណ្តុះបណ្តាលនាយកសាលា។

ទី៦–តេស្តវាយតម្លៃថ្នាក់ជាតិសម្រាប់ថ្នាក់ទី៣ ទី៦ និង ទី៩ ត្រូវបានបង្កើត។

ទី៧–គោលការណ៍ណែនាំ ស្តង់ដាទទួលស្គាល់គុណភាពឧត្តមសិក្សា។

គម្រោងគាំទ្រវិស័យអប់រំកម្ពុជា(CESSP) បន្តពីឆ្នាំ២០០៥ ដល់២០១១។ គម្រោងបានសម្រេចនូវគ្រប់គោលបំណងនៃការអភិវឌ្ឍ ក្នុងគោលដៅនៃការពង្រីកកម្មវិធីនេះ ក្នុងនោះ ពង្រីកការទទួលបានសេវាអប់រំ ដោយដោះស្រាយបញ្ហាផ្នែកផ្គត់ផ្គង់ ផ្នែកតម្រូវការ គុណភាព និង ឧបសគ្គផ្នែកប្រសិទ្ធភាព ដោយផ្តោតលើជនក្រីក្រ និង ឃុំដែលទទួលសេវាអប់រំមិនគ្រប់គ្រាន់។ លទ្ធផលអាចសម្រេចបាន ដោយដាក់ឱ្យអនុវត្តក្របខណ្ឌលទ្ធផល។ ធាតុចេញដែលសម្រេចបានមានដូចខាងក្រោម ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***សមាសភាពទី ១*** ៖ សមភាពនៃការទទួលបានសេវាអប់រំ ៖ (១) ការសាងសង់ ៖ សាលាចំនួន២៤៥ ត្រូវបានសាងសង់ ដោយកែប្រែពីគោលដៅចំនួន២៤៩។ គោលដៅបានកែប្រែដោយសារថ្លៃសាងសង់កើនឡើងក្នុងឆ្នាំ២០០៨ និង (២) អាហារូបករណ៍ ៖ ចំនួនសិស្សងាយរងគ្រោះសរុបចំនួន ៣៤ ៣៤៨ បានទទួលអាហារូបករណ៍ក្នុងចំណោមសិស្សគោលដៅចំនួន ៣៤ ០០០។

***សមាសភាពទី ២*** ៖ គុណភាព និងប្រសិទ្ធភាព ៖ (១) ភាពជាអ្នកដឹកនាំ ៖ នាយកសាលាចំនួន ៩០៨ នាក់ ត្រូវបានបណ្តុះបណ្តាលក្នុងខេត្តចំនួន ១៣ ធៀបនឹងគោលដៅដំបូងមានចំនួនតែ ៤៥០ នាក់ ក្នុងខេត្តចំនួន ១០។ មន្ត្រីការិយាល័យអប់រំខេត្ត ស្រុក និងនាយករងចំនួន ១ ១៦៥ នាក់ ត្រូវបានបណ្តុះបណ្តាល។ មន្ត្រីខ្លះត្រូវបានបណ្តុះបណ្តាលជាគ្រូឧទ្ទេសបន្តនៅក្នុងមូលដ្ឋាន (២) ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ៖ គ្រូចំនួន ៦ ០០០ នាក់ ត្រូវបានបណ្តុះបណ្តាលដោយធៀបនឹងគោលដៅដំបូង ដែលមានតែ ៤ ០០០ នាក់។ ចំនួនបណ្តុះបណ្តាលសរុបបាន ៨ ០០០នាក់ (៣) ការបង្កើតស្តង់ដាគ្រូបង្រៀន ៖ ស្តង់ដាគ្រូបង្រៀនត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា (៤) សាលាកុមារមេត្រី(ធ្វើវិមជ្ឈការ) សាលារៀនចំនួន ១៣៩ ទទួលបានការគាំទ្រថវិកា សម្រាប់អនុវត្តពេញលេញទៅតាមគោលនយោបាយសាលារៀនកុមារមេត្រី។ កម្មវិធីនៃភាពជាអ្នកដឹកនាំចំពោះសាលារៀន ៨៦៩ បន្ថែម ត្រូវបានផ្តោតលើការអនុវត្តគោលនយោបាយសាលារៀនកុមារមេត្រី ដែលមិនមានកំណត់ក្នុងគោលដៅដំបូង និង (៥) ការវាយតម្លៃថ្នាក់ជាតិ ៖ តេស្តត្រូវបានរៀបចំធ្វើចំពោះសិស្សថ្នាក់ទី៣ ទី៦ និងទី៩ ហើយប្រព័ន្ធវាយតម្លៃថ្នាក់ជាតិត្រូវបានអនុវត្ត។

***សមាសភាពទី ៣*** ៖ ការគាំទ្រដល់កម្រិតឧត្តមសិក្សា ៖ (១) បង្កើតនៅទស្សនៈវិស័យ និងយុទ្ធសាស្ត្រសម្រាប់វិស័យឧត្តមសិក្សា ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៥ (២) បញ្ចប់និងបោះពុម្ពផ្សព្វផ្សាយស្តង់ដា និងគោលការណ៍ណែនាំក្នុងការទទួលស្គាល់គុណភាពនៃស្ថាប័នឧត្តមសិក្សា ក្នុងនោះគោលការណ៍ណែនាំសម្រាប់ថ្នាក់មូលដ្ឋានត្រូវបានបញ្ចប់ និងបោះផ្សាយ (៣) ពង្រីកបណ្ណាល័យនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលកិច្ចសន្យាសាងសង់មានតម្លៃ ១,៦ លានដុល្លារអាមេរិក។ ដំណើរការនៃការរចនាការពង្រីកបណ្ណាល័យត្រូវបានពន្យារពេល ដោយសារការរចនាប្លង់ដើមដោយគម្រោងស្រាវជ្រាវស្ថាបត្យកម្មខ្មែរ(ARK) មិនអាចបំពេញបានទៅនឹងតម្រូវការរបស់ក្រសួងអប់រំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យុវជន និងកីឡា ក្នុងការធ្វើសមាហរណកម្មរវាងទស្សនទាននៃការរចនាជាមួយនឹងបណ្ណាល័យដែលមានស្រាប់។ មានការពន្យារពេលក្នុងការសាងសង់។

បន្ថែមលើនេះ កញ្ចប់លទ្ធកម្មបណ្ណាល័យត្រូវបានធ្វើឡើង ២ ជុំ។ ជុំទី១ ក្នុងឆ្នាំ ២០០៩ និងទី២ គឺក្នុងឆ្នាំ២០១១។ ក្នុងជុំទីមួយ កញ្ចប់បណ្ណាល័យបានបញ្ចូលទៅអនុវិទ្យាល័យចំនួន ៣៥៥ ដែលចំនួន ២៤៧ ត្រូវបានសាងសង់ដោយគម្រោង CESSP សល់ពីនោះគឺសាលារៀនស្ថិតនៅក្នុងគម្រោង CESSP តាមរយៈគំនិតផ្តួចផ្តើមសាលាកុមារមេត្រី។ កញ្ចប់នីមួយៗមានសៀវភៅចំនួន ៥៦៩ ក្បាល ទូដាក់សៀវភៅចំនួន៤ និង ទូដាក់សម្ភារចំនួន២។ ក្នុងដើមឆ្នាំ២០១១ គម្រោងមានមូលនិធិគ្រប់គ្រាន់ដែលនៅសល់ ដើម្បីផ្គត់ផ្គង់ជាកញ្ចប់បណ្ណាល័យដល់អនុវិទ្យាល័យ ដែលមិនស្ថិតនៅក្នុងគោលដៅចំនួន២៥៨ នៅក្នុងខេត្តគោលដៅទាំង១២ នៃគម្រោង CESSP ។

**៣.កម្មវិធីពង្រីកវិសាលភាពនៃសកម្មភាពគាំទ្រវិស័យអប់រំ (ESSSUAP) ២០០៨-២០១២**

គោលបំណង ៖ (១) ពង្រីកសេវាអប់រំថ្នាក់មត្តេយ្យ និងបឋមសិក្សាដល់ក្រុមកុមារដែលងាយរងគ្រោះ និង (២) ពង្រឹងវិជ្ជាជីវៈ និងសមត្ថភាពរដ្ឋបាលនៃរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអប់រំ ថ្នាក់កណ្តាល ខេត្ត ស្រុក និងសាលារៀន។ គម្រោងនេះផ្តោតលើការអប់រំបឋមសិក្សា។

មូលនិធិ ៖ ជំនួយឥតសំណងចំនួន ៥៧,៤ លានដុល្លារបានពីអង្គការភាពជាដៃគូសកលសម្រាប់ការអប់រំ ដែលគ្រប់គ្រងដោយធនាគារពិភពលោក បានបើកផ្តល់មានចំនួន ៩៦% នៃមូលនិធិសរុប ត្រឹមខែធ្នូ ឆ្នាំ២០១២។

ការពន្យារពេលអនុវត្ត ៖ កម្មវិធីនេះបានពន្យារពេលអនុវត្តពីខែមិថុនា ឆ្នាំ២០១០ ដល់ខែមិថុនា ឆ្នាំ២០១២ ។ ការពន្យារពេលអនុវត្តបន្ថែមពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០១៣ ត្រូវបានអនុម័ត ដើម្បីបញ្ចប់កម្មវិធីសាងសង់ ដែលបណ្តាលមកពីទឹកជំនន់ខ្ពស់។

លទ្ធផលគន្លឹះ ៖

ទី១–ការសាងសង់សាលារៀនបានចំនួន៤៦៩ ធៀបនឹងគោលដៅ៤៨៦ សាងសង់ការិយាល័យស្រុក៥៣ នៃធៀបនឹងគោលដៅ៦០ សង់សាលាមត្តេយ្យ២៥ នៃគោលដៅ ២៥ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូមត្តេយ្យមួយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទី២–អាហារូបករណ៍ បានផ្តល់ដល់សិស្សក្រីក្រ និងងាយរងគ្រោះចំនួន ១៥ ១២២ នាក់ នៃគោលដៅចំនួន ២៥ ០០០ ដែលរៀនថ្នាក់ទី៤ ដល់ ទី៦ ក្នុងសាលាចំនួន២១៧ ក្នុងខេត្តចំនួន ៣។ អ្នកទទួលបានអាហារូបករណ៍ ៨៥% គឺជាគ្រួសារជនជាតិភាគតិច។

ទី៣–ការផ្តល់ថវិកាដល់សាលារៀន និងកញ្ចប់បណ្ណាល័យបានផ្តល់ដល់សាលាបឋមចំនួន៦០៦។

ទី៤–ការបង្កើតសៀវភៅអំណានថ្មី សៀវភៅថ្នាក់ទី១ និង២ បានបោះពុម្ព និងចែកចាយដល់គ្រប់សាលាបឋមសិក្សាក្នុងប្រទេស។ សៀវភៅថ្នាក់ទី៣ បច្ចុប្បន្នកំពុងតែធ្វើការសាកល្បង ។

ទី៥–ការប្រមូលទិន្នន័យ ពីក្មេងដែលមានអាយុពី២ ដល់១៧ ឆ្នាំ ចំនួន ៤៩ ២៨៣ នាក់ អំពីហេតុផលដែលបោះបង់ការសិក្សា។ សកម្មភាព និងការតាមដានពីលទ្ធផលនៃការសិក្សានេះនេះនឹងបញ្ចូលទៅ ក្នុងផែនការយុទ្ធសាស្រ្តអប់រំឆ្នាំ២០១៣-២០១៨។

**៤. គម្រោងកែលម្អសមត្ថភាព និងគុណភាពឧត្តមសិក្សា (HEQCIP) ខែតុលា ឆ្នាំ ២០១០ ដល់ខែកញ្ញា ឆ្នាំ២០១៧**

គោលបំណង ៖ ធ្វើឱ្យប្រសើរនូវ (ក) គុណភាពនៃការបង្រៀន ការគ្រប់គ្រង និងការស្រាវជ្រាវ នៅក្នុងស្ថាប័នដែលគាំទ្រដោយគម្រោង និង (ខ) ផ្តោតគោលដៅលើសិស្សដែលរងគ្រោះ ដើម្បីពង្រីកការទទួលបានសេវាអប់រំ និងការមិនបោះបង់ការសិក្សា។

មូលនិធិ ៖

- ១១,៥ លានដុល្លារអាមេរិក ជំនួយឥតសំណង លេខ H607-KH
- ១១,៥ លានដុល្លារអាមេរិក កម្ចី លេខ ៤៧៩៦-KH

ការពន្យារពេលអនុវត្ត ៖ គម្រោងនេះបានពន្យារពេលពី ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៧។ គោលបំណងនៃការពន្យារពេលអនុវត្តនេះ គឺអាចប្រើប្រាស់ថវិកានៅសល់ សម្រាប់គាំទ្រការអនុវត្តរបៀបវារៈនៃកំណែទម្រង់ឧត្តមសិក្សា។ ជាក់ស្តែង គឺគាំទ្រក្នុងការអភិវឌ្ឍស្ថាប័នឧត្តមសិក្សាគំរូ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយដាក់ចេញនូវក្របខណ្ឌការវាយតម្លៃ និងត្រួតពិនិត្យផ្អែកលើលទ្ធផលនៃគ្រឹះស្ថានឧត្តមសិក្សា ដោយជួយគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ឱ្យសម្រេចបាននៅលក្ខខណ្ឌវិនិច្ឆ័យនៃគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា តាមរយៈការពង្រឹងការទទួល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គុណភាពផ្ទៃក្នុង(IQA) និងការចាប់ផ្ដើមដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សាតាមព័ត៌មានវិទ្យា។

លទ្ធផលគន្លឹះ ៖

ទី១–ការសាងសមត្ថភាពសម្រាប់កែលម្អគុណភាពក្នុងវិស័យឧត្តមសិក្សា។ លទ្ធផលនេះទទួលបានជោគជ័យ តាមរយៈការផ្ដល់មូលនិធិក្នុងការរៀបចំសិក្ខាសាលាជាច្រើនស្ដីពីការគ្រប់គ្រងការអប់រំ និងភាពជាអ្នកដឹកនាំ ការធានាគុណភាពផ្ទៃក្នុង ព្រមទាំងផ្ដល់ថវិកាដល់បុគ្គលិកឧត្តមសិក្សាចំនួន ៦៤ នាក់ទៅសិក្សាថ្នាក់អនុបណ្ឌិត នៅប្រទេសអូស្ត្រាលី។

ទី២–ការផ្ដល់ថវិកាសម្រាប់ការស្រាវជ្រាវអភិវឌ្ឍន៍ និងច្នៃប្រឌិត ៖ គម្រោងស្រាវជ្រាវចំនួន៩៥ បានបញ្ចប់ដោយជោគជ័យ ហើយវប្បធម៌នៃការស្រាវជ្រាវត្រូវបានបង្កើតឡើង។ វេទិកានៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ថ្នាក់ជាតិត្រូវបានបង្កើត។

ទី៣–អាហារូបករណ៍អាទិភាពពិសេស ៖ សិស្សចំនួន ៩៩៩ នាក់មកពីតំបន់ក្រីក្រ និងងាយរងគ្រោះបានទទួលអាហារូបករណ៍។ អត្រាបន្តការសិក្សាមានចំនួន ៨៦%។

ទី៤–ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ៖ បុគ្គលិកគម្រោង ព្រមទាំងបុគ្គលិកនៃគ្រឹះស្ថានឧត្តមសិក្សាត្រូវបានបណ្ដុះបណ្ដាលផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុ និងផែនការព្រមទាំងការគ្រប់គ្រងលទ្ធកម្ម។

ទី៥–ការត្រួតពិនិត្យ និងវាយតម្លៃ ៖ លទ្ធផលថ្នាក់ជាតិ ផ្អែកលើក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃត្រូវបានបង្កើតឡើង។

ទី៦–HEMIS គឺជាប្រព័ន្ធគ្រប់គ្រងព័ត៌មានឧត្តមសិក្សាបែបព័ត៌មានវិទ្យា ដែលតភ្ជាប់ជាមួយនឹងនាយកដ្ឋានឧត្តមសិក្សាត្រូវបានតម្លើង និងដាក់ឱ្យដំណើរការ។

ទី៧–អភិបាលកិច្ច ៖ សេចក្ដីព្រាងគោលនយោបាយស្ដីពីអភិបាលកិច្ចឧត្តមសិក្សា និងការគ្រប់គ្រងត្រូវបានរៀបចំ។

ទី៨–ចក្ខុវិស័យ និងយុទ្ធសាស្ត្រ ៖ ចក្ខុវិស័យ និងយុទ្ធសាស្ត្រថ្នាក់ឧត្តមសិក្សាក្នុងឆ្នាំ ២០៣០ ត្រូវបានអនុម័ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**៥. គម្រោងគាំទ្រវិស័យអប់រំទី២ (SESSP) ខែកក្កដា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ កក្កដា ឆ្នាំ២០១៧**

គោលបំណង ៖ (១) ពង្រីកការទទួលបានការអប់រំកុមារតូចសម្រាប់ក្មេងអាយុ ៣-៥ ឆ្នាំ។ (២) ចូលរួមចំណែកកែលម្អការទទួលបាន និងគុណភាពសេវាអប់រំមូលដ្ឋាន ជាពិសេស សម្រាប់អ្នកងាយរងគ្រោះ។

មូលនិធិ ៖ ជំនួយឥតសំណងចំនួន ៣៨,៥ លានដុល្លារអាមេរិក បានមកពីភាពជាដៃគូសកលសម្រាប់ការអប់រំ ដែលគ្រប់គ្រងដោយធនាគារពិភពលោក។

លទ្ធផលគន្លឹះ ៖

ទី១–ការត្រួតពិនិត្យ និងវាយតម្លៃ ៖ ក្របខណ្ឌនៃការត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើលទ្ធផលថ្នាក់ជាតិត្រូវបានបង្កើត។

ទី២–ការសាងសង់សាលាមត្តេយ្យសហគមន៍ ៖ សាលាមត្តេយ្យសហគមន៍ចំនួន ១០១ បានបញ្ចប់ការសាងសង់ក្នុងដំណាក់កាលទី១ ជាមួយនឹងការសាងសង់សាលាមត្តេយ្យក្នុងប្រព័ន្ធ ការិយាល័យអប់រំស្រុក និងសាលាបឋមសិក្សា និងមធ្យមសិក្សា។

ទី៣–ការអប់រំឪពុកម្តាយ ៖ អនុស្សរណៈយោគយល់គ្នាជាមួយនឹងក្រសួងមហាផ្ទៃស្តីពីការបង្កើតកម្មវិធីទូរទស្សន៍ស្តីពីការអប់រំម្តាយ ត្រូវបានចុះហត្ថលេខា ហើយកម្មវិធីនេះកំពុងធ្វើការផលិត។

ទី៤–ពន្លឿនគម្រោងផ្តល់អាហារូបករណ៍ ៖ សិស្សងាយរងគ្រោះ និងក្រីក្រចំនួន ៦៨ ២៣៤ នាក់ (សិស្សស្រី ៣៥ ៩៦២ នាក់) រៀនថ្នាក់ទី៤ ទី៥ និងទី៦ ទទួលអាហារូបករណ៍ផ្អែកលើសមត្ថភាព។ អាហារូបករណ៍នេះបច្ចុប្បន្នគ្រប់គ្រងដោយរដ្ឋាភិបាល។ សិស្សងាយរងគ្រោះ និងក្រីក្រចំនួន ៥៩ ៩១២ នាក់ (សិស្សស្រី ៣៥ ៧០៥ នាក់) រៀនថ្នាក់ទី៧ ដល់ទី៩ បានផ្តល់អាហារូបករណ៍បន្ថែមដោយប្រើមូលនិធិគម្រោង។ ចំនួនទឹកប្រាក់អាហារូបករណ៍ដែលបានកើនឡើងនេះបច្ចុប្បន្នផ្តល់ដោយរដ្ឋាភិបាល។

ទី៥–សកម្មភាពកែលម្អគុណភាពភាពអប់រំ ដែលបានអនុវត្តរួមមាន ៖ (១) កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនាយកសាលាត្រូវបានបង្កើត និងកំពុងអនុវត្ត (២) កម្មវិធីគណិត-វិទ្យាថ្នាក់តូចកំពុងរៀបចំ (៣) ការសាងសង់អគារសាលារៀន និងការិយាល័យអប់រំស្រុកស្ថិតក្នុងដំណើរការ (៤) ផ្តល់ជំនួយដើម្បីពង្រឹងសមត្ថភាពបុគ្គលិកនៃនាយកដ្ឋានទទួលស្គាល់គុណភាពអប់រំ និងផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃថ្នាក់ជាតិ និង (៥) ប្រព័ន្ធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អេឡិចត្រូនិកតាមដាន ការអភិវឌ្ឍការអប់រំពីដំណាក់កាលដំបូង ដើម្បីចាត់វិធានទាន់ពេលលើសិស្សទៅនឹងលទ្ធផលនៃការសិក្សា។

ទី៦–ការកែលម្អលទ្ធផលសិក្សាតាមរយៈការលើកកម្ពស់សុខភាព ៖ (១)សេវាសុខាភិបាលវិជ្ជាជីវៈត្រូវបានជួលសម្រាប់ពិនិត្យត្រចៀក និងភ្នែករបស់ក្មេងថ្នាក់ទី១ (២)នាយកដ្ឋានសុខភាពនៃសាលារៀន ធ្វើការសាកល្បងការពិនិត្យសុខភាពមូលដ្ឋានសម្រាប់ក្មេងថ្នាក់ទី១ (៣)នាយកដ្ឋានបណ្តុះបណ្តាលគ្រូបង្រៀនបានធ្វើវិក្រឹតការដល់គ្រូបង្រៀន ៣ ៧៧០ នាក់ សម្រាប់កែលម្អការគ្រប់គ្រងថ្នាក់រៀន និងវិធីសាស្ត្របង្រៀន ដើម្បីជួយជំរុញការរៀនរបស់ក្មេងម្នាក់ៗដែលពិការ ឬមានភាពមិនប្រក្រតី។

### ១៤.៦.៣ សហភាពអឺរ៉ុប

យុទ្ធសាស្ត្ររបស់សហភាពអឺរ៉ុប សម្រាប់គាំទ្រការកែទម្រង់វិស័យអប់រំ ដែលផ្តោតទៅលើប្រជាជនក្រីក្រ ប្រើប្រាស់អភិក្រមគ្របដណ្តប់លើវិស័យអប់រំ ដោយប្រើប្រាស់ «ថវិកាគាំទ្រ» គឺជាយន្តការហិរញ្ញប្បទាន ដែលយន្តការនេះប្រើប្រាស់ប្រព័ន្ធថវិការបស់រដ្ឋាភិបាលក្នុងការរៀបចំផែនការគ្រោងថវិកា និងបើកផ្តល់។ ការធ្វើបែបនេះ គឺជាមធ្យោបាយតែមួយដើម្បីធានានិរន្តរភាព និងធានាភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ព្រមទាំងពង្រឹងយន្តការរៀបចំផែនការ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

*តារាងទី៥០ ៖ កម្មវិធីថវិកាគាំទ្ររបស់សហភាពអឺរ៉ុបក្នុងវិស័យអប់រំ*

| លរ. | ចំណងជើង | ថវិកាសរុប | ថវិកាគាំទ្រ | ថវិកាបញ្ចេញ |
|---|---|---|---|---|
| 1 | ថវិកាគាំទ្រក្នុងគោលដៅកែទម្រង់ការអប់រំមូលដ្ឋានរបស់ប្រជាជនក្រីក្រក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣-២០០៧ | 20 លានអឺរ៉ូ | 15 លានអឺរ៉ូ | 15 លានអឺរ៉ូ |
| 2 | ថវិកាគាំទ្រវិស័យអប់រំមូលដ្ឋានដល់ប្រជានជនក្រីក្រ កម្ពុជា ឆ្នាំ ២០០៨-២០១០ នៃសហគមន៍អឺរ៉ុប | 10 លានអឺរ៉ូ | 7.5 លានអឺរ៉ូ | 7.36 លានអឺរ៉ូ |
| 3 | កម្មវិធីគាំទ្រគោនយោបាយវិស័យអប់រំឆ្នាំ២០១១-២០១៣ | 30.8 លានអឺរ៉ូ | 23.1 លានអឺរ៉ូ | -6.7 លានអឺរ៉ូ (បញ្ចេញសាច់ប្រាក់លើកទី១ ឆ្នាំ ២០១១)<br>-7.19 លានអឺរ៉ូ (បញ្ចេញសាច់ប្រាក់លើកទី២ ឆ្នាំ ២០១២) |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | |
|---|---|---|---|---|
| | | | | -6.5 លានអឺរ៉ូ (បញ្ចេញសាច់ប្រាក់ លើកទី៣ ឆ្នាំ ២០១៣)<br>-0.64 លានអឺរ៉ូ (ស្នើបញ្ចេញសាច់ប្រាក់លើកទី៤ ឆ្នាំ ២០១៤) |
| 4 | ភាពជាដៃគូនៃការកែទម្រង់វិស័យអប់រំកម្ពុជានិង សហគមន៍អឺរ៉ុបឆ្នាំ២០១៤- ២០១៦ | 37 លានអឺរ៉ូ | 32 លានអឺរ៉ូ | 9.6លានអឺរ៉ូ(ស្នើបញ្ចេញសាច់ប្រាក់ លើកទី១ ឆ្នាំ ២០១៤) |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ក្នុងឆ្នាំ២០០៣ សហភាពអឺរ៉ុបបានចាប់ផ្តើមផ្តល់ការ «គាំទ្រថវិកា» លើកដំបូងរបស់ខ្លួននៅកម្ពុជា គឺកម្មវិធីគាំទ្រថវិកាដោយបំពេញគោលដៅក្នុងវិស័យអប់រំ ឆ្នាំ២០០៣-២០០៧ ដោយមានទឹកប្រាក់ ២០លានអឺរ៉ូ ដែលរួមមានជំនួយបច្ចេកទេស ដើម្បីគាំទ្រការអភិវឌ្ឍគោលនយោបាយ និងការពង្រឹងស្ថាប័ន។ បន្ទាប់មក បន្តពីកម្មវិធីគាំទ្រថវិកាដោយមិនកំណត់គោលដៅមានឈ្មោះថា កម្មវិធីគាំទ្រគោលនយោបាយវិស័យអប់រំ (ESPSP) ឆ្នាំ២០០៨-២០១០ (១០ លានអឺរ៉ូ) ដែលរួមទាំងការគាំទ្របំពេញបន្ថែមក្នុងទម្រង់ជាជំនួយបច្ចេកទេស និងសកម្មភាពអភិវឌ្ឍសមត្ថភាព។

«**ការគាំទ្រការអប់រំមូលដ្ឋាន**» គឺជាវិស័យស្នូលមួយ នៃវិស័យស្នូលទាំង ២ នៃកិច្ចសហប្រតិបត្តិការរបស់កម្ពុជា និងសហភាពអឺរ៉ុប។

*តារាងទី៥១ ៖ ការគាំទ្ររបស់សហភាពអឺរ៉ុប ២០០៨–២០១០*

| ថវិកា | 2008 | 2009 | 2010 | សរុប | លក្ខខណ្ឌ |
|---|---|---|---|---|---|
| ថេរ | 2M€ | 2M€ | 1M€ | 5M€ | -វឌ្ឍនភាពនៃអនុវត្តកម្មវិធីការកែទម្រង់ហិរញ្ញវត្ថុសាធារណៈមធ្យមរយៈពេលចំណាយក្របខណ្ឌ<br>- ការវិភាជថវិកា (យ៉ាងហោចណាស់ ៦០ នៃថវិការបស់រដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការយុទ្ធ–សាស្ត្រអភិវឌ្ឍជាតិ)<br>- របាយការណ៍សមិទ្ធកម្មនៃវិស័យអប់រំប្រចាំឆ្នាំ |
| អថេរ | 1M€ | 1M€ | 0.5M€ | 2.5M€ | - ម៉ាទ្រីសសកម្មភាពគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលទាក់ទងនឹងការរកឃើញ និង អនុសាសន៍នៃរបាយការណ៍ការសមិទ្ធកម្មនៃវិស័យអប់រំ និងការត្រួតពិនិត្យវិស័យអប់រំប្រចាំឆ្នាំ<br>- ការចុះហត្ថលេខារួមគ្នាលើឯកសារជំនួយស្មារតីរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងតំណាងដៃគូអភិវឌ្ឍន៍។ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ដំណាក់កាលទី ១** ៖ កម្មវិធីគាំទ្រថវិកាដោយដាក់គោលដៅ ក្នុងវិស័យអប់រំ (២០០៣-២០០៧ មានទឹកប្រាក់ ២០លានអឺរ៉ូ ដែលរួមមានជំនួយបច្ចេកទេស ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ និងការពង្រឹងស្ថាប័ន)។

*តារាងទី៥២ ៖ ការគាំទ្ររបស់សហភាពអឺរ៉ុប ២០១១-២០១៣*

| ការផ្តល់ថវិកា | 2011 | 2012 | 2013 | លក្ខខណ្ឌ |
|---|---|---|---|---|
| លក្ខខណ្ឌមូលដ្ឋាន (ថេរ) | 5 200 000 | 5 200 000 | 5 200 000 | -វឌ្ឍនភាពជាទីពេញចិត្តក្នុងការអនុវត្តគោលនយោបាយនិង យុទ្ធសាស្ត្រនៃវិស័យអប់រំ គឺផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០០៩-២០១៣<br>-បន្តការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកប ដោយស្ថេរភាព<br>-វឌ្ឍនភាពគួរជាទីពេញចិត្តនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ព័ត៌មាននិងប្រព័ន្ធរបាយការណ៍របស់ថ្នាក់ជាតិ |
| លក្ខខណ្ឌសមិទ្ធកម្ម (អថេរ) | 2,500,000 | 2,500,000 | 2,500,000 | សូចនាករលទ្ធផល ១១ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយបង្កើនការវិភាជថវិកាដល់ក្រសួងអប់រំ យុវជន និងកីឡា លើកកម្ពស់សមិទ្ធកម្មសាលារៀន បង្កើនភាពស្វយ័តសាលារៀន កែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការលម្អការរៀបចំផែនការ |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

**ដំណាក់កាលទី ២** ៖ កម្មវិធីគាំទ្រថវិកាដោយមិនដាក់គោលដៅ គឺកម្មវិធីគាំទ្រគោលនយោបាយវិស័យអប់រំ (ESPSP) ឆ្នាំ២០០៨-២០១០ មានចំនួន (១០ លានអឺរ៉ូ) ដែលរួមទាំងការគាំទ្របំពេញបន្ថែម ក្នុងទម្រង់នៃជំនួយបច្ចេកទេស និងសកម្មភាពអភិវឌ្ឍសមត្ថភាព។

### យុទ្ធសាស្ត្ររបស់សហភាពអឺរ៉ុបឆ្នាំ២០០៧-២០១៣

យុទ្ធសាស្ត្ររបស់សហភាពអឺរ៉ុបគឺ ដើម្បីគាំទ្រគោលនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ នៅក្នុងការអប់រំជាមូលដ្ឋានតាមរយៈការគាំទ្រថវិកាចំនួន ៣០,៨ លានអឺរ៉ូ ក្នុងឆ្នាំ២០០៧-២០១០។ «យុទ្ធសាស្ត្រអន្តរាគមន៍របស់សហភាពអឺរ៉ុប គឺដើម្បីបន្តនិងពង្រីក «ការគាំទ្រថវិកា» សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងដើម្បីសម្រេចបានលទ្ធផលគោលចង់បាន ដែលស្របទៅនឹងគោលបំណងរយៈពេលវែងគឺការអប់រំសម្រាប់ទាំងអស់គ្នា»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជំណាក់កាលទី ៣** ៖ កម្មវិធីគាំទ្រគោលនយោបាយវិស័យអប់រំដោយមិនកំណត់គោលដៅ(ESPSP) ឆ្នាំ២០១១-២០១៣ មានការគាំទ្រថវិកាចំនួន ៣០,៨ លានអឺរ៉ូ ដែល ២៣,១ លានអឺរ៉ូ សម្រាប់ថវិកាគាំទ្រ និង ៧,៤៥ លានអឺរ៉ូ សម្រាប់ **មូលនិធិភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ** (CDPF) ដែលគ្រប់គ្រងដោយ UNICEF ដោយការដាក់បញ្ចូលធនធានមកពីសហភាពអឺរ៉ុប ស៊ុយអ៊ែត និងUNICEF ដែលមានទឹកប្រាក់សរុបចំនួន ១៤,៥ លានដុល្លារអាមេរិក ដើម្បីគាំទ្រការអភិវឌ្ឍសមត្ថភាពក្នុងក្រសួង ជាពិសេសនៅថ្នាក់ក្រោមជាតិ។ លទ្ធផលរំពឹងទុកជារួមនៃកម្មវិធី គឺដើម្បីជំរុញការលើកកម្ពស់ការអនុវត្តក្នុងវិស័យនេះទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលមានក្នុងផែនការយុទ្ធសាស្ត្រ វិស័យអប់រំឆ្នាំ ២០០៩-២០១៣ ដោយក្នុងនោះរួមមានការកាត់បន្ថយភាពភាពប្រែប្រួលខុសគ្នានៃលទ្ធផលអប់រំនៅកម្រិតសាលារៀន និងនៅកម្រិតស្រុក។

**ជំណាក់កាលទី ៤** មានទឹកប្រាក់ ៣៧,៧ លានអឺរ៉ូ សម្រាប់ឆ្នាំ ២០១៤-២០១៦។ «យុទ្ធសាស្ត្រអន្តរាគមន៍របស់សហភាពអឺរ៉ុប គឺដើម្បីបន្ត និង ពង្រឹង «ការគាំទ្រថវិកា» ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងសម្រេចនូវលទ្ធផលគោលនយោបាយ ដែលចង់បាន ស្របគ្នាជាមួយគោលបំណងរយៈពេលវែង គឺអប់រំសម្រាប់ទាំងអស់គ្នា»។

គោលបំណងរួមនៃកម្មវិធីថ្មី «ភាពជាដៃគូក្នុងកំណែទម្រង់វិស័យអប់រំអឺរ៉ុប-កម្ពុជា» (ESRP) ឆ្នាំ២០១៤-២០១៦ គឺដើម្បីគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបានចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ ដូចដែលមានក្នុងផែនការអភិវឌ្ឍយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

គោលបំណងជាក់លាក់គឺ៖

ដោយផ្អែកលើការពិភាក្សាគោលនយោបាយកម្រិតខ្ពស់ រវាងម្ចាស់ជំនួយ ជាមួយរាជរដ្ឋាភិបាល ជំនួយត្រូវធ្វើសុខដុមនីយកម្ម និងតម្រែតម្រង់ ឆ្ពោះទៅសម្រេចឱ្យបានការកែទម្រង់គន្លឹះៗ និងដោះស្រាយបញ្ហាប្រឈមគន្លឹះៗរបស់រាជរដ្ឋាភិបាល រួមទាំងឧបសគ្គនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងទី៥៣ ៖ ការគាំទ្ររបស់សហភាពអឺរ៉ុបឆ្នាំ ២០១៤-២០១៦*

| កាផ្ទេរថវិកា | 2014 | 2015 | 2016 | សរុប(លានអឺរ៉ូ) |
|---|---|---|---|---|
| លក្ខខណ្ឌមូលដ្ឋាន(លានអឺរ៉ូ) | 5 | 5 | 5 | 15 |
| លក្ខខណ្ឌអថេរ (លានអឺរ៉ូ) | 5 | 6 | 6 | 17 |
| សរុប (លានអឺរ៉ូ) | 10 | 11 | 11 | 32 |

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា*

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញលិខិតលេខ ៥៥៦៣ MEF/GDB ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ដែលស្នើសុំបញ្ចេញប្រាក់ក្នុងឆ្នាំ២០១៤ ក្នុងនោះលក្ខខណ្ឌមូលដ្ឋានចំនួន ៥ លានអឺរ៉ូ និង លក្ខខណ្ឌសមិទ្ធកម្ម ចំនួន ៤,៦ លានអឺរ៉ូ ពីគណប្រតិភូសហភាពអឺរ៉ុបសម្រាប់ព្រះរាជាណាចក្រកម្ពុជាដែលមានចំនួនសរុប ៩,៦លានអឺរ៉ូ។ លក្ខខណ្ឌនៃការបញ្ចេញប្រាក់គឺ ៖

– <u>លក្ខខណ្ឌថេរ</u> ៖ មានលក្ខខណ្ឌថេរមាន ៤ ដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តម្លាភាពថវិកា និងយុទ្ធសាស្ត្រតាមវិស័យ។

– <u>លក្ខខណ្ឌអថេរ</u> ៖ មានលក្ខខណ្ឌចំនួន ១០ ដូចជា ការចុះឈ្មោះចូលរៀនរបស់កុមារតូច អត្រាបញ្ចប់បឋមសិក្សា អត្រាបញ្ចប់អនុវិទ្យាល័យ បន្ថយអត្រាបោះបង់ការសិក្សាអនុវិទ្យាល័យ អាហារូបករណ៍សម្រាប់បឋមសិក្សា អាហារូបករណ៍សម្រាប់មធ្យមសិក្សា ការអប់រំពហុភាសា គុណភាពគ្រូបង្រៀន ការវាយតម្លៃថ្នាក់ជាតិ និងប្រសិទ្ធភាពនិងតម្លាភាពថវិការបស់ក្រសួង អប់រំ យុវជន និងកីឡា។

## ១៤.៦.៤ ភាពជាដៃគូសកលសម្រាប់ការអប់រំ

កម្ពុជាក៏ទទួលបានជំនួយចំនួន ៥៧,៤ លានដុល្លារអាមេរិក ដែលផ្តល់ដោយ **មូលនិធិដោយភាពជាដៃគូសកលសម្រាប់ការអប់រំ** (ដែលពីមុនហៅថា Fast Track Initiative (FTI)) ដែលបានបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០១២។ សហភាពអឺរ៉ុប និងប្រទេសសមាជិកបានផ្តល់ធនធានជាង ៨០-៩០% នៃភាពជាដៃគូសកលសម្រាប់ការអប់រំ។ គម្រោងនេះ ដំបូងផ្តោតលើការសាងសង់សាលា ការពង្រីកការអប់រំកុមារតូច ការបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀន និងការណែនាំវិធីសាស្ត្រថ្មី សម្រាប់ជំនួយអំណាននៅថ្នាក់តូចៗ គម្រោងនេះ បានលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រថ្នាក់ទី៤ ដល់ទី៦។ គម្រោងភាពជាដៃគូសកលសម្រាប់ការអប់រំទី២ (ឆ្នាំ២០១៤-២០១៧) ត្រូវបានផ្តល់ជំនួយឥតសំណងចំនួន ៣៨,៥ លានដុល្លារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាមេរិក និងផ្តោតជាសំខាន់លើការសាងសង់សាលាមត្តេយ្យ ការពង្រីកការអប់រំកុមារតូច សុខភាពសិក្សា ការបណ្តុះបណ្តាលនាយកសាលា និងការសាកល្បងវិធីសាស្ត្រថ្មីសម្រាប់ជំនួយគណិតវិទ្យាថ្នាក់តូច។

### ១៤.៦.៥. ការផ្តល់ហិរញ្ញប្បទានផ្សេងទៀតពីប្រទេសសមាជិកសហគមន៍អឺរ៉ុប

**ប្រទេសស៊ុយអែត** ៖ ក្រៅពីការគាំទ្រតាមរយៈ UNICEF (UNICEF/Sida) ក៏មានការគាំទ្រ សម្រាប់ការធានាគុណភាព ក្នុងរូបភាពជាសហប្រតិបត្តិការបច្ចេកទេស និងថវិកាកែលម្អសាលារៀន (SIG) ប្រហែលជា ២៣ លានដុល្លារអាមេរិក។

**បែលហ្ស៊ិក** ៖ តាមរយៈភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍បែលហ្ស៊ិក បែលហ្ស៊ិកបានគាំទ្រការអប់រំមូលដ្ឋាន និងបណ្តុះបណ្តាលគ្រូបង្រៀន(BETT) ក្នុងខេត្តសៀមរាប ឧត្តរមានជ័យ និងខេត្តកំពង់ចាម ដែលមានទឹកប្រាក់ប្រហែលជា ១៣,៥៥ លានអឺរ៉ូ។

**ចារាំង** ៖ គាំទ្រវិស័យឧត្តមសិក្សាក្នុងផ្នែកសុខាភិបាល នីតិសាស្ត្រ សេដ្ឋកិច្ច វិស្វកម្ម កសិកម្ម និង វិទ្យាសាស្ត្រមនុស្ស។

### ១៤.៦.៦. មូលនិធិភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ (CDPF)

**មូលនិធិភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ** (CDPF) គឺជាមូនិធិជំនួយពហុភាគីដែលផ្តល់ ដោយសហភាពអឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត(Sida) និងយូនីសេហ្វ ។ គោលបំណងនៃ CDPF គឺដើម្បីពង្រឹងជំនាញបុគ្គលិកក្រសួងអប់រំ យុវជន និងកីឡា (ថ្នាក់ជាតិ ខេត្ត ស្រុក និង កម្រិតសាលា) ទាក់ទងនឹងផែនការហិរញ្ញវត្ថុ និង ការគ្រប់គ្រងវិស័យអប់រំ ដូច្នេះសេវាអប់រំអាចនឹងត្រូវបានផ្តល់ឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលសម្រាប់កម្ពុជា។

ក្នុងដំណាក់កាលដំបូងនៃ CDPF គឺ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ និងមានទឹកប្រាក់ចំនួន ១៤,១ លានដុល្លារអាមេរិក។ ដំណាក់កាលទី២ គឺ ពីខែកុម្ភៈ ឆ្នាំ ២០១៥ ដល់ ខែធ្នូ ឆ្នាំ ២០១៦ គឺមានទឹកប្រាក់ចំនួន ១១ លានដុល្លារអាមេរិក។ ដំណាក់កាលទី២ បានចាប់ផ្តើមក្នុងខែកុម្ភៈ ឆ្នាំ២០១៥។ សហភាពអឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុីស(Sida) និងUNCECF រួមបញ្ចូលគ្នា បង្កើតជាមូលនិធិភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ(CDPF) ដើម្បីបំពេញបន្ថែមថវិកាក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាល។ អភិក្រមនៃរួមបញ្ចូលគ្នានេះនឹងមានឥទ្ធិពលកាន់តែធំ ដោយបើកលទ្ធភាពអាចឱ្យរដ្ឋាភិបាលអនុវត្ត និងរក្សានិរន្តរភាពសកម្មភាពកាន់តែប្រសើរសម្រាប់ប្រព័ន្ធអប់រំទាំងមូល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

CDPF ផ្តល់ជំនួយបច្ចេកទេស ជំនួយថវិកា និងជំរុញការច្នៃប្រឌិតនៅកម្រិតថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រព័ន្ធអប់រំ ដោយធ្វើការជាមួយនាយកដ្ឋានបច្ចេកទេសចំនួន ១ ការិយាល័យអប់រំខេត្តក្នុងចំណោម២៥ និង អង្គការអន្តរជាតិចំនួន២ អង្គការ CARE និង អង្គការ VSO ។ CDPF កំពុងគាំទ្រ ការអភិវឌ្ឍជំនាញទាំងបីកម្រិតក្នុងប្រព័ន្ធអប់រំ ៖

ទី១. ការពង្រឹងជំនាញ ចំណេះដឹង និងគណនេយ្យភាពនៃបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំផែនការ ការត្រួតពិនិត្យ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយ និងការគ្រប់គ្រងកំណែទម្រង់ការអប់រំ សម្រាប់លើកកម្ពស់សមិទ្ធកម្មក្នុងវិស័យ។

ទី២. ពង្រឹងជំនាញ ចំណេះដឹង និងគណនេយ្យភាពនៅថ្នាក់ស្រុក និងខេត្ត ដើម្បីរៀបចំផែនការការគ្រប់គ្រង ការត្រួតពិនិត្យ និងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយសម្រាប់ការផ្តល់សេវាអប់រំកាន់តែប្រសើរ។

ទី៣. ពង្រឹងជំនាញ ចំណេះដឹង និងគណនេយ្យភាពនៅក្នុងសាលារៀន ក្នុងការធ្វើផែនការ គ្រោងថវិកា និងការគ្រប់គ្រងក្នុងគោលបំណងបង្កើនការចូលរួម និងការសិក្សារបស់កុមារ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៥
# ការកែលម្អគុណភាពរបស់សាលារៀន ៖ ការបង្កើតសាលារៀនជំនាន់ថ្មី និងការគ្រប់គ្រងសាលារៀននៅកម្ពុជា

ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំ រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងផ្តល់សេវាអប់រំប្រកបដោយភាពជឿជាក់និងរហ័សរហួន ព្រមទាំងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា។ ទោះជាយ៉ាងណា តាមរយៈឯកសារស្រាវជ្រាវអន្តរជាតិបានបង្ហាញថា ការអប់រំដែលមានគុណភាព អាស្រ័យលើ ***កត្តាគ្រូបង្រៀននិងសាលារៀន*** និង ***កត្តាសិស្សនិងគ្រួសារ***[293]។ ជាទូទៅ កត្តាសាលារៀន រួមបញ្ចូលទាំងការអនុវត្តគោលការណ៍ ***គ្រប់គ្រងសាលារៀន*** (School-Based Management-SBM) និងការកែលម្អហេដ្ឋារចនាសម្ពន្ធសាលារៀន ដែលអាចមានឥទ្ធិពលជាវិជ្ជមានលើគុណភាពនៃការអប់រំ និងការបង្រៀននិងរៀន ។ នៅក្នុងផ្នែកនេះនឹងពិនិត្យមើលអំពី (i) កម្មវិធីសាលារៀនជំនាន់ថ្មី (NGS) និង (ii) ***ការគ្រប់គ្រងសាលារៀន*** (Siber) ។

## ១៥.១. សាលារៀនជំនាន់ថ្មី

នៅក្នុងការអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់គុណភាពអប់រំ កម្ពុជាបានប្រឈមមុខនឹងបញ្ហាចម្បងមួយគឺ ខណៈពេលដែលកម្ពុជាត្រូវការផ្តល់សេវាអប់រំប្រកបដោយសមធម៌ដើម្បីធានាឱ្យមានយុត្តិធម៌សង្គម កម្ពុជាក៏ត្រូវតែកែលម្អគុណភាពអប់រំរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការធនធានមនុស្សដែលមានសមត្ថភាព។ កម្ពុជាបានអនុវត្តយុទ្ធសាស្ត្រលក្ខណៈសេរី មានន័យថា ប្រព័ន្ធអប់រំរបស់កម្ពុជារួមបញ្ចូលទាំងផ្នែកសាធារណៈ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ នៅពេលដែល សាលារៀនសាធារណៈតម្រូវឱ្យអនុវត្តកម្មវិធីសិក្សាផ្លូវការ សាលារៀនឯកជននិងសាលា គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលមានសេរីភាពក្នុងការកែច្នៃកម្មវិធីសិក្សាផ្លូវការ ឱ្យបំពេញតាមស្តង់ដាអន្តរជាតិ ដោយអនុវត្តតាមកម្មវិធីសិក្សានៅបណ្តាប្រទេសអភិវឌ្ឍន៍ជាច្រើន

---

293 Glewwe, P. (2014), Overview of Education Issues in Developing Countries, in Glewwe, P. (2014) Edited, Education Policy in Developing Countries, University of Chicago Press, Chicago, p. 3.


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទៀត។ ចាប់តាំងពីឆ្នាំ ២០១៣មក ក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតលើកំណែទម្រង់អាទិភាព២ គឺ ទី (១) ការបង្កើតសាលារៀនមួយចំនួនតូចឱ្យមានស្តង់ដាខ្ពស់ ដើម្បីដោះស្រាយគម្លាតជំនាញនិងបង្កើនចំនួនសិស្សសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា តាមរយៈការបង្កើតសាលារៀនជំនាន់ថ្មី និងទី (២) ការអនុវត្តកម្មវិធីកំណែទម្រង់ឆ្ពោះទៅពង្រឹងប្រព័ន្ធអប់រំជាទូទៅ[294] តាមរយៈ ការអនុវត្តគោលនយោបាយសាលារៀនកុមារមេត្រីនៅទូទាំងប្រទេស។ ដូច្នេះ ស្របពេលដែលកម្មវិធីកំណែទម្រង់ជាច្រើនជាកិច្ចការសំខាន់ត្រូវអនុវត្ត រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវពិនិត្យឡើងវិញអំពីការរៀបចំសាលារៀនក្នុងរូបភាពមួយប្លែកពីមុន ក្នុងគោលបំណងដើម្បីលើកកម្ពស់គុណភាពអប់រំ។

### ១៤.១.១. ការបង្កើតសាលាជំនាន់ថ្មី ដើម្បីលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច

គម្រោងសាលារៀនជំនាន់ថ្មី ត្រូវបានសាកល្បងដោយក្រសួងអប់រំ យុវជន និងកីឡា អង្គការសកម្មភាពបឋមសិក្សានៅកម្ពុជា (KAPE) និងអង្គការអប់រំពិភពលោក នៅក្នុងទីតាំងសាលារៀនអនុវត្តនៃសាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមថ្មីក្នុងវិស័យអប់រំ។ គម្រោងនេះមានគោលបំណងបង្កើតគំរូនៃការគ្រប់គ្រងចម្រុះមួយ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ គណនេយ្យភាព និងស្វ័យភាពនៅកម្រិតសាលារៀន។ ក្នុងន័យនេះ សាលារៀនជំនាន់ថ្មីស្រដៀងគ្នាទៅនឹងសាលារៀន Charter School ឬ សាលារៀន Theme school នៅសហរដ្ឋអាមេរិក ឬក៏ជាសាលារៀន Independent school នៅប្រទេសអូស្ត្រាលី[295]។

គម្រោងសាលារៀនជំនាន់ថ្មីនេះ នឹងផ្តល់លទ្ធភាពឱ្យសាលារៀនរដ្ឋមួយចំនួនតូចនៅកម្ពុជាធ្វើការលើកកម្ពស់អភិបាលកិច្ចល្អ បង្កើនស្តង់ដាវិជ្ជាជីវៈកម្រិតខ្ពស់ និងផ្តល់ការរៀនសូត្រមានគុណភាពខ្ពស់ ដែលគាំទ្រដោយសេណារីយ៉ូវិនិយោគកម្រិតខ្ពស់មួយ។ ប្រការនេះមានន័យថា ការបង្កើនវិនិយោគពីថវិកានិងឯកជន ជាកត្តាចាំបាច់សម្រាប់គម្រោងសាលារៀនជំនាន់ថ្មីនេះ ដើម្បីដំណើរការក្នុងរូបភាពជាគំរូមួយរបស់សាលារៀនរដ្ឋ។ ការវិនិយោគនេះនឹងអនុញ្ញាតឱ្យគណៈគ្រប់គ្រងសាលារៀនមានលទ្ធភាពធ្វើទំនើបកម្មអគារសិក្សា និងបំពាក់សម្ភារបរិក្ខារ ស្របនឹងស.វ.ទី ២១ រួមបញ្ចូលទាំងការប្រើប្រាស់ ICT សម្រាប់ការបង្រៀននិងការរៀន និងអនុវត្តគោលនយោបាយសាលាកុមារមេត្រីប្រកបដោយប្រសិទ្ធភាព។ ដើម្បីដោះស្រាយបញ្ហាសមធម៌ មូលនិធិសមធម៌ពិសេសមួយ

---

[294] See also KAPE (2016), Discussion Note: Achieving Greater Efficiencies in Educational Development through High and Low Cost Development Strategy. June 2016.

[295] See KAPE (2015). Developing Future Generation Schools in Cambodia. A Proposal to Provide Technical Assistance to MoEYS for an FGS National Initiative.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នឹងត្រូវបង្កើតឡើងដោយផ្តោតលើសិស្សក្រីក្រនិងរៀនពូកែ។ ផ្អែកលើទិដ្ឋភាពទាំងនេះ គម្រោងសាលារៀនជំនាន់ថ្មីមានគោលបំណងជំរុញកំណែទម្រង់វិស័យអប់រំ លើផ្នែកអភិបាលកិច្ចស្ថាប័ន និងសកម្មភាពបង្រៀននិងរៀន ព្រមទាំងការត្រួតពិនិត្យការបំពេញការងាររបស់គ្រូបង្រៀន[296]។

គោលបំណងក្នុងការបង្កើតសាលារៀនជំនាន់ថ្មី គឺដើម្បីលើកកម្ពស់ ៖

i. ***ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព*** ៖ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាជាធាតុដ៏សំខាន់ ក្នុងការកែលម្អគុណភាពអប់រំនិងលទ្ធផលសិក្សារបស់សិស្ស។ ដូច្នេះ ការបណ្តុះបណ្តាលនិងវិក្រឹតការនាយកសាលារៀន ជាកិច្ចការសំខាន់ក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំ ប្រកបដោយប្រសិទ្ធភាពនៅកម្រិតសាលារៀន។ លើសពីនេះទៀត ការតែងតាំងនាយកសាលារៀនផ្អែកលើសមត្ថភាពការងារ ក៏នឹងជួយលើកកម្ពស់គុណភាពនៃភាពជាអ្នកដឹកនាំនិងសុចរិតភាពផងដែរ។ ដោយហេតុនេះហើយ ទើបផែនការសកម្មភាព និងសិក្ខាសាលាស្តីពីគោលការណ៍នៃអភិបាល-កិច្ចល្អ ត្រូវបានរៀបចំឡើងសម្រាប់គណៈគ្រប់គ្រងវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យមួយចំនួនទៀតដើម្បីរៀនសូត្រ។

ii. ***គណនេយ្យភាពនៅកម្រិតសាលារៀន*** ៖ ប្រសិទ្ធផលនៃការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន និងការងារវិក្រឹតការគ្រូបង្រៀន នឹងផ្អែកលើការសន្មតថា នាយកសាលារៀនជំរុញនិងតាមដានការបំពេញការងាររបស់គ្រូបង្រៀន [297] ។ កង្វះគណនេយ្យភាពនៅក្នុងសាលារៀនសាធារណៈ បណ្តាលមកពីប្រាក់បៀវត្សនៅទាប និងកង្វះការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន ព្រមទាំងការវាយតម្លៃនាយកសាលារៀនផ្អែកលើសមត្ថភាពការងារ។ ថ្វីបើ ពេលខ្លះសិស្សត្រូវបានតម្រូវឱ្យបង់ថ្លៃរៀនគួរបន្ថែមឬចំណាយក្រៅផ្លូវការក៏ដោយ ក៏ការចំណាយទាំងនេះមិនបានឆ្លុះបញ្ចាំងអំពីគុណភាពនៃការរៀនសូត្រនោះទេ [298] ។ ខណៈពេលដែលគម្រោងសាលារៀនជំនាន់ថ្មីតម្រូវឱ្យមាតាបិតាសិស្សចូលរួមវិភាគទាន កិច្ចព្រមព្រៀងថ្មីមួយស្តីពីគណនេយ្យភាពរវាងសាលារៀនសាធារណៈនិងមាតាបិតាសិស្សនឹងត្រូវបង្កើតឡើង ដើម្បីធានាការផ្តល់សេវាអប់រំដែលមានគុណភាពខ្ពស់ស្ថិតក្នុងទម្រង់អភិបាលកិច្ចថ្មី។ នៅពេល

---

[296] MoEYS, KAPE and World Education (2016). Progress Report 3 on New Generation School Initiative (Sisovath HS), April to June 2016.
[297] See also KAPE (2016), Discussion Note: Achieving Greater Efficiencies in Educational Development through High and Low Cost Development Strategy. June 2016.
[298] KAPE (2014). Creating a New Generation of Schools in Cambodia. Discussion Paper: Experimenting in New Governance Structures to Create High Quality Education Models. Final Draft. October 2014. p. 2.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដែលគោលការណ៍បង់ថ្លៃដោយស្ម័គ្រចិត្តត្រូវបានដាក់ឱ្យអនុវត្ត ពេលនោះរូបភាពអវិជ្ជមានមួយចំនួនត្រូវបានលុបបំបាត់ ដូចជា ការដាក់កំហិតឱ្យសិស្សរៀនគួរបន្ថែម ការលក់ដូរចំណីនៅក្នុងថ្នាក់រៀន និងការបង់ថ្លៃក្រដាសប្រឡង។

iii. *សហគមន៍សិក្សាវិជ្ជាជីវៈ* ៖ វត្ថុបំណងមួយនៃផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនគឺ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនដើម្បីលើកកម្ពស់គុណភាពនៃការរៀនសូត្រ។ ទោះជាយ៉ាងណា ការស្រាវជ្រាវបានបង្ហាញថា ការគាំទ្រគ្នាទៅវិញទៅមក រវាងគ្រូបង្រៀននិងគ្រូបង្រៀន និងការបង្កើតបណ្ដាញគ្រូដើម្បីចែករំលែកបទពិសោធល្អៗ នឹងអាចនាំឱ្យគុណភាពនៅកម្រិតសាលារៀនមានភាពល្អប្រសើរឡើងផងដែរ។ ជាផ្នែកមួយនៃការបង្កើនបទពិសោធជាលក្ខណៈអន្តរជាតិ បុគ្គលិកនៃគម្រោងសាលារៀនជំនាន់ថ្មីបានធ្វើទស្សនកិច្ចសិក្សានៅសាលារៀនចំនួន ៣ ក្នុងនោះមានដូចជា សាលា Lamplaimat Pathana[299] និងសាកលវិទ្យាល័យក្នុងខេត្ត Buriram នៃប្រទេសថៃ។ សាលា Lamplaimat ជាសាលាគំរូមួយ ដែលកំពុងដំណើរការក្នុងរូបភាពជាសាលារៀនជំនាន់ថ្មី និងបានបញ្ចូលនូវបណ្ដុំវិធីសាស្ត្រសាកល្បងថ្មីៗក្នុងការអភិវឌ្ឍអប់រំ ដូចជា ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ ការសិក្សាដោះស្រាយបញ្ហា និង Mind Mapping។

iv. *គំរូនៃការគ្រប់គ្រងចម្រុះ* ៖ ការគ្រប់គ្រងសាលារៀនគឺជាកត្តាសំខាន់ ក្នុងការកែលម្អគុណភាពអប់រំ។ ក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពមកពីក្រសួងអប់រំ យុវជន និងកីឡានិងបុគ្គលិកអង្គការ KAPE ត្រូវបានបង្កើតឡើង ដើម្បីធានាគណនេយ្យភាពរបស់នាយកសាលានិងគ្រូបង្រៀន ចំពោះលទ្ធផលការងាររបស់សាលារៀន។ គ្រូបង្រៀនថ្មីត្រូវបានជ្រើសរើសតាមរូបភាពប្រកួតប្រជែងនិងមានតម្លាភាព ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល។ ក្រៅពីនេះ ដើម្បីទទួលបានប្រាក់បៀវត្សបន្ថែម គ្រូបង្រៀនត្រូវបានកំណត់ឱ្យបញ្ឈប់ការបង្រៀនគួរ និងងាកមក ផ្ដោតលើការបង្រៀននៅក្នុងថ្នាក់។ គណៈគ្រប់គ្រងសាលានិងគ្រូបង្រៀនត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើកិច្ចសន្យា ដែលផ្សារភ្ជាប់ប្រាក់បៀវត្សបន្ថែមជាមួយនឹងការបំពេញការងារ។

v. *សម្ភារបរិក្ខារទំនើបនិងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈបន្តច្បាស់លាស់* ៖ ស្របពេលដែលការ វិនិយោគលើបរិស្ថានសាលារៀន ដូចជាអគារសិក្សាទំនើប សម្ភារបរិក្ខារ បណ្ណាល័យ សម្ភារ ICT និងបន្ទប់ពិសោធន៍ ត្រូវបានយកចិត្តទុកដាក់ ជាមួយគ្នានេះ ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈ

[299] It is the top school in Buriram Province and scores among the top 10% of schools in the Kingdom of Thailand.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ច្បាស់លាស់និងប្រព័ន្ធផ្តល់លាភការ នឹងធានានូវការបន្តលើកទឹកចិត្តគ្រូបង្រៀន[300] (អាហារូបករណ៍បន្តការសិក្សា ការប្រើប្រាស់ឧបករណ៍ ICT ដូចជា កុំព្យូទ័រយួរដៃ ឧបករណ៍បញ្ចាំង និងឱកាសដំឡើងឋានន្តរស័ក្តិ)។ សោភណភាពរបស់បរិស្ថានសាលារៀន ក៏មានផលប៉ះពាល់ជាវិជ្ជមានលើការរៀនសូត្រផងដែរ។ គ្រូបង្រៀនដែលបម្រើការនៅសាលារៀនជំនាន់ថ្មី ស្ថិតក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ នឹងបន្តទទួលបានការគាំទ្រជាការអភិវឌ្ឍសមត្ថភាពតាមរូបភាពជាច្រើន ដូចជា ការប្រើប្រាស់បច្ចេកវិទ្យា។ ការធ្វើតេស្តបានបង្ហាញអំពីការកើនឡើងនៃភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ ICT ពី ៣២ % ដល់ ៥៩ % ឬក៏កើនឡើង ២៧ %។ ភាពស្ទាត់ជំនាញនេះបានកើនឡើងខ្លាំង ដោយសារគ្រូបង្រៀនជាច្រើនមិនធ្លាប់ប្រើប្រាស់ឧបករណ៍ ICT។ ការធ្វើតេស្តនេះផ្តោតលើជំនាញ ៣ គឺ ជំនាញ ICT ទូទៅ ជំនាញប្រើប្រាស់ ICT ក្នុងការអប់រំ និងការប្រើប្រាស់អ៊ិនធឺណិត។ គ្រូបង្រៀនជាច្រើនមានជំនាញតិចតួចក្នុងការប្រើប្រាស់ ICT ក្នុងការអប់រំ (ទិន្នន័យមូលដ្ឋាន ២៣%) ហើយជំនាញនេះក៏ជាជំនាញដែលមានការកើនឡើងខ្លាំងជាងគេផងដែរ[301]។

vi. *គ្រូបង្រៀនសកម្ម* ៖ គំនិតផ្តួចផ្តើមនេះគឺជាការផ្លាស់ប្តូរជាមូលដ្ឋានមួយនៃវប្បធម៌ការងារ ការគ្រប់គ្រង និងបរិស្ថានរូបវន្ត។

## ១៥.១.២ .ការអនុវត្តគម្រោងសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ

ក្រសួងបានសាកល្បងគម្រោងសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ ដោយបានចុះកិច្ចសន្យាជាមួយអង្គការ KAPE នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៥ ដើម្បីបង្កើតសាលារៀនជំនាន់ថ្មី១នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយផ្អែកលើទស្សនទានសាលារៀនក្នុងសាលារៀន។ ជាបន្តបន្ទាប់ អង្គការ KAPE បានជួបជាមួយអ្នកគ្រប់គ្រងនៃវិទ្យាល័យព្រះស៊ីសុវត្ថិ ដើម្បីបង្ហាញអំពីគម្រោងសាលារៀនជំនាន់ថ្មី។ ផែនការសម្មភាពរបស់គម្រោងនេះត្រូវបានអនុម័តនៅខែធ្នូ ឆ្នាំ២០១៥។ នៅក្នុងឆ្នាំទី១ គម្រោងសាលារៀនជំនាន់ថ្មីនឹងអនុវត្តចំពោះថ្នាក់ទី៧ និងថ្នាក់ទី១០ តែប៉ុណ្ណោះ។ ក្រុមប្រឹក្សាភិបាលសាលាជំនាន់ថ្មីត្រូវបានបង្កើតឡើងនិងដឹកនាំដោយអគ្គនាយកអប់រំ ដើម្បីពិនិត្យមើលទូទៅលើគម្រោងនេះ។ ក្រុម

---

[300] KAPE (2014). Creating a New Generation of Schools in Cambodia. Discussion Paper: Experimenting in New Governance Structures to Create High Quality Education Models. Final Draft. October 2014. p. 4.

[301] MoEYS, KAPE and World Education (2016). Progress Report 3 on New Generation School Initiative (Sisowath HS), April to June 2016. p. 8.

ប្រឹក្សាភិបាលនេះមានភារកិច្ចពិនិត្យមើលលើថវិកា និងការសម្រេចចិត្តសំខាន់ៗទាក់ទងនឹងការចូលរៀន ការជ្រើសរើសគ្រូ និងការគ្រប់គ្រងនៅក្នុងសាលារៀន។

ចំណុចសំខាន់ៗនៅក្នុងផែនការសកម្មភាព មានដូចខាងក្រោម[302] ៖

- *មុខវិជ្ជាសិក្សា* ៖ មុខវិជ្ជាសិក្សាចំនួន៤ គឺ គីមីវិទ្យា រូបវិទ្យា ជីវវិទ្យា និងបច្ចេក-វិទ្យា។ មុខវិជ្ជានីមួយៗនឹងបង្កើនម៉ោងសិក្សាពី២ ទៅ៤ ម៉ោងក្នុង១សប្តាហ៍ ទៅ៨ ម៉ោងក្នុង១សប្តាហ៍
- *ការបង្កើនម៉ោងសិក្សា* ៖ គម្រោងសាលារៀនជំនាន់ថ្មីនឹងផ្តល់ការសិក្សា ៤០ ម៉ោង ក្នុង ១ សប្តាហ៍ ដោយបន្ថែមម៉ោងសិក្សាសម្រាប់មុខវិជ្ជា STEM ដូចជា គីមីវិទ្យា រូបវិទ្យា។ល។
- *ម៉ោងបង្រៀន* ៖ គ្រូបង្រៀននឹងបំពេញការងារជាអប្បបរមា១៨ ម៉ោងក្នុង១ សប្តាហ៍
- *ការជ្រើសរើសគ្រូបង្រៀន* ៖ ការជ្រើសរើសនឹងឈរលើគោលការណ៍ស្ម័គ្រចិត្ត ប្រកួតប្រជែង និងតម្លាភាព
- *បៀវត្សផ្អែកលើលទ្ធផលការងារ* ៖ គ្រូបង្រៀននឹងត្រូវបានផ្តល់របប ១៦៥ ដុល្លារក្នុង១ខែ បន្ថែមទៅលើការឧបត្ថម្ភបន្ថែមដទៃទៀត។ គ្រូបង្រៀននឹងចុះហត្ថលេខាលើកិច្ចសន្យាដែលកំណត់ច្បាស់ពីតួនាទី និងភារកិច្ចរបស់ខ្លួន។ ការប្រព្រឹត្តកំហុសនានានឹងត្រូវរាយការណ៍ទៅក្រុមប្រឹក្សា ដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្តចុងក្រោយទាក់ទងនឹងការបញ្ឈប់ការងារ ដោយយោងទៅលើអនុសាសន៍ពីសាលារៀន
- *កម្មវិធីអភិវឌ្ឍសមត្ថភាព* ៖ គ្រូបង្រៀននិងអ្នកគ្រប់គ្រងសាលារៀននឹងចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់។ អ្នកគ្រប់គ្រងសាលារៀននឹងទទួលការបំប៉នអំពីភាពជាអ្នកដឹកនាំ ការកសាងផែនការ គោលការណ៍ក្នុងការលើកកម្ពស់យុវជន និងការពង្រឹងអភិបាលកិច្ចល្អ (រួមបញ្ចូលទាំង ការលុបបំបាត់ការរៀនគួរក្នុងម៉ោងសិក្សា)។ សកម្មភាពអភិវឌ្ឍសមត្ថភាពសម្រាប់គ្រូបង្រៀននឹងផ្តោតលើ ជំនាញត្រិះរិះពិចារណា ការបង្កើតថ្មី និងការបញ្ចូលនូវបច្ចេក-វិទ្យាថ្មីៗក្នុងការបង្រៀននៅតាមថ្នាក់រៀន។ គ្រូបង្រៀនអាចមានលទ្ធភាពស្នើសុំអាហារូបករណ៍ សម្រាប់ការបណ្តុះបណ្តាលដទៃទៀត

[302] MoEYS, KAPE and World Education (2016). Progress Report 1 on New Generation School Initiative (Sisovath HS), April to June 2016.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- *ការបង្រៀនគួរ* ៖ គ្រូបង្រៀននឹងមិនត្រូវអនុញ្ញាតឱ្យបង្រៀនគួរឯកជនក្នុងម៉ោងសិក្សា ឬក៏ជាមួយនឹងសិស្សផ្ទាល់របស់ខ្លួន
- *ការជួសជុល*៖គម្រោងនឹងជួសជុលបន្ទប់កុំព្យូទ័រ១បន្ទប់ពិសោធន៍វិទ្យាសាស្រ្ត ៣ និង បន្ទប់រៀន១២ បន្ថែមទៅលើបន្ទប់បណ្ណាល័យ បន្ទប់សម្រាប់គ្រូបង្រៀន និងបន្ទប់សម្រាប់ប្រឹក្សាអាជីព។

ពិធីសម្ពោធគម្រោងសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ បានធ្វើឡើងក្នុងខែមេសា ឆ្នាំ២០១៦។ សិស្សប្រមាណ ៤០០ នាក់បានចូលរៀន បុគ្គលិក ២៦ រូបត្រូវបានជ្រើសរើសប្រកបដោយភាពប្រកួតប្រជែង និងមានអ្នករដ្ឋបាល ២ រូប បណ្ណារក្ស ១ រូប និងអ្នកផ្តល់ប្រឹក្សាអាជីព ១ រូប [303] ។ គម្រោងសាលារៀនជំនាន់ថ្មីចាប់ផ្តើមដំណើរការជាមួយនឹងសិស្សថ្នាក់ទី៧ និងថ្នាក់ទី១០។ សិស្សទាំងនេះកំពុងសិក្សា ៤០ ម៉ោងក្នុង ១ សប្តាហ៍ និងផ្តោតលើមុខវិជ្ជាវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា។

បន្ទាប់ពីបញ្ចប់ការជ្រើសរើសគ្រូបង្រៀននៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦ គម្រោងផ្តោត លើបុគ្គលិកបានចាប់ផ្តើមសកម្មភាពអភិវឌ្ឍសមត្ថភាព ដោយផ្តោតលើ ៖ (១) ការតម្រង់ទិសគ្រូបង្រៀនអំពីទស្សនទានសាលារៀនជំនាន់ថ្មី (២) ការគ្រប់គ្រងនិងរៀបចំថ្នាក់រៀន (៣) បច្ចេកទេសគរុកោសល្យទូទៅ ដូចជា Cooperative learning, Taxonomy of question and critical thinking ៤) ការបញ្ចូល ICT ទៅក្នុងការបង្រៀននិងរៀន។ ថ្នាក់តម្រង់ទិសត្រូវបានរៀបចំសម្រាប់សិស្សដោយផ្តោតលើ សិស្សមជ្ឈមណ្ឌល ការរៀបចំកម្មវិធីតាមប្រធានបទ (ឧទា. គីមីវិទ្យា រូបវិទ្យា ។ល។) ការរៀបចំគម្រោង សេវាប្រឹក្សា និងការជួសជុលបរិស្ថានបន្ទប់រៀន។

ក្លឹបសិក្សាត្រូវបានបង្កើតឡើង និងផ្តោតលើមុខវិជ្ជាជាច្រើនដូចជា ក្លឹបវិទ្យាសាស្រ្ត ICT ប្រវត្តិវិទ្យា ភាសាខ្មែរ និងភាសាអង់គ្លេស។ មជ្ឈមណ្ឌលយុវជនបានចាប់ដំណើរការ និងកំពុងសិក្សាអង្កេតស្តីពីយុវជនមានហានិភ័យខ្ពស់ សម្រាប់ការគាំទ្រជាប្រឹក្សាលក្ខណៈឯកជន។

ការអនុវត្តការសិក្សាតាមបែប Project work នៅគ្រប់កម្រិតនិងថ្នាក់ទាំងអស់ទទួលបានក្តីសាទរពីសិស្សគ្រប់រូប ដូច្នេះហើយនៅតាមបន្ទប់រៀនពោរពេញទៅដោយកិច្ចការស្នាដៃស្រាវជ្រាវ ដែលសិស្សបានរៀបចំ។

[303] MoEYS, KAPE and World Education (2016). Progress Report 3 on New Generation School Initiative (Sisovath HS), April to June 2016.

ជាផ្នែកមួយនៃក្របខណ្ឌលទ្ធផល ដូចមានរៀបរាប់ក្នុងកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គម្រោងសាលារៀនជំនាន់ថ្មីនឹងធ្វើតេស្តឆ្នាំមូលដ្ឋាន ទៅលើជំនាញគិតត្រិះរិះដែលមានសមាសធាតុ៦។ តេស្តនេះត្រូវបានរៀបចំនិងសាកល្បងដោយអង្គការ KAPE ស្ថិតក្រោមគម្រោង Beacon School Initiative ដោយមានកម្រិតជឿជាក់ខ្ពស់ ប្រើប្រាស់វិធីសាស្រ្ត Cronbach's alpha។ តេស្តនេះគឺជាការវាយតម្លៃមិនគិតលើកម្រិតសិក្សា ដែលអាចត្រូវបានប្រើប្រាស់ជាមួយនឹងសិស្សនៅមធ្យមសិក្សា ជាពិសេសនៅកម្រិតដំបូង។

ក្រសួងអប់រំ យុវជន និងកីឡានិងអង្គការ KAPE សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការ រៀបចំគោលការណ៍ណែនាំស្តីពី សាលារៀនជំនាន់ថ្មី។ គោលការណ៍នេះពិពណ៌នាអំពី ក្របខណ្ឌទស្សនទានគ្រប់គ្រងសាលារៀនជំនាន់ថ្មី និងសំណុំនៃគោលការណ៍ណែនាំប្រតិបត្តិសម្រាប់អនុវត្តគម្រោងសាលារៀនជំនាន់ថ្មី និងឧបសម្ពន្ធមួយចំនួនព្រមទាំងទម្រង់ការណ៍មួយចំនួន សម្រាប់ជាជំនួយដល់អ្នកអប់រំថ្នាក់ជាតិ។

កម្មវិធីថ្មីពង្រីកការគាំទ្រដល់វិទ្យាល័យព្រះស៊ីសុវត្ថិ (បង្កើន៦ ថ្នាក់ បន្ថែមទៀត) ពង្រីកការគាំទ្រដល់សាលាអនុវត្តនិងវិទ្យាល័យស្គន់ ក្នុងខេត្តកំពង់ចាម និងសាលា២ទីតាំងទៀតដែលនឹងកំណត់នៅក្នុងត្រីមាសបន្តបន្ទាប់។ សំណើពង្រីកនេះនឹងធ្វើឱ្យគម្រោងសាលារៀនជំនាន់ថ្មីអាចគ្របដណ្តប់ដល់សាលារៀន៦ ក្នុងខេត្តចំនួន៤ ដូចជា រាជធានីភ្នំពេញ ខេត្តកំពង់ចាម ស្វាយរៀង និងខេត្ត១ទៀតមិនទាន់បានកំណត់។ អង្គការ KAPE ក៏នឹងអាចមានដៃគូអភិវឌ្ឍថ្មី ដែលយល់ព្រមសហការរួមមូលនិធិជាមួយ នឹងក្រសួងអប់រំ យុវជន និងកីឡា។ ស្ថិតក្រោមការពង្រីកវិសាលភាពនេះ សាលាជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិនឹងបង្កើនពី១២ ថ្នាក់ដល់១៨ ថ្នាក់ និងមានសិស្សប្រមាណ ៦០០ នាក់ ពីថ្នាក់ទី៧ ទី៨ ទី១០ និងទី១១។ ក្នុងឆ្នាំទី ៣ សាលាជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិនឹងសម្រេចបានវិសាលភាពពី ថ្នាក់ទី៧ ដល់ ទី១២។

## ១៤.១.៣ .សេចក្តីសន្និដ្ឋាន

ការសាកល្បងគម្រោងសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ អាចត្រូវបានប្រើប្រាស់ ដើម្បីធ្វើកំណែទម្រង់ទំនាក់ទំនងរវាងក្រសួង ជាមួយសាលារៀននិងគ្រូ ក្នុងប្រព័ន្ធអប់រំនៅកម្ពុជា ជាពិសេសការកំណត់ឡើងវិញនូវទំនាក់ទំនងនានានៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសនាយកសាលារៀននិងគ្រូបង្រៀន(ដែលជាភ្នាក់ងារ) ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ម៉ូដែលសាលារៀនជំនាន់ថ្មីអាចត្រូវបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រើប្រាស់សម្រាប់ការកែលម្អគណនេយ្យភាពនៅកម្រិតសាលារៀន។ នៅក្នុងរូបភាពនៃកំណែទម្រង់គណនេយ្យភាព យុទ្ធសាស្ត្រ៣ ត្រូវបានគេប្រើប្រាស់ទូលំទូលាយ ដើម្បីកែលម្អលទ្ធផលសិក្សាគឺ ៖ (១) ការគ្រប់គ្រងផ្អែកលើសាលារៀន (២) ព័ត៌មានស្ដីពីគណនេយ្យភាព និង (៣) ការលើកទឹកចិត្តគ្រូបង្រៀន[304]។ សមាសភាពទាំង៣ នៃគណនេយ្យភាពត្រូវបានផ្ដោតជាមូលដ្ឋានក្នុងម៉ូដែល សាលារៀនជំនាន់ថ្មី។

## ១៥.២. ការលើកកម្ពស់ការគ្រប់គ្រងសាលារៀននៅកម្ពុជា

ការគ្រប់គ្រងសាលារៀន ត្រូវបានកំណត់និយមន័យថា «ការផ្ទេរវិមជ្ឈការនៃសិទ្ធិអំណាចពីរដ្ឋាភិបាលទៅដល់កម្រិតសាលារៀន។ ការទទួលខុសត្រូវនិងសិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងដំណើរការសាលារៀន ត្រូវបានផ្ទេរទៅដល់ភ្នាក់ងារនៅមូលដ្ឋាន» [305]។ នៅក្នុងបរិបទនៃសាលារៀនជំនាន់ថ្មី ក្រសួងបានផ្ទេរការទទួលខុសត្រូវទៅឱ្យក្រុមប្រឹក្សាភិបាលនៃសាលារៀនជំនាន់ថ្មី (១) ។ កំណែទម្រង់នេះផ្ដោតលើការផ្សារភ្ជាប់ការផ្ដល់លាភការបន្ថែមជាមួយនឹងការបំពេញការងាររបស់គ្រូបង្រៀន(២)

### ១៥.២.១. តួនាទីថ្មីរបស់ក្រុមប្រឹក្សាភិបាលសាលារៀន ជាជម្រើសនៃស្វ័យភាព

ការស្រាវជ្រាវអន្តរជាតិបានបង្ហាញថា ប្រទេសណាដែលបានផ្ដល់សិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងគណនេយ្យភាពកាន់តែច្រើនដល់ថ្នាក់មូលដ្ឋាន ប្រទេសនោះសម្រេចបានលទ្ធផលនៃការសិក្សារបស់សិស្សក្នុងកម្រិតខ្ពស់ (Fuchs and Woessmann 2007; Woessmann 2003)។ កំណែទម្រង់អប់រំដែលកើតមាននៅប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍមួយចំនួន បានផ្ដោតលើការកែលម្អការគ្រប់គ្រងសាលារៀនតាមរយៈការបង្កើតក្រុមប្រឹក្សាភិបាលសម្រាប់ជាក្របខណ្ឌច្បាប់ សម្រាប់អនុវត្តកំណែទម្រង់ទាក់ទងនឹងការគ្រប់គ្រងផ្អែកលើសាលារៀន[306] ដូចជាកំណែទម្រង់ប្រព័ន្ធអប់រំរបស់ប្រទេសអូស្ត្រាលីនៅទសវត្សរ៍ទី ៩០ ច្បាប់កំណែទម្រង់អប់រំរបស់ប្រទេសអង់គ្លេស នៅឆ្នាំ ១៩៨៨ និង ការអប់រំនៅ El Salvador ដោយមានការចូលរួមពីសហគមន៍ ឬ EDUCO នៅឆ្នាំ ១៩៩១។

ក្នុងគម្រោងសាលារៀនជំនាន់ថ្មី ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវពិនិត្យមើលលើថវិកា និងការសម្រេចចិត្តសំខាន់ៗទាក់ទងនឹងការចូលរៀនរបស់សិស្ស ការជ្រើសរើសគ្រូ

[304] Bruns, B., Filmer, D. and Patrinos, H. (2011), Making Schools Work: New Evidence on Accountability Reform, World Bank, Washington, DC. p. 13.
[305] Bruns, B., Filmer, D. and Patrinos, H. (2011), *Op. Cit.*, p. 15.
[306] The 1967 Currie Report recommend the establishing of governing bodies for each school, consisting of teachers, parents, local community members, and students (see Bruns, B., Filmer, D. and Patrinos, H. (2011), *Op. cit.*, p. 17)


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បង្រៀន និងការគ្រប់គ្រងតាមបែបសាលារៀននៅក្នុងសាលារៀន។ ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល អាចត្រូវបានពង្រីកដោយផ្តោតលើការបំពេញការងាររបស់សាលារៀន រួមបញ្ចូលទាំងមុខងារ ដូចខាងក្រោម [307] ៖

- ពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន ដោយវាស់វែងតាមរយៈពិន្ទុតេស្ត ឬគ្រូបង្រៀន និងវត្តមានរបស់សិស្ស
- ជួយសាលារៀនក្នុងការអនុវត្តកម្មវិធីសិក្សា
- ធ្វើលទ្ធកម្មសៀវភៅសិក្សានិងសម្ភារសិក្សាដទៃទៀត
- កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងរៀបចំផែនការអភិវឌ្ឍសាលារៀន
- ពិនិត្យតាមដាននិងវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀននិងលទ្ធផលសិក្សារបស់សិស្ស
- បែងចែកធនធានថវិកា
- អនុម័តថវិកាប្រចាំឆ្នាំ និងពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ។

នៅក្នុងគំរូសាលារៀនជំនាន់ថ្មី មូលនិធិសមធម៌អប់រំអាចត្រូវបានបង្កើតឡើង ដើម្បីកៀរគរធនធានពីមាតាបិតា អ្នកពាក់ព័ន្ធសំខាន់ៗ និងសហគមន៍មូលដ្ឋាន និងប្រើប្រាស់ធនធានទាំងនេះ តាមរបៀបដែលមានប្រសិទ្ធភាពនិងតម្លាភាព ដើម្បីកែលម្អលទ្ធផលសិក្សា។ មាតាបិតានិងសហគមន៍មូលដ្ឋាន ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ឆ្ពោះទៅធានាសេវាអប់រំប្រកបដោយគុណភាពខ្ពស់។ ក្នុងន័យនេះ ក្រុមប្រឹក្សាភិបាលជាច្រកមួយ ដើម្បីបង្រួមប្រព័ន្ធគណនេយ្យភាព [308] ។ ការផ្តល់សេវាអប់រំ តាមរយៈគម្រោងសាលារៀនជំនាន់ថ្មីអាចត្រូវបានធ្វើកិច្ចសន្យាការងារជាមួយអង្គការមិនមែនរដ្ឋាភិបាល។

ក្រៅពីនេះ ព័ត៌មានគណនេយ្យភាពស្ថិតក្រោមគម្រោងសាលារៀនជំនាន់ថ្មី អាចនឹងនាំទៅរកការកែលម្អគុណភាពអប់រំ។ ការស្រាវជ្រាវបានស្នើថា ព័ត៌មានរាយការណ៍សាមញ្ញស្តីពីពិន្ទុតេស្ត នឹងនាំទៅដល់ការបង្កើនការបំពេញការងារ(Hoxby 2001, Hanushek and Raymond 2003)។ ក្នុងហេតុផលនេះ ព័ត៌មានស្តីពីការបំពេញការងាររបស់សាលារៀន

[307] Bruns, B., Filmer, D. and Patrinos, H. (2011), *Op. cit.*, pp. 15-16.
[308] The sequence of principal-agent problems forms a long route of accountability between users of services and front-line providers. In the first step, the clients (parents and students) hold the state accountable through the electoral process in order to ensure that policy makers deliver the service they demand. In a second step, the state holds providers (schools and teachers) accountable for their behaviors and their results through a compact or a managerial relationship. See Bruns, B., Filmer, D. and Patrinos, H. (2011), *Op. cit.*, p. 12.


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងធាតុចូល ដូចជាការងារថវិកាគួរតែបង្ហាញជាសាធារណៈ និងដល់គណៈកម្មការទ្រទ្រង់សាលារៀន និងក្រុមប្រឹក្សាភិបាល។

### ១៤.២.២. ការផ្តល់លាភការផ្អែកលើការបំពេញការងារ

គំរូសាលារៀនជំនាន់ថ្មី មានវត្ថុបំណងបង្កើនទំនាក់ទំនងរវាងការបំពេញការងាររបស់គ្រូបង្រៀន និងការផ្តល់ប្រាក់បៀវត្សបន្ថែម។ ក្រុមប្រឹក្សាភិបាលគួរមានលទ្ធភាពផ្តល់អនុសាសន៍សម្រាប់ការតម្លើងថ្នាក់ដល់គ្រូបង្រៀននិងគន្លងអាជីព ដែលនឹងត្រូវដាក់អនុវត្តនៅពេលអនាគតខាងមុខ ខណៈដែលក្រុមប្រឹក្សានេះក៏មានភារកិច្ចវាយតម្លៃគ្រូបង្រៀនផងដែរ។ ការផ្តល់លាភការផ្អែកលើការបំពេញការងារ គួរត្រូវបានអនុវត្តដោយភ្ជាប់ជាមួយនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន។

នៅក្នុងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន បានលើកឡើងអំពីការអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀន (ពី ១២+២ ទៅ ១២+៤ សម្រាប់គ្រូកម្រិតបឋមសិក្សានិងគ្រូកម្រិតអប់រំមូលដ្ឋាន និងពីបរិញ្ញាបត្រ+១ ទៅបរិញ្ញាបត្រជាន់ខ្ពស់សម្រាប់គ្រូកម្រិតឧត្តម)។ ទោះជាយ៉ាងណា ការស្រាវជ្រាវបង្ហាញថា ចំនួនឆ្នាំនៃការបណ្តុះបណ្តាលសញ្ញាបត្រផ្លូវការអតីតភាព និងប្រសិទ្ធភាពរបស់គ្រូបង្រៀននៅក្នុងថ្នាក់រៀន មិនមានទំនាក់ទំនងទៅនឹងសមត្ថភាពក្នុងការបង្រៀនសិស្ស ឱ្យសម្រេចបានលទ្ធផលសិក្សាល្អនោះទេ (Rivkin, Hanushek, and Kain 2005)។ ជាងនេះទៀត ការស្រាវជ្រាវបានលើកឡើងអំពីទំនាក់ទំនងរវាងការងារវិក្រឹតការ និងការបំពេញការងាររបស់គ្រូបង្រៀន។ ឆ្លើយតបនឹងចំណុចនេះ គម្រោងសាលារៀនជំនាន់ថ្មីនឹងផ្តោតលើការងារវិក្រឹតការ។ ជាងនេះទៀត ការគ្រប់គ្រងនិងការពិនិត្យតាមដាន អាចនាំទៅដល់ការកែលម្អគុណភាព។ ស្ថិតក្រោមគម្រោងសាលារៀនជំនាន់ថ្មី គ្រូបង្រៀននឹងចុះកិច្ចសន្យាការងារនិងការបំពេញការងារផ្សារភ្ជាប់នឹងការផ្តល់លាភការបន្ថែម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# បញ្ជីឈ្មោះតារាង និងរូបភាព


ទំព័រ

**តារាង ៖**

តារាងទី១ ៖ ចំនួនសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ....73
តារាងទី២ ៖ លទ្ធផលនៃការប្រឡងផ្សេងៗក្នុងឆ្នាំ១៩៦២-៦៣ ....74
តារាងទី៣ ៖ ការអភិវឌ្ឍវិស័យអប់រំនៅសម័យសង្គមរាស្ត្រនិយម ....74
តារាងទី៤ ៖ ការចូលរៀននៅបឋមសិក្សា ឆ្នាំ១៩៦៨/៦៩-១៩៨៨/៨៩....87
តារាងទី៥ ៖ ការចូលរៀននៅមធ្យមសិក្សាបឋមភូមិ ឆ្នាំ១៩៦៨/៦៩-១៩៨៨/៨៩ ....88
តារាងទី៦ ៖ ការចូលរៀននៅមធ្យមសិក្សាទុតិយភូមិ ឆ្នាំ១៩៦៨/៦៩-១៩៨៨/៨៩ ....89
តារាងទី៧ ៖ ចំនួនសាលារៀន ឆ្នាំ១៩៦៩-១៩៨៩ ....89
តារាងទី៨ ៖ បុគ្គលិកអប់រំ ឆ្នាំ១៩៦៩-១៩៨៩ ....90
តារាងទី៩ ៖ ចំណាយរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំ ឆ្នាំ២០០១-២០០៥ ....126
តារាងទី១០ ៖ គម្រោងចំណាយក្នុងវិស័យអប់រំ ឆ្នាំ២០០៣-២០០៥ ....127
តារាងទី១១ ៖ សូចនាករបំពេញការងារ និងចំណុចដៅ ឆ្នាំ២០០៣-២០០៥ ....127
តារាងទី១២ ៖ ចំនួនគ្រូបឋមសិក្សាមានកម្រិតនៃការអប់រំ និងទីកន្លែងបម្រើការងារ ....131
តារាងទី១៣ ៖ លទ្ធផលប្រឡងថ្នាក់ទី១២ ឆ្នាំសិក្សា ២០០០-២០០១ និង ២០០១-២០០២ ....132
តារាងទី១៤ ៖ ការបែងចែកថវិកាចរន្តសម្រាប់វិស័យអប់រំ ឆ្នាំ២០០០-២០០៦ គិតជាពាន់លានរៀល ....134
តារាងទី១៥ ៖ ថវិកាផ្តោតលើជនក្រីក្រក្នុងថវិកាចរន្តរបស់ក្រសួង ឆ្នាំ២០០២-២០០៦ ....138
តារាងទី១៦ ៖ ថវិកាសម្រាប់បង្កើនការចូលរៀនរបស់សិស្សស្រី និងសិស្សជនជាតិដើមភាគតិច ....139
តារាងទី១៧ ៖ សូចនាករសំខាន់ៗ ស្តីពីជនជាតិដើមភាគតិច ....140
តារាងទី១៨ ៖ សាលារៀនដាច់ស្រយាល និងមិនគ្រប់កម្រិត ឆ្នាំ២០០២ ....141
តារាងទី១៩ ៖ ចំនួនសាលារៀនតាមកម្រិតសិក្សា និងប្រភេទអ្នកផ្តល់សេវា ....221
តារាងទី២០ ៖ ចំនួនសិស្សតាមកម្រិតសិក្សា និងប្រភេទអ្នកផ្តល់សេវា ....222
តារាងទី២១ ៖ កម្មវិធីសិក្សាពហុភាសា ....233
តារាងទី២២ ៖ ចំនួនប្រជាជនកម្ពុជាសរុបតាមក្រុមអាយុ ឆ្នាំ១៩៥០-២០១០ ....246
តារាងទី២៣ ៖ តម្រូវការគ្រូបង្រៀន....268
តារាងទី២៤ ៖ ស្តង់ដាគុណវឌ្ឍិគ្រូបង្រៀន ....269
តារាងទី២៥ ៖ កម្រិតវប្បធម៌របស់គ្រូបង្រៀន ....270




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាងទី២៦ ៖ គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ........ 351
តារាងទី២៧ ៖ ការចុះឈ្មោះចូលរៀនរបស់សិស្ស........ 351
តារាងទី២៨ ៖ គ្រូបច្ចេកទេសដែលទទួលបានការបណ្តុះបណ្តាលដោយមូលនិធិគម្រោង ........ 352
តារាងទី២៩ ៖ ការចុះឈ្មោះចូលរៀនរបស់សិស្ស ........ 352
តារាងទី៣០ ៖ គ្រូអប់រំបច្ចេកទេស ........ 353
តារាងទី៣១ ៖ ការចុះឈ្មោះចូលរៀនរបស់សិស្ស........ 353
តារាងទី៣២ ៖ TVET និងការចុះឈ្មោះចូលរៀននៅកម្ពុជា ........ 356
តារាងទី៣៣ ៖ តម្រូវការជំនាញជាក់ស្តែង និងការរំពឹងទុក ........361
តារាងទី៣៤ ៖ ការពិពណ៌នាប្រភេទនៃបុគ្គលិកលក្ខណៈរបស់ហូឡែន ........413
តារាងទី៣៥ ៖ ការបែងចែកតាមវិស័យ និងក្រសួងអាទិភាព ........ 420
តារាងទី៣៦ ៖ ថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (គិតជាលានរៀល)........ 422
តារាងទី៣៧ ៖ ចំណាយតាមរដ្ឋបាលថ្នាក់កណ្តាល និងខេត្ត ........ 423
តារាងទី៣៨ ៖ និន្នាការថវិកាថ្នាក់កណ្តាល និងខេត្ត ឆ្នាំ២០០៩-២០១៥........ 423
តារាងទី៣៩ ៖ ការបែងចែកថវិកាតាមអនុវិស័យ ........ 424
តារាងទី៤០ ៖ និន្នាការនៃការវិភាជថវិការដ្ឋតាមអនុកម្មវិធីនិងអនុវិស័យ ........ 424
តារាងទី៤១ ៖ ផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០១៤-២០១៨ ឱកាសវិនិយោគតាមអាទិភាពនៃការអប់រំ ........ 425
តារាងទី៤២ ៖ និន្នាការនៃថវិកាកម្មវិធី ឆ្នាំ២០១១-២០១៥ ........ 426
តារាងទី៤៣ ៖ ការវិភាជថវិកាតាមកម្មវិធី........ 427
តារាងទី៤៤ ៖ ថវិកាអាហារូបករណ៍ និងទំហំ ឆ្នាំ២០១៥ ........ 428
តារាងទី៤៥ ៖ ទឹកប្រាក់ថេរផ្អែកលើចំនួនថ្នាក់រៀន ........ 430
តារាងទី៤៦ ៖ ចំនួនសិស្ស ........ 430
តារាងទី៤៧ ៖ ការវិភាជសម្រាប់សាលាបឋមសិក្សា ........ 430
តារាងទី៤៨ ៖ ថវិកាដំណើរការសាលា និងថវិកាដែលបានបញ្ចេញក្នុងឆ្នាំ២០១៥........431
តារាងទី៤៩ ៖ ហិរញ្ញប្បទានក្នុងវិស័យអប់រំដោយដៃគូអភិវឌ្ឍន៍ ........ 440
តារាងទី៥០ ៖ កម្មវិធីថវិកាគាំទ្ររបស់សហភាពអឺរ៉ុបក្នុងវិស័យអប់រំ ........ 453
តារាងទី៥១ ៖ ការគាំទ្ររបស់សហភាពអឺរ៉ុប ឆ្នាំ២០០៨-២០១០ ........ 454
តារាងទី៥២ ៖ ការគាំទ្ររបស់សហភាពអឺរ៉ុប ឆ្នាំ២០១៤-២០១៦........ 455
តារាងទី៥៣ ៖ ការគាំទ្ររបស់សហភាពអឺរ៉ុប ឆ្នាំ២០១៤-២០១៦ ........ 457



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទំព័រ

**រូបភាព ៖**


រូបភាពទី១ ៖ ចំនួនសិស្សចូលរៀននៅបឋមសិក្សា.......... 128
រូបភាពទី២ ៖ ចំណែកហិរញ្ញប្បទានរាជរដ្ឋាភិបាលសម្រាប់វិស័យអាទិភាព (២០០០-២០០៥) ..... 133
រូបភាពទី៣ ៖ អត្រារួមនិងអត្រាពិតនៃការសិក្សានៅបឋមសិក្សា.......... 137
រូបភាពទី៤ ៖ អត្រានៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ.......... 220
រូបភាពទី៥ ៖ អត្រានៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ .......... 225
រូបភាពទី៦ ៖ អត្រានៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ .......... 226
រូបភាពទី៧ ៖ សាជីនៃប្រជាជនកម្ពុជា ឆ្នាំ២០១២ .......... 245
រូបភាពទី៨ ៖ លំហូរកូនសិស្សក្នុងប្រព័ន្ធសាលារៀន .......... 252
រូបភាពទី៩ ៖ ប្រព័ន្ធអប់រំនៅកម្ពុជា.......... 345
រូបភាពទី១០ ៖ ចំនួននិស្សិតឧត្តមសិក្សា.......... 372
រូបភាពទី១១ ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សា ឆ្នាំ១៩៧៩-២០១០ .......... 373
រូបភាពទី១២ ៖ បញ្ហាដែលពាក់ព័ន្ធនឹងគុណភាពអប់រំ .......... 374
រូបភាពទី១៣ ៖ ថវិកាក្រសួងអប់រំ យុវជន និងកីឡា គិតជាពាន់លាន ពីឆ្នាំ១៩៩៤-២០១៤ .......... 419
រូបភាពទី១៤ ៖ ភាគរយនៃថវិកាថវន្តជាតិដែលបែងចែកទៅក្រសួងអប់រំ យុវជន និងកីឡា .......... 421





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឯកសារយោង

## I. ឈ្មោះសៀវភៅយោងជាភាសាខ្មែរ


**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** (២០១៦) «កម្រងច្បាប់ខ្មែរពីបុរាណ» (Codes anciens du Cambodge. Corpus de 1891) ក្រុមប្រឹក្សានីតិកម្ម ២០១៦។

**ក្រសួងអប់រំជាតិ** (១៩៧២) «ស្ថានភាពខេមរយានកម្មនៅមធ្យមសិក្សា ឆ្នាំ១៩៧២» វិទ្យាស្ថានជាតិខេមរយានកម្ម។

**ក្រសួងអប់រំ** (១៩៨៥) កំណត់ហេតុស្ដីពីសម័យប្រជុំអន្តរក្រសួងនៅវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៨៥។

**ក្រសួងអប់រំ យុវជន និងកីឡា** (២០១៥) «សមិទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៦ នៃតេស្តវាយតម្លៃថ្នាក់ជាតិ ឆ្នាំ២០១៣» របាយការណ៍ចុងក្រោយ៖ នាយកដ្ឋានធានាគុណភាពអប់រំ, EQAD, ខែធ្នូ ឆ្នាំ២០១៥។

**ក្រសួងអប់រំ យុវជន និងកីឡា** (២០១៥) «ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ» ភ្នំពេញ។

**ឃីង ហុកឌី** (២០០៣) «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ។

**ឃីង ហុកឌី** (២០០៣) «មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី១៩»។

**ឃីង ហុកឌី** (ប្រមូលផ្តុំអត្ថបទដោយ) (២០០៦) «សម្ងួហាកម្មអក្សរសាស្ត្រខ្មែរ (Mélanges littéraires offerts au Professeur KENG Vannsak)» បណ្ណាគារអង្គរ ភ្នំពេញ។

**ឃីង ហុកឌី** (២០០៧) «អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០៖ កវីនិពន្ធ និងកម្រងអត្ថបទ» (Litérature cambodgienne du XXème siècle: Écrivains et textes) សក្ខាសាលាស្ដីអំពី «អក្សរសិល្ប៍ខ្មែរទំនើប» ឆ្នាំ២០០៥ រៀបចំដោយសម្ងួហាកម្មអក្សរសិល្ប៍ នូ ហាច បណ្ណាគារអង្គរ ។

**ឃីង ហុកឌី** និង **ថោង ឆៃល** (២០១០) «កម្រងសិក្សាកថាវប្បធម៌ខ្មែរ ៖ ឧទ្ទិសប្រគេនព្រះមហាវិរិយបណ្ឌិតតោ ប៉ាង ខាត់ (១៩១០-១៩៧៥)» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ភ្នំពេញ។

បណ្ឌិតសភាចារ្យ **ឃីង ហុកឌី** (២០១៦) «លោកគ្រូធំ កេង វ៉ាន់សាក់» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ភ្នំពេញ។

**ត្រឹង ងា** (**១៩៧៤**) «ប្រវត្តិសាស្ត្រខ្មែរ» ភាគ១ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។

**ឆាយ ច័ន្ទនីដា** (២០១៥) «នរណាជានរណា» ក្នុងបុព្វហេតុកំណែទម្រង់ប្រព័ន្ធអប់រំលោក ហង់ជួន ណារ៉ុន ទទួលទានដំណេក ៣ ម៉ោងក្នុងមួយយប់ Khmer Post. Sat, 17 January 2015។

**ប៊ែរណារ ហ្វីលីប គ្រោស្លីយេ** (២០០៣) «ទីក្រុងអង្គរ ជំហរអារ្យធម៌ខ្មែរ» មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ភ្នំពេញ។

**ពន់ ឆាយ** (២០១៥) «ប្រវត្តិសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១៩៦០-២០១៥» ការផ្សាយចេញពី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ព្រះភគ្គុ ប៉ាង ខាត់** (១៩៦០) «ពុទ្ធសាសនា ២៥០០» ភ្នំពេញ។

**ម៉ុញ្ញ សារី** (២០១១) «វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ (Encyclopedia of Khmer Literature)» មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិតសភាកម្ពុជា ទំព័រ ៥៣៨។

**មីសែល ត្រាណេ** (២០០៤) «វប្បធម៌ អារ្យធម៌ខ្មែរ ៖ អំពីសាសនាខ្មែរតាំងពីសម័យបុរេប្រវត្តិសាស្ត្រ (សង្ខេប)» ភ្នំពេញ។

**មីសែល ត្រាណេ** (២០១៣) «មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ» គ្រឹះស្ថានបោះពុម្ពខ្មែរ ភ្នំពេញ ទំព័រ ៤១២-៤១៣។

J. Madison Seymour, Final Report: Cambodia EGRA (ការវាយតម្លៃអំណានកម្រិតដំបូង) លទ្ធផលតេស្តឆ្នាំ២០១០ និង២០១២ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២។

**លី ធាមតេង** (១៩៦០) «អក្សរសាស្ត្រខ្មែរ» ។

**លី សុធីរ** (២០០៨) «ដំណើរប្រវត្តិស្ដីពីសាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និង ក្រុមជំនុំ៣»។

**លាង ហាប់អាន** (១៩៦៥) «អ្នកនិពន្ធខ្មែរព្រះបាទអង្គឌួង ៖ ព្រះជីវប្រវត្តិ-ស្នាព្រះហស្ត» បណ្ណាគារ អ៊ឹង ហ៊ុន Reproduced by Editions Angkor។

**លាង ហាប់អាន** (១៩៦៧) «សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ៖ សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សរ៍ទី១ ដល់ ១៨៥៩)» ទំព័រ ២១២-២១៣។

**សម្ដេចព្រះមហាសុមេធាធិបតី ហួត តាត** (១៩៧០) «កល្យាណមិត្តរបស់ខ្ញុំ គឺ សម្ដេចព្រះសង្ឃរាជ ជួន ណាត(ជោតញ្ញាណោ)»។

**ស៊ន សំណាង** (១៩៩៩) «ទិដ្ឋភាពទូទៅនៃការបណ្ដុះបណ្ដាលធនធានមនុស្ស នៅប្រទេសកម្ពុជា ពីដើមសតវត្សរ៍ទី២០ដល់ឆ្នាំ១៩៧៥» នៅក្នុងកម្រងឯកសារនៃសន្និសីទជាតិស្ដីពីការបណ្ដុះបណ្ដាលធនធានមនុស្សនៅកម្ពុជា ៖ គុណភាព និងចក្ខុវិស័យ» ដោយរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី ២៣-២៤ ខែធ្នូ ឆ្នាំ១៩៩៩ ទំព័រ ១-២៤។

**ស៊ិន សុវណ្ណនិ** (២០១២) «ឯកសារស្រាវជ្រាវក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដកនៃប្រទេសកម្ពុជា» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។

**ហម ឆាយលី** (២០១០) «ប្រជុំអត្ថបទសម្រាំង (អត្ថបទប្រវត្តិសាស្ត្រ)» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ទំព័រ ៩។

**អ្នកស្រី ត្រឹង ងា** (១៩៧៥) «អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់ (កម្មវិធីថ្មី)»។

**អ៊ិត សារិន** (១៩៧៣) «ស្រណោះព្រលឹងខ្មែរ»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## II. ឈ្មោះសៀវភៅយោងជាភាសាបរទេស


Ab Latif, A. A., Kurniawan, Y., & Chan, H. (2012). The Gap between business management curriculum and employability requirements: a study among Banks and Micro-Finance Institutions (MFIs) in Battambang, Cambodia. *Proceedings of the 3rd International Conference on Technology and Operations Management "Sustainable Competitiveness through Green Technology Management"*. Bandung, Indonesia, July 406, 2012. (pp.431-445)

Abadzi, H. (2006). *Efficient Learning for the Poor: Insights from the Frontier of Cognitive Neuroscience* (Directions in Development). Washington D.C : World Bank.

Abadzi, H. (2008). Efficient Learning for the Poor: New Insights into Literacy Acquisition for Children. *International Review of Education, 54*(5-6), 581-604.

Abdul-Hamid, H., Abu-Lebdeh, K.M., & Patrinos, H.A. (2011). Assessment testing can be used to inform policy decisions: the case of Jordan. *World Bank Policy Research Working Paper Series 5890*.

Aghlon, P., Dewatripont, M., Hoxby, C., Mas-Colell, A, & Sapir, A. (2010). The governance and performance of universities: evidence from Europe and the US, *Economic Policy, 25*(61), 7-59.

Alderman, H. (2011). *No Small Matter: The Impact of Poverty, Shocks, and Human Capital Investments in Early Childhood Development.* Washington D.C.: World Bank.

Barber, M., & Mourshed, M. (2007). *How the World's Best Performing School Systems Come Out on Top*. Retrieved from http://mckinseyonsociety.com/how-the-worlds-best-performing-schools-come-out-on-top/

Barom, N. (2009). *Privatization of Higher Education in Cambodia.* Paper presented at the International Seminar on Skills Development for the Emerging New Dynamism in Asian Developing Countries under Globalization, Bangkok, 23-25 January 2009.

Bilodeau, C., Pathammavong, S., & Hong, L.Q. (1955). *Compulsory Education in Cambodia, Laos and Viet-Nam*. Paris: UNESCO




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Booth, M. (2014). Education and Gender in Contemporary Cambodia. *International Journal of Humanities and Social Sciences, 4*(10).

Brehm, W.C. & Silova, I. (2014). Hidden Privatization of Public Education in Cambodia: Equity Implications of Private Tutoring. *Journal for Educational Research Online,* 6 (1), 94-116.

Bruni, M. (n.d). *Demographic trends, education and the labor market in Cambodia,* Phnom Penh: MLVT.

Bruni, M., Luch, L., & Kouch, S. (2013). *Skills Shortages and Skill Gaps in Cambodian Labor Market: Evidence from Employer Skills Needs Survey*. Phnom Penh: National Employment Agency

Bruns, B., Filmer, D. & Patrinos, H. A. (2011). *Making Schools Work: New Evidence on Accountability Reforms.* Washington DC: World Bank.

Burkhardt, J. A. (2009). Rebuilding the Education System in Cambodia: One Teacher Training at a Time. *Journal of McMaster School for Advancing Humanity, 4, 84-88*

Chan, H. & Ab Latif, A.A. (2013). Historical Perspectives of Business Education at the Higher Learning Institutions and Skills Development for Industry in Cambodia. *International Journal of Learning & Development.* 3(1), 148-163.

Cheng, I-Hsuan (2010). Case Studies of Integrated Pedagogy in Vocational Education: A Three-Tier Approach to Empowering Vulnerable Youth in Urban Cambodia. *International Journal of Educational Development,* 30 (4), 438-446.

Cheng, Kai-Ming (2010). Shanghai and Hong Kong: Two Distinct Examples of Education Reform in China. In OECD (Ed.), *Strong performers and successful reformers in education: Lessons from PISA for the United States,( pp. 83-115).* Paris: OECD.

Chap, C., The, I., & Thomas, A.(2003). *Bilingual education in Cambodia.* Retrieved from http://www-01.sil.org/asia/ldc/parallel_papers/ he_chey_chap.pdf

Chin, Y. (2003). Cambodian National Curriculum and Human Rights Education. Retrieved from www.hurights.or.jp/.../cambodian-national-curriculum-and-human-rights-education.html

Clarke, G. (2010). Education MTEF: Approaches, Experience and Lessons from Nine Countries in Asia. *Asia-Pacific Education System Review Series, 3*. Bangkok: UNESCO.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Clayton, T. (1995). Restriction or Resistance? French colonial education development in Cambodia. *Education policy analysis archives, 3* (19), 1-10.

Clayton, T., & Ngoy, Y. (1997). *Asian Higher Education: An International Handbook and Reference Guide*. Santa Barbara, CA : Greenwood Press.

Clayton, T. (2000). *Education and the Politics of Language. Hegemony and Pragmatism in Cambodia, 1979-1989*. Hong Kong: Comparative Education Research Center.

Constitutional Council. (2010). *Constitution of the Kingdom of Cambodia*. Phnom Penh.

Craig, H. J., Kraft, R. J. & Plessis, J. D. (1998). *Teacher Development: Making an Impact*. Washington, DC: Agency for International Development and World Bank.

Dagens, B. (2005). *Les Khmers*. Paris: Les belles lettres.

Damico. S. (2010). *Higher Education and Skills for the Labor Market in Cambodia.* Retrieved from siteresources.worldbank.org /.../ Resources / Cambodia HE and Skills for Labor Market.pdf

Darling-Hammond, L., & Berry, B. (2006). Highly Qualified Teachers for All. *Educational Leadership*, *64* (3), 14–20.

Darling-Hammond, L. & Lieberman, A. (2012). *Teacher Education around the World: Changing Policies and practice*. New York: Routledge.

David, C. (1996). *Facing the Cambodian Past*. Chiang Mai: Silkworm Books.

Dewey, J. (1938). *Experience and Education*. New York: Macmillan.

Dulieu, R. H. (1969). Cambodge: *L'enseignement primaire*. Paris: UNESCO.

Economic Institute of Cambodia. (2008), *Cambodia's Labor Market and Employment*, Phnom Penh.

Fillippi, Jean-Michel. (2011, June 17). Cambodia's turbulent educational history, The *Phnom Penh Post*, Retrieved from http://www.phnompenhpost.com/post-plus/cambodias-turbulent-educational-history.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Fullan, M. (2010). *All Systems Go: The Change Imperative for Whole System Reform*. Thousand Oaks, CA: Corwin. Gary Thomas (2013). *Education: A Very Short Introduction*. Oxford: Oxford University Press.

Gertler, P., Patrinos, H., & Rubio-Codina, M. (2012). Empowering parents to improve education: Evidence from rural Mexico. *Journal of Development Economics,* 99(1), 68-79.

Garmier, E. & Renou. G. (2002). L'éducation de base au Cambodge: un système en reconstruction. *Revue international d'éducation de Sèvres, 31,129-138*.

Greaney, V. & Kellaghan, T. (2008). *Assessing National Achievement Levels in Education*. Washington D.C: World Bank.

Greeno, J. G., Collins, A. M. & Resnick, L. B. (1996). Cognition and Learning. In D. Berliner and R. Calfee, (Ed.), *Handbook of Educational Psychology*, (pp.15–41). New York: Macmillan.

Hansen, A. R. (2004). Khmer Identity and Theravada Buddhism, in J. Marston and E. Guthrie (Eds*.), History, Buddhism, and New Religious Movements in Cambodia*, (pp.40-62), Honolulu: University of Hawai`i Press.

Hansen, A. R. (2011). *How to Behave: Buddhism and Modernity in Colonial Cambodia, 1860-1930*. Honolulu: University of Hawai`i Press.

Hanushek, E.A. (1971). Teacher Characteristics and Gains in Student Achievement: Estimation Using Micro Data. *American Economic Review, 60*, 280-288.

Hanushek, E.A. (1986). The Economics of Schooling: Production and Efficiency in Public Schools. *Journal of Economic Literature,* 24, 1141-1177.

Hanushek, E.A. (1996). A More Complete Picture of School Resource Policies. *Review of Educational Research,* 66, 397-409.

Hanushek, E.A. & Rivkin, S.G. (2003). How to Improve the Supply of High Quality Teachers. Paper presented at the Brookings Papers on Education Policy, Brooking, 21-23 May 2003.

Hanushek, E.A. & Woessmann, L. (2007a). The Role of School Improvement in Economic Development. *NBER Working paper No.12832.*Retrieved from http://www.nber.org/papers/w12832.

Hanushek, E.A. & Woessmann. L. (2007b). The Role of Education Quality in Economic Growth. *World Bank Policy Research Working Paper 4122*.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Hanushek, E.A. & Woessmann. L. (2008). The Role of Cognitive Skills in Economic Development. *Journal of Economic Literature,* 46(3), 607-668.

Hanushek, E.A. (2009). School Policy: Implications of Recent Research for Human Capital Investments in South Asia and Other Developing Countries. *Educational Economics,* 17(3), 291-313.

Hanushek, E.A. & Rivkin, S.G. (2010). Constrained Job Matching: Does Teacher Job Search Harm Disadvantaged Urban Schools? *Working Paper 15816*. National Bureau of Economic Research.

Harris, I. (2008). Cambodian Buddhism: History and Practice, Honolulu: University of Hawai`i Press.

Hayden, M, & Martin, R. (2011). The Education System in Cambodia: Making Progress under Difficult Circumstances, in C Brock & LP Symaco (Eds.*), Education in South-East Asia*, (pp.31-52) Oxford: Symposium Books.

Heckman, J.J., Stixrud, J. & Urzua, S. (2006). The Effects of Cognitive and Noncognitive Abilities on Labor Market Outcomes and Social Behavior*. Working Paper 12006*. *National Bureau of Economic Research.*

Hill, P. (2010). *Examination Systems.* Asia-Pacific Secondary Education System Review Series. UNESCO Bangkok: Asia and Pacific Regional Bureau for Education.

Ho, Esther Sui-chui. (2013). *Student Learning Assessment.* Asia-Pacific Education System Review Series No. 5. UNESCO Bangkok: Asia and Pacific Regional Bureau for Education.

Igawa, K. (2008). English Language and Its Education in Cambodia, a Country in Transition. *Shitennoji University Bulletin, 46*, 343-369

International Labor Office. (2007), *ILO Policy Brief on youth employment in Cambodia*, Retrieved from http://www.ilo.org/public/english/region/asro/bangkok/library/download/pub07-08.pdf

International Labor Office. (2010). *Labor and Social Trends in Cambodia 2010*, National Institute of Statistics.

Japan International Cooperation Agency. (2012), *The preparatory study for Human Resource Development for Industry in the Kingdom of Cambodia*. JICA

Jeong, Hyeok (2013). *Skill Need Assessment of Cambodian Labor Market*, forthcoming.




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Leclère, Adhémard (1914). *Histoire du Ca*mbodge. Paris: Librairie Paul Geuthner.

Lewin, K.M. & Caillods, F. (2001). *Financing Secondary Education in Developing Countries: Strategies for Susstainble Growth*, Paris: International Institute for Educational Planning.

Marston, J., & Guthrie, E. (2004). *History, Buddhism, New Religious Movements in Cambodia*, Honolulu: University of Hawai`i Press.

Ministry of Education, Youth and Sport (2000). *Education For All (EFA): the Year 2000 Assessment. Country Report by the National EFA 2000 Assessment Group*. Phnom Penh.

Ministry of Education, Youth and Sport. (2001). *Policy on Education for All 2001-2005*. Phnom Penh.

Ministry of Education, Youth and Sport. (2001). *Core Curriculum for Basic Education in Cambodia*. Phnom Penh.

Ministry of Education, Youth and Sport. (2003). *National EFA Plan.* Phnom Penh.

Ministry of Education, Youth and Sport. (2004). *Policy for Curriculum Development, 2005-2009*. Phnom Penh.

Ministry of Education, Youth and Sport. (2006). *Policy for Life Skills Education*. Phnom Penh.

Ministry of Education, Youth, and Sport. (2007). Law on Education. Phnom Penh.

Ministry of Education, Youth and Sport. (2007). *Policy on Child Friendly School*. Phnom Penh.

Ministry of Education, Youth and Sport. (2007). *Education Law*. Phnom Penh.

Ministry of Education, Youth and Sport. (2008). *Policy on Education Health*. Phnom Penh.

Ministry of Education, Youth and Sport. (2008). *Policy on Education for Children with Disabilities*. Phnom Penh.

Ministry of Education, Youth and Sport. (2008). *Policy on Non-Formal Education Equivalency Programme*. Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Ministry of Education, Youth and Sport. (2008). *Policy on Secondary School Resource Centers*. Phnom Penh.

Ministry of Education, Youth and Sport. (2009). *Policy on School Health*. Phnom Penh.

Ministry of Education, Youth and Sport. (2010). *Master Plan for Information and Communication Technology in Education.* Phnom Penh.

Ministry of Education, Youth and Sport. (2010). *Policy on Cluster School Development*. Phnom Penh.

Ministry of Education, Youth and Sport. (2010). *National Policy on Early Childhood Care and Development.* Phnom Penh.

Ministry of Education, Youth and Sport. (2010). *Policy on Research Development in the Education Sector.* Phnom Penh.

Ministry of Education, Youth and Sport. (2011*). Master Plan for Research Development in the Education Sector, 2011-2015.* Phnom Penh.

Ministry of Education, Youth and Sport. (2011). *Teacher Professional Standards.* Phnom Penh.

Ministry of Education, Youth and Sport (2011). *Competency Standards for Directors of Teacher Training Centers.* Phnom Penh.

Ministry of Education, Youth and Sport. (2011). *National Policy on Cambodia Youth Development*. Phnom Penh.

Ministry of Education, Youth and Sport. (2012). *Master Plan for Capacity Development in the Education Sector, 2011-2015.* Phnom Penh.

Ministry of Education, Youth and Sport. (2012). *Action Plan for Research Development in the Education Sector, 2011-2015.* Phnom Penh.

Ministry of Education, Youth and Sport. (2012). *Policy on Child Friendly School for Basic Education*. Phnom Penh.

Ministry of Education, Youth and Sport. (2012). *Education Books Policy*. Phnom Penh.

Ministry of Education, Youth and Sport. (2012). *Policy on Human Resources in Education Sector.* Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Ministry of Education, Youth and Sport. (2012). *Details of Higher Education Institutions*. Phnom Penh: Higher Education Department.

Ministry of Education, Youth and Sport. (2013). *Teacher Policy*. Phnom Penh.

Ministry of Education, Youth and Sport. (2013). *Country Literacy Acceleration Plan (CLAP) 2013-2015*. Phnom Penh.

Ministry of Education, Youth and Sport. (2013). *Policy on Technical Education*. Phnom Penh.

Ministry of Education, Youth and Sport. (2013). *Equivalency Curriculum Program for Non Formal Lower Secondary Education*. Phnom Penh.

Ministry of Education, Youth and Sport. (2013). *Technical Orientation Education for Lower Secondary Education.* Phnom Penh.

Ministry of Education, Youth and Sport. (2013). *The Country Literacy Acceleration Plan (2013-215).* Phnom Penh.

Ministry of Education, Youth and Sport. (2014). *Policy on Higher Education Vision 2030.* Phnom Penh.

Ministry of Education, Youth and Sport. (2014). *Education Strategic Plan, 2014-2018.* Phnom Penh.

Ministry of Education, Youth and Sport. (2014). *Manual for Management of Community Learning Center (CLC).* Phnom Penh.

Ministry of Education, Youth and Sport. (2014). *Report on Non-Formal Education in 2012-2013 and Action Plan for 2013-2014.* Phnom Penh.

Ministry of Education, Youth and Sport. (2015). *Teacher Policy Action Plan*. Phnom Penh.

Ministry of Education, Youth and Sport. (2015). *Report on Multi-lingual education*. January 2015. Phnom Penh.

Ministry of Education, Youth and Sport. (2015). *Multilingual Education National Action Plan (MENAP), 2015-2018*. Phnom Penh.

Mourshed, M., Chijioke, C., & Barber, M. (2011). How the worlds most improved school systems keep getting better. *Educational Studies, 2*, 5-122.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Mullis, I. V., Martin, M. O., Foy, P., & Arora, A. (2012). *TIMSS 2011 International Results in Mathematics*, TIMSS & PIRLS International Study Center, Lynch School of Education, Boston College, Chestnut Hill.

Sovanroth, N. (2015). Information, Communication and Technology and Higher Education in Cambodia. *Asia-Pacific International University Press.*

NIS & ILO. (2010). *Labour and social trends in Cambodia 2010.* Cambodia: National Institute of Statistics.

Hanushek, E. A., & Woessmann, L. (2010). *The High Cost of Low Educational Performance: The Long-Run Economic Impact of Improving PISA Outcomes.* Paris: OECD Publishing.

Schleicher, A. (2012). Building a High-Quality Teaching Profession. Lessons from around the world*. Educational Studies, 1,* 74-92.

Patrinos, H. A., Velez, E., & Wang, C. Y. (2013). Framework for the Reform of Education Systems and Planning for Quality. *Policy Research Working Paper 6701.* Washington D.C.: World Bank.

Ton, P.,& Kim Hourn, T. (1971). *L'Enseignement Superieur et le Developpement*. Rapport final du Colloque National tenu a Phnom Penh du 27 au 31 decembre 1971.

Psacharopoulos, G. & Patrinos. H. A. (2004). Returns to investment in education: a further update*, Education Economics, 12*(2): 111-34.

Phirom, L. (2010). *Students' Perceptions toward Private Sector Higher Education in Cambodia*. Doctoral Dissertation, Ohio University.

Pina, P., Kotin, T., Hausman, V., & Macharia, E. (2012). *Skills for employability: the informal economy*. Retrieved from http://r4d. org/sites/resultsfordevelopment. Org / files / resources / Skills% 20for% 20Employability% 20in% 20the% 20Informal, 20.

Richardson, J. W. (2008). ICT in education reform in Cambodia: problems, politics, and policies impacting implementation. *Information Technologies & International Development, 4*(4), 67.

Rice, J. K. (2003). *Teacher Quality: Understanding the Effectiveness of Teacher Attributes*. Washington, DC: Economic Policy Institute.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Rivkin, S.G., Hanushek, E.A., & Kain, J.F. (2005). *Teachers, Schools and Academic Achievement*. *Econometrica,* 73(2), 417-458.

Robin, A. (2000). *Culture and Pedagogy*. Malden, MA: Blackwell Publishing.

Royal Government of Cambodia. (2002). *National Policy on Non-Formal Education*. Phnom Penh.

Royal Government of Cambodia. (2004). *Policy on Curriculum Development for Secondary Education, 2005-2009.* Phnom Penh.

Royal Government of Cambodia. (2008). *Sub-decree on Code of Professional Ethic of Teachers*. Phnom Penh.

Royal Government of Cambodia. (2010). *National Policy on Early Childhood Care and Development.* Phnom Penh.

Royal Government of Cambodia. (2013). *Cambodia's National Science and Technology Master Plan (2014-2020).* Phnom Penh.

Rany, S., Zain, A. N. M., & Jamil, H. (2012). Cambodia's higher education development in historical perspectives (1863-2012). *International Journal of Learning and Development, 2*(2), 224-241.

Schleicher, A. (2011). *Building a High-Quality Teaching Profession: Lessons from Around the World*. Paris: Organisation for Economic Co-operation and Development.

Sideth, S. D. (2004). Strategies and Policies for Basic Education in Cambodia: Historical Perspectives. *International Education Journal,* 5(1), 90-97.

Shoraku, A. (2008). Educational Movement toward School-based Management in East Asia: Cambodia, Indonesia and Thailand. Paper commissioned for the EFA Global Monitoring Report 2009.

Sloper, D. W. (Ed.). (1999*). Higher education in Cambodia: The social and educational context for reconstruction.* UNESCO Principal Regional Office for Asia and the Pacific.

Smith, A. (2010). *The Influence of Education on Conflict and Peace Building*. Paper commissioned for the EFA Global Monitoring Report 2011, The Hidden Crisis: Armed Conflict and Education. UNESCO.

SNEC. (2011). Diversifying the Cambodian Economy: the role of industrial development. Working paper.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

SNEC. (2011). Cambodia's Garments sector: Impacts of crisis and its rebound. Working Paper.

Stewart, V. (2011). Singapore: a journey to the top, step by step', in M. Tucker (ed.) *Surpassing Shanghai: An Agenda for American Education Built on the World's Leading Systems*, (pp.113-139). Cambridge: Harvard Education Press.

Stewart, V. (2012). *A World-class Education: Learning from International Models of Excellence and Innovation*, ACSD, Alexandria.

Thomas, G. (2013). *Education: A Very Short Introduction*. Oxford: Oxford University Press.

Toan, T. (2009). *Histoire des Khmers. L'Odyssee du peuple cambodgien*. Paris: L'Harmattan.

Toan, T. (2012). *Les Khmers à l'ère de l'hindouisme (50-1336 apr. J.-C.). Les secrets d'Angkor*. Paris: L'Harmattan.

Tunon, M., & Rim, K. (2013). *Cross-border labour migration in Cambodia: Considerations for the national employment policy*. ILO.

Tucker, M.S. (ed.). (2011). *Surpassing Shanghai: An Agenda for American Education Built on the World's Leading Systems*, Cambridge, MA: Harvard Education Press.

Tooley, J. & P. Dixon. (2005). *Private Education Is Good for the Poor: A Study of Private Schoo1s Serving the Poor in Low-income Countries*, Washington DC: Cato Institute.

Leang, U. (nd.). *Upper Secondary School Curriculum Reform in Cambodia: Relevance for Employment and Tertiary Education*. Retrieved from http://www.academia.edu/6180031/Upper_Secondary_School_Curriculum_Reform_in_Cambodia_Relevance_for_Employment_and_Tertiary_Education_Table_of_Contents. UNESCO. *Meeting Basic Learning Needs*. Paris.

United Nations Development Programme. (2011), *Human Capital Implications of Future Economic Growth in Cambodia: Elements of a Suggested Roadmap*, Discussion Paper.

United Nations Development Programme. (2014), *Curbing Private Tutoring and Informal Fees in Cambodia's Basic Education*, Background Paper for Cambodia Human Development Report 2015.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Watts, K. (1989). *Report of the Kampuchea Needs Assessment Study*, UNDP.

Wayne, A. J., & Youngs, P. (2003). Teacher characteristics and student achievement gains: A review. *Review of Educational research, 73*(1), 89-122.

World Bank. (2003). *World Development Report 2004: Making services work for poor people.* Washington DC: World Bank.

World Bank. (2005). *Cambodia: Balancing the Books. Household Financing of Basic Education.* Working Paper Series No. 2005-2. Washington DC: World Bank.

World Bank. (2008). *What is School-based Reform?* Washington DC: World Bank.

World Bank. (2009). *Rapid Assessment Study in Pre-service Training of Teachers*. Background paper, Jakarta:World Bank.

World Bank. (2010). *Stepping up Skills: For more jobs and higher productivity.* Washington DC: World Bank.

World Bank. (2011a). *Learning for All: Investing in People's Knowledge and Skills to Promote Development* (World Bank Group Education Strategy 2020). Washington D.C.: World Bank.

World Bank. (2011b). *Cambodia: Teacher Policies.* SABER Country Report. Washington DC: World Bank.

World Bank (2012a). *Matching Aspirations: Skills for Implementing Cambodia's Growth Strategy*, Washington DC: World Bank.

World Bank (2012b), *Putting Higher Education to Work: Skills and Research for Growth in East Asia*, Washington DC: World Bank.

United Nations Educational, Scientific and Cultural Organization. (2013). *Policy review of TVET in Cambodia.* Phnom Penh.

United Nations Educational, Scientific and Cultural Organization. (2013). *Water, Sanitation and Hygiene in Primary Schools in South-East Asian Countries: Realities, Needs and Recommendations*. East Asia and Pacific Regional Office.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# បណ្ឌិត ហង់ជួន ណារ៉ុន



បណ្ឌិត **ហង់ជួន ណារ៉ុន** បច្ចុប្បន្នជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) និង ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងនីតិកាលទី៥នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់(១៩៨៨) និងបណ្ឌិត(១៩៩១) ផ្នែកសេដ្ឋកិច្ចអន្តរជាតិពី **វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិក្រុងម៉ូស្គូ** ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី **វិទ្យាស្ថានធានារ៉ាប់រង**(CII) ប្រទេសអង់គ្លេស និង **វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី** (MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រអន្តរជាតិពី **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** នៃប្រទេសកម្ពុជា និង **សាកលវិទ្យាល័យ** Lyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែក **នីតិសមុទ្រ** ពី **បណ្ឌិត្យសភា** Rhodes **ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ**។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត ជាអ្នកស្រាវជ្រាវក្នុងវិទ្យាស្ថានស្រាវជ្រាវធំៗជាច្រើន និងជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩ មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយ រួមមាន គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (World Bank)។

នៅឆ្នាំ២០០៤ ដល់ ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូកបី ពីឆ្នាំ២០០០ ដល់២០១០ និងធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ានឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

នៅក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ដែលជាស្ថាប័នខួរក្បាលខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសីទអន្តរជាតិដូចជា មហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ពន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីប៉ូវ៉ា និងវេទិការអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាលជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ក្រោមចំណងជើងថា «Cambodian Economy: Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្នាដៃរបស់អ្នកនិពន្ធ

**1-Hang Chuon Naron**—*L'Économie du Cambodge: La lute pour le développement*, Phnom Penh, 2005.

**2-Hang Chuon Naron**—*Essais économiques*, Phnom Penh, 2007.

**3-Hang Chuon Naron et Patrick Gilbert-Desvallons**—*Les finances publiques du Cambodge*, Phnom Penh, 2007.

**4-Hang Chuon Naron**—*Cambodia: Recent Macroeconomic and Financial Sector Development*, Phnom Penh, 2008.

**5-Hang Chuon Naron**—*Three Essays on Macroeconomic Management of Cambodia*, Phnom Penh, 2008.

**6-Hang Chuon Naron**—*Introduction to Insurance*, Phnom Penh, 2008.

**7-ហង់ជួន ណារ៉ុន-ម៉ាក្រូសេដ្ឋកិច្ច** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ ២០០៩។

**8-Hang Chuon Naron and Patrick Gilbert-Desvallons**—*Public Finance in Cambodia*, Phnom Penh: Preah Vihear Editions, 2009.

**9-ហង់ជួន ណារ៉ុន** និង **ហ្សីលប៊ែ ដឺវ៉ាល់ឡុង- ហិរញ្ញវត្ថុសាធារណៈ** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ ២០០៩។

**10-ហង់ជួន ណារ៉ុន-ប្រាសាទព្រះវិហារ** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ ២០០៩។

**11-Hang Chuon Naron**—***Cambodian Economy:*** *Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects*, Phnom Penh: Preah Vihear Editions, 2009.

**12-Hang Chuon Naron**—***L'économie du Cambodge:*** *Nouvelles frontières du développement socio-économique*, Phnom Penh: Preah Vihear Editions, 2010.

**13-Hang Chuon Naron**—***Regards sur le différend maritime khméro-thaïlandais*** *à la lumière de la jurisprudence internationale*, Phnom Penh: Preah Vihear Editions, 2012.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

9 789924 911418